# ព្រះត្រៃបិដក

## ប្រែរួមនឹងព្រះអដ្ឋកថា

## ភាគ៣១

បាលីប្រែ ៤៩ - ៥០ - ៥១

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

# មនោរថបូរណី អដ្ឋកថា

### សេចក្តីប្រែជាភាសាខ្មែរ

# អង្គុត្តរនិកាយ

## នវកនិបាត ទសមភាគ

## ទសកនិបាត ឯកាទសមភាគ

## ទសក-ឯកាទសកនិបាត ទ្វាទសមភាគ

# ៣១

## បាលីប្រែ ៤៩-៥០-៥១

*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៣១
# អង្គុត្តរនិកាយ នវកនិបាត
# ទសមភាគ

*សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ*

## បណ្ណាសក
## សម្ពោធវគ្គទី ១
### សម្ពោធិសូត្រទី ១

*[ ១ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ ក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ប្រសិនបើពួកបរិព្វាជក ជាអន្យតិរ្ថិយ គប្បីសួរយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ហេតុនៃសេចក្តីចម្រើន នូវពួកធម៌ជាចំណែកនៃការត្រាស់ដឹង តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ បើពួកអន្យតិរ្ថិយ សួរយ៉ាងនេះហើយ អ្នកទាំងឡាយគប្បីដោះស្រាយ ដល់ពួកបរិព្វាជកជាអន្យតិរ្ថិយទាំង*

នោះដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់យើងខ្ញុំព្រះអង្គមានព្រះដ៏មានព្រះភាគជាមូល ។បេ។ ពួកភិក្ខុបានស្តាប់ចំពោះព្រះដ៏មានព្រះភាគហើយ ក៏នឹងចាំទុក ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយចូរចាំស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែងប្រាប់ ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ ពួកបរិព្វាជកជាអន្យតិរ្ថិយ គប្បីសួរយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ហេតុនៃសេចក្តីចម្រើននូវពួកធម៌ជាចំណែកនៃការត្រាស់ដឹង តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ កាលបើពួកអន្យតិរ្ថិយសួរយ៉ាងនេះ អ្នកទាំងឡាយ គប្បីដោះស្រាយដល់ពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានមិត្តល្អ មានសម្លាញ់ល្អ សមគប់នឹងមិត្តល្អ ។ ម្នាលអាវុសោទាំងឡាយ នេះជាហេតុនៃសេចក្តីចម្រើននូវពួកធម៌ជាចំណែកនៃការត្រាស់ដឹងទី ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារនិងគោចរ ឃើញនូវភ័យក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ នេះជាហេតុនៃសេចក្តីចម្រើន នូវពួកធម៌ជាចំណែកនៃការត្រាស់ដឹងទី ២ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បាន

ដោយងាយនូវកថាមានសភាពយ៉ាងនេះ ដែលជាកថាផូរផង់ ជាទីសប្បាយ ទូលាយចិត្ត គឺអប្បិច្ឆកថា សន្តុដ្ឋិកថា បវិវេកកថា អសំសគ្គកថា វីរិយារម្ភកថា សីលកថា សមាធិកថា បញ្ញាកថា វិមុត្តិកថា វិមុត្តិញាណទស្សនកថា ។ ម្នាលអាវុសោទាំងឡាយ នេះជាហេតុនៃសេចក្ដីចម្រើន នូវពួកធម៌ជាចំណែកនៃការត្រាស់ដឹងទី ៣ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុប្រារព្ធនូវសេចក្ដីព្យាយាម ដើម្បីលះបង់នូវពួកអកុសលធម៌ចេញ ដើម្បីញ៉ាំងពួកកុសលធម៌ឲ្យកើតឡើង ជាអ្នកមានកម្លាំង មានសេចក្ដីប្រឹងប្រែងខ្ជាប់ខ្ជួន មិនដាក់ធុរៈចោល ក្នុងធម៌ទាំងឡាយជាកុសល ។ ម្នាលអាវុសោទាំងឡាយ នេះជាហេតុនៃសេចក្ដីចម្រើន នូវពួកធម៌ជាចំណែកនៃការត្រាស់ដឹងទី ៤ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានបញ្ញា ប្រកបដោយបញ្ញាដែលអាចកំណត់នូវការកើតឡើង និងការវិនាសទៅ ( នៃខន្ធបញ្ចកៈ ) ជាគ្រឿងទម្លាយនូវកិលេសដ៏ប្រសើរ ជាចម្ងជាតដល់នូវកិរិយាអស់ទៅនៃទុក្ខដោយប្រពៃ ។ ម្នាលអាវុសោទាំងឡាយ នេះជាហេតុនៃសេចក្ដីចម្រើន នូវពួកធម៌ជាចំណែកនៃការត្រាស់ដឹងទី ៥ ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះរមែងកើតប្រាកដដល់ភិក្ខុ អ្នកមានមិត្តល្អ មានសម្លាញ់ល្អ សមគប់នឹងមិត្តល្អ គឺភិក្ខុនោះនឹងបានជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារ និងគោចរ ជាអ្នកឃើញភ័យក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាល

ភិក្ខុទាំងឡាយ ហេតុនេះរមែងកើតប្រាកដដល់ភិក្ខុអ្នកមានមិត្តល្អ មានសម្លាញ់ល្អ សមគប់នឹងមិត្តល្អ គឺភិក្ខុនោះនឹងបានជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយ នូវកថាមានសភាពយ៉ាងនេះ ដែលជាកថាផូរផង់ ជាទីសប្បាយទូលាយចិត្ត គឺអប្បិច្ឆកថា សន្តុដ្ឋិកថា បវិវេកកថា អសំសគ្គកថា វីរិយារម្ភកថា សីលកថា សមាធិកថា បញ្ញាកថា វិមុត្តិកថា វិមុត្តិញាណទស្សនកថា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះរមែងកើតប្រាកដដល់ភិក្ខុអ្នកមានមិត្តល្អ មានសម្លាញ់ល្អ សមគប់នឹងមិត្តល្អ គឺភិក្ខុនោះនឹងបានជាអ្នកប្រារព្ធនូវសេចក្តីព្យាយាម ដើម្បីលះបង់នូវពួកអកុសលធម៌ចេញ ដើម្បីញ៉ាំងពួកកុសលធម៌ឲ្យកើតឡើង ជាអ្នកមានកម្លាំង មានសេចក្តីប្រឹងប្រែងខ្ជាប់ខ្ជួន មិនដាក់ធុរៈចោលក្នុងកុសលធម៌ទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ រមែងកើតប្រាកដដល់ភិក្ខុ អ្នកមានមិត្តល្អ មានសម្លាញ់ល្អ សមគប់នឹងមិត្តល្អ គឺភិក្ខុនោះនឹងបានជាអ្នកមានបញ្ញា ប្រកបដោយបញ្ញាដែលអាចកំណត់នូវការកើតឡើង និងការវិនាសទៅ ( នៃខន្ធបញ្ចកៈ ) ជាគ្រឿងទម្លាយនូវកិលេសដ៏ប្រសើរ ជាធម្មជាតដល់នូវកិរិយាអស់ទៅនៃទុក្ខដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុនោះតាំងនៅក្នុងធម៌ទាំង

៥ នេះហើយ គប្បីចម្រើននូវធម៌ ៤ យ៉ាងតទៅទៀត គឺ ចម្រើនអសុភ ដើម្បីលះរាគៈ ចម្រើនមេត្តា ដើម្បីលះព្យាបាទ ចម្រើនអនាបានស្សតិ ដើម្បីផ្តាច់ផ្តិលនូវវិតក្ក ចម្រើនអនិច្ចសញ្ញា ដើម្បីដកចោលនូវអស្មិមានះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសម្គាល់ថា មិនមែនខ្លួន រមែងប្រាកដដល់ភិក្ខុអ្នកមានសេចក្តីសម្គាល់ថា មិនទៀង ភិក្ខុអ្នកមានសេចក្តីសម្គាល់ថា មិនមែនខ្លួន រមែងដល់នូវព្រះនិព្វាន ជាគ្រឿងដកចោលនូវអស្មិមានះ ក្នុងបច្ចុប្បន្ន ។

# អដ្ឋកថា

# នវកនិបាត

# បឋមបណ្ណាសក

## សម្ពោធវគ្គទី ១

### សម្ពោធិសូត្រ

[ ១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសម្ពោធិសូត្រទី ១ នៃនវកនិបាតដូចតទៅនេះ បទថា **សម្ពោធិបក្ខិកានំ** បានដល់ ចម្រើនក្នុងចំណែកនៃធម៌ជាគ្រឿងត្រាស់ដឹង ពោល គឺមគ្គ ៤ អធិប្បាយថា ជាឧបការៈ រមែងសួរបំណាងដល់ធម៌ ៩ ប្រការ ដែលមកហើយក្នុងបាលី ។ បទថា **កា ឧបនិសា** បានដល់អ្វីជាហេតុ គឺជាបច្ច័យ ។ កថា ឈ្មោះថា **អភិសល្លេខិកា** ព្រោះរមែងជុសខាត់កិលេស ។ ឈ្មោះថា **ចេតោវិវរណសប្បាយា** ព្រោះជាទីសប្បាយនិងមានឧបការៈ ក្នុងការបើកចិត្តដោយសមថៈ និងវិបស្សនា ។ ពាក្យដែលប្រព្រឹត្តទៅប្រារព្ធដល់សេចក្តីប្រាថ្នាតិច ឈ្មោះថា អប្បិច្ឆកថា ក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នា ។

បទថា **អសុភា ភាវេតព្វា រាគស្ស បហានាយ** អត្ថគប្បីអធិប្បាយឲ្យជាក់ច្បាស់ ដោយការប្រៀបធៀបនឹងបុគ្គលប្រូតស្រូវដូចតទៅនេះ បានឮ

ថា បុរសម្នាក់កាន់កណ្តៀវ ហើយច្រូតស្រូវសាលីទាំងឡាយក្នុងស្រែស្រូវសាលី តាំងអំពីចុង បន្ទាប់មក គោទាំងឡាយទម្លាយរបងស្រូវសាលីនោះហើយចូលទៅ គេដាក់កណ្តៀវ កាន់រំពាត់ដេញគោទាំងឡាយ ចេញទៅតាមផ្លូវនោះឯង ធ្វើរបងឲ្យដូចប្រក្រតីហើយ ទើបកាន់កណ្តៀវ ច្រូតស្រូវទៀត ។ ក្នុងការប្រៀបធៀបនោះ គប្បីឃើញព្រះពុទ្ធសាសនា ប្រៀបដូចស្រែស្រូវសាលី ព្រះយោគាវចរ ប្រៀបដូចអ្នកច្រូតស្រូវ បញ្ញាប្រៀបដូចកណ្តៀវ ខណៈធ្វើវិបស្សនា ប្រៀបដូចពេលច្រូតស្រូវ អសុភកម្មដ្ឋាន ប្រៀបដូចរំពាត់ការសង្រួម ប្រៀបដូចរបង ការឡេះឡោះ មិនទាន់ពិចារណារាគៈ កើតឡើងយ៉ាងឆាប់រហ័ស ប្រៀបដូចគោទាំងឡាយទម្លាយរបង ហើយចូលទៅ ពេលដែលសង្កត់រាគៈបានដោយអសុភកម្មដ្ឋាន ហើយផ្តើមធ្វើវិបស្សនាទៀត ប្រៀបដូចការដាក់កណ្តៀវ កាន់រំពាត់ដេញគោចេញទៅតាមផ្លូវដែលគោមកនោះឯង ធ្វើរបងឲ្យជាប្រក្រតីហើយ គប្បីច្រូតស្រូវទៀត ។ ព្រះមានព្រះភាគទ្រង់សំដៅសេចក្តីនេះ ទើបត្រាស់ថា **អសុភា ភាវេតព្វា រាគស្ស បហានាយ** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **រាគស្ស** បានដល់ រាគៈប្រកបដោយបញ្ចកាមគុណ ។

មេត្តាកម្មដ្ឋាន ឈ្មោះថា **មេត្តា** ។ បទថា **ព្យាបាទស្ស បហានាយ** បានដល់ ដើម្បីលះសេចក្តីក្រោធដែលកើតឡើង ដោយន័យដែលពោលហើយ ។ បទថា **អានាបានស្សតិ** បានដល់ អានាបានស្សតិមានអារម្មណ៍

*១៦ ។ បទថា* **វិតក្កូបច្ឆេទាយ** *បានដល់ ដើម្បីចូលទៅកាត់វិតក្កទាំងឡាយ ដែលកើតឡើងដោយន័យដែលពោលហើយ ។ បទថា* **អស្មិមានសមុគ្ឃា-តាយ** *បានដល់ ដើម្បីដកនូវមានះ ៩ យ៉ាង ដែលកើតឡើងថា ជាអញ ដូច្នេះ ។ បទថា* **អនត្តសញ្ញា សណ្ឋាតិ** *បានដល់ កាលបុគ្គលឃើញ អនិច្ចលក្ខណៈហើយ អនត្តលក្ខណៈក៏បានឃើញហើយដូចគ្នា ។ ដ្បិតថា ក្នុងលក្ខណៈទាំង ៣ នោះ កាលឃើញលក្ខណៈ ១ ហើយ លក្ខណៈ ២ ក្រៅអំពីនេះ ក៏បានឃើញដូចគ្នា ដោយហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ថា* **អនិច្ចសញ្ញិនោ ភិក្ខវេ អនត្តសញ្ញា សណ្ឋាតិ** *ដូច្នេះ ។ បទថា* **និព្វេវ ធម្មេ និព្វានំ** *សេចក្តីថា បុគ្គលដែលបានអនត្តសញ្ញា រមែងដល់នូវ ការរលត់ដោយឥតសេសសល់ ដោយមិនមានបច្ច័យក្នុងបច្ចុប្បន្ននោះឯង ។ ក្នុងសូត្រនេះ លោកពោលវដ្តៈផង វិវដ្តៈផង ។*

**អដ្ឋកថាសម្ពោធិសូត្រទី ១ ចប់**

# សុត្តន្តបិដក

## និស្សយសូត្រទី ២

[ ២ ] គ្រានោះ ភិក្ខុ ១ រូប ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ។បេ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន គេតែងនិយាយថា ភិក្ខុអ្នកបរិបូណ៌ដោយនិស្ស័យ ( ទីពឹង ) អ្នកបរិបូណ៌ដោយនិស្ស័យដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ចុះភិក្ខុអ្នកបរិបូណ៌ដោយនិស្ស័យ តើដោយហេតុដូចម្តេច ។ ម្នាលភិក្ខុ បើភិក្ខុអាស្រ័យសទ្ធាហើយលះបង់នូវអកុសល ចម្រើននូវកុសលបាន អកុសលនោះ ឈ្មោះថាភិក្ខុនោះបានលះបង់ហើយ ។ បើភិក្ខុអាស្រ័យហិរិ បើភិក្ខុអាស្រ័យឱត្តប្បៈ បើភិក្ខុអាស្រ័យវិរិយៈ បើភិក្ខុអាស្រ័យបញ្ញា ហើយលះបង់នូវអកុសលចម្រើននូវកុសលបាន អកុសលនោះ ឈ្មោះថា ភិក្ខុនោះ បានលះបង់ហើយ ព្រោះថា អកុសលដែលភិក្ខុណា ឃើញដោយបញ្ញាដ៏ប្រសើរ ហើយលះអកុសលនោះ ឈ្មោះថា ភិក្ខុនោះលះហើយ លះស្រឡះហើយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុនោះតាំងនៅក្នុងធម៌ទាំង ៥ នេះហើយ ត្រូវប្រកបដោយឧបនិស្ស័យ ៤ យ៉ាង ។ ឧបនិស្ស័យ ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាហើយ ទើបសេពនូវវត្ថុដែលគួរសេព ១ ពិចារណាហើយ ទើបអត់សង្កត់នូវវត្ថុដែលគួរអត់សង្កត់ ១ ពិចារណាហើយ ទើបវៀរនូវវត្ថុដែលគួរវៀរ ១ ពិចារណាហើយ ទើបបន្ទោ

បង់ចោលនូវវត្ថុដែលគួរបន្ទោបង់ចោល ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយនិស្ស័យ យ៉ាងនេះឯង ។

# អដ្ឋកថា

## និស្សយសូត្រ

[ ២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិស្សយសូត្រទី ២ ដូចតទៅនេះ បទថា **និស្សយសម្បន្នោ** បានដល់ ភិក្ខុដែលដល់ព្រមដោយទីពឹង ។ បទថា **សទ្ធំ** បានដល់ សទ្ធាជាហេតុឲ្យសម្រេច ។ បទថា **វីរិយំ** បានដល់ សេចក្ដីព្យាយាមតាមផ្លូវកាយ និងចិត្ត ។ បទថា **យំស** កាត់បទជា **យំ អស្ស** ។ បទថា **អរិយាយ បញ្ញាយ** បានដល់ មគ្គប្បញ្ញា និងវិបស្សនា ។ បទថា **សង្ខាយ** បានដល់ ដឹងហើយ ។ បទថា **ឯកំ បដិសេវតិ** បានដល់ រមែងសេពរបស់ដែលគួរសេព ។ បទថា **អធិវាសេតិ** បានដល់ រមែងអត់សង្កត់នូវរបស់ដែលគួរអត់សង្កត់ ។ បទថា **បរិវជ្ជេតិ** បានដល់ រមែងវៀររបស់ដែលគួរវៀរ ។ បទថា **វិនោទេតិ** បានដល់ រមែងនាំរបស់ដែលគួរនាំចេញទៅ ។ បទថា **ឯវំ ខោ ភិក្ខុ** សេចក្ដីថា ម្នាលភិក្ខុ ដោយហេតុយ៉ាងនេះឯង ភិក្ខុធ្វើការសេពឲ្យយល់ រហូតជាក់ច្បាស់ល្អបាន ក៏ដោយអំណាចការរៀន

និងការសោកស្ករ និងដោយអំណាចការកំណត់ធម៌ សេព អត់សង្កត់ វៀរ បន្ទោបង់ ឈ្មោះថា ជាអ្នកដល់ព្រមដោយទីពឹង ដោយប្រការដូច្នេះ ។

## អដ្ឋកថានិស្សយសូត្រទី ២ ចប់

# សុត្តន្តបិដក

## មេឃិយសូត្រទី ៣

[ ៣ ] សម័យមួយ ព្រះដ៏មានព្រះភាគ គង់លើភ្នំចាលិកា ទៀបក្រុងចាលិកា ។ សម័យនោះឯង ព្រះមេឃិយៈដ៏មានអាយុ ជាឧបដ្ឋាកព្រះដ៏មានព្រះភាគ ។ គ្រានោះ ព្រះមេឃិយៈដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះព្រះមេឃិយៈដ៏មានអាយុ ឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ប្រាថ្នានឹងចូលទៅកាន់ជន្តុគ្រាម ដើម្បីបិណ្ឌបាត ។ ម្នាលមេឃិយៈ អ្នកចូរសម្គាល់នូវកាលដែលគួរនឹងទៅ ក្នុងកាលឥឡូវនេះចុះ ។ គ្រានោះ មេឃិយៈដ៏មានអាយុ ស្លៀកស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ជន្តុគ្រាម ដើម្បីបិណ្ឌបាត លុះត្រាច់ទៅបិណ្ឌបាតក្នុងជន្តុគ្រាម

ហើយ ក៏ត្រឡប់អំពីបិណ្ឌបាត ក្នុងកាលជាខាងក្រោយនៃភត្ត ក៏ចូលទៅរកឆ្នេរស្ទឹងកិមិកាឡា ។ ព្រះមេឃិយៈដ៏មានអាយុ កំពុងចង្រ្កមតាមលំដាប់ត្រាច់ទៅតាមលំដាប់ដើម្បីសម្រាកស្មង ទៀបឆ្នេរស្ទឹងកិមិកាឡា បានឃើញព្រៃស្វាយ ជាទីជ្រះថ្លា ជាទីត្រេកអរ លុះឃើញហើយ លោកក៏មានសេចក្តីត្រិះរិះដូច្នេះថា ឱហ្ន៎ ព្រៃស្វាយនេះ ជាទីជ្រះថ្លា ជាទីត្រេកអរ ឱហ្ន៎ ព្រៃស្វាយនេះ គួរដល់ការតាំងព្យាយាមរបស់កុលបុត្ត អ្នកត្រូវការដោយការតាំងព្យាយាម ប្រសិនបើព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតឲ្យអាត្មាអញ អាត្មាអញនឹងមកកាន់ព្រៃស្វាយនេះ ដើម្បីតាំងសេចក្តីព្យាយាម ។ លំដាប់នោះ ព្រះមេឃិយៈដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះមេឃិយៈដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ទីក្នុងឯណោះ ខ្ញុំព្រះអង្គស្លៀកស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ជន្តុគ្រាមដើម្បីបិណ្ឌបាត លុះត្រាច់ទៅបិណ្ឌបាតក្នុងជន្តុគ្រាមហើយ ត្រឡប់មកអំពីបិណ្ឌបាត ក្នុងកាលជាខាងក្រោយនៃភត្ត រួចក៏ចូលទៅរកឆ្នេរស្ទឹងកិមិកាឡា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គកំពុងដើរចង្រ្កមតាមលំដាប់ ត្រាច់ទៅតាមលំដាប់ ដើម្បីសម្រាកស្មងទៀបឆ្នេរស្ទឹងកិមិកាឡា បានឃើញព្រៃស្វាយជាទីជ្រះថ្លា ជាទីត្រេកអរ លុះឃើញហើយ ខ្ញុំព្រះអង្គក៏មានសេចក្តីត្រិះរិះ

ដូច្នេះថា ឱហ្ន៎ ព្រៃស្វាយនេះ ជាទីជ្រះថ្លា ជាទីត្រេកអរ ឱហ្ន៎ ព្រៃស្វាយនេះ គួរដល់ការតាំងព្យាយាមរបស់កុលបុត្ត អ្នកត្រូវការដោយការតាំងព្យាយាម ប្រសិនបើព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតឲ្យអាត្មាអញ អាត្មាអញនឹងមកកាន់ព្រៃស្វាយនេះ ដើម្បីតាំងសេចក្ដីព្យាយាម ។ ប្រសិនបើព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតឲ្យខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គនឹងទៅកាន់ព្រៃស្វាយនោះ ដើម្បីតាំងសេចក្ដីព្យាយាម ។ កាលបើព្រះមេឃិយៈដ៏មានអាយុពោលយ៉ាងនេះហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងព្រះមេឃិយៈដ៏មានអាយុដូច្នេះថា ម្នាលមេឃិយៈ អ្នកចូរបង្អង់សិនចុះ កុំអាល ដ្បិតតថាគតតែម្នាក់ឯង ទម្រាំមានភិក្ខុណាមួយឯទៀតមកប្រាកដសិន ( សឹមអ្នកទៅចុះ ) ។ ព្រះមេឃិយៈដ៏មានអាយុក្រាបបង្គំទូលព្រះដ៏មានព្រះភាគជាគម្រប់ ២ ដងដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន កិច្ចដែលត្រូវធ្វើតទៅទៀតបន្តិចបន្តួច របស់ព្រះដ៏មានព្រះភាគមិនមាន ការសន្សំនូវកិច្ចដែលធ្វើហើយមិនមានទេ បពិត្រព្រះអង្គដ៏ចម្រើន ចំណែកខ្ញុំព្រះអង្គ នៅមានករណីយកិច្ចតទៅទៀត នៅមានការសន្សំនូវកិច្ចដែលធ្វើហើយ ប្រសិនបើព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតឲ្យខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គនឹងទៅកាន់ព្រៃស្វាយនោះ ដើម្បីតាំងព្យាយាម ។ ម្នាលមេឃិយៈ អ្នកចូរបង្អង់សិនចុះ កុំអាល ដ្បិតតថាគតតែម្នាក់ឯង ទម្រាំមានភិក្ខុណាមួយឯទៀតមកប្រាកដសិន ( សឹមអ្នកទៅចុះ ) ។ ព្រះមេឃិយៈដ៏មានអាយុ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ជាគម្រប់ ៣ ដងដូច្នេះថា

បពិត្រព្រះអង្គដ៏ចម្រើន ករណីយកិច្ចតទៅទៀត បន្តិចបន្តួច របស់ព្រះដ៏មានព្រះភាគ មិនមាន ការសន្សំនូវកិច្ចដែលធ្វើហើយមិនមាន បពិត្រព្រះអង្គដ៏ចម្រើន ចំណែកខ្ញុំព្រះអង្គ នៅមានករណីយកិច្ចតទៅទៀត នៅមានការសន្សំនូវកិច្ចដែលធ្វើហើយ ប្រសិនបើព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតឲ្យខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គគប្បីទៅកាន់ព្រៃស្វាយនោះ ដើម្បីតាំងព្យាយាម ។ ម្នាលមេឃិយៈ តថាគតគប្បីនិយាយដូចម្តេចនឹងអ្នក ដែលចេះតែនិយាយថា ការតាំងព្យាយាមដូច្នេះ ម្នាលមេឃិយៈ អ្នកចូរសម្គាល់នូវកាល ដែលគួរនឹងទៅក្នុងកាលឥឡូវនេះចុះ ។ គ្រានោះឯង ព្រះមេឃិយៈដ៏មានអាយុ ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណហើយចូលទៅរកព្រៃស្វាយនោះ លុះទៅដល់ហើយ ក៏ចូលទៅកាន់ព្រៃស្វាយនោះ អង្គុយសម្រាកក្នុងវេលាថ្ងៃ ទៀបគល់ឈើមួយដើម ។ លំដាប់នោះ កាលព្រះមេឃិយៈដ៏មានអាយុ នៅក្នុងព្រៃស្វាយនោះ អកុសលវិតក្កដ៏លាមក ៣ យ៉ាង គឺកាមវិតក្ក ១ ព្យាបាទវិតក្ក ១ វិហឹសាវិតក្ក ១ ក៏ពុះពោរឡើងរឿយៗ ។ លំដាប់នោះ ព្រះមេឃិយៈដ៏មានអាយុ ក៏មានសេចក្តីត្រិះរិះដូច្នេះថា យីអើ អស្ចារ្យណាស់ យីអើ ចម្លែកណាស់ហ្ន៎ បុគ្គលទាំងឡាយចេញចាកផ្ទះនោះ ចូលកាន់ផ្នួសដោយសទ្ធា ក៏នៅតែមានអកុសលវិតក្កដ៏លាមក ៣ ប្រការនេះ គឺកាមវិតក្ក ១ ព្យាបាទវិតក្ក ១ វិហឹសាវិតក្ក ១ តាមរួបរឹតទៀត ។ លំដាប់នោះ ព្រះមេឃិយៈដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មាន

ព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះមេឃិយៈដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះកាលខ្ញុំព្រះអង្គនៅក្នុងព្រៃស្វាយនោះ អកុសលវិតក្កដ៏លាមក ៣ ប្រការគឺកាមវិតក្ក ១ ព្យាបាទវិតក្ក ១ វិហឹសាវិតក្ក ១ តែងពុះពោរឡើងរឿយៗ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ មានសេចក្តីត្រិះរិះដូច្នេះថា យីអើអស្ចារ្យណាស់ យីអើ ចម្លែកណាស់ កុលបុត្តទាំងឡាយចេញចាកផ្ទះនោះចូលកាន់ផ្នួសដោយសទ្ធាហើយ ក៏នៅតែមានអកុសលវិតក្កដ៏លាមក ៣ ប្រការនេះ គឺកាមវិតក្ក ១ ព្យាបាទវិតក្ក ១ វិហឹសាវិតក្ក ១ តាមរួបរឹតទៀត ។ ម្នាលមេឃិយៈ ធម៌ទាំងឡាយ ៥ យ៉ាង តែងប្រព្រឹត្តទៅ ដើម្បីចេតោវិមុត្តិដែលពុំទាន់ចាស់ក្លា ឲ្យចាស់ក្លាឡើងបាន ។ ធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលមេឃិយៈ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានមិត្តល្អ មានសម្លាញ់ល្អ សមគប់នឹងមិត្តល្អ ។ ម្នាលមេឃិយៈ នេះធម៌ទី ១ តែងប្រព្រឹត្តទៅ ដើម្បីចេតោវិមុត្តិ ដែលពុំទាន់ចាស់ក្លា ឲ្យចាស់ក្លាឡើងបាន ។ ម្នាលមេឃិយៈ មួយទៀត ភិក្ខុជាអ្នកមានសីល សង្រួមហើយ ដោយការសង្រួមក្នុងបាតិមោក្ខ បរិបូណ៌ដោយអាចារ និងគោចរ ឃើញភ័យក្នុងទោសទាំង-ឡាយ សូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលមេឃិយៈ នេះជាធម៌ទី ២ តែងប្រព្រឹត្តទៅ ដើម្បីចេតោវិមុត្តិ ដែលពុំទាន់

ចាស់ក្លា ឲ្យចាស់ក្លាឡើងបាន ។ ម្នាលមេឃិយៈ មួយទៀត ភិក្ខុជាអ្នកបាន តាមប្រាថ្នា បានមិនលំបាក បានដោយងាយ នូវកថាមានសភាពយ៉ាងនេះ ដែលជាកថាដ៏ផូរផង់ ជាទីសប្បាយទូលាយចិត្ត គឺអប្បិច្ឆកថា សន្តុដ្ឋិកថា បវិវេកកថា អសំសគ្គកថា វីរិយារម្ភកថា សីលកថា សមាធិកថា បញ្ញាកថា វិមុត្តិកថា វិមុត្តិញ្ញាណទស្សនកថា ។ ម្នាលមេឃិយៈ នេះជាធម៌ទី ៣ ប្រព្រឹត្តទៅ ដើម្បីចេតោវិមុត្តិ ដែលពុំទាន់ចាស់ក្លា ឲ្យចាស់ក្លាឡើងបាន ។ ម្នាលមេឃិយៈ មួយទៀត ភិក្ខុជាអ្នកប្រារព្ធនូវសេចក្តីព្យាយាម ដើម្បីលះបង់នូវពួកអកុសលធម៌ចេញ ដើម្បីញ៉ាំងពួកកុសលធម៌ឲ្យកើតឡើង ជាអ្នកមានកម្លាំង មានសេចក្តីប្រឹងប្រែងដ៏មាំមួន មិនដាក់ធុរៈចោល ក្នុងកុសលធម៌ទាំងឡាយ ។ ម្នាលមេឃិយៈ នេះជាធម៌ទី ៤ តែងប្រព្រឹត្តទៅ ដើម្បីចេតោវិមុត្តិ ដែលពុំទាន់ចាស់ក្លា ឲ្យចាស់ក្លាឡើងបាន ។ ម្នាលមេឃិយៈ មួយទៀត ភិក្ខុជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញា ដែលកំណត់នូវការកើតឡើង និងវិនាសទៅ ជាគ្រឿងទម្លាយនូវកិលេសដ៏ប្រសើរ ជាធម្មជាតដល់នូវកិរិយាអស់ទៅនៃទុក្ខ ដោយប្រពៃ ។ ម្នាលមេឃិយៈ នេះជាធម៌ជាទី ៥ តែងប្រព្រឹត្តទៅ ដើម្បីចេតោវិមុត្តិ ដែលពុំទាន់ចាស់ក្លា ឲ្យចាស់ក្លាឡើងបាន ។ ម្នាលមេឃិយៈ ហេតុនេះ រមែងកើតប្រាកដដល់ភិក្ខុអ្នកមានមិត្តល្អ មានសម្លាញ់ល្អ សមគប់នឹងមិត្តល្អ គឺភិក្ខុនោះនឹងបានជាអ្នកមានសីល ។បេ។ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលមេឃិយៈ ហេតុនេះ រមែង

កើតប្រាកដដល់ភិក្ខុ អ្នកមានមិត្តល្អ មានសម្លាញ់ល្អ សមគប់នឹងមិត្តល្អ គឺភិក្ខុនោះនឹងបាន ជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយ នូវកថាមានសភាពយ៉ាងនេះ ដែលជាកថាដ៏ផូរផង់ ជាទីសប្បាយទូលាយចិត្ត គឺអប្បិច្ឆកថា ។បេ។ វិមុត្តិញ្ញាណទស្សនកថា ។ ម្នាលមេឃិយៈ ហេតុនេះ រមែងកើតប្រាកដដល់ភិក្ខុអ្នកមានមិត្តល្អ មានសម្លាញ់ល្អ សមគប់នឹងមិត្តល្អ គឺភិក្ខុនោះនឹងបានជាអ្នកប្រារព្ធនូវសេចក្ដីព្យាយាម ។បេ។ ជាអ្នកមិនដាក់ធុរៈចោលក្នុងកុសលធម៌ទាំងឡាយ ។ ម្នាលមេឃិយៈ ហេតុនេះរមែងកើតប្រាកដ ដល់ភិក្ខុអ្នកមានមិត្តល្អ មានសម្លាញ់ល្អ សមគប់នឹងមិត្តល្អ គឺភិក្ខុនោះនឹងបានជាអ្នកមានបញ្ញា ។បេ។ ជាធម្មជាតដល់នូវកិរិយាអស់ទៅនៃទុក្ខដោយប្រពៃ ។ ម្នាលមេឃិយៈ មួយទៀត ភិក្ខុនោះតាំងនៅក្នុងធម៌ទាំង ៥ នេះហើយ គប្បីចម្រើននូវធម៌ ៤ យ៉ាងតទៅ គឺចម្រើនអសុភដើម្បីលះរាគៈ ចម្រើនមេត្តា ដើម្បីលះព្យាបាទ ចម្រើនអនាបានស្សតិ ដើម្បីផ្ដាច់បង់នូវវិតក្ក ចម្រើនអនិច្ចសញ្ញា ដើម្បីដកចោលនូវអស្មិមានះ ។ ម្នាលមេឃិយៈ សេចក្ដីសម្គាល់ថា មិនមែនខ្លួន រមែងប្រាកដដល់ភិក្ខុអ្នកមានសេចក្ដីសម្គាល់ថា មិនទៀង ភិក្ខុអ្នកមានសេចក្ដីសម្គាល់ថា មិនមែនខ្លួន រមែងដល់ព្រះនិព្វាន ជាគ្រឿងដកចោលនូវអស្មិមានះ ក្នុងបច្ចុប្បន្ន ។

# អដ្ឋកថា

## មេឃិយសូត្រ

[ ៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមេឃិយសូត្រទី ៣ ដូចតទៅនេះ បទថា **ចាលិកាយំ** បានដល់ ក្នុងក្រុងមានឈ្មោះយ៉ាងនោះ ។ បានឮថា ក្រុងនោះរមែងប្រាកដហាក់ដូចកម្រើកដល់បុគ្គលទាំងឡាយ ដែលកំពុងសម្លឹងមើល ព្រោះមហាជនបានអាស្រ័យដីភក់ សាងហើយ ដូច្នោះ ទើបហៅថា ក្រុងចាលិកា ។ បទថា **ចាលិកាបព្វតេ** បានដល់ ភ្នំនោះ ប្រាកដដូចកម្រើកដល់បុគ្គលកំពុងសម្លឹងមើលក្នុងថ្ងៃឧបោសថខាងខ្នោច ព្រោះសស្ទុះ ហេតុនោះ ទើបហៅថា **ចាលិកបព្វត** ។ បុគ្គលទាំងឡាយសាងវិហារធំ លើចាលិកបព៌តនោះ ។ ព្រះមានព្រះភាគ ទ្រង់អាស្រ័យក្រុងនោះ គង់នៅក្នុងចាលិកបព្វតមហាវិហារ ដោយប្រការដូច្នេះ ។ បទថា **ជន្តុគ្គាមំ** បានដល់ គោចរគ្រាមមួយទៀត ដែលមានឈ្មោះយ៉ាងនោះរបស់វិហារនោះដូចគ្នា លោកពោលថា **ជន្តុគ្គាមំ** ដូច្នេះ ក៏មាន ។

បទថា **បធានត្ថិកស្ស** បានដល់ ធ្វើនូវសេចក្តីព្យាយាម ។ បទថា **បធានាយ** បានដល់ ដើម្បីធ្វើសមណធម៌ ។ បទថា **អាគមេហិ តាវ** សេចក្តីថា ព្រះសាស្តាស្តាប់ពាក្យរបស់ព្រះថេរៈហើយ ទ្រង់ពិចារណា ទ្រង់ដឹងថា ញាណរបស់ព្រះថេរៈនោះ មិនចាស់ក្លា ដូច្នេះ ទើបត្រាស់ឃាត់យ៉ាងនេះ ។ ឯបទនេះថា **ឯកកម្ហិ តាវ** បានត្រាស់ដល់ព្រះមេឃិយៈនោះ

ដើម្បីឲ្យកើតចិត្តទន់ភ្លន់ ដោយទ្រង់ព្រះតម្រិះថា ព្រះមេឃិយៈនេះ សូម្បីទៅហើយយ៉ាងនេះ កាលកម្មដ្ឋានមិនសម្រេច អស់នូវសេចក្តីសង្ស័យ នឹងត្រឡប់មកវិញ ដោយអំណាចសេចក្តីស្រឡាញ់ ដូច្នេះ ។ បទថា **នត្ថិ កិញ្ចិ ឧត្តរឹ ករណីយំ** សេចក្តីថា ឈ្មោះថា កិច្ចដែលគប្បីធ្វើដទៃឲ្យក្រៃលែង រមែងមិនមាន ព្រោះទ្រង់ធ្វើកិច្ច ៤ ក្នុងសច្ចៈ ៤ ស្រេចហើយ ។ បទថា **កតស្ស វា បដិចយោ** សេចក្តីថា ម្យ៉ាងទៀត រមែងមិនមានការសន្សំអរិយមគ្គដែលធ្វើហើយ មគ្គដែលទ្រង់ចម្រើនហើយ ទ្រង់ក៏មិនចម្រើនទៀត កិលេសដែលទ្រង់លះបានហើយ ក៏មិនមានការលះទៀត ។ បទថា **បធានន្តិ ខោ មេឃិយ វទមានំ កិន្តិ វទេយ្យាម** សេចក្តីថា តថាគតគប្បីពោលអ្វីដទៃដល់អ្នក ដែលពោលថា អញនឹងធ្វើសមណធម៌ ដូច្នេះ ។

បទថា **ទិវាវិហារំ និសីទិ** បានដល់ អង្គុយដើម្បីសម្រាកក្នុងពេលថ្ងៃ បុគ្គលជាព្រះរាជាមកអស់ ៥០០ ជាតិ តាមលំដាប់ក្នុងកាលមុន កាលលេងក្នុងឧទ្យាន ក៏មានអ្នករបាំ ៣ ពួកជាបរិវារ អង្គុយហើយលើផ្ទៃនមង្គលសិលាណា ព្រះមេឃិយៈអង្គុយលើផ្ទៃនសិលាមង្គលនោះដូចគ្នា ។ ភាពជាសមណៈរបស់ព្រះថេរៈ ហាក់ដូចជាបោះបោលទៅ តាំងអំពីកាលដែលលោកអង្គុយហើយ ។ បុគ្គលកាន់យកភេទព្រះរាជា ដែលមានអ្នករបាំចោមរោមហើយ ហាក់ដូចអង្គុយលើបល្ល័ង្កធំ ដែលសមគួរខាងក្រោមស្វេតច្ឆត្រ កាលបើដូច្នោះ កាមវិតក្កកើតឡើងហើយដល់បុគ្គលនោះ ដែលត្រេកអរក្នុង

សម្បត្តិនោះ ។ ក្នុងខណៈនោះឯង បុគ្គលនោះបានឃើញចោរ ២ នាក់ ត្រូវមេទ័ពចាប់ហើយ នាំមកចំពោះមុខ ព្យាបាទវិតក្កកើតហើយដល់បុគ្គលនោះ ដោយអំណាចការបញ្ជាឲ្យសម្លាប់ចោរម្នាក់ ក្នុងចោរទាំងនោះ វិហិង្សាវិតក្ក រមែងកើតឡើង ដោយអំណាចការបញ្ជាឲ្យចងចោរម្នាក់ ។ បុគ្គលនោះត្រូវអកុសលវិតក្កចោមរោមស្ទុះស្ទាញហើយដោយអកុសល ដូចដើមឈើដែលត្រូវវល្លិ៍របរឹត និងដូចបុគ្គលសម្លាប់មេឃ្មុំយកទឹកឃ្មុំ ត្រូវមេឃ្មុំចោមរោមដូច្នោះ ។ លោកសំដៅដល់សេចក្តីនោះ ទើបលោកពោលពាក្យជាដើមថា **អថខោ អាយស្មតោ មេឃិយស្ស** ដូច្នេះ ។ បទថា **អន្វាសត្តា** បានដល់ជាបុគ្គលត្រូវអកុសលវិតក្កជាប់តាមចោមរោមហើយ ។ បទថា **យេន ភគវា តេនុបសង្កមិ** សេចក្តីថា ព្រះមេឃិយៈស្ទុះស្ទាញហើយ ដោយអកុសលដ៏លាមកយ៉ាងនេះ មិនអាចធ្វើកម្មដ្ឋានឲ្យជាទីសប្បាយបាន ទើបបានកំណត់ថា ព្រះមានព្រះភាគទ្រង់ឃើញកាលវែង ទ្រង់ឃើញហេតុនេះហ្ន៎ ទើបទ្រង់ឃាត់ គិតថា អញនឹងក្រាបទូលហេតុនេះដល់ព្រះទសពល ដូច្នេះ ទើបក្រោកចាក អាសនៈដែលអង្គុយ ហើយចូលទៅគាល់ព្រះមានព្រះភាគ ៕

## អដ្ឋកថាមេឃិយសូត្រទី ៣ ចប់

# សុត្តន្តបិដក

## ឆន្នកសូត្រទី ៤

[ ៤ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះនន្ទកៈដ៏មានអាយុ បានញុំាងភិក្ខុទាំងឡាយឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ក្នុងឧបដ្ឋានសាលា ។ គ្រានោះ ព្រះដ៏មានព្រះភាគ ចេញអំពីទីពួនសម្ងំ ក្នុងសាយណ្ហសម័យ ចូលទៅឧបដ្ឋានសាលា លុះស្តេចចូលទៅដល់ហើយ ក៏ប្រថាប់នៅទៀបខ្លោងទ្វារខាងក្រៅ រង់ចាំចប់កថា ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបច្បាស់ថាចប់កថាហើយ ក៏គ្រហែម ហើយគោះបន្ទះទ្វារ ។ ពួកភិក្ខុទាំងនោះ ក៏បើកទ្វារថ្វាយព្រះដ៏មានព្រះភាគ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ស្តេចចូលទៅក្នុងឧបដ្ឋានសាលា ហើយទ្រង់គង់លើអាសនៈ ដែលគេក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគគង់ហើយ ទ្រង់ត្រាស់នឹងព្រះនន្ទកៈដ៏មានអាយុថា នែនន្ទកៈ ធម្មបរិយាយរបស់អ្នកនេះ វែងពេកណាស់ប្រាកដដល់ភិក្ខុទាំងឡាយហើយ ប៉ុន្តែអម្បាលតថាគតឈរទៀបខ្លោងទ្វារខាងក្រៅ រង់ចាំទម្រាំតែចប់កថាទាល់តែរោយខ្នង។ កាលបើព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះនន្ទកៈដ៏មានអាយុ ក៏អៀនអន់ខ្មាស បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំមិនដឹងជាព្រះដ៏មានព្រះភាគ ទ្រង់ប្រថាប់នៅទៀបខ្លោងទ្វារខាងក្រៅទេ បពិត្រព្រះអង្គដ៏ចម្រើន បើប្រសិនជាខ្ញុំព្រះអង្គដឹងថា ព្រះដ៏មាន

ព្រះភាគ ទ្រង់សណ្ឋិតនៅទៀបខ្លោងទ្វារខាងក្រៅដូច្នេះ ខ្ញុំព្រះអង្គក៏មិនគប្បីសម្តែងនូវពាក្យមានប្រមាណប៉ុណ្ណោះទេ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបច្បាស់នូវព្រះនន្ទកៈដ៏មានអាយុ ជាអ្នកមានសភាពអៀនអន់ហើយទ្រង់ត្រាស់នឹងព្រះនន្ទកៈដ៏មានអាយុដូច្នេះថា ម្នាលនន្ទកៈ ប្រពៃហើយៗម្នាលនន្ទកៈ អ្នកទាំងឡាយ គប្បីអង្គុយប្រជុំគ្នា ដោយធម្មីកថាណា ការអង្គុយប្រជុំគ្នាដោយធម្មីកថានោះ សមគួរដល់អ្នកទាំងឡាយ ដែលជាកុលបុត្តចេញចាកផ្ទះ ចូលកាន់ផ្នួសដោយសទ្ធាហើយ ម្នាលនន្ទកៈ អ្នកទាំងឡាយដែលប្រជុំគ្នាហើយ គប្បីធ្វើកិច្ច ២ យ៉ាង គឺធម្មីកថា ១ អរិយតុណ្ហីភាព ១ ។ ម្នាលនន្ទកៈ ភិក្ខុជាអ្នកមានសទ្ធា តែគ្មានសីល កាលបើយ៉ាងនេះ ភិក្ខុនោះ ឈ្មោះថា មិនពេញដោយអង្គនោះទេ ភិក្ខុនោះ ត្រូវបំពេញអង្គនោះ ដោយគិតថា អាត្មាអញគប្បីជាអ្នកមានសទ្ធាផង មានសីលផង មិនដូច្នោះឬ ។ ម្នាលនន្ទកៈ កាលណាភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង កាលបើយ៉ាងនេះ ភិក្ខុនោះឈ្មោះថា ជាអ្នកពេញដោយអង្គនោះ ម្នាលនន្ទកៈ ភិក្ខុមានសទ្ធាផង មានសីលផង តែមិនបាននូវចេតោសមាធិខាងក្នុងសន្តាន កាលបើយ៉ាងនេះ ភិក្ខុនោះឈ្មោះថា មិនពេញដោយអង្គនោះទេ ភិក្ខុនោះ ត្រូវបំពេញអង្គនោះ ដោយគិតថា អាត្មាអញគប្បីជាអ្នកមានសទ្ធាផង មានសីលផង បាននូវចេតោសមាធិខាងក្នុងសន្តានផង មិនដូច្នោះឬ ។ ម្នាលនន្ទកៈ កាលណាភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង

បានទូវចេតោសមាធិខាងក្នុងសន្តានផង កាលបើយ៉ាងនេះ ភិក្ខុនោះឈ្មោះថា ជាអ្នកពេញដោយអង្គនោះ ម្នាលនន្ទក: ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង បានទូវចេតោសមាធិខាងក្នុងសន្តានផង តែមិនបានទូវអធិប្បញ្ញាធម្ម-វិបស្សនា កាលបើយ៉ាងនេះ ភិក្ខុនោះឈ្មោះថា មិនពេញដោយអង្គនោះ ។ ម្នាលនន្ទក: ដូចសត្វជើង ២ សត្វជើង ៤ តែជើង ១ របស់សត្វនោះៗ ថោកថយអន់ កាលបើយ៉ាងនេះ សត្វនោះឈ្មោះថា មិនពេញដោយអង្គនោះ យ៉ាងណាមិញ ម្នាលនន្ទក: ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង បានទូវចេតោសមាធិខាងក្នុងសន្តានផង តែមិនបានទូវអធិប្បញ្ញាធម្មវិបស្សនា កាលបើយ៉ាងនេះ ភិក្ខុនោះឈ្មោះថា មិនពេញដោយអង្គនោះ ភិក្ខុនោះត្រូវបំពេញអង្គនោះ ដោយគិតថា អាត្មាអញគប្បីជាអ្នកមានសទ្ធាផង មានសីលផង បានទូវចេតោសមាធិខាងក្នុងសន្តានផង បានទូវអធិប្បញ្ញាធម្មវិបស្សនាផង មិនដូច្នោះឬ ក៏យ៉ាងនោះដែរ ។ ម្នាលនន្ទក: កាលណា ភិក្ខុជាអ្នកមានសទ្ធាផង មានទូវសីលផង បានទូវចេតោសមាធិខាងក្នុងសន្តានផង បានទូវអធិប្បញ្ញាធម្មវិបស្សនាផង កាលបើយ៉ាងនេះ ភិក្ខុនោះឈ្មោះថា ជាអ្នកពេញដោយអង្គនោះៗ ព្រះដ៏មានព្រះភាគ ត្រាស់ពាក្យនេះចប់ហើយ លុះព្រះសុគតទ្រង់ពោលពាក្យនេះហើយ ក៏ក្រោកចាកអាសនៈ ចូលទៅកាន់វិហារ ។ គ្រានោះ ព្រះនន្ទក:ដ៏មានអាយុ កាលព្រះដ៏មានព្រះភាគចៀសចេញទៅមិនយូរប៉ុន្មាន ក៏ហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោទាំងឡាយ ឥឡូវនេះ ព្រះដ៏

មានព្រះភាគ ទ្រង់ប្រកាសព្រហ្មចរិយធម៌ដ៏បរិសុទ្ធ គ្រប់ទាំងអស់ ដោយបទទាំងឡាយ ៤ ហើយទ្រង់ស្តេចក្រោកចាកអាសនៈចូលទៅកាន់វិហារ ត្រាស់ថា ម្នាលនន្ទកៈ ភិក្ខុជាអ្នកមានសទ្ធាតែគ្មានសីល កាលបើយ៉ាងនេះ ភិក្ខុនោះឈ្មោះថា មិនពេញដោយអង្គនោះ ភិក្ខុនោះ ត្រូវតែបំពេញអង្គនោះ ដោយគិតថា អាត្មាអញ គប្បីជាអ្នកមានសទ្ធាផង មានសីលផង មិនដូច្នោះឬ ។ ម្នាលនន្ទកៈ កាលណា ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង កាលបើយ៉ាងនេះ ភិក្ខុនោះឈ្មោះថា ពេញដោយអង្គនោះ ម្នាលនន្ទកៈ ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង តែមិនបានទូវចេតោសមាធិខាងក្នុងសន្តាន ។បេ។ បានទូវចេតោសមាធិខាងក្នុងសន្តានផង តែមិនបានទូវអធិប្បញ្ញាធម្មវិបស្សនា កាលបើយ៉ាងនេះ ភិក្ខុនោះ ឈ្មោះថាមិនពេញដោយអង្គនោះ ម្នាលនន្ទកៈ ដូចសត្វជើង ២ សត្វជើង ៤ តែជើង ១ របស់សត្វនោះៗ ថោកថយ អន់ កាលបើយ៉ាងនេះ សត្វនោះ ឈ្មោះថា មិនពេញដោយអង្គនោះ យ៉ាងណាមិញ ម្នាលនន្ទកៈ ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង បានទូវចេតោ-សមាធិខាងក្នុងសន្តានផង តែមិនបានទូវអធិប្បញ្ញាធម្មវិបស្សនា កាលបើយ៉ាងនេះ ភិក្ខុនោះ ឈ្មោះថា មិនពេញដោយអង្គនោះ ភិក្ខុនោះត្រូវបំពេញអង្គនោះ ដោយគិតថា អាត្មាអញគប្បីជាអ្នកមានសទ្ធាផង មានសីលផង បានទូវចេតោសមាធិខាងក្នុងសន្តានផង បានទូវអធិប្បញ្ញាធម្មវិបស្សនាផង មិនដូច្នោះឬ ក៏យ៉ាងនោះដែរ ។ ម្នាលនន្ទកៈ កាលណា ភិក្ខុជាអ្នកមានសទ្ធា

ផង មានសីលផង បានទូវចេតោសមាធិខាងក្នុងសន្តានផង បានទូវ អធិប្បញ្ញាធម្មវិបស្សនាផង កាលបើយ៉ាងនេះ ភិក្ខុនោះ ឈ្មោះថា ពេញ ដោយអង្គនោះ ។ ម្នាលអាវុសោទាំងឡាយ អានិសង្សក្នុងការស្តាប់ធម៌តាម កាលគួរ ក្នុងការសាកច្ឆាធម៌តាមកាលគួរនេះ មាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ សម្តែងធម៌ដល់ភិក្ខុទាំងឡាយ ជាធម៌ពីរោះបទដើម ពីរោះបទកណ្តាល ពីរោះ បទចុង ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយធម៌ ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ម្នាលអាវុសោទាំងឡាយ ភិក្ខុសម្តែងធម៌ដល់ ភិក្ខុទាំងឡាយ ជាធម៌ពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយធម៌ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ដោយប្រការណាៗ ភិក្ខុនោះ ជាទីស្រឡាញ់ផង ជាទីគាប់ ចិត្តផង ជាទីគោរពផង ជាទីសរសើរផង របស់គ្រូនោះៗ ដោយប្រការ ដូច្នោះៗ ។ ម្នាលអាវុសោទាំងឡាយ នេះជាអានិសង្សទី ១ ក្នុងការស្តាប់ ធម៌តាមកាលគួរ ក្នុងការសាកច្ឆាធម៌តាមកាលគួរ ។ ម្នាលអាវុសោទាំង-ឡាយ មួយទៀត ភិក្ខុសម្តែងធម៌ដល់ភិក្ខុទាំងឡាយ ជាធម៌ពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយធម៌ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ម្នាលអាវុសោទាំង-ឡាយ ភិក្ខុសម្តែងធម៌ដល់ភិក្ខុទាំងឡាយ ជាធម៌ពីរោះបទដើម ។បេ។ ប្រកាស

នូវព្រហ្មចរិយធម៌ ដោយប្រការណាៗ ភិក្ខុនោះ ជាអ្នកដឹងច្បាស់នូវអត្ថផង ដឹងច្បាស់នូវធម៌ផង ក្នុងធម៌នោះ ដោយប្រការដូច្នោះៗ ។ ម្នាលអាវុសោទាំងឡាយ នេះជាអានិសង្សទី ២ ក្នុងការស្តាប់ធម៌តាមកាលគួរ ក្នុងការសាកច្ឆាធម៌តាមកាលគួរ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុសម្តែងធម៌ដល់ភិក្ខុទាំងឡាយ ជាធម៌ពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយធម៌ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ម្នាលអាវុសោទាំងឡាយ ភិក្ខុសម្តែងធម៌ដល់ភិក្ខុទាំងឡាយ ជាធម៌ពីរោះបទដើម ។បេ។ ប្រកាសនូវព្រហ្មចរិយធម៌ ដោយប្រការណាៗ ភិក្ខុនោះ រមែងឃើញច្បាស់នូវអត្ថ និងបទដ៏ជ្រាលជ្រៅ ក្នុងធម៌នោះ ដែលខ្លួនចាក់ធ្លុះដោយបញ្ញា ដោយប្រការដូច្នោះៗ ។ ម្នាលអាវុសោទាំងឡាយ នេះជាអានិសង្សទី ៣ ក្នុងការស្តាប់ធម៌តាមកាលគួរ ក្នុងការសាកច្ឆាធម៌តាមកាលគួរ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុសម្តែងធម៌ដល់ភិក្ខុទាំងឡាយ ជាធម៌ពីរោះបទដើម ។បេ។ ប្រកាសនូវព្រហ្មចរិយធម៌ សព្រហ្មចារីបុគ្គលទាំងឡាយ តែងសរសើរនូវភិក្ខុនោះតទៅ ដោយប្រការដូច្នោះៗ ថា ភិក្ខុអ្នកដ៏មានអាយុនេះដល់ហើយ ឬនឹងដល់ ( នូវព្រះអរហត្តមិនខាន ) ។ ម្នាលអាវុសោទាំងឡាយ នេះជាអានិសង្សទី ៤ ក្នុងការស្តាប់ធម៌តាមកាលគួរ ក្នុងការសាកច្ឆាធម៌តាមកាលគួរ ។ ម្នាលអាវុសោទាំង-ឡាយ មួយវិញទៀត ភិក្ខុសម្តែងធម៌ដល់ភិក្ខុទាំងឡាយ ជាធម៌ពីរោះបទដើម

ពីរោះបទកណ្ដាល ពីរោះបទចុង ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយធម៌ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ម្នាលអាវុសោទាំងឡាយ ភិក្ខុសម្ដែងធម៌ដល់ភិក្ខុទាំងឡាយ ជាធម៌ពីរោះបទដើម ពីរោះបទកណ្ដាល ពីរោះបទចុង ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយធម៌ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ដោយប្រការណាៗ បណ្ដាភិក្ខុទាំងនោះ ពួកភិក្ខុណាជាសេក្ខៈ មានសេចក្ដីប្រាថ្នាក្នុងចិត្ត គឺអរហត្តមិនទាន់សម្រេច ប្រាថ្នានូវធម៌ក្សេមចាកយោគៈដ៏ប្រសើរ ពួកភិក្ខុទាំងនោះ បានស្ដាប់ធម៌នោះហើយ ក៏រមែងប្រារព្ធសេចក្ដីព្យាយាម ដើម្បីដល់នូវធម៌ដែលខ្លួនមិនទាន់ដល់ ដើម្បីត្រាស់ដឹងនូវធម៌ ដែលខ្លួនមិនទាន់ត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ មួយទៀត បណ្ដាភិក្ខុទាំងនោះ ពួកភិក្ខុណា ជាអរហន្តខីណាស្រព ប្រព្រឹត្តព្រហ្មចរិយធម៌ចប់ហើយ មានសោឡសកិច្ចធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ បានសម្រេចប្រយោជន៍របស់ខ្លួនដោយលំដាប់ហើយ មានធម៌ជាគ្រឿងប្រកបសត្វក្នុងភពអស់ហើយ មានចិត្តផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃ ភិក្ខុទាំងនោះ បានស្ដាប់ធម៌នោះហើយ រមែងប្រកបរឿយៗ នូវធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ។ ម្នាលអាវុសោទាំងឡាយ នេះជាអានិសង្សទី ៥ ក្នុងការស្ដាប់ធម៌តាមកាលគួរ ក្នុងការសាកច្ឆាធម៌តាមកាលគួរ ។ ម្នាលអាវុសោទាំងឡាយ នេះជាអានិសង្ស ៥ ប្រការ ក្នុងការស្ដាប់ធម៌តាមកាល

*គួរ ក្នុងការសាកច្ឆាធម៌តាមកាលគួរ ។*

# អដ្ឋកថា

## ឆន្ទកសូត្រ

[ ៤ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងនន្ទកសូត្រទី ៤ ដូចតទៅនេះ បទថា* **ឧបដ្ឋានសាលាយំ** *បានដល់ រោងឆាន់ ។ បទថា* **យេនុបដ្ឋានសាលា** *ធម្មតា ព្រះសាស្តាស្តាប់សំឡេងនូវការសម្តែងធម៌ ដែលព្រះនន្ទកត្ថេរផ្តើមហើយ ដោយសំឡេងដ៏ពីរោះ ទើបត្រាស់សួរថា អានន្ទ នុ៎ះ អ្នកណាសម្តែងធម៌ដោយសំឡេងដ៏ពីរោះក្នុងឧបដ្ឋានសាលា ទ្រង់បានឮថា បពិត្រព្រះអង្គដ៏ចម្រើន ថ្ងៃនេះ ជាវារៈរបស់ពួកនន្ទកត្ថេរ ដែលជាធម្មកថិក បានត្រាស់ថា អានន្ទ ភិក្ខុនោះសម្តែងធម៌ពីរោះពន់ពេក តថាគតនឹងទៅស្តាប់ដូច្នេះ ទើបចូលទៅកាន់ឧបដ្ឋានសាលា ។ បទថា* **ឧបសង្កមិត្វា ពហិទ្វារ-កោដ្ឋកេ អដ្ឋាសិ** *បានដល់ ទ្រង់បិទបាំងឆព្វណ្ណរង្សីក្នុងស្រទាប់ចីវរ ហើយប្រថាប់ឈរដោយភេទ ដែលបុគ្គលណាមួយមិនស្គាល់ ។ បទថា* **កថា-បរិយោសានំ អាគមយមានោ** *សេចក្តីថា ប្រថាប់ឈរស្តាប់ធម្មកថា ដល់កថាចុងក្រោយថា* **ឥធមហោច** *ដូច្នេះ ។ គ្រានោះ ព្រះអានន្ទបានទូលថ្វាយសញ្ញាដល់ព្រះសាស្តា កាលកន្លងបឋមយាមទៅហើយថា បពិត្រព្រះអង្គដ៏*

ចម្រើន បឋមយាមកន្លងទៅហើយ សូមទ្រង់សម្រាកបន្តិច ដូច្នេះ ។ ព្រះសាស្តាប្រថាប់ឈរក្នុងទីនោះឯង ក្នុងកាលបន្ទាប់មក កាលវំលងមជ្ឈិមយាមទៅហើយ ព្រះអានន្ទបានក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់ជាខត្តិយ-សុខុមាលជាតិ ទ្រង់ជាពុទ្ធសុខុមាលជាតិ ទ្រង់ជាសុខុមាលជាតិដ៏ក្រៃលែង សូម្បីមជ្ឈិមយាមក៏កន្លងទៅហើយ សូមទ្រង់សម្រាកមួយស្របក់ ដូច្នេះ ។ ព្រះសាស្តាប្រថាប់ឈរក្នុងទីនោះឯង ។ អរុណាប្រាកដហើយដល់ព្រះសាស្តាអង្គនោះ ទ្រង់ប្រថាប់ឈរនោះឯង ។ អរុណរះក្តី ការចប់កថាដល់បទថា **ឥធមហោច** របស់កថាក្តី ការបញ្ចេញធព្វណ្ណរង្សីរបស់ព្រះទសពលក្តី មានដំណាលគ្នាក្នុងគ្រានោះឯង ។ បទថា **អគ្គឡំ អាកោដេសិ** បានដល់ ទ្រង់យកចុងព្រះនខាទោះសន្ទះទ្វារ ។

បទថា **សារជ្ជមានរូបោ** បានដល់ ខ្មាស ខ្មាចក្រែង ញាប់ញ័រ ឯព្រះនន្ទុកត្ថេរនោះ មិនមានការតក់ស្លុត ដោយការខូចចិត្ត ។ បទថា **ឃត្តកំបិ នោ នប្បដិភាសេយ្យ** សេចក្តីថា បុគ្គលណាបានបដិសម្ភិទា ឈ្មោះថាអស់បដិភាណ រមែងមិនមាន តែលោកសម្តែងថា អញមិនគប្បីពោលពាក្យប្រមាណប៉ុណ្ណេះ ។ បទថា **សាធុ សាធុ** បានដល់ ទ្រង់ត្រេកអរនឹងការសម្តែងរបស់ព្រះថេរៈ ទើបត្រាស់ហើយ ។ ក្នុងសេចក្តីនេះ មានអត្ថដូច្នេះថា ធម្មទេសនា អ្នកកាន់យកសេចក្តីបានល្អ និងសម្តែងបានល្អហើយ ដូច្នេះ ។ បទថា **កុលបុត្តានំ** បានដល់ កុលបុត្រមានមារយាទ និងកុលបុត្រមានជាតិ

ត្រកូល ។ បទថា **អរិយោ វា តុណ្ហីភាវោ** បានដល់ ត្រាស់សំដៅយក សមាបត្តិក្នុងទុតិយជ្ឈាន ។

បទថា **អធិប្បញ្ញាធម្មវិបស្សនាយ** បានដល់ វិបស្សនាញាណកំណត់ សង្ខារ ។ បទថា **ចតុប្បាទកោ** បានដល់ ប្រៀបដូចសត្វ មានសេះ គោ និងលាជាដើម ។ បទថា **ឥធំ វត្វា** បានដល់ ត្រាស់ធម៌នេះ ប្រកបដោយ អង្គ ៤ ។ បទថា **វិហារំ ចាវិសិ** បានដល់ យាងចូលទៅកាន់ព្រះគន្ធកុដិ ។

បទថា **កាលេន ធម្មស្សវនេ** បានដល់ ក្នុងការស្តាប់ធម៌តាមកាល ។ បទថា **ធម្មសាកច្ឆាយ** បានដល់ ក្នុងការពោលសួរគ្នា ។ បទថា **គម្ភីរំ អត្ថបទំ** បានដល់ អត្ថដែលជ្រាលជ្រៅ គឺកំបាំង ។ បទថា **បញ្ញាយ** បាន ដល់ មគ្គប្បញ្ញា មួយអន្លើដោយវិបស្សនា បញ្ញាដែលដឹងច្បាស់ ចាក់ធ្លុះ ដោយការពិចារណាក្តី បញ្ញាដែលកើតអំពីការរៀន និងការសាកសួរក្តី រមែង គួរទាំងអស់ ។ បទថា **បត្តោ វា គច្ឆតិ វា** សេចក្តីថា បុគ្គលនោះ រមែង សរសើរដោយការសរសើរគុណយ៉ាងនេះថា លោកម្ចាស់អង្គនេះសម្រេច ហើយ ឬនឹងសម្រេចអរហត្ត ដូច្នេះ ។ បទថា **អប្បត្តមានសា** បានដល់ ឈ្មោះថា **អប្បត្តមានសា** ព្រោះមិនទាន់សម្រេចអរហត្ត ឬពួកភិក្ខុទាំងនោះ មានចិត្តមិនសម្រេចអរហត្ត ដូច្នេះក៏មាន ។ ក្នុងបទថា **ទិដ្ឋធម្មសុខវិហារំ** នេះ បានដល់ ធម៌ដែលជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ជាលោកិយផង លោកុត្តរផង រមែងគួរ ។៚

# សុត្តន្តបិដក

## ពលសូត្រទី ៥

[ ៥ ] ម្នាលភិក្ខុទាំងឡាយ ពលនេះមាន ៤ យ៉ាង ។ ពល ៤ យ៉ាង តើដូចម្ដេច ។ គឺបញ្ញាពល ១ វិរិយពល ១ អនវជ្ជពល ១ សង្គហពល ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបញ្ញាពល តើដូចម្ដេច ។ ធម៌ទាំងឡាយណា ជាកុសល រាប់ថាជាកុសល ធម៌ទាំងឡាយណា ជាអកុសល រាប់ថាជាអកុសល ធម៌ទាំងឡាយណា មានទោស រាប់ថាមានទោស ធម៌ទាំងឡាយណា មិនមានទោស រាប់ថាមិនមានទោស ធម៌ទាំងឡាយណា ជាធម៌ខ្មៅ រាប់ថាជាធម៌ខ្មៅ ធម៌ទាំងឡាយណា ជាធម៌ស រាប់ថាជាធម៌ស ធម៌ទាំងឡាយណាមិនគួរសេព រាប់ថាជាធម៌មិនគួរសេព ធម៌ទាំងឡាយគួរសេព រាប់ថាជាធម៌គួរសេព ធម៌ទាំងឡាយណា មិនគួរដល់ព្រះអរិយៈ រាប់ថាជាធម៌មិនគួរដល់ព្រះអរិយៈ ធម៌ទាំងឡាយណាគួរដល់ព្រះអរិយៈ រាប់ថាជាធម៌គួរដល់ព្រះអរិយៈ ធម៌ទាំងនោះ បុគ្គលឃើញច្បាស់ សួនចុះដោយបញ្ញាតាមពិត ម្នាលភិក្ខុទាំងឡាយ នេះហៅថា បញ្ញាពល ។ ម្នាលភិក្ខុទាំងឡាយ ចុះវិរិយពល តើដូចម្ដេច ។ ធម៌ទាំងឡាយណា ជាអកុសល រាប់ថាជាអកុសល ធម៌ទាំងឡាយណា មានទោស រាប់ថាជាធម៌មានទោស ធម៌ទាំងឡាយណា ជាធម៌ខ្មៅ រាប់ថាជាធម៌ខ្មៅ ធម៌ទាំងឡាយណា មិនគួរសេព រាប់ថាជាធម៌មិនគួរសេព ធម៌ទាំងឡាយណា មិនគួរដល់ព្រះអរិយៈ រាប់ថាជាធម៌មិនគួរដល់ព្រះអរិយៈ បុគ្គលក៏បានញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង

ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីលះបង់នូវធម៌ទាំងនោះ ។ ធម៌ទាំងឡាយណាជាកុសល រាប់ថាជាកុសល ធម៌ទាំងឡាយណាមិនមានទោស រាប់ថាជាធម៌ មិនមានទោស ធម៌ទាំងឡាយណា ជាធម៌ស រាប់ថាជាធម៌ស ធម៌ទាំងឡាយណា គួរសេព រាប់ថាជាធម៌គួរសេព ធម៌ទាំងឡាយណា គួរដល់ព្រះអរិយៈ រាប់ថាជាធម៌គួរដល់ព្រះអរិយៈ បុគ្គលក៏បានញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្តដើម្បីឲ្យបាននូវធម៌ទាំងនោះ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វិរិយពល ។ ម្នាលភិក្ខុទាំងឡាយ ចុះអនវជ្ជពល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកប្រកបដោយកាយកម្មមិនមានទោស ប្រកបដោយវចីកម្មមិនមានទោស ប្រកបដោយមនោកម្មមិនមានទោស ម្នាលភិក្ខុទាំងឡាយ នេះហៅថា អនវជ្ជពល ។ ម្នាលភិក្ខុទាំងឡាយ ចុះសង្គហពល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សង្គហវត្ថុនេះមាន ៤ យ៉ាង គឺការឲ្យទាន ១ ការពោលពាក្យជាទីស្រឡាញ់ ១ ការប្រព្រឹត្តអំពើឲ្យជាប្រយោជន៍ ១ ភាពជាអ្នកតាំងខ្លួនស្មើ ១ ម្នាលភិក្ខុទាំងឡាយ បណ្តាទានទាំងឡាយ ទានដែលប្រសើរបំផុតនោះ គឺធម្មទាន ម្នាលភិក្ខុទាំងឡាយ បណ្តាការពោលពាក្យជាទីស្រឡាញ់ទាំងឡាយ ការពោលពាក្យជាទីស្រឡាញ់ដ៏ប្រសើរបំផុតនោះ គឺធម្មកថិកសម្តែងធម៌រឿយៗ ដល់អ្នកត្រូវការស្តាប់ អ្នកផ្ទៀងត្រចៀកស្តាប់ ម្នាលភិក្ខុទាំងឡាយ បណ្តាការប្រព្រឹត្តអំពើឲ្យជាប្រយោជន៍ទាំងឡាយ ការប្រព្រឹត្ត

អំពើ ឲ្យជាប្រយោជន៍ដ៏ប្រសើរនោះ គឺបុគ្គលអ្នកញ៉ាំងជនមិនមានសទ្ធា ឲ្យកាន់យក ឲ្យតាំងនៅ ឲ្យតម្កល់ស៊ប់ក្នុងសទ្ធាសម្បទា ញ៉ាំងជនទ្រុស្តសីល ឲ្យកាន់យក ឲ្យតាំងនៅ ឲ្យតម្កល់ស៊ប់ក្នុងសីលសម្បទា ញ៉ាំងជនអ្នកមានសេចក្ដីកំណាញ់ ឲ្យកាន់យក ឲ្យតាំងនៅ ឲ្យតម្កល់ស៊ប់ក្នុងចាគសម្បទា ញ៉ាំងជនអ្នកមិនមានបញ្ញា ឲ្យកាន់យក ឲ្យតាំងនៅ ឲ្យតម្កល់ស៊ប់ក្នុងបញ្ញាសម្បទា ម្នាលភិក្ខុទាំងឡាយ បណ្ដាភាពជាអ្នកតាំងខ្លួនស្មើទាំងឡាយ ភាពជាអ្នកតាំងខ្លួនស្មើដ៏ប្រសើរនោះ គឺសោតាបន្នបុគ្គល មានខ្លួនស្មើនឹងសោតាបន្នបុគ្គល សកទាគាមិបុគ្គល មានខ្លួនស្មើនឹងសកទាគាមិបុគ្គល អនាគាមិបុគ្គល មានខ្លួនស្មើនឹងអនាគាមិបុគ្គល អរហន្ត មានខ្លួនស្មើនឹងអរហន្ត ម្នាលភិក្ខុទាំងឡាយ នេះហៅថា សង្គហពល ។ ម្នាលភិក្ខុទាំងឡាយ ពលមាន ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ប្រកបដោយពល ៤ យ៉ាងនេះហើយ រមែងជាអ្នកឆ្លងផុតភ័យ ៥ យ៉ាង ។ ភ័យ ៥ យ៉ាង តើដូចម្ដេច ។ គឺអាជីវិតភយៈ ( ភ័យអំពីការចិញ្ចឹមជីវិត ) ១ អសិលោកភយៈ ( ភ័យអំពីការមិនសរសើរ ) ១ បរិសំសារជ្ជភយៈ ( ភ័យអំពីការកោតញញើតក្នុងបរិសទ្យ ) ១ មរណភយៈ ( ភ័យអំពីការស្លាប់ ) ១ ទុគ្គតិភយៈ ( ភ័យអំពីទុគ្គតិ ) ១ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកនោះ ពិចារណាដូច្នេះថា អាត្មាអញមិនខ្លាចចំពោះអាជីវិតភ័យ អាត្មាអញនឹងខ្លាចអាជីវិតភ័យដូចម្ដេច បើពលទាំង ៤ គឺបញ្ញាពល វិរិយពល អន-

វជ្ជពល សង្គហពលរបស់អាត្មាអញ មានស្រេចហើយ ។ ឯបុគ្គលគ្មានប្រាជ្ញា គប្បីខ្លាចអាជីវិតភ័យ បុគ្គលខ្ជិល គប្បីខ្លាចអាជីវិតភ័យ គប្បីខ្លាចអាជីវិតភ័យដោយកាយកម្ម វចីកម្ម មនោកម្ម ដែលមានទោស បុគ្គលជាអ្នកមិនសង្គ្រោះ គប្បីខ្លាចអាជីវិតភ័យ អាត្មាអញមិនខ្លាចអសិលោកភ័យទេ ។បេ។ អាត្មាអញមិនខ្លាចបរិសំសារជ្ជភ័យទេ អាត្មាអញមិនខ្លាចមរណ-ភ័យទេ អាត្មាអញមិនខ្លាចទុគ្គតិភ័យទេ អាត្មាអញនឹងខ្លាចទុគ្គតិភ័យដូចម្តេចបើពលទាំង ៤ គឺបញ្ញាពល វីរិយពល អនវជ្ជពល សង្គហពល របស់អាត្មាអញ មានស្រេចហើយ ។ ឯបុគ្គលគ្មានប្រាជ្ញា គប្បីខ្លាចទុគ្គតិភ័យ បុគ្គលខ្ជិល គប្បីខ្លាចទុគ្គតិភ័យ គប្បីខ្លាចទុគ្គតិភ័យដោយកាយកម្ម វចីកម្ម មនោកម្ម ដែលមានទោស បុគ្គលមិនមានសេចក្តីសង្គ្រោះ គប្បីខ្លាចទុគ្គតិ-ភ័យ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ប្រកបដោយពល ៤ យ៉ាងនេះឯង ជាអ្នកកន្លងផុតនូវភ័យទាំង ៥ នេះបាន ។

# អដ្ឋកថា

## ពលសូត្រ

[ ៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងពលសូត្រទី ៥ ដូចតទៅនេះ គប្បីឃើញបញ្ញាពលជាដើម ព្រោះមិនញាប់ញ័រក្នុងអវិជ្ជា ការខ្ជិលច្រអូស ការពោលទោស និងការមិនជឿ ។ បទថា **អកុសលសង្ខាតា** បានដល់ ដឹងថា ជាអកុសល ក្នុងបទទាំងពួង ក៏មានន័យដូច្នេះ ។ បទថា **នាលមរិយ** បានដល់ ធម៌ដែលមិនអាចធ្វើនូវភាពជាព្រះអរិយៈ ឬមិនសមគួរដល់ព្រះអរិយៈ ។ បទថា **វោទិដ្ឋា** បានដល់ ធម៌ដែលបុគ្គលឃើញហើយដោយល្អ ។ បទថា **វោចរិតា** បានដល់ ធម៌ដែលប្រាកដនៅក្នុងមនោទ្វារ ។ បទថា **អត្ថិកស្ស** បានដល់ ដែលត្រូវការដោយការសម្តែងធម៌ ។ បទថា **អាជីវិតភយំ** បានដល់ ភ័យដែលប្រព្រឹត្តទៅក្នុងជីវិត ។ បទថា **អសិលោកភយំ** បានដល់ ភ័យកើតអំពីការតិះដៀល ។ បទថា **បរិសសារជ្ជភយំ** បានដល់ ភ័យដែលដល់បរិស័ទ ហើយកើតការញាប់ញ័រ ។ ក្នុងសូត្រនេះ លោកពោលវដ្តៈផង វិវដ្តៈផង ៕

**អដ្ឋកថា ពលសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## សេវនាសូត្រទី ៦

[ ៦ ] ក្នុងទីនោះឯង ព្រះសារីបុត្តដ៏មានអាយុ ហៅភិក្ខុទាំងឡាយថា ។បេ។ ព្រះសារីបុត្តដ៏មានអាយុ បានពោលដូច្នេះថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីស្គាល់បុគ្គល ២ ពួក គឺបុគ្គលគួរសេពគប់ ១ បុគ្គលមិនគួរសេពគប់ ១ ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីស្គាល់ចីវរ ២ យ៉ាង គឺចីវរគួរប្រើប្រាស់ ១ មិនគួរប្រើប្រាស់ ១ ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីស្គាល់បិណ្ឌបាត ២ យ៉ាង គឺបិណ្ឌបាតគួរសេព ១ មិនគួរសេព ១ ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីស្គាល់សេនាសនៈ ២ យ៉ាង គឺសេនាសនៈគួរសេព ១ មិនគួរសេព ១ ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីស្គាល់ស្រុក និងនិគម ២ យ៉ាង គឺស្រុក និងនិគម គួរសេព ១ មិនគួរសេព ១ ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីស្គាល់ជនបទ និងប្រទេស ២ យ៉ាង គឺជនបទ និងប្រទេសដែលគួរសេព ១ មិនគួរសេព ១ ។ ក៏ពាក្យថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីស្គាល់បុគ្គល ២ ពួក គឺបុគ្គលគួរសេព ១ មិនគួរសេព ១ ដូច្នេះនេះ ដែលខ្ញុំពោលហើយ ពាក្យដែលខ្ញុំពោលហើយនុ៎ះ តើព្រោះអាស្រ័យហេតុដូចម្តេច ។ បណ្តាបុគ្គលទាំង ២ ពួកនោះ បើបុគ្គលស្គាល់បុគ្គលណាថា កាលបើអាត្មាអញសេពគប់បុគ្គលនេះ អកុសលធម៌ទាំងឡាយ តែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងវិនាសទៅ មួយ

ទៀត គ្រឿងបម្រុងជីវិតទាំងឡាយណា គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ដែលអាត្មាអញជាបព្វជិតត្រូវប្រមូលមក ក៏គ្រឿងបម្រុងជីវិតទាំងនោះ តែងមូលមកបានដោយក្រ មួយទៀត អាត្មាអញចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ដល់ប្រយោជន៍នៃសមណៈណា ប្រយោជន៍នៃសមណៈនោះ មិនដល់នូវការបរិបូណ៌ដោយភាវនា ដល់អាត្មាអញដូច្នេះ ម្នាលអាវុសោទាំងឡាយ បុគ្គលអ្នកសេពគប់នោះ លុះដឹងក្នុងចំណែករាត្រីក្ដី ក្នុងចំណែកថ្ងៃក្ដី មិនគប្បីលាហើយចៀសចេញទៅ ឬក៏មិនគប្បីជាប់តាមបុគ្គលមិនគួរសេពគប់នោះឡើយ ។ បណ្ដាបុគ្គលទាំង ២ ពួកនោះ បុគ្គលស្គាល់បុគ្គលណាថា កាលបើអាត្មាអញសេពគប់បុគ្គលនេះ អកុសលធម៌ទាំងឡាយ តែងវិនាសទៅ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង មួយទៀត គ្រឿងបម្រុងជីវិតទាំងឡាយណា គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ដែលអាត្មាអញជាបព្វជិតត្រូវប្រមូលមក ក៏គ្រឿងបម្រុងជីវិតទាំងនោះ តែងមូលមកបានដោយងាយ មួយទៀត អាត្មាអញចេញចាកផ្ទះចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ដល់ប្រយោជន៍នៃសមណៈណា ប្រយោជន៍នៃសមណៈនោះ ដល់នូវការបរិបូណ៌ដោយភាវនា ដល់អាត្មាអញដូច្នេះ ម្នាលអាវុសោទាំងឡាយ បុគ្គលនោះ បើស្គាល់ហើយ គប្បីជាប់តាមបុគ្គលនោះ មិនគប្បីចៀសចេញទៅដរាបដល់អស់ជីវិតឡើយ ។ បណ្ដាបុគ្គលទាំង ២ ពួកនោះ បុគ្គលស្គាល់បុគ្គលណា

ថា កាលអាត្មាអញសេពគប់បុគ្គលនេះ អកុសលធម៌ទាំងឡាយ តែងវិនាសទៅ កុសលធម៌ទាំងឡាយតែងចម្រើនឡើង មួយទៀត គ្រឿងបម្រុងជីវិតទាំងឡាយណា គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ដែលអាត្មាអញជាបព្វជិតត្រូវប្រមូលមក ក៏គ្រឿងបម្រុងជីវិតទាំងនោះ មូលមកបានដោយងាយ មួយទៀត អាត្មាអញចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ដល់ប្រយោជន៍នៃសមណៈណា ប្រយោជន៍នៃសមណៈនោះ តែងដល់នូវការបរិបូណ៌ដោយភាវនា ដល់អាត្មាអញដូច្នេះ ម្នាលអាវុសោទាំងឡាយ បុគ្គលនោះ គប្បីជាប់តាមបុគ្គលនោះ មិនគប្បីចៀសចេញទៅដរាបដល់អស់ជីវិតឡើយ ។ បណ្ដាបុគ្គលទាំង ២ ពួកនោះ បុគ្គលស្គាល់បុគ្គលណាថា កាលអាត្មាអញសេពគប់បុគ្គលនេះ អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង មួយទៀត គ្រឿងបម្រុងជីវិតទាំងឡាយណា គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្ប-ច្ចយភេសជ្ជបរិក្ខារ ដែលអាត្មាអញជាបព្វជិតត្រូវប្រមូលមក ក៏គ្រឿងបម្រុងជីវិតទាំងនោះមូលមកបានដោយងាយ មួយទៀត អាត្មាអញចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ដល់ប្រយោជន៍នៃសមណៈណា ប្រយោជន៍នៃសមណៈនោះ តែងដល់នូវការបរិបូណ៌ដោយភាវនា ដល់អាត្មាអញដូច្នេះ ម្នាលអាវុសោទាំងឡាយ បុគ្គលនោះ ទោះបីត្រូវគេបណ្ដេញចេញ គប្បីជាប់តាមបុគ្គលនោះ មិនគប្បីចៀសចេញទៅដរាបដល់អស់ជីវិតឡើយ ។ ពាក្យ

ណាថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីស្គាល់បុគ្គល ២ ពួក គឺបុគ្គលគួរសេព ១ មិនគួរសេព ១ ដូច្នេះ ដែលខ្ញុំពោលហើយ ពាក្យដែលខ្ញុំពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុនេះ ។ ក៏ពាក្យថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយគប្បីស្គាល់ចីវរ ២ យ៉ាង គឺចីវរគួរប្រើប្រាស់ ១ មិនគួរប្រើប្រាស់ ១ ដូច្នេះនេះ ដែលខ្ញុំពោលហើយ ពាក្យដែលខ្ញុំពោលហើយនុ៎ះ តើព្រោះអាស្រ័យហេតុដូចម្តេច ។ បណ្តាចីវរទាំង ២ យ៉ាងនោះ ភិក្ខុស្គាល់ចីវរណាថា កាលអាត្មាអញប្រើប្រាស់ចីវរនេះហើយ អកុសលធម៌ទាំងឡាយ តែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ ដូច្នេះ ចីវរបែបនេះ ភិក្ខុមិនគួរប្រើប្រាស់ឡើយ ។ បណ្តាចីវរទាំង ២ យ៉ាងនោះ ភិក្ខុស្គាល់ចីវរបែបណាថា កាលបើអាត្មាអញប្រើប្រាស់ចីវរនេះ អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង ដូច្នេះ ចីវរបែបនេះ ភិក្ខុគួរប្រើប្រាស់បាន ។ ពាក្យណាថា ម្នាលអាវុសោទាំងឡាយ ភិក្ខុត្រូវស្គាល់ចីវរមាន ២ យ៉ាង គឺចីវរគួរប្រើប្រាស់ ១ មិនគួរប្រើប្រាស់ ១ ដូច្នេះ ដែលខ្ញុំពោលហើយ ពាក្យដែលខ្ញុំពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុនេះ ។ ក៏ពាក្យថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីស្គាល់បិណ្ឌបាត ២ យ៉ាង គឺបិណ្ឌបាតគួរសេព ១ មិនគួរសេព ១ ដូច្នេះនេះ ដែលខ្ញុំពោលហើយ ពាក្យដែលខ្ញុំពោលហើយនោះ តើព្រោះអាស្រ័យហេតុដូចម្តេច ។ បណ្តាបិណ្ឌបាតទាំង ២

យ៉ាងនោះ ភិក្ខុស្គាល់បិណ្ឌបាតណាថា កាលបើអាត្មាអញសេពនូវបិណ្ឌបាតនេះ អកុសលធម៌ទាំងឡាយ តែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ ដូច្នេះ បិណ្ឌបាតបែបនេះ ភិក្ខុមិនគួរសេពឡើយ ។ បណ្តាបិណ្ឌបាតទាំង ២ យ៉ាងនោះ ភិក្ខុស្គាល់បិណ្ឌបាតណាថា កាលបើអាត្មាអញសេពនូវបិណ្ឌបាតនេះ អកុសលធម៌ទាំងឡាយតែងសាបសូន្យទៅ កុសលធម៌ទាំងឡាយតែងចម្រើនឡើងដូច្នេះ បិណ្ឌបាតបែបនេះ ភិក្ខុគួរសេពបាន ។ ពាក្យណាថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីស្គាល់បិណ្ឌបាត ២ យ៉ាង គឺបិណ្ឌបាតគួរសេព ១ មិនគួរសេព ១ ដូច្នេះ ដែលខ្ញុំពោលហើយ ពាក្យដែលខ្ញុំពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុនោះ ។ ក៏ពាក្យថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីស្គាល់សេនាសនៈ ២ យ៉ាង គឺសេនាសនៈគួរសេព ១ មិនគួរសេព ១ ដូច្នេះនេះ ដែលខ្ញុំពោលហើយ ពាក្យដែលខ្ញុំពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុដូចម្តេច ។ បណ្តាសេនាសនៈទាំង ២ យ៉ាងនោះ ភិក្ខុស្គាល់សេនាសនៈណាថា កាលបើអាត្មាអញសេពសេនាសនៈនេះ អកុសលធម៌ទាំងឡាយតែងចម្រើនឡើង កុសលធម៌ទាំងឡាយតែងសាបសូន្យទៅ ដូច្នេះ សេនាសនៈបែបនេះ ភិក្ខុមិនគួរសេពឡើយ ។ បណ្តាសេនាសនៈទាំង ២ យ៉ាងនោះ ភិក្ខុស្គាល់សេនាសនៈណាថា កាលបើអាត្មាអញសេពសេនាសនៈនេះហើយ អកុសលធម៌ទាំងឡាយតែងសាបសូន្យទៅកុសលធម៌ទាំងឡាយតែងចម្រើនឡើង ដូច្នេះ សេនាសនៈ

បែបនេះ ភិក្ខុគួរសេពបាន ។ ក៏ពាក្យណាថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយគប្បីស្គាល់សេនាសនៈមាន ២ យ៉ាង គឺសេនាសនៈគួរសេព ១ មិនគួរសេព ១ ដូច្នេះ ដែលខ្ញុំពោលហើយ ពាក្យដែលខ្ញុំពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុនេះ ។ ក៏ពាក្យថា ម្នាលអាវុសោទាំងឡាយ អ្នកទាំង-ឡាយ គប្បីស្គាល់ស្រុក និងនិគម ២ យ៉ាង គឺស្រុក និងនិគមគួរសេព ១ មិនគួរសេព ១ ដូច្នេះនេះ ដែលខ្ញុំពោលហើយ ពាក្យដែលខ្ញុំពោលហើយនុ៎ះ តើព្រោះអាស្រ័យហេតុដូចម្ដេច ។ បណ្ដាស្រុក និងនិគមទាំង ២ យ៉ាងនោះ ភិក្ខុស្គាល់ស្រុក និងនិគមណាថា កាលបើអាត្មាអញសេពស្រុក និងនិគមនេះ អកុសលធម៌ទាំងឡាយ តែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ ដូច្នេះ ស្រុក និងនិគមបែបនេះ ភិក្ខុមិនគួរសេពឡើយ ។ បណ្ដាស្រុក និងនិគម ២ យ៉ាងនោះ ភិក្ខុស្គាល់ស្រុក និងនិគមណាថា កាលបើអាត្មាអញសេពស្រុក និងនិគមនេះ អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង ដូច្នេះ ស្រុក និងនិគមបែបនេះ ភិក្ខុគួរសេពបាន ។ ក៏ពាក្យណាថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយគប្បីស្គាល់ស្រុក និងនិគម ២ យ៉ាង គឺស្រុក និងនិគមគួរសេព ១ មិនគួរសេព ១ ដូច្នេះ ដែលខ្ញុំពោលហើយ ពាក្យនុ៎ះ ដែលខ្ញុំពោលហើយ ព្រោះអាស្រ័យហេតុនេះ ។ ក៏ពាក្យថា ម្នាលអាវុសោទាំងឡាយ អ្នកទាំង-ឡាយ គប្បីស្គាល់ជនបទ និងប្រទេស ២ យ៉ាង គឺជនបទ និងប្រទេស

ដែលគួរសេព ១ មិនគួរសេព ១ ដូច្នេះនេះ ដែលខ្ញុំពោលហើយ ពាក្យដែលខ្ញុំពោលហើយនុ៎ះ តើព្រោះអាស្រ័យហេតុដូចម្តេច ។ បណ្តាជនបទ និងប្រទេសទាំង ២ យ៉ាងនោះ ភិក្ខុស្គាល់ជនបទ និងប្រទេសណាថា កាលបើអាត្មាអញសេពជនបទ និងប្រទេសនេះ អកុសលធម៌ទាំងឡាយ តែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ ដូច្នេះ ជនបទ និងប្រទេសបែបនេះ ភិក្ខុមិនគួរសេពឡើយ ។ បណ្តាជនបទ និងប្រទេសទាំង ២ យ៉ាងនោះ ភិក្ខុស្គាល់ជនបទ និងប្រទេសណាថា កាលបើអាត្មាអញសេពនូវជនបទ និងប្រទេសនេះ អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនឡើងដូច្នេះ ជនបទ និងប្រទេសបែបនេះ ភិក្ខុគួរសេពបាន ។ ក៏ពាក្យណាថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយគប្បីស្គាល់ជនបទ និងប្រទេស ២ យ៉ាង គឺជនបទ និងប្រទេសដែលគួរសេព ១ មិនគួរសេព ១ ដូច្នេះ ដែលខ្ញុំពោលហើយ ពាក្យដែលខ្ញុំពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុនេះ ។

# អដ្ឋកថា

## សេវនាសូត្រ

[ ៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសេវនាសូត្រទី ៦ ដូចតទៅនេះ បទថា **ជីវិតបរិក្ខារា** បានដល់ ជាវត្ថុចម្រើនដោយជីវិត ។ បទថា **សមុទានេតព្វា** បានដល់ បព្វជិតគប្បីប្រមូលប្រមូល ។ បទថា **កសិរេន សមុទាគច្ឆន្តិ** បានដល់ រមែងកើតឡើងបានដោយសេចក្តីលំបាក ។ ក្នុងបទថា **រត្តិភាគំ វា ទិវសភាគំ វា** នេះ បុគ្គលនោះដឹងក្នុងកណ្តាលយប់ គប្បីចៀសចេញទៅក្នុងកណ្តាលយប់នោះឯង កាលអន្តរាយ មានសត្វសាហាវជាដើម មានក្នុងពេលយប់ គប្បីរង់ចាំឲ្យព្រះអាទិត្យរះឡើង ដឹងក្នុងពេលថ្ងៃ គប្បីចៀសចេញទៅក្នុងពេលថ្ងៃ កាលអន្តរាយមានក្នុងពេលថ្ងៃ គប្បីរង់ចាំដល់ព្រះអាទិត្យលិច ។ បទថា **សង្ខាបិ** បានដល់ ដឹងហេតុអាក្រក់ពេញដោយការនារបស់ភាពជាសមណៈ ។ ឯបទថា **សោ បុគ្គលោ** គប្បីសម្ពន្ធដោយបទនេះថា **នានុពន្ធិតព្វោ** ។ បទថា **អនាបុច្ឆា** សេចក្តីថា តែក្នុងទីនេះ គប្បីចៀសចេញទៅ មិនត្រូវលាបុគ្គលនោះ ។

បទថា **អបិ បនុជ្ជមានេន** បានដល់ ត្រូវប្រានចេញទៅ បុគ្គលបែបនេះ ដាក់ទោសឲ្យលើកបាច់ខ្សាច់ ១០០ បាច់ ក្អមទឹក ១០០ ក្អម ឬផ្ទាំងខ្សាច់ ១០០ ផ្ទាំង ឬបណ្តេញចេញទៅ ដោយពោលថា អ្នកកុំនៅក្នុងទីនេះ សូម្បីឲ្យបុគ្គលនោះសូមទោសហើយ គប្បីជាប់តាម គឺមិនគប្បីបោះបង់បុគ្គលនោះដរាបដល់អស់ជីវិត ៕៚

# សុត្តន្តបិដក

## សុតវាសូត្រទី ៧

[ ៧ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់លើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯង បរិព្វាជកឈ្មោះសុតវន្តុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះសុតវន្តុបរិព្វាជក អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន សម័យមួយ ខ្ញុំព្រះអង្គនៅក្នុងក្រុងរាជគ្រឹះ ដែលមានភ្នំ ( ព័ទ្ធជុំវិញ ) ដូចជាក្រោលនេះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានស្តាប់ចំពោះព្រះភក្ត្រ បានទទួលយកចំពោះព្រះភក្ត្រនៃព្រះដ៏មានព្រះភាគ ក្នុងទីនោះថា ម្នាលសុតវន្តុ ភិក្ខុណាជាអរហន្តខីណាស្រព មានព្រហ្មចរិយធម៌ បានប្រព្រឹត្តរួចហើយ មានសោឡសកិច្ចបានធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ មានធម៌ជាគ្រឿងប្រកបសត្វក្នុងភពអស់ហើយ ជាអ្នករួចស្រឡះព្រោះដឹងដោយប្រពៃ ភិក្ខុនោះ មិនគួរប្រព្រឹត្តកន្លងនូវហេតុ ៥ យ៉ាង គឺភិក្ខុជាខីណាស្រព មិនគួរក្លែងផ្តាច់បង់ជីវិតសត្វ ១ ភិក្ខុជាខីណាស្រព មិនគួរកាន់យកនូវវត្ថុដែលគេមិនបានឲ្យ ដែលហៅថាលួច ១ ភិក្ខុជាខីណាស្រព មិនគួរសេពមេថុនធម្ម ១ ភិក្ខុជាខីណាស្រព មិនគួរពោលពាក្យកុហកទាំងដឹងខ្លួន ១ ភិក្ខុជាខីណាស្រព មិនគួរធ្វើនូវការ

សន្សំទុក ហើយបរិភោគនូវកាមទាំងឡាយ ដូចជានៅជាគ្រហស្ថក្នុងកាលមុន ១ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានស្តាប់ល្អហើយ បានទទួលល្អហើយ បានធ្វើទុកក្នុងចិត្តល្អហើយ ចាំបានល្អហើយនូវព្រះពុទ្ធដីកា របស់ព្រះដ៏មានព្រះភាគនុ៎ះមែនឬ ។ អើ ពាក្យនុ៎ះ អ្នកស្តាប់ល្អហើយ រៀនល្អហើយ ធ្វើទុកក្នុងចិត្តល្អហើយ ចាំល្អហើយ ម្នាលសុតវន្ត ក្នុងកាលពីដើមក្តី ក្នុងកាលឥឡូវនេះក្តី តថាគតតែងពោលយ៉ាងនេះថា ភិក្ខុណា ជាអរហន្តខីណាស្រព មានព្រហ្មចរិយធម៌បានប្រព្រឹត្តរួចហើយ មានសោឡសកិច្ច បានធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ មានធម៌ជាគ្រឿងប្រកបសត្វក្នុងភពអស់ហើយ ជាអ្នករួចស្រឡះ ព្រោះដឹងដោយប្រពៃ ភិក្ខុនោះ មិនគួរប្រព្រឹត្តកន្លងនូវហេតុ ៩ យ៉ាង គឺភិក្ខុជាខីណាស្រព មិនគួរក្លែងផ្តាច់បង់ជីវិតសត្វ ១ ភិក្ខុជាខីណាស្រព មិនគួរកាន់យកនូវវត្ថុដែលគេមិនបានឲ្យ ដែលហៅថាលួច ១ ភិក្ខុជាខីណាស្រព មិនគួរសេពមេថុនធម្ម ១ ភិក្ខុជាខីណាស្រព មិនគួរពោលពាក្យកុហកទាំងដឹងខ្លួន ១ ភិក្ខុជាខីណាស្រព មិនគួរធ្វើនូវការសន្សំទុក ហើយបរិភោគនូវកាមទាំងឡាយ ដូចជានៅជាគ្រហស្ថក្នុងកាលមុន ១ ភិក្ខុជាខីណាស្រព មិនគួរលុះក្នុងឆន្ទាគតិ ១ ភិក្ខុជាខីណាស្រព មិនគួរលុះក្នុងទោសាគតិ ១ ភិក្ខុជាខីណាស្រព មិនគួរលុះក្នុងមោហាគតិ ១ ភិក្ខុជាខីណាស្រព មិនគួរលុះក្នុងភយាគតិ ១ ម្នាលសុតវន្ត ក្នុងកាលពីដើមក្តី ក្នុងកាលឥឡូវនេះក្តី តថាគត

តែងពោលយ៉ាងនេះថា ភិក្ខុណាជាអរហន្តខីណាស្រព ដែលមានព្រហ្មចរិយធម៌ បានប្រព្រឹត្តរួចហើយ មានសោឡសកិច្ច បានធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ មានធម៌ជាគ្រឿងប្រកបសត្វក្នុងភពអស់ហើយ ជាអ្នករួចស្រឡះ ព្រោះដឹងដោយប្រពៃ ភិក្ខុនោះ មិនគួរប្រព្រឹត្តកន្លងនូវហេតុទាំង ៩ យ៉ាងនេះ ។

# អដ្ឋកថា

## សុតវាសូត្រ

[ ៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសុតវាសូត្រទី ៧ ដូចតទៅនេះ បទថា **បញ្ច ឋានានិ អជ្ឈាចរិតុំ** បានដល់ ភិក្ខុមិនគួរកន្លងហេតុ ៥ ។ បទថា **ថាណំ** បានដល់ ដោយហោចស្រមោចខ្មៅ ស្រមោចក្រហម ។ បទថា **អទិន្នំ** បានដល់ របស់អ្នកដទៃ ដោយហោចសូម្បីស្មៅមួយសរសៃ ។ បទថា **ថេយ្យសង្ខាតំ** បានដល់ សូម្បីមានចិត្តលួច ។ បទថា **សន្និធិការកំ កាមេ បរិភុញ្ជិតុំ** បានដល់ មិនគួរធ្វើការសន្សំ គឺរៀបរិភោគវត្ថុកាម និងកិលេសកាម ។ សេចក្តីនោះ លោកពោលសំដៅយកកាមគុណដែលជាអកប្បិយ ។ បទថា **ពុទ្ធំ បច្ចក្ខាតុំ** បានដល់ ហាមយ៉ាងនេះថា បុគ្គលនេះ មិនមែនជាព្រះពុទ្ធ ដូច្នេះ ។ ក្នុងធម៌ជាដើម ក៏មានន័យនេះដូចគ្នា ។ សេចក្តី

នោះមកហើយ ក្នុងអដ្ឋកថាមុនយ៉ាងនេះ ចំណែកក្នុងបាលីក្នុងសូត្រនេះ លោកពោលដល់ការមិនលម្មៀង ។ល។

### អដ្ឋកថា សុតវាសូត្រទី ៧ ចប់

# សុត្តន្តបិដក

## សជ្ឈសូត្រទី ៨

[ ៨ ] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯង បរិព្វាជកឈ្មោះសជ្ឈៈ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះសជ្ឈបរិព្វាជក អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន សម័យមួយ ខ្ញុំព្រះអង្គនៅក្នុងក្រុងរាជគ្រឹះ ដែលមានភ្នំ ( ព័ទ្ធជុំវិញ ) ដូចជាក្រោលនេះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានស្តាប់ចំពោះព្រះភក្ត្រ បានទទួលយកចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគក្នុងទីនោះថា ម្នាលសជ្ឈៈ ភិក្ខុណាជាអរហន្តខីណាស្រព មានព្រហ្មចរិយធម៌ បានប្រព្រឹត្ត

រួចហើយ មានសោឡសកិច្ច បានធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ មានធម៌ជាគ្រឿងប្រកបសត្វក្នុងភព អស់ហើយ ជាអ្នករួចស្រឡះ ព្រោះដឹងដោយប្រពៃ ភិក្ខុនោះ មិនគួរប្រព្រឹត្ត កន្លងនូវហេតុ ៥ យ៉ាង គឺភិក្ខុជាខីណាស្រព មិនគួរក្លែងផ្តាច់បង់ជីវិតសត្វ ១ ភិក្ខុជាខីណាស្រព មិនគួរកាន់យកនូវវត្ថុដែលគេមិនបានឲ្យ ដែលហៅថា លួច ១ ភិក្ខុជាខីណាស្រព មិនគួរសេពនូវមេថុនធម្ម ១ ភិក្ខុជាខីណាស្រព មិនគួរពោលនូវពាក្យកុហកទាំងដឹងខ្លួន ១ ភិក្ខុជាខីណាស្រព មិនគួរធ្វើនូវការសន្សំទុក ហើយបរិភោគនូវកាមទាំងឡាយ ដូចជានៅជាគ្រហស្ថក្នុង កាលមុន ១ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានស្តាប់ល្អហើយ បាន ទទួលល្អហើយ បានធ្វើទុកក្នុងចិត្តល្អហើយ ចាំបានល្អហើយ នូវព្រះពុទ្ធដីកា នុ៎ះ របស់ព្រះដ៏មានព្រះភាគមែនឬ ។ ម្នាលសជ្ឈៈ អើ ពាក្យនោះ អ្នកបាន ស្តាប់ល្អហើយ បានទទួលល្អហើយ បានធ្វើទុកក្នុងចិត្តល្អហើយ បានចាំទុក ល្អហើយ ។ ម្នាលសជ្ឈៈ ក្នុងកាលពីដើមក្តី ឥឡូវនេះក្តី តថាគតក៏ពោល យ៉ាងនេះថា ភិក្ខុណា ជាអរហន្តខីណាស្រព ជាអ្នកមានព្រហ្មចរិយធម៌បាន ប្រព្រឹត្តរួចហើយ មានសោឡសកិច្ចបានធ្វើស្រេចហើយ មានភារៈដាក់ចុះ ហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ មានធម៌ជាគ្រឿងប្រកបសត្វ ក្នុងភពអស់ហើយ ជាអ្នករួចស្រឡះ ព្រោះដឹងដោយប្រពៃ ភិក្ខុនោះ មិនគួរ ប្រព្រឹត្តកន្លងនូវហេតុ ៩ យ៉ាង គឺភិក្ខុជាខីណាស្រព មិនគួរក្លែងផ្តាច់បង់

ជីវិតសត្វ ១ ។បេ។ ភិក្ខុជាខីណាស្រព មិនគួរធ្វើនូវការសន្សំទុក ហើយបរិភោគនូវកាមទាំងឡាយ ដូចជានៅជាគ្រហស្ថក្នុងកាលមុន ១ ភិក្ខុជាខីណាស្រព មិនគួរលះបង់ព្រះពុទ្ធ ១ ភិក្ខុជាខីណាស្រព មិនគួរលះបង់ព្រះធម៌ ១ ភិក្ខុជាខីណាស្រព មិនគួរលះបង់ព្រះសង្ឃ ១ ភិក្ខុជាខីណាស្រព មិនគួរលះបង់សិក្ខា ១ ម្នាលសជ្ឈៈ ក្នុងកាលពីដើមក្តី ឥឡូវនេះក្តី តថាគតក៏ពោលយ៉ាងនេះថា ភិក្ខុណាជាអរហន្តខីណាស្រព មានព្រហ្មចរិយធម៌បានប្រព្រឹត្តរួចហើយ មានសោឡសកិច្ចបានធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ មានធម៌ជាគ្រឿងប្រកបសត្វក្នុងភពអស់ហើយ ជាអ្នករួចស្រឡះ ព្រោះដឹងដោយប្រពៃ ភិក្ខុនោះមិនគួរប្រព្រឹត្តកន្លងនូវហេតុ ៩ យ៉ាងនេះ ។

# អដ្ឋកថា

## សជ្ឈសូត្រ

[ ៨ ] ក្នុងសជ្ឈសូត្រទី ៨ លោកពោលចំពោះព្រះសម្ពុទ្ធជាដើម ។

អដ្ឋកថាសជ្ឈសូត្រទី ៨ ចប់

# សុត្តន្តបិដក

## បុគ្គលសូត្រទី ៩

[ ៩ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៩ ពួកនេះ តែងមានប្រាកដក្នុងលោក ។ បុគ្គល ៩ ពួក តើដូចម្ដេច ។ គឺអរហន្ត ១ បុគ្គលប្រតិបត្តិដើម្បីអរហន្ត ១ អនាគាមិបុគ្គល ១ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ១ សកទាគាមិបុគ្គល ១ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ១ សោតាបន្នបុគ្គល ១ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ១ បុថុជ្ជន ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៩ ពួកនេះឯង តែងមានប្រាកដក្នុងលោក ។

# អដ្ឋកថា

## បុគ្គលសូត្រ

[ ៩ ] ក្នុងបុគ្គលសូត្រទី ៩ លោកពោលថា **អាហុនេយ្យា** ជាបុគ្គលគួរដល់របស់ដែលគេបូជា ។ល។

**អដ្ឋកថា បុគ្គលសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## អាហុនេយ្យសូត្រទី ១០

[ ១០ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៩ ពួកនេះ ជាអ្នកគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា គួរទទួលនូវអាគន្តុកទាន ដែលគេនាំមកដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ បុគ្គល ៩ ពួក តើដូចម្តេច ។ គឺអរហន្ត ១ បុគ្គលប្រតិបត្តិដើម្បីអរហត្ត ១ អនាគាមិបុគ្គល ១ បុគ្គលប្រតិបត្តិដើម្បី ធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ១ សកទាគាមិបុគ្គល ១ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ១ សោតាបន្នបុគ្គល ១ បុគ្គលអ្នកប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ១ គោត្រភូបុគ្គល ១ ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលទាំង ៩ ពួកនេះឯង ជាអ្នកគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។

### សម្ពោធវគ្គទី ១ ចប់

ឧទ្ទានក្នុងសម្ពោធវគ្គនោះគឺ

និយាយអំពីការត្រាស់ដឹង ១ អំពីនិស្ស័យ ១ អំពីមេឃិយត្ថេរ ១ អំពីនន្ទកត្ថេរ ១ អំពីពលៈ ១ អំពីការសេព ១ អំពីសុតវន្ត-បរិព្វាជក ១ អំពីសជ្ឈបរិព្វាជក ១ អំពីបុគ្គល ១ អំពីអាហុ-ណេយ្យបុគ្គល ១ ។

# អដ្ឋកថា

## អាហុនេយ្យសូត្រ

[ ១០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអាហុនេយ្យសូត្រទី ១០ ដូចតទៅនេះ បទថា **គោត្រភូ** បានដល់ ជាបុគ្គលប្រកបដោយវិបស្សនាចិត្ត ដែលមានកម្លាំងដល់ទីបំផុត ដោយអនន្តរប្បច្ច័យនៃសោតាបត្តិមគ្គ ។ បទដ៏សេសក្នុងវារៈទាំងពួង មានអត្ថងាយយល់ហើយ ៕

អដ្ឋកថា អាហុនេយ្យសូត្រទី ១០ ចប់

សម្មោធវគ្គទី ១ ចប់

# សុត្តន្តបិដក

# សីហនាទវគ្គ

## វុដ្ឋិសូត្រទី ១

[ ១១ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ព្រះសារីបុត្តដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ការនៅចាំវស្សាក្នុងក្រុងសាវត្ថី ខ្ញុំព្រះអង្គនៅរួចហើយ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គប្រាថ្នាដើម្បីទៅកាន់ចារិកក្នុងជនបទ ។ ព្រះអង្គត្រាស់ថា ម្នាលសារីបុត្ត អ្នកចូរសម្គាល់នូវការគួរក្នុងកាលឥឡូវនេះចុះ ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុនោះ ក្រោកចាកអាសនៈ ថ្វាយបង្គំលាព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។ លំដាប់នោះ កាលព្រះសារីបុត្តដ៏មានអាយុ ចៀសចេញទៅមិនយូរប៉ុន្មាន ភិក្ខុ ១ រូប បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះសារីបុត្តដ៏មានអាយុ បានប៉ះខ្ញុំព្រះអង្គ មិនបានខមាទោស ហើយចៀសចេញទៅកាន់ចារិក ។ លំដាប់នោះ ព្រះដ៏មានព្រះភាគត្រាស់ហៅភិក្ខុ ១ រូបមកថា ម្នាលភិក្ខុ អ្នកចូរមកអាយ ចូរទៅហៅ

សារីបុត្តតាមពាក្យតថាគតថា ម្នាលអាវុសោសារីបុត្ត ព្រះសាស្ដាទ្រង់ត្រាស់ហៅលោក ។ ភិក្ខុនោះទទួលព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ចូលទៅរកព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយបាននិយាយនឹងព្រះសារីបុត្តដ៏មានអាយុដូច្នេះថា ម្នាលអាវុសោសារីបុត្ត ព្រះសាស្ដាទ្រង់ត្រាស់ហៅលោក ។ ព្រះសារីបុត្តដ៏មានអាយុ ទទួលពាក្យភិក្ខុនោះថា ករុណាអាវុសោ ។ សម័យនោះឯង ព្រះមហាមោគ្គល្លានដ៏មានអាយុនិងព្រះអានន្ទដ៏មានអាយុ កាន់យកនូវកូនសោ ដើរចូលទៅកាន់វិហារហើយនិយាយថា លោកដ៏មានអាយុទាំងឡាយ ចូរទៅចាប់ លោកដ៏មានអាយុទាំងឡាយ ចូរទៅចាប់ ដ្បិតព្រះសារីបុត្តដ៏មានអាយុ នឹងបន្លឺនូវសីហនាទចំពោះព្រះភក្ត្រនៃព្រះដ៏មានព្រះភាគក្នុងកាលឥឡូវនេះ ។ គ្រានោះ ព្រះសារីបុត្តដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ បានត្រាស់ដូច្នេះថា ម្នាលសារីបុត្ត ក្នុងទីនោះ មានសព្រហ្មចារី ១ រូប អាក់អន់ចិត្តនឹងអ្នកថាបពិត្រព្រះអង្គដ៏ចម្រើន ព្រះសារីបុត្តដ៏មានអាយុ បានប៉ះខ្ញុំព្រះអង្គ មិនបានខមាទោស ហើយចៀសចេញទៅកាន់ចារិក ។ ព្រះសារីបុត្តក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាយគតាសតិ ដែលបុគ្គលណាមិនបានតាំងទុកក្នុងកាយហើយ បុគ្គលនោះ ប៉ះសព្រហ្មចារីណាមួយ ក្នុងលោកនេះ មិនបាន

ខមាទោស ហើយចៀសចេញទៅកាន់ចារិក បពិត្រព្រះអង្គដ៏ចម្រើន ពួកអ្នកផងដាក់វត្ថុស្អាតក្តី ដាក់វត្ថុមិនស្អាតក្តី ដាក់លាមកក្តី ដាក់មូត្រក្តី ដាក់ទឹកមាត់ក្តី ដាក់ខ្ទុះក្តី ដាក់ឈាមក្តី លើផែនដី ផែនដីមិនធុញទ្រាន់ មិនទៀយណាយ មិនខ្ពើមរអើម ដោយវត្ថុនោះទេ យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានចិត្តស្មើដោយផែនដី ជាចិត្តទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ យ៉ាងនោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន កាយគតាសតិ ដែលបុគ្គលណាមិនបានតាំងទុកហើយ ក្នុងកាយដោយពិត បុគ្គលនោះ ប៉ះសព្រហ្មចារីណាមួយ ក្នុងលោកនេះ មិនបានខមាទោស គប្បីចៀសចេញទៅកាន់ចារិក ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកអ្នកផង លាងវត្ថុស្អាតក្តី លាងវត្ថុមិនស្អាតក្តី លាងលាមកក្តី មូត្រក្តី ទឹកមាត់ក្តី ខ្ទុះក្តី ឈាមក្តី ក្នុងទឹក ទឹករមែងមិនធុញទ្រាន់ ឬទៀយណាយ ឬក៏ខ្ពើមរអើមដោយវត្ថុនោះទេ យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានចិត្តស្មើដោយទឹក ជាចិត្តធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ក៏យ៉ាងនោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន កាយគតាសតិ ដែលបុគ្គលណាមិនបានតាំងទុកហើយ ក្នុងកាយដោយពិត បុគ្គលនោះប៉ះសព្រហ្មចារីណាមួយក្នុងលោកនេះ មិនបានខមាទោស គប្បីចៀសចេញទៅកាន់ចារិក ។ បពិត្រព្រះអង្គដ៏ចម្រើន ភ្លើងតែងឆេះវត្ថុស្អាតក្តី ឆេះវត្ថុមិនស្អាតក្តី ឆេះលាមកក្តី មូត្រក្តី ទឹកមាត់ក្តី ខ្ទុះក្តី ឈាមក្តី ភ្លើងរមែងមិនធុញទ្រាន់ ឬទៀយណាយ

ឬក៏ខ្ពើមរអើមដោយវត្ថុនោះ យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានចិត្តស្មើដោយភ្លើង ជាចិត្តធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ក៏យ៉ាងនោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន កាយគតាសតិដែលបុគ្គលណាមិនបានតាំងទុកហើយក្នុងកាយ ដោយពិត បុគ្គលនោះប៉ះសព្រហ្មចារីណាមួយ ក្នុងលោកនេះហើយ មិនបានខមាទោស គប្បីចៀសចេញទៅកាន់ចារិក ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្យល់បក់វត្ថុស្អាតក្តី បក់វត្ថុមិនស្អាតក្តី បក់លាមកក្តី មូត្រក្តី ទឹកមាត់ក្តី ខ្ទុះក្តី ឈាមក្តី ខ្យល់រមែងមិនធុញទ្រាន់ ឬនឿយណាយ ឬក៏ខ្ពើមរអើមដោយវត្ថុនោះ យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានចិត្តស្មើដោយខ្យល់ ជាចិត្តធំទូលាយប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ក៏យ៉ាងនោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន កាយគតាសតិដែលបុគ្គលណា មិនបានតាំងទុកក្នុងកាយដោយពិត បុគ្គលនោះប៉ះសព្រហ្មចារីណាមួយ ក្នុងលោកនេះ មិនបានខមាទោស គប្បីចៀសចេញទៅកាន់ចារិក ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលជូតវត្ថុស្អាតក្តី ជូតវត្ថុមិនស្អាតក្តី ជូតលាមកក្តី មូត្រក្តី ទឹកមាត់ក្តី ខ្ទុះក្តី ឈាមក្តី ដោយសំពត់សម្រាប់ជូតធូលីៗ រមែងមិនធុញទ្រាន់ ឬនឿយណាយ ឬក៏ខ្ពើមរអើមនឹងវត្ថុនោះទេ យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានចិត្តស្មើដោយសំពត់សម្រាប់ជូតធូលី ជាចិត្តធំទូលាយប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ក៏យ៉ាងនោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន

កាយគតាសតិ ដែលបុគ្គលណា មិនបានតាំងទុកក្នុងកាយដោយពិត បុគ្គលនោះប៉ះសព្រហ្មចារីណាមួយ ក្នុងលោកនេះ មិនបានខមាទោស គប្បីចៀសចេញទៅកាន់ចារិក ។ បពិត្រព្រះអង្គដ៏ចម្រើន ចណ្ឌាលកុមារក្តី ចណ្ឌាលកុមារីក្តី មានដៃកាន់កញ្ជើ ស្លៀកពាក់សំពត់រេចជាយ ចូលទៅកាន់ស្រុកក្តី និគមក្តី រមែងដាក់ចិត្តឲ្យទាប ហើយចូលទៅ យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានចិត្តស្មើដោយចណ្ឌាលកុមារ ជាចិត្តធំទូលាយប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ក៏យ៉ាងនោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន កាយគតាសតិដែលបុគ្គលណា មិនបានតាំងទុកក្នុងកាយដោយពិត បុគ្គលនោះប៉ះសព្រហ្មចារីណាមួយ ក្នុងលោកនេះ មិនបានខមាទោស គប្បីចៀសចេញទៅកាន់ចារិក ។ បពិត្រព្រះអង្គដ៏ចម្រើន គោឧសភៈបាក់ស្នែងជាសត្វស្លូត ដែលគេទូន្មានហើយ បង្ហាត់ល្អហើយ ដើរទៅកាន់ប្រកតាមប្រក ដើរទៅកាន់ផ្លូវបែកតាមផ្លូវបែក មិនដែលបៀតបៀនអ្វីៗ ដោយជើងក្តី ដោយស្នែងក្តី យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានចិត្តស្មើដោយគោឧសភៈបាក់ស្នែង ជាចិត្តធំទូលាយប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ក៏យ៉ាងនោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន កាយគតាសតិដែលបុគ្គលណាមិនបានតាំងទុកហើយ ក្នុងកាយដោយពិត បុគ្គលនោះប៉ះសព្រហ្មចារីណាមួយ ក្នុងលោកនេះ មិនបានខមាទោស គប្បីចៀសចេញទៅកាន់ចារិក ។ បពិត្រព្រះអង្គដ៏ចម្រើន ស្ត្រី ឬបុរសកំលោះ ឬជំទង់

ប្រកបដោយជាតិជាអ្នកស្អិតស្អាង គប្បីធុញទ្រាន់ នឿយណាយ ខ្ពើមរអើម នឹងសាកសពពស់ ឬសាកសពកូនសុនខ ដែលជាប់ត្រង់ក យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គរមែងធុញទ្រាន់ នឿយណាយ ខ្ពើមរអើម នឹងកាយស្អុយនេះ ក៏យ៉ាងនោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន កាយគតា-សតិ ដែលបុគ្គលណាមិនបានតាំងទុកក្នុងកាយដោយពិត បុគ្គលនោះ ប៉ះសព្រហ្មចារីណាមួយ ក្នុងលោកនេះ មិនបានខមាទោស គប្បីចៀសចេញទៅកាន់ចារិក ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសរក្សាភាជនៈសម្រាប់ដាក់ខ្លាញ់ ដែលមានរន្ធតូច ធំ ហូរចេញចូល យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គរក្សានូវកាយនេះ ដែលមានរន្ធតូច ធំ ហូរចេញចូល ក៏យ៉ាងនោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន កាយគតាសតិ ដែលបុគ្គលណាមិនបានតាំងទុក ក្នុងកាយដោយពិត បុគ្គលនោះប៉ះសព្រហ្មចារីណាមួយក្នុងលោកនេះ មិនបានខមាទោស គប្បីចៀសចេញទៅកាន់ចារិក ។ លំដាប់នោះ ភិក្ខុនោះក្រោកចាកអាសនៈ ធ្វើសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាង ក្រាបចុះទៀបព្រះបាទទាំងគូ របស់ព្រះដ៏មានព្រះភាគដោយក្បាល ហើយក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ទោសដែលប្រព្រឹត្តកន្លងហើយ នូវខ្ញុំព្រះអង្គ ព្រោះជាមនុស្សពាល ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស យ៉ាងណា ខ្ញុំព្រះអង្គណា និយាយបន្ទាច់ព្រះសារីបុត្តដ៏មានអាយុ ដោយពាក្យមិនមែន ជាពាក្យទទេ ជាពាក្យកុហក មិនពិត

បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ អត់ទោសតាមទោស ដល់ខ្ញុំព្រះអង្គនោះ ដើម្បីសង្រួមតទៅ ។ ម្នាលភិក្ខុ អើ ទោសកំហុសដែលប្រព្រឹត្តកន្លងនូវអ្នក ព្រោះជាមនុស្សពាល ជាមនុស្សល្ងង់ ជាមនុស្សមិនឈ្លាស យ៉ាងណា អ្នកពោលបង្កាច់សារីបុត្ត ដោយពាក្យមិនមែន ជាពាក្យទទេ កុហក មិនពិត ម្នាលភិក្ខុ កាលណាបើអ្នកឃើញទោសតាមទោសដែលប្រព្រឹត្តកន្លងហើយ ត្រឡប់ធ្វើឲ្យត្រូវតាមធម៌វិញ តថាគតក៏អត់ទោសអ្នក បើបុគ្គលណាឃើញទោសតាមទោស ដែលប្រព្រឹត្តកន្លងហើយ ត្រឡប់ធ្វើឲ្យត្រូវតាមធម៌វិញ ដល់នូវការសង្រួមតទៅ ម្នាលភិក្ខុ នេះជាសេចក្តីចម្រើនក្នុងវិន័យរបស់ព្រះអរិយៈ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅព្រះសារីបុត្តដ៏មានអាយុថា ម្នាលសារីបុត្ត លោកចូរអត់ទោសដល់មោឃបុរសនេះចុះ ដ្បិតមោឃបុរសនេះ នឹងបែកក្បាលជា ៧ ភាគក្នុងទីនោះឯង ។ ព្រះសារីបុត្តក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គអត់ទោស ដល់លោកដ៏មានអាយុនោះ បើលោកដ៏មានអាយុនោះនិយាយនឹងខ្ញុំព្រះអង្គយ៉ាងនេះ សូមលោកដ៏មានអាយុនោះ អត់ទោសដល់ខ្ញុំព្រះអង្គវិញ ។

# អដ្ឋកថា
# សីហនាទវគ្គទី ២

## វុដ្ឋិសូត្រ

[ ១១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវុដ្ឋិសូត្រទី ១ នៃសីហនាទវគ្គទី ២ ដូចតទៅនេះ បទថា **យេន ភគវា តេនុបសង្កមិ** សេចក្ដីថា ព្រះសារីបុត្តគិតថា បើព្រះសាស្ដាទ្រង់បំណងនឹងចៀសចេញទៅកាន់ទីចារិក ទ្រង់គប្បីចៀសចេញទៅក្នុងកាលនេះ ណ្ហើយចុះ អញនឹងទូលលាព្រះសាស្ដា ដើម្បីទៅកាន់ទីចារិក ដូច្នេះ ជាបុគ្គលដែលពួកភិក្ខុចោមរោមចូលទៅគាល់ហើយ ។ បទថា **អាយស្មា មំ ភន្តេ** សេចក្ដីថា បានឮថា ភិក្ខុនោះឃើញព្រះថេរៈមកដោយភិក្ខុបរិវារដ៏ច្រើន គិតថា ពួកភិក្ខុទាំងនេះចោលព្រះតថាគត ហើយចេញទៅចោមរោមព្រះសារីបុត្ត អញនឹងទូលហាមការទៅរបស់ព្រះថេរៈ ដូច្នេះ ចងសេចក្ដីក្រោធ ដោយមិនមែនឋានៈ ទើបបានក្រាបទូលហើយយ៉ាងនោះ ។ បទថា **អាសជ្ជ** បានដល់ ប៉ះខ្ទប់ ។ បទថា **អប្បដិនិស្សជ្ជ** បានដល់ មិនសូមទោស គឺមិនសម្ដែងកំហុស ។ សួរថា ភិក្ខុនោះចងអាឃាតព្រោះហេតុអ្វី ។ ឆ្លើយថា ព្រះថេរៈទៅថ្វាយបង្គំព្រះទសពល ក្រោកឡើង ជាយចីវរពាល់ត្រូវខ្លួនរបស់ភិក្ខុនោះហើយ ។ អាចារ្យខ្លះពោលថា ខ្យល់ផាត់ទៅពាល់ត្រូវដូច្នេះក៏មាន ។ លោកចងអាឃាតដោយហេតុ មានប្រមាណប៉ុណ្ណេះហើយ កាលបានឃើញព្រះថេរៈទៅដោយបរិវារដ៏ច្រើន កើតនូវការច្រណែន ទើប

ពោលយ៉ាងនេះថា អញនឹងទូលហាមការទៅរបស់ព្រះថេរៈនោះ ដូច្នេះ ។

បទថា **ឯហិ ត្វំ ភិក្ខុ** សេចក្ដីថា ព្រះសាស្ដាស្ដាប់ពាក្យរបស់ភិក្ខុនោះហើយ ទ្រង់ដឹងថា កាលបុគ្គលណាពោលជំទាស់ថា ព្រះសារីបុត្តមិនបានប្រហារភិក្ខុនោះ លោកនឹងទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់ចូលខាងចំណែកអគ្គសាវករបស់ព្រះអង្គតែម្យ៉ាង មិនបានចូលខាងខ្ញុំព្រះអង្គ ដូច្នេះ គប្បីអាក់អន់ក្នុងតថាគត ហើយកើតក្នុងអបាយ ដូច្នេះ បានត្រាស់នឹងភិក្ខុមួយរូបថា ចូរហៅសារីបុត្តមក តថាគតនឹងសាកសួររឿងនេះ ដូច្នេះ ទើបត្រាស់ហើយយ៉ាងនេះ ។ បទថា **អបាបុរណំ អាទាយ** បានដល់ កាន់នូវកូនសោ ។ បទថា **សីហនាទំ** បានដល់ បន្ទឺដ៏ប្រសើរចំពោះព្រះភក្ត្រ មិនផ្លាស់ប្ដូរ ភិក្ខុសង្ឃដែលព្រះមហាថេរៈទាំង ២ រូបប្រកាសហើយយ៉ាងនេះ ក៏នាំគ្នាមកបោះបង់ទីសម្រាកពេលយប់ និងពេលថ្ងៃ បានទៅកាន់សម្នាក់របស់ព្រះសាស្ដា ។ បទថា **វីយធម្មំ** បានដល់ ធម្មកថា ។ បទថា **គូថគតំ** គឺលាមក ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យដូចគ្នា ។

បទថា **បឋវីសមេន** បានដល់ ឈ្មោះថា មានចិត្តស្មើដោយផែនដី ព្រោះមិនក្រោធ ព្រោះមិនប្រទូស្ដ ។ ពិតហើយ ផែនដីមិនធ្វើការត្រេកអរថា ជនទាំងឡាយ ចោលរបស់ស្អាតលើអញ ដូច្នេះ មិនធ្វើការកើតទុក្ខថា ជនទាំងឡាយចោលរបស់មិនស្អាត ដូច្នេះ លោកសម្ដែងថា សូម្បីចិត្តរបស់ខ្ញុំព្រះអង្គ ក៏បែបនោះ ។ បទថា **វិបុលេន** បានដល់ មិនតិច ។ បទថា

**មហាគ្គតេន** បានដល់ ដល់នូវភាពធំទូលាយ ។ បទថា **អប្បមាណេន** បានដល់ ពង្រីកចេញបានមិនមានប្រមាណ ។ បទថា **អវេរេន** បានដល់ វៀរហើយចាកពៀរចំពោះអកុសល និងចាកពៀរចំពោះបុគ្គល ។ បទថា **អព្យាបជ្ឈេន** បានដល់ មិនមានទុក្ខ គឺប្រាសចាកទោមនស្ស ។ បទថា **សោ ឥធ** បានដល់ ភិក្ខុនោះជាអ្នកមានកាយានុបស្សនាសតិប្បដ្ឋានមិនចូលទៅតាំងទុកហើយ គប្បីធ្វើយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដូចខ្ញុំព្រះអង្គ នឹងធ្វើកម្មបែបនោះបានដូចម្តេច ដូច្នោះ ទើបលោកបន្លឺហើយនូវសីហនាទជាលើកដំបូង ។ គប្បីជ្រាបការប្រកបក្នុងបទទាំងពួងយ៉ាងនេះ ។

បទថា **រជោហរណំ** បានដល់ រាជត្រកូល ពួកគេមិនបោសដោយអំបោស តែពួកគេជូតដោយកំណាត់សំពត់ ។ នុ៎ះជាឈ្មោះរបស់រជោហរណៈ ។ បទថា **កឡោបិហត្ថោ** បានដល់ ជាបុគ្គលមានដៃកាន់កញ្ជើ ឬកាន់ផ្ទាំងបាយ ។ បទថា **ឆន្និកវាសី** បានដល់ ជាអ្នកស្លៀកសំពត់ចាស់ដាច់ដាយ ។ បទថា **សុរតោ** បានដល់ ជាអ្នកមានប្រក្រតីជ្រះថ្លា ប្រកបដោយសេចក្តីស្ងប់ស្ងៀម ។ បទថា **សុទន្តោ** បានដល់ ទទួលនូវការទូន្មានល្អហើយ ។ បទថា **សុសិក្ខិតោ** បានដល់ ជាអ្នកសិក្សាល្អហើយ ។ បទថា **ន កិញ្ចិ ហឹសតិ** បានដល់ មិនបៀតបៀនបុគ្គលណាម្នាក់ សូម្បីចាប់ត្រង់ស្នែងជាដើម ឬសូម្បីស្ទាបខ្នង ។ បទថា **ឧសភច្ឆិន្នវិសាណាសមេន** បានដល់ ដូចគ្នានឹងចិត្តរបស់គោឧសភៈដែលបាក់ស្នែង ។

បទថា **អដ្ដិយេយ្យ** បានដល់ គប្បីជាអ្នកមានអាការ គឺត្រូវបៀតបៀន ។ បទថា **ហរាយេយ្យ** បានដល់ ខ្មាស ។ បទថា **ជិគុច្ឆេយ្យ** បានដល់ ដល់នូវការស្អប់ខ្ពើម ។ បទថា **មេទកថាលិកំ** បានដល់ ភាជនៈដែលបុគ្គលធ្វើសម្រាប់ខ្លែ ចោះជារន្ធក្នុងទីនោះៗ ដើម្បីការហូរចេញនៃទឹកសម្ល ទើបហៅថា **មេទកថាលិកំ។** បទថា **បរិហរេយ្យ** បានដល់ បុគ្គលគប្បីជាក់ឲ្យពេញដោយសាច់ ហើយលើកឡើងដើរទៅ ។ បទថា **ឆិទ្ទាវឆិទ្ទំ** បានដល់ ប្រកបដោយប្រហោងតូច-ធំ ។ បទថា **ឧគ្ឃរន្តំ** បានដល់ ទឹកសម្លហូរតាមរន្ធដែលជាប្រហោងខាងលើ ។ បទថា **បគ្ឃរន្តំ** បានដល់ ទឹកសម្លហូរតាមរន្ធដែលជាប្រហោងខាងក្រោម ។ រាងកាយទាំងមូលរបស់បុគ្គលគប្បីប្រឡាក់ដោយទឹកសម្ល ដោយអាការយ៉ាងនេះ ។ បទថា **ឆិទ្ទាវឆិទ្ទំ** បានដល់ ជាប្រហោងតូច-ធំ អំពីមុខដំបៅទាំង ៩ ។ ក្នុងសេចក្តីនេះ ព្រះថេរៈពោលហើយ ដោយភាពដែលខ្លួនមិនមានឆន្ទរាគៈក្នុងរាងកាយ ដោយអង្គទី ៨ ឬទី ៩ ដោយអាការយ៉ាងនេះ ។

បទថា **អថ ខោ សោ ភិក្ខុ** សេចក្តីថា លំដាប់នោះឯង ភិក្ខុនោះកាលព្រះថេរៈបន្លឺសីហនាទ ដោយហេតុ ៩ យ៉ាងនេះហើយ ។ បទថា **អច្ចយោ** បានដល់ កំហុស ។ បទថា **មំ អច្ចគមា** បានដល់ ខ្ញុំរមែងទទួលទោស ដែលបានប្រព្រឹត្តទៅហើយ ។ បទថា **បដិគ្គណ្ហាតុ** បានដល់ សូមព្រះមានព្រះភាគទ្រង់អត់ទោសផងចុះ ។ បទថា **អាយតឹ សំវរាយ**

បានដល់ ដើម្បីការសង្រួមក្នុងអនាគត ។ គឺដើម្បីមិនធ្វើនូវកំហុសបែបនេះទៀត ។

បទថា **តស្ស** គឺដោយពិតប្រាកដ ។ បទថា **យថាធម្មំ បដិករោសិ** បានដល់ លោកបានធ្វើតាមធម៌ដែលតាំងនៅហើយ លោកអធិប្បាយថា ឲ្យតថាគតអត់ទោស ដូច្នេះ ។ បទថា **តន្តេ មយំ បដិគ្គណ្ហាម** សេចក្ដីថា តថាគតមិនយកទោសនោះដល់អ្នក ។ បទថា **វុឌ្ឍិ ហេសា ភិក្ខុ អរិយស្ស វិនយេ** សេចក្ដីថា ម្នាលភិក្ខុ នេះឈ្មោះថា ការចម្រើនក្នុងវិន័យរបស់ព្រះអរិយៈ គឺក្នុងសាសនារបស់ព្រះមានព្រះភាគ ។ សួរថា ការចម្រើនដូចម្ដេច ឆ្លើយថា ការឃើញទោសដោយភាពជាទោស ហើយសម្ដែងតាមធម៌ដល់ការសង្រួមតទៅ ។ កាលព្រះថេរៈធ្វើទេសនាឲ្យជាបុគ្គលាធិដ្ឋាន ទើបពោលថា **យោ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោតិ អាយតឹ សំវរំ អាបជ្ជតិ** ដូច្នេះ ។

បទថា **ផលតិ** សេចក្ដីថា បើព្រះថេរៈមិនគប្បីអត់ទោសសោតក្បាលរបស់ភិក្ខុនោះគប្បីបែកជា ៧ ចម្រៀកព្រោះទោសនោះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនោះ ។ បទថា **សចេ មំ សោ** សេចក្ដីថា បើភិក្ខុនេះ ពោលនឹងខ្ញុំយ៉ាងនេះថា សូមលោកម្ចាស់អត់ទោសដល់ខ្ញុំចុះ ដូច្នេះ ។ បទថា **ខមតុ ច មេ សោ** សេចក្ដីថា ព្រះថេរៈអត់ទោសដល់ភិក្ខុនោះយ៉ាងនេះ ដោយគិតថា អាវុសោនេះ អត់ទោសដល់ខ្ញុំ

*ដូច្នេះ ឲ្យភិក្ខុនោះអត់ទោស ចំពោះព្រះភក្ត្ររបស់ព្រះសាស្តា ដោយខ្លួនឯង ដូច្នេះ ។ល។*

**អដ្ឋកថាវុដ្ឋិសូត្រទី ១ ចប់**

# សុត្តន្តបិដក

## សឧចានិសេសសូត្រទី ២

[ ១២ ] *សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ព្រះសារីបុត្តដ៏មានអាយុ ស្លៀកស្បង់ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា ការត្រាច់ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី នៅព្រឹកនៅឡើយ បើដូច្នោះ គួរអាត្មាអញ ឈៀងចូលទៅឯអារាមពួកអន្យតិរ្ថិយបរិព្វាជកសិន ។ ទើបព្រះសារីបុត្តដ៏មានអាយុ ឈៀងចូលទៅឯអារាមរបស់ពួកអន្យតិរ្ថិយបរិព្វាជក លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយទៅរកពួកអន្យតិរ្ថិយបរិព្វាជក លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួរឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ សម័យនោះឯង អន្តរាកថានោះ កើតដល់ពួកអន្យតិរ្ថិយ-*

បរិព្វាជក ដែលកំពុងអង្គុយប្រជុំគ្នាទាំងនោះថា ម្នាលអាវុសោទាំងឡាយ បុគ្គលណានីមួយ ជាសឧបាទិសេស ធ្វើមរណកាលទៅ បុគ្គលទាំងអស់នោះ មិនដែលផុតអំពីនរក មិនផុតអំពីកំណើតតិរច្ឆាន មិនផុតអំពីបិត្តិវិស័យ មិនផុតអំពីអបាយ ទុគ្គតិ និងវិនិបាតទេ ។ គ្រានោះ ព្រះសារីបុត្តដ៏មានអាយុ មិនត្រេកអរ មិនជំទាស់នឹងភាសិត របស់អន្យតិរ្ថិយបរិព្វាជកទាំងនោះ លុះមិនត្រេកអរ មិនជំទាស់ហើយ ទើបក្រោកចាកអាសនៈ ចៀសចេញទៅ ដោយគិតថា អាត្មាអញនឹងដឹងនូវសេចក្តីនៃភាសិតនេះ ក្នុងសម្នាក់នៃព្រះដ៏មានព្រះភាគ ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ ចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី លុះត្រឡប់ចាកបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្តហើយ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គស្លៀកស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ដើម្បីចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះដូច្នេះថា ការចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី នៅព្រឹកនៅឡើយ បើដូច្នោះ គួរតែអាត្មាអញ ឈៀងចូលទៅឯអារាមរបស់ពួកអន្យតិរ្ថិយបរិព្វាជកសិន ។ បពិត្រព្រះអង្គដ៏ចម្រើន ទើបខ្ញុំព្រះអង្គ ឈៀងចូលទៅឯអារាមរបស់ពួកអន្យតិរ្ថិយបរិព្វាជក លុះចូលទៅដល់ហើយ

ក៏ធ្វើសេចក្តីរីករាយទៅរកអន្យតិរ្ថិយបរិព្វាជកទាំងនោះ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ សម័យនោះឯង អន្តរាកថានេះកើតឡើង ដល់ពួកអន្យតិរ្ថិយបរិព្វាជក ដែលកំពុងអង្គុយប្រជុំគ្នាថា ម្នាលអាវុសោទាំងឡាយ បុគ្គលណានីមួយ ជាសឧបា-ទិសេស ធ្វើមរណកាលទៅ បុគ្គលទាំងអស់នោះ មិនដែលផុតអំពីនរក មិនផុតអំពីកំណើតតិរច្ឆាន មិនផុតអំពីបិត្តិវិស័យ មិនផុតអំពីអបាយ ទុគ្គតិ និងវិនិបាតទេ ។ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ ខ្ញុំព្រះអង្គមិនត្រេកអរ មិនជំទាស់នឹងភាសិតរបស់ពួកអន្យតិរ្ថិយបរិព្វាជកទាំងនោះ លុះខ្ញុំព្រះអង្គមិនត្រេកអរ មិនជំទាស់ហើយ ទើបក្រោកចាកអាសនៈ ចៀសចេញទៅ ដោយគិតថា អាត្មាអញនឹងដឹងនូវសេចក្តីនៃភាសិតនេះ ក្នុងសម្នាក់នៃព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលសារីបុត្ត ពួកអន្យតិរ្ថិយបរិព្វាជកនីមួយ ជាមនុស្សល្ងង់ ជាមនុស្សមិនឈ្លាស ពួកណាខ្លះ នឹងដឹងនូវសឧបាទិសេស-បុគ្គល ថាជាសឧបាទិសេសបុគ្គលក្តី នឹងដឹងនូវអនុបាទិសេសបុគ្គល ថាជាអនុបាទិសេសបុគ្គលក្តី ។ ម្នាលសារីបុត្ត បុគ្គលជាសឧបាទិសេសនេះ មាន ៩ ពួក កាលធ្វើមរណកាលទៅ តែងផុតចាកនរក ផុតចាកកំណើតតិរច្ឆាន ផុតចាកបិត្តិវិស័យ ផុតចាកអបាយ ទុគ្គតិ និងវិនិបាត ។ បុគ្គល ៩ ពួកដូចម្តេចខ្លះ ។ ម្នាលសារីបុត្ត បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីល ធ្វើឲ្យបរិបូណ៌ក្នុងសមាធិ តែងធ្វើឲ្យល្មមប្រមាណក្នុងបញ្ញា បុគ្គល

នោះ ជាអន្តរាបរិនិព្វាយី ព្រោះអស់សំយោជនៈជាចំណែកខាងក្រោម ៥ ។ ម្នាលសារីបុត្ត នេះជាសឧបាទិសេសបុគ្គលទី ១ កាលធ្វើមរណកាលទៅ ផុតចាកនរក ផុតចាកកំណើតតិរច្ឆាន ផុតចាកបិត្តិវិស័យ ផុតចាកអបាយ ទុគ្គតិ និងវិនិបាតហើយ ។ ម្នាលសារីបុត្ត មួយទៀត បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីល ធ្វើឲ្យបរិបូណ៌ក្នុងសមាធិ តែធ្វើឲ្យល្មមប្រមាណក្នុងបញ្ញា បុគ្គលនោះ ជាឧបហច្ចបរិនិព្វាយី ជាអសង្ខារបរិនិព្វាយី ជាសសង្ខារបរិនិព្វាយី ជាឧទ្ធំសោតអកនិដ្ឋគាមី ព្រោះអស់ទៅនៃសំយោជនៈជាចំណែកខាងក្រោម ៥ ។ ម្នាលសារីបុត្ត នេះជាសឧបាទិសេសបុគ្គលទី ៥ កាលធ្វើមរណកាលទៅ ផុតចាកនរក ផុតចាកកំណើតតិរច្ឆាន ផុតចាកបិត្តិ-វិស័យ ផុតចាកអបាយ ទុគ្គតិ និងវិនិបាតហើយ ។ ម្នាលសារីបុត្ត មួយទៀត បុគ្គលខ្លះក្នុងលោកនេះ ធ្វើឲ្យបរិបូណ៌ក្នុងសីល តែធ្វើឲ្យល្មមប្រមាណក្នុងសមាធិ ធ្វើឲ្យល្មមប្រមាណ ក្នុងបញ្ញា បុគ្គលនោះ ជាសកទាគាមី ព្រោះអស់សំយោជនៈ ៣ ព្រោះមានរាគៈ ទោសៈ មោហៈស្រាលស្តើង មកកាន់មនុស្សលោកនេះម្តងទៀត ទើបធ្វើទីបំផុតទុក្ខបាន ។ ម្នាលសារីបុត្ត នេះជាសឧបាទិសេសបុគ្គលទី ៦ កាលធ្វើមរណកាលទៅ ផុតចាកនរក ។បេ។ ផុតចាកអបាយ ទុគ្គតិ និងវិនិបាតហើយ ។ ម្នាលសារីបុត្ត មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ធ្វើឲ្យបរិបូណ៌ក្នុងសីល តែធ្វើឲ្យល្មមប្រមាណក្នុងសមាធិ ធ្វើឲ្យល្មមប្រមាណក្នុងបញ្ញា បុគ្គលនោះ ជាឯកពីជី ព្រោះអស់សំយោជនៈ

៣ ត្រូវកើតក្នុងមនុស្សភពម្តងទៀត ទើបធ្វើទីបំផុតទុក្ខបាន ។ ម្នាលសារីបុត្ត នេះជាសឧបាទិសេសបុគ្គលទី ៧ កាលធ្វើមរណកាលទៅ ផុតចាកនរក ។បេ។ ផុតចាកអបាយ ទុគ្គតិ និងវិនិបាតហើយ ។ ម្នាលសារីបុត្ត មួយទៀត បុគ្គលពួកខ្លះក្នុងលោកនេះ ធ្វើឲ្យបរិបូណ៌ក្នុងសីល តែធ្វើឲ្យល្មមប្រមាណក្នុងសមាធិ ធ្វើឲ្យល្មមប្រមាណក្នុងបញ្ញា បុគ្គលនោះ ជាកោលំកោលៈ ព្រោះអស់សំយោជនៈ ៣ ត្រាច់ រង្គាត់ អន្ទោលទៅកាន់ត្រកូល ២ ឬ ៣ ទៀត ទើបធ្វើទីបំផុតទុក្ខបាន ។ ម្នាលសារីបុត្ត នេះជាសឧបាទិសេសបុគ្គលទី ៨ កាលធ្វើមរណកាលទៅ ផុតចាកនរក ។បេ។ ផុតចាកអបាយ ទុគ្គតិ និងវិនិបាតហើយ ។ ម្នាលសារីបុត្ត មួយវិញទៀត បុគ្គលខ្លះក្នុងលោកនេះ ធ្វើឲ្យបរិបូណ៌ក្នុងសីល តែធ្វើឲ្យល្មមប្រមាណក្នុងសមាធិ ធ្វើឲ្យល្មមប្រមាណក្នុងបញ្ញា បុគ្គលនោះ ជាសត្តក្ខត្តុំបរមៈ ព្រោះអស់សំយោជនៈ ៣ ត្រាច់រង្គាត់ អន្ទោលទៅ កាន់ទេវលោក និងមនុស្សលោក ៧ ជងទៀត ដោយច្រើន ទើបធ្វើទីបំផុតទុក្ខ ។ ម្នាលសារីបុត្ត នេះជាសឧបាទិសេសបុគ្គលទី ៩ កាលធ្វើមរណកាលទៅ ផុតចាកនរក ផុតចាកកំណើតតិរច្ឆាន ផុតចាកបិត្តិវិស័យ ផុតចាកអបាយ ទុគ្គតិ និងវិនិបាតហើយ ។ ម្នាលសារីបុត្ត ពួកអន្យតិត្ថិយបរិព្វាជកនីមួយ ជាមនុស្សល្ងង់ មិនឈ្លាស ពួកណាខ្លះ នឹងដឹងនូវសឧបាទិសេសបុគ្គល ថាជាសឧបាទិសេសបុគ្គលក្តី និងដឹងនូវអនុបាទិសេសបុគ្គល ថាជាអនុបាទិសេសបុគ្គលក្តី ។ ម្នាលសារីបុត្ត សឧបាទិ-

សេសបុគ្គលទាំង ៩ ពួកនេះឯង កាលធ្វើមរណកាលទៅ ផុតចាកនរក ផុតចាកកំណើតតិរច្ឆាន ផុតចាកបិត្តិវិស័យ ផុតចាកអបាយ ទុគ្គតិ និង វិនិបាតហើយ ។ ម្នាលសារីបុត្ត ធម្មបរិយាយនេះ មិនទាន់ភ្លឺច្បាស់ដល់ពួក ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកានៅឡើយទេ ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះថា ធម្មបរិយាយណា ដែលតថាគតសម្តែងហើយ ដោយបញ្ហា-ធិប្បាយ ពួកជនបានស្តាប់ធម្មបរិយាយនោះហើយ ចូរកុំដល់នូវសេចក្តី ប្រមាទឡើយ ។

# អដ្ឋកថា

## សឧបាទិសេសសូត្រ

[ ១២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសឧបាទិសេសសូត្រទី ២ ដូចតទៅនេះ បទថា **សឧបាទិសេសំ** បានដល់ ជាបុគ្គលអ្នកនៅមានបញ្ចក្ខន្ធសេសសល់ ។ បទថា **អនុបាទិសេសំ** បានដល់ ជាអ្នកមិនសេសសល់ឧបាទាន គឺអស់នូវការប្រកាន់ ។ បទថា **មត្តសោការី** បានដល់ ជាអ្នកធ្វើល្មមប្រមាណ គឺមិនធ្វើឲ្យបរិបូណ៌ ។ បទថា **ន តាវាយំ សារីបុត្ត ធម្មបរិយាយោ បដិភាសិ** សេចក្តីថា ក្នុងសេចក្តីនេះ មានអត្ថដូច្នេះថា ធម្មតា ការមិនជាក់ច្បាស់រមែង

មិនមានដល់ព្រះមានព្រះភាគ តថាគតនឹងមិនពោលធម្មបរិយាយនេះជាបឋមឡើយ ។ បទថា **មាយិមំ ធម្មបរិយាយំ សុត្វា បមាទំ អាហរឹសុ** សេចក្តីថា បុគ្គលទាំងឡាយ កាលមិនធ្វើសេចក្តីព្យាយាមដើម្បីអរហត្តខាងលើ កុំដល់នូវសេចក្តីប្រមាទ ដោយយល់ថា បានឮថា យើងទាំងឡាយ ផុតហើយចាកអបាយ ៤ ដូច្នេះ ។ បទថា **បញ្ហាធិប្បាយេន ភាសិតោ** លោកសម្តែងថា តថាគតពោលថា តថាគតពោលតាមបញ្ហា ដែលអ្នកសួរហើយដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់ធ្វើហេតុនោះប៉ុណ្ណោះឲ្យកើត ដើម្បីបន្ទោបង់នូវឆន្ទរាគៈក្នុងភពទាំងឡាយរបស់បុគ្គលទាំង ៩ ពួកនេះហើយ ទើបបានត្រាស់ព្រះសូត្រនេះថា ម្នាលភិក្ខុទាំងឡាយ ដូចលាមក សូម្បីបន្តិចបន្តួច រមែងមានក្លិនស្អុយ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលសរសើរនូវបដិសន្ធិក្នុងភពសូម្បីបន្តិចបន្តួច ដោយហោចទៅសូម្បីអស់កាល ត្រឹមតែផ្ទាត់ម្រាមដៃម្តងឡើយ ក៏យ៉ាងនោះឯង ។ មិនមែនតែមួយភូមិដែលប្រព្រឹត្តទៅរបស់បុគ្គល ៩ ពួកនោះ ក៏ជាប់តគ្នា ។ សរណៈ ៣ សីល ៥ សលាកភត្ត ១ បក្ខិកភត្ត ១ វស្សាវាសិក ១ ស្រះបោក្ខរណី ១ អាវាស ១ បុណ្យដែលទាក់ទងគ្នាបែបនេះ មានដល់ត្រកូលទាំងឡាយណា គតិរបស់ត្រកូលទាំងឡាយនោះ ក៏ទាក់ទងគ្នា ត្រកូលទាំងឡាយនោះ ដូចគ្នានឹងសោតាបន្នបុគ្គលនោះឯង ៕

# សុត្តន្តបិដក

## កោដ្ឋិកសូត្រទី ៣

[ ១៣ ] គ្រានោះ ព្រះមហាកោដ្ឋិកៈដ៏មានអាយុ ចូលទៅរកព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះសារីបុត្តដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះមហាកោដ្ឋិកៈដ៏មានអាយុអង្គុយទីសមគួរហើយ បានសួរព្រះសារីបុត្តដ៏មានអាយុដូច្នេះថា ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាដែលឲ្យផលក្នុងបច្ចុប្បន្ន សូមឲ្យកម្មនោះឲ្យផល ក្នុងបរលោកដល់អាត្មាអញវិញ បានឬ ។ ម្នាលអាវុសោ មិនបានទេ ។ ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិ-យធម៌ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាឲ្យផល ក្នុងបរលោក សូមឲ្យកម្មនោះ ឲ្យផលក្នុងបច្ចុប្បន្នដល់អាត្មាអញវិញ បានដែរឬ ។ ម្នាលអាវុសោ មិនបានទេ ។ ម្នាលអាវុសោសារី-បុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាដែលឲ្យផលជាសុខ សូមឲ្យកម្មនោះឲ្យផលជាទុក្ខ ដល់អាត្មាអញវិញ បានដែរឬ ។ ម្នាលអាវុសោ មិនបានទេ ។ ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាឲ្យផលជាទុក្ខ សូម

ឲ្យកម្មនោះ ឲ្យផលជាសុខដល់អាត្មាអញវិញ បានដែរឬ ។ ម្នាលអាវុសោ មិនបានទេ ។ ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាដែលមានវេទនាឲ្យផល សូមឲ្យកម្មនោះទៅជាមានវេទនា មិនឲ្យផលដល់អាត្មាអញវិញ បានដែរឬ ។ ម្នាលអាវុសោ មិនបានទេ ។ ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រ-យោជន៍ដល់ហេតុនេះថា កម្មណាដែលមានវេទនាមិនឲ្យផល សូមឲ្យកម្មនោះទៅជាមានវេទនា ឲ្យផលដល់អាត្មាអញវិញ បានដែរឬ ។ ម្នាលអាវុសោ មិនបានទេ ។ ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាឲ្យផលច្រើន សូមឲ្យកម្មនោះ ត្រឡប់ទៅជាឲ្យផលតិច ដល់អាត្មាអញវិញ បានដែរឬ ។ ម្នាលអាវុសោ មិនបានទេ ។ ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាឲ្យផលតិច សូមឲ្យកម្មនោះ ត្រឡប់ទៅជាឲ្យផលច្រើនដល់អាត្មាអញវិញ បានដែរឬ ។ ម្នាលអាវុសោ មិនបានទេ ។ ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាដែលឲ្យផល សូមឲ្យកម្មនោះត្រឡប់ជាមិនឲ្យផលដល់អាត្មាអញវិញ បានដែរឬ ។ ម្នាលអាវុសោ មិន

បានទេ ។ ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាមិនឲ្យផល សូមឲ្យកម្មនោះ ត្រឡប់ជាឲ្យផលដល់អាត្មាអញវិញ បានដែរឬ ។ ម្នាលអាវុសោ មិនបានទេ ។

ព្រះមហាកោដ្ឋិកៈដ៏មានអាយុពោលថា កាលដែលខ្ញុំសួរដូច្នេះថា ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាដែលឲ្យផល ក្នុងបច្ចុប្បន្ន សូមឲ្យកម្មនោះឲ្យផល ក្នុងបរលោកដល់អាត្មាអញវិញ បានដែរឬ លោកឆ្លើយថា ម្នាលអាវុសោ មិនបានទេ ។ កាលដែលខ្ញុំសួរដូច្នេះថា ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាដែលឲ្យផល ក្នុងបរលោក សូមឲ្យកម្មនោះ ឲ្យផលក្នុងបច្ចុប្បន្ននេះ ដល់អាត្មាអញវិញ បានដែរឬ លោកឆ្លើយថា ម្នាលអាវុសោ មិនបានទេ ។ កាលដែលខ្ញុំសួរដូច្នេះថា ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាឲ្យផលជាសុខ សូមឲ្យកម្មនោះឲ្យផលជាទុក្ខដល់អាត្មាអញវិញ បានដែរឬ លោកឆ្លើយថា ម្នាលអាវុសោ មិនបានទេ ។ កាលដែលខ្ញុំសួរដូច្នេះថា ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រ-

យោជន៍ ដល់ហេតុនេះថា កម្មណាដែលឲ្យផលជាទុក្ខ សូមឲ្យកម្មនោះត្រឡប់ឲ្យផលជាសុខដល់អាត្មាអញវិញ បានដែរឬ លោកឆ្លើយថា ម្នាលអាវុសោ មិនបានទេ ។ កាលដែលខ្ញុំសួរដូច្នេះថា ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាដែលមានវារៈឲ្យផល សូមឲ្យកម្មនោះមានវារៈ មិនឲ្យផលដល់អាត្មាអញវិញ បានដែរឬ លោកឆ្លើយថា ម្នាលអាវុសោ មិនបានទេ ។ កាលដែលខ្ញុំសួរដូច្នេះថា ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាដែលមានវារៈមិនឲ្យផល សូមឲ្យកម្មនោះមានវារៈ ឲ្យផលដល់អាត្មាអញវិញ បានដែរឬ លោកឆ្លើយថា ម្នាលអាវុសោ មិនបានទេ ។ កាលដែលខ្ញុំសួរដូច្នេះថា ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាដែលឲ្យផលច្រើន សូមឲ្យកម្មនោះត្រឡប់ឲ្យផលតិចដល់អាត្មាអញវិញ បានដែរឬ លោកឆ្លើយថា ម្នាលអាវុសោ មិនបានទេ ។ កាលដែលខ្ញុំសួរដូច្នេះថា ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាដែលឲ្យផលតិច សូមឲ្យកម្មនោះត្រឡប់ជាឲ្យផលច្រើន ដល់អាត្មាអញវិញ បានដែរឬ លោកឆ្លើយថា ម្នាលអាវុសោ មិនបានទេ ។ កាលដែលខ្ញុំសួរដូច្នេះថា ម្នាលអាវុសោ

សារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាដែលឲ្យផល សូមឲ្យកម្មនោះត្រឡប់ជាមិនឲ្យផលដល់អាត្មាអញវិញ បានដែរឬ លោកឆ្លើយថា ម្នាលអាវុសោ មិនបានទេ ។ កាលដែលខ្ញុំសួរដូច្នេះថា ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាដែលមិនឲ្យផល សូមឲ្យកម្មនោះត្រឡប់ជាឲ្យផលដល់អាត្មាអញវិញ បានដែរឬ លោកឆ្លើយថា ម្នាលអាវុសោ មិនបានទេ ម្នាលអាវុសោ កាលបើដូច្នេះ ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ តើប្រព្រឹត្តដើម្បីអ្វី ។ ម្នាលអាវុសោ គុណជាតិណាដែលបុគ្គលមិនបានដឹង មិនបានឃើញ មិនបានដល់ មិនបានធ្វើឲ្យជាក់ច្បាស់ មិនបានត្រាស់ដឹងនៅឡើយ បុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ដើម្បីដឹងដើម្បីឃើញ ដើម្បីដល់ ដើម្បីធ្វើឲ្យជាក់ច្បាស់ ដើម្បីត្រាស់ដឹងនូវគុណជាតិនោះ ម្នាលអាវុសោ នេះជាទុក្ខ ម្នាលអាវុសោ នេះជាទុក្ខសមុទយៈ ម្នាលអាវុសោ នេះជាទុក្ខនិរោធ ម្នាលអាវុសោ នេះជាទុក្ខនិរោធគាមិនីបដិបទា ដែលបុគ្គលមិនបានដឹង មិនបានឃើញ មិនបានដល់ មិនបានធ្វើឲ្យជាក់ច្បាស់ មិនបានត្រាស់ដឹង បុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ដើម្បីដឹង ដើម្បីឃើញ ដើម្បីដល់ ដើម្បីធ្វើឲ្យជាក់ច្បាស់ ដើម្បីត្រាស់ដឹង នូវគុណជាតិនោះ ម្នាលអាវុសោ នេះឯង ជាគុណ-

ជាតិ ដែលបុគ្គលមិនបានដឹង មិនបានឃើញ មិនបានដល់ មិនបានធ្វើឲ្យជាក់ច្បាស់ មិនបានត្រាស់ដឹង បុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ដើម្បីដឹង ដើម្បីឃើញ ដើម្បីដល់ ដើម្បីធ្វើឲ្យជាក់ច្បាស់ ដើម្បីត្រាស់ដឹងនូវគុណជាតិនោះ ។

# អដ្ឋកថា

## កោដ្ឋិកសូត្រ

[ ១៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកោដ្ឋិតសូត្រទី ៣ ដូចតទៅនេះ បទថា **ទិដ្ឋធម្មវេទនីយំ** បានដល់ កម្មដែលឲ្យផលក្នុងអត្តភាពនេះប៉ុណ្ណោះ ។ បទថា **សម្បរាយវេទនីយំ** បានដល់ កម្មដែលឲ្យផលក្នុងអត្តភាពទី ២ ។ បទថា **សុខវេទនីយំ** បានដល់ កម្មដែលតាក់តែងឲ្យកើតសុខវេទនា ។ បទថា **ទុក្ខវេទនីយំ** បានដល់ កម្មដែលតាក់តែងឲ្យកើតទុក្ខវេទនា ។ បទថា **បរិបក្កវេទនីយំ** បានដល់ កម្មឲ្យផលសម្រេចហើយម្តង ។ បទថា **អបរិបក្កវេទនីយំ** បានដល់ កម្មឲ្យផលមិនទាន់សម្រេចហើយម្តង ។ បទថា **ពហុវេទនីយំ** បានដល់ កម្មឲ្យផលច្រើន ។ បទថា **អប្បវេទនីយំ** បានដល់ កម្មឲ្យផលមិនច្រើន ។ បទថា **វេទនីយំ** បានដល់ កម្មនៅឲ្យផល ។ បទថា **អវេទនីយំ** បានដល់ កម្មដែលមិនទាន់ឲ្យផល ។ វដ្តៈ និងវិវដ្តៈ ត្រាស់ហើយ ក្នុងសូត្រនេះ ។៚

# សុត្តន្តបិដក

## សមិទ្ធិសូត្រទី ៤

[ ១៤ ] គ្រានោះ ព្រះសមិទ្ធិដ៏មានអាយុ ចូលទៅរកព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ ថ្វាយបង្គំព្រះសារីបុត្តដ៏មានអាយុ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះសមិទ្ធិដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះសារីបុត្តដ៏មានអាយុ សួរដូច្នេះថា ម្នាលសមិទ្ធិ វិតក្កជាសង្កប្បៈរបស់បុរសមានអ្វីជាអារម្មណ៍ ទើបកើតឡើង ព្រះសមិទ្ធិឆ្លើយតបថា បពិត្រលោកម្ចាស់ដ៏ចម្រើន មាននាម និងរូបជាអារម្មណ៍ ។ ម្នាលសមិទ្ធិ ធម៌ទាំងនោះ ដល់នូវភាពផ្សេងគ្នា ក្នុងទីដូចម្តេច ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ក្នុងពួកធាតុ ។ ម្នាលសមិទ្ធិ ធម៌ទាំងនោះ មានអ្វីជាដែនកើត ។ បពិត្រលោកម្ចាស់ដ៏ចម្រើន មានផស្សៈជាដែនកើត ។ ម្នាលសមិទ្ធិ ធម៌ទាំងនោះ មានអ្វីជាទីប្រជុំចុះ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន មានវេទនាជាទីប្រជុំចុះ ។ ម្នាលសមិទ្ធិ ធម៌ទាំងនោះមានអ្វីជាប្រធាន ។ បពិត្រលោកម្ចាស់ដ៏ចម្រើន មានសមាធិជាប្រធាន ។ ម្នាលសមិទ្ធិ ធម៌ទាំងនោះ មានអ្វីជាអធិបតី ។ បពិត្រលោកម្ចាស់ដ៏ចម្រើន មានសតិជាអធិបតី ។ ម្នាលសមិទ្ធិ ធម៌ទាំងនោះ មានអ្វីជារបស់ខ្ពង់ខ្ពស់ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន មានបញ្ញា ជារបស់ខ្ពង់ខ្ពស់ ។ ម្នាលសមិទ្ធិ ធម៌ទាំងនោះ មានអ្វីជាខ្លឹម ។ បពិត្រលោកម្ចាស់ដ៏ចម្រើន មានវិមុត្តិជាខ្លឹម ។ ម្នាលសមិទ្ធិ ធម៌ទាំងនោះ មានអ្វីជាទីតាំងនៅស៊ប់ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន មានអមតៈជាទីតាំងនៅស៊ប់ ។ កាលដែលខ្ញុំសួរថា ម្នាលសមិទ្ធិ

វិតក្កជាសង្កប្បៈរបស់បុរស មានអ្វីជាអារម្មណ៍ ទើបកើតឡើង លោកឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន មាននាម និងរូបជាអារម្មណ៍ ។ កាលដែលខ្ញុំសួរថា ម្នាលសមិទ្ធិ ធម៌ទាំងនោះ ដល់នូវភាពផ្សេងគ្នា ក្នុងទីដូចម្ដេច លោកឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន ក្នុងពួកធាតុ ។ កាលដែលខ្ញុំសួរថា ម្នាលសមិទ្ធិ ធម៌ទាំងនោះ មានអ្វីជាដែនកើត លោកឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន មានផស្សៈជាដែនកើត ។ កាលដែលខ្ញុំសួរថា ម្នាលសមិទ្ធិ ធម៌ទាំងនោះ មានអ្វីជាទីប្រជុំចុះ លោកឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន មានវេទនាជាទីប្រជុំចុះ ។ កាលដែលខ្ញុំសួរថា ម្នាលសមិទ្ធិ ធម៌ទាំងនោះ មានអ្វីជាប្រធាន លោកឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន មានសមាធិជាប្រធាន ។ កាលដែលខ្ញុំសួរថា ម្នាលសមិទ្ធិ ធម៌ទាំងនោះ មានអ្វីជាអធិបតី លោកឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន មានសតិជាអធិបតី ។ កាលដែលខ្ញុំសួរថា ម្នាលសមិទ្ធិ ធម៌ទាំងនោះ មានអ្វីជារបស់ខ្ពង់ខ្ពស់ លោកឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន មានបញ្ញាជារបស់ខ្ពង់ខ្ពស់ ។ កាលដែលខ្ញុំសួរថា ម្នាលសមិទ្ធិ ធម៌ទាំងនោះ មានអ្វីជាខ្លឹម លោកឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន មានវិមុត្តិជាខ្លឹម ។ កាលដែលខ្ញុំសួរថា ម្នាលសមិទ្ធិ ធម៌ទាំងនោះ មានអ្វីជាទីតាំងនៅស៊ប់ លោកឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន មានអមតៈជាទីតាំងនៅស៊ប់ ។ ម្នាលសមិទ្ធិ ប្រពៃណាស់ ម្នាលសមិទ្ធិ អ្នកវិសជ្ជនាប្រស្នាដែលខ្ញុំសួរហើយ ត្រូវណាស់ មួយទៀត

អ្នកកុំបានចិត្តព្រោះការវិសជ្ជនាប្រស្នានោះឡើយ ៗ

# អដ្ឋកថា

## សមិទ្ធិសូត្រ

[ ១៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសមិទ្ធិសូត្រទី ៤ ដូចតទៅនេះ បទថា **សមិទ្ធិ** បានដល់ ព្រះថេរៈមានសទ្ធិវិហារិកឈ្មោះយ៉ាងនេះ ព្រោះការសម្រេចរបស់អត្តភាព ( មានរូបស្អាត ) ។ បទថា **កិមារម្មណា** បានដល់ មានអ្វីជាបច្ច័យ ។ បទថា **សង្កប្បវិតក្កា** បានដល់ វិតក្កដែលជាការត្រិះរិះ ។ បទថា **នាមរូបារម្មណា** បានដល់ មាននាមរូបជាបច្ច័យ ។ លោកសម្តែងថា ដោយបទនេះ អរូបក្ខន្ធ ៤ ភូតរូប និងឧបាទាយរូប ជាបច្ច័យនៃវិតក្កទាំងឡាយ ។ បទថា **ក្វ នានត្តំ គច្ឆន្តិ** សេចក្តីថា រមែងដល់ចំណែកផ្សេងៗគ្នាជាសភាវៈ គឺការប្លែកក្នុងទីណា ។ បទថា **ធាតូសុ** គឺក្នុងរូបធាតុជាដើម ។ ព្រោះថា កាលត្រិះរិះក្នុងរូបណាមួយ ការត្រិះរិះក្នុងសំឡេងជាដើមណាមួយ ដោយប្រការដូច្នេះ ។ បទថា **ផស្សសមុទយា** បានដល់ មានផស្សៈជាបច្ច័យប្រកបគ្នា ។ បទថា **វេទនាសមោសរណា** បានដល់ មានវេទនា ៣ ជាទីប្រជុំចុះ ។ លោកពោលកុសល និងអកុសលរួមគ្នាហើយ ដោយហេតុប្រមាណប៉ុណ្ណេះ ។ ឯធម៌ជាដើមថា **សមាធិប្បមុខា** គប្បីជ្រាបថា ជាធម៌

ផ្នែកខាងកម្ចាត់កិលេសឲ្យអស់ទៅ ។ ក្នុងបទនោះ វិតក្ក ឈ្មោះថា សមាធិ-ប្បមុខា ព្រោះអត្ថថា មានសមាធិជាប្រមុខ ដោយអត្ថថា ជាប្រធាន ឬដោយអត្ថថា ជាធំ ។ ឈ្មោះថា **សតាធិបតេយ្យា** បានដល់ មានសតិជាធំ ដោយអត្ថថា ជាហេតុរបស់បុគ្គលជាធំ ។ ឈ្មោះថា **បញ្ញុត្តរា** ព្រោះមានមគ្គប្បញ្ញាជាកំពូល ។ ឈ្មោះថា **វិមុត្តិសារា** ព្រោះអត្ថថា មានការសម្រេចផល-វិមុត្តិជាខ្លឹម ។ ឈ្មោះថា **អមតោគធា** ព្រោះអត្ថថា ឈមចុះកាន់អមត-និព្វាន គឺតាំងនៅក្នុងអមតនិព្វាននោះហើយ ដោយអំណាចអារម្មណ៍ ។ បទថា **តេន វា មា មញ្ញិ** សេចក្ដីថា អ្នកកុំធ្វើការបានចិត្ត ឬអួតអាងដោយការដោះស្រាយនោះថា អគ្គសាវក សួរបញ្ហាហើយ អញដោះស្រាយបានហើយ ដូច្នេះ ៕

## អដ្ឋកថា សមិទ្ធិសូត្រទី ៤ ចប់

# សុត្តន្តបិដក

## គណ្ឌសូត្រទី ៥

[ ១៥ ] ម្នាលភិក្ខុទាំងឡាយ ដូចបុរសរាប់ដោយឆ្នាំមិនតែមួយ មុខដំបៅមាន ៩ គឺមុខដំបៅដែលមិនមានអ្នកណាទម្លាយទាំង ៩ របស់បុរសនោះទេ វត្ថុនីមួយគប្បីហូរចេញ របស់មិនស្អាតក៏គប្បីហូរចេញ ក្លិនអាក្រក់ក៏គប្បីផ្សាយចេញ របស់គួរខ្ពើមក៏គប្បីហូរចេញ វត្ថុនីមួយក៏គប្បីជ្រាបចេញ របស់មិនស្អាតក៏គប្បីជ្រាបចេញ ក្លិនអាក្រក់ក៏គប្បីផ្សាយចេញ របស់ដែលគួរខ្ពើមក៏គប្បីផ្សាយចេញអំពីមុខដំបៅនោះ ៗ ម្នាលភិក្ខុទាំងឡាយ ពាក្យថាបុរសនេះ ជាឈ្មោះរបស់កាយ ដែលប្រកបដោយមហាភូតរូប ៤ នេះ មានមាតាបិតាជាដែនកើត ចម្រើនដោយបាយ និងនំកុម្មាស មានសេចក្ដីមិនទៀង មានកិរិយាប្រោះព្រំ គក់ប្រចាច់ បែកធ្លាយ វិនាសខ្ចាត់ខ្ចាយជាធម្មតា មុខដំបៅមាន ៩ គឺមុខដំបៅដែលមិនមានអ្នកណាទម្លាយទាំង ៩ របស់កាយនោះទេ វត្ថុមួយតែងហូរចេញ របស់មិនស្អាតក៏ហូរចេញ ក្លិនអាក្រក់ក៏ហូរចេញ របស់គួរខ្ពើមក៏ហូរចេញ វត្ថុនីមួយក៏ជ្រាបចេញ របស់មិនស្អាតក៏ជ្រាបចេញ ក្លិនអាក្រក់ក៏ជ្រាបចេញ របស់គួរខ្ពើមក៏ជ្រាបចេញ អំពីមុខដំបៅនោះ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយ ចូរនឿយណាយក្នុងកាយនេះ ៗ

# អដ្ឋកថា

## គណ្ឌសូត្រ

[ ១៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងគណ្ឌសូត្រទី ៥ ដូចតទៅនេះ ៣ ឆ្នាំ ៤ ឆ្នាំ ឈ្មោះថា ការរាប់ឆ្នាំ ។ ឈ្មោះថា **អនេកវស្សគណិកោ** ព្រោះអត្ថថា ឆ្នាំនោះកើតឡើងហើយ រាប់បានច្រើនឆ្នាំ ។ បទថា **តស្សស្ស** កាត់បទជា **តស្ស ភវេយ្យុំ** ប្រែថា គប្បីមានដល់បុសនោះ ។ បទថា **អភេទនមុខានិ** សេចក្ដីថា មិនមែនបែក ព្រោះត្រូវអ្នកណាមួយធ្វើឡើយ តែមុខដំបៅ កើតអំពីកម្មតែម្យ៉ាងពិតៗ ។ បទថា **ជេគុច្ឆិយំយេវ** បានដល់ គួរខ្ពើម គឺជារបស់បដិកូលនោះឯង ។ បទថា **ចាតុម្មហាភូតិកស្ស** បានដល់ កាយសម្រេចដោយមហាភូតរូប ៤ ។ បទថា **ឱទនកុម្មាសុបចយស្ស** បានដល់ កាយសន្សំ គឺចម្រើនធំធាត់ហើយ ដោយបាយ និងនំស្រស់ ។

បទថា **អនិច្ចុច្ឆាទនបរិមទ្ទនភេទនវិទ្ធំសនធម្មស្ស** សេចក្ដីថា មានការមិនទៀងជាធម្មតា ដោយអត្ថថា មានហើយ ទៅជាមិនមាន ។ មានការបិទបាំងជាធម្មតា ដោយការលាបស្រឡាប ដើម្បីកម្ចាត់ក្លិនស្អុយ មានការគក់ប្របាច់ជាធម្មតាដោយដៃ ដើម្បីបន្ទោបង់នូវការឈឺថ្កាត់ ត្រង់អង្គអវយវៈតូចធំ ។ ម្យ៉ាងទៀត ក្នុងកាលនៅក្មេង មានការគក់ប្របាច់ជាធម្មតា ដោយលាបថ្នាំ និងប្របាច់ជាដើម ដើម្បីឲ្យអវយវៈ តូចធំដែលតាំងនៅមិនល្អទាំងនោះ ឲ្យសម្បូរដោយការឲ្យដេកលើភ្លៅទាំងពីរក្នុងបន្ទប់ សូម្បីរក្សាហើយយ៉ាងនេះ ក៏មានការបែកធ្លាយជាធម្មតា អធិប្បាយថា មានការបែកខ្ចាត់ខ្ចាយ

ជាធម្មតា ក្នុងសេចក្តីនេះ លោកពោលការរលត់នៃកាយនោះ ដោយបទថា មិនទៀង និងដោយបទថា បែក និងធ្លាយ លោកពោលការកើតដោយបទដ៏សេស ។ បទថា **និព្វិន្ទថ** លោកសម្តែងថា អ្នកទាំងឡាយ ចូរនឿយណាយ គឺលះបង់កាយនេះចេញ ដូច្នេះ ។ ក្នុងសូត្រនេះ លោកពោលដល់វិបស្សនាដែលមានកម្លាំង ដោយប្រការដូច្នេះ ។៚

**អដ្ឋកថា គណ្ឌសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## សញ្ញាសូត្រទី ៦

[ ១៦ ] ម្នាលភិក្ខុទាំងឡាយ សញ្ញា ៩ យ៉ាងនេះ ដែលបុគ្គលចម្រើន ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានអមតៈជាទីតាំងនៅស៊ប់ មានអមតៈជាបរិយោសាន ។ សញ្ញា ៩ យ៉ាង តើដូចម្តេចខ្លះ ។ គឺអសុភសញ្ញា ១ មរណសញ្ញា ១ អាហារេបដិកូលសញ្ញា ១ សព្វលោកេអនភិរតសញ្ញា ១ អនិច្ចសញ្ញា ១ អនិច្ចេទុក្ខសញ្ញា ១ ទុក្ខេអនត្តសញ្ញា ១ បហានសញ្ញា ១ វិរាគសញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាមាន ៩ យ៉ាងនេះឯង ដែលបុគ្គលចម្រើន ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានអមតៈជាទីតាំងនៅស៊ប់ មានអមតៈជាបរិយោសាន ។

# អដ្ឋកថា

## សញ្ញាសូត្រ

[ ១៦ ] សញ្ញាសូត្រទី ៦ មានន័យដូចលោកពោលហើយ តែក្នុងសូត្រនេះ លោកពោលញាណប៉ុណ្ណោះ ដោយមានសញ្ញាជាធំ ។៚

### អដ្ឋកថាសញ្ញាសូត្រទី ៦ ចប់

# សុត្តន្តបិដក

## កុលសូត្រទី ៧

[ ១៧ ] ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៩ ដែលភិក្ខុមិនទាន់ចូលទៅ ក៏មិនគួរចូលទៅ បើភិក្ខុចូលជ្រុលទៅហើយ ក៏មិនគួរអង្គុយ ។ ត្រកូលប្រកបដោយអង្គ ៩ តើដូចម្តេចខ្លះ ។ គឺគេមិនក្រោកទទួលដោយសេចក្តីពេញចិត្ត ១ មិនថ្វាយបង្គំដោយសេចក្តីពេញចិត្ត ១ មិនឲ្យអាសនៈដោយសេចក្តីពេញចិត្ត ១ លាក់របស់ដែលមាន ១ របស់មានច្រើនឲ្យតិច ១ មានរបស់ដែលថ្លៃថ្លាឲ្យរបស់សៅហ្មង ១ ឲ្យដោយមិនគោរព មិនឲ្យដោយគោរព ១ មិនចូលទៅអង្គុយជិតដើម្បីស្តាប់ធម៌ដោយគោរព ១ មិនត្រេកអរនឹងភាសិតរបស់ភិក្ខុនោះ ១ ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៩ នេះឯង ដែលភិក្ខុមិនធ្លាប់ចូលទៅ ក៏មិនគួរចូលទៅ ឬចូល

ជ្រុលទៅហើយ ក៏មិនគួរអង្គុយ ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៩ ដែលភិក្ខុមិនទាន់ចូលទៅ ក៏គួរចូលទៅបាន ឬចូលទៅហើយ ក៏គួរអង្គុយបាន ។ ត្រកូលប្រកបដោយអង្គ ៩ តើដូចម្តេចខ្លះ ។ គឺគេក្រោកទទួលដោយសេចក្តីពេញចិត្ត ១ ថ្វាយបង្គំដោយសេចក្តីពេញចិត្ត ១ ឲ្យអាសនៈដោយសេចក្តីពេញចិត្ត ១ មិនលាក់របស់ដែលមាន ១ របស់ដែលមានច្រើនឲ្យច្រើន ១ របស់ដែលថ្លៃថ្លាឲ្យរបស់ថ្លៃថ្លា ១ ឲ្យដោយគោរព មិនឲ្យដោយមិនគោរព ១ ចូលទៅអង្គុយជិតដើម្បីស្តាប់ធម៌ ១ ត្រេកអរនឹងភាសិតរបស់ភិក្ខុនោះ ១ ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៩ នេះឯង ដែលភិក្ខុមិនទាន់ចូលទៅ ក៏គួរចូលទៅបាន ឬចូលទៅហើយ ក៏គួរអង្គុយបាន ។

# អដ្ឋកថា

## កុលសូត្រ

[ ១៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកុលសូត្រទី ៧ ដូចតទៅនេះ បទថា **ន មនាបេន បច្ចុដ្ឋេន្តិ** សេចក្តីថា ក្រោកចាកអាសនៈហើយ រមែងមិនធ្វើការទទួលដោយការត្រេកអរ គឺដោយការជាប់ចិត្ត ។ បទថា **ន មនាបេន អភិវាទេន្តិ** សេចក្តីថា រមែងមិនថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ។ បទថា

**អសក្កច្ចំ ទេន្តិ** សេចក្តីថា រមែងឲ្យដោយការមិនរាប់អាន ។ បទថា **នោ សក្កច្ចំ** សេចក្តីថា រមែងមិនឲ្យដោយដៃរបស់ខ្លួន ។ បទថា **ន ឱបនិសីទន្តិ ធម្មស្សវនាយ** សេចក្តីថា រមែងមិនអង្គុយក្នុងទីជិត ដោយគិតថា យើងទាំងឡាយនឹងស្តាប់ធម៌ ។ បទថា **ន រមិស្សន្តិ** សេចក្តីថា រមែងមិនត្រេកអរ គឺរមែងទៅមិនត្រឡប់ ដូចទឹកដែលស្រក់លើពាងធំ ដូច្នោះ ។

**អដ្ឋកថា កុលសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## សត្តសូត្រទី ៨

[ ១៨ ] ម្នាលភិក្ខុទាំងឡាយ ឧបោសថប្រកបដោយអង្គ ៩ ប្រការ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានការផ្សាយទៅច្រើន ។ ម្នាលភិក្ខុទាំងឡាយ ឧបោសថប្រកបដោយអង្គ ៩ ប្រការ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានការផ្សាយទៅច្រើន តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ពិចារណាដូច្នេះថា ព្រះអរហន្តទាំងឡាយ លះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មាន

សេចក្តីខ្មាស ដល់នូវសេចក្តីអាណិតអាសូរ អនុគ្រោះដោយប្រយោជន៍ដល់សត្វទាំងអស់ជរាបអស់ជីវិត ក្នុងថ្ងៃនេះ ចំណែកអាត្មាអញ ក៏លះបង់នូវបាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាស ដល់នូវសេចក្តីអាណិតអាសូរ អនុគ្រោះដោយប្រយោជន៍ដល់សត្វទាំងពួង អស់យប់នេះ និងថ្ងៃនេះដែរ អាត្មាអញយកតម្រាប់ព្រះអរហន្តផង អាត្មាអញនឹងចាំរក្សាឧបោសថដោយអង្គនេះផង ឧបោសថប្រកបដោយអង្គទី ១ នេះ ដូច្នេះ ។បេ។ ព្រះអរហន្តលះបង់ទីដេកដ៏ខ្ពស់ និងទីដេកដ៏ប្រសើរ វៀរចាកទីដេកដ៏ខ្ពស់ និងទីដេកដ៏ប្រសើរ សម្រេចនូវទីដេកដ៏ទាប គឺលើគ្រែតូចក្តី លើកម្រាលស្មៅក្តី ជរាបអស់ជីវិត ក្នុងថ្ងៃនេះ ចំណែកអាត្មាអញ ក៏លះបង់ទីដេកដ៏ខ្ពស់ និងទីដេកដ៏ប្រសើរ វៀរចាកទីដេកដ៏ខ្ពស់ និងទីដេកដ៏ប្រសើរ សម្រេចទីដេកដ៏ទាប គឺលើគ្រែតូចក្តី លើកម្រាលស្មៅក្តី អស់យប់នេះ និងថ្ងៃនេះដែរ អាត្មាអញយកតម្រាប់ព្រះអរហន្តផង អាត្មាអញនឹងរក្សាឧបោសថដោយអង្គនេះឯងឧបោសថប្រកបដោយអង្គទី ៨ នេះដូច្នេះ បុគ្គលមានចិត្តប្រកបដោយមេត្តាផ្សាយទៅកាន់ទិសទី ១ ទី ២ ទី ៣ ទី ៤ ក៏ដូចៗ គ្នា ផ្សាយទៅកាន់ទិសខាងលើ ខាងក្រោម និងទិសទទឹង មានចិត្តប្រកបដោយមេត្តាដ៏ទូលាយប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយយកខ្លួនប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងពួង ឧបោសថ

ប្រកបដោយអង្គទី ៩ នេះដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ឧបោសថប្រកបដោយអង្គ ៩ ប្រការ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានតេជះច្រើន មានការផ្សាយទៅច្រើន យ៉ាងនេះឯង ៗ។

# អដ្ឋកថា

## សត្តសូត្រ

[ ១៨ ] ក្នុងសត្តសូត្រទី ៨ លោកពោលថា ឧបោសថប្រកបដោយអង្គ ៩ ( ព្រោះ ) បន្ថែមមេត្តាភាវនា ដោយអំណាចអធ្យាស្រ័យរបស់វេនេយ្យបុគ្គល ៗ។

**អដ្ឋកថា សត្តសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## ទេវតាសូត្រទី ៩

[ ១៩ ] ម្នាលភិក្ខុទាំងឡាយ ក្នុងវេលាយប់នេះ ពួកទេវតាជាច្រើន កាលដែលរាត្រីបឋមយាមកន្លងទៅហើយ មានរស្មីដ៏រុងរឿង ញុំាងវត្តជេតពនទាំងអស់ឲ្យភ្លឺច្បាស់ ចូលមករកតថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគត ហើយឋិតនៅក្នុងទីសមគួរ ។ ម្នាលភិក្ខុទាំងឡាយ លុះពួកទេវតាទាំងនោះ ឋិតនៅក្នុងទីសមគួរហើយ បានពោលនឹងតថាគតដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកបព្វជិតបានមកកាន់ផ្ទះយើងខ្ញុំព្រះអង្គ កាលដែលកើតជាមនុស្ស ក្នុងកាលមុន បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គទាំងនោះ បានក្រោកទទួលហើយ តែមិនបានថ្វាយបង្គំ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គទាំងនោះ ជាអ្នកមានបុញ្ញកម្មមិនបរិបូណ៌ គួរឲ្យមានសេចក្តីស្តាយ ក្តៅក្រហាយជាខាងក្រោយ ទើបបានទៅកើតក្នុងពួកថោកទាប ។ ម្នាលភិក្ខុទាំងឡាយ ពួកទេវតាជាច្រើនពួកទៀត ចូលមករកតថាគត ហើយពោលដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកបព្វជិតចូលមកកាន់ផ្ទះរបស់យើងខ្ញុំព្រះអង្គ កាលដែលកើតជាមនុស្សក្នុងកាលមុន យើងខ្ញុំព្រះអង្គទាំងនោះបានក្រោកទទួលផង បានថ្វាយបង្គំផង ហើយតែមិនបានប្រគេនអាសនៈ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គទាំងនោះ ជាអ្នកមានបុញ្ញកម្ម មិនបរិបូណ៌ មានសេចក្តីស្តាយ ក្តៅក្រហាយជាខាងក្រោយ ទើបបានទៅកើតក្នុងពួកថោកទាប ។ ម្នាលភិក្ខុទាំងឡាយ ពួកទេវតាជាច្រើនផ្សេងៗ ទៀត

ចូលមករកតថាគត បានពោលដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកបព្វជិត បានចូលមកកាន់ផ្ទះរបស់យើងខ្ញុំព្រះអង្គ កាលដែលកើតជាមនុស្សក្នុងកាលមុន បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងនោះ បានក្រោកទទួលផង ថ្វាយបង្គំផង បានប្រគេនអាសនៈផង តែមិនបានចាត់ចែង តាមសមគួរដល់យសសក្តិ តាមសមគួរដល់កម្លាំង ។បេ។ ចាត់ចែងតាមសមគួរដល់យសសក្តិ តាមសមគួរដល់កម្លាំងហើយ តែមិនបានចូលទៅអង្គុយជិត ដើម្បីស្តាប់ធម៌ បានចូលទៅអង្គុយជិត ដើម្បីស្តាប់ធម៌ហើយ តែមិនបានផ្ចង់ត្រចៀកស្តាប់ធម៌ បានផ្ចង់ត្រចៀកស្តាប់ធម៌ហើយ តែថា ស្តាប់ធម៌ហើយមិនបានចាំទុក បានស្តាប់ធម៌ចាំទុកហើយ តែថា មិនបានពិចារណាសេចក្តីនៃធម៌ដែលចាំទុក ពិចារណាសេចក្តីនៃធម៌ដែលចាំទុកបានហើយ តែថា យល់អត្ថ យល់ធម៌ហើយ មិនបានប្រតិបត្តិធម៌ តាមសមគួរដល់ធម៌ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គទាំងនោះ ជាអ្នកមានបុញ្ញកម្ម មិនបរិបូណ៌ គួរឲ្យមានសេចក្តីស្តាយ ក្តៅក្រហាយខាងក្រោយ ទើបទៅកើតក្នុងពួកថោកទាប ម្នាលភិក្ខុទាំងឡាយ ពួកទេវតាជាច្រើនផ្សេងទៀត ចូលមករកតថាគត ហើយពោលដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកបព្វជិតចូលមកកាន់ផ្ទះរបស់យើងខ្ញុំព្រះអង្គ កាលដែលកើតជាមនុស្សក្នុងកាលមុន យើងខ្ញុំព្រះអង្គទាំងនោះ បានក្រោកទទួលផង បានថ្វាយបង្គំផង បានប្រគេនអាសនៈផង បានចាត់ចែងតាមសមគួរដល់យសសក្តិ តាមសមគួរដល់កម្លាំងផង ចូលទៅអង្គុយ

ជិតស្តាប់ធម៌ផង ផ្ទង់ត្រចៀកស្តាប់ធម៌ផង ស្តាប់ធម៌ហើយ បានចាំទុកផង បានពិចារណាសេចក្តីនៃធម៌ដែលចាំទុកផង យល់អត្ថ យល់ធម៌ ហើយប្រតិបត្តិធម៌តាមសមគួរដល់ធម៌ផង បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គទាំងនោះ ជាអ្នកមានបុញ្ញកម្មបរិបូណ៌ មិនមានសេចក្តីស្តាយ ក្តៅក្រហាយខាងក្រោយ ទើបបានទៅកើតក្នុងពួកខ្ពង់ខ្ពស់ ។ ម្នាលភិក្ខុទាំងឡាយ នុ៎ះជារុក្ខមូល នុ៎ះជាសុញ្ញាគារដ្ឋាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចម្រើនឈាន ចូរកុំប្រមាទ ចូរកុំមានសេចក្តីស្តាយ ក្នុងកាលខាងក្រោយ ដូចជាពួកទេវតាមុននោះឡើយ ។

## អដ្ឋកថា

## ទេវតាសូត្រ

[ ១៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទេវតាសូត្រទី ៩ ដូចតទៅនេះ បទថា **វិប្បដិសារិនិយោ** សេចក្តីថា ខ្ញុំព្រះអង្គទាំងឡាយ ដល់នូវការក្តៅក្រហាយ គឺភាពជាអ្នកខ្មាសអៀន ។ បទថា **ហីនំ កាយំ** សេចក្តីថា ពួកទេវតាជាន់ទាប លោកហៅថា ថោកទាប ក៏ព្រោះអាស្រ័យទេវលោកជាន់ខ្ពស់ ។ បទថា **នោ ច ខោ យថាសត្តិយថាពលំ សំវិភជិម្ហា** សេចក្តីថា ខ្ញុំព្រះអង្គទាំងឡាយ មិនទាន់បែងចែករបស់ ឲ្យដល់អ្នកមានសីលទាំងឡាយ តាម

សមត្ថភាព គឺតាមសមគួរដល់កម្លាំងរបស់ខ្លួន បរិភោគហើយ ។

## អដ្ឋកថា ទេវតាសូត្រទី ៩ ចប់

# សុត្តន្តបិដក

## វេលាមសូត្រទី ១០

[ ២០ ] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់ក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះ អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរដូច្នេះថា ម្នាលគហបតី ទានក្នុងត្រកូលអ្នកនៅតែឲ្យដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ទានក្នុងត្រកូលខ្ញុំព្រះអង្គនៅតែឲ្យដែរ តែទាននោះឯងស្មោហ្មង គឺបាយចុងអង្ករ និងទឹកជ្រក់ជាគម្រប់ ២ ។ ម្នាលគហបតី បុគ្គលឲ្យទានសៅហ្មងក្តី ឲ្យទានថ្លៃថ្លាក្តី តែឲ្យទាននោះមិនគោរព ធ្វើសេចក្តីកោតក្រែងហើយឲ្យ មិនឲ្យដោយដៃខ្លួនឯង បោះឲ្យ យល់ថា មិនមានផល ហើយឲ្យ វិបាករបស់ទាននោះៗ កើតក្នុងត្រកូលណាៗ ចិត្តក៏មិនឱនទៅ ដើម្បីប្រើប្រាស់នូវភត្តដ៏ថ្លៃថ្លា ចិត្តមិនឱនទៅ

ដើម្បីប្រើប្រាស់នូវសំពត់ដ៏ថ្លៃថ្លា ចិត្តមិនឱនទៅ ដើម្បីប្រើប្រាស់យានដ៏ថ្លៃថ្លា ចិត្តមិនឱនទៅ ដើម្បីប្រើប្រាស់ក្នុងកាមគុណ ៥ ដ៏ថ្លៃថ្លា មួយទៀត ពួកជនណា ដែលជាកូនក្តី ប្រពន្ធក្តី ទាសៈក្តី អ្នកបម្រើក្តី កម្មករក្តី របស់បុគ្គលនោះ ជនទាំងនោះ មិនស្តាប់ មិនផ្ចង់ត្រចៀកស្តាប់ រមែងបញ្ជូនចិត្តទៅក្នុងអារម្មណ៍ដទៃ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលគហបតី ព្រោះថា វិបាកនៃកម្មទាំងឡាយ ដែលបុគ្គលធ្វើដោយមិនគោរព រមែងមានយ៉ាងនេះឯង ម្នាលគហបតី បុគ្គលឲ្យទានសៅហ្មងក្តី ថ្លៃថ្លាក្តី តែឲ្យទាននោះដោយគោរព ធ្វើសេចក្តីកោតក្រែង ហើយឲ្យ ឲ្យដោយដៃខ្លួនឯង មិនបោះឲ្យ យល់ថា មានផល ហើយឲ្យ វិបាករបស់ទាននោះៗ កើតក្នុងត្រកូលណាៗ ចិត្តក៏រមែងឱនទៅ ដើម្បីប្រើប្រាស់ភត្តដ៏ថ្លៃថ្លា ចិត្តរមែងឱនទៅ ដើម្បីប្រើប្រាស់សំពត់ដ៏ថ្លៃថ្លា ចិត្តរមែងឱនទៅ ដើម្បីប្រើប្រាស់យានដ៏ថ្លៃថ្លា ចិត្តរមែងឱនទៅ ដើម្បីប្រើប្រាស់ក្នុងកាមគុណ ៥ ដ៏ថ្លៃថ្លា មួយទៀត ពួកជនណា ដែលជាកូនក្តី ប្រពន្ធក្តី ទាសៈក្តី អ្នកបម្រើក្តី កម្មករក្តី របស់បុគ្គលនោះ ជនទាំងនោះ រមែងស្តាប់ ផ្ចង់ត្រចៀកស្តាប់ មិនបញ្ជូនចិត្តទៅក្នុងអារម្មណ៍ដទៃឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលគហបតី ព្រោះថា វិបាករបស់កម្មទាំងឡាយ ដែលបុគ្គលធ្វើដោយគោរព រមែងមានយ៉ាងនេះឯង ។ ម្នាលគហបតី កាលពីព្រេងនាយ មានព្រាហ្មណ៍ឈ្មោះវេលាមៈ លោកបានឲ្យទាន ជាមហាទាន មានសភាពយ៉ាងនេះ គឺបានឲ្យ

ភាជន៍មាស ៨៤០០០ ដែលពេញដោយប្រាក់ បានឲ្យភាជន៍ប្រាក់ ៨៤០០០ ដែលពេញដោយមាស បានឲ្យភាជន៍សំរិទ្ធិ ៨៤០០០ ដែលពេញដោយប្រាក់ បានឲ្យដំរី ៨៤០០០ ដែលមានគ្រឿងអលង្ការមាស មានទង់ជ័យមាស ព្រមទាំងបាំងដោយបណ្តាញមាស បានឲ្យរថ ៨៤០០០ ដែលពាសដោយស្បែកសីហៈ ដែលពាសដោយស្បែកខ្លាធំ ពាសដោយស្បែកខ្លាដំបង ពាសដោយសំពត់កម្ពល មានពណ៌លឿង មានគ្រឿងអលង្ការមាស មានទង់ជ័យមាស បិទបាំងដោយបណ្តាញមាស បានឲ្យមេគោ ៨៤០០០ សម្រាប់រូតបង្ហូរ ( ទឹកដោះ ) មានភាជន៍សំរិទ្ធិសម្រាប់ត្រង បានឲ្យនាងកញ្ញា ៨៤០០០ ដែលពាក់កែវមណី និងកុណ្ឌល បានឲ្យបល្ល័ង្ក ៨៤០០០ ដែលក្រាលដោយព្រំ ក្រាលដោយកម្រាលរោមមានពណ៌ស ក្រាលដោយកម្រាលរោម មានផ្កាជាចង្កោម ក្រាលដោយកម្រាលដ៏ប្រសើរ ធ្វើពីរោមម្រឹគឈ្មុស មានខ្នើយមានពណ៌ក្រហមទាំង ២ ខាង ព្រមទាំងពិតានមានពណ៌ក្រហម បានឲ្យកោដិនៃសំពត់ ៨៤០០០ គឺសំពត់ធ្មៃមានសាច់ល្អិត សំពត់សូត្រមានសាច់ល្អិត សំពត់អម្បោះមានសាច់ល្អិត បាច់និយាយថ្វីដល់បាយ ទឹក បង្អែម ភោជន គ្រឿងលាបទីដេក ដូចជាស្ទឹងតែងហូរទៅ ម្នាលគហបតី អ្នកប្រហែលជាមានសេចក្តីសម្គាល់នូវវេលាមព្រាហ្មណ៍នុ៎ះ យ៉ាងនេះថា ក្នុងសម័យនោះ វេលាម-ព្រាហ្មណ៍ ជាបុគ្គលដទៃដោយពិត ( ក្រៅពីតថាគត ) លោកបានឲ្យទាននោះ ជាមហាទាន ។ ម្នាលគហបតី ហេតុនុ៎ះ អ្នកមិនត្រូវយល់យ៉ាងនេះ

ឡើយ ក្នុងសម័យនោះ វេលាមព្រាហ្មណ៍ ក៏គឺតថាគត ទានដែលតថាគត បានឲ្យនោះ ជាមហាទាន ។ ម្នាលគហបតី មិនមានទក្ខិណេយ្យបុគ្គលណា មួយ ក្នុងទាននោះទេ មិនមានបុគ្គលណាមួយ សម្អាតទក្ខិណាទាននោះទេ ។ ម្នាលគហបតី វេលាមព្រាហ្មណ៍បានឲ្យទានណា ដែលឈ្មោះថាមហាទាន និងបុគ្គលណាញ៉ាំងបុគ្គលដែលមានទិដ្ឋិល្អមួយរូប ( សោតាបន្នបុគ្គល ) ឲ្យ បរិភោគទាននេះ ជាទានមានផលច្រើនជាងមហាទាន បុគ្គលណា ញ៉ាំង បុគ្គលដែលមានទិដ្ឋិល្អ ១០០ រូបឲ្យបរិភោគ និងបុគ្គលណា ញ៉ាំងបុគ្គល ជាសកទាគាមី ១ រូបឲ្យបរិភោគ ។បេ។ បុគ្គលណា ញ៉ាំងបុគ្គលជាសក-ទាគាមី ១០០ រូបឲ្យបរិភោគ និងបុគ្គលណា ញ៉ាំងបុគ្គលជាអនាគាមី ១ រូប ឲ្យបរិភោគ បើបុគ្គលណា ញ៉ាំងបុគ្គលជាអនាគាមី ១០០ រូបឲ្យបរិភោគ និងបុគ្គលណា ញ៉ាំងបុគ្គលជាព្រះអរហន្ត ១ រូបឲ្យបរិភោគ បុគ្គលណា ញ៉ាំងបុគ្គលជាព្រះអរហន្ត ១០០ រូបឲ្យបរិភោគ និងបុគ្គលណា ញ៉ាំងព្រះ បច្ចេកពុទ្ធ ១ អង្គឲ្យបរិភោគ បុគ្គលណា ញ៉ាំងព្រះបច្ចេកពុទ្ធ ១០០ អង្គ ឲ្យបរិភោគ និងបុគ្គលណា ញ៉ាំងព្រះតថាគត អរហន្តសម្មាសម្ពុទ្ធឲ្យ បរិភោគ បុគ្គលណា ញ៉ាំងសង្ឃ មានព្រះពុទ្ធជាប្រធានឲ្យបរិភោគ និង បុគ្គលណា ឲ្យគេធ្វើវិហារ ឧទ្ទិសចំពោះសង្ឃមកពីទិសទាំង ៤ បុគ្គលណា មានចិត្តជ្រះថ្លាដល់នូវព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង និង បុគ្គលណា មានចិត្តជ្រះថ្លា សមាទាននូវសិក្ខាបទទាំងឡាយ គឺចេតនាវៀរ

ចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ ដោយការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ បុគ្គលណា មានចិត្តជ្រះថ្លា សមាទាននូវសិក្ខាបទទាំងឡាយ គឺចេតនាវៀរចាកបាណាតិបាត ។បេ។ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ ដោយការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ដោយហោចទៅ បុគ្គលណា ចម្រើននូវមេត្តាចិត្ត សូម្បីអស់កាលត្រឹមតែមួយរឹតទឹកដោះគោប៉ុណ្ណោះ ការចម្រើនមេត្តាចិត្តនេះ របស់បុគ្គលទាំងនោះ មានផលច្រើនជាងទាននោះទៅទៀត ។ ម្នាលគហបតី វេលាមព្រាហ្មណ៍បានឲ្យទាន ជាមហាទានណា និងបុគ្គលណា ញុំាងបុគ្គលមានទិដ្ឋិសម្បន្ន ១ រូប ឲ្យបរិភោគ បុគ្គលណា ញុំាងបុគ្គលមានទិដ្ឋិសម្បន្ន ១០០ រូបឲ្យបរិភោគ និងបុគ្គលណា ញុំាងបុគ្គលជាសកទាគាមី ១ រូបឲ្យបរិភោគ បុគ្គលណា ញុំាងបុគ្គលជាសកទាគាមី ១០០ រូបឲ្យបរិភោគ និងបុគ្គលណា ញុំាងបុគ្គលជាអនាគាមី ១ រូបឲ្យបរិភោគ បុគ្គលណា ញុំាងបុគ្គលជាអនាគាមី ១០០ រូប ឲ្យបរិភោគ និងបុគ្គលណា ញុំាងព្រះអរហន្ត ១ អង្គឲ្យបរិភោគ បុគ្គលណា ញុំាងព្រះអរហន្ត ១០០ អង្គ ឲ្យបរិភោគ និងបុគ្គលណា ញុំាងព្រះបច្ចេកពុទ្ធ ១ អង្គ ឲ្យបរិភោគ បុគ្គលណា ញុំាងពួកព្រះបច្ចេកពុទ្ធ ១០០ អង្គ ឲ្យបរិភោគ និងបុគ្គលណា ញុំាងព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ឲ្យបរិភោគ បុគ្គលណា ញុំាងភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានឲ្យបរិភោគ និងបុគ្គលណា ឲ្យគេធ្វើ

វិហារ ឧទ្ទិសចំពោះសង្ឃមកអំពីទិសទាំង ៤ បុគ្គលណា មានចិត្តជ្រះថ្លា ដល់នូវព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង និងបុគ្គលណា មានចិត្តជ្រះថ្លា សមាទាននូវសិក្ខាបទទាំងឡាយ គឺចេតនាវៀរចាកបាណាតិបាត ។បេ។ វៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ ដោយការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ដោយហោចទៅ និងបុគ្គលណា ចម្រើននូវមេត្តាចិត្ត សូម្បីអស់កាលត្រឹមតែមួយរឺតទឹកដោះគោប៉ុណ្ណោះ និងបុគ្គលណា ចម្រើននូវអនិច្ចសញ្ញា សូម្បីអស់កាលគ្រាន់តែផ្ទាត់ម្រាមដៃប៉ុណ្ណោះ ការចម្រើននេះ មានផលច្រើនជាងទាននោះទៅទៀត ។

*សីហនាទវគ្គទី ២ ចប់*

## ឧទ្ទានក្នុងសីហនាទវគ្គនោះគឺ

និយាយអំពីការចាំរក្សាឧបោសថ ១ សឧបាទិសេស និង
អនុបាទិសេស ១ ព្រះកោដ្ឋិតភិក្ខុ ១ ព្រះសមិទ្ធិភិក្ខុ ១
កាយដូចជាបូស ១ សញ្ញា ១ ត្រកូល ១ មេត្តា ១
ទេវតា ១ វេលាមព្រាហ្មណ៍ ១ ។

# អដ្ឋកថា

## វេលាមសូត្រ

[ ២០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវេលាមសូត្រទី ១០ ដូចតទៅនេះ បទថា **អបិ នុ តេ គហបតិ កុលេ ទានំ ទិយ្យតិ** សេចក្តីថា ព្រះមានព្រះភាគទ្រង់មិនបានត្រាស់សួរដល់ទាន ដែលគាត់ប្រគេនដល់ភិក្ខុសង្ឃ ពិតហើយ ក្នុងផ្ទះរបស់សេដ្ឋីនៅឲ្យទានដ៏ប្រណីត ជាប្រចាំដល់ភិក្ខុសង្ឃ ព្រះសាស្តាទ្រង់មិនដឹងដល់សេចក្តីនោះក៏មិនមែន ចំណែកទានដែលឲ្យដល់លោកិយមហាជន ទាននោះសៅហ្មង សេដ្ឋីមិនត្រេកអរ ទើបត្រាស់សួរទាននោះ ។ បទថា **កាណាជកំ** សេចក្តីថា អង្ករលាយកន្ទក់ គឺចម្អិនហើយ ដោយអង្ករមួយកាកណិកលាយនឹងកន្ទក់ ។ បទថា **ពិលង្គទុតិយំ** គឺមានទឹកបន្ទៃ ៥ ជាគម្រប់ ២ ។

បទថា **អសក្កច្ចំ ទេតិ** បានដល់ ឲ្យដោយមិនគោរព ។ បទថា **អបចិត្តឹ កត្វា ទេតិ** សេចក្តីថា ឲ្យដោយមិនរាប់អាន គឺមិនគោរពក្នុងទក្ខិណេយ្យបុគ្គល ។ បទថា **អសហត្ថា ទេតិ** សេចក្តីថា មិនឲ្យដោយដៃរបស់ខ្លួន ឲ្យដោយដៃរបស់អ្នកដទៃ អធិប្បាយថា រមែងធ្វើត្រឹមតែពាក្យប្រើប៉ុណ្ណោះ ។ បទថា **អបវិទ្ធំ ទេតិ** សេចក្តីថា មិនឲ្យជាប់តគ្នា គឺឲ្យដូចបុគ្គលប្រាថ្នានឹងបោះចោល ដូចបុគ្គលចាប់ទន្សងដាក់ក្នុងដំបូក ដូចគ្រឿងសំណែនរបស់អ្នកលេងសុរាប្រចាំឆ្នាំ ដូច្នោះ ។ បទថា **អនាគមនទិដ្ឋិកោ ទេតិ** សេចក្តីថា មិនជឿកម្ម និងផលនៃកម្ម ហើយឲ្យទាន ។

*បទថា* **យត្ថ យត្ថ** *បានដល់ បណ្តាកុលសម្បទាទាំង ៣ ក្នុងត្រកូលណាមួយ ក្នុងបទជាដើមថា* **ឆ ឧឡារាយ ភត្តភោគាយ** *មានវិនិច្ឆ័យដូច្នេះថា កាលបុគ្គលបង្អោនភោជននៃស្រូវសាលីក្រអូប ដែលមានរសឆ្ងាញ់ផ្សេងៗ ចូលទៅហើយ បុគ្គលនោះមិនបង្អោនចិត្តទៅដើម្បីបរិភោគ គង់ពោលថា អ្នកចូរនាំទៅចុះ ទុំរភេគកម្រើក ដូច្នេះ គាប់ចិត្តបរិភោគបាយបុងអង្ករមានទឹកជ្រក់ ដូចបរិភោគអមតៈ។ កាលបុគ្គលបង្អោនសំពត់យ៉ាងល្អ មានសំពត់កាសីជាដើមចូលទៅហើយ ក៏ពោលថា អ្នកចូរនាំទៅចុះ សំពត់ទាំងនេះមិនអាចបិទបាំងបាន រមែងមិនជាប់នៅត្រង់រាងកាយរបស់បុគ្គលដែលស្លៀក ដូច្នេះ ពេញចិត្តនឹងសំពត់ដែលមានសាច់គ្រោតគ្រាត ដូចគ្នានឹងសម្បកដូង ធ្វើជាសំពត់ដោយគិតថា បុគ្គលស្លៀកសំពត់ទាំងនេះ រមែងដឹងថា ស្លៀកដណ្តប់ហើយ សំពត់ទាំងនោះ រមែងបិទបាំងនូវវត្ថុដែលគួរបិទបាំង ដូច្នេះ កាលបុគ្គលបង្អោនយានដំរី យានសេះ រថ ឬ វិមានជាដើមចូលទៅឲ្យ ក៏ពោលថា អ្នកចូរនាំទៅចុះ យានទាំងនោះ បុគ្គលណាម្នាក់មិនអាចអង្គុយជាសុខក្នុងយាននេះបានឡើយ ដូច្នេះ កាលបុគ្គលបង្អោនរថចាស់គ្រាំគ្រាចូលទៅ ក៏ពោលថា រថនេះមិនរង្គើ ក្នុងរថនេះអង្គុយបានជាសុខ ដូច្នេះ រមែងត្រេកអរក្នុងរថនោះ។ បទថា* **ឆ ឧឡារេសុ បញ្ចសុ កាមគុណេសុ** *សេចក្តីថា បុគ្គលនោះបានឃើញស្រីទាំងឡាយ ជាអ្នកមានរូបប្រដាប់តាក់តែងហើយគិតថា ស្រីនេះ ប្រហែលគ្នានឹងយក្ខិនី យក្ខិនីទាំង*

*នោះ ជាអ្នកប្រាថ្នានឹងស៊ី ប្រយោជន៍អ្វីដោយស្រីទាំងនោះ ដូច្នេះ រមែងឲ្យកាលកន្លងទៅតាមផាសុក ។ បទថា* **ន សុស្សូសន្តិ** *សេចក្ដីថា បរិវារជនទាំងឡាយ រមែងមិនប្រាថ្នានឹងស្ដាប់ អធិប្បាយថា រមែងមិនស្ដាប់បង្គាប់ក៏មាន ។ បទថា* **ន សោតំ ឱទហន្តិ** *សេចក្ដីថា រមែងមិនផ្ទៀងសោតប្បសាទដើម្បីស្ដាប់ពាក្យដែលបុគ្គលនោះពោលហើយ ។ បទជាដើមថា* **សក្កច្ចំ** *គប្បីជ្រាបដោយបរិយាយផ្ទុយគ្នាតាមដែលពោលហើយ ។*

*បទថា* **វេលាមោ** *សេចក្ដីថា ជាឈ្មោះដែលបានហើយយ៉ាងនេះ ព្រោះប្រកបដោយគុណទាំងឡាយដ៏ធំកន្លងនូវព្រំដែន ជាតិ គោត្រ រូប ភោគៈ សទ្ធា និងបញ្ញាជាដើម ។ ក្នុងបទថា* **សោ ឯវរូបំ ទានមទាសិ មហាទានំ** *នេះ មានអនុបុព្វីកថាដូច្នេះតទៅ*

*បានឮថា ក្នុងអតីតកាល វេលាមព្រាហ្មណ៍នោះ បានបដិសន្ធិហើយក្នុងផ្ទះបុរោហិត ក្នុងក្រុងពារាណសី ពួកញាតិបានដាក់ឈ្មោះថា វេលាមកុមារ ។ វេលាមកុមារនោះ បានទៅហើយកាន់នគរតក្កសិលា ដើម្បីរៀនសិប្បៈ ជាមួយរាជកុមារក្រុងពារាណសី ក្នុងកាលអាយុ ១៦ ឆ្នាំ ជនទាំង ២ នោះប្រាថ្នាហើយនូវសិប្បៈ ក្នុងសម្នាក់របស់អាចារ្យទិសាបាមោក្ខ ។ ពួកបុគ្គលប្រាថ្នាហើយយ៉ាងណា ចំណែករាជកុមារ ៨៤០០០ នាក់ ក្នុងជម្ពូទ្វីបក៏ប្រាថ្នាហើយ ដូច្នោះ ។ ព្រះពោធិសត្វដឹងថា តំណែងខ្លួនបានទទួលជាអាចារ្យ ទើបឲ្យកុមារ ៨៤០០០ សិក្សា ខ្លួនឯងរៀនសិប្បៈដែលគេរៀន ១៦*

ឆ្នាំ ចប់ក្នុងកាល ៣ ឆ្នាំប៉ុណ្ណោះ ។ អាចារ្យដឹងថា សិប្បៈរបស់វេលាមកុមារស្ទាត់ជំនាញហើយ ទើបពោលថា នែកូនទាំងឡាយ វេលាមៈចេះនូវសិប្បៈទាំងអស់ដែលខ្ញុំចេះហើយ ពួកអ្នកគ្រប់គ្នា ចូរស្រុះស្រួលគ្នារៀនសិប្បៈក្នុងសម្នាក់របស់វេលាមៈ ដូច្នេះ ទើបប្រគល់កុមារ ៨៤០០០ ឲ្យដល់ព្រះពោធិសត្វៗ ថ្វាយបង្គំអាចារ្យហើយ ជាអ្នកមានកុមារ ៨៤០០០ ចោមរោមចេញទៅហើយ ដល់ក្រុងដែលនៅជិតមួយកន្លែង ទើបឲ្យរាជកុមារដែលជាម្ចាស់ក្រុងនោះរៀន កាលរាជកុមារជំនាញក្នុងសិប្បៈហើយ ទើបបញ្ជូនទៅកាន់ក្រុងនោះឯង ។ ព្រះពោធិសត្វទៅកាន់ក្រុង ៨៤០០០ ដោយឧបាយនោះហើយឲ្យរៀននូវសិប្បៈរបស់ព្រះរាជកុមារ ៨៤០០០ ជំនាញហើយ ទើបឲ្យរាជកុមារនោះៗ ត្រឡប់ទៅក្នុងក្រុងនោះៗ ហើយក៏នាំព្រះរាជកុមារក្រុងពារាណសី ត្រឡប់មកកាន់ក្រុងពារាណសី ។ មនុស្សទាំងឡាយក្នុងក្រុងពារាណសីនោះ បានអភិសេករាជកុមារដែលរៀនចប់សិប្បៈហើយទុកក្នុងរាជសម្បត្តិ បានឲ្យតំណែងបុរោហិតដល់វេលាមៈ ។ រាជកុមារ ៨៤០០០ នោះបានអភិសេកហើយ ក្នុងរាជសម្បត្តិទាំងឡាយរបស់ខ្លួន ក៏នៅតែនាំគ្នាមកទំនុកបម្រុងព្រះបាទពារាណសីរាល់ឆ្នាំ ។ ព្រះរាជកុមារទាំងនោះ គាល់ព្រះរាជាហើយ បានទៅកាន់សម្នាក់របស់វេលាមៈ ពោលថា បពិត្រលោកអាចារ្យ កាលយើងទាំងឡាយតាំងនៅក្នុងរាជសម្បត្តិ លោកអាចារ្យត្រូវការវត្ថុណាគប្បីប្រាប់ ហើយក៏នាំគ្នាទៅ ។ កាលរាជកុមារទាំងនោះ នាំយករទេះ

រថ មោគោ ឰគោ មាន់ និងជ្រូកជាដើម ក្នុងកាលទៅ និងកាលមកជនបទក៏ត្រូវបៀតបៀនយ៉ាងធ្ងន់ ។ មហាជនប្រជុំព្រមគ្នា ហើយនាំគ្នាស្រែកសំណូមពរត្រង់លានព្រះរាជវាំង ។ ព្រះរាជាត្រាស់ឲ្យហៅវេលាមៈមកហើយត្រាស់ថា នែលោកអាចារ្យ ជនបទត្រូវបៀតបៀន ព្រះរាជាទាំងឡាយ ធ្វើនូវការប្រជុំ ក្នុងពេលទៅ និងពេលមក មនុស្សទាំងឡាយ មិនអាចតាំងនៅស្ងប់បានឡើយ អ្នកចូរធ្វើឧបាយណាមួយ ដើម្បីឲ្យជនបទស្ងប់ចាកការបៀតបៀន ដូច្នេះ ។ វេលាមៈក្រាបទូលថា បពិត្រមហារាជ ទូលបង្គំនឹងធ្វើឧបាយ ទ្រង់មានសេចក្ដីត្រូវការដោយជនបទប្រមាណប៉ុនណា ទ្រង់កំណត់នូវជនបទនោះ ហើយកាន់យក ។ ព្រះរាជាទ្រង់បានធ្វើយ៉ាងនោះហើយ ។ វេលាមៈដើរមើលក្នុងជនបទរបស់ព្រះរាជា ៨៤០០០ ទើបឲ្យរួមចូលមកក្នុងជនបទរបស់ព្រះរាជា ដូចរួមកាំរទេះទុកត្រង់ដុំ ដូច្នោះ ។ ចាប់តាំងអំពីនោះព្រះរាជាទាំងឡាយនោះ យាងមកក្ដី ទៅក្ដី រមែងត្រាច់ទៅតាមជនបទរៀងៗខ្លួនប៉ុណ្ណោះ ទ្រង់មិនធ្វើការប្រជុំ ដោយទ្រង់ត្រិះរិះថា ជនបទរបស់យើងទាំង-ឡាយ ដូច្នេះ ទ្រង់មិនបៀតបៀនជនបទរបស់ព្រះរាជា ដោយសេចក្ដីគោរពចំពោះព្រះរាជា ។ ជនបទទាំងឡាយក៏ស្ងប់ស្ងៀម មិនមានសំឡេងតវ៉ា ។ ព្រះរាជាទាំងពួងទ្រង់ត្រេកអរ ទ្រង់ប្រាថ្នាថា បពិត្រលោកអាចារ្យ លោកត្រូវការដោយវត្ថុណា ចូរប្រាប់វត្ថុនោះដល់យើងទាំងឡាយ ដូច្នេះ ។ វេលាមៈកក់ក្បាលហើយ បើកទ្វារបន្ទប់ដែលពេញដោយរតនៈ ៧ ប្រការ ក្នុងនិវេសន៍

របស់ខ្លួន សម្លឹងមើលទ្រព្យដែលរក្សាមកអស់ ៧ ជួរត្រកូល ពិចារណានូវសេចក្តីចម្រើន និងការសោបសូន្យ គិតថា អញគួរឲ្យទានឲ្យផ្សាយទៅពេញជម្ពូទ្វីប ដូច្នេះ បានក្រាបទូលដល់ព្រះរាជា ឲ្យធ្វើចង្ក្រានជាជួរក្នុងទីប្រមាណ ១២ យោជន៍ ក្បែរឆ្នេរស្ទឹងគង្គា ឲ្យសាងឃ្លាំងធំ ដើម្បីដាក់សប្បិ ទឹកឃ្មុំ ទឹកអំពៅ ប្រេង ល្ង និងអង្ករជាដើមក្នុងទីនោះៗ បានចាត់ចែងមនុស្សទាំង-ឡាយថា ក្នុងទីនោះៗ ប្រើមនុស្សប្រមាណប៉ុណ្ណោះៗ ជួយរៀបចំវត្ថុណាមួយដែលឈ្មោះថា ពួកមនុស្សគប្បីបាន កាលរបស់ណាមួយមិនមានអំពីរបស់នោះ អ្នកទាំងឡាយគប្បីប្រាប់ដល់ខ្ញុំ ដូច្នេះ ទើបឲ្យវាយស្គរ ដើរទៅក្នុងក្រុងថា សូមជនទាំងឡាយបរិភោគទានរបស់វេលាមព្រាហ្មណ៍ ចាប់តាំងអំពីថ្ងៃនោះ ដូច្នេះ កាលបុគ្គលអ្នកចាត់ការរោងទានប្រាប់ថា រោងទានសម្រេចហើយ ស្មៀកសំពត់តម្លៃ ១០០០ សំពត់ធៀងស្មាមានតម្លៃ ៥០០ តាក់តែងហើយដោយគ្រឿងអលង្ការគ្រប់យ៉ាង ដាក់ទឹកដែលមានពណ៌ដូចកែវផលិក ឲ្យពេញក្នុងសុវណ្ណភិង្គារហើយ ដើម្បីធ្វើសច្ចកិរិយាថា បើក្នុងលោកមានទក្ខិណេយ្យបុគ្គល ដែលសមគួរទទួលទាននេះ សូមទឹកនេះហូរចេញហើយប្រូចលើផែនដី បើមិនមាន ទឹកកុំហូរចេញឡើយ បានផ្អៀងមាត់សុវណ្ណ-ភិង្គារហើយ ។ ទឹកហាក់ដូចជានៅក្នុងធម្មក្រក ដែលត្រូវបិទមាត់ហើយ ។ ព្រះពោធិសត្វមិនបានក្តៅក្រហាយថា ឱ អ្នកដ៏ចម្រើន ជម្ពូទ្វីបទទេ មិនមានសូម្បីតែបុគ្គលម្នាក់ដែលគួរទទួលទក្ខិណា ដូច្នេះ គិតហើយថា បើទក្ខិណា

បរិសុទ្ធខាងទាយក សូមទឹកហូរចេញ ហើយចូរសើមផែនដី ដូច្នេះ ។ ទឹកដែលមានពណ៌ដូចកែវផលិកហូរចេញហើយ សើមនូវផែនដីហើយ ពេលនោះ គាត់ទៅកាន់រោងទានដោយគិតថា នឹងឲ្យទាន សម្លឹងមើលទានហើយប្រើឲ្យមនុស្សឲ្យបបរ ក្នុងកាលនៃបបរ ឲ្យរបស់ទំពា ក្នុងកាលនៃរបស់ទំពាឲ្យអាហារ ក្នុងកាលនៃអាហារហើយ ។ ព្រះពោធិសត្វបានឲ្យទានរាល់ៗ ថ្ងៃដោយទំនងនេះឯង ។ ឯក្នុងរោងទាននេះ មិនមានពាក្យដែលគប្បីពោលថារបស់នេះមាន របស់នេះមិនមាន ។ ទាននេះនឹងមិនចប់ ដោយហេតុមានប្រមាណប៉ុណ្ណេះ ដូច្នោះ ទើបនាំយកមាសចេញទៅធ្វើថាសមាស ហើយបញ្ជូនដំណឹងទៅដល់ព្រះរាជា ៨៤០០០ ថាសជាដើម ។ ព្រះរាជាទាំងឡាយទ្រង់ព្រះតម្រិះថា យើងទាំងឡាយ ដែលអាចារ្យបានអនុគ្រោះមកយូរហើយដូច្នេះ ទើបកាលឲ្យទាននោះកន្លងទៅហើយ ៧ ឆ្នាំ ៧ ខែ ។ បន្ទាប់មកព្រាហ្មណ៍គិតថា អញនឹងចែកប្រាក់ឲ្យជាទាន ដូច្នេះហើយ ទើបឲ្យរៀបចំទានត្រៀមទុកក្នុងឱកាសដែលសំខាន់ កាលត្រៀមស្រេចហើយ បានឲ្យហើយអំពីខាងចុងដល់ថាសមាស ៨៤០០០ ថាស ជាខាងដើម ។

ក្នុងបទនោះ បទថា **រូបិយបូរានិ** បានដល់ ពេញដោយថាសប្រាក់កាជន៍ប្រាក់ និងមាសកប្រាក់ ឯថាសទាំងឡាយបុគ្គលមិនគួរកំណត់ថាតូច ។ ថាស ៤ តាំងនៅហើយ ក្នុងទីកំណត់បានមួយករីស ។ គម្របថាសសម្រេចដោយរតនៈ ៩ យ៉ាង កណ្តាប់មាត់សម្រេចដោយរតនៈ ៨ យ៉ាង ។ រថ

*ដែលទឹមដោយសេះអាជានេយ្យ ប្រកបព្រមហើយ ( អាចបរ ) ជុំវិញ កណ្ដាប់មាត់ថាសបាន ។ បានឲ្យថាស ៨៤០០០ ថាសយ៉ាងនេះថា កាល ឲ្យតាមប្រក្រតី រៀបចំបដិគ្គាហកជាពួកៗ មានទីបំផុតនៅខាងក្រៅ ដាក់ក្នុង ថាសស្រេចហើយ លើកបញ្ជូនឲ្យតគ្នាទៅចុងជួរ សូម្បីក្នុងបទថា* **រូបិយថាតិ** *ជាដើម ក៏ន័យនេះដូចគ្នា ។ សូម្បីក្នុងបទនេះ បទថា* **សុវណ្ណាបូរានិ** *បាន ដល់ ពេញដោយថាសមាស កាជន៍មាស និងមាសកមាស ។ បទថា* **ហិរញ្ញបូរានិ** *បានដល់ ពេញដោយរតនៈ ៧ យ៉ាង ។ បទថា* **សោវណ្ណា-លង្ការានិ** *បានដល់ គ្រឿងប្រដាប់សម្រេចអំពីមាស ។ បទថា* **កំសុបធា-រណានិ** *បានដល់ កាជន៍ធ្វើដោយប្រាក់សម្រាប់ទទួលទឹកដោះ ។ ឯស្នែង ទាំងឡាយរបស់មេគោទឹកដោះទាំងឡាយនោះ បានពាក់ដោយចង្កឹមាសត្រង់ ក បំពាក់ដោយកម្រងផ្កាម្ទិះត្រង់ជើងទាំង ៤ បានប្រដាប់នូវគ្រឿងប្រដាប់ជើង ត្រង់ខ្នងដណ្ដប់ដោយសំពត់សាច់ល្អដ៏ប្រសើរ ត្រង់កចងដោយត្រដោក មាស ។ បទថា* **វត្ថកោដិសហស្សានិ** *បានដល់ សំពត់ ២០ គូ សត្វ លោក ហៅថា* **ឯកកោដិ** *តែក្នុងទីនេះ សំពត់ ២០*[១] *ហៅថា* **ឯកកោដិ។** *ក្នុងបទជាដើមថា* **ខោមសុខុមានំ** *គប្បីជ្រាបវិនិច្ឆ័យដូច្នេះ បណ្ដាសំពត់សម្បក ឈើជាដើម សំពត់ណាមួយជាសំពត់សាច់ម៉ដ្ឋ បានឲ្យហើយនូវសំពត់នោះៗ*

---

*១- ត្រង់លេខយោងបិដកខ្មែរដាក់ថា សំពត់សាដក ១០ ហៅថា ១ កោដិ ព្រោះ កាន់យកតាមច្បាប់ភូមា ។*

ប៉ុណ្ណោះ ។ ចំណែកទានទាំងឡាយណា ដែលឃើញហើយថា មិនមែនជាទាន គឺឥត្តីទាន ឧសភទាន មជ្ឈទាន សមជ្ឈទាន វេលាមៈនេះបានឲ្យទានទាំងនោះ ដើម្បីជាបរិវារ ដើម្បីកាត់នូវពាក្យពោលថា ឈ្មោះថា វត្ថុនេះក្នុងហេតុនៃទានរបស់វេលាមៈ រមែងមិនមាន ។ បទថា **ឧជ្ជោ មញ្ចោ វិស្សន្ទន្តិ** បានដល់ រមែងហូរទៅដូចស្ទឹង ។

ព្រះសាស្តាត្រាស់ទានរបស់វេលាមៈ ដោយហេតុប្រមាណប៉ុណ្ណោះ ហើយត្រាស់ថា ម្នាលគហបតី អ្នកដទៃមិនបានឲ្យហើយ នូវមហាទាននោះ តថាគតបានឲ្យហើយ តថាគតកាលឲ្យទានបែបនោះ មិនបានបុគ្គលដែលសមគួរដើម្បីទទួល ឯអ្នកបានឲ្យទានដើម្បីព្រះពុទ្ធដូចតថាគត ប្រាកដនៅក្នុងលោក ព្រោះហេតុអ្វី ទើបគិតដូច្នេះ កាលទ្រង់ទេសនាចេញទៅទូលំទូលាយដល់សេដ្ឋី ទើបត្រាស់ពាក្យជាដើមថា **សិយា ខោ បន តេ** ដូច្នេះ ។ សួរថា រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណពួកណា មានហើយក្នុងកាលនោះ រូបជាដើមនោះ រលត់ហើយមិនមែនឬ ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា សម័យនោះ តថាគតជាព្រាហ្មណ៍ឈ្មោះវេលាមៈ ដូច្នេះ ។ ឆ្លើយថា ព្រោះកាត់បវេណីមិនដាច់ ដ្បិតថា រូបជាដើមនោះ កាលរលត់ ឲ្យបច្ច័យដល់ធម៌ មានវេទនាជាដើមនេះហើយ ទើបរលត់ ព្រះមានព្រះភាគត្រាស់យ៉ាងនេះ សំដៅដល់ ប្រពៃណី គឺធម៌ដែលបន្តគ្នាមិនដាច់ ។ បទថា **ន តំ កោចិ ទក្ខិណំ សោធេតិ** សេចក្តីថា មិនមានបុគ្គលណា

*គប្បីពោលថា បុគ្គលណាជាសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ក្រោកឡើងហើយ រមែងជម្រះទក្ខិណាឲ្យបរិសុទ្ធ ។ ដោយឧក្រិដ្ឋ ព្រះសម្ពុទ្ធ គប្បីជម្រះទក្ខិណានោះឲ្យបរិសុទ្ធ ។ បទថា* **ធិដ្ឋសម្បន្នំ** *បានដល់ ទានដែលបុគ្គលជាព្រះសោតាបន្ន ដល់ព្រមដោយទស្សនៈ ។ បទថា* **ឥទំ តតោ មហប្ផលតរំ** *សេចក្តីថា ទានដែលឲ្យហើយដល់បុគ្គលដែលជាសោតាបន្ន នេះ មានផលច្រើនជាងទាន ដែលបុគ្គលបរិច្ចាគប្រាក់ និងមាសប្រមាណប៉ុណ្ណេះ ឲ្យហើយ ដល់លោកិយមហាជន អស់ ៧ ឆ្នាំ ៧ ខែ ។*

*ក្នុងបទនេះថា* **យោ ច សតំ ទិដ្ឋិសម្បន្នានំ** *សេចក្តីថា គប្បីជ្រាបការរាប់សោតាបន្នដល់បុគ្គលដែលជាសោតាបន្នច្រើនរយ ដោយអំណាចបុគ្គលដែលជាសកទាគាមីម្នាក់ ។ ដោយឧបាយនេះ គប្បីជ្រាបការរាប់បុគ្គលគុណនឹង ១០០ ដោយលំដាប់ខាងលើហើយ ក្នុងខាងដើម ក្នុងវារៈទាំងពួង ។*

*ក្នុងបទថា* **ពុទ្ធប្បមុខំ** *នេះ សង្ឃធ្វើព្រះសម្មាសម្ពុទ្ធឲ្យជាព្រះសង្ឃត្ថេរឲ្យគង់ហើយ គប្បីជ្រាបថា សង្ឃមានព្រះពុទ្ធជាប្រធាន ដូច្នេះ ។ ក្នុងបទនេះថា* **ចាតុទ្ទិសំ សង្ឃំ ឧទ្ទិស្ស** *សេចក្តីថា ចេតិយរមែងប្រតិស្ឋាន ការស្តាប់ធម៌ពួកបុគ្គលរមែងធ្វើក្នុងទីដែលមានវិហារ ដែលបុគ្គលសាងថ្វាយសង្ឃដែលមកអំពីទិសទាំង ៤ ភិក្ខុទាំងឡាយមកអំពីទិសទាំង ៤ និងអំពីទិសតូចហើយ មិនចាំបាច់សាកសួរ លាងជើងហើយ យកកូនសោបើកទ្វារ ធ្វើនូវការសម្អាត*

សេនាសនៈស្រេចហើយ រមែងបានទូវភាពជាសុកវិហារនោះ ដោយហេតុសូម្បីជាបណ្ណសាលាដែលកើតដល់ខ្លួន ក្នុងទិសទាំង ៤ ក៏ហៅថា វិហារដែលបុគ្គលធ្វើថ្វាយសង្ឃដែលមកអំពីទិសទាំង ៤ ដូចគ្នា ។

ក្នុងបទថា **សរណំ គច្ឆេយ្យ** លោកសំដៅដល់សរណៈដែលមិនវិលត្រឡប់ហើយដោយមគ្គ ។ ឯអាចារ្យពួកខ្លះពោលថា ឈ្មោះថា **សរណាគមន៍** ព្រោះប្រគល់ខ្លួនឲ្យហើយ លោកអធិប្បាយថា មានផលច្រើនជាងទាននោះ ។ បទថា **សិក្ខាបទំ សមាទិយេយ្យ** បានដល់ គប្បីទទួលបញ្ចសីល ។ សូម្បីសីល លោកពោលសំដៅយកសីលដែលមិនវិលត្រឡប់ប៉ុណ្ណោះ ដែលមកហើយក្នុងមគ្គ ។ ឯអាចារ្យមួយពួកទៀតពោលថា ឈ្មោះថា **សីល** ព្រោះខ្លួនឲ្យអភយទានហើយ ដល់សត្វទាំងពួង លោកអធិប្បាយថា មានផលច្រើនជាងសរណគមន៍នោះ ។ បទថា **គទ្ទូហានមត្តំ** បានត្រឹមតែជាការត្រិះរិះក្នុងគ្រឿងក្រអូប គឺត្រឹមតែយកម្រាមទាំង ២ ចាប់ដុំបាយក្រអូបមកហិត ។ ចំណែកអាចារ្យមួយពួកទៀតពោលព្រះបាលីថា **គោទោហានមត្តំ** ហើយទើបបានពោលអត្ថថា ត្រឹមតែតំណក់ទឹកដោះស្រក់របស់មេគោ ។

បទថា **មេត្តចិត្តំ** បានដល់ ចិត្តដែលផ្សាយទៅជាប្រយោជន៍ដល់សត្វទាំងពួង តែចិត្តនោះ លោកកាន់យកហើយ ដោយអំណាចអប្បនាប៉ុណ្ណោះ ។ បទថា **អនិច្ចសញ្ញំ** បានដល់ វិបស្សនាដែលមានកម្លាំងដល់ទីបំផុត ដោយភាពជាអនន្តរប្បច្ច័យដល់មគ្គ ។ ចំណែកបុណ្យទាំងឡាយ មានទានជាដើម

នេះ គប្បីជ្រាបដោយឧបមាយ៉ាងនេះ ។ បើបុគ្គលធ្វើជម្ពូទ្វីបឲ្យរាបស្មើ ដូចមុខស្គរ ក្រាលបល្ល័ង្កតាំងអំពីដើម គប្បីឲ្យព្រះអរិយបុគ្គលអង្គុយក្នុងទីនោះ មានសោតាបន្នបុគ្គល ១០ ជួរ សកទាគាមិបុគ្គល ៥ ជួរ អនាគាមិបុគ្គល ២ ជួរកន្លះ ព្រះខីណាស្រព ១ ជួរកន្លះ ព្រះបច្ចេកពុទ្ធគប្បីមាន ១ ជួរ ។ ព្រះសម្មាសម្ពុទ្ធ ១ អង្គប៉ុណ្ណោះ ទានដែលបុគ្គលថ្វាយដល់ព្រះសម្មាសម្ពុទ្ធ មានផលច្រើនជាងទានដែលថ្វាយហើយ ដល់ជនមានប្រមាណប៉ុណ្ណោះ ។ ឯទានក្រៅអំពីនេះ គឺ

វិហារទាន បិណ្ឌបាត សិក្ខា ការចម្រើនមេត្តា រមែងមិនដល់

ចម្រៀកទី ១៦ របស់បុគ្គលដែលពិចារណាដោយការអស់ទៅ ។

ដោយហេតុនោះឯង ទើបព្រះមានព្រះភាគបានត្រាស់ក្នុងសម័យទៀបនឹងបរិនិព្វានថា ជាអ្នកប្រតិបត្តិនូវធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌ បុគ្គលនោះឈ្មោះថា ធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត ដោយគ្រឿងបូជាដ៏ឧត្តម ។ បទដ៏សេសក្នុងបទទាំងពួង មានអត្ថងាយយល់ហើយ ដោយប្រការដូច្នេះ ។

**អដ្ឋកថាវេលាមសូត្រទី ១០ ចប់**

**សីហនាទវគ្គទី ២ ចប់**

# សុត្តន្តបិដក

## សត្តាវាសវគ្គ

### ឋានសូត្រទី ១

[ ២១ ] ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សអ្នកនៅក្នុងឧត្តរកុរុទ្វីប ខ្ពង់ខ្ពស់ហួសពួកទេវតាជាន់តាវត្តិង្សផង និងពួកមនុស្សអ្នកនៅក្នុងជម្ពូទ្វីបផង ដោយស្ថាន ៣ យ៉ាង ។ ស្ថាន ៣ យ៉ាង តើដូចម្តេចខ្លះ ។ គឺមិនមានសេចក្តីអន្ទះសា ១ មិនមានសេចក្តីហួងហែង ១ មានអាយុទៀង មានកំណើតដ៏វិសេស ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សនៅក្នុងឧត្តរកុរុទ្វីប តែងខ្ពង់ខ្ពស់ ហួសពួកទេវតាជាន់តាវត្តិង្សផង និងពួកមនុស្សអ្នកនៅក្នុងជម្ពូទ្វីបផង ដោយស្ថាន ៣ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកទេវតាជាន់តាវត្តិង្ស ខ្ពង់ខ្ពស់ហួសពួកមនុស្សអ្នកនៅក្នុងឧត្តរកុរុទ្វីបផង និងពួកមនុស្សអ្នកនៅក្នុងជម្ពូទ្វីបផង ដោយស្ថាន ៣ យ៉ាង ។ ស្ថាន ៣ យ៉ាង តើដូចម្តេចខ្លះ ។ គឺអាយុជាទិព្វ ១ សម្បុរជាទិព្វ ១ សេចក្តីសុខជាទិព្វ ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកទេវតាជាន់តាវត្តិង្ស តែងខ្ពង់ខ្ពស់ហួសពួកមនុស្សអ្នកនៅក្នុងឧត្តរកុរុទ្វីបផង និងពួកមនុស្សអ្នកនៅក្នុងជម្ពូទ្វីបផង ដោយស្ថាន ៣ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សអ្នកនៅក្នុងជម្ពូទ្វីប ខ្ពង់ខ្ពស់ហួសពួកមនុស្សអ្នកនៅក្នុងឧត្តរកុរុទ្វីបផង និងពួកទេវតាជាន់តាវត្តិង្សផង ដោយស្ថាន ៣ យ៉ាង ។ ស្ថាន ៣ យ៉ាង តើដូចម្តេចខ្លះ ។ គឺមាន

សេចក្ដីក្លៀវក្លា ១ មានស្មារតី ( ខ្ជាប់ខ្ជួន ) ១ មានការបំពេញព្រហ្មចរិយ-ធម៌ដ៏វិសេស ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សនៅក្នុងជម្ពូទ្វីប តែងខ្ពង់ខ្ពស់ហួសពួកមនុស្សអ្នកនៅក្នុងឧត្តរកុរុទ្វីបផង និងពួកទេវតាជាន់តាវត្តិង្សផង ដោយស្ថាន ៣ យ៉ាងនេះឯង ។

# អដ្ឋកថា
# សត្តាវាសវគ្គទី ៣

## ឋានសូត្រ

[ ២១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឋានសូត្រទី ១ នៃសត្តាវាសវគ្គទី ៣ ដូច្នេះ បទថា **ឧត្តរកុរុកា** បានដល់ មនុស្សទាំងឡាយអ្នកឧត្តរកុរុទ្វីប ។ បទថា **អធិគ្គណ្ហន្តិ** បានដល់ រមែងជាធំ គឺជាបុគ្គលក្រៃលែង ជាបុគ្គលប្រសើរ ជាបុគ្គលចម្រើនបំផុត ។ បទថា **អមមា** បានដល់ មិនមានតណ្ហា ។ ឯក្នុងអដ្ឋកថាពោលថា មិនមានទុក្ខ ។ បទថា **អបរិគ្គហា** បានដល់ វៀរនូវការហួងហែងថា វត្ថុនេះរបស់អញ ។ បទថា **និយតាយុកា** សេចក្ដីថា មនុស្សទាំងឡាយនោះ ក៏មានអាយុ ១០០០ ឆ្នាំស្មើគ្នាទាំងអស់ សូម្បីគតិក៏ស្មើគ្នា មនុស្សទាំងនោះស្លាប់អំពីនោះហើយ រមែងកើតក្នុងស្ថានសួគ៌ប៉ុណ្ណោះ ។ បទ

ថា **សតិមន្តោ** សេចក្តីថា ពួកទេវតារមែងមានសតិមិនពិតប្រាកដ ព្រោះមានសេចក្តីសុខដោយចំណែកមួយ ។ ពួកសត្វនរកក៏មិនពិតប្រាកដ ព្រោះមានសេចក្តីទុក្ខដោយចំណែកមួយ ចំណែកមនុស្សទាំងនេះ ឈ្មោះថា មានសតិស៊ប់សួន ព្រោះមានសុខផង ទុក្ខផង លាយឡំគ្នាហើយ ។ បទថា **ឥធ ព្រហ្មចរិយវាសោ** សេចក្តីថា ការនៅប្រព្រឹត្តមគ្គព្រហ្មចរិយៈប្រកបដោយអង្គ ៨ រមែងមានក្នុងទីនេះប៉ុណ្ណោះ ព្រោះព្រះពុទ្ធ និងព្រះបច្ចេកពុទ្ធកើតឡើងក្នុងជម្ពូទ្វីប ។ល។

**អដ្ឋកថា ឋានសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ខឡុង្គសូត្រទី ២

[ ២២ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវសេះខឡុង្គៈ ៣ ពួកផង នូវបុរសខឡុង្គៈ ៣ ពួកផង នូវសេះសទស្សៈ ៣ ពួកផង នូវបុរសសទស្សៈ ៣ ពួកផង នូវសេះអាជានេយ្យដ៏ប្រសើរ ៣ ពួកផង នូវបុរសអាជានេយ្យដ៏ប្រសើរ ៣ ពួកផង ចូរអ្នកទាំងឡាយ ស្តាប់នូវធម៌នោះ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេះខឡុង្គៈ ៣ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុ

ទាំងឡាយ សេះខ្សឹង្គៈខ្លះ ក្នុងលោកនេះ ជាសត្វបរិបូណ៌ដោយសម្ទុះ តែមិនបរិបូណ៌ដោយសម្បុរ មិនបរិបូណ៌ដោយកម្ពស់ និងទំហំ ១ ។ ម្នាលភិក្ខុទាំងឡាយ សេះខ្សឹង្គៈខ្លះ ក្នុងលោកនេះ ជាសត្វបរិបូណ៌ដោយសម្ទុះ បរិបូណ៌ដោយពណ៌សម្បុរ តែមិនបរិបូណ៌ដោយកម្ពស់ និងទំហំ ១ ។ ម្នាលភិក្ខុទាំងឡាយ សេះខ្សឹង្គៈខ្លះ ក្នុងលោកនេះ បរិបូណ៌ដោយសម្ទុះផង បរិបូណ៌ដោយពណ៌សម្បុរផង បរិបូណ៌ដោយកម្ពស់ និងទំហំផង ១ ។ ម្នាលភិក្ខុទាំងឡាយ សេះខ្សឹង្គៈ មាន ៣ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរសខ្សឹង្គៈ ៣ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុរសខ្សឹង្គៈខ្លះ ក្នុងលោកនេះ ជាអ្នកបរិបូណ៌ដោយសម្ទុះ តែមិនបរិបូណ៌ដោយគុណ មិនបរិបូណ៌ដោយកម្ពស់ និងទំហំ ១ ។ ម្នាលភិក្ខុទាំងឡាយ បុរសខ្សឹង្គៈខ្លះ ក្នុងលោកនេះ ជាអ្នកបរិបូណ៌ដោយសម្ទុះ បរិបូណ៌ដោយគុណ តែមិនបរិបូណ៌ដោយកម្ពស់ និងទំហំ ១ ។ ម្នាលភិក្ខុទាំងឡាយ បុរសខ្សឹង្គៈខ្លះ ក្នុងលោកនេះ ជាអ្នកបរិបូណ៌ដោយសម្ទុះផង បរិបូណ៌ដោយគុណផង បរិបូណ៌ដោយកម្ពស់ និងទំហំផង ១ ។ ម្នាលភិក្ខុទាំងឡាយ បុរសខ្សឹង្គៈ មាន ៣ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរសខ្សឹង្គៈ ជាអ្នកបរិបូណ៌ដោយសម្ទុះ តែមិនបរិបូណ៌ដោយគុណ មិនបរិបូណ៌ដោយកម្ពស់ និងទំហំ តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះ

ជាហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមពិតថា នេះជាធម៌រម្ងត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាបដិបទាជាដំណើរទៅកាន់ធម៌រម្ងត់ទុក្ខ តថាគតពោលថា នេះជាសម្ពុះរបស់ភិក្ខុនោះ កាលបើគេសួរប្រស្នាក្នុងអភិធម្ម ឬក្នុងអភិវិន័យ ដោះស្រាយមិនបរិបូណ៌ តថាគតពោលថា នេះមិនមែនជាគុណរបស់ភិក្ខុនោះទេ ទាំងជាអ្នកឆ្អែងលាភចំពោះចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយ-ភេសជ្ជបរិក្ខារ តថាគតពោលថា នេះមិនមែនជាកម្ពស់ និងទំហំរបស់ភិក្ខុនោះទេ ។ ម្នាលភិក្ខុទាំងឡាយ បុរសខ្សឹក្គៈអ្នកបរិបូណ៌ដោយសម្ពុះ តែមិនបរិ-បូណ៌ដោយគុណ មិនបរិបូណ៌ដោយកម្ពស់ និងទំហំយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរសអ្នកបរិបូណ៌ដោយសម្ពុះផង បរិបូណ៌ដោយគុណផង តែមិនបរិបូណ៌ដោយកម្ពស់ និងទំហំ តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ។បេ។ ដឹងច្បាស់តាមពិតថា នេះជាបដិបទាជាដំណើរទៅកាន់ធម៌រម្ងត់ទុក្ខ តថាគតពោលថា នេះជាសម្ពុះរបស់ភិក្ខុនោះ កាលបើគេសួរប្រស្នាក្នុងអភិធម្ម ឬក្នុងអភិវិន័យ ដោះស្រាយរួច មិនទើសទាល់ឡើយ តថាគតពោលថា នេះជាគុណរបស់ភិក្ខុនោះ ប៉ុន្តែជាអ្នកឆ្អែងលាភចំពោះចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ តថាគតពោលថា នេះមិនមែនជាកម្ពស់ និងទំហំរបស់ភិក្ខុនោះទេ ។ ម្នាលភិក្ខុទាំងឡាយ បុរសខ្សឹក្គៈអ្នកបរិបូណ៌ដោយសម្ពុះផង បរិបូណ៌ដោយគុណផង តែមិនបរិបូណ៌ដោយកម្ពស់ និង

ទំហំយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរសខឡុង្គៈ អ្នកបរិបូណ៌ដោយសមុះផង បរិបូណ៌ដោយគុណផង បរិបូណ៌ដោយកម្ពស់ និងទំហំផង តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ។បេ។ ដឹងច្បាស់តាមពិតថា នេះជាបដិបទាជាដំណើរទៅកាន់ធម៌រម្ងាត់ទុក្ខ តថាគតពោលថា នេះជាសមុះរបស់ភិក្ខុនោះ កាលបើគេសួរប្រស្នាក្នុងអភិធម្ម ឬក្នុងអភិវិន័យ ដោះស្រាយរួច មិនទើសទាល់ឡើយ តថាគតពោលថា នេះជាគុណរបស់ភិក្ខុនោះ ទាំងជាអ្នកស្វាក់លាភចំពោះចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ តថាគតពោលថា នេះជាកម្ពស់ និងទំហំរបស់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំង-ឡាយ បុរសខឡុង្គៈ អ្នកបរិបូណ៌ដោយសមុះផង បរិបូណ៌ដោយគុណផង បរិបូណ៌ដោយកម្ពស់ និងទំហំផងយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុរសខឡុង្គៈមាន ៣ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះសេះសទស្សៈ ៣ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេះសទស្សៈខ្លះ ក្នុងលោកនេះ ។បេ។ ជាសត្វបរិបូណ៌ដោយសមុះផង បរិបូណ៌ដោយពណ៌សម្បុរផង បរិបូណ៌ដោយកម្ពស់ និងទំហំផង ។ ម្នាលភិក្ខុទាំងឡាយ សេះសទស្សៈមាន ៣ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរសសទស្សៈ ៣ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុរសសទស្សៈខ្លះ ក្នុងលោកនេះ ។បេ។ អ្នកបរិបូណ៌ដោយសមុះផង បរិបូណ៌ដោយគុណផង បរិបូណ៌ដោយ

កម្ពស់ និងទំហំផង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរសសទស្សៈ អ្នកបរិបូណ៌ដោយសម្មុះផង បរិបូណ៌ដោយគុណផង បរិបូណ៌ដោយកម្ពស់ និងទំហំផង តើដោយប្រការដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះអស់ទៅនៃសំយោជនៈជាចំណែកខាងក្រោម ៥ ជាឱបបាតិកសត្វ បរិនិព្វានក្នុងទីនោះ មានសភាពមិនបានត្រឡប់ចាកលោកនោះ តថាគតពោលថា នេះជាសម្មុះរបស់ភិក្ខុនោះ កាលបើគេសួរប្រស្នាក្នុងអភិធម្ម ឬក្នុងអភិវិន័យ ដោះស្រាយរួច មិនទើសទាល់ តថាគតពោលថា នេះជាគុណរបស់ភិក្ខុនោះ ទាំងជាអ្នកស្ទាក់លាភចំពោះចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយ-ភេសជ្ជបរិក្ខារ តថាគតពោលថា នេះជាកម្ពស់ និងទំហំរបស់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ បុរសសទស្សៈ អ្នកបរិបូណ៌ដោយសម្មុះផង បរិបូណ៌ដោយគុណផង បរិបូណ៌ដោយកម្ពស់ និងទំហំផងយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុរសសទស្សៈមាន ៣ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះសេះអាជានេយ្យដ៏ប្រសើរ ៣ ពួក តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើរខ្លះ ក្នុងលោកនេះ ។បេ។ ជាសត្វបរិបូណ៌ដោយសម្មុះផង បរិបូណ៌ដោយពណ៌សម្បុរផង បរិបូណ៌ដោយកម្ពស់ និងទំហំផង ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើរមាន ៣ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរសអាជានេយ្យដ៏ប្រសើរ ៣ ពួក តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុរសអាជានេយ្យដ៏ប្រសើរខ្លះ ក្នុងលោកនេះ ។បេ។ ជាអ្នក

បរិបូណ៌ដោយសមុះផង បរិបូណ៌ដោយគុណផង បរិបូណ៌ដោយកម្ពស់ និង ទំហំផង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរសអាជានេយ្យដ៏ប្រសើរ តើដោយប្រការដូចម្តេច ។បេ។ ជាអ្នកបរិបូណ៌ដោយសមុះផង បរិបូណ៌ដោយគុណផង បរិបូណ៌ដោយកម្ពស់ និងទំហំផង ។ ម្នាលភិក្ខុទាំងឡាយ បុរសអាជានេយ្យដ៏ប្រសើរ ក្នុងលោកនេះ ធ្វើឲ្យជាក់ច្បាស់សម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន តថាគតពោលថា នេះជាសមុះរបស់ភិក្ខុនោះ កាលបើគេសួរប្រស្នាក្នុងអភិធម្ម ឬក្នុងអភិវិន័យ អាចដោះស្រាយរួច មិនទើសទាល់ឡើយ តថាគតពោលថា នេះជាគុណរបស់ភិក្ខុនោះ ទាំងជាអ្នកស្ទាក់លាភចំពោះចីវរបិណ្ឌបាតសេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ តថាគតពោលថា នេះជាកម្ពស់ និងទំហំរបស់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំង-ឡាយ បុរសអាជានេយ្យដ៏ប្រសើរ ជាអ្នកបរិបូណ៌ដោយសមុះផង បរិបូណ៌ដោយគុណផង បរិបូណ៌ដោយកម្ពស់ និងទំហំផង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុរសអាជានេយ្យដ៏ប្រសើរ មាន ៣ ពួកនេះឯង ។

# អដ្ឋកថា

## ខឡុង្គសូត្រ

[ ២២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងខឡុង្គសូត្រទី ២ ដូចតទៅនេះ បទថា **ជវសម្បន្នោ** បានដល់ ដល់ព្រមដោយសម្ទុះដើររហ័ស ។ បទថា **ន វណ្ណសម្បន្នោ** បានដល់ មិនសម្បូរដោយពណ៌សម្បុរកាយ ។ ក្នុងបុរសខ្លូក មានអត្ថដូចតទៅនេះ បទថា **ជវសម្បន្នោ** បានដល់ បុរសខ្លូក ដល់ព្រមដោយ **ជវ** គឺញាណ ។ បទថា **ន វណ្ណសម្បន្នោ** បានដល់ មិនដល់ព្រមដោយវណ្ណៈ គឺគុណ ។ បទដ៏សេស គប្បីជ្រាបតាមន័យរបស់បាលីនោះចុះ ។ ក្នុងសូត្រនេះគួរពោលដល់សេចក្តីណា សេចក្តីនោះលោកអធិប្បាយហើយ ក្នុងអដ្ឋកថាតិកនិបាតហើយ ៕

**អដ្ឋកថាខឡុង្គសូត្រទី ២ ចប់**

# សុត្តន្តបិដក

## តណ្ហាសូត្រទី ៣

[ ២៣ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវពួកធម៌ដែលមានតណ្ហាជាឫសគល់ ៩ យ៉ាង អ្នកទាំងឡាយ ចូរស្តាប់នូវធម៌នោះចុះ ។បេ។ ម្នាលភិក្ខុទាំងឡាយ ចុះពួកធម៌ដែលមានតណ្ហាជាឫសគល់ ៩ យ៉ាង តើដូចម្តេចខ្លះ ។ គឺការអាស្រ័យតណ្ហា ទើបមានការស្វែងរក ១ អាស្រ័យការស្វែងរក ទើបកើតលាភ ១ អាស្រ័យលាភ ទើបកើតសេចក្តីត្រិះរិះ ១ អាស្រ័យសេចក្តីត្រិះរិះ ទើបកើតសេចក្តីប្រាថ្នា សេចក្តីត្រេកអរ ១ អាស្រ័យសេចក្តីប្រាថ្នា សេចក្តីត្រេកអរ ទើបកើតសេចក្តីជ្រៀតជ្រែក ១ អាស្រ័យសេចក្តីជ្រៀតជ្រែក ទើបកើតការហួងហែងទុក ១ អាស្រ័យការហួងហែងទុក ទើបកើតសេចក្តីកំណាញ់ ១ អាស្រ័យសេចក្តីកំណាញ់ ទើបកើតការរក្សាទុក ១ អាស្រ័យការរក្សាជាហេតុហើយ ទើបអកុសលធម៌ទាំងឡាយ ដ៏លាមកជាច្រើន គឺការកាន់ដំបង កាន់គ្រឿងសស្ត្រាវុធ ឈ្លោះទាស់ទែងជជែកគ្នាថាឯងៗ ទាំងនិយាយញុះញង់ និយាយកុហកក៏កើតឡើង ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកធម៌មានតណ្ហាជាឫសគល់ មាន ៩ យ៉ាងនេះឯង ។

# អដ្ឋកថា

## តណ្ហាសូត្រ

[ ២៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតណ្ហាសូត្រទី ៣ ដូចតទៅនេះ បទថា **តណ្ហំ បដិច្ច** បានដល់ តណ្ហា ២ យ៉ាង គឺឯសនតណ្ហា គឺតណ្ហាក្នុងការស្វែងរក ១ ឯសិតតណ្ហា តណ្ហាក្នុងការស្វែងបានហើយ ១ ។ បុគ្គលដើរទៅតាមផ្លូវពពែ និងផ្លូវដែលមានដង្គត់ជាដើម ស្វែងរកភោគៈដោយតណ្ហាណា តណ្ហានោះ ឈ្មោះថា **ឯសនតណ្ហា ។** តណ្ហាណា កាលបុគ្គលស្វែងរកបានភោគៈហើយ តណ្ហានេះ ឈ្មោះថា ឯសិតតណ្ហា ។ តែព្រះសូត្រនេះ គប្បីឃើញថា បានដល់ ឯសនតណ្ហា ។ បទថា **បរិយេសនា** បានដល់ ការស្វែងរកអារម្មណ៍ មានរូបជាដើម កាលឯសនតណ្ហាមាន ការស្វែងរកនោះក៏មាន ។ បទថា **លាភោ** បានដល់ ការបានអារម្មណ៍ មានរូបជាដើម កាលការស្វែងរកមាន ការបានក៏មាន ។

វិនិច្ឆ័យមាន ៤ យ៉ាង គឺញាណវិនិច្ឆ័យ ១ តណ្ហាវិនិច្ឆ័យ ១ ទិដ្ឋិវិនិច្ឆ័យ ១ វិតក្កវិនិច្ឆ័យ ១ ។ ក្នុងវិនិច្ឆ័យ ៤ យ៉ាងនោះ បុគ្គលដឹងដល់សុខវិនិច្ឆ័យក្នុងប្រការដែលលោកពោលថា គប្បីដឹងនូវសេចក្តីសុខដែលថោកថយ លុះដឹងនូវសេចក្តីសុខដែលថោកថយហើយ គប្បីប្រកបរឿយៗ នូវសេចក្តីសុខក្នុងសន្តាន នេះឈ្មោះថា ញាណវិនិច្ឆ័យ ។ បទថា **វិនិច្ឆយោ** ត្រង់ពាក្យថា វិនិច្ឆ័យ បានដល់វិនិច្ឆ័យ ២ គឺតណ្ហាវិនិច្ឆ័យ ១ ទិដ្ឋិវិនិច្ឆ័យ ១ ។ តណ្ហាវិចរិត ១០៨ ឈ្មោះថា តណ្ហាវិនិច្ឆ័យ ។ ទិដ្ឋិ ៦២ ឈ្មោះថា ទិដ្ឋិ-

វិនិច្ឆ័យ ។ តែក្នុងទីនេះ លោកពោលដល់វិនិច្ឆ័យ គឺវិតក្កប៉ុណ្ណោះ ដូចមកក្នុងសូត្រថា **ឆន្ទោ ខោ ទេវានមិន្ទ វិតក្កនិទានោ** សេចក្តីថា បពិត្រទេវានមិន្ទ ឆន្ទៈ មានវិតក្ក ( សេចក្តីត្រិះរិះ ) ជាដើមហេតុ ដូច្នេះ ។ បុគ្គលបានលាភហើយ ក៏គង់ត្រិះរិះដល់វត្ថុដែលគួរពេញចិត្ត និងមិនគួរពេញចិត្ត ដល់នូវវត្ថុល្អ និងមិនល្អដោយវិតក្កថា ប៉ុណ្ណេះ នឹងមានដើម្បីរូបារម្មណ៍ដល់អញ ប៉ុណ្ណេះ នឹងមានដើម្បីសទ្ទារម្មណ៍ ប៉ុណ្ណេះ នឹងមានដល់អញ ប៉ុណ្ណេះ នឹងមានដល់អ្នកដទៃ អញនឹងបរិភោគ ប៉ុណ្ណេះ អញនឹងរក្សាទុក ប៉ុណ្ណេះ ដូច្នេះ ដោយហេតុនោះ ទើបលោកពោលថា **លាភំ បដិច្ច វិនិច្ឆយោ** ប្រែថា ត្រិះរិះអាស្រ័យលាភ ដូច្នេះ ។

បទថា **ឆន្ទរាគោ** សេចក្តីថា រាគៈយ៉ាងទន់ និងរាគៈយ៉ាងខ្លាំងក្លាតែងកើតឡើងក្នុងវត្ថុដែលត្រិះរិះ ដោយអកុសលវិតក្កយ៉ាងនេះ ពិតហើយ បទថា **ឆន្ទោ** ក្នុងសូត្រនេះ ជាឈ្មោះរបស់រាគៈយ៉ាងទន់ ។ បទថា **បរិគ្គហោ** បានដល់ ធ្វើការប្រកាន់ដោយអំណាចតណ្ហា និងទិដ្ឋិ ។ បទថា **មច្ឆរិយំ** បានដល់ អត់ធន់ចំពោះភាពជារបស់ទូទៅ ដល់អ្នកដទៃមិនបាន ។ ដោយហេតុនោះឯងទើបបុរាណាចារ្យពោលពាក្យយ៉ាងនេះ នៃមច្ឆរិយៈនោះថា ការអស្ចារ្យនេះ ព្រះមានព្រះភាគត្រាស់ថា មច្ឆរិយៈ ព្រោះប្រព្រឹត្តទៅហើយ ក្នុងសេចក្តីថា សេចក្តីអស្ចារ្យមានដល់អញប៉ុណ្ណោះ ចូរកុំមានដល់អ្នកដទៃឡើយ ដូច្នេះ ។ បទថា **អារក្ខា** បានដល់ ការរក្សាទុកដោយល្អ ព្រោះបិទទ្វារ និងរក្សាទុក

ក្នុងហិបជាដើម ។ ឈ្មោះថា អធិករណ៍ ព្រោះធ្វើឲ្យក្រៃលែង បទនោះជាឈ្មោះនៃហេតុ ។ បទថា **អារក្ខាធិករណំ** ជាទបុំសកលិង្គការសាធនៈ អធិប្បាយថា ហេតុនៃការរក្សា ។ ក្នុងបទថា **ទណ្ឌាទាន** ជាដើម គប្បីជ្រាបវិនិច្ឆ័យ ដូច្នេះ ការកាន់ដំបងដើម្បីការពារអ្នកដទៃ ឈ្មោះថា **ទណ្ឌាទានំ** ការកាន់សស្ត្រាមានមុខតែម្ខាង ឈ្មោះថា **សត្ថាទានំ** ការទាស់ទែងគ្នាដោយកាយក្តី ការទាស់ទែងគ្នាដោយវាចាក្តី ឈ្មោះថា **កលហោ**។ ពេលដំបូងជាវិគ្គហៈ ពេលក្រោយជាវិវាទ ។ បទថា **តុវំតុវំ** បានដល់ និយាយឯង មីង អា ហង ដោយមិនគោរពគ្នា ។ល។

**អដ្ឋកថា តណ្ហាសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## សត្តសញ្ញាសូត្រទី ៤

[ ២៤ ] ម្នាលភិក្ខុទាំងឡាយ សត្តាវាស ( ប្រទេសជាទីនៅរបស់សត្វ ) នេះមាន ៩ យ៉ាង ។ សត្តាវាស ៩ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នាក៏មាន ដូចពួកមនុស្ស និងទេវតាពួកខ្លះ និងអសុរកាយពួកខ្លះ នេះជាសត្តាវាសទី ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាដូចគ្នាក៏មាន ដូច

ពួកព្រហ្មកាយិកទេវតា ដែលកើតក្នុងជាន់បឋមជ្ឈានភូមិ នេះជាសត្តាវាសទី ២ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានកាយដូចគ្នា មានសញ្ញាផ្សេងគ្នាក៏មាន ដូចពួកទេវតាជាន់អាភស្សរៈ នេះជាសត្តាវាសទី ៣ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានកាយដូចគ្នា មានសញ្ញាដូចគ្នាក៏មាន ដូចពួកទេវតាជាន់សុភកិណ្ហៈ នេះជាសត្តាវាសទី ៤ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វឥតសញ្ញា ឥតមានទទួលការដឹងក៏មាន ដូចពួកទេវតាជាន់អសញ្ញីសត្វ នេះជាសត្តាវាសទី ៥ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វលុះបានកន្លងរូបសញ្ញា បានរម្ងាប់បដិឃសញ្ញា មិនបានធ្វើទុកក្នុងចិត្តចំពោះនានត្តសញ្ញា ដោយប្រការទាំងពួង ហើយបានដល់អាកាសានញ្ចាយតនជ្ឈានដោយបរិកម្មថា អាកាសមិនមានទីបំផុតដូច្នេះក៏មាន នេះជាសត្តាវាសទី ៦ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វកន្លងអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់វិញ្ញាណញ្ចាយតនជ្ឈាន ដោយបរិកម្មថា វិញ្ញាណ មិនមានទីបំផុតដូច្នេះក៏មាន នេះជាសត្តាវាសទី ៧ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វកន្លងវិញ្ញា-ណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់អាកិញ្ចញ្ញាយត-នជ្ឈាន ដោយបរិកម្មថា វត្ថុតិចតួចមិនមានដូច្នេះ នេះជាសត្តាវាសទី ៨ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វកន្លងអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់នេវសញ្ញានាសញ្ញាយតនជ្ឈាន នេះជាសត្តាវាសទី ៩ ។ ម្នាលភិក្ខុទាំងឡាយ សត្តាវាសមាន ៩ យ៉ាងនេះឯង ។

# អដ្ឋកថា

## សត្តសញ្ញាសូត្រ

[ ២៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសត្តសញ្ញាសូត្រទី ៤ ដូចតទៅនេះ បទថា **សត្តាវាសា** បានដល់ លំនៅរបស់សត្វទាំងឡាយ អធិប្បាយថា ដែលជាលំនៅ ។ ក្នុងបទនោះ សូម្បីសុទ្ធាវាសក៏ជាសត្តាវាសដូចគ្នា តែលោកមិនបានរាប់បញ្ចូល ព្រោះសុទ្ធាវាស មិនមានសព្វកាលទាំងពួង ។ ដ្បិតថា សុទ្ធាវាសជាទីស្នាក់អាស្រ័យរបស់ព្រះពុទ្ធទាំងឡាយ កាលព្រះពុទ្ធមិនកើតឡើងមួយអសង្ខេយ្យកប្ប ទីនោះក៏ទទេ ព្រោះហេតុនោះ ទើបលោកមិនរាប់បញ្ចូល ព្រោះសុទ្ធាវាសមិនមានសព្វកាលទាំងពួង ។ បទដ៏សេសក្នុងសូត្រនេះ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងវិញ្ញាណដ្ឋិតិនោះឯង ។ល។

**អដ្ឋកថា សត្តសញ្ញាសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## បឋមសិលាយូបសូត្រទី ៥

[ ២៥ ] ម្នាលភិក្ខុទាំងឡាយ កាលណាបើចិត្តដែលភិក្ខុបានសន្សំល្អហើយ ដោយប្រាជ្ញា ម្នាលភិក្ខុទាំងឡាយ ការសន្សំរបស់ភិក្ខុនោះ គួរពោលថា ភិក្ខុនោះ រមែងដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលភិក្ខុបានសន្សំល្អហើយ ដោយប្រាជ្ញា តើដោយប្រការដូចម្តេច ។ ចិត្តដែលភិក្ខុបានសន្សំល្អហើយ ដោយប្រាជ្ញាថា ចិត្តរបស់អាត្មាអញ ប្រាសចាករាគៈហើយ ចិត្តដែលភិក្ខុបានសន្សំល្អហើយ ដោយប្រាជ្ញាថា ចិត្តរបស់អាត្មាអញ ប្រាសចាកទោសៈហើយ ចិត្តដែលភិក្ខុបានសន្សំល្អហើយ ដោយប្រាជ្ញាថា ចិត្តរបស់អាត្មាអញ ប្រាសចាកមោហៈហើយ ចិត្តដែលភិក្ខុសន្សំល្អហើយ ដោយប្រាជ្ញាថា ចិត្តរបស់អាត្មាអញមានសភាពមិនប្រកបដោយរាគៈ ចិត្តដែលភិក្ខុបានសន្សំល្អហើយ ដោយប្រាជ្ញាថា ចិត្តរបស់អាត្មាអញ មានសភាពមិនប្រកបដោយទោសៈ ចិត្តដែលភិក្ខុបានសន្សំល្អហើយ ដោយប្រាជ្ញាថា ចិត្តរបស់អាត្មាអញ មានសភាពមិនប្រកបដោយមោហៈ ចិត្តដែលភិក្ខុបានសន្សំល្អហើយ ដោយប្រាជ្ញាថា ចិត្តរបស់អាត្មាអញ មានសភាពមិនត្រឡប់ទៅដើម្បីកាមរាគៈ ចិត្តដែលភិក្ខុបានសន្សំល្អហើយ ដោយប្រាជ្ញាថា ចិត្តរបស់អាត្មាអញ មានសភាពមិនត្រឡប់

ទៅដើម្បីរូបរាគៈ ចិត្តដែលភិក្ខុបានសន្សំល្អហើយ ដោយប្រាជ្ញាថា ចិត្តរបស់អាត្មាអញ មានសភាពមិនត្រឡប់ទៅដើម្បីអរូបរាគៈ ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើចិត្តដែលភិក្ខុបានសន្សំល្អហើយ ដោយប្រាជ្ញាថា ម្នាលភិក្ខុទាំង-ឡាយ ការសន្សំរបស់ភិក្ខុនោះ គួរពោលថា ភិក្ខុនោះដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ចក៏អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

# អដ្ឋកថា

## បឋមសិលាយូបសូត្រ

[ ២៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមសិលាយូបសូត្រទី ៥ ដូចតទៅនេះ បទថា **យតោ** ប្រែថា ក្នុងកាលណា ។ បទថា **សុបរិចិតំ ហោតិ** បានដល់ អប់រំល្អហើយ ចម្រើនល្អហើយ ។ បទថា **កល្លំ វចនាយ** បានដល់ គួរដើម្បីនឹងពោល ។ បទថា **វីតរាគំ** បានដល់ ប្រាសចាករាគៈ ។ បទថា **អសរាគធម្មំ** បានដល់ អស់នូវភាពដែលឲ្យត្រេកអរដោយរាគៈ ។ បទថា **អនាវត្តិធម្មំ** បានដល់ អស់សភាវៈដែលនឹងត្រឡប់មក គឺមិនគួរកើតតទៅ អធិប្បាយថា មានភាពរលត់ឥតសេសសល់ ដោយមិនមានបដិសន្ធិ

តទៅនោះឯង ។ ក្នុងសូត្រនេះ លោកពោលដល់ព្រះខីណាស្រពប៉ុណ្ណោះ ។

## អដ្ឋកថា បឋមសិលាយូបសូត្រទី ៥ ចប់

# សុត្តន្តបិដក

## ទុតិយសិលាយូបសូត្រទី ៦

[ ២៦ ] សម័យមួយ ព្រះសារីបុត្តដ៏មានអាយុ និងព្រះចន្ទិកាបុត្តដ៏មានអាយុ គង់ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ ក្នុងទីនោះឯង ព្រះចន្ទិកាបុត្តដ៏មានអាយុ ហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោទាំងឡាយ ទេវទត្តសម្តែងធម៌ដល់ភិក្ខុទាំងឡាយ យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ វេលាណាចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្ត ចិត្តនុ៎ះ របស់ភិក្ខុនោះ គួរដើម្បីព្យាករថា ភិក្ខុនោះរមែងដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ កាលបើព្រះចន្ទិកាបុត្តដ៏មានអាយុ ពោលយ៉ាងនេះហើយ ព្រះសារីបុត្តដ៏មានអាយុ ក៏ពោលទៅនឹងព្រះចន្ទិកាបុត្តដ៏មានអាយុដូច្នេះថា ម្នាលអាវុសោចន្ទិកាបុត្ត ទេវទត្តមិនសម្តែង

ធម៌ដល់ភិក្ខុទាំងឡាយ យ៉ាងនេះទេថា ម្នាលអាវុសោទាំងឡាយ វេលាណា ចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្ត ចិត្តនុ៎ះ របស់ភិក្ខុនោះ គួរដើម្បីព្យាករថា ភិក្ខុនោះរមែងដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ មគ្គ-ព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ ម្នាលអាវុសោចន្ទិកាបុត្ត ទេវទត្តបានតែសម្តែងធម៌ដល់ភិក្ខុទាំងឡាយ យ៉ាងនេះទេ ម្នាលអាវុសោទាំងឡាយ វេលាណាចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្ត ចិត្តនុ៎ះរបស់ភិក្ខុនោះ គួរដើម្បីព្យាករថា ភិក្ខុនោះរមែងដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ ព្រះចន្ទិកាបុត្តដ៏មានអាយុ ហៅភិក្ខុទាំងឡាយមក ជាគម្រប់ ២ ដងទៀតថា ម្នាលអាវុសោទាំងឡាយ ទេវទត្តសម្តែងធម៌ដល់ភិក្ខុទាំងឡាយ យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ វេលាណាចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្ត ចិត្តនុ៎ះ របស់ភិក្ខុនោះ គួរដើម្បីព្យាករថា ភិក្ខុនោះរមែងដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គ-ភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ព្រះ

សារីបុត្តដ៏មានអាយុ ពោលទៅនឹងព្រះចន្ទិកាបុត្តដ៏មានអាយុ ជាគម្រប់ ២ ដងទៀតដូច្នេះថា ម្នាលអាវុសោចន្ទិកាបុត្ត ទេវទត្តមិនសម្តែងធម៌ដល់ភិក្ខុទាំងឡាយ យ៉ាងនេះទេថា ម្នាលអាវុសោទាំងឡាយ វេលាណាចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្ត ចិត្តនុ៎ះ របស់ភិក្ខុនោះ គួរដើម្បីព្យាករថា ភិក្ខុនោះរមែងដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលអាវុសោចន្ទិកាបុត្ត ទេវទត្តបានតែសម្តែងធម៌ដល់ភិក្ខុទាំង-ឡាយ យ៉ាងនេះទេថា ម្នាលអាវុសោទាំងឡាយ វេលាណាចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្ត ចិត្តនុ៎ះ របស់ភិក្ខុនោះ គួរដើម្បីព្យាករថា ភិក្ខុនោះរមែងដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ព្រះចន្ទិកាបុត្តដ៏មានអាយុ ហៅភិក្ខុទាំងឡាយមក ជាគម្រប់ ៣ ដងទៀតថា ម្នាលអាវុសោទាំងឡាយ ទេវទត្តសម្តែងធម៌ដល់ភិក្ខុទាំងឡាយ យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ វេលាណាចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្ត ចិត្តនុ៎ះ របស់ភិក្ខុនោះ គួរដើម្បីព្យាករថា ភិក្ខុនោះរមែងដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្ត

រួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ព្រះសារីបុត្តដ៏មានអាយុ ពោលទៅនឹងព្រះចន្ទិកាបុត្តដ៏មានអាយុ ជាគម្រប់ ៣ ដង ដូច្នេះថា ម្នាលអាវុសោចន្ទិកាបុត្ត ទេវទត្តមិនសម្តែងធម៌ដល់ភិក្ខុទាំងឡាយ យ៉ាងនេះទេថា ម្នាលអាវុសោទាំងឡាយ វេលាណាចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្ត ចិត្តនុ៎ះ របស់ភិក្ខុនោះ គួរដើម្បីព្យាករថា ភិក្ខុនោះ រមែងដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលអាវុសោចន្ទិកាបុត្ត ទេវទត្តបានតែសម្តែងធម៌ដល់ភិក្ខុទាំងឡាយ យ៉ាងនេះទេថា ម្នាលអាវុសោទាំងឡាយ វេលាណាចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្ត ចិត្តនុ៎ះ របស់ភិក្ខុនោះ គួរដើម្បីព្យាករថា ភិក្ខុនោះរមែងដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បី សោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលអាវុសោ ចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្ត តើដូចម្តេច ។ ចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្តថា ចិត្តរបស់អាត្មាអញប្រាសចាករាគៈហើយ ចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្តថា ចិត្តរបស់អាត្មាអញប្រាសចាកទោសៈហើយ ចិត្ត

ដែលភិក្ខុចម្រើនល្អហើយ ដោយចិត្តថា ចិត្តរបស់អាត្មាអញប្រាសចាកមោហៈហើយ ចិត្តដែលភិក្ខុចម្រើនល្អហើយដោយចិត្តថា ចិត្តរបស់អាត្មាអញមានសភាពមិនប្រកបដោយរាគៈ ចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្តថា ចិត្តរបស់អាត្មាអញ មានសភាពមិនប្រកបដោយទោសៈ ចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្តថា ចិត្តរបស់អាត្មាអញ មានសភាពមិនប្រកបដោយមោហៈ ចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្តថា ចិត្តរបស់អាត្មាអញ មានសភាពមិនបានត្រឡប់មកដើម្បីកាមភព ចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្តថា ចិត្តរបស់អាត្មាអញ មានសភាពមិនបានត្រឡប់មកដើម្បីរូបភព ចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្តថា ចិត្តរបស់អាត្មាអញ មានសភាពមិនបានត្រឡប់មកដើម្បីអរូបភព ។ ម្នាលអាវុសោ ភិក្ខុដែលមានចិត្តរួចស្រឡះដោយប្រពៃយ៉ាងនេះហើយ ទោះរូបដ៏ក្រៃលែងដែលគប្បីដឹងដោយចក្ខុ មកកាន់គន្លងនៃចក្ខុ ក៏គ្របសង្កត់ចិត្តរបស់ភិក្ខុនោះមិនបានឡើយ ចិត្តរបស់ភិក្ខុនោះមិនជាប់ស្អិត ជាចិត្តតាំងនៅ ដល់នូវការមិនញាប់ញ័រ ភិក្ខុនោះរមែងពិចារណាឃើញច្បាស់នូវសេចក្តីវិនាសទៅនៃចិត្តនោះ ទោះបីសំឡេងដ៏ក្រៃលែង គប្បីដឹងដោយត្រចៀក ។បេ។ ក្លិនគប្បីដឹងដោយច្រមុះ រសគប្បីដឹងដោយអណ្តាត ផោដ្ឋព្វៈគប្បីដឹងដោយកាយ ធម្មារម្មណ៍គប្បីដឹងដោយចិត្ត មកកាន់គន្លងនៃចិត្ត ក៏គ្របសង្កត់ចិត្តរបស់ភិក្ខុនោះ មិនបានឡើយ ចិត្តភិក្ខុនោះមិនជាប់ស្អិត ជាចិត្តតាំងនៅ ដល់នូវការមិនញាប់ញ័រ ភិក្ខុនោះរមែង

ពិចារណាឃើញច្បាស់នូវសេចក្ដីវិនាសទៅនៃចិត្តនោះ ម្នាលអាវុសោ ដូចសសរថ្ម មានប្រវែង ១៦ ហត្ថ សសរថ្មនោះដាំចុះទៅខាងក្រោមរណ្ដៅ ៨ ហត្ថ សល់នៅខាងលើរណ្ដៅ ៨ ហត្ថ ខាងក្រោយមក ទោះបីភ្លៀងប្រកបដោយខ្យល់យ៉ាងខ្លាំង មកពីទិសខាងកើត ក៏មិនកម្រើក មិនញាប់ញ័រ មិនរំកើប ទោះបីភ្លៀងប្រកបដោយខ្យល់យ៉ាងខ្លាំង មកពីទិសខាងលិច មកពីទិសខាងជើង ឬមកពីទិសខាងត្បូង ក៏មិនកម្រើក មិនញាប់ញ័រ មិនរំកើបដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលអាវុសោ ព្រោះថា សសរថ្មដែលគេជីកដាំជ្រៅល្អ យ៉ាងណាមិញ ម្នាលអាវុសោ ភិក្ខុដែលមានចិត្តរួចស្រឡះដោយប្រពៃយ៉ាងនេះហើយ ទោះបីរូបដ៏ក្រៃលែង ដែលគប្បីដឹងដោយចក្ខុ មកកាន់គន្លងនៃចក្ខុ ក៏គ្របសង្កត់ចិត្តរបស់ភិក្ខុនោះមិនបានឡើយ ចិត្តភិក្ខុនោះ មិនជាប់ស្អិត ជាចិត្តតាំងនៅ ដល់នូវការមិនញាប់ញ័រ ភិក្ខុនោះរមែងពិចារណាឃើញច្បាស់ នូវសេចក្ដីវិនាសទៅនៃចិត្តនោះ ទោះបីសំឡេងដ៏ក្រៃលែង គប្បីដឹងដោយត្រចៀក ។បេ។ ក្លិនគប្បីដឹងដោយច្រមុះ រសគប្បីដឹងដោយអណ្ដាត ផោដ្ឋព្វៈគប្បីដឹងដោយកាយ ធម្មារម្មណ៍គប្បីដឹងដោយចិត្ត មកកាន់គន្លងនៃចិត្ត ក៏គ្របសង្កត់ចិត្ត របស់ភិក្ខុនោះមិនបានឡើយ ចិត្តរបស់ភិក្ខុនោះ មិនជាប់ស្អិត ជាចិត្តតាំងនៅ ដល់នូវការមិនញាប់ញ័រ ភិក្ខុនោះរមែងពិចារណាឃើញច្បាស់ នូវសេចក្ដីវិនាសទៅនៃចិត្តនោះ ក៏យ៉ាងនោះដែរ ។

# អដ្ឋកថា

## ទុតិយសិលាយូបសូត្រ

[ ២៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយសិលាយូបសូត្រទី ៦ ដូចតទៅនេះ បទថា **ចន្ទិកាបុត្តោ** បានដល់ ព្រះថេរៈឈ្មោះចន្ទិកាបុត្រ ប្រាកដឈ្មោះតាមមាតា ។ បទថា **ចេតសា ចិត្តំ សុបរិចិតំ ហោតិ** សេចក្តីថា របៀបការប្រព្រឹត្តរបស់ចិត្តដែលភិក្ខុអប់រំល្អហើយ គឺចម្រើនល្អហើយ ឲ្យខ្ពស់ទៅៗ ដោយការប្រព្រឹត្តរបស់ចិត្ត ។ បទថា **នេវស្ស ចិត្តំ បរិយាទិយន្តិ** បានដល់ អារម្មណ៍ទាំងនោះមិនអាចជាប់ស្អិតចិត្តុប្បាទរបស់ព្រះខីណាស្រពនោះ ឲ្យអស់ទៅ ហើយតាំងនៅបាន ។ បទថា **អមិស្សីកតំ** បានដល់ ចិត្តមិនច្របូកច្របល់ដោយអារម្មណ៍ទាំងនោះ ព្រោះអារម្មណ៍ទាំងនោះមិនជាប់ ។ បទថា **អានេញ្ជប្បត្តំ** បានដល់ ដល់នូវការមិនញាប់ញ័រ គឺការមិនអន្ទះអន្ទែង ។ បទថា **សិលាយូបោ** បានដល់ សសរថ្ម ។ បទថា **សោឡសកុក្កុកោ** បានដល់ ប្រវែង ១៦ ហត្ថ ។ បទថា **ហេដ្ឋានេមង្គមា** បានដល់ ចាក់ចូលទៅបាតរណ្តៅ ។ បទថា **ឧបរិនេមស្ស** បានដល់ លើរណ្តៅ ។ បទថា **សុនិខាតត្តា** បានដល់ យកអង្រែដែកដំកប់រហូតបានជ្រៅ ។ ក្នុងបទថា **ឯវមេវ ខោ** នេះ គប្បីឃើញព្រះខីណាស្រព ដូចសសរថ្ម កិលេសកើតក្នុងទ្វារ ៦ ដូចខ្យល់ព្យុះ គប្បីជ្រាបកិលេសកើតឡើងក្នុងទ្វារ ៦ មិនអាចញុំាងចិត្តរបស់ព្រះខីណាស្រពឲ្យញាប់ញ័របាន ដូចខ្យល់ដែលបក់មកអំពី

ទិសទាំង ៤ មិនអាចឲ្យសសរថ្មញាប់ញ័របាន ដូច្នោះ ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគ ត្រាស់ដល់ព្រះខីណាស្រពប៉ុណ្ណោះ ។៚

## អដ្ឋកថា ទុតិយសិលាយូបសូត្រទី ៦ ចប់

# សុត្តន្តបិដក

## បឋមវេរសូត្រទី ៧

[ ២៧ ] គ្រានោះ អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលគហបតី វេលាណាអរិយសាវកបានរម្ងាប់នូវភ័យ និងពៀរទាំង ៥ និងប្រកបដោយអង្គ នៃសោតាបត្តិ ៤ យ៉ាងហើយ អរិយសាវកនោះ កាលប្រាថ្នា គប្បីព្យាករនូវខ្លួនដោយខ្លួនឯងបានថា អាត្មាអញមាននរកអស់ហើយ មានតិរច្ឆានកំណើតអស់ហើយ មានបិត្តិវិស័យអស់ហើយ មានអបាយ ទុគ្គតិ វិនិបាត អស់ហើយ អាត្មាអញជាអ្នកដល់នូវសោតៈ មានសភាពមិនបានធ្លាក់ចុះ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។ ភ័យ និងពៀរ ៥ ដែលអរិយសាវកបានរម្ងាប់ហើយ តើដូចម្តេច ។ ម្នាលគហបតី បុគ្គលជាអ្នកសម្លាប់សត្វ

រមែងបាននូវភ័យ និងពៀរ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នផង បាននូវភ័យ និងពៀរ ដែលប្រព្រឹត្តទៅក្នុងលោកខាងមុខផង ទទួលនូវទុក្ខ និងទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្តផង ព្រោះការសម្លាប់សត្វជាបច្ច័យ បុគ្គលជាអ្នកវៀរចាកបាណាតិបាត រមែងមិនបាននូវភ័យ និងពៀរ ដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្នផង មិនបាននូវភ័យ និងពៀរ ដែលប្រព្រឹត្តទៅ ក្នុងលោកខាងមុខផង មិនបានទទួលនូវទុក្ខ និងទោមនស្សដែលប្រព្រឹត្តទៅក្នុងចិត្តផង កាលបើបុគ្គលវៀរចាកបាណាតិបាតហើយ ទើបភ័យ និងពៀរនោះ ស្ងប់រម្ងាប់ទៅបានយ៉ាងនេះ ។ ម្នាលគហបតី បុគ្គលជាអ្នកកាន់យកនូវរបស់ដែលគេមិនបានឲ្យ ។បេ។ ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ជាអ្នកពោលពាក្យកុហក ជាអ្នកផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ តែងបាននូវភ័យ និងពៀរដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្នផង បាននូវភ័យ និងពៀរ ដែលប្រព្រឹត្តទៅ ក្នុងលោកខាងមុខផង ទទួលនូវទុក្ខ និងទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្តផង ព្រោះការផឹកនូវទឹកស្រវឹង គឺ សុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទជាបច្ច័យ បុគ្គលជាអ្នកវៀរចាកការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យដែលជាទីតាំងនៃសេចក្តីប្រមាទហើយ រមែងមិនបាននូវភ័យ និងពៀរដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្នផង មិនបាននូវភ័យ និងពៀរដែលប្រព្រឹត្តទៅ ក្នុងលោកខាងមុខផង មិនទទួលនូវទុក្ខ និងទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្តផង កាលបើបុគ្គលវៀចាកការផឹកនូវទឹក

ស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទហើយ ទើបភ័យ និងពៀរនោះស្ងប់រម្ងាប់ទៅបាន យ៉ាងនេះឯង ។ ភ័យ និងពៀរដែលអរិយ-សាវកបានរម្ងាប់ហើយមាន ៥ យ៉ាងនេះឯង ។ អរិយសាវកប្រកបដោយអង្គនៃសោតាបត្តិ ៤ យ៉ាង តើដូចម្តេច ។ ម្នាលគហបតី អរិយសាវកក្នុងសាសនានេះ ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ព្រះអង្គបរិបូណ៌ដោយវិជ្ជា និងចរណៈ ព្រះអង្គមានដំណើរទៅកាន់ព្រះនិព្វាន ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវចតុរាអរិយសច្ច ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ អរិយសាវក ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះធម៌ថា ព្រះបរិយត្តិធម៌ ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយដោយល្អ ជាធម៌ដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ជាធម៌ឲ្យនូវផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិ-បស្សិវិធី ជាធម៌ដែលបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយ គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។ អរិយសាវក ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះសង្ឃថា ព្រះសង្ឃសាវកនៃ

ព្រះដ៏មានព្រះភាគ ប្រតិបត្តិដោយប្រពៃ ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិត្រង់ ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិសមគួរ គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា បុរសបុគ្គលណា បើរាប់ជាគូបាន ៤ គូ បើរាប់រៀងជាបុរសបុគ្គលមាន ៨ ព្រះសង្ឃសាវ័ករបស់ព្រះដ៏មានព្រះភាគនុ៎ះ លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលនាំមកបូជា គួរទទួលនូវអាគន្តុកទាន គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។ អរិយសាវ័កនោះប្រកបដោយសីល ជាទីត្រេកអររបស់ព្រះអរិយៈ ជាសីលមិនដាច់ មិនធ្លុះមិនពព្រុស មិនពពាល ជាសីលជានា ដែលពួកអ្នកប្រាជ្ញ សរសើរហើយ ជាសីលមិនបពោសបង្អែលដោយតណ្ហា ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។ អរិយសាវ័ក ជាអ្នកប្រកបដោយអង្គនៃសោតាបត្តិ ៤ យ៉ាងនេះឯង ។ ម្នាលគហបតី វេលាណា អរិយសាវ័ក បានរម្ងាប់នូវភ័យ និងពៀរទាំង ៥ នេះទាំងប្រកបដោយអង្គនៃសោតាបត្តិទាំង ៤ យ៉ាងនេះហើយ អរិយសាវ័កនោះកាលបើប្រាថ្នា គប្បីព្យាករខ្លួនដោយខ្លួនឯងបានថា អាត្មាអញមាននរកអស់ហើយ មានតិរច្ឆានកំណើតអស់ហើយ មានបិត្តិវិស័យអស់ហើយ មានអបាយទុគ្គតិ និងវិនិបាតអស់ហើយ អាត្មាអញជាអ្នកដល់នូវសោតៈហើយជាអ្នកមានសភាពមិនបានធ្លាក់ចុះ ជាអ្នកទៀង មានសេចក្តីត្រាស់ដឹងប្រព្រឹត្ត

ទៅខាងមុខ ។

# អដ្ឋកថា

## បឋមវេរសូត្រ

[ ២៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមវេរសូត្រទី ៧ ដូចតទៅនេះ បទថា **ភយំ វេរំ បសវតិ** បានដល់ ជួបនូវការភ័យកើតអំពីចិត្តតក់ស្លុត និងពៀរកើតអំពីបុគ្គល ។ បទថា **ចេតសិកំ** បានដល់ អាស្រ័យចិត្ត ។ បទថា **ទុក្ខំ** បានដល់ មានកាយជាទីតាំង ។ បទថា **ទោមនស្សំ** បានដល់ ទុក្ខដែលសម្បយុត្តដោយការចង្អៀតចង្អល់ ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគ ត្រាស់ដល់សោតាបត្តិមគ្គ ។

**អដ្ឋកថា បឋមវេរសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ទុតិយវេរសូត្រទី ៨

[ ២៨ ] ម្នាលភិក្ខុទាំងឡាយ វេលាណា អរិយសាវក បានរម្ងាប់នូវភ័យ និងពៀរទាំង ៥ ទាំងប្រកបដោយអង្គនៃសោតាបត្តិទាំង ៤ យ៉ាងហើយ អរិយសាវកនោះ កាលបើប្រាថ្នា គប្បីព្យាករនូវខ្លួនដោយខ្លួនឯងបានថា អាត្មាអញ មាននរកអស់ហើយ មានតិរច្ឆានកំណើតអស់ហើយមានបិត្តិវិស័យអស់ហើយ មានអបាយទុគ្គតិ និងវិនិបាតអស់ហើយ អាត្មាអញជាអ្នកដល់នូវសោតៈ ជាអ្នកមានសភាពមិនបានធ្លាក់ចុះ ជាអ្នកទៀង មានសេចក្តីត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។ ភ័យ និងពៀរទាំង ៥ ដែលអរិយសាវកបានរម្ងាប់ហើយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលជាអ្នកសម្លាប់សត្វតែងបាននូវភ័យ និងពៀរ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នផង បាននូវភ័យ និងពៀរ ដែលប្រព្រឹត្តទៅក្នុងលោកខាងមុខផង ទទួលនូវទុក្ខ និងទោមនស្សដែលប្រព្រឹត្តទៅក្នុងចិត្តផង ព្រោះការសម្លាប់សត្វជាបច្ច័យ បុគ្គលជាអ្នកវៀរចាកការសម្លាប់សត្វ ។បេ។ ទើបភ័យ និងពៀរនោះ រម្ងាប់ទៅបានយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាន់យកទ្រព្យ ដែលគេមិនបានឲ្យ ។បេ។ បុគ្គលជាអ្នកប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ជាអ្នកពោលពាក្យកុហក ជាអ្នកផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ តែងបាននូវភ័យ និងពៀរ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នផង បាននូវភ័យ និងពៀរ ដែលប្រព្រឹត្តទៅក្នុងលោកខាងមុខផង ទទួលនូវទុក្ខ និង

ទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្តផង ព្រោះការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្ដីប្រមាទជាបច្ច័យ បុគ្គលអ្នកវៀរចាកការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្ដីប្រមាទហើយ តែងមិនបាននូវភ័យ និងពៀរ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នផង មិនបាននូវភ័យ និងពៀរ ដែលប្រព្រឹត្តទៅក្នុងលោកខាងមុខផង មិនទទួលនូវទុក្ខ និងទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្តផង កាលបើបុគ្គលវៀរចាកការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្ដីប្រមាទហើយ ទើបភ័យ និងពៀរនោះ រម្ងាប់ទៅបានយ៉ាងនេះ ។ ភ័យ និងពៀរ ដែលអរិយសាវកបានរម្ងាប់ហើយ មាន ៥ យ៉ាងនេះឯង ។ ចុះអរិយសាវក ដែលប្រកបដោយអង្គនៃសោតាបត្តិ ៤ យ៉ាង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកប្រកបដោយសេចក្ដីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។ ព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀត ។ ក្នុងព្រះធម៌ ។បេ។ ក្នុងព្រះសង្ឃ ។ អរិយសាវកប្រកបដោយសីលទាំងឡាយ ដែលជាទីត្រេកអរបស់ព្រះអរិយៈ ជាសីលមិនដាច់ មិនធ្លុះ មិនពព្រុស មិនពពាល ជាសីលជានា ដែលពួកអ្នកប្រាជ្ញសរសើរហើយ ជាសីលមិនបរាមាសអន្លែលដោយតណ្ហា ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។ អរិយសាវកប្រកបដោយអង្គ នៃសោតាបត្តិ ៤

យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ វេលាណា អរិយសាវ័ក បានរម្ងាប់នូវភ័យ និងពៀរ ៥ យ៉ាងនេះ ទាំងប្រកបហើយដោយអង្គ នៃសោតាបត្តិទាំង ៤ យ៉ាងនេះហើយ អរិយសាវ័កនោះ កាលបើប្រាថ្នា គប្បីព្យាករនូវខ្លួនដោយខ្លួនឯងបានថា អាត្មាអញមាននរកអស់ហើយ មានតិរច្ឆានកំណើតអស់ហើយ មានបិត្តិវិស័យអស់ហើយ មានអបាយ ទុគ្គតិ និងវិនិបាតអស់ហើយ អាត្មាអញជាអ្នកដល់នូវសោតៈ ជាអ្នកមានសភាពមិនបានធ្លាក់ចុះ ជាអ្នកទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។

# អដ្ឋកថា

## ទុតិយវេរសូត្រ

[ ២៨ ] ទុតិយវេរសូត្រទី ៨ ព្រះមានព្រះភាគត្រាស់ដល់ពួកភិក្ខុ តែក្នុងសូត្រនេះ លោកពោលថា ព្រះមានព្រះភាគ ត្រាស់ដល់ព្រះសោតាបន្នប៉ុណ្ណោះ ។

### អដ្ឋកថាទុតិយវេរសូត្រទី ៨ ចប់

# សុត្តន្តបិដក

## បឋមអាឃាតសូត្រទី ៩

[ ២៩ ] ម្នាលភិក្ខុទាំងឡាយ អាឃាតវត្ថុ ( ហេតុជាទីតាំងនៃសេចក្តីគុំកួន ) នេះមាន ៩ យ៉ាង ។ អាឃាតវត្ថុទាំង ៩ យ៉ាង តើដូចម្តេចខ្លះ ។ គឺបុគ្គលចងគំនុំ ដោយគិតថា ជនឯណោះ បានប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ ១ ចងគំនុំដោយគិតថា ជនឯណោះកំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ ១ ចងគំនុំដោយគិតថា ជនឯណោះនឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ ដល់អាត្មាអញ ១ ចងគំនុំដោយគិតថា ជនឯណោះ បានប្រព្រឹត្តហើយនូវអំពើមិនជាប្រយោជន៍ដល់សត្វ និងសង្ខារជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អាត្មាអញ ១ ចងគំនុំដោយគិតថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើ មិនជាប្រយោជន៍ដល់សត្វ និងសង្ខារជាទីស្រឡាញ់ ជាទីពេញចិត្តរបស់អាត្មាអញ ១ ចងគំនុំដោយគិតថា ជនឯណោះនឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់សត្វ និងសង្ខារជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អាត្មាអញ ១ ចងគំនុំដោយគិតថា ជនឯណោះ បានប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់សត្វ និងសង្ខារ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ១ ចងគំនុំដោយគិតថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់សត្វ និងសង្ខារ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ១ ចងគំនុំដោយគិតថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់សត្វ និងសង្ខារ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់

*អាត្មាអញ ១ ។ ម្នាលភិក្ខុទាំងឡាយ អាឃាតវត្ថុមាន ៩ យ៉ាងនេះឯង ។*

# អដ្ឋកថា

## បឋមអាឃាតសូត្រ

*[ ២៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមអាឃាតសូត្រទី ៩ ដូចតទៅនេះ បទថា* **អាឃាតវត្ថូនិ** *បានដល់ ហេតុនៃអាឃាត ។ បទថា* **អាឃាតំ ពន្ធតិ** *បានដល់ ដែលចងសេចក្តីក្រោធ គឺធ្វើសេចក្តីក្រោធឲ្យកើតឡើង ។ល។*

**អដ្ឋកថា បឋមអាឃាតសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ទុតិយអាឃាតសូត្រទី ១០

*[ ៣០ ] ម្នាលភិក្ខុទាំងឡាយ អាឃាតប្បដិវិន័យ ( ការកម្ចាត់បង់នូវសេចក្តីគុំកួន ) នេះមាន ៩ យ៉ាង ។ អាឃាតប្បដិវិន័យទាំង ៩ យ៉ាង តើដូចម្តេច ។ គឺបុគ្គលកម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ បានប្រព្រឹត្តនូវអំពើ មិនជាប្រយោជន៍ដល់អាត្មាអញ ព្រោះហេតុនោះ អាត្មាអញគប្បីបាននូវអំពើមិនជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះ អំពីណា ១ កម្ចាត់បង់*

នូវគំនុំ ដោយគិតថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើ មិនជាប្រយោជន៍ដល់អាត្មាអញ ព្រោះហេតុនោះ អាត្មាអញគប្បីបាននូវអំពើ មិនជាប្រ-យោជន៍នោះ ក្នុងបុគ្គលនុ៎ះ អំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើ មិនជាប្រយោជន៍ដល់អាត្មាអញ ព្រោះហេតុនោះ អាត្មាអញគប្បីបាននូវអំពើ មិនជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះ អំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ បានប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់សត្វ និងសង្ខារជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អាត្មាអញ ព្រោះហេតុនោះ អាត្មាអញគប្បីបាននូវអំពើមិនជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះ អំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើ មិនជាប្រយោជន៍ដល់សត្វ និងសង្ខារជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អាត្មាអញ ព្រោះហេតុនោះ អាត្មាអញគប្បីបាននូវអំពើ មិនជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះ អំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើ មិនជាប្រយោជន៍ដល់សត្វ និងសង្ខារជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អាត្មាអញ ព្រោះហេតុនោះ អាត្មាអញគប្បីបាននូវអំពើ មិនជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះ អំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ បានប្រព្រឹត្តនូវអំពើ ជាប្រយោជន៍ដល់សត្វ និងសង្ខារមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ព្រោះហេតុនោះ អាត្មាអញគប្បីបាននូវអំពើជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះ អំពី

ណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើ ជាប្រយោជន៍ដល់សត្វ និងសង្ខារ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ព្រោះហេតុនោះ អាត្មាអញគប្បីបាននូវអំពើ ជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះ អំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើ ជាប្រយោជន៍ដល់សត្វ និងសង្ខារមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ព្រោះហេតុនោះ អាត្មាអញគប្បីបាននូវអំពើ ជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះ អំពីណា ១ ។ ម្នាលភិក្ខុទាំងឡាយ អាឃាតប្បដិវិន័យ មាន ៩ យ៉ាងនេះឯង ។

# អដ្ឋកថា

## ទុតិយអាឃាតសូត្រ

[ ៣០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយអាឃាតសូត្រទី ១០ ដូចតទៅនេះ បទថា **អាឃាតប្បដិវិនយា** បានដល់ ហេតុនៃការកម្ចាត់អាឃាត ។ បទថា **តំ កុតេត្ថ លព្ភា** សេចក្តីថា អាត្មាអញគប្បីបានក្នុងបុគ្គលនេះអំពីណា គឺអាត្មាអញ អាចបានដោយហេតុដូចម្តេចថា ការប្រព្រឹត្តមិនជាប្រយោជន៍នោះ កុំមានឡើយដូច្នេះ ។ អធិប្បាយថា បុគ្គលគិតយ៉ាងនេះថា ជម្ងឺតាអ្នកដទៃនឹងធ្វើសេចក្តីវិនាសដល់អ្នកដទៃ តាមការពេញចិត្តរបស់ខ្លួន ដូច្នេះហើយ

កម្ចាត់នូវអាឃាតចេញបាន ។ម្យ៉ាងទៀត បើយើងធ្វើសេចក្តីក្រោធតប ការធ្វើសេចក្តីក្រោធនោះ យើងគប្បីបានក្នុងបុគ្គលនោះ អំពីណា អធិប្បាយថា យើងអាចនឹងបានដោយហេតុអ្វី ។ បាឋៈថា **តំ កុតោ លាភា** ដូច្នេះក៏មានសេចក្តីថា បើយើងគប្បីធ្វើសេចក្តីក្រោធក្នុងបុគ្គលនេះ ក្នុងការធ្វើសេចក្តីក្រោធរបស់យើងនោះ គប្បីបានអំពីណា អធិប្បាយថា ឈ្មោះថា គប្បីបានអ្វីមក ។ បទថា **តំ** ក្នុងអត្ថនេះ ត្រឹមតែជានិបាតប៉ុណ្ណោះ ៕

**អដ្ឋកថា ទុតិយអាឃាតសូត្រទី ១០ ចប់**

# សុត្តន្តបិដក

## អនុបុព្វនិរោធសូត្រទី ១១

[ ៣១ ] ម្នាលភិក្ខុទាំងឡាយ អនុបុព្វនិរោធ ( ធម៌ជាគ្រឿងរលត់ដោយលំដាប់ឈាន ) នេះមាន ៩ យ៉ាង ។ អនុបុព្វនិរោធទាំង ៩ យ៉ាង តើដូចម្តេច ។ គឺកាលបុគ្គលចូលបឋមជ្ឈានហើយ អាមិសសញ្ញារលត់ទៅ ១ កាលចូលទុតិយជ្ឈាន វិតក្កវិចារៈរលត់ទៅ ១ កាលចូលតតិយជ្ឈាន បីតិរលត់ទៅ ១ កាលចូលទៅចតុត្ថជ្ឈាន អស្សាសៈ និងបស្សាសៈ រលត់ទៅ ១ កាលចូលអាកាសានញ្ចាយតនជ្ឈាន រូបសញ្ញារលត់ទៅ ១ កាលចូលវិញ្ញាណញ្ចាយតនជ្ឈាន អាកាសានញ្ចាយតនសញ្ញារលត់ទៅ ១ កាល

ចូលអាកិញ្ចញ្ញាយតនជ្ឈាន វិញ្ញាណញ្ចាយតនសញ្ញារលត់ទៅ ១ កាលចូលនេវសញ្ញានាសញ្ញាយតនជ្ឈាន អាកិញ្ចញ្ញាយតនសញ្ញារលត់ទៅ ១ កាលចូលសញ្ញាវេទយិតនិរោធ សញ្ញា និងវេទនារលត់ទៅ ១ ។ ម្នាលភិក្ខុទាំងឡាយ អនុបុព្វនិរោធ មាន ៩ យ៉ាងនេះឯង ។

សត្តាវាសវគ្គទី ៣ ចប់

## ឧទ្ទានក្នុងសត្តាវាសវគ្គនោះ គឺ

និយាយអំពីហេតុដ៏ប្រសើរ ១ អំពីគោត្រ ១ អំពីតណ្ហាមូលកធម៌ ១ អំពីវិវត្តសញ្ញា ១ អំពីការប្រៀបដោយសសរថ្ម ១ អំពីពៀរមាន ២ លើក អំពីអាឃាតវត្ថុមាន ២ លើក អំពីអនុបុព្វនិរោធ ១ ។

# អដ្ឋកថា

## អនុបុព្វនិរោធសូត្រ

[ ៣១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអនុបុព្វនិរោធសូត្រទី ១១ ដូចតទៅនេះ បទថា **អនុបុព្វនិរោធា** បានដល់ រលត់ទៅតាមលំដាប់ ។ ពាក្យដ៏សេសក្នុងបទទាំងពួង ងាយយល់ទាំងអស់ហើយ ៕

**អដ្ឋកថា អនុបុព្វនិរោធសូត្រទី ១១ ចប់**

**សត្តាវាសវគ្គទី ៣ ចប់**

# សុត្តន្តបិដក
# មហាវគ្គទី ៤

## បឋមវិហារសូត្រទី ១

[ ៣២ ] ម្នាលភិក្ខុទាំងឡាយ អនុបុព្វវិហារ ( ធម៌ជាគ្រឿងនៅតាមលំដាប់ ) នេះមាន ៩ យ៉ាង ។ អនុបុព្វវិហារ ៩ យ៉ាង តើដូចម្តេច ។ គឺ បឋមជ្ឈាន ១ ទុតិយជ្ឈាន ១ តតិយជ្ឈាន ១ ចតុត្ថជ្ឈាន ១ អាកាសានញ្ចាយតនជ្ឈាន ១ វិញ្ញាណញ្ចាយតនជ្ឈាន ១ អាកិញ្ចញ្ញាយតនជ្ឈាន ១ នេវសញ្ញានាសញ្ញាយតនជ្ឈាន ១ សញ្ញាវេទយិតនិរោធ ១ ។ ម្នាលភិក្ខុទាំងឡាយ អនុបុព្វវិហារ មាន ៩ យ៉ាងនេះឯង ។

# អដ្ឋកថា

## មហាវគ្គទី ៤

### បឋមវិហារសូត្រ

[ ៣២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមវិហារសូត្រទី ១ នៃមហាវគ្គទី ៤ ដូចតទៅនេះ បទថា **អនុបុព្វវិហារា** បានដល់ វិហារធម៌ ដែលគួរចូលដល់តាមលំដាប់ ៗ។ល។

អដ្ឋកថា បឋមវិហារសូត្រទី ១ ចប់

# សុត្តន្តបិដក

## ទុតិយវិហារសូត្រទី ២

[ ៣៣ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវអនុបុព្វវិហារ-សមាបត្តិ ៩ យ៉ាងនេះ អ្នកទាំងឡាយ ចូរប្រុងស្តាប់នូវអនុបុព្វវិហារសមា-បត្តិនោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ អនុបុព្វវិហារសមាបត្តិ ៩ យ៉ាង តើដូចម្តេចខ្លះ ។ តថាគតពោលថា កាមទាំងឡាយរលត់ទៅ ក្នុងទីណា មួយទៀត ជនទាំងឡាយណា បានរម្ងាត់អស់ហើយ នូវកាមទាំងឡាយ អ្នកដ៏មានអាយុទាំងនោះ ឈ្មោះថា អ្នកមិនមានសេចក្តីស្រេកឃ្លាន អ្នករម្ងាត់ទុក្ខ

បានឆ្លងនូវកាមទាំងឡាយ បានដល់នូវត្រើយ ដោយអង្គនៃឈាននោះដោយពិត ។ ( បើ ) បុគ្គលណាមួយ គប្បីពោលយ៉ាងនេះដូច្នេះថា កាមទាំង-ឡាយរលត់ទៅ ក្នុងទីដូចម្តេច មួយទៀត ពួកជនដូចម្តេចដែលរម្ងត់អស់ហើយនូវកាមទាំងឡាយ ខ្ញុំមិនស្គាល់នូវហេតុនុ៎ះ ខ្ញុំមិនឃើញនូវហេតុនុ៎ះទេ បុគ្គលនោះ អ្នកទាំងឡាយ គួរប្រាប់យ៉ាងនេះទៅវិញថា ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ បានស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំង-ឡាយ បានដល់បឋមជ្ឈាន ដែលប្រកបដោយវិតក្ក និងវិចារៈ មានបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ កាមទាំងឡាយ តែងរលត់ទៅ ក្នុងបឋមជ្ឈាននុ៎ះ បុគ្គលទាំងនោះ ឈ្មោះថា បានរម្ងត់អស់ហើយនូវកាមទាំង-ឡាយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកមិនអួតអាង មិនមានមាយា គប្បីត្រេកអរ គប្បីអនុមោទនានូវភាសិតថា សាធុដូច្នេះ ដោយពិត លុះត្រេកអរ និងអនុមោទនានូវភាសិតថា សាធុដូច្នេះហើយ គប្បីនមស្ការប្រណម្យអញ្ជលីហើយ ចូលទៅអង្គុយជិត ។ តថាគតពោលថា វិតក្ក និងវិចារៈទាំងឡាយ រលត់ទៅក្នុងទីណា មួយទៀត ពួកជនណា បានរម្ងត់អស់ហើយ នូវវិតក្ក និងវិចារៈទាំងឡាយ អ្នកដ៏មានអាយុទាំងនោះ ឈ្មោះថា អ្នកមិនមានសេចក្តីស្រេកឃ្លាន អ្នករម្ងត់ទុក្ខ បានឆ្លងនូវកាមទាំងឡាយ បានដល់នូវត្រើយ ដោយអង្គនៃឈាននោះដោយពិត ។ ( បើ ) បុគ្គលណាពោលយ៉ាងនេះថា វិតក្ក និងវិចារៈ រលត់ទៅក្នុងទីដូចម្តេច មួយទៀត ពួក

ជនដូចម្តេច ដែលរម្ងាប់នូវវិតក្ក និងវិចារៈ ខ្ញុំមិនស្គាល់នូវហេតុនុ៎ះ ខ្ញុំមិនឃើញនូវហេតុនុ៎ះទេ បុគ្គលនោះ អ្នកទាំងឡាយ គួរប្រាប់យ៉ាងនេះទៅវិញថា ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ព្រោះរម្ងាប់នូវវិតក្ក និងវិចារៈ ។បេ។ បានដល់នូវទុតិយជ្ឈាន វិតក្ក និងវិចារៈ តែងរលត់ទៅ ក្នុងទុតិយជ្ឈាននុ៎ះ បុគ្គលទាំងនោះ ឈ្មោះថា រម្ងាប់អស់ហើយនូវវិតក្ក និងវិចារៈ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកមិនអួតអាង មិនមានមាយា គប្បីត្រេកអរ គប្បីអនុមោទនានូវភាសិតថា សាធុដូច្នេះ ដោយពិត លុះត្រេកអរអនុមោទនានូវភាសិតថា សាធុដូច្នេះហើយ គប្បីនមស្ការប្រណម្យអញ្ជលី ហើយចូលទៅអង្គុយជិត ។ តថាគតពោលថា បីតិរលត់ទៅក្នុងទីណា មួយទៀត ពួកជនណា បានរម្ងាប់អស់ហើយ នូវបីតិ អ្នកដ៏មានអាយុទាំងនោះ ឈ្មោះថា អ្នកមិនមានសេចក្តីស្រេកឃ្លាន អ្នករម្ងាប់ទុក្ខ បានឆ្លងនូវកាមទាំងឡាយ បានដល់នូវត្រើយដោយអង្គនៃឈាននោះដោយពិត ។ ( បើ ) បុគ្គលណាពោលយ៉ាងនេះថា បីតិរលត់ទៅ ក្នុងទីដូចម្តេច មួយវិញទៀត ពួកជនដូចម្តេច ដែលរម្ងាប់អស់ហើយនូវបីតិ ខ្ញុំមិនស្គាល់នូវហេតុនុ៎ះ ខ្ញុំមិនឃើញនូវហេតុនុ៎ះទេ បុគ្គលនោះ អ្នកទាំងឡាយ គួរប្រាប់យ៉ាងនេះទៅវិញថា ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះប្រាសចាកបីតិផង ។បេ។ បានដល់តតិយជ្ឈាន បីតិតែងរលត់ទៅក្នុងតតិយជ្ឈាននុ៎ះ បុគ្គលទាំងនោះ ឈ្មោះថា រម្ងាប់អស់ហើយនូវបីតិ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកមិន

អួតអាង មិនមានមាយា គប្បីត្រេកអរ គប្បីអនុមោទនានូវភាសិតថា សាធុ ដូច្នេះ ដោយពិត លុះត្រេកអរអនុមោទនានូវភាសិតថា សាធុដូច្នេះហើយ គប្បីនមស្ការប្រណម្យអញ្ជលី ហើយចូលទៅអង្គុយជិត ។ តថាគតពោលថា សេចក្តីសុខក្នុងឧបេក្ខារលត់ទៅក្នុងទីណា មួយទៀត ពួកជនណាបាន រលត់អស់ហើយនូវសេចក្តីសុខក្នុងឧបេក្ខា អ្នកដ៏មានអាយុទាំងនោះ ឈ្មោះថា អ្នកមានសេចក្តីស្រេចឃ្លាន អ្នករម្ងត់ទុក្ខ បានឆ្លងនូវកាមទាំងឡាយ បានដល់នូវត្រើយ ដោយអង្គនៃឈាននោះដោយពិត ។ ( បើ ) បុគ្គលណាពោលយ៉ាងនេះថា សេចក្តីសុខក្នុងឧបេក្ខារលត់ទៅក្នុងទីដូចម្តេច មួយទៀត ពួកជនដូចម្តេចដែលរលត់អស់ហើយនូវសេចក្តីសុខក្នុងឧបេក្ខា ខ្ញុំមិនស្គាល់នូវហេតុនុ៎ះ ខ្ញុំមិនឃើញនូវហេតុនុ៎ះទេ បុគ្គលនោះ អ្នកទាំងឡាយគួរប្រាប់យ៉ាងនេះទៅវិញថា ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់នូវសុខផង ។បេ។ បានដល់ចតុត្ថជ្ឈាន សេចក្តីសុខក្នុងឧបេក្ខា តែងរលត់ទៅក្នុងចតុត្ថជ្ឈាននុ៎ះ ជនទាំងនោះ ឈ្មោះថា បានរម្ងត់អស់ហើយនូវសេចក្តីសុខក្នុងឧបេក្ខា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកមិនអួតអាង មិនមានមាយា គប្បីត្រេកអរ គប្បីអនុមោទនានូវភាសិតថា សាធុដូច្នេះ ដោយពិត លុះត្រេកអរ អនុមោទនានូវភាសិតថា សាធុដូច្នេះហើយ គប្បីនមស្ការប្រណម្យអញ្ជលី ហើយចូលទៅអង្គុយជិត ។ តថាគតពោលថា រូបសញ្ញារលត់ទៅក្នុងទីណា មួយទៀត ពួកជនណា បានរម្ងត់អស់ហើយនូវរូបសញ្ញា

អ្នកដ៏មានអាយុទាំងនោះ ឈ្មោះថា អ្នកមិនមានសេចក្ដីស្រេកឃ្លាន អ្នករម្ងត់ទុក្ខ បានឆ្លងនូវកាមទាំងឡាយ បានដល់នូវត្រើយ ដោយអង្គនៃឈាននោះដោយពិត ។ ( បើ ) បុគ្គលណា ពោលយ៉ាងនេះថា រូបសញ្ញារលត់ទៅក្នុងទីដូចម្ដេច មួយទៀត ពួកជនដូចម្ដេច ដែលរលត់អស់ហើយនូវរូបសញ្ញា ខ្ញុំមិនស្គាល់នូវហេតុនុ៎ះ ខ្ញុំមិនឃើញនូវហេតុនុ៎ះទេ បុគ្គលនោះ អ្នកទាំង-ឡាយ គួរប្រាប់យ៉ាងនេះទៅវិញថា ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងនូវរូបសញ្ញាដោយប្រការទាំងពួង ព្រោះអស់ទៅ នៃបដិឃសញ្ញាហើយ លែងធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ហើយបានដល់នូវអាកាសា-នញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុត ដូច្នេះ រូបសញ្ញាតែងរលត់ទៅ ក្នុងអាកាសានញ្ចាយតនជ្ឈាននុ៎ះ ជនទាំងនោះឈ្មោះថា បានរម្ងត់អស់ហើយនូវរូបសញ្ញា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកមិនអួតអាង មិនមានមាយា គប្បីត្រេកអរ គប្បីអនុមោទនានូវភាសិតថា សាធុដូច្នេះ ដោយពិត លុះត្រេកអរ អនុមោទនានូវភាសិតថា សាធុដូច្នេះហើយ គប្បីនមស្ការប្រណម្យអញ្ជលី ហើយចូលទៅអង្គុយជិត ។ តថាគតពោលថា អាកាសានញ្ចាយតនសញ្ញា រលត់ទៅក្នុងទីណា មួយទៀត ពួកជនណាបានរម្ងត់អស់ហើយនូវអាកាសានញ្ចាតនសញ្ញា អ្នកដ៏មានអាយុទាំងនោះ ឈ្មោះថា អ្នកមិនមានសេចក្ដីស្រេកឃ្លាន អ្នករម្ងត់ទុក្ខ បានឆ្លងនូវកាមទាំងឡាយហើយ បានដល់នូវត្រើយ ដោយអង្គនៃឈាននោះ ដោយ

ពិត ។ ( បើ ) បុគ្គលណាពោលយ៉ាងនេះថា អាកាសានញ្ចាយតនសញ្ញា រលត់ទៅក្នុងទីដូចម្តេច មួយទៀត ពួកជនដូចម្តេចដែលរម្ងត់អស់ហើយនូវ អាកាសានញ្ចាយតនសញ្ញា ខ្ញុំមិនស្គាល់នូវហេតុនុ៎ះ ខ្ញុំមិនឃើញនូវហេតុនុ៎ះ ទេ បុគ្គលនោះ អ្នកទាំងឡាយគួរប្រាប់យ៉ាងនេះទៅវិញថា ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការ ទាំងពួង ហើយបានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុត ដូច្នេះ អាកាសានញ្ចាយតនសញ្ញា តែងរលត់ទៅក្នុង វិញ្ញាណញ្ចាយតនៈនោះ ជនទាំងនោះ ឈ្មោះថា បានរលត់អស់ហើយនូវ អាកាសានញ្ចាយតនសញ្ញា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកមិនអួតអាង មិនមានមាយា គប្បីត្រេកអរ គប្បីអនុមោទនានូវភាសិតថា សាធុដូច្នេះ ដោយពិត លុះត្រេកអរ អនុមោទនានូវភាសិតថា សាធុដូច្នេះហើយ គប្បី នមស្ការប្រណម្យអញ្ជលី ហើយចូលទៅអង្គុយជិត ។ តថាគតពោលថា វិញ្ញាណញ្ចាយតនសញ្ញារលត់ទៅក្នុងទីណា មួយទៀត ពួកជនណា បាន រម្ងត់អស់ហើយនូវវិញ្ញាណញ្ចាយតនសញ្ញា អ្នកដ៏មានអាយុទាំងនោះ ឈ្មោះ ថា អ្នកមិនមានសេចក្តីស្រេកឃ្លាន អ្នករម្ងត់ទុក្ខ បានឆ្លងនូវកាមទាំងឡាយ ហើយបានដល់នូវត្រើយ ដោយអង្គនៃឈាននោះដោយពិត ។ ( បើ ) បុគ្គលណា ពោលយ៉ាងនេះថា វិញ្ញាណញ្ចាយតនសញ្ញាតែងរលត់ទៅក្នុងទី ដូចម្តេច មួយទៀត ពួកជនដូចម្តេច ដែលរម្ងត់អស់ហើយនូវវិញ្ញាណញ្ចា-

យតនសញ្ញា ខ្ញុំមិនស្គាល់នូវហេតុនុ៎ះ ខ្ញុំមិនឃើញនូវហេតុនុ៎ះទេ បុគ្គលនោះ អ្នកទាំងឡាយគួរប្រាប់យ៉ាងនេះទៅវិញថា ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា របស់អ្វីបន្តិចបន្តួចមិនមានដូច្នេះ វិញ្ញាណញ្ចាយតនសញ្ញា តែងរលត់ទៅក្នុងអាកិញ្ចញ្ញាយតនៈនុ៎ះ ជនទាំងនោះ ឈ្មោះថា បានរម្ងត់អស់ហើយ នូវវិញ្ញាណញ្ចាយតនសញ្ញា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកមិនអួតអាង មិនមានមាយា គប្បីត្រេកអរ គប្បីអនុមោទនានូវភាសិតថា សាធុដូច្នេះ ដោយពិត លុះត្រេកអរ អនុមោទនានូវភាសិតថា សាធុដូច្នេះហើយ គប្បីនមស្ការប្រណម្យអញ្ជលី ហើយចូលទៅអង្គុយជិត ។ តថាគតពោលថា អាកិញ្ចញ្ញាយតនសញ្ញា តែងរលត់ទៅក្នុងទីណា មួយទៀត ពួកជនណា បានរម្ងត់អស់ហើយនូវអាកិញ្ចញ្ញាយតនសញ្ញា អ្នកដ៏មានអាយុទាំងនោះឈ្មោះថា អ្នកមិនមានសេចក្តីស្រេកឃ្លាន អ្នករម្ងត់ទុក្ខ បានឆ្លងនូវកាមទាំងឡាយ បានដល់នូវត្រើយដោយអង្គនៃឈាននោះ ។ ( បើ ) បុគ្គលណាពោលយ៉ាងនេះថា អាកិញ្ចញ្ញាយតនសញ្ញា តែងរលត់ទៅក្នុងទីដូចម្តេច មួយទៀត ពួកជនដូចម្តេច ដែលរម្ងត់អស់ហើយនូវអាកិញ្ចញ្ញាយតនសញ្ញា ខ្ញុំមិនស្គាល់នូវហេតុនុ៎ះ ខ្ញុំមិនឃើញនូវហេតុនោះទេ បុគ្គលនោះ អ្នកទាំងឡាយគួរប្រាប់យ៉ាងនេះទៅវិញថា ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងនូវអាកិញ្ចញ្ញា-

យតនៈ ដោយប្រការទាំងពួង ហើយបានដល់នូវនេវសញ្ញានាសញ្ញាយត-
នជ្ឈាន អាកិញ្ចញ្ញាយតនសញ្ញា តែងរលត់ទៅក្នុងនេវសញ្ញានាសញ្ញាយតនៈ
នុ៎ះ ជនទាំងនោះ ឈ្មោះថា បានរម្ងត់អស់ហើយនូវអាកិញ្ចញ្ញាយតនសញ្ញា ។
ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកមិនអួតអាង មិនមានមាយា គប្បីត្រេកអរ
គប្បីអនុមោទនានូវភាសិតថា សាធុដូច្នេះ ដោយពិត លុះត្រេកអរ អនុ-
មោទនានូវភាសិតថា សាធុដូច្នេះហើយ គប្បីនមស្ការប្រណម្យអញ្ជលី ហើយ
ចូលទៅអង្គុយជិត ។ តថាគតពោលថា នេវសញ្ញានាសញ្ញាយតនសញ្ញា
តែងរលត់ទៅក្នុងទីណា មួយទៀត ពួកជនណា បានរម្ងត់អស់ហើយនូវ
នេវសញ្ញានាសញ្ញាយតនសញ្ញា អ្នកដ៏មានអាយុទាំងនោះ ឈ្មោះថា អ្នកមិន
មានសេចក្តីស្រេកឃ្លាន អ្នករម្ងត់ទុក្ខ បានឆ្លងនូវកាមទាំងឡាយហើយ បាន
ដល់នូវត្រើយ ដោយអង្គនៃឈាននោះ ដោយពិត ។ ( បើ ) បុគ្គលណា
ពោលយ៉ាងនេះថា នេវសញ្ញានាសញ្ញាយតនសញ្ញា តែងរលត់ទៅក្នុងទីដូច
ម្តេច មួយទៀត ពួកជនដូចម្តេច ដែលរម្ងត់អស់ហើយនូវនេវសញ្ញានា-
សញ្ញាយតនសញ្ញា ខ្ញុំមិនស្គាល់នូវហេតុនុ៎ះ ខ្ញុំមិនឃើញនូវហេតុនុ៎ះទេ បុគ្គល
នោះ អ្នកទាំងឡាយគួរប្រាប់យ៉ាងនេះទៅវិញថា ម្នាលអាវុសោ ភិក្ខុក្នុង
សាសនានេះ ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំង
ពួង បានដល់នូវសញ្ញាវេទយិតនិរោធ នេវសញ្ញានាសញ្ញាយតនសញ្ញា តែង
រលត់ទៅក្នុងសញ្ញាវេទយិតនិរោធនុ៎ះ ជនទាំងនោះ ឈ្មោះថា បានរម្ងត់អស់

ហើយនូវនេវសញ្ញានាសញ្ញាយតនសញ្ញា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកមិនអួតអាង មិនមានមាយា គប្បីត្រេកអរ គប្បីអនុមោទនានូវភាសិតថា សាធុដូច្នេះ ដោយពិត លុះត្រេកអរ អនុមោទនានូវភាសិតថា សាធុដូច្នេះហើយ គប្បីនមស្ការប្រណម្យអញ្ជលីហើយចូល ទៅអង្គុយជិត ។ ម្នាលភិក្ខុទាំងឡាយ អនុបុព្វវិហារសមាបត្តិ មាន ៩ យ៉ាងនេះឯង ។

# អដ្ឋកថា

## ទុតិយវិហារសូត្រ

[ ៣៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយវិហារសូត្រទី ២ ដូចតទៅនេះ បទថា **យត្ថ កាមា និរុជ្ឈន្តិ** បានដល់ កាមទាំងឡាយ រមែងស្ងប់ទៅក្នុងទីណា ។ បទថា **និរោធេត្វា** បានដល់ មិនត្រឡប់មកទៀតឡើយ ។ បទថា **និច្ឆាតា** បានដល់ អស់នូវការចង់បាន ព្រោះមិនមានការចង់បានគឺតណ្ហា និងទិដ្ឋិតទៅទៀត ។ បទថា **និព្វុតា** សេចក្តីថា រលត់ឥតសេសសល់ហើយ ព្រោះមិនមានកិលេសជាគ្រឿងធ្វើឲ្យក្តៅខាងក្នុង ។ បទថា **តិណ្ណា** បានដល់ ឆ្លងផុតកាមទាំងឡាយហើយ ។ បទថា **ចារគតា** បានដល់ ទៅហួសច្រាំងនៃកាម ។ បទថា **តទង្គេន** បានដល់ ដោយអង្គឈាននោះ ។ បទថា **ឯត្ថ កាមា និរុជ្ឈន្តិ** បានដល់ កាមទាំងឡាយរមែងរលត់

ក្នុងបឋមជ្ឈានទេះ ។ បទថា **តេ ច** បានដល់ បុគ្គលណាចូលដល់ បឋមជ្ឈាន បុគ្គលនោះ ឈ្មោះថា វមុត្តកាម ។ បទថា **បញ្ជលិកោ** បាន ដល់ ផ្គងនូវអញ្ជលី ។ បទថា **បយិរុបាសេយ្យ** ប្រែថា គប្បីចូលទៅរក ។ គប្បីជ្រាបអត្ថក្នុងបទទាំងពួង ដោយទំនងនេះឯង ។៚

**អដ្ឋកថា ទុតិយវិហារសូត្រទី ២ ចប់**

# សុត្តន្តបិដក

## និព្វានសូត្រទី ៣

[ ៣៤ ] សម័យមួយ ព្រះសារីបុត្តដ៏មានអាយុ គង់ក្នុងវត្តវេឡុវ័ន ជា កលន្ទកនិវាបស្ថាន ក្បែរក្រុងរាជគ្រឹះ ។ ក្នុងទីនោះឯង ព្រះសារីបុត្តដ៏មាន អាយុ ហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោទាំងឡាយ និព្វាននេះជាសុខ ម្នាលអាវុសោទាំងឡាយ និព្វាននេះជាសុខ ។ កាលបើព្រះសារីបុត្តពោល យ៉ាងនេះហើយ ព្រះឧទាយិដ៏មានអាយុ ក៏បានពោលទៅនឹងព្រះសារីបុត្តដ៏ មានអាយុដូច្នេះថា ម្នាលអាវុសោសារីបុត្ត ការដឹងណា ក្នុងព្រះនិព្វានទុំះ មិនមានទេ ចុះសុខក្នុងព្រះនិព្វានទុំះ តើដូចម្តេច ។ ម្នាលអាវុសោ ការដឹង ណា ក្នុងព្រះនិព្វានទុំះ មិនមានទេ ហ្នឹងហើយជាសុខក្នុងព្រះនិព្វានទុំះឯង ។

ម្នាលអាវុសោ កាមគុណទាំងឡាយនេះ មាន ៥ យ៉ាង ។ កាមគុណ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺរូបដែលគប្បីដឹងដោយភ្នែកជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាម ជាទីរីករាយ សំឡេងដែលគប្បីដឹងដោយត្រចៀក ។បេ។ ក្លិនដែលគប្បីដឹងដោយច្រមុះ រស ដែលគប្បីដឹងដោយអណ្តាត ផោដ្ឋព្វៈដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាម ជាទីរីករាយ ។ ម្នាលអាវុសោ កាមគុណមាន ៥ យ៉ាងនេះឯង ។ ម្នាល អាវុសោ សុខ និងសោមនស្សណា កើតឡើង ព្រោះអាស្រ័យនូវកាមគុណ ៥ យ៉ាងនេះ ម្នាលអាវុសោ នេះហៅថា កាមសុខ ។ ម្នាលអាវុសោ ភិក្ខុ ក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ម្នាល អាវុសោ កាលបើភិក្ខុនោះ កំពុងនៅដោយវិហារធម៌នេះហើយ សញ្ញាមនសិការ ( ការធ្វើទុកក្នុងចិត្តនូវសញ្ញា ) ប្រកបដោយកាម ក៏ច្រួលច្រាល់ ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ។ ម្នាលអាវុសោ ដូចសេចក្តីទុក្ខ គប្បី កើតឡើង ដល់បុគ្គលដែលមានសេចក្តីសុខ ជាហេតុឲ្យកើតអាពាធជា កំណត់ យ៉ាងណាមិញ សញ្ញាមនសិការ ប្រកបដោយកាមទាំងនោះ របស់ ភិក្ខុនោះ ច្រួលច្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោ អាពាធណាដែលកើតឡើងហើយ អាពាធនុ៎ះ ព្រះដ៏មានព្រះ ភាគ ទ្រង់ពោលថាជាទុក្ខ ។ ម្នាលអាវុសោ ព្រះនិព្វាន ដែលមានសេចក្តី

សុខយ៉ាងណានុ៎ះ គប្បីដឹងដោយបរិយាយនេះចុះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុព្រោះរម្ងាប់នូវវិតក្ក និងវិចារៈទាំងឡាយ ។បេ។ បានដល់ទុតិយជ្ឈាន ម្នាលអាវុសោ កាលបើភិក្ខុនោះ កំពុងនៅដោយវិហារធម៌នេះហើយ សញ្ញាមនសិការ ដែលប្រកបដោយវិតក្ក ក៏ប្រួលប្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ។ ម្នាលអាវុសោ ដូចសេចក្ដីទុក្ខ គប្បីកើតឡើងដល់បុគ្គលដែលមានសេចក្ដីសុខ ជាហេតុឲ្យកើតអាពាធជាកំណត់ យ៉ាងណាមិញ សញ្ញាមនសិការដែលប្រកបដោយវិតក្កទាំងនោះ របស់ភិក្ខុនោះ ប្រួលប្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោ អាពាធណាដែលកើតឡើងហើយ អាពាធនុ៎ះ ព្រះដ៏មានព្រះភាគទ្រង់ពោលថាជាទុក្ខ ។ ម្នាលអាវុសោ ព្រះនិព្វានដែលមានសេចក្ដីសុខយ៉ាងណានុ៎ះ គប្បីដឹងដោយបរិយាយនេះចុះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុព្រោះនឿយណាយចាកបីតីផង ។បេ។ បានដល់តតិយជ្ឈាន ម្នាលអាវុសោ កាលបើភិក្ខុនោះ កំពុងនៅដោយវិហារធម៌នេះហើយ សញ្ញាមនសិការ ដែលប្រកបដោយបីតិ ក៏ប្រួលប្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ។ ម្នាលអាវុសោ ដូចសេចក្ដីទុក្ខ គប្បីកើតឡើងដល់បុគ្គលដែលមានសេចក្ដីសុខជាហេតុ ឲ្យកើតអាពាធជាកំណត់ យ៉ាងណាមិញ សញ្ញាមនសិការ ដែលប្រកបដោយបីតិទាំងនោះ របស់ភិក្ខុនោះ ប្រួលប្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោ អាពាធណាដែលកើត

ឡើងហើយ អាពាធនុ៎ះព្រះដ៏មានព្រះភាគ ទ្រង់ពោលថាជាទុក្ខ ។ ម្នាល អាវុសោ ព្រះនិព្វានដែលមានសេចក្តីសុខយ៉ាងណានុ៎ះ គប្បីដឹងដោយបរិយាយនេះចុះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុព្រោះលះបង់នូវសុខផង ។បេ។ បានដល់ចតុត្ថជ្ឈាន ម្នាលអាវុសោ កាលបើភិក្ខុនោះ កំពុងនៅដោយវិហារធម៌នេះហើយ សញ្ញាមនសិការ ដែលប្រកបដោយឧបេក្ខា ក៏ច្រួលច្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ។ ម្នាលអាវុសោ ដូចសេចក្តីទុក្ខ គប្បីកើតឡើងដល់បុគ្គល ដែលមានសេចក្តីសុខជាហេតុឲ្យកើតអាពាធជាកំណត់ យ៉ាងណាមិញ សញ្ញាមនសិការដែលប្រកបដោយឧបេក្ខាទាំងនោះរបស់ភិក្ខុនោះ ច្រួលច្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោ អាពាធណាដែលកើតឡើងហើយ អាពាធនុ៎ះព្រះដ៏មានព្រះភាគទ្រង់ពោលថាជាទុក្ខ ។ ម្នាលអាវុសោ ព្រះនិព្វានដែលមានសេចក្តីសុខយ៉ាងណានុ៎ះ គប្បីដឹងដោយបរិយាយនេះចុះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុព្រោះកន្លងនូវរូបសញ្ញាដោយប្រការទាំងពួង ព្រោះវិនាសទៅនៃបដិឃសញ្ញា ព្រោះមិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ហើយបានដល់នូវអាកាសានញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ ម្នាលអាវុសោ កាលបើភិក្ខុនោះ កំពុងនៅដោយវិហារធម៌នេះហើយ សញ្ញាមនសិការ ដែលប្រកបដោយរូប ក៏ច្រួលច្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ។ ម្នាលអាវុសោ ដូចសេចក្តីទុក គប្បីកើតឡើង ដល់បុគ្គល

ដែលមានសេចក្ដីសុខ ជាហេតុឲ្យកើតអាពាធ យ៉ាងណាមិញ សញ្ញាមនសិការដែលប្រកបដោយរូបទាំងនោះ របស់ភិក្ខុនោះ ប្រួលប្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោ អាពាធណាដែលកើតឡើងហើយ អាពាធនុ៎ះ ព្រះដ៏មានព្រះភាគ ទ្រង់ពោលថាជាទុក្ខ ។ ម្នាលអាវុសោ ព្រះនិព្វានដែលមានសេចក្ដីសុខយ៉ាងណានុ៎ះ គប្បីដឹងដោយបរិយាយនេះចុះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុព្រោះកន្លងបង់នូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួងហើយ បានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុត ដូច្នេះ ម្នាលអាវុសោ កាលបើភិក្ខុនោះ កំពុងនៅដោយវិហារធម៌នេះហើយ សញ្ញាមនសិការ ដែលប្រកបដោយអាកាសានញ្ចាយតនជ្ឈាន ក៏ប្រួលប្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ។ ម្នាលអាវុសោ ដូចសេចក្ដីទុក្ខ គប្បីកើតឡើងដល់បុគ្គល ដែលមានសេចក្ដីសុខជាហេតុ ឲ្យកើតអាពាធជាកំណត់ យ៉ាងណាមិញ សញ្ញាមនសិការ ដែលប្រកបដោយអាកាសានញ្ចាយតនជ្ឈានទាំងនោះ របស់ភិក្ខុនោះ ប្រួលប្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោ អាពាធណា ដែលកើតឡើងហើយ អាពាធនុ៎ះ ព្រះដ៏មានព្រះភាគ ទ្រង់ពោលថាជាទុក្ខ ។ ម្នាលអាវុសោ ព្រះនិព្វានដែលមានសេចក្ដីសុខយ៉ាងណានុ៎ះ គប្បីដឹងដោយបរិយាយនេះចុះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុព្រោះកន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយ

ប្រការទាំងពួង ហើយបានដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្ត ថា របស់បន្តិចបន្តួចមិនមានដូច្នេះ ម្នាលអាវុសោ កាលបើភិក្ខុនោះ កំពុងនៅដោយវិហារធម៌នេះហើយ សញ្ញាមនសិការដែលប្រកបដោយវិញ្ញាណញ្ចា-យតនជ្ឈាន ក៏ច្រួលច្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ។ ម្នាលអាវុសោ ដូចសេចក្តីទុក្ខ គប្បីកើតឡើងដល់បុគ្គល ដែលមានសេចក្តីសុខជាហេតុ ឲ្យកើតអាពាធជាកំណត់ យ៉ាងណាមិញ សញ្ញាមនសិការដែលប្រកបដោយវិញ្ញាណញ្ចាយតនជ្ឈានទាំងនោះ របស់ភិក្ខុនោះ ច្រួលច្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ យ៉ាងនោះដែរ ។ ម្នាលអាវុសោ អាពាធណាដែលកើតឡើងហើយ អាពាធនុ៎ះ ព្រះដ៏មានព្រះភាគ ទ្រង់ពោលថាជាទុក្ខ ។ ម្នាលអាវុសោ ព្រះនិព្វានដែលមានសេចក្តីសុខយ៉ាងណានុ៎ះ គប្បីដឹងដោយបរិយាយនេះចុះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុព្រោះកន្លងបង់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់នេវសញ្ញា-នាសញ្ញាយតនជ្ឈាន ម្នាលអាវុសោ កាលបើភិក្ខុនោះ កំពុងនៅដោយវិហារធម៌នេះហើយ សញ្ញាមនសិការដែលប្រកបដោយអាកិញ្ចញ្ញាយតនជ្ឈាន ច្រួលច្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ។ ម្នាលអាវុសោ ដូចសេចក្តីទុក្ខ គប្បីកើតឡើងដល់បុគ្គល ដែលមានសេចក្តីសុខជាហេតុឲ្យកើតអាពាធជាកំណត់ យ៉ាងណាមិញ សញ្ញាមនសិការដែលប្រកបដោយអាកិញ្ចញ្ញាយត-នជ្ឈានទាំងនោះ របស់ភិក្ខុនោះ ច្រួលច្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុ

នោះ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោ អាពាធណា ដែលកើតឡើងហើយ អាពាធនុ៎ះ ព្រះដ៏មានព្រះភាគ ទ្រង់ពោលថាជាទុក្ខ ។ ម្នាលអាវុសោ ព្រះនិព្វានដែលមានសេចក្តីសុខយ៉ាងណានុ៎ះ គប្បីដឹងដោយបរិយាយនេះចុះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុព្រោះកន្លងបង់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់សញ្ញាវេទយិតនិរោធ អាសវៈទាំងឡាយរបស់ភិក្ខុនោះ ក៏អស់រលីងទៅ ព្រោះបានឃើញដោយបញ្ញា ។ ម្នាលអាវុសោ ព្រះនិព្វានដែលមានសេចក្តីសុខយ៉ាងណានុ៎ះ គប្បីដឹងដោយបរិយាយនេះចុះ ។

# អដ្ឋកថា

## និព្វានសូត្រ

[ ៣៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិព្វានសូត្រទី ៣ ដូចតទៅនេះ បទថា **ឧទាយិ** បានដល់ ព្រះលោឡុទាយិត្ថេរ ។ បទថា **ឯត្ថេវ ខ្វេត្ថ** កាត់បទជា **ឯត្ថេវ ខោ ឯត្ថ** បានដល់ មិនមានសេចក្តីសុខនោះឯង ក្នុងទីនេះ ។ បទថា **កាមសហគតា** គឺអាស្រ័យកាម ។ បទថា **សមុទាចរន្តិ** បានដល់ ត្រាច់ទៅក្នុងមនោទ្វារ ។ បទថា **អាពាធាយ** បានដល់ ដើម្បីបៀតបៀន គឺដើម្បីធ្វើឲ្យលំបាក ។ បទថា បរិយាយេន ប្រែថា ដោយហេតុ ។ គប្បី

ជ្រាបអត្ថក្នុងវារៈទាំងអស់យ៉ាងនេះ ។ ក្នុងសូត្រនេះ ព្រះសារីបុត្រពោលដល់អវេទយិតសុខ ។ល។

## អដ្ឋកថា និព្វានសូត្រទី ៣ ចប់

# សុត្តន្តបិដក

## គាវីសូត្រទី ៤

[ ៣៥ ] ម្នាលភិក្ខុទាំងឡាយ ដូចមេគោ ដើរទៅកាន់ភ្នំ ជាសត្វល្ងង់ មិនឈ្លាសវៃ មិនស្គាល់ខេត្ត មិនប្រសប់ ត្រាច់ទៅលើភ្នំដែលមិនស្មើ មេគោនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នេះ គួរតែអាត្មាអញ ទៅកាន់ទិសដែលអញមិនធ្លាប់ទៅផង ទំពាស៊ីនូវស្មៅដែលអញមិនធ្លាប់ទំពាស៊ីផង ផឹកទឹកដែលអញមិនធ្លាប់ផឹកផង ។ មេគោនោះ មិនទាន់ឈរជើងមុខឲ្យស៊ប់ស្រួល ហើយលើកនូវជើងខាងក្រោយឡើង មេគោនោះ មិនគប្បីទៅកាន់ទិស ដែលខ្លួនមិនធ្លាប់ទៅបានផង មិនគប្បីទំពាស៊ីនូវស្មៅដែលខ្លួនមិនធ្លាប់ទំពាស៊ីបានផង មិនគប្បីផឹកទឹកដែលខ្លួនមិនធ្លាប់ផឹកបានផង មេគោនោះឈរក្នុងប្រទេសណា តែងមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញទៅកាន់ទិសដែលអញមិនធ្លាប់ទៅផង ទំពាស៊ីនូវស្មៅដែលអញមិនធ្លាប់ទំពា

ស៊ីផង ផឹកទឹកដែលអញមិនធ្លាប់ផឹកផង ។ មេគោនោះ មិនគប្បីត្រឡប់មក កាន់ប្រទេសនោះ ដោយសួស្តីបានវិញទេ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះតែមេគោនោះ ត្រាច់ទៅកាន់ភ្នំ ជាសត្វល្ងង់ មិនឈ្លាសវៃ មិនស្គាល់ខេត្ត មិនប្រសប់ ត្រាច់ទៅលើភ្នំដែលមិនស្មើ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុខ្លះ ក្នុងសាសនានេះ ជាអ្នកល្ងង់ មិនឈ្លាសវៃ មិនស្គាល់ខេត្ត មិនប្រសប់ ក្នុងការស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយហើយ ដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កៈ និងវិចារៈ មានបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងាត់ ក៏យ៉ាងនោះដែរ ។ ភិក្ខុនោះ មិនសេព មិនចម្រើន មិនធ្វើឲ្យរឿយៗ នូវនិមិត្តនោះ មិនតាំងទុកនូវនិមិត្ត ដែលខ្លួនតាំងទុកល្អហើយ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ រម្ងាប់វិតក្កៈ និងវិចារៈ រួចហើយ ចូលកាន់ទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លា គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈឡើយ មានតែបីតិ និងសុខ ដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ។ ភិក្ខុនោះ មិនអាច ដើម្បីរម្ងាប់វិតក្កវិចារៈ ។បេ។ បានដល់ទុតិយជ្ឈាន ។ ភិក្ខុនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ ស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ហើយ ដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កៈ និងវិចារៈ មានតែបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងាត់ ។ ភិក្ខុនោះ មិន

អាចស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈានហើយ ។ ម្នាល ភិក្ខុទាំងឡាយ ភិក្ខុនេះ ហៅថា ជាអ្នកដឹងផង ជាអ្នកអង់អាចផង ជាអ្នក សាបសូន្យចាកកាម និងអកុសលធម៌ទាំង ២ ផង ដូចជាមេគោនោះ ត្រាច់ ទៅកាន់ភ្នំ ជាសត្វល្ងង់ មិនឈ្លាសវៃ មិនស្គាល់ខេត្ត មិនប្រសប់ ត្រាច់ទៅ លើភ្នំ ដែលមិនស្មើ ។ ម្នាលភិក្ខុទាំងឡាយ ដូចមេគោត្រាច់ទៅលើភ្នំ ជា សត្វមានបញ្ញាឈ្លាសវៃ ស្គាល់នូវខេត្ត ប្រសប់ ត្រាច់ទៅលើភ្នំ ដែលមិន ស្មើ មេគោនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ ទៅកាន់ទិស ដែលអញមិនធ្លាប់ទៅផង ទំពាស៊ីនូវស្មៅ ដែលអញមិនធ្លាប់ ទំពាស៊ីផង ផឹកទឹកដែលអញមិនធ្លាប់ផឹកផង ។ មេគោនោះ ឈរជើងមុខ ឲ្យស៊ប់ល្អហើយ លើកជើងខាងក្រោយឡើង មេគោនោះ ទើបគប្បីទៅកាន់ ទិស ដែលខ្លួនមិនធ្លាប់ទៅបានផង ទំពាស៊ីនូវស្មៅ ដែលខ្លួនមិនធ្លាប់ទំពាស៊ី បានផង ផឹកទឹកដែលខ្លួនមិនធ្លាប់ផឹកបានផង កាលបើមេគោនោះ ឈរក្នុង ប្រទេសណា មេគោនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែ អាត្មាអញ ទៅកាន់ទិសដែលអញមិនធ្លាប់ទៅផង ទំពាស៊ីស្មៅដែលអញ មិនធ្លាប់ទំពាស៊ីផង ផឹកទឹកដែលអញ មិនធ្លាប់ផឹកផង ។ មេគោនោះ គប្បី ត្រឡប់មកកាន់ប្រទេសនោះវិញ ដោយសួស្ដី ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា មេគោនោះ ត្រាច់ទៅកាន់ភ្នំ ជាសត្វមាន បញ្ញាឈ្លាសវៃ ស្គាល់នូវខេត្ត ប្រសប់ ត្រាច់ទៅលើភ្នំដែលមិនស្មើ យ៉ាង

ណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុខ្លះក្នុងសាសនានេះ ជាអ្នកមានបញ្ញា ឈ្លាសវៃ ស្គាល់នូវខេត្ត ជាអ្នកប្រសប់ក្នុងការស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយបានដល់បឋមជ្ឈាន ប្រកបដោយវិតក្ក និងវិចារៈ មានតែបីតិ និងសុខ ដែលកើតអំពីសេចក្ដីស្ងាត់ ក៏យ៉ាងនោះដែរ ។ ភិក្ខុនោះខំសេព ខំចម្រើន ខំធ្វើឲ្យរឿយៗ នូវនិមិត្តនោះ បានតាំងទុកនូវនិមិត្ត ដែលខ្លួនតាំងទុកល្អហើយ ភិក្ខុនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ រម្ងាប់វិតក្ក និងវិចារៈ ហើយដល់នូវទុតិយជ្ឈាន ជាធម្មជាតកើតមាន ក្នុងសន្ដានខ្លួន ប្រកបដោយសេចក្ដីជ្រះថ្លា គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្ក មិនមានវិចារៈ មានតែបីតិ និងសុខ ដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ។ ភិក្ខុនោះមិនបានសម្រេចទុតិយជ្ឈាន ក៏រម្ងាប់នូវវិតក្ក និងវិចារៈ ។បេ។ បានដល់ទុតិយជ្ឈាន ។ ភិក្ខុនោះ ខំសេព ខំចម្រើន ខំធ្វើឲ្យរឿយៗ នូវនិមិត្តនោះ បានតាំងទុកនូវនិមិត្ត ដែលខ្លួនតាំងទុកល្អហើយ ភិក្ខុនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ នឿយណាយចាកបីតិ ជាអ្នកប្រកបដោយឧបេក្ខាផង មានសតិ និងសម្បជញ្ញៈផង សោយនូវសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយ តែងសរសើរបុគ្គលដែលបាននូវតតិយជ្ឈាននោះថា បុគ្គលប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខ ដូច្នេះ ព្រោះតតិយជ្ឈានណា ក៏គួរដល់នូវតតិយជ្ឈាននោះ ។ ភិក្ខុនោះ មិនបានសម្រេចនូវ

តតិយជ្ឈាន ព្រោះនឿយណាយចាកបីតិ ។បេ។ បានដល់នូវតតិយជ្ឈាន ។ ភិក្ខុនោះ ខំសេព ខំចម្រើន ខំធ្វើឲ្យរឿយៗ នូវនិមិត្តនោះ បានតាំងទុកនូវនិមិត្ត ដែលខ្ជួនតាំងទុកល្អហើយ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ លះបង់នូវសុខផង លះបង់នូវទុក្ខផង មានសោមនស្ស និងទោមនស្សអស់ហើយ ក្នុងកាលមុនផង ហើយគួរដល់នូវចតុត្ថជ្ឈាន ជាធម្មជាតមានអារម្មណ៍មិនជាទុក្ខ មិនជាសុខ មានតែសតិដ៏បរិសុទ្ធ កើតអំពីឧបេក្ខា ។ ភិក្ខុនោះ មិនបានសម្រេចចតុត្ថជ្ឈាន ព្រោះលះបង់នូវសុខផង ។បេ។ បានដល់នូវចតុត្ថជ្ឈាន ។ ភិក្ខុនោះ ខំសេព ខំចម្រើន ខំធ្វើឲ្យរឿយៗ នូវនិមិត្តនោះ បានតាំងទុកនូវនិមិត្ត ដែលខ្ជួនតាំងទុកល្អហើយ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ កន្លងនូវរូបសញ្ញា ដោយប្រការទាំងពួង អស់ទៅនៃបដិឃសញ្ញា លែងធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ហើយគួរដល់អាកាសានញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុត ដូច្នេះ ។ ភិក្ខុនោះ មិនបានសម្រេចអាកាសានញ្ចាយតនជ្ឈាន ព្រោះកន្លងនូវរូបសញ្ញា ដោយប្រការទាំងពួង ។បេ។ បានដល់អាកាសានញ្ចាយតនជ្ឈាន ។ ភិក្ខុនោះ ខំសេព ខំចម្រើន ខំធ្វើឲ្យរឿយៗ នូវនិមិត្តនោះ បានតាំងទុកនូវនិមិត្ត ដែលខ្ជួនតាំងទុកល្អហើយ ភិក្ខុនោះមាន សេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ កន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយដល់នូវវិញ្ញាណញ្ចាយត-

នជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុតដូច្នេះ ។ ភិក្ខុនោះ មិនបានសម្រេចវិញ្ញាណញ្ចាយតនជ្ឈាន ព្រោះកន្លងនូវអាកាសានញ្ចាយត-នជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុតដូច្នេះ ។ ភិក្ខុនោះ ខំសេព ខំចម្រើន ខំធ្វើឲ្យរឿយៗ នូវនិមិត្តនោះ បានតាំងទុកនូវនិមិត្ត ដែលខ្លួនតាំងទុកល្អហើយ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ កន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វត្ថុតិចតួចមិនមានដូច្នេះ ។ ភិក្ខុនោះមិនបានសម្រេចអាកិញ្ចញ្ញាយតនជ្ឈាន ហើយកន្លងនូវវិញ្ញាណញ្ចា-យតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វត្ថុតិចតួចមិនមានដូច្នេះ ។ ភិក្ខុនោះ ខំសេព ខំចម្រើន ខំធ្វើឲ្យរឿយៗ នូវនិមិត្តនោះ បានតាំងទុកនូវនិមិត្ត ដែលខ្លួនតាំងទុកល្អហើយ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ កន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយដល់នូវនេវ-សញ្ញានាសញ្ញាយតនជ្ឈាន ។ ភិក្ខុនោះ មិនបានសម្រេចនូវនេវសញ្ញានា-សញ្ញាយតនជ្ឈាន ហើយកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយដល់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ។ ភិក្ខុនោះ ខំសេព ខំចម្រើន ខំធ្វើឲ្យរឿយៗ នូវនិមិត្តនោះ បានតាំងទុកនូវនិមិត្ត ដែលខ្លួនតាំងទុក

ល្អហើយ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ កន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយដល់នូវសញ្ញាវេទយិតនិរោធ ។ ភិក្ខុនោះមិនបានសម្រេចសញ្ញាវេទយិតនិរោធ ក៏កន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយដល់នូវសញ្ញាវេទយិតនិរោធ ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើភិក្ខុ ចូលកាន់សមាបត្តិនោះៗ ក្តី ចេញចាកសមាបត្តិនោះៗ ក្តី ចិត្តរបស់ភិក្ខុនោះ ក៏ទន់គួរដល់ការនាកម្ម សមាធិដែលមានប្រមាណមិនបានដោយចិត្ត ក៏ទន់គួរដល់ការនាកម្ម ឈ្មោះថា ភិក្ខុនោះ បានចម្រើនហើយដោយប្រពៃ ភិក្ខុនោះ ក៏បង្អោនចិត្តទៅចំពោះធម៌ណាដែលគប្បីធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តម ដោយសមាធិដែលមានប្រមាណមិនបាន ដែលខ្លួនបានចម្រើនដោយប្រពៃ ដើម្បីធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម កាលបើហេតុមានហើយ ភិក្ខុនោះក៏ដល់នូវភាវៈដែលគួរជាក់ច្បាស់ក្នុងធម៌នោះៗ បាន ។ បើភិក្ខុនោះ ប្រាថ្នាថា អាត្មាអញគប្បីសម្តែងនូវតាក់តែងឫទ្ធិ បានច្រើនប្រការ គឺអាត្មាអញតែម្នាក់ ធ្វើឲ្យទៅជាច្រើននាក់ក៏បាន ឬអាត្មាអញច្រើននាក់ ធ្វើឲ្យទៅជាម្នាក់វិញក៏បាន ។បេ។ អាត្មាអញធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយដរាបដល់ព្រហ្ម-លោកក៏បាន កាលបើហេតុមានហើយ ភិក្ខុនោះក៏ដល់នូវភាវៈដែលគួរជាក់ច្បាស់ក្នុងធម៌នោះៗ ។ បើភិក្ខុនោះ ប្រាថ្នាដោយសោតធាតុជាទិព្វ ។បេ។ កាលបើហេតុមានហើយ ។ បើភិក្ខុនោះប្រាថ្នាថា អាត្មាអញគប្បីកំណត់ដឹង

ចិត្តរបស់សត្វដទៃ របស់បុគ្គលដទៃ ដោយចិត្តរបស់ខ្លួន គឺចិត្តដែលប្រកប ដោយរាគៈក្តី អាត្មាអញក៏ស្គាល់ថា ចិត្តប្រកបដោយរាគៈ ចិត្តដែលប្រាស ចាករាគៈក្តី ក៏ស្គាល់ថា ចិត្តប្រាសចាករាគៈ ចិត្តដែលប្រកបដោយទោសៈក្តី ក៏ស្គាល់ថា ចិត្តប្រកបដោយទោសៈ ចិត្តដែលប្រាសចាកទោសៈក្តី ក៏ស្គាល់ ថា ចិត្តប្រាសចាកទោសៈ ចិត្តដែលប្រកបដោយមោហៈក្តី ក៏ស្គាល់ថា ចិត្ត ប្រកបដោយមោហៈ ចិត្តដែលប្រាសចាកមោហៈក្តី ក៏ស្គាល់ថា ចិត្តប្រាស ចាកមោហៈ ចិត្តដែលរួញរាក្តី ចិត្តដែលរាយមាយក្តី ចិត្តដែលជាមហគ្គតៈ គឺរូបាវចរ និងអរូបាវចរក្តី ចិត្តដែលមិនមែនជាមហគ្គតៈក្តី ចិត្តដែលជា សឧត្តរៈ គឺចិត្តដែលមានចិត្តដទៃក្រៃលែងជាងក្តី ចិត្តដែលជាអនុត្តរៈ គឺចិត្ត ដែលមិនមានចិត្តដទៃក្រៃលែងជាងក្តី ចិត្តដែលមិនតាំងមាំក្តី ចិត្តដែលតាំង មាំក្តី ចិត្តដែលផុតស្រឡះក្តី ចិត្តដែលមិនផុតស្រឡះក្តី ក៏ស្គាល់ថា ចិត្តមិន ទាន់ផុតស្រឡះ កាលបើហេតុមានហើយ ភិក្ខុនោះ ក៏ដល់នូវភាវៈដែលគួរ ជាក់ច្បាស់ក្នុងធម៌នោះៗ ។ បើភិក្ខុនោះប្រាថ្នាថា អាត្មាអញគប្បីរឭកឃើញ នូវបុព្វេនិវាស មានប្រការដ៏ច្រើន គឺរឭកឃើញ ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ អាត្មាអញគប្បីរឭកឃើញនូវបុព្វេនិវាស មានប្រការដ៏ច្រើន ព្រម ទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ កាលបើហេតុមានហើយ ភិក្ខុនោះក៏ដល់នូវភាវៈដែលគួរជាក់ច្បាស់ក្នុងធម៌នោះៗ ។ បើភិក្ខុនោះ ប្រាថ្នា ថា អាត្មាអញ មានចក្ខុជាទិព្វដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុរបស់មនុស្សធម្មតា

។បេ។ អាត្មាអញ ក៏ដឹងច្បាស់នូវពួកសត្វដែលអន្ទោលទៅតាមកម្ម ( របស់ខ្លួន ) កាលបើហេតុមានហើយ ភិក្ខុនោះ ក៏ដល់នូវភាវៈដែលគួរជាក់ច្បាស់ក្នុងធម៌នោះៗ ។ បើភិក្ខុនោះប្រាថ្នាថា អាត្មាអញគប្បីធ្វើឲ្យជាក់ច្បាស់ បានដល់ ។បេ។ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ កាលបើហេតុមានហើយ ភិក្ខុនោះ ក៏ដល់នូវភាវៈដែលគួរជាក់ច្បាស់ក្នុងធម៌នោះៗ ។

# អដ្ឋកថា

## គាវីសូត្រ

[ ៣៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងគាវីសូត្រទី ៤ ដូចតទៅនេះ បទថា **បព្វតេយ្យា** បានដល់ មេគោរមែងត្រាច់ទៅលើភ្នំ ។ បទថា **ន សុប្បតិដ្ឋិតំ បតិដ្ឋាបេត្វា** បានដល់ មិនដាក់ជើងមុខឲ្យស៊ប់ល្អ ។ បទថា **តំ និមិត្តំ** បានដល់ និមិត្ត ពោល គឺបឋមជ្ឈាននោះ ។ បទថា **ន ស្វាធិដ្ឋិតំ អធិដ្ឋាតិ** បានដល់ មិនអធិដ្ឋានចិត្តដោយល្អ ។ បទថា **អនភិហិសមាធោ** បានដល់ ឲ្យសម្រេច ។ បទថា **មុទុ ចិត្តំ ហោតិ កម្មនិយំ** សេចក្តីថា វិបស្សនាចិត្តទន់ក្នុងខណៈនៃលោកុត្តរមគ្គ ជាចិត្តអត់ធន់ចំពោះការងារ គឺគួរប្រកបការងារ យ៉ាងណា ចិត្តក្នុងចតុត្ថជ្ឈាន មានអភិញ្ញាជាបាទនៃភិក្ខុនោះ រមែងជាចិត្តទន់ គួរដល់ការងារ ដូច្នោះ ។ បទថា **អប្បមាណោ សមាធិ** សេចក្តី

ថា សមាធិក្នុងព្រហ្មវិហារ ៤ ក្តី សមាធិក្នុងមគ្គផលក្តី ឈ្មោះថា សមាធិមិនមានប្រមាណ តែក្នុងសូត្រនេះ សំដៅដល់អារម្មណ៍ដែលមិនមានប្រមាណ ព្រោះហេតុនោះ គប្បីឃើញថា សមាធិស្ទាត់ជំនាញដោយល្អ ដែលជាអប្បមាណសមាធិ ដោយបរិយាយនេះ ។ បទថា **សោ អប្បមាណេន សមាធិនា សុភាវិតេន** សេចក្តីថា ភិក្ខុនេះ ចម្រើនវិបស្សនាក្នុងឋានៈនេះហើយ ទើបសម្រេចអរហត្ត ។ ឥឡូវនេះ ព្រះមានព្រះភាគកាលទ្រង់សម្តែងលំដាប់នៃអភិញ្ញារបស់ព្រះខីណាស្រព ទើបត្រាស់ពាក្យជាដើមថា **យំ យស្សេវ** ដូច្នេះ ។ល។

**អដ្ឋកថា គាវីសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## ឈានសូត្រទី ៥

[ ៣៦ ] ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការអស់ទៅនៃអាសវៈ ព្រោះអាស្រ័យបឋមជ្ឈានខ្លះ ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការអស់ទៅនៃអាសវៈ ព្រោះអាស្រ័យទុតិយជ្ឈានខ្លះ ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការអស់ទៅនៃអាសវៈ ព្រោះអាស្រ័យតតិយជ្ឈានខ្លះ ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការអស់ទៅនៃអាសវៈ ព្រោះអាស្រ័យ

បតុត្ថជ្ឈានខ្លះ ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការអស់ទៅនៃអាសវៈ ព្រោះអាស្រ័យអាកាសានញ្ចាយតនជ្ឈានខ្លះ ។បេ។ ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការអស់ទៅនៃអាសវៈ ព្រោះអាស្រ័យនេវសញ្ញានាសញ្ញាយតនជ្ឈានខ្លះ ។

ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការអស់ទៅនៃអាសវៈ ព្រោះអាស្រ័យបឋមជ្ឈាន ព្រោះហេតុនោះ ពាក្យដែលតថាគតពោលហើយនុ៎ះ ពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យសេចក្តីដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ។ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណណាដែលប្រព្រឹត្តទៅក្នុងបឋមជ្ឈាននោះ ភិក្ខុនោះ ក៏រមែងពិចារណាឃើញច្បាស់នូវធម៌ គឺបញ្ចក្ខន្ធទាំងនោះថា ជារបស់មិនទៀង ជាទុក្ខ ជារោគ ជាពក ជាសរ ជាគ្រឿងបៀតបៀន ជាអាពាធ ជារបស់ដទៃ ជារបស់ទ្រុឌទ្រោម ជារបស់សូន្យ ជារបស់អនត្តា ។ ភិក្ខុនោះ ញុំាងចិត្តឲ្យតម្កល់នៅស៊ប់ដោយធម៌ទាំងនោះ លុះភិក្ខុនោះ ញុំាងចិត្តឲ្យតម្កល់នៅស៊ប់ដោយធម៌ទាំងនោះហើយ ក៏ប្រមូលមកនូវចិត្ត ទុកក្នុងអមតធាតុថា ការរម្ងាប់នូវសង្ខារទាំងពួង ការលះបង់នូវកិលេសទាំងពួង ការអស់ទៅនៃតណ្ហា សេចក្តីនឿយណាយ សេចក្តីរលត់តណ្ហា គឺព្រះនិព្វានណា ព្រះនិព្វាននុ៎ះជាទីស្ងប់ ព្រះនិព្វាននុ៎ះជារបស់ប្រសើរ ។ ភិក្ខុនោះ បានឋិតនៅក្នុងវិបស្សនា ដែលមានត្រៃលក្ខណ៍ជាអារម្មណ៍នោះ

ហើយ រមែងដល់នូវការអស់ទៅអាសវៈទាំងឡាយ បើមិនបានដល់នូវការអស់ទៅនៃអាសវៈទេ ក៏គង់បានទៅកើតជាឱបបាតិកកំណើត ព្រោះសេចក្តីត្រេកអរ ចំពោះសមថធម៌ និងវិបស្សនាធម៌នោះ ព្រោះសេចក្តីរីករាយចំពោះធម៌នោះ ព្រោះអស់ទៅនៃឱរម្ភាគិយសំយោជនៈ ៥ ហើយនឹងបរិនិព្វានក្នុងទីនោះ មិនត្រឡប់អំពីលោកនោះមកវិញឡើយ ម្នាលភិក្ខុទាំងឡាយ ដូចខ្មាន់ធ្នូក្តី កូនសិស្សរបស់ខ្មាន់ធ្នូក្តី ធ្វើនូវការប្រកបក្នុងរូបភាព បុរសជាវិការនៃស្មៅក្តី ក្នុងដុំដីស្អិតក្តី សម័យខាងក្រោយមក ខ្មាន់ធ្នូនោះ បាញ់បានឆ្ងាយផង បាញ់ត្រង់ផង អាចទម្លាយនូវកាយដ៏ធំផង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ក៏យ៉ាងនោះដែរ ។ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណណា ដែលប្រព្រឹត្តទៅក្នុងបឋមជ្ឈាននោះ ភិក្ខុនោះ រមែងពិចារណាឃើញច្បាស់នូវធម៌ គឺបញ្ចក្ខន្ធទាំងនោះថា ជារបស់មិនទៀង ជាទុក្ខ ជារោគ ជាពក ជាសរ ជាគ្រឿងបៀតបៀន ជាអាពាធ ជារបស់ដទៃ ជារបស់ទ្រុឌទ្រោម ជារបស់សូន្យ ជារបស់អនត្តា ។ ភិក្ខុនោះ ញុំាងចិត្តឲ្យតម្កល់នៅស៊ប់ដោយធម៌ទាំងនោះ លុះភិក្ខុនោះ ញុំាងចិត្តឲ្យតម្កល់នៅស៊ប់ ដោយធម៌ទាំងនោះហើយ ក៏ប្រមូលមកនូវចិត្ត ទុកក្នុងអមតធាតុថា ការរម្ងាប់បង់នូវសង្ខារទាំងពួង លះបង់នូវកិលេសទាំងពួង ការអស់ទៅនៃតណ្ហា សេចក្តីនឿយណាយ សេចក្តីរលត់តណ្ហា គឺព្រះនិព្វានណា ព្រះនិព្វាននុ៎ះជាទីស្ងប់ ព្រះនិព្វាននុ៎ះជារបស់

ប្រសើរ ។ ភិក្ខុនោះ បានឋិតនៅក្នុងវិបស្សនា ដែលមានត្រៃលក្ខណ៍ជាអារម្មណ៍នោះហើយ រមែងដល់នូវការអស់ទៅនៃអាសវៈទាំងឡាយ បើមិនបានដល់នូវការអស់ទៅអាសវៈទេ ក៏គង់បានទៅកើតជាឱបបាតិកកំណើត ព្រោះសេចក្តីត្រេកអរ ចំពោះធម៌នោះ ព្រោះសេចក្តីរីករាយ ចំពោះធម៌នោះ ព្រោះអស់ទៅនៃឱរម្ភាគិយសំយោជនៈ ៥ ហើយនឹងបរិនិព្វានក្នុងទីនោះ មិនត្រឡប់អំពីលោកនោះមកវិញឡើយ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យណាដែលតថាគតពោលថា តថាគត ពោលនូវការអស់ទៅនៃអាសវៈ ព្រោះអាស្រ័យបឋមជ្ឈាន ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យនូវហេតុនេះ ។ ម្នាលភិក្ខុទាំងឡាយ តថាគត ព្រោះអាស្រ័យនូវទុតិយជ្ឈាន ។បេ។ ម្នាលភិក្ខុទាំងឡាយ តថាគត ព្រោះអាស្រ័យនូវតតិយជ្ឈាន ។បេ។ ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការអស់ទៅនៃអាសវៈ ព្រោះអាស្រ័យនូវចតុត្ថជ្ឈាន ព្រោះហេតុនោះ ពាក្យដែលតថាគតពោលហើយនុ៎ះ ពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យនូវហេតុដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង មានសោមនស្ស និងទោមនស្សអស់ទៅ ក្នុងកាលមុន ហើយដល់នូវចតុត្ថជ្ឈាន ដែលជាធម្មជាតមានអារម្មណ៍ មិនមែនជាទុក្ខ មិនមែនជាសុខ គឺជាឧបេក្ខា មានសតិដ៏បរិសុទ្ធ ដោយឧបេក្ខា ។ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណណា ដែលប្រព្រឹត្តទៅក្នុងចតុត្ថជ្ឈាននោះ ភិក្ខុនោះ រមែងពិចារណាឃើញច្បាស់

នូវធម៌ គឺបញ្ចក្ខន្ធទាំងនោះថា ជារបស់មិនទៀង ជាទុក្ខ ជារោគ ជាពក ជាសរ ជាគ្រឿងបៀតបៀន ជាអាពាធ ជារបស់ដទៃ ជារបស់ទ្រុឌទ្រោម ជារបស់សូន្យ ជារបស់អនត្តា ។ ភិក្ខុនោះ ញុំាងចិត្តឲ្យតម្កល់នៅស៊ប់ ដោយធម៌ទាំងនោះ លុះភិក្ខុនោះ ញុំាងចិត្តឲ្យតម្កល់នៅស៊ប់ ដោយធម៌ទាំងនោះហើយ ក៏ប្រមូលមកនូវចិត្តទុកក្នុងអមតធាតុថា ការរម្ងាប់បង់នូវសង្ខារទាំងពួង ការលះបង់នូវកិលេសទាំងពួង ការអស់ទៅនៃតណ្ហា សេចក្តីនឿយណាយ សេចក្តីរលត់តណ្ហា គឺព្រះនិព្វានណា ព្រះនិព្វាននុ៎ះ ជាទីស្ងប់ ព្រះនិព្វាននុ៎ះ ជារបស់ប្រសើរ ។ ភិក្ខុនោះ បានឋិតនៅក្នុងវិបស្សនា ដែលមានត្រៃលក្ខណ៍ ជាអារម្មណ៍នោះហើយ រមែងដល់នូវការអស់ទៅនៃអាសវៈទាំងឡាយ បើមិនបានដល់នូវការអស់ទៅនៃអាសវៈទេ ក៏គង់បានទៅកើតជាឱបបាតិកកំណើត ព្រោះសេចក្តីត្រេកអរចំពោះធម៌នោះ ព្រោះសេចក្តីរីករាយចំពោះធម៌នោះ ព្រោះអស់ទៅនៃឱរម្ភាគិយសំយោជនៈ ៥ ហើយនឹងបរិនិព្វានក្នុងទីនោះ មិនត្រឡប់អំពីលោកនោះមកវិញឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចនាយខ្មាន់ធ្នូក្តី កូនសិស្សរបស់ខ្មាន់ធ្នូក្តី ធ្វើនូវគ្រឿងប្រកបក្នុងរូបភាពបុរស ជាវិការនៃស្មៅក្តី ក្នុងដុំដីស្អិតក្តី លុះសម័យខាងក្រោយមក ខ្មាន់ធ្នូនោះ បាញ់បានឆ្ងាយផង បាញ់ត្រង់ផង អាចទម្លាយនូវកាយដ៏ធំបានផង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុព្រោះលះបង់នូវសុខផង ។បេ។ បានដល់ចតុត្ថជ្ឈាន ក៏យ៉ាងនោះដែរ ។ រូប វេទនាណា ដែលប្រព្រឹត្តទៅ

ក្នុងចតុត្ថជ្ឈាននោះ ភិក្ខុនោះ ។បេ។ មានសភាពមិនត្រឡប់ អំពីលោកនោះ មកវិញឡើយ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យណាដែលតថាគតពោលហើយ ថា តថាគត ពោលនូវការអស់ទៅនៃអាសវៈ ព្រោះអាស្រ័យនូវចតុត្ថជ្ឈាន ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យនូវហេតុនោះ ។ ម្នាលភិក្ខុ ទាំងឡាយ តថាគតពោលនូវការអស់ទៅនៃអាសវៈ ព្រោះអាស្រ័យនូវ អាកាសានញ្ចាយតនជ្ឈាន ព្រោះហេតុនោះ ពាក្យដែលតថាគតពោលហើយ នុ៎ះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យនូវហេតុដូចម្តេច ។ ម្នាល ភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងបង់រូបសញ្ញា ដោយប្រការ ទាំងពួង ព្រោះអស់បដិឃសញ្ញាហើយ លែងធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ហើយដល់នូវអាកាសានញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អាកាស មិនមានទីបំផុត ។ វេទនា សញ្ញា សង្ខារ វិញ្ញាណណា ដែលប្រព្រឹត្តទៅក្នុង អាកាសានញ្ចាយតនជ្ឈាននោះ ភិក្ខុនោះ ក៏រមែងពិចារណាឃើញនូវធម៌ គឺ ខន្ធទាំងនោះថា ជារបស់មិនទៀង ជាទុក្ខ ជារោគ ជាពក ជាសរ ជាសេចក្តី បៀតបៀន ជាអាពាធ ជារបស់ដទៃ ជារបស់ទ្រុឌទ្រោម ជារបស់សូន្យ ជា របស់អនត្តា ។ ភិក្ខុនោះ ញុំាងចិត្តឲ្យតម្កល់នៅស៊ប់ដោយធម៌ទាំងនោះ លុះ ភិក្ខុនោះ បានញុំាងចិត្តឲ្យតម្កល់នៅស៊ប់ ដោយធម៌ទាំងនោះហើយ ក៏ប្រមូល ចិត្តទៅក្នុងអមតធាតុថា ការម្ងាប់បង់នូវសង្ខារទាំងពួង លះបង់នូវកិលេស ទាំងពួង ការអស់ទៅនៃតណ្ហា សេចក្តីនឿយណាយ សេចក្តីរលត់តណ្ហា គឺ

ព្រះនិព្វានណា ព្រះនិព្វាននុ៎ះ ជាទីស្ងប់ ព្រះនិព្វាននុ៎ះ ជារបស់ប្រសើរ ។ ភិក្ខុនោះ បានឋិតនៅក្នុងវិបស្សនា ដែលមានត្រៃលក្ខណ៍ជាអារម្មណ៍នោះ ហើយ រមែងដល់នូវការអស់ទៅនៃអាសវៈទាំងឡាយ បើមិនបានដល់នូវការ អស់ទៅនៃអាសវៈទេ ក៏គង់បានទៅកើតជាឱបបាតិកកំណើត ព្រោះសេចក្តី ត្រេកអរចំពោះធម៌នោះ ព្រោះសេចក្តីរីករាយចំពោះធម៌នោះ ព្រោះអស់ទៅ នៃឱរម្ភាគិយសំយោជនៈ ៥ ហើយនឹងបរិនិព្វានក្នុងទីនោះ មិនត្រឡប់អំពី លោកនោះមកវិញឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចខ្មាន់ធ្នូក្តី កូនសិស្ស របស់ខ្មាន់ធ្នូក្តី ធ្វើនូវការប្រកបក្នុងរូបភាពបុរស ជាវិការនៃស្មៅក្តី ក្នុងដុំដី ស្អិតក្តី លុះសម័យខាងក្រោយមក ខ្មាន់ធ្នូនោះ បាញ់បានឆ្ងាយផង បាញ់ ត្រង់ផង អាចទម្លាយនូវកាយដ៏ធំផង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុព្រោះកន្លងបង់រូបសញ្ញាដោយប្រការទាំងពួង ព្រោះអស់បដិឃសញ្ញា ហើយ លែងធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ហើយដល់នូវអាកាសានញ្ចាយ-តនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ ។ វេទនា សញ្ញាណា ដែលប្រព្រឹត្តទៅក្នុងអកាសានញ្ចាយតនជ្ឈានោះ ភិក្ខុនោះ ។បេ។ មានសភាពមិនបានត្រឡប់អំពីលោកនោះ មកវិញឡើយ ។ ម្នាលភិក្ខុទាំង-ឡាយ ពាក្យណាដែលតថាគតពោលថា តថាគត ពោលនូវការអស់ទៅនៃ អាសវៈ ព្រោះអាស្រ័យនូវអាកាសានញ្ចាយតនជ្ឈាន ពាក្យនេះ តថាគត ពោលហើយ ព្រោះអាស្រ័យនូវហេតុនេះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះអា-

ស្រ័យនូវវិញ្ញាណញ្ចាយតនជ្ឈាន ។បេ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោល នូវការអស់ទៅនៃអាសវៈ ព្រោះអាស្រ័យនូវអាកិញ្ចញ្ញាយតនជ្ឈាន ព្រោះហេតុនោះ ពាក្យដែលតថាគតពោលហើយនុ៎ះ ពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យនូវហេតុដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វត្ថុតិចតួចមិនមាន ដូច្នេះ ។ វេទនា សញ្ញា សង្ខារ វិញ្ញាណណា ដែលប្រព្រឹត្តទៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះ ភិក្ខុនោះ ក៏រមែងពិចារណាឃើញនូវធម៌ គឺខន្ធទាំងនោះថា ជារបស់មិនទៀង ជាទុក្ខ ជារោគ ជាពក ជាសរ ជាគ្រឿងបៀតបៀន ជាអាពាធ ជារបស់ដទៃ ជារបស់ទ្រុឌទ្រោម ជារបស់សូន្យ ជារបស់អនត្តា ។ ភិក្ខុនោះ ញុំាងចិត្តឲ្យតម្កល់នៅស៊ប់ដោយធម៌ទាំងនោះ លុះភិក្ខុនោះ ញុំាងចិត្តឲ្យតម្កល់នៅស៊ប់ ដោយធម៌ទាំងនោះហើយ ក៏ប្រមូលចិត្តទៅក្នុងអមតធាតុថា ការរម្ងាប់បង់នូវសង្ខារទាំងពួង លះបង់នូវកិលេសទាំងពួង ការអស់ទៅនៃតណ្ហា សេចក្តីនឿយណាយ សេចក្តីរលត់តណ្ហា គឺព្រះនិព្វានណា ព្រះនិព្វាននុ៎ះ ជាទីស្ងប់ ព្រះនិព្វាននុ៎ះ ជារបស់ប្រសើរ ។ ភិក្ខុនោះបានឋិតនៅក្នុងវិបស្សនា ដែលមានត្រៃលក្ខណ៍ជាអារម្មណ៍ ហើយរមែងដល់នូវការអស់ទៅនៃអាសវៈទាំងឡាយ បើមិនបានដល់នូវការអស់ទៅនៃអាសវៈទេ ក៏គង់បានទៅកើតជាឱបបាតិកកំណើត ព្រោះសេចក្តីត្រេកអរ

ចំពោះធម៌នោះ ព្រោះសេចក្តីរីករាយ ចំពោះធម៌នោះ ព្រោះអស់ទៅនៃឱរម្ភាគិយសំយោជនៈ ៥ ហើយនឹងបរិនិព្វានក្នុងទីនោះ មិនត្រឡប់អំពីលោកនោះ មកវិញឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចខ្មាន់ធ្នូក្តី កូនសិស្សរបស់ខ្មាន់ធ្នូក្តី ធ្វើនូវការប្រកបក្នុងរូបភាពបុរស ជាវិការនៃស្មៅក្តី ក្នុងដុំដីស្អិតក្តី លុះសម័យខាងក្រោយមក ខ្មាន់ធ្នូនោះ បាញ់បានឆ្ងាយផង បាញ់ត្រង់ផង អាចទម្លាយនូវកាយដ៏ធំផង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុព្រោះកន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួងហើយ ដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វត្ថុតិចតួចមិនមាន ដូច្នេះ យ៉ាងនោះដែរ ។ វេទនា សញ្ញា សង្ខារ វិញ្ញាណណា ដែលប្រព្រឹត្តទៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះ ភិក្ខុនោះ ក៏រមែងពិចារណាឃើញនូវធម៌ គឺខន្ធទាំងនោះថា ជារបស់មិនទៀង ជាទុក្ខ ជារោគ ជាពក ជាសរ ជាគ្រឿងបៀតបៀន ជាអាពាធ ជារបស់ដទៃ ជារបស់ទ្រុឌទ្រោម ជារបស់សូន្យ ជារបស់អនត្តា ។ ភិក្ខុនោះ ញុំាងចិត្តឲ្យតម្កល់នៅស៊ប់ដោយធម៌ទាំងនោះ លុះភិក្ខុនោះ ញុំាងចិត្តឲ្យតម្កល់នៅស៊ប់ ដោយធម៌ទាំងនោះហើយ ក៏ប្រមូលចិត្តទៅក្នុងអមតធាតុថា ការម្ងាប់នូវសង្ខារទាំងពួង ការលះបង់នូវកិលេសទាំងពួង ការអស់ទៅនៃតណ្ហា សេចក្តីនឿយណាយ សេចក្តីរលត់តណ្ហា គឺព្រះនិព្វានណា ព្រះនិព្វាននុ៎ះ ជាទីស្ងប់ ព្រះនិព្វាននុ៎ះ ជារបស់ប្រសើរ ។ ភិក្ខុនោះបានឋិតនៅក្នុងវិបស្សនា ដែលមានត្រៃលក្ខណ៍ ជាអារម្មណ៍នោះហើយ

រមែងដល់នូវការអស់ទៅនៃអាសវៈទាំងឡាយ បើមិនបានដល់នូវការអស់ទៅនៃអាសវៈទេ ក៏គង់បានទៅកើតជាឱបបាតិកកំណើត ព្រោះសេចក្តីត្រេកអរចំពោះធម៌នោះ ព្រោះសេចក្តីរីករាយចំពោះធម៌នោះ ព្រោះអស់ទៅនៃឱរម្ភាគិយសំយោជនៈ ៥ ហើយនឹងបរិនិព្វានក្នុងទីនោះ មិនត្រឡប់អំពីលោកនោះមកវិញឡើយ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យណាដែលតថាគតពោលហើយថា តថាគតពោលនូវការអស់ទៅនៃអាសវៈ ព្រោះអាស្រ័យនូវអាកិញ្ចញ្ញាយតនជ្ឈាន ពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យនូវហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សញ្ញា សមាបត្តិ មាននៅដរាបណា សញ្ញាបដិវេធ ក៏មាននៅដរាបនោះ ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានឈាន ព្រោះអាស្រ័យនូវអាយតនៈទាំង ២ ណា គឺនេវសញ្ញានាសញ្ញាយតនសមាបត្តិ ១ សញ្ញាវេទយិតនិរោធ ១ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវអាយតនៈទាំងនុ៎ះថា ភិក្ខុដែលមានឈានឈ្លាសវៃ ក្នុងការចូលកាន់សមាបត្តិ ឈ្លាសវៃក្នុងការចេញចាកសមាបត្តិ គួរពោលថា ចូលចេញដោយប្រពៃ ។

# អដ្ឋកថា

## ឈានសូត្រ

[ ៣៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឈានសូត្រទី ៥ ដូចតទៅនេះ បទថា **អាសវានំ ខយំ** បានដល់ អរហត្ត ។ បទថា **យទេវ តត្ថ ហោតិ រូបគតំ** សេចក្ដីថា ធម្មតារូបណា រមែងប្រព្រឹត្តទៅក្នុងខណៈបឋមជ្ឈាននោះដោយវត្ថុក្ដី ដោយចិត្តជាសមុដ្ឋានក្ដី ។ គប្បីជ្រាបវេទនាជាដើម ដោយអំណាចសំយុត្តវេទនា គឺវេទនាដែលប្រកបគ្នាជាដើម ។ បទថា **តេ ធម្មេ** បានដល់ធម៌ គឺបញ្ចក្ខន្ធ មានរូបជាដើមនោះ ។

ក្នុងបទទាំងឡាយ មានបទថា **អនិច្ចតោ** ជាដើម គប្បីជ្រាបសេចក្ដីដូច្នេះ ឈ្មោះថា ជារបស់មិនទៀង ព្រោះអាការមានហើយ ទៅជាមិនមាន ឈ្មោះថា ជាទុក្ខ ព្រោះការបៀតបៀន ឈ្មោះថា ជារោគ ព្រោះការចាក់ដោត ឈ្មោះថា ជាបូស ព្រោះឈឺខាងក្នុង ឈ្មោះថា ជាព្រួញ ព្រោះចាក់ចូលទៅ និងព្រោះមុតចូលទៅ ឈ្មោះថា សេចក្ដីលំបាក ព្រោះអត់ធន់បានដោយកម្រ ឈ្មោះថា អាពាធ ព្រោះត្រូវបៀតបៀន ឈ្មោះថា ជាវត្ថុដទៃព្រោះមិនមែនជារបស់ខ្លួន ឈ្មោះថា ជារបស់បែកធ្លាយ ព្រោះពុកទៅ ឈ្មោះថា ជារបស់សូន្យ ព្រោះមិនមែនជាម្ចាស់ ឈ្មោះថា ជាអនត្តា ព្រោះមិននៅក្នុងអំណាច ។ បទថា **សមនុបស្សតិ** បានដល់ ឃើញដោយវិបស្សនាញាណដែលចាស់ក្លា ។ បទថា **តេហិ ធម្មេហិ** បានដល់ ដោយធម៌ គឺបញ្ចក្ខន្ធទាំងនោះ ។ បទថា **បតិដ្ឋាបេតិ** បានដល់ ត្រឡប់ទៅដោយការ

ទៀយណាយ ។ បទថា **អមតាយ ធាតុយា** បានដល់ និព្វានធាតុ ។ បទថា **ចិត្តំ ឧបសំហរតិ** បានដល់ ឃើញដោយវិបស្សនាញាណដែលចាស់ក្លា គឺឃើញអានិសង្សដោយញាណ ហើយឈមចុះ ។ បទថា **សន្តំ** បានដល់ ឈ្មោះថា ស្ងប់ ព្រោះស្ងប់ចាកកិលេសដែលជាសត្រូវ ។ បទថា **បណីតំ** បានដល់ មិនក្តៅក្រហាយ ។ បទថា **សោ តត្ថ ឋិតោ អាសវានំ ខយំ បាបុណាតិ** សេចក្តីថា ភិក្ខុនោះតាំងនៅក្នុងបឋមជ្ឈាននោះ ចម្រើនវិបស្សនាចាស់ក្លា រមែងសម្រេចអរហត្ត ។

គប្បីជ្រាបន័យដទៃទៀតថា បទថា **សោ តេហិ ធម្មេហិ** សេចក្តីថា ព្រោះក្នុងបទថា **អនិច្ចតោ** ជាដើម លោកពោលដល់អនិច្ចលក្ខណៈ ដោយ ២ បទ គឺ **អនិច្ចតោ បលោកតោ** ពោលដល់ ទុក្ខលក្ខណៈ ដោយ ៦ បទ មានបទថា **ទុក្ខតោ** ជាដើម ពោលដល់អនត្តលក្ខណៈ ដោយ ៣ បទ គឺ **បរតោ សុញ្ញតោ អនត្តតោ** ដូច្នោះ ភិក្ខុនោះលើកឡើងកាន់ត្រៃលក្ខណ៍ យ៉ាងនេះដោយធម៌ គឺបញ្ចក្ខន្ធខាងក្នុងសមាបត្តិ ដែលខ្លួនឃើញហើយនោះ ។ បទថា **ចិត្តំ បតិដ្ឋាបេតិ** បានដល់ រួបរួមបង្អោនចិត្តចូលទៅ ។ បទថា **ឧបសំហរតិ** សេចក្តីថា ភិក្ខុបង្អោនចូលទៅនូវវិបស្សនាចិត្ត ដោយអសង្ខតធាតុ អមតធាតុ យ៉ាងនេះថា និព្វានស្ងប់ ដោយលំនៅ ដោយការសរសើរ ដោយបរិយត្តិ និងដោយបញ្ញត្តិ ភិក្ខុរមែងពោលដល់និព្វាន ដែលជាមគ្គចិត្ត យ៉ាងនេះថា នេះស្ងប់ នេះប្រណីត ដោយធ្វើឲ្យជាអារម្មណ៍ប៉ុណ្ណោះ អធិប្បាយ

ថា ដោយប្រការនេះ ភិក្ខុចាក់ចុះនូវធម៌នោះ បង្អោនចិត្តចូលទៅក្នុងធម៌នោះ ដូច្នេះ ។ បទថា **សោ តត្ថ ឋិតោ** សេចក្តីថា ភិក្ខុតាំងនៅក្នុងវិបស្សនាដែលមានត្រៃលក្ខណ៍ជាអារម្មណ៍នោះ ។ បទថា **អាសវានំ ខយំ បាបុណាតិ** សេចក្តីថា ភិក្ខុចម្រើនមគ្គ ៤ តាមលំដាប់ ហើយសម្រេចអរហត្ត ។

បទថា **តេនេវ ធម្មរាគេន** បានដល់ ឆន្ទរាគៈក្នុងធម៌ គឺសមថៈ និងវិបស្សនា ។ បទថា **ធម្មនន្ទិយា** ជាវេវចនៈនៃបទថា **ធម្មរាគេន** នោះឯង ។ ពិតហើយ ភិក្ខុកាលអាចគ្របសង្កត់ឆន្ទរាគៈក្នុងសមថៈ និងវិបស្សនាបានដោយប្រការទាំងពួង រមែងសម្រេចអរហត្តបាន កាលមិនអាច ក៏ជាព្រះអនាគាមី ។ បទថា **តិណបុរិសរូបកេ វា** បានដល់ ចង្កៀងជារូបមនុស្ស ។ ឈ្មោះថា **ទូរេបាតី** ព្រោះបាញ់ព្រួញឲ្យធ្លាក់ទៅក្នុងទីឆ្ងាយ ។ ឈ្មោះថា **អក្ខណវេធី** ព្រោះបាញ់មិនខុស ។

ក្នុងបទថា **យទេវ តត្ថ ហោតិ វេទនាគតំ** នេះ មិនកាន់យករូប ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះកន្លងទៅហើយ ។ ពិតហើយ ភិក្ខុនេះចូលដល់រូបាវចរជ្ឈានខាងក្រោយ កាលកន្លងរូបទៅហើយ សូម្បីចូលដល់អរូបាវចរសមាបត្តិ ក្រោយមក ពិចារណារូបដែលកន្លងរូបទៅហើយ ដោយអរូបាវចរសមាបត្តិនោះ ដោយសមថៈ កាលកន្លងរូបទៅហើយ ក្នុងឥឡូវនេះ រមែងពិចារណាអរូប ដោយហេតុនោះ ទើបរូបកន្លងទៅហើយ ដោយអរូបនោះ ដោយវិបស្សនាក្នុងអរូប រមែងមិនមានរូប ដោយប្រការទាំងពួង ព្រោះ

ដូច្នោះ សូម្បីលោកសំដៅដល់រូបនោះ តែក្នុងទីនេះ មិនកាន់យករូបឡើយ ។ សួរថា កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបមិនកាន់យកនេវសញ្ញានាសញ្ញាយតនៈផង ឆ្លើយថា ព្រោះជារបស់សុខុម ។ ពិតហើយ ក្នុងនេវសញ្ញានាសញ្ញាយតនៈនោះ សូម្បីអរូបក្ខន្ធ ៤ ក៏សុខុម មិនសមដែលនឹងពិចារណា សមដូចព្រះមានព្រះភាគត្រាស់ថា **ឥតិ ខោ ភិក្ខវេ ។បេ។ អញ្ញាបដិវេធោ ។** សេចក្តីនេះ មានអធិប្បាយដូច្នេះថា ឈ្មោះថា **សចិត្តកសមាបត្តិ** មានប្រមាណប៉ុនណា ការចាក់ធ្លុះដល់អរហត្ត រមែងមានដល់បុគ្គលពិចារណាធម៌ដ៏ក្រៃលែង មានប្រមាណប៉ុណ្ណោះ បុគ្គលនោះ រមែងចូលដល់អរហត្ត តែនេវសញ្ញានាសញ្ញាយតនៈ លោកមិនពោលថា ជាសញ្ញាសមាបត្តិឡើយ ព្រោះភាពជារបស់សុខុម ។

បទថា **ឈាយីហេតេ** សេចក្តីថា អាយតនៈទាំង ២ នេះ ដែលបុគ្គលសម្រឹង គឺជាអ្នកត្រេកអរក្នុងឈាន គួរពោលដល់ដោយប្រពៃ ។ បទថា **វុដ្ឋហិត្វា** បានដល់ ចេញអំពីសមាបត្តិនោះ ។ បទថា **សម្មទក្ខាតព្វានិ** បានដល់ គប្បីពោលដោយប្រពៃ ។ បុគ្គលគប្បីពោល គប្បីលើកតម្កើង គប្បីសរសើរនេវសញ្ញានាសញ្ញាយតនសមាបត្តិ និងសញ្ញាវេទយិតនិរោធសមាបត្តិ តែម្យ៉ាងថា ស្ងប់ ប្រណីត ដូច្នេះ ។៙

**អដ្ឋកថាឈានសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## អានន្ទសូត្រទី ៦

[ ៣៧ ] សម័យមួយ ព្រះអានន្ទដ៏មានអាយុ គង់នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ ក្នុងទីនោះឯង ព្រះអានន្ទដ៏មានអាយុ មានថេរវាចានឹងភិក្ខុទាំងឡាយថា ម្នាលអាវុសោភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលតបព្រះអានន្ទដ៏មានអាយុថា ករុណាអាវុសោ ។ ព្រះអានន្ទដ៏មានអាយុ មានថេរវាចាដូច្នេះថា ម្នាលអាវុសោទាំងឡាយ អស្ចារ្យណាស់ ម្នាលអាវុសោទាំងឡាយ ចម្លែកណាស់ ព្រោះព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ព្រះអង្គត្រាស់ដឹងនូវការបាននូវឱកាសដើម្បីសេចក្តីបរិសុទ្ធ ដើម្បីកន្លងបង់នូវសេចក្តីសោក និងខ្សឹកខ្សួល ដើម្បីរលត់ទុក្ខ និងទោមនស្ស ដើម្បីបាននូវព្រះនិព្វាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន របស់សត្វទាំងឡាយ ( ការបាននូវឱកាសនោះ គឺ ) ចក្ខុប្បសាទនោះ ក៏មានរូបទាំងឡាយនោះ មកកាន់រង្វង់ចក្ខុ តែមិនទទួលដឹងចំពោះរូបាយតនៈនោះ ១ សោតប្បសាទក៏មាន សំឡេងទាំងឡាយនោះក៏មក តែមិនទទួលដឹងចំពោះសទ្ទាយតនៈនោះ ១ ឃានប្បសាទនោះក៏មាន ក្លិនទាំងឡាយនោះក៏មក តែមិនទទួលដឹងចំពោះគន្ធាយតនៈនោះ ១ ជិវ្ហាបសាទនោះក៏មាន រសទាំងឡាយនោះក៏មក តែមិនទទួលដឹងចំពោះរសាយតនៈនោះ ១ កាយប្បសាទនោះក៏មាន សម្ផស្សទាំងឡាយក៏មក តែមិនទទួលដឹងចំពោះផោដ្ឋព្វាយតនៈនោះ ១ ។ កាលដែលអានន្ទដ៏មានអាយុ មានថេរ

វាចាយ៉ាងនេះហើយ ព្រះឧទាយីដ៏មានអាយុ បានសួរព្រះអានន្ទដ៏មានអាយុ ដូច្នេះថា អើ អាវុសោអានន្ទ ចុះ ដែលមិនទទួលដឹងចំពោះអាយតនៈនោះ តើមានសញ្ញាឬទេ ឬក៏មិនមានសញ្ញា ។ ព្រះអានន្ទដ៏មានអាយុតបថា បុគ្គលដែលទទួលដឹង ចំពោះអាយតនៈនោះ សុទ្ធតែជាអ្នកមានសញ្ញា មិនមែនជាអ្នកមិនមានសញ្ញាទេ ។ ព្រះឧទាយីដ៏មានអាយុ សួរទៀតថា ម្នាលអាវុសោ ចុះបុគ្គលមានសញ្ញាបែបណាទៅ ទើបមិនទទួលដឹងចំពោះអាយតនៈនោះ ។

ព្រះអានន្ទដ៏មានអាយុតបថា ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងបង់នូវរូបសញ្ញា ព្រោះរលត់នូវបដិឃសញ្ញា ព្រោះមិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង ក៏បានដល់នូវអាកាសានញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុត ។ ម្នាលអាវុសោ ភិក្ខុមានសញ្ញាយ៉ាងនេះឯង តែងមិនទទួលដឹងចំពោះអាយតនៈនោះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុព្រោះកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុត ។ ម្នាលអាវុសោ ភិក្ខុមានសញ្ញាយ៉ាងនេះឯង តែងមិនទទួលដឹងចំពោះអាយតនៈនោះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុព្រោះកន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្ត

ថា អ្វីតិចតួចមិនមាន ។ ម្នាលអាវុសោ ភិក្ខុមានសញ្ញាយ៉ាងនេះឯង តែង មិនទទួលដឹងចំពោះអាយតនៈនោះ ។

ម្នាលអាវុសោ សម័យមួយ ខ្ញុំនៅក្នុងអញ្ជនវ័ន ( ព្រៃអញ្ជ័ន ) ជាទីឲ្យអភ័យដល់ម្រឹគ ជិតក្រុងសាកេត ។ ម្នាលអាវុសោ គ្រានោះ នាងភិក្ខុនីជាបងប្អូននឹងជដិល បានចូលមករកខ្ញុំ លុះចូលមកដល់ហើយ ថ្វាយបង្គំខ្ញុំហើយឋិតនៅក្នុងទីដ៏សមគួរ ។ ម្នាលអាវុសោ លុះភិក្ខុនីជាបងប្អូននឹងជដិលឋិតនៅក្នុងទីដ៏សមគួរស៊ប់ហើយ បានសួរខ្ញុំដូច្នេះថា បពិត្រព្រះអានន្ទដ៏ចម្រើន សមាធិដែលលែងទោរទៅ ( ដោយអំណាចរាគៈ ) លែងងប់ទៅ ( ដោយអំណាចទោសៈ ) លែងសង្កត់សង្កិនហាមឃាត់នូវកិលេសដោយព្យាយាម ( ទៀតហើយ ) ជាសមាធិ ឈ្មោះថា តាំងនៅហើយ ព្រោះផុតស្រឡះចាកកិលេស ជាសមាធិ ឈ្មោះថា ត្រេកអរ ព្រោះតាំងនៅ ជាសមាធិ ឈ្មោះថា មិនតក់ស្លុត ព្រោះត្រេកអរ បពិត្រព្រះអានន្ទដ៏ចម្រើន តើសមាធិនេះព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា មានអ្វីជាផល ។ ម្នាលអាវុសោ កាលភិក្ខុនីនោះ សួរយ៉ាងនេះហើយ ខ្ញុំក៏បានឆ្លើយតបនឹងនាងភិក្ខុនីជាបងប្អូននឹងជដិលនោះថា ម្នាលនាង សមាធិ ដែលលែងទោរទៅ ( ដោយអំណាចរាគៈ ) លែងងប់ទៅ ( ដោយអំណាចទោសៈ ) លែងសង្កត់សង្កិន ហាមឃាត់នូវកិលេសដោយព្យាយាម ( ទៀតហើយ ) ជាសមាធិ ឈ្មោះថា តាំងនៅ ព្រោះផុតស្រឡះចាកកិលេស ជាសមាធិ ឈ្មោះថា ត្រេកអរ ព្រោះ

*តាំងនៅ ជាសមាធិ ឈ្មោះថា មិនតក់ស្លុត ព្រោះសេចក្តីត្រេកអរ ម្នាល នាង សមាធិនេះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា មានអរហត្តជាផល ។ ម្នាលអាវុសោ បុគ្គលមានសញ្ញាយ៉ាងនេះឯង តែងមិនទទួលដឹងចំពោះ អាយតនៈនោះ ។*

# អដ្ឋកថា

## អានន្ទសូត្រ

*[ ៣៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអានន្ទសូត្រទី ៦ ដូចតទៅនេះ បទថា* **សម្ពាធេ**[១] *បានដល់ ក្នុងទីចង្អៀត គឺកាមគុណ ៥ ។ បទថា* **ឱកាសាធិគមោ** *បានដល់ ដល់នូវឱកាស ។ បទថា* **សត្តានំ វិសុទ្ធិយា** *បានដល់ ដើម្បីឲ្យសត្វទាំងឡាយដល់នូវភាពបរិសុទ្ធ ។ បទថា* **សមតិក្កមាយ** *បាន ដល់ ដើម្បីជាប្រយោជន៍ដល់ការកន្លងទៅ ។ បទថា* **អត្ថង្គមាយ** *បានដល់ ដើម្បីជាប្រយោជន៍ដល់ការរលត់ទៅ ។ បទថា* **ញាយស្ស អធិគមាយ** *បាន ដល់ ដើម្បីជាប្រយោជន៍ដល់ការសម្រេចមគ្គ មួយអន្លើដោយវិបស្សនា ។ បទថា* **និព្វានស្ស សច្ឆិកិរិយាយ** *បានដល់ ដើម្បីជាប្រយោជន៍ដល់ការធ្វើ*

---

*១- បទថា សម្ពាធេ នេះ មានក្នុងខេលឃ្នាប ៤២ ឯណោះ តែព្រះអដ្ឋកថា លោក លើកមកក្នុងទីនេះ ទើបយើងរក្សាទុក ។*

និព្វានដែលមិនមានបច្ច័យតាក់តែងឲ្យប្រែបក្ស ។ បទថា **តនេវ ឆាម ចក្ខុំ ភវិស្សតិ** បានដល់ ចក្ខុនោះឯង គឺបសាទចក្ខុ នឹងប្រែកគ្នាទៅក៏មិនមែន ។ បទថា **តេ រូបា** បានដល់ រូបារម្មណ៍នោះឯងនឹងមកកាន់គន្លងបសាទចក្ខុ ។ បទថា **តញ្ចាយតនំ នោ បដិសំវេទិស្សតិ** បានដល់ បុគ្គលដែលមានសញ្ញា និងមិនដឹងរូបាយតនៈនោះ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

បទថា **ឧទាយិ** បានដល់ ព្រះកាឡុទាយិត្ថេរ ។ បទថា **សញ្ញីមេវ នុ ខោ** បានដល់ ជាអ្នកមានចិត្តឬហ្ន៎ ។ **ម** អក្ខរៈ ត្រឹមតែជាបទសន្ធិ ។ បទថា **កឹសញ្ញី** បានដល់ ជាអ្នកមានសញ្ញាដោយសញ្ញាប្រភេទណា ។ បទថា **សព្វសោ រូបសញ្ញានំ** ព្រោះកន្លងនូវរូបសញ្ញា ដោយប្រការទាំងពួង សេចក្តីថា សួរថា ព្រោះហេតុអ្វី ទើបព្រះអានន្ទកាន់យករូបសញ្ញានេះ ការសោយអារម្មណ៍ មានរូបារម្មណ៍ជាដើម រមែងមានដល់លោក ដែលដល់ព្រមដោយបឋមជ្ឈានជាដើមឬ ។ ឆ្លើយថា មិនមាន ឯកសិណរូបនៅជាអារម្មណ៍ដរាបណា រូប ឈ្មោះថា មិនទាន់កន្លងទៅដរាបនោះ រូបនោះនឹងអាចជាបច្ច័យ ព្រោះមិនទាន់កន្លងទៅ តែរូបនោះ ព្រោះមិនទាន់កន្លងទៅ ទើបឈ្មោះថា មិនមាន ព្រះអានន្ទកាន់យកពាក្យនោះឯង ដើម្បីសម្តែងថា ព្រោះរូបមិនមាន ទើបមិនអាចជាបច្ច័យបាន ។

*បទថា* **ជដិលគាហិយា** *បានដល់ ភិក្ខុនីនៅក្នុងនគរជដិលគហៈ*[១] *ក្នុងបទថា* **ន ចាភិណតោ** *ជាដើម គប្បីជ្រាបអត្ថដូចតទៅនេះ សមាធិឈ្មោះថា សង្កត់ ដោយការដឹកនាំមិនបាន ព្រោះមិនបង្អោនទៅដោយអំណាចរបស់រាគៈ មិននាំចេញទៅដោយអំណាចរបស់ទោសៈ សង្កត់កិលេសទាំងឡាយ ហើយតាំងនៅដោយការដឹកនាំ ដោយការប្រកបមិនបាន តែកើតឡើងបានក្នុងកាលកាត់កិលេសបានហើយ ។ បទថា* **វិមុត្តត្តា ឋិតោ** *បានដល់ ឈ្មោះថា តាំងនៅហើយ ព្រោះផុតចាកកិលេសទាំងឡាយ ។ បទថា* **ឋិតត្តា សន្តុសិតោ** *បានដល់ ឈ្មោះថា សន្ដោស ព្រោះតាំងមាំហើយនោះឯង ។ បទថា* **សន្តុសិតត្តា នោ បរិតស្សតិ** *បានដល់ មិនដល់នូវការតក់ស្លុត ព្រោះជាអ្នកសន្ដោសហើយ ។ បទថា* **អយំ ភន្តេ អានន្ទ សមាធិ កឹផលោ** *នេះ ព្រះថេរីកាន់យកសមាធិក្នុងអរហត្តផល ហើយសួរថា បពិត្រលោកម្ចាស់អានន្ទ សមាធិនេះ ព្រះមានព្រះភាគត្រាស់ថា ជាផលរបស់អ្វី ដូចកាន់យកផ្លែត្នោត ហើយសួរថា ផ្លែនេះ ឈ្មោះផ្លែអ្វី ដូច្នេះ ។ បទថា* **អញ្ញាផលោ វុត្តោ** *សេចក្ដីថា ព្រះមានព្រះភាគត្រាស់ហៅអរហត្តថា* **អញ្ញា** *ឈ្មោះថា សមាធិក្នុងអរហត្តផល ព្រះមានព្រះភាគត្រាស់ហើយ ។ បទថា* **ឯវំសញ្ញីបិ** *សេចក្ដីថា សូម្បីមានសញ្ញា ដោយសញ្ញាក្នុងអរហត្តផល*

---

*១- បិដកខ្មែរ ប្រែថា ជាបងប្អូននឹងជដិល ឃើញថា ខុសក្នុងន័យរបស់អដ្ឋកថា ព្រោះបទថា ជដិលគាហិយា នេះ ជាឈ្មោះរបស់នគរទេ ។*

នេះ ក៏មិនសោយអាយតនៈនោះ ព្រោះហេតុនោះ ក្នុងព្រះសូត្រនេះ ទើបព្រះមានព្រះភាគត្រាស់ដល់សមាធិក្នុងអរហត្តផល ដោយប្រការដូច្នេះ ។

## អដ្ឋកថា អានន្ទសូត្រទី ៦ ចប់

# សុត្តន្តបិដក

## ព្រាហ្មណសូត្រទី ៧

[ ៣៨ ] គ្រានោះឯង ព្រាហ្មណ៍ ២ នាក់ ជាអ្នកចេះស្ទាត់នូវគម្ពីរលោកាយតៈ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ពោលពាក្យរាក់ទាក់ជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭករួចហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះព្រាហ្មណ៍ទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន គ្រូឈ្មោះបូរណកស្សបៈជាអ្នកដឹងនូវហេតុទាំងពួង ឃើញនូវហេតុទាំងពួង តែងប្តេជ្ញានូវការដឹង ការឃើញមិនមានសេសសល់ថា កាលអញដើរក្តី ឈរក្តី កាលអញដេកក្តី ភ្ញាក់ឡើងក្តី ការដឹង និងការឃើញ ( នូវហេតុទាំងពួង ) តែងតម្កល់នៅស៊ប់សព្វពេលវេលា ជានិរន្តរ៍ ។ បូរណកស្សបៈនោះ និយាយយ៉ាងនេះថា អញតែងដឹង តែងឃើញនូវលោកដែលមិនមានទីបំផុតដោយសារញាណមិន

*មានទីបំផុត ។ បពិត្រព្រះគោតមដ៏ចម្រើន សូម្បីគ្រូឈ្មោះនិគ្គណ្ឋនាដបុត្ត នេះ ក៏ជាអ្នកដឹងនូវហេតុទាំងពួង ឃើញនូវហេតុទាំងពួងដែរ តែងប្តេជ្ញា នូវការដឹង ការឃើញ មិនមានសេសសល់ថា កាលអញដើរក្តី ឈរក្តី អញដេកក្តី ភ្ញាក់ឡើងក្តី ការដឹង ការឃើញ ( នូវហេតុទាំងពួង ) តែង តម្កល់នៅស៊ប់ សព្វពេលវេលា ជានិរន្តរ៍ ។ និគ្គណ្ឋនាដបុត្តនោះនិយាយ យ៉ាងនេះថា អញតែងដឹង តែងឃើញនូវលោកដែលមិនមានទីបំផុត ដោយសារ ញាណមិនមានទីបំផុត ។ បពិត្រព្រះគោតមដ៏ចម្រើន បណ្តាញាណវាទៈទាំង ២ និងវិបច្ចនិកវាទៈ ទៅវិញទៅមកទាំង ២ នេះ តើវាទៈណាពិត វាទៈណា កុហក ។*

*ម្នាលព្រាហ្មណ៍ទាំងឡាយ ណ្ហើយកុំសួរត្រង់ពាក្យថា បណ្តាញាណ វាទៈទាំង ២ និងវិបច្ចនិកវាទៈ ទៅវិញទៅមកទាំង ២ នេះ តើវាទៈណាពិត វាទៈណាកុហក ដូច្នេះនុ៎ះ ចូរផ្អាកទុកទៅចុះ ម្នាលព្រាហ្មណ៍ទាំងឡាយ តថាគតនឹងសម្តែងធម៌ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់ធម៌នោះ សិន ចូរធ្វើទុកក្នុងចិត្តឲ្យល្អ តថាគតនឹងសម្តែង ។ ព្រាហ្មណ៍ទាំងនោះ បាន ទទួលស្តាប់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ទាំងឡាយ ដូចបុរស ៤ នាក់ ឈរនៅក្នុង ទិសទាំង ៤ ដែលបរិបូណ៌ដោយដំណើរ របស់បុរសផង ដោយសម្ទុះផង ដោយដំហានជើងដ៏រហ័សក្រៃលែងផង ជាអ្នកប្រកបដោយសម្ទុះ មានសភាព*

យ៉ាងនេះឯង ( ក្នុងបុរសម្នាក់ៗ សុទ្ធតែជាអ្នកប្រកប ) ដោយជំហានជើង ( ដែលអាចដើរឆ្លងចក្កវាឡដោយឆាប់រហ័សបាន ) មានសភាពដូចជាខ្មាន់ធ្នូដែលខ្លាំងពូកែ បានសិក្សារួចហើយ មានដៃស្ទាត់ហើយ ធ្លាប់ចូលចំណោមហើយ ក៏យកព្រួញដ៏ស្រាល បាញ់ស្រមោលដើមត្នោត ត្រង់ពាក់កណ្តាលដើមដោយមិនលំបាកដូច្នោះឯង មានតួយ៉ាងដូចសមុទ្រទិសខាងកើត និងសមុទ្រទិសខាងលិច គ្រានោះ បុរសដែលឈរក្នុងទិសខាងកើត និយាយយ៉ាងនេះថា អញនឹងដើរទៅឲ្យដល់ទីបំផុតនៃលោក បុរសនោះមានអាយុ ១០០ ឆ្នាំ រស់នៅ ១០០ ឆ្នាំ ក៏ដើរទៅអស់ ១០០ ឆ្នាំ ( មិនឈប់ ) វៀរលែងតែស៊ី ទំពាស៊ី លិទ្ធភ្លក់អាហារ វៀរលែងតែការធ្វើឧច្ចារៈ និងបស្សាវៈ វៀរលែងតែដេក និងការបន្ទោរបង់នូវសេចក្តីនឿយហត់ចេញ ក៏មិនបានដល់ដូចបំណងឡើយ ហើយធ្វើមរណកាលក្នុងទីជាចន្លោះៗ នៃលោក ចំណែកបុរសដែលឈរក្នុងទិសខាងលិច ។បេ។ ចំណែកបុរសដែលឈរ ក្នុងទិសខាងត្បូង ក៏និយាយយ៉ាងនេះថា អញនឹងដើរទៅឲ្យដល់ទីបំផុតនៃលោក បុរសនោះ មានអាយុ ១០០ ឆ្នាំ រស់នៅ ១០០ ឆ្នាំ ក៏ដើរទៅអស់ ១០០ ឆ្នាំ ( មិនឈប់ ) វៀរលែងតែស៊ី ទំពាស៊ី លិទ្ធភ្លក់អាហារ វៀរលែងតែការធ្វើឧច្ចារៈ និងបស្សាវៈ វៀរលែងតែដេក និងការបន្ទោរបង់នូវសេចក្តីនឿយហត់ចេញ ក៏មិនបានដល់ដូចបំណងឡើយ ហើយធ្វើមរណកាលក្នុងទីជាចន្លោះៗ នៃលោក ដំណើរនុ៎ះ ព្រោះហេតុអ្វី ម្នាលព្រាហ្មណ៍ទាំងឡាយ

ព្រោះតថាគតមិនពោលថា ទីបំផុតនៃលោក បុគ្គលត្រូវដឹង ត្រូវឃើញ ត្រូវទៅដល់បាន ដោយសារសម្ទុះដើរ មានសភាពយ៉ាងនោះឡើយ ។ ម្នាលព្រាហ្មណ៍ទាំងឡាយ ឯតថាគតមិនធ្លាប់ពោលអំពីដំណើរសត្វ ដែលមិនទាន់បានដល់នូវទីបំផុតនៃលោកហើយ ( ថា ) ធ្វើនូវទីបំផុតនៃទុក្ខសោះឡើយ ។

ម្នាលព្រាហ្មណ៍ទាំងឡាយ កាមគុណ ៥ ប្រការនេះ តថាគតហៅថា លោក លោកក្នុងអរិយវិន័យ ។ កាមគុណ ៥ ប្រការនោះ តើដូចម្តេចខ្លះ ។ រូបទាំងឡាយ ដែលគប្បីដឹងបាន ដោយចក្ខុជាទីប្រាថ្នា ត្រេកអរ ពេញចិត្ត មានសភាព ជាទីស្រឡាញ់ ប្រកបដោយកាម ជាទីគាប់ចិត្ត ១ សំឡេងទាំងឡាយ ដែលគប្បីដឹងដោយត្រចៀក ១ ។បេ។ ក្លិនទាំងឡាយ ដែលគប្បីដឹងដោយច្រមុះ ១ រសទាំងឡាយ ដែលគប្បីដឹងដោយអណ្តាត ១ ផោដ្ឋព្វៈទាំងឡាយ ដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ត្រេកអរ ពេញចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាម ជាទីគាប់ចិត្ត ១ ។ ម្នាលព្រាហ្មណ៍ទាំងឡាយ កាមគុណ ៥ ប្រការនេះឯង តថាគតហៅថា លោក លោកក្នុងអរិយវិន័យ ។

ម្នាលព្រាហ្មណ៍ទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំង-ឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយបានដល់បឋមជ្ឈាន ដែលប្រកបដោយវិតក្ក និងវិចារៈ មានបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ។ ម្នាលព្រាហ្មណ៍ទាំងឡាយ ភិក្ខុនេះតថាគតហៅថា បានដល់ទីបំផុត

នៃលោក ឋិតនៅក្នុងបំផុតនៃលោក ។ ពួកជនឯទៀត បាននិយាយចំពោះភិក្ខុនោះយ៉ាងនេះថា ភិក្ខុនេះរាប់បញ្ចូលក្នុងលោកផង ភិក្ខុនេះ មិនរលាស់ចេញចាកលោកបានផង ។ ម្នាលព្រាហ្មណ៍ទាំងឡាយ ឯតថាគតក៏ពោលយ៉ាងនេះថា ភិក្ខុនេះ រាប់បញ្ចូលក្នុងលោកផង ភិក្ខុនេះ មិនរលាស់ចេញចាកលោកបានផង ដូច្នេះដែរ ។

ម្នាលព្រាហ្មណ៍ទាំងឡាយ មួយទៀត ភិក្ខុ ព្រោះរម្ងាប់វិតក្កៈ និងវិចារៈ ។បេ។ ក៏បានដល់ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ។ ម្នាលព្រាហ្មណ៍ទាំងឡាយ ភិក្ខុនេះ តថាគតហៅថា បានដល់ទីបំផុតនៃលោក ឋិតនៅក្នុងបំផុតនៃលោក ។ ពួកជនឯទៀត បាននិយាយចំពោះ ភិក្ខុនោះយ៉ាងនេះថា ភិក្ខុនេះ រាប់បញ្ចូលក្នុងលោកផង ភិក្ខុនេះ មិនរលាស់ចេញចាកលោកបានផង ។ ម្នាលព្រាហ្មណ៍ទាំងឡាយ ឯតថាគតក៏ពោលយ៉ាងនេះថា ភិក្ខុនេះ រាប់បញ្ចូលក្នុងលោកផង ភិក្ខុនេះ មិនរលាស់ចេញចាកលោកបានផង ដូច្នេះដែរ ។

ម្នាលព្រាហ្មណ៍ទាំងឡាយ មួយទៀត ភិក្ខុ ព្រោះកន្លងបង់រូបសញ្ញា ព្រោះរលត់បដិឃសញ្ញា ព្រោះធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ក៏បានដល់អាកាសានញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុត ។ ម្នាលព្រាហ្មណ៍ទាំងឡាយ ភិក្ខុនេះ តថាគតហៅថា បានដល់ទីបំផុតនៃលោក ឋិតនៅក្នុងបំផុតនៃលោក ។ ពួកជនឯទៀត បាននិយាយ

ចំពោះភិក្ខុនោះយ៉ាងនេះថា ភិក្ខុនេះ រាប់បញ្ចូលក្នុងលោកផង ភិក្ខុនេះ មិនទាន់រលាស់ចេញចាកលោកបានផង ។ ម្នាលព្រាហ្មណ៍ទាំងឡាយ ឯតថាគតក៏ពោលយ៉ាងនេះថា ភិក្ខុនេះ រាប់បញ្ចូលក្នុងលោកផង ភិក្ខុនេះ មិនទាន់រលាស់ចេញចាកលោកបានផង ដូច្នេះដែរ ។

ម្នាលព្រាហ្មណ៍ទាំងឡាយ មួយទៀត ភិក្ខុ ព្រោះកន្លងបង់អាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់វិញ្ញាណញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុត ។បេ។ ព្រោះកន្លងបង់វិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់អាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អ្វីតិចតួចមិនមាន ព្រោះកន្លងបង់អាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នេវសញ្ញានាសញ្ញាយតនជ្ឈាន ។ ម្នាលព្រាហ្មណ៍ទាំងឡាយ ភិក្ខុនេះ តថាគតហៅថា បានដល់ទីបំផុតនៃលោក ឋិតនៅក្នុងបំផុតនៃលោក ។ ពួកជនឯទៀត បាននិយាយចំពោះភិក្ខុនោះយ៉ាងនេះថា ភិក្ខុនេះ រាប់បញ្ចូលក្នុងលោកផង ភិក្ខុនេះ មិនទាន់រលាស់ចេញចាកលោកបានផង ។ ម្នាលព្រាហ្មណ៍ទាំងឡាយ តថាគតក៏និយាយយ៉ាងនោះថា ភិក្ខុនេះ រាប់បញ្ចូលក្នុងលោកផង ភិក្ខុនេះ មិនទាន់រលាស់ចេញចាកលោកបានផង ដូច្នេះដែរ ។

ម្នាលព្រាហ្មណ៍ទាំងឡាយ មួយទៀត ភិក្ខុព្រោះកន្លងបង់នេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់សញ្ញាវេទយិតនិរោធ ។

អាសវៈរបស់ភិក្ខុនោះ ក៏អស់រលីងទៅ ព្រោះយល់ឃើញដោយប្រាជ្ញា ។ ម្នាលព្រាហ្មណ៍ទាំងឡាយ ភិក្ខុនេះ តថាគតហៅថា បានដល់ទីបំផុតនៃលោក ឋិតនៅក្នុងទីបំផុតនៃលោក បានឆ្លងផុតនូវតណ្ហាក្នុងលោកហើយ ។

# អដ្ឋកថា

## ព្រាហ្មណសូត្រ

[ ៣៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងព្រាហ្មណសូត្រទី ៧ ដូចតទៅនេះ បទថា **លោកាយតិកា** បានដល់ ព្រាហ្មណ៍ដែលបង្រៀនគម្ពីរលោកាយតៈ ។ បទថា **សតតំ** គឺក្នុងកាលគ្រប់កាល ។ បទថា **សមិតំ** បានដល់ មិនមានរវាងចន្លោះ ។ បទថា **តិដ្ឋតេតំ** កាត់បទជា **តិដ្ឋតុ ឯតំ** ប្រែថា សេចក្តីនេះលើកទុកសិនចុះ គឺពួកអ្នកកុំផ្តើមដល់រឿងនេះឡើយ មិនមានប្រយោជន៍អ្វីដល់ពួកអ្នកទេ ។ បទថា **ធម្មំ វោ ព្រាហ្មណា ទេសេស្សាមិ** សេចក្តីថា តថាគតនឹងសម្តែងធម៌ដល់ពួកអ្នក ។ បទថា **ទឡ្ហធម្មោ** បានដល់ ខ្មាន់ធ្នូឈរកាន់ធ្នូធ្ងន់ ។ បទថា **ធនុគ្គហោ** បានដល់ ខ្មាន់ធ្នូ ។ ឈ្មោះថា ធ្នូធ្ងន់ លោកពោលថា ត្រូវប្រើកម្លាំងមនុស្ស ២០០០ នាក់ ដើម្បីលើក ។ ឈ្មោះថា ប្រើកម្លាំងមនុស្ស ២០០០ នាក់ កាន់ខ្សែធ្នូជាលោហៈ កាលនឹងលើក ក៏ចាប់ដងធ្នូលើកឡើង រហូតដល់ក ទើបផុតផែនដី ។ បទថា **សិក្ខិតោ** បាន

រៀនសិប្បៈក្នុងសម្នាក់អាចារ្យអស់ ២២ ឆ្នាំ ។

បទថា **កតហត្ថោ** បានដល់ នាយខ្មាន់ធ្នូម្នាក់សិក្សាសិប្បៈប៉ុណ្ណោះ មិនបានប្រឡងថ្វីដៃ តែនាយខ្មាន់ធ្នូនេះ បានប្រឡងថ្វីដៃហើយ គឺមានការជំនាញច្រើន ។ បទថា **កតុបាសនោ** បានដល់ បង្ហាញថ្វីដៃក្នុងរាជត្រកូលមកហើយ ។ បទថា **លហុកេន អសនេន** បានដល់ ដោយព្រួញដែលស្រាលធ្វើខាងក្នុងឲ្យជាប្រហោង យកសំឡីជាដើមញាត់ពេញ ធ្វើជាសញ្ញា ពិតហើយ ព្រួញធម្មតាដែលធ្វើបាញ់ស្ទុះទៅត្រឹមមួយឧសភៈ តែព្រួញរបស់នាយខ្មាន់ធ្នូ ហើរទៅបាន ២ ឧសភៈ ។បេ។ ព្រួញធម្មតាស្ទុះទៅបាន ៨ ឧសភៈ តែព្រួញរបស់នាយខ្មាន់ធ្នូស្ទុះទៅបាន ១៦ ឧសភៈ ។ បទថា **អប្បកសិរេន** គឺដោយមិនលំបាក ។ បទថា **អតិបាតេយ្យ** គឺកន្លងទៅបាន អធិប្បាយថា ខ្មាន់ធ្នូនោះឈានកន្លងស្រមោលប្រមាណ ១ ចំអាម ៤ ធ្នាប់ បានដោយឆាប់រួសរាន់ យ៉ាងណា បុគ្គលមានសម្ទុះជើងរហ័ស អាចឈានរំលងចក្កវាឡបានឆាប់ ដូច្នោះ ។ បទថា **សន្ធាវនិកាយ** បានដល់ ស្ទុះទៅដោយជើង ។ បទថា **ឯវមាហំសុ** ប្រែថា បានពោលហើយយ៉ាងនេះ ។៚

**អដ្ឋកថា ព្រាហ្មណសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ទេវសូត្រទី ៨

[ ៣៩ ] ម្នាលភិក្ខុទាំងឡាយ មានរឿងពីព្រេងនាយមកថា សង្គ្រាមនៃអសុរ មួយអន្ទើដោយពួកទេវតា ជាសង្គ្រាមតទល់ប្រឡូកកៀកគ្នាហើយ ម្នាលភិក្ខុទាំងឡាយ ក្នុងសង្គ្រាមនោះឯង ពួកអសុរឈ្នះ ពួកទេវតាចាញ់ ម្នាលភិក្ខុទាំងឡាយ លុះពួកទេវតាបរាជ័យហើយ ក៏បានរត់ឆ្ពោះមុខទៅកាន់ទិសខាងជើង ពួកអសុរក៏ដេញតាម ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ពួកទេវតាមានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកអសុរ នាំគ្នានៅតែដេញតាមមិនលែងសោះ បើដូច្នោះ គួរតែពួកយើងតយុទ្ធនឹងពួកអសុរឲ្យអស់ពីរគ្រា ។

ម្នាលភិក្ខុទាំងឡាយ ពួកទេវតា បានតយុទ្ធនឹងពួកអសុរ ក្នុងលើកទី ២ ទៀត ម្នាលភិក្ខុទាំងឡាយ ក្នុងលើកទី ២ នោះឯង ពួកអសុរឈ្នះ ពួកទេវតាចាញ់ ( ទៀត ) ។ ម្នាលភិក្ខុទាំងឡាយ លុះពួកទេវតាបរាជ័យហើយ ក៏បានរត់ឆ្ពោះមុខទៅកាន់ទិសខាងជើង ពួកអសុរក៏នាំគ្នាដេញតាម ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ពួកទេវតាមានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកអសុរនៅតែនាំគ្នាដេញតាមមិនលែងសោះ បើដូច្នោះ គួរតែពួកយើងតយុទ្ធនឹងពួកអសុរឲ្យអស់បីគ្រា ។

ម្នាលភិក្ខុទាំងឡាយ ពួកទេវតា បានតយុទ្ធនឹងពួកអសុរ ក្នុងលើកទី ៣ ទៀត ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលើកទី ៣ នោះឯង ពួកអសុរឈ្នះ ពួកទេវតាចាញ់ ( ទៀត ) ។ ម្នាលភិក្ខុទាំងឡាយ លុះពួកទេវតាបរាជ័យ

ហើយ ក៏ភ័យរត់ចូលក្នុងទេវបុរីវិញ ។ ម្នាលភិក្ខុទាំងឡាយ ឯងពួកទេវតា ដែលបានចូលទៅដល់ទេវបុរីហើយ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ ពួកយើងមានខ្លួនបានដល់នូវទីការពារភ័យហើយ ទាំងពួកអសុរ ក៏មិនគប្បី ធ្វើអ្វីយើងបាន ។ ម្នាលភិក្ខុទាំងឡាយ ចំណែកពួកអសុរ មានសេចក្តីត្រិះរិះ យ៉ាងនេះថា ឥឡូវនេះ ពួកទេវតាមានខ្លួនបានដល់នូវទីការពារភ័យហើយ ពួកយើងមិនគប្បីធ្វើអ្វីបានទេ ។

ម្នាលភិក្ខុទាំងឡាយ មានរឿងពីព្រេងនាយមកថា សង្គ្រាមនៃអសុរ មួយអន្លើដោយទេវតា ជាសង្គ្រាមតទល់ប្រឡូកកៀកគ្នាហើយ ។ ម្នាលភិក្ខុ ទាំងឡាយ ក្នុងសង្គ្រាមនោះឯង ពួកទេវតាឈ្នះ ពួកអសុរចាញ់ ម្នាលភិក្ខុ ទាំងឡាយ លុះពួកអសុរបរាជ័យហើយ ក៏បានរត់ឆ្ពោះមុខទៅទិសខាងត្បូង ពួកទេវតាក៏នាំគ្នាដេញតាម ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ពួកអសុរ មានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកទេវតានៅតែនាំគ្នាដេញតាមមិនលែងសោះ បើដូច្នោះ គួរតែពួកយើងតយុទ្ធនឹងពួកទេវតាឲ្យអស់ពីរគ្រាចុះ ។

ម្នាលភិក្ខុទាំងឡាយ ពួកអសុរ បានតយុទ្ធនឹងទេវតា ក្នុងលើកទី ២ ទៀត ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលើកទី ២ នោះឯង ពួកទេវតាឈ្នះ ពួក អសុរចាញ់ទៀត ម្នាលភិក្ខុទាំងឡាយ លុះពួកអសុរបរាជ័យហើយ ក៏បានរត់ ឆ្ពោះមុខទៅកាន់ទិសខាងត្បូង ពួកទេវតាក៏នាំគ្នាដេញតាម ។ ម្នាលភិក្ខុ ទាំងឡាយ គ្រានោះឯង ពួកអសុរមានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកទេវតា

នៅតែនាំគ្នាដេញតាមមិនលែងសោះ បើដូច្នោះ គួរតែពួកយើងតយុទ្ធនឹងពួកទេវតា ឲ្យអស់បីគ្រា ។

ម្នាលភិក្ខុទាំងឡាយ ពួកអសុរច្បាំងតនឹងពួកទេវតា ក្នុងលើកទី ៣ ទៀត ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលើកទី ៣ នោះឯង ពួកទេវតាឈ្នះពួកអសុរចាញ់ទៀត ម្នាលភិក្ខុទាំងឡាយ លុះពួកអសុរបរាជ័យហើយ ក៏ភ័យរត់ចូលទៅកាន់អសុរបុរី ម្នាលភិក្ខុទាំងឡាយ ឯពួកអសុរដែលទៅដល់អសុរបុរីហើយ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ ពួកយើងមានខ្លួនបានដល់នូវទីការពារភ័យហើយ ទាំងពួកទេវតា ក៏មិនគប្បីធ្វើអ្វីយើងបាន ។ ម្នាលភិក្ខុទាំងឡាយ ចំណែកពួកទេវតា មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះពួកអសុរមានខ្លួនបានដល់នូវទីការពារភ័យហើយ ពួកយើងមិនគប្បីធ្វើអ្វីបានទេ ។

ម្នាលភិក្ខុទាំងឡាយ រឿងនេះមានឧបមេយ្យ ដូចភិក្ខុដែលស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយបានដល់បឋមជ្ឈានប្រកបដោយវិតក្ក និងវិចារៈ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ក្នុងសម័យណា ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា អញមានខ្លួនបានដល់នូវធម៌ជាគ្រឿងការពារភ័យហើយ មារមិនគប្បីធ្វើអ្វីអញបាន ម្នាលភិក្ខុទាំងឡាយ ចំណែកមារមានចិត្តបាប មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ ភិក្ខុមានខ្លួនបានដល់នូវគ្រឿងការពារភ័យហើយ អញ

មិនគប្បីធ្វើអ្វីបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ព្រោះរម្ងាប់វិតក្កៈ និងវិចារៈ ។បេ។ ក៏បានដល់ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ក្នុងសម័យណា ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ អញមានខ្លួនបានដល់នូវគ្រឿងការពារភ័យហើយ មារមិនគប្បីធ្វើអ្វីអញបាន ម្នាលភិក្ខុទាំងឡាយ ចំណែកមារមានចិត្តបាប ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ ភិក្ខុមានគ្រឿងការពារភ័យបានហើយ អញមិនគប្បីធ្វើអ្វីបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុព្រោះកន្លងបង់រូបសញ្ញា ព្រោះរលត់បដិឃសញ្ញា ព្រោះមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង ក៏បានដល់អាកាសានញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុត ក្នុងសម័យណា ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ភិក្ខុនេះតថាគតហៅថា បានធ្វើមារឲ្យផុតដើង ហៅថា រុំខ្ទប់ភ្នែកមារឲ្យជិតស្លុង ហៅថា ដល់នូវការមិនឃើញនៃមារ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ព្រោះកន្លងបង់អាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់វិញ្ញាណញ្ចាយតនជ្ឈាន ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត ។បេ។ ភិក្ខុព្រោះកន្លងបង់វិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់អាកិញ្ចញ្ញាយតនជ្ឈាន ដោយកាធ្វើទុកក្នុងចិត្តថា អ្វីតិចតួចមិនមាន ។បេ។ ភិក្ខុ ព្រោះកន្លងបង់អាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នេវសញ្ញានាសញ្ញាយតនជ្ឈាន ។បេ។ ភិក្ខុ ព្រោះកន្លងបង់នេវសញ្ញានា-

សញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់សញ្ញាវេទយិតនិរោធ អាសវៈរបស់ភិក្ខុនោះ ក៏អស់រលីងទៅ ព្រោះឃើញដោយប្រាជ្ញា ក្នុងសម័យណា ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ភិក្ខុនេះ តថាគតហៅថា បានធ្វើមារឲ្យផុតដើង ហៅថា រំខូបក្នែកមារឲ្យជិតស្ងួង ហៅថា បានដល់នូវការមិនឃើញនៃមារ ហៅថា ឆ្លងផុតនូវតណ្ហាក្នុងលោកហើយ ។

# អដ្ឋកថា

## ទេវសូត្រ

[ ៣៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទេវសូត្រទី ៨ ដូចតទៅនេះ បទថា **សមុបព្យូឡ្ហោ អហោសិ** គឺបានប្រឈមមុខគ្នាហើយ ។ បទថា **សង្គា-មេយ្យាម** បានដល់ ធ្វើសង្គ្រាម គឺច្បាំងគ្នា ។ បទថា **អបសក្កិំសុ** បានដល់ ពួកទេវតានាំគ្នាគេចទៅ ។ បទថា **ឧត្តរាភិមុខា** គឺបែរមុខទៅកាន់ទិសឧត្តរ ។ បទថា **អភិភយន្តេវ** បានដល់ ដេញតាមទៅ ។ បទថា **ភីរុត្តាណគតេន** បានដល់ ទៅរកទីពឹងពួន ដើម្បីការពារសេចក្តីខ្លាច គឺហាមសេចក្តីខ្លាច ។ បទថា **អករណីយា** បានដល់ ពួកអសុរធ្វើការច្បាំងមិនបាន ។

សួរថា ព្រោះហេតុអ្វី ទើបពួកទេវតា និងពួកអសុរច្បាំងគ្នា ឆ្លើយថា

ព្រោះពួកអសុរធ្លាប់នៅក្នុងភពតាវត្តិង្សមកអំពីមុន កាលដល់ពេលផ្កាចិត្ត-បាតលីក ពួកអសុររឭកដល់ផ្កាបារិច្ឆត្តកៈដែលជាទិព្វ បន្ទាប់អំពីនោះ ពួកអសុរក៏កើតការខឹងសម្បាឡើង ពោលថា ពួកអ្នកចូរចាប់ទេវតា ដូច្នេះហើយនាំគ្នាឡើងភ្នំសិនេរុ ប្រឈមមុខគ្នាហើយ ពួកទេវតាក៏នាំគ្នាចេញមក ។ ការច្បាំងរបស់ទេវតា និងអសុរទាំងនោះ ដូចគ្នានឹងក្មេងឃ្វាលគោ យកដំបងវាយគ្នានិងគ្នា ។ សក្កទេវរាជតាំងការរក្សាក្នុងទី ៥ កន្លែងខាងក្រោមចំណែកខាងលើ ទ្រង់តាំងរូបសិប្បនិម្មិត ព្រះហស្តកាន់វជិរាវុធ ការពារទេវបុរី ។ ពួកអសុរឆ្លងទៅដល់ទី ៥ កន្លែងខាងក្រោម ឃើញឥន្ទប្បដិមាទើបនាំគ្នាត្រឡប់ទៅកាន់អសុរបុរីមួយរំពេច ។

បទថា **ទក្ខិណេន មុខា** បានដល់ បែរមុខទៅទិសទក្សិណ ។ បទថា **អបទំ វធិត្វា** បានដល់ មិនឲ្យសល់គន្លងជើង ។ បទថា **អទស្សនំ គតោ** សេចក្តីថា មារក៏ដឹងចិត្តរបស់ភិក្ខុដែលចូលរូបាវចរចតុត្ថជ្ឈាន ដែលមានវដ្តៈជាបាទ ដឹងចិត្តភិក្ខុដែលចូលសមាបត្តិដែលមានវិបស្សនាជាបាទនោះឯង មាររមែងមិនដឹងចិត្តរបស់ភិក្ខុ ដែលចូលអរូបាវចរសមាបត្តិ ដែលមានវដ្តៈជាបាទ ឬមានវិបស្សនាជាបាទ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **អទស្សនំ គតោ បាបិមតោ** ដូច្នេះ ។៚

## អដ្ឋកថា នវសូត្រទី ៨ ចប់

# សុត្តន្តបិដក

## ឆាគសូត្រទី ៩

[ ៤០ ] ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ដំរីឈ្មោលក្តី ដំរីញីក្តី ដំរីស្ទាវក្តី កូនដំរីក្តី ទៅកាត់ចុងស្មៅមុនៗ ជាងដំរីដ៏ប្រសើរ ដែលនៅក្នុងព្រៃ ខ្វល់ខ្វាយរកចំណី ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ដំរីដ៏ប្រសើរនៅក្នុងព្រៃ តែងធុញទ្រាន់ នឿយណាយ ជិនឆ្អន់ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ដំរីឈ្មោលក្តី ដំរីញីក្តី ដំរីស្ទាវក្តី កូនដំរីក្តី ទំពាស៊ីមែកឈើបាក់ ដែលដំរីដ៏ប្រសើរ នៅក្នុងព្រៃខ្វល់ខ្វាយរកចំណី បានកាច់បំបាក់ខ្ទេចខ្ទីហើយ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ដំរីដ៏ប្រសើរ នៅក្នុងព្រៃ តែងធុញទ្រាន់ នឿយណាយ ជិនឆ្អន់ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ដំរីដ៏ប្រសើរនៅក្នុងព្រៃ ចុះកាន់កំពង់ទឹក ដំរីឈ្មោលក្តី ដំរីញីក្តី ដំរីស្ទាវក្តី កូនដំរីក្តី តែងទៅកូរទឹកដោយប្រមោយមុនៗ ( ជាងដំរីនោះ ) ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ដំរីដ៏ប្រសើរនៅក្នុងព្រៃ រមែងធុញទ្រាន់ នឿយណាយ ជិនឆ្អន់ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ដំរីដ៏ប្រសើរ នៅក្នុងព្រៃ ចុះកាន់កំពង់ទឹក ដំរីញីទាំងឡាយ តែងដើរជជុសកាយ ម្នាលភិក្ខុទាំង-ឡាយ ព្រោះហេតុនោះ ដំរីដ៏ប្រសើរ នៅក្នុងព្រៃ រមែងធុញទ្រាន់ នឿយណាយ ជិនឆ្អន់ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ដំរីដ៏ប្រសើរ នៅក្នុងព្រៃ មានសេចក្តីត្រិះរិះយ៉ាងនេះថា ក្នុងកាលឥឡូវនេះ អញនៅច្រឡូកច្រឡំ ដោយដំរីឈ្មោល ដំរីញី ដំរីស្ទាវ កូនដំរី អញតែងទំពាស៊ីស្មៅដែល

ដំរីទាំងនោះកាត់ចុងផង អញទំពាស៊ីមែកឈើបាក់ ដែលដំរីទាំងនោះ កាច់បំបាក់ខ្ទេចខ្ទីហើយផង អញផឹកទឹកដ៏ល្អក់ផង កាលដែលអញឡើងអំពីកំពង់ទឹក ដំរីញីទាំងឡាយ តែងដើរជជុសកាយផង បើដូច្នោះ គួរតែអញគេចចេញចាកហ្វូងទៅនៅតែម្នាក់ឯង ។ ក្នុងសម័យខាងក្រោយមក ដំរីនោះក៏គេចចេញចាកហ្វូង ទៅនៅតែម្នាក់ឯង ក៏ទំពាស៊ីនូវស្មៅមិនរេចចុងផង មិនទំពាស៊ីមែកឈើបាក់ ដែលដំរីទាំងនោះ កាច់បំបាក់ខ្ទេចខ្ទីហើយផង ផឹកទឹកមិនល្អក់ផង កាលដែលឡើងអំពីកំពង់ទឹក ដំរីញីទាំងឡាយ មិនបានដើរជជុសកាយផង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ដំរីដ៏ប្រសើរនៅក្នុងព្រៃ មានសេចក្តីត្រិះរិះយ៉ាងនេះថា ក្នុងកាលពីដើម អញនៅច្រឡូកច្រឡំ ដោយដំរីឈ្មោល ដំរីញី ដំរីស្ទាវ កូនដំរី អញទំពាស៊ីនូវស្មៅ ដែលដំរីទាំងនោះ កាត់ចុងហើយផង អញទំពាស៊ីនូវមែកឈើបាក់ ដែលដំរីទាំងនោះ កាច់បំបាក់ខ្ទេចខ្ទីហើយផង អញផឹកទឹកល្អក់ផង កាលដែលអញឡើងអំពីកំពង់ទឹក ដំរីញីទាំងឡាយ ដើរជជុសកាយផង ឥឡូវនេះ អញនោះ ចៀសចេញចាកហ្វូងមកនៅតែម្នាក់ឯង បានទំពាស៊ីនូវស្មៅមិនមានរេចចុងផង អញមិនទំពាស៊ីមែកឈើបាក់ដែលដំរីទាំងនោះ កាច់បំបាក់ខ្ទេចខ្ទីហើយផង អញផឹកទឹកមិនល្អក់ផង កាលដែលអញឡើងអំពីកំពង់ទឹក ដំរីញីទាំងឡាយមិនដើរជជុសកាយអញផង ។ ដំរីនោះ ក៏កាច់បំបាក់មែកឈើដោយប្រមោយ ហើយយកមែកឈើបាក់នោះមកបបោសកាយ មានចិត្តត្រេកអរ កម្ចាត់បង់សេចក្តី

ស្មៀបរមាស់ ។ម្នាលភិក្ខុទាំងឡាយ រឿងនេះ មានឧបមេយ្យដូចជាភិក្ខុដែលនៅច្រឡូកច្រឡំ ដោយពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ព្រះរាជា រាជមហាមាត្យ តិរ្ថិយ និងសាវ័កនៃតិរ្ថិយ ក្នុងសម័យណា ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ភិក្ខុរមែងមានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ អញនៅច្រឡូកច្រឡំ ដោយពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ព្រះរាជា រាជមហាមាត្យ តិរ្ថិយ និងសាវ័កនៃតិរ្ថិយ បើដូច្នោះ គួរតែអញគេចចេញចាកពួកទៅនៅតែម្នាក់ឯង ។ ភិក្ខុនោះ រមែងគប់រកនូវសេនាសនៈស្ងាត់ គឺព្រៃគល់ឈើ ភ្នំ ញកភ្នំ គុហាភ្នំ ព្រៃស្មសាន ព្រៃស្រោង ទីវាល គំនរចំបើង ភិក្ខុនោះ ទៅនៅក្នុងព្រៃក្តី នៅក្នុងម្លប់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងអង្គុយពែនភ្នែន តម្រង់កាយឲ្យត្រង់ហើយ តាំងស្មារតីឲ្យឆ្ពោះមុខទៅកាន់កម្មដ្ឋាន ភិក្ខុនោះ លះបង់អភិជ្ឈាក្នុងលោក ក៏មានចិត្តប្រាសចាកអភិជ្ឈា ធ្វើចិត្តឲ្យបរិសុទ្ធចាកអភិជ្ឈា ។ លះបង់នូវការប្រទូស្ត គឺព្យាបាទ ជាអ្នកមិនមានចិត្តព្យាបាទ ជាអ្នកអនុគ្រោះដោយប្រយោជន៍ ដល់សត្វទាំងពួង ធ្វើចិត្តឲ្យស្អាតចាកការប្រទូស្ត គឺព្យាបាទ ។ លះបង់ថីនមិទ្ធៈ ជាអ្នកប្រាសចាកថីនមិទ្ធៈ មានសេចក្តីសម្គាល់នូវពន្លឺ មានស្មារតី ជាអ្នកដឹងខ្លួន ធ្វើចិត្តឲ្យស្អាតចាកថីនមិទ្ធៈ។ លះបង់ឧទ្ធច្ចកុក្កុច្ចៈ ជាអ្នកមានចិត្តមិនរវើរវាយ មានចិត្តស្ងប់រម្ងាប់ខាងក្នុងសន្តាន ធ្វើចិត្តឲ្យស្អាតចាកឧទ្ធច្ចកុក្កុច្ចៈ ។ លះបង់វិចិកិច្ឆា ជាអ្នកឆ្លងផុតវិចិកិច្ឆា មិនមានសេចក្តីងឿងឆ្ងល់ ក្នុងកុសលធម៌ទាំងឡាយ ហើយធ្វើចិត្តឲ្យ

ស្អាតចាកវិចិកិច្ឆា ។ ភិក្ខុនោះ លុះលះបង់នូវនីវរណៈទាំង ៥ ប្រការ ដែលជាឧបក្កិលេសនៃចិត្ត ជាធម៌ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយនេះហើយ ក៏ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយបានដល់បឋមជ្ឈានប្រកបដោយវិតក្ក និងវិចារៈ មានបីតិ និងសុខដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ភិក្ខុនោះ រមែងមានចិត្តក្រេតអរ កម្ចាត់បង់នូវសេចក្តីស្កៀបរមាស់ ។ ព្រោះរម្ងាប់បង់នូវវិតក្ក និងវិចារៈ ។បេ។ ក៏បានដល់ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ភិក្ខុនោះ រមែងមានចិត្តត្រេកអរ កម្ចាត់បង់នូវសេចក្តីស្កៀបរមាស់ចេញ ។ ព្រោះកន្លងបង់នូវរូបសញ្ញា ព្រោះរលត់បដិឃសញ្ញា ព្រោះមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញាដោយប្រការទាំងពួង ក៏បានដល់អាកាសានញ្ចាយតនជ្ឈានដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុត ភិក្ខុនោះ រមែងមានចិត្តត្រេកអរ កម្ចាត់បង់នូវសេចក្តីស្កៀបរមាស់ ។ ព្រោះកន្លងបង់នូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់វិញ្ញាណញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុត ។បេ។ ព្រោះកន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់អាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អ្វីតិចតួចមិនមាន ព្រោះកន្លងបង់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នេវសញ្ញានាសញ្ញាយតនជ្ឈាន ព្រោះកន្លងបង់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់សញ្ញាវេទយិតនិរោធ អាសវៈទាំង-

ឡាយ របស់ភិក្ខុនោះ ក៏អស់រលីងទៅ ព្រោះយល់ឃើញដោយប្រាជ្ញា ភិក្ខុនោះ រមែងមានចិត្តត្រេកអរ កម្ចាត់បង់នូវសេចក្ដីស្មៀបរមាស់បាន ។

# អដ្ឋកថា

## នាគសូត្រ

[ ៤០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនាគសូត្រទី ៩ ដូចតទៅនេះ បទថា **អារញ្ញកស្ស** បានដល់ ដំរីនៅក្នុងព្រៃ ។ បទថា **គោចរប្បសុតស្ស** បានដល់ ទៅរកអាហារ ។ បទថា **ហត្ថិកុលភាបិ** បានដល់ កូនដំរីធំៗ ។ បទថា **ហត្ថិច្ឆាចា** បានដល់ កូនដំរីតូច ។ បទថា **ឱភគ្គោភគ្គំ** បានដល់ បង្អោនចុះមកតាំងទុក ។ បទថា **ឱគាហំ ឱតិណ្ណស្ស** បានដល់ ដំរីចុះកាន់កំពង់ទឹកដែលមានឈ្មោះថា **ឱគាហា** ព្រោះជាទីដែលដំរីគប្បីចុះងូតបាន ។ បទថា **ឱគាហា ឧត្តិណ្ណស្ស** បានដល់ ដំរីឡើងអំពីកំពង់ទឹក ។ បទថា **វូបកដ្ឋោ** បានដល់ ចៀសចេញទៅម្នាក់ឯង ។ ឥឡូវនេះ ព្រោះមិនមានកិច្ចដោយដំរីដ៏ប្រសើររបស់ព្រះទសពល តែទ្រង់នាំព្រះតម្រាស់នេះមក ដើម្បីសម្ដែងដល់បុគ្គលដែលប្រៀបដូចដំរីនោះក្នុងព្រះសាសនា ដូច្នោះ កាលទ្រង់សម្ដែងដល់បុគ្គលនោះ ទើបត្រាស់ពាក្យជាដើមថា **ឯវមេវ ខោ** ដូច្នេះ ។

**អដ្ឋកថា នាគសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## តបុស្សសូត្រទី ១០

[ ៤១ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងឧរុវេលកប្ប-និគម របស់ពួកមល្លជន ក្នុងដែនមល្លៈ ។ គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ស្បង់ ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយស្តេចចូលទៅកាន់ឧរុវេលកប្បនិគម ដើម្បីបិណ្ឌបាត ។ លុះស្តេចទៅបិណ្ឌបាតក្នុង ឧរុវេ-លកប្បនិគម ហើយត្រឡប់មកអំពីបិណ្ឌបាត ក្នុងកាលខាងក្រោយភត្តវិញ បានត្រាស់នឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ អ្នកចូរនៅក្នុងទីនេះសិន ទម្រាំតថាគតចូលទៅកាន់មហាវ័ន ( ព្រៃធំ ) ដើម្បីសម្រាកក្នុងវេលាថ្ងៃ ។ ព្រះអានន្ទដ៏មានអាយុ បានទទួលស្តាប់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ស្តេចចូលទៅកាន់មហាវ័ន ហើយគង់សម្រាកក្នុងវេលាថ្ងៃ ក្នុងម្លប់ឈើមួយ ។

លំដាប់នោះ តបុស្សគហបតី បានចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ ថ្វាយបង្គំព្រះអានន្ទដ៏មានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះតបុស្សគហបតី អង្គុយក្នុងទីសមគួរហើយ បានទូលសួរព្រះអានន្ទដ៏មានអាយុដូច្នេះថា បពិត្រព្រះអានន្ទដ៏ចម្រើន យើងជាគ្រហស្ថ ជាអ្នកបរិភោគកាម មានកាមជាគ្រឿងត្រេកអរ ត្រេកអរក្នុងកាម រីករាយក្នុងកាម បពិត្រលោកម្ចាស់ដ៏ចម្រើន នេក្ខម្មៈ គឺបព្វជ្ជា យើងជាគ្រហស្ថ ជាអ្នកបរិភោគកាម មានកាមជាគ្រឿងត្រេកអរ ត្រេកអរក្នុងកាម រីករាយក្នុង

កាម យល់ឃើញប្រាកដថា ដូចជាជ្រោះធំ បពិត្រលោកម្ចាស់ដ៏ចម្រើន យើងខ្ញុំ បានឮថា ពួកភិក្ខុកំលោះៗ ក្នុងធម្មវិន័យនេះ ដែលយល់ឃើញថា នេក្ខម្មៈ គឺ បព្វជ្ជានុ៎ះ ជាធម្មជាតស្ងប់ ដូច្នេះ ចិត្តក៏ស្ទុះទៅ ជ្រះថ្លាតាំងនៅ ចុះស៊ប់ក្នុងនេក្ខម្មៈ គឺបព្វជ្ជា បពិត្រលោកដ៏ចម្រើន នេក្ខម្មៈ គឺបព្វជ្ជា ដែលជារបស់ពួកភិក្ខុក្នុងធម្មវិន័យនេះជាទំទាស់នឹងជន ( ជាគ្រហស្ថ ) ច្រើនគ្នា ។ ព្រះអានន្ទ ដ៏មានអាយុតបថា ម្នាលគហបតី នេះពាក្យជាប្រធាន ដែលនាំឲ្យជួបព្រះដ៏មានព្រះភាគ ម្នាលគហបតី មក យើងទៅ យើងនឹងចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ នឹងក្រាបទូលរឿងនុ៎ះដល់ព្រះដ៏មានព្រះភាគ បើព្រះដ៏មានព្រះភាគ ទ្រង់ព្យាករដល់យើងយ៉ាងណា យើងនឹងធ្វើតាមយ៉ាងនោះ ។ ឯតបុស្សគហបតី ទទួលស្តាប់ព្រះអានន្ទដ៏មានអាយុថា ព្រះករុណាលោកម្ចាស់ដ៏ចម្រើន ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ ជាមួយនឹងតបុស្សគហបតី លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានអាយុ ហើយគង់នៅក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ គង់នៅក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន តបុស្សគហបតីនេះ បាននិយាយនឹងខ្ញុំព្រះអង្គយ៉ាងនេះថា បពិត្រព្រះអានន្ទដ៏ចម្រើន យើងជាគ្រហស្ថ ជាអ្នកបរិភោគកាម មានកាមជាគ្រឿងត្រេកអរ ត្រេកអរក្នុងកាម រីករាយក្នុងកាម បពិត្រលោកម្ចាស់ដ៏ចម្រើន នេក្ខម្មៈ គឺបព្វជ្ជា យើងជាគ្រហស្ថ

ជាអ្នកបរិភោគកាម មានកាមជាគ្រឿងត្រេកអរ ត្រេកអរក្នុងកាម រីករាយក្នុងកាម យល់ឃើញប្រាកដថា ដូចជាជ្រោះធំ បពិត្រលោកម្ចាស់ដ៏ចម្រើន យើងខ្ញុំបានឮថា ពួកភិក្ខុកំលោះៗ ក្នុងធម្មវិន័យនេះ ដែលយល់ឃើញថា នេក្ខម្មៈ គឺ បព្វជ្ជានុ៎ះ ជាធម្មជាតស្ងប់ដូច្នេះ ចិត្តក៏ស្ទុះទៅ ជ្រះថ្លាតាំងនៅ ចុះស៊ប់ក្នុងនេក្ខម្មៈ គឺបព្វជ្ជា បពិត្រលោកម្ចាស់ដ៏ចម្រើន នេក្ខម្មៈ គឺបព្វជ្ជា ដែលជារបស់ពួកភិក្ខុក្នុងធម្មវិន័យនេះ ជាទំទាស់នឹងជន ( ជាគ្រហស្ថ ) ច្រើនគ្នាណាស់ ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ ដំណើរនោះយ៉ាងនេះឯង ម្នាលអានន្ទ ដំណើរនោះយ៉ាងនេះឯង ម្នាលអានន្ទ សូម្បីតថាគតកាលនៅជាពោធិសត្វ មិនទាន់ត្រាស់ដឹង ក្នុងកាលមុន អំពីកាលជាទីត្រាស់ដឹងនូវឡើយ គង់មានសេចក្តីយល់ឃើញថា នេក្ខម្មៈជាគុណជាតប្រពៃ សេចក្តីស្ងប់ស្ងាត់ជាគុណជាតប្រពៃ ដូច្នេះដែរ ។ ម្នាលអានន្ទ តែកាលតថាគតយល់ឃើញថា នេក្ខម្មៈនុ៎ះជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងនេក្ខម្មៈឡើយ ម្នាលអានន្ទ ទើបតថាគតមានសេចក្តីងឿងឆ្ងល់ថា ចុះហេតុអ្វី បច្ច័យអ្វី បានជាកាលអញយល់ឃើញថា នេក្ខម្មៈនុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងនេក្ខម្មៈ ម្នាលអានន្ទ តថាគតមានសេចក្តីយល់ឃើញដូច្នេះថា ឱទោសក្នុងកាមទាំងឡាយ អញមិនទាន់ឃើញទេ ទាំងទោស

នោះ អញមិនទាន់ធ្វើឲ្យច្រើន អានិសង្សក្នុងនេក្ខម្មៈ អញមិនទាន់បានទេ ទាំងអានិសង្សនោះ អញមិនទាន់សេពគប់ទេតើ បានជាកាលអញយល់ឃើញ ថា នេក្ខម្មៈនុ៎ះជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏នៅតែមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុងនេក្ខម្មៈ ម្នាលអានន្ទ ទើបតថាគតមានសេចក្តី ត្រិះរិះដូច្នេះថា បើអញឃើញទោស ក្នុងកាមទាំងឡាយហើយ គប្បីធ្វើនូវ ការឃើញទោសនោះឲ្យច្រើន បើបានអានិសង្សក្នុងនេក្ខម្មៈហើយ គប្បីសេព គប់នូវអានិសង្សនោះ ហេតុនុ៎ះតែងមានជាប្រាកដ ត្រង់ពាក្យថា កាលអញ យល់ឃើញថា នេក្ខម្មៈនុ៎ះជារបស់ស្ងប់ដូច្នេះហើយ ចិត្តគប្បីស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ ក្នុងនេក្ខម្មៈបាន ម្នាលអានន្ទ លុះសម័យខាងក្រោយមក តថាគតនោះ ឃើញទោសក្នុងកាមទាំងឡាយហើយ ក៏ធ្វើនូវការឃើញទោស នោះឲ្យច្រើន បានអានិសង្សក្នុងនេក្ខម្មៈហើយ ក៏សេពគប់អានិសង្សនោះ ម្នាលអានន្ទ កាលតថាគតយល់ឃើញថា នេក្ខម្មៈនុ៎ះជារបស់ស្ងប់ដូច្នេះ ចិត្ត ក៏ត្រឡប់ជាស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ ក្នុងនេក្ខម្មៈឡើង ម្នាលអានន្ទ តថាគតនោះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយចូលទៅកាន់បឋមជ្ឈាន ប្រកបដោយវិតក្ក និងវិចារៈ មានបីតិ និង សុខ កើតអំពីសេចក្តីស្ងប់ស្ងាត់ ។ ម្នាលអានន្ទ កាលតថាគតប្រព្រឹត្ត នៅ ដោយវិហារធម៌នេះ សញ្ញា ( ការសម្គាល់ ) និងមនសិការ ( ការធ្វើទុកក្នុង ចិត្ត ) ប្រកបដោយកាម ក៏ច្រួលច្រាល់ឡើង ការច្រួលច្រាល់នៃសញ្ញា និង

មនសិការនោះ ទុកជាអាពាធរបស់តថាគត ម្នាលអានន្ទ សេចក្តីទុក្ខ គប្បីកើតឡើងដល់បុគ្គលដែលធ្លាប់មានសេចក្តីសុខ សេចក្តីទុក្ខនោះ នឹងប្រព្រឹត្តទៅ ដើម្បីអាពាធជាកំណត់ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចសញ្ញា និងមនសិការ របស់តថាគតប្រកបដោយកាម ដែលច្រួលច្រាល់ឡើង ការច្រួលច្រាល់នៃសញ្ញា និងមនសិការនោះ ទុក្ខជាអាពាធរបស់តថាគតដូច្នោះឯង ។

ម្នាលអានន្ទ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះ គួរតែអញរម្ងាប់បង់នូវវិតក្ក និងវិចារៈ ។បេ។ ហើយចូលទៅកាន់ទុតិយជ្ឈាន ។ ម្នាលអានន្ទ កាលតថាគតយល់ឃើញថា អវិតក្កជ្ឈានន៉ុះ ជារបស់ស្ងប់ ដូច្នេះហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុងអវិតក្កជ្ឈានឡើយ ម្នាលអានន្ទ ទើបតថាគតមានសេចក្តីងឿងឆ្ងល់ថា ចុះហេតុអ្វី បច្ច័យអ្វី បានជាកាលអញយល់ឃើញថា អវិតក្កជ្ឈាន៉ុះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុងអវិតក្កជ្ឈាន ម្នាលអានន្ទ តថាគតមានសេចក្តីយល់ឃើញដូច្នេះថា ឱ ទោសក្នុងវិតក្កជ្ឈានទាំងឡាយ អញមិនទាន់ឃើញ ទាំងទោសនោះអញមិនទាន់ធ្វើឲ្យច្រើន អានិសង្សក្នុងអវិតក្កជ្ឈាន អញមិនទាន់បានទេ ទាំងអានិសង្សនោះ អញមិនទាន់សេពគប់ទេតើ បានជាកាលអញយល់ឃើញថា អវិតក្កជ្ឈាន៉ុះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏នៅតែមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ

មិនចុះស៊ប់ ក្នុងអវិតក្កជ្ឈាន ម្នាលអានន្ទ ទើបតថាគតមានសេចក្ដីត្រិះរិះដូច្នេះថា បើអញឃើញទោសក្នុងវិតក្កជ្ឈានទាំងឡាយហើយ គប្បីធ្វើនូវការឃើញទោសនោះឲ្យច្រើន បើបាននូវអានិសង្សក្នុងអវិតក្កជ្ឈានហើយ គប្បីសេពគប់នូវអានិសង្សនោះ ហេតុនេះ តែងមានជាប្រាកដ ត្រង់ពាក្យថា កាលអញយល់ឃើញថា អវិតក្កជ្ឈាននុ៎ះជារបស់ស្ងប់ ដូច្នេះហើយ ចិត្តគប្បីស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងអវិតក្កជ្ឈានបាន ម្នាលអានន្ទ លុះសម័យខាងក្រោយមក តថាគតនោះ ឃើញនូវទោសក្នុងវិតក្កជ្ឈានទាំង-ឡាយហើយ ក៏ធ្វើនូវការឃើញទោសនោះឲ្យច្រើន បាននូវអានិសង្សក្នុងអវិតក្កជ្ឈានហើយ ក៏សេពគប់នូវអានិសង្សនោះ ម្នាលអានន្ទ កាលតថាគតយល់ឃើញថា អវិតក្កជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះ ចិត្តក៏ត្រឡប់ជាស្ទុះទៅជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងអវិតក្កជ្ឈាឡើង ម្នាលអានន្ទ តថាគត ព្រោះរម្ងាប់នូវវិតក្ក និងវិចារៈ ។បេ។ ហើយចូលកាន់ទុតិយជ្ឈាន ។ ម្នាលអានន្ទ កាលតថាគតប្រព្រឹត្តនៅដោយវិហារធម៌នេះ សញ្ញា និងមនសិការ ប្រកបដោយវិតក្កក៏ច្រួលច្រាល់ឡើង ការច្រួលច្រាល់នៃសញ្ញា និងមនសិការនោះទុកជាអាពាធរបស់តថាគត ម្នាលអានន្ទ សេចក្ដីទុក្ខគប្បីកើតឡើងដល់បុគ្គលដែលធ្លាប់មានសេចក្ដីសុខ សេចក្ដីទុក្ខនោះ នឹងប្រព្រឹត្តទៅ ដើម្បីអាពាធជាកំណត់ មានឧបមាដូចម្ដេចមិញ មានឧបមេយ្យដូចសញ្ញា និងមនសិការរបស់តថាគត ប្រកបដោយវិតក្កដែលច្រួលច្រាល់ឡើង ការច្រួល

ប្រាល់នៃសញ្ញា និងមនសិការនោះ ទុកជាអាពាធរបស់តថាគតដូច្នោះឯង ។

ម្នាលអានន្ទ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះ អញគួរជាអ្នកព្រងើយកន្តើយ ព្រោះប្រាសចាកបីតិផង ជាអ្នកប្រកបដោយសតិ និងសម្បជញ្ញៈផង សោយសេចក្តីសុខដោយនាមកាយផង រួចចូលកាន់តតិយជ្ឈាន ដែលព្រះអរិយៈទាំងឡាយសរសើរថា បុគ្គលអ្នកដល់តតិយជ្ឈាន ជាអ្នកព្រងើយកន្តើយ មានស្មារតី នៅជាសុខ ។ ម្នាលអានន្ទ កាលតថាគតយល់ឃើញថា និប្បីតិកជ្ឈាន ( ឈានមិនមានបីតី ) នុ៎ះ ជារបស់ស្ងប់ដូច្នេះ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុងនិប្បីតិកជ្ឈានឡើយ ម្នាលអានន្ទ ទើបតថាគត មានសេចក្តីងឿងឆ្ងល់ដូច្នេះថា ចុះហេតុអ្វី បច្ច័យអ្វី បានជាកាលអញយល់ឃើញថា និប្បីតិកជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងនិប្បីតិកជ្ឈាន ម្នាលអានន្ទ តថាគតមានសេចក្តីយល់ឃើញដូច្នេះថា ឱទោសក្នុងបីតិ អញមិនទាន់ឃើញទាំងទោសនោះ អញមិនទាន់ធ្វើឲ្យច្រើនអានិសង្សក្នុងនិប្បីតិកជ្ឈាន អញមិនទាន់បានទេ ទាំងអានិសង្សនោះ អញមិនទាន់សេពគប់ទេតើ បានជាកាលអញយល់ឃើញថា និប្បីតិកជ្ឈាននុ៎ះជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏នៅតែមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅមិនចុះស៊ប់ក្នុងនិប្បីតិកជ្ឈាន ម្នាលអានន្ទ ទើបតថាគតមានសេចក្តីត្រិះរិះដូច្នេះថា បើអញឃើញទោសក្នុងបីតិហើយ គប្បីធ្វើនូវការឃើញទោសនោះ

ឲ្យច្រើន បានអានិសង្សក្នុងនិប្បីតិកជ្ឈានហើយ គប្បីសេពគប់នូវអានិសង្ស នោះ ហេតុនោះ តែងមានជាប្រាកដ ត្រង់ពាក្យថា កាលអញយល់ឃើញថា និប្បីតិកជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តគប្បីស្ទុះទៅ ជ្រះថ្លា តាំង នៅ ចុះស៊ប់ក្នុងនិប្បីតិកជ្ឈានបាន ម្នាលអានន្ទ លុះសម័យខាងក្រោយមក តថាគតនោះឃើញទោសក្នុងបីតិហើយ ក៏ធ្វើនូវការឃើញទោសនោះឲ្យច្រើន បានអានិសង្សក្នុងនិប្បីតិកជ្ឈានហើយ ក៏សេពគប់នូវអានិសង្សនោះ ម្នាល អានន្ទ កាលតថាគតយល់ឃើញថា និប្បីតិកជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះ ចិត្តក៏ត្រឡប់ជាស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ ក្នុងនិប្បីតិកជ្ឈានឡើង ម្នាលអានន្ទ តថាគតនោះឯង ព្រោះប្រាសចាកបីតិផង ។បេ។ ក៏បានចូល កាន់តតិយជ្ឈាន ។ ម្នាលអានន្ទ តថាគត កាលប្រព្រឹត្តទៅដោយវិហារធម៌ នេះ សញ្ញា និងមនសិការ ប្រកបដោយបីតិក៏ច្រួលច្រាល់ឡើង ការច្រួល ច្រាល់នៃសញ្ញា និងមនសិការនោះ ទុកជាអាពាធរបស់តថាគត ម្នាលអានន្ទ សេចក្តីទុក្ខ គប្បីកើតឡើងដល់បុគ្គលដែលធ្លាប់មានសេចក្តីសុខ សេចក្តីទុក្ខ នោះនឹងប្រព្រឹត្តទៅ ដើម្បីអាពាធជាកំណត់ មានឧបមាដូចម្តេចមិញ មាន ឧបមេយ្យដូចសញ្ញា និងមនសិការរបស់តថាគត ប្រកបដោយបីតិ ដែល ច្រួលច្រាល់ឡើង ការច្រួលច្រាល់នៃសញ្ញា និងមនសិការនោះ ទុកជាអាពាធ របស់តថាគតដូច្នោះឯង ។ ម្នាលអានន្ទ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះ គួរតែអញចូលកាន់ចតុត្ថជ្ឈាន ដែលឥតទុក្ខឥតសុខ មានឧបេក្ខាដ៏

បរិសុទ្ធដោយសតិ ព្រោះលះបង់សេចក្តីសុខផង លះបង់សេចក្តីទុក្ខផង វិនាសសោមនស្ស និងទោមនស្សផង ក្នុងកាលមុន ។ ម្នាលអានន្ទ កាលតថាគតយល់ឃើញថា ចតុត្ថជ្ឈានដែលឥតទុក្ខឥតសុខនុ៎ះ ជារបស់ស្ងប់ដូច្នេះ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងចតុត្ថជ្ឈាន ដែលឥតទុក្ខឥតសុខឡើយ ម្នាលអានន្ទ ទើបតថាគតមានសេចក្តីងឿងឆ្ងល់ដូច្នេះថា ចុះហេតុអ្វី បច្ច័យអ្វី បានជាកាលអញយល់ឃើញថា ចតុត្ថជ្ឈានដែលឥតទុក្ខឥតសុខនុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុងចតុត្ថជ្ឈានដែលឥតទុក្ខឥតសុខ ម្នាលអានន្ទ តថាគតមានសេចក្តីយល់ឃើញដូច្នេះថា ឱទោសក្នុងសេចក្តីសុខ ក្នុងឧបេក្ខា អញមិនទាន់ឃើញ ទាំងទោសនោះ អញមិនទាន់ធ្វើឲ្យច្រើន អានិសង្សក្នុងចតុត្ថជ្ឈាន ដែលឥតទុក្ខឥតសុខ អញមិនទាន់បានទេ ទាំងអានិសង្សនោះ អញមិនទាន់សេពគប់ទេតើ បានជាកាលអញយល់ឃើញថា ចតុត្ថជ្ឈានដែលឥតទុក្ខឥតសុខនុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏នៅតែមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងចតុត្ថជ្ឈានដែលឥតទុក្ខឥតសុខឡើយ ម្នាលអានន្ទ ទើបតថាគតមានសេចក្តីត្រិះរិះដូច្នេះថា បើអញឃើញទោសក្នុងសេចក្តីសុខក្នុងឧបេក្ខាហើយ គប្បីធ្វើនូវការឃើញទោសនោះឲ្យច្រើន បាននូវអានិសង្សក្នុងចតុត្ថជ្ឈាន ដែលឥតទុក្ខឥតសុខហើយ គប្បីសេពគប់នូវអានិសង្សនោះ ហេតុនេះ តែងមានជាប្រាកដ ត្រង់ពាក្យថា កាលអញ

យល់ឃើញថា ចតុត្ថជ្ឈានដែលឥតទុក្ខឥតសុខនុ៎ះ ជារបស់ស្ងប់ដូច្នេះ ចិត្ត គប្បីទៅស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងចតុត្ថជ្ឈាន ដែលឥតទុក្ខឥត សុខបាន ម្នាលអានន្ទ លុះសម័យខាងក្រោយ តថាគតនោះឯង ឃើញទោស ក្នុងសេចក្តីសុខ ក្នុងឧបេក្ខាហើយ ក៏ធ្វើនូវការឃើញទោសនោះឲ្យច្រើន បាន អានិសង្សក្នុងចតុត្ថជ្ឈានដែលឥតទុក្ខឥតសុខហើយ ក៏សេពគប់នូវអានិសង្ស នោះ ម្នាលអានន្ទ កាលតថាគតយល់ឃើញថា ចតុត្ថជ្ឈានដែលឥតទុក្ខឥត សុខនុ៎ះ ជារបស់ស្ងប់ដូច្នេះ ចិត្តក៏ត្រឡប់ជាស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះ ស៊ប់ក្នុងចតុត្ថជ្ឈាន ដែលឥតទុក្ខឥតសុខឡើយ ម្នាលអានន្ទ លុះសម័យ ខាងក្រោយមក តថាគតនោះឯង ព្រោះលះបង់នូវសុខផង ។បេ។ ក៏ចូល កាន់ចតុត្ថជ្ឈាន ។ ម្នាលអានន្ទ កាលតថាគតប្រព្រឹត្តនៅដោយវិហារធម៌នោះ សញ្ញា និងមនសិការ ប្រកបដោយឧបេក្ខា ក៏ប្រួលប្រាល់ឡើង ការប្រួល ប្រាល់នៃសញ្ញា និងមនសិការនោះ ទុកជាអាពាធរបស់តថាគត ម្នាលអានន្ទ សេចក្តីទុក្ខ គប្បីកើតឡើងដល់បុគ្គលដែលធ្លាប់មានសេចក្តីសុខ សេចក្តីទុក្ខ នោះ នឹងប្រព្រឹត្តទៅ ដើម្បីអាពាធជាកំណត់ មានឧបមាដូចម្តេចមិញ មាន ឧបមេយ្យដូចសញ្ញា និងមនសិការរបស់តថាគត ប្រកបដោយឧបេក្ខាដែល ប្រួលប្រាល់ឡើង ការប្រួលប្រាល់នៃសញ្ញា និងមនសិការនោះ ទុកជា អាពាធរបស់តថាគតដូច្នោះឯង ។

ម្នាលអានន្ទ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះ គួរតែអញ

ចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ ព្រោះកន្លងបង់នូវរូបសញ្ញា ព្រោះរលត់បដិឃសញ្ញា ព្រោះមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង ។ ម្នាលអានន្ទ កាលតថាគតយល់ឃើញថា អាកាសានញ្ចាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ ដូច្នេះ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុងអាកាសានញ្ចាយ-តនជ្ឈានឡើយ ម្នាលអានន្ទ ទើបតថាគត មានសេចក្តីងឿងឆ្ងល់ដូច្នេះថា ហេតុអ្វី បច្ច័យអ្វី កាលអញយល់ឃើញថា អាកាសានញ្ចាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងអាកាសានញ្ចាយតនជ្ឈាន ម្នាលអានន្ទ តថាគតមានសេចក្តីយល់ឃើញដូច្នេះថា ឱទោសក្នុងរូបទាំងឡាយ អញមិនទាន់ឃើញ ទាំងទោសនោះ អញមិនទាន់ធ្វើឲ្យច្រើន អានិសង្សក្នុងអាកាសានញ្ចាយតនជ្ឈាន អញមិនទាន់បានទេ ទាំងអានិសង្សនោះ អញមិនទាន់សេពគប់ទេតើ បានជាកាលអញយល់ឃើញថា អាកាសានញ្ចាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏នៅតែមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុងអាកាសា-នញ្ចាយតនជ្ឈាន ម្នាលអានន្ទ ទើបតថាគតមានសេចក្តីត្រិះរិះដូច្នេះថា បើអញឃើញទោសក្នុងរូបទាំងឡាយហើយ គប្បីធ្វើនូវការឃើញទោសនោះឲ្យច្រើន បានអានិសង្សក្នុងអាកាសានញ្ចាយតនជ្ឈានហើយ គប្បីសេពគប់នូវអានិសង្សនោះ ហេតុនេះ តែងមានជាប្រាកដ ត្រង់ពាក្យថា កាលអញយល់

ឃើញថា អាកាសានញ្ចាយតនជ្ឈានទុំះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តគប្បីស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងអាកាសានញ្ចាយតនជ្ឈានបាន ម្នាលអានន្ទ លុះសម័យខាងក្រោមមក តថាគតនោះឯង ឃើញទោសក្នុងរូបទាំងឡាយហើយ ក៏ធ្វើនូវការឃើញទោសនោះឲ្យច្រើន បាននូវអានិសង្សក្នុងអាកាសានញ្ចាយតនជ្ឈានហើយ ក៏សេពគប់នូវអានិសង្សនោះ ម្នាលអានន្ទ កាលតថាគតយល់ឃើញថា អាកាសានញ្ចាយតនជ្ឈានទុំះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏ត្រឡប់ជាស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងអាកាសានញ្ចាយតនជ្ឈានឡើង ម្នាលអានន្ទ តថាគតនោះឯង ព្រោះកន្លងបង់នូវរូបសញ្ញា ព្រោះរលត់បដិឃសញ្ញា ព្រោះមិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង ក៏ចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុត ។ ម្នាលអានន្ទ កាលតថាគតនោះប្រព្រឹត្តនៅដោយវិហារធម៌នេះ សញ្ញា និងមនសិការប្រកបដោយរូប ក៏ច្រួលច្រាល់ឡើង ការច្រួលច្រាល់នៃសញ្ញា និងមនសិការនោះ ទុកជាអាពាធរបស់តថាគត ម្នាលអានន្ទ សេចក្តីទុក្ខ គប្បីកើតឡើងដល់បុគ្គលដែលធ្លាប់មានសេចក្តីសុខ សេចក្តីទុក្ខនោះនឹងប្រព្រឹត្តទៅ ដើម្បីអាពាធជាកំណត់ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចសញ្ញា និងមនសិការរបស់តថាគតប្រកបដោយរូបដែលច្រួលច្រាល់ឡើង ការច្រួលច្រាល់នៃសញ្ញា និងមនសិការនោះ ទុកជាអាពាធរបស់តថាគត ដូច្នោះឯង ។

ម្នាលអានន្ទ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះ គួរតែអញកន្លងបង់នូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុត ។ ម្នាលអានន្ទ កាលតថាគតយល់ឃើញថា វិញ្ញាណញ្ចាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងវិញ្ញាណញ្ចាយតនជ្ឈានឡើយ ម្នាលអានន្ទ ទើបតថាគត មានសេចក្តីងឿងឆ្ងល់ថា ចុះហេតុអ្វី បច្ច័យអ្វី បានជាកាលអញយល់ឃើញថា វិញ្ញាណញ្ចាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងវិញ្ញាណញ្ចាយតនជ្ឈាន ម្នាលអានន្ទ តថាគតមានសេចក្តីយល់ឃើញថា ឱ ទោសក្នុងអាកាសានញ្ចាយតនជ្ឈាន អញមិនទាន់ឃើញ ទាំងទោសនោះ អញមិនទាន់ធ្វើឲ្យច្រើន អានិសង្សក្នុងវិញ្ញាណញ្ចាយតនជ្ឈាន អញមិនទាន់បានទេ ទាំងអានិសង្សនោះ អញមិនទាន់សេពគប់ទេតើ បានជាកាលអញយល់ឃើញថា វិញ្ញាណញ្ចាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏នៅតែមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងវិញ្ញាណញ្ចាយតនជ្ឈាន ម្នាលអានន្ទ ទើបតថាគតមានសេចក្តីត្រិះរិះដូច្នេះថា បើអញឃើញទោសក្នុងអាកាសានញ្ចាយតនជ្ឈានហើយ គប្បីធ្វើនូវការឃើញទោសនោះឲ្យច្រើន បាននូវអានិសង្សក្នុងវិញ្ញាណញ្ចាយតនជ្ឈានហើយ គប្បីសេពគប់នូវអានិសង្សនោះ ហេតុនេះ តែងមានជាប្រាកដ ត្រង់ពាក្យថា

កាលអញយល់ឃើញថា វិញ្ញាណញ្ចាយតនជ្ឈានទុំះ ជារបស់ស្ងប់ដូច្នេះ ហើយ ចិត្តគប្បីស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងវិញ្ញាណញ្ចាយតនជ្ឈានបាន ម្នាលអានន្ទ លុះសម័យខាងក្រោយមក តថាគតនោះឯង ឃើញទោសក្នុងអាកាសានញ្ចាយតនជ្ឈាន ហើយក៏ធ្វើនូវការឃើញទោសនោះឲ្យច្រើន បាននូវអានិសង្សក្នុងវិញ្ញាណញ្ចាយតនជ្ឈានហើយ ក៏សេពគប់នូវអានិសង្សនោះ ម្នាលអានន្ទ កាលតថាគតយល់ឃើញថា វិញ្ញាណញ្ចាយតនជ្ឈានទុំះ ជារបស់ស្ងប់ដូច្នេះ ចិត្តក៏ត្រឡប់ជាស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងវិញ្ញាណញ្ចាយតនជ្ឈានឡើង ម្នាលអានន្ទ តថាគតនោះឯង កន្លងបង់នូវអាកាសានញ្ចាយតនជ្ឈាន ហើយចូលកាន់វិញ្ញាណញ្ចាយយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុត ។ ម្នាលអានន្ទ កាលតថាគតនៅដោយវិហារធម៌នេះ សញ្ញា និងមនសិការ ប្រកបដោយអាកាសានញ្ចាយតនជ្ឈាន ក៏ច្រួលច្រាល់ឡើង ការច្រួលច្រាល់នៃសញ្ញា និងមនសិការនោះ ទុកជាអាពាធរបស់តថាគត ម្នាលអានន្ទ សេចក្តីទុក្ខគប្បីកើតឡើងដល់បុគ្គលដែលធ្លាប់មានសេចក្តីសុខ សេចក្តីទុក្ខនោះ នឹងប្រព្រឹត្តទៅដើម្បីអាពាធជាកំណត់ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចសញ្ញា និងមនសិការរបស់តថាគត ប្រកបដោយអាកាសានញ្ចាយតនជ្ឈាន ដែលច្រួលច្រាល់ឡើង ការច្រួលច្រាល់នៃសញ្ញា និងមនសិការនោះ ទុកជាអាពាធរបស់តថាគតដូច្នោះឯង ។

ម្នាលអានន្ទ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះ គួរតែអាត្មាអញ កន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ហើយចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អ្វីតិចតួចមិនមាន ។ ម្នាលអានន្ទ កាលតថាគតយល់ឃើញថា អាកិញ្ចញ្ញាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងអាកិញ្ចញ្ញាយតនជ្ឈានឡើយ ម្នាលអានន្ទ ទើបតថាគតមានសេចក្តីងឿងឆ្ងល់ដូច្នេះថា ចុះហេតុអ្វី បច្ច័យអ្វី បានជាកាលអញយល់ឃើញថា អាកិញ្ចញ្ញាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងអាកិញ្ចញ្ញាយតនជ្ឈាន ម្នាលអានន្ទ តថាគតមានសេចក្តីយល់ឃើញដូច្នេះថា ឱទោសក្នុងវិញ្ញាណញ្ចាយតនជ្ឈាន អញមិនទាន់ឃើញ ទាំងទោសនោះ អញមិនទាន់ធ្វើឲ្យច្រើន អានិសង្សក្នុងអាកិញ្ចញ្ញាយតនជ្ឈាន អញមិនទាន់បានទេ ទាំងអានិសង្សនោះ អញមិនទាន់សេពគប់ទេតើ បានជាកាលអញយល់ឃើញថា អាកិញ្ចញ្ញាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏នៅតែមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុងអាកិញ្ចញ្ញាយតនជ្ឈាន ម្នាលអានន្ទ ទើបតថាគតមានសេចក្តីត្រិះរិះដូច្នេះថា បើអញឃើញទោសក្នុងវិញ្ញាណញ្ចាយតនជ្ឈានហើយ គប្បីធ្វើនូវការឃើញទោសនោះឲ្យច្រើន បាននូវអានិសង្សក្នុងអាកិញ្ចញ្ញាយតនជ្ឈានហើយ គប្បីសេពគប់នូវអានិសង្សនោះ ហេតុនេះ តែងមានជាប្រាកដ ត្រង់ពាក្យថា កាលអញយល់

ឃើញថា អាកិញ្ចញ្ញាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តគប្បីស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងអាកិញ្ចញ្ញាយតនជ្ឈានបាន ម្នាលអានន្ទ លុះសម័យខាងក្រោយមក តថាគតនោះឯង ឃើញទោសក្នុងវិញ្ញាណញ្ចាយតនជ្ឈានហើយ ក៏ធ្វើនូវការឃើញទោសនោះឲ្យច្រើន បាននូវអានិសង្ស ក្នុងអាកិញ្ចញ្ញាយតនជ្ឈានហើយ ក៏សេពគប់នូវអានិសង្សនោះ ម្នាលអានន្ទ កាលតថាគតយល់ឃើញថា អាកិញ្ចញ្ញាយតនជ្ឈាននោះ ជារបស់ស្ងប់ដូច្នេះ ចិត្តក៏ត្រឡប់ជាស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងអាកិញ្ចញ្ញាយតនជ្ឈានឡើង ម្នាលអានន្ទ តថាគតនោះ កន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អ្វីតិចតួចមិនមាន ។ ម្នាលអានន្ទ កាលតថាគតនៅដោយវិហារធម៌នេះ សញ្ញា និងមនសិការ ប្រកបដោយវិញ្ញាណញ្ចាយតនជ្ឈាន ក៏ច្រួលច្រាល់ឡើង ការច្រួលច្រាល់នៃសញ្ញា និងមនសិការនោះ ទុកជាអាពាធរបស់តថាគត ម្នាលអានន្ទ សេចក្តីទុក្ខគប្បីកើតឡើង ដល់បុគ្គលដែលធ្លាប់មានសេចក្តីសុខ សេចក្តីទុក្ខនោះ នឹងប្រព្រឹត្តទៅដើម្បីអាពាធជាកំណត់ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចសញ្ញា និងមនសិការរបស់តថាគត ប្រកបដោយវិញ្ញាណញ្ញាយតនជ្ឈាន ដែលច្រួលច្រាល់ឡើង ការច្រួលច្រាល់នៃសញ្ញា និងមនសិការនោះ ទុកជាអាពាធរបស់តថាគត ដូច្នោះឯង ។

ម្នាលអានន្ទ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះ គួរតែអញ

កន្លងបង់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលទៅកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន ។ ម្នាលអានន្ទ កាលតថាគតយល់ឃើញថា នេវសញ្ញានាសញ្ញាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈានឡើយ ម្នាលអានន្ទ ទើបតថាគតមានសេចក្តីងឿងឆ្ងល់ដូច្នេះថា ចុះហេតុអ្វី បច្ច័យអ្វី បានជាកាលអញយល់ឃើញថា នេវសញ្ញានាសញ្ញាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈាន ម្នាលអានន្ទ តថាគតមានសេចក្តីយល់ឃើញដូច្នេះថា ឱ ទោសក្នុងអាកិញ្ចញ្ញាយតនជ្ឈាន អញមិនទាន់ឃើញ ទាំងទោសនោះ អញមិនទាន់ធ្វើឲ្យច្រើន អានិសង្សក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈាន អញមិនទាន់បាន ទាំងអានិសង្សនោះ អញមិនទាន់សេពគប់ទេតើ បានជាកាលអញយល់ឃើញថា នេវសញ្ញានាសញ្ញាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏នៅតែមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈាន ម្នាលអានន្ទ ទើបតថាគតមានសេចក្តីត្រិះរិះដូច្នេះថា អញឃើញទោសក្នុងអាកិញ្ចញ្ញាយតនជ្ឈានហើយ គប្បីធ្វើនូវការឃើញទោសនោះឲ្យច្រើន បើបានអានិសង្សក្នុងនេវសញ្ញានាសញ្ញាយត-នជ្ឈានហើយ គប្បីសេពគប់នូវអានិសង្សនោះ ហេតុនេះ តែងមានជាប្រាកដត្រង់ពាក្យថា កាលអញយល់ឃើញថា នេវសញ្ញានាសញ្ញាយតនជ្ឈាននុ៎ះ

ជារបស់ស្ងប់ដូច្នេះហើយ ចិត្តគប្បីស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈាន ម្នាលអានន្ទ លុះសម័យខាងក្រោយមក តថាគតនោះឯង ឃើញទោសក្នុងអាកិញ្ចញ្ញាយតនជ្ឈានហើយ ក៏ធ្វើនូវការឃើញទោសនោះឲ្យច្រើន បាននូវអានិសង្សក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈានហើយ ក៏សេពគប់នូវអានិសង្សនោះ ម្នាលអានន្ទ កាលតថាគតយល់ឃើញថា នេវសញ្ញានាសញ្ញាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះ ចិត្តក៏ត្រឡប់ជាស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈានឡើង ម្នាលអានន្ទ តថាគតនោះឯង កន្លងបង់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន ។ ម្នាលអានន្ទ កាលតថាគតនៅដោយវិហារធម៌នេះ សញ្ញា និងមនសិការដែលប្រកបដោយអាកិញ្ចញ្ញាយតនជ្ឈាន ក៏ច្រួលច្រាល់ឡើង ការច្រួលច្រាល់នៃសញ្ញា និងមនសិការនោះ ទុកជាអាពាធរបស់តថាគត ម្នាលអានន្ទ សេចក្តីទុក្ខគប្បីកើតឡើង ដល់បុគ្គលដែលធ្លាប់មានសេចក្តីសុខ សេចក្តីទុក្ខនោះ នឹងប្រព្រឹត្តទៅដើម្បីអាពាធជាកំណត់ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចសញ្ញា និងមនសិការរបស់តថាគត ដែលប្រកបដោយអាកិញ្ចញ្ញាយតនជ្ឈាន ដែលច្រួលច្រាល់ឡើង ការច្រួលច្រាល់នៃសញ្ញា និងមនសិការនោះ ទុកជាអាពាធរបស់តថាគតដូច្នោះឯង ។

ម្នាលអានន្ទ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះ គួរតែអញ

កន្លងបង់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ហើយចូលកាន់សញ្ញាវេទយិតនិរោធ ។ ម្នាលអានន្ទ កាលតថាគតយល់ឃើញថា សញ្ញាវេទយិតនិរោធនុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងសញ្ញាវេទយិតនិរោធឡើយ ម្នាលអានន្ទ ទើបតថាគតមានសេចក្តីងឿងឆ្ងល់ថា ចុះហេតុអ្វី បច្ច័យអ្វី បានជាកាលអញយល់ឃើញថា សញ្ញាវេទយិតនិរោធនុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងសញ្ញាវេទយិតនិរោធ ម្នាលអានន្ទ តថាគតមានសេចក្តីយល់ឃើញដូច្នេះថា ឱ ទោសក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈាន អញមិនទាន់ឃើញ ទាំងទោសនោះ អញមិនទាន់ធ្វើឲ្យច្រើន អានិសង្សក្នុងសញ្ញាវេទយិតនិរោធ អញមិនទាន់បាន ទាំងអានិសង្សនោះ អញមិនទាន់សេពគប់ទេតើ បានជាកាលអញយល់ឃើញថា សញ្ញាវេទយិតនិរោធនុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏នៅតែមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងសញ្ញាវេទយិតនិរោធ ម្នាលអានន្ទ ទើបតថាគតមានសេចក្តីត្រិះរិះដូច្នេះថា បើអញឃើញទោសក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈានហើយ គប្បីធ្វើនូវការឃើញទោសនោះឲ្យច្រើន បាននូវអានិសង្សក្នុងសញ្ញាវេទយិតនិរោធហើយ គប្បីសេពគប់នូវអានិសង្សនោះ ហេតុនេះ តែងមានជាប្រាកដ ត្រង់ពាក្យថា កាលអញយល់ឃើញថា សញ្ញាវេទយិតនិតរោធនុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តគប្បីស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងសញ្ញាវេទយិតនិរោធបាន ម្នាល

អានន្ទ លុះសម័យខាងក្រោយមក តថាគតនោះឯង ឃើញទោសក្នុងនេវ-សញ្ញានាសញ្ញាយតនជ្ឈានហើយ ក៏ធ្វើនូវការឃើញទោសនោះឲ្យច្រើន បាននូវអានិសង្សក្នុងសញ្ញាវេទយិតនិរោធហើយ ក៏សេពគប់នូវអានិសង្សនោះ ម្នាលអានន្ទ កាលតថាគតយល់ឃើញថា សញ្ញាវេទយិតនិរោធនុ៎ះ ជារបស់ស្ងប់ដូច្នេះ ចិត្តក៏ត្រឡប់ជាស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងសញ្ញាវេទយិ-តនិរោធឡើង ម្នាលអានន្ទ តថាគតនោះឯង កន្លងបង់នូវនេវសញ្ញានា-សញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់សញ្ញាវេទយិត-និរោធ ឯអាសវៈទាំងឡាយរបស់តថាគត ក៏ដល់នូវការអស់រលីងទៅ ព្រោះឃើញដោយប្រាជ្ញា ។

ម្នាលអានន្ទ អនុបុព្វវិហារសមាបត្តិទាំង ៩ នេះ តថាគតមិនទាន់ចូលផង មិនទាន់ចេញផង ជាអនុលោមបដិលោម យ៉ាងនេះបាន ដរាបណា ម្នាលអានន្ទ តថាគតក៏មិនទាន់ហ៊ានប្តេជ្ញាថា ជាអ្នកត្រាស់ដឹងច្បាស់នូវសម្មា-សម្ពោធិញ្ញាណដ៏ប្រសើរ ក្នុងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ដរាបនោះឡើយ ម្នាលអានន្ទ លុះតែអនុបុព្វវិហារសមាបត្តិទាំង ៩ នេះ តថាគតចូលផង ចេញផង ជាអនុ-លោមបដិលោម យ៉ាងនេះបាន ក្នុងកាលណា ម្នាលអានន្ទ ទើបតថាគតហ៊ានប្តេជ្ញាថា ជាអ្នកត្រាស់ដឹងច្បាស់នូវសម្មាសម្ពោធិញ្ញាណដ៏ប្រសើរ ក្នុង

លោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្ស ដ៏សេស ក្នុងកាលនោះ ឯញាណទស្សនៈ ( ការដឹង និងការឃើញ ) ក៏កើតឡើងដល់តថាគតថា ចេតោវិមុត្តិរបស់អញមិនកម្រើក នេះជាតិជាទីបំផុត ( របស់អញ ) កពថ្មីក្នុងកាលឥឡូវនេះ មិនមានឡើយ ។

មហាវគ្គទី ៤ ចប់

## ឧទ្ទានក្នុងមហាវគ្គនោះ គឺ

និយាយអំពីអនុបុព្វវិហារធម៌ ២ លើក ព្រះនិព្វាន ១ មេគោ ១ ឈានជាគម្រប់ ៥ ព្រះអានន្ទ ១ លោកាយតិកព្រាហ្មណ៍ ១ សង្គ្រាមរបស់ទេវតា និងអសុរ ១ ដំរីដ៏ប្រសើរ ១ តបុស្សគហបតី ១ ។

# អដ្ឋកថា

## តបុស្សសូត្រ

[ ៤១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតបុស្សសូត្រទី ១០ ដូចតទៅនេះ បទថា **មល្លកេសុ** បានដល់ ក្នុងដែនរបស់ស្តេចមល្លក្សត្រ ។ ព្រះមានព្រះភាគទ្រង់ដឹងថា នឹងមានការសន្ទនាគ្នារវាងតបុស្សគហបតី និងព្រះអានន្ទ ដែល

នៅក្នុងទីនេះ តថាគតនឹងសម្ដែងធម្មបរិយាយច្រើន មានរឿងនោះជាហេតុ ទើបត្រាស់ព្រះតម្រាស់នេះថា ម្នាលអានន្ទ អ្នកចូរនៅក្នុងទីនេះសិនចុះ ដូច្នេះ ។ បទថា **ឧបសង្កមិ** សេចក្ដីថា បានឮថា តបុស្សគហបតីនោះបរិភោគអាហារព្រឹកហើយ គិតថា អញនឹងគាល់ព្រះទសពល ដូច្នេះ ទើបចេញទៅ ឃើញព្រះថេរៈអំពីចម្ងាយ ទើបចូលទៅរកព្រះអានន្ទ ។

បទថា **បបាតោ វិយ ខាយតិ យទិទំ នេក្ខម្មំ** សេចក្ដីថា នេក្ខម្មៈពោល គឺបព្វជ្ជានេះប្រាកដដោយល្អ គឺប្រាកដច្បាស់ដល់ខ្ញុំ ដូចជ្រោះធំ ។ បទថា **នេក្ខម្មេ ចិត្តំ បក្ខន្ទតិ** សេចក្ដីថា ចិត្តរមែងស្ទុះទៅក្នុងបព្វជ្ជា ដោយធ្វើឲ្យជាអារម្មណ៍ គឺចិត្តធ្វើបព្វជ្ជានោះឲ្យជាអារម្មណ៍ រមែងជ្រះថ្លា រមែងតាំងមាំក្នុងបព្វជ្ជានោះ រមែងរួចផុតចាកធម៌ដែលជាសត្រូវ ។ បទថា **ឯតំ សន្តន្តិ បស្សតោ** បានដល់ របស់ភិក្ខុដែលឃើញយ៉ាងនេះថា នេក្ខម្មៈនេះស្ងប់ គឺប្រាសចាកសេចក្ដីក្រវល់ក្រវាយ និងការក្ដៅក្រហាយ ។ បទថា **ពហុនា ជនេន វិសភាគោ** សេចក្ដីថា នេក្ខម្មៈនេះនៃភិក្ខុទាំងឡាយ ជាវិសភាគ គឺមិនដូចគ្នានឹងមហាជន ។

បទថា **កថាបាភតំ** គឺជាហេតុដែលពោលចរចាគ្នា ។ បទថា **តស្ស មយ្ហំ អានន្ទ នេក្ខម្មេ ចិត្តំ ន បក្ខន្ទតិ** សេចក្ដីថា ចិត្តនៃអាត្មាអញសូម្បីត្រិះរិះយ៉ាងនេះ ក៏មិនទាន់ឈមចុះក្នុងបព្វជ្ជា ។ បទថា **ឯតំ សន្តន្តិ បស្សតោ** សេចក្ដីថា សូម្បីឃើញថានេក្ខម្មៈនេះ ស្ងប់ដោយការត្រិះរិះដោយជុំវិញថា

នេក្ខម្មៈនេះល្អពិត ដូច្នេះ ។ បទថា **អនាសេវិតោ** បានដល់ មិនសេព គឺ មិនពាល់ត្រូវ មិនធ្វើឲ្យជាក់ច្បាស់ ។ បទថា **អធិគម្ម** បានដល់ ដល់ គឺ សម្រេច ធ្វើឲ្យជាក់ច្បាស់ ។ បទថា **តមាសេវេយ្យំ** បានដល់ គប្បីសេព គឺគប្បីជួបប្រទះអានិសង្សនោះ ។ បទថា **យម្មេ** បានដល់ របស់អញ ដោយហេតុណា ។ បទថា **អធិគម្ម** ប្រែថា សម្រេចហើយ ។ បទថា **ស្វាស្ស មេ ហោតិ អាពាធោ** បានដល់ ឈ្មោះថា អាពាធ ព្រោះអត្ថថា បៀតបៀនអាត្មាអញ ។ បទថា **អវិតក្កេ ចិត្តំ ន បក្ខន្ទតិ** សេចក្តីថា ចិត្តរមែងមិនស្ទុះទៅក្នុងទុតិយជ្ឈាន ដែលមិនមានវិតក្ក និងវិចារៈ ដោយអំណាចអារម្មណ៍ ។ បទថា **វិតក្កេសុ** បានដល់ វិតក្ក និងវិចារៈ ។ ពាក្យដ៏សេសក្នុងបទទាំងពួង មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថា តបុស្សសូត្រទី ១០ ចប់**

**មហាវគ្គទី ៤ ចប់**

# សុត្តន្តបិដក
# បញ្ចាលវគ្គទី ៥

## បញ្ចាលសូត្រទី ១

[ ៤២ ] សម័យមួយ ព្រះអានន្ទដ៏មានអាយុ កាលគង់នៅក្នុងឃោសិ-តារាម ជិតក្រុងកោសម្ពី ។ គ្រានោះ ព្រះឧទាយិដ៏មានអាយុ បានចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះអានន្ទដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះឧទាយិដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ បាននិយាយនឹងព្រះអានន្ទដ៏មានអាយុដូច្នេះថា ម្នាលអាវុសោ ទេវបុត្តឈ្មោះបញ្ចាលចណ្ឌៈ ពោលនូវពាក្យនេះថា

បុគ្គលណា មានបញ្ញាក្រាស់ ដូចផែនដី ជ្រាបច្បាស់
នូវឱកាសដែលតាំងនៅក្នុងទីចង្អៀត ជាព្រះពុទ្ធ ត្រាស់
ដឹងនូវឈាន បុគ្គលនោះ ជាអ្នកប្រាជ្ញលាក់ខ្លួន នឹង
ប្រសើរផុត ។

ម្នាលអាវុសោ ទីចង្អៀតនោះ តើដូចម្តេចខ្លះ ។ ការត្រាស់ដឹងនូវឱកាសក្នុងទីចង្អៀត ដែលព្រះដ៏មានព្រះភាគសម្តែងហើយ តើដូចម្តេចខ្លះ ។ ម្នាលអាវុសោ កាមគុណ ៥ យ៉ាងនេះ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងថា ទីចង្អៀត ។ កាមគុណ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺរូបដែលគប្បីដឹងដោយ

ចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ ១ សំឡេងដែលគប្បីដឹងដោយសោតៈ ១ ។បេ។ ក្លិនដែលគប្បីដឹងដោយច្រមុះ ១ រសដែលគប្បីដឹងដោយអណ្តាត ១ ផ្សព្វដែលគប្បីដឹងច្បាស់ដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ ១ ។ ម្នាលអាវុសោ កាមគុណ ៥ យ៉ាងនេះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងថា ទីចង្អៀត ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់នូវបឋមជ្ឈាន ម្នាលអាវុសោ ការត្រាស់ដឹងនូវឱកាសក្នុងទីចង្អៀត ដែលព្រះដ៏មានព្រះភាគត្រាស់សម្តែងហើយ ដោយបរិយាយមានប្រមាណប៉ុណ្ណេះឯង ។ ទីចង្អៀតតែងមានក្នុងបឋមជ្ឈាននោះ ទីចង្អៀតក្នុងបឋមជ្ឈាននោះ តើដូចម្តេច ។ កាលណាបើវិតក្ក និងវិចារៈ ក្នុងបឋមជ្ឈាននោះ មិនទាន់រលត់ទៅទេ កាលនោះ វិតក្ក និងវិចារៈនេះ ឈ្មោះថា ជាទីចង្អៀតក្នុងបឋមជ្ឈាននុ៎ះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុព្រោះស្ងប់រម្ងាប់នូវវិតក្ក និងវិចារៈ ។បេ។ បានដល់នូវទុតិយជ្ឈាន ម្នាលអាវុសោ ការត្រាស់ដឹងនូវឱកាសក្នុងទីចង្អៀត ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ ដោយបរិយាយមានប្រមាណប៉ុណ្ណេះឯង ។ ទីចង្អៀតតែងមានក្នុងទុតិយជ្ឈាននោះ ទីចង្អៀតក្នុងទុតិយជ្ឈាននោះ តើដូចម្តេច ។ កាលណាបើបីតិក្នុងទុតិយជ្ឈាននោះ មិនទាន់រលត់ទៅទេ

កាលនោះ ភាពមិនរលត់ទៅនៃបីតិនេះ ឈ្មោះថា ទីចង្អៀតក្នុងទុតិយជ្ឈាននុ៎ះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុព្រោះប្រាសចាកបីតិផង ។បេ។ បានដល់នូវតតិយជ្ឈាន ម្នាលអាវុសោ ការត្រាស់ដឹងនូវឱកាសក្នុងទីចង្អៀតដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយ ដោយបរិយាយត្រឹមប៉ុណ្ណោះឯង ។ ទីចង្អៀតតែងមាន ក្នុងតតិយជ្ឈាននោះ ទីចង្អៀតក្នុងតតិយជ្ឈាននោះ តើដូចម្តេច ។ កាលណាបើឧបេក្ខា និងសុខ ក្នុងតតិយជ្ឈាននោះ មិនទាន់រលត់ទៅទេ កាលនោះ ភាពមិនរលត់ទៅនៃឧបេក្ខា និងសុខ នេះឈ្មោះថា ទីចង្អៀតក្នុងតតិយជ្ឈាននុ៎ះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុព្រោះលះបង់នូវសេចក្តីសុខផង ។បេ។ បានដល់នូវចតុត្ថជ្ឈាន ម្នាលអាវុសោ ការត្រាស់ដឹងនូវឱកាសក្នុងទីចង្អៀត ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយ ដោយបរិយាយត្រឹមប៉ុណ្ណោះឯង ។ ទីចង្អៀត រមែងមានក្នុងចតុត្ថជ្ឈាននោះ ទីចង្អៀតក្នុងចតុត្ថជ្ឈាននោះ តើដូចម្តេច ។ កាលណា បើរូបសញ្ញាក្នុងចតុត្ថ-ជ្ឈាននោះ មិនទាន់រលត់ទៅទេ កាលនោះ ភាពមិនរលត់ទៅនៃរូបសញ្ញានេះ ឈ្មោះថា ទីចង្អៀតក្នុងចតុត្ថជ្ឈាននុ៎ះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបានដល់នូវអាកាសានញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ ព្រោះកន្លងនូវរូបសញ្ញា ព្រោះរលត់នូវបដិឃសញ្ញា ព្រោះមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង ម្នាលអាវុសោ ការត្រាស់ដឹងនូវឱកាសក្នុងទីចង្អៀត ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែង

ហើយ ដោយបរិយាយត្រឹមប៉ុណ្ណោះឯង ។ ទីចង្អៀត រមែងមានក្នុងអាកា-សានញ្ចាយតនជ្ឈានទោះ ទីចង្អៀតក្នុងអាកាសានញ្ចាយតនជ្ឈានទោះ តើដូចម្តេច ។ កាលណាបើអាកាសានញ្ចាយតនសញ្ញា ក្នុងអាកាសានញ្ចាយតន-ជ្ឈានទោះ មិនទាន់រលត់ទៅទេ កាលនោះ ភាពមិនរលត់ទៅនៃអាកាសា-នញ្ចាយតនសញ្ញានេះ ឈ្មោះថា ទីចង្អៀតក្នុងអាកាសានញ្ចាយតនជ្ឈាននុ៎ះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុតដូច្នេះ ព្រោះកន្លងនូវអាកាសានញ្ចា-យតនជ្ឈាន ដោយប្រការទាំងពួង ម្នាលអាវុសោ ការត្រាស់ដឹងនូវឱកាសក្នុងទីចង្អៀត ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយ ដោយបរិយាយត្រឹមប៉ុណ្ណោះឯង ។ ទីចង្អៀតរមែងមានក្នុងវិញ្ញាណញ្ចាយតនជ្ឈាននោះ ទីចង្អៀតក្នុងវិញ្ញាណញ្ចាយតនជ្ឈាននោះ តើដូចម្តេច ។ កាលណាបើវិញ្ញា-ណញ្ចាយតនសញ្ញា ក្នុងវិញ្ញាណញ្ចាយតនជ្ឈាននោះ មិនទាន់រលត់ទៅទេ កាលនោះ ភាពមិនរលត់ទៅនៃវិញ្ញាណញ្ចាយតនជ្ឈាននេះ ឈ្មោះថា ទីចង្អៀតក្នុងវិញ្ញាណញ្ចាយតនជ្ឈាននោះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបានដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វត្ថុតិចតួចមិនមានដូច្នេះ ព្រោះកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ម្នាលអាវុសោ ការត្រាស់ដឹងនូវឱកាសក្នុងទីចង្អៀត ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយ ដោយបរិយាយត្រឹមប៉ុណ្ណោះឯង ។ ទីចង្អៀតរមែងមាន

ក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះ ទីចង្អៀតក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះ តើដូចម្ដេច ។ កាលណាបើអាកិញ្ចញ្ញាយតនសញ្ញា ក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះ មិនទាន់រលត់ទៅទេ កាលនោះ ភាពមិនរលត់ទៅនៃអាកិញ្ចញ្ញាយតនសញ្ញានេះ ឈ្មោះថា ទីចង្អៀតក្នុងអាកិញ្ចញ្ញាយតនជ្ឈានទុំះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបានដល់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ព្រោះកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ម្នាលអាវុសោ ការត្រាស់ដឹងនូវឱកាសក្នុងទីចង្អៀត ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្ដែងហើយដោយបរិយាយត្រឹមប៉ុណ្ណេះឯង ។ ទីចង្អៀតរមែងមានក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈាននោះ ទីចង្អៀតក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈាននោះ តើដូចម្ដេច ។ កាលណាបើនេវសញ្ញានាសញ្ញាយតនសញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈាននោះ មិនទាន់រលត់ទៅទេ កាលនោះ ភាពមិនរលត់ទៅនៃនេវសញ្ញានាសញ្ញាយតនសញ្ញានេះ ឈ្មោះថា ទីចង្អៀតក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈានទុំះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបានដល់នូវសញ្ញាវេទយិតនិរោធ ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង អាសវៈទាំងឡាយរបស់ភិក្ខុនោះ ក៏អស់រលីងទៅ ព្រោះឃើញដោយបញ្ញា ម្នាលអាវុសោ ការត្រាស់ដឹងនូវឱកាសក្នុងទីចង្អៀត ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្ដែងហើយ ដោយនិប្បរិយាយត្រឹមប៉ុណ្ណេះឯង ។

# អដ្ឋកថា
# បញ្ចាលវគ្គទី ៥

## បញ្ចាលសូត្រ

[ ៤២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបញ្ចាលសូត្រទី ១ នៃបញ្ចាលវគ្គទី ៥ ដូចតទៅនេះ បទថា **ឧទាយិ** បានដល់ ព្រះថេរៈឈ្មោះកាឡុទាយី ។ បទថា **អវិទា** ប្រែថា បានដឹងហើយ ។ បទថា **ភូរិមេធសោ** ប្រែថា មានបញ្ញាច្រើន ។ បទថា **យោ ឈានមពុជ្ឈិ ពុទ្ធោ** គឺព្រះពុទ្ធទ្រង់បានត្រាស់ដឹងឈាន ។ បទថា **បដិលីនសិសភោ** បានដល់ ពួនសម្ងំម្នាក់ឯង និងជាបុគ្គលប្រសើរខ្ពង់ខ្ពស់ ។ បទថា **មុនិ** បានដល់ ព្រះពុទ្ធមុនី ។ បទថា **បរិយាយេន** គឺដោយហេតុ ១ ។ បឋមជ្ឈាន ឈ្មោះថា សម្រេចតាមឱកាស ដោយត្រឹមមិនមានការចង្អៀតចង្អល់ផ្លូវកាមប៉ុណ្ណោះ មិនទូទៅទាំងអស់ឡើយ ។ បទថា **តត្របត្តិ សម្ពាធោ** បានដល់ កាលនៅមានបឋមជ្ឈាន ការចង្អៀតចង្អល់ គឺការបៀតបៀនក៏នៅមាននោះឯង ។ បាលីថា **តត្ថ បត្តិ** ដូច្នេះក៏មាន ។ បទថា **កិញ្ច តត្ថ សម្ពាធោ** បានដល់ ក្នុងឈាននោះ ឈ្មោះថា ចង្អៀតចង្អល់ដូចម្ដេច ។ បទថា **អយមេត្ថ សម្ពាធោ** បានដល់ ភាពដែលវិតក្ក និងវិចារៈ មិនទាន់រលត់ទៅ នេះឈ្មោះថា ជាការចង្អៀតចង្អល់ គឺបៀតបៀនជានិច្ច ។ គប្បីជ្រាបអត្ថក្នុងវារៈទាំងអស់ ដោយឧបាយនេះ ។ បទថា **និប្បរិយាយេន** គឺមិនមែនដោយអាការ ១ អធិប្បាយ

ថា ដោយពិត ឈ្មោះថា ការអស់អាសវៈ ឈ្មោះថា ជាការសម្រេចតាមឱកាស ១ ដោយប្រការទាំងពួង ព្រោះលះការចង្អៀតចង្អល់ទាំងអស់បាន ។៤១

អដ្ឋកថា បញ្ចាលសូត្រទី ១ ចប់

# សុត្តន្តបិដក

## បឋមកាមហេសសូត្រទី ២

[ ៤៣ ] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងថា កាយសក្ខិ កាយសក្ខិ ដូច្នេះ ម្នាលអាវុសោ កាយសក្ខិ ដែលព្រះមានព្រះភាគសម្តែងហើយ តើដោយហេតុប៉ុន្មាន ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់នូវបឋមជ្ឈាន អាយតនៈ គឺបឋមជ្ឈាននោះមាន ព្រោះអាការណាៗ ភិក្ខុក៏ពាល់ត្រូវអាយតនៈនោះ ដោយកាយព្រោះអាការនោះៗ ម្នាលអាវុសោ កាយសក្ខិបុគ្គល ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ ដោយបរិយាយត្រឹមប៉ុណ្ណោះឯង ។ ម្នាលអាវុសោ មួយទៀត ភិក្ខុព្រោះស្ងប់រម្ងាប់នូវវិតក្ក និងវិចារៈ ។បេ។ ក៏បានដល់នូវទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន អាយតនៈនោះកើតព្រោះអាការណាៗ ភិក្ខុក៏ពាល់ត្រូវនូវអាយតនៈនោះដោយកាយ ព្រោះអាការនោះៗ ម្នាលអាវុសោ កាយ-

សក្ខិបុគ្គល ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ ដោយបរិយាយត្រឹមប៉ុណ្ណោះឯង ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបានដល់នូវអាកាសានញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ ព្រោះកន្លងនូវរូបសញ្ញា ព្រោះវិនាសទៅនៃបដិឃសញ្ញា ព្រោះមិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង អាយតនៈនោះកើតព្រោះអាការណាៗ ភិក្ខុក៏ពាល់ត្រូវនូវអាយតនៈនោះដោយកាយ ព្រោះអាការនោះៗ ម្នាលអាវុសោ កាយសក្ខិបុគ្គល ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ ដោយបរិយាយត្រឹមប៉ុណ្ណោះឯង ។បេ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបានដល់នូវសញ្ញាវេទយិតនិរោធ ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង អាសវៈទាំងឡាយរបស់ភិក្ខុនោះ ក៏អស់រលីងទៅ ព្រោះឃើញដោយបញ្ញា អាយតនៈនោះកើតព្រោះអាការណាៗ ភិក្ខុក៏ពាល់ត្រូវនូវអាយតនៈនោះដោយកាយ ព្រោះអាការនោះ ម្នាលអាវុសោ កាយសក្ខិបុគ្គល ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ ដោយនិប្បរិយាយត្រឹមប៉ុណ្ណោះឯង ។

# អដ្ឋកថា

## បឋមកាមហេសសូត្រ

[ ៤៣ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមកាមហេសសូត្រទី ២ ដូចតទៅនេះ បទថា* **យថា យថា ច តទាយតនំ** *សេចក្តីថា អាយតនៈ គឺបឋមជ្ឈាននោះ រមែងមានដោយហេតុណា គឺដោយប្រការណាមួយ ។ បទថា* **តថា តថា នំ កាយេន ផុសិត្វា វិហរតិ** *សេចក្តីថា ភិក្ខុពាល់ត្រូវសមាបត្តិនោះ ដោយសហជាតនាមកាយ ដោយហេតុនោះៗ គឺដោយអាការនោះៗ ដោយអត្ថថាចូលដល់ ។ បទថា* **កាយសក្ខិ វុត្តោ ភគវតា បរិយាយេន** *សេចក្តីថា ព្រោះលោកធ្វើបឋមជ្ឈានឲ្យជាក់ដោយនាមកាយនោះ ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់កាយសក្ខីដោយបរិយាយនេះ ។ បទថា* **និប្បរិយាយេន** *បានដល់ គួរធ្វើឲ្យជាបន្ទាល់ដោយកាយប៉ុនណា នេះឈ្មោះថា កាយសក្ខីដោយនិប្បរិយាយ ព្រោះធ្វើឲ្យអស់ហើយ ៕*

**អដ្ឋកថា បឋមកាមហេសសូត្រទី ២ ចប់**

# សុត្តន្តបិដក

## ទុតិយកាមហេសសូត្រទី ៣

[ ៤៤ ] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា បញ្ញាវិមុត្ត បញ្ញាវិមុត្ត ដូច្នេះ ម្នាលអាវុសោ បញ្ញាវិមុត្តបុគ្គល ដែលព្រះអង្គសម្តែងហើយ តើដោយហេតុប៉ុន្មាន ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ក៏បានដល់នូវបឋមជ្ឈាន ទាំងដឹងច្បាស់ដោយបញ្ញា ម្នាលអាវុសោ បញ្ញាវិមុត្តបុគ្គល ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយ ដោយបរិយាយត្រឹមប៉ុណ្ណេះឯង ។បេ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបានដល់នូវសញ្ញាវេទយិតនិរោធ ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង អាសវៈទាំងឡាយរបស់ភិក្ខុនោះ ក៏អស់រលីងទៅ ព្រោះឃើញដោយបញ្ញា ទាំងភិក្ខុនោះក៏ដឹងច្បាស់ដោយបញ្ញា ម្នាលអាវុសោ បញ្ញាវិមុត្តបុគ្គល ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ ដោយនិប្បរិយាយត្រឹមប៉ុណ្ណេះឯង ។

# អដ្ឋកថា

## ទុតិយកាមហេសសូត្រ

[ ៤៤ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយកាមហេសសូត្រទី ៣ ដូចតទៅនេះ បទថា* **បញ្ញាយ បន បជានាតិ** *បានដល់ ដឹងអាយតនៈនោះៗ ដោយបឋមជ្ឈាន និងវិបស្សនាបញ្ញា ។ ក្នុងព្រះសូត្រនេះ គប្បីជ្រាបភាពជាបរិយាយ និងនិប្បរិយាយ ដោយន័យមុននោះឯង ។ ក្នុងព្រះសូត្រនេះ យ៉ាងណា ក្នុងព្រះសូត្រដទៃក្រៅអំពីនេះ ក៏យ៉ាងនោះ ។៚*

**អដ្ឋកថាទុតិយកាមហេសសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## តតិយកាមហេសសូត្រទី ៤

[ ៤៥ ] *ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ឧភតោភាគវិមុត្ត ឧភតោភាគវិមុត្ត ដូច្នេះ ម្នាលអាវុសោ ឧភតោភាគវិមុត្តបុគ្គល ដែលព្រះមានព្រះភាគសម្តែងហើយ តើដោយហេតុប៉ុន្មាន ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ក៏បានដល់នូវបឋមជ្ឈាន អាយតនៈនោះកើតព្រោះអាការណាៗ ភិក្ខុពាល់ត្រូវនូវអាយតនៈនោះដោយកាយ ព្រោះអាការនោះៗ ទាំងដឹងច្បាស់ដោយបញ្ញា ម្នាលអាវុសោ ឧភតោភាគវិមុត្តបុគ្គល ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ*

ដោយបរិយាយត្រឹមប៉ុណ្ណោះឯង ។បេ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបាន ដល់នូវសញ្ញាវេទយិតនិរោធ ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង អាសវៈទាំងឡាយរបស់ភិក្ខុនោះ ក៏អស់រលីងទៅ ព្រោះឃើញដោយបញ្ញា អាយតនៈនោះកើតព្រោះអាការណាៗ ភិក្ខុពាល់ត្រូវ នូវអាយតនៈនោះដោយកាយ ព្រោះអាការនោះៗ ទាំងបានដឹងច្បាស់ដោយ បញ្ញា ម្នាលអាវុសោ ឧភតោភាគវិមុត្តបុគ្គល ដែលព្រះដ៏មានព្រះភាគទ្រង់ សម្តែងហើយ ដោយនិប្បរិយាយត្រឹមប៉ុណ្ណោះឯង ។

# អដ្ឋកថា

## តតិយកាមហេសសូត្រ

[ ៤៥ ] តតិយកាមហេសសូត្រទី ៤ គប្បីជ្រាបដោយន័យរបស់ព្រះ សូត្រទាំង ២ នោះឯង ។ បទថា **ឧភតោភាគវិមុត្តោ** ក្នុងសូត្រនេះ បាន ដល់ ផុតហើយ ចាកកិលេសដែលជាសត្រូវនៃសមថៈ និងវិបស្សនាដោយ ចំណែកទាំង ២ ។ ក្នុងទីបំផុត គប្បីជ្រាបថា ឈ្មោះថា ឧភតោភាគវិមុត្ត ព្រោះផុតចាករូបកាយដោយសមាបត្តិ ចាកនាមកាយដោយអរិយមគ្គ ។

**អដ្ឋកថា តតិយកាមហេសសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## បឋមសន្ទិដ្ឋិកសូត្រទី ៥

[ ៤៦ ] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា សន្ទិដ្ឋិកធម៌ សន្ទិដ្ឋិកធម៌ ដូច្នេះ ម្នាលអាវុសោ សន្ទិដ្ឋិកធម៌ដែលព្រះអង្គសំដែងហើយ តើដោយហេតុប៉ុន្មាន ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ក៏បានដល់នូវបឋមជ្ឈាន ម្នាលអាវុសោ សន្ទិដ្ឋិកធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ដោយបរិយាយត្រឹមប៉ុណ្ណេះឯង ។បេ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបានដល់នូវសញ្ញាវេទយិតនិរោធ ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង អាសវៈទាំងឡាយរបស់ភិក្ខុនោះ ក៏អស់រលីងទៅ ព្រោះឃើញដោយបញ្ញា ម្នាលអាវុសោ សន្ទិដ្ឋិកធម៌ ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ដោយនិប្បរិយាយត្រឹមប៉ុណ្ណេះឯង ។

## ទុតិយសន្ទិដ្ឋិកសូត្រទី ៦

[ ៤៧ ] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា សន្ទិដ្ឋិកនិព្វាន សន្ទិដ្ឋិកនិព្វាន ដូច្នេះ ម្នាលអាវុសោ សន្ទិដ្ឋិកនិព្វាន ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ តើដោយហេតុប៉ុន្មាន ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ក៏ដល់នូវបឋមជ្ឈាន ម្នាលអាវុសោ សន្ទិដ្ឋិកនិព្វាន ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងហើយ ដោយបរិយាយមានត្រឹមប៉ុណ្ណេះឯង ។បេ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបានដល់

នូវសញ្ញាវេទយិតនិរោធ ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង អាសវៈទាំងឡាយរបស់ភិក្ខុនោះ ក៏អស់រលីងទៅ ព្រោះឃើញដោយបញ្ញា ម្នាលអាវុសោ សន្ទិដ្ឋិកនិព្វាន ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ដោយនិប្បរិយាយត្រឹមប៉ុណ្ណោះឯង ។

## និព្វានសូត្រទី ៧

[ ៤៨ ] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា និព្វាន និព្វាន ដូច្នេះ ។បេ។

## បរិនិព្វានសូត្រទី ៨

[ ៤៩ ] ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា បរិនិព្វាន បរិនិព្វាន ដូច្នេះ ។បេ។

## តទង្គសូត្រទី ៩

[ ៥០ ] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា តទង្គនិព្វាន តទង្គនិព្វាន ដូច្នេះ ។បេ។

## ទិដ្ឋធម្មិកសូត្រទី ១០

[ ៥១ ] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ទិដ្ឋធម្មនិព្វាន ទិដ្ឋធម្មនិព្វាន ដូច្នេះ ម្នាលអាវុសោ ទិដ្ឋធម្មនិព្វាន ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សំដែងហើយ ដោយហេតុប៉ុន្មាន ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ក៏បានដល់នូវបឋមជ្ឈាន

ម្នាលអាវុសោ ទិដ្ឋធម្មនិព្វាន ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយ ដោយបរិយាយត្រឹមប៉ុណ្ណោះឯង ។បេ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបានដល់នូវសញ្ញាវេទយិតនិរោធ ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយ-តនជ្ឈាន ដោយប្រការទាំងពួង អាសវៈទាំងឡាយរបស់ភិក្ខុនោះ ក៏អស់រលីងទៅ ព្រោះឃើញដោយបញ្ញា ម្នាលអាវុសោ ទិដ្ឋធម្មនិព្វាន ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយ ដោយនិប្បរិយាយត្រឹមប៉ុណ្ណោះឯង ។

**បញ្ចាលវគ្គទី ៥ ចប់**

## ឧទ្ទានក្នុងបញ្ចាលវគ្គនោះ គឺ

និយាយអំពីបញ្ចាលចណ្ឌទេវបុត្ត ១ ការបៀតបៀន
កាម ១ បញ្ញាវិមុត្ត ១ ឧភតោភាគវិមុត្តបុគ្គល ១
សន្ទិដ្ឋិកៈ មាន ២ លើក និព្វាន ១ បរិនិព្វាន ១
តទង្គនិព្វាន ១ និងទិដ្ឋធម្មិកនិព្វាន ១ ។

**បណ្ណាសកក្នុងនវកនិបាត ចប់**

# អដ្ឋកថា

## បឋមសន្ទិដ្ឋិកសូត្រជាដើម

[ ៤៦-៥១ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងបឋមសន្ទិដ្ឋិកសូត្រជាដើមដូច្នេះ បទថា **សន្ទិដ្ឋិកោ** ប្រែថា ដែលបុគ្គលគប្បីឃើញឯង ។ បទថា **និព្វានំ** បានដល់ រម្ងត់កិលេស ។ បទថា **បរិនិព្វានំ** ជាវេវចនៈនៃបទថា **និព្វានំ** នោះឯង ។ បទថា **តទង្គនិព្វានំ** បានដល់ និព្វានដោយអង្គនោះ មាន បឋមជ្ឈានជាដើម ។ បទថា **ទិដ្ឋធម្មនិព្វានំ** បានដល់ និព្វានក្នុងអត្តភាព នោះឯង ។ ពាក្យដ៏សេស ក្នុងបទទាំងអស់មានអត្ថងាយយល់ហើយ ដោយ ប្រការដូច្នេះ ។

**អដ្ឋកថា បឋមសន្ទិដ្ឋិកសូត្រជាដើមចប់**

**បញ្ចាលវគ្គទី ៥ ចប់**

**ទុតិយបណ្ណាសក**

# សុត្តន្តបិដក
# បណ្ណាសកាសង្គហិតវគ្គ

## ខេមវគ្គទី ១
### ខេមសូត្រទី ១

[ ៥២ ] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា សេចក្ដីក្សេម សេចក្ដីក្សេម ដូច្នេះ ម្នាលអាវុសោ សេចក្ដីក្សេម ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយ តើដោយហេតុប៉ុន្មាន ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់នូវបឋមជ្ឈាន ម្នាលអាវុសោ សេចក្ដីក្សេម ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយ ដោយបរិយាយត្រឹមប៉ុណ្ណោះឯង ។បេ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបានដល់នូវសញ្ញាវេទយិតនិរោធ ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង អាសវៈទាំងឡាយ របស់ភិក្ខុនោះក៏អស់រលីងទៅ ព្រោះឃើញដោយបញ្ញា ម្នាលអាវុសោ សេចក្ដីក្សេម ដែលព្រះដ៏មានព្រះភាគទ្រង់សម្ដែងហើយ ដោយនិប្បរិយាយត្រឹមប៉ុណ្ណោះឯង ។

### ខេមបត្តសូត្រទី ២

[ ៥៣ ] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា បុគ្គលដល់នូវសេចក្ដីក្សេម ដល់នូវសេចក្ដីក្សេម ដូច្នេះ ។បេ។

## អមតសូត្រទី ៣

[ ៥៤ ] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា អមតៈ អមតៈ ដូច្នេះ ។

## អមតបត្តសូត្រទី ៤

[ ៥៥ ] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា បុគ្គលដល់នូវអមតៈ ដល់នូវអមតៈ ដូច្នេះ ។

## អភយសូត្រទី ៥

[ ៥៦ ] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ទីមិនមានភ័យ ទីមិនមានភ័យ ដូច្នេះ ។

## អភយបត្តសូត្រទី ៦

[ ៥៧ ] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា បុគ្គលដល់នូវទីមិនមានភ័យ ដល់នូវទីមិនមានភ័យ ដូច្នេះ ។

## បស្សទ្ធិសូត្រទី ៧

[ ៥៨ ] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា សេចក្តីស្ងប់រម្ងាប់ សេចក្តីស្ងប់រម្ងាប់ ដូច្នេះ ។

## អនុបុព្វបស្សទ្ធិសូត្រទី ៨

[ ៥៩ ] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា សេចក្តីស្ងប់រម្ងាប់ដោយលំដាប់ សេចក្តីស្ងប់រម្ងាប់ដោយលំដាប់ ដូច្នេះ ។

## និរោធសូត្រទី ៩

[ ៦០ ] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា សេចក្តីរលត់ សេចក្តីរលត់ ដូច្នេះ ។

## អនុបុព្វនិរោធសូត្រទី ១០

[ ៦១ ] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា សេចក្តីរលត់ដោយលំដាប់ៗ ដូច្នេះ ម្នាលអាវុសោ សេចក្តីរលត់ដោយលំដាប់ ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយ តើដោយហេតុប៉ុន្មាន ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់នូវបឋមជ្ឈាន ម្នាលអាវុសោ សេចក្តីរលត់ដោយលំដាប់ ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ ដោយបរិយាយត្រឹមប៉ុណ្ណោះឯង ។បេ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបានដល់នូវសញ្ញាវេទយិតនិរោធ ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង អាសវៈទាំងឡាយរបស់ភិក្ខុនោះក៏អស់រលីងទៅ ព្រោះឃើញដោយបញ្ញា ម្នាលអាវុសោ សេចក្តីរលត់ដោយលំដាប់ ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយដោយនិប្បរិយាយត្រឹមប៉ុណ្ណោះឯង ។

## ធម្មបហាយភព្វសូត្រទី ១១

[ ៦២ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់នូវធម៌ ៩ យ៉ាង មិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តបាន ។ ធម៌ ៩ យ៉ាង តើដូចម្តេចខ្លះ ។ គឺរាគៈ ១ ទោសៈ ១ មោហៈ ១ កោធៈ ១ ឧបនាហៈ ១ មក្ខៈ

១ បលាសៈ ១ ឥស្សា ១ មច្ឆរិយៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនទាន់លះបង់នូវធម៌ ៩ យ៉ាងនេះទេ មិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលបានលះបង់នូវធម៌ ៩ យ៉ាងនេះហើយ គួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តបាន ។ ធម៌ ៩ យ៉ាងតើដូចម្ដេចខ្លះ ។ គឺរាគៈ ១ ទោសៈ ១ មោហៈ ១ កោធៈ ១ ឧបនាហៈ ១ មក្ខៈ ១ បលាសៈ ១ ឥស្សា ១ មច្ឆរិយៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់នូវធម៌ ៩ យ៉ាងនេះឯងហើយ ទើបគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តបាន ។

### ខេមវគ្គទី ១ ចប់

## ឧទ្ទានក្នុងខេមវគ្គនោះ គឺ

និយាអំពីសេចក្ដីក្សេម ១ អ្នកដល់នូវសេចក្ដីក្សេម ១ អមតៈ ១ អ្នកដល់នូវអមតៈ ១ ទីមិនមានភ័យ ១ អ្នកដល់នូវទីមិនមានភ័យ ១ សេចក្ដីស្ងប់រម្ងាប់ ១ សេចក្ដីស្ងប់រម្ងាប់ដោយលំដាប់ ១ សេចក្ដីរលត់ ១ សេចក្ដីរលត់ដោយលំដាប់ ១ និងបុគ្គលលះបង់នូវធម៌ ៩ យ៉ាង គួរធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្ត ១ ។

# សុត្តន្តបិដក

## សតិប្បដ្ឋានវគ្គទី ២

### សិក្ខាសូត្រទី ១

[ ៦៣ ] ម្នាលភិក្ខុទាំងឡាយ ហេតុនៃសិក្ខាមានកម្លាំងថយនេះ មាន ៥ យ៉ាង ។ ហេតុនៃសិក្ខាមានកម្លាំងថយ ៥ យ៉ាង តើអ្វីខ្លះ ។ គឺបាណាតិបាត ១ អទិន្នាទាន ១ កាមេសុមិច្ឆាចារ ១ មុសាវាទ ១ សុរាមេរយមជ្ជប្បមាទដ្ឋាន ១ ។ ម្នាលភិក្ខុទាំងឡាយ ហេតុនៃសិក្ខាមានកម្លាំងថយ មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើនសតិប្បដ្ឋាន ៤ ដើម្បីលះបង់នូវហេតុនៃសិក្ខា មានកម្លាំងថយ ៥ យ៉ាងនេះឯង ។ សតិប្បដ្ឋាន ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតីកម្ចាត់បង់នូវអភិជ្ឈា និងទោមនស្ស ក្នុងលោកចេញ ១ ក្នុងវេទនាទាំងឡាយ ១ ។បេ។ ក្នុងចិត្ត ១ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្ស ក្នុងលោកចេញ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើននូវសតិប្បដ្ឋាន ៤ នេះ ដើម្បីលះបង់នូវហេតុនៃសិក្ខាមានកម្លាំងថយ ៥ យ៉ាងនេះឯង ។

## នីវរណសូត្រទី ២

[ ៦៤ ] ម្នាលភិក្ខុទាំងឡាយ នីវរណធម៌នេះមាន ៥ យ៉ាង ។ នីវរណធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺកាមច្ឆន្ទនីវរណៈ ១ ព្យាបាទនីវរណៈ ១ ថីនមិទ្ធនីវរណៈ ១ ឧទ្ធច្ចកុក្កុច្ចនីវរណៈ ១ វិចិកិច្ឆានីវរណៈ ១ ។ ម្នាលភិក្ខុទាំងឡាយ នីវរណធម៌មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើននូវសតិប្បដ្ឋាន ៤ ដើម្បីលះបង់នូវនីវរណៈ ៥ យ៉ាងនេះឯង ។ សតិប្បដ្ឋាន ៤ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយ ក្នុងកាយជាប្រក្រតី មានព្យាយាម ជាគ្រឿងដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ១ ក្នុងវេទនាទាំងឡាយ ១ ។បេ។ ក្នុងចិត្ត ១ ពិចារណាឃើញនូវធម៌ ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតីកម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើននូវសតិប្បដ្ឋាន ៤ នេះ ដើម្បីលះបង់នូវនីវរណៈ ៥ យ៉ាងនេះឯង ។

## កាមគុណសូត្រទី ៣

[ ៦៥ ] ម្នាលភិក្ខុទាំងឡាយ កាមគុណនេះ មាន ៥ យ៉ាង ។ កាមគុណ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺរូបដែលគប្បីដឹងដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ ១ សំឡេងដែលគប្បីដឹងដោយត្រចៀក ១ ។បេ។

ក្លិនដែលគប្បីដឹងដោយច្រមុះ ១ រសដែលគប្បីដឹងដោយអណ្ដាត ១ ផ្សព្វដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្ដីត្រេកអរ ១ ។ ម្នាលភិក្ខុទាំងឡាយ កាមគុណមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើននូវសតិប្បដ្ឋាន ៤ យ៉ាងនេះ ដើម្បីលះបង់នូវកាមគុណ ៥ យ៉ាងនេះឯង ។

## ឧបាទានក្ខន្ធសូត្រទី ៨

[ ៦៦ ] ម្នាលភិក្ខុទាំងឡាយ ឧបាទានក្ខន្ធនេះ មាន ៥ យ៉ាង ។ ឧបាទានក្ខន្ធ ៥ យ៉ាង តើដូចម្ដេចខ្លះ ។ គឺរូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ ។ ម្នាលភិក្ខុទាំងឡាយ ឧបាទានក្ខន្ធ មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើននូវសតិប្បដ្ឋាន ៤ យ៉ាងនេះ ដើម្បីលះបង់នូវឧបាទានក្ខន្ធ ៥ យ៉ាងនេះឯង ។

## ឱរម្ភាគិយសូត្រទី ៩

[ ៦៧ ] ម្នាលភិក្ខុទាំងឡាយ សំយោជនៈ ជាចំណែកខាងក្រោមនេះ មាន ៥ យ៉ាង ។ សំយោជនៈ ៥ យ៉ាង តើដូចម្ដេចខ្លះ ។ គឺសក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១ កាមច្ឆន្ទៈ ១ ព្យាបាទៈ ១ ។ ម្នាលភិក្ខុទាំងឡាយ សំយោជនៈជាចំណែកខាងក្រោមមាន ៥ យ៉ាងនេះឯង ។ ម្នាល

ភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើននូវសតិប្បដ្ឋាន ៤ យ៉ាងនេះ ដើម្បីលះបង់នូវសំយោជនៈ ជាចំណែកខាងក្រោម ៥ យ៉ាងនេះឯង ។

## គតិសូត្រទី ៦

[ ៦៨ ] ម្នាលភិក្ខុទាំងឡាយ គតិនេះ មាន ៥ យ៉ាង ។ គតិ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺនិរយៈ ១ តិរច្ឆានយោនិ ១ បិត្តិវិស័យ ១ មនុស្ស ១ ទេវតា ១ ។ ម្នាលភិក្ខុទាំងឡាយ គតិមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើននូវសតិប្បដ្ឋាន ៤ យ៉ាងនេះ ដើម្បីលះបង់នូវគតិ ៥ យ៉ាងនេះឯង ។

## មច្ឆរិយសូត្រទី ៧

[ ៦៩ ] ម្នាលភិក្ខុទាំងឡាយ សេចក្តីកំណាញ់នេះ មាន ៥ យ៉ាង ។ សេចក្តីកំណាញ់ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់គុណ ១ កំណាញ់ធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីកំណាញ់មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើននូវសតិប្បដ្ឋាន ៤ យ៉ាងនេះ ដើម្បីលះបង់នូវសេចក្តីកំណាញ់ ៥ យ៉ាងនេះឯង ។

## ឧទ្ធម្ភាគិយសូត្រទី ៨

[ ៧០ ] ម្នាលភិក្ខុទាំងឡាយ សំយោជនៈ ជាចំណែកខាងលើនេះ មាន ៥ យ៉ាង ។ សំយោជនៈ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺរូបរាគៈ ១

អរូបរាគៈ ១ មានះ ១ ឧទ្ធច្ចៈ ១ អវិជ្ជា ១ ។ ម្នាលភិក្ខុទាំងឡាយ សំយោជនៈ ជាចំណែកខាងលើ មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុគួរចម្រើននូវសតិប្បដ្ឋាន ៤ យ៉ាងនេះ ដើម្បីលះបង់សំយោជនៈ ជាចំណែកខាងលើ ៥ យ៉ាងនេះឯង ។

# ចេតោខីលសូត្រទី ៩

[ ៧១ ] ម្នាលភិក្ខុទាំងឡាយ សេចក្ដីរឹងត្អឹងនៃចិត្តនេះមាន ៥ យ៉ាង ។ សេចក្ដីរឹងត្អឹងនៃចិត្ត ៥ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ សង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះថ្លា ក្នុងព្រះសាស្ដា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា សង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះថ្លា ក្នុងព្រះសាស្ដា ចិត្តរបស់ភិក្ខុនោះ រមែងមិនឱនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្ដៅកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាម ។ ចិត្តរបស់ភិក្ខុណា មិនឱនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្ដៅកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាម មិនដាច់ ដើម្បីតាំងទុកនូវព្យាយាម នេះជាសេចក្ដីរឹងត្អឹងនៃចិត្តទី ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុសង្ស័យក្នុងព្រះធម៌ ។បេ។ សង្ស័យក្នុងព្រះសង្ឃ សង្ស័យក្នុងសិក្ខា ជាមនុស្សខឹង មានចិត្តអាក់អន់ មានចិត្តត្រូវទោសខ្ទាំងខ្ទប់ហើយ មានចិត្តរឹងរូស ក្នុងពួកសព្រហ្មចារី ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ជាមនុស្សខឹង មានចិត្តអាក់

អន់ មានចិត្តត្រូវទោសខ្ទាំងខ្ទប់ហើយ មានចិត្តរឹងរូស ក្នុងពួកសព្រហ្មចារី ចិត្តរបស់ភិក្ខុនោះ រមែងមិនឱនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាម មិនដាច់ ដើម្បីតាំងទុកនូវព្យាយាម ។ ចិត្តរបស់ភិក្ខុណា រមែងមិនឱនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាម មិនដាច់ ដើម្បីតាំងទុកនូវព្យាយាម នេះជាសេចក្តីរឹងត្អឹងនៃចិត្តទី ៥ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើននូវសតិប្បដ្ឋាន ៤ យ៉ាងនេះ ដើម្បីលះបង់នូវសេចក្តីរឹងត្អឹងនៃចិត្ត ៥ យ៉ាងនេះឯង ។

## វិនិពន្ធសូត្រទី ១០

[ ៧២ ] ម្នាលភិក្ខុទាំងឡាយ ចំណងរបស់ចិត្តនេះ មាន ៥ យ៉ាង ។ ចំណងរបស់ចិត្ត ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកសេចក្តីពេញចិត្ត មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីក្តៅក្រហាយ មិនទាន់ប្រាសចាកសេចក្តីប្រាថ្នា ក្នុងកាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា មិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកសេចក្តីពេញចិត្ត មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីក្តៅក្រហាយ មិនទាន់ប្រាសចាកសេចក្តីប្រាថ្នា ក្នុងកាមទាំងឡាយ

ចិត្តរបស់ភិក្ខុនោះ រមែងមិនឱនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាម មិនដាច់ ដើម្បីតាំងទុកនូវព្យាយាម ។ ចិត្តរបស់ភិក្ខុណា មិនឱនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាម មិនដាច់ ដើម្បីតាំងទុកនូវព្យាយាម នេះជាចំណងនៃចិត្តទី ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមិនទាន់ប្រាសចាកតម្រេកក្នុងកាយ មិនទាន់ប្រាសចាកតម្រេកក្នុងរូប ជាអ្នកបរិភោគភោជន ដរាបដល់ឆ្អែតពេញផ្ទៃ ហើយប្រកបរឿយៗ នូវទីដេកស្រួល នូវទីផ្អែកស្រួល និងសេចក្តីលក់ស្រួល ប្រព្រឹត្តព្រហ្មចារ្យ ប្រាថ្នានូវទេវនិកាយណាមួយ ដោយគិតថា អាត្មាអញនឹងបានជាទេវតាមានសក្តិធំ ឬជាទេវតាមានសក្តិតូចណាមួយ ដោយសីល ឬវត្ត តបៈ ឬព្រហ្មចារ្យនេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាប្រព្រឹត្តព្រហ្មចារ្យ ប្រាថ្នានូវទេវនិកាយណាមួយ ដោយគិតថា អាត្មាអញនឹងបានជាទេវតាមានសក្តិធំ ឬជាទេវតាមានសក្តិតូចណាមួយ ដោយសីល ឬវត្ត តបៈ ឬព្រហ្មចារ្យនេះ ចិត្តរបស់ភិក្ខុនោះ រមែងមិនឱនទៅ ដើម្បីព្យាយាមជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាម មិនដាច់ ដើម្បីតាំងទុកនូវព្យាយាម ។ ចិត្តរបស់ភិក្ខុណា រមែងមិនឱនទៅដើម្បីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាម នេះជាចំណងនៃចិត្ត

ទី ៥ ។ ម្នាលភិក្ខុទាំងឡាយ ចំណងរបស់ចិត្ត មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើននូវសតិប្បដ្ឋាន ៤ ដើម្បីលះបង់នូវចំណងរបស់ចិត្ត ៥ យ៉ាងនេះ ។ សតិប្បដ្ឋាន ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណារឿយៗ នូវកាយ ក្នុងកាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតីកម្ចាត់បង់នូវអភិជ្ឈា និងទោមនស្ស ក្នុងលោកចេញ ក្នុងវេទនាទាំងឡាយ ។បេ។ ក្នុងចិត្តពិចារណារឿយៗនូវធម៌ ក្នុងធម៌ទាំងឡាយ ជាប្រក្រតី មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតីកម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើននូវសតិប្បដ្ឋាន ៤ យ៉ាង ដើម្បីលះបង់នូវចំណងរបស់ចិត្ត ៥ យ៉ាងនេះឯង ។

សតិប្បដ្ឋានវគ្គទី ២ ចប់

## ឧទ្ទានក្នុងសតិប្បដ្ឋានវគ្គនោះ គឺ

និយាយអំពីសិក្ខា ១ នីវរណៈ ១ កាម ១ ឧបាទានក្ខន្ធ
១ សំយោជនៈជាចំណែកខាងក្រោម ១ គតិ ១ សេចក្តី
កំណាញ់ ១ សំយោជនៈជាចំណែកខាងលើជាគម្រប់ប្រាំ
បី ១ សេចក្តីរឹងត្អឹងនៃចិត្ត ១ និងចំណងរបស់ចិត្ត ១ ។

# អដ្ឋកថា

# វគ្គដែលមិនសង្គ្រោះចូលក្នុងបណ្ណាសក

## ខេមវគ្គទី ១

### ខេមសូត្រជាដើម

[ ៥២-៧២ ] *ក្នុងសូត្រទាំងឡាយដទៃក្រៅអំពីនេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា* **ខេមំ** *បានដល់ មិនមានអន្តរាយ ។ បទថា* **ខេមប្បត្តោ** *បានដល់ ដល់នូវភាពជាបុគ្គលមិនមានអន្តរាយ ។ បទថា* **សិក្ខាទុព្វល្យានិ** *បានដល់ ហេតុនៃការអស់កម្លាំងរបស់សិក្ខា ។ ពាក្យដ៏សេស ក្នុងបទទាំងអស់ មានអត្ថងាយយល់ហើយ ដោយប្រការដូច្នេះ ។*

**អដ្ឋកថា ខេមវគ្គជាដើម ចប់**

# សុត្តន្តបិដក

## សម្មប្បធានវគ្គទី ៣

[ ៧៣ ] ម្នាលភិក្ខុទាំងឡាយ ហេតុនៃសិក្ខា មានកម្លាំងថយនេះ មាន ៥ យ៉ាង ។ ហេតុនៃសិក្ខាមានកម្លាំងថយ ៥ យ៉ាង តើដូចម្តេច ។ គឺ បាណាតិបាត ១ ។បេ។ សុរាមេរយមជ្ជប្បមាទដ្ឋាន ១ ។ ម្នាលភិក្ខុទាំង-ឡាយ ហេតុនៃសិក្ខាមានកម្លាំងថយមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុ ទាំងឡាយ ភិក្ខុគួរចម្រើនសម្មប្បធាន ៤ យ៉ាង ដើម្បីលះបង់នូវហេតុនៃ សិក្ខាមានកម្លាំងថយ ៥ យ៉ាងនេះ ។ សម្មប្បធាន ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើតឡើង សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីជុតអកុសលធម៌ទាំងឡាយដ៏ លាមក ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ១ ញុំាងឆន្ទៈឲ្យ កើតឡើង សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីលះបង់នូវ អកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតឡើងហើយ ១ ញុំាងឆន្ទៈឲ្យ កើតឡើង សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីបណ្តុះបណ្តាល កុសលធម៌ទាំងឡាយ ដែលមិនទាន់កើតឡើង ឲ្យកើតឡើងបាន ១ ញុំាង ឆន្ទៈឲ្យកើតឡើង សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីញុំាង កុសលធម៌ទាំងឡាយ ដែលកើតឡើងហើយ ឲ្យឋិតនៅ មិនឲ្យវិនាសទៅ ឲ្យរឹងរឹតតែចម្រើនឡើង ឲ្យធំទូលាយ ឲ្យចម្រើនពេញលេញ ១ ។ ម្នាល ភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើនសម្មប្បធាន ៤ យ៉ាងនេះ ដើម្បីលះបង់នូវ

ហេតុនៃសិក្ខា មានកម្លាំងថយ ៥ យ៉ាងនេះឯង ។ បណ្ឌិតសម្តែងសេចក្តីឲ្យពិស្តារ ដោយអំណាចសម្មប្បធានត្រឹមណាផងចុះ ។

[ ៧៤ ] ម្នាលភិក្ខុទាំងឡាយ ចំណងនៃចិត្តនេះ មាន ៥ យ៉ាង ។ ចំណងរបស់ចិត្ត ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនទាន់ប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ។បេ។ ម្នាលភិក្ខុទាំងឡាយ ចំណងរបស់ចិត្តមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើនសម្មប្បធាន ៤ យ៉ាង ដើម្បីលះបង់នូវចំណងរបស់ចិត្ត ៥ យ៉ាងនេះ ។ សម្មប្បធាន ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើតឡើង សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីជុតអកុសលធម៌ទាំងឡាយដ៏លាមកដែលមិនទាន់កើត មិនឲ្យកើតឡើងបាន ១ ដើម្បីលះបង់នូវអកុសលធម៌ទាំងឡាយដ៏លាមកដែលកើតឡើងហើយ ១ ។បេ។ ញុំាងឆន្ទៈឲ្យកើតឡើង សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីញុំាងកុសលធម៌ទាំង-ឡាយ ដែលមិនទាន់កើតឡើង ឲ្យកើតបាន ១ ដើម្បីញុំាងកុសលធម៌ទាំង-ឡាយ ដែលកើតឡើងហើយ ឲ្យឋិតនៅ មិនឲ្យវិនាសទៅ ឲ្យរឹងរឹតតែចម្រើនឡើង ឲ្យធំទូលាយ ឲ្យចម្រើនពេញលេញ ១ ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុគួរចម្រើនសម្មប្បធាន ៤ យ៉ាងនេះ ដើម្បីលះបង់នូវចំណងរបស់ចិត្ត ៥ យ៉ាងនេះឯង ។

សម្មប្បធានវគ្គទី ៣ ចប់

# អដ្ឋកថា

## សម្មប្បធានវគ្គទី ៣

*[ ៧៣-៧៤ ] សម្មប្បធានវគ្គទី ៣ មានអត្ថងាយយល់ទាំងអស់ហើយ ។*

*អដ្ឋកថាសម្មប្បធានវគ្គទី ៣ ចប់*

# សុត្តន្តបិដក

## ឥទ្ធិបាទវគ្គទី៤

*[ ៧៥ ] ម្នាលភិក្ខុទាំងឡាយ ហេតុនៃសិក្ខា មានកម្លាំងថយនេះ មាន ៥ យ៉ាង ។ ហេតុនៃសិក្ខា មានកម្លាំងថយ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺ បាណាតិបាត ១ ។បេ។ សុរាមេរយមជ្ជប្បមាទដ្ឋាន ១ ។ ម្នាលភិក្ខុទាំង-ឡាយ ហេតុនៃសិក្ខា មានកម្លាំងថយមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើនឥទ្ធិបាទ ៤ យ៉ាង ដើម្បីលះបង់នូវហេតុនៃសិក្ខា មានកម្លាំងថយ ៥ យ៉ាងនេះ ។ ឥទ្ធិបាទ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនឥទ្ធិបាទ ដែលប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ១ ចម្រើនឥទ្ធិបាទដែលប្រកបដោយវីរិយ-សមាធិ និងបធានសង្ខារ ១ ចម្រើនឥទ្ធិបាទ ដែលប្រកបដោយចិត្តសមាធិ និងបធានសង្ខារ ១ ចម្រើនឥទ្ធិបាទ ដែលប្រកបដោយវីមំសាសមាធិ និង*

បធានសង្ខារ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើនឥទ្ធិបាទ ៤ យ៉ាងនេះ ដើម្បីលះបង់នូវហេតុនៃសិក្ខា មានកម្លាំងថយ ៥ យ៉ាងនេះឯង ។ ( បទដ៏សេសទាំង ២ ត្រូវសម្តែងឲ្យពិស្តារដោយអំណាចឥទ្ធិបាទផងចុះ ) ។

[ ៧៦ ] ម្នាលភិក្ខុទាំងឡាយ ចំណងរបស់ចិត្តនេះ មាន ៥ យ៉ាង ។ ចំណងរបស់ចិត្ត ៥ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនទាន់ប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ។បេ។ ម្នាលភិក្ខុទាំងឡាយ ចំណងរបស់ចិត្តមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើនឥទ្ធិបាទ ៤ យ៉ាងនេះ ដើម្បីលះបង់នូវចំណងរបស់ចិត្ត ៥ យ៉ាងនេះឯង ។ ឥទ្ធិបាទ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទ ដែលប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ចម្រើនឥទ្ធិបាទ ដែលប្រកបដោយវិរិយសមាធិ ចិត្តសមាធិ វីមំសាសមាធិ និងបធានសង្ខារ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើនឥទ្ធិបាទ ៤ យ៉ាងនេះ ដើម្បីលះបង់នូវចំណងរបស់ចិត្ត ៥ យ៉ាងនេះឯង ។

**ឥទ្ធិបាទវគ្គទី ៤ ចប់**

គប្បីប្រកបសតិប្បដ្ឋាន ៤ យ៉ាង បទ គឺសម្មប្បធាន
៤ យ៉ាង ឥទ្ធិបាទ ៤ យ៉ាង តាមន័យដែលមានមក
ហើយក្នុងខាងដើមផងចុះ ។

# អដ្ឋកថា

## ឥទ្ធិបាទវគ្គទី ៤

[ ៧៥-៧៦ ] ឥទ្ធិបាទវគ្គទី ៤ មានអត្ថងាយយល់ទាំងអស់ហើយ ។

អដ្ឋកថាឥទ្ធិបាទវគ្គទី ៤ ចប់

# សុត្តន្តបិដក

## វគ្គទី ៥

[ ៧៧ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើនធម៌ ៩ យ៉ាង ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៩ យ៉ាង តើដូចម្តេចខ្លះ ។ គឺសេចក្តីសម្គាល់ថាមិនល្អ ១ សេចក្តីសម្គាល់ដោយមរណានុបស្សនាញាណ ១ សេចក្តីសម្គាល់ក្នុងអាហារថាជារបស់គួរខ្ពើម ១ សេចក្តីសម្គាល់ក្នុងលោកទាំងពួងថា មិនគួរត្រេកអរ ១ សេចក្តីសម្គាល់ថា មិនទៀង ១ សេចក្តីសម្គាល់ក្នុងរបស់ដែលមិនទៀងថាជាទុក្ខ ១ សេចក្តីសម្គាល់ក្នុងរបស់ដែលជាទុក្ខថាមិនមែនរបស់ខ្លួន ១ សេចក្តីសម្គាល់នូវរបស់ដែលត្រូវលះបង់ ១ សេចក្តីសម្គាល់ថា គួរនឿយណាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើនធម៌ ៩ យ៉ាងនេះ ដើម្បីដឹងច្បាស់នូវរាគៈ ។

[ ៧៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើនធម៌ ៩ យ៉ាង ដើម្បីដឹង

ច្បាស់នូវរាគៈ ។ ធម៌ ៩ យ៉ាង តើដូចម្តេចខ្លះ ។ គឺ បឋមជ្ឈាន ១ ទុតិយជ្ឈាន ១ តតិយជ្ឈាន ១ ចតុត្ថជ្ឈាន ១ អាកាសានញ្ចាយតនជ្ឈាន ១ វិញ្ញាណញ្ចាយតនជ្ឈាន ១ អាកិញ្ចញ្ញាយតនជ្ឈាន ១ នេវសញ្ញានាសញ្ញាយតនជ្ឈាន ១ សញ្ញាវេទយិតនិរោធ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើនធម៌ ៩ យ៉ាងនេះឯង ដើម្បីដឹងច្បាស់នូវរាគៈ ។

[ ៧៩ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើននូវធម៌ ៩ យ៉ាងនេះ ដើម្បីកំណត់ដឹង ដើម្បីអស់រលីងទៅ ដើម្បីលះ ដើម្បីអស់ទៅ ដើម្បីសូន្យទៅ ដើម្បីនឿយណាយ ដើម្បីរលត់ ដើម្បីលះបង់ ដើម្បីរលាស់ចោលនូវរាគៈ ។ ភិក្ខុគួរចម្រើនធម៌ ៩ យ៉ាងនេះ ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់រលីងទៅ ដើម្បីលះ ដើម្បីអស់ទៅ ដើម្បីសូន្យទៅ ដើម្បីនឿយណាយ ដើម្បីរលត់ ដើម្បីលះបង់ ដើម្បីរលាស់ចោលនូវទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ ឥស្សា មច្ឆរិយៈ មាយា សាថេយ្យៈ ថម្ភៈ សារម្ភៈ មានះ អតិមានះ មទៈ បមាទៈ ។ លុះព្រះដ៏មានព្រះភាគទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ។ ភិក្ខុទាំងនោះ ក៏ពេញចិត្តត្រេកអរនឹងភាសិតរបស់ព្រះដ៏មានព្រះភាគ ។

**នវកនិបាត ចប់**

# អដ្ឋកថា

## វគ្គទី ៩

[ ៧៧-៧៩ ] *វគ្គទី ៩ មានអត្ថងាយយល់ទាំងអស់ហើយ ។*

**អដ្ឋកថា វគ្គទី ៩ ចប់**

**វគ្គក្រៅបណ្ណាសក ចប់**

**នវកនិបាត ចប់**

# សុត្តន្តបិដក
# អង្គុត្តរនិកាយ ទសកនិបាត
# ឯកាទសមភាគ

*សូមនមស្ការចំពោះព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ*

# បឋមបណ្ណាសក

## អានិសំសវគ្គទី ១

### កិមត្ថិយសូត្រទី ១

*[ ១ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកសីលជាកុសល មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ ពួកសីលជាកុសល មានអវិប្បដិសារៈ ( សេចក្តីមិនក្តៅក្រហាយ ) ជាប្រយោជន៍ មានអវិប្បដិសារៈ ជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះអវិប្បដិសារៈ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិ-*

សង្ស ។ ម្នាលអានន្ទ អវិប្បដិសារៈ មានបាមុជ្ជ ( សេចក្ដីរីករាយ ) ជាប្រយោជន៍ មានបាមុជ្ជជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះបាមុជ្ជមានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ បាមុជ្ជ មានបីតិ ( សេចក្ដីឆ្អែតចិត្ត ) ជាប្រយោជន៍ មានបីតិជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះបីតិមានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ បីតិមានបស្សទ្ធិ ( សេចក្ដីស្ងប់ ) ជាប្រយោជន៍ មានបស្សទ្ធិជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះបស្សទ្ធិមានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ បស្សទ្ធិមានសុខជាប្រយោជន៍ មានសុខជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះសុខមានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ សុខមានសមាធិជាប្រយោជន៍ មានសមាធិជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះសមាធិមានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ សមាធិមានយថាភូតញ្ញាណទស្សនៈ ( វិបស្សនាញាណទន់ខ្ចី ) ជាប្រយោជន៍ មានយថាភូតញ្ញាណទស្សនៈជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះយថាភូតញ្ញាណទស្សនៈ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ យថាភូតញ្ញាណទស្សនៈ មាននិព្វិទា និងវិរាគៈ ( វិបស្សនាញាណដ៏មានកម្លាំង និងមគ្គ ) ជាប្រយោជន៍ មាននិព្វិទា និងវិរាគៈជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះនិព្វិទា និងវិរាគៈ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ និព្វិទា និងវិរាគៈ មានវិមុត្តិញ្ញាណទស្សនៈ

( អរហត្តផល និងបច្ចវេក្ខណញ្ញាណ ) ជាប្រយោជន៍ មានវិមុត្តិញ្ញាណ-ទស្សនៈ ជាអានិសង្ស ។ ម្នាលអានន្ទ ពួកសីលជាកុសល មានអវិប្បដិសារៈ ជាប្រយោជន៍ មានអវិប្បដិសារៈ ជាអានិសង្ស អវិប្បដិសារៈ មានបាមុជ្ជ ជាប្រយោជន៍ មានបាមុជ្ជជាអានិសង្ស បាមុជ្ជ មានបីតិជាប្រយោជន៍ មានបីតិ ជាអានិសង្ស បីតិ មានបស្សទ្ធិជាប្រយោជន៍ មានបស្សទ្ធិជាអានិសង្ស បស្សទ្ធិ មានសុខជាប្រយោជន៍ មានសុខជាអានិសង្ស សុខ មានសមាធិជាប្រយោជន៍ មានសមាធិជាអានិសង្ស សមាធិ មានយថាភូតញ្ញាណទស្សនៈ ជាប្រយោជន៍ មានយថាភូតញ្ញាណទស្សនៈ ជាអានិសង្ស យថាភូតញ្ញាណទស្សនៈ មាន និព្វិទា និងវិរាគៈ ជាប្រយោជន៍ មាននិព្វិទា និងវិរាគៈ ជាអានិសង្ស និព្វិទា និងវិរាគៈ មានវិមុត្តិញ្ញាណទស្សនៈ ជាប្រយោជន៍ មានវិមុត្តិញ្ញាណទស្សនៈ ជាអានិសង្ស ដោយប្រការដូច្នេះឯង ។ ម្នាលអានន្ទ ពួកសីលជាកុសល រមែង ញ៉ាំងធម៌ទាំងនោះ ឲ្យពេញតាមលំដាប់ ដើម្បីព្រះអរហត្តដោយ ប្រការដូច្នេះ ។

# អដ្ឋកថា
# អង្គុត្តរនិកាយ ឈ្មោះ មនោរថបូរណី
# ទសកនិបាត
# បឋមបណ្ណាសកៈ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## អានិសំសវគ្គទី ១
## កិមត្ថិយសូត្រ

[ ១ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងកិមត្ថិយសូត្រទី ១ នៃទសកនិបាតដូចតទៅ បទថា* **កុសលានិ សីលានិ** *បានដល់ សីលដែលមិនមានទោស ។* **សីល** *ឈ្មោះថា មានការមិនក្តៅក្រហាយចិត្តជាប្រយោជន៍ ព្រោះប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ដល់ភាពជាអ្នកមិនខ្មាសអៀន មិនក្តៅក្រហាយចិត្ត ឈ្មោះថា មានការមិនក្តៅក្រហាយចិត្តជាអានិសង្ស គឺផលល្អ ព្រោះសីលទាំងនោះមានការមិនក្តៅក្រហាយចិត្តនោះឯង ជាអានិសង្ស ។ ក្នុងពាក្យថា* **យថាភូតញ្ញាណទស្សនត្ថោ** *ជាដើម វិបស្សនាយ៉ាងទន់ ឈ្មោះថា* **យថាភូតញ្ញាណទស្សនៈ** *វិបស្សនាដែលមានកម្លាំងឈ្មោះថា* **និព្វិទា** *មគ្គ ឈ្មោះថា*

**វិភាគ** អរហត្តផល ឈ្មោះថា **វិមុត្តិ** បច្ចវេក្ខណញ្ញាណ ឈ្មោះថា **ញាណទស្សនៈ** ។ បទថា **អរហត្តាយ ប្ចូរេន្តិ** បានដល់ រមែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ដល់អរហត្ត ។ល។

**អដ្ឋកថា កិមត្ថិយសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ចេតនាសូត្រទី ២

[ ២ ] ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានសីល បរិបូណ៌ដោយសីលហើយ មិនបាច់ធ្វើដោយចេតនាថា អវិប្បដិសារៈចូរកើតឡើងដល់អាត្មាអញ ។ ម្នាលភិក្ខុទាំងឡាយ អវិប្បដិសារៈ កើតឡើងដល់បុគ្គលមានសីល អ្នកបរិបូណ៌ដោយសីល ដោយហេតុណា ហេតុនុ៎ះរមែងមានជាធម្មតា ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គល មិនមានវិប្បដិសារៈហើយ មិនបាច់ធ្វើដោយចេតនាថា បាមុជ្ជចូរកើតឡើងដល់អាត្មាអញ ។ ម្នាលភិក្ខុទាំងឡាយ បាមុជ្ជ កើតឡើងដល់បុគ្គលមិនមានវិប្បដិសារៈ ដោយហេតុណា ហេតុនុ៎ះរមែងមានជាធម្មតា ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានបាមុជ្ជហើយ មិនបាច់ធ្វើដោយចេតនាថា បីតិចូរកើតឡើងដល់អាត្មាអញ ។ ម្នាលភិក្ខុទាំងឡាយ បីតិ

កើតឡើងដល់បុគ្គលអ្នកមានបាមុជ្ជ ដោយហេតុណា ហេតុនុ៎ះរមែងមានជាធម្មតា ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គល មានចិត្តប្រកបដោយបីតិហើយ មិនបាច់ធ្វើដោយចេតនាថា កាយរបស់អាត្មាអញចូរស្ងប់រម្ងាប់ ។ ម្នាលភិក្ខុទាំងឡាយ កាយស្ងប់រម្ងាប់ ដល់បុគ្គលមានចិត្តប្រកបដោយបីតិ ដោយហេតុណា ហេតុនុ៎ះរមែងមានជាធម្មតា ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គល មានកាយស្ងប់រម្ងាប់ហើយ មិនបាច់ធ្វើដោយចេតនាថា អាត្មាអញនឹងសោយសុខ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានកាយស្ងប់រម្ងាប់សោយសុខ ដោយហេតុណា ហេតុនុ៎ះរមែងមានជាធម្មតា ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានសុខហើយ មិនបាច់ធ្វើដោយចេតនាថា ចិត្តរបស់អាត្មាអញចូរនឹងធឹង ។ ម្នាលភិក្ខុទាំងឡាយ ចិត្តរបស់បុគ្គលមានសុខ នឹងធឹងដោយហេតុណា ហេតុនុ៎ះរមែងមានជាធម្មតា ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានចិត្តនឹងធឹងហើយ មិនបាច់ធ្វើដោយចេតនាថា អាត្មាអញនឹងដឹង នឹងឃើញតាមពិត ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានចិត្តនឹងធឹង ដឹង ឃើញតាមពិតដោយហេតុណា ហេតុនុ៎ះរមែងមានជាធម្មតា ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលដឹង ឃើញតាមពិតហើយ មិនបាច់ធ្វើដោយចេតនាថា អាត្មាអញនឹងធុញទ្រាន់ នឿយណាយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹង ឃើញតាមពិត ធុញទ្រាន់នឿយណាយ ដោយហេតុណា ហេតុនុ៎ះរមែងមានជាធម្មតា ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលធុញទ្រាន់ នឿយណាយហើយ មិនបាច់ធ្វើដោយចេតនាថា អាត្មាអញ

នឹងធ្វើឲ្យជាក់ច្បាស់ នូវវិមុត្តិញាណទស្សនៈ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលធុញទ្រាន់ នឿយណាយ ធ្វើឲ្យជាក់ច្បាស់នូវវិមុត្តិញាណទស្សនៈ ដោយហេតុណា ហេតុនុ៎ះរមែងមានជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ និព្វិទា និងវិរាគៈ មានវិមុត្តិញាណទស្សនៈជាប្រយោជន៍ មានវិមុត្តិញាណទស្សនៈជាអានិសង្ស យថាភូតញាណទស្សនៈ មាននិព្វិទា និងវិរាគៈជាប្រយោជន៍ មាននិព្វិទា និងវិរាគៈជាអានិសង្ស សមាធិ មានយថាភូតញាណទស្សនៈជាប្រយោជន៍ មានយថាភូតញាណទស្សនៈជាអានិសង្ស សុខ មានសមាធិជាប្រយោជន៍ មានសមាធិជាអានិសង្ស បស្សទ្ធិ មានសុខជាប្រយោជន៍ មានសុខជាអានិសង្ស បីតិ មានបស្សទ្ធិជាប្រយោជន៍ មានបស្សទ្ធិជាអានិសង្ស បាមុជ្ជ មានបីតិជាប្រយោជន៍ មានបីតិជាអានិសង្ស អវិប្បដិសារៈ មានបាមុជ្ជជាប្រយោជន៍ មានបាមុជ្ជៈជាអានិសង្ស ពួកសីលជាកុសល មានអវិប្បដិសារៈជាប្រយោជន៍ មានអវិប្បដិសារៈជាអានិសង្ស ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ តែងហូរទៅកាន់ធម៌ទាំងឡាយ ធម៌ទាំងឡាយ តែងញុំាងធម៌ទាំងឡាយឲ្យពេញ ដើម្បីចេញចាកទីមិនមែនជាត្រើយ គឺវដ្តៈប្រកបដោយភូមិ ៣ ហើយ ទៅកាន់ត្រើយ គឺព្រះនិព្វាន ដោយប្រការដូច្នេះឯង ។

# អដ្ឋកថា

## ចេតនាសូត្រ

[ ២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចេតនាសូត្រទី ២ ដូចតទៅនេះ បទថា **ន ចេតនាយ ករណីយំ** បានដល់ មិនគិត មិនកំណត់ធ្វើ ។ បទថា **ធម្មតា ឯសា** បានដល់ នុ៎ះជាសភាវធម៌ នេះជានិយមនៃហេតុ ។ បទថា **អភិសន្ទេន្តិ** បានដល់ ឲ្យប្រព្រឹត្តទៅ ។ បទថា **បរិបូរេន្តិ** បានដល់ ធ្វើឲ្យបរិបូណ៌ ។ បទថា **អបារាបរំ គមនាយ** បានដល់ ដើម្បីជាប្រយោជន៍ដល់ការទៅកាន់ត្រើយនាយ គឺព្រះនិព្វាន ចាកវដ្ដៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលជាត្រើយអាយ ។l៚

**អដ្ឋកថា ចេតនាសូត្រទី ២ ចប់**

# សុត្តន្តបិដក

## សីលសូត្រទី ៣

[ ៣ ] ម្នាលភិក្ខុទាំងឡាយ អវិប្បដិសារៈ របស់បុគ្គលទ្រុស្តសីល វិបត្តិចាកសីល រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើអវិប្បដិសារៈមិនមានហើយ បាមុជ្ជរបស់បុគ្គលវិបត្តិចាកអវិប្បដិសារៈ រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើបាមុជ្ជមិនមានហើយ បីតិរបស់បុគ្គលវិបត្តិចាកបាមុជ្ជ

រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើបីតិមិនមានហើយ បស្សទ្ធិរបស់បុគ្គលវិបត្តិចាកបីតិ រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើបស្សទ្ធិមិនមានហើយ សុខរបស់បុគ្គលវិបត្តិចាកបស្សទ្ធិ រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើសុខមិនមានហើយ សម្មាសមាធិ របស់បុគ្គលវិបត្តិចាកសុខ រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើសម្មាសមាធិមិនមានហើយ យថាភូតញ្ញាណទស្សនៈ របស់បុគ្គលវិបត្តិចាកសម្មាសមាធិ រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើយថាភូតញ្ញាណទស្សនៈមិនមានហើយ និព្វិទា និងវិរាគៈ របស់បុគ្គលវិបត្តិចាកយថាភូតញ្ញាណទស្សនៈ រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើនិព្វិទា និងវិរាគៈ មិនមានហើយ វិមុត្តិញ្ញាណទស្សនៈរបស់បុគ្គលវិបត្តិចាកនិព្វិទា និងវិរាគៈ រមែងសាបសូន្យចាកឧបនិស្ស័យ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចដើមឈើ ដែលមិនមានមែក និងស្លឹកហើយ ក្រមររបស់ឈើនោះក្តី ក៏មិនសូវបរិបូណ៌ សម្បកក្តី ស្រាយក្តី ខ្លឹមក្តី ក៏មិនសូវបរិបូណ៌យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អវិប្បដិសារៈរបស់បុគ្គលទ្រុស្តសីល វិបត្តិចាកសីល រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើអវិប្បដិសារៈមិនមានហើយ បាមុជ្ជរបស់បុគ្គលវិបត្តិចាកអវិប្បដិសារៈ រមែងសាបសូន្យចាកឧបនិស្ស័យ ។បេ។ វិមុត្តិញ្ញាណទស្សនៈ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ អវិប្បដិសារៈរបស់បុគ្គលមានសីល បរិបូណ៌ដោយសីល រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើមានអវិប្បដិសារៈហើយ បាមុជ្ជរបស់

បុគ្គលបរិបូណ៌ដោយអវិប្បដិសារៈ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើបាមុជ្ជមានហើយ បីតិរបស់បុគ្គលបរិបូណ៌ដោយបាមុជ្ជ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើបីតិមានហើយ បស្សទ្ធិរបស់បុគ្គលបរិបូណ៌ដោយបីតិ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើបស្សទ្ធិមានហើយ សុខរបស់បុគ្គលបរិបូណ៌ដោយបស្សទ្ធិ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើសុខមានហើយ សម្មាសមាធិរបស់បុគ្គលបរិបូណ៌ដោយសុខ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើសម្មាសមាធិមានហើយ យថាភូតញ្ញាណទស្សនៈរបស់បុគ្គលបរិបូណ៌ដោយសម្មាសមាធិ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើយថាភូតញ្ញាណទស្សនៈមានហើយ និព្វិទា និងវិរាគៈរបស់បុគ្គលបរិបូណ៌ដោយយថាភូតញ្ញាណទស្សនៈ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើនិព្វិទា និងវិរាគៈមានហើយ វិមុត្តិញ្ញាណទស្សនៈរបស់បុគ្គលបរិបូណ៌ដោយនិព្វិទា និងវិរាគៈ រមែងបរិបូណ៌ដោយឧបនិស្ស័យ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចដើមឈើដែលបរិបូណ៌ដោយមែក និងស្លឹកហើយ ក្រមររបស់ឈើនោះក្តី ក៏រមែងបរិបូណ៌ សម្បកក្តី ស្រាយក្តី ខ្លឹមក្តី ក៏រមែងបរិបូណ៌ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អវិប្បដិសារៈ របស់បុគ្គលមានសីល បរិបូណ៌ដោយសីល រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើអវិប្បដិសារៈមានហើយ បាមុជ្ជរបស់បុគ្គលបរិបូណ៌ដោយអវិប្បដិសារៈ រមែងបរិបូណ៌ដោយឧបនិស្ស័យ ។បេ។ វិមុត្តិញ្ញាណទស្សនៈ ក៏យ៉ាងនោះដែរ ។

# អដ្ឋកថា

## សីលសូត្រ

[ ៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសីលសូត្រទី ៣ ដូចតទៅនេះ បទថា **ហតូបនិសោ** ប្រែថា និព្វិទា និងវិរាគៈ មានហេតុត្រូវកម្ចាត់ចេញហើយ ។

**អដ្ឋកថា សីលសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ឧបនិសាសូត្រទី ៤ ជាដើម

[ ៤ ] ក្នុងទីនោះឯង ព្រះសារីបុត្តដ៏មានអាយុ មានថេរវាចានឹងភិក្ខុទាំងឡាយថា ម្នាលអាវុសោទាំងឡាយ អវិប្បដិសារៈរបស់បុគ្គលទ្រុស្តសីល វិបត្តិចាកសីល រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើអវិប្បដិសារៈមិនមានហើយ បាមុជ្ជរបស់បុគ្គលវិបត្តិចាកអវិប្បដិសារៈ រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើបាមុជ្ជមិនមានហើយ បីតិរបស់បុគ្គលវិបត្តិចាកបាមុជ្ជ រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើបីតិមិនមានហើយ បស្សទ្ធិរបស់បុគ្គលវិបត្តិចាកបីតិ រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើបស្សទ្ធិមិនមានហើយ សុខរបស់បុគ្គលវិបត្តិចាកបស្សទ្ធិ រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើសុខមិនមានហើយ សម្មាសមាធិរបស់បុគ្គលវិបត្តិចាកសុខ រមែង

សាបសូន្យចាកឧបនិស្ស័យ កាលបើសម្មាសមាធិមិនមានហើយ យថាភូតញ្ញាណទស្សនៈ របស់បុគ្គលវិបត្តិចាកសម្មាសមាធិ រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើយថាភូតញ្ញាណទស្សនៈមិនមានហើយ និព្វិទា និងវិរាគៈរបស់បុគ្គលវិបត្តិចាកយថាភូតញ្ញាណទស្សនៈ រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើនិព្វិទា និងវិរាគៈមិនមានហើយ វិមុត្តិញ្ញាណទស្សនៈរបស់បុគ្គលវិបត្តិចាកនិព្វិទា និងវិរាគៈ រមែងសាបសូន្យចាកឧបនិស្ស័យ ។ ម្នាលអាវុសោទាំងឡាយ ប្រៀបដូចដើមឈើ ដែលវិបត្តិចាកមែក និងស្លឹកហើយ ក្រមររបស់ឈើនោះក្តី ក៏មិនសូវបរិបូណ៌ សម្បកក្តី ស្រាយក្តី ខ្លឹមក្តី ក៏មិនសូវបរិបូណ៌ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ អវិប្បដិសារៈរបស់បុគ្គលទ្រុស្តសីល វិបត្តិចាកសីល រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើអវិប្បដិសារៈមិនមានហើយ បាមុជ្ជរបស់បុគ្គលវិបត្តិចាកអវិប្បដិសារៈ រមែងសាបសូន្យចាកឧបនិស្ស័យ ។បេ។ វិមុត្តិញ្ញាណទស្សនៈ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោទាំងឡាយ អវិប្បដិសារៈរបស់បុគ្គលមានសីល បរិបូណ៌ដោយសីលហើយ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើអវិប្បដិសារៈមានហើយ បាមុជ្ជរបស់បុគ្គលបរិបូណ៌ដោយអវិប្បដិសារៈ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើបាមុជ្ជមានហើយ បីតិរបស់បុគ្គលបរិបូណ៌ដោយបាមុជ្ជ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើបីតិមានហើយ បស្សទ្ធិរបស់បុគ្គលបរិបូណ៌ដោយបីតិ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើបស្សទ្ធិមានហើយ

សុខរបស់បុគ្គលបរិបូណ៌ដោយបស្សទ្ធិ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាល បើសុខមានហើយ សម្មាសមាធិរបស់បុគ្គលបរិបូណ៌ដោយសុខ រមែង បរិបូណ៌ដោយឧបនិស្ស័យ កាលបើសម្មាសមាធិមានហើយ យថាភូតញ្ញា-ណទស្សនៈរបស់បុគ្គលបរិបូណ៌ដោយសម្មាសមាធិ រមែងបរិបូណ៌ដោយឧប-និស្ស័យ កាលបើយថាភូតញ្ញាណទស្សនៈមានហើយ និព្វិទា និងវិរាគៈរបស់ បុគ្គលបរិបូណ៌ដោយយថាភូតញ្ញាណទស្សនៈ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើនិព្វិទា និងវិរាគៈមានហើយ វិមុត្តិញ្ញាណទស្សនៈរបស់បុគ្គលបរិបូណ៌ ដោយនិព្វិទា និងវិរាគៈ រមែងបរិបូណ៌ដោយឧបនិស្ស័យ ។ ម្នាលអាវុសោ ទាំងឡាយ ប្រៀបដូចដើមឈើ ដែលបរិបូណ៌ដោយមែក និងស្លឹកហើយ ក្រមររបស់ឈើនោះក្តី ក៏បរិបូណ៌ សម្បកក្តី ស្រាយក្តី ខ្លឹមក្តី ក៏បរិបូណ៌ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ អវិប្បដិសារៈរបស់បុគ្គលមានសីល បរិបូណ៌ដោយសីល រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើអវិប្បដិសារៈ មានហើយ បាមុជ្ជរបស់បុគ្គលបរិបូណ៌ដោយអវិប្បដិសារៈ រមែងបរិបូណ៌ ដោយឧបនិស្ស័យ ។បេ។ វិមុត្តិញ្ញាណទស្សនៈ ក៏យ៉ាងនោះដែរ ។

[ ៥ ] ក្នុងទីនោះឯង ព្រះអានន្ទដ៏មានអាយុ មានថេរវាចាទឹងភិក្ខុទាំង-ឡាយថា ម្នាលអាវុសោទាំងឡាយ អវិប្បដិសារៈរបស់បុគ្គលទ្រុស្តសីល វិបត្តិចាកសីល រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើអវិប្បដិសារៈមិន មានហើយ បាមុជ្ជរបស់បុគ្គលវិបត្តិចាកអវិប្បដិសារៈ រមែងសាបសូន្យចាក

ឧបនិស្ស័យ កាលបើបាមុជ្ជមិនមានហើយ បីតិរបស់បុគ្គលវិបត្តិចាកបាមុជ្ជ រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើបីតិមិនមានហើយ បស្សទ្ធិរបស់បុគ្គលវិបត្តិចាកបីតិ រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើបស្សទ្ធិមិនមានហើយ សុខរបស់បុគ្គលវិបត្តិចាកបស្សទ្ធិ រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើសុខមិនមានហើយ សម្មាសមាធិរបស់បុគ្គលវិបត្តិចាកសុខ រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើសម្មាសមាធិមិនមានហើយ យថាភូតញ្ញាណទស្សនៈ របស់បុគ្គលវិបត្តិចាកសម្មាសមាធិ រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើយថាភូតញ្ញាណទស្សនៈមិនមានហើយ និព្វិទា និងវិរាគៈ របស់បុគ្គលវិបត្តិចាកយថាភូតញ្ញាណទស្សនៈ រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើនិព្វិទា និងវិរាគៈមិនមានហើយ វិមុត្តិញ្ញាណទស្សនៈរបស់បុគ្គលវិបត្តិចាកនិព្វិទា និងវិរាគៈ រមែងសាបសូន្យចាកឧបនិស្ស័យ ។ ម្នាលអាវុសោទាំងឡាយ ប្រៀបដូចដើមឈើ ដែលវិបត្តិចាកមែក និងស្លឹកហើយ ក្រមររបស់ឈើនោះក្តី ក៏មិនសូវបរិបូណ៌ សម្បកក្តី ស្រាយក្តី ខ្លឹមក្តី ក៏មិនសូវបរិបូណ៌ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ អវិប្បដិសារៈរបស់បុគ្គលទ្រុស្តសីល វិបត្តិចាកសីលហើយ រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើអវិប្បដិសារៈមិនមានហើយ បាមុជ្ជរបស់បុគ្គលវិបត្តិចាកអវិប្បដិសារៈ រមែងសាបសូន្យចាកឧបនិស្ស័យ ។បេ។ វិមុត្តិញ្ញាណទស្សនៈ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោទាំងឡាយ អវិប្បដិសារៈរបស់បុគ្គលមានសីល បរិបូណ៌ដោយ

សីលហើយ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើអវិប្បដិសារៈមានហើយ បាមុជ្ជៈរបស់បុគ្គលបរិបូណ៌ ដោយអវិប្បដិសារៈ រមែងបរិបូណ៌ដោយឧប-និស្ស័យ កាលបើបាមុជ្ជមានហើយ បីតិរបស់បុគ្គលបរិបូណ៌ដោយបាមុជ្ជ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើបីតិមានហើយ បស្សទ្ធិរបស់បុគ្គល បរិបូណ៌ដោយបីតិ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើបស្សទ្ធិមានហើយ សុខរបស់បុគ្គលបរិបូណ៌ដោយបស្សទ្ធិ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើសុខមានហើយ សម្មាសមាធិរបស់បុគ្គលបរិបូណ៌ដោយសុខ រមែង បរិបូណ៌ដោយឧបនិស្ស័យ កាលបើសម្មាសមាធិមានហើយ យថាភូត-ញាណទស្សនៈរបស់បុគ្គលបរិបូណ៌ដោយសម្មាសមាធិ រមែងបរិបូណ៌ដោយ ឧបនិស្ស័យ កាលបើយថាភូតញាណទស្សនៈមានហើយ និព្វិទា និងវិរាគៈ របស់បុគ្គលបរិបូណ៌ដោយយថាភូតញាណទស្សនៈ រមែងបរិបូណ៌ដោយឧប-និស្ស័យ កាលបើនិព្វិទា និងវិរាគៈមានហើយ វិមុត្តិញាណទស្សនៈរបស់ បុគ្គលបរិបូណ៌ដោយនិព្វិទា និងវិរាគៈ រមែងបរិបូណ៌ដោយឧបនិស្ស័យ ។ ម្នាលអាវុសោទាំងឡាយ ប្រៀបដូចដើមឈើ ដែលបរិបូណ៌ដោយមែក និង ស្លឹកហើយ ក្រមររបស់ឈើនោះក្តី ក៏រមែងបរិបូណ៌ សម្បកក្តី ស្រាយក្តី ខ្លឹម ក្តី ក៏រមែងបរិបូណ៌ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ អវិប្បដិសារៈ របស់បុគ្គលមានសីល បរិបូណ៌ដោយសីលហើយ រមែងបរិបូណ៌ដោយឧប-និស្ស័យ កាលបើអវិប្បដិសារៈមានហើយ បាមុជ្ជរបស់បុគ្គលបរិបូណ៌ដោយ

អវិប្បដិសារៈ រមែងបរិបូណ៌ដោយឧបនិស្ស័យ ។បេ។ វិមុត្តិញ្ញាណទស្សនៈ ក៏យ៉ាងនោះដែរ ។

# អដ្ឋកថា

## ឧបនិសាសូត្រទី ៤ ជាដើម

[ ៤-៥ ] ឧបនិសាសូត្រទី ៤ និងអានន្ទសូត្រទី ៥ ផ្សេងគ្នាត្រង់ពាក្យសម្ដីដែលព្រះថេរៈទាំង ២ គឺព្រះសារីបុត្រ និងព្រះអានន្ទពោល ។៚

### អដ្ឋកថា ឧបនិសាសូត្រទី ៤-៥ ចប់

# សុត្តន្តបិដក

## សមាធិសូត្រទី ៦

[ ៦ ] គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយគង់ក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ គង់ក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ការបាននូវសមាធិ

មានសភាពដូច្នោះ គប្បីមានដល់ភិក្ខុដែរឬ ដូចយ៉ាងភិក្ខុមិនសម្គាល់ថា ដីក្នុងដី មិនសម្គាល់ថាទឹកក្នុងទឹក មិនសម្គាល់ថាភ្លើងក្នុងភ្លើង មិនសម្គាល់ថាខ្យល់ក្នុងខ្យល់ មិនសម្គាល់ថាអាកាសានញ្ចាយតនៈ ក្នុងអាកាសានញ្ចាយតនៈ មិនសម្គាល់ថាវិញ្ញាណញ្ចាយតនៈ ក្នុងវិញ្ញាណញ្ចាយតនៈ មិនសម្គាល់ថាអាកិញ្ចញ្ញាយតនៈ ក្នុងអាកិញ្ចញ្ញាយតនៈ មិនសម្គាល់ថានេវសញ្ញានាសញ្ញាយតនៈ ក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសម្គាល់ថាលោកនេះ ក្នុងលោកនេះ មិនសម្គាល់ថាលោកខាងមុខ ក្នុងលោកខាងមុខទេ គ្រាន់តែជាអ្នកមានសញ្ញា ( សេចក្តីសម្គាល់ជាធម្មតា ) ប៉ុណ្ណោះ ។ ម្នាលអានន្ទ ការបាននូវសមាធិមានសភាពដូច្នោះ គប្បីមានដល់ភិក្ខុដែរ ដូចយ៉ាងភិក្ខុមិនសម្គាល់ថាដីក្នុងដី មិនសម្គាល់ថាទឹកក្នុងទឹក មិនសម្គាល់ថាភ្លើងក្នុងភ្លើង មិនសម្គាល់ថាខ្យល់ក្នុងខ្យល់ មិនសម្គាល់ថាអាកាសានញ្ចាយតនៈ ក្នុងអាកាសានញ្ចាយតនៈ មិនសម្គាល់ថាវិញ្ញាណញ្ចាយតនៈ ក្នុងវិញ្ញាណញ្ចាយតនៈ មិនសម្គាល់ថាអាកិញ្ចញ្ញាយតនៈ ក្នុងអាកិញ្ចញ្ញាយតនៈ មិនសម្គាល់ថានេវសញ្ញានាសញ្ញាយតនៈ ក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសម្គាល់ថាលោកនេះ ក្នុងលោកនេះ មិនសម្គាល់ថាលោកខាងមុខ ក្នុងលោកខាងមុខទេ គ្រាន់តែមានសញ្ញាជាធម្មតាប៉ុណ្ណោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះការបាននូវសមាធិមានសភាពដូច្នោះ គប្បីមានដល់ភិក្ខុ តើដូចម្តេច ដូចយ៉ាងភិក្ខុមិនសម្គាល់ថា ដីក្នុងដី មិនសម្គាល់ថាទឹកក្នុងទឹក មិនសម្គាល់ថាភ្លើងក្នុងភ្លើង មិនសម្គាល់ថាខ្យល់

ក្នុងខ្យល់ មិនសម្គាល់ថាអាកាសានញ្ចាយតនៈ ក្នុងអាកាសានញ្ចាយតនៈ មិនសម្គាល់ថាវិញ្ញាណញ្ចាយតនៈ ក្នុងវិញ្ញាណញ្ចាយតនៈ មិនសម្គាល់ថាអាកិញ្ចញ្ញាយតនៈ ក្នុងអាកិញ្ចញ្ញាយតនៈ មិនសម្គាល់ថានេវសញ្ញានាសញ្ញាយតនៈ ក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសម្គាល់ថាលោកនេះ ក្នុងលោកនេះ មិនសម្គាល់ថាលោកខាងមុខ ក្នុងលោកខាងមុខទេ គ្រាន់តែជាអ្នកមានសញ្ញាជាធម្មតាប៉ុណ្ណោះ ។ ម្នាលអានន្ទ ក្នុងធម្មវិន័យនេះ ភិក្ខុជាអ្នកមានសេចក្តីសម្គាល់យ៉ាងនេះថា នុ៎ះជាធម្មជាតស្ងប់ នុ៎ះជាធម្មជាតឧត្តម គឺធម៌ជាគ្រឿងរម្ងាប់នូវសង្ខារទាំងពួង ជាគ្រឿងរលាស់ចោល នូវកិលេសទាំងពួង ជាគ្រឿងអស់ទៅនៃតណ្ហា ជាគ្រឿងនឿយណាយ ជាទីរលត់ គឺព្រះនិព្វាន ។ ម្នាលអានន្ទ ការបាននូវសមាធិមានសភាពដូច្នោះ គប្បីមានដល់ភិក្ខុយ៉ាងនេះឯង ដូចយ៉ាងភិក្ខុមិនសម្គាល់ថា ដីក្នុងដី មិនសម្គាល់ថាទឹកក្នុងទឹក មិនសម្គាល់ថាភ្លើងក្នុងភ្លើង មិនសម្គាល់ថាខ្យល់ក្នុងខ្យល់ មិនសម្គាល់ថាអាកាសានញ្ចាយតនៈ ក្នុងអាកាសានញ្ចាយតនៈ មិនសម្គាល់ថាវិញ្ញាណញ្ចាយតនៈ ក្នុងវិញ្ញាណញ្ចាយតនៈ មិនសម្គាល់ថា អាកិញ្ចញ្ញាយតនៈ ក្នុងអាកិញ្ចញ្ញាយតនៈ មិនសម្គាល់ថានេវសញ្ញានាសញ្ញាយតនៈ ក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសម្គាល់ថាលោកនេះ ក្នុងលោកនេះ មិនសម្គាល់ថាលោកខាងមុខ ក្នុងលោកខាងមុខទេ គ្រាន់តែជាអ្នកមានសញ្ញាជាធម្មតាប៉ុណ្ណោះ ។

# អដ្ឋកថា

## សមាធិសូត្រ

[ ៦ ] ក្នុងសមាធិសូត្រទី ៦ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាសមាធិសូត្រទី ៦ ចប់

# សុត្តន្តបិដក

## សារិបុត្តសូត្រទី ៧

[ ៧ ] គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅរកព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងព្រះសារីបុត្តដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏គង់ក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ គង់ក្នុងទីដ៏សមគួរហើយ ក៏មានថេរវាចានឹងព្រះសារីបុត្តដ៏មានអាយុ ដូច្នេះថា ម្នាលអាវុសោសារីបុត្ត ការបាននូវសមាធិមានសភាពដូច្នោះ គប្បីមានដល់ភិក្ខុដែរឬហ្ន៎ ដូចយ៉ាងភិក្ខុមិនសម្គាល់ថាដីក្នុងដី មិនសម្គាល់ថាទឹកក្នុងទឹក មិនសម្គាល់ថាភ្លើងក្នុងភ្លើង មិនសម្គាល់ថាខ្យល់ក្នុងខ្យល់ មិនសម្គាល់ថាអាកាសានញ្ចាយតនៈ ក្នុងអាកាសានញ្ចាយតនៈ មិនសម្គាល់ថាវិញ្ញាណញ្ចាយតនៈ ក្នុងវិញ្ញាណញ្ចាយតនៈ មិនសម្គាល់ថាអាកិញ្ចញ្ញាយតនៈ ក្នុងអាកិញ្ចញ្ញាយតនៈ មិនសម្គាល់ថានេវសញ្ញានាសញ្ញាយតនៈ ក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសម្គាល់ថាលោក

នេះ ក្នុងលោកនេះ មិនសម្គាល់ថាលោកខាងមុខ ក្នុងលោកខាងមុខទេ គ្រាន់តែជាអ្នកមានសញ្ញា ជាធម្មតាប៉ុណ្ណោះ ។ ម្នាលអាវុសោអានន្ទ ការបាននូវសមាធិមានសភាពដូច្នោះ គប្បីមានដល់ភិក្ខុដែរ ដូចយ៉ាងភិក្ខុមិនសម្គាល់ថាដីក្នុងដី ។បេ។ មិនសម្គាល់ថាលោកខាងមុខ ក្នុងលោកខាងមុខទេ គ្រាន់តែជាអ្នកមានសញ្ញា ជាធម្មតាប៉ុណ្ណោះ ។ ម្នាលអាវុសោសារីបុត្ត ចុះការបាននូវសមាធិមានសភាពដូច្នោះ គប្បីមានដល់ភិក្ខុ តើដូចម្តេច ដូចយ៉ាងភិក្ខុមិនសម្គាល់ថាដីក្នុងដី ។បេ។ មិនសម្គាល់ថាលោកខាងមុខ ក្នុងលោកខាងមុខទេ គ្រាន់តែជាអ្នកមានសញ្ញា ជាធម្មតាប៉ុណ្ណោះ ។ ម្នាលអាវុសោអានន្ទ សម័យមួយ ខ្ញុំនៅក្នុងអន្ធវ័ន ទៀបក្រុងសាវត្ថីនេះឯង ខ្ញុំបានចូលសមាធិមានសភាពដូច្នោះ ក្នុងទីនោះ គឺខ្ញុំមិនសម្គាល់ថាដីក្នុងដី មិនសម្គាល់ថាទឹកក្នុងទឹក មិនសម្គាល់ថា ភ្លើងក្នុងភ្លើង មិនសម្គាល់ថាខ្យល់ក្នុងខ្យល់ មិនសម្គាល់ថាអាកាសានញ្ចាយតនៈ ក្នុងអាកាសានញ្ចាយតនៈ មិនសម្គាល់ថា វិញ្ញាណញ្ចាយតនៈ ក្នុងវិញ្ញាណញ្ចាយតនៈ មិនសម្គាល់ថា អាកិញ្ចញ្ញាយតនៈ ក្នុងអាកិញ្ចញ្ញាយតនៈ មិនសម្គាល់ថា នេវសញ្ញានាសញ្ញាយតនៈ ក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសម្គាល់ថាលោកនេះ ក្នុងលោកនេះ មិនសម្គាល់ថាលោកខាងមុខ ក្នុងលោកខាងមុខទេ គ្រាន់តែជាអ្នកមានសញ្ញា ជាធម្មតាប៉ុណ្ណោះ ។ ចុះព្រះសារីបុត្តដ៏មានអាយុ មានសញ្ញាដូចម្តេចក្នុងសម័យនោះ ។ ម្នាលអាវុសោ សញ្ញាកើតឡើងដល់ខ្ញុំដោយឡែកថា ការរលត់ទៅនៃភព គឺ

និព្វាន ការរលត់ទៅនៃភព គឺនិព្វានដូច្នេះ សញ្ញារលត់ទៅវិញដោយឡែក ។ ម្នាលអាវុសោ ប្រៀបដូចបំណែកភ្លើងកំពុងឆេះ អណ្តាតកើតឡើងដោយឡែក អណ្តាតរលត់ទៅវិញដោយឡែក យ៉ាងណាមិញ ម្នាលអាវុសោ សញ្ញាកើតឡើងដល់ខ្ញុំដោយឡែកថា ការរលត់ទៅនៃភព គឺនិព្វាន ការរលត់ទៅនៃភព គឺនិព្វានដូច្នេះ សញ្ញារលត់ទៅវិញដោយឡែក ម្នាលអាវុសោ ក្នុងសម័យនោះ ខ្ញុំទៅតែមានសញ្ញាថា ការរលត់ទៅនៃភព គឺនិព្វាន ( ប៉ុណ្ណោះ ) ។

# អដ្ឋកថា

## សារិបុត្តសូត្រ

[ ៧ ] ក្នុងសារិបុត្តសូត្រទី ៧ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាសារិបុត្តសូត្រទី ៧ ចប់

# សុត្តន្តបិដក

## សទ្ធាសូត្រទី ៨

[ ៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសទ្ធាហើយ តែមិនមានសីល ភិក្ខុនោះឈ្មោះថា មិនពេញលេញដោយអង្គនោះ យ៉ាងនេះ ភិក្ខុនោះគប្បីបំពេញអង្គនោះ ឲ្យពេញលេញឡើងដោយគិតថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញមានសទ្ធាផង មានសីលផង ។ ម្នាលភិក្ខុទាំងឡាយ កាលណាភិក្ខុមានសទ្ធាផង មានសីលផង ទើបភិក្ខុនោះឈ្មោះថា ពេញលេញដោយអង្គនោះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសទ្ធាទាំងមានសីលហើយ តែជាមិនបានចេះដឹងច្រើន ។បេ។ ចេះដឹងច្រើនហើយ តែមិនចេះសម្តែងធម៌ ចេះសម្តែងធម៌ហើយ តែចូលកាន់បរិស័ទមិនកើត ចូលកាន់បរិស័ទកើតហើយ តែមិនក្លៀវក្លាសម្តែងធម៌ដល់បរិស័ទ ក្លៀវក្លាសម្តែងធម៌ដល់បរិស័ទហើយ តែមិនទ្រទ្រង់វិន័យ ទ្រទ្រង់វិន័យហើយ តែមិនប្រព្រឹត្តនៅក្នុងព្រៃ ដែលមានសេនាសនៈស្ងាត់ នៅក្នុងព្រៃមានសេនាសនៈស្ងាត់ហើយ តែមិនបានតាមប្រាថ្នា មិនបានដោយមិនលំបាក មិនបានដោយងាយនូវចតុត្ថជ្ឈាន ដែលអាស្រ័យនូវចិត្តដ៏ប្រសើរ ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន បានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយនូវចតុត្ថជ្ឈាន ដែលអាស្រ័យនូវចិត្តដ៏ប្រសើរ ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នហើយ តែមិនធ្វើឲ្យជាក់ច្បាស់ នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ។ ភិក្ខុនោះឈ្មោះថា នៅមិនទាន់ពេញលេញដោយអង្គ

នោះយ៉ាងនេះ ភិក្ខុនោះត្រូវបំពេញអង្គនោះដោយគិតថា ធ្វើដូចម្ដេចហ្ន៎ ឲ្យអាត្មាអញមានសទ្ធាផង មានសីលផង ជាអ្នកចេះដឹងច្រើនផង ចេះសម្ដែងធម៌ផង ចូលកាន់បរិស័ទកើតផង ក្លៀវក្លាសម្ដែងធម៌ដល់បរិស័ទផង ទ្រទ្រង់វិន័យផង ប្រព្រឹត្តនៅក្នុងព្រៃមានសេនាសនៈស្ងាត់ផង បានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយនូវចតុត្ថជ្ឈាន ដែលអាស្រ័យនូវចិត្តដ៏ប្រសើរ ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នផង បានធ្វើឲ្យជាក់ច្បាស់ នូវចេតោវិមុត្តិ និងបញ្ញា-វិមុត្តិដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ កាលណាភិក្ខុមានសទ្ធាផង មានសីលផង ជាអ្នកចេះដឹងច្រើនផង ចេះសម្ដែងធម៌ផង ចូលកាន់បរិស័ទកើតផង ក្លៀវក្លាសម្ដែងធម៌ដល់បរិស័ទផង ទ្រទ្រង់វិន័យផង ប្រព្រឹត្តនៅក្នុងព្រៃមានសេនាសនៈស្ងាត់ផង បានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយនូវចតុត្ថជ្ឈាន ដែលអាស្រ័យនូវចិត្តដ៏ប្រសើរ ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នផង ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្នផង ។ ភិក្ខុនោះទើបពេញលេញ ដោយអង្គនោះយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយធម៌ទាំង ១០ នេះហើយ ឈ្មោះថានាំឲ្យកើតសេចក្ដីជ្រះថ្លា ដោយជុំវិញផង បរិបូណ៌ដោយអាការគ្រប់យ៉ាងផង ។

# អដ្ឋកថា

## សទ្ធាសូត្រ

[ ៨ ] ក្នុងសទ្ធាសូត្រទី ៨ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាសទ្ធាសូត្រទី ៨ ចប់

# សុត្តន្តបិដក

## សន្តសូត្រទី ៩

[ ៩ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសទ្ធាហើយ តែគ្មានសីល មានសីលហើយ តែមិនចេះដឹងច្រើន ចេះដឹងច្រើនហើយ តែមិនចេះសម្តែងធម៌ ចេះសម្តែងធម៌ហើយ តែចូលកាន់បរិស័ទមិនកើត ចូលកាន់បរិស័ទកើតហើយ តែមិនក្លៀវក្លាសម្តែងធម៌ដល់បរិស័ទ ក្លៀវក្លាសម្តែងធម៌ដល់បរិស័ទហើយ តែមិនទ្រទ្រង់វិន័យ ទ្រទ្រង់វិន័យហើយ តែមិនប្រព្រឹត្តនៅក្នុងព្រៃ មានសេនាសនៈស្ងាត់ ប្រព្រឹត្តនៅក្នុងព្រៃ មានសេនាសនៈស្ងាត់ហើយ តែមិនបានវិមោក្ខធម៌ដ៏ល្អិត ដែលកន្លងរូបជ្ឈានហើយ បានអារុប្បជ្ឈានដោយកាយ បានវិមោក្ខធម៌ដ៏ល្អិត ដែលកន្លងរូបជ្ឈាន បានអារុប្បជ្ឈានដោយកាយហើយ តែមិនបានធ្វើឲ្យជាក់ច្បាស់ នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។ ភិក្ខុនោះឈ្មោះថា នៅមិនទាន់ពេញលេញដោយអង្គនោះ យ៉ាងនេះ ភិក្ខុនោះត្រូវបំពេញ

អន្តនោះដោយគិតថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញមានសទ្ធាផង មានសីលផង ចេះដឹងច្រើនផង ចេះសម្តែងធម៌ផង ចូលកាន់បរិស័ទកើតផង ក្លៀវក្លាសម្តែងធម៌ដល់បរិស័ទផង ទ្រទ្រង់វិន័យផង ប្រព្រឹត្តនៅក្នុងព្រៃ មានសេនសនៈស្ងាត់ផង បានវិមោក្ខធម៌ដ៏ល្អិត ដែលកន្លងរូបជ្ឈានហើយ បានអារុប្បជ្ឈានដោយកាយផង ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្នផង ។ ម្នាលភិក្ខុទាំងឡាយ កាលណាភិក្ខុមានសទ្ធាផង មានសីលផង ចេះដឹងច្រើនផង ចេះសម្តែងធម៌ផង ចូលកាន់បរិស័ទកើតផង ក្លៀវក្លាសម្តែងធម៌ដល់បរិស័ទផង ទ្រទ្រង់វិន័យផង ប្រព្រឹត្តនៅក្នុងព្រៃ មានសេនាសនៈស្ងាត់ផង បានវិមោក្ខធម៌ដ៏ល្អិត ដែលកន្លងរូបជ្ឈានហើយ បានអារុប្បជ្ឈានដោយកាយផង ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្នផង ភិក្ខុនោះទើបឈ្មោះថា ពេញលេញដោយអង្គនោះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយធម៌ទាំង ១០ នេះហើយ ឈ្មោះថា នាំឲ្យកើតសេចក្តីជ្រះថ្លា ដោយជុំវិញផង បរិបូណ៌ដោយអាការគ្រប់យ៉ាងផង ។

# អដ្ឋកថា

## សន្តសូត្រ

[ ៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសន្តសូត្រទី ៩ ដូចតទៅនេះ បទថា **សន្តា** បានដល់ ស្ងប់ ព្រោះមានអារម្មណ៍ស្ងប់ខ្លះ ព្រោះមានអង្គស្ងប់ខ្លះ ដែលបានឈ្មោះយ៉ាងនេះថា **វិមោក្ខ** ព្រោះផុតចាកធម៌ដែលជាសត្រូវ និង ព្រោះរួចផុតដោយល្អ ដោយប្រាសចាកសង្ស័យក្នុងអារម្មណ៍ ។ បទថា **អតិក្កម្ម រូបេ** បានដល់ កន្លងនូវរូបជ្ឈាន ប្រព្រឹត្តទៅ ។ ពាក្យដ៏សេស ក្នុងទីគ្រប់អន្លើ មានអត្ថងាយយល់ហើយ ៕៚

**អដ្ឋកថា សន្តសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## វិជយសូត្រទី ១០

[ ១០ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសទ្ធាហើយ តែមិនមានសីល ភិក្ខុនោះឈ្មោះថា នៅមិនទាន់ពេញលេញដោយអង្គនោះ យ៉ាងនេះឡើយ ភិក្ខុនោះត្រូវបំពេញអង្គនោះ ដោយគិតថា ធ្វើដូចម្ដេចហ្ន៎ ឲ្យអាត្មាអញមានសទ្ធាផង មានសីលផង ។ ម្នាលភិក្ខុទាំងឡាយ កាលណាភិក្ខុមានសទ្ធាផង មានសីលផងហើយ ភិក្ខុនោះទើបឈ្មោះថា ពេញលេញដោយអង្គនោះ យ៉ាងនេះ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសទ្ធាផង មានសីលផងហើយ តែមិនជាអ្នកចេះដឹងច្រើន ចេះដឹងច្រើនហើយ តែមិនចេះសម្តែងធម៌ ចេះសម្តែងធម៌ហើយ តែចូលកាន់បរិស័ទមិនកើត ចូលកាន់បរិស័ទកើតហើយ តែមិនក្លៀវក្លាសម្តែងធម៌ដល់បរិស័ទ ក្លៀវក្លាសម្តែងធម៌ដល់បរិស័ទហើយ តែមិនទ្រទ្រង់វិន័យ ទ្រទ្រង់វិន័យហើយ តែមិនបានរឭកនូវបុព្វេនិវាសច្រើនប្រការ គឺរឭកឃើញ ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ រឭកឃើញនូវបុព្វេនិវាសច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ រឭកឃើញនូវបុព្វេនិវាសច្រើនប្រការ គឺរឭកឃើញ ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ រឭកឃើញនូវបុព្វេនិវាសច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះហើយ តែទាស់មិនមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងនូវចក្ខុជារបស់មនុស្សធម្មតា ។បេ។ ដឹងច្បាស់នូវពួកសត្វដែលអន្ទោលទៅតាមកម្ម មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងនូវចក្ខុជារបស់មនុស្សធម្មតា ។បេ។ ដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមកម្មហើយ តែមិនធ្វើឲ្យជាក់ច្បាស់ ។បេ។ ព្រោះអស់អាសវៈទាំងឡាយហើយ ។ ភិក្ខុនោះឈ្មោះថា នៅមិនទាន់ពេញលេញដោយអង្គនោះ យ៉ាងនេះឡើយ ភិក្ខុនោះត្រូវបំពេញអង្គនោះដោយគិតថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញមានសទ្ធាផង មានសីលផង ជាអ្នកចេះដឹងច្រើនផង ចេះសម្តែងធម៌ផង ចូលកាន់បរិស័ទកើតផង ក្លៀវក្លាសម្តែងធម៌ដល់បរិស័ទផង ទ្រទ្រង់វិន័យផង រឭកឃើញនូវបុព្វេនិវាសច្រើនប្រការ គឺរឭកឃើញ ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ រឭកឃើញ

នូវបុព្វេនិវាសច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះផង មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងនូវចក្ខុជារបស់មនុស្សធម្មតា ។បេ។ ដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមកម្មផង ធ្វើឲ្យជាក់ច្បាស់ ។បេ។ ព្រោះអស់អាសវៈទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ កាលណាភិក្ខុមានសទ្ធាផង មានសីលផង ជាអ្នកចេះដឹងច្រើនផង ចេះសម្តែងធម៌ផង ចូលកាន់បរិស័ទកើតផង ក្លៀវក្លាសម្តែងធម៌ដល់បរិស័ទផង ទ្រទ្រង់វិន័យផង រឭកឃើញនូវបុព្វេនិវាសច្រើនប្រការ គឺរឭកឃើញ ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ រឭកឃើញនូវបុព្វេនិវាសច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះផង មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងនូវចក្ខុជារបស់មនុស្សធម្មតាផង ។បេ។ ដឹងច្បាស់នូវពួកសត្វដែលអន្ទោលទៅតាមកម្មផង ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្នផង ភិក្ខុនោះទើបឈ្មោះថាពេញលេញដោយអង្គនោះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយធម៌ទាំង ១០ យ៉ាងនេះហើយ ឈ្មោះថា នាំឲ្យកើតសេចក្តីជ្រះថ្លាដោយជុំវិញផង បរិបូណ៌ដោយអាការគ្រប់យ៉ាងផង ។

**អានិសំសវគ្គទី ១ ចប់**

**ឧទ្ទាននៃអានិសំសវគ្គនោះ គឺ**

និយាយអំពីសីល មានប្រយោជន៍ដូចម្ដេច ១ អំពីចេតនា ១ អំពីសីល ១ អំពីការសោបសូន្យចាកឧបនិស្ស័យ ១ អំពីព្រះអានន្ទជាគម្រប់ ៥ អំពីសមាធិ ១ អំពីព្រះសារីបុត្ត ១ អំពីភិក្ខុមានសទ្ធា ១ អំពីសន្តិវិមោក្ខ ១ អំពីភិក្ខុមានសទ្ធាជាដើម ១ ។

# អដ្ឋកថា

## វិជយសូត្រ

[ ១០ ] ក្នុងវិជយសូត្រទី ១០ មានអត្ថងាយយល់ហើយ ។

**អដ្ឋកថាវិជយសូត្រទី ១០ ចប់**

**អានិសង្សវគ្គទី ១ ចប់**

# សុត្តន្តបិដក

## ឆាជការណាវគ្គទី ២

### សេនាសនសូត្រទី ១

[ ១១ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ ៥ កាលសេពគប់នូវសេនាសនៈ ដែលប្រកបដោយអង្គ ៥ មិនយូរប៉ុន្មាន គប្បីធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ ៥ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានសទ្ធា ជឿសេចក្តីត្រាស់ដឹងរបស់ព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ជាព្រះសុគត ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ជាសារថីទូន្មាននូវបុរស ជាសាស្តានៃទេវតា និងមនុស្សទាំងឡាយ ជាព្រះពុទ្ធ មានបុញ្ញសិរី ១ ជាអ្នកមានអាពាធតិច មានទុក្ខតិច ប្រកបដោយតេជោធាតុបក់កម្តៅស្មើ គឺមិនត្រជាក់ពេក មិនក្តៅពេក យ៉ាងកណ្តាល អត់ធន់នូវសេចក្តីព្យាយាមបាន ១ មិនជាអ្នកអួតអាង មិនមានមាយា គឺប្រព្រឹត្តខ្លួនឲ្យពិតប្រាកដក្នុងព្រះសាស្តា ឬក្នុងពួកសព្រហ្មចារី ជាអ្នកចេះដឹង ១ ជាអ្នកមានព្យាយាមប្រារព្ធ ដើម្បីលះបង់ពួកអកុសលធម៌ ចូលដល់នូវកុសលធម៌ ១ ជាអ្នកមានកម្លាំង ប្រឹងប្រែងមាំមួន មិនដាក់ធុរៈ

ក្នុងកុសលធម៌ទាំងឡាយ ១ មានប្រាជ្ញាប្រកបដោយបញ្ញាយល់ច្បាស់នូវសេចក្ដីចម្រើន និងសេចក្ដីវិនាស ជាប្រាជ្ញាប្រសើរមោះមុត ប្រព្រឹត្តទៅដើម្បីឲ្យអស់ទុក្ខដោយប្រពៃ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះសេនាសនៈប្រកបដោយអង្គ ៥ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ សេនាសនៈក្នុងលោកនេះ មិនឆ្ងាយពេក មិនជិតពេក ល្មមទៅមកស្រួល មិនកុះករដោយមនុស្សក្នុងវេលាថ្ងៃ មិនសូវមានសំឡេង មិនសូវគឹកកងក្នុងរាត្រី មិនសូវមានសម្ផស្សដោយរបោមមូសខ្យល់ កម្ដៅថ្ងៃ និងពស់តូចពស់ធំ ១ ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ កើតឡើងដល់ភិក្ខុដែលនៅក្នុងសេនាសនៈនោះដោយមិនលំបាក ១ ពួកភិក្ខុជាថេរៈដែលនៅក្នុងសេនាសនៈនោះ ជាពហុស្សូត ចេះចាំនូវនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ១ ភិក្ខុចូលទៅរកភិក្ខុជាថេរៈទាំងនោះម្ដងៗ ហើយ សួរប្រឹក្សាថា បពិត្រលោកដ៏ចម្រើន រឿងនេះ តើដូចម្ដេច សេចក្ដីអធិប្បាយនៃរឿងនេះ តើដូចម្ដេច ១ លោកដ៏មានអាយុទាំងនោះ រមែងពន្យល់រឿងដែលមិនទាន់ច្បាស់លាស់ផង ធ្វើឲ្យងាយនូវរឿងដែលជ្រៅផង បន្ទោបង់នូវសេចក្ដីសង្ស័យ ក្នុងធម៌ទាំងឡាយ ដែលជាទីតាំងនៃសេចក្ដីសង្ស័យច្រើនប្រការផង ១ ។ ម្នាលភិក្ខុទាំងឡាយ សេនាសនៈប្រកបដោយអង្គ ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ ៥ កាលបើសេពគប់ នូវសេនាសនៈប្រកប

ដោយអង្គ ៥ ហើយ មិនយូរប៉ុន្មាន នឹងបានធ្វើឲ្យជាក់ច្បាស់ ។បេ។ ព្រោះអស់អាសវៈទាំងឡាយ ។

# អដ្ឋកថា

# នាថករណវគ្គទី ២

## សេនាសនសូត្រ

[ ១១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសេនាសនសូត្រទី ១ នៃនាថករណវគ្គទី ២ ដូចតទៅនេះ បទថា **បញ្ចង្គសមន្នាគតោ** បានដល់ ដែលប្រកបដោយអង្គគុណ ៥ ។ បទថា **នាតិទូរំ ហោតិ នាច្ចាសន្នំ** សេចក្តីថា ទីកន្លែងណាឆ្ងាយពេក ភិក្ខុត្រាច់បិណ្ឌបាតក្នុងទីនោះ ក៏មានសេចក្តីលំបាកកាយ និងចិត្ត លោកក៏ធ្វើសមាធិ ដែលមិនទាន់កើតឲ្យកើតមិនបាន ឬធ្វើសមាធិដែលកើតហើយឲ្យមាំទាំមិនបាន ស្ថានទីជិតពេក ក៏កុះករដោយមនុស្សជាច្រើន ។ ទីដែលផុតចាកទោសទាំង ២ នោះ ក្នុងបទេសប្រមាណ ៤០ ឧសភៈ ឈ្មោះថា ដល់ព្រមដោយការទៅមក ។ បទថា **ទិវា អប្បកិណ្ណំ** បានដល់ មិនដេរដាសដោយមនុស្សជាច្រើន ក្នុងពេលថ្ងៃ ៕

**អដ្ឋកថា សេនាសនសូត្រទី ១ ចប់**

# សុត្តន្តបិដក

## អង្គសូត្រទី ២

[ ១២ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុលះអង្គ ៥ ប្រកបដោយអង្គ ៥ ហៅថាជាឧត្តមបុរស មានគុណគ្រប់គ្រាន់ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងធម្មវិន័យនេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុលះអង្គ ៥ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះកាមច្ឆន្ទៈ ១ លះព្យាបាទ ១ លះថីនមិទ្ធៈ ១ លះឧទ្ធច្ចកុក្កុច្ចៈ ១ លះវិចិកិច្ឆា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុលះអង្គ ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុប្រកបដោយអង្គ ៥ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ភិក្ខុប្រកបដោយសីលក្ខន្ធជាអសេក្ខៈ ១ ប្រកបដោយសមាធិក្ខន្ធជាអសេក្ខៈ ១ ប្រកបដោយបញ្ញាខន្ធជាអសេក្ខៈ ១ ប្រកបដោយវិមុត្តិក្ខន្ធជាអសេក្ខៈ ១ ប្រកបដោយវិមុត្តិញាណទស្សនក្ខន្ធជាអសេក្ខៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុលះអង្គ ៥ ប្រកបដោយអង្គ ៥ ហៅថា ជាឧត្តមបុរសមានគុណគ្រប់គ្រាន់ ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងធម្មវិន័យនេះ ។

កាមច្ឆន្ទៈ ១ ព្យាបាទៈ ១ ថីនមិទ្ធៈ ១ ឧទ្ធច្ចៈ ១ វិចិកិច្ឆា ១
មិនមានដល់ភិក្ខុដោយប្រការទាំងពួង ភិក្ខុបែបនោះ ប្រកប
ដោយអសេក្ខសីលផង ដោយអសេក្ខសមាធិផង ( ដោយ
អសេក្ខបញ្ញាផង ) ដោយវិមុត្តិផង ដោយវិមុត្តិញាណផង

ភិក្ខុនោះឯង ឈ្មោះថាប្រកបដោយអង្គ ៥ លះអង្គ ៥ ភិក្ខុនោះឯងហៅថា ប្រកបដោយគុណទាំងអស់ក្នុងធម្មវិន័យនេះ ។

# អដ្ឋកថា

## អង្គសូត្រ

[ ១២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអង្គសូត្រទី ២ ដូចតទៅនេះ បទថា **កេវលី** បានដល់ ប្រកបដោយគុណទាំងមូល ។ បទថា **វុសិតវា** ប្រែថា មានព្រហ្មចរិយៈនៅចប់ហើយ ។ បទថា **អសេក្ខេន** បានដល់ លោកុត្តរធម៌ដែលទាក់ទងក្នុងអសេក្ខធម៌ ។ បទថា **សីលក្ខន្ធេន** ប្រែថា ដោយគំនរសីល ។ ក្នុងបទថា **វិមុត្តិក្ខន្ធេន** នេះ វៀរសីលជាដើមចេញ ផលធម៌ដ៏សេសទាំង ៣ ឈ្មោះថា **វិមុត្តិ** ។ វិមុត្តិញាណទស្សនៈ ឈ្មោះថា **បច្ចវេក្ខណាញ្ញាណ** បច្ចវេក្ខណញ្ញាណនោះ ជាលោកិយតែម្យ៉ាង ។

### អដ្ឋកថា អង្គសូត្រទី ២ ចប់

# សុត្តន្តបិដក

## សំយោជនសូត្រទី ៣

[ ១៣ ] ម្នាលភិក្ខុទាំងឡាយ សំយោជនៈនេះ មាន ១០ យ៉ាង ។ សំយោជនៈ ១០ យ៉ាង តើដូចម្តេច ។ គឺសំយោជនៈជាចំណែកខាងក្រោម ៥ សំយោជនៈជាចំណែកខាងលើ ៥ ។ សំយោជនៈជាចំណែកខាងក្រោម ៥ តើដូចម្តេច ។ គឺសក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាស ១ កាមច្ឆន្ទៈ ១ ព្យាបាទៈ ១ ។ នេះជាសំយោជនៈជាចំណែកខាងក្រោម ៥ ។ សំយោជនៈជាចំណែកខាងលើ ៥ តើដូចម្តេច ។ គឺ រូបរាគៈ ១ អរូបរាគៈ ១ មានៈ ១ ឧទ្ធច្ចៈ ១ អវិជ្ជា ១ ។ នេះជាសំយោជនៈជាចំណែកខាងលើ ៥ ។ ម្នាលភិក្ខុទាំងឡាយ សំយោជនៈ មាន ១០ យ៉ាងនេះឯង ។

# អដ្ឋកថា

## សំយោជនសូត្រ

[ ១៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសំយោជនសូត្រទី ៣ ដូចតទៅនេះ បទថា **ឱរម្ភាគិយានិ** ប្រែថា ជាចំណែកខាងក្រោម ។ បទថា **ឧទ្ធម្ភាគិយានិ** ប្រែថា ជាចំណែកខាងលើ ។ ក្នុងសូត្រនេះ លោកពោលវដ្តៈតែម្យ៉ាង ។

**អដ្ឋកថា សំយោជនសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ទីលសូត្រទី ៨

[ ១៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ឬភិក្ខុនីណាមួយ មិនបានលះសេចក្តីរឹងត្អឹងនៃចិត្ត ៥ មិនបានផ្តាច់ផ្តិលចំណងរបស់ចិត្ត ៥ ទេ យប់ ឬថ្ងៃមកដល់ភិក្ខុ ឬភិក្ខុនីនោះ សេចក្តីសាបសូន្យក្នុងកុសលធម៌ទាំងឡាយ រមែងប្រាកដឡើង មិនមានសេចក្តីចម្រើនឡើយ ។ សេចក្តីរឹងត្អឹងនៃចិត្ត ៥ ដែលភិក្ខុមិនបានលះបង់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ សង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះថ្លាក្នុងព្រះសាស្តា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាសង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះថ្លាក្នុងព្រះសាស្តា ចិត្តរបស់ភិក្ខុនោះ មិនបង្អោនទៅដើម្បីព្យាយាមជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកព្យាយាម ។ ចិត្តរបស់ភិក្ខុណាមិនបង្អោនទៅដើម្បីព្យាយាមជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាម ភិក្ខុនោះឈ្មោះថាមិនបានលះបង់សេចក្តីរឹងត្អឹងនៃចិត្តទី ១ នេះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុសង្ស័យក្នុងធម៌ ។បេ។ សង្ស័យក្នុងសង្ឃ សង្ស័យក្នុងសិក្ខា ក្រោធខឹង មិនពេញចិត្ត មានចិត្តត្រូវទោសៈខ្ទាំងខ្ទប់ មានសេចក្តីរឹងរូសក្នុងសព្រហ្មចារីទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ជាអ្នកក្រោធខឹង មិនពេញចិត្ត មានចិត្តត្រូវទោសៈខ្ទាំងខ្ទប់ មានសេចក្តីរឹងរូសក្នុងសព្រហ្មចារីទាំងឡាយហើយ ចិត្តរបស់ភិក្ខុនោះ រមែងមិនបង្អោនទៅ ដើម្បី

ព្យាយាមជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាម ។ ចិត្តរបស់ភិក្ខុណាមិនបង្អោនទៅ ដើម្បីព្យាយាមជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកព្យាយាម ភិក្ខុនោះ ឈ្មោះថា មិនបានលះបង់សេចក្តីរឹងត្អឹងនៃចិត្តទាំង ៥ នេះ យ៉ាងនេះឯង ។ នេះជាសេចក្តីរឹងត្អឹងនៃចិត្តទាំង ៥ ដែលភិក្ខុមិនបានលះបង់ហើយ ។ ចុះចំណងរបស់ចិត្ត ៥ ដែលភិក្ខុមិនបានផ្តាច់ផ្តិល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកសេចក្តីប្រាថ្នា មិនទាន់ប្រាសចាកសេចក្តីគាប់ចិត្ត មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីក្តៅក្រហាយ មិនទាន់ប្រាសចាកបំណងក្នុងកាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា មិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកសេចក្តីប្រាថ្នា មិនទាន់ប្រាសចាកសេចក្តីគាប់ចិត្ត មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីក្តៅក្រហាយ មិនទាន់ប្រាសចាកបំណងក្នុងកាមទាំងឡាយហើយ ចិត្តរបស់ភិក្ខុនោះ រមែងមិនបង្អោនទៅ ដើម្បីព្យាយាមជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកព្យាយាម ។ ចិត្តរបស់ភិក្ខុណា មិនបង្អោនទៅ ដើម្បីព្យាយាមជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកព្យាយាមទេ ភិក្ខុនោះ ឈ្មោះថា មិនបានផ្តាច់ផ្តិលនូវ

ចំណងរបស់ចិត្តទី ១ នេះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមិនទាន់ប្រាសចាកតម្រេកក្នុងកាយ ។បេ។ មិនទាន់ប្រាសចាកតម្រេកក្នុងរូប បរិភោគអាហារពេញពោះដរាបដល់ឆ្អែត រៀបចំតែទីដេកឲ្យស្រួល ទីផ្អែកឲ្យស្រួល ទីលក់ឲ្យស្រួល ប្រព្រឹត្តព្រហ្មចរិយធម៌ ព្រោះតម្កល់ទុកនូវសេចក្តីប្រាថ្នាឲ្យបានជាពួកទេវតាណាមួយថា ខ្ញុំ សូមឲ្យបានជាទេវតាធំ ឬទេវតាតូចណាមួយដោយសីល ឬវត្ត ឬតបៈ ឬក៏ព្រហ្មចរិយៈនេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាប្រព្រឹត្តព្រហ្មចរិយធម៌ ព្រោះតម្កល់ទុកនូវសេចក្តីប្រាថ្នាឲ្យបានជាពួកទេវតាណាមួយថា ខ្ញុំ សូមឲ្យបានជាទេវតាធំ ឬទេវតាតូចណាមួយដោយសីល ឬវត្ត ឬតបៈ ឬក៏ព្រហ្មចរិយៈនេះ ចិត្តរបស់ភិក្ខុនោះរមែងមិនបង្អោនទៅ ដើម្បីព្យាយាមជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកព្យាយាម ។ ចិត្តរបស់ភិក្ខុណាមិនបង្អោនទៅ ដើម្បីព្យាយាមជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកព្យាយាមមិនដាច់ទេ ភិក្ខុនោះ ឈ្មោះថាមិនបានផ្តាច់ផ្តិលនូវចំណងរបស់ចិត្តទី ៥ នេះ យ៉ាងនេះឯង ។ នេះជាចំណងរបស់ចិត្តទាំង ៥ ដែលភិក្ខុមិនបានផ្តាច់ផ្តិល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ឬភិក្ខុនីណាមួយ មិនបានលះបង់នូវសេចក្តីរឹងត្អឹងរបស់ចិត្តទាំង ៥ នេះ មិនបានផ្តាច់ផ្តិលនូវចំណងរបស់ចិត្តទាំង ៥ នេះហើយ យប់ និងថ្ងៃមកដល់ភិក្ខុ ឬភិក្ខុនីនោះ សេចក្តីសាបសូន្យក្នុងកុសលធម៌ទាំងឡាយរមែងប្រាកដ

មិនមានសេចក្តីចម្រើនឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាយប់ និងថ្ងៃ រមែងមកដល់ព្រះចន្ទក្នុងកាឡបក្ស តែងសាបសូន្យចាកវណ្ណៈ សាបសូន្យចាកមណ្ឌល សាបសូន្យចាករស្មី សាបសូន្យចាកទំហំ និងកម្ពស់ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ឬភិក្ខុនីណាមួយ មិនបានលះបង់នូវសេចក្តីរឹងត្អឹងរបស់ចិត្តទាំង ៥ នេះ មិនបានផ្តាច់ផ្តិលនូវចំណងរបស់ចិត្តទាំង ៥ នេះហើយ យប់ និងថ្ងៃមកដល់ ភិក្ខុ ឬភិក្ខុនីនោះ សេចក្តីសាបសូន្យក្នុងកុសលធម៌ទាំងឡាយរមែងប្រាកដ មិនមានសេចក្តីចម្រើនឡើយក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ឬភិក្ខុនីណាមួយ បានលះបង់នូវចំណងរបស់ចិត្ត ៥ បានផ្តាច់ផ្តិលនូវចំណងរបស់ចិត្ត ៥ ហើយ យប់ និងថ្ងៃមកដល់ ភិក្ខុ ឬភិក្ខុនីនោះ សេចក្តីចម្រើនក្នុងកុសលធម៌ទាំងឡាយរមែងប្រាកដ មិនបានសាបសូន្យឡើយ ។ សេចក្តីរឹងត្អឹងរបស់ចិត្តទាំង ៥ ដែលភិក្ខុ ឬភិក្ខុនីបានលះបង់ហើយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនងឿងឆ្ងល់ មិនសង្ស័យ ចុះចិត្តស៊ប់ ជ្រះថ្លាក្នុងព្រះសាស្តា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមិនងឿងឆ្ងល់ មិនសង្ស័យ ចុះចិត្តស៊ប់ ជ្រះថ្លាក្នុងព្រះសាស្តាហើយ ចិត្តរបស់ភិក្ខុនោះ រមែងបង្អោនទៅដើម្បីព្យាយាមជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកព្យាយាម ។ ចិត្តរបស់ភិក្ខុណាបង្អោនទៅ ដើម្បីព្យាយាមជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយៗ ដើម្បីព្យាយាមមិនដាច់ ដើម្បី

តាំងទុកព្យាយាម ភិក្ខុនោះ ឈ្មោះថា បានលះបង់នូវសេចក្តីរឹងត្អឹងរបស់ចិត្តទី ១ នេះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមិនងឿងឆ្ងល់ក្នុងធម៌ ។បេ។ មិនងឿងឆ្ងល់ក្នុងសង្ឃ... មិនងឿងឆ្ងល់ក្នុងសិក្ខា មិនក្រោធខឹង មិនអន់ចិត្ត មិនមានចិត្តត្រូវទោសៈខ្ទាំងខ្ទប់ មិនមានសេចក្តីរឹងរូសក្នុងពួកសព្រហ្មចារី ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមិនក្រោធខឹង មិនអន់ចិត្ត មិនមានចិត្តត្រូវទោសៈខ្ទាំងខ្ទប់ មិនមានសេចក្តីរឹងរូស ក្នុងពួកសព្រហ្មចារីហើយ ចិត្តរបស់ភិក្ខុនោះ រមែងបង្អោនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកព្យាយាម ចិត្តរបស់ភិក្ខុណា បង្អោនទៅ ដើម្បីព្យាយាមជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកព្យាយាម ភិក្ខុនោះ ឈ្មោះថា លះបង់នូវសេចក្តីរឹងត្អឹងរបស់ចិត្តទី ៥ នេះ យ៉ាងនេះឯង ។ នេះជាសេចក្តីរឹងត្អឹងរបស់ចិត្តទាំង ៥ ដែលភិក្ខុបានលះបង់ហើយ ។ ចំណងរបស់ចិត្ត ៥ ដែលភិក្ខុបានផ្តាច់ផ្តិលហើយតើ ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រាសចាកតម្រេក ប្រាសចាកសេចក្តីប្រាថ្នា ប្រាសចាកសេចក្តីស្រឡាញ់ ប្រាសចាកសម្រេក ប្រាសចាកសេចក្តីក្តៅក្រហាយ ប្រាសចាកចំណង់ក្នុងកាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាអ្នកប្រាសចាកតម្រេក បាសចាកសេចក្តីប្រាថ្នា ប្រាសចាកសេចក្តីស្រឡាញ់ ប្រាសចាកសម្រេក ប្រាសចាកសេចក្តីក្តៅក្រហាយ

ប្រាសចាកចំណង់ក្នុងកាមទាំងឡាយហើយ ចិត្តរបស់ភិក្ខុនោះ រមែងបង្អោន ទៅដើម្បីព្យាយាមជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកព្យាយាម ។ ចិត្តរបស់ភិក្ខុណា បង្អោនទៅដើម្បីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកព្យាយាម ភិក្ខុនោះ ឈ្មោះថា បានផ្តាច់ផ្តិលនូវចំណងរបស់ចិត្តទី ១ នេះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកប្រាសចាកតម្រេកក្នុងកាយ ។បេ។ ប្រាសចាកតម្រេកក្នុងរូប មិនបរិភោគពេញពោះ ដរាបដល់ឆ្អែត ហើយរៀបចំតែទីដេកឲ្យស្រួល ទីផ្អែកឲ្យស្រួល ទីលក់ឲ្យស្រួល មិនប្រព្រឹត្តព្រហ្មចរិយធម៌ ព្រោះតម្កល់ទុកនូវសេចក្តីប្រាថ្នាឲ្យបានជាពួកទេវតាណាមួយថា អាត្មាអញ សូមឲ្យបានជាទេវតាធំ ឬទេវតាតូចណាមួយដោយសីល ឬវត្ត ឬក៏តបៈ ឬក៏ព្រហ្មចរិយៈនេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា មិនប្រព្រឹត្តព្រហ្មចរិយៈ ព្រោះតម្កល់ទុកនូវសេចក្តីប្រាថ្នាឲ្យបានជាពួកទេវតាណាមួយថា អាត្មាអញ សូមឲ្យបានជាទេវតាធំ ឬទេវតាតូចណាមួយ ដោយសីល ឬវត្ត ឬក៏តបៈ ឬក៏ព្រហ្មចរិយៈនេះហើយ ចិត្តរបស់ភិក្ខុនោះ រមែងបង្អោនទៅដើម្បីព្យាយាមជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកព្យាយាម ។ ចិត្តរបស់ភិក្ខុណា បង្អោនទៅដើម្បីព្យាយាមជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកព្យាយាម ។ ភិក្ខុនោះឈ្មោះថា

ផ្តាច់ផ្តិលនូវចំណង របស់ចិត្តទី ៥ នេះ យ៉ាងនេះឯង ។ នេះជាចំណង របស់ចិត្តទាំង ៥ ដែលភិក្ខុបានផ្តាច់ផ្តិល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ឬ ភិក្ខុនីណាមួយ បានលះបង់នូវសេចក្តីរឹងត្អឹងរបស់ចិត្តទាំង ៥ នេះ បានផ្តាច់ផ្តិលនូវចំណងរបស់ចិត្តទាំង ៥ នេះហើយ យប់និងថ្ងៃមកដល់ភិក្ខុ ឬភិក្ខុនីនោះ សេចក្តីចម្រើនក្នុងកុសលធម៌ទាំងឡាយ រមែងប្រាកដ មិនមានសេចក្តីសាបសូន្យឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចយប់ និងថ្ងៃ រមែងមកដល់ព្រះចន្ទខាងខ្នើត តែងចម្រើនដោយវណ្ណៈ ចម្រើនដោយមណ្ឌល ចម្រើនដោយរស្មី ចម្រើនដោយកម្ពស់ និងទំហំ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ឬភិក្ខុនីណាមួយ បានលះបង់នូវសេចក្តីរឹងត្អឹងរបស់ចិត្តទាំង ៥ នេះ បានផ្តាច់ផ្តិលនូវសេចក្តីរឹងត្អឹងរបស់ចិត្តទាំង ៥ នេះហើយ យប់ និងថ្ងៃមកដល់ ភិក្ខុ ឬភិក្ខុនីនោះ សេចក្តីចម្រើនក្នុងកុសលធម៌ទាំងឡាយរមែងប្រាកដ មិនមានសេចក្តីសាបសូន្យឡើយ ក៏យ៉ាងនោះដែរ ។

# អដ្ឋកថា

## ខីលសូត្រ

[ ១៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងខីលសូត្រទី ៤ ដូចតទៅនេះ កិលេសជាគ្រឿងជោតចិត្ត ដូចចម្រឹង ពោលពិស្តារហើយ ក្នុងបញ្ចកនិបាត ។ បទថា **អារោហបរិណាហេន** បានដល់ ដោយកម្ពស់ និងទំហំ ។l៙៚

# សុត្តន្តបិដក

## អប្បមាទសូត្រទី ៥

[ ១៥ ] ម្នាលភិក្ខុទាំងឡាយ ពួកសត្វទាំងអម្បាលម៉ាន ទោះបីមិនមានជើងក្តី មានជើងពីរក្តី មានជើងបួនក្តី មានជើងច្រើនក្តី មានរូបក្តី មិនមានរូបក្តី មានសញ្ញាក្តី មិនមានសញ្ញាក្តី មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនក្តី ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធប្រាជកជាប្រសើរជាងពួកសត្វទាំងអម្បាលនោះ ( យ៉ាងណាមិញ ) ម្នាលភិក្ខុទាំងឡាយ កងធម៌ជាកុសលឯណានីមួយ កងធម៌ជាកុសលទាំងអស់នោះ មានអប្បមាទជាឫសប្រជុំចុះក្នុងអប្បមាទ អប្បមាទប្រាកដជាប្រសើរជាងកងធម៌ជាកុសលទាំងនោះ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាស្នាមជើងទាំងឡាយណាមួយរបស់ពួកសត្វដែលដើរលើផ្ទៃផែនដី ស្នាមជើងទាំងអស់នោះរមែងដល់នូវការប្រជុំចុះក្នុងស្នាមជើងនៃដំរី ស្នាមជើងនៃដំរីប្រាកដជាប្រសើរជាងស្នាមជើងនៃសត្វទាំងនោះ ព្រោះជាស្នាមជើងធំ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កងធម៌ជាកុសលឯណានីមួយ កងធម៌ជាកុសលទាំងអស់នោះមានអប្បមាទជាឫស ប្រជុំចុះក្នុងអប្បមាទ អប្បមាទប្រាកដជាប្រសើរជាងកងធម៌ជាកុសលទាំងអស់នោះ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបង្កង់ទាំងឡាយឯណានីមួយ របស់កូដាគារ ( ផ្ទះដែលគេសង្រ្គោះដោយកំពូល ) បង្កង់ទាំងអស់នោះ ឈមទៅរកកំពូល ទេរទៅរកកំពូល ប្រជុំទៅត្រង់កំពូល កំពូលប្រាកដជាប្រសើរជាងបង្កង់ទាំងនោះ យ៉ាងណាមិញ ម្នាល

ភិក្ខុទាំងឡាយ កុសលធម៌ជាកុសលឯណានីមួយ កុសលធម៌ជាកុសលទាំងអស់នោះ មានអប្បមាទជាឫស ប្រជុំចុះក្នុងអប្បមាទ អប្បមាទប្រាកដជាប្រសើរជាង កុសលធម៌ជាកុសលទាំងនោះ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាក្លិនឫសឈើទាំងឡាយឯណានីមួយ ក្លិនឫសក្រាំពាក់ ប្រាកដជាប្រសើរជាងក្លិនឫសឈើទាំងនោះ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ។បេ។ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាក្លិនខ្លឹមទាំងឡាយណានីមួយ ក្លិនខ្លឹមចន្ទន៍ក្រហម ប្រាកដជាប្រសើរជាងក្លិនខ្លឹមទាំងនោះ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ។បេ។ យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាក្លិនផ្កាឈើទាំងឡាយ ឯណានីមួយ ក្លិនផ្កាម្លិះប្រាកដជាប្រសើរជាងក្លិនផ្កាឈើទាំងនោះ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ។បេ។ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាពួកស្តេចតូចៗ ឯណានីមួយ ពួកស្តេចតូចៗ ទាំងអស់នោះ រមែងជាចំណុះរបស់ស្តេចចក្រពត្តិ ស្តេចចក្រពត្តិ ប្រាកដជាប្រសើរជាងពួកស្តេចតូចៗ ទាំងនោះ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ។បេ។ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាពន្លឺរបស់រូបផ្កាយទាំងឡាយឯណានីមួយ ពន្លឺទាំងអស់នោះ មិនបានដល់នូវចំណិតជាគម្រប់ ១៦ៗ ដងនៃពន្លឺព្រះចន្ទ ពន្លឺព្រះចន្ទប្រាកដជាប្រសើរជាងពន្លឺនៃរូបផ្កាយទាំងនោះ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ។បេ។ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាព្រះអាទិត្យ កាលបើភ្លៀង

ស្វាន ប្រាសចាកពពកក្នុងសរទសម័យ ខ្ពស់ផុតពពក កម្ចាត់បង់នូវងងឹតទាំងអស់ដែលនៅលើអាកាស ហើយភ្លឺស្វាងរុងរឿង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ។បេ។ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាទន្លេធំទាំងឡាយ ឯណានីមួយ គឺ ទន្លេគង្គា យមុនា អចិរវតី សរភូ មហីទន្លេទាំងអស់នោះ ក៏ឈមទៅរកសមុទ្រ ឱនទៅរកសមុទ្រ ទេរទៅរកសមុទ្រញោចទៅរកសមុទ្រ មហាសមុទ្រប្រាកដជាប្រសើរជាងទន្លេធំទាំងនោះ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កងធម៌ជាកុសលឯណានីមួយ កងធម៌ជាកុសលទាំងអស់នោះ មានអប្បមាទជាឫស ប្រជុំចុះក្នុងអប្បមាទ អប្បមាទប្រាកដជាប្រសើរជាងកងធម៌ជាកុសលទាំងនោះ ក៏យ៉ាងនោះដែរ ។

# អដ្ឋកថា

## អប្បមាទសូត្រ

[ ១៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអប្បមាទសូត្រទី ៥ ដូចតទៅនេះ បទថា **ឯវមេវ ខោ** (ក៏យ៉ាងនោះដែរ)សេចក្តីថា គឺការមិនប្រមាទហេតុឲ្យធ្វើកុសលគប្បីឃើញថា ជាកំពូលនៃកុសលធម៌គ្រប់យ៉ាង ដូចព្រះសម្ពុទ្ធទ្រង់ជាកំពូលនៃសត្វទាំងពួង ដូច្នោះ ។ សួរថា អប្បមាទនោះជាលោកិយ ឯកុសលធម៌ទាំងឡាយជាលោកុត្តរក៏មាន អប្បមាទនេះជាកាមាវចរតែម្យ៉ាង រីឯកុសល

*ធម៌ទាំងឡាយ ប្រព្រឹត្តទៅក្នុងភូមិ៤ មិនមែនឬ ប្រសិនបើដូច្នោះ អប្បមាទនេះ ជាកំពូលនៃកុសលធម៌ពួកនោះ បានដូចម្តេច ។ ឆ្លើយថា ព្រោះអត្ថថាជាហេតុឲ្យបាន ។ ពិតហើយ កុសលធម៌ទាំងនោះ បុគ្គលរមែងបាន ដោយការមិនប្រមាទ ព្រោះដូច្នោះ ការមិនប្រមាទនោះ ទើបឈ្មោះថា ជាកំពូលនៃកុសលធម៌ទាំងនោះ ដោយហេតុនោះ ទើបត្រាស់ថា កុសលធម៌ទាំងអស់នោះ មានការមិនប្រមាទជាមូល ។ បទថា* **ជង្គលានំ** *ប្រែថា ដែលសញ្ចរទៅសព្វផ្ទៃផែនដី ។ បទថា* **ចាណានំ** *បានដល់ សត្វមានជើង ។ បទថា* **បទជាតានិ** *ប្រែថា ស្នាមជើង ។ បទថា* **សមោធានំ** **គច្ឆន្តិ** *ប្រែថា រមែងប្រជុំចុះ ដាក់ចុះ ។ បទថា* **អគ្គមក្ខាយតិ** *ប្រែថា លោកពោលថាប្រសើរ ។ បទថា* **យទិទំ មហន្តត្តេន** *សេចក្តីថា លោកពោលថា ប្រសើរព្រោះជាស្នាមជើងធំ មិនមែនពោលដោយគុណាឡើយ ។ បទថា* **វស្សិកំ** *បានដល់ ផ្កាម្លិះ បានឮថា ព្រះបាទភាតិយមហារាជ ទ្រង់ស្តាប់ព្រះសូត្រនេះហើយ ទ្រង់បំណងនឹងសាកល្បង ទើបឲ្យយកផ្កាក្រអូបមកអប់ដោយក្លិន ៤ ប្រភេទ ក្នុងបន្ទប់នីមួយៗ ដាក់បាច់ផ្កាម្លិះទុកក្នុងបន្ទប់មួយ ធ្វើផ្កាដ៏សេសជាបាច់ទុកដោយជុំវិញផ្កាម្លិះនោះ ទ្រង់បើកទ្វារ ហើយចេញទៅខាងក្រៅ កាលទ្រង់សម្រាកខាងក្រៅមួយស្របក់ ហើយបើកទ្វារចូល ក្លិនផ្កាម្លិះប៉ះព្រះនាសិកមុនផ្កាទាំងពួង ។ ទ្រង់ផ្ទុំលើព្រះទែនធំនោះឯង បែរព្រះភក្ត្រទៅរកមហាចេតិយ ថ្វាយបង្គំមហាចេតិយ ដោយទ្រង់ទទួលថា ព្រះសម្មាសម្ពុទ្*

កាលត្រាស់ថា ផ្កាម្ទិះជាកំពូលនៃបុប្ផគន្ធជាតិទាំងនោះ ឈ្មោះថា ត្រាស់ប្រពៃហើយ ។ បទថា **កុទ្ធរាជានោ** បានដល់ ព្រះរាជាតូច ។ បាឋៈថា **កុដ្ដរាជានោ** ដូច្នេះក៏មាន ។ល។

## អដ្ឋកថាអប្បមាទសូត្រទី ៥ ចប់

# សុត្តន្តបិដក

## អាហុនេយ្យសូត្រទី ៦

[ ១៦ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ១០ ពួកនេះ ជាអ្នកគួរទទួលនូវវត្ថុដែលគេនាំមកដើម្បីបូជា គួរទទួលវត្ថុដែលគេតាក់តែងដើម្បីទទួលភ្ញៀវ គួរទទួលទានដែលគេជឿកម្ម និងផលរបស់កម្មហើយបូជា គួរឲ្យបុគ្គលដែលត្រូវការដោយកុសល ប្រណម្យអញ្ជលី ជាស្រែបុណ្យដ៏ប្រសើររបស់សត្វលោក ។ បុគ្គលទាំង ១០ ពួក តើដូចម្ដេច ។ គឺព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ១ ព្រះបច្ចេកសម្ពុទ្ធ ១ ឧភតោភាគវិមុត្តបុគ្គល ១ បញ្ញាវិមុត្តបុគ្គល ១ កាយសក្ខីបុគ្គល ១ ទិដ្ឋិប្បត្តបុគ្គល ១ សទ្ធាវិមុត្តបុគ្គល ១ ធម្មានុសារីបុគ្គល ១ សទ្ធានុសារីបុគ្គល ១ គោត្រភូបុគ្គល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ១០ ពួកនេះ ជាអ្នកគួរទទួលនូវវត្ថុដែលគេនាំមកដើម្បីបូជា ។បេ។

ជាស្រែបុណ្យដ៏ប្រសើររបស់សត្វលោក ។

# អដ្ឋកថា

## អាហុនេយ្យសូត្រ

[ ១៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអាហុនេយ្យសូត្រទី ៦ ដូចតទៅនេះ បទថា **គោត្រភូ** បានដល់ ប្រកបដោយគោត្រភូញាណ ដែលមាននិព្វាន ជាអារម្មណ៍ ដែលជាវិបស្សនាដល់កំពូលហើយ ។

**អដ្ឋកថា អាហុនេយ្យសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## បឋមនាថសូត្រទី ៧

[ ១៧ ] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរជាបុគ្គលមានទីពឹង កុំជាបុគ្គលមិនមានទីពឹងឡើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនមានទីពឹង រមែងនៅជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ នាថករណធម៌ ( ធម៌សម្រាប់ធ្វើឲ្យមានទីពឹង ) នេះមាន ១០ យ៉ាង ។ នាថករណធម៌ ១០ យ៉ាង តើដូចម្តេច ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិ-មោក្ខសំវរៈ បរិបូណ៌ដោយអាចារ និងគោចរ ជាអ្នកឃើញភ័យក្នុងទោសសូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសីល ។បេ។ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ព្រោះធម៌ណា នេះឯងជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាពហុស្សូត ទ្រទ្រង់នូវពុទ្ធវចនៈដែលខ្លួនបានស្តាប់ហើយ សន្សំនូវពុទ្ធវចនៈដែលខ្លួនបានស្តាប់ហើយ ធម៌ទាំងឡាយណា មានលម្អបទដើម លម្អបទកណ្តាល លម្អបទចុង ប្រកាសនូវព្រហ្មចរិយៈ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈដ៏បរិបូណ៌ បរិសុទ្ធទាំងអស់ ធម៌មានសភាពដូច្នោះ ភិក្ខុនោះ ក៏ចេះចាំច្រើន បានចាំទុក ចាំជាប់ក្នុងចិត្ត បានចាក់ធ្លុះល្អដោយទិដ្ឋិ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាពហុស្សូត ។បេ។ បានចាក់ធ្លុះល្អដោយទិដ្ឋិព្រោះធម៌ណា នេះឯងជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមានមិត្តល្អ មានសម្លាញ់ល្អ ជាអ្នកពត់ខ្លួនតាមមិត្តសម្លាញ់ល្អ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានមិត្តល្អ មានសម្លាញ់ល្អ ជាអ្នកផ្អាកចិត្តទៅតាមមិត្តសម្លាញ់ល្អ ព្រោះធម៌ណា នេះឯងជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកប្រដៅងាយ ប្រកបដោយធម៌ទាំងឡាយ ជាគ្រឿងធ្វើឲ្យប្រដៅងាយ ជាអ្នកអត់ធន់ ទទួលយកនូវពាក្យប្រៀនប្រដៅដោយផ្ចិតផ្ចង់ ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុជាអ្នកដែលគេប្រដៅងាយ ជាអ្នកអត់ធន់ ទទួលយកនូវពាក្យប្រៀន

ប្រដៅដោយផ្ចិតផ្ចង់ ព្រោះធម៌ណា នេះឯងជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អំពើណាដ៏ខ្ពស់ និងទាប ដែលពួកសព្រហ្មចារីបុគ្គលត្រូវសួរគ្នីគ្នាហើយទើបធ្វើ ភិក្ខុជាអ្នកឈ្លាសវៃ មិនខ្ជិលច្រអូសក្នុងអំពើនោះប្រកបដោយការពិចារណា ដោយឧបាយក្នុងអំពើនោះថា គួរធ្វើ គួរចាត់ចែងបាន ។ ម្នាលភិក្ខុទាំងឡាយ អំពើណាដ៏ខ្ពស់ និងទាប ដែលពួកសព្រហ្មចារីបុគ្គល ត្រូវសួរគ្នីគ្នាហើយទើបធ្វើ ភិក្ខុ ។បេ។ ថាគួរធ្វើ គួរចាត់ចែង ព្រោះធម៌ណា នេះឯងជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកប្រាថ្នាធម៌ ពេញចិត្តនឹងការនិយាយធម៌ មានសេចក្តីរីករាយដ៏លើសលុបក្នុងអភិធម៌ និងអភិវិន័យ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រាថ្នាធម៌ ពេញចិត្តនឹងការនិយាយធម៌ មានសេចក្តីរីករាយលើសលុបក្នុងអភិធម៌ និងអភិវិន័យ ព្រោះធម៌ណា នេះឯងជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកប្រារព្ធព្យាយាម ដើម្បីលះបង់នូវពួកអកុសលធម៌ និងញ៉ាំងពួកកុសលធម៌ឲ្យសម្រេច ជាអ្នកមានកម្លាំង សង្វាតមាំមួន មិនដាក់ចុះនូវធុរៈក្នុងកុសលធម៌ទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រារព្ធព្យាយាម ដើម្បីលះបង់នូវអកុសលធម៌ និងញ៉ាំងកុសលធម៌ឲ្យសម្រេច ជាអ្នកមានកម្លាំងសង្វាតមាំមួន មិនដាក់ចុះនូវធុរៈ ក្នុងកុសលធម៌ទាំងឡាយ ព្រោះធម៌ណា នេះឯងជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមាន

តាមបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមាន តាមបាន ព្រោះហេតុណា នេះឯងជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានស្មារតី ប្រកបដោយស្មារតី និងបញ្ញាដ៏ឧត្តម ជាអ្នករឭកឃើញ រឭកតាមនូវអំពើដែលធ្វើយូរហើយផង នូវពាក្យដែលនិយាយយូរហើយផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានស្មារតី ប្រកបដោយស្មារតី និងបញ្ញាដ៏ឧត្តម ជាអ្នករឭកឃើញ រឭកតាមនូវអំពើ ដែលធ្វើយូរហើយផង នូវពាក្យដែលនិយាយយូរហើយផង ព្រោះហេតុណា នេះឯងជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញាជាគ្រឿងដឹងនូវការកើត និងការរលត់នៃ ( ខន្ធ ) ដ៏ប្រសើរ ជាប្រាជ្ញាសម្រាប់ទម្លុះទម្លាយនូវកិលេស ប្រព្រឹត្តទៅក្នុងធម៌ជាគ្រឿងអស់ទៅ នៃទុក្ខដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញាជាគ្រឿងដឹងនូវការកើត និងការរលត់នៃ ( ខន្ធ ) ដ៏ប្រសើរ ជាប្រាជ្ញាសម្រាប់ទម្លុះទម្លាយនូវកិលេស ប្រព្រឹត្តទៅក្នុងធម៌ ជាគ្រឿងអស់ទៅនៃទុក្ខ ដោយប្រពៃ ព្រោះធម៌ណា នេះឯងជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរជាបុគ្គលមានទីពឹង កុំជាបុគ្គលមិនមានទីពឹងឡើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនមានទីពឹង រមែងនៅជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ នាថករណធម៌ ( ធម៌ជាគ្រឿងធ្វើឲ្យមានទីពឹង ) ១០ យ៉ាងនេះឯង ។

# អដ្ឋកថា

## បឋមនាថសូត្រ

[ ១៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមនាថសូត្រទី ៧ ដូចតទៅនេះ បទថា **សនាថា** សេចក្ដីថា មានញាតិ គឺមានញាតិច្រើន ។ ជនពួកណាធ្វើទីពឹង ហេតុនោះ ជនទាំងនោះ ឈ្មោះថា ធ្វើទីពឹង អធិប្បាយថា ធ្វើឲ្យមានទីពឹង ទីពំនាក់ដល់ខ្លួន ។ ក្នុងបទថា **កល្យាណមិត្តោ** ជាដើម ឈ្មោះថា មានកល្យាណមិត្ត ព្រោះមានមិត្រល្អ ដែលសម្បូរដោយសីលជាដើម ។ ឈ្មោះថា មានកល្យាណមិត្ត ព្រោះជនទាំងនោះជាសម្លាញ់របស់បុគ្គលនោះ ព្រោះទៅរួមគ្នាក្នុងឥរិយាបថ មានឈរ អង្គុយជាដើម ។ ដែលឈ្មោះថា **កល្យាណសម្បវង្កោ** ព្រោះទន់ភ្ជន់ក្នុងពួកកល្យាណមិត្តដោយកាយ និងចិត្ត ។

បទថា **សុវចោ ហោតិ** សេចក្ដីថា រមែងជាបុគ្គលដែលគេប្រដៅងាយ ដែលគេគប្បីទូន្មានបានងាយ ។ បទថា **ខមោ** បានដល់ ត្រូវពោលដោយពាក្យគ្រោតគ្រាត ពាក្យទ្រគោះ ក៏អត់ធន់បាន មិនក្រោធ ។ បទថា **បទក្ខិណគ្គាហី អនុសាសនឹ** សេចក្ដីថា មិនធ្វើដូចបុគ្គលខ្លះ កាលត្រូវលោកទូន្មាន ក៏ទទួលយកខាងឆ្វេង គឺមិនគោរព តបត ឬមិនស្ដាប់ ដើរចេញទៅ ទទួលយកខាងស្ដាំ ដោយពោលថា សូមលោកទូន្មានខ្ញុំចុះ កាលលោកមិនទូន្មាន អ្នកដទៃណានឹងទូន្មាន ដូច្នេះ ។

បទថា **ឧច្ចាវចានិ** ប្រែថា ខ្ពស់ទាប ។ បទថា **កឹករណីយានិ** បានដល់ កិច្ចកម្មដែលសួរយ៉ាងនេះថា ខ្ញុំធ្វើអ្វី ហើយធ្វើ ។ បណ្ដាកិច្ចកម្មខ្ពស់

ទាប ឈ្មោះថា កិច្ចកម្មខ្ពស់ បានដល់ កិច្ច ដូចជាធ្វើចីវរ ជ្រលក់ចីវរ បូក បាយ-អព្រះចេតិយ កិច្ចកម្មដែលគប្បីធ្វើក្នុងរោងឧបោសថ ខឿនព្រះចេតិយ និងខឿនពោធិព្រឹក្ស យ៉ាងនេះជាដើម ។ ឈ្មោះថា កិច្ចកម្មទាប បានដល់ កិច្ចកម្មតិចតួច ដូចជាលាងបាត្រ លាបប្រេងជាដើម ។ បទថា **តត្រុ-បាយាយ** បានដល់ ដែលប្រព្រឹត្តទៅក្នុងកិច្ចកម្មនោះ ។ បទថា **អលំ កាតុំ** ប្រែថា ជាអ្នកអាចធ្វើបានឯង ។ បទថា **អលំ សំវិធាតុំ** ប្រែថា អាច ចាត់ចែងការបាន ។

ភិក្ខុ ឈ្មោះថា ធម្មកាម ព្រោះមានការស្រឡាញ់ក្នុងធម៌ អធិប្បាយ ថា រមែងស្រឡាញ់ព្រះត្រៃបិដក ពុទ្ធវចនៈ ។ បទថា **បិយសមុទាហារោ** សេចក្ដីថា កាលអ្នកដទៃពោល ក៏ស្ដាប់ដោយគោរព ទាំងខ្លួនក៏ប្រាថ្នានឹង សម្ដែងដល់អ្នកដទៃ ។ ក្នុងពាក្យថា **អភិធម្មេ អភិវិនយេ** នេះ គប្បីជ្រាប ចតុក្កៈ គឺធម៌ ១ អភិធម្ម ១ វិន័យ ១ អភិវិន័យ ១ ។ ក្នុងចតុក្កៈនោះ ឈ្មោះថា ធម៌ បានដល់ ព្រះសុត្តន្តបិដក ឈ្មោះថា អភិធម្ម បានដល់ បករណ៍ទាំង ៧ ។ ឈ្មោះថា វិន័យ បានដល់ វិភង្គទាំង ២ ឈ្មោះថា អភិវិន័យ បានដល់ ខន្ធកៈ និងបរិវារ ។ ន័យម្យ៉ាងទៀត សុត្តន្តបិដកក្ដី អភិធម្មបិដកក្ដី ឈ្មោះថា ធម៌ទាំងអស់ ។ មគ្គ ផល ឈ្មោះថា អភិធម្ម វិនយបិដកទាំងមូល ឈ្មោះថា វិន័យ ការធ្វើការរម្ងាប់កិលេស ឈ្មោះថា អភិវិន័យ អធិប្បាយថា ជាបុគ្គលមានបាមោជ្ជយ៉ាងឱឡារ ក្នុងធម៌ អភិធម្ម

វិន័យ និងអភិវិន័យទាំងអស់ ដោយប្រការដូច្នេះ ។ បទថា **កុសលេសុ ធម្មេសុ** ជាសត្តមីវិភត្តិ ចុះក្នុងអត្ថតតិយាវិភត្តិ ។ អធិប្បាយថា ជាបុគ្គលមិនដាក់ធុរៈ ដើម្បីសម្រេចធម៌ទាំងនោះ ព្រោះហេតុនៃកុសលធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។៙

**អដ្ឋកថា បឋមនាថសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ទុតិយនាថសូត្រទី ៨

[ ១៨ ] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរជាបុគ្គលមានទីពឹង កុំជាបុគ្គលមិនមានទីពឹងឡើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនមានទីពឹង រមែងនៅជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ នាថករណធម៌ ( ធម៌ជាគ្រឿងធ្វើឲ្យមានទីពឹង ) នេះមាន ១០ យ៉ាង ។ នាថករណធម៌ ១០ យ៉ាងតើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។បេ។ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ពួកភិក្ខុជាថេរៈក្តី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ពួកភិក្ខុជាកណ្តាលក្តី ... ពួកភិក្ខុថ្មីក្តី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ដោយគិតថា ឱហ្ន៎ភិក្ខុនេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារ និងគោចារ ជា

អ្នកឃើញភ័យក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយដែរ ។ កាលភិក្ខុនោះ ដែលភិក្ខុជាថេរៈអនុគ្រោះហើយ ដែលភិក្ខុជាកណ្តាលអនុគ្រោះហើយ ដែលភិក្ខុថ្មីអនុគ្រោះហើយ រមែងមានសេចក្តីចម្រើនប្រាកដ ក្នុងកុសលធម៌ទាំងឡាយតែម្យ៉ាង មិនមានសេចក្តីសាបសូន្យឡើយ នេះឯងជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាពហុស្សូត ។បេ។ បានចាក់ធ្លុះល្អដោយទិដ្ឋិ ពួកភិក្ខុជាថេរៈតែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ពួកភិក្ខុជាកណ្តាលក្តី ... ពួកភិក្ខុថ្មីក្តី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ដោយគិតថា ឱហ្ន៎ ភិក្ខុនេះជាពហុស្សូត ទ្រទ្រង់នូវពុទ្ធវចនៈ ដែលខ្លួនបានស្តាប់ហើយ សន្សំនូវពុទ្ធវចនៈ ដែលខ្លួនបានស្តាប់ហើយ ធម៌ទាំងឡាយណា មានលម្អបទដើម លម្អបទកណ្តាល លម្អបទចុង ប្រកាសនូវព្រហ្មចរិយៈ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈដ៏បរិបូណ៌ បរិសុទ្ធទាំងអស់ ធម៌មានសភាពដូច្នោះ ភិក្ខុនោះ ក៏បានចេះចាំច្រើន បានចាំទុក ចាំរត់មាត់ ចាំជាប់ក្នុងចិត្ត បានចាក់ធ្លុះល្អដោយទិដ្ឋិដែរ ។ កាលភិក្ខុនោះ ដែលភិក្ខុជាថេរៈអនុគ្រោះហើយ ដែលភិក្ខុជាកណ្តាលអនុគ្រោះហើយ ដែលភិក្ខុថ្មីអនុគ្រោះហើយ រមែងមានសេចក្តីចម្រើនប្រាកដ ក្នុងកុសលធម៌ទាំងឡាយតែម្យ៉ាង មិនមានសេចក្តីសាបសូន្យឡើយ នេះឯងជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានមិត្តល្អ មានសម្លាញ់ល្អ មានការផ្អោកចិត្តទៅតាមមិត្ត

សម្លាញ់ល្អ ពួកភិក្ខុជាថេរៈក្តី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ពួកភិក្ខុជាកណ្តាលក្តី ... ពួកភិក្ខុថ្មីក្តី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ដោយគិតថា ឱហ្ន៎ ភិក្ខុនេះជាអ្នកមានមិត្តល្អ មានសម្លាញ់ល្អ មានការងាកចិត្តទៅតាមសម្លាញ់ល្អដែរ ។ កាលភិក្ខុនោះ ដែលភិក្ខុជាថេរៈអនុគ្រោះហើយ ដែលភិក្ខុជាកណ្តាលអនុគ្រោះហើយ ដែលភិក្ខុថ្មីអនុគ្រោះហើយ រមែងមានសេចក្តីចម្រើនប្រាកដ ក្នុងកុសលធម៌ទាំងឡាយតែម្យ៉ាង មិនមានសេចក្តីសាបសូន្យឡើយ នេះឯងជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកប្រដៅងាយ ប្រកបដោយធម៌ ជាគ្រឿងធ្វើឲ្យប្រដៅងាយ ជាអ្នកអត់ធន់ ទទួលយកនូវពាក្យប្រៀនប្រដៅដោយផ្ចិតផ្ចង់ ពួកភិក្ខុជាថេរៈក្តី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ពួកភិក្ខុជាកណ្តាលក្តី ... ពួកភិក្ខុថ្មីក្តី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ដោយគិតថា ឱហ្ន៎ ភិក្ខុនេះជាអ្នកប្រដៅងាយ ប្រកបដោយធម៌ ជាគ្រឿងធ្វើឲ្យប្រដៅងាយ ជាអ្នកអត់ធន់ ទទួលយកនូវពាក្យប្រៀនប្រដៅ ដោយផ្ចិតផ្ចង់ដែរ ។ កាលភិក្ខុនោះ ដែលភិក្ខុជាថេរៈអនុគ្រោះហើយ ដែលភិក្ខុជាកណ្តាលអនុគ្រោះហើយ ដែលភិក្ខុថ្មីអនុគ្រោះហើយ រមែងមានសេចក្តីចម្រើនប្រាកដ ក្នុងកុសលធម៌ទាំងឡាយតែម្យ៉ាង មិនមានសេចក្តីសាបសូន្យឡើយ នេះឯងជានាថករណ-ធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អំពើណាដ៏ខ្ពស់ និងទាប ដែល

ពួកសព្រហ្មចារីបុគ្គល ត្រូវសួរគ្នីគ្នាហើយទើបធ្វើ ភិក្ខុជាអ្នកឈ្លាសវៃ មិនខ្ជិលច្រអូសក្នុងអំពើនោះ ប្រកបដោយប្រាជ្ញា ជាគ្រឿងពិចារណាដោយឧបាយក្នុងអំពើនោះថា គួរធ្វើ គួរចាត់ចែងបាន ។ ពួកភិក្ខុជាថេរៈក្តី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ពួកភិក្ខុជាកណ្តាលក្តី ... ពួកភិក្ខុថ្មីក្តី តែងសម្គាល់ភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ដោយគិតថា ឱហ្ន៎ អំពើណាដ៏ខ្ពស់ និងទាប ដែលពួកសព្រហ្មចារីបុគ្គល ត្រូវសួរគ្នីគ្នាហើយទើបធ្វើភិក្ខុនេះជាអ្នកឈ្លាសវៃ មិនខ្ជិលច្រអូស ក្នុងអំពើនោះ ប្រកបដោយប្រាជ្ញា ជាគ្រឿងពិចារណា ដោយឧបាយក្នុងអំពើនោះថា គួរធ្វើ គួរចាត់ចែងបានដែរ ។ កាលភិក្ខុនោះ ដែលភិក្ខុជាថេរៈអនុគ្រោះហើយ ដែលភិក្ខុជាកណ្តាលអនុគ្រោះហើយ ដែលភិក្ខុថ្មីអនុគ្រោះហើយ រមែងមានសេចក្តីចម្រើនកើតប្រាកដ ក្នុងកុសលធម៌ទាំងឡាយតែម្យ៉ាង មិនមានសេចក្តីសាបសូន្យឡើយ នេះឯងជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀតភិក្ខុជាអ្នកប្រាថ្នាធម៌ មានសេចក្តីពេញចិត្តចំពោះការពោលធម៌ មានសេចក្តីរីករាយដ៏លើសលុបក្នុងអភិធម៌ ក្នុងអភិវិន័យ ពួកភិក្ខុជាថេរៈក្តី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ពួកភិក្ខុជាកណ្តាលក្តី ... ពួកភិក្ខុថ្មីក្តី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ដោយគិតថា ឱហ្ន៎ ភិក្ខុនេះ ជាអ្នកប្រាថ្នាធម៌ មានសេចក្តីពេញចិត្តចំពោះការពោលធម៌ មានសេចក្តីរីករាយដ៏លើសលុប ក្នុងអភិធម៌ ក្នុងអភិវិន័យដែរ ។ កាលភិក្ខុ

នោះ ដែលភិក្ខុជាថេរៈអនុគ្រោះហើយ ដែលភិក្ខុជាកណ្តាលអនុគ្រោះហើយ ដែលភិក្ខុថ្មីអនុគ្រោះហើយ រមែងមានសេចក្តីចម្រើនកើតប្រាកដ ក្នុងកុសលធម៌ទាំងឡាយតែម្យ៉ាង មិនមានសេចក្តីសាបសូន្យឡើយ នេះឯងជានាថករណធម៌ ១ ។ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកប្រារព្ធព្យាយាម ដើម្បីលះបង់នូវអកុសលធម៌ ញុំាងពួកកុសលធម៌ឲ្យសម្រេច ជាអ្នកមានកម្លាំង សង្វាតមាំ មិនដាក់ចុះនូវធុរៈ ក្នុងកុសលធម៌ទាំងឡាយ ពួកភិក្ខុជាថេរៈក្តី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ពួកភិក្ខុជាកណ្តាលក្តី ... ពួកភិក្ខុថ្មីក្តី តែងសម្គាល់នូវភិក្ខុនោះថា ជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ដោយគិតថា ឱហ្ន៎ ភិក្ខុនេះជាអ្នកប្រារព្ធព្យាយាម ដើម្បីលះបង់នូវពួកអកុសលធម៌ ទាំងញុំាងពួកកុសលធម៌ឲ្យសម្រេច ជាអ្នកមានកម្លាំងសង្វាតមាំ មិនដាក់ចុះនូវធុរៈក្នុងកុសលធម៌ទាំងឡាយដែរ ។ កាលភិក្ខុនោះដែលភិក្ខុជាថេរៈអនុគ្រោះហើយ ដែលភិក្ខុជាកណ្តាលអនុគ្រោះហើយ ដែលភិក្ខុថ្មីអនុគ្រោះហើយ រមែងមានសេចក្តីចម្រើនប្រាកដ ក្នុងកុសលធម៌ទាំងឡាយតែម្យ៉ាង មិនមានសេចក្តីសាបសូន្យឡើយ នេះឯងជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារតាមមានតាមបាន ពួកភិក្ខុជាថេរៈក្តី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ពួកភិក្ខុជាកណ្តាលក្តី ... ពួកភិក្ខុថ្មីក្តី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី

គួរប្រៀនប្រដៅ ដោយគិតថា ឱហ្ន៎ ភិក្ខុនេះជាអ្នកសន្ដោសដោយចីវរ បិណ្ឌ-បាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារដែរ ។ កាលភិក្ខុនោះដែលភិក្ខុជាថេរៈអនុគ្រោះហើយ ដែលភិក្ខុជាកណ្ដាលអនុគ្រោះហើយ ដែលភិក្ខុថ្មីអនុគ្រោះហើយ រមែងមានសេចក្ដីចម្រើនប្រាកដ ក្នុងកុសលធម៌ទាំង-ឡាយតែម្យ៉ាង មិនមានសេចក្ដីសាបសូន្យឡើយ នេះឯងជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានស្មារតី ប្រកបដោយស្មារតី និងបញ្ញាដ៏ឧត្ដម ជាអ្នករឭកឃើញ រឭកតាមនូវអំពើដែលធ្លាប់ធ្វើមកយូរហើយផង នូវពាក្យដែលធ្លាប់និយាយមកយូរហើយផង ពួកភិក្ខុជាថេរៈក្ដីតែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្ដី គួរប្រៀនប្រដៅ ពួកភិក្ខុជាកណ្ដាលក្ដី ... ពួកភិក្ខុថ្មីក្ដី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្ដី គួរប្រៀនប្រដៅដោយគិតថា ឱហ្ន៎ ភិក្ខុនេះ ជាអ្នកមានស្មារតី ប្រកបដោយស្មារតីនិងបញ្ញាដ៏ឧត្ដម ជាអ្នករឭកឃើញ រឭកតាមនូវអំពើដែលធ្លាប់ធ្វើមកយូរហើយផង នូវពាក្យដែលធ្លាប់និយាយមកយូរហើយផង បានដែរ ។ កាលភិក្ខុនោះ ដែលភិក្ខុជាថេរៈអនុគ្រោះហើយ ដែលភិក្ខុជាកណ្ដាលអនុគ្រោះហើយ ដែលភិក្ខុថ្មីអនុគ្រោះហើយ រមែងមានសេចក្ដីចម្រើនប្រាកដ ក្នុងកុសលធម៌ទាំងឡាយតែម្យ៉ាង មិនមានសេចក្ដីសាបសូន្យឡើយ នេះឯង ជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញា ជាគ្រឿងដឹងការកើត និងការរលត់ ( ខន្ធ ) ជាបញ្ញា

ដ៏ប្រសើរ ជាគ្រឿងទម្លុះទម្លាយនូវកិលេស ប្រព្រឹត្តទៅក្នុងធម៌ ជាគ្រឿងអស់ទុក្ខដោយប្រពៃ ពួកភិក្ខុជាថេរៈក្តី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ពួកភិក្ខុជាកណ្តាលក្តី ... ពួកភិក្ខុថ្មីក្តី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ដោយគិតថា ឱហ្ន៎ ភិក្ខុនេះ ជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញា ជាគ្រឿងដឹងការកើត និងការរលត់ ជាបញ្ញាដ៏ប្រសើរ ជាគ្រឿងទម្លុះទម្លាយនូវកិលេស ប្រព្រឹត្តទៅក្នុងធម៌ ជាគ្រឿងអស់ទុក្ខដោយប្រពៃដែរ ។ កាលភិក្ខុនោះ ដែលភិក្ខុជាថេរៈអនុគ្រោះហើយ ដែលភិក្ខុជាកណ្តាលអនុគ្រោះហើយ ដែលភិក្ខុថ្មីអនុគ្រោះហើយ រមែងមានសេចក្តីចម្រើនកើតប្រាកដ ក្នុងកុសលធម៌ទាំងឡាយតែម្យ៉ាង មិនមានសេចក្តីសាបសូន្យឡើយ នេះឯងជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរជាបុគ្គលមានទីពឹង កុំជាបុគ្គលមិនមានទីពឹងឡើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនមានទីពឹង រមែងនៅជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ នាថករណធម៌ ( ធម៌ជាគ្រឿងធ្វើឲ្យមានទីពឹង ) មាន ១០ យ៉ាងនេះឯង ។

# អដ្ឋកថា

## ទុតិយនាថសូត្រ

[ ១៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយនាថសូត្រទី ៨ ដូចតទៅនេះ បទថា **ថេរានុកម្បិតស្ស** បានដល់ បុគ្គលដែលព្រះថេរៈទាំងឡាយអនុគ្រោះដោយ

ការផ្សាយនូវប្រយោជន៍ ដែលឧស្សាហ៍ ព្រោះការឲ្យឱវាទ និងប្រៀនប្រដៅជាហេតុ ។

**អដ្ឋកថា ទុតិយនាថសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## បឋមអរិយាវាសសូត្រទី ៩

[ ១៩ ] ម្នាលភិក្ខុទាំងឡាយ អរិយាវាសៈ ( ធម៌ជាគ្រឿងអប់រំដ៏ប្រសើរ ) នេះមាន ១០ យ៉ាង ដែលពួកព្រះអរិយៈបានអប់រំហើយក្តី កំពុងអប់រំក្តី នឹងអប់រំក្តី ។ អរិយាវាសៈទាំង ១០ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់នូវអង្គ ៥ ប្រកបដោយអង្គ ៦ មានគ្រឿងរក្សាចិត្តតែមួយ មានធម៌ជាបង្អែក ៤ បានបន្ទោបង់នូវបច្ចេកសច្ចៈ ( សច្ចៈដែលតិរ្ថិយប្រកាន់ប្លែកៗ គ្នា ) បានលះបង់នូវការស្វែងរកជ្រះស្រឡះហើយ មានការត្រិះរិះមិនកករល្អក់ មានកាយសង្ខារស្ងប់រម្ងាប់ហើយ មានចិត្តផុតស្រឡះហើយមានប្រាជ្ញាដឹងថា ចិត្តផុតស្រឡះហើយ ។ ម្នាលភិក្ខុទាំងឡាយ អរិយាវាសៈ ១០ យ៉ាងនេះឯង ដែលពួកព្រះអរិយៈ បានអប់រំហើយក្តី កំពុងអប់រំក្តី នឹងអប់រំក្តី ។

# អដ្ឋកថា

## បឋមអរិយាវាសសូត្រ

[ ១៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមអរិយាវាសសូត្រទី ៩ ដូចតទៅនេះ បទថា **អរិយាវាសា** បានដល់ ឈ្មោះថា អរិយាវាស ក៏ព្រោះជាទីដែលព្រះអរិយៈទាំងឡាយនៅហើយ កំពុងនៅ និងនៅចប់ព្រហ្មចរិយៈហើយ ។ ពាក្យថា **យទរិយា** កាត់បទជា **យេ វាសេ អរិយា** ដូច្នេះ ។

**អដ្ឋកថា បឋមអរិយាវាសសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ទុតិយអរិយាវាសសូត្រទី ១០

[ ២០ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងនិគម ឈ្មោះកម្មាសធម្មៈ របស់ពួកជនអ្នកដែនកុរុ ជិតដែនកុរុ ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅពួកភិក្ខុមក ។បេ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អរិយាវាសៈនេះមាន ១០ យ៉ាង ដែលពួកព្រះអរិយៈបានអប់រំហើយក្តី កំពុងអប់រំក្តី នឹងអប់រំក្តី ។ អរិយាវាសៈ ១០ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់នូវអង្គ ៥ ប្រកបដោយអង្គ ៦ មានគ្រឿងរក្សាចិត្តតែមួយ មានធម៌ជាបង្អែក ៤ បាន

បន្ទាបង់នូវបច្ចេកសច្ចៈ បានលះបង់នូវការស្វែងរក ជ្រះស្រឡះហើយ មានការត្រិះរិះមិនកករល្អក់ មានកាយសង្ខារស្ងប់រម្ងាប់ហើយ មានចិត្តផុតស្រឡះហើយ មានប្រាជ្ញាដឹងថា ចិត្តផុតស្រឡះហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានលះបង់អង្គ ៥ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះកាមច្ឆន្ទៈ បានលះព្យាបាទ បានលះថីនមិទ្ធៈ បានលះឧទ្ធច្ចកុក្កុច្ចៈ បានលះវិចិកិច្ឆា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានលះអង្គ ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ ៦ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានឃើញរូបដោយភ្នែកហើយ មិនសោមនស្ស មិនទោមនស្ស ជាបុគ្គលមានចិត្តព្រងើយ មានស្មារតី ដឹងខ្លួនគ្រប់ឥរិយាបថទាំង ៤ បានឮសំឡេងដោយត្រចៀក ។បេ។ បានធុំក្លិនដោយច្រមុះ បានជញ្ជក់រសដោយអណ្តាត បានប៉ះផ្សព្វដោយកាយ បានដឹងធម្មារម្មណ៍ ដោយចិត្តហើយ មិនសោមនស្ស មិនទោមនស្ស ជាបុគ្គលមានចិត្តព្រងើយ មានស្មារតី ដឹងខ្លួនគ្រប់ឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ ៦ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានគ្រឿងរក្សាចិត្តតែមួយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ប្រកបដោយចិត្ត ដែលមានស្មារតីថែរក្សា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានគ្រឿងរក្សាចិត្តតែមួយ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានធម៌ជាបង្អែក ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាហើយ ទើបសេពនូវរបស់ដែលគួរ

សេព ពិចារណាហើយ ទើបអត់សង្កត់នូវហេតុដែលគួរអត់សង្កត់ ពិចារណាហើយ ទើបវៀរនូវហេតុដែលគួរវៀរ ពិចារណាហើយ ទើបបន្ទោបង់នូវហេតុដែលគួរបន្ទោបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានធម៌ជាបង្អែក ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានបន្ទោបង់នូវបច្ចេកសច្ចៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បច្ចេកសច្ចៈជាច្រើនណា របស់សមណៈ និងព្រាហ្មណ៍ជាច្រើន គឺការប្រកាន់ថា លោកទៀងដូច្នេះខ្លះ លោកមិនទៀងដូច្នេះខ្លះ លោកមានទីបំផុតដូច្នេះខ្លះ លោកមិនមានទីបំផុតដូច្នេះខ្លះ ជីវិតនោះ គឺសរីរៈនោះដូច្នេះខ្លះ ជីវិតដទៃសរីរៈដទៃដូច្នេះខ្លះ សត្វស្លាប់ទៅកើតទៀតដូច្នេះខ្លះ សត្វស្លាប់ទៅមិនកើតទៀតដូច្នេះខ្លះ សត្វស្លាប់ទៅកើតទៀតក៏មាន មិនកើតទៀតក៏មានដូច្នេះខ្លះ សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះខ្លះ ភិក្ខុក្នុងសាសនានេះ បានបន្ទោបង់ បោះបង់ លះបង់ ខ្ជាក់ចោល លែងចោល លះលែង លះស្រឡះនូវបច្ចេកសច្ចៈ ជាច្រើនទាំងអស់នោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានបន្ទោបង់នូវបច្ចេកសច្ចៈ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ ចុះភិក្ខុបានលះបង់នូវការស្វែងរក ជ្រះស្រឡះហើយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់ការស្វែងរកកាម លះបង់ការស្វែងរកភព មានការស្វែងរកនូវព្រហ្មចរិយៈ ស្ងប់រម្ងាប់ហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានលះបង់ការស្វែងរកជ្រះស្រឡះហើយ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមានសេចក្តីត្រិះរិះមិនកករល្អក់ តើដូចម្តេច ។ ម្នាល

ភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់សេចក្តីត្រិះរិះក្នុងកាម បានលះបង់សេចក្តីត្រិះរិះក្នុងការព្យាបាទ បានលះបង់សេចក្តីត្រិះរិះ ក្នុងការបៀតបៀន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសេចក្តីត្រិះរិះមិនកករល្អក់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានកាយសង្ខារស្ងប់រម្ងាប់ហើយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់សុខផង ព្រោះលះបង់ទុក្ខផង ព្រោះអស់ទៅនៃសោមនស្ស និងទោមនស្សក្នុងកាលមុន ក៏បានសម្រេចនូវចតុត្ថជ្ឈាន មិនមែនជាទុក្ខ មិនមែនជាសុខ មានតែសតិដ៏បរិសុទ្ធ កើតអំពីឧបេក្ខា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានកាយសង្ខារស្ងប់រម្ងាប់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តផុតស្រឡះហើយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានចិត្តផុតស្រឡះចាករាគៈ មានចិត្តផុតស្រឡះចាកទោសៈ មានចិត្តផុតស្រឡះចាកមោហៈ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តផុតស្រឡះហើយ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានប្រាជ្ញាដឹងថា ចិត្តផុតស្រឡះហើយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់ថា អាត្មាអញបានលះបង់រាគៈហើយ បានផ្តាច់ផ្តិលឫសគល់ហើយ ធ្វើមិនឲ្យមានទីកើត ដូចជាត្នោតកំបុតចុង ធ្វើមិនឲ្យមានបែបភាព ជាសភាពមិនមានការកើតឡើងតទៅទៀតជាធម្មតា ដឹងច្បាស់ថា អាត្មាអញបានលះបង់ទោសៈហើយ ។បេ។ អាត្មាអញ បានលះបង់មោហៈហើយ បានផ្តាច់ផ្តិលឫសគល់ហើយ ធ្វើមិនឲ្យមាន

ទីកើត ដូចជាត្នោតកំបុតចុង បានធ្វើមិនឲ្យមានបែបភាព ជាសភាពមិនមានការកើតឡើងតទៅទៀតជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានប្រាជ្ញាដឹងថាចិត្តផុតស្រឡះហើយ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកអរិយៈណាមួយ បានអាស្រ័យនៅក្នុងអរិយវាសៈ ក្នុងកាលដែលកន្លងហើយ ពួកអរិយៈទាំងអស់នោះ បានអាស្រ័យនៅក្នុងអរិយវាសៈទាំង ១០ យ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ ពួកអរិយៈណាមួយ នឹងអាស្រ័យនៅក្នុងអរិយវាសៈ ក្នុងកាលដែលមិនទាន់មកដល់ ពួកអរិយៈទាំងអស់នោះ នឹងអាស្រ័យនៅក្នុងអរិយវាសៈទាំង ១០ យ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ ពួកអរិយៈណាមួយកំពុងអាស្រ័យនៅក្នុងអរិយវាសៈ ក្នុងកាលឥឡូវនេះ ពួកអរិយៈទាំងអស់នោះ អាស្រ័យនៅក្នុងអរិយវាសៈទាំង ១០ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ អរិយវាសៈទាំង ១០ នេះឯង ដែលពួកអរិយៈបានអប់រំហើយក្តី កំពុងអប់រំក្តី នឹងអប់រំក្តី ។

## នាថករណវគ្គទី ២ ចប់

## ឧទ្ទាននៃនាថករណវគ្គនោះ គឺ

និយាយអំពីសេនាសនៈ ១ អំពីអង្គ ១ អំពីសំយោជនៈ ១
អំពីចេតោខីលៈ ១ អំពីអប្បមាទ ១ អំពីអាហុនេយ្យ ១ អំពី
នាថករណធម៌មានពីរលើក អំពីអរិយវាសៈមានពីរលើក ។

# អដ្ឋកថា

## ទុតិយអរិយាវាសសូត្រ

[ ២០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយអរិយាវាសសូត្រទី ១០ ដូចតទៅនេះ ព្រោះហេតុដែលភិក្ខុអ្នកកុរុរដ្ឋ មានបញ្ញាជ្រាលជ្រៅ ខ្វល់ខ្វាយក្នុងកាលដ៏សមគួរ ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់សូត្រដែលជ្រាលជ្រៅ នាំត្រៃលក្ខណ៍ ដែលល្អិតជ្រាលជ្រៅមកយ៉ាងនោះដូចគ្នា ដូចដែលត្រាស់មហានិទានសូត្រជាដើម ក្នុងគម្ពីរទីឃនិកាយជាដើមដល់ភិក្ខុទាំងនោះ ដូច្នោះ ។ បណ្ដាបទទាំងនោះ បទថា **បញ្ចង្គវិប្បហីនោ** សេចក្ដីថា ភិក្ខុដែលមិនប្រកបដោយអង្គ ៥ អស់អាសវៈហើយ មានព្រហ្មចរិយៈនៅចប់ហើយ កំពុងនៅនឹងនៅ ព្រោះដូច្នោះ ទើបភិក្ខុនេះ ត្រាស់ហៅថា **អរិយាវាស** ព្រោះមានធម៌ជាគ្រឿងនៅសម្រាប់ព្រះអរិយៈ ព្រោះជាបុគ្គលលះអង្គ ៥ បានហើយ ក្នុងបទទាំងពួង ក៏ន័យដូច្នេះ ។

បទថា **ឯវំ ខោ ភិក្ខវេ ភិក្ខុ ឆឡង្គសមន្នាគតោ ហោតិ** សេចក្ដីថា រមែងជាបុគ្គលប្រកបដោយឆឡង្គុបេក្ខា សួរថា អ្វីឈ្មោះថា ឆឡង្គុបេក្ខាធម៌ ឆ្លើយថា ធម៌ទាំងឡាយ មានញាណជាដើម កាលពោលថាញាណ រមែងបានក្នុងកិរិយាចិត្តដែលសម្បយុត្តដោយញាណ ៤ ដួង កាលពោលថា ធម៌ជាគ្រឿងនៅជាប់តគ្នា ក៏បានដល់មហាចិត្ត ៨ ដួង កាលពោលថា សេចក្ដីស្រឡាញ់ សេចក្ដីក្រោធមិនមាន ក៏បានដល់ចិត្ត ១០ ដួង សោមនស្សញ្ញាណក៏បានដោយអំណាចអាសេវនប្បច្ច័យ ។

បទថា **សតារក្ខេន ចេតសា** សេចក្តីថា សតិរបស់ព្រះខីណាស្រព រមែងឲ្យសម្រេចកិច្ច គឺរក្សាក្នុងទ្វារទាំង ៣ សព្វកាល ដោយហេតុនោះឯង ញាណទស្សនៈរបស់ព្រះខីណាស្រពនោះ ទោះដើរ ឈរ និទ្រា ភ្ញាក់ ទើបលោកហៅថា រមែងប្រាកដជាប់តគ្នា មានព្រមហើយ ។ បទថា **បុថុសមណព្រាហ្មណានំ** បានដល់ របស់សមណព្រាហ្មណ៍ដ៏ច្រើន ។ ក្នុងពាក្យថា **បុថុសមណព្រាហ្មណានំ** នេះ ដែលឈ្មោះថា សមណៈ បានដល់ បុគ្គលកាន់យកបព្វជ្ជា ដែលឈ្មោះថា ព្រាហ្មណ៍ បានដល់ បុគ្គលពោលថា អ្នកដ៏ចម្រើន ។

បទថា **បុថុប្បច្ចេកសច្ចានិ** បានដល់ សច្ចៈមួយផ្នែក ឈ្មោះថា ច្រើន អធិប្បាយថា សច្ចៈជាច្រើនដែលប្រកាន់ជាផ្នែកៗ យ៉ាងនេះថា ការយល់ឃើញនេះប៉ុណ្ណោះជាសច្ចៈ ។ បទថា **នុណ្ណានិ** ប្រែថា ត្រូវនាំចេញហើយ ។ បទថា **បនុណ្ណានិ** ប្រែថា ត្រូវនាំចេញដោយល្អហើយ ។ បទថា **ចត្តានិ** ប្រែថា ដែលគេលះបង់ហើយ ។ បទថា **វន្តានិ** ប្រែថា ខ្ជាក់ចេញហើយ ។ បទថា **មុត្តានិ** បានដល់ កាត់គ្រឿងចងបានហើយ ។ បទថា **បហីនានិ** ប្រែថា ដែលលះចេញហើយ ។ បទថា **បដិនិស្សដ្ឋានិ** បានដល់ លះបង់ដោយទស្សនៈទាំងនោះ មិនឡើងកាន់ចិត្តទៀត ។ បទទាំងនោះ បទទាំងអស់ជាវេវចនៈនៃភាពដែលបុគ្គលលះបង់ការប្រកាន់ ដែលខ្លួនប្រកាន់បានហើយ ។

បទថា **សមវយសដ្ឋេសនោ** សេចក្តីថា **អវយា** ប្រែថា មិនធូរថយ

**សទ្ធា** ប្រែថា លះបានហើយ ។ ការស្វែងរកដែលមិនធូរថយ ដែលលះបានហើយរបស់ភិក្ខុនោះមានហេតុនោះ ភិក្ខុនោះ ឈ្មោះថា មានការស្វែងរកមិនធូរថយ ដែលលះបានហើយដោយល្អ អធិប្បាយថា អ្នកស្វែងសច្ចៈដែលខ្ទប់លះហើយបានដោយល្អ ។ បទថា **រាគា ចិត្តំ វិមុត្តំ** ចិត្តផុតចាករាគៈជាដើម ត្រាស់មគ្គធ្វើកិច្ចដែលសម្រេចដោយបទថា **រាគោ មេ បហីនោ** រាគៈអាត្មាអញលះបានហើយជាដើម ត្រាស់ផលដោយបច្ចវេក្ខណញ្ញាណ ។ ពាក្យដ៏សេសក្នុងទីគ្រប់អន្ទើ ងាយយល់ទាំងអស់ហើយ ៕

**អដ្ឋកថា ទុតិយអរិយវាសសូត្រទី ១០ ចប់**

**នាថករណវគ្គទី ២ ចប់**

# សុត្តន្តបិដក

# មហាវគ្គទី ៣

## សីហសូត្រទី ១

[ ២១ ] ម្នាលភិក្ខុទាំងឡាយ ក្នុងសាយណ្ហសម័យ សត្វសីហៈជាស្តេចម្រឹគ ចេញពីលំនៅ លុះចេញពីលំនៅហើយ ក៏មិតពត់ខ្លួន លុះមិតពត់ខ្លួនរួចហើយ ក៏ក្រឡេកមៀងមើលទិសទាំង ៤ ជុំវិញ លុះក្រឡេកមៀងមើលទិសទាំង ៤ ជុំវិញហើយ ក៏បន្លឺសីហនាទ ៣ ដង លុះបន្លឺសីហនាទ ៣ ដងហើយ ទើបចេញទៅរកចំណី ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថា សត្វសីហៈគិតថា អាត្មាអញកុំធ្វើពួកសត្វតូចៗ ដែលដើរទៅរកស៊ី ក្នុងទីក្រហេងក្រហូងឲ្យស្លាប់ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថាសីហៈនេះ ជាឈ្មោះរបស់ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតសម្តែងធម៌ដល់បរិស័ទដោយហេតុណា នេះជាសីហនាទ របស់ព្រះតថាគតនោះ ។ ម្នាលភិក្ខុតថាគតពល របស់ព្រះតថាគតនេះមាន ១០ ប្រការ គឺព្រះតថាគតប្រកបដោយពលទាំងឡាយហើយ ទើបប្តេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ ញ៉ាំងព្រហ្មចក្ក ( ចក្កដ៏ប្រសើរ ) ឲ្យប្រព្រឹត្តទៅ ។ តថាគតពល ១០ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតក្នុងលោកនេះ រមែងជ្រាបច្បាស់នូវហេតុតាមហេតុផង ជ្រាបច្បាស់នូវអំពើមិនមែនជាហេតុ តាមអំពើមិនមែនជាហេតុផង ដោយសេចក្តីជាក់លាក់ ។ ម្នាលភិក្ខុទាំងឡាយ

ត្រង់ដែលព្រះតថាគត ជ្រាបច្បាស់នូវហេតុតាមហេតុផង ជ្រាបច្បាស់នូវអំពើមិនមែនជាហេតុ តាមអំពើមិនមែនជាហេតុផង ដោយសេចក្តីជាក់លាក់ ម្នាលភិក្ខុទាំងឡាយ នេះជាតថាគតពលរបស់ព្រះតថាគត ព្រោះព្រះតថាគតអាស្រ័យនឹងពលហើយ ប្តេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្កឲ្យប្រព្រឹត្តទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគតជ្រាបច្បាស់នូវវិបាកនៃកុសលកម្ម និងអកុសលកម្ម ដែលសត្វបានធ្វើហើយ ទាំងអតីត អនាគត និងបច្ចុប្បន្ន តាមឋាក់ តាមហេតុ ដោយសេចក្តីជាក់លាក់ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ដែលព្រះតថាគត ជ្រាបច្បាស់នូវវិបាកនៃកុសលកម្ម និងអកុសលកម្ម ដែលសត្វបានធ្វើហើយ ទាំងអតីត អនាគត និងបច្ចុប្បន្ន តាមឋាក់ តាមហេតុ ដោយសេចក្តីជាក់លាក់ ម្នាលភិក្ខុទាំង-ឡាយ នេះជាតថាគតពលរបស់ព្រះតថាគត ព្រោះព្រះតថាគតអាស្រ័យនឹងពលហើយ ប្តេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្កឲ្យប្រព្រឹត្តទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគតជ្រាបច្បាស់នូវផ្លូវដែលទៅកាន់ទីទាំងពួង ដោយសេចក្តីជាក់លាក់ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ដែលព្រះតថាគតជ្រាបច្បាស់នូវផ្លូវ ដែលទៅកាន់ទីទាំងពួង ដោយសេចក្តីជាក់លាក់ ម្នាលភិក្ខុទាំងឡាយ នេះជាតថាគតពល របស់ព្រះតថាគត ព្រោះព្រះតថាគតអាស្រ័យនឹងពលហើយ ប្តេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្កឲ្យប្រព្រឹត្តទៅ ។ ម្នាលភិក្ខុទាំង-

ឡាយ មួយទៀត ព្រះតថាគតជ្រាបច្បាស់នូវលោក ដែលមានធាតុច្រើន យ៉ាង មានធាតុផ្សេងៗ គ្នា ដោយសេចក្តីជាក់លាក់ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ដែលព្រះតថាគតជ្រាបច្បាស់ នូវលោកដែលមានធាតុច្រើនយ៉ាង មាន ធាតុផ្សេងៗ គ្នា ដោយសេចក្តីជាក់លាក់ ម្នាលភិក្ខុទាំងឡាយ នេះជាតថា-គតពលរបស់ព្រះតថាគត ព្រោះព្រះតថាគតអាស្រ័យនឹងពលហើយ ប្តេជ្ញា នូវហេតុដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្កឲ្យប្រព្រឹត្តទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគតជ្រាបច្បាស់នូវអធ្យាស្រ័យផ្សេងៗ គ្នា របស់ពួកសត្វដោយសេចក្តីជាក់លាក់ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ដែល ព្រះតថាគតជ្រាបច្បាស់នូវអធ្យាស្រ័យផ្សេងៗ គ្នា របស់ពួកសត្វ ដោយ សេចក្តីជាក់លាក់ ម្នាលភិក្ខុទាំងឡាយ នេះជាតថាគតពលរបស់ព្រះតថាគត ព្រោះព្រះតថាគតអាស្រ័យនឹងពលហើយ ប្តេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហ-នាទក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្កឲ្យប្រព្រឹត្តទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគតជ្រាបច្បាស់នូវឥន្ទ្រិយក្លៀវក្លា និងទន់របស់ពួកសត្វដទៃ ពួកបុគ្គលដទៃដោយសេចក្តីជាក់លាក់ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ដែលព្រះ តថាគតជ្រាបច្បាស់នូវឥន្ទ្រិយក្លៀវក្លា និងទន់របស់ពួកសត្វដទៃ ពួកបុគ្គល ដទៃ ដោយសេចក្តីជាក់លាក់ ម្នាលភិក្ខុទាំងឡាយ នេះជាតថាគតពលរបស់ ព្រះតថាគត ព្រោះព្រះតថាគតអាស្រ័យនឹងពលហើយ ប្តេជ្ញានូវហេតុដ៏ ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្កឲ្យប្រព្រឹត្តទៅ ។ ម្នាល

ភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគតជ្រាបច្បាស់នូវសេចក្ដីសៅហ្មង ផូរផង់ និងការចេញចាកឈាន វិមោក្ខ សមាធិ និងសមាបត្តិ ដោយសេចក្ដីជាក់លាក់ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ដែលព្រះតថាគត ជ្រាបច្បាស់នូវសេចក្ដីសៅហ្មង ផូរផង់ និងការចេញចាកឈាន វិមោក្ខ សមាធិ និងសមាបត្តិ ដោយសេចក្ដីជាក់លាក់ ម្នាលភិក្ខុទាំងឡាយ នេះជាតថាគតពលរបស់ព្រះតថាគត ព្រោះព្រះតថាគតអាស្រ័យនឹងពលហើយ ប្ដេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្កឲ្យប្រព្រឹត្តទៅ ។ ម្នាលភិក្ខុទាំង-ឡាយ មួយទៀត ព្រះតថាគតរឭកឃើញជាតិ ដែលបាននៅអាស្រ័យក្នុងកាលមុនជាអនេកជាតិ គឺ ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១០០ ជាតិខ្លះ ១០០០ ជាតិខ្លះ ១០០០០ ជាតិខ្លះ រឭកឃើញបានច្រើនសំវដ្ដកប្បខ្លះ ច្រើនវិវដ្ដកប្បខ្លះ ច្រើនសំវដ្ដវិវដ្ដកប្បខ្លះថា ក្នុងភពឯណោះ អាត្មាអញមានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ អាត្មាអញនោះ ច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯណោះ ដែលទៅកើតក្នុងភពនោះទៀត អាត្មាអញមានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះអាត្មាអញនោះច្យុតចាក

អត្តភាពនោះហើយ ទើបមកកើតក្នុងភពនេះ ។ ព្រះតថាគតរឭកឃើញជាតិដែលបាននៅអាស្រ័យក្នុងកាលមុន ជាអនេកជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ដែលព្រះតថាគតរឭកឃើញជាតិដែលបាននៅអាស្រ័យក្នុងកាលមុន ជាអនេកជាតិ គឺ ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ រឭកឃើញជាតិដែលបាននៅអាស្រ័យក្នុងកាលមុន ជាអនេក-ជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ នេះជាតថាគតពលរបស់ព្រះតថាគត ព្រោះព្រះតថាគតអាស្រ័យនឹងពលហើយ ប្តេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ ញ៉ាំងព្រហ្មចក្កឲ្យប្រព្រឹត្តទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគតមានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា ឃើញនូវពួកសត្វដែលកំពុងច្យុត កំពុងកើត ជាសត្វថោកទាបខ្លះ ខ្ពង់ខ្ពស់ខ្លះ មានសម្បុរល្អខ្លះ មានសម្បុរអាក្រក់ខ្លះ មានគតិល្អខ្លះ មានគតិអាក្រក់ខ្លះ ជ្រាបច្បាស់នូវពួកសត្វដែលអន្ទោលទៅតាមកម្មថា អើហ្ន៎ សត្វអម្បាលនេះ ដែលជាអ្នកប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត តិះដៀលពួកអរិយៈ ជាមិច្ឆាទិដ្ឋិ ប្រកាន់កម្មជាមិច្ឆាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក អើហ្ន៎ ចំណែកខាងសត្វទាំងនេះ ដែលជាអ្នកប្រកបដោយកាយសុចរិត ប្រកបដោយវចី-សុចរិត ប្រកបដោយមនោសុចរិត មិនតិះដៀលពួកអរិយៈ ជាសម្មាទិដ្ឋិ

ប្រកាន់កម្មជាសម្មាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ ព្រះតថាគតមានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា ឃើញនូវពួកសត្វដែលច្យុត ដែលកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ជ្រាបច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្មដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ដែលព្រះតថាគតមានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា ។បេ។ ជ្រាបច្បាស់នូវពួកសត្វដែលអន្ទោលទៅតាមកម្ម ម្នាលភិក្ខុទាំងឡាយ នេះជាតថាគតពលរបស់ព្រះតថាគត ព្រោះព្រះតថាគតអាស្រ័យនឹងពលហើយ ប្ដេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ ញ៉ាំងព្រហ្មចក្កឲ្យប្រព្រឹត្តទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ព្រះតថាគតបានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយដោយប្រាជ្ញាដ៏ប្រសើរ ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ដែលព្រះតថាគតបានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយដោយប្រាជ្ញាដ៏ប្រសើរ ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ម្នាលភិក្ខុទាំងឡាយ នេះជាតថាគតពលរបស់ព្រះតថាគត ព្រោះព្រះតថាគតអាស្រ័យនឹងពលហើយ ប្ដេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ ញ៉ាំងព្រហ្មចក្កឲ្យប្រព្រឹត្តទៅ ។ ម្នាលភិក្ខុទាំងឡាយ នេះជា

តថាគតពល ១០ ប្រការរបស់ព្រះតថាគត ព្រោះព្រះតថាគតប្រកបដោយពលទាំងឡាយហើយ ប្តេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ ញ៉ាំងព្រហ្មចក្កឲ្យប្រព្រឹត្តទៅ ។

# មហាវគ្គទី ៣

## អដ្ឋកថា

### សីហសូត្រ

[ ២១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសីហសូត្រទី ១ នៃមហាវគ្គទី ៣ ដូចតទៅនេះ បទថា **វិសមគតេ** បានដល់ ទៅក្នុងទីរកចំណីដែលមិនរាបស្មើ ។ បទថា **សង្ឃាតំ អាបាទេសិ** ប្រែថា ឲ្យដល់ឃាតៈ គឺការត្រូវសម្លាប់ ។ ពិតហើយ រាជសីហ៍នោះ មានការអាណិតអាសូរក្នុងពួកសត្វតូចៗ ព្រោះខ្លួនមានអំណាចច្រើន ព្រោះដូច្នោះ ទើបគិតថា ពួកសត្វទាំងឡាយណា អាចតាំងនៅក្នុងឋានៈជាសត្រូវ ចាំបាច់ត្រូវសម្លាប់សត្វទាំងនោះ ពួកសត្វណាខ្សោយកម្លាំង បំណងនឹងគេច ពួកសត្វទាំងនោះ ចូរគេចទៅចុះ ទើបបន្លឺសីហនាទហើយចេញទៅរកចំណី ។ បទថា **តថាគតស្សេតំ អធិវចនំ** សេចក្តីថា ព្រះតថាគត ឈ្មោះថា **សីហ** ព្រោះទ្រង់អត់ធន់ ១ ព្រោះទ្រង់សម្លាប់ ១ ទើប

ទ្រង់អត់ធន់ក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍គ្រប់យ៉ាង និងទ្រង់សម្លាប់ដោយការញាំញីវាទៈរបស់ពួកជន ដែលមានវាទៈជាសត្រូវគ្រប់គ្នា ។ បទថា **ឥទមស្ស ហោតិ សីហនាទស្មឹ** បានដល់ នេះជាសីហនាទ គឺការបន្លឺដែលមិនមានការខ្លាចរបស់ព្រះតថាគតនោះ ។

បទថា **តថាគតស្ស តថាគតពលានិ** បានដល់ ជាកម្លាំងរបស់ព្រះតថាគតប៉ុណ្ណោះ ។ មិនទូទៅដល់អ្នកដទៃ ។ អធិប្បាយថា ពលរបស់ព្រះពុទ្ធទាំងឡាយ ក្នុងកាលមុន មកហើយដោយសម្បត្តិ គឺបុណ្យ និងយសយ៉ាងណា សូម្បីព្រះតថាគតក៏យ៉ាងនោះ ដូច្នេះ ។ ក្នុងពាក្យថា កម្លាំងនៃព្រះតថាគតនេះ កម្លាំងមាន ២ យ៉ាង គឺកម្លាំងព្រះវរកាយ ១ កម្លាំងព្រះញាណ ១ ក្នុងកម្លាំង ២ យ៉ាងនោះ កម្លាំងព្រះវរកាយ គប្បីជ្រាបដោយការប្រៀបធៀបនឹងត្រកូលដំរី ។ បុរាណាចារ្យទាំងឡាយពោលថា

**កាឡាវកញ្ច គង្គេយ្យំ បណ្ឌរំ តម្ពបិង្គលំ**
**គន្ធមង្គលហេមញ្ច ឧបោសថច្ឆទ្ទន្តិមេ ។**

ត្រកូលដំរីទាំងនេះ គឺកាឡាវកៈ ១ គង្គេយ្យៈ ១
បណ្ឌរៈ ១ តម្ពៈ ១ បិង្គលៈ ១ គន្ធៈ ១ មង្គលៈ ១
ហេមៈ ១ ឧបោសថៈ ១ ឆទ្ទន្តៈ ១ ។

ដំរី ១០ ត្រកូលនេះ បណ្តាត្រកូលដំរីទាំងនោះ ត្រកូលដំរីកាឡាវកៈគប្បីឃើញថា ជាត្រកូលដំរីធម្មតា កម្លាំងកាយរបស់បុរស ១០ នាក់ ស្មើ

នឹងកម្លាំងដំរីត្រកូលកាឡាវក: ១ កម្លាំងកាយរបស់ត្រកូលដំរីកាឡាវក: ១០ ស្មើនឹងកម្លាំងកាយរបស់ត្រកូលដំរីគង្គេយ្យ: ១ កម្លាំងកាយរបស់ដំរីត្រកូលគង្គេយ្យ: ១០ ស្មើនឹងកម្លាំងកាយរបស់ដំរីត្រកូលបណ្ឌរ: ១ កម្លាំងកាយរបស់ដំរីត្រកូលបណ្ឌរ: ១០ ស្មើគ្នានឹងកម្លាំងកាយដំរីត្រកូលតម្ព: ១ កម្លាំងកាយដំរីត្រកូលតម្ព: ១០ ស្មើនឹងកម្លាំងកាយរបស់ដំរីត្រកូលបិង្គល: ១ កម្លាំងកាយរបស់ដំរីត្រកូលបិង្គល: ១០ ស្មើនឹងកម្លាំងកាយរបស់ដំរីត្រកូលគន្ធ: ១ កម្លាំងកាយរបស់ដំរីត្រកូលគន្ធ: ១០ ស្មើគ្នានឹងកម្លាំងកាយរបស់ដំរីត្រកូលមង្គល: ១ កម្លាំងកាយរបស់ដំរីត្រកូលមង្គល: ១០ ស្មើនឹងកម្លាំងកាយរបស់ដំរីត្រកូលហេម: ១ កម្លាំងកាយរបស់ដំរីត្រកូលហេម: ១០ ស្មើនឹងកម្លាំងកាយរបស់ដំរីត្រកូលឧបោសថ ១ កម្លាំងកាយរបស់ដំរីត្រកូលឧបោសថ ១០ ស្មើគ្នានឹងកម្លាំងរបស់ដំរីត្រកូលឆទ្ទន្ត ១ កម្លាំងកាយរបស់ដំរីត្រកូលឆទ្ទន្ត ១០ ស្មើនឹងកម្លាំងវរកាយរបស់ព្រះតថាគតមួយព្រះអង្គ កម្លាំងព្រះវរកាយរបស់ព្រះតថាគតនេះ ហៅថា នារាយណពលដូច្នេះក៏បាន ។ កម្លាំងព្រះវរកាយរបស់ព្រះតថាគតនេះ កាលប្រៀបនឹងដំរីធម្មតា ស្មើនឹងកម្លាំង ១០០០ កោដិ ស្មើគ្នានឹងកម្លាំងបុរស ១០០០០ កោដិ នេះជាកម្លាំងព្រះវរកាយរបស់ព្រះតថាគត ។

គប្បីជ្រាបកម្លាំងព្រះញាណដែលមកក្នុងបាលីមុន ព្រះទសពលញ្ញាណមកក្នុងគម្ពីរមជ្ឈិមនិកាយ ចតុវេសារជ្ជញ្ញាណ អកម្បនញ្ញាណក្នុងបរិស័ទ ៨

ចតុយោនិបរិច្ឆេទញ្ញាណ បញ្ចគតិបរិច្ឆេទញ្ញាណ ញាណ ៧៣ ញាណ ៧៧ មកក្នុងគម្ពីរសំយុត្តនិកាយ រួមញាណដូចពោលមកនេះ ញាណច្រើនពាន់យ៉ាងដទៃទៀត ។ នេះឈ្មោះថា កម្លាំងព្រះញាណ ។ ក្នុងសូត្រនេះ លោកក៏បំណងយកកម្លាំងព្រះញាណប៉ុណ្ណោះ ។ ពិតហើយ ព្រះញាណលោកហៅថា ពល ព្រោះអត្ថថា មិនញាប់ញ័រ និងព្រោះអត្ថថា ឧបត្ថម្ភ ។

បទថា **អាសភណ្ឋានំ** បានដល់ ឋានៈដ៏ប្រសើរបំផុត គឺឋានៈដ៏ឧត្តម ។ ម្យ៉ាងទៀត ព្រះពុទ្ធទាំងឡាយក្នុងកាលមុន ឈ្មោះថា **អាសភ** អធិប្បាយថា ឋានៈរបស់អាសភៈព្រះពុទ្ធទាំងនោះក្នុងកាលមុន ។ ម្យ៉ាងទៀត គោនាំមុខរបស់គោ ១០០ ឈ្មោះថា **ឧសភ** គោនាំមុខរបស់គោ ១០០០ ឈ្មោះថា **អាសភ** ឬ មេហ្វូងរបស់គោ ១០០ ក្រោល ឈ្មោះថា **ឧសភ** មេហ្វូងរបស់គោ ១០០០ ក្រោល ឈ្មោះថា **អាសភ** គោដ៏ប្រសើរបំផុតនៃគោទាំងអស់ អត់ធន់អន្តរាយបានគ្រប់យ៉ាង ពណ៌ស អាចអូសរបស់ធ្ងន់បានច្រើនសូម្បីសំឡេងរន្ទះ ១ រយដង ក៏មិនតក់ស្លុត ឈ្មោះថា **និសភ** លោកបំណងយកគោនិសភនោះ ថាជាគោឧសភក្នុងសូត្រនេះ ។ ពាក្យនេះជាពាក្យបរិយាយនៃពាក្យថា **ឧសភ** នោះ ។ **ឧសភស្ស**នេះឯង បានដល់ **អាសភ**។ បទថា **ឋានំ** បានដល់ ទីដែលគោអាសភៈយកជើងទាំង ៤ ជាន់ផែនដីក្នុងទីនេះ ដូចអាសភៈ ព្រោះហេតុនោះ ទើបឈ្មោះថា **អាសភ** គឺឈរយ៉ាងអង់អាច ព្រោះប្រៀបដូចគោឧសភៈ ដែលរាប់បានថា គោនិសភៈ

ប្រកបដោយកម្លាំងរបស់គោឧសភៈ ឈរយកជើងទាំង ៤ ជាន់ក្នុងទីឈរដោយមិនកម្រើក យ៉ាងណា សូម្បីព្រះតថាគត ទ្រង់ប្រកបដោយកម្លាំងរបស់ព្រះតថាគត ១០ ប្រការ ទ្រង់ជាន់ផែនដី គឺបរិស័ទ ៨ ដែលសត្រូវ ឬបច្ចាមិត្រណាមួយ ធ្វើឲ្យញាប់ញ័រមិនបាន ទ្រង់ឈរក្នុងទីដ៏មាំទាំ ដូច្នោះ កាលទ្រង់ឈរយ៉ាងនោះ ក៏ទ្រង់ប្ដេជ្ញាចូលដល់ មិនលះបង់ឋានៈដ៏ឧត្ដម ដែលមានក្នុងព្រះអង្គ ដោយហេតុនោះ ទើបត្រាស់ថា **អាសភណ្ឌានំ បដិជានាតិ** ប្ដេជ្ញាឋានៈដ៏ឧត្ដម ដូច្នេះ ។

បទថា **បរិសាសុ** បានដល់ ក្នុងបរិស័ទ ៨ គឺខត្តិយបរិស័ទ ១ ព្រាហ្មណបរិស័ទ ១ គហបតិបរិស័ទ ១ សមណបរិស័ទ ១ ចាតុម្មហារាជិកបរិស័ទ ១ តាវត្តិង្សបរិស័ទ ១ មារបរិស័ទ ១ ព្រហ្មបរិស័ទ ១ ។ បទថា **សីហនាទំ នទតិ** ប្រែថា បន្លឺ ការបន្លឺដ៏ប្រសើរបំផុត ការបន្លឺរបស់បុគ្គលដែលមិនមានការតក់ស្លុត ឬបន្លឺដូចការបន្លឺរបស់រាជសីហ៍ ។ ក្នុងសេចក្ដីនោះ មានឧបមាដូច្នេះ រាជសីហ៍ ប្រកបដោយកម្លាំងរបស់រាជសីហ៍ ក្លៀវក្លាក្នុងទីគ្រប់អន្លើ ប្រាសចាកការព្រឺរោមព្រឺស្បែក រមែងបន្លឺសីហនាទ យ៉ាងណា សូម្បីរាជសីហ៍ គឺព្រះតថាគត ទ្រង់ប្រកបដោយកម្លាំងរបស់ព្រះតថាគត ទ្រង់ក្លៀវក្លាក្នុងបរិស័ទ ៨ ប្រាសចាកការព្រឺរោមព្រឺស្បែក បន្លឺសីហនាទ ដែលដល់ព្រមដោយលីលានៃទេសនាច្រើនវិធី ដោយន័យថា ដូច្នេះសក្កាយជាដើមក៏ដូច្នោះ ដោយហេតុនោះ ទើបត្រាស់ថា **បរិសាសុ សីហនាទំ**

**ឋនតិ** បន្លឺសីហនាទក្នុងបរិស័ទទាំងឡាយ ដូច្នេះ ។

ក្នុងពាក្យថា **ព្រហ្មចក្កំ បវត្តេតិ** នេះ ពាក្យថា **ព្រហ្មំ** ប្រែថា ប្រសើរ ឧត្តុង្គឧត្តម វិសេស ។ ពាក្យថា **ចក្កំ** បានដល់ ធម្មចក្ក ធម្មចក្កនេះមាន ២ យ៉ាង គឺបដិវេធញ្ញាណ ១ ទេសនាញាណ ១ ។ ក្នុង ២ យ៉ាងនោះ ធម្មចក្កដែលព្រះបញ្ញាអប់រំ នាំអរិយផលមកឲ្យព្រះអង្គ ឈ្មោះថា **បដិវេធញ្ញាណ** ធម្មចក្កដែលព្រះករុណាអប់រំ នាំអរិយផលមកឲ្យសាវកទាំងឡាយ ឈ្មោះថា **ទេសនាញាណ** ក្នុងញាណទាំង ២ នោះ បដិវេធញ្ញាណ មាន ២ គឺដែលកំពុងកើត ដែលកើតហើយ ពិតហើយ បដិវេធញ្ញាណនោះ ឈ្មោះថា កំពុងកើត តាំងអំពីទ្រង់យាងចេញសាងព្រះផ្នួស រហូតដល់អរហត្តមគ្គ ឈ្មោះថា កើតហើយក្នុងខណៈនៃផលចិត្ត ឬថា ឈ្មោះថា កំពុងកើត តាំងអំពីតុសិតពិភព រហូតដល់អរហត្តមគ្គ ក្នុងពោធិបល្ល័ង្ក ឈ្មោះថា កើតហើយក្នុងខណៈនៃផលចិត្ត ឬឈ្មោះថា កំពុងកើត ចាប់តាំងអំពីការប្រាថ្នាទៀបព្រះបាទនៃព្រះពុទ្ធព្រះនាមទីបង្ករ រហូតដល់សម្រេចអរហត្តមគ្គ ឈ្មោះថា កើតហើយ ក្នុងខណៈនៃផលចិត្ត ។ ឯទេសនាញាណក៏មាន ២ គឺកំពុងប្រព្រឹត្តទៅ ដែលប្រព្រឹត្តទៅហើយ ។ ពិតហើយ ទេសនាញាណនោះ ឈ្មោះថា កំពុងប្រព្រឹត្តទៅ រហូតដល់សោតាបត្តិមគ្គ របស់ព្រះអញ្ញាកោណ្ឌញ្ញៈ ឈ្មោះថា ប្រព្រឹត្តទៅហើយ ក្នុងខណៈនៃផលចិត្ត គឺសោតាបត្តិផល ។ ក្នុងញាណទាំង ២ នោះ បដិវេធញ្ញាណជាលោកុត្តរ ទេសនាញាណ

ដែលប្រព្រឹត្តទៅហើយ ជាលោកិយ សូម្បីញាណទាំងនោះ មិនទូទៅដល់សាវកដទៃៗ ឡើយ ជាញាណដែលកើតក្នុងព្រះអង្គនៃព្រះពុទ្ធទាំងឡាយតែប៉ុណ្ណោះ ។

ឥឡូវនេះ កាលទ្រង់សម្តែងដោយពិស្តារដល់ព្រះពល ដែលព្រះតថាគតទ្រង់អប់រំហើយ ទ្រង់ប្តេជ្ញាឋានៈដ៏ឧត្តម ទើបត្រាស់ថា **កតមានិ ទស ឥធ ភិក្ខវេ តថាគតោ ឋានញ្ច ឋានតោ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **ឋានញ្ច ឋានតោ** បានដល់ ហេតុដោយ ភាពជាហេតុ ។ ពិតហើយ ព្រោះហេតុដែលផលតាំងនៅ កើត និងប្រព្រឹត្តទៅក្នុងហេតុនោះ ព្រោះប្រព្រឹត្តទៅ ទាក់ទងដោយហេតុនោះ ដូច្នោះ ទើបហេតុលោកហៅថា ឋានៈ ។ កាលព្រះមានព្រះភាគ ទ្រង់ជ្រាបហេតុនោះៗ ថា ឋានៈ ព្រោះធម៌ដែលជាហេតុ ជាបច្ច័យនៃធម៌កើតឡើង ទ្រង់ជ្រាបហេតុនោះៗ ថា អឋានៈ ព្រោះធម៌ដែលមិនជាហេតុ មិនជាបច្ច័យនៃធម៌កើតឡើង ឈ្មោះថា ទ្រង់ជ្រាបឋានៈជាឋានៈ អឋានៈជាអឋានៈ តាមសេចក្តីពិត ។ តែក្នុងអភិធម្មពាក្យនេះ លោកបានពោលពិស្តារហើយដោយន័យជាដើមថា បណ្តាញាណទាំងនោះ ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវហេតុថាជាហេតុផង នូវអំពើមិនមែនហេតុ ថាជាអំពើមិនមែនហេតុផង តើដូចម្តេច ដូច្នេះ ។ បទថា **យម្បិ** ប្រែថា ដោយញាណណា ។ បទថា **ឥទម្បិ ភិក្ខវេ តថាគតស្ស** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ឋានាឋានញ្ញាណនេះ ឈ្មោះថា តថាគត-

ពលរបស់តថាគត ។ គប្បីជ្រាបការប្រែកបសេចក្តីក្នុងបទទាំងពួង ដោយប្រការយ៉ាងនេះ ។

បទថា **កម្មសមាទានានំ** បានដល់ របស់កុសលកម្ម និងអកុសល-កម្ម ដែលបុគ្គលប្រកាន់មាំធ្វើហើយ ម្យ៉ាងទៀត កម្មនោះឯង ឈ្មោះថា កម្មសមាទាន ។ បទថា **ឋានសោ ហេតុសោ** ប្រែថា ដោយភាពជាបច្ច័យ និងដោយភាពជាហេតុ ។ ក្នុងកម្មសមាទាននោះ កថាពោលដោយញាណនេះដោយពិស្តារថា កម្មជាហេតុនៃវិបាក ព្រោះគតិ ឧបធិ កាល និងបយោគ មកហើយក្នុងអភិធម្ម ដោយន័យជាដើមថា ព្រះតថាគតក្នុងលោកនេះ ទ្រង់ជ្រាបច្បាស់ថា កម្មសមាទានដ៏លាមកពួកខ្លះ មានគតិសម្បត្តិរារាំងមិនឲ្យផលក៏មាន ។

បទថា **សព្វត្ថគាមិនឹ** បានដល់ ដែលឲ្យដល់នូវគតិទាំងពួង និងទីមិនឲ្យដល់គតិ ។ បទថា **បដិបទំ** បានដល់ មគ្គ ។ បទថា **យថាភូតំ បជានាតិ** សេចក្តីថា កាលមនុស្សជាច្រើនសម្លាប់សត្វមួយប៉ុណ្ណោះ បុគ្គលនោះរមែងដឹងច្បាស់នូវសភាពនៃកិច្ចបដិបត្តិទាំងឡាយ ពោល គឺកុសល-ចេតនា និងអកុសលចេតនាក្នុងវត្ថុតែមួយជាមួយគ្នា ដោយមិនខុស តាមន័យនេះថា បុគ្គលនេះ នឹងមានចេតនាទៅនរក បុគ្គលនេះ នឹងមានចេតនាទៅកំណើតតិរច្ឆាន ។ ម្យ៉ាងទៀត កថាពោលដោយញាណនេះ ដោយពិស្តារមកហើយក្នុងអភិធម្មដូចគ្នា ដោយន័យជាដើមថា បណ្តាញាណទាំងនោះ ព្រះ

តថាគត មានការជ្រាបច្បាស់តាមពិត នូវបដិបទាជាដំណើរទៅក្នុងទីទាំងពួង តើដូចម្តេច ។ ព្រះតថាគតក្នុងលោកនេះ ទ្រង់ជ្រាបច្បាស់ថា នេះផ្លូវ នេះសេចក្តីប្រតិបត្តិ ជាដំណើរទៅកាន់នរក ដូច្នេះ ។ បទថា **អនេកធាតុំ** បានដល់ ធាតុដែលច្រើន ដោយចក្ខុធាតុជាដើម ឬកាមធាតុជាដើម ។ បទថា **នានាធាតុំ** បានដល់ ធាតុ មានប្រការផ្សេងៗ ព្រោះកំណត់ការផ្សេងគ្នានៃធាតុទាំងនោះ ។ បទថា **លោកំ** បានដល់ ខន្ធលោក អាយតនៈលោក និងធាតុលោក ។ បទថា **យថាភូតំ បជានាតិ** បានដល់ ទ្រង់ចាក់ធ្លុះសភាវៈរបស់ធាតុទាំងនោះដោយមិនខុស ។ ញាណនេះ លោកពោលពិស្តារហើយក្នុងអភិធម្ម ដោយន័យជាដើមថា បណ្តាញាណទាំងនោះ ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវលោកដែលមានធាតុច្រើន មានធាតុផ្សេងៗ គ្នា តើដូចម្តេច ។ ព្រះតថាគតក្នុងលោកនេះ ទ្រង់ជ្រាបច្បាស់នូវសេចក្តីផ្សេងៗគ្នានៃខន្ធ ... ដូច្នេះ ។

បទថា **នានាធិមុត្តិកតំ** បានដល់ ភាពដែលសត្វទាំងឡាយមានអធ្យាស្រ័យផ្សេងៗ គ្នា ដោយអធ្យាស្រ័យទាំងឡាយ មានអធ្យាស្រ័យអាក្រក់ជាដើម ។ ញាណនេះ លោកពោលពិស្តារហើយ ក្នុងអភិធម្ម ដោយន័យជាដើមថា បណ្តាញាណទាំងនោះ ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវអធ្យាស្រ័យផ្សេងៗ គ្នា នៃពួកសត្វ តើដូចម្តេច ។ ព្រះតថាគតក្នុងលោកនេះ ទ្រង់ជ្រាបច្បាស់ថា ពួកសត្វមានអធ្យាស្រ័យថោកទាប

ក៏មាន ដូច្នេះ ។

បទថា **បរសត្តានំ** បានដល់ សត្វដែលមានឥន្ទ្រិយល្អ ។ បទថា **បរបុគ្គលានំ** បានដល់ សត្វដែលមានឥន្ទ្រិយអាក្រក់ដទៃអំពីនោះ ។ម្យ៉ាងទៀត ពីរបទនេះ មានសេចក្តីដូចគ្នា ត្រាស់ ២ ចំណែក ក៏ដោយអំណាចវេនេយ្យសត្វ ។ បទថា **ឥន្ទ្រិយបរោបរិយត្តំ** សេចក្តីថា ការចាស់ក្លា និងការធូរថយ ការចម្រើន និងការវិនាសនៃឥន្ទ្រិយទាំងឡាយ មានសទ្ធិន្ទ្រិយជាដើម ។ កថាពោលដោយញាណនេះ ដោយពិស្តារ ក៏មកក្នុងអភិធម្មដូចគ្នា ដោយន័យជាដើមថា បណ្តាញាណទាំងនោះ ព្រះតថាគត មានការជ្រាបច្បាស់តាមពិតនូវឥន្ទ្រិយចាស់ក្លា និងទន់របស់ពួកសត្វដទៃ របស់ពួកបុគ្គលដទៃ តើដូចម្តេច ។ ព្រះតថាគតក្នុងលោកនេះ ទ្រង់ជ្រាបច្បាស់នូវអាសយៈ ( ធម៌ជាទីនៅអាស្រ័យរបស់ពួកសត្វ ) ទ្រង់ជ្រាបច្បាស់នូវអនុសយៈ ( កិលេសដែលដេកត្រាំនៅក្នុងសន្តានរបស់ពួកសត្វ ) ... ដូច្នេះ ។

បទថា **ឈានវិមោក្ខសមាធិសមាបត្តីនំ** បានដល់ នៃឈាន ៤ មានបឋមជ្ឈានជាដើម វិមោក្ខ ៨ មាន **រូបី រូបានិ បស្សតិ** បុគ្គលចម្រើនរូបជ្ឈាន ឃើញរូបទាំងឡាយជាដើម សមាធិ ៣ មានសមាធិដែលមានវិតក្កមានវិចារៈជាដើម និងអនុបុព្វវិហារសមាបត្តិ ៩ មានបឋមជ្ឈានសមាបត្តិជាដើម ។ បទថា **សង្កិលេសំ** បានដល់ ធម៌ចំណែកវិនាស ។ បទថា **វោទានំ** បានដល់ ធម៌ចំណែកវិសេស ។ បទថា **វុដ្ឋានំ** បានដល់ ការចេញ

អំពីសមាធិនោះៗ ក៏ឈ្មោះថា វុដ្ឋាន ឈានដែលស្ទាត់ជំនាញ និងភវង្គចិត្ត និងផលសមាបត្តិ លោកក៏ហៅយ៉ាងនោះ ពិតហើយ ឈានដែលស្ទាត់ជំនាញហើយខាងក្រោម រមែងជាបទដ្ឋានរបស់ឈានជាន់ខ្ពស់ៗ ឡើង ព្រោះដូច្នោះ សូម្បីវោទាន ក៏ហៅថា វុដ្ឋាន ការចេញអំពីឈានទាំងពួង រមែងមានដោយភវង្គចិត្ត ការចេញអំពីនិរោធសមាបត្តិ រមែងមានដោយផលសមាបត្តិ ។ ខ្ញុំសំដៅយកសេចក្តីនោះ ទើបពោលថា សូម្បីការចេញអំពីសមាធិនោះៗ ឈ្មោះថា **វុដ្ឋានា** សូម្បីញាណនេះ លោកក៏ពោលពិស្តារហើយក្នុងអភិធម្មដោយន័យជាដើមថា បណ្តាញាណទាំងនោះ ព្រះតថាគត មានការជ្រាបច្បាស់តាមពិតនូវសេចក្តីសៅហ្មង នូវសេចក្តីផូរផង់ នូវការចេញនៃឈានវិមោក្ខ សមាធិ និងសមាបត្តិ តើដូចម្តេច ។ ពាក្យថា បុគ្គលមានឈានបានដល់បុគ្គលមានឈាន ៤ ពួក គឺបុគ្គលមានឈាន ១ ពួក សម្គាល់នូវសម្បត្តិ ថាជាវិបត្តិក៏មាន ... ដូច្នេះ ។ ការវិនិច្ឆ័យក្នុងកថាពោលដោយញាណទាំងឡាយ ដោយពិស្តារថា សព្វវិបត្តិជាដើម ក៏ពោលហើយក្នុងអដ្ឋកថាគម្ពីរវិភង្គ ឈ្មោះថា សម្មោហវិនោទនី ។ កថាដែលពោលដោយបុព្វេនិវាសានុស្សតិញ្ញាណ និងទិព្វចក្ខុញ្ញាណ ក៏ពោលពិស្តារហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គ ។ កថាពោលដោយអាសវក្ខយញ្ញាណ ក៏ពោលហើយក្នុងខាងដើមនោះឯង ។

ក្នុងរឿងព្រះញាណរបស់ព្រះតថាគតនោះ មានពាក្យសួររបស់បរវាទីថា

ញាណមួយផ្នែក ឈ្មោះថា ទសពលញ្ញាណមិនមាន ។ នេះជាប្រភេទនៃសព្វញ្ញុតញ្ញាណនោះឯង ។ ពាក្យនោះមិនគួរឃើញយ៉ាងនោះ ដ្បិតថា ទស-ពលញ្ញាណជាញាណ ១ សព្វញ្ញុតញ្ញាណជាញាណ ១ ។ ពិតហើយ ព្រះទសពលញ្ញាណ ក៏ដឹងចំពោះកិច្ចរៀងៗ ខ្លួនប៉ុណ្ណោះ ។ ព្រះសព្វញ្ញុតញ្ញាណតែងដឹងកិច្ចរៀងៗ ខ្លួននោះ ទាំងកិច្ចដ៏សេសក្រៅអំពីរបស់ខ្លួននោះ ។ សេចក្តីពិត ក្នុងព្រះទសពលញ្ញាណទាំងឡាយ ព្រះញាណទី ១ ដឹងហេតុ និងមិនមែនហេតុ ព្រះញាណទី ២ ដឹងកម្មជវៃ និងវិបាកជវៃ ព្រះញាណទី ៣ ដឹងការកំណត់កម្ម ព្រះញាណទី ៤ ដឹងហេតុនៃធាតុដែលផ្សេងៗ គ្នា ញាណទី ៥ រមែងដឹងអធិមុត្តិ គឺអធ្យាស្រ័យរបស់សត្វទាំងឡាយ ព្រះញាណទី ៦ រមែងដឹងភាពដែលឥន្ទ្រិយរបស់សត្វទាំងឡាយថាចាស់ក្លា និងទន់ខ្សោយ ព្រះញាណទី ៧ រមែងដឹងការសៅហ្មងជាដើមរបស់ធម៌ជាដើមទាំងនោះ មួយអន្លើដោយឈានជាដើម ព្រះញាណទី ៨ រមែងដឹងសន្តិ គឺការបន្តនៃខន្ធដែលអាស្រ័យនៅក្នុងជាតិមុនៗ ព្រះញាណទី ៩ រមែងដឹងចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ ព្រះញាណទី ១០ រមែងដឹងនូវការកំណត់សច្ចៈ ។ ឯព្រះសព្វញ្ញុតញ្ញាណ រមែងដឹងការដែលញាណទាំងនោះគួរដឹង និងការដែលច្រើនជាងព្រះញាណទាំងនោះ ។ ព្រះសព្វញ្ញុតញ្ញាណ មិនធ្វើកិច្ចរបស់ព្រះញាណទាំងនោះគ្រប់យ៉ាងឡើយ ។ ពិតហើយ ព្រះសព្វញ្ញុតញ្ញាណនោះ មិនមែនជាញាណដែលចុះស៊ប់បានឡើយ មិនជាឥទ្ធិក្នុងការសម្តែងឫទ្ធិផ្សេងៗ

បានឡើយ មិនមែនជាមគ្គ ធ្វើកិលេសទាំងឡាយឲ្យអស់ទៅបានឡើយ ។

ម្យ៉ាងទៀត បរវាទីគប្បីសួរយ៉ាងនេះថា ធម្មតា ទសពលញ្ញាណនេះ មានវិតក្ក មានវិចារៈ មិនមានវិតក្ក មានត្រឹមវិចារៈ ឬមិនមានវិតក្ក មិនមានវិចារៈ ជាកាមាវចរ រូបាវចរ ឬអរូបាវចរ ជាលោកិយ ឬលោកុត្តរ កាលដឹង ក៏នឹងឆ្លើយថា ព្រះញាណ ៧ តាមលំដាប់ មានវិតក្ក មានវិចារៈ និងឆ្លើយថា ព្រះញាណ ២ ក្រៅអំពីព្រះញាណ ៧ នោះ មិនមានវិតក្ក មិនមានវិចារៈ ។ និងឆ្លើយថា អាសវក្ខយញ្ញាណ មានវិតក្កវិចារៈក៏មាន និងឆ្លើយថា ព្រះញាណ ៧ តាមលំដាប់ក៏ដូចគ្នា ជាកាមាវចរ ព្រះញាណ ២ ក្រៅអំពីព្រះញាណ ៧ នោះ ជារូបាវចរ ព្រះញាណ ១ ចុងក្រោយ ជាលោកុត្តរ ចំណែកសព្វញ្ញុតញ្ញាណ មានវិតក្ក មានវិចារៈ ជាកាមាវចរប៉ុណ្ណោះ ជាលោកិយប៉ុណ្ណោះ ។ កាលដឹងកិច្ចពណ៌នាតាមបទក្នុងព្រះញាណ របស់ព្រះតថាគតនោះយ៉ាងនេះហើយ ឥឡូវនេះ ព្រោះហេតុដែលព្រះតថាគត ទ្រង់ឃើញការមិនមានកិលេសជាគ្រឿងរារាំងចិត្ត ជាឋានៈ និងអឋានៈនៃការសម្រេចធម៌ជាទីអស់អាសវៈ និងមិនសម្រេចរបស់វេនេយ្យសត្វទាំងឡាយ ដោយឋានាឋានញ្ញាណមុននោះឯង ព្រោះទ្រង់ឃើញសម្មាទិដ្ឋិជាដើម ដែលជាលោកិយ និងព្រោះទ្រង់ឃើញភាពមិនមាននិយតមិច្ឆាទិដ្ឋិ លំដាប់នោះ ទើបទ្រង់ឃើញការមិនមានវិបាកជាគ្រឿងរារាំង ដោយកម្មវិបាកញ្ញាណ ព្រោះទ្រង់ឃើញបដិសន្ធិរបស់សត្វដែលមានត្រៃហេតុ ទ្រង់ឃើញការមិនមានកម្មជាគ្រឿង

រារាំង ដោយសព្វត្ថគាមិនីបដិបទាញាណ ព្រោះទ្រង់ឃើញការមិនមានអនន្តរិយកម្ម កាលបើដូច្នោះ ទើបទ្រង់ឃើញការវិសេសនៃចរិយារបស់ពួកសត្វ ដែលមិនមានគ្រឿងរារាំង ដោយអនេកធាតុនានាធាតុញ្ញាណ ដើម្បីទ្រង់សម្តែងធម៌ដែលអនុកូល ព្រោះទ្រង់ឃើញការដែលធាតុផ្សេងគ្នា បន្ទាប់អំពីនោះ ក៏ទ្រង់ឃើញអធិមុត្តិ គឺអធ្យាស្រ័យរបស់សត្វទាំងនោះ ដោយនានាធិមុត្តិកតញ្ញាណ ដើម្បីទ្រង់មិនទាញយកប្រយោគ ក៏ទ្រង់សម្តែងធម៌ដោយអំណាចអធិមុត្តិ ទ្រង់ឃើញភាពដែលសត្វមានឥន្ទ្រិយក្រៃលែង និងទន់ដោយឥន្ទ្រិយបរោបរិយត្តិញ្ញាណ ដើម្បីទ្រង់សម្តែងធម៌តាមសមត្ថភាព និងតាមកម្លាំង ដោយអំណាចពួកសត្វ ដែលទ្រង់ឃើញអធិមុត្តិហើយយ៉ាងនោះ ព្រោះទ្រង់ឃើញឥន្ទ្រិយរបស់សត្វទាំងឡាយ មានសទ្ធាជាដើមចាស់ក្លា និងទន់ខ្សោយ តែសត្វទាំងនោះដែលទ្រង់កំណត់ដឹងថា មានឥន្ទ្រិយក្រៃលែងនិងជួរថយយ៉ាងនោះ បើនៅឆ្ងាយអំពីនោះ ទ្រង់ក៏ចូលទៅជិតសត្វទាំងនោះយ៉ាងរួសរាន់ដោយភាពវិសេសនៃឫទ្ធិ និងព្រោះទ្រង់ជំនាញក្នុងឈានជាដើមដោយឈានាទិញ្ញាណ កាលយាងចូលទៅជិតហើយ កាលទ្រង់ឃើញការៈនៃសត្វទាំងនោះ ក្នុងជាតិមុនៗ ដោយបុព្វេនិវាសានុស្សតិញ្ញាណ កាលទ្រង់ឃើញភាពវិសេសនៃសម្បត្តិ ដែលសត្វសម្រេចហើយ ដោយចេតោបរិយញ្ញាណ ដែលគប្បីសម្រេចព្រោះអានុភាពនៃទិព្វចក្ខុញ្ញាណ ទើបទ្រង់សម្តែងធម៌ដើម្បីបដិបទា ដែលឲ្យដល់នូវធម៌ជាទីអស់អាសវៈ ដើម្បីការអស់

ទៅនៃអាសវៈ ព្រោះជាបុគ្គលប្រាសចាកការវង្វេងហើយ ដោយអានុភាពនៃអាសវក្ខយញ្ញាណ ដូច្នោះ គប្បីជ្រាបតាមលំដាប់ដូច្នេះថា ត្រាស់ពលទាំងឡាយ ដោយលំដាប់នេះ ។

**អដ្ឋកថា សីហសូត្រទី ១ ចប់**

# សុត្តន្តបិដក

## អធិមុត្តិសូត្រទី ២

[ ២២ ] គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលអានន្ទ ធម៌ទាំងឡាយណា ប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវអធិមុត្តិបទទាំងឡាយនោះៗ ដោយប្រាជ្ញាដ៏ឧត្តម ម្នាលអានន្ទ តថាគតជាអ្នកក្លៀវក្លា ដឹងច្បាស់ក្នុងអធិមុត្តិបទនោះៗ អាចសម្តែងធម៌ដល់ពួកសត្វនោះៗ តាមដែលអ្នកប្រតិបត្តិហើយ និងដឹងរបស់ដែលមាន ថាមានក្តី ដឹងរបស់ដែលមិនមាន ថាមិនមានក្តី ដឹងរបស់ដែលថោកទាប ថាថោកទាបក្តី ដឹងរបស់ឧត្តម ថាឧត្តមក្តី ដឹងរបស់ដែលមានរបស់ដទៃប្រសើរជាង ថាមានរបស់ដទៃប្រសើរជាងក្តី ដឹងរបស់ដែលមិនមានរបស់ដទៃប្រសើរជាង ថា

មិនមានរបស់ដទៃប្រសើរជាងក្តី ម្យ៉ាងទៀត របស់នោះដែលបុគ្គលត្រូវដឹង ឬត្រូវឃើញ ឬក៏ត្រូវធ្វើឲ្យជាក់ច្បាស់ដោយហេតុណាៗ នឹងដឹង ឬនឹងឃើញ ឬក៏នឹងធ្វើឲ្យជាក់ច្បាស់ដោយហេតុនោះៗ ហេតុនេះ រមែងមានជាធម្មតា ។ ម្នាលអានន្ទ បណ្តាសេចក្តីដឹងទាំងឡាយ សេចក្តីដឹងតាមពិតក្នុងធម៌នោះៗ ណាមួយ សេចក្តីដឹងតាមពិតនុ៎ះ ឈ្មោះថា មិនមានសេចក្តីដឹងដទៃប្រសើរជាង ។ ម្នាលអានន្ទ មួយទៀត តថាគតសម្តែងថា ញាណដទៃលើសលុប ឬថ្លៃថ្លាជាងញាណនុ៎ះ មិនមានទេ ។ ម្នាលអានន្ទ តថាគតពលរបស់ព្រះតថាគតនេះ មាន ១០ ប្រការ ព្រោះព្រះតថាគតប្រកបដោយពលទាំងឡាយហើយ ទើបប្តេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្កឲ្យប្រព្រឹត្តទៅ ។ ចុះតថាគតពល ១០ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលអានន្ទ ព្រះតថាគតក្នុងលោកនេះ ជ្រាបច្បាស់នូវហេតុតាមហេតុផង ជ្រាបច្បាស់នូវអំពើមិនមែនជាហេតុ តាមអំពើមិនមែនជាហេតុផង ដោយសេចក្តីជាក់លាក់ ។ ម្នាលអានន្ទ ត្រង់ដែលព្រះតថាគតជ្រាបច្បាស់នូវហេតុតាមហេតុផង ជ្រាបច្បាស់នូវអំពើដែលមិនមែនជាហេតុ តាមអំពើដែលមិនមែនជាហេតុផង ដោយសេចក្តីជាក់លាក់ ។ ម្នាលអានន្ទ នេះជាតថាគត-ពលរបស់ព្រះតថាគត ព្រោះព្រះតថាគតអាស្រ័យនឹងពលហើយ ប្តេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្កឲ្យប្រព្រឹត្តទៅ ។ ម្នាលអានន្ទ មួយទៀត ព្រះតថាគតជ្រាបច្បាស់នូវវិបាកនៃកុសលកម្ម និង

អកុសលកម្មដែលសត្វបាន ធ្វើហើយ ទាំងអតីត អនាគត និងបច្ចុប្បន្ន តាមឋាក់ តាមហេតុដោយសេចក្តីជាក់លាក់ ។ ម្នាលអានន្ទ ត្រង់ដែល ។បេ។ ម្នាលអានន្ទ នេះជា ។បេ។ ម្នាលអានន្ទ មួយទៀត ព្រះតថាគតជ្រាបច្បាស់នូវផ្លូវដែលទៅកាន់ទីទាំងពួង ដោយសេចក្តីជាក់លាក់ ។ ម្នាលអានន្ទ ត្រង់ដែល ។បេ។ ម្នាលអានន្ទ នេះជា ។បេ។ ម្នាលអានន្ទ មួយទៀត ព្រះតថាគតជ្រាបច្បាស់នូវលោក ដែលមានធាតុច្រើនយ៉ាង មានធាតុផ្សេងៗ គ្នា ដោយសេចក្តីជាក់លាក់ ។ ម្នាលអានន្ទ ត្រង់ដែល ។បេ។ ម្នាលអានន្ទ នេះជា ។បេ។ ម្នាលអានន្ទ មួយទៀត ព្រះតថាគតជ្រាបច្បាស់នូវអធ្យាស្រ័យផ្សេងៗ គ្នា របស់សត្វទាំងឡាយ ដោយសេចក្តីជាក់លាក់ ។ ម្នាលអានន្ទ ត្រង់ដែល ។បេ។ ម្នាលអានន្ទ នេះជា ។បេ។ ម្នាលអានន្ទ មួយទៀត ព្រះតថាគតជ្រាបច្បាស់នូវឥន្ទ្រិយក្សៀវក្លា និងទន់របស់ពួកសត្វដទៃ របស់ពួកបុគ្គលដទៃដោយសេចក្តីជាក់លាក់ ។ ម្នាលអានន្ទ ត្រង់ដែល ។បេ។ ម្នាលអានន្ទ នេះជា ។បេ។ ម្នាលអានន្ទ មួយទៀត ព្រះតថាគតជ្រាបច្បាស់នូវសេចក្តីសៅហ្មង សេចក្តីផូរផង់ និងការចេញចាកឈាន វិមោក្ខ សមាធិ និងសមាបត្តិទាំងឡាយ ដោយសេចក្តីជាក់លាក់ ។ ម្នាលអានន្ទ ត្រង់ដែល ។បេ។ ម្នាលអានន្ទ នេះជា ។បេ។ ម្នាលអានន្ទ មួយទៀត ព្រះតថាគតរឭកឃើញនូវជាតិដែលបាននៅអាស្រ័យក្នុងកាលមុន ជាអនេកជាតិ គឺ ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ រឭកឃើញនូវជាតិដែលធ្លាប់នៅអាស្រ័យហើយ ក្នុង

កាលមុនជាច្រើន ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ។ ម្នាលអានន្ទ ត្រង់ដែល ។បេ។ ម្នាលអានន្ទ នេះជា ។បេ។ ម្នាលអានន្ទ មួយទៀត ព្រះតថាគតមានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងផុតចក្ខុរបស់មនុស្សធម្មតា ។បេ។ ជ្រាបច្បាស់នូវសត្វទាំងឡាយដែលអន្ទោលទៅតាមកម្ម ។ ម្នាលអានន្ទ ត្រង់ដែល ។បេ។ ម្នាលអានន្ទ នេះជា ។បេ។ ម្នាលអានន្ទ មួយវិញទៀត ព្រះតថាគតបានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ។ ម្នាលអានន្ទ ត្រង់ដែលព្រះតថាគតធ្វើឲ្យជាក់ច្បាស់សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ម្នាលអានន្ទនេះជាតថាគតពលរបស់ព្រះតថាគត ព្រោះព្រះតថាគតអាស្រ័យនឹងពលហើយ ប្ដេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្កឲ្យប្រព្រឹត្តទៅ ។ ម្នាលអានន្ទ នេះជាតថាគតពល របស់ព្រះតថាគតទាំង ១០ ប្រការ ព្រោះព្រះតថាគតប្រកបដោយពលទាំងឡាយ ហើយប្ដេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្កឲ្យប្រព្រឹត្តទៅ ។

# អដ្ឋកថា

## អធិមុត្តិសូត្រ

[ ២២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអធិមុត្តិសូត្រទី ២ ដូចតទៅនេះ បទថា **យេ តេ ធម្មា** បានដល់ ធម៌ គឺព្រះទសពលញ្ញាណ និងព្រះសព្វញ្ញុតញ្ញាណទាំងនោះ ។ បទថា **អធិមុត្តិបទានំ** បានដល់ បទ គឺឈ្មោះ អធិប្បាយថា ធម៌ គឺខន្ធ អាយតនៈ ធាតុ ។ ពិតហើយ ឈ្មោះ លោកហៅថា អធិមុត្តិ ព្រោះជាបទដ្ឋាននៃទេសនា ដែលជាបទនៃធម៌នោះៗ ។ ពិតហើយ ព្រះសម្ពុទ្ធទាំងឡាយដែលកន្លងទៅហើយ ក៏ត្រាស់ធម៌ទាំងនោះដូចគ្នា សូម្បីព្រះពុទ្ធដែលមិនទាន់មកដល់ ក៏នឹងត្រាស់ធម៌ទាំងនោះដូចគ្នា ព្រោះដូច្នោះ ធម៌ទាំងឡាយ មានខន្ធជាដើម ឈ្មោះថា អធិមុត្តិបទ ។ អធិមុត្តិបទទាំងនោះ ។ ម្យ៉ាងទៀត ទិដ្ឋិទាំងឡាយ លោកហៅថា អធិមុត្តិ ព្រោះគ្របសង្កត់សេចក្តីពិត មិនកាន់យកតាមសេចក្តីពិតប្រព្រឹត្តទៅ ។ បទនៃទិដ្ឋិទាំងឡាយ ឈ្មោះថា អធិមុត្តិបទ អធិប្បាយថា ពាក្យដែលសម្តែងទិដ្ឋិនៃអធិមុត្តិបទទាំងនោះ ។

បទថា **អភិញ្ញា សច្ឆិកិរិយាយ** សេចក្តីថា ដើម្បីជាប្រយោជន៍ដល់ការដឹង ហើយធ្វើឲ្យប្រចក្ស ។ បទថា **វិសារទោ** បានដល់ ដល់នូវសោមនស្ស ដែលប្រកបដោយកាយ ។ បទថា **តត្ថ** បានដល់ ក្នុងធម៌ទាំងនោះ ។ បទថា

**តេសំ តេសំ តថា តថា ធម្មំ ទេសេតុំ** *សេចក្ដីថា ដើម្បីទ្រង់ដឹងអាសយៈ គឺអធ្យាស្រ័យដែលល្អរបស់ពួកសត្វនោះៗ ដែលមានទិដ្ឋិ ឬក្រៅអំពីនេះ ហើយ ទ្រង់សម្ដែងធម៌ដោយប្រការនោះៗ ។ បទថា* **ឋានំ វា ឋានតោ ញស្សតិ** *សេចក្ដីថា ឬនឹងដឹងធម៌អាក្រក់ ថាជាធម៌អាក្រក់ ។ បទថា* **ញាតយ្យំ** *ប្រែថា គប្បីដឹង ។ បទថា* **ទិដ្ឋយ្យំ** *ប្រែថា គប្បីឃើញ ។ បទថា* **សច្ឆិកាតយ្យំ** *ប្រែថា គប្បីធ្វើឲ្យជាក់ច្បាស់ ។ បទថា* **តត្ថ តត្ថ យថាភូតញាណំ** *បានដល់ ញាណដែលដឹងតាមសេចក្ដីពិតក្នុងធម៌នោះ ។ ទ្រង់សម្ដែងព្រះសព្វញ្ញុតញ្ញាណយ៉ាងនេះហើយ កាលទ្រង់សម្ដែងព្រះទស-ពលញ្ញាណទៀត ទើបត្រាស់ថា* **ឧសយិមានិ** *ជាដើម ។ ពិតហើយ សូម្បីព្រះទសពលញ្ញាណ ឬព្រះញាណដែលដឹងតាមសេចក្ដីពិតក្នុងធម៌នោះៗ ឯង ។ល។*

## អដ្ឋកថា អធិមុត្តិសូត្រទី ២ ចប់

# សុត្តន្តបិដក

## កាយសូត្រទី ៣

[ ២៣ ] ម្នាលភិក្ខុទាំងឡាយ ពួកធម៌ដែលបុគ្គលគប្បីលះដោយកាយ មិនបាច់វាចាក៏មាន ម្នាលភិក្ខុទាំងឡាយ ពួកធម៌ដែលបុគ្គលគប្បីលះដោយវាចា មិនបាច់កាយក៏មាន ម្នាលភិក្ខុទាំងឡាយ ពួកធម៌ដែលបុគ្គលមិនគប្បីលះដោយកាយ មិនគប្បីលះដោយវាចា គប្បីលះចេញ ព្រោះឃើញជាក់ស្តែងដោយប្រាជ្ញាក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ចុះពួកធម៌ដែលបុគ្គលគប្បីលះដោយកាយ មិនបាច់វាចា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកត្រូវនូវចំណែកនៃអាបត្តិណាមួយ ជាអកុសលដោយកាយ ។ ពួកវិញ្ញូជនជាសព្រហ្មចារី ជៀងមើលរឿយៗ នូវភិក្ខុនោះហើយនិយាយយ៉ាងនេះថា លោកដ៏មានអាយុបានត្រូវនូវចំណែកនៃអាបត្តិណាមួយជាអកុសលដោយកាយហើយ លោកដ៏មានអាយុចូរលះកាយទុច្ចរិត ហើយចម្រើនកាយសុចរិតឲ្យត្រឹមត្រូវឡើង ។ កាលពួកវិញ្ញូជនជាសព្រហ្មចារីជៀងមើលរឿយៗ ហើយស្តីថា ភិក្ខុនោះក៏លះកាយទុច្ចរិត ហើយចម្រើនកាយ-សុចរិតទៅ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលបុគ្គលគប្បីលះដោយកាយ មិនបាច់វាចា ។ ម្នាលភិក្ខុទាំងឡាយ ចុះពួកធម៌ដែលបុគ្គលគប្បីលះដោយវាចា មិនបាច់កាយ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកត្រូវនូវចំណែកនៃអាបត្តិណាមួយ ជាអកុសលដោយវាចា ។ ពួកវិញ្ញូជនជាសព្រហ្មចារី ជៀងមើលរឿយៗ នូវភិក្ខុនោះ

ហើយនិយាយយ៉ាងនេះថា លោកដ៏មានអាយុ បានត្រូវនូវចំណែកនៃអាបត្តិណាមួយ ជាអកុសលដោយវាចាហើយ លោកដ៏មានអាយុចូរលះវចីទុច្ចរិត ហើយចម្រើនវចីសុចរិតឲ្យត្រឹមត្រូវឡើង ។ កាលពួកវិញ្ញូជនជាសព្រហ្មចារីដៀងមើលរឿយៗ ហើយស្តីថា ភិក្ខុនោះក៏លះវចីទុច្ចរិត ហើយចម្រើនវចីសុចរិតទៅ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលបុគ្គលគប្បីលះដោយវាចា មិនបាច់ប្រើកាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះពួកធម៌ដែលបុគ្គលមិនគប្បីលះដោយកាយ មិនគប្បីលះដោយវាចា គប្បីលះចេញ ព្រោះឃើញជាក់ស្តែងដោយប្រាជ្ញាបាន តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ លោភៈ បុគ្គលមិនគប្បីលះដោយកាយ មិនគប្បីលះដោយវាចាទេ គប្បីលះចេញព្រោះឃើញជាក់ស្តែងដោយប្រាជ្ញាបាន ។ ម្នាលភិក្ខុទាំងឡាយ ទោសៈ ... ម្នាលភិក្ខុទាំងឡាយ មោហៈ ... ម្នាលភិក្ខុទាំងឡាយ កោធៈ .... ម្នាលភិក្ខុទាំងឡាយ ឧបនាហៈ ... ម្នាលភិក្ខុទាំងឡាយ មក្ខៈ ... ម្នាលភិក្ខុទាំងឡាយ បលាសៈ ... ម្នាលភិក្ខុទាំងឡាយ មច្ឆរិយៈ បុគ្គលមិនគប្បីលះដោយកាយ មិនគប្បីលះដោយវាចា គប្បីលះចេញព្រោះឃើញជាក់ស្តែង ដោយប្រាជ្ញាបាន ។ ម្នាលភិក្ខុទាំងឡាយ ឥស្សាដ៏លាមក បុគ្គលមិនគប្បីលះដោយកាយ មិនគប្បីលះដោយវាចាទេ គប្បីលះចេញព្រោះឃើញជាក់ស្តែងដោយប្រាជ្ញាបាន ។ ម្នាលភិក្ខុទាំងឡាយ ចុះឥស្សាដ៏លាមក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គហបតី ឬគហបតិបុត្តក្នុងលោកនេះ បរិបូណ៌ដោយទ្រព្យក្តី ស្រូវ

ក្តី ប្រាក់ក្តី មាសក្តី ។ ខ្ញុំកំដរ ឬអ្នកដែលនៅជ្រកកោនណាមួយ មាន សេចក្តីប្រណែននឹងគហបតី ឬគហបតិបុត្តនោះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ កុំឲ្យគហបតី ឬគហបតិបុត្តនេះ បានបរិបូណ៌ដោយទ្រព្យក្តី ស្រូវក្តី ប្រាក់ក្តី មាសក្តីដូច្នេះឡើយ ។ ចំណែកខាងសមណៈ ឬព្រាហ្មណ៍វិញ ដែលជាអ្នកបាននូវចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារ ។ សមណៈ ឬព្រាហ្មណ៍ណាមួយ មានសេចក្តីប្រណែននឹងសមណៈ ឬព្រាហ្មណ៍នោះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ កុំឲ្យលោកដ៏មានអាយុនេះ បានចីវរ បិណ្ឌ-បាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារដូច្នេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឥស្សាដ៏លាមក ។ ម្នាលភិក្ខុទាំងឡាយ ឥស្សាដ៏លាមក បុគ្គលមិនគប្បីលះដោយកាយ មិនគប្បីលះដោយវាចាទេ គប្បីលះចេញ ព្រោះឃើញជាក់ស្តែងដោយប្រាជ្ញាបាន ។ ម្នាលភិក្ខុទាំងឡាយ ឥច្ឆាដ៏លាមក បុគ្គលមិនគប្បីលះដោយកាយ មិនគប្បីលះដោយវាចាទេ គប្បីលះចេញ ព្រោះឃើញជាក់ស្តែងដោយប្រាជ្ញាបាន ។ ម្នាលភិក្ខុទាំងឡាយ ចុះឥច្ឆាដ៏លាមក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះជាបុគ្គលមិនមានសទ្ធា តែប្រាថ្នាថា អ្នកផង គប្បីស្គាល់អញ ថាជាអ្នកមានសទ្ធា ជាបុគ្គលទ្រុស្តសីល តែប្រាថ្នាថា អ្នកផង គប្បីស្គាល់អញ ថាជាអ្នកមានសីល ជាបុគ្គលចេះដឹងតិច តែប្រាថ្នាថា អ្នកផង គប្បីស្គាល់អញថាជាអ្នកចេះដឹងច្រើន ជាបុគ្គលត្រេកអរ ក្នុងការប្របូកប្របល់ ដោយគ្នីគ្នា តែ

ប្រាថ្នាថា អ្នកផង គប្បីស្គាល់អញ ថាជាអ្នកស្ងាត់កាយ ជាបុគ្គលខ្ជិល តែប្រាថ្នាថា អ្នកផង គប្បីស្គាល់អញ ថាជាអ្នកមានប្រារព្ធព្យាយាម ជាបុគ្គលភ្លេចកាំងស្មារតី តែប្រាថ្នាថា អ្នកផង គប្បីស្គាល់អញ ថាជាអ្នកមានស្មារតីតាំងមាំ ជាបុគ្គលមិនបានសមាធិ តែប្រាថ្នាថា អ្នកផង គប្បីស្គាល់អញថាជាអ្នកបានសមាធិ ជាបុគ្គលអាប់ប្រាជ្ញា តែប្រាថ្នាថា អ្នកផង គប្បីស្គាល់អញ ថាជាអ្នកមានប្រាជ្ញា ជាបុគ្គលមិនទាន់អស់អាសវៈ តែប្រាថ្នាថា អ្នកផង គប្បីស្គាល់អញ ថាជាអ្នកអស់អាសវៈហើយ ។ ម្នាលភិក្ខុទាំងឡាយនេះហៅថា ឥច្ឆាដ៏លាមក ។ ម្នាលភិក្ខុទាំងឡាយ ឥច្ឆាដ៏លាមក បុគ្គលមិនគប្បីលះដោយកាយ មិនគប្បីលះដោយវាចាទេ គប្បីលះចេញ ព្រោះឃើញជាក់ស្តែងដោយប្រាជ្ញាបាន ។ ម្នាលភិក្ខុទាំងឡាយ បើលោភៈគ្របសង្កត់ភិក្ខុនោះ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សាដ៏លាមក ឥច្ឆាដ៏លាមកគ្របសង្កត់ភិក្ខុនោះ អ្នកទាំងឡាយ គប្បីដឹងយ៉ាងនេះថា លោភៈមិនកើតមានដល់បុគ្គលដែលដឹងច្បាស់ យ៉ាងនេះ ថាលោកដ៏មានអាយុនេះ មិនដឹងច្បាស់យ៉ាងនោះទេ ហេតុដូច្នោះ បានជាលោភៈមកគ្របសង្កត់លោកដ៏មានអាយុនេះបាន ។ ទោសៈ មិនមានដល់បុគ្គលដែលដឹងច្បាស់ យ៉ាងណា លោកដ៏មានអាយុនេះ មិនដឹងច្បាស់យ៉ាងនោះទេ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សាដ៏លាមក ឥច្ឆាដ៏លាមកមិនមាន ហេតុដូច្នោះ ទើបឥច្ឆាដ៏លាមកគ្របសង្កត់លោកដ៏មាន

អាយុនេះបាន ។ ម្នាលភិក្ខុទាំងឡាយ បើលោកៈមិនគ្របសង្កត់ភិក្ខុនោះទេ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សាដ៏លាមក ឥច្ឆាដ៏លាមកមិនគ្របសង្កត់ភិក្ខុនោះ អ្នកទាំងឡាយ គប្បីដឹងយ៉ាងនេះថា លោកៈ មិនមានដល់បុគ្គលដែលដឹងច្បាស់ យ៉ាងណា លោកដ៏មានអាយុនេះ ក៏ដឹងច្បាស់យ៉ាងនោះដែរ ហេតុដូច្នោះ បានជាលោកៈមិនគ្របសង្កត់លោកដ៏មានអាយុនេះបាន ។ ទោសៈ មិនមានដល់បុគ្គលដែលដឹងច្បាស់ យ៉ាងណា លោកដ៏មានអាយុនេះដឹងច្បាស់យ៉ាងនោះដែរ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សាដ៏លាមក ឥច្ឆាដ៏លាមកមិនមាន ហេតុដូច្នោះ បានជាឥច្ឆាដ៏លាមកមិនគ្របសង្កត់លោកដ៏មានអាយុនេះបាន ។

# អដ្ឋកថា

## កាយសូត្រ

[ ២៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកាយសូត្រទី ៣ ដូចតទៅនេះ បទថា **អាបន្នោ ហោតិ កញ្ចិទេវ ទេសំ** សេចក្ដីថា ជាអ្នកត្រូវចំណែកនៃអាបត្តិឯណានីមួយ ។ បទថា **អនុវិច្ច** បានដល់ ចូលទៅពិចារណា គឺមើលដោយជុំវិញហើយ ។ បទថា **កាយទុច្ចរិតំ** បានដល់ កាយទុច្ចរិត ៣ យ៉ាង ។

បទថា **វចីទុច្ចរិតំ** បានដល់ វចីទុច្ចរិត ៤ យ៉ាង ។ បទថា **ធាបិកា ឥស្សា** បានដល់ ការប្រណែនដ៏ថោកទាប ។ បទថា **បញ្ញាយ ទិស្វា ទិស្វា** បានដល់ សម្លឹងឃើញហើយ គប្បីលះដោយមគ្គប្បញ្ញា ព្រមដោយវិបស្សនា ។ បទថា **ឥជ្ឈតិ** ប្រែថា សម្រេចព្រម ។ បទថា **ឧបវាសស្ស** បានដល់ ចូលទៅអាស្រ័យ ។ បទថា **អភិភុយ្យ** បានដល់ គ្របសង្កត់ញាំញី ។ បទថា **ឥរិយតិ** បានដល់ ប្រព្រឹត្តទៅ ។ ក្នុងព្រះសូត្រនេះ ត្រាស់មគ្គ មួយអន្លើដោយវិបស្សនា ។៚

**អដ្ឋកថា កាយសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ចុន្ទសូត្រទី ៤

[ ២៤ ] សម័យមួយ ព្រះមហាចុន្ទដ៏មានអាយុ គង់ក្នុងប្រទេសឈ្មោះសហជាតិ ក្នុងដែនចេតី ។ ក្នុងទីនោះឯង ព្រះមហាចុន្ទដ៏មានអាយុហៅភិក្ខុទាំងឡាយថា ម្នាលអាវុសោភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ បានទទួលស្ដាប់ពាក្យរបស់ព្រះមហាចុន្ទដ៏មានអាយុថា ម្នាលអាវុសោ ។ ព្រះមហាចុន្ទដ៏មានអាយុ មានថេរវាចាដូច្នេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនិយាយនូវញាណវាទថា ខ្ញុំដឹងធម៌នេះ ខ្ញុំឃើញធម៌នេះ ។ ម្នាលអាវុសោទាំងឡាយ បើ

លោភៈគ្របសង្កត់ភិក្ខុនោះ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សាដ៏លាមក ឥច្ឆាដ៏លាមកគ្របសង្កត់ភិក្ខុនោះ អ្នកទាំងឡាយ គប្បីដឹងយ៉ាងនេះថា លោភៈ មិនមានដល់បុគ្គលដែលដឹងច្បាស់យ៉ាងណា លោកដ៏មានអាយុនេះ មិនដឹងច្បាស់យ៉ាងនោះទេ ហេតុដូច្នោះបានជាលោភៈគ្របសង្កត់លោកដ៏មានអាយុនេះ ទោសៈ មិនមានដល់បុគ្គលដែលដឹងច្បាស់ យ៉ាងណា លោកដ៏មានអាយុនេះ មិនដឹងច្បាស់យ៉ាងនោះទេ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សាដ៏លាមក ឥច្ឆាដ៏លាមក មិនមាន ហេតុដូច្នោះ បានជាឥច្ឆាដ៏លាមក គ្របសង្កត់លោកដ៏មានអាយុនេះ ។ ម្នាលអាវុសោទាំងឡាយ កាលភិក្ខុនិយាយការនោះទេថា ខ្ញុំជាអ្នកបានចម្រើនកាយ បានចម្រើនសីល បានចម្រើនចិត្ត បានចម្រើនប្រាជ្ញាហើយ ។ ម្នាលអាវុសោទាំងឡាយ បើលោភៈគ្របសង្កត់ភិក្ខុនោះ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សាដ៏លាមក ឥច្ឆាដ៏លាមក គ្របសង្កត់ភិក្ខុនោះ អ្នកទាំងឡាយ គប្បីដឹងយ៉ាងនេះថា លោភៈ មិនមានដល់បុគ្គលដែលដឹងច្បាស់ យ៉ាងណា លោកដ៏មានអាយុនេះ មិនដឹងច្បាស់យ៉ាងនេះទេ ហេតុដូច្នោះ បានជាលោភៈគ្របសង្កត់លោកដ៏មានអាយុនោះ ។ ទោសៈ មិនមានដល់បុគ្គល ដែលដឹងច្បាស់យ៉ាងណា លោកដ៏មានអាយុនេះ មិនដឹងច្បាស់យ៉ាងនោះទេ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សាដ៏លាមក ឥច្ឆាដ៏លាមក មិន

មាន ហេតុដូច្នោះ បានជាឥច្ឆាដ៏លាមក គ្របសង្កត់លោកដ៏មានអាយុនេះ ។ ម្នាលអាវុសោទាំងឡាយ កាលភិក្ខុអ្នកនិយាយនូវញាណវាទ និងភាវនាវាទថា ខ្ញុំដឹងធម៌នេះ ខ្ញុំឃើញធម៌នេះ ខ្ញុំជាអ្នកបានចម្រើនកាយ បានចម្រើនសីល បានចម្រើនចិត្ត បានចម្រើនប្រាជ្ញាហើយ ។ ម្នាលអាវុសោទាំងឡាយ បើលោភៈគ្របសង្កត់ភិក្ខុនោះ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សាដ៏លាមក ឥច្ឆាដ៏លាមក គ្របសង្កត់ភិក្ខុនោះ អ្នកទាំងឡាយ គប្បីដឹងយ៉ាងនេះថា លោភៈ មិនមានដល់បុគ្គលដែលដឹងច្បាស់យ៉ាងណា លោកដ៏មានអាយុនេះ មិនដឹងច្បាស់យ៉ាងនោះទេ ហេតុដូច្នោះ បានជាលោភៈ គ្របសង្កត់លោកដ៏មានអាយុនេះ ។ លោភៈ ទោសៈ មិនមានដល់បុគ្គលដែលដឹងច្បាស់ យ៉ាងណា លោកដ៏មានអាយុនេះ មិនដឹងច្បាស់យ៉ាងនោះទេ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សាដ៏លាមក ឥច្ឆាដ៏លាមក មិនមាន ហេតុដូច្នោះ បានជាឥច្ឆាដ៏លាមក គ្របសង្កត់លោកដ៏មានអាយុនេះ ។ ម្នាលអាវុសោទាំងឡាយ ដូចបុរសកម្សត់ តែអួតថា អ្នកស្តុកស្តម្ភ ជាអ្នកឥតទ្រព្យ តែអួតថា អ្នកមានទ្រព្យ ជាអ្នកឥតភោគៈ តែអួតថា ជាអ្នកមានភោគៈ បុរសនោះ មិនអាចប្រមូលមកនូវទ្រព្យក្តី ស្រូវក្តី ប្រាក់ក្តី មាសក្តី បានឡើយ អ្នកផងត្រូវដឹងបុរសនោះយ៉ាងនេះថា អ្នកដ៏មានអាយុនេះ ជាអ្នកកម្សត់សោះ តែអួតថា អ្នកស្តុកស្តម្ភ អ្នកដ៏មានអាយុនេះ ឥតទ្រព្យសោះ តែអួតថា អ្នកមានទ្រព្យ អ្នកដ៏

មានអាយុនេះ ជាអ្នកឥតភោគៈសោះ តែអួតថា អ្នកមានភោគៈ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថា កាលបើកិច្ចដែលត្រូវធ្វើ ដោយទ្រព្យណាមួយកើតឡើងហើយ អ្នកដ៏មានអាយុនេះ មិនអាចដើម្បីប្រមូលមកនូវទ្រព្យក្តី ស្រូវក្តី ប្រាក់ក្តី មាសក្តី បានឡើយ យ៉ាងណាមិញ ។ ម្នាលអាវុសោទាំងឡាយ កាលភិក្ខុនិយាយនូវញាណវាទ និងភាវនាវាទថា ខ្ញុំដឹងធម៌នេះ ឃើញធម៌នេះ ខ្ញុំជាអ្នកបានចម្រើនកាយ បានចម្រើនសីល បានចម្រើនចិត្ត បានចម្រើនប្រាជ្ញាហើយ ម្នាលអាវុសោទាំងឡាយ បើលោភៈគ្របសង្កត់ភិក្ខុនោះ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សាដ៏លាមក ឥច្ឆាដ៏លាមក គ្របសង្កត់ភិក្ខុនោះ អ្នកទាំងឡាយ គប្បីដឹងយ៉ាងនេះថា លោភៈ មិនមានដល់បុគ្គលដែលដឹងច្បាស់ យ៉ាងណា លោកដ៏មានអាយុនេះ មិនដឹងច្បាស់យ៉ាងនោះទេ ហេតុដូច្នោះ បានជាលោភៈគ្របសង្កត់លោកដ៏មានអាយុនេះ ។ ទោសៈ មិនមានដល់បុគ្គលដែលដឹងច្បាស់ យ៉ាងណា លោកដ៏មានអាយុនេះ មិនដឹងច្បាស់យ៉ាងនោះទេ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សាដ៏លាមក ឥច្ឆាដ៏លាមក មិនមាន ហេតុដូច្នោះ បានជាឥច្ឆាដ៏លាមក គ្របសង្កត់លោកដ៏មានអាយុនេះយ៉ាងនេះដែរ ។ ម្នាលអាវុសោទាំងឡាយ កាលភិក្ខុនិយាយនូវញាណវាទថា ខ្ញុំដឹងធម៌នេះ ឃើញធម៌នេះ ។ ម្នាលអាវុសោទាំងឡាយ បើលោភៈមិនគ្របសង្កត់ភិក្ខុនោះទេ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ

មច្ឆរិយៈ ឥស្សាដ៏លាមក ឥច្ឆាដ៏លាមក មិនគ្របសង្កត់ភិក្ខុនោះ អ្នកទាំង-ឡាយ គប្បីដឹងយ៉ាងនេះថា លោកៈ មិនមានដល់បុគ្គលដែលដឹងច្បាស់ យ៉ាងណា លោកដ៏មានអាយុនេះ ក៏ដឹងច្បាស់យ៉ាងនោះដែរ ហេតុដូច្នោះ បានលោភៈមិនគ្របសង្កត់លោកដ៏មានអាយុនេះ ។ ទោសៈ មិនមានដល់ បុគ្គលដែលដឹងច្បាស់ យ៉ាងណា លោកដ៏មានអាយុនេះ ក៏ដឹងច្បាស់យ៉ាង នោះដែរ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សា ដ៏លាមក ឥច្ឆាដ៏លាមក មិនមាន ហេតុដូច្នោះ បានជាឥច្ឆាដ៏លាមក មិន គ្របសង្កត់លោកដ៏មានអាយុនេះ ។ ម្នាលអាវុសោទាំងឡាយ កាលភិក្ខុ និយាយនូវការនោវាទថា ខ្ញុំជាអ្នកបានចម្រើនកាយ បានចម្រើនសីល បាន ចម្រើនចិត្ត បានចម្រើនប្រាជ្ញាហើយ ។ ម្នាលអាវុសោទាំងឡាយ បើលោភៈ មិនគ្របសង្កត់ភិក្ខុនោះ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សាដ៏លាមក ឥច្ឆាដ៏លាមក មិនគ្របសង្កត់ទេ ភិក្ខុនោះ អ្នក ទាំងឡាយ គប្បីដឹងយ៉ាងនេះថា លោភៈ មិនមានដល់បុគ្គលដែលដឹងច្បាស់ យ៉ាងណា លោកដ៏មានអាយុនេះ ក៏ដឹងច្បាស់យ៉ាងនោះដែរ ហេតុដូច្នោះ បានជាលោភៈ មិនគ្របសង្កត់លោកដ៏មានអាយុនេះ ។ ទោសៈ មិនមានដល់ បុគ្គលដែលដឹងច្បាស់ យ៉ាងណា លោកដ៏មានអាយុនេះ ក៏ដឹងច្បាស់យ៉ាង នោះដែរ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សា ដ៏លាមក ឥច្ឆាដ៏លាមក មិនមាន ហេតុដូច្នោះ បានជាឥច្ឆាដ៏លាមក មិនគ្រប

សន្តត់លោកដ៏មានអាយុនេះ ។ ម្នាលអាវុសោទាំងឡាយ កាលភិក្ខុអ្នកនិយាយនូវញាណវាទ និងការនាវាទថា ខ្ញុំដឹងធម៌នេះ ឃើញធម៌នេះ ខ្ញុំជាអ្នកបានចម្រើនកាយ បានចម្រើនសីល បានចម្រើនចិត្ត បានចម្រើនប្រាជ្ញាហើយ ។ ម្នាលអាវុសោទាំងឡាយ បើជាលោកៈមិនគ្របសង្កត់ភិក្ខុនោះទេ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សាដ៏លាមក ឥច្ឆាដ៏លាមក មិនគ្របសង្កត់ទេ ភិក្ខុនោះ អ្នកទាំងឡាយ គប្បីដឹងយ៉ាងនេះថា លោកៈ មិនមានដល់បុគ្គលដែលដឹងច្បាស់ យ៉ាងណា លោកដ៏មានអាយុនេះ ក៏ដឹងច្បាស់យ៉ាងនោះដែរ ហេតុដូច្នោះ បានជាលោកៈមិនគ្របសង្កត់លោកដ៏មានអាយុនេះ ។ ទោសៈ មិនមានដល់បុគ្គលដែលដឹងច្បាស់យ៉ាងណា លោកដ៏មានអាយុនេះ ក៏ដឹងច្បាស់យ៉ាងនោះដែរ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សាដ៏លាមក ឥច្ឆាដ៏លាមក មិនមាន ហេតុដូច្នោះ បានជាឥច្ឆាដ៏លាមក មិនគ្របសង្កត់លោកដ៏មានអាយុនេះបានឡើយ ។ ម្នាលអាវុសោទាំងឡាយ ដូចជាបុរសស្តុកស្តម្ភមែន ហើយនិយាយថា អ្នកស្តុកស្តម្ភ អ្នកមានទ្រព្យមែន ហើយនិយាយថា អ្នកមានទ្រព្យ អ្នកមានភោគៈមែន ហើយនិយាយថា អ្នកមានភោគៈ កាលបើកិច្ចដែលត្រូវធ្វើដោយទ្រព្យណាមួយកើតឡើងហើយ បុរសនោះ ក៏អាចប្រមូលមកនូវទ្រព្យក្តី ស្រូវក្តី ប្រាក់ក្តី មាសក្តី អ្នកផង ត្រូវដឹងបុរសនោះយ៉ាងនេះថា អ្នកដ៏មានអាយុនេះ ជាអ្នកស្តុកស្តម្ភមែន ហើយនិយាយថា អ្នក

សុក្កសុក្ក អ្នកដ៏មានអាយុនេះ ជាអ្នកមានទ្រព្យមែន និយាយថា អ្នកមានទ្រព្យ អ្នកដ៏មានអាយុនេះ ជាអ្នកមានភោគៈមែន និយាយថា អ្នកមានភោគៈ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថា កាលបើកិច្ចដែលខ្លួនត្រូវធ្វើ ដោយទ្រព្យណាមួយកើតឡើងហើយ អ្នកដ៏មានអាយុនេះ ក៏អាចប្រមូលមកនូវទ្រព្យក្តី ស្រូវក្តី ប្រាក់ក្តី មាសក្តីបាន យ៉ាងណាមិញ ។ ម្នាលអាវុសោទាំងឡាយ កាលភិក្ខុនិយាយអួតញាណវាទ និងភាវនាវាទថា ខ្ញុំដឹងធម៌នេះ ឃើញធម៌នេះ ខ្ញុំជាអ្នកបានចម្រើនកាយ បានចម្រើនសីល បានចម្រើនចិត្ត បានចម្រើនប្រាជ្ញាហើយ ។ ម្នាលអាវុសោទាំងឡាយ បើជាលោភៈ មិនគ្របសង្កត់ភិក្ខុនោះ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សាដ៏លាមក ឥច្ឆាដ៏លាមក មិនគ្របសង្កត់ទេ ភិក្ខុនោះ អ្នកទាំងឡាយ គប្បីដឹងយ៉ាងនេះថា លោភៈ មិនមានដល់បុគ្គលដែលដឹងច្បាស់ យ៉ាងណា លោកដ៏មានអាយុនេះ ក៏ដឹងច្បាស់យ៉ាងនោះដែរ ហេតុដូច្នោះ បានជាលោភៈ មិនគ្របសង្កត់លោកដ៏មានអាយុនេះបាន ។ ទោសៈ មិនមានដល់បុគ្គលដែលដឹងច្បាស់ យ៉ាងណា លោកដ៏មានអាយុនេះ ក៏ដឹងច្បាស់យ៉ាងនោះដែរ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សាដ៏លាមក ឥច្ឆាដ៏លាមក មិនមាន ហេតុដូច្នោះ បានជាឥច្ឆាដ៏លាមកមិនគ្របសង្កត់លោកដ៏មានអាយុនេះ ។

# អដ្ឋកថា

## ចុន្ទសូត្រ

[ ២៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចុន្ទសូត្រទី ៤ ដូចតទៅនេះ ព្រះមហាចុន្ទពោលអាការនៃញាណទស្សនៈ ដោយបទថា **ជាឆាមិមំ ធម្មំ** នេះ ។ លោកពោលវាទៈទាំង ២ រួមគ្នា ក្នុងវារៈទី ៣ នៃការនៅវារៈ ដោយបទថា **ភាវិតកាយោម្ហិ** ជាដើម ។ វាទៈទាំង ៣ នោះ រមែងប្រែជាអរហត្តដូចគ្នា ។ បទថា **អឡាវាធំ វាទេយ្យ** សេចក្ដីថា គប្បីពោលអួតថា ខ្ញុំជាបុគ្គលមានការមាំទាំ ។ បទថា **ឧបនីហាតុំ** ប្រែថា ដើម្បីនាំចេញឲ្យ ។៚

អដ្ឋកថាចុន្ទសូត្រទី ៤ ចប់

# សុត្តន្តបិដក

## កសិណសូត្រទី ៥

[ ២៥ ] ម្នាលភិក្ខុទាំងឡាយ កសិណាយតនៈនេះមាន ១០ ប្រការ ។ កសិណាយតនៈ ១០ ប្រការ តើដូចម្ដេចខ្លះ ។ បុគ្គលមួយពួក ដឹងបឋវីកសិណ ទាំងខាងលើ ខាងក្រោម ទទឹង មិនមានគូ មិនមានប្រមាណ ១ បុគ្គលមួយពួក ដឹងអាបោកសិណ... ១ បុគ្គលមួយពួកដឹងតេជោកសិណ... ១ បុគ្គលមួយពួក ដឹងវាយោកសិណ... ១ បុគ្គលមួយពួកដឹងនីលកសិណ... ១ បុគ្គលមួយពួក

ដឹងបីតកសិណ... ១ បុគ្គលមួយពួកដឹងលោហិតកសិណ... ១ បុគ្គលមួយពួកដឹងឱទាតកសិណ... ១ បុគ្គលមួយពួកដឹងអាកាសកសិណ... ១ បុគ្គលមួយពួកដឹងវិញ្ញាណកសិណ ទាំងខាងលើ ខាងក្រោម ទទឹង មិនមានគូ មិនមានប្រមាណ ១ ។ ម្នាលភិក្ខុទាំងឡាយ កសិណាយតនៈ មាន ១០ ប្រការនេះឯង ។

# អដ្ឋកថា

## កសិណសូត្រ

[ ២៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកសិណសូត្រទី ៥ ដូចតទៅនេះ ឈ្មោះថា **កសិណ** ព្រោះអត្ថថា ទាំងមូល ឈ្មោះថា **អាយតន** ព្រោះអត្ថថា ជាខេត្តនៃធម៌ទាំងឡាយ មានកសិណនោះជាអារម្មណ៍ ឬព្រោះអត្ថថា តាំងទុក ។ ហេតុនោះ ទើបឈ្មោះថា **កសិណាយតន** គឺជាប្រកពកើតនៃអារម្មណ៍ដែលជាកសិណ ។ បទថា **ឧទ្ធំ** បានដល់ ងើយមើលអាកាសខាងលើ ។ បទថា **អធោ** បានដល់ ឈ្ងោកមើលផែនដីខាងក្រោម ។ បទថា **តិរិយំ** បានដល់ កំណត់ជុំវិញ ដូចវាលស្រែ ។ ពិតហើយ ព្រះយោគាវចរ រូបខ្លះ ចម្រើនកសិណខាងលើប៉ុណ្ណោះ រូបខ្លះ ចម្រើនខាងក្រោម រូបខ្លះ ក៏ប្រាសយ៉ាងនេះ ដោយអាការនោះៗ ក្នុងទីជុំវិញ ដូចត្រូវការមើល

រូបដែលមានពន្លឺ ដោយហេតុនោះ ទើបព្រះថេរៈពោលថា **បឋវីកសិណ-មេកោ សញ្ជានាតិ ឧទ្ធំ អធោ តិរិយំ។** បទថា **អទ្វយំ** នេះ លោកពោលដើម្បីកសិណណាមួយ មិនប្រែជាដទៃ ឧបមាដូចកាលព្រះយោគាវចរចូលទៅកាន់ទឹក គឺអាបោកសិណ គ្រប់ទិសក៏មានទឹកតែម្យ៉ាង មិនមានអ្វីដទៃ យ៉ាងណា បឋវីកសិណ ក៏ដូច្នោះដូចគ្នា រមែងជាបឋវីកសិណតែម្យ៉ាង មិនលាយដោយកសិណដទៃ ក្នុងកសិណទាំងពួង ក៏ន័យនេះដូចគ្នា ។ ពាក្យថា **អប្បមាណំ** នេះ លោកពោលដោយអំណាចការផ្សាយកសិណនោះៗ ទៅមិនមានប្រមាណ ។ ពិតហើយ ព្រះយោគាវចរកាលផ្សាយកសិណនោះដោយចិត្ត រមែងផ្សាយទូទៅនោះឯង មិនកាន់យកប្រមាណថា នេះជាខាងដើមរបស់កសិណនោះ នេះជាកណ្តាល ។ ក្នុងបទថា **វិញ្ញាណកសិណំ** នេះ វិញ្ញាណប្រព្រឹត្តទៅក្នុងអាកាស ដែលបើកកសិណ ពិតហើយ វិញ្ញាណនោះ លោកហៅថា វិញ្ញាណ គប្បីជ្រាបភាពជាខាងលើ ខាងក្រោម ទទឹង ក្នុងវិញ្ញាណ ដែលប្រព្រឹត្តទៅក្នុងវិញ្ញាណកសិណនោះ ដោយអំណាចអាកាសដែលបើកកសិណ ។ នេះជាសេចក្តីសង្ខេបក្នុងវិញ្ញាណកសិណនោះ ។ ឯកសិណ មានបឋវីកសិណជាដើមនោះ ក៏ពោលពិស្តារហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គ ក្នុងកម្មដ្ឋានភាវនានោះឯង ៕

**អដ្ឋកថា កសិណសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## កាឡីសូត្រទី ៦

[ ២៦ ] សម័យមួយ ព្រះមហាកច្ចានៈ គង់នៅបវត្តបពិត ជិតក្រុងកុររឃរៈ ក្នុងដែនអវន្តី ។ គ្រានោះ នាងកាលីឧបាសិកា នៅក្នុងក្រុងឈ្មោះកុររឃរៈ ចូលទៅរកព្រះមហាកច្ចានៈដ៏មានអាយុ លុះចូលទៅដល់ ថ្វាយបង្គំព្រះកច្ចានៈដ៏មានអាយុ ហើយអង្គុយក្នុងទីសមគួរ ។ លុះនាងកាលី-ឧបាសិកានៅក្នុងក្រុងឈ្មោះកុររឃរៈ អង្គុយក្នុងទីសមគួរហើយ ក៏ទូលព្រះមហាកច្ចានៈដ៏មានអាយុដូច្នេះថា បពិត្រលោកដ៏ចម្រើន ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ក្នុងកុមារីបញ្ហាថា

ការសម្រេចប្រយោជន៍ ជាសេចក្ដីស្ងប់រម្ងាប់នៃហឫទ័យតថាគត
ម្នាក់ឯង បានឈ្នះនូវកិលេសសេនា ជាទីស្រឡាញ់ ជាទីត្រេកអរ
បានឈាន ត្រាស់ដឹងនូវព្រះនិព្វាន ជាសុខ ហេតុនោះ តថាគត
មិនធ្វើសាក្សីដោយសារជនទេ សាក្សី ( មិត្តធម៌ ) ដោយជន
ណាមួយ មិនសម្រេចដល់តថាគតឡើយ ។

បពិត្រលោកដ៏ចម្រើន សេចក្ដីនៃភាសិត ដែលព្រះដ៏មានព្រះភាគសម្ដែងដោយសង្ខេបនេះ យើងគប្បីយល់ដោយពិស្ដារដូចម្ដេចបាន ។ ម្នាលនាងពួកសមណព្រាហ្មណ៍ខ្លះ ចូលកាន់បឋវីកសិណដ៏ឧត្ដម ហើយញុំាងបឋវី-កសិណនោះឲ្យកើត ដោយប្រកាន់ថាជាប្រយោជន៍ ។ ម្នាលនាង ព្រះដ៏មានព្រះភាគ បានត្រាស់ដឹងនូវការចូលកាន់បឋវីកសិណដ៏ឧត្ដមនោះ ព្រះដ៏មាន

ព្រះភាគ បានជ្រាបច្បាស់នូវការចូលកាន់បឋវីកសិណដ៏ឧត្តមនោះ ហើយបាន ឃើញខាងដើម គឺសមុទយសច្ច បានឃើញទោស គឺទុក្ខសច្ច បានឃើញនូវ ធម៌ជាគ្រឿងរលាស់ គឺនិរោធសច្ច បានឃើញមគ្គាមគ្គញ្ញាណទស្សនៈ គឺ មគ្គសច្ច ព្រះអង្គបានជ្រាបនូវការសម្រេចប្រយោជន៍ ជាការស្ងប់នៃហឫទ័យ ព្រោះហេតុនៃការឃើញខាងដើម ព្រោះហេតុនៃការឃើញទោស ព្រោះហេតុ នៃការឃើញនូវធម៌ ជាគ្រឿងរលាស់ ព្រោះហេតុនៃការឃើញនូវមគ្គា-មគ្គញ្ញាណ ។ ម្នាលនាង ... ចូលកាន់អាបោកសិណដ៏ឧត្តម ម្នាលនាង ... ចូលកាន់តេជោកសិណដ៏ឧត្តម ម្នាលនាង ... ចូលកាន់វាយោកសិណដ៏ឧត្តម ម្នាលនាង ... ចូលកាន់នីលកសិណដ៏ឧត្តម ម្នាលនាង ... ចូលកាន់បីតកសិណ ដ៏ឧត្តម ម្នាលនាង ... ចូលកាន់លោហិតកសិណដ៏ឧត្តម ម្នាលនាង ... ចូល កាន់ឱទាតកសិណដ៏ឧត្តម ម្នាលនាង ... ចូលកាន់អាកាសកសិណដ៏ឧត្តម ម្នាលនាង ពួកសមណព្រាហ្មណ៍ខ្លះ ចូលកាន់វិញ្ញាណកសិណដ៏ឧត្តម ហើយ ញុំាងវិញ្ញាណកសិណ ( នោះ ) ឲ្យកើត ដោយប្រកាន់ថាជាប្រយោជន៍ ។ ម្នាលនាង ព្រះដ៏មានព្រះភាគ បានជ្រាបច្បាស់នូវការចូលកាន់វិញ្ញាណកសិណ ដ៏ឧត្តមនោះ លុះព្រះដ៏មានព្រះភាគ បានជ្រាបច្បាស់នូវការចូលកាន់វិញ្ញាណ-កសិណដ៏ឧត្តមនោះហើយ បានឃើញខាងដើម បានឃើញទោស បានឃើញ ធម៌ជាគ្រឿងរលាស់ បានឃើញមគ្គាមគ្គញ្ញាណទស្សនៈ ព្រះអង្គជ្រាបនូវការ បានសម្រេចប្រយោជន៍ ជាការស្ងប់ហឫទ័យ ព្រោះហេតុនៃការឃើញខាងដើម

ព្រោះហេតុនៃការឃើញទោស ព្រោះហេតុនៃការឃើញធម៌ជាគ្រឿងរលាស់ ព្រោះហេតុនៃការឃើញមគ្គាមគ្គញ្ញាណ ។ ម្នាលនាង ព្រះដ៏មានព្រះភាគ បានត្រាស់ពាក្យណា ក្នុងកុមារីបញ្ហាទាំងឡាយថា

ការសម្រេចប្រយោជន៍ ជាសេចក្ដីស្ងប់ នៃហឫទ័យតថាគត ម្នាក់ឯង បានឈ្នះនូវកិលេសសេនា ជាទីស្រឡាញ់ ជាទីត្រេកអរ បានឈាន ត្រាស់ដឹងនូវព្រះនិព្វានជាសុខ ហេតុនោះ តថាគតមិនធ្វើសាក្សី ដោយសារជនទេ សាក្សីដោយសារជន ( ណាមួយ ) មិនសម្រេចដល់តថាគតឡើយ ។

ម្នាលនាង សេចក្ដីនៃភាសិត ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្ដែងដោយសង្ខេបនេះឯង យើងគប្បីដឹងដោយពិស្ដារយ៉ាងនេះ ។

# អដ្ឋកថា

## កាឡីសូត្រ

[ ២៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកាឡីសូត្រទី ៦ ដូចតទៅនេះ បទថា **កុមារីបញ្ហេសុ** បានដល់ ក្នុងពាក្យសួររបស់ធីតាមារ ដែលនៅជាកុមារី ។ ត្រាស់ព្រះអរហត្តតែម្យ៉ាង ដោយបទទាំង ២ ថា **អត្ថស្ស បត្តិំ ហទយស្ស សន្តិំ** ការសម្រេចប្រយោជន៍ ជាការស្ងប់នៃព្រះហឫទ័យ ។ បទថា **សេនំ**

*បានដល់ កង្វល់កិលេស មានរាគៈជាដើម ។ បទថា* **បិយសាតរូបំ** *បាន ឈ្មោះយ៉ាងនេះ ក៏ព្រោះកិលេសកើតក្នុងវត្ថុទាំងឡាយ ដែលគួរស្រឡាញ់ និង គួរត្រេកអរ ។ បទថា* **ឯកោហំ ឈាយី សុខមានុពោធឹ** *សេចក្តីថា តថាគតប៉ុណ្ណោះ នឹងស្គាល់កង្វល់កិលេសយ៉ាងនេះ ទើបចូលឈាន ត្រាស់ ដឹងបានដោយងាយ ។ បទថា* **សក្ខី** *សេចក្តីថា បានដល់ ប្រចក្សធម៌ដែល ដល់នូវការប្រចក្ស ។ បទថា* **សក្ខី ន សម្បជ្ជតិ កេនចិ មេ** *សេចក្តីថា តថាគតមិនមានមិត្តជាមួយបុគ្គលណាម្នាក់ឡើយ ។*

*បទថា* **បឋវីកសិណសមាបត្តិបរមា ខោ ភគិនិ ឯកេ សមណ-ព្រាហ្មណា អត្ថាភិនិព្វត្តេសុំ** *សេចក្តីថា សមណព្រាហ្មណ៍ពួកមួយប្រកាន់ ថា បឋវីកសិណសមាបត្តិជាប្រយោជន៍ដ៏ក្រៃលែង ទើបធ្វើឲ្យកើត ។ បទថា* **យាវតា ខោ ភគិនិ បឋវីកសិណសមាបត្តិបរមតា** *សេចក្តីថា ភាព ដែលប្រយោជន៍ មានបឋវីកសិណសមាបត្តិ មានកំពូលខ្ពស់បំផុត ប្រមាណ ត្រឹមណា ។ បទថា* **តទភិញ្ញាសិ ភគវា** *បានដល់ ព្រះមានព្រះភាគទ្រង់ ដឹងច្បាស់នូវបឋវីកសិណសមាបត្តិនោះ ដោយការដឹងក្រៃលែងនូវប្រយោជន៍ នោះ ដោយព្រះបញ្ញា ។ បទថា* **អាទិមទ្ទស** *បានដល់ ទ្រង់បានឃើញ សមុទយសច្ច ។ បទថា* **អាទីនវមទ្ទស** *បានដល់ ទ្រង់បានឃើញទុក្ខសច្ច ។ បទថា* **និស្សរណមទ្ទស** *បានដល់ ទ្រង់បានឃើញនិរោធសច្ច ។ បទថា* **មគ្គាមគ្គញ្ញាណទស្សនមទ្ទស** *បានដល់ ទ្រង់ឃើញមគ្គសច្ច ។ បទថា*

**អត្ថស្ស បត្តិ** បានដល់ ការសេពប្រយោជន៍ ពោល គឺអរហត្ត ព្រោះ ឃើញសច្ចៈទាំង ៤ នេះ ជាការស្ងប់នៃព្រះហឫទ័យ ព្រោះការក្រវល់ក្រវាយ និងការក្តៅក្រហាយស្ងប់ទៅ ។

**អដ្ឋកថា កាឡីសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## បឋមមហាបញ្ហាសូត្រទី ៧

[ ២៧ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ពួកភិក្ខុច្រើនរូប ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថី ។ លំដាប់នោះ ភិក្ខុទាំងនោះ មានសេចក្តីត្រិះរិះដូច្នេះថា ការត្រាច់ទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថីនៅព្រឹកពេក បើដូច្នោះ គួរយើងចូលទៅឯអារាម នៃពួកបរិព្វាជក ជាអន្យតិរ្ថិយសិនចុះ ។ លំដាប់នោះ ភិក្ខុទាំងនោះ ក៏ចូលទៅឯអារាមរបស់បរិព្វាជក ជាអន្យតិរ្ថិយ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររព្ញកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក៏ពួកបរិព្វាជកអន្យតិរ្ថិយទាំងនោះ

បាននិយាយថា ម្នាលអាវុសោទាំងឡាយ សមណគោតមតែងសំដែងធម៌ដល់សាវកទាំងឡាយ យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរមកនេះ អ្នកទាំងឡាយ ចូរដឹងច្បាស់នូវធម៌ទាំងពួង អ្នកទាំងឡាយ ចូរត្រាស់ដឹងរឿយៗ នូវធម៌ទាំងពួង ។ ម្នាលអាវុសោទាំងឡាយ ពួកយើងក៏សំដែងធម៌ដល់ពួកសាវកយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ ចូរចូលមកនេះ អ្នកទាំងឡាយ ចូរដឹងច្បាស់នូវធម៌ទាំងពួង អ្នកទាំងឡាយ ចូរត្រាស់ដឹងរឿយៗ នូវធម៌ទាំងពួង ។ ម្នាលអាវុសោទាំងឡាយ ដូចយ៉ាងធម្មទេសនាជាមួយនឹងធម្មទេសនាក្តី ពាក្យប្រៀនប្រដៅជាមួយនឹងពាក្យប្រៀនប្រដៅក្តី របស់សមណគោតម នឹងយើងនេះ តើមានសេចក្តីប្លែកគ្នាដូចម្តេច មានអធិប្បាយដូចម្តេច មានដំណើរផ្សេងៗ គ្នាដូចម្តេច ។ លំដាប់នោះ ភិក្ខុទាំងនោះ ក៏មិនត្រេកអរ មិនទទឹងទាស់ នឹងភាសិតរបស់ពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ លុះមិនត្រេកអរ មិនទទឹងទាស់ហើយ ក៏ក្រោកចាកអាសនៈចៀសចេញទៅ ដោយគិតថា យើងទាំងឡាយ នឹងយល់សេចក្តីនៃភាសិតនុ៎ះ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគចុះ ។ គ្រានោះ ភិក្ខុទាំងនោះ ក៏ត្រាច់ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាជាខាងក្រោយភត្តហើយ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួររួចហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏

ចម្រើន ក្នុងទីឯណោះ យើងខ្ញុំទាំងឡាយ ស្លៀកស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ។ បពិត្រព្រះអង្គ ដ៏ចម្រើន យើងខ្ញុំទាំងនោះ មានសេចក្ដីត្រិះរិះដូច្នេះថា ការត្រាច់ទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថី នៅព្រឹកពេកនៅឡើយ បើដូច្នោះ គួរតែយើងឈានចូលទៅ ឯអារាមរបស់ពួកបរិព្វាជក ជាអន្យតិរ្ថិយសិនចុះ ។ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ ពួកយើងខ្ញុំក៏បានចូលទៅឯអារាម របស់ពួកបរិព្វាជកជាអន្យ-តិរ្ថិយ លុះចូលដល់ហើយ ក៏ធ្វើសេចក្ដីរីករាយ ជាមួយនឹងពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ បពិត្រព្រះអង្គដ៏ចម្រើន លុះពួកយើងខ្ញុំ អង្គុយក្នុងទីសមគួរហើយ ពួកបរិព្វាជកជាអន្យតិរ្ថិយ បាននិយាយពាក្យដូច្នេះ ថា ម្នាលអាវុសោទាំងឡាយ សមណគោតម តែងសម្ដែងធម៌ដល់ពួកសាវក យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចូលមកនេះ អ្នកទាំង-ឡាយ ចូរដឹងច្បាស់នូវធម៌ទាំងពួង អ្នកទាំងឡាយ ចូរត្រាស់ដឹងរឿយៗ នូវ ធម៌ទាំងពួង ។ ម្នាលអាវុសោទាំងឡាយ ពួកយើងក៏សម្ដែងធម៌ ដល់ពួក សាវកយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ ចូរចូលមកនេះ អ្នកទាំងឡាយ ចូរដឹងច្បាស់នូវធម៌ទាំងពួង អ្នកទាំងឡាយ ចូរត្រាស់ដឹង រឿយៗ នូវធម៌ទាំងពួងដែរ ។ ម្នាលអាវុសោទាំងឡាយ ដូចយ៉ាងធម្មទេសនា ជាមួយនឹងធម្មទេសនាក្ដី ពាក្យប្រដៅជាមួយនឹងពាក្យប្រដៅក្ដី របស់សមណ-

គោតមទឹងយើងនេះ តើមានសេចក្តីប្លែកគ្នាដូចម្តេច មានអធិប្បាយដូចម្តេច មានដំណើរផ្សេងៗ គ្នាដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ ពួកយើងខ្ញុំមិនត្រេកអរ មិនទទឹងទាស់នឹងភាសិតរបស់ពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះទេ លុះមិនត្រេកអរ មិនទទឹងទាស់ហើយ ក៏ក្រោកចាកអាសនៈ ចៀសចេញទៅ ដោយគិតថា ពួកយើងនឹងយល់សេចក្តីនៃភាសិតនុ៎ះ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគចុះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវនិយាយយ៉ាងនេះ នឹងពួកបរិព្វាជកជាអន្យតិរ្ថិយ ដែលមានវាទៈយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ចុះបញ្ហា ១ ឧទ្ទេស ១ វេយ្យាករណ៍ ១ បញ្ហា ២ ឧទ្ទេស ២ វេយ្យាករណ៍ ២ បញ្ហា ៣ ឧទ្ទេស ៣ វេយ្យាករណ៍ ៣ បញ្ហា ៤ ឧទ្ទេស ៤ វេយ្យាករណ៍ ៤ បញ្ហា ៥ ឧទ្ទេស ៥ វេយ្យាករណ៍ ៥ បញ្ហា ៦ ឧទ្ទេស ៦ វេយ្យាករណ៍ ៦ បញ្ហា ៧ ឧទ្ទេស ៧ វេយ្យាករណ៍ ៧ បញ្ហា ៨ ឧទ្ទេស ៨ វេយ្យាករណ៍ ៨ បញ្ហា ៩ ឧទ្ទេស ៩ វេយ្យាករណ៍ ៩ បញ្ហា ១០ ឧទ្ទេស ១០ វេយ្យាករណ៍ ១០ ( តើដូចម្តេច ) ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ សួរយ៉ាងនេះហើយ ពួកបរិព្វាជកជាអន្យតិរ្ថិយ ក៏ឆ្លើយមិនរួចទាំងបានសេចក្តីចង្អៀតចង្អល់ថែមទៀតផង ។ ដំណើរនោះ ព្រោះអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា មិនមែនជាវិស័យរបស់ខ្លួនទេ ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស

តថាគតមិនដែលឃើញអ្នកណាមួយ អាចញ៉ាំងចិត្តតថាគតឲ្យត្រេកអរ ដោយការធ្វើយនូវបញ្ហាទាំងនេះបានឡើយ លើកលែងតែព្រះតថាគត ឬសាវករបស់ព្រះតថាគត ឬក៏អ្នកធ្លាប់ស្តាប់ អំពីសម្នាក់ព្រះតថាគតចេញ ។ ពាក្យថា បញ្ហា ១ ឧទ្ទេស ១ វេយ្យាករណ៍ ១ ដូច្នេះនុ៎ះ តថាគតពោលហើយ ចុះពាក្យដែលតថាគតពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលភិក្ខុទាំង-ឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌មួយ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌មួយ គឺអ្វី ។ គឺពួកសត្វទាំងពួង រស់នៅដោយសារអាហារ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌មួយនេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលតថាគតពោលថា បញ្ហា ១ ឧទ្ទេស ១ វេយ្យាករណ៍ ១ ដូច្នេះ ពាក្យនុ៎ះ ដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុនោះ ។ ពាក្យថា បញ្ហា ២ ឧទ្ទេស ២ វេយ្យាករណ៍ ២ ដូច្នេះនុ៎ះ តថាគតពោលហើយ ពាក្យដែលតថាគតពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ ២ រមែងធ្វើ

នូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ២ គឺអ្វី ។ គឺនាម ១ រូប ១ ។ ម្នាល ភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ទាំង ២ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណាដែលតថាគតពោលថា បញ្ហា ២ ឧទ្ទេស ២ វេយ្យាករណ៍ ២ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។ ពាក្យថា បញ្ហា ៣ ឧទ្ទេស ៣ វេយ្យាករណ៍ ៣ ដូច្នេះនុ៎ះ តថាគតពោលហើយ ពាក្យដែលតថាគតពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ ៣ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៣ គឺអ្វីខ្លះ ។ គឺវេទនាទាំង ៣ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ទាំង ៣ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលតថាគតពោលថា បញ្ហា ៣ ឧទ្ទេស ៣ វេយ្យាករណ៍ ៣ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។ ពាក្យថា បញ្ហា ៤ ឧទ្ទេស ៤ វេយ្យាករណ៍ ៤ ដូច្នេះនុ៎ះ តថាគតពោលហើយ ពាក្យដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុ

អ្វី ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ ៤ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៤ គឺអ្វី ។ គឺអាហារទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ទាំង ៤ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណាដែលតថាគតពោលថា បញ្ហា ៤ ឧទ្ទេស ៤ វេយ្យាករណ៍ ៤ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។ ពាក្យថា បញ្ហា ៥ ឧទ្ទេស ៥ វេយ្យាករណ៍ ៥ ដូច្នេះនុ៎ះ តថាគតពោលហើយ ចុះពាក្យដែលតថាគតពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ ៥ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៥ គឺអ្វីខ្លះ ។ គឺឧបាទានក្ខន្ធទាំង ៥ ។ ម្នាលភិក្ខុទាំង-ឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ទាំង ៥ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណាដែលតថាគតពោលថា បញ្ហា ៥ ឧទ្ទេស ៥ វេយ្យាករណ៍ ៥ ដូច្នេះ ពាក្យ

នុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។ ពាក្យថាបញ្ហា ៦ ឧទ្ទេស ៦ វេយ្យាករណ៍ ៦ ដូច្នេះនុ៎ះ តថាគតពោលហើយ ចុះពាក្យដែលតថាគតពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ ៦ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៦ គឺអ្វី ។ គឺអាយតនៈខាងក្នុងទាំង ៦ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ទាំង ៦ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នបាន ។ ពាក្យណាដែលតថាគតពោលថា បញ្ហា ៦ ឧទ្ទេស ៦ វេយ្យាករណ៍ ៦ ដូច្នេះនុ៎ះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។ ពាក្យថា បញ្ហា ៧ ឧទ្ទេស ៧ វេយ្យាករណ៍ ៧ ដូច្នេះនុ៎ះ តថាគតពោលហើយ ចុះពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ ៧ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៧ គឺអ្វី ។ គឺវិញ្ញាណដ្ឋិតិទាំង ៧ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុត

នៃទុក្ខដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ទាំង ៧ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នបាន ។ ពាក្យណាដែលតថាគតពោលថា បញ្ហា ៧ ឧទ្ទេស ៧ វេយ្យាករណ៍ ៧ ដូច្នេះនុ៎ះ ពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។ ពាក្យថាបញ្ហា ៨ ឧទ្ទេស ៨ វេយ្យាករណ៍ ៨ ដូច្នេះនុ៎ះ តថាគតពោលហើយ ចុះពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនៀយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតនៃទុក្ខដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ ៨ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៨ គឺអ្វី ។ គឺលោកធម៌ទាំង ៨ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនៀយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតនៃទុក្ខដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ទាំង ៨ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នបាន ។ ពាក្យណាដែលតថាគតពោលថា បញ្ហា ៨ ឧទ្ទេស ៨ វេយ្យាករណ៍ ៨ ដូច្នេះ ពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។ ពាក្យថាបញ្ហា ៩ ឧទ្ទេស ៩ វេយ្យាករណ៍ ៩ ដូច្នេះនុ៎ះ តថាគតពោលហើយ ចុះពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនៀយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ ៩ រមែងធ្វើនូវទី

បំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៩ គឺអ្វី ។ គឺសត្តាវាសទាំង ៩ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ទាំង ៩ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណាដែលតថាគតពោលថា បញ្ហា ៩ ឧទ្ទេស ៩ វេយ្យាករណ៍ ៩ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។ ពាក្យថា បញ្ហា ១០ ឧទ្ទេស ១០ វេយ្យាករណ៍ ១០ ដូច្នេះនុ៎ះ តថាគតពោលហើយ ចុះពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ទាំង ១០ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ទាំង ១០ គឺអ្វី ។ គឺអកុសលកម្មបថទាំង ១០ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ទាំង ១០ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណាដែលតថាគតពោលថា បញ្ហា ១០ ឧទ្ទេស ១០ វេយ្យាករណ៍ ១០ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

# អដ្ឋកថា

## បឋមមហាបញ្ហាសូត្រ

[ ២៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមមហាបញ្ហាសូត្រទី ៧ ដូចតទៅនេះ បទថា **អភិជានាថ** បានដល់ ដឹងក្រៃលែង ធ្វើឲ្យប្រចក្ស ។ បទថា **អភិញ្ញាយ** ប្រែថា ដឹងក្រៃលែង ។ បទថា **ឥធ** ប្រែថា ក្នុងធម្មទេសនា ឬ អនុសាសនីនេះ ។ បទថា **ធម្មទេសនាយ វា ធម្មទេសនំ** សេចក្តីថា ពួកតិរ្ថិយពោលថា ពួកអ្នកប្រាប្តាធម្មទេសនារបស់យើង និងព្រះធម្មទេសនារបស់ព្រះសមណគោតម ឬព្រះធម្មទេសនារបស់ព្រះសមណគោតម និងធម្មទេសនារបស់យើង ហើយពោលថា ផ្សេងគ្នា តើផ្សេងគ្នាដូចម្តេច ។ ក្នុងបទទី ២ ក៏ន័យនេះដូចគ្នា ។ ដូច្នោះ ទើបពួកតិរ្ថិយទាំងនោះ តាំងលទ្ធិរបស់ខ្លួនប្រៀបធៀបនឹងព្រះសាស្តាថា មានធុរៈស្មើគ្នាត្រឹមតែពាក្យពោលដូចតាំងមាសដែលប្រហោង ដូច្នោះ ។ បទថា **នេវ អភិនន្ទឹសុ** បានដល់ មិនទទួលថា សេចក្តីនោះយ៉ាងនោះ ។ បទថា **នប្បដិក្កោសឹសុ** បានដល់ មិនបដិសេធថា សេចក្តីនេះមិនដូច្នោះឡើយ ព្រោះហេតុអ្វី បានឮថា ពួកភិក្ខុទាំងនោះមិនទទួល ដោយគិតថា ឈ្មោះថា ពួកតិរ្ថិយ ជាពួកខ្វាក់ភ្នែក ទោះដឹង ឬមិនដឹងក៏ពោលទៅ ។ បទថា **នេវ សម្បាយិស្សន្តិ** បានដល់ នឹងឆ្លើយមិនបាន ។ បទថា **ឧត្តរឹបិ វិឃាតំ** បានដល់ នឹងជួបនូវទុក្ខក្រៃលែង ព្រោះឆ្លើយមិនបាន កាលពួកតិរ្ថិយឆ្លើយមិនបាន ក៏កើតទុក្ខ ។ ពាក្យថា **តំ** ក្នុងបាលីថា **យថាតំ ភិក្ខវេ អវិសយស្មឹ** នេះ ត្រឹមតែជានិបាត ។ បទថា

**យថា** ជាពាក្យពោលដល់ហេតុ ។ អធិប្បាយថា ពួកតិរ្ថិយត្រូវសួរបញ្ហាក្នុងវត្ថុដែលមិនមែនវិស័យ ព្រោះហេតុណា ។ បទថា **ឥតោ វា បន សុត្វា** ប្រែថា ឬស្តាប់អំពីសាសនារបស់យើងនេះ ។ ពិតហើយ បុគ្គលនោះស្តាប់អំពីសាសនានេះ គឺអំពីព្រះតថាគតខ្លះ អំពីសាវករបស់ព្រះតថាគតខ្លះ ។ បទថា **អារាធេយ្យ** ប្រែថា គប្បីត្រេកអរ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងថា ឈ្មោះថា ការត្រេកអរដោយប្រការដទៃមិនមាន ។ បទថា **ឯកធម្មេ** ប្រែថា ក្នុងធម៌ឯណានីមួយ ។ ទ្រង់សម្តែងឧទ្ទេសដោយបទនេះ ។

ដោយបរន័យ ទ្រង់សម្តែងបញ្ហាដោយបទនេះថា **កតមស្មឹ ឯកធម្មេ** ។ ពាក្យថា **សព្វេ សត្តា អាហារដ្ឋិតិកា** នេះ ជាពាក្យវេយ្យាករណ៍ ឆ្លើយក្នុងបញ្ហានេះ ក្នុងបញ្ហាដ៏សេសក៏ន័យនេះដូចគ្នា ។ ក្នុងពាក្យថា **សម្មា និព្វិន្ទមានោ** ជាដើម សេចក្តីថា ការនឿយណាយ គឺដកឡើងដោយនិព្វិទានុបស្សនាញាណ ប្រាសចាកតម្រេកដោយវិរាគានុបស្សនាញាណ ដឹងឧបាយនៃការរួចផុតហើយ ផុតដោយបដិសង្ខានុបស្សនាញាណ ឬផុតដោយអំណាចអធិមោក្ខ ធ្វើនូវការដាក់ចិត្តដោយប្រពៃ គឺដោយហេតុ ដោយន័យ ។ ឈ្មោះថា មានប្រក្រតីឃើញទីបំផុតដោយជុំវិញ ព្រោះកំណត់ដោយការកើត និងការវិនាស ហើយឃើញខាងដើម ខាងចុង ។ បទថា **សម្មត្តាភិសមេច្ច** បានដល់ ត្រាស់ដឹងប្រយោជន៍នៃសភាវៈដោយប្រពៃ ដោយញាណ ។ បទថា **ទុក្ខស្សន្តករោ ហោតិ** បានដល់ ធ្វើទីបំផុតនៃវដ្តទុក្ខទាំងមូល ។ បទថា

**សព្វេ សត្តា** បានដល់ សត្វគ្រប់ប្រភេទក្នុងភពទាំងពួង មានកាមភពជាដើម មានសញ្ញាភពជាដើម ។ និងមានឯកវោការភពជាដើម ។ បទថា **អាហារដ្ឋិតិកា** បានដល់ សត្វទាំងពួង ឈ្មោះថា អាហារដ្ឋិតិកា ព្រោះតាំងជីវិតនៅដោយអាហារ ។ ធម៌ ១ ឈ្មោះថា អាហារ ព្រោះជាហេតុតាំងនៅនៃសត្វទាំងពួង ដោយប្រការដូច្នេះ ។ ក្នុងធម៌ ១ នោះ ។ សួរថា កាលបើដូច្នោះ ពាក្យណាដែលត្រាស់ថា អសញ្ញីសត្វមិនមានហេតុ មិនមានអាហារ មិនមានផស្សៈជាដើម ក៏មិនខុសហើយឬ ។ ឆ្លើយថា មិនខុសទេ ព្រោះឈានរបស់អសញ្ញីសត្វទាំងនោះឯងជាអាហារ ។ សួរថា កាលបើដូច្នោះ ពាក្យថា ម្នាលភិក្ខុទាំងឡាយ អាហារទាំង ៤ នោះ ក៏ខុស ។ ឆ្លើយថា មិនខុសទេ ព្រោះក្នុងព្រះសូត្រនោះ ធម៌ទាំងឡាយ មានលក្ខណៈជាអាហារ ត្រាស់ថា អាហារដោយត្រង់ ។ ចំណែកក្នុងព្រះសូត្រនេះ បច្ច័យទាំងឡាយ ត្រាស់ថា អាហារដោយអម ។ ពិតហើយ បច្ច័យនៃធម៌ទាំងអស់ គួរបានឈ្មោះថា អាហារ ដ្បិតថា បច្ច័យនោះញុំាងផលណាឲ្យកើត ក៏ឈ្មោះថា រមែងនាំផលនោះមក ព្រោះដូច្នោះ ទើបបច្ច័យលោកហៅថា អាហារ ។ ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សូម្បីអវិជ្ជាក៏មានអាហារ មិនពោលថា មិនមានអាហារឡើយ ម្នាលភិក្ខុទាំងឡាយ អ្វីជាអាហាររបស់អវិជ្ជា គួរពោលថា នីវរណៈ ៥ ។ ក្នុងព្រះសូត្រនេះ ទ្រង់បំណងយកបច្ចយាហារនេះ ។ កាលទ្រង់កាន់យកបច្-

យាហារម៉្យាងហើយ ព្រមទាំងអាហារដោយអម និងអាហារដោយត្រង់ ក៏ឈ្មោះថា ទ្រង់កាន់យកទាំងអស់នោះឯង ។ ក្នុងអសញ្ញីភពនោះ រមែងបានបច្ចយាហារ កាលទ្រង់មិនទាន់កើតឡើង សត្វទាំងឡាយបួសក្នុងលទ្ធិតិរ្ថិយ ធ្វើបរិកម្មក្នុងវាយោកសិណ ធ្វើឈានឲ្យកើត ចេញចាកឈាននោះឯង កើតនូវការពេញចិត្ត ពេញថ្លើមថា ចិត្តនេះហ្ន៎ មិនមានចិត្តខូចបាន គួរជាចិត្តល្អ ព្រោះអាស្រ័យចិត្ត ទើបកើតទុក្ខ មានការសម្លាប់ ការចងជាដើមជាបច្ច័យ កាលមិនមានចិត្ត ទុក្ខនោះក៏មិនមាន ដូច្នេះហើយ មិនទាន់វិនាសឈាន ធ្វើកាលកិរិយា កើតក្នុងអសញ្ញីភព ។ ឥរិយាបថណា ដែលបុគ្គលបានតាំងទុកហើយក្នុងមនុស្សលោក បុគ្គលនោះកើតតាមឥរិយាបថនោះ ដូចរូបចិត្រកម្មតាំងនៅ ៥០០ កប្ប ដូចដេកអស់កាលមានប្រមាណប៉ុណ្ណោះ ដូច្នោះ ។ ពួកសត្វបែបនេះ ក៏បានបច្ច័យជាអាហារ ។ ពិតហើយ សត្វទាំងនោះ ចម្រើនឈានណាមួយកើតហើយ ឈាននោះឯង ជាបច្ច័យរបស់សត្វទាំងនោះ ។ ព្រួញ ដែលបាញ់ទៅ ព្រោះកម្លាំងរហ័សនៃខ្សែធ្នូណា កម្លាំងរហ័សនៃខ្សែនៅមានព្រួញ ក៏នៅស្ទុះទៅបានដរាបនោះ យ៉ាងណា ដរាបណាដែលបច្ច័យ ដែលឈាននៅមាន ដរាបនោះ សត្វទាំងឡាយក៏តាំងនៅបាន យ៉ាងនោះ កាលបច្ច័យនៃឈាននោះអស់ហើយ សត្វទាំងនោះក៏ធ្លាក់ទៅ ( ចុតិ ) ដូចព្រួញដែលអស់កម្លាំង ដូច្នោះ ។ សួរថា សត្វនរកពួកណា លោកពោលថា មិនមែនអាស្រ័យផលនៃសេចក្តីព្យាយាមរស់នៅ មិនអាស្រ័យផលនៃ

បុណ្យរស់នៅ សត្វនរកទាំងនោះ មានអ្វីជាអាហារ ។ ឆ្លើយថា សត្វនរកទាំងនោះ មានកម្មតែម្យ៉ាងជាអាហារ ។ សួរថា អាហារមាន ៥ ឬ ឆ្លើយថា មិនគួរពោលថា អាហារមាន ៥ អាហារមិនមានដល់ ៥ ទេ ។ សួរថា បច្ច័យជាអាហារមិនមែនឬ ឆ្លើយថា លោកពោលយ៉ាងនេះថា ព្រោះដូច្នោះ សត្វទាំងឡាយកើតក្នុងនរកព្រោះកម្មណា កម្មនោះឯងជាអាហារ ព្រោះជាបច្ច័យនៃការតាំងនៅបាននៃសត្វទាំងនោះ ព្រោះដូច្នោះ លោកសំដៅយកកម្មណា ទើបពោលពាក្យនេះ សត្វនរកមិនទាន់ធ្វើកាលកិរិយាដរាបណា បាបកម្មនោះមិនទាន់អស់ ។ សូម្បីកពឡិង្ការាហារ គឺ អាហារជាពុំនូត ក៏មិនគួរជំទាស់គ្នា ក្នុងរឿងអាហារនេះ ។ សេចក្តីពិត ទឹកមាត់ដែលកើតក្នុងមាត់ក៏សម្រេចកិច្ចជាអាហារសម្រាប់សត្វទាំងនោះ ដ្បិតថា ទឹកមាត់ ក៏ជាទុក្ខ-វេទនីយប្បច្ច័យ គឺបច្ច័យដែលឲ្យសោយទុក្ខក្នុងនរក ជាសុខវេទនីយប្បច្ច័យ គឺបច្ច័យដែលឲ្យសោយសុខក្នុងស្ថានសួគ៌ ។ ដោយហេតុនេះ ទើបក្នុងកាមភពមានអាហារ ៤ ដោយត្រង់ ។ ក្នុងបណ្តារូបភព និងអរូបភព វៀរអសញ្ញភព អាហារ ៣ រមែងមានដល់ព្រហ្មដ៏សេស បច្ចយាហារ រមែងមានដល់អសញ្ញសត្វ និងសត្វដ៏សេស ព្រោះហេតុនោះ ទើបគួរជ្រាបថា សត្វទាំងអស់ តាំងនៅបានដោយអាហារ ដោយទំនងនេះ ។ ក្នុងរឿងអាហារនោះ គប្បីធ្វើការប្រកបសេចក្តីក្នុងទីគ្រប់អន្លើ ដោយអំណាចសច្ចៈ ៤ យ៉ាងនេះថា អាហារ ៤ ក្តី បច្ចយាហារណាមួយក្តី ជាទុក្ខសច្ច តណ្ហាមុនៗ ដែលមាន

អាហារជាសមុដ្ឋាន ជាសមុទយសច្ច ការមិនប្រព្រឹត្តទៅនៃសច្ចៈទាំង ២ ជានិរោធសច្ច បញ្ញាដែលដឹងនិរោធសច្ច ជាមគ្គសច្ច ។ល។

## អដ្ឋកថា បឋមមហាបញ្ហាសូត្រទី ៧ ចប់

# សុត្តន្តបិដក

## ទុតិយមហាបញ្ហាសូត្រទី ៨

[ ២៨ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទៀបក្រុងកជង្គលា ។ គ្រានោះ ពួកកជង្គលឧបាសក ( ឧបាសកអ្នកនៅក្នុងក្រុងកជង្គលា ) ជាច្រើនគ្នា បានចូលទៅរកកជង្គលាភិក្ខុនី ( ភិក្ខុនីនៅក្នុងក្រុងកជង្គលា ) លុះចូលទៅដល់ ថ្វាយបង្គំកជង្គលាភិក្ខុនីហើយ អង្គុយក្នុងទីសមគួរ ។ លុះពួកកជង្គលឧបាសក អង្គុយក្នុងទីសមគួរហើយ ក៏ពោលទៅនឹងកជង្គលាភិក្ខុនីថា បពិត្រនាងម្ចាស់ ពាក្យដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ក្នុងមហាបញ្ហាថា បញ្ហា ១ ឧទ្ទេស ១ វេយ្យាករណ៍ ១ បញ្ហា ២ ឧទ្ទេស ២ វេយ្យាករណ៍ ២ បញ្ហា ៣ ឧទ្ទេស ៣ វេយ្យាករណ៍ ៣ បញ្ហា ៤ ឧទ្ទេស ៤ វេយ្យាករណ៍ ៤ បញ្ហា ៥ ឧទ្ទេស ៥ វេយ្យាករណ៍ ៥ បញ្ហា ៦ ឧទ្ទេស ៦ វេយ្យាករណ៍ ៦ បញ្ហា ៧ ឧទ្ទេស ៧ វេយ្យាករណ៍ ៧ បញ្ហា ៨ ឧទ្ទេស ៨

វេយ្យាករណ៍ ៨ បញ្ហា ៩ ឧទ្ទេស ៩ វេយ្យាករណ៍ ៩ បញ្ហា ១០ ឧទ្ទេស ១០ វេយ្យាករណ៍ ១០ ។ បពិត្រនាងម្ចាស់ សេចក្ដីនៃពាក្យដែលព្រះដ៏មានព្រះភាគ ទ្រង់សម្ដែងដោយបង្រួញនេះ តើគួរយល់ដោយពិស្ដារដូចម្ដេច ។ ម្នាលអាវុសោទាំងឡាយ ពាក្យនុ៎ះ អាត្មាមិនបានស្ដាប់ ក្នុងទីចំពោះព្រះភក្ត្រ មិនបានត្រងត្រាប់ ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះដ៏មានព្រះភាគទេ ទាំងមិនបានស្ដាប់ក្នុងទីចំពោះមុខ មិនបានត្រងត្រាប់ ក្នុងទីចំពោះមុខពួកភិក្ខុ អ្នកអប់រំចិត្តទេ ប៉ុន្តែពាក្យនុ៎ះ អាត្មាយល់យ៉ាងណា អ្នកទាំងឡាយចូរប្រុងស្ដាប់ ចូរធ្វើទុកក្នុងចិត្ត នូវពាក្យនុ៎ះឲ្យប្រពៃចុះ អាត្មានឹងសម្ដែងប្រាប់ ។ ពួកកជង្គលឧបាសកក៏បានទទួលពាក្យ នៃកជង្គលាភិក្ខុនីថា ករុណានាងម្ចាស់ ។ កជង្គលាភិក្ខុនីបានពោលដូច្នេះថា ពាក្យដែលព្រះដ៏មានព្រះភាគសម្ដែងថា បញ្ហា ១ ឧទ្ទេស ១ វេយ្យាករណ៍ ១ ដូច្នេះនុ៎ះ ពាក្យនុ៎ះ ព្រះដ៏មានព្រះភាគសម្ដែងហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុនៀយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ ១ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ១ គឺអ្វី ។ គឺសត្វទាំងពួង រស់ដោយសារអាហារ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុនៀយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌មួយនេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុង

បច្ចុប្បន្នបាន ។ ពាក្យណា ដែលព្រះដ៏មានព្រះភាគសម្តែងថា បញ្ហា ១ ឧទ្ទេស ១ វេយ្យាករណ៍ ១ ដូច្នេះ ពាក្យនុ៎ះ ព្រះដ៏មានព្រះភាគសម្តែងហើយ ព្រោះអាស្រ័យហេតុនេះ ។ ពាក្យដែលព្រះដ៏មានព្រះភាគសម្តែងថា បញ្ហា ២ ឧទ្ទេស ២ វេយ្យាករណ៍ ២ ដូច្នេះនុ៎ះ ពាក្យនុ៎ះ ព្រះដ៏មានព្រះភាគសម្តែងហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ ២ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ២ គឺអ្វី ។ គឺនាម ១ រូប ១ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ទាំង ២ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណាដែលព្រះមានព្រះភាគសម្តែងថា បញ្ហា ២ ឧទ្ទេស ២ វេយ្យាករណ៍ ២ ដូច្នេះ ពាក្យនុ៎ះព្រះមានព្រះភាគសម្តែងហើយ ព្រោះអាស្រ័យហេតុនេះ ។ ពាក្យដែលព្រះដ៏មានព្រះភាគសម្តែងថា បញ្ហា ៣ ឧទ្ទេស ៣ វេយ្យាករណ៍ ៣ ដូច្នេះនុ៎ះ ពាក្យនុ៎ះ ព្រះដ៏មានព្រះភាគសម្តែងហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ទាំង ៣ ជាអ្នកធ្វើនូវទី

បំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៣ គឺអ្វី ។ គឺវេទនាទាំង ៣ ។ ម្នាល អាវុសោទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ទាំង ៣ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលព្រះដ៏មានព្រះភាគសម្តែងថា បញ្ហា ៣ ឧទ្ទេស ៣ វេយ្យាករណ៍ ៣ ដូច្នេះ ពាក្យនុ៎ះ ព្រះដ៏មានព្រះភាគសម្តែងហើយ ព្រោះអាស្រ័យហេតុនេះ ។ ពាក្យដែលព្រះដ៏មានព្រះភាគសម្តែងថា បញ្ហា ៤ ឧទ្ទេស ៤ វេយ្យាករណ៍ ៤ ដូច្នេះនុ៎ះ ពាក្យនុ៎ះ ព្រះដ៏មានព្រះភាគសម្តែងហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តចម្រើនល្អដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ ៤ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៤ គឺអ្វី ។ គឺសតិប្បដ្ឋាន ៤ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តចម្រើនល្អដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ទាំង ៤ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលព្រះដ៏មានព្រះភាគសម្តែងថា បញ្ហា ៤ ឧទ្ទេស ៤ វេយ្យាករណ៍ ៤ ដូច្នេះ ពាក្យនុ៎ះ ព្រះដ៏មានព្រះភាគសម្តែងហើយ ព្រោះអាស្រ័យហេតុនេះ ។ ពាក្យដែលព្រះដ៏មានព្រះភាគសម្តែងថា បញ្ហា ៥ ឧទ្ទេស ៥ វេយ្យាករណ៍ ៥ ដូច្នេះនុ៎ះ ពាក្យនុ៎ះ ព្រះដ៏មានព្រះភាគសម្តែង

ហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តបាន ចម្រើនល្អដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌ ៥ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៥ គឺអ្វី ។ គឺឥន្ទ្រិយទាំង ៥ ... ធម៌ ៦ គឺអ្វី ។ គឺនិស្សរណីយធាតុទាំង ៦ ... ធម៌ ៧ គឺអ្វី ។ គឺពោជ្ឈង្គទាំង ៧ ... ធម៌ ៨ គឺអ្វី ។ គឺអដ្ឋង្គិក- មគ្គដ៏ប្រសើរទាំង ៨ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តចម្រើនល្អ ដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ទាំង ៨ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលព្រះដ៏មានព្រះភាគសម្តែងថា បញ្ហា ៨ ឧទ្ទេស ៨ វេយ្យាករណ៍ ៨ ដូច្នេះ ពាក្យនុ៎ះ ព្រះមានព្រះភាគសម្តែងហើយ ព្រោះអាស្រ័យហេតុនេះ ។ ពាក្យដែលព្រះមានព្រះភាគសម្តែងថា បញ្ហា ៩ ឧទ្ទេស ៩ វេយ្យាករណ៍ ៩ ដូច្នេះនុ៎ះ ពាក្យនុ៎ះ ព្រះដ៏មានព្រះភាគសម្តែងហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹង នូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ ៩ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្ន បាន ។ ធម៌ ៩ គឺអ្វី ។ គឺសត្តាវាសទាំង ៩ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះ ដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយ

ប្រពៃ ក្នុងធម៌ទាំង ៩ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលព្រះដ៏មានព្រះភាគសម្តែងថា បញ្ហា ៩ ឧទ្ទេស ៩ វេយ្យាករណ៍ ៩ ដូច្នេះ ពាក្យនុ៎ះ ព្រះដ៏មានព្រះភាគសម្តែងហើយ ព្រោះអាស្រ័យហេតុនេះ ។ ពាក្យដែលព្រះដ៏មានព្រះភាគសម្តែងថា បញ្ហា ១០ ឧទ្ទេស ១០ វេយ្យាករណ៍ ១០ ដូច្នេះនុ៎ះ ពាក្យនុ៎ះ ព្រះដ៏មានព្រះភាគសម្តែងហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តបានចម្រើនល្អដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ ១០ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ១០ គឺអ្វី ។ គឺកុសលកម្មបថទាំង ១០ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តចម្រើនល្អដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ទាំង ១០ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលព្រះដ៏មានព្រះភាគ សម្តែងថា បញ្ហា ១០ ឧទ្ទេស ១០ វេយ្យាករណ៍ ១០ ដូច្នេះ ពាក្យនុ៎ះ ព្រះដ៏មានព្រះភាគសម្តែងហើយ ព្រោះអាស្រ័យហេតុនេះ ។ ម្នាលអាវុសោទាំងឡាយ ពាក្យណា ដែលព្រះដ៏មានព្រះភាគសម្តែងហើយក្នុងមហាបញ្ហាថា បញ្ហា ១ ឧទ្ទេស ១ វេយ្យាករណ៍ ១ ។បេ។ បញ្ហា ១០ ឧទ្ទេស ១០ វេយ្យាករណ៍ ១០ ដូច្នេះនោះ ម្នាលអាវុសោទាំងឡាយ ពាក្យដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងដោយសង្ខេបនេះ អាត្មាយល់សេចក្តីដោយពិស្តារយ៉ាងនេះ ។ ម្នាលអាវុសោទាំងឡាយ

ប្រសិនណាបើអ្នកទាំងឡាយ ប្រាថ្នា ( ចង់ដឹងច្បាស់ ) ត្រូវចូលទៅគាល់ព្រះដ៏មានព្រះភាគ ហើយទូលសួរបញ្ហាក់សេចក្តីនុ៎ះ ព្រះដ៏មានព្រះភាគ ទ្រង់ដោះស្រាយសេចក្តីនោះយ៉ាងណា អ្នកទាំងឡាយ ចូរចាំទុកនូវសេចក្តីនោះយ៉ាងនេះចុះ ។ ពួកកជង្គលឧបាសក ក៏ត្រេកអរអនុមោទនា នូវភាសិតរបស់កជង្គលាភិក្ខុនីថា ករុណានាងម្ចាស់ ហើយក៏ក្រោកចាកអាសនៈ ថ្វាយបង្គំកជង្គលាភិក្ខុនី រួចធ្វើប្រទក្សិណ ហើយក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគលុះចូលទៅដល់ ក្រាបបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះពួកកជង្គលឧបាសក អង្គុយក្នុងទីសមគួរហើយ ក្រាបទូលព្រះដ៏មានព្រះភាគ តាមទំនងពាក្យដែលខ្លួនបានសំណេះសំណាល ជាមួយនឹងកជង្គលាភិក្ខុនី ដោយសព្វគ្រប់ ។ ( ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ) ម្នាលគហបតីទាំងឡាយ ល្អហើយ ល្អហើយ ម្នាលគហបតីទាំងឡាយ កជង្គលាភិក្ខុនីជាអ្នកប្រាជ្ញ ម្នាលគហបតីទាំងឡាយ កជង្គលាភិក្ខុនី ជាមនុស្សមានប្រាជ្ញាច្រើនមែន ម្នាលគហបតីទាំងឡាយ ប្រសិនបើអ្នកទាំងឡាយ ចូលមករកតថាគត ហើយសួរនូវសេចក្តីនុ៎ះ តថាគតក៏ដោះស្រាយសេចក្តីនុ៎ះយ៉ាងនោះ ដូចជាកជង្គលាភិក្ខុនី ដែលដោះស្រាយដែរ ។ នុ៎ះជាសេចក្តីនៃបញ្ហានោះ អ្នកទាំងឡាយ ត្រូវចាំទុកនូវសេចក្តីនុ៎ះ យ៉ាងនេះចុះ ។

# អដ្ឋកថា

## ទុតិយមហាបញ្ហាសូត្រ

[ ២៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយមហាបញ្ហាសូត្រទី ៨ ដូចតទៅនេះ បទថា **កជង្គលាយំ** បានដល់ នគរមានឈ្មោះយ៉ាងនេះ ។ បទថា **កជង្គលា** ប្រែថា អ្នកកជង្គលានគរ ។ បទថា **មហាបញ្ហេសុ** បានដល់ បញ្ហាដែលកំណត់សេចក្តីធំៗ ។ បទថា **យថាមេត្ថ ខាយតិ** សេចក្តីថា ប្រាកដដល់ខ្ញុំក្នុងសេចក្តីនេះដោយប្រការណា ។ បទថា **សម្មាសុភាវិតចិត្តោ** បានដល់ ដែលមានចិត្តអប់រំដោយល្អ ដោយហេតុ ដោយន័យ ។ បទថា **ឃសោ ចេវ តស្ស អត្ថោ** សេចក្តីថា បញ្ហាជាដើមថា ធម៌ ៤ ប្រការ ព្រះមានព្រះភាគវិសជ្ជនាថា អាហារ ៤ យ៉ាង ដូច្នេះជាដើមក៏ពិត តែព្រោះហេតុដែលកំណត់ដឹងអាហារ ៤ ហើយ សតិប្បដ្ឋាន ៤ ក៏ឈ្មោះថា អប់រំហើយ កាលអប់រំសតិប្បដ្ឋាន ៤ ហើយ អាហារ ៤ ក៏កំណត់ដឹងហើយ ដូច្នោះ ទើបក្នុងបញ្ហានេះផ្សេងគ្នាត្រឹមតែព្យញ្ជនៈ ព្រោះការផ្សេងគ្នានៃទេសនាប៉ុណ្ណោះ ចំណែកអត្ថក៏ដូចគ្នាតែមួយ ក្នុងធម៌ មានឥន្ទ្រិយជាដើម ក៏មានន័យដូចគ្នា ។ ដោយហេតុនោះ ទ្រង់ត្រាស់ថា នុ៎ះឯងជាអត្ថនៃភាសិតសង្ខេបរបស់តថាគត ។ ពិតហើយ ពោលដោយសេចក្តី ពាក្យទាំង ២ នោះ ក៏ដូចជាមាសដែលប្រហោងខាងក្នុង ដូច្នោះ ។

**អដ្ឋកថា ទុតិយមហាបញ្ហាសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## បឋមកោសលសូត្រទី ៩

[ ២៩ ] ម្នាលភិក្ខុទាំងឡាយ ជនអ្នកនៅក្នុងកាសីជនបទ និងកោសលជនបទ កំណត់ត្រឹមណា ដែនរបស់ស្តេចបសេនទិកោសលកំណត់ត្រឹមណា ស្តេចបសេនទិកោសល ប្រាកដថាជាអ្នកប្រសើរក្នុងដែននោះ ( កំណត់ត្រឹមណោះ ) ។ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែស្តេចបសេនទិកោសល គង់មានសភាពក្លាយទៅ ប្រែប្រួលទៅ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកអ្នកចេះដឹង កាលបើឃើញយ៉ាងនេះហើយ រមែងនឿយណាយក្នុងការឋិតនៅក្នុងរាជសម្បត្តិនោះ កាលនឿយណាយ ក្នុងការឋិតនៅក្នុងរាជសម្បត្តិនោះហើយ រមែងមិនត្រេកអរក្នុងភាពនៃខ្លួនជាស្តេច ក្នុងដែនកោសលដ៏ប្រសើរ ដោយរាជសម្បត្តិឡើយ នឹងបាច់ពោលទៅថ្វីក្នុងរបស់ដ៏ថោកទាប ម្នាលភិក្ខុទាំងឡាយ ព្រះចន្ទ និងព្រះអាទិត្យទាំងឡាយ គោចរទៅត្រឹមណា ទិសទាំងឡាយក៏ភ្លឺរុងរឿង កំណត់ត្រឹមណោះ លោកធាតុត្រឹមមួយពាន់ក្នុងលោកមួយពាន់នោះ មានព្រះចន្ទមួយពាន់ ព្រះអាទិត្យមួយពាន់ ស្តេចភ្នំសិនេរុមួយពាន់ ជម្ពូទ្វីបមួយពាន់ អមរគោយានទ្វីបមួយពាន់ ឧត្តរកុរុទ្វីបមួយពាន់ បុព្វវិទេហទ្វីបមួយពាន់ មហាសមុទ្រ ៤ ពាន់ មហារាជ ៤ ពាន់ ចាតុម្មហារាជិកៈមួយពាន់ តាវត្តិង្សមួយពាន់ យាមៈមួយពាន់ តុសិតមួយពាន់ និម្មានរតីមួយពាន់ បរនិម្មិតវសវត្តីមួយពាន់ ព្រហ្មលោកមួយពាន់ ម្នាលភិក្ខុទាំងឡាយ លោកធាតុមួយពាន់ កំណត់ត្រឹមណា មហាព្រហ្មប្រាកដថាជា

អ្នកប្រសើរក្នុងលោកធាតុមួយពាន់នោះ កំណត់ត្រឹមណោះ ។ ម្នាលភិក្ខុទាំង-ឡាយ ប៉ុន្តែមហាព្រហ្ម គង់មានសភាពក្លាយទៅ ប្រែប្រួលទៅ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកអ្នកចេះដឹង កាលឃើញយ៉ាងនេះហើយ រមែងនឿយណាយ ក្នុងការឋិតនៅក្នុងសម្បត្តិនោះ កាលនឿយណាយក្នុងការឋិតនៅក្នុងសម្បត្តិនោះ ហើយរមែងមិនត្រេកអរ ក្នុងភាពនៃខ្លួនជាអ្នកប្រសើរឡើយ នឹងបាច់ពោលទៅថ្វីក្នុងរបស់ដ៏ថោកទាប ។ ម្នាលភិក្ខុទាំងឡាយ មានសម័យដែលលោកនេះកំពុងវិនាស ម្នាលភិក្ខុទាំងឡាយ កាលលោកកំពុងវិនាស ពួកសត្វជាច្រើនរមែងទៅកើតក្នុងព្រហ្មលោកជាន់អាភស្សរៈ ។ ពួកសត្វក្នុងជាន់អាភស្សរៈនោះ កើតដោយឈានចិត្ត មានបីតិជាអាហារ មានពន្លឺខ្លួនឯង ចរទៅក្នុងអាកាស ឋិតនៅក្នុងវិមានដ៏ល្អ ឋិតនៅអស់កាលដ៏យូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ កាលលោកកំពុងវិនាស ពួកទេវតាជាន់អាភស្សរៈរមែងប្រសើរជាងគេ ។ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែពួកទេវតាជាន់អាភស្សរៈ គង់មានសភាពក្លាយទៅ ប្រែប្រួលទៅ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកអ្នកចេះដឹង កាលឃើញយ៉ាងនេះហើយ រមែងនឿយណាយក្នុងការឋិតនៅក្នុងសម្បត្តិនោះ កាលនឿយណាយក្នុងការឋិតនៅក្នុងសម្បត្តិនោះហើយ រមែងមិនត្រេកអរក្នុងភាពនៃខ្លួនជាអ្នកប្រសើរ នឹងបាច់ពោលទៅថ្វីក្នុងរបស់ដ៏ថោកទាប ។ ម្នាលភិក្ខុទាំងឡាយ កសិណាយតនៈមាន ១០ យ៉ាង ។ កសិណាយតនៈ ១០ យ៉ាង តើដូចម្តេចខ្លះ ។ គឺបុគ្គលពួកមួយ

ស្គាល់ច្បាស់នូវបឋវីកសិណ ទាំងខាងលើ ខាងក្រោម ទទឹង មិនមានចំណែកពីរ រកប្រមាណមិនបាន ។ បុគ្គលពួកមួយ ស្គាល់ច្បាស់នូវអាបោកសិណ... បុគ្គលពួកមួយ ស្គាល់ច្បាស់នូវតេជោកសិណ... បុគ្គលពួកមួយ ស្គាល់ច្បាស់នូវវាយោកសិណ... បុគ្គលពួកមួយស្គាល់ច្បាស់នូវនីលកសិណ... បុគ្គលពួកមួយ ស្គាល់ច្បាស់នូវបីតកសិណ... បុគ្គលពួកមួយ ស្គាល់ច្បាស់នូវលោហិតកសិណ... បុគ្គលពួកមួយ ស្គាល់ច្បាស់នូវឱទាតកសិណ... បុគ្គលពួកមួយ ស្គាល់ច្បាស់នូវអាកាសកសិណ... បុគ្គលពួកមួយ ស្គាល់ច្បាស់នូវវិញ្ញាណកសិណ ទាំងខាងលើ ខាងក្រោម ទទឹង មិនមានចំណែកពីរ រកប្រមាណមិនបាន ។ ម្នាលភិក្ខុទាំងឡាយ កសិណាយតនៈមាន ១០ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាកសិណាយតនៈទាំង ១០ នេះ កសិណាយតនៈដ៏ប្រសើរទុំះ បានដល់ បុគ្គលពួកមួយ ស្គាល់ច្បាស់នូវវិញ្ញាណកសិណ ទាំងខាងលើ ខាងក្រោម ទទឹង មិនមានចំណែកពីរ រកប្រមាណមិនបាន ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វតែងមានសេចក្តីសម្គាល់យ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែពួកសត្វដែលមានសញ្ញាយ៉ាងនេះ គង់មានសភាពក្លាយទៅ ប្រែប្រួលទៅ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកអ្នកចេះដឹង កាលឃើញយ៉ាងនេះហើយ រមែងនឿយណាយក្នុងវិញ្ញាណកសិណានោះ កាលនឿយណាយ ក្នុងវិញ្ញាណកសិណានោះហើយ រមែងមិនត្រេកអរក្នុងរបស់ដ៏ប្រសើរ នឹងបាច់ពោលទៅថ្វីក្នុងរបស់ដ៏ថោកទាប ។ ម្នាល

ភិក្ខុទាំងឡាយ អភិភាយតនៈ ( ហេតុជាគ្រឿងគ្របសង្កត់នូវបច្ចនីកធម៌ ) នេះមាន ៨ យ៉ាង ។ អភិភាយតនៈ ៨ យ៉ាង តើដូចម្តេចខ្លះ ។ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ មានប្រមាណតិច មានសម្បុរល្អ ឬសម្បុរអាក្រក់ គ្របសង្កត់រូបទាំងនោះហើយ មានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ១ ។ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ មានប្រមាណច្រើន មានសម្បុរល្អ ឬសម្បុរអាក្រក់ គ្របសង្កត់នូវរូបទាំងនោះហើយ មានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ២ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ មានប្រមាណតិច មានសម្បុរល្អ ឬសម្បុរអាក្រក់ គ្របសង្កត់នូវរូបទាំងនោះហើយ មានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៣ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ហើយឃើញនូវរូបខាងក្រៅ មានប្រមាណច្រើន មានសម្បុរល្អ ឬសម្បុរអាក្រក់ គ្របសង្កត់នូវរូបទាំងនោះហើយ មានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៤ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ដែលជារូបខៀវ មានសម្បុរខៀវ ជាទីចង្អុលបង្ហាញថា នេះមានសម្បុរខៀវ មាន

ពន្លឺខៀវ ។ ប្រៀបដូចជាផ្កាត្រកៀតខៀវ មានពណ៌ខៀវជាទីចន្លុលបង្ហាញថា នេះមានពណ៌ខៀវ មានពន្លឺខៀវ ពុំនោះសោតរូបនោះ ប្រៀបដូចជាសំពត់កើតក្នុងក្រុងពារាណសី មានសាច់ម៉ដ្ឋទាំងពីរខាង ហៅថា សំពត់ខៀវ មានពណ៌ខៀវជាទីចន្លុលបង្ហាញថា នេះមានពណ៌ខៀវ មានពន្លឺខៀវ យ៉ាងណាមិញ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅដែលជារូបខៀវ មានសម្បុរខៀវជាទីចន្លុលបង្ហាញថា នេះមានសម្បុរខៀវ មានពន្លឺខៀវគ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ ក៏យ៉ាងនោះដែរ នេះជាអភិ-កាយតនៈទី ៥ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ដែលជារូបលឿង មានសម្បុរលឿង ជាទីចន្លុលបង្ហាញថា នេះមានសម្បុរលឿង មានពន្លឺលឿង ។ ប្រៀបដូចជាផ្កាកណិការលឿង មានពណ៌លឿង ជាទីចន្លុលបង្ហាញថា នេះមានពណ៌លឿង មានពន្លឺលឿង ពុំនោះសោត រូបនោះ ប្រៀបដូចជាសំពត់កើតក្នុងក្រុងពារាណសី មានសាច់ម៉ដ្ឋទាំងពីរខាង ហៅថា សំពត់លឿង ជាទីចន្លុលបង្ហាញថា នេះមានពណ៌លឿង មានពន្លឺលឿង យ៉ាងណាមិញ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅដែលជារូបលឿង មានសម្បុរលឿង ជាទីចន្លុលបង្ហាញថា នេះមានសម្បុរលឿង មានពន្លឺលឿងគ្របសង្កត់នូវរូបទាំងនោះហើយ មានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញ

ដឹង អាត្មាអញឃើញដូច្នេះ ក៏យ៉ាងនោះដែរ នេះជាអភិភាយតនៈទី ៦ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ដែលជារូបក្រហម មានសម្បុរក្រហម ជាទីចង្អុលបង្ហាញថា នេះមានសម្បុរក្រហម មានពន្លឺក្រហម ។ ប្រៀបដូចជាផ្កាចប្បាក្រហម មានពណ៌ក្រហម ជាទីចង្អុលបង្ហាញថា នេះមានពណ៌ក្រហម មានពន្លឺក្រហម ពុំនោះសោត រូបនោះ ប្រៀបដូចសំពត់កើតក្នុងក្រុងពារាណសី មានសាច់ម៉ដ្តទាំងពីរខាង ដែលជាសំពត់ក្រហម មានពណ៌ក្រហម ជាទីចង្អុលបង្ហាញថា នេះមានពណ៌ក្រហម មានពន្លឺក្រហមយ៉ាងណាមិញ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ដែលជារូបក្រហម មានសម្បុរក្រហម ជាទីចង្អុលបង្ហាថា នេះមានសម្បុរក្រហម មានពន្លឺក្រហមគ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ ក៏យ៉ាងនោះដែរ នេះជាអភិភាយតនៈទី ៧ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ដែលជារូបស មានសម្បុរស ជាទីចង្អុលបង្ហាញថា នេះមានសម្បុរស មានពន្លឺស ។ ប្រៀបដូចជាផ្កាយព្រឹកស មានពណ៌ស ជាទីចង្អុលបង្ហាញថា នេះមានពណ៌ស មានពន្លឺស ពុំនោះសោត រូបនោះ ប្រៀបដូចជាសំពត់កើតក្នុងក្រុងពារាណសី មានសាច់ម៉ដ្តទាំងពីរខាង ដែលជាសំពត់ស មានពណ៌ស ជាទីចង្អុលបង្ហាញថា នេះមានពណ៌ស មានពន្លឺស យ៉ាងណាមិញ បុគ្គលពួក

មួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ដែលជារូបស មានសម្បុរស ជាទីចង្អុលបង្ហាញថា នេះមានសម្បុរស មានពន្លឺស គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ ក៏យ៉ាងនោះដែរ នេះជាអភិភាយតនៈទី ៨ ។ ម្នាលភិក្ខុទាំងឡាយ អភិភាយតនៈមាន ៨ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាអភិភាយតនៈទាំង ៨ នេះ អភិភាយតនៈដ៏ប្រសើរទុំះ បានដល់ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ដែលជារូបស មានសម្បុរស ជាទីចង្អុលបង្ហាញថា នេះមានសម្បុរស មានពន្លឺស គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វតែងមានសេចក្តីសម្គាល់យ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែពួកសត្វដែលមានសញ្ញាយ៉ាងនេះ គង់មានសភាពក្លាយទៅ ប្រែប្រួលទៅ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកអ្នកចេះដឹង កាលឃើញយ៉ាងនេះហើយ រមែងនឿយណាយក្នុងអត្តភាពនៃពួកសត្វនោះ កាលនឿយណាយ ក្នុងអត្តភាពនៃពួកសត្វនោះ រមែងមិនត្រេកអរក្នុងរបស់ដ៏ប្រសើរ នឹងបាច់ពោលទៅថ្វីក្នុងរបស់ដ៏ថោកទាប ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រតិបត្តិនេះមាន ៤ យ៉ាង ។ សេចក្តីប្រតិបត្តិ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺសេចក្តីប្រតិបត្តិលំបាក ទាំងត្រាស់ដឹងបានដោយយឺតយូរ ១ សេចក្តីប្រតិបត្តិលំបាក តែត្រាស់ដឹងបានដោយឆាប់រហ័ស ១ សេចក្តី

ប្រតិបត្តិស្រួល តែត្រាស់ដឹងបានដោយយឺតយូរ ១ សេចក្តីប្រតិបត្តិស្រួល ទាំងត្រាស់ដឹងបានដោយឆាប់រហ័ស ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រតិ-បត្តិមាន ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសេចក្តីប្រតិបត្តិទាំង ៤ យ៉ាងនេះ សេចក្តីប្រតិបត្តិដ៏ប្រសើរទុំះ បានដល់ សេចក្តីប្រតិបត្តិស្រួល ទាំងត្រាស់ដឹងបានដោយឆាប់រហ័ស ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វតែងមានសេចក្តីប្រតិបត្តិយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែ ពួកសត្វដែលមានសេចក្តីប្រតិបត្តិយ៉ាងនេះ គង់មានសភាពក្លាយទៅ ប្រែប្រួលទៅ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកអ្នកចេះដឹង កាលឃើញយ៉ាងនេះហើយ រមែងនឿយណាយក្នុងអត្តភាពនៃពួកសត្វនោះ កាលនឿយណាយ ក្នុងអត្តភាពនៃពួកសត្វនោះហើយ រមែងមិនត្រេកអរក្នុងរបស់ដ៏ប្រសើរ នឹងបាច់ពោលទៅថ្វីក្នុងរបស់ដ៏ថោកទាប ។ ម្នាលភិក្ខុទាំងឡាយ សញ្ញានេះមាន ៤ យ៉ាង ។ សញ្ញា ៤ យ៉ាង តើដូចម្តេចខ្លះ ។ បុគ្គលពួកមួយ ស្គាល់នូវបរិត្តា-រម្មណ៍ គឺកាមាវចរ បុគ្គលពួកមួយ ស្គាល់នូវមហគ្គតារម្មណ៍ គឺរូបាវចរ បុគ្គលពួកមួយ ស្គាល់នូវអប្បមាណារម្មណ៍ គឺលោកុត្តរ បុគ្គលពួកមួយ ស្គាល់នូវអាកិញ្ចញ្ញាយតនៈថា វត្ថុតិចតួចមិនមាន ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាមាន ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសញ្ញាទាំង ៤ យ៉ាងនេះ សញ្ញាដ៏ប្រសើរទុំះ បានដល់បុគ្គលពួកមួយ ស្គាល់នូវអាកិញ្ចញ្ញា-យតនៈថា វត្ថុតិចតួចមិនមានដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វតែង

មានសញ្ញាយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែពួកសត្វដែលមានសញ្ញាយ៉ាងនេះ គង់មានសភាពក្លាយទៅ ប្រែប្រួលទៅ ។ ម្នាលភិក្ខុទាំងឡាយ អរិយ-សាវកអ្នកចេះដឹង កាលឃើញយ៉ាងនេះហើយ រមែងនឿយណាយក្នុងអត្ត-ភាពនៃពួកសត្វនោះ កាលនឿយណាយក្នុងអត្តភាពនៃពួកសត្វនោះហើយ រមែងមិនត្រេកអរក្នុងរបស់ដ៏ប្រសើរ នឹងបាច់ពោលទៅថ្វីក្នុងរបស់ដ៏ថោកទាប ។ ម្នាលភិក្ខុទាំងឡាយ បណ្តាទិដ្ឋិ ( សេចក្តីយល់ ) ទាំងឡាយដែលប្រព្រឹត្តទៅខាងក្រៅសាសនា សេចក្តីយល់ដ៏លើសទុំះ បានដល់សេចក្តីយល់ថា បើអាត្មាអញមិនមានក្នុងអតីតទេ អត្តភាពរបស់អាត្មាអញនេះ ក៏មិនមានក្នុងបច្ចុប្បន្នដែរ បើអាត្មាអញនឹងមិនមានក្នុងអនាគតទេ គ្រឿងកង្វល់បន្តិចបន្តួច ក៏មិនមានដល់អាត្មាអញដែរ ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះតែងកើតប្រាកដ ដល់បុគ្គលអ្នកមានទិដ្ឋិយ៉ាងនេះថា ការមិនខ្ពើមរអើមក្នុងភពណារបស់បុគ្គលនោះ ការមិនខ្ពើមរអើមនោះ នឹងមិនមានដល់បុគ្គលនោះផង ការខ្ពើមរអើមក្នុងធម៌ ជាគ្រឿងរលត់ភពណា របស់បុគ្គលនោះ ការខ្ពើមរអើមនោះ នឹងមិនមានដល់បុគ្គលនោះផង ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វតែងមានទិដ្ឋិយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែពួកសត្វដែលមានទិដ្ឋិយ៉ាងនេះ ក៏គង់មានសភាពក្លាយទៅ ប្រែប្រួលទៅ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកអ្នកចេះដឹង កាលឃើញយ៉ាងនេះហើយ រមែងនឿយណាយក្នុងពួកសត្វនោះ កាលនឿយណាយក្នុងពួកសត្វនោះហើយ រមែងមិនត្រេកអរ

ក្នុងរបស់ដ៏ប្រសើរ នឹងបាច់ពោលទៅថ្វីក្នុងរបស់ដ៏ថោកទាប ។ ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ រមែងបញ្ញត្តនូវសេចក្ដីបរិសុទ្ធក្នុងសត្វដ៏ឧត្ដម ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកសមណព្រាហ្មណ៍ កាលបញ្ញត្តនូវសេចក្ដីបរិសុទ្ធក្នុងពួកសត្វដ៏ឧត្ដម ការបញ្ញត្តដ៏ប្រសើរនុ៎ះ បានដល់បុគ្គលដែលកន្លងនូវអាកិញ្ចញ្ញាយតនៈ ដោយប្រការទាំងពួង ហើយបានដល់នូវនេវសញ្ញានាសញ្ញាយតនៈ ។ ពួកសមណព្រាហ្មណ៍ទាំងនោះ ដឹងនូវនេវ-សញ្ញានាសញ្ញាយតនៈនោះហើយ ក៏សម្ដែងធម៌ដើម្បីធ្វើឲ្យជាក់ច្បាស់នូវនេវ-សញ្ញានាសញ្ញាយតនៈនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វទុកជាមានវាទយ៉ាងនេះហើយ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែ ពួកសត្វដែលមានវាទយ៉ាងនេះគង់មានសភាពក្លាយទៅ ប្រែប្រួលទៅ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកអ្នកចេះដឹង កាលឃើញយ៉ាងនេះ រមែងនឿយណាយក្នុងពួកសត្វនោះ កាលនឿយណាយ ក្នុងពួកសត្វនោះហើយ រមែងមិនត្រេកអរក្នុងរបស់ដ៏ប្រសើរ នឹងបាច់ពោលទៅថ្វីក្នុងរបស់ដ៏ថោកទាប ។ ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ តែងបញ្ញត្តនូវព្រះនិព្វានដ៏ឧត្ដម ក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកសមណព្រាហ្មណ៍ កាលបញ្ញត្តនូវនិព្វានដ៏ឧត្ដមក្នុងបច្ចុប្បន្ន ការបញ្ញត្តដ៏ប្រសើរនុ៎ះ បានដល់ការរួចស្រឡះ ដោយមិនប្រកាន់ ព្រោះដឹងតាមពិតនូវការកើតឡើងផង នូវការរលត់ទៅផង នូវអានិសង្សផង នូវទោសផង នូវការរលាស់ចេញផង នៃផស្សាយតនៈទាំង ៦

មានសមណព្រាហ្មណ៍ពួកមួយ តែងនិយាយបន្តាច់តថាគតដែលពោលយ៉ាងនេះ ប្រាប់យ៉ាងនេះ ដោយពាក្យមិនទៀងទាត់ មិនពិត ជាពាក្យកុហកថា សមណគោតមមិនបញ្ញត្តនូវការកំណត់ដឹងពួកកាមផង មិនបញ្ញត្តនូវការកំណត់ដឹងនូវពួករូបផង មិនបញ្ញត្តនូវការកំណត់ដឹងពួកវេទនាផង ។ ម្នាលភិក្ខុទាំងឡាយ តថាគតបញ្ញត្តនូវការកំណត់ដឹងនូវកាមទាំងឡាយផង បញ្ញត្តនូវការកំណត់ដឹងនូវរូបទាំងឡាយផង បញ្ញត្តនូវការកំណត់ដឹងនូវវេទនាទាំង-ឡាយផង តថាគតមិនមានសេចក្តីស្រេកឃ្លាន មានទុក្ខរលត់ហើយ មានត្រជាក់កើតហើយ រមែងបញ្ញត្តនូវបរិនិព្វាន ដោយមិនមានសេចក្តីប្រកាន់ក្នុងបច្ចុប្បន្នដូច្នេះ ។

# អដ្ឋកថា

## បឋមកោសលសូត្រ

[ ២៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមកោសលសូត្រទី ៩ ដូចតទៅនេះ បទថា **យាវតា** ប្រែថា មានប្រមាណប៉ុនណា ។ បទថា **កាសិកោសលា** បានដល់ អ្នកដែនកាសី និងកោសល ។ បទថា **តត្ថេវ អញ្ញថត្តំ** ប្រែថា ភាពជាទៃមាន ។ បទថា **អត្ថិ វិបរិណាមោ** ប្រែថា ការប្រែប្រួលមាន ។ បទថា **តស្មឹបិ និព្វិន្ទតិ** បានដល់ រមែងខ្ចាចក្នុងភាវៈនោះ ដែលតាំងនៅ

ដោយសម្បត្តិ ។ បទថា **អគ្គេ វិរជ្ជតិ** បានដល់ រមែងប្រាសចាកតម្រេកក្នុងការៈជាព្រះបាទកោសលដែលក្រៃលែងដោយសម្បត្តិ ។ បទថា **បគេវ ហីនស្មឹ** សេចក្តីថា នឹងពោលទៅថ្វីដល់កាមគុណ ៥ របស់មនុស្សក្រៅអំពីនេះដែលថោកថយជាងនេះ ។ បទថា **មនោមយា** ប្រែថា ដែលកើតឡើងដោយសម្បយុត្តឈានចិត្ត ។

បទថា **ពារាណសេយ្យកំ** ប្រែថា ដែលកើតឡើងក្នុងក្រុងពារាណសី ។ ពិតហើយ ក្នុងក្រុងពារាណសីនោះ សូម្បីសំឡីក៏ទន់ សរសៃអំបោះក៏រវៃបានល្អ ការត្បាញក៏ល្អ ជាងតម្បាញក៏ឈ្លាស ទឹកក៏ថ្លាស្អាត ។ បទថា **ឧភតោ-ភាគវិមដ្ឋំ** បានដល់ ប្រាកដជារលោងទាំងសងខាង ទន់ និងស្អាត ។ ទ្រង់ត្រាស់បដិបទា ៤ លាយឡំដោយលោកិយ និងលោកុត្តរ ។

បណ្តាសញ្ញាទាំងឡាយ សញ្ញាទី ១ គឺកាមាវចរសញ្ញា សញ្ញាទី ២ គឺរូបាវចរសញ្ញា សញ្ញាទី ៣ គឺលោកុត្តរសញ្ញា សញ្ញាទី ៤ គឺអាកិញ្ចញ្ញា-យតនសញ្ញា តែព្រោះហេតុដែលសញ្ញានោះទាញមកជាកំពូល ទ្រង់មិនបានបញ្ញត្តសញ្ញាដទៃក្រៅអំពីនោះ ដូច្នោះ ទើបត្រាស់ថា ប្រសើរ ។ បទថា **ពាហិរកានំ** បានដល់ ទិដ្ឋិដែលប្រព្រឹត្តទៅខាងក្រៅសាសនា ។ បទថា **នោ ចស្សំ នោ ច មេ សិយា** សេចក្តីថា បើអាត្មាអញមិនមានហើយក្នុងអតីត សូម្បីបច្ចុប្បន្ន អត្តភាពរបស់អាត្មាអញក៏មិនគប្បីមាន ។ បទថា **ភវិស្សាមិ ន មេ ភវិស្សតិ** សេចក្តីថា បើក្នុងអនាគត អាត្មាអញមិនមានសោត ការ

កន្លល់ណាមួយរបស់អាត្មាអញនឹងមិនមាន ។

បទថា **អគ្គេ វិរជ្ឈតិ** បានដល់ រមែងប្រាសចាកតម្រេកក្នុងឧច្ឆេទទិដ្ឋិ ។ ពិតហើយ ឧច្ឆេទទិដ្ឋិ ឈ្មោះថា ជាកំពូល ព្រោះជាគ្រឿងដុតព្រះនិព្វានក្នុងព្រះសាសនានេះ ។ បទថា **បរមយក្ខវិសុទ្ធិ** បានដល់ បរិសុទ្ធក្នុងសត្វដ៏ប្រសើរ ពាក្យនេះ ជាឈ្មោះរបស់នេវសញ្ញានាសញ្ញាយតនសមាបត្តិ ។ ពិតហើយ អាកិញ្ចញ្ញាយតនៈ ឈ្មោះថា ប្រសើរ ព្រោះជាបទដ្ឋាននៃវិបស្សនា នេវសញ្ញានាសញ្ញាយតនៈ ឈ្មោះថា ប្រសើរ ព្រោះមានអាយុវែង ។

បទថា **បរមទិដ្ឋធម្មនិព្វានំ** ប្រែថា និព្វានជាកំពូលក្រៃលែងក្នុងអត្តភាពនេះ ។ បទថា **អនុបាទាវិមោក្ខោ** បានដល់ ការរួចផុតនៃចិត្តព្រោះមិនប្រកាន់មាំដោយឧបាទាន ៤ ពាក្យនេះ ជាឈ្មោះនៃអរហត្ត ។ បទថា **បរិញ្ញំ** បានដល់ ការឈានកន្លង ។ ក្នុងពាក្យនោះ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តការកំណត់ដឹងកាមទាំងឡាយ ដោយបឋមជ្ឈាន ទ្រង់បញ្ញត្តការកំណត់ដឹងរូបទាំងឡាយ ដោយអរូបាវចរជ្ឈានទាំងឡាយ ទ្រង់បញ្ញត្តការកំណត់ដឹងវេទនាទាំងឡាយ ដោយអនុបាទាបរិនិព្វាន ។ ព្រះនិព្វាន ឈ្មោះថា កំណត់ដឹងវេទនាទាំងឡាយ ព្រោះលះវេទនាបានអស់ ។ បទថា **អនុបាទាបរិនិព្វានំ** បានដល់ អប្បច្ចយបរិនិព្វាន គឺនិព្វានដែលមិនមានបច្ច័យ ។ តែព្រះមានព្រះភាគកាលត្រាស់ព្រះសូត្រនេះ ទ្រង់ឃើញភិក្ខុ ៥០០ រូបចង់សឹក ទើបត្រាស់ដើម្បីបន្ទោបង់ចំណង់ក្នុងការសឹករបស់ភិក្ខុទាំងនោះ ។ ភិក្ខុទាំងនោះបន្ទោបង់

នូវការចង់សឹកបានហើយ ជម្រះញាណតាមក្រសែទេសនា ក៏ជាសោតាបន្ន បន្ទាប់មក ចម្រើនវិបស្សនា ក៏សម្រេចអរហត្ត ដូច្នេះ ។ ៙

## អដ្ឋកថា បឋមកោសលសូត្រទី ៩ ចប់

# សុត្តន្តបិដក

## ទុតិយកោសលសូត្រទី ១០

[ ៣០ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះ ព្រះបាទបសេនទិកោសល ទ្រង់ត្រឡប់មកពីច្បាំង ទ្រង់បានឈ្នះសង្គ្រាមហើយ ទ្រង់បានតាមព្រះរាជបំណងហើយ ។ គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់ស្តេចទៅកាន់អារាម ទ្រង់ស្តេចទៅដោយព្រះរាជយាន កំណត់ត្រឹមទីដែលបរយានទៅបាន រួចស្តេចទ្រង់ចុះអំពីព្រះរាជយាន ទ្រង់ស្តេចទៅដោយព្រះបាទទទេ ចូលទៅកាន់អារាម ។ សម័យនោះ ភិក្ខុទាំងឡាយជាច្រើនរូប កំពុងចង្ក្រម ក្នុងទីវាល ។ គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់ក៏ចូលទៅរកភិក្ខុទាំងឡាយនោះ លុះចូលទៅដល់ហើយ បានសួរភិក្ខុទាំងនោះដូច្នេះថា បពិត្រព្រះករុណាទាំងឡាយដ៏ចម្រើន ឥឡូវនេះ ព្រះដ៏មានព្រះភាគអរហន្តសម្មា-

សម្ពុទ្ធ ស្តេចគង់នៅក្នុងទីណា បពិត្រព្រះករុណាទាំងឡាយដ៏ចម្រើន ដ្បិត យើងខ្ញុំមានប្រាថ្នាចង់គាល់ព្រះដ៏មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ។ បពិត្រ មហារាជ វិហារនុ៎ះ មានទ្វារបិទហើយ សូមព្រះអង្គមានព្រះសូរសៀងតិច ស្តេចចូលទៅតាមទ្វារនោះ កុំរួសរាន់ពេក ចូលទៅកាន់របៀងសឹមគ្រហែម ហើយគោះសន្ទះទ្វារ ព្រះដ៏មានព្រះភាគនឹងទ្រង់បើកទ្វារថ្វាយព្រះអង្គ ។ គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់មានព្រះសូរសៀងតិច ហើយចូលទៅកាន់វិហារដែលមានទ្វារបិទហើយ មិនបានរួសរាន់ ហើយទ្រង់ចូលទៅកាន់របៀង ហើយគ្រហែមគោះសន្ទះទ្វារ ។ ព្រះដ៏មានព្រះភាគ ក៏ទ្រង់បើកទ្វារ ។ គ្រានោះ ព្រះបាទបសេនទិកោសល ស្តេចចូលទៅកាន់វិហារ ក្រាបចុះទៀបព្រះបាទទាំងគូនៃព្រះដ៏មានព្រះភាគដោយព្រះសិរ្ស ហើយជប់នូវព្រះបាទទាំងគូ នៃព្រះដ៏មានព្រះភាគ ដោយព្រះឱស្ឋផង ទ្រង់ប្របាច់ដោយព្រះហស្តផង ទ្រង់ក្រាបទូលឲ្យជ្រាបព្រះនាមផងថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាស្តេច ឈ្មោះបសេនទិកោសល បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាស្តេចឈ្មោះបសេនទិកោសល ។ បពិត្រមហារាជ ព្រះអង្គពិចារណាឃើញនូវអំណាចប្រយោជន៍ដូចម្តេច ទើបធ្វើសេចក្តីគោរពដ៏ក្រៃលែង ទ្រង់សម្តែងនូវកិរិយារាប់អានប្រកបដោយមេត្តា មានសភាពយ៉ាងនេះ ចំពោះសរីរៈនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ពិចារណាឃើញនូវកតញ្ញូកតវេទិតា ទើបធ្វើសេចក្តីគោរពដ៏ក្រៃលែង សម្តែងនូវកិរិយារាប់អាន ប្រកបដោយមេត្តា

មានសភាពយ៉ាងនេះ ចំពោះព្រះដ៏មានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន ដ្បិតព្រះដ៏មានព្រះភាគ ប្រតិបត្តិដើម្បីប្រយោជន៍ដល់ជនច្រើន ព្រះអង្គទ្រង់តាំងទុកនូវអរិយញ្ញាណទាំងឡាយ គឺកល្យាណធម៌ និងកុសលធម៌ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីប្រយោជន៍ដល់ជនច្រើន ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ ទ្រង់ប្រតិបត្តិដើម្បីប្រយោជន៍ដល់ជនច្រើន ព្រះអង្គទ្រង់តាំងទុកនូវអរិយញ្ញាណទាំងឡាយ គឺកល្យាណធម៌ និងកុសលធម៌ ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីប្រយោជន៍ដល់ជនច្រើន ដោយអំណាចនៃប្រយោជន៍ណា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញនូវអំណាចនៃប្រយោជន៍នេះឯង ទើបធ្វើសេចក្ដីគោរពដ៏ក្រៃលែង សម្ដែងនូវកិរិយារាប់អានប្រកបដោយមេត្តា មានសភាពយ៉ាងនេះ ចំពោះព្រះដ៏មានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះដ៏មានព្រះភាគ ព្រះអង្គមានសីល មានសីលចម្រើនហើយ មានសីលដ៏ប្រសើរ មានកុសលសីល ( សីលល្អ ) ប្រកបដោយកុសលសីល ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគមានសីល មានសីលចម្រើនហើយ មានសីលដ៏ប្រសើរ មានកុសល-សីល ប្រកបដោយកុសលសីល ដោយអំណាចនៃប្រយោជន៍ណា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញ នូវអំណាចនៃប្រយោជន៍នេះឯង ទើបធ្វើនូវសេចក្ដីគោរពដ៏ក្រៃលែង សម្ដែងនូវកិរិយា រាប់អានប្រកបដោយមេត្តា មានសភាពយ៉ាងនេះ ចំពោះព្រះដ៏មានព្រះភាគ ។ បពិត្រព្រះអង្គដ៏

ចម្រើន មួយទៀត ព្រះដ៏មានព្រះភាគ ព្រះអង្គគង់នៅក្នុងព្រៃ ទ្រង់គប់រកសេនាសនៈដ៏ស្ងាត់ ដែលតាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយអស់កាលយូរ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ ព្រះអង្គគង់នៅក្នុងព្រៃ ទ្រង់គប់រកសេនាសនៈដ៏ស្ងាត់ ដែលតាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយអស់កាលយូរ ដោយអំណាចនៃប្រយោជន៍ណា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញនូវអំណាចនៃប្រយោជន៍នេះឯង ទើបធ្វើនូវសេចក្តីគោរពដ៏ក្រៃលែង សម្តែងនូវកិរិយារាប់អាន ប្រកបដោយមេត្តា មានសភាពយ៉ាងនេះ ចំពោះព្រះដ៏មានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះដ៏មានព្រះភាគទ្រង់សន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជ-បរិក្ខារតាមមាន តាមបាន ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគទ្រង់សន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារតាមមាន តាមបាន ដោយអំណាចនៃប្រយោជន៍ណា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញនូវអំណាចនៃប្រយោជន៍នេះឯង ទើបធ្វើនូវសេចក្តីគោរពដ៏ក្រៃលែង សម្តែងកិរិយារាប់អាន ប្រកបដោយមេត្តា មានសភាពយ៉ាងនេះ ចំពោះព្រះដ៏មានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះដ៏មានព្រះភាគ ព្រះអង្គគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា គួរទទួលនូវទាន ដែលគេតាក់តែងដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ បពិត្រព្រះអង្គដ៏

ចម្រើន ព្រះដ៏មានព្រះភាគ ព្រះអង្គគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា គួរទទួលនូវទាន ដែលគេតាក់តែងដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ដោយអំណាចនៃប្រយោជន៍ណា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញនូវអំណាចនៃប្រយោជន៍នេះឯង ទើបធ្វើនូវសេចក្តីគោរពដ៏ក្រៃលែង សម្តែងកិរិយារាប់អាន ប្រកបដោយមេត្តា មានសភាពយ៉ាងនេះ ចំពោះព្រះដ៏មានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះដ៏មានព្រះភាគ ព្រះអង្គបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយ នូវកថាមានសភាពយ៉ាងនេះ ដែលជាកថាជួរផង់ដ៏ក្រៃលែង ជាទីសប្បាយនៃការត្រាច់ទៅនៃចិត្ត គឺអប្បិច្ឆកថា សន្តុដ្ឋិកថា បវិវេកកថា អសំសគ្គកថា វិរិយារម្ភកថា សីលកថា សមាធិកថា បញ្ញាកថា វិមុត្តិកថា វិមុត្តិញ្ញាណទស្សនកថា ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ ព្រះអង្គបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយ នូវកថាមានសភាពយ៉ាងនេះ ដែលជាកថាជួរផង់ដ៏ក្រៃលែង ជាទីសប្បាយនៃការត្រាច់ទៅនៃចិត្ត គឺអប្បិច្ឆកថា ។បេ។ វិមុត្តិញ្ញាណទស្សនកថា ដោយអំណាចនៃប្រយោជន៍ណា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញនូវអំណាចនៃប្រយោជន៍នេះឯង ទើបធ្វើនូវសេចក្តីគោរពដ៏ក្រៃលែង សម្តែងនូវកិរិយារាប់អាន ប្រកបដោយមេត្តា មានសភាពយ៉ាងនេះ ចំពោះព្រះដ៏មានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះដ៏

មានព្រះភាគ ព្រះអង្គបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយ នូវឈានទាំង ៤ ដែលប្រព្រឹត្តទៅក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ ព្រះអង្គបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយនូវឈានទាំង ៤ ដែលប្រព្រឹត្តទៅក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ដោយអំណាចនៃប្រយោជន៍ណា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញនូវអំណាចនៃប្រយោជន៍នេះឯង ទើបធ្វើនូវសេចក្តីគោរពដ៏ក្រៃលែង សម្តែងនូវកិរិយារាប់អាន ប្រកបដោយមេត្តា មានសភាពយ៉ាងនេះ ចំពោះព្រះដ៏មានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះដ៏មានព្រះភាគ ព្រះអង្គរឭកឃើញនូវជាតិដែលព្រះអង្គធ្លាប់អាស្រ័យនៅ ក្នុងកាលមុនជាច្រើនជាតិ គឺរឭកឃើញបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១០០ ជាតិខ្លះ ១០០០ ជាតិខ្លះ ១ សែនជាតិខ្លះ រឭកឃើញបានច្រើនសំវដ្តកប្បខ្លះ ច្រើនវិវដ្តកប្បខ្លះ ច្រើនសំវដ្តវិវដ្តកប្បខ្លះ ដូច្នេះថា អាត្មាអញនៅក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណោះ លុះអាត្មាអញនោះ ច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯណោះ ដែលទៅកើតក្នុងភពនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាង

នេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ លុះអាត្មាអញនោះ ច្យុតចាកអត្តភាពនោះហើយ មកកើតក្នុងភពនេះ ។ ព្រះមានព្រះភាគ ព្រះអង្គរឭកឃើញជាតិ ដែលព្រះអង្គធ្លាប់អាស្រ័យនៅក្នុងកាលមុនបានច្រើនជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ ទ្រង់រឭកឃើញនូវជាតិ ដែលព្រះអង្គធ្លាប់អាស្រ័យនៅ ក្នុងកាលមុនជាច្រើនជាតិ គឺរឭកឃើញបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ រឭកឃើញនូវជាតិ ដែលព្រះអង្គធ្លាប់អាស្រ័យនៅ ក្នុងកាលមុនបានច្រើនជាតិ ព្រមទាំងអាការ ទាំងឧទ្ទេសដូច្នេះ ដោយអំណាចនៃប្រយោជន៍ណា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញនូវអំណាចនៃប្រយោជន៍នេះឯង ទើបធ្វើនូវសេចក្តីគោរពដ៏ក្រៃលែង សម្តែងកិរិយារាប់អាន ប្រកបដោយមេត្តា មានសភាពយ៉ាងនេះ ចំពោះព្រះដ៏មានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះដ៏មានព្រះភាគ មានចក្ខុទិព្វដ៏បរិសុទ្ធកន្លងបង់ចក្ខុរបស់មនុស្សធម្មតា ទ្រង់ឃើញសត្វទាំងឡាយដែលច្យុត ដែលចាប់បដិសន្ធិ ជាសត្វថោកទាប និងឧត្តម មានសម្បុរល្អ និងសម្បុរអាក្រក់ ទៅកាន់សុគតិ និងទុគ្គតិ ដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមកម្មថា អើហ្ន៎ សត្វទាំងនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាមិច្ឆាទិដ្ឋិ តិះដៀលពួកអរិយបុគ្គល ប្រកាន់មាំនូវកម្មជាមិច្ឆាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុង

អបាយ ទុគ្គតិ វិនិបាត នរក អើហ្ន៎ ចំណែកឯសត្វទាំងនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាសម្មាទិដ្ឋិ មិនតិះដៀលពួកអរិយបុគ្គល ប្រកាន់មាំនូវកម្មជាសម្មាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិសួគ៌ ទេវលោក ។ ព្រះដ៏មានព្រះភាគ មានចក្ខុទិព្វដ៏បរិសុទ្ធ កន្លងបង់ចក្ខុរបស់មនុស្សធម្មតា ទ្រង់ឃើញនូវសត្វទាំងឡាយ ដែលច្យុត ដែលចាប់បដិសន្ធិ ជាសត្វថោកទាប និងឧត្តម មានសម្បុរល្អ និងសម្បុរអាក្រក់ ទៅកាន់សុគតិ និងទុគ្គតិ ដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមកម្ម ដោយប្រការដូច្នេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ មានចក្ខុទិព្វដ៏បរិសុទ្ធ កន្លងបង់ចក្ខុជារបស់មនុស្សធម្មតា ។បេ។ ដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមកម្ម ដោយអំណាចនៃប្រយោជន៍ណា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញនូវអំណាចនៃប្រយោជន៍នេះឯង ទើបធ្វើនូវសេចក្តីគោរពដ៏ក្រៃលែង សម្តែងនូវកិរិយារាប់អាន ប្រកបដោយមេត្តា មានសភាពយ៉ាងនេះ ចំពោះព្រះដ៏មានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះដ៏មានព្រះភាគ ធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយព្រះអង្គឯងក្នុងបច្ចុប្បន្ន ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ ធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅ

នៃអាសវៈទាំងឡាយ ។បេ។ ដោយអំណាចនៃប្រយោជន៍ណា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញអំណាចនៃប្រយោជន៍នេះឯង ទើបធ្វើនូវសេចក្តីគោរពដ៏ក្រៃលែង សម្តែងនូវកិរិយាពប់អាន ប្រកបដោយមេត្តាមានសភាពយ៉ាងនេះ ចំពោះព្រះដ៏មានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន ណ្ហើយប៉ុណ្ណឹងចុះ យើងខ្ញុំព្រះអង្គនឹងទៅឥឡូវនេះ ( ព្រោះថា ) យើងខ្ញុំព្រះអង្គមានកិច្ចច្រើន មានការងារច្រើន ។ បពិត្រមហារាជ សូមព្រះអង្គសម្គាល់នូវកាលគួរនឹងស្តេចយាងទៅ ក្នុងកាលឥឡូវនេះចុះ ។ គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។

**មហាវគ្គទី ៣ ចប់**

## ឧទ្ទាននៃមហាវគ្គនោះ គឺ

និយាយអំពីសត្វសីហៈ ១ អធិមុត្តបទ ១ អំពីធម៌
ដែលត្រូវលះដោយកាយ ១ ព្រះចុន្ទត្ថេរ ១ កសិណា-
យតនៈ ១ ឧបាសិកាឈ្មោះកាលី ១ មហាបញ្ហាពីរ
លើក ព្រះបាទបសេនទិកោសលពីរលើកដទៃទៀត ។

# អដ្ឋកថា

## ទុតិយកោសលសូត្រ

[ ៣០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយកោសលសូត្រទី ១០ ដូចតទៅនេះ បទថា **ឧយ្យោធិកាយ និវត្តោ ហោតិ** សេចក្តីថា ទ្រង់យាងត្រឡប់អំពីការច្បាំង ។ បទថា **លទ្ធាធិប្បាយោ** សេចក្តីថា បានឮថា ព្រះបាទកោសល កាលថ្វាយធីតាដល់ព្រះបាទពិម្ពិសារ ក៏ព្រះរាជទានកាសីគាមដែលមានតម្លៃមួយមួយសែន វាំងដែនរបស់ព្រះរាជាទាំង ២ ដល់ព្រះរាជធីតា ។ កាលព្រះបាទអជាតសត្តុផ្តាច់ព្រះជន្មព្រះជនកហើយ សូម្បីព្រះមាតារបស់ទ្រង់មិនយូរប៉ុន្មាន ក៏សោយព្រះវិលាល័យ ដោយសេចក្តីសោកសង្រេង ព្រោះវិប្បយោគដល់ព្រះស្វាមី ។ កាលនោះ ព្រះបាទបសេនទិកោសល ទ្រង់ព្រះតម្រិះថា ព្រះបាទអជាតសត្តុផ្តាច់ព្រះជន្មព្រះជនកជននី កាសីគាមក៏គួរធ្លាក់ជាសម្បត្តិរបស់បិតាអញ ទើបទ្រង់សាងរបងជុំវិញ ដើម្បីកាសីគាមនោះ ។ ដូច្នោះ ដើម្បីចង់បានស្រុកនោះ ទើបស្តេចអំ និងក្មួយទាំង ២ អង្គ លើកចតុរង្គសិនីសេនាទាំង ២ ចំណែកចេញច្បាំងគ្នា ។ ក្នុងសង្គ្រាមនោះ ព្រះបាទបសេនទិកោសល ទ្រង់ចាញ់ទាំង ២ ដង ទើបទ្រង់ត្រឡប់ចូលព្រះនគរ លើកទី ៣ ទ្រង់ព្រះតម្រិះថា អញគប្បីឈ្នះបានដូចម្តេចហ្ន៎ ទ្រង់ដឹងដោយអាការដែលគួរច្បាំង ដោយវិធីលួចចូលទៅស៊ើបអាថ៌កំបាំង ទើបទ្រង់បង្ហាញកងទ័ពទាំងសងខាង ចាប់ព្រះបាទអជាតសត្តុបាននោះឯង ទ្រង់ក៏បានសមតាមបំណង ព្រោះបានឈ្នះតាមបំណង ។

បទថា **យេនារាមោ តេន ចាយាសិ** សេចក្តីថា ទ្រង់ឲ្យបោះព្រះពន្លាធ្លនជ័យជម្នះក្រៅព្រះនគរ ទ្រង់ព្រះតម្រិះថា អ្នកនគរប្រជាប់ព្រះនគរជេរាបណា អញនឹងថ្វាយបង្គំព្រះសាស្តាជេរាបនោះ តាំងអំពីកាលដែលចូលព្រះនគរហើយ ក៏នឹងយឺតយូរ ទ្រង់មានពួកអមាត្យចោមរោម ហើយយាងទៅកាត់តាមអារាម ទ្រង់ចូលទៅកាន់អារាម ។ សួរថា ទ្រង់ចូលទៅក្នុងកាលណា ឆ្លើយថា កាលព្រះសម្មាសម្ពុទ្ធ ប្រទានឱវាទដល់ពួកភិក្ខុ ដែលត្រឡប់អំពីបិណ្ឌបាត ទ្រង់ចូលព្រះគន្ធកុដិ កាលភិក្ខុសង្ឃទទួលឱវាទហើយ ចូលទៅកាន់ទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃរៀងៗខ្លួន ។ បទថា **ចង្កមន្តិ** សេចក្តីថា ភិក្ខុទាំងឡាយ កំពុងចង្រ្កមក្នុងពេលនោះ ព្រោះហេតុអ្វី ។ ឆ្លើយថា ភិក្ខុទាំងនោះចង្រ្កមក្នុងពេលថ្ងៃ ដើម្បីបន្ទោបង់ថីនមិទ្ធៈ គឺការងងុយងោកងក់ ដែលមានការឆាន់កោជនដ៏ប្រណីតជាបច្ច័យ ។ ពិតហើយ ពួកភិក្ខុដែលមានសភាពដូច្នោះ ចង្រ្កមខាងក្រោយឆាន់អាហារ ងូតទឹកជម្រះខ្លួនហើយទើបអង្គុយធ្វើសមណធម៌ ទើបចិត្តមានអារម្មណ៍ ១ ។ បទថា **យេន តេ ភិក្ខូ** សេចក្តីថា បានឮថា ព្រះបាទបសេនទិកោសលនោះ ទ្រង់ត្រិះរិះថា ព្រះសុគតប្រថាប់នៅទីណា យាងមកពិនិត្យមើលបរិវេណទាំងមូល ដោយមានព្រះបំណងនឹងចូលទៅទូលសួរ ទតឃើញពួកភិក្ខុអ្នកសមាទានបំសុកូ-លិកង្គធុតង្គកំពុងចង្រ្កម ក្នុងមហាចង្រ្កម ដូចដីរីក្នុងព្រៃ ទើបយាងចូលទៅរកភិក្ខុទាំងនោះ លោកសំដៅយកសេចក្តីនោះ ទើបពោលពាក្យនេះ ។

បទថា **ឧស្សូរកាមា** ប្រែថា ត្រូវការទីងគាល់ ។ ភិក្ខុទាំងឡាយ សំដៅយកព្រះគន្ធកុដិ ទើបពោលថា **វិហារោ** ដូច្នេះ ។ បទថា **អតរមានោ** ប្រែថា មិនប្រញាប់ប្រញាល់ អធិប្បាយថា សន្សឹមៗ ដាក់ព្រះបាទលើទី សមគួរដល់ព្រះបាទ មិនឲ្យខ្សាច់ដែលប្រៀបដូចកែវមុក្តា ឬពួរជ្រៃដែលរាប ស្មើល្អ ត្រូវវិនាស ។ បទថា **អាឡិន្ទំ** បានដល់ សំយាប ។ បទថា **អគ្គឡំ** បានដល់ សន្ទះទ្វារ ។ បទថា **ឧក្កាសិត្វា** ប្រែថា ធ្វើសំឡេង គ្រហាម ។ បទថា **អាកោដេហិ** លោកអធិប្បាយថា យកក្រចកដៃគោះ រឿយៗ ក្បែរត្រដោកទ្វារ ។ បានឮថា ពួកអមនុស្សគោះខ្ពស់ពេក ពួក ទីឃជាតិ មានពស់ជាដើម គោះទាបពេក ព្រះបាទបសេនទិកោសលគោះ យ៉ាងនោះ គឺទ្រង់គោះត្រង់កណ្តាល ជិតត្រដោកទ្វារ ព្រោះដូច្នោះ អាចារ្យ ពួកខ្លះសម្តែងថា នេះជាទំនៀមក្នុងការគោះទ្វារ ។ បទថា **វិវរិ ភគវា ទ្វារំ** សេចក្តីថា ព្រះមានព្រះភាគទ្រង់មិនក្រោកឡើងទៅបើកទ្វារ តែទ្រង់លាព្រះ ហស្តត្រាស់ថា ទ្វារចូរបើកចុះ ។ បន្ទាប់អំពីនោះ ព្រះមានព្រះភាគ ទ្រង់ ត្រិះរិះថា កាលព្រះអង្គឲ្យទានមកច្រើនកោដិកប្ប មិនធ្លាប់បិទទ្វារដោយខ្លួន ឯង ទ្វារបើកឯង តែព្រោះទ្វារនោះ បើកដោយព្រះហឫទ័យរបស់ព្រះមាន ព្រះភាគ ដូច្នោះ ទើបគួរពោលថា **វិវរិ ភគវា ទ្វារំ** ប្រែថា ព្រះមាន ព្រះភាគទ្រង់បើកទ្វារ ។ បទថា **មេត្តូបហារំ** បានដល់ ការបង្អោនចូលទៅ ដោយកាយ និងវាចាដែលប្រកបដោយមេត្តា ។ បទថា **កតញ្ញុតំ** បានដល់

ព្រះរាជាអង្គនេះ ក្នុងកាលមុន ទ្រង់មានសរីរៈធាត់ សោយបាយមួយនាឡិ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ប្រទានឱវាទដល់ព្រះរាជាយ៉ាងនេះថា

**មនុជស្ស សទា សតិមតោ**

**មត្តំ ជានតោ លទ្ធភោជនេ**

**តនុកស្ស ភវន្តិ វេទនា**

**សណិកំ ជិរតិ អាយុបាលយំ ។**

មនុស្ស មានស្មារតីសព្វកាល ដឹងប្រមាណក្នុងភោជន

ដែលខ្លួនបានហើយ រមែងមានវេទនាស្រាល អាហារ

នោះ តែងរក្សាអាយុ ជ្រួតជ្រាបបន្តិចម្តងៗ ។

ព្រះរាជាតាំងនៅក្នុងឱវាទនេះ បន្ថយអាហារ បន្តិចម្តងៗ រាល់ៗ ថ្ងៃ រហូតសល់ត្រឹមមួយនាឡិយ៉ាងច្រើនដោយលំដាប់ ព្រះវរកាយរបស់ទ្រង់ ក៏ស្រាល មាំទាំ ទ្រង់សំដៅយកឧបការៈ ដែលព្រះមានព្រះភាគទ្រង់ធ្វើហើយនោះ ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញនូវកតញ្ញូកតវេទិតា ដូច្នេះ ។ បទថា **អរិយញ្ញាយេ** បានដល់ មគ្គមួយអន្លើដោយវិបស្សនា ។ បទថា **ពុទ្ធសីលោ** បានដល់ បុគ្គលដែលមានសីល

ដ៏ចម្រើន ។ បទថា **អរិយសីលោ** បានដល់ បុគ្គលដែលប្រកបដោយសីល មិនមែនរបស់បុថុជ្ជន ។ បទថា **កុសលសីលោ** បានដល់ បុគ្គលប្រកបដោយសីលទាំងឡាយដែលមិនមានទោស ។ បទថា **អារញ្ញកោ** សេចក្តីថា កាលទ្រង់សម្តែងថា ព្រះមានព្រះភាគ កើតក៏កើតក្នុងព្រៃ ត្រាស់ដឹងក៏ត្រាស់ដឹងក្នុងព្រៃ ទោះបីនៅក្នុងព្រះគន្ធកុដិ ដូចគ្នានឹងទេវវិមាន ក៏ប្រថាប់នៅក្នុងព្រៃដូចគ្នា ទើបក្រាបទូលយ៉ាងនេះ ។ ពាក្យដ៏សេស គ្រប់ៗ បទ មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថា ទុតិយកោសលសូត្រទី ១០ ចប់**

**មហាវគ្គទី ៣ ចប់**

# សុត្តន្តបិដក
# ឧបាលិវគ្គទី ៤

## បឋមឧបាលិសូត្រទី ១ និងឧបាលិសូត្រទី ២

[ ៣១ ] គ្រានោះ ព្រះឧបាលិដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះឧបាលិដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលចំពោះព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះតថាគតទ្រង់បញ្ញត្តសិក្ខាបទ សម្តែងឡើងនូវបាតិមោក្ខ ដល់សាវកទាំង-ឡាយ តើព្រោះអាស្រ័យអំណាចប្រយោជន៍ប៉ុន្មានយ៉ាង ។ ម្នាលឧបាលិ តថាគតបញ្ញត្តសិក្ខាបទ សម្តែងឡើងនូវបាតិមោក្ខ ដល់សាវកទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍ ១០ យ៉ាង ។ ប្រយោជន៍ ១០ យ៉ាង តើដូចម្តេចខ្លះ ។ គឺដើម្បីសេចក្តីល្អនៃសង្ឃ ១ ដើម្បីនៅសប្បាយនៃសង្ឃ ១ ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយ ដែលទ្រុស្តសីល ១ ដើម្បីនៅជាសុខស្រួលនៃភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ ១ ដើម្បីរារាំងនូវអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន ១ ដើម្បីកម្ចាត់បង់នូវអាសវធម៌ទាំងឡាយក្នុងបរលោក ១ ដើម្បីញុំាងបុគ្គលទាំងឡាយ ដែលមិនជ្រះថ្លា ឲ្យជ្រះថ្លាឡើង ១ ដើម្បីញុំាងបុគ្គលទាំងឡាយ ដែលជ្រះថ្លាស្រាប់ហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង ១ ដើម្បីតាំងនៅមាំនៃព្រះសទ្ធម្ម ១ ដើម្បីអនុគ្រោះដល់ព្រះវិន័យ

១ ។ ម្នាលឧបាលិ តថាគតបញ្ញត្តសិក្ខាបទ សម្តែងឡើងនូវបាតិមោក្ខ ដល់សាវកទាំងឡាយ ព្រោះអាស្រ័យនូវអំណាចប្រយោជន៍ ១០ យ៉ាងនេះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន ការបញ្ឈប់បាតិមោក្ខ តើមានប៉ុន្មានយ៉ាង ។ ម្នាលឧបាលិ ការបញ្ឈប់បាតិមោក្ខមាន ១០ យ៉ាង ។ ការបញ្ឈប់បាតិមោក្ខ ១០ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុត្រូវបារាជិក អង្គុយក្នុងបរិស័ទនោះ ១ ពាក្យពណ៌នាអំពីភិក្ខុត្រូវបារាជិក ដែលសង្ឃធ្វើមិនទាន់ស្រេច ១ អនុបសម្បន្នអង្គុយក្នុងបរិស័ទនោះ ១ ពាក្យពណ៌នាអំពីអនុបសម្បន្ន ដែលសង្ឃធ្វើមិនទាន់ស្រេច ១ ភិក្ខុពោលលាសិក្ខាអង្គុយក្នុងបរិស័ទនោះ ១ ពាក្យពណ៌នាអំពីភិក្ខុអ្នកពោលលាសិក្ខា ដែលសង្ឃធ្វើមិនទាន់ស្រេច ១ បណ្ឌកៈអង្គុយក្នុងបរិស័ទនោះ ១ ពាក្យពណ៌នាអំពីបណ្ឌកៈ ដែលសង្ឃធ្វើមិនទាន់ស្រេច ១ ភិក្ខុអ្នកប្រទូស្តភិក្ខុនី អង្គុយក្នុងបរិស័ទនោះ ១ ពាក្យពណ៌នាអំពីភិក្ខុអ្នកប្រទូសភិក្ខុនី ដែលសង្ឃធ្វើមិនទាន់ស្រេច ១ ។ ម្នាលឧបាលិ ការបញ្ឈប់បាតិមោក្ខមានប្រយោជន៍ ១០ យ៉ាងនេះឯង ។

# អដ្ឋកថា
# ឧបាលិវគ្គទី ៤

## បឋមឧបាលិសូត្រ និងទុតិយឧបាលិសូត្រ

[ ៣១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមឧបាលិសូត្រទី ១ នៃឧបាលិវគ្គទី ៤ ដូចតទៅនេះ ឈ្មោះថា **សង្ឃសុដ្ឋុតាយ** បានដល់ ការដែលសង្ឃទទួលថាល្អ គឺភាពដែលសង្ឃទទួលដោយពាក្យជាទីស្រឡាញ់ថា **សុដ្ឋុ ភន្តេ** ល្អណាស់ ព្រះអង្គ ដូចក្នុងអាគតដ្ឋានថា **សុដ្ឋុ ទេវ** ល្អណាស់ ព្រះសម្មតិទេព ។ សង្ឃណាទទួលព្រះតម្រាស់ព្រះតថាគតនោះ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់សង្ឃនោះសព្វកាល ព្រោះដូច្នោះ ព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ដើម្បីសង្ឃទទួលដោយពាក្យជាទីស្រឡាញ់ថា **សុដ្ឋុ ភន្តេ** ល្អណាស់ ព្រះអង្គ ព្រះមានព្រះភាគកាលទ្រង់សម្ដែងទោសក្នុងការមិនទទួល និងអានិសង្សក្នុងការទទួលហើយ កាលទ្រង់ធ្វើឲ្យជាក់ច្បាស់សេចក្ដីនេះ ទ្រង់មិនបានកាន់យកអំណាចដោយកម្លាំង ទើបត្រាស់ថា **សង្ឃសុដ្ឋុតាយ** ។ បទថា **សង្ឃផាសុតាយ** បានដល់ ដើម្បីផាសុក ដើម្បីការមានជីវិតរួមគ្នានៃសង្ឃ អធិប្បាយថា ជាប្រយោជន៍ដល់ការនៅជាសុខ ។

បទថា **ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ** សេចក្ដីថា បុគ្គលទ្រុស្តសីលឈ្មោះថា ប្រដៅក្រ ។ បុគ្គលពួកណា សូម្បីត្រូវគេធ្វើឲ្យខ្មាសអៀន ក៏មិនមានទុក្ខ ទោមនស្ស ឬធ្វើនូវការល្មើសសិក្ខាបទ ឬធ្វើហើយ ក៏មិនខ្មាស

ដើម្បីប្រយោជន៍ដល់ការសង្កត់បុគ្គលទាំងនោះ ។ ពិតហើយ ភិក្ខុទាំងនោះ កាលសិក្ខាបទមាន ក៏នឹងបៀតបៀនសង្ឃថា ពួកអ្នកឃើញអ្វី បានឮអ្វី ពួកខ្ញុំធ្វើអ្វី ពួកលោកលើកអាបត្តិណា ក្នុងវត្ថុមកសង្កត់ខ្ញុំ កាលសិក្ខាបទមាន សង្ឃនឹងសម្តែងសិក្ខាបទដល់ភិក្ខុទាំងនោះ សង្កត់ដោយសហធម៌ ដោយហេតុនោះ ទើបត្រាស់ថា **ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ** ដើម្បីសង្កត់សង្កិនបុគ្គលប្រដៅក្រ ។ បទថា **បេសលានំ** បានដល់ ដើម្បីជាប្រយោជន៍ដល់ការនៅផាសុក នៃពួកភិក្ខុដែលមានសីលជាទីស្រឡាញ់ ។ ពិតហើយ ភិក្ខុមានសីលជាទីស្រឡាញ់ មិនដឹងកាលដែលគួរធ្វើ និងមិនគួរធ្វើ កាលដែលមានទោស និងមិនមានទោស និងព្រំដែនព្យាយាម ធ្វើត្រៃសិក្ខាឲ្យបរិបូណ៌ រមែងលំបាក តែភិក្ខុទាំងនោះ ដឹងការដែលមានទោស និងមិនមានទោស និងព្រំដែនព្យាយាម ធ្វើត្រៃសិក្ខាឲ្យបរិបូណ៌ រមែងមិនលំបាក ដោយហេតុនោះ ទើបការបញ្ញត្តសិក្ខាបទ ប្រព្រឹត្តទៅដើម្បីនៅជាសុខដល់ភិក្ខុទាំងនោះ ឬការសង្កត់សង្កិនបុគ្គលដែលប្រដៅក្រនោះឯង ជាការនៅជាសុខនៃភិក្ខុទាំងនោះ អាស្រ័យបុគ្គលប្រដៅក្រ ឧបោសថ និងបវារណា ក៏តាំងនៅមិនបាន សង្ឃកម្ម ក៏ប្រព្រឹត្តទៅមិនបាន មិនមានការសាមគ្គីគ្នា ភិក្ខុទាំងឡាយមានអារម្មណ៍ច្រើន ប្រកបឧទ្ទេសជាដើមមិនបាន កាលបុគ្គលទ្រុស្តសីល ត្រូវសង្កត់សង្កិនហើយ ឧបទ្រវទាំងអស់ក៏មាន បន្ទាប់អំពីនោះ ភិក្ខុដែលគួរស្រឡាញ់ រមែងនៅជាសុខ ។ ក្នុងពាក្យថា **បេសលានំ ភិក្ខូនំ**

**ជាសុរិយាភាយ** នេះ គប្បីជ្រាបសេចក្តី ២ ចំណែក ដោយប្រការដូច្នេះ ។

បទថា **ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ** សេចក្តីថា ទុក្ខពិសេសមានការប្រហារដោយបាតដៃ ការប្រហារដោយដំបង ប្រហារដោយសស្រ្តាកាត់ដៃ-ជើង រមែងវិនាសកិត្តិយស និងក្តៅក្រហាយចិត្ត ជាអ្នកតាំងនៅក្នុងការមិនសង្រួម គប្បីដល់ក្នុងអត្តភាពនោះប៉ុណ្ណោះ ឈ្មោះថា អាសវៈដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន ដើម្បីការពារ គឺកាត់ផ្លូវមកដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន ។ បទថា **សម្បរាយិកានំ** សេចក្តីថា ទុក្ខពិសេសដែលមានបាបកម្មធ្វើហើយជាមូល ដែលតាំងនៅក្នុងការមិនសង្រួម គប្បីដល់ក្នុងអបាយ មាននរកជាដើម ក្នុងភពខាងមុខ ឈ្មោះថា អាសវៈដែលប្រព្រឹត្តទៅខាងមុខ ដើម្បីជាប្រយោជន៍ដល់ការរម្ងាប់អាសវៈ ដែលប្រព្រឹត្តទៅខាងមុខនោះ ។

បទថា **អប្បសន្នានំ** សេចក្តីថា កាលមានការបញ្ញត្តសិក្ខាបទ មនុស្សពួកណាដែលជាបណ្ឌិត ដែលមិនទាន់ជ្រះថ្លា ដឹងការបញ្ញត្តសិក្ខាបទ ឬឃើញភិក្ខុបដិបត្តិសិក្ខាបទតាមដែលទ្រង់បញ្ញត្ត មនុស្សទាំងនោះ រមែងដល់នូវការជ្រះថ្លាថា សមណៈទាំងនេះវៀរចាកឋានៈ ជាទីតាំងនៃសេចក្តីស្រឡាញ់ សេចក្តីក្រោធ ការវង្វេងនៃមហាជនក្នុងលោក ឈ្មោះថា ធ្វើកិច្ចដែលធ្វើបានលំបាកហ្ន៎ ឃើញគម្ពីរក្នុងព្រះវិន័យក៏ជ្រះថ្លា ដូចកតវេទិព្រាហ្មណ៍មិច្ឆាទិដ្ឋិ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **អប្បសន្នានំ បសាទាយ**

ដើម្បីសេចក្តីជ្រះថ្លានៃអ្នក ដែលមិនទាន់ជ្រះថ្លា ។

បទថា **បសន្នានំ** សេចក្តីថា កុលបុត្រពួកណា ជ្រះថ្លាក្នុងព្រះសាសនាហើយ កុលបុត្រទាំងនោះ ដឹងការបញ្ញត្តសិក្ខាបទ ឬឃើញភិក្ខុបដិបត្តិតាមសិក្ខាបទដែលទ្រង់បញ្ញត្ត រមែងជ្រះថ្លាក្រៃលែងឡើងថា ឱ លោកម្ចាស់ធាន់មួយពេល រក្សាព្រហ្មចរិយៈ សង្រួមដរាបដល់អស់ជីវិត ឈ្មោះថា ធ្វើកិច្ចដែលធ្វើបានលំបាកហ្ន៎ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **បសន្នានំ ភិយ្យោភាវាយ** ដើម្បីជ្រះថ្លាក្រៃលែងឡើង នៃបុគ្គលដែលជ្រះថ្លាហើយ ។

បទថា **សទ្ធម្មដ្ឋិតិយា** សេចក្តីថា សទ្ធម្មមាន ៣ យ៉ាង គឺបរិយត្តិសទ្ធម្ម ១ បដិបត្តិសទ្ធម្ម ១ អធិគមសទ្ធម្ម ១ ។ ក្នុងបណ្តាសទ្ធម្ម ៣ យ៉ាងនោះ ពុទ្ធវចនៈទាំងមូល ឈ្មោះថា **បរិយត្តិសទ្ធម្ម** សទ្ធម្ម គឺធុតង្គ ១៣ ចារិតសីល វារិតសីល សមាធិ វិបស្សនា ឈ្មោះថា **បដិបត្តិសទ្ធម្ម**។ លោកុត្តរធម៌ ៩ ឈ្មោះថា **អធិគមសទ្ធម្ម** ។ សទ្ធម្មទាំងអស់នោះ ព្រោះហេតុដែលកាលមានបញ្ញត្តសិក្ខាបទ ភិក្ខុទាំងឡាយ រមែងរៀនសិក្ខាបទវិភង្គនៃសិក្ខាបទនោះ និងពុទ្ធវចនៈដទៃ ដើម្បីចុះបញ្ចាំងសិក្ខាបទ និងវិភង្គនោះ និងកាលបដិបត្តិសិក្ខាបទតាមដែលទ្រង់បញ្ញត្ត បំពេញបដិបទា រមែងសម្រេចលោកុត្តរធម៌ ដែលគប្បីសម្រេចដោយបដិបទានោះ ដូច្នោះ ទើបព្រះសទ្ធម្មតាំងនៅបានយូរ ព្រោះការបញ្ញត្តសិក្ខាបទ ដោយហេតុនោះ ទើបព្រះ

មានព្រះភាគត្រាស់ថា **ធម្មដ្ឋិតិយា** ដើម្បីការតាំងមាំនៃព្រះសទ្ធម្ម ។

បទថា **វិនយានុគ្គហាយ** សេចក្ដីថា កាលមានការបញ្ញត្តសិក្ខាបទក៏ឈ្មោះថា អនុគ្រោះឧបត្ថម្ភគាំទ្រនូវវិន័យទាំង ៤ យ៉ាង គឺសំវរវិន័យ ១ បហានវិន័យ ១ សមថវិន័យ ១ បញ្ញត្តិវិន័យ ១ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **វិនយានុគ្គហាយ** ដើម្បីអនុគ្រោះដល់ព្រះវិន័យ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយឧបាលិសូត្រទី ២ ដូចតទៅនេះថា

បទថា **បារាជិកោ** បានដល់ ដែលត្រូវអាបត្តិបារាជិក ។ បទថា **បារាជិកកថា វិប្បកតា ហោតិ** សេចក្ដីថា រឿងយ៉ាងនេះថា បុគ្គលឈ្មោះនោះត្រូវអាបត្តិបារាជិកឬហ្ន៎ ដែលជាការផ្ដើមហើយមិនទាន់ចប់ ក្នុងបទទាំងពួងក៏ន័យនេះដូចគ្នា ៕៚

## អដ្ឋកថា បឋមឧបាលិសូត្រទី ១ និងទុតិយឧបាលិសូត្រទី ២ ចប់[១]

១- ក្នុងសូត្រនេះលេខឃ្នាបតែមួយ តែអដ្ឋកថាលោកបំបែកជាពីរសូត្រ ។

# សុត្តន្តបិដក

## ឧព្វាហិកាសូត្រទី ៣

[ ៣២ ] បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុប្រកបដោយធម៌ប៉ុន្មានយ៉ាង ទើបគួរសន្មតដោយឧព្វាហិកាកម្មវាចាបាន ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយធម៌ ១០ យ៉ាង ទើបគួរសន្មតដោយឧព្វាហិកាកម្មវាចាបាន ។ ប្រកបដោយធម៌ ១០ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីលសង្រួមហើយ ដោយការសង្រួមក្នុងបាតិមោក្ខ បរិបូណ៌ដោយអាចារនិងគោចរ ឃើញភ័យក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ពហុស្សូតទ្រទ្រង់នូវពុទ្ធវចនៈ ដែលខ្លួនបានស្តាប់ហើយ សន្សំទុកនូវពុទ្ធវចនៈ ដែលខ្លួនបានស្តាប់ហើយ ធម៌ទាំងឡាយណាមានលម្អបទដើម លម្អបទកណ្តាល លម្អបទចុង ប្រកាសនូវព្រហ្មចរិយធម៌ព្រមទាំងអត្ថ ទាំងព្យញ្ជនៈ ដ៏បរិសុទ្ធបរិបូណ៌ទាំងអស់ ធម៌ទាំងឡាយមានសភាពដូច្នោះ ភិក្ខុនោះក៏បានស្តាប់ច្រើន បានចាំទុក បានសន្សំទុកដោយវាចា ( ស្ទាត់ជំនាញ ) ជាក់ច្បាស់ក្នុងចិត្ត ចេះដឹងល្អដោយទិដ្ឋិ ១ មិនតែប៉ុណ្ណោះទេ ទើបឯបាតិមោក្ខទាំងពីរយ៉ាង ក៏ភិក្ខុនោះចាំបានដោយពិស្តារ ចេះចែករំលែកបានដោយស្រួល ចេះស្ទាត់រត់មាត់ វិនិច្ឆ័យបានដោយល្អ តាមសូត្រ តាមអនុព្យញ្ជនៈ ១ ជាអ្នកខ្ជាប់ខ្ជួន ឥតទើសទាល់ក្នុងផ្លូវវិន័យ ១ ជាអ្នកអង់អាច ដើម្បីធ្វើបុគ្គលទាំងពីរដែលជាសត្រូវនឹងគ្នា ឲ្យដឹងច្បាស់ ឲ្យពិនិត្យ ឲ្យពិចារណា ឲ្យឃើញ ឲ្យជ្រះថ្លាបាន ១ អ្នកឈ្លាសក្នុងការរម្ងាប់អធិករណ៍

ដែលកើតឡើងហើយ ១ អ្នកស្គាល់អធិករណ៍ ១ ស្គាល់ហេតុដែលកើតអធិករណ៍ ១ ស្គាល់ធម៌សម្រាប់រម្ងាប់អធិករណ៍ ១ ស្គាល់បដិបទាជាដំណើរទៅកាន់ធម៌សម្រាប់រម្ងាប់អធិករណ៍ ១ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយធម៌ ១០ យ៉ាងនេះឯង ទើបគួរសន្មតដោយឧព្វាហិកាកម្មវាចាបាន ។

# អដ្ឋកថា

## ឧព្វាហិកាសូត្រ

[ ៣២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧព្វាហិកាសូត្រទី ៣ ដូចតទៅនេះ បទថា **ឧព្វាហិកាយ** បានដល់ ដើម្បីជាប្រយោជន៍ដល់ការលើកឡើង ដើម្បីរម្ងាប់អធិករណ៍ដែលមកដល់ហើយ ។ បទថា **វិនយេ ខោ បន ឋិតោ ហោតិ** បានដល់ ជាបុគ្គលតាំងនៅក្នុងលក្ខណៈនៃវិន័យ ។ បទថា **អសំហិរោ** បានដល់ មិនលះបង់នូវលទ្ធិរបស់ខ្លួន ដោយហេតុត្រឹមតែវាចារបស់បុគ្គលដទៃ ។ បទថា **បដិពលោ** បានដល់ ប្រកបដោយកម្លាំងកាយខ្លះ កម្លាំងវិជ្ជាខ្លះ ។ បទថា **សញ្ញាបេតុំ** បានដល់ ឲ្យយល់ព្រម ។ បទថា **និជ្ឈាបេតុំ** បានដល់ ឲ្យសម្លឹងមើល ។ បទថា **បេក្ខាតុំ** បានដល់ ឲ្យឃើញ ។ បទថា **បសាទេតុំ** បានដល់ ធ្វើឲ្យកើតសេចក្តីជ្រះថ្លាឯង ។ បទថា **អធិករណំ**

បានដល់ អធិករណ៍ ៤ មានវិវាទាធិករណ៍ជាដើម ។ បទថា **អធិករណ-សមុទយំ** បានដល់ ហេតុកើតអធិករណ៍ មានមូលវិវាទជាដើម ។ បទថា **អធិករណនិរោធំ** បានដល់ រម្ងាប់អធិករណ៍ ។ បទថា **អធិករណនិរោធ-គាមិនីបដិបទំ** បានដល់ អធិករណសមថៈ ៧ យ៉ាង ។៙

**អដ្ឋកថា ឧព្វាហិកាសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ឧបសម្បទាសូត្រទី ៤

[ ៣៣ ] បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុប្រកបដោយធម៌ប៉ុន្មានយ៉ាង ទើបគួរញ៉ាំងកុលបុត្រឲ្យឧបសម្បទាបាន ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយធម៌ ១០ យ៉ាង គួរញ៉ាំងកុលបុត្រឲ្យឧបសម្បទាបាន ។ ប្រកបដោយធម៌ ១០ យ៉ាង តើអ្វីខ្លះ ។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីលសង្រួមហើយ ដោយការសង្រួមក្នុងបាតិមោក្ខ បរិបូណ៌ដោយអាចារ និងគោចរ ឃើញភ័យក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទាន សិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ពហុស្សូតទ្រទ្រង់នូវពុទ្ធវចនៈ ដែលខ្លួនបានស្តាប់ហើយ សន្សំទុកនូវពុទ្ធវចនៈ ដែលខ្លួនបានស្តាប់ហើយ ធម៌ទាំងឡាយណាមានលម្អបទដើម លម្អបទកណ្តាល លម្អបទចុង ប្រកាសនូវព្រហ្មចរិយធម៌

ព្រមទាំងអត្ថ ទាំងព្យញ្ជនៈដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ធម៌ទាំងឡាយ មានសភាពដូច្នោះ ភិក្ខុនោះក៏បានស្តាប់ច្រើន បានចាំទុក បានសន្សំទុកដោយវាចា ( ស្ទាត់ជំនាញ ) ជាក់ច្បាស់ក្នុងចិត្ត ចេះដឹងល្អដោយទិដ្ឋិ ១ មិនតែប៉ុណ្ណោះទេ បាតិមោក្ខក៏ភិក្ខុនោះ ចាំបានដោយពិស្តារ ចេះចែករំលែកបានស្រួល ចេះស្ទាត់រត់មាត់ វិនិច្ឆ័យបានដោយល្អ តាមសូត្រ តាមអនុព្យញ្ជនៈ ១ អ្នកអង់អាចដើម្បីបម្រើ ឬឲ្យគេបម្រើនូវអ្នកជំងឺ ១ អ្នកអង់អាចដើម្បីរម្ងាប់ ឬឲ្យគេរម្ងាប់សេចក្តីអផ្សុក ១ អ្នកអង់អាច ដើម្បីបន្ទោបង់សេចក្តីសង្ស័យដែលកើតហើយដោយធម៌ ១ អ្នកអង់អាច ដើម្បីកម្ចាត់បង់ទិដ្ឋិ ដែលកើតហើយដោយធម៌ ១ អ្នកអង់អាច ដើម្បីញុំាងបុគ្គលឲ្យសមាទានក្នុងអធិសីល ១ អ្នកអង់អាច ដើម្បីញុំាងបុគ្គលឲ្យសមាទានក្នុងអធិចិត្ត ១ អ្នកអង់អាច ដើម្បីញុំាងបុគ្គលឲ្យសមាទានក្នុងអធិប្បញ្ញា ១ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយធម៌ ១០ យ៉ាងនេះឯង ទើបគួរញុំាងកុលបុត្តឲ្យឧបសម្បទាបាន ។

# អដ្ឋកថា

## ឧបសម្បទាសូត្រ

[ ៣៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧបសម្បទាសូត្រទី ៤ ដូចតទៅនេះ បទថា **អនភិរតឹ** បានដល់ ភាពជាអ្នកអផ្សុក ។ បទថា **វូបកាសេតុំ** បាន

ដល់ កម្ចាត់ ។ បទថា **អធិសីលេ** បានដល់ សីលដ៏ឧត្តម ។ ក្នុងចិត្ត និង បញ្ញា ក៏មានន័យនេះដូចគ្នា ។០៚

**អដ្ឋកថា ឧបសម្បទាសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## និស្សយសូត្រទី ៥ និងសាមណេរសូត្រទី ៦

[ ៣៤ ] បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុប្រកបដោយធម៌ប៉ុន្មានយ៉ាង ទើបគួរឲ្យនិស្ស័យបាន ។បេ។ គួរឲ្យសាមណេរបម្រើបាន ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយធម៌ ១០ យ៉ាង គួរឲ្យសាមណេរបម្រើបាន ។ ប្រកបដោយធម៌ ១០ យ៉ាង តើអ្វីខ្លះ ។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។បេ។ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ពហុស្សូត ។បេ។ចេះដឹងល្អដោយទិដ្ឋិ ១ មិនតែប៉ុណ្ណោះឡើយ បាតិមោក្ខក៏ភិក្ខុនោះចាំបានដោយពិស្ដារ ចេះចែករំលែកបានដោយស្រួល ចាំស្ទាត់រត់មាត់ វិនិច្ឆ័យបានដោយស្រួល តាមសូត្រ តាមអនុព្យញ្ជនៈ ១ អ្នកអង់អាចដើម្បីបម្រើ ឬឲ្យគេបម្រើននូវអ្នកជំងឺ ១ អ្នកអង់អាចដើម្បីរម្ងាប់ ឬប្រើគេឲ្យរម្ងាប់នូវសេចក្ដីអផ្សុក ១ អ្នកអង់អាចដើម្បីបន្ទោបង់សេចក្ដីសង្ស័យ ដែលកើតឡើងហើយដោយធម៌ ១

អ្នកអង់អាចដើម្បីកម្ចាត់បង់នូវទិដ្ឋិ ដែលកើតឡើងហើយដោយធម៌ ១ អ្នកអង់អាចដើម្បីញុំាងកុលបុត្ត ឲ្យសមាទានក្នុងអធិសីល ១ អ្នកអង់អាចដើម្បីញុំាងកុលបុត្ត ឲ្យសមាទានក្នុងអធិចិត្ត ១ អ្នកអង់អាចដើម្បីញុំាងកុលបុត្ត ឲ្យសមាទានក្នុងអធិប្បញ្ញា ១ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយធម៌ ១០ យ៉ាងនេះឯង ទើបគួរឲ្យសាមណេរបម្រើបាន ។

# អដ្ឋកថា

## និស្សយសូត្រ និង សាមណេរសូត្រ

[ ៣៤ ] ក្នុងនិស្សយសូត្រទី ៥ និងសាមណេរសូត្រទី ៦ មានអត្ថងាយយល់ហើយ ។

**អដ្ឋកថា និស្សយសូត្រទី ៥ និងសាមណេរសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## ឧបាលិសង្ឃភេទសូត្រទី ៧

[ ៣៥ ] បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថា ការបែកសង្ឃៗ បពិត្រព្រះអង្គដ៏ចម្រើន សង្ឃបែកគ្នា តើដោយហេតុប៉ុន្មានយ៉ាង ។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សម្តែងសភាពមិនមែនធម៌ ថាជាធម៌ ១ សម្តែងធម៌ថាមិនមែនធម៌ ១ សម្តែងសភាពមិនមែនជាវិន័យ ថាជាវិន័យ ១ សម្តែងវិន័យថាមិនមែនជាវិន័យ ១ សម្តែងធម្មវិន័យ ដែលតថាគតមិនបានសម្តែង មិនបានពោលហើយថា ជាធម្មវិន័យដែលតថាគត បានសម្តែង បានពោលហើយ ១ សម្តែងធម្មវិន័យ ដែលតថាគតបានសម្តែង បានពោលហើយថា ធម្មវិន័យដែលតថាគតមិនបានសម្តែង មិនបានពោលហើយ ១ សម្តែងនូវវត្ត ដែលតថាគត មិនបានសន្សំហើយ ថាជាវត្តដែលតថាគត បានសន្សំហើយ ១ សម្តែងនូវវត្តដែលតថាគតបានសន្សំហើយ ថាជាវត្តដែលតថាគត មិនបានសន្សំវិញ ១ សម្តែងនូវសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្តហើយ ថាជាសិក្ខាបទ ដែលតថាគតបានបញ្ញត្ត ១ សម្តែងនូវសិក្ខាបទ ដែលតថាគតបានបញ្ញត្តហើយ ថាជាសិក្ខាបទដែលតថាគត មិនបានបញ្ញត្តហើយ ១ ។ ភិក្ខុទាំងនោះ ដឹកនាំបង្ខំធ្វើនូវសង្ឃកម្មផ្សេងគ្នា សម្តែងនូវបាតិមោក្ខផ្សេងគ្នា ដោយវត្ថុ ១០ យ៉ាងនេះឯង ។ ម្នាលឧបាលិ សង្ឃបែកគ្នាដោយហេតុប៉ុណ្ណេះឯង ។

# អដ្ឋកថា

## ឧបាលិសង្ឃភេទសូត្រ

[ ៣៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧបាលិសង្ឃភេទសូត្រទី ៧ ដូចតទៅនេះ បទថា **វត្ថូហិ** បានដល់ ហេតុទាំងឡាយ ។ បទថា **អវកស្សន្តិ** បានដល់ រុញចេញទៅ បោះចោលទៅ បែកចាកអំពីគ្នានូវបរិស័ទមួយចំណែក ។ បទថា **បវកស្សន្តិ** បានដល់ ប្រានចេញទៅ ហើយបណ្តេញចេញទៅ ។ បទថា **អាវេណិកកម្មានិ ករោន្តិ** បានដល់ ធ្វើសង្ឃកម្មបែកគ្នា ៕

**អដ្ឋកថា ឧបាលិសង្ឃភេទសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ឧបាលិសាមគ្គីសូត្រទី ៨

[ ៣៦ ] បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថា សេចក្តីព្រមព្រៀងនៃសង្ឃៗ បពិត្រព្រះអង្គដ៏ចម្រើន សង្ឃព្រមព្រៀងគ្នា តើដោយហេតុប៉ុន្មានយ៉ាង ។ ម្នាលឧបាលិ ពួកភិក្ខុក្នុងសាសនានេះ សម្តែងនូវសភាពមិនមែនធម៌ជាមិនមែនធម៌ ១ សម្តែងនូវធម៌ថាជាធម៌ ១ សម្តែងនូវសភាពមិនមែនជាវិន័យថា មិនមែនជាវិន័យ ១ សម្តែងនូវវិន័យថាជាវិន័យ ១ សម្តែងនូវធម្ម-

វិន័យ ដែលតថាគតមិនបានសម្តែង មិនបានពោលហើយ ថាជាធម្មវិន័យដែលតថាគតមិនបានសម្តែង មិនបានពោលហើយ ១ សម្តែងនូវធម្មវិន័យ ដែលតថាគតបានសម្តែង បានពោលហើយ ថាជាធម្មវិន័យ ដែលតថាគតបានសម្តែង បានពោលហើយ ១ សម្តែងនូវវត្ត ដែលតថាគតមិនបានសន្សំហើយ ថាជាវត្តដែលតថាគត មិនបានសន្សំហើយ ១ សម្តែងនូវវត្ត ដែលតថាគតបានសន្សំហើយ ថាជាវត្តដែលតថាគតបានសន្សំហើយ ១ សម្តែងនូវសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្តហើយ ថាជាសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្តហើយ ១ សម្តែងនូវសិក្ខាបទ ដែលតថាគតបានបញ្ញត្តហើយ ថាជាសិក្ខាបទដែលតថាគតបានបញ្ញត្ត ១ ។ ភិក្ខុទាំងនោះ មិនដឹកនាំ មិនបង្ខំ មិនធ្វើនូវសង្ឃកម្មផ្សេងគ្នា មិនសម្តែងនូវបាតិមោក្ខផ្សេងគ្នា ដោយវត្ថុ ១០ យ៉ាងនេះឯង ។ ម្នាលឧបាលិ សង្ឃព្រមព្រៀងគ្នា ដោយហេតុប៉ុណ្ណេះឯង ។

# អដ្ឋកថា

## ឧបាលិសាមគ្គីសូត្រ

[ ៣៦ ] ក្នុងឧបាលិសាមគ្គីសូត្រទី ៨ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាឧបាលិសាមគ្គីសូត្រទី ៨ ចប់

# សុត្តន្តបិដក

## អានន្ទសង្ឃភេទសូត្រទី ៩

[ ៣៧ ] គ្រានោះ ព្រះអានន្ទដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំចំពោះព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថា ការបែកសង្ឃៗ បពិត្រព្រះអង្គដ៏ចម្រើន សង្ឃបែកគ្នា តើដោយហេតុប៉ុន្មានយ៉ាង ។ ម្នាលអានន្ទ ពួកភិក្ខុក្នុងសាសនានេះ សម្តែងនូវសភាពមិនមែនធម៌ ថាជាធម៌ ១ សម្តែងនូវធម៌ ថាមិនមែនជាធម៌ ១ សម្តែងនូវសភាពមិនមែនវិន័យ ថាជាវិន័យ ១ សម្តែងនូវវិន័យថា មិនមែនជាវិន័យ ១ សម្តែងនូវធម្មវិន័យ ដែលតថាគតមិនបានសម្តែង មិនបានពោលហើយ ថាជាធម្មវិន័យ ដែលតថាគតបានសម្តែង បានពោលហើយ ១ សម្តែងនូវធម្មវិន័យ ដែលតថាគត បានសម្តែងបានពោលហើយថា ជាធម្មវិន័យដែលតថាគត មិនបានសម្តែង មិនបានពោលវិញ ១ សម្តែងនូវវត្ត ដែលតថាគតមិនបានសន្សំហើយ ថាជាវត្តដែលតថាគតបានសន្សំហើយ ១ សម្តែងនូវវត្ត ដែលតថាគតបានសន្សំហើយ ថាជាវត្តដែលតថាគតមិនបានសន្សំវិញ ១ សម្តែងនូវសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្តហើយ ថាជាសិក្ខាបទ ដែលតថាគតបានបញ្ញត្តហើយ ១ សម្តែងនូវសិក្ខាបទដែលតថាគតបានបញ្ញត្តហើយ ថាជាសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្តវិញ ១ ។ ភិក្ខុទាំងនោះដឹកនាំបន្ទំ ធ្វើនូវសង្ឃកម្មផ្សេងគ្នា សម្តែងនូវបាតិមោក្ខ

ផ្សេងគ្នា ដោយវត្ថុ ១០ យ៉ាងនេះឯង ។ ម្នាលអានន្ទ សង្ឃបែកគ្នា ដោយហេតុប៉ុណ្ណោះឯង ។

[ ៣៨ ] បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុបំបែកសង្ឃ ដែលព្រមព្រៀងគ្នានោះ តើទទួលនូវផលដូចម្ដេច ។ ម្នាលអានន្ទ ភិក្ខុនោះ រមែងទទួលផលដ៏ខ្វាចផ្សា តាំងនៅអស់មួយកប្ប ។ បពិត្រព្រះអង្គដ៏ចម្រើន ផលដ៏ខ្វាចផ្សា តាំងនៅអស់មួយកប្ប តើដូចម្ដេច ។ ម្នាលអានន្ទ ភិក្ខុនោះ ឆេះនៅក្នុងនរក អស់មួយកប្ប ។

ភិក្ខុអ្នកបំបែកសង្ឃ ត្រេកអរក្នុងពួក មិនតាំងខ្លួននៅក្នុងធម៌ ទៅកើតក្នុងអបាយ ទៅកើតក្នុងនរក តាំងនៅអស់មួយកប្ប រមែងឃ្លាតចាកធម៌ ជាគ្រឿងក្សេមចាកយោគៈ ភិក្ខុបំបែកសង្ឃ ដែលព្រមព្រៀងគ្នា រមែងឆេះនៅក្នុងនរក អស់មួយកប្ប ។

# អដ្ឋកថា

## អានន្ទសង្ឃភេទសូត្រ

[ ៣៧-៣៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអានន្ទសង្ឃភេទសូត្រទី ៩ ដូច្នេះ បទថា **កប្បដ្ឋិយំ** បានដល់ ហេតុនៃការតាំងនៅក្នុងនរកអស់អាយុកប្ប ។ បទថា **កិព្ពិសំ បសវតិ** សេចក្ដីថា រមែងបានវិបាកនៃបាប ។ បទថា **អាបា-យិកោ** បានដល់ ទៅកាន់អបាយ ។ បទថា **នេរយិកោ** បានដល់ កើតក្នុង

នរក ។ បទថា **វគ្គរតោ** បានដល់ ត្រេកអរក្នុងការបែកគ្នា ។ បទថា **យោគក្ខេមតោ ធំសតិ** បានដល់ ភ្លាត់ចាកអរហត្តដែលជាដែនក្សេមចាក យោគៈ ។ល។

**អដ្ឋកថា អានន្ទសង្ឃភេទសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## អានន្ទសង្ឃសាមគ្គីសូត្រទី ១០

[ ៣៩ ] បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថា សេចក្តីព្រមព្រៀងគ្នានៃសង្ឃៗ បពិត្រព្រះអង្គដ៏ចម្រើន សង្ឃព្រមព្រៀងគ្នា តើដោយហេតុប៉ុន្មានយ៉ាង ។ ម្នាលអានន្ទ ពួកភិក្ខុក្នុងសាសនានេះ សម្តែងនូវសភាពមិនមែនធម៌ថាមិនមែនធម៌ ១ សម្តែងនូវធម៌ថាជាធម៌ ១ សម្តែងនូវសភាពមិនមែនជាវិន័យ ថាមិនមែនជាវិន័យ ១ សម្តែងនូវវិន័យថាជាវិន័យ ១ សម្តែងធម្មវិន័យដែលតថាគតមិនបានសម្តែង មិនបានពោលហើយ ថាជាធម្មវិន័យ ដែលតថាគតមិនបានសម្តែង មិនបានពោលហើយ ១ សម្តែងនូវធម្មវិន័យ ដែលតថាគតបានសម្តែង បានពោលហើយថា ជាធម្មវិន័យដែលតថាគត បានសម្តែង បានពោលហើយ ១ សម្តែងនូវវត្តដែលតថាគតមិនបានសន្សំហើយ ថាជាវត្តដែលតថាគតមិនបានសន្សំហើយ ១ សម្តែងនូវវត្តដែលតថាគតបាន

សន្សំហើយ ថាជាវត្តដែលតថាគតបានសន្សំហើយ ១ សម្តែងនូវសិក្ខាបទដែលតថាគតមិនបានបញ្ញត្តហើយ ថាជាសិក្ខាបទដែលតថាគតមិនបានបញ្ញត្តហើយ ១ សម្តែងនូវសិក្ខាបទដែលព្រះតថាគតបានបញ្ញត្តហើយ ថាជាសិក្ខា-បទដែលតថាគតបានបញ្ញត្ត ១ ។ ភិក្ខុទាំងនោះ មិនដឹកនាំ មិនបង្ខំ មិនធ្វើសង្ឃកម្មផ្សេងគ្នា មិនសម្តែងបាតិមោក្ខផ្សេងគ្នា ដោយវត្ថុ ១០ យ៉ាងនេះឯង ។ ម្នាលអានន្ទ សង្ឃព្រមព្រៀងគ្នា ដោយហេតុប៉ុណ្ណោះឯង ។

[ ៤០ ] បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុអ្នកសង្រួបសង្រួមសង្ឃ ដែលបែកគ្នាហើយ ឲ្យបានព្រមព្រៀងគ្នាទៅវិញនោះ តើទទួលផលដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុនោះរមែងទទួលនូវបុណ្យដ៏ប្រសើរ ។ បពិត្រព្រះអង្គដ៏ចម្រើន បុណ្យដ៏ប្រសើរ តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុនោះ រមែងបានរីករាយក្នុងឋានសួគ៌ អស់មួយកប្ប ។

សេចក្តីព្រមព្រៀងគ្នានៃសង្ឃ រមែងនាំមកនូវសេចក្តីសុខ ភិក្ខុ
អ្នកអនុគ្រោះពួកភិក្ខុ ដែលព្រមព្រៀងគ្នាផង អ្នកត្រេកអរក្នុង
ការព្រមព្រៀងគ្នាផង តាំងនៅក្នុងធម៌ផង រមែងមិនឃ្លាតចាក
ធម៌ ជាគ្រឿងក្សេមចាកយោគៈ ភិក្ខុអ្នកសង្រួបសង្រួមសង្ឃ
ឲ្យព្រមព្រៀងគ្នា រមែងរីករាយក្នុងឋានសួគ៌ អស់មួយកប្ប ។

ឧបាលិវគ្គទី ៤ ចប់

**ឧទ្ទាននៃឧបាលិវគ្គនោះ គឺ**

*និយាយអំពីព្រះឧបាលិ ១ ឧព្វាហិកាកម្មវាចា ១ ភិក្ខុគួរឲ្យឧបសម្បទាដល់កុលបុត្ត ១ ភិក្ខុគួរឲ្យនិស្ស័យ ១ ភិក្ខុគួរឲ្យសាមណេរបម្រើ ១ សង្ឃភេទ ២ លើក សង្ឃភេទ ២ លើកដទៃទៀត ដែលព្រះឧបាលិ និងព្រះអានន្ទទូលសួរ ។*

# អដ្ឋកថា

## អានន្ទសង្ឃសាមគ្គីសូត្រ

*[ ៣៩-៤០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអានន្ទសង្ឃសាមគ្គីសូត្រទី ១០ ដូចតទៅនេះ បទថា* **អនុគ្គហោ** *បានដល់ ការសង្គ្រោះ អនុគ្រោះដល់គ្នានិងគ្នា ។ ពាក្យដ៏សេសក្នុងទីគ្រប់អន្លើមានអត្ថងាយយល់ហើយ ។*

**អដ្ឋកថា អានន្ទសង្ឃសាមគ្គីសូត្រទី ១០ ចប់**

**ឧបាលិវគ្គទី ៤ ចប់**

# សុត្តន្តបិដក

# អង្គុត្តរនិកាយ (ខ)

# អក្កោសវគ្គទី ៩

## វិវាទសូត្រទី ១

[ ៤១ ] គ្រានោះ ព្រះឧបាលិដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះឧបាលិដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យសេចក្តីបង្កហេតុ ជម្លោះ សេចក្តីប្រកួតប្រកាន់ វិវាទគ្នា កើតឡើងក្នុងសង្ឃ ពួកភិក្ខុក៏នៅមិនសប្បាយ ។ ម្នាលឧបាលិ ពួកភិក្ខុក្នុងសាសនានេះ សម្តែងនូវសភាពមិនមែនធម៌ ថាជាធម៌ ១ សម្តែងនូវធម៌ថាមិនមែនជាធម៌ ១ សម្តែងនូវសភាពមិនមែនជាវិន័យ ថាជាវិន័យ ១ សម្តែងនូវវិន័យថាមិនមែនជាវិន័យ ១ សម្តែងនូវធម្មវិន័យ ដែលតថាគតមិនបានសម្តែង មិនបានពោលហើយ ថាជាធម្មវិន័យ ដែលតថាគតបានសម្តែង បានពោលហើយ ១ សម្តែងនូវធម្មវិន័យ ដែលតថាគតបានសម្តែង បានពោលហើយ ថាជាធម្មវិន័យ ដែលតថាគតមិនបានសម្តែង មិនបានពោលវិញ ១ សម្តែងនូវវត្តដែលតថាគតមិនបានសន្សំហើយ ថាជាវត្តដែលតថាគត បានសន្សំហើយ ១ សម្តែងនូវវត្តដែលតថាគតបានសន្សំហើយ ថាជាវត្តដែលតថាគត មិនបានសន្សំហើយ ១ សម្តែងនូវសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្តហើយ ថាជាសិក្ខាបទ ដែល

តថាគតបានបញ្ញត្តហើយ ១ សម្តែងនូវសិក្ខាបទ ដែលតថាគតបានបញ្ញត្តហើយ ថាជាសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្តហើយ ១ ។ ម្នាលឧបាលិ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យមានសេចក្តីបង្កហេតុ ជម្លោះ សេចក្តីប្រកួតប្រកាន់ វិវាទគ្នា កើតឡើងក្នុងសង្ឃ ពួកភិក្ខុក៏នៅមិនសប្បាយ ។

# អដ្ឋកថា

## អក្កោសវគ្គទី ៥

### វិវាទសូត្រ

[ ៤១ ] ក្នុងវិវាទសូត្រទី ១ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាវិវាទសូត្រទី ១ ចប់

# សុត្តន្តបិដក

## បឋមវិវាទមូលសូត្រទី ២

[ ៤២ ] បពិត្រព្រះអង្គដ៏ចម្រើន មូលហេតុនៃវិវាទ មានប៉ុន្មានយ៉ាង ។ ម្នាលឧបាលិ មូលហេតុនៃវិវាទមាន ១០ យ៉ាង ។ មូលហេតុនៃវិវាទ ១០ យ៉ាងតើដូចម្តេចខ្លះ ។ ម្នាលឧបាលិ ពួកភិក្ខុក្នុងសាសនានេះ សម្តែងនូវសភាពមិនមែនធម៌ ថាជាធម៌ ១ សម្តែងនូវធម៌ថា មិនមែនជាធម៌ ១ សម្តែងនូវសភាពមិនមែនវិន័យ ថាជាវិន័យ ១ សម្តែងនូវវិន័យ ថាមិនមែនជាវិន័យ ១ សម្តែងនូវធម្មវិន័យ ដែលតថាគតមិនបានសម្តែង មិនបានពោលហើយ ថាជាធម្មវិន័យ ដែលតថាគតបានសម្តែង បានពោលហើយ ១ សម្តែងនូវធម្មវិន័យ ដែលតថាគតបានសម្តែង បានពោលហើយ ថាជាធម្មវិន័យ ដែលតថាគតមិនបានសម្តែង មិនបានពោលវិញ ១ សម្តែងនូវវត្តដែលតថាគត មិនបានសន្សំហើយ ថាជាវត្តដែលតថាគត បានសន្សំហើយ ១ សម្តែងនូវវត្តដែលតថាគតបានសន្សំហើយ ថាជាវត្តដែលតថាគត មិនបានសន្សំហើយ ១ សម្តែងនូវសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្តហើយ ថាជាសិក្ខាបទ ដែលតថាគតបានបញ្ញត្តហើយ ១ សម្តែងនូវសិក្ខាបទ ដែលតថាគតបានបញ្ញត្តហើយ ថាជាសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្តហើយ ១ ។ ម្នាលឧបាលិ មូលហេតុនៃវិវាទមាន ១០ យ៉ាងនេះឯង ។

# អដ្ឋកថា

## បឋមវិវាទមូលសូត្រ

[ ៤២ ] ក្នុងបឋមវិវាទមូលសូត្រទី ២ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាបឋមវិវាទមូលសូត្រទី ២ ចប់

# សុត្តន្តបិដក

## ទុតិយវិវាទមូលសូត្រទី ៣

[ ៤៣ ] បពិត្រព្រះអង្គដ៏ចម្រើន មូលហេតុនៃវិវាទ តើមានប៉ុន្មានយ៉ាង ។ ម្នាលឧបាលិ មូលហេតុនៃវិវាទមាន ១០ យ៉ាង ។ មូលហេតុនៃវិវាទ ១០ យ៉ាងតើដូចម្ដេចខ្លះ ។ ម្នាលឧបាលិ ពួកភិក្ខុក្នុងសាសនានេះ សម្ដែងនូវអនាបត្តិ ជាជាអាបត្តិ ១ សម្ដែងនូវអាបត្តិ ជាជាអនាបត្តិ ១ សម្ដែងនូវលហុកាបត្តិ ជាជាគរុកាបត្តិ ១ សម្ដែងនូវគរុកាបត្តិ ជាជាលហុកាបត្តិ ១ សម្ដែងនូវទុដ្ឋុល្លាបត្តិ ជាជាអទុដ្ឋុល្លាបត្តិ ១ សម្ដែងអទុដ្ឋុល្លាបត្តិ ជាជាទុដ្ឋុល្លាបត្តិ ១ សម្ដែងនូវសាវសេសាបត្តិ ជាជាអនវសេសាបត្តិ ១ សម្ដែងនូវអនវសេសាបត្តិ ជាជាសាវសេសាបត្តិ ១ សម្ដែងសប្បដិកម្មាបត្តិ គឺអាបត្តិដែលកែបាន ជាជាអប្បដិកម្មាបត្តិ គឺអាបត្តិកែមិនបាន ១ សម្ដែងនូវអប្បដិកម្មាបត្តិ ជាជាសប្បដិកម្មាបត្តិ ១ ។ ម្នាលឧបាលិ មូលហេតុនៃវិវាទមាន ១០ យ៉ាង នេះឯង ។

# អដ្ឋកថា

## ទុតិយវិវាទមូលសូត្រ

[ ៤៣ ] ក្នុងទុតិយវិវាទមូលសូត្រទី ៣ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាទុតិយវិវាទមូលសូត្រទី ៣ ចប់

# សុត្តន្តបិដក

## កុសិនារាសូត្រទី ៤

[ ៤៤ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងដងព្រៃ ជាទីនាំទៅនូវពលិកម្ម ( ដើម្បីប្រយោជន៍ដល់ទេវតា ) ទៀបក្រុងកុសិនារា ។ ក្នុងទីនោះ ព្រះដ៏មានព្រះភាគ ត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយដូច្នេះ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកា នៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកចោទ មានបំណងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាធម៌ ៥ ប្រការ ចំពោះខ្លួនឯងសិន ត្រូវតាំងធម៌ ៥ ប្រការទុកក្នុងខ្លួន រួចសឹមចោទភិក្ខុដទៃ ។ ធម៌ ៥ ប្រការតើដូចម្តេច ដែលភិក្ខុអ្នកចោទ ត្រូវពិចារណាចំពោះខ្លួនឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកចោទ មានបំណងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាងនេះថា អាត្មាអញមានកាយសមាចារ បរិសុទ្ធឬហ្ន៎ អាត្មាអញជាអ្នកប្រកបដោយកាយសមាចារ ដ៏បរិសុទ្ធមិនធ្លុះធ្លាយ មិនមានទំនងគួរឲ្យគេចាប់ថ្នាក់

បាន ធម៌នុ៎ះមានគ្រប់គ្រាន់ដល់អាត្មាអញ ឬមិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមិនមានកាយសមាចារបរិសុទ្ធ តែមិនប្រកបដោយកាយសមាចារបរិសុទ្ធ មិនធ្លុះធ្លាយ មិនមានទំនងគួរឲ្យគេចាប់ថ្នាក់បាន ភិក្ខុនោះឯង គង់មានអ្នកផងស្តីជាស់តឿនថា នែលោកដ៏មានអាយុ លោកសិក្សានូវសមាចារ ផ្លូវកាយជាមុនសិន ភិក្ខុនោះគង់មានអ្នកផងស្តីជាស់តឿន ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុអ្នកចោទ មានបំណងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាងនេះថា អាត្មាអញមានវចីសមាចារបរិសុទ្ធឬហ្ន៎ អាត្មាអញប្រកបដោយវចីសមាចារដ៏បរិសុទ្ធ មិនធ្លុះធ្លាយ មិនមានទំនងគួរឲ្យគេចាប់ថ្នាក់បាន ធម៌នុ៎ះមានគ្រប់គ្រាន់ដល់អាត្មាអញ ឬមិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមិនមានវចី-សមាចារបរិសុទ្ធទេ មិនប្រកបដោយវចីសមាចារបរិសុទ្ធ មិនធ្លុះធ្លាយ មិនមានទំនងគួរឲ្យគេចាប់ថ្នាក់បាន ភិក្ខុនោះគង់មានអ្នកផង ស្តីជាស់តឿនថា នែលោកដ៏មានអាយុ ចូរលោកសិក្សានូវសមាចារ ផ្លូវវាចាជាមុនសិន ភិក្ខុនោះគង់មានអ្នកផងស្តីជាស់តឿន ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុអ្នកចោទមានបំណងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាងនេះថា ចិត្តរបស់អាត្មាអញមានមេត្តាតាំងមាំ មិនមានអាឃាត ក្នុងសព្រហ្មចារីបុគ្គលទេឬហ្ន៎ ធម៌នុ៎ះមានគ្រប់គ្រាន់ដល់អាត្មាអញ ឬមិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមិនតាំងមេត្តាចិត្ត ដែលមិនមានអាឃាត ក្នុងសព្រហ្មចារីបុគ្គលទេ ភិក្ខុនោះ គង់មានអ្នកផងស្តីជាស់តឿនថា នែលោកដ៏មានអាយុ ចូរលោកតាំងមេត្តាចិត្ត ( ឲ្យ

មាំ ) ក្នុងសព្រហ្មចារីបុគ្គលចុះ ភិក្ខុនោះគង់មានអ្នកផងស្តីដាស់តឿន ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុអ្នកចោទ មានបំណងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាងនេះថា អាត្មាអញជាពហុស្សូត ជាអ្នកទ្រទ្រង់នូវពុទ្ធវចនៈ ដែលខ្លួនបានស្តាប់មកហើយ សន្សំនូវពុទ្ធវចនៈដែលខ្លួនបានស្តាប់ ហើយឬហ្ន៎ ធម៌ទាំងឡាយណាមានលម្អបទដើម លម្អបទកណ្តាល លម្អបទចុង ប្រកាសនូវព្រហ្មចរិយៈ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈ ដ៏បរិសុទ្ធបរិបូណ៌ទាំងអស់ ធម៌ទាំងឡាយមានសភាពដូច្នោះ ដែលអាត្មាអញនោះបានស្តាប់ច្រើន បានទ្រទ្រង់ បានសន្សំដោយពាក្យ បានពិចារណាមុតមាំក្នុងចិត្ត បានយល់ត្រឹមត្រូវដោយទិដ្ឋិ ធម៌នុ៎ះមានគ្រប់គ្រាន់ដល់អាត្មាអញ ឬមិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមិនមែនជាពហុស្សូត ជាអ្នកទ្រទ្រង់នូវពុទ្ធវចនៈ ដែលខ្លួនបានស្តាប់ហើយ សន្សំទុកនូវពុទ្ធវចនៈ ដែលខ្លួនបានស្តាប់ហើយសោះទេ បើធម៌ទាំងឡាយណាមានលម្អបទដើម លម្អបទកណ្តាល លម្អបទចុង ប្រកាសនូវព្រហ្មចរិយៈ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈ ដ៏បរិសុទ្ធបរិបូណ៌ទាំងអស់ ធម៌ទាំងឡាយមានសភាពដូច្នោះ ភិក្ខុនោះជាអ្នកមិនបានស្តាប់ច្រើន ទ្រទ្រង់សន្សំដោយពាក្យ ពិចារណាមុតមាំក្នុងចិត្ត យល់ត្រឹមត្រូវដោយទិដ្ឋិទេ ភិក្ខុនោះឯង គង់មានអ្នកផងស្តីដាស់តឿនថា នែលោកដ៏មានអាយុ ចូរលោករៀននិកាយសិនទៅ ភិក្ខុនោះគង់មានអ្នកផងស្តីដាស់តឿន ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុអ្នកចោទ មានបំណងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាថា បាតិមោក្ខទាំងពីរ អាត្មាអញ

ចេះចាំដោយពិស្តារ ចែកចេញបានដោយប្រពៃ ចាំស្ទាត់រត់មាត់ កាត់សេចក្តីបានដោយល្អ តាមសូត្រ គឺខន្ធក: និងបរិវារ: តាមអនុព្យញ្ជនៈដែរឬ ធម៌នុ៎ះមានគ្រប់គ្រាន់ដល់អាត្មាអញ ឬមិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ បើបាតិមោក្ខទាំងពីរ ភិក្ខុមិនបានចេះចាំដោយពិស្តារ ចែកចេញដោយប្រពៃ ចាំស្ទាត់រត់មាត់ កាត់សេចក្តីដោយល្អ តាមសូត្រ តាមអនុព្យញ្ជនៈទេ ភិក្ខុនោះឯង បើមានគេសួរថា ម្នាលលោកដ៏មានអាយុ ចុះសិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់សម្តែងក្នុងទីណា មុខជានឹងឆ្លើយប្រាប់ទៅវិញមិនរួច ភិក្ខុនោះឯង គង់មានអ្នកផងស្តីជាស់តឿនថា នែលោកដ៏មានអាយុ ចូរលោករៀនទូវវិន័យសិនទៅ ភិក្ខុនោះ គង់មានអ្នកផងស្តីជាស់តឿន ១ ។ ធម៌ ៥ ប្រការនេះ ភិក្ខុត្រូវពិចារណាចំពោះខ្លួន ។ ធម៌ ៥ ប្រការ តើដូចម្តេច ដែលភិក្ខុអ្នកចោទ ត្រូវតាំងទុកក្នុងខ្លួន ។ អាត្មាអញនិយាយត្រូវតាមកាល មិននិយាយខុសកាល ១ អាត្មាអញនិយាយពាក្យពិត មិននិយាយពាក្យមិនពិត ១ អាត្មាអញនិយាយពាក្យផ្អែមល្ហែម មិននិយាយពាក្យអាក្រក់ ១ អាត្មាអញនិយាយពាក្យប្រកបដោយប្រយោជន៍ មិននិយាយពាក្យដែលឥតប្រយោជន៍ ១ អាត្មាអញតាំងមេត្តាចិត្តហើយសឹមនិយាយ មិននិយាយទាំងទោសចិត្ត ១ ។ ធម៌ ៥ ប្រការនេះឯង ដែលភិក្ខុអ្នកចោទ ត្រូវតាំងទុកក្នុងខ្លួន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកចោទ មានបំណងដើម្បីចោទភិក្ខុដទៃ ត្រូវពិចារណាធម៌ ៥ ប្រការនេះ ចំពោះខ្លួនហើយ ត្រូវតាំងធម៌ ៥ ប្រការនេះទុកក្នុងខ្លួន រួចសឹមចោទភិក្ខុដទៃ ។

# អដ្ឋកថា

## កុសិនារាសូត្រ

[ ៤៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកុសិនារាសូត្រទី ៤ នៃអក្កោសវគ្គទី ៥ ដូចតទៅនេះ ឈ្មោះថា **កុសិនារាយំ** បានដល់ នគរមានឈ្មោះយ៉ាងនោះ ជនទាំងឡាយ រមែងនាំពលីទៅសែន ដើម្បីជាប្រយោជន៍ដល់ទេវតាទាំង-ឡាយក្នុងទីនោះ ហេតុនោះ ទើបទីនោះ ឈ្មោះថា **ពលិហរណា** ជាទីនាំពលីទៅបួងសួង ។ ក្នុងទីធ្វើពលីទៅបួងសួងនោះ ។ ក្នុងបទថា **អច្ឆិទ្ទេន អប្ប-ដិមំសេន** ជាដើម គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា ការប្រមាទ ឬអនេសនកម្ម មានវេជ្ជកម្មជាដើម ដែលភិក្ខុរូបណាមួយធ្វើហើយ កាយសមាចាររបស់ភិក្ខុនោះ រមែងធ្លុះ ដូចស្នឹកត្នោតដែលកណ្ដៀរជាដើមកាត់ហើយ និងឈ្មោះថា ខ្វះខាត ព្រោះអាចពាល់ត្រូវ គឺចាប់ទីណាមួយអូសមកបាន កាយសមាចារផ្ទុយគ្នា ឈ្មោះថា មិនមានឱកាសមិនខ្វះខាត ។ ចំណែកវចីសមាចារ ឈ្មោះថា ជាឱកាសខុសឆ្គង ព្រោះនិយាយកុហក និយាយចាក់ដោត និយាយស៊ិកសៀត ចោទដោយអាបត្តិ ដែលមិនមានមូលជាដើម វចីសមាចារផ្ទុយគ្នា ឈ្មោះថា មិនមានឱកាសមិនខ្វះខាត ។ បទថា **មេត្តំ នុ ខោ មេ ចិត្តំ** បានដល់ មេត្តាចិត្តដែលភិក្ខុកាត់កង្វល់បានមកដោយការប្រកបរឿយៗ នូវកម្មដ្ឋានភាវនា ។ បទថា **អនាឃាតំ** បានដល់ វៀរអាឃាត អធិប្បាយថា កម្ចាត់អាឃាតដោយការសង្កត់ ។ បទថា **កត្ថ វុត្តំ** សេចក្ដីថា សិក្ខាបទនេះត្រាស់ត្រង់នគរណា ។

បទថា **កាលេន វក្ខាមិ** ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះថា ភិក្ខុឲ្យភិក្ខុដទៃធ្វើឱកាស ហើយចោទ ឈ្មោះថា ពោលដោយកាល ។ ចោទកណ្ដាលសង្ឃ កណ្ដាលគណៈ ត្រង់រោងស្លាក រោងយាគូ រោងភត្ត រោងពិភាក្សា ផ្លូវភិក្ខាចារ និងសាលាឆាន់ ត្រង់សាលាសម្រាប់ចូលគាល់ ឬក្នុងគណៈពួកឧបដ្ឋាក បវារណា ឈ្មោះថា ពោលដោយមិនមែនកាល ពោលដោយរឿងដែលពិត ឈ្មោះថា ពោលដោយរឿងពិត ពោលថា នែបា តាចាស់បាទម្ចាយបរិស័ទ បាកាន់បង្សុកូល បាអ្នកទេសកៈ នេះសមគួរដល់បាឬ ឈ្មោះថា ពោលដោយពាក្យគ្រោតគ្រាត ពោលថា លោកដ៏ចម្រើន លោកជាមនុស្សចាស់ លោកជាអ្នកអនុគ្រោះបរិស័ទ លោកជាអ្នកទ្រទ្រង់សំពត់បង្សុកូល លោកជាធម្មកថិក នេះសមគួរដល់លោកឬ ឈ្មោះថា ពោលដោយពាក្យពីរោះ ពោលដោយអាស្រ័យហេតុ ឈ្មោះថា ពោលដោយពាក្យអាស្រ័យប្រយោជន៍ ។ បទថា **មេត្តចិត្តោ វក្ខាមិ នោ ទោសន្តរោ** សេចក្ដីថា ព្រោះតាំងមេត្តាចិត្តពោល មិនមានបទុដ្ឋចិត្តពោលឡើយ ៕

## អដ្ឋកថា កុសិនារាសូត្រទី ៤ ចប់

# សុត្តន្តបិដក

## បវេសនសូត្រទី ៥

[ ៤៥ ] ម្នាលភិក្ខុទាំងឡាយ ទោស ១០ យ៉ាងនេះ រមែងមានក្នុងការចូលទៅខាងក្នុងរាជបុរី ។ ទោស ១០ យ៉ាងតើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំង-ឡាយ ព្រះរាជាក្នុងលោកនេះ កំពុងគង់នៅជាមួយនឹងមហេសី បើភិក្ខុចូលទៅក្នុងទីនោះ មហេសីបានឃើញភិក្ខុនោះ រមែងធ្វើនូវញញឹមឲ្យប្រាកដខ្លះ ភិក្ខុឃើញមហេសីហើយ ធ្វើនូវញញឹមឲ្យប្រាកដខ្លះ ព្រះរាជារមែងរង្កៀសក្នុងរឿងនោះយ៉ាងនេះថា ការកន្ទួងនូវមេថុន នៃអ្នកទាំងពីរនេះបានធ្វើហើយ ឬថា នឹងធ្វើនូវការកន្ទួង នូវមេថុនមិនខាន ។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ១ ក្នុងការចូលទៅក្នុងរាជបុរី ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះរាជាជាបុគ្គលមានកិច្ចច្រើន មានការងារច្រើន ទ្រង់ស្ដេចទៅប្រោសប្រាណស្ត្រីណាមួយហើយក៏ភ្លេចទៅ ឯស្ត្រីនោះក៏មានគភ៌ ដោយព្រះរាជានោះ ព្រះរាជារមែងរង្កៀសក្នុងរឿងនោះ យ៉ាងនេះថា បុគ្គលដទៃមួយដទៃ មិនដែលចូលទៅក្នុងទីនេះទេលើកលែងតែបព្វជិតចេញ ទំនងជាកម្មរបស់បព្វជិតទេដឹង ។ ម្នាលភិក្ខុទាំង-ឡាយ នេះជាទោសទី ២ ក្នុងការចូលទៅខាងក្នុងរាជបុរី ។ ម្នាលភិក្ខុទាំង-ឡាយ មួយទៀត រតនៈណាមួយក្នុងរាជបុរីបាត់ទៅ ព្រះរាជារមែងរង្កៀសក្នុងរឿងនោះ យ៉ាងនេះថា បុគ្គលដទៃមួយដទៃ មិនដែលចូលទៅក្នុងទីនេះទេ លើកលែងតែបព្វជិតចេញ ទំនងជាកម្មរបស់បព្វជិតទេដឹង ។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ៣ ក្នុងការចូលទៅខាងក្នុងរាជបុរី ។ ម្នាលភិក្ខុទាំងឡាយ មួយ

ទៀត រឿងរ៉ាវទាំងឡាយ ដែលព្រះរាជាត្រូវបិទបាំងទុកខាងក្នុង មាននៅខាងក្នុងបុរីរបស់ព្រះរាជា ត្រឡប់បែកខ្ចរខ្ចាយទៅខាងក្រៅ ព្រះរាជាទ្រង់រង្កៀសក្នុងរឿងនោះ យ៉ាងនេះថា បុគ្គលដទៃមួយដទៃ មិនដែលចូលទៅក្នុងទីនេះទេ លើកលែងតែបព្វជិតចេញ ទំនងជាកម្មរបស់បព្វជិតទេដឹង ។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ៤ ក្នុងការចូលទៅខាងក្នុងរាជបុរី ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះរាជបិតារមែងប្រាថ្នា ( ដើម្បីសម្លាប់ ) ព្រះរាជបុត្រខាងក្នុងរាជបុរី ឬថាព្រះរាជបុត្តប្រាថ្នា ( ដើម្បីសម្លាប់ ) ព្រះរាជបិតា ព្រះរាជបិតា និងព្រះរាជបុត្ត ទ្រង់រង្កៀសយ៉ាងនេះថា បុគ្គលទីមួយដទៃមិនដែលចូលទៅក្នុងទីនេះទេ លើកលែងតែបព្វជិតចេញ ទំនងជាកម្មរបស់បព្វជិតទេដឹង ។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ៥ ក្នុងការចូលទៅខាងក្នុងរាជបុរី ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ស្តេចទ្រង់តាំងមន្ត្រី ដែលតាំងនៅក្នុងតំណែងទាប ឲ្យឡើងកាន់តំណែងខ្ពស់ ការតាំងនោះ មិនជាទីគាប់ចិត្តរបស់ជនទាំងឡាយណា ជនទាំងឡាយនោះ រមែងរង្កៀសយ៉ាងនេះថា ស្តេចតែងនៅប្រឡូកប្រឡំដោយបព្វជិត ទំនងជាកម្មរបស់បព្វជិតទេដឹង ។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ៦ ក្នុងការចូលទៅខាងក្នុងរាជបុរី ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះរាជាទ្រង់បន្ថយមន្ត្រី ដែលតាំងនៅក្នុងតំណែងខ្ពស់ ឲ្យថយចុះក្នុងតំណែងទាបវិញ ការតាំងនោះមិនជាទីគាប់ចិត្ត របស់ជនទាំងឡាយណា ជនទាំងឡាយនោះ រមែងរង្កៀសយ៉ាងនេះថា ព្រះរាជាតែងនៅប្រឡូកប្រឡំ ដោយ

បព្វជិត ទំនងជាកម្មរបស់បព្វជិតទេដឹង ។ ម្នាលភិក្ខុទាំងឡាយ នេះជាទោស ទី ៧ ក្នុងការចូលទៅខាងក្នុងរាជបុរី ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះរាជា ទ្រង់បញ្ជូនកងទ័ពទៅក្នុងកាលមិនគួរ ការបញ្ជូនកងទ័ពទៅនោះ មិនជាទីគាប់ចិត្តរបស់ជនទាំងឡាយណា ជនទាំងឡាយនោះ រមែងរង្កៀសយ៉ាងនេះថា ព្រះរាជានៅប្រឡូកប្រឡំដោយបព្វជិត ទំនងជាកម្មរបស់បព្វជិតទេដឹង ។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ៨ ក្នុងការចូលទៅខាងក្នុងរាជបុរី ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះរាជាបញ្ជូនកងទ័ពទៅក្នុងកាលគួរ ហើយឲ្យត្រឡប់មកវិញ ពាក់កណ្តាលផ្លូវ ការឲ្យត្រឡប់មកវិញនោះ មិនជាទីគាប់ចិត្តរបស់ជនទាំងឡាយណា ជនទាំងឡាយនោះ រមែងរង្កៀសយ៉ាងនេះថា ព្រះរាជានៅប្រឡូកប្រឡំដោយបព្វជិត ទំនងជាកម្មរបស់បព្វជិតទេដឹង ។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ៩ ក្នុងការចូលទៅក្នុងរាជបុរី ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ខាងក្នុងរាជបុរី តែងចង្អៀតដោយដំរី ចង្អៀតដោយសេះ ចង្អៀតដោយរថ ទាំងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ជាហេតុនៃសេចក្តីត្រេកអរ សុទ្ធតែជារបស់មិនសមគួរដល់បព្វជិតទេ ។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ១០ ក្នុងការចូលទៅខាងក្នុងរាជបុរី ។ ម្នាលភិក្ខុទាំងឡាយ ទោស ១០ យ៉ាងនេះឯង រមែងមានក្នុងការចូលទៅខាងក្នុងរាជបុរី ។

# អដ្ឋកថា

## បវេសនសូត្រ

[ ៤៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបវេសនសូត្រទី ៥ ដូចតទៅនេះ បទថា **កតំ វា ករិស្សន្តិ វា** បានដល់ ធ្វើការកន្ទងល្មើសមេថុនហើយ ឬនឹងធ្វើការកន្ទងល្មើសមេថុននោះ ។ បទថា **រតនំ** បានដល់ បណ្ដារតនៈ មានមណីរតនៈជាដើមណាមួយ ។ បទថា **បត្ថេតិ** បានដល់ បំណងនឹងឲ្យស្លាប់ ។ បទថា **ហត្ថិសម្មទ្ទំ** ប្រែថា ដែលចង្អៀតដោយដំរី ។ បាឋៈថា **ហត្ថិមទ្ទនំ** ក៏មាន ។ ពាក្យនោះមានអត្ថថា ឈ្មោះថា **ហត្ថិសម្មទ្ទ** ព្រោះមានដំរីជាន់ ។ ក្នុងពាក្យដ៏សេសក៏ន័យនេះដូចគ្នា ។ បទថា **រជនីយានិ រូបសទ្ទគន្ធរសផោដ្ឋព្វានិ** សេចក្តីថា អារម្មណ៍ទាំងឡាយ មានរូបជាដើម ដែលធ្វើឲ្យកើតទាំងនោះ រមែងជារបស់ត្រូវញាក្នុងសេចក្តីនោះ ៕

**អដ្ឋកថា បវេសនសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## សក្កសូត្រទី ៦

[ ៤៦ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងនិគ្រោធារាម ទៀបក្រុងកបិលពស្តុ ក្នុងដែនសក្កៈ ។ គ្រានោះ ពួកសក្យឧបាសកជាច្រើន បានចូលទៅគាល់ព្រះដ៏មានព្រះភាគ ក្នុងថ្ងៃឧបោសថនោះ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះពួកសក្យ-ឧបាសក អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ បានត្រាស់ដូច្នេះថា ម្នាលសក្យៈទាំងឡាយ អ្នកទាំងឡាយ បានរក្សាឧបោសថប្រកបដោយអង្គ ៨ ដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ជួនកាលយើងទាំងឡាយ បានរក្សាឧបោសថ ប្រកបដោយអង្គ ៨ ជួនកាលយើងទាំងឡាយ មិនបានរក្សា ។ ម្នាលសក្យៈ ទាំងឡាយ អ្នកទាំងឡាយនោះ ពេញជាឥតលាភហើយ ការបាននូវអត្តភាព ជាមនុស្ស អ្នកទាំងឡាយនោះ បានដោយកម្រ ដ្បិតថា អ្នកទាំងឡាយ ជួនកាល ក៏បានរក្សាឧបោសថប្រកបដោយអង្គ ៨ ជួនកាល ក៏មិនបានរក្សា ក្នុងជីវិត ប្រកបដោយសោក និងភ័យ ក្នុងជីវិតប្រកបដោយមរណៈ និងភ័យយ៉ាងនេះ ។ ម្នាលសក្យៈទាំងឡាយ អ្នកទាំងឡាយ សម្គាល់ហេតុនោះដូចម្តេច ។ បុរស ក្នុងលោកនេះ ក្នុង ១ ថ្ងៃ រកបានកន្លះកហាបណៈ ដោយហេតុនៃការងារ ណាមួយ ដែលមិនប៉ះពាល់អកុសលកម្ម តើគួរហៅថា បុរសអ្នកឈ្លាស បរិបូណ៌ ដោយសេចក្តីព្យាយាមដែរឬទេ ។ ព្រះករុណា ព្រះអង្គ ។ ម្នាល សក្យៈទាំងឡាយ អ្នកទាំងឡាយ សម្គាល់ហេតុនោះដូចម្តេច ។ បុរសក្នុង

លោកនេះ ក្នុង ១ ថ្ងៃ រកបាន ១ កហាបណៈ ដោយហេតុនៃការងារណា មួយ ដែលមិនប៉ះពាល់អកុសលកម្ម តើគួរហៅថា បុរសអ្នកឈ្លាស បរិបូណ៌ ដោយសេចក្តីព្យាយាមដែរឬទេ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលសក្យៈ ទាំងឡាយ អ្នកទាំងឡាយ សម្គាល់នូវហេតុដូចម្តេច ។ បុរសក្នុងលោកនេះ ក្នុង ១ ថ្ងៃ រកបាន ២ កហាបណៈ ដោយហេតុនៃការងារណាមួយ ដែល មិនប៉ះពាល់អកុសលកម្ម រកបាន ៣ កហាបណៈ រកបាន ៤ កហាបណៈ រកបាន ៥ កហាបណៈ រកបាន ៦ កហាបណៈ រកបាន ៧ កហាបណៈ រក បាន ៨ កហាបណៈ រកបាន ៩ កហាបណៈ រកបាន ១០ កហាបណៈ រក បាន ២០ កហាបណៈ រកបាន ៣០ កហាបណៈ រកបាន ៤០ កហាបណៈ រកបាន ៥០ កហាបណៈ រកបាន ១០០ កហាបណៈ តើគួរហៅថា បុរស អ្នកឈ្លាស បរិបូណ៌ដោយសេចក្តីព្យាយាមដែរឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលសក្យៈទាំងឡាយ អ្នកទាំងឡាយ សម្គាល់ហេតុនោះដូចម្តេច ។ បុរស នោះ កាលរកបាន ១០០ កហាបណៈ ១០០០ កហាបណៈ ក្នុងមួយថ្ងៃ ទុកដាក់នូវកហាបណៈដែលខ្លួនរកបានហើយៗ រស់នៅបាន ១០០ ឆ្នាំ គប្បី បាននូវគំនរនៃភោគៈដ៏ច្រើនដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលសក្យៈទាំង-ឡាយ អ្នកទាំងឡាយសម្គាល់នូវហេតុនោះដូចម្តេច ។ បុរសនោះ គប្បីបាន ទទួលនូវសុខយ៉ាងឯក អស់រាត្រីមួយ ឬមួយថ្ងៃ អស់កន្លះរាត្រី ឬកន្លះថ្ងៃ ដែលមានភោគៈជាហេតុ មានភោគៈជាគ្រឿងប្រគល់ឲ្យ មានភោគៈជាអធិ-

ករណី មែនដែរឬ ។ ហេតុនុ៎ះ មិនមែនទេព្រះអង្គ ។ រឿងនោះ ព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា កាមទាំងឡាយមិនទៀង ទទេ មិនពិត វិនាសទៅជាធម្មតា ។ ម្នាលសក្យៈទាំងឡាយ ចំណែកខាងសាវ័ករបស់តថាគត ក្នុងសាសនានេះ ជាអ្នកមិនមានសេចក្តីប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ប្រតិបត្តិតាមពាក្យដែលតថាគតប្រៀនប្រដៅហើយអស់ ១០ ឆ្នាំ គប្បីទទួលសេចក្តីសុខយ៉ាងឯក អស់ ១០០ ឆ្នាំក៏មាន ១០០០០ ( ១ ម៉ឺន ) ឆ្នាំក៏មាន ១០០០០០ ( ១ សែន ) ឆ្នាំក៏មាន ។ សាវ័ករបស់តថាគតនោះ បានជាសកទាគាមីខ្លះ អនាគាមីខ្លះ បានដល់សោតៈពិតប្រាកដខ្លះ ។ ម្នាលសក្យៈទាំងឡាយ ១០ ឆ្នាំលើកទុកចុះ សាវ័ករបស់តថាគតក្នុងសាសនានេះ ជាអ្នកមិនមានសេចក្តីប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ប្រតិបត្តិតាមពាក្យដែលតថាគតប្រៀនប្រដៅហើយ អស់ ៩ ឆ្នាំ ៨ ឆ្នាំ ៧ ឆ្នាំ ៦ ឆ្នាំ ៥ ឆ្នាំ ៤ ឆ្នាំ ៣ ឆ្នាំ ២ ឆ្នាំ ១ ឆ្នាំ គប្បីទទួលនូវសេចក្តីសុខយ៉ាងឯក អស់ ១០០ ឆ្នាំក៏មាន ១០០០០ ( ១ ម៉ឺន ) ឆ្នាំក៏មាន ១០០០០០ ( ១ សែន ) ឆ្នាំក៏មាន ។ សាវ័ករបស់តថាគតនោះ បានជាសកទាគាមីខ្លះ អនាគាមីខ្លះ បានដល់សោតៈពិតប្រាកដខ្លះ ។ ម្នាលសក្យៈទាំងឡាយ ១ ឆ្នាំលើកទុកចុះ សាវ័ករបស់តថាគតក្នុងសាសនានេះ ជាអ្នកមិនមានសេចក្តីប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ប្រតិបត្តិតាមពាក្យដែលតថាគតប្រៀនប្រដៅហើយ

អស់ត្រឹមតែ ១០ ខែ ក៏គប្បីទទួលនូវសេចក្តីសុខយ៉ាងឯកអស់ ១០០ ឆ្នាំក៏មាន ១០០០០ ( ១ ម៉ឺន ) ឆ្នាំក៏មាន ១០០០០០ ( ១ សែន ) ឆ្នាំក៏មាន ។ សាវ័ករបស់តថាគតនោះ បានជាសកទាគាមីខ្លះ អនាគាមីខ្លះ បានដល់សោតៈពិតប្រាកដខ្លះ ។ ម្នាលសក្យៈទាំងឡាយ ១០ ខែលើកទុកចុះ សាវ័ករបស់តថាគត ក្នុងសាសនានេះ ជាអ្នកមិនមានសេចក្តីប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ប្រតិបត្តិតាមពាក្យដែលតថាគតប្រៀនប្រដៅហើយ អស់ ៩ ខែ ៨ ខែ ៧ ខែ ៦ ខែ ៥ ខែ ៤ ខែ ៣ ខែ ២ ខែ ១ ខែ កន្លះខែ ក៏គប្បីបានទទួលនូវសេចក្តីសុខយ៉ាងឯកអស់ ១០០ ឆ្នាំក៏មាន ១០០០០ ( ១ ម៉ឺន ) ឆ្នាំក៏មាន ១០០០០០ ( ១ សែន ) ឆ្នាំក៏មាន ។ សាវ័ករបស់តថាគតនោះ បានជាសកទាគាមីខ្លះ អនាគាមីខ្លះ បានដល់សោតៈពិតប្រាកដខ្លះ ។ ម្នាលសក្យៈទាំងឡាយ កន្លះខែលើកទុកចុះ សាវ័ករបស់តថាគត ក្នុងសាសនានេះ ជាអ្នកមិនមានសេចក្តីប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ប្រតិបត្តិតាមពាក្យដែលតថាគតប្រៀនប្រដៅហើយ អស់យប់ និងថ្ងៃ ១០ ក៏គប្បីបានទទួលនូវសេចក្តីសុខយ៉ាងឯកអស់ ១០០ ឆ្នាំក៏មាន ១០០០០ ( ១ ម៉ឺន ) ឆ្នាំ ក៏មាន ១០០០០០ ( ១ សែន ) ឆ្នាំក៏មាន ។ សាវ័ករបស់តថាគតនោះ បានជាសកទាគាមីខ្លះ អនាគាមីខ្លះ បានដល់សោតៈពិតប្រាកដខ្លះ ។ ម្នាលសក្យៈទាំងឡាយ យប់ និងថ្ងៃ ១០ លើកទុកចុះ សាវ័ករបស់តថាគតក្នុងសាសនានេះ ជាអ្នកមិនមានសេចក្តីប្រមាទ មានព្យាយាមជា

គ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ប្រតិបត្តិតាមពាក្យដែលតថាគតប្រៀនប្រដៅហើយ អស់យប់ និងថ្ងៃ ៩ យប់ និងថ្ងៃ ៨ យប់ និងថ្ងៃ ៧ យប់ និងថ្ងៃ ៦ យប់ និងថ្ងៃ ៥ យប់ និងថ្ងៃ ៤ យប់ និងថ្ងៃ ៣ យប់ និងថ្ងៃ ២ យប់ និងថ្ងៃ ១ ក៏គប្បីបានទទួលនូវសេចក្តីសុខយ៉ាងឯកអស់ ១០០ ឆ្នាំក៏មាន ១០០០០ ( ១ ម៉ឺន ) ឆ្នាំ ក៏មាន ១០០០០០ ( ១ សែន ) ឆ្នាំក៏មាន ។ សាវ័ករបស់តថាគតនោះ បានជាសកទាគាមីខ្លះ អនាគាមីខ្លះ បានដល់សោតៈពិតប្រាកដខ្លះ ។ ម្នាលសក្យៈទាំងឡាយ អ្នកទាំងឡាយចំជាឥតលាភហើយ ការបាននូវអត្តភាពជាមនុស្ស អ្នកទាំងឡាយនោះបានដោយកម្រដ្បិតថា អ្នកទាំងឡាយ ជួនកាល បានរក្សាឧបោសថប្រកបដោយអង្គ ៨ ជួនកាល មិនបានរក្សា ក្នុងជីវិតប្រកបដោយសោក និងភ័យ ក្នុងជីវិតប្រកបដោយមរណៈ និងភ័យយ៉ាងនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន យើងទាំងឡាយនេះនឹងរក្សានូវឧបោសថប្រកបដោយអង្គ ៨ ចាប់ដើមតាំងពីថ្ងៃនេះ តរៀងទៅ ។

# អដ្ឋកថា

## សក្កសូត្រ

[ ៤៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសក្កសូត្រទី ៦ ដូចតទៅនេះ បទថា **សោកសភយេ** ប្រែថា មានភ័យព្រោះសេចក្តីសោក ។ បាឋៈថា **សោក-ភយេ** ដូច្នេះក៏មាន ។ ក្នុងបទទី ២ ក៏មានន័យនេះដូចគ្នា ។ បទថា **យេឍ**

**កម្មដ្ឋានេន** សេចក្តីថា បណ្តាការងារទាំងឡាយ មានការភ្ជួរ ការលក់ដូរជាដើម ការងារណាមួយ ។ បទថា **អនាបជ្ជ អកុសលំ** សេចក្តីថា មិនដល់អកុសលណាមួយ ។ បទថា **និព្វិសេយ្យ** បានដល់ គប្បីឲ្យកើតឡើង មិនគប្បីឲ្យបាត់បង់ទៅ ។ បទថា **ឧក្ខោ** ប្រែថា អ្នកឈ្លាស ។ បទថា **ឧដ្ឋានសម្បន្នោ** បានដល់ ដែលប្រកបដោយសេចក្តីព្យាយាម ។ បទថា **អលំវចនាយ** ប្រែថា គួរនឹងពោល ។ បទថា **ឯកន្តសុខប្បដិសំវេទី វិហារេយ្យ** សេចក្តីថា ទទួលសោយសុខផ្លូវកាយ និងផ្លូវចិត្តដោយចំណែកមួយ ដោយញាណ ។

បទថា **អនិច្ចា** បានដល់ មានហើយ ក៏មិនមាន ។ បទថា **តុច្ឆា** បានដល់ វៀរចាកការផ្អែតក្នុងចិត្ត ។ បទថា **មុសា** បានដល់ កាម សូម្បីកន្ទង ហាក់បីដូចជាខៀង ស្អាត និងសុខ ក៏មិនជាយ៉ាងនោះ ហេតុនោះ ទើបឈ្មោះថា **មោសធម្មា** បានដល់ មានការវិនាសទៅជាសភាវៈ ព្រោះដូច្នោះទើបទ្រង់ចង្អុលបង្ហាញថា អាស្រ័យកាមទាំងនោះ ទើបកើតទុក្ខ ។ បទថា **វោ** ក្នុងពាក្យថា **ឥធ ខោ បន វោ** នេះ ត្រឹមតែជានិបាត ។ បទថា **អបណ្ណកំ វា សោតាបន្នោ** សេចក្តីថា ឬថា ជាសោតាបន្នបដិបត្តិមិនខុសដោយចំណែកមួយ ។ បុគ្គលនោះធ្វើឈានឲ្យកើតហើយ ក៏ទៅព្រហ្មលោក ឬសោយសុខដោយចំណែកមួយ ។ ក្នុងកាមាវចរ ៦ ជាន់ ។ ក្នុងព្រះសូត្រនេះ ព្រះសាស្តាត្រាស់គុណរបស់ឧបោសថប្រកបដោយអង្គ ៨ ។ល។

# សុត្តន្តបិដក

## មហាលិសូត្រទី ៧

[ ៤៧ ] *សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារសាលា នាមហាវ័ន ជិតក្រុងវេសាលី ។ គ្រានោះ លិច្ឆវីឈ្មោះមហាលិ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះលិច្ឆវីឈ្មោះមហាលិ អង្គុយក្នុងទីសមគួរ ហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ចុះអ្វីជាហេតុ អ្វីជាបច្ច័យ នៃកិរិយាធ្វើនូវកម្មដ៏លាមក នៃកិរិយាប្រព្រឹត្តទៅនៃកម្មដ៏លាមក ។ ម្នាលមហាលិ លោភៈជាហេតុ លោភៈជាបច្ច័យ នៃកិរិយាធ្វើនូវកម្មដ៏លាមក នៃកិរិយាប្រព្រឹត្តទៅនៃកម្មដ៏លាមក ម្នាលមហាលិ ទោសៈជាហេតុ ទោសៈជាបច្ច័យ នៃកិរិយាធ្វើនូវកម្មដ៏លាមក នៃកិរិយាប្រព្រឹត្តទៅនៃកម្មដ៏លាមក ម្នាលមហាលិ មោហៈជាហេតុ មោហៈជាបច្ច័យ នៃកិរិយាធ្វើនូវកម្មដ៏លាមក នៃកិរិយាប្រព្រឹត្តទៅនៃកម្មដ៏លាមក ម្នាលមហាលិ អយោនិសោមនសិការ ( ការមិនបានធ្វើទុកក្នុងចិត្តដោយឧបាយ ) ជាហេតុ អយោនិសោមនសិការជាបច្ច័យ នៃកិរិយាធ្វើនូវកម្មដ៏លាមក នៃកិរិយាប្រព្រឹត្តទៅនៃកម្មដ៏លាមក ម្នាលមហាលិ ចិត្តដែលបុគ្គលតម្កល់ខុសជាហេតុ ចិត្តដែលបុគ្គលតម្កល់ខុសជាបច្ច័យ នៃកិរិយាធ្វើនូវកម្មដ៏លាមក នៃកិរិយាប្រព្រឹត្តទៅនៃកម្មដ៏លាមក ។ ម្នាលមហាលិ នេះជាហេតុ នេះជាបច្ច័យ នៃកិរិយាធ្វើនូវកម្មដ៏លាមក នៃកិរិយាប្រព្រឹត្តទៅនៃកម្មដ៏លាមក ។ បពិត្រព្រះអង្គដ៏ចម្រើន*

ចុះអ្វីជាហេតុ អ្វីជាបច្ច័យ នៃកិរិយាធ្វើនូវកម្មដ៏ល្អ នៃកិរិយាប្រព្រឹត្តទៅនៃកម្មដ៏ល្អ ។ ម្នាលមហាលិ អលោភៈ ( ការមិនលោភ ) ជាហេតុ អលោភៈជាបច្ច័យ នៃកិរិយាធ្វើនូវកម្មដ៏ល្អ នៃកិរិយាប្រព្រឹត្តទៅនៃកម្មដ៏ល្អ ម្នាលមហាលិ អទោសៈ ( ការមិនប្រទូស្ត ) ជាហេតុ អទោសៈជាបច្ច័យ នៃកិរិយាធ្វើនូវកម្មដ៏ល្អ នៃកិរិយាប្រព្រឹត្តទៅនៃកម្មដ៏ល្អ ម្នាលមហាលិ អមោហៈ ( ការមិនវង្វេង ) ជាហេតុ អមោហៈជាបច្ច័យ នៃកិរិយាធ្វើនូវកម្មដ៏ល្អ នៃកិរិយាប្រព្រឹត្តទៅនៃកម្មដ៏ល្អ ម្នាលមហាលិ យោនិសោមនសិការ ( ការធ្វើទុកក្នុងចិត្តដោយឧបាយ ) ជាហេតុ យោនិសោមនសិការជាបច្ច័យ នៃកិរិយាធ្វើនូវកម្មដ៏ល្អ នៃកិរិយាប្រព្រឹត្តទៅនៃកម្មដ៏ល្អ ម្នាលមហាលិ ចិត្តដែលបុគ្គលតម្កល់ត្រូវជាហេតុ ចិត្តដែលបុគ្គលតម្កល់ត្រូវជាបច្ច័យ នៃកិរិយាធ្វើនូវកម្មដ៏ល្អ នៃកិរិយាប្រព្រឹត្តទៅនៃកម្មដ៏ល្អ ។ ម្នាលមហាលិ នេះជាហេតុ នេះជាបច្ច័យ នៃកិរិយាធ្វើនូវកម្មដ៏ល្អ នៃកិរិយាប្រព្រឹត្តទៅនៃកម្មដ៏ល្អ ។ ម្នាលមហាលិ បើធម៌ ១០ យ៉ាងនេះ មិនគប្បីមានក្នុងលោកទេ ពាក្យថា អធម្មចរិយាវិសមចរិយាក្តី ពាក្យធម្មចរិយសមចរិយាក្តី ក៏មិនគប្បីប្រាកដក្នុងលោកនេះដែរ ។ ម្នាលមហាលិ ព្រោះតែធម៌ ១០ យ៉ាងនេះ មានប្រាកដក្នុងលោក ហេតុនោះ បានជាពាក្យថា អធម្មចរិយាវិសមចរិយាក្តី ធម្មចរិយសមចរិយាក្តី ទើបមានប្រាកដ ។

# អដ្ឋកថា

## មហាលិសូត្រ

[ ៤៧ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងមហាលិសូត្រទី ៧ ដូចតទៅនេះ បទថា* **មិច្ឆាបណិហិតំ** *ប្រែថា ដែលគេតាំងទុកខុស ។ បទថា* **អធម្មចរិយា-វិសមចរិយា** *សេចក្តីថា គប្បីជ្រាបវិសមចរិយា គឺការប្រព្រឹត្តមិនរាបស្មើពោល គឺអធម្មចរិយា ការប្រព្រឹត្តអធម៌ ក៏ដោយអំណាចអកុសលកម្មបថចរិយាក្រៅអំពីនេះ ក៏ដោយអំណាចកុសលកម្មបថ ។ ក្នុងព្រះសូត្រនេះត្រាស់ចំពោះវដ្តៈប៉ុណ្ណោះ ដោយប្រការដូច្នេះ ។*

**អដ្ឋកថា មហាលិសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## អភិណ្ហប្បច្ចវេក្ខណធម្មសូត្រទី ៨

[ ៤៨ ] *ម្នាលភិក្ខុទាំងឡាយធម៌ ១០ យ៉ាងនេះបព្វជិតគប្បីពិចារណារឿយៗ ។ ធម៌ ១០ គឺអ្វីខ្លះ ។ គឺបព្វជិតគប្បីពិចារណារឿយៗ ថា អាត្មាអញកាន់យកនូវភេទដ៏ប្លែក អំពីភេទរបស់គ្រហស្ថ ១ បព្វជិតគប្បីពិចា-រណារឿយៗ ថា ការប្រព្រឹត្តចិញ្ចឹមជីវិតរបស់អាត្មាអញប្រព្រឹត្តជាប់ដោយបុគ្គលដទៃ ១ បព្វជិតគប្បីពិចារណារឿយៗ ថា អាកប្បកិរិយាផ្សេងអំពី*

គ្រហស្ថ អាត្មាអញគួរធ្វើ ១ បព្វជិតគប្បីពិចារណារឿយៗ ថា អាត្មាអញមិនតិះដៀលខ្លួនឯងដោយសីលធម៌បានទេឬ ១ បព្វជិតគប្បីពិចារណារឿយៗ ថា ពួកសព្រហ្មចារីជាវិញ្ញូជនគយគន់មើលហើយ មិនតិះដៀលអាត្មាអញដោយសីលធម៌បានទេឬ ១ បព្វជិតគប្បីពិចារណារឿយៗ ថា ការព្រាត់ប្រាសនិរាសចាកសត្វ និងសង្ខារទាំងអស់ ដែលជាទីស្រឡាញ់ ជាទីគាប់ចិត្តនៃអាត្មាអញ តែងមានជាធម្មតា ១ បព្វជិតគប្បីពិចារណារឿយៗ ថា អាត្មាអញមានកម្មជារបស់ខ្លួន មានកម្មជាទាយាទ មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាគ្រឿងរឭកឃើញ អាត្មាអញនឹងធ្វើនូវកម្មណា ល្អ ឬអាក្រក់ អាត្មាអញគង់នឹងបានជាអ្នកទទួលយកនូវផលនៃកម្មនោះ ពុំខានឡើយ ១ បព្វជិតគប្បីពិចារណារឿយៗ ថា យប់ និងថ្ងៃទាំងឡាយ ចេះតែកន្លងទៅៗ តើអាត្មាអញបានធ្វើដូចម្តេចខ្លះហើយ ១ បព្វជិតគប្បីពិចារណារឿយៗ ថា សព្វថ្ងៃនេះ អាត្មាអញមានសេចក្តីអភិរម្យត្រេកអរក្នុងផ្ទះដ៏ស្ងាត់ខ្លះដែរឬទេ ១ បព្វជិតគប្បីពិចារណារឿយៗ ថា ឧត្តរិមនុស្សធម៌ គឺធម៌ជារបស់មនុស្សដ៏ប្រសើរក្រៃលែង មានដល់អាត្មាអញដែរឬ ធម៌ដ៏វិសេសដែលគួរនឹងឃើញដោយប្រាជ្ញាដ៏ប្រសើរ អាត្មាអញបានត្រាស់ដឹងហើយឬអាត្មាអញនោះ សព្រហ្មចារីទាំងឡាយ សួរក្នុងកាលជាទីបំផុត ( មរណសម័យ ) នឹងមិនអឹមអៀមទេឬ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាងនេះឯង បព្វជិតគប្បីពិចារណារឿយៗ ។

# អដ្ឋកថា

## អភិណ្ហប្បច្ចវេក្ខណធម្មសូត្រ

[ ៤៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអភិណ្ហប្បច្ចវេក្ខណធម្មសូត្រទី ៨ ដូច្នេះ បទថា **បព្វជិតេន** បានដល់ ដែលលះឃរាវាស គឺការគ្រប់គ្រងផ្ទះ ចូលដល់ការបួសក្នុងព្រះសាសនា ។ បទថា **អភិណ្ហំ** ប្រែថា រឿយៗ ញយៗ ។ បទថា **បច្ចវេក្ខិតព្វា** ប្រែថា គប្បីពិចារណាមើល គប្បីកំណត់មើល ។

បទថា **វេវណ្ណិយំ** ប្រែថា មានភេទផ្សេង មានរូបរាងផ្សេងៗ ។ ការមានភេទផ្សេងនោះ មាន ២ យ៉ាង គឺការមានភេទផ្សេងដោយសរីរៈ ១ ការមានភេទផ្សេងដោយបរិក្ខារ ១ បណ្ដាការមានភេទផ្សេង ២ យ៉ាងនោះ ការមានភេទផ្សេងដោយសរីរៈ គប្បីជ្រាបបានដោយការកោរសក់ និងពុតមាត់ ។ មុនបួសក៏ស្លៀកសំពត់ ត្រូវប្រើសំពត់ល្អ សាច់ម៉ដ្ឋ ជ្រលក់ពណ៌ផ្សេងៗ សូម្បីបរិភោគ ក៏ត្រូវបរិភោគរសឆ្ងាញ់ផ្សេងៗ ដាក់ភាជនៈមាសនិងប្រាក់ សូម្បីដេក ឬអង្គុយ ក៏ត្រូវដេក និងអង្គុយយ៉ាងល្អ ក្នុងបន្ទប់ដ៏ស្អាត សូម្បីប្រកបថ្នាំ ក៏ត្រូវប្រើសប្បិ នវនីតជាដើម តាំងអំពីបួសហើយ ចាំបាច់ត្រូវស្លៀកសំពត់ដែលកាត់ដាច់ សំពត់ប៉ះ សំពត់ជ្រលក់ទឹកម្ចត់ ឆាន់តែបាយដែលលាយក្នុងបាត្រដែក ឬបាត្រដី ត្រូវដេកលើគ្រែដែលក្រាលដោយស្មៅជាដើម ក្នុងសេនាសនៈ មានគល់ឈើជាដើម ចាំបាច់ត្រូវអង្គុយលើកំណាត់ស្បែក និងកន្ទេលផែងជាដើម ចាំបាច់ត្រូវប្រកបថ្នាំ ដោយទឹកមូត្រស្អុយជាដើម ។ គប្បីជ្រាបការមានភេទផ្សេងដោយបរិក្ខារក្នុងសេចក្ដីនេះ

ដោយប្រការដូច្នេះ ។ បព្វជិតពិចារណាយ៉ាងនេះ រមែងលះកោបៈ គឺការអាក់អន់ និងមានះ គឺការប្រកាន់ខ្លួនបាន ។

បទថា **បរប្បដិពទ្ធា មេ ជីវិកា** សេចក្តីថា បព្វជិតគប្បីពិចារណាយ៉ាងនេះថា ភាពជាអ្នករស់នៅដោយបច្ច័យ ៤ ចាំបាច់ទាក់ទងក្នុងអ្នកដទៃ ឥរិយាបថក៏សមគួរ អាជីវៈក៏បរិសុទ្ធ ទាំងជាការគោរពកោតក្រែងដល់បិណ្ឌ-បាត ឈ្មោះថា ជាអ្នកបរិភោគមិនពិចារណាក្នុងបច្ច័យ ៤ ក៏មិនមែន ។

បទថា **អញ្ញោ មេ អាកប្បោ ករណីយោ** សេចក្តីថា បព្វជិតគប្បីពិចារណាថា អាកប្បកិរិយាដើរដែលបុគ្គលណារបស់គ្រហស្ថ គឺការឈានទៅមុខមិនកំណត់ដោយអាការពើងទ្រូងយ៉ាងសង្ហា អញគប្បីធ្វើអាកប្បកិរិយាផ្សេងអំពីអាកប្បកិរិយារបស់គ្រហស្ថនោះ អញគប្បីមានឥន្ទ្រិយស្ងប់ មានចិត្តស្ងប់ សម្លឹងមួយជួរនឹម ឈានជំហានកំណត់តែបន្តិច មិនឈានវែង គប្បីដើរទៅដូចរទេះដឹកទឹក ក្នុងទីមិនរាបស្មើ ។ ដ្បិតថា បព្វជិតពិចារណាយ៉ាងនេះ រមែងមានអាកប្បកិរិយាសមគួរ សិក្ខា ៣ រមែងបរិបូណ៌ ។

សព្ទថា **កច្ចិ នុ ខោ** សង្គ្រោះនិបាតចុះក្នុងការកំណត់ ។ បទថា **អត្តា** បានដល់ ចិត្ត ។ បទថា **សីលតោ ន ឧបវទតិ** បានដល់ មិនតិះដៀលខ្លួនឯង ព្រោះសីលជាបច្ច័យយ៉ាងនេះថា សីលរបស់អញមិនបរិបូណ៌ ។ ដ្បិតថា បព្វជិតពិចារណាយ៉ាងនេះ រមែងតាំងហិរិ គឺការខ្មាសខាងក្នុង ។ ហិរិនោះ ក៏សម្រេចការសង្រួមក្នុងទ្វារទាំង ៣ ។ ការសង្រួមក្នុង

*ក្នុងទ្វារទាំង ៣ រមែងជាចតុប្បារិសុទ្ធិសីល បព្វជិតដែលតាំងនៅក្នុងចតុ-ប្បារិសុទ្ធសីល ចម្រើនវិបស្សនាហើយ រមែងទាញយកអរហត្តបាន ។*

*បទថា* **អនុវិច្ច វិញ្ញូ សព្រហ្មចារី** *សេចក្តីថា ពួកសព្រហ្មចារីដែលជាអ្នកប្រព្រឹត្តព្រហ្មចរិយៈរួមជាមួយបុគ្គលដែលជាបណ្ឌិត ពិចារណាហើយ ដ្បិតថា បព្វជិតពិចារណាយ៉ាងនេះ ឱត្តប្បៈ ការក្រែងខ្លាចបាបខាងក្រៅ រមែងតាំងឡើង ។ ឱត្តប្បៈនោះ រមែងឲ្យសម្រេចការសង្រួមក្នុងទ្វារទាំង ៣ ដូច្នោះ ទើបគួរជ្រាបដោយន័យក្នុងលំដាប់បន្ទាប់មកនោះឯង ។*

*បទថា* **ឆាឆាភាវោ វិឆាភាវោ** *សេចក្តីថា ការកើតផ្សេងៗ ព្រោះកើតមក រមែងព្រាត់ប្រាសព្រោះមរណៈ ដ្បិតថា បព្វជិតពិចារណាយ៉ាងនេះ ឈ្មោះថា មិនមានអាការ គឺប្រមាទក្នុងទ្វារទាំង ៣ ។ មរណស្សតិ គឺការរឭកដល់សេចក្តីស្លាប់ ឈ្មោះថា ចុះស៊ប់ដោយល្អ ។*

*ក្នុងបទថា* **កម្មស្សកោម្ហិ** *ជាដើម គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា កម្មជារបស់អញ គឺជាសម្បត្តិរបស់ខ្លួន ហេតុនោះ ទើបអាត្មាអញជាបុគ្គលមានកម្មជារបស់ខ្លួន ។ ផលដែលកម្មគប្បីឲ្យ ឈ្មោះថា* **ផលទាយ** *ផលនៃកម្មឈ្មោះថា* **កម្មទាយ** *អាត្មាអញរមែងទទួលផលនៃកម្មនោះ ហេតុនោះ ទើបអាត្មាអញជាបុគ្គលទទួលផលនៃកម្ម ។ កម្មជាកំណើត គឺហេតុរបស់អាត្មាអញ ហេតុនោះ ទើបអាត្មាអញជាបុគ្គលមានកម្មជាកំណើត ។ កម្មជាផៅពង្សជាញាតិរបស់អញ ហេតុនោះ ទើបជាបុគ្គលមានកម្មជាផៅពង្ស ។ កម្មដែល*

គប្បីអាស្រ័យរបស់អញ ហេតុនោះ ទើបអញជាបុគ្គលមានកម្ម ដែលគប្បីអាស្រ័យ ។ បទថា **តស្ស ទាយាទោ ភវិស្សាមិ** បានដល់ អញនឹងជាទាយាទ គឺជាបុគ្គលទទួលផលដែលកម្មនោះឲ្យហើយ ដ្បិតថា បព្វជិតពិចារណាដល់ការដែលបុគ្គលមានកម្ម ជារបស់ខ្លួនយ៉ាងនោះ រមែងមិនឈ្មោះថាធ្វើបាប ។

បទថា **កថម្ភូតស្ស មេ រត្តិន្ទិវា វីតិបតន្តិ** សេចក្តីថា យប់ថ្ងៃកន្លងទៅ ប្រែប្រួលទៅ អាត្មាដូចម្តេច គឺអាត្មាអញកំពុងធ្វើវត្តបដិបត្តិ ឬមិនធ្វើ កំពុងទន្ទេញព្រះពុទ្ធវចនៈ ឬមិនទន្ទេញ កំពុងធ្វើកិច្ចកម្មក្នុងយោនិសោមនសិការ ឬមិនធ្វើ ដ្បិតថា បព្វជិតពិចារណាយ៉ាងនេះ ការមិនប្រមាទ រមែងបរិបូណ៌ ។

បទថា **សុញ្ញាគារេ អភិរមាមិ** សេចក្តីថា អាត្មាអញតែម្នាក់នៅក្នុងគ្រប់ឥរិយាបថ នៅក្នុងឱកាសដ៏ស្ងាត់ ត្រេកអរក្រៃលែងឬហ្ន៎ ដ្បិតថា បព្វជិតពិចារណាយ៉ាងនេះ កាយវិវេករមែងបរិបូណ៌ ។

បទថា **ឧត្តរិមនុស្សធម្មា** សេចក្តីថា ធម៌ទាំងឡាយ មានឈានជាដើម របស់បុគ្គលអ្នកបានឈាន និងព្រះអរិយៈដែលជាមនុស្សដ៏ក្រៃលែងជាមនុស្ស ឬធម៌ទាំងឡាយដែលក្រៃលែង ដែលប្រសើរជាងមនុស្សធម៌ ពោល គឺអកុសលកម្មបថ ១០ មាន គឺកើតនៅក្នុងសន្តានរបស់អាត្មាអញឬ ។ បទថា **អលមរិយញាណទស្សនវិសេសោ** សេចក្តីថា ឈ្មោះថា **ញាណ**

ព្រោះអត្ថថា ឲ្យកើតមហគ្គតប្បញ្ញា និងលោកុត្តរប្បញ្ញា ឈ្មោះថា **ទស្សន** ព្រោះអត្ថថា ឃើញធម៌ ដោយធ្វើឲ្យប្រចក្ស ដូចឃើញដោយចក្ខុ ហេតុនោះ ទើបឈ្មោះថា **ញាណទស្សន** ។ ញាណទស្សនៈដែលជាអរិយៈ គឺបរិសុទ្ធ ហេតុនោះ ទើបឈ្មោះថា **អរិយញាណទស្សន** ។ អរិយញាណទស្សនៈ ដែលអាច គឺជាអរិយៈ អាចកម្ចាត់កិលេស មានក្នុងធម៌នោះ ឬដល់ធម៌នោះ ហេតុនោះ ទើបធម៌នោះ ឈ្មោះថា **អលមរិយញាណទស្សន** បានដល់ ធម៌របស់មនុស្សដ៏ក្រៃលែង មានឈានជាដើម ។ អលមរិយញាណទស្សនៈនោះផង វិសេសផង ហេតុនោះ ទើបឈ្មោះថា **អលមរិយញាណទស្សនវិសេសោ** ។ ម្យ៉ាងទៀត គុណវិសេស គឺញាណទស្សនៈដ៏បរិសុទ្ធ អាចកម្ចាត់កិលេសបាននោះឯង ហេតុនោះ ទើបឈ្មោះថា **អលមរិយញាណទស្សនវិសេសេ** ក៏បាន ។ បទថា **អធិគតោ** បានដល់ សេចក្តីវិសេសដែលអាត្មាអញបានហើយ មានឬហ្ន៎ ។ បទថា **សោហំ** បានដល់ អាត្មាអញមានគុណវិសេសដែលបានហើយ ។ បទថា **បច្ឆិមេ កាលេ** បានដល់ ក្នុងកាលដេកលើគ្រែសម្រាប់ស្លាប់ ។ បទថា **បុដ្ឋោ** បានដល់ ត្រូវសព្រហ្មចារីសួរដល់គុណវិសេសដែលសម្រេច ។ បទថា **ន មង្កុ ភវិស្សាមិ** បានដល់ អញនឹងមិនជាបុគ្គលឱនក អស់នូវអំណាច ដ្បិតថា បព្វជិតពិចារណាយ៉ាងនេះ រមែងមិនឈ្មោះថា ស្លាប់ទទេ ។ល។

## អដ្ឋកថាអភិណ្ហប្បច្ចវេក្ខណធម្មសូត្រទី ៨ ចប់

# សុត្តន្តបិដក

## សរីរដ្ឋធម្មសូត្រទី ៩

[ ៤៩ ] ម្នាលភិក្ខុទាំងឡាយ ធម៌ដែលឋិតនៅក្នុងសរីរៈ ១០ យ៉ាង នេះ បព្វជិតគប្បីពិចារណារឿយៗ ។ ធម៌ ១០ យ៉ាង តើអ្វីខ្លះ ។ គឺត្រជាក់ ១ ក្តៅ ១ សេចក្តីឃ្លាន ១ ស្រេក ១ ឧច្ចារៈ ១ បស្សាវៈ ១ សង្រួមកាយ ១ សង្រួមវាចា ១ សង្រួមក្នុងការចិញ្ចឹមជីវិត ១ ភវសង្ខារដែលនាំសត្វឲ្យកើតក្នុងភពទៀត ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាងនេះឯងដែលឋិតនៅក្នុងសរីរៈ ។

# អដ្ឋកថា

## សរីរដ្ឋធម្មសូត្រ

[ ៤៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសរីរដ្ឋធម្មសូត្រទី ៩ ដូចតទៅនេះ បទថា **ពោនោព្ភវិកោ** បានដល់ កើតក្នុងភពថ្មីទៀត ។ បទថា **ភវសង្ខារោ** បានដល់ កម្មជាគ្រឿងតាក់តែងភព ។ ក្នុងព្រះសូត្រនេះ ត្រាស់ចំពោះវដ្តៈប៉ុណ្ណោះ ។

### អដ្ឋកថា សរីរដ្ឋធម្មសូត្រទី ៩ ចប់

# សុត្តន្តបិដក

## ភណ្ឌនសូត្រទី ១០

[ ៥០ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកភិក្ខុច្រើនរូប ត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្តហើយ អង្គុយប្រជុំគ្នា ក្នុងឧបដ្ឋានសាលា កើតមានសេចក្ដីប្រកួតប្រកាន់ ឈ្លោះប្រកែក និយាយចាក់ដោតគ្នា ដោយលំពែង គឺមាត់ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ចេញចាកទីពួនសម្ងំ ក្នុងសាយណ្ហសម័យ ក៏ចូលទៅរកឧបដ្ឋានសាលា លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគទ្រង់គង់ហើយ ក៏ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នា ដោយកថាដូចម្ដេច ចុះអន្តរាកថាដូចម្ដេច ដែលអ្នកទាំងឡាយ ធ្វើមិនទាន់ដាច់ស្រេច ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីនេះ យើងខ្ញុំទាំងឡាយ ត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្ត ហើយអង្គុយប្រជុំគ្នា ក្នុងឧបដ្ឋានសាលា ក៏កើតមានសេចក្ដីប្រកួតប្រកាន់ ឈ្លោះប្រកែក និយាយចាក់ដោតគ្នា ដោយលំពែងគឺមាត់ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមានសេចក្ដីប្រកួតប្រកាន់ ឈ្លោះប្រកែក និយាយចាក់ដោតគ្នា ដោយលំពែង គឺមាត់ ព្រោះហេតុណា ហេតុនុ៎ះ មិនសមគួរដល់អ្នកទាំងឡាយជាកុលបុត្រ អ្នកមានសទ្ធាចេញចាកផ្ទះ ចូលមកកាន់ផ្នួសសោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាងនេះ ជាធម៌គួររឭករកគ្នា ធ្វើ

នូវសេចក្ដីស្រឡាញ់ ធ្វើនូវសេចក្ដីគោរព ប្រព្រឹត្តទៅដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្ដីព្រមព្រៀង ដើម្បីមូលមិត្តគ្នា ។ ធម៌ ១០ យ៉ាងតើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌អាចារ និងគោចរ ឃើញភ័យក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសីល ។បេ។ សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ដោយហេតុណា នេះជាធម៌គួររឭករកគ្នា ធ្វើនូវសេចក្ដីស្រឡាញ់ ធ្វើនូវសេចក្ដីគោរព ប្រព្រឹត្តទៅដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្ដីព្រមព្រៀង ដើម្បីមូលមិត្តគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាពហុស្សូត ទ្រទ្រង់នូវពុទ្ធវចនៈ ដែលខ្លួនបានស្ដាប់ហើយ សន្សំទុកនូវពុទ្ធវចនៈដែលខ្លួនបានស្ដាប់ហើយ ធម៌ទាំងឡាយណា មានលម្អបទដើម លម្អបទកណ្ដាល លម្អបទចុង ប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈដ៏បរិសុទ្ធបរិបូណ៌ទាំងអស់ ធម៌ទាំងឡាយមានសភាពដូច្នោះ ភិក្ខុនោះឯង ក៏បានស្ដាប់ច្រើន បានចាំទុក ចាំស្ទាត់រត់មាត់ ជាក់ច្បាស់ក្នុងចិត្ត ត្រាស់ដឹងល្អដោយទិដ្ឋិ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាពហុស្សូត ។បេ។ ចេះដឹងល្អដោយទិដ្ឋិ ដោយហេតុណា នេះជាធម៌គួររឭករកគ្នា ធ្វើនូវសេចក្ដីស្រឡាញ់ ធ្វើនូវសេចក្ដីគោរព ប្រព្រឹត្តទៅដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្ដីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមានមិត្ត

ល្អ មានសម្លាញ់ល្អ សមគប់រកមិត្តល្អ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានមិត្តល្អ មានសម្លាញ់ល្អ សមគប់រកមិត្តល្អ ដោយហេតុណា នេះជាធម៌គួររឭករកគ្នា ធ្វើនូវសេចក្តីស្រឡាញ់ ធ្វើនូវសេចក្តីគោរព ប្រព្រឹត្តទៅដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុដែលគេប្រដៅងាយ ប្រកបដោយធម៌ជាគ្រឿងធ្វើនូវភាវៈជាអ្នកប្រដៅងាយ ជាអ្នកអត់ធន់ ទទួលយកនូវពាក្យប្រៀនប្រដៅដោយចំណែកខាងស្តាំ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលគេប្រដៅងាយ ប្រកបដោយធម៌ ជាគ្រឿងធ្វើនូវភាវៈជាអ្នកប្រដៅងាយ ជាអ្នកអត់ធន់ ទទួលយកនូវពាក្យប្រៀនប្រដៅ ដោយចំណែកខាងស្តាំ ដោយហេតុណា នេះជាធម៌គួររឭករកគ្នា ធ្វើនូវសេចក្តីស្រឡាញ់ ធ្វើនូវសេចក្តីគោរព ប្រព្រឹត្តទៅដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត កិច្ចការណានីមួយ ធំ ឬតូច របស់សព្រហ្មចារីបុគ្គលទាំងឡាយ ភិក្ខុជាអ្នកប៉ិនប្រសប់ មិនខ្ជិលច្រអូសក្នុងកិច្ចការទាំងនោះ ប្រកបដោយឧបាយជាគ្រឿងពិចារណា ក្នុងកិច្ចការទាំងនោះថា គួរធ្វើ គួរចាត់ចែង ។ ម្នាលភិក្ខុទាំងឡាយ កិច្ចការណានីមួយ ធំ ឬតូចរបស់សព្រហ្មចារីបុគ្គលទាំងឡាយ ភិក្ខុជាអ្នកប៉ិនប្រសប់មិនខ្ជិលច្រអូសក្នុងកិច្ចការទាំងនោះ ប្រកបដោយឧបាយជាគ្រឿងពិចារណា ក្នុងកិច្ចការទាំងនោះថា គួរធ្វើ គួរចាត់ចែង ដោយហេតុណា នេះជាធម៌គួររឭករកគ្នា ធ្វើនូវ

សេចក្តីស្រឡាញ់ ធ្វើនូវសេចក្តីគោរព ប្រព្រឹត្តទៅដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកប្រាថ្នាក្នុងធម៌ មានការហៅរកដោយពាក្យជាទីស្រឡាញ់ អ្នកមានសេចក្តីរីករាយដ៏លើសលុប ក្នុងអភិធម្ម ក្នុងអភិវិន័យ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រាថ្នានូវធម៌ មានការហៅរកដោយពាក្យជាទីស្រឡាញ់ អ្នកមានសេចក្តីរីករាយដ៏លើសលុបក្នុងអភិធម្ម ក្នុងអភិវិន័យ ដោយហេតុណា នេះជាធម៌គួររឭករកគ្នា ធ្វើនូវសេចក្តីស្រឡាញ់ ធ្វើនូវសេចក្តីគោរព ប្រព្រឹត្តទៅដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកប្រារព្ធព្យាយាម ដើម្បីលះបង់ពួកអកុសលធម៌ ដើម្បីធ្វើនូវពួកកុសលធម៌ឲ្យបរិបូណ៌ ជាអ្នកមានកម្លាំង មានសេចក្តីប្រឹងប្រែងមាំមួន មិនដាក់ធុរៈក្នុងពួកកុសលធម៌ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រារព្ធព្យាយាមដើម្បី លះបង់ពួកអកុសល-ធម៌ ដើម្បីធ្វើពួកកុសលធម៌ឲ្យបរិបូណ៌ ជាអ្នកមានកម្លាំង មានសេចក្តីប្រឹងប្រែងមាំមួន មិនដាក់ធុរៈក្នុងពួកកុសលធម៌ ដោយហេតុណា នេះជាធម៌គួររឭករកគ្នា ធ្វើនូវសេចក្តីស្រឡាញ់ ធ្វើនូវសេចក្តីគោរព ប្រព្រឹត្តទៅ ដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមានតាមបាន ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកសន្តោសដោយចីវរបិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារតាមមាន តាមបាន ដោយហេតុណា នេះជាធម៌គួររឭករកគ្នា ធ្វើនូវសេចក្តីស្រឡាញ់ ធ្វើនូវសេចក្តីគោរព ប្រព្រឹត្តទៅដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានស្មារតី ប្រកបដោយស្មារតី និងការៈជាអ្នកមានប្រាជ្ញាចាស់ក្លាដ៏ប្រសើរ រឭកឃើញរឿយៗ នូវកិច្ចដែលខ្លួនធ្វើយូរហើយផង នូវសម្តីដែលខ្លួននិយាយយូរហើយផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានស្មារតី ប្រកបដោយស្មារតី និងការៈជាអ្នកមានប្រាជ្ញាចាស់ក្លាដ៏ប្រសើរ រឭកឃើញរឿយៗ នូវកិច្ចដែលខ្លួនធ្វើយូរហើយផង នូវសម្តីដែលខ្លួននិយាយយូរហើយផង ដោយហេតុណា នេះជាធម៌គួររឭករកគ្នា ធ្វើនូវសេចក្តីស្រឡាញ់ ធ្វើនូវសេចក្តីគោរព ប្រព្រឹត្តទៅដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុជាអ្នកមានបញ្ញា ប្រកបដោយបញ្ញា ដែលអាចកំណត់នូវការកើតឡើង និងសេចក្តីវិនាសទៅ ( នៃខន្ធបញ្ចកៈ ) ជាបញ្ញាដ៏ប្រសើរ ជាគ្រឿងទម្លាយបង់នូវកិលេស ជាធម្មជាតដល់នូវការអស់ទៅនៃទុក្ខដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានបញ្ញា ប្រកបដោយបញ្ញា ដែលអាចកំណត់នូវការកើតឡើង និងវិនាសទៅ ជាបញ្ញាដ៏ប្រសើរ ជាគ្រឿងទម្លាយបង់នូវកិលេស ជាធម្មជាតដល់នូវកិរិយា

អស់ទៅនៃទុក្ខដោយប្រពៃ ដោយហេតុណា នេះជាធម៌គួររឭករកគ្នា ធ្វើនូវសេចក្ដីស្រឡាញ់ ធ្វើនូវសេចក្ដីគោរព ប្រព្រឹត្តទៅដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្ដីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាងនេះឯង ជាធម៌គួររឭករកគ្នា ធ្វើនូវសេចក្ដីស្រឡាញ់ ធ្វើនូវសេចក្ដីគោរព ប្រព្រឹត្តទៅដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្ដីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ។

អក្កោសវគ្គទី ៥ ចប់

## ឧទ្ទាននៃអក្កោសវគ្គនោះ គឺ

និយាយអំពីវិវាទ ១ វិវាទមូលពីរលើក ព្រះដ៏មាន
ព្រះភាគទ្រង់គង់ក្នុងនគរកុសិនារា ១ ទោសក្នុងការ
ចូលទៅខាងក្នុងរាជបុរី ១ សក្យឧបាសក ១ លច្ឆវី
ឈ្មោះមហាលិ ១ ធម៌ដែលបព្វជិត គួរពិចារណា
រឿយៗ ១ ធម៌ដែលឋិតនៅក្នុងសរីរៈ ១ ពួកភិក្ខុអ្នក
មានសេចក្ដីប្រកួតប្រកាន់គ្នា ១ ។

# អដ្ឋកថា

## ភណ្ឌនសូត្រ

[ ៥០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងភណ្ឌនសូត្រទី ១០ ដូចតទៅនេះ ព្រះមានព្រះភាគត្រាស់សីល ពាហុសច្ចៈ វីរិយៈ សតិ និងបញ្ញាលាយគ្នា ទាំងលោកិយ និងលោកុត្តរ ។ ពាក្យដ៏សេស ក្នុងទីគ្រប់អន្ទើ មានអត្ថងាយយល់ហើយ ៕៚

**អដ្ឋកថាភណ្ឌនសូត្រទី ១០ ចប់**

**អក្កោសកវគ្គទី ៥ ចប់**

**បឋមបណ្ណាសក ចប់**

# សុត្តន្តបិដក
# ទុតិយបណ្ណាសក

## សចិត្តវគ្គទី ៦

### សចិត្តសូត្រទី ១

[ ៥១ ] *សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ដូច្នេះ ។ ភិក្ខុទាំងនោះ ទទួលតបព្រះពុទ្ធដីកា នៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគបានត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមិនឈ្លាសក្នុងវារៈនៃចិត្តអ្នកដទៃទេ ត្រូវគិតថាយើងទាំងឡាយ គួរជាអ្នកឈ្លាសក្នុងវារៈនៃចិត្តរបស់ខ្លួន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកឈ្លាសក្នុងវារៈនៃចិត្តរបស់ខ្លួន តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដូចជាស្ត្រី ឬបុរសកំលោះជំទង់ ប្រកបដោយជាតិជាអ្នកស្អិតស្អាង កាលពិចារណាមើលនូវស្រមោលមុខរបស់ខ្លួនក្នុងកញ្ចក់ដែលបរិសុទ្ធផូរផង់ ឬក្នុងភាជន៍ទឹកថ្លា បើឃើញធូលី ឬកន្ទួលក្នុងកញ្ចក់នោះ រមែងព្យាយាមដើម្បីលះបង់នូវធូលី ឬកន្ទួលនោះចេញ បើមិនឃើញធូលី ឬកន្ទួលក្នុងកញ្ចក់នោះទេ ក៏មានចិត្តត្រេកអរ មានសេចក្តីត្រិះរិះគ្រប់គ្រាន់ ដោយ*

ហេតុនោះថា ឱហ្ន៎ អាត្មាអញមានលាភ ឱហ្ន៎ មុខរបស់អាត្មាអញបរិសុទ្ធ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ឧបមេយ្យដូចជាការពិចារណាក្នុងកុសលធម៌ទាំងឡាយ រមែងមានឧបការៈច្រើនដល់ភិក្ខុថា អាត្មាអញជាអ្នកមានអភិជ្ឈាច្រើនឬហ្ន៎ អាត្មាអញជាអ្នកមិនមានអភិជ្ឈាច្រើនឬហ្ន៎ អាត្មាអញជាអ្នកមានចិត្តព្យាបាទច្រើនឬហ្ន៎ អាត្មាអញជាអ្នកមិនមានចិត្តព្យាបាទច្រើនឬហ្ន៎ អាត្មាអញជាអ្នកត្រូវថីនមិទ្ធៈរួបរឹតច្រើនឬហ្ន៎ អាត្មាអញជាអ្នកប្រាសចាកថីនមិទ្ធៈច្រើនឬហ្ន៎ អាត្មាអញជាអ្នកមានចិត្តរវើរវាយច្រើនឬហ្ន៎ អាត្មាអញជាអ្នកមិនមានចិត្តរវើរវាយច្រើនឬហ្ន៎ អាត្មាអញជាអ្នកមានវិចិកិច្ឆាច្រើនឬហ្ន៎ អាត្មាអញជាអ្នកឆ្លងចាកវិចិកិច្ឆាច្រើនឬហ្ន៎ អាត្មាអញមានសេចក្តីក្រោធច្រើនឬហ្ន៎ អាត្មាអញជាអ្នកមានចិត្តសៅហ្មងច្រើនឬហ្ន៎ អាត្មាអញជាអ្នកមានចិត្តមិនសៅហ្មងច្រើនឬហ្ន៎ អាត្មាអញជាអ្នកមានកាយក្រវល់ក្រវាយច្រើនឬហ្ន៎ អាត្មាអញមានកាយមិនបានក្រវល់ក្រវាយច្រើនឬហ្ន៎ អាត្មាអញមានសេចក្តីខ្ជិលច្រអូសច្រើនឬហ្ន៎ អាត្មាអញមានព្យាយាមប្រារព្ធហើយច្រើនឬហ្ន៎ អាត្មាអញមានចិត្តមិនខ្ជាប់ខ្ជួនច្រើនឬហ្ន៎ អាត្មាអញមានចិត្តខ្ជាប់ខ្ជួនច្រើនឬហ្ន៎ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុកាលពិចារណាដឹងយ៉ាងនេះថា អាត្មាអញមានអភិជ្ឈាច្រើន អាត្មាអញមានចិត្តព្យាបាទច្រើន អាត្មាអញត្រូវថីនមិទ្ធៈរួបរឹតច្រើន អាត្មាអញមានចិត្តរវើរវាយច្រើន អាត្មាអញមានវិចិកិច្ឆាច្រើន អាត្មាអញមានសេចក្តីក្រោធច្រើន អាត្មាអញមានចិត្តសៅហ្មង

ច្រើន អាត្មាអញមានកាយក្រវល់ក្រវាយច្រើន អាត្មាអញជាអ្នកខ្ជិលច្រអូស ច្រើន អាត្មាអញមានចិត្តមិនខ្ជាប់ខ្ជួនច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ គប្បីធ្វើនូវសេចក្តីប៉ុនប៉ងផង សេចក្តីព្យាយាមផង ឱ្យឃ្មាតផង សេចក្តីប្រឹង ប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីលះបង់នូវពួកអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលភិក្ខុទាំង-ឡាយ ដូចជាសំពត់ដែលភ្លើងឆេះ ឬក្បាលដែលត្រូវភ្លើងឆេះ បុគ្គលគប្បីធ្វើ នូវសេចក្តីប៉ុនប៉ងផង ព្យាយាមផង ឱ្យឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិន រួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីលត់សំពត់ ឬ ក្បាលនោះឯង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីធ្វើនូវ សេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីឱ្យឃ្មាតផង ប្រឹងប្រែងផង សេចក្តី មិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីលះបង់នូវពួក អកុសលធម៌ដ៏លាមកទាំងនោះ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បើ ភិក្ខុកាលពិចារណាដឹងយ៉ាងនេះថា អាត្មាអញជាអ្នកមិនមានអភិជ្ឈាច្រើន អាត្មា អញជាអ្នកមានចិត្តមិនព្យាបាទច្រើន អាត្មាអញជាអ្នកប្រាសចាកថីនមិទ្ធៈច្រើន អាត្មាអញជាអ្នកមានចិត្តមិនអណ្តែងអណ្តូងច្រើន អាត្មាអញជាអ្នកឆ្លងចាក វិចិកិច្ឆាច្រើន អាត្មាអញជាអ្នកមិនមានសេចក្តីក្រោធច្រើន អាត្មាអញជាអ្នក មានចិត្តមិនសៅហ្មងច្រើន អាត្មាអញជាអ្នកមានកាយមិនក្រវល់ក្រវាយច្រើន អាត្មាអញជាអ្នកប្រារព្ធសេចក្តីព្យាយាមច្រើន អាត្មាអញជាអ្នកមានចិត្តខ្ជាប់

ខ្លួនច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីតាំងនៅក្នុងកុសលធម៌ទាំងនោះ ធ្វើព្យាយាមដើម្បីឲ្យអស់ទៅនៃអាសវៈទាំងឡាយតទៅ ។

# អដ្ឋកថា

# ទុតិយបណ្ណាសក

## សចិត្តវគ្គទី ១

### សចិត្តសូត្រ

[ ៥១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសចិត្តសូត្រទី ១ នៃទុតិយបណ្ណាសក ដូចតទៅនេះ បទថា **សចិត្តបរិយាយកុសលា** ប្រែថា ដែលឈ្លាសក្នុងវារចិត្តរបស់ខ្លួន ។ បទថា **រជំ** បានដល់ ឧបក្កិលេសដែលចរមក ។ បទថា **អង្គណំ** បានដល់ អាចម៍រុយ និងប្រជ្រុយជាដើមកើតក្នុងមុខនិមិត្ត គឺស្រមោលមុខនោះ ។ បទថា **អាសវានំ ខយាយ** បានដល់ ដើម្បីជាប្រយោជន៍ដល់អរហត្ត ។ល។

**អដ្ឋកថា សចិត្តសូត្រទី ១ ចប់**

# សុត្តន្តបិដក

## សារិបុត្តសូត្រទី ២

[ ៥២ ] ក្នុងទីនោះឯង ព្រះសារីបុត្តដ៏មានអាយុ ហៅភិក្ខុទាំងឡាយថា ម្នាលអាវុសោភិក្ខុទាំងឡាយ ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ថេរវាចារបស់ព្រះសារីបុត្តដ៏មានអាយុថា ករុណាអាវុសោ ។ ព្រះសារីបុត្តដ៏មានអាយុបានពោលពាក្យនេះថា ម្នាលអាវុសោទាំងឡាយ បើភិក្ខុមិនឆ្លាសក្នុងវារៈនៃចិត្តបុគ្គលដទៃទេ ត្រូវគិតថា យើងទាំងឡាយ គួរជាអ្នកឆ្លាសក្នុងវារៈនៃចិត្តរបស់ខ្លួន ។ ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយគួរសិក្សាយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ចុះភិក្ខុជាអ្នកឆ្លាសក្នុងវារៈនៃចិត្តរបស់ខ្លួន តើដោយប្រការដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ដូចជាស្ត្រី ឬបុរសកំលោះជំទង់ ប្រកបដោយជាតិជាអ្នកស្អិតស្អាង កាលពិចារណាមើលស្រមោលរបស់ខ្លួនក្នុងកញ្ចក់ ដែលបរិសុទ្ធផូរផង់ ឬក្នុងភាជន៍ទឹកថ្លា បើឃើញធូលី ឬកន្ទួលក្នុងកញ្ចក់ ក៏រមែងព្យាយាមលះបង់នូវធូលី ឬកន្ទួលនោះចេញ បើមិនឃើញធូលី ឬកន្ទួលនោះទេ ក៏មានចិត្តត្រេកអរ មានតម្រិះគ្រប់គ្រាន់ ដោយហេតុនោះថា ឱហ្ន៎ អាត្មាអញមានលាភ ឱហ្ន៎ ( មុខ ) របស់អាត្មាអញបរិសុទ្ធយ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ ឧបមេយ្យដូចជា ការពិចារណាក្នុងកុសលធម៌ទាំងឡាយ រមែងមានឧបការៈច្រើនដល់ភិក្ខុថា អាត្មាអញជាអ្នកមានអភិជ្ឈាច្រើនឬហ្ន៎ អាត្មាអញជាអ្នកមិនមានអភិជ្ឈាច្រើនឬហ្ន៎ អាត្មាអញមានចិត្តព្យាបាទច្រើនឬហ្ន៎ អាត្មាអញត្រូវថីនមិទ្ធៈរួបរឹតច្រើនឬហ្ន៎ អាត្មាអញ

មិនមានចិត្តព្យាបាទច្រើនឬហ្ន៎ អាត្មាអញប្រាសចាកថីនមិទ្ធៈច្រើនឬហ្ន៎ អាត្មាអញមានចិត្តអណ្តែតអណ្តូងច្រើនឬហ្ន៎ អាត្មាអញមិនមានចិត្តអណ្តែតអណ្តូងច្រើនឬហ្ន៎ អាត្មាអញមានវិចិកិច្ឆាច្រើនឬហ្ន៎ អាត្មាអញឆ្លងវិចិកិច្ឆាច្រើនឬហ្ន៎ អាត្មាអញមានសេចក្តីក្រោធច្រើនឬហ្ន៎ អាត្មាអញមិនមានសេចក្តីក្រោធច្រើនឬហ្ន៎ អាត្មាអញមានចិត្តសៅហ្មងច្រើនឬហ្ន៎ អាត្មាអញមិនមានចិត្តសៅហ្មងច្រើនឬហ្ន៎ អាត្មាអញមានកាយក្រវល់ក្រវាយច្រើនឬហ្ន៎ អាត្មាអញមានកាយមិនក្រវល់ក្រវាយច្រើនឬហ្ន៎ អាត្មាអញខ្ជិលច្រអូសច្រើនឬហ្ន៎ អាត្មាអញប្រារព្ធព្យាយាមច្រើនឬហ្ន៎ អាត្មាអញមានចិត្តមិនខ្ជាប់ខ្ជួនច្រើនឬហ្ន៎ អាត្មាអញមានចិត្តខ្ជាប់ខ្ជួនច្រើនឬហ្ន៎ ។ ម្នាលអាវុសោទាំងឡាយ បើភិក្ខុពិចារណារមែងដឹងយ៉ាងនេះថា អាត្មាអញមានអភិជ្ឈាច្រើន ។បេ។ អាត្មាអញមានចិត្តមិនបានខ្ជាប់ខ្ជួនច្រើន ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគប្បីធ្វើនូវសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង មិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ ដូចជាសំពត់ដែលត្រូវភ្លើងឆេះ ឬក្បាលដែលត្រូវភ្លើងឆេះ បុគ្គលគប្បីប្រញាប់ធ្វើនូវសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីលត់សំពត់ ឬក្បាលនោះឯង យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះ គប្បីប្រញាប់ធ្វើនូវសេចក្តីប៉ុន

ប៉ុនផង ព្យាយាមផង សេចក្ដីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្ដីមិនរួញរាផង សតិផង សម្បជញ្ញៈផងឲ្យលើសលុប ដើម្បីលះបង់នូវពួកអកុសលធម៌ដ៏លាមកទាំងនោះចេញ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោទាំងឡាយ បើភិក្ខុពិចារណាវមែងដឹងយ៉ាងនេះថា អាត្មាអញជាអ្នកមិនមានអភិជ្ឈាច្រើន ។បេ។ អាត្មាអញមានចិត្តខាប់ខ្ជួនច្រើន ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះ គួរតាំងនៅក្នុងកុសលធម៌ទាំងនោះ ហើយធ្វើនូវសេចក្ដីព្យាយាមដើម្បីអស់ទៅនៃអាសវៈទាំងឡាយតទៅ ។

# អដ្ឋកថា

## សារិបុត្តសូត្រ

[ ៥២ ] ក្នុងសារិបុត្តសូត្រទី ២ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាសារិបុត្តសូត្រទី ២ ចប់

# សុត្តន្តបិដក

## ឋិតិសូត្រទី ៣

[ ៥៣ ] ម្នាលភិក្ខុទាំងឡាយ តថាគតមិនសរសើរ ការតាំងនៅដដែល ក្នុងកុសលធម៌ទាំងឡាយទេ នឹងបាច់និយាយថ្វី ដល់ការសាបសូន្យ ។ ម្នាលភិក្ខុទាំងឡាយ តថាគតសរសើរនូវសេចក្តីចម្រើន ក្នុងកុសលធម៌ទាំងឡាយតែម្យ៉ាង មិនសរសើរការតាំងនៅដដែល មិនសរសើរការសាបសូន្យទេ ។ ម្នាលភិក្ខុទាំងឡាយ ការសាបសូន្យក្នុងកុសលធម៌ទាំងឡាយ មិនមែនជាការតាំងនៅដដែល មិនមែនជាការចម្រើន តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងប៉ុន្មានក្នុងសាសនានេះ ប្រកបដោយសទ្ធា សីលៈ សុតៈ ចាគៈ បញ្ញា និងបដិភាណ ធម៌ទាំងឡាយនោះរបស់ភិក្ខុនោះ មិនតាំងនៅដដែល មិនចម្រើន ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវហេតុនេះថា ជាសេចក្តីសាបសូន្យ ក្នុងកុសលធម៌ទាំងឡាយ មិនមែនជាការតាំងនៅដដែល មិនមែនជាសេចក្តីចម្រើនទេ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសាបសូន្យក្នុងកុសលធម៌ទាំងឡាយ មិនមែនជាការតាំងនៅដដែល មិនមែនសេចក្តីចម្រើន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ការតាំងនៅដដែល ក្នុងកុសលធម៌ទាំងឡាយ មិនមែនជាសេចក្តីសាបសូន្យ មិនមែនជាសេចក្តីចម្រើន តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងប៉ុន្មានក្នុងសាសនានេះ ប្រកបដោយសទ្ធា សីលៈ សុតៈ ចាគៈ បញ្ញា និងបដិភាណ ពួកធម៌នោះរបស់ភិក្ខុនោះ មិនសាបសូន្យ មិនចម្រើន ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវហេតុនេះ ថាជាការតាំងនៅ

ដដែលក្នុងកុសលធម៌ទាំងឡាយ មិនមែនជាការសោបសូន្យ មិនមែនជាសេចក្តីចម្រើន ។ ម្នាលភិក្ខុទាំងឡាយ ការតាំងនៅដដែល ក្នុងកុសលធម៌ទាំងឡាយ មិនមែនជាការសោបសូន្យ មិនមែនជាសេចក្តីចម្រើន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនក្នុងកុសលធម៌ទាំងឡាយ មិនមែនជាការតាំងនៅដដែល មិនមែនជាការសោបសូន្យ តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងប៉ុន្មានក្នុងសាសនានេះ ប្រកបដោយសទ្ធា សីលៈ សុតៈ ចាគៈ បញ្ញា និងបដិភាណ ពួកធម៌នោះរបស់ភិក្ខុនោះ មិនតាំងនៅដដែល មិនសាបសូន្យទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវហេតុនេះថា ជាសេចក្តីចម្រើនក្នុងកុសលធម៌ទាំងឡាយ មិនមែនជាការតាំងនៅដដែល មិនមែនជាសេចក្តីសាបសូន្យទេ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន ក្នុងកុសលធម៌ទាំងឡាយ មិនមែនជាការតាំងនៅដដែល មិនមែនជាសេចក្តីសាបសូន្យ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមិនឆ្លាសក្នុងវារៈនៃចិត្តបុគ្គលដទៃទេ គួរគិតថា យើងទាំងឡាយ ជាអ្នកឆ្លាសក្នុងវារៈនៃចិត្តរបស់ខ្លួន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរសិក្សាយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុឆ្លាសក្នុងវារៈនៃចិត្តរបស់ខ្លួន តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ ដូចជាស្រ្តី ឬបុរសកំលោះ ឬជំទង់ ប្រកបដោយជាតិជាអ្នកស្អិតស្អាងកាលពិចារណាមើលស្រមោលមុខរបស់ខ្លួនក្នុងកញ្ចក់ ដ៏បរិសុទ្ធផូរផង់ ឬក្នុងភាជន៍ទឹកថ្លា បើឃើញនូវធូលី ឬកន្ទួលក្នុងកញ្ចក់ ឬទឹកនោះ តែងព្យាយាម

ដើម្បីលះបង់នូវធូលី ឬកន្ទួលនោះចេញ បើមិនឃើញធូលី ឬកន្ទួលក្នុងកញ្ចក់ ឬទឹកនោះទេ ក៏មានចិត្តត្រេកអរ មានតម្រិះគ្រប់គ្រាន់ ដោយហេតុនោះថា ឱហ្ន៎ អាត្មាអញមានលាភ ឱហ្ន៎ មុខរបស់អាត្មាអញបរិសុទ្ធ ឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ឧបមេយ្យដូចជាការពិចារណា ក្នុងកុសលធម៌ទាំងឡាយ រមែងមានឧបការៈច្រើនដល់ភិក្ខុនោះថា អាត្មាអញជាអ្នកមានអភិជ្ឈាច្រើនឬហ្ន៎ អាត្មាអញជាអ្នកមិនមានអភិជ្ឈាច្រើនឬហ្ន៎ អាត្មាអញជាអ្នកមានចិត្តព្យាបាទច្រើនឬហ្ន៎ អាត្មាអញជាអ្នកមានចិត្តមិនមានព្យាបាទច្រើនឬហ្ន៎ អាត្មាអញជាអ្នកត្រូវថីនមិទ្ធៈគ្របសង្កត់ច្រើនឬហ្ន៎ អាត្មាអញជាអ្នកប្រាសចាកថីនមិទ្ធៈច្រើនឬហ្ន៎ អាត្មាអញជាអ្នកមានចិត្តអណ្តែតអណ្តូងច្រើនឬហ្ន៎ អាត្មាអញជាអ្នកមានចិត្តមិនអណ្តែតអណ្តូងច្រើនឬហ្ន៎ អាត្មាអញជាអ្នកមានវិចិកិច្ឆាច្រើនឬហ្ន៎ អាត្មាអញជាអ្នកឆ្លងចាកវិចិកិច្ឆាច្រើនឬហ្ន៎ អាត្មាអញជាអ្នកមានសេចក្តីក្រោធច្រើនឬហ្ន៎ អាត្មាអញមិនមានសេចក្តីក្រោធច្រើនឬហ្ន៎ អាត្មាអញជាអ្នកមានចិត្តសៅហ្មងច្រើនឬហ្ន៎ អាត្មាអញជាអ្នកមានចិត្តមិនសៅហ្មងច្រើនឬហ្ន៎ អាត្មាអញជាអ្នកមានកាយ ក្រវល់ក្រវាយច្រើនឬហ្ន៎ អាត្មាអញជាអ្នកមានកាយ មិនក្រវល់ក្រវាយច្រើនឬហ្ន៎ អាត្មាអញជាអ្នកខ្ជិលច្រអូសច្រើនឬហ្ន៎ អាត្មាអញជាអ្នកមានព្យាយាមប្រារព្ធច្រើនឬហ្ន៎ អាត្មាអញជាអ្នកមានចិត្តមិនខ្ជាប់ខ្ជួនច្រើនឬហ្ន៎ អាត្មាអញជាអ្នកមានចិត្តខ្ជាប់ខ្ជួនច្រើនឬហ្ន៎ៗម្នាលភិក្ខុទាំងឡាយ បើភិក្ខុពិចារណាដឹងយ៉ាងនេះថា អាត្មាអញជាអ្នក

មានអភិជ្ឈាច្រើន អាត្មាអញជាអ្នកមានចិត្តព្យាបាទច្រើន អាត្មាអញជាអ្នកត្រូវថីនមិទ្ធៈគ្របសង្កត់ច្រើន អាត្មាអញជាអ្នកមានចិត្តអណ្តែតអណ្តូងច្រើន អាត្មាអញជាអ្នកមានវិចិកិច្ឆាច្រើន អាត្មាអញជាអ្នកមានសេចក្តីក្រោធច្រើន អាត្មាអញជាអ្នកមានចិត្តសៅហ្មងច្រើន អាត្មាអញជាអ្នកមានកាយក្រវល់ក្រវាយច្រើន អាត្មាអញជាអ្នកខ្ជិលច្រអូសច្រើន អាត្មាអញជាអ្នកមានចិត្តមិនខ្ជាប់ខ្ជួនច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគួរធ្វើសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីលះបង់នូវពួកអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាសំពត់ត្រូវភ្លើងឆេះ ឬក្បាលដែលត្រូវភ្លើងឆេះ បុគ្គលគប្បីប្រញាប់ធ្វើសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផងឲ្យលើសលុប ដើម្បីលត់សំពត់ ឬក្បាលនោះឯង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគួរប្រញាប់ធ្វើសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផងឲ្យលើសលុប ដើម្បីលះបង់នូវពួកអកុសលធម៌ដ៏លាមកទាំងនោះចេញ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុពិចារណាដឹងយ៉ាងនេះថា អាត្មាអញជាអ្នកមិនមានអភិជ្ឈាច្រើន អាត្មាអញជាអ្នកមានចិត្តមិនព្យាបាទច្រើន អាត្មាអញជាអ្នកប្រាសចាកថីនមិទ្ធៈច្រើន អាត្មាអញជាអ្នកមានចិត្តមិនអណ្តែង

*អណ្តូងច្រើន អាត្មាអញជាអ្នកឆ្លងចាកវិចិកិច្ឆាច្រើន អាត្មាអញជាអ្នកមិនមានសេចក្តីក្រោធច្រើន អាត្មាអញជាអ្នកមានចិត្តមិនសៅហ្មងច្រើន អាត្មាអញជាអ្នកមានកាយមិនក្រវល់ក្រវាយច្រើន អាត្មាអញជាអ្នកមានព្យាយាមប្រារព្ធច្រើន អាត្មាអញជាអ្នកមានចិត្តខ្ជាប់ខ្ជួនច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីតាំងនៅក្នុងកុសលធម៌ទាំងនោះ ហើយគួរធ្វើព្យាយាម ដើម្បីឲ្យអស់ទៅនៃអាសវៈទាំងឡាយតទៅ ។*

# អដ្ឋកថា

## ឋិតិសូត្រ

*[ ៥៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឋិតិសូត្រទី ៣ ដូចតទៅនេះ បទថា* **បដិភាណេន** *បានដល់ ដោយការតាំងពាក្យទុក ។*

**អដ្ឋកថាឋិតិសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## សមថសូត្រទី ៤

[ ៥៤ ] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមិនឈ្លាសក្នុងវារៈនៃចិត្តអ្នកដទៃទេ គួរគិតថា យើងទាំងឡាយ ជាអ្នកឈ្លាសក្នុងវារៈនៃចិត្តរបស់ខ្លួន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គួរសិក្សាយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុឈ្លាសក្នុងវារៈនៃចិត្តរបស់ខ្លួន តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដូចជាស្ត្រី ឬបុរសកំលោះ ឬជំទង់ ប្រកបដោយជាតិជាអ្នកស្អិតស្អាង ពិចារណាមើលស្រមោលមុខរបស់ខ្លួន ក្នុងកញ្ចក់ដ៏បរិសុទ្ធផូរផង់ ឬក្នុងភាជន៍ទឹកថ្លា បើឃើញនូវធូលី ឬកន្ទួលក្នុងកញ្ចក់ឬទឹកនោះ ក៏ព្យាយាមដើម្បីលះបង់នូវធូលី ឬកន្ទួលនោះចេញ បើមិនឃើញធូលី ឬកន្ទួលនៃមុខនោះទេ ក៏មានចិត្តត្រេកអរ មានតម្រិះគ្រប់គ្រាន់ ដោយហេតុនោះថា ឱហ្ន៎ អាត្មាអញមានលាភ ឱហ្ន៎ មុខរបស់អាត្មាអញបរិសុទ្ធ ឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ឧបមេយ្យដូចជាការពិចារណា ក្នុងកុសលធម៌ទាំងឡាយ រមែងមានឧបការៈច្រើនដល់ភិក្ខុថា អាត្មាអញជាអ្នកបាននូវចេតោសមថៈ ខាងក្នុងសន្តានឬហ្ន៎ អាត្មាអញជាអ្នកមិនបាននូវចេតោសមថៈ ខាងក្នុងសន្តានឬហ្ន៎ អាត្មាអញជាអ្នកបានអធិប្បញ្ញាធម្មវិបស្សនាឬហ្ន៎ អាត្មាអញជាអ្នកមិនបានអធិប្បញ្ញាធម្មវិបស្សនាឬហ្ន៎ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុពិចារណាដឹងយ៉ាងនេះថា អាត្មាអញបានចេតោសមថៈខាងក្នុងសន្តាន តែមិនបានអធិប្បញ្ញាធម្មវិបស្សនាទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ គួរឋិតនៅក្នុងចេតោ-

សមថៈខាងក្នុងសន្តានហើយ ធ្វើព្យាយាមក្នុងអធិប្បញ្ញាធម្មវិបស្សនា ។ លុះសម័យខាងក្រោយមក ភិក្ខុនោះ ក៏បាននូវចេតោសមថៈខាងក្នុងសន្តានផង បាននូវអធិប្បញ្ញាធម្មវិបស្សនាផង ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុពិចារណាវមែងដឹងយ៉ាងនេះថា អាត្មាអញបាននូវអធិប្បញ្ញាធម្មវិបស្សនា តែមិនបានចេតោសមថៈខាងក្នុងសន្តានទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគួរឋិតនៅក្នុងអធិប្បញ្ញាធម្មវិបស្សនាហើយ ធ្វើសេចក្តីព្យាយាម ក្នុងចេតោសមថៈខាងក្នុងសន្តាន ។ លុះសម័យខាងក្រោយមក ភិក្ខុនោះបាននូវអធិប្បញ្ញាធម្មវិបស្សនាផង បាននូវចេតោសមថៈខាងក្នុងសន្តានផង ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុពិចារណាវមែងដឹងយ៉ាងនេះថា អាត្មាអញមិនបានចេតោសមថៈខាងក្នុងសន្តានទាំងមិនបានអធិប្បញ្ញាធម្មវិបស្សនា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីធ្វើសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីបាននូវពួកធម៌ជាកុសលទាំងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ដូចជាសំពត់ដែលភ្លើងឆេះ ឬក្បាលដែលត្រូវភ្លើងឆេះ បុគ្គលគប្បីប្រញាប់ធ្វើសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីលត់នូវសំពត់ ឬក្បាលនោះឯង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីធ្វើនូវសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យ

លើសលុប ដើម្បីបាននូវពួកកុសលធម៌ទាំងនោះ ក៏យ៉ាងនោះដែរ ។ លុះសម័យខាងក្រោយមក ភិក្ខុនោះបាននូវចេតោសមថៈខាងក្នុងសន្តានផង បាននូវអធិប្បញ្ញាធម្មវិបស្សនាផង ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុពិចារណាមែងដឹងយ៉ាងនេះថា អាត្មាអញបានចេតោសមថៈខាងក្នុងសន្តាន បានអធិប្បញ្ញា-ធម្មវិបស្សនា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគួរតាំងនៅក្នុងកុសលធម៌ទាំងនោះ ហើយធ្វើព្យាយាមដើម្បីឲ្យអស់ទៅនៃអាសវៈទាំងឡាយតទៅ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវចីវរ ដោយចំណែកពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបិណ្ឌបាត ដោយចំណែកពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវសេនាសនៈ ដោយចំណែកពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវស្រុក ឬនិគមដោយចំណែកពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវជនបទ ឬប្រទេសដោយចំណែកពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គល ដោយចំណែកពីរ គឺគួរសេព ១ មិនគួរសេព ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវចីវរ ដោយចំណែកពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ពាក្យនេះ តថាគតពោលហើយ ដោយប្រការដូច្នេះឯង ពាក្យដែលតថាគតពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុដូចម្តេច ។ បណ្តាចីវរទាំងពីរប្រការនោះ ភិក្ខុគប្បីដឹងនូវចីវរណាថា កាលបើអាត្មា

អញសេពចីវរនេះឯង អកុសលធម៌ទាំងឡាយ តែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ ចីវរបែបនេះ ភិក្ខុមិនគួរសេពឡើយ ។ បណ្តាចីវរទាំងពីរប្រការនោះ ភិក្ខុគប្បីដឹងចីវរណាថា កាលបើអាត្មាអញសេព ចីវរណា អកុសលធម៌ទាំងឡាយសាបសូន្យ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង ចីវរបែបនេះភិក្ខុគួរសេព ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវចីវរដោយចំណែកពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ពាក្យណា ដែលតថាគតពោលហើយ ដោយប្រការដូច្នេះ ពាក្យនេះតថាគតពោលហើយ ព្រោះសំដៅហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបិណ្ឌបាត ដោយចំណែកពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ពាក្យនុ៎ះ តថាគតពោលហើយដោយប្រការដូច្នេះនេះ ពាក្យដែលតថាគតពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុដូចម្តេច ។ បណ្តាបិណ្ឌបាតទាំងនោះ ភិក្ខុគប្បីដឹងនូវបិណ្ឌបាតណាថា កាលបើអាត្មាអញសេពបិណ្ឌបាតនេះឯង អកុសលធម៌ទាំងឡាយ ចម្រើនឡើងកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ បិណ្ឌបាតបែបនេះ ភិក្ខុមិនគួរសេពឡើយ ។ បណ្តាបិណ្ឌបាតទាំងនោះ ភិក្ខុគប្បីដឹងនូវបិណ្ឌបាតណាថា កាលបើអាត្មាអញសេពបិណ្ឌបាតនេះឯង អកុសលធម៌ទាំងឡាយ សាបសូន្យទៅកុសលធម៌ទាំងឡាយ តែងចម្រើនឡើង បិណ្ឌបាតបែបនេះ ភិក្ខុគួរសេព ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបិណ្ឌបាត ដោយចំណែកពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ពាក្យណា ដែលតថាគតពោលហើយ ដោយប្រការ

ដូច្នេះ ពាក្យនេះតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាល ភិក្ខុទាំងឡាយ តថាគតពោលនូវសេនាសនៈ ដោយចំណែកពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ពាក្យនុ៎ះ តថាគតពោលហើយ ដោយប្រការដូច្នេះ ពាក្យដែលតថាគតពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុដូចម្តេច ។ បណ្តាសេនាសនៈទាំងនោះ ភិក្ខុគប្បីដឹងនូវសេនាសនៈណាថា កាលបើអាត្មាអញសេពសេនាសនៈនេះឯង អកុសលធម៌ទាំងឡាយចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ សេនាសនៈបែបនេះ ភិក្ខុមិនគួរសេពឡើយ ។ បណ្តាសេនាសនៈទាំងនោះ ភិក្ខុគប្បីដឹងនូវសេនាសនៈណាថា កាលបើអាត្មាអញសេពសេនសនៈនេះឯង អកុសលធម៌ទាំងឡាយសាបសូន្យទៅ កុសល-ធម៌ទាំងឡាយតែងចម្រើនឡើង សេនាសនៈបែបនេះ ភិក្ខុគួរសេព ។ ម្នាល ភិក្ខុទាំងឡាយ តថាគតពោលនូវសេនាសនៈ ដោយចំណែកពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ពាក្យណាដែលតថាគតពោលហើយ ដោយប្រការដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាល ភិក្ខុទាំងឡាយ តថាគតពោលនូវស្រុក ឬនិគម ដោយចំណែកពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ពាក្យនុ៎ះ តថាគតពោលហើយដោយប្រការដូច្នេះ ពាក្យដែលតថាគតពោលហើយ អាស្រ័យហេតុដូចម្តេច ។ បណ្តាស្រុក ឬនិគមនោះ ភិក្ខុគប្បីដឹងនូវស្រុក ឬនិគមណាថា កាលបើអាត្មាអញសេពស្រុក ឬនិគមនោះឯង អកុសលធម៌ទាំងឡាយ ចម្រើនឡើង កុសលធម៌ទាំងឡាយ

តែងសាបសូន្យទៅ ស្រុក ឬនិគមបែបនេះ ភិក្ខុមិនគួរសេពឡើយ ។ បណ្ដា ស្រុក ឬនិគមទាំងនោះ ភិក្ខុគប្បីដឹងស្រុក ឬនិគមណាថា កាលបើអាត្មាអញ សេពស្រុក ឬនិគមនេះឯង អកុសលធម៌ទាំងឡាយសាបសូន្យទៅ កុសល-ធម៌ទាំងឡាយ តែងចម្រើនឡើង ស្រុក ឬនិគមបែបនេះ ភិក្ខុគួរសេព ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវស្រុក ឬនិគម ដោយចំណែកពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ពាក្យណា ដែលតថាគតពោលហើយ ដោយប្រការដូច្នេះ ពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវជនបទ ឬប្រទេស ដោយចំណែកពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ពាក្យនុ៎ះ តថាគតពោលហើយ ដោយប្រការដូច្នេះ ពាក្យដែលតថាគតពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុដូចម្ដេច ។ បណ្ដាជនបទ ឬប្រទេសទាំងនោះ ភិក្ខុគប្បីដឹងជនបទ ឬប្រទេសណាថា កាលបើអាត្មាអញសេពជនបទ ឬប្រទេសនេះឯង អកុសលធម៌ទាំង-ឡាយ ចម្រើនឡើង កុសលធម៌ទាំងឡាយសាបសូន្យទៅ ជនបទ ឬប្រទេសបែបនេះ ភិក្ខុមិនគួរសេពឡើយ ។ បណ្ដាជនបទ ឬប្រទេសទាំងនោះ ភិក្ខុគប្បីដឹងនូវជនបទ ឬប្រទេសណាថា កាលបើអាត្មាអញសេពជនបទ ឬប្រទេសនេះឯង អកុសលធម៌ទាំងឡាយសាបសូន្យទៅ កុសលធម៌ទាំងឡាយតែងចម្រើនឡើង ជនបទ ឬប្រទេសបែបនេះ ភិក្ខុគួរសេព ។ ម្នាលភិក្ខុទាំង-ឡាយ តថាគតពោលនូវជនបទ ឬប្រទេស ដោយចំណែកពីរប្រការ គឺគួរ

សេព ១ មិនគួរសេព ១ ពាក្យណាដែលតថាគតពោលហើយ ដោយប្រការដូច្នេះ ពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលដោយចំណែកពីរ គឺគួរសេព ១ មិនគួរសេព ១ ពាក្យនុ៎ះតថាគតពោលហើយ ដោយប្រការដូច្នេះ ពាក្យដែលតថាគតពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុដូចម្ដេច ។ បណ្ដាបុគ្គលទាំងនោះ ភិក្ខុគប្បីដឹងនូវបុគ្គលណាថា កាលបើអាត្មាអញសេពបុគ្គលនេះឯង អកុសលធម៌ទាំងឡាយចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ បុគ្គលបែបនេះ ភិក្ខុមិនគួរសេព ។ បណ្ដាបុគ្គលទាំងនោះ ភិក្ខុគប្បីដឹងនូវបុគ្គលណាថា កាលបើអាត្មាអញសេពបុគ្គលនេះឯង អកុសលធម៌ទាំងឡាយសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង បុគ្គលបែបនេះ ភិក្ខុគួរសេព ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលដោយចំណែកពីរ គឺគួរសេព ១ មិនគួរសេព ១ ពាក្យណា ដែលតថាគតពោលហើយដោយប្រការដូច្នេះ ពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។

# អដ្ឋកថា

## សមថសូត្រ

[ ៥៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសមថសូត្រទី ៤ ដូចតទៅនេះ បទថា **អធិប្បញ្ញាធម្មវិបស្សនាយ** បានដល់ វិបស្សនាដែលកំណត់យកសង្ខារជាអារម្មណ៍ ៗ៚

**អដ្ឋកថា សមថសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## បរិហានសូត្រទី ៥

[ ៥៥ ] ក្នុងទីនោះ ព្រះសារីបុត្តដ៏មានអាយុ ហៅភិក្ខុទាំងឡាយថា ម្នាលអាវុសោភិក្ខុទាំងឡាយ ។ ពួកភិក្ខុទាំងនោះ ទទួលថេរវាចារបស់ព្រះសារីបុត្តដ៏មានអាយុថា អាវុសោ ។ ព្រះសារីបុត្តដ៏មានអាយុ បានពោលពាក្យនេះថា ម្នាលអាវុសោទាំងឡាយ អ្នកផងតែងនិយាយថា បុគ្គលមានធម៌សាបសូន្យ បុគ្គលមានធម៌សាបសូន្យដូច្នេះ ម្នាលអាវុសោទាំងឡាយ អ្នកផងតែងនិយាយថា បុគ្គលមានធម៌មិនសាបសូន្យ បុគ្គលមានធម៌មិនសាបសូន្យដូច្នេះ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលមានធម៌សាបសូន្យ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយ ដោយបរិយាយដូចម្តេច ចំណែកខាងបុគ្គលមានធម៌មិនសាបសូន្យ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយ ដោយបរិយាយដូចម្តេច ។ ពួកភិក្ខុ

តបថា ម្នាលអាវុសោទាំងឡាយ យើងទាំងឡាយមកអំពីចម្ងាយ ដើម្បីដឹងនូវសេចក្ដីនៃភាសិតនេះ ក្នុងសម្នាក់នៃព្រះសារីបុត្តដ៏មានអាយុ សូមព្រះសារីបុត្តដ៏មានអាយុ សម្ដែងនូវសេចក្ដីនៃភាសិតនោះឲ្យទាន ពួកភិក្ខុបានស្ដាប់ ព្រះសារីបុត្តដ៏មានអាយុហើយ នឹងចងចាំបាន ។ ម្នាលអាវុសោទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយចូរប្រុងស្ដាប់ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ ខ្ញុំនឹងសម្ដែង ។ ពួកភិក្ខុទាំងនោះ ទទួលថេរវាចារបស់ព្រះសារីបុត្តដ៏មានអាយុថា ករុណាអាវុសោ យ៉ាងនេះ ។ ព្រះសារីបុត្តដ៏មានអាយុ បានពោលពាក្យនេះថា ម្នាលអាវុសោទាំងឡាយ បុគ្គលដែលមានធម៌សាបសូន្យ ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយ ដោយបរិយាយដូចម្ដេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនបានស្ដាប់ធម៌ ដែលខ្លួនមិនធ្លាប់បានស្ដាប់ផង ធម៌ទាំងឡាយដែលភិក្ខុនោះ ធ្លាប់បានស្ដាប់ហើយ ក៏ដល់នូវការភ្លេចភ្លាំងទៅផងមួយទៀត ធម៌ទាំងឡាយណាដែលភិក្ខុនោះ ធ្លាប់ពាល់ត្រូវដោយចិត្ត ក្នុងកាលមុន ធម៌ទាំងនោះ ក៏មិនផុសឡើងដល់ភិក្ខុនោះផង ភិក្ខុនោះមិនដឹងនូវធម៌ ដែលខ្លួនមិនទាន់ដឹងផង ។ ម្នាលអាវុសោទាំងឡាយ បុគ្គលមានធម៌សាបសូន្យ ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយ ដោយបរិយាយប៉ុណ្ណេះឯង ។ ម្នាលអាវុសោទាំងឡាយ បុគ្គលមានធម៌មិនសាបសូន្យ ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយ ដោយបរិយាយដូចម្ដេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ដាប់នូវធម៌ដែលខ្លួនមិនធ្លាប់បានស្ដាប់ផង ពួកធម៌ដែលភិក្ខុនោះ

ធ្លាប់ស្តាប់ហើយ ក៏មិនដល់នូវការភ្លេចភ្លាំងទៅផង មួយទៀត ពួកធម៌ណា ដែលភិក្ខុនោះ ធ្លាប់ពាល់ត្រូវដោយចិត្តក្នុងកាលមុន ពួកធម៌នោះ ក៏ផុសឡើង ដល់ភិក្ខុនោះឯង ភិក្ខុនោះក៏ដឹងច្បាស់នូវធម៌ ដែលខ្លួនមិនធ្លាប់ដឹងផង ។ ម្នាល អាវុសោទាំងឡាយ បុគ្គលមានធម៌មិនសាបសូន្យ ដែលព្រះដ៏មានព្រះភាគទ្រង់ ត្រាស់ហើយ ដោយបរិយាយប៉ុណ្ណេះឯង ។ ម្នាលអាវុសោទាំងឡាយ បើភិក្ខុ មិនឈ្លាសក្នុងវារៈនៃចិត្តអ្នកដទៃ គួរគិតថា យើងទាំងឡាយ ជាអ្នកឈ្លាស ក្នុងវារៈនៃចិត្តរបស់ខ្លួន ។ ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយគួរសិក្សា យ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកឈ្លាសក្នុងវារៈនៃចិត្ត របស់ខ្លួន តើដោយប្រការដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ដូចជាស្ត្រី ឬបុរសកំលោះ ឬជំទង់ ប្រកបដោយជាតិជាអ្នកស្អិតស្អាង កាលពិចារណា មើលស្រមោលមុខរបស់ខ្លួនក្នុងកញ្ចក់ដ៏បរិសុទ្ធផូរផង់ ឬក្នុងភាជន៍ទឹកថ្លា បើ ឃើញធូលី ឬកន្ទួលក្នុងកញ្ចក់ ឬទឹកនោះ តែងព្យាយាមដើម្បីលះបង់ធូលី ឬកន្ទួលនោះចេញ បើមិនឃើញធូលី ឬកន្ទួលក្នុងកញ្ចក់ ឬទឹកនោះទេ ក៏មាន ចិត្តត្រេកអរ មានតម្រិះគ្រប់គ្រាន់ដោយហេតុនោះថា ឱហ្ន៎ អាត្មាអញមាន លាភ ឱហ្ន៎ ( មុខ ) របស់អាត្មាអញបរិសុទ្ធ មានឧបមាយ៉ាងណា ម្នាល អាវុសោទាំងឡាយ ឧបមេយ្យដូចជាការពិចារណា ក្នុងកុសលធម៌ទាំងឡាយ ជាធម៌មានឧបការៈច្រើនដល់ភិក្ខុថា អាត្មាអញជាអ្នកមិនមានអភិជ្ឈាច្រើនឬ ហ្ន៎ ធម៌នុ៎ះមានដល់អាត្មាអញឬហ្ន៎ ឬថាមិនមានទេ អាត្មាអញជាអ្នកមិនមាន

ចិត្តព្យាបាទច្រើនឬហ្ន៎ ធម៌នុ៎ះមានដល់អាត្មាអញឬហ្ន៎ ឬថាមិនមានទេ អាត្មាអញជាអ្នកប្រាសចាកថីនមិទ្ធៈច្រើនឬហ្ន៎ ធម៌នុ៎ះមានដល់អាត្មាអញឬហ្ន៎ ឬថាមិនមានទេ អាត្មាអញជាអ្នកមានចិត្តមិនអណ្តែងអណ្តូងច្រើនឬហ្ន៎ ធម៌នុ៎ះមានដល់អាត្មាអញឬហ្ន៎ ឬថាមិនមានទេ អាត្មាអញជាអ្នកឆ្លងចាកវិចិកិច្ឆាច្រើនឬហ្ន៎ ធម៌នុ៎ះមានដល់អាត្មាអញឬហ្ន៎ ឬថាមិនមានទេ អាត្មាអញជាអ្នកមិនមានសេចក្តីក្រោធច្រើនឬហ្ន៎ ធម៌នុ៎ះមានដល់អាត្មាអញឬហ្ន៎ ឬថាមិនមានទេ អាត្មាអញជាអ្នកមានចិត្តមិនសៅហ្មងច្រើនឬហ្ន៎ ធម៌នុ៎ះមានដល់អាត្មាអញឬហ្ន៎ ឬថាមិនមានទេ អាត្មាអញជាអ្នកបាននូវធម្មប្បាមុជ្ជខាងក្នុងសន្តានឬហ្ន៎ ធម៌នុ៎ះមានដល់អាត្មាអញឬហ្ន៎ ឬថាមិនមានទេ អាត្មាអញជាអ្នកបានចេតោសមថៈខាងក្នុងសន្តានឬហ្ន៎ ធម៌នុ៎ះមានដល់អាត្មាអញឬហ្ន៎ ឬថាមិនមានទេ អាត្មាអញជាអ្នកបាននូវអធិប្បញ្ញាធម្មវិបស្សនាឬហ្ន៎ ធម៌នុ៎ះមានដល់អាត្មាអញឬហ្ន៎ ឬថាមិនមានទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណាមិនឃើញពួកកុសលធម៌ទាំងអស់នេះក្នុងខ្លួនទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគប្បីធ្វើនូវសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីបាននូវពួកកុសលធម៌ទាំងអស់នេះ ។ ម្នាលអាវុសោទាំងឡាយ ដូចជាសំពត់ដែលត្រូវភ្លើងឆេះ ឬក្បាលដែលត្រូវភ្លើងឆេះ បុគ្គលគួរប្រញាប់ធ្វើនូវសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង

សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីលត់នូវសំពត់ ឬក្បាលនោះឯងយ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគប្បីប្រញាប់ធ្វើនូវសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីបានចំពោះនូវពួកកុសលធម៌ទាំងនេះ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោទាំងឡាយ បើភិក្ខុពិចារណាឃើញនូវកុសលធម៌ទាំងឡាយ ពួកខ្លះក្នុងខ្លួន មិនឃើញនូវកុសលធម៌ទាំងឡាយ ពួកខ្លះក្នុងខ្លួនទេ ម្នាលអាវុសោទាំង-ឡាយ ភិក្ខុនោះពិចារណាឃើញនូវកុសលធម៌ទាំងឡាយណាក្នុងខ្លួន ឋិតនៅក្នុងកុសលធម៌ទាំងឡាយនោះ ( បើ ) មិនទាន់ឃើញនូវកុសលធម៌ទាំង-ឡាយណាក្នុងខ្លួនទេ ត្រូវធ្វើនូវសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីបាននូវកុសលធម៌ទាំងឡាយនោះ ។ ម្នាលអាវុសោទាំង-ឡាយ ដូចជាសំពត់ដែលត្រូវភ្លើងឆេះ ឬក្បាលដែលត្រូវភ្លើងឆេះ បុគ្គលគប្បីប្រញាប់ធ្វើនូវសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីលត់សំពត់ ឬក្បាលនោះឯង យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះពិចារណាឃើញនូវកុសលធម៌ទាំងឡាយណា ក្នុងខ្លួន ឋិតនៅក្នុងកុសលធម៌ទាំងឡាយនោះ ( បើ ) មិនទាន់ឃើញនូវកុសលធម៌ទាំងឡាយណាក្នុង

ខ្លួនទេ ត្រូវធ្វើនូវសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីបាននូវកុសលធម៌ទាំងឡាយនោះ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណាឃើញកុសលធម៌ទាំងអស់នេះ ក្នុងខ្លួន ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះ គួរឋិតនៅកុសលធម៌ទាំងអស់នេះ ហើយធ្វើនូវសេចក្តីព្យាយាម ដើម្បីអស់ទៅនៃអាសវៈទាំងឡាយតទៅ ។

# អដ្ឋកថា
# បរិហានសូត្រ

[ ៥៥ ] ក្នុងបរិហានសូត្រទី ៥ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាបរិហានសូត្រទី ៥ ចប់

# សុត្តន្តបិដក

## បឋមសញ្ញាសូត្រទី ៦

[ ៥៦ ] ម្នាលភិក្ខុទាំងឡាយ សញ្ញានេះមាន ១០ ប្រការ ដែលបុគ្គលបានចម្រើន បានធ្វើឲ្យច្រើនហើយ មានផលច្រើន មានអានិសង្សច្រើន ឈមទៅកាន់អមតៈ មានអមតៈជាបរិយោសាន ។ សញ្ញា ១០ តើដូចម្តេចខ្លះ ។ គឺអសុភសញ្ញា ( សម្គាល់ថាមិនស្អាត ) ១ មរណសញ្ញា ( សម្គាល់ក្នុងសេចក្តីស្លាប់ ) ១ អាហារេបដិកូលសញ្ញា ( សម្គាល់ថាគួរខ្ពើមរអើមក្នុងអាហារ ) ១ សព្វលោកេ អនភិរតសញ្ញា ( សេចក្តីសម្គាល់ថាមិនគួរត្រេកអរក្នុងលោកទាំងអស់ ) ១ អនិច្ចសញ្ញា ( សម្គាល់ថាមិនទៀង ) ១ អនិច្ចេទុក្ខសញ្ញា ( សម្គាល់ថាជាទុក្ខក្នុងរបស់មិនទៀង ) ១ ទុក្ខេអនត្តសញ្ញា ( សម្គាល់ថាមិនមែនខ្លួនក្នុងរបស់ដែលជាទុក្ខ ) ១ បហានសញ្ញា ( សម្គាល់ថាគួរលះបង់ ) ១ វិរាគសញ្ញា (សម្គាល់ការប្រាសចាកតម្រេក) ១ និរោធសញ្ញា ( សម្គាល់ការរលត់ ) ១ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាទាំង ១០ នេះឯង ដែលបុគ្គលបានចម្រើន បានធ្វើឲ្យច្រើនហើយ មានផលមានអានិសង្សច្រើន ឈមទៅកាន់អមតៈ មានអមតៈជាបរិយោសាន ។

# អដ្ឋកថា

## បឋមសញ្ញាសូត្រ

[ ៥៦ ] ក្នុងបឋមសញ្ញាសូត្រទី ៦ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាបឋមសញ្ញាសូត្រទី ៦ ចប់

# សុត្តន្តបិដក

## ទុតិយសញ្ញាសូត្រទី ៧

[ ៥៧ ] ម្នាលភិក្ខុទាំងឡាយ សញ្ញានេះមាន ១០ ប្រការ ដែលបុគ្គលបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ មានផលច្រើន មានអានិសង្សច្រើន ឈមទៅកាន់អមតៈ មានអមតៈជាបរិយោសាន ។ សញ្ញា ១០ តើដូចម្ដេចខ្លះ ។ គឺអនិច្ចសញ្ញា ១ អនត្តសញ្ញា ១ មរណសញ្ញា ១ អាហារេបដិកូលសញ្ញា ១ សព្វលោកេ អនភិរតសញ្ញា ១ អដ្ឋិកសញ្ញា ( សម្គាល់អសុភដែលមានតែរាងឆ្អឹង ) ១ បុឡុវកសញ្ញា ( សម្គាល់អសុភដែលមានដង្កូវចុះ ) ១ វិនីលកសញ្ញា ( សម្គាល់អសុភដែលមានពណ៌ខៀវ ) ១ វិច្ឆិទ្ទកសញ្ញា ( សម្គាល់អសុភដែលដាច់ជាកំណាត់ ) ១ ឧទ្ធុមាតកសញ្ញា ( សម្គាល់អសុភដែលហើមប៉ោង ) ១ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញា ១០ យ៉ាងនេះឯង ដែលបុគ្គលបានចម្រើន បានធ្វើឲ្យច្រើនហើយ មានផលច្រើន មានអានិសង្សច្រើន ឈមទៅកាន់អមតៈ មានអមតៈជាបរិយោសាន ។

# អដ្ឋកថា

## ទុតិយសញ្ញាសូត្រ

[ ៥៧ ] ក្នុងទុតិយសញ្ញាសូត្រទី ៧ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាទុតិយសញ្ញាសូត្រទី ៧ ចប់

# សុត្តន្តបិដក

## មូលសូត្រទី ៨

[ ៥៨ ] ម្នាលភិក្ខុទាំងឡាយ កាលបើពួកអន្យតិរ្ថិយបរិព្វាជកសួរយ៉ាងនេះថា ម្នាលអាវុសោ ពួកធម៌ទាំងអស់ មានអ្វីជាឫសគល់ ពួកធម៌ទាំងអស់មានអ្វីជាដែនកើត ពួកធម៌ទាំងអស់មានអ្វីជាទីប្រជុំកើត ពួកធម៌ទាំងអស់មានអ្វីជាទីប្រជុំចុះ ពួកធម៌ទាំងអស់មានអ្វីជាប្រធាន ពួកធម៌ទាំងអស់មានអ្វីជាធំ ពួកធម៌ទាំងអស់មានអ្វីជាគ្រឿងវិសេស ពួកធម៌ទាំងអស់មានអ្វីជាខ្លឹម ពួកធម៌ទាំងអស់មានអ្វីជាគ្រឿងឈមទៅរក ពួកធម៌ទាំងអស់មានអ្វីជាបរិយោសាន ម្នាលភិក្ខុទាំងឡាយ កាលបើត្រូវពួកអន្យតិរ្ថិយបរិព្វាជកទាំងនោះសួរយ៉ាងនេះ តើអ្នកទាំងឡាយ គប្បីដោះស្រាយដូចម្តេច ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយមានព្រះដ៏មានព្រះភាគជាឫសគល់ មានព្រះដ៏មានព្រះភាគជាអ្នកណែនាំ មានព្រះដ៏មានព្រះភាគជាទីពឹងនៃយើងទាំងឡាយស្រាប់ហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគសម្តែងនូវសេចក្តី

នៃភាសិតនេះ ភិក្ខុទាំងឡាយបានស្ដាប់ព្រះពុទ្ធដីកា របស់ព្រះដ៏មានព្រះភាគហើយ នឹងចងចាំបាន ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយ ចូរស្ដាប់ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្ដែង ។ ពួកភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះដ៏មានព្រះភាគបានត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បើពួកអន្យតិរ្ថិយ-បរិព្វាជកសួរយ៉ាងនេះថា ម្នាលអាវុសោ ពួកធម៌ទាំងអស់ មានអ្វីជាឫសគល់ ពួកធម៌ទាំងអស់ មានអ្វីជាដែនកើត ពួកធម៌ទាំងអស់ មានអ្វីជាទីប្រជុំកើត ពួកធម៌ទាំងអស់មាន អ្វីជាទីប្រជុំចុះ ពួកធម៌ទាំងអស់មានអ្វីជាប្រធាន ពួកធម៌ទាំងអស់ មានអ្វីជាធំ ពួកធម៌ទាំងអស់ មានអ្វីជាគ្រឿងវិសេស ពួកធម៌ទាំងអស់ មានអ្វីជាខ្លឹម ពួកធម៌ទាំងអស់ មានអ្វីជាគ្រឿងឈមទៅរក ពួកធម៌ទាំងអស់ មានអ្វីជាបរិយោសាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កាលបើត្រូវពួកអន្យតិរ្ថិយបរិព្វាជកទាំងនោះសួរយ៉ាងនេះ គប្បីដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោ ពួកធម៌ទាំងអស់ មានឆន្ទៈជាឫសគល់ ពួកធម៌ទាំងអស់ មានមនសិការជាដែនកើត ពួកធម៌ទាំងអស់ មានផស្សៈជាទីប្រជុំកើត ពួកធម៌ទាំងអស់ មានវេទនាជាទីប្រជុំចុះ ពួកធម៌ទាំងអស់មានសមាធិជាប្រធាន ពួកធម៌ទាំងអស់ មានសតិជាធំ ពួកធម៌ទាំងអស់ មានបញ្ញាជាគ្រឿងវិសេស ពួកធម៌ទាំងអស់មានវិមុត្តិជាខ្លឹម ពួកធម៌ទាំងអស់ មានអមតៈជាគ្រឿងឈមទៅរក ពួកធម៌ទាំងអស់ មានព្រះនិព្វានជាបរិយោសាន ម្នាល

*ភិក្ខុទាំងឡាយ កាលបើត្រូវពួកអន្យតិរ្ថិយបរិព្វាជកទាំងនោះ សួរយ៉ាងនេះ គប្បីដោះស្រាយយ៉ាងនេះឯង ។*

# អដ្ឋកថា

## មូលសូត្រ

[ ៥៨ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងមូលសូត្រទី ៨ ដូចតទៅនេះ ក្នុងបទថា* **អមតោគធា** *នេះ ត្រាស់សឧបាទិសេសនិព្វានធាតុ ។ ក្នុងបទថា* **និព្វានបរិយោសានា** *នេះ ត្រាស់អនុបាទិសេសនិព្វានធាតុ ដ្បិតថា ភិក្ខុសម្រេចអនុបាទិសេសនិព្វានហើយ រមែងឈ្មោះថា សម្រេចទីបំផុតនៃធម៌សព្វបែបយ៉ាង ។ បទដ៏សេសមានអត្ថដូចពោលខាងដើមនោះឯង ។*

**អដ្ឋកថា មូលសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## បញ្ញុជិតសូត្រទី ៩

[ ៥៩ ] ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ ភិក្ខុគប្បីសិក្សាយ៉ាងនេះថា ចិត្តយើងនឹងសន្សំដោយសមគួរដល់បញ្ញាផង អកុសលធម៌ដ៏លាមកដែលកើតឡើងហើយ ក៏នឹងមិនគ្របសង្កត់ចិត្តផង ចិត្តយើងសន្សំក្នុងអនិច្ចសញ្ញាផង ចិត្តយើងនឹងសន្សំក្នុងអនត្តសញ្ញាផង ចិត្តយើងនឹងសន្សំក្នុងអសុភសញ្ញាផង ចិត្តយើងនឹងសន្សំក្នុងអាទីនវសញ្ញាផង ចិត្តយើងនឹងសន្សំក្នុងសញ្ញានោះ ព្រោះដឹងនូវសុចរិត និងទុច្ចរិតនៃសត្វលោកផង ចិត្តយើងនឹងសន្សំក្នុងសញ្ញានោះ ព្រោះដឹងនូវសេចក្ដីចម្រើន និងសេចក្ដីវិនាសនៃសត្វលោកផង ចិត្តយើងនឹងសន្សំក្នុងសញ្ញានោះ ព្រោះដឹងការប្រជុំកើតនិងសាបសូន្យទៅ នៃសត្វលោកផង ចិត្តយើងនឹងសន្សំក្នុងបហានសញ្ញាផង ចិត្តយើងនឹងសន្សំក្នុងវិរាគសញ្ញាផង ចិត្តយើងនឹងសន្សំក្នុងនិរោធសញ្ញាផង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គួរសិក្សាយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើចិត្តដែលភិក្ខុសន្សំហើយ ដោយសមគួរដល់បញ្ញាផង ពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ក៏មិនគ្របសង្កត់ចិត្តផង ចិត្តដែលភិក្ខុសន្សំហើយក្នុងអនិច្ចសញ្ញាផង ចិត្តដែលភិក្ខុសន្សំហើយ ក្នុងអនត្តសញ្ញាផង ចិត្តដែលភិក្ខុសន្សំហើយក្នុងអសុភសញ្ញាផង ចិត្តដែលភិក្ខុសន្សំហើយក្នុងអាទីនវសញ្ញាផង ចិត្តដែលភិក្ខុសន្សំហើយក្នុងសញ្ញានោះ ព្រោះដឹងនូវសុចរិត និងទុច្ចរិតរបស់សត្វលោកផង ចិត្តដែលភិក្ខុសន្សំហើយ ក្នុង

*សញ្ញានោះ ព្រោះដឹងនូវសេចក្តីចម្រើន និងវិនាសរបស់សត្វលោកផង ចិត្តដែលភិក្ខុសន្សំហើយក្នុងសញ្ញានោះ ព្រោះដឹងនូវការប្រជុំកើត និងសាបសូន្យរបស់សត្វលោកផង ចិត្តដែលភិក្ខុសន្សំហើយក្នុងបហានសញ្ញាផង ចិត្តដែលភិក្ខុសន្សំហើយក្នុងវិរាគសញ្ញាផង ចិត្តដែលភិក្ខុសន្សំហើយក្នុងនិរោធសញ្ញាផង ។ បណ្តាផលទាំងពីរ ផលណាមួយរមែងប្រាកដដល់ភិក្ខុនោះ គឺនឹងបានអរហត្តផលក្នុងបច្ចុប្បន្ន ឬកាលបើឧបាទិនៅសេសសល់ នឹងបានជាអនាគាមិផល ។*

# អដ្ឋកថា

## បព្វជិតសូត្រ

[ ៥៩ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងបព្វជិតសូត្រទី ៩ ដូចតទៅនេះ បទថា* **តស្មា** *ប្រែថា ព្រោះហេតុដែលប្រយោជន៍នៃ សាមញ្ញផល មិនដល់ព្រមដល់បុគ្គលដែលមានចិត្តមិនបានសន្សំយ៉ាងនេះ ដូច្នោះ ។ បទថា* **យថាបព្វជ្ជាបរិចិតញ្ច នោ ចិត្តំ ភវិស្សតិ** *សេចក្តីថា សន្សំមកដោយសមគួរដល់ការបួស ពិតហើយ ពួកជនណាមួយ ឈ្មោះថា បួស ជនទាំងអស់នោះក៏ប្រាថ្នាអរហត្ត ព្រោះហេតុនោះ ចិត្តណា បុគ្គលសន្សំអប់រំមកដើម្បីជាប្រយោជន៍ដល់ការសម្រេចអរហត្តចិត្តនោះ គប្បីជ្រាបថា ឈ្មោះថា សន្សំមក*

ដោយសមគួរដល់ការបួស ។ អ្នកគប្បីសិក្សាយ៉ាងនេះថា ចិត្តរបស់អញនឹងជាដូច្នេះ ។ បទថា **លោកស្ស សមញ្ច វិសមញ្ច** បានដល់ សុចរិត និងទុច្ចរិតរបស់សត្វលោក ។ បទថា **លោកស្ស សម្ភវញ្ច វិភវញ្ច** បានដល់សេចក្ដីចម្រើន និងសេចក្ដីវិនាសរបស់សត្វលោកនោះ ម្យ៉ាងទៀត បានដល់សម្បត្តិ និងវិបត្តិ ។ បទថា **លោកស្ស សមុទយញ្ច អដ្ឋង្គមញ្ច** ត្រាស់សំដៅយកសង្ខារលោក អធិប្បាយថា ដឹងការកើត និងការបែកធ្លាយនៃខន្ធទាំងឡាយ ។

អដ្ឋកថា បព្វជិតសូត្រទី ៩ ចប់

# សុត្តន្តបិដក

## គិរិមានន្ទសូត្រទី ១០

[ ៦០ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះគិរិមានន្ទដ៏មានអាយុ លោកមានអាពាធប្រកបដោយទុក្ខវេទនា ជាជំងឺធ្ងន់ ។ គ្រានោះឯង ព្រះអានន្ទត្ថេរដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ ត្រង់ទីដែលព្រះអង្គគង់ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយ

អង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទត្ថេរដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលនូវពាក្យនេះ នឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន គិរិមានន្ទដ៏មានអាយុមានអាពាធប្រកបដោយទុក្ខវេទនា ជាជំងឺធ្ងន់ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទ្រង់អនុគ្រោះ ( ចំពោះគិរិ-មានន្ទ ) សូមស្តេចចូលទៅត្រង់កន្លែងដែលគិរិមានន្ទអាស្រ័យនៅ ។ ព្រះដ៏មានព្រះភាគត្រាស់តបថា ម្នាលអានន្ទ ប្រសិនបើអ្នកចូលទៅកាន់សម្នាក់នៃគិរិមានន្ទភិក្ខុ សម្តែងប្រាប់សញ្ញាទាំង ១០ ប្រការ ដំណើរនេះ ជាហេតុនឹងនាំឲ្យអាពាធរបស់គិរិមានន្ទភិក្ខុនោះ បានរម្ងាប់សះស្បើយទៅមួយរំពេច ព្រោះគិរិមានន្ទភិក្ខុ បានស្តាប់នូវសញ្ញាទាំង ១០ ប្រការ ។ សញ្ញាទាំង ១០ ប្រការនោះ ដូចម្តេចខ្លះ ។ គឺអនិច្ចសញ្ញា ១ អនត្តសញ្ញា ១ អសុភសញ្ញា ១ អាទីនវសញ្ញា ១ បហានសញ្ញា ១ វិរាគសញ្ញា ១ និរោធសញ្ញា ១ សព្វលោកេ អនភិរតសញ្ញា ១ សព្វសង្ខារេសុ អនិច្ចសញ្ញា ១ អានាបានស្សតិ ១ ។

ម្នាលអានន្ទ អនិច្ចសញ្ញា តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះដ៏ស្ងាត់ក្តី ពិចារណាឃើញដូច្នេះថា រូបមិនទៀង វេទនាមិនទៀង សញ្ញាមិនទៀង សង្ខារទាំងឡាយមិនទៀង វិញ្ញាណមិនទៀង ។ ភិក្ខុពិចារណាឃើញរឿយៗ ថា មិនទៀងក្នុងឧបាទានក្ខន្ធទាំង ៥ នេះ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ នេះហៅថា អនិច្ចសញ្ញា ។

ម្នាលអានន្ទ អនត្តសញ្ញា តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី ពិចារណាឃើញដូច្នេះថា ភ្នែកមិនមែនជារបស់ខ្លួនទេ រូបមិនមែនជារបស់ខ្លួនទេ ត្រចៀកមិនមែនជារបស់ខ្លួនទេ សំឡេងទាំងឡាយមិនមែនជារបស់ខ្លួនទេ ច្រមុះមិនមែនជារបស់ខ្លួនទេ ក្លិនទាំងឡាយមិនមែនជារបស់ខ្លួនទេ អណ្តាតមិនមែនជារបស់ខ្លួនទេ រសទាំងឡាយមិនមែនជារបស់ខ្លួនទេ កាយមិនមែនជារបស់ខ្លួនទេ ផោដ្ឋព្វៈទាំងឡាយមិនមែនជារបស់ខ្លួនទេ ចិត្តមិនមែនជារបស់ខ្លួនទេ ធម៌ទាំងឡាយមិនមែនជារបស់ខ្លួនទេ ។ ភិក្ខុពិចារណាឃើញរឿយៗ ដូច្នេះថា មិនមែនជារបស់ខ្លួនក្នុងអាយតនៈខាងក្នុង ៦ និងអាយតនៈខាងក្រៅ ៦ នេះដោយប្រការដូច្នេះ ។ ម្នាលអានន្ទ នេះហៅថា អនត្តសញ្ញា ។

ម្នាលអានន្ទ អសុភសញ្ញា តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយនេះឯង ខាងលើអំពីផ្ទៃបាតជើងឡើងទៅ ខាងក្រោមអំពីចុងសក់ចុះមក ព័ទ្ធជុំវិញដោយស្បែក ពេញដោយគ្រឿងមិនស្អាតមានប្រការផ្សេងៗ ដូច្នេះថា ក្នុងរូបកាយនេះ សក់ទាំងឡាយ រោមទាំងឡាយ ក្រចកទាំងឡាយ ធ្មេញទាំងឡាយ ស្បែក សាច់ សរសៃទាំងឡាយ ឆ្អឹងទាំងឡាយ ខួរក្នុងឆ្អឹង ទាច បេះដូង ថ្លើម វាវ ក្រពះ ឬលំពែងអរិស សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករំអិល

ទឹកមូត្រ ។ ភិក្ខុពិចារណាឃើញរឿយៗ ថា មិនល្អក្នុងរូបកាយនេះ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ នេះហៅថា អសុភសញ្ញា ។

ម្នាលអានន្ទ អាទីនវសញ្ញា តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី ពិចារណាឃើញដូច្នេះថា រូបកាយនេះមានទុក្ខច្រើន មានទោសច្រើនដោយពិត ។ អាពាធទាំងឡាយផ្សេងៗ តែងកើតឡើងក្នុងកាយនេះដូច្នេះ អាពាធនោះដូចម្តេចខ្លះ គឺរោគក្នុងភ្នែក រោគក្នុងត្រចៀក រោគក្នុងច្រមុះ រោគក្នុងអណ្តាត រោគក្នុងកាយ រោគក្នុងក្បាល រោគក្នុងស្លឹកត្រចៀក រោគក្នុងមាត់ រោគត្រង់គល់ធ្មេញ រោគក្អក រោគហឺត រោគខាងក្រៅច្រមុះ រោគក្តៅក្រហាយ រោគស្គាំងស្គម រោគក្នុងផ្ទៃ រោគខ្យល់ចាប់ វិលមុខ រោគធ្លាក់ឈាម រោគចុកសៀត រោគចុះរាក រោគឃ្លង់ រោគមួល រោគស្រែង រោគរីងរៃ រោគឆ្កួតជ្រូក រោគជំនួចពិស រោគរមាស់ រោគកមក្រិន រោគកើតក្នុងទីដែលខ្វារដោយក្រចក រោគឃ្លង់ដែក រោគឈាម រោគប្រមាត់ រោគទឹកនោមផ្អែម រោគឫសដូងដុះ រោគរលកកែវ រោគឫសដូងបាត អាពាធបណ្តាលអំពីប្រមាត់ អាពាធបណ្តាលអំពីស្លេស្ម អាពាធបណ្តាលអំពីខ្យល់ អាពាធបណ្តាលអំពីសន្និបាត គឺការកម្រើកប្រមាត់ ស្លេស្ម និងខ្យល់ប្រជុំគ្នា អាពាធកើតអំពីរដូវប្រែប្រួល អាពាធកើតអំពីការផ្លាស់ប្តូរឥរិយាបថមិនស្មើគ្នា អាពាធកើតអំពីសេចក្តីព្យាយាមរបស់អ្នកឯទៀត ( មានចាប់ចងវាយជាដើម ) អាពាធកើតអំពីវិបាករបស់

កម្ម ការត្រជាក់ ការក្តៅ សេចក្តីឃ្លាន សេចក្តីស្រេក ឧច្ចារៈ ( អាចម៍ ) បស្សាវៈ ( មូត្រ ) ។ ភិក្ខុពិចារណាឃើញរឿយៗ ថាជាទោសក្នុងរូបកាយនេះ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ នេះហៅថា អាទីនវសញ្ញា ។

ម្នាលអានន្ទ បហានសញ្ញា តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះមិនទទួលទុក លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតទៀតនូវកាមវិតក្ក ដែលកើតឡើងហើយ មិនទទួលទុក លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតទៀតនូវព្យាបាទវិតក្ក ដែលកើតឡើងហើយ មិនទទួលទុក លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតតទៅទៀតនូវវិហិង្សាវិតក្ក ដែលកើតឡើងហើយ មិនទទួលទុក លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតតទៅទៀតនូវធម៌ ដែលជា បាបអកុសល ដែលកើតឡើងហើយរឿយៗ ។ ម្នាលអានន្ទ នេះហៅថា បហានសញ្ញា ។

ម្នាលអានន្ទ វិរាគសញ្ញា តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី ពិចារណាឃើញរឿយៗ ដូច្នេះថា ធម៌ជាគ្រឿងរម្ងាប់សង្ខារទាំងពួង លះបង់នូវឧបធិទាំងពួង អស់ទៅនៃតណ្ហា ប្រាសចាករាគៈ រម្ងត់ទុក្ខ នេះជាធម៌ស្ងប់ ធម៌ឧត្តម ។ ម្នាលអានន្ទ នេះហៅថា វិរាគសញ្ញា ។

ម្នាលអានន្ទ និរោធសញ្ញា តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះដ៏ស្ងាត់ក្តី ពិចារណាឃើញដូច្នេះ

ថា ធម៌ជាគ្រឿងរម្ងាប់សង្ខារទាំងពួង លះបង់នូវឧបធិទាំងពួង អស់ទៅនៃតណ្ហា ប្រាសចាករាគៈ រលត់ទុក្ខ នេះជាធម៌ស្ងប់ ជាធម៌ឧត្តម ។ ម្នាលអានន្ទ នេះហៅថា និរោធសញ្ញា ។

ម្នាលអានន្ទ សព្វលោកេ អនភិរតសញ្ញា តើដូចម្តេច ។ ម្នាលអានន្ទ ឧបាយ គឺតណ្ហា និងទិដ្ឋិណា ឧបាទាន គឺសេចក្តីប្រកាន់មាំណា អភិនិវេសៈ គឺសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិជាទីអាស្រ័យនៅនៃចិត្តណា អនុស័យ គឺកិសលដែលដេកនៅរឿយៗ ក្នុងសត្តសន្តានណា ក្នុងលោក ភិក្ខុក្នុងសាសនានេះ កាលបើលះបង់នូវបាបធម៌ទាំងនោះ មិនបានប្រកាន់មាំដោយចិត្ត ក៏រមែងវៀរ ( ចាកបាបធម៌ទាំងនោះ ) បាន ។ ម្នាលអានន្ទ នេះហៅថា សព្វលោកេ អនភិរតសញ្ញា ។

ម្នាលអានន្ទ សព្វសង្ខារេសុអនិច្ចសញ្ញា តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នឿយណាយ ធុញទ្រាន់ ស្អប់ខ្ពើមចាកសង្ខារទាំងពួង ។ ម្នាលអានន្ទ នេះហៅថា សព្វសង្ខារេសុអនិច្ចសញ្ញា ។

ម្នាលអានន្ទ អានាបានស្សតិតើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះដ៏ស្ងាត់ក្តី អង្គុយផ្គត់ភ្នែនតាំងកាយឲ្យត្រង់ ផ្ចង់ស្មារតីឲ្យខ្ពោះត្រង់ ( ទៅរកកម្មដ្ឋាន ) ។ ភិក្ខុនោះមានស្មារតីដកដង្ហើមចេញ មានស្មារតីដកដង្ហើមចូល កាលដកដង្ហើមចេញវែង ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង កាលដកដង្ហើមចូលវែង ក៏ដឹង

ច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញខ្លី កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវកាយ គឺដង្ហើមចេញទាំងអស់ឲ្យប្រាកដ ទើបដកដង្ហើមចេញ ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវកាយ គឺដង្ហើមចូលទាំងអស់ឲ្យប្រាកដ ទើបដកដង្ហើមចូល ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នករម្ងាប់នូវកាយសង្ខារ គឺដង្ហើមចេញ ទើបដកដង្ហើមចេញ ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នករម្ងាប់នូវកាយសង្ខារ គឺដង្ហើមចូល ទើបដកដង្ហើមចូល ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវបីតិ ទើបដកដង្ហើមចេញ ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវបីតិ ទើបដកដង្ហើមចូល ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវសេចក្តីសុខ ទើបដកដង្ហើមចេញ ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវសេចក្តីសុខ ទើបដកដង្ហើមចូល ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវចិត្តសង្ខារ ទើបដកដង្ហើមចេញ ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវចិត្តសង្ខារ ទើបដកដង្ហើមចូល ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នករម្ងាប់នូវចិត្តសង្ខារ ទើបដកដង្ហើមចេញ ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នករម្ងាប់នូវចិត្តសង្ខារ ទើបដកដង្ហើមចូល ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវចិត្ត ទើបដកដង្ហើមចេញ ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវចិត្ត ទើបដកដង្ហើមចូល ភិក្ខុសិក្សាថា

អាត្មាអញធ្វើចិត្តឲ្យរីករាយ... តម្កល់ចិត្តឲ្យស្មើក្នុងអារម្មណ៍... ដោះចិត្តឲ្យរួចចាកនីវរណធម៌ជាដើម... ឃើញរឿយៗ នូវបញ្ចក្ខន្ធថាមិនទៀង... ឃើញរឿយៗ នូវធម៌ដែលប្រាសចាករាគៈ... ឃើញរឿយៗ នូវធម៌ដែលរលត់បង់នូវកងទុក្ខ... ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នកឃើញរឿយៗ នូវធម៌ជាគ្រឿងលះបង់នូវកិលេស ទើបដកដង្ហើមចេញ ភិក្ខុសិក្សាថាអាត្មាអញនឹងជាអ្នកឃើញរឿយៗ នូវធម៌ជាគ្រឿងលះបោលនូវកិលេស ទើបដកដង្ហើមចូល ។ ម្នាលអានន្ទ នេះហៅថា អានាបានស្សតិ ។ ម្នាលអានន្ទ បើអ្នកចូលទៅ ( កាន់សម្នាក់ ) នៃគិរិមានន្ទភិក្ខុហើយ គប្បីសម្តែងនូវសញ្ញាទាំងឡាយ ១០ ប្រការនេះ ដំណើរនេះ ជាហេតុនឹងឲ្យអាពាធរបស់គិរិមានន្ទភិក្ខុនោះ រម្ងាប់សះស្បើយទៅ ១ រំពេច ព្រោះគិរិមានន្ទភិក្ខុ បានស្តាប់សញ្ញាទាំងឡាយ ១០ ប្រការនេះ ។ លំដាប់នោះ ព្រះអានន្ទត្ថេរដ៏មានអាយុ ក៏រៀនសញ្ញាទាំងឡាយ ១០ ប្រការនេះក្នុងសម្នាក់នៃព្រះដ៏មានព្រះភាគ ហើយចូលទៅត្រង់កន្លែងដែលគិរិមានន្ទលោកគង់នៅ លុះចូលទៅដល់ហើយ បានសម្តែងសញ្ញាទាំងឡាយ ១០ ប្រការនេះដល់គិរិមានន្ទដ៏មានអាយុ ។ លំដាប់នោះឯង អាពាធរបស់គិរិមានន្ទដ៏មានអាយុនោះ ក៏រម្ងាប់សះស្បើយទៅ ១ រំពេច ព្រោះបានស្តាប់សញ្ញាទាំងឡាយ ១០ ប្រការនេះ ឯគិរិមានន្ទដ៏មានអាយុ ក៏បានជាសះស្បើយចាកអាពាធនោះ ក៏អាពាធនោះ គិរិមានន្ទដ៏មានអាយុ លះបង់បានហើយ ដោយកិរិយាបានស្តាប់សញ្ញាទាំង

១០ ប្រការ ដែលព្រះអានន្ទត្ថេរសម្តែងហើយដូច្នោះ ដោយប្រការដូច្នេះឯង ។

សចិត្តវគ្គទី ១ ចប់

## ឧទ្ទាននៃសចិត្តវគ្គនោះ

និយាយអំពីការឈ្លាសក្នុងវារចិត្តរបស់ខ្លួន ១ អំពីព្រះសារីបុត្ត ១ អំពីការតាំងនៅដដែល ១ អំពីសមថៈ ១ អំពីបរិហានៈ ១ អំពីសញ្ញាពីរលើក អំពីធម៌ជាមូល ១ ចិត្តសន្សំដោយបព្វជ្ជា ១ អាពាធ ១ ។

# អដ្ឋកថា

## អាពាធសូត្រ

[ ៦០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអាពាធសូត្រទី ១០ ដូចតទៅនេះ បទថា **អនុកម្បំ ឧបាទាយ** បានដល់ ទ្រង់អាស្រ័យសេចក្តីករុណាក្នុងព្រះគិរិមា-នន្ទត្ថេរ ។ គប្បីជ្រាបរោគទាំងឡាយ មានរោគភ្នែកជាដើម ដោយអំណាចវត្ថុ ។ ពិតហើយ ធម្មតាបុគ្គលកើតសេចក្តីជ្រះថ្លាហើយ មិនមានរោគ ។ បទថា **កណ្ណរោគោ** បានដល់ រោគត្រចៀកខាងក្រៅ ។ បទថា **បិនាសោ** បានដល់ រោគច្រមុះខាងក្រៅ ។ បទថា **ខសោ** បានដល់ រោគ ក្នុងទីដែលប្រើក្រចកអេះ ។ បទថា **បិត្តសមុដ្ឋានា** បានដល់ អាពាធដែលកើតអំពី

ប្រមាត់ ។ បានឮថា អាពាធទាំងនោះមាន ៣២ យ៉ាង ។ សូម្បីក្នុងអាពាធដែលមានសេម្ហៈជាសមុដ្ឋាន ក៏មានន័យដូចគ្នា ។ បទថា **ឧតុបរិណាមជា** បានដល់ រោគដែលកើតដោយក្តៅខ្លាំង ត្រជាក់ខ្លាំង ព្រោះរដូវប្រែប្រួល ។ បទថា **វិសមបរិហារជា** បានដល់ អាពាធដែលកើតដោយការបរិហារឥរិយាបថមិនស្មើ មានឈរ ឬអង្គុយយូរពេកជាដើម ។ បទថា **ឱបក្កមិកា** បានដល់ អាពាធដែលកើតឡើងដោយសេចក្តីព្យាយាមបៀតបៀនរបស់អ្នកដទៃ មានការកាប់ ចាក់ ការចងជាដើម ។ បទថា **កម្មវិបាកជា** បានដល់ អាពាធដែលកើតអំពីវិបាករបស់កម្មដ៏មានកម្លាំង ។ បទថា **សន្តំ** បានដល់ គុណជាតដែលឈ្មោះថា **សន្ត** ព្រោះកិលេស មានរាគៈជាដើមស្ងប់ ។ ឈ្មោះថា **បណីតំ** ព្រោះអត្ថថា មិនក្តៅក្រហាយ ។ ពាក្យដ៏សេស ក្នុងទីគ្រប់អន្លើ មានអត្ថងាយយល់ហើយ ។៙

## អដ្ឋកថាអាពាធសូត្រទី ១០ ចប់

## សចិត្តវគ្គទី ១ ចប់

# សុត្តន្តបិដក

## យមកវគ្គទី ២

### អវិជ្ជាសូត្រទី ១

[ ៦១ ] ម្នាលភិក្ខុទាំងឡាយ ទីបំផុតខាងដើមរបស់អវិជ្ជាមិនប្រាកដទេ អវិជ្ជាមិនមានក្នុងកាលមុន អំពីកាលនេះ ឬថា កើតឡើងក្នុងខាងក្រោយឡើយ ហេតុនោះ ម្នាលភិក្ខុទាំងឡាយ ពាក្យថា អវិជ្ជានេះ តថាគតពោលយ៉ាងនេះ តែថា អវិជ្ជារមែងប្រាកដព្រោះមានរបស់នេះជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា អវិជ្ជាប្រាកដដោយអាហារ មិនបានពោលថា អវិជ្ជាឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់អវិជ្ជា ។ គប្បីឆ្លើយថា នីវរណៈ ៥ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា នីវរណៈ ៥ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់នីវរណៈ ៥ ។ គប្បីឆ្លើយថា ទុច្ចរិត ៣ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ទុច្ចរិត ៣ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់ទុច្ចរិត ៣ ។ គប្បីឆ្លើយថា ការមិនសង្រួមឥន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ការមិនសង្រួមឥន្ទ្រិយ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់ការមិនសង្រួមឥន្ទ្រិយ ។ គប្បីឆ្លើយថា ការមិនមានសតិ មិនមានសម្បជញ្ញៈ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ការមិនមានសតិ មិនមានសម្បជញ្ញៈ ប្រកប

ដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់ការមិនមានសតិ មិនមានសម្បជញ្ញៈ ។ គប្បីឆ្លើយថា អយោនិសោមនសិការ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា អយោនិសោមនសិការប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់អយោនិសោមនសិការ ។ គប្បីឆ្លើយថា អស្សទ្ធិយៈ ( សេចក្តីមិនជឿ ) ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា អស្សទ្ធិយៈប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់អស្សទ្ធិយៈ ។ គប្បីឆ្លើយថា អស្សទ្ធម្មស្សវនៈ ( ការមិនស្តាប់ព្រះសទ្ធម្ម ) ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា អស្សទ្ធម្មស្សវនៈ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់អស្សទ្ធម្មស្សវនៈ ។ គប្បីឆ្លើយថា អសប្បុរិសសំសេវៈ ( ការសេពគប់អសប្បុរស ) ។ ម្នាលភិក្ខុទាំងឡាយ អសប្បុរិសសំសេវៈពេញបរិបូណ៌ រមែងញុំាងអស្សទ្ធម្មស្សវនៈឲ្យពេញបរិបូណ៌ អស្សទ្ធម្មស្សវនៈពេញបរិបូណ៌ រមែងញុំាងអស្សទ្ធិយៈឲ្យពេញបរិបូណ៌ អស្សទ្ធិយៈពេញបរិបូណ៌ រមែងញុំាងអយោនិសោមនសិការឲ្យពេញបរិបូណ៌ អយោនិសោមនសិការពេញបរិបូណ៌ រមែងញុំាងការមិនមានសតិ និងមិនមានសម្បជញ្ញៈឲ្យពេញបរិបូណ៌ ការមិនមានសតិ មិនមានសម្បជញ្ញៈពេញបរិបូណ៌ រមែងញុំាងការមិនសង្រួមឥន្ទ្រិយឲ្យពេញបរិបូណ៌ ការមិនសង្រួមឥន្ទ្រិយពេញបរិបូណ៌ រមែងញុំាងទុច្ចរិត ៣ ឲ្យពេញបរិបូណ៌

ទុច្ចរិតទាំង ៣ ពេញបរិបូណ៌ រមែងញ៉ាំងនីវរណៈ ៥ ឲ្យពេញបរិបូណ៌ នីវរណៈ ៥ ពេញបរិបូណ៌ រមែងញ៉ាំងអវិជ្ជាឲ្យពេញបរិបូណ៌ ដោយប្រការដូច្នេះឯង ។ អាហាររបស់អវិជ្ជានេះ រមែងមានយ៉ាងនេះ អាហាររបស់អវិជ្ជានេះ ពេញបរិបូណ៌យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ដូចទឹកភ្លៀងមានតំណក់ធ្លាស កាលបន្លឺរ កាលរំលា ហូរធ្លាក់លើកំពូលភ្នំ ទឹកនោះ ក៏ហូរទៅតាមទីទាប រមែងញ៉ាំងជ្រោះភ្នំ ល្អាង និងអូរតូចឲ្យពេញ ជ្រោះភ្នំ ល្អាង និងអូរតូចពេញហើយ រមែងញ៉ាំងត្រពាំងតូចឲ្យពេញ ត្រពាំងតូចពេញហើយ រមែងញ៉ាំងត្រពាំងធំឲ្យពេញ ត្រពាំងធំពេញហើយ រមែងញ៉ាំងស្ទឹងតូចឲ្យពេញ ស្ទឹងតូចពេញហើយ រមែងញ៉ាំងស្ទឹងធំឲ្យពេញ ស្ទឹងធំពេញហើយ រមែងញ៉ាំងមហាសមុទ្ទសាគរឲ្យពេញ អាហារនៃមហាសមុទ្ទសាគរនេះ រមែងមានយ៉ាងនេះ មហាសមុទ្ទសាគរពេញបរិបូណ៌យ៉ាងនេះ ឧបមាយ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ឧបមេយ្យដូចជាអសប្បុរិសសំសេវៈពេញបរិបូណ៌ រមែងញ៉ាំងអសទ្ធម្មស្សវនៈឲ្យពេញបរិបូណ៌ អសទ្ធម្មស្សវនៈពេញបរិបូណ៌ហើយ រមែងញ៉ាំងអសទ្ធិយៈឲ្យពេញបរិបូណ៌ អសទ្ធិយៈពេញបរិបូណ៌ហើយ រមែងញ៉ាំងអយោនិសោមនសិការឲ្យពេញបរិបូណ៌ អយោនិសោ-មនសិការពេញបរិបូណ៌ហើយ រមែងញ៉ាំងការមិនមានសតិ មិនមានសម្ប-ជញ្ញៈឲ្យពេញបរិបូណ៌ ការមិនមានសតិ មិនមានសម្បជញ្ញៈពេញបរិបូណ៌ហើយ រមែងញ៉ាំងការមិនសង្រួមឥន្ទ្រិយឲ្យពេញបរិបូណ៌ ការមិនសង្រួម

ឥន្ទ្រិយពេញបរិបូណ៌ហើយ រមែងញ៉ាំងទុច្ចរិត ៣ ឲ្យពេញបរិបូណ៌ ទុច្ចរិត ៣ ពេញបរិបូណ៌ហើយ រមែងញ៉ាំងនីវរណៈ ៥ ឲ្យពេញបរិបូណ៌ នីវរណៈ ៥ ពេញបរិបូណ៌ហើយ រមែងញ៉ាំងអវិជ្ជាឲ្យពេញបរិបូណ៌ ដោយប្រការដូច្នេះ ។ អាហាររបស់អវិជ្ជានេះ រមែងមានយ៉ាងនេះ អាហាររបស់អវិជ្ជានេះ ពេញបរិបូណ៌យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា វិជ្ជា និងវិមុត្តិ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់វិជ្ជា និងវិមុត្តិ ។ គប្បីឆ្លើយថា ពោជ្ឈង្គ ៧ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ពោជ្ឈង្គ ៧ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់ពោជ្ឈង្គ ៧ ។ គប្បីឆ្លើយថា សតិប្បដ្ឋាន ៤ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សតិប្បដ្ឋាន ៤ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់សតិប្បដ្ឋាន ៤ ។ គប្បីឆ្លើយថា សុចរិត ៣ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សុចរិត ៣ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់សុចរិត ៣ ។ គប្បីឆ្លើយថា ការសង្រួមឥន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ការសង្រួមឥន្ទ្រិយប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហារ របស់ការសង្រួមឥន្ទ្រិយ ។ គប្បីឆ្លើយថា សតិ និងសម្បជញ្ញៈ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សតិ និងសម្បជញ្ញៈ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់

សតិ និងសម្បជញ្ញៈ ។ គប្បីឆ្លើយថា យោនិសោមនសិការ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា យោនិសោមនសិការប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់យោនិសោមនសិការ ។ គប្បីឆ្លើយថា សទ្ធា ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សទ្ធាប្រកបដោយអាហារ មិនបានពោលថាឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់សទ្ធា ។ គប្បីឆ្លើយថា សទ្ធម្មស្សវនៈ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សទ្ធម្មស្សវនៈប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់សទ្ធម្មស្សវនៈ ។ គប្បីឆ្លើយថា សប្បុរិសសំសេវៈ ។ ម្នាលភិក្ខុទាំងឡាយ សប្បុរិសសំសេវៈពេញបរិបូណ៌ រមែងញុំាងសទ្ធម្មស្សវនៈឲ្យពេញបរិបូណ៌ សទ្ធម្មស្សវនៈពេញបរិបូណ៌ហើយ រមែងញុំាងសទ្ធាឲ្យពេញបរិបូណ៌ សទ្ធាពេញបរិបូណ៌ហើយ រមែងញុំាងយោនិសោមនសិការឲ្យពេញបរិបូណ៌ យោនិសោមនសិការពេញបរិបូណ៌ហើយ រមែងញុំាងសតិ និងសម្បជញ្ញៈឲ្យពេញបរិបូណ៌ សតិ និងសម្បជញ្ញៈពេញបរិបូណ៌ហើយ រមែងញុំាងការសង្រួមឥន្ទ្រិយឲ្យពេញបរិបូណ៌ ការសង្រួមឥន្ទ្រិយពេញបរិបូណ៌ហើយ រមែងញុំាងសុចរិត ៣ ឲ្យពេញបរិបូណ៌ សុចរិត ៣ ពេញបរិបូណ៌ហើយ រមែងញុំាងសតិប្បដ្ឋាន ៤ ឲ្យពេញបរិបូណ៌ សតិប្បដ្ឋាន ៤ ពេញបរិបូណ៌ហើយ រមែងញុំាងពោជ្ឈង្គ ៧ ឲ្យពេញបរិបូណ៌ ពោជ្ឈង្គ ៧ ពេញបរិបូណ៌ហើយ រមែងញុំាងវិជ្ជា និងវិមុត្តិឲ្យពេញបរិបូណ៌ ដោយប្រការដូច្នេះឯង ។ អាហារ

របស់វិជ្ជា និងវិមុត្តិនេះ រមែងមានយ៉ាងនេះ ពេញបរិបូណ៌យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ដូចទឹកភ្លៀង មានតំណក់ថ្លោស កាលបង្អុរ កាលរលំ ហូរធ្លាក់លើកំពូលភ្នំ ទឹកនោះ ក៏ហូរទៅតាមទីទាប រមែងញ៉ាំងជ្រោះភ្នំ ល្អាង និងអូរតូចឲ្យពេញ ជ្រោះភ្នំ ល្អាង និងអូរតូចពេញហើយ រមែងញ៉ាំងត្រពាំងតូចឲ្យពេញ ត្រពាំងតូចពេញហើយ រមែងញ៉ាំងត្រពាំងធំឲ្យពេញ ត្រពាំងធំពេញហើយ រមែងញ៉ាំងស្ទឹងតូចឲ្យពេញ ស្ទឹងតូចពេញហើយ រមែងញ៉ាំងស្ទឹងធំឲ្យពេញ ស្ទឹងធំពេញហើយ រមែងញ៉ាំងមហាសមុទ្ទសាគរឲ្យពេញ អាហារនៃមហាសមុទ្ទសាគរនេះ រមែងមានយ៉ាងនេះ ពេញបរិបូណ៌យ៉ាងនេះ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ឧបមេយ្យដូចជាសប្បុរិសសំសេវៈពេញបរិបូណ៌ រមែងញ៉ាំងសទ្ធម្មស្សវនៈឲ្យពេញបរិបូណ៌ សទ្ធម្មស្សវនៈពេញបរិបូណ៌ហើយ រមែងញ៉ាំងសទ្ធាឲ្យពេញបរិបូណ៌ សទ្ធាពេញបរិបូណ៌ហើយ រមែងញ៉ាំងយោនិសោមនសិការឲ្យពេញបរិបូណ៌ យោនិសោមនសិការពេញបរិបូណ៌ហើយ រមែងញ៉ាំងសតិ និងសម្បជញ្ញៈឲ្យពេញបរិបូណ៌ សតិ និងសម្បជញ្ញៈពេញបរិបូណ៌ហើយ រមែងញ៉ាំងការសង្រួមឥន្ទ្រិយឲ្យពេញបរិបូណ៌ ការសង្រួមឥន្ទ្រិយពេញបរិបូណ៌ហើយ រមែងញ៉ាំងសុចរិត ៣ ឲ្យពេញបរិបូណ៌ សុចរិត ៣ ពេញបរិបូណ៌ហើយ រមែងញ៉ាំងសតិប្បដ្ឋាន ៤ ឲ្យពេញបរិបូណ៌ សតិប្បដ្ឋាន ៤ ពេញបរិបូណ៌ហើយ រមែងញ៉ាំងពោជ្ឈង្គ ៧ ឲ្យពេញបរិបូណ៌ ពោជ្ឈង្គ ៧ ពេញបរិបូណ៌ហើយ រមែង

ញ៉ាំងវិជ្ជា និងវិមុត្តិឲ្យពេញបរិបូណ៌ ដោយប្រការដូច្នេះ ។ អាហាររបស់វិជ្ជា និងវិមុត្តិនេះ រមែងមានយ៉ាងនេះ ពេញបរិបូណ៌យ៉ាងនេះ ។

# អដ្ឋកថា

## យមកវគ្គទី ២

### អវិជ្ជាសូត្រ

[ ៦១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអវិជ្ជាសូត្រទី ១ នៃយមកវគ្គទី ២ ដូច្នេះ បទថា **សាហារំ** បានដល់ មានបច្ច័យ ។ បទថា **វិជ្ជាវិមុត្តិំ** បានដល់ ផលញ្ញាណ និងសម្បយុត្តធម៌ដ៏សេស ។ បទថា **ពោជ្ឈង្គា** បានដល់ អង្គនៃបញ្ញាជាគ្រឿងត្រាស់ដឹង គឺមគ្គ ។៚

**អដ្ឋកថាអវិជ្ជាសូត្រទី ១ ចប់**

# សុត្តន្តបិដក

## តណ្ហាសូត្រទី ២

[ ៦២ ] ម្នាលភិក្ខុទាំងឡាយ ទីបំផុតខាងដើមរបស់ភវតណ្ហាមិនប្រាកដទេ ភវតណ្ហា ( សេចក្តីប្រាថ្នាក្នុងភព ) មិនមានក្នុងកាលមុន អំពីកាលនេះ ឬថា កើតឡើងក្នុងខាងក្រោយឡើយ ហេតុនោះ ម្នាលភិក្ខុទាំងឡាយ ក៏ពាក្យថា ភវតណ្ហានេះ តថាគតពោលយ៉ាងនេះ តែថា ភវតណ្ហារមែងប្រាកដព្រោះមានរបស់នេះជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ភវតណ្ហាប្រកបដោយអាហារ មិនបានពោលថាឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់ភវតណ្ហា ។ គប្បីឆ្លើយថា អវិជ្ជា ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា អវិជ្ជាប្រកបដោយអាហារ មិនបានពោលថាឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់អវិជ្ជា ។ គប្បីឆ្លើយថា នីវរណៈ ៥ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា នីវរណៈ ៥ ប្រកបដោយអាហារ មិនបានពោលថាឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់នីវរណៈ ៥ ។ គប្បីឆ្លើយថា ទុច្ចរិត ៣ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ទុច្ចរិត ៣ ប្រកបដោយអាហារ មិនបានពោលថាឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់ទុច្ចរិត ៣ ។ គប្បីឆ្លើយថា ការមិនសង្រួមឥន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ការមិនសង្រួមឥន្ទ្រិយប្រកបដោយអាហារ មិនបានពោលថាឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់ការមិនសង្រួមឥន្ទ្រិយ ។ គប្បីឆ្លើយថា ការមិនមានសតិ មិនមានសម្បជញ្ញៈ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ការមិនមានសតិ មិន

មានសម្បជញ្ញៈប្រកបដោយអាហារ មិនបានពោលថាឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់ការមិនមានសតិ មិនមានសម្បជញ្ញៈ ។ គប្បីឆ្លើយថា អយោនិសោមនសិការ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា អយោនិ-សោមនសិការប្រកបដោយអាហារ មិនបានពោលថាឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់អយោនិសោមនសិការ ។ គប្បីឆ្លើយថា អស្សទ្ធិយៈ ( សេចក្តីមិនជឿ ) ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា អស្សទ្ធិយៈប្រកបដោយអាហារ មិនបានពោលថាឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់អស្សទ្ធិយៈ ។ គប្បីឆ្លើយថា អស្សទ្ធម្មស្សវនៈ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា អស្សទ្ធម្មស្សវនៈប្រកបដោយអាហារ មិនបានពោលថាឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់អស្សទ្ធម្មស្សវនៈ ។ គប្បីឆ្លើយថា អសប្បុរិសសំសេវៈ ។ ម្នាលភិក្ខុទាំងឡាយ អសប្បុរិសសំសេវៈពេញបរិបូណ៌ហើយ រមែងញុំាង អស្សទ្ធម្មស្សវនៈឲ្យពេញបរិបូណ៌ លុះអស្សទ្ធម្មស្សវនៈពេញបរិបូណ៌ហើយ រមែងញុំាងអស្សទ្ធិយៈ ឲ្យពេញបរិបូណ៌ លុះអស្សទ្ធិយៈពេញបរិបូណ៌ហើយ រមែងញុំាងអយោនិសោមនសិការឲ្យពេញបរិបូណ៌ លុះអយោនិសោមនសិការពេញបរិបូណ៌ហើយ រមែងញុំាងការមិនមានសតិ មិនមានសម្បជញ្ញៈឲ្យពេញបរិបូណ៌ លុះការមិនមានសតិ មិនមានសម្បជញ្ញៈពេញបរិបូណ៌ហើយ រមែងញុំាងការមិនសង្រួមឥន្ទ្រិយឲ្យពេញបរិបូណ៌ លុះការមិនសង្រួមឥន្ទ្រិយពេញបរិបូណ៌ហើយ រមែងញុំាងទុច្ចរិត ៣ ឲ្យពេញបរិបូណ៌ លុះទុច្ចរិត ៣ ពេញ

បរិបូណ៌ហើយ រមែងញ៉ាំងនីវរណៈ ៥ ឲ្យពេញបរិបូណ៌ លុះនីវរណៈ ៥ ពេញបរិបូណ៌ហើយ រមែងញ៉ាំងអវិជ្ជាឲ្យពេញបរិបូណ៌ លុះអវិជ្ជាពេញបរិបូណ៌ហើយ រមែងញ៉ាំងភវតណ្ហាឲ្យពេញបរិបូណ៌ ដោយប្រការដូច្នេះឯង ។ អាហាររបស់ភវតណ្ហានេះ រមែងមានយ៉ាងនេះ ពេញបរិបូណ៌យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ដូចទឹកភ្លៀងមានតំណក់ដ៏ថ្លោស កាលបន្លឺរ កាលរំលោហូរធ្លាក់លើកំពូលភ្នំ ទឹកនោះ ក៏ហូរទៅកាន់ទីទាប រមែងញ៉ាំងជ្រោះភ្នំ ល្អាង និងអូរតូចឲ្យពេញ លុះជ្រោះភ្នំ ល្អាង និងអូរតូចពេញហើយ រមែងញ៉ាំងត្រពាំងតូចឲ្យពេញ លុះញ៉ាំងត្រពាំងតូចឲ្យពេញហើយ រមែងញ៉ាំងត្រពាំងធំឲ្យពេញ លុះញ៉ាំងត្រពាំងធំពេញហើយ រមែងញ៉ាំងស្ទឹងតូចឲ្យពេញ លុះស្ទឹងតូចពេញហើយ រមែងញ៉ាំងស្ទឹងធំឲ្យពេញ លុះស្ទឹងធំពេញហើយ រមែងញ៉ាំងមហាសមុទ្ទសាគរឲ្យពេញ អាហារនៃមហាសមុទ្ទសាគរនេះ រមែងមានយ៉ាងនេះ ពេញបរិបូណ៌ហើយយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ឧបមេយ្យដូចជាអសប្បុរិសសំសេវៈពេញបរិបូណ៌ហើយ រមែងញ៉ាំងអសទ្ធម្មស្សវនៈឲ្យពេញបរិបូណ៌ លុះអសទ្ធម្មស្សវនៈពេញបរិបូណ៌ហើយ រមែងញ៉ាំងអសទ្ធិយៈឲ្យពេញបរិបូណ៌ លុះអសទ្ធិយៈពេញបរិបូណ៌ហើយ រមែងញ៉ាំងអយោនិសោមនសិការឲ្យពេញបរិបូណ៌ លុះអយោនិសោមនសិការពេញបរិបូណ៌ហើយ រមែងញ៉ាំងការមិនមានសតិ មិនមានសម្បជញ្ញៈឲ្យពេញបរិបូណ៌ លុះការមិនមានសតិ មិនមានសម្បជញ្ញៈពេញបរិបូណ៌ហើយ រមែង

ញុំាងការមិនសង្រួមឥន្ទ្រិយឲ្យពេញបរិបូណ៌ លុះការមិនសង្រួមឥន្ទ្រិយពេញបរិបូណ៌ហើយ រមែងញុំាងទុច្ចរិត ៣ ឲ្យពេញបរិបូណ៌ លុះទុច្ចរិត ៣ ពេញបរិបូណ៌ហើយ រមែងញុំាងនីវរណៈ ៥ ឲ្យពេញបរិបូណ៌ លុះនីវរណៈ ៥ ពេញបរិបូណ៌ហើយ រមែងញុំាងអវិជ្ជាឲ្យពេញបរិបូណ៌ លុះអវិជ្ជាពេញបរិបូណ៌ហើយ រមែងញុំាងភវតណ្ហាឲ្យពេញបរិបូណ៌ ។ អាហាររបស់ភវតណ្ហានេះរមែងមានយ៉ាងនេះ ពេញបរិបូណ៌យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា វិជ្ជា និងវិមុត្តិប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់វិជ្ជា និងវិមុត្តិ ។ គប្បីឆ្លើយថា ពោជ្ឈង្គ ៧ ប្រការ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ពោជ្ឈង្គ ៧ ប្រការប្រកបដោយអាហារ មិនបានពោលថាឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់ពោជ្ឈង្គ ៧ ប្រការ ។ គប្បីឆ្លើយថា សតិប្បដ្ឋាន ៤ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សតិប្បដ្ឋាន ៤ ប្រកបដោយអាហារ មិនបានពោលថាឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់សតិប្បដ្ឋាន ៤ ។ គប្បីឆ្លើយថា សុចរិត ៣ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សុចរិត ៣ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់សុចរិត ៣ ។ គប្បីឆ្លើយថា ការសង្រួមឥន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ការសង្រួមឥន្ទ្រិយប្រកបដោយអាហារ មិនបានពោលថាឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់ការសង្រួមឥន្ទ្រិយ ។ គប្បីឆ្លើយថា សតិ និងសម្បជញ្ញៈ ។

ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សតិ និងសម្បជញ្ញៈ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់សតិ និងសម្បជញ្ញៈ ។ គប្បីឆ្លើយថា យោនិសោមនសិការ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា យោនិសោមនសិការប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់យោនិសោមនសិការ ។ គប្បីឆ្លើយថា សទ្ធា ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សទ្ធាប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់សទ្ធា ។ គប្បីឆ្លើយថា សទ្ធម្មស្សវនៈ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សទ្ធម្មស្សវនៈប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់សទ្ធម្មស្សវនៈ ។ គប្បីឆ្លើយថា សប្បុរិសសំសេវៈ ។ ម្នាលភិក្ខុទាំងឡាយ សប្បុរិសសំសេវៈពេញបរិបូណ៌ហើយ រមែងញុំាងសទ្ធម្មស្សវនៈឲ្យពេញបរិបូណ៌ លុះសទ្ធម្មស្សវនៈពេញបរិបូណ៌ហើយ រមែងញុំាងសទ្ធាឲ្យពេញបរិបូណ៌ លុះសទ្ធាពេញបរិបូណ៌ហើយ រមែងញុំាងយោនិសោមនសិការឲ្យពេញបរិបូណ៌ លុះយោនិសោមនសិការពេញបរិបូណ៌ហើយ រមែងញុំាងសតិ និងសម្បជញ្ញៈឲ្យពេញបរិបូណ៌ លុះសតិ និងសម្បជញ្ញៈពេញបរិបូណ៌ហើយ រមែងញុំាងការសង្រួមឥន្ទ្រិយឲ្យពេញបរិបូណ៌ លុះការសង្រួមឥន្ទ្រិយពេញបរិបូណ៌ហើយ រមែងញុំាងសុចរិត ៣ ឲ្យពេញបរិបូណ៌ លុះសុចរិត ៣ ពេញបរិបូណ៌ហើយ រមែងញុំាងសតិប្បដ្ឋាន ៤ ឲ្យពេញ

បរិបូណ៌ លុះសតិប្បដ្ឋាន ៤ ពេញបរិបូណ៌ហើយ រមែងញ៉ាំងពោជ្ឈង្គ ៧ ប្រការឲ្យពេញបរិបូណ៌ លុះពោជ្ឈង្គ ៧ ប្រការពេញបរិបូណ៌ហើយ រមែងញ៉ាំងវិជ្ជា និងវិមុត្តិឲ្យពេញបរិបូណ៌ ដោយប្រការដូច្នេះឯង ។ អាហាររបស់វិជ្ជា និងវិមុត្តិនេះ រមែងមានយ៉ាងនេះ ពេញបរិបូណ៌យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ដូចទឹកភ្លៀងមានតំណក់ដ៏ថ្លោស កាលបង្អុរ កាលរំលា ហូរធ្លាក់លើកំពូលភ្នំ ទឹកនោះ ក៏ហូរទៅកាន់ទីទាប រមែងញ៉ាំងជ្រោះភ្នំ ល្អាង និងអូរតូចឲ្យពេញ លុះជ្រោះភ្នំ ល្អាង និងអូរតូចពេញ រមែងញ៉ាំងត្រពាំងតូចឲ្យពេញ លុះត្រពាំងតូចពេញ រមែងញ៉ាំងត្រពាំងធំឲ្យពេញ លុះត្រពាំងធំពេញ រមែងញ៉ាំងស្ទឹងតូចឲ្យពេញ លុះស្ទឹងតូចពេញ រមែងញ៉ាំងស្ទឹងធំឲ្យពេញ លុះស្ទឹងធំពេញហើយ រមែងញ៉ាំងមហាសមុទ្ទសាគរឲ្យពេញ អាហាររបស់មហាសមុទ្ទសាគរនេះ រមែងមានយ៉ាងនេះ ពេញបរិបូណ៌យ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ឧបមេយ្យដូចជាសប្បុរិសសំសេវៈពេញបរិបូណ៌ហើយ រមែងញ៉ាំងសទ្ធម្មស្សវនៈឲ្យពេញបរិបូណ៌ លុះសទ្ធម្មស្សវនៈពេញបរិបូណ៌ រមែងញ៉ាំងសទ្ធាឲ្យពេញបរិបូណ៌ លុះសទ្ធាពេញបរិបូណ៌ រមែងញ៉ាំងយោនិសោ-មនសិការឲ្យពេញបរិបូណ៌ លុះយោនិសោមនសិការពេញបរិបូណ៌ហើយ រមែងញ៉ាំងសតិ និងសម្បជញ្ញៈឲ្យពេញបរិបូណ៌ លុះសតិ និងសម្បជញ្ញៈពេញបរិបូណ៌ រមែងញ៉ាំងការសង្រួមឥន្ទ្រិយឲ្យពេញបរិបូណ៌ លុះការសង្រួមឥន្ទ្រិយពេញបរិបូណ៌ រមែងញ៉ាំងសុចរិត ៣ ឲ្យពេញបរិបូណ៌ លុះសុចរិត ៣

ពេញបរិបូណ៌ រមែងញុំាងសតិប្បដ្ឋាន ៤ ឲ្យពេញបរិបូណ៌ លុះសតិប្បដ្ឋាន ៤ ពេញបរិបូណ៌ រមែងញុំាងពោជ្ឈង្គ ៧ ប្រការឲ្យពេញបរិបូណ៌ លុះពោជ្ឈង្គ ៧ ប្រការពេញបរិបូណ៌ រមែងញុំាងវិជ្ជា និងវិមុត្តិឲ្យពេញបរិបូណ៌ ។ អាហារ របស់វិជ្ជា និងវិមុត្តិនេះ រមែងមានយ៉ាងនេះ ពេញបរិបូណ៌យ៉ាងនេះឯង ។

# អដ្ឋកថា

## តណ្ហាសូត្រ

[ ៦២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតណ្ហាសូត្រទី ២ ដូចតទៅនេះ បទថា **ភវតណ្ហាយ** បានដល់ សេចក្តីប្រាថ្នាភព ។ ក្នុងសូត្រទាំង ២ ត្រាស់ចំពោះវដ្តៈតែម្យ៉ាង តែវដ្តៈក្នុងសូត្រទាំង ២ នេះ សូត្រទី ១ ត្រាស់វដ្តៈមានអវិជ្ជាជាមូល សូត្រទី ២ ត្រាស់វដ្តៈ មានតណ្ហាជាមូល ៕

**អដ្ឋកថា តណ្ហាសូត្រទី ២ ចប់**

# សុត្តន្តបិដក

## និដ្ឋាសូត្រទី ៣

[ ៦៣ ] ម្នាលភិក្ខុទាំងឡាយ ជនទាំងឡាយណាទីមួយ ដល់នូវការចូលចិត្តចំពោះតថាគត បុគ្គលទាំងអស់នោះ ជាអ្នកបរិបូណ៌ដោយទិដ្ឋិ ។ បណ្តាអ្នកបរិបូណ៌ដោយទិដ្ឋិនោះ បុគ្គល ៥ ពួក សម្រេច ( បរិនិព្វាន ) ក្នុងលោកនេះ បុគ្គល ៥ ពួក លះលោកនេះហើយ ទើបសម្រេច ។ បុគ្គល ៥ ពួក ដែលសម្រេចក្នុងលោកនេះ តើដូចម្តេច ។ គឺសត្តក្ខត្តុំបរមបុគ្គល ១ កោលំកោលបុគ្គល ១ ឯកពីជិបុគ្គល ១ សកទាគាមិបុគ្គល ១ ព្រះអរហន្តក្នុងបច្ចុប្បន្ន ១ បុគ្គល ៥ ពួកនេះ មានការសម្រេចក្នុងលោកនេះ ។ បុគ្គល ៥ ពួក ដែលលះលោកនេះហើយសម្រេច តើដូចម្តេច ។ គឺអន្តរាបរិនិព្វាយិបុគ្គល ១ ឧបហច្ចបរិនិព្វាយិបុគ្គល ១ អសង្ខារបរិនិព្វាយិបុគ្គល ១ សសង្ខារបរិនិព្វាយិបុគ្គល ១ ឧទ្ធំសោតអកនិដ្ឋគាមិបុគ្គល ១ បុគ្គល ៥ ពួកនេះ លះលោកនេះហើយ ទើបសម្រេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំងឡាយណាទីមួយ ដល់នូវការចូលចិត្តចំពោះតថាគត ពួកបុគ្គលទាំងអស់នោះ ជាអ្នកបរិបូណ៌ដោយទិដ្ឋិ ។ បណ្តាអ្នកបរិបូណ៌ដោយទិដ្ឋិនោះ បុគ្គល ៥ ពួកនេះ សម្រេចក្នុងលោកនេះ បុគ្គល ៥ ពួកនេះ លះលោកនេះហើយ ទើបសម្រេច ។

# អដ្ឋកថា

## និដ្ឋាសូត្រ

[ ៦៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិដ្ឋាសូត្រទី ៣ ដូចតទៅនេះ បទថា **និដ្ឋង្គតា** បានដល់ អស់សេចក្ដីសង្ស័យ ។ បទថា **ឥធ និដ្ឋា** បានដល់ បរិនិព្វានក្នុងលោកនេះប៉ុណ្ណោះ ។ បទថា **ឥធ វិហាយ និដ្ឋា** បានដល់ លះលោកនេះហើយ ទៅកាន់ព្រហ្មលោកជាន់សុទ្ធាវាស ។៙

**អដ្ឋកថានិដ្ឋាសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## អវេច្ចសូត្រទី ៤

[ ៦៤ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំងឡាយណានីមួយ ជ្រះថ្លាមិនញាប់ញ័រចំពោះតថាគត ពួកបុគ្គលទាំងអស់នោះ ជាសោតាបន្ន ជាអ្នកដល់នូវដើមខ្សែនៃអរិយមគ្គ ។ បណ្ដាសោតាបន្នបុគ្គលទាំងនោះ បុគ្គល ៥ ពួកសម្រេចក្នុងលោកនេះ បុគ្គល ៥ ពួក លះលោកនេះ ទើបសម្រេច ។ បុគ្គល ៥ ពួក ដែលសម្រេចក្នុងលោកនេះ តើដូចម្ដេច ។ គឺសត្តក្ខត្តុំបរមបុគ្គល ១ កោលំ-កោលបុគ្គល ១ ឯកពីជិបុគ្គល ១ សកទាគាមិបុគ្គល ១ ព្រះអរហន្តក្នុងបច្ចុប្បន្ន ១ បុគ្គល ៥ ពួកនេះ មានការសម្រេចក្នុងលោកនេះ ។ បុគ្គល ៥

ពួក ដែលលះលោកនេះហើយទើបសម្រេច តើដូចម្ដេច ។ គឺអន្តរាបរិនិព្វាយិបុគ្គល ១ ឧបហច្ចបរិនិព្វាយិបុគ្គល ១ អសង្ខារបរិនិព្វាយិបុគ្គល ១ សសង្ខារបរិនិព្វាយិបុគ្គល ១ ឧទ្ធំសោតអកនិដ្ឋគាមិបុគ្គល ១ បុគ្គល ៥ ពួកនេះ លះលោកនេះហើយទើបសម្រេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំងឡាយណានីមួយ ជ្រះថ្លាមិនញាប់ញ័រចំពោះតថាគត ពួកបុគ្គលទាំងអស់នោះ ជាសោតាបន្ន ( អ្នកដល់នូវដើមខ្សែនៃអរិយមគ្គ ) ។ បណ្ដាសោតាបន្នបុគ្គលទាំងនោះ បុគ្គល ៥ ពួកនេះ សម្រេចក្នុងលោកនេះ បុគ្គល ៥ ពួកនេះ លះលោកនេះហើយ ទើបសម្រេច ។

# អដ្ឋកថា

## អវេច្ចសូត្រ

[ ៦៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអវេច្ចសូត្រទី ៤ ដូចតទៅនេះ បទថា **អវេច្ចប្បសន្នា** បានដល់ ដល់ព្រមហើយដោយការ ជ្រះថ្លាមិនញាប់ញ័រ ។ បទថា **សោតាបន្នា** បានដល់ ដល់នូវក្រសែនៃអរិយមគ្គ ៕

**អដ្ឋកថា អវេច្ចសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## បឋមសុខសូត្រទី ៥

[ ៦៥ ] សម័យមួយ ព្រះសារីបុត្តដ៏មានអាយុ គង់នៅទាលកគ្រាមក្នុងដែនមគធៈ ។ គ្រានោះ បរិព្វាជកឈ្មោះសាមណ្ឌកានិ ចូលទៅរកព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏បានពោលពាក្យរាក់ទាក់ជាមួយនឹងព្រះសារីបុត្តដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះបរិព្វាជកឈ្មោះសាមណ្ឌកានិ អង្គុយក្នុងទីសមគួរហើយ បានសួរព្រះសារីបុត្តដ៏មានអាយុដូច្នេះថា ម្នាលអាវុសោសារីបុត្ត អ្វីហ្ន៎ឈ្មោះថា សុខ អ្វីឈ្មោះថា ទុក្ខ ។ ព្រះសារីបុត្តឆ្លើយថា ម្នាលអាវុសោ ការកើតឡើងហ្នឹងឯង ឈ្មោះថា ទុក្ខ ការមិនកើតឡើងឈ្មោះថា សុខ ។ ម្នាលអាវុសោ កាលបើមានការកើតឡើង សេចក្តីទុក្ខនេះរមែងប្រាកដ គឺការត្រជាក់ ក្តៅ ឃ្លាន ស្រេក ឧច្ចារៈ បស្សាវៈ ប៉ះត្រូវនឹងភ្លើង ប៉ះត្រូវនឹងដំបង ប៉ះត្រូវនឹងគ្រឿងសស្ត្រាវុធ ញាតិទាំងឡាយក្តី មិត្តទាំងឡាយក្តី រមែងជួបជុំប្រសព្វគ្នា បៀតបៀនបុគ្គលនោះ ។ ម្នាលអាវុសោ កាលបើមានការកើតឡើង សេចក្តីទុក្ខនេះ រមែងប្រាកដ ។ ម្នាលអាវុសោ កាលបើមិនមានការកើតឡើង សេចក្តីសុខនេះ រមែងប្រាកដ គឺការមិនមានត្រជាក់ មិនមានក្តៅ មិនមានឃ្លាន មិនមានស្រេក មិនមានឧច្ចារៈ មិនមានបស្សាវៈ មិនមានប៉ះត្រូវនឹងភ្លើង មិនមានប៉ះត្រូវនឹងដំបង មិនមានប៉ះត្រូវនឹងគ្រឿងសស្ត្រាវុធ ឬញាតិទាំងឡាយក្តី មិត្តទាំងឡាយក្តី មិនជួបជុំប្រសព្វគ្នា

បៀតបៀនបុគ្គលនោះ ។ ម្នាលអាវុសោ កាលបើមិនមានការកើតឡើង សេចក្ដីសុខនេះ រមែងប្រាកដ ។

# អដ្ឋកថា

## បឋមសុខសូត្រ

[ ៦៥ ] បឋមសុខសូត្រទី ៥ សាមណ្ឌកានិបរិព្វាជកសួរព្រះសារីបុត្រដល់ សុខ ទុក្ខ ដែលមានវដ្ដៈជាមូល ។

**អដ្ឋកថាបឋមសុខសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## ទុតិយសុខសូត្រទី ៦

[ ៦៦ ] សម័យមួយ ព្រះសារីបុត្តដ៏មានអាយុ នៅក្នុងនាលកគ្រាមក្នុងដែនមគធៈ ។ គ្រានោះ បរិព្វាជកឈ្មោះសាមណ្ឌកានិ ចូលទៅរកព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ សំណេះសំណាលជាមួយនឹងព្រះសារីបុត្តដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះបរិព្វាជកឈ្មោះសាមណ្ឌ-កានិ អង្គុយក្នុងទីដ៏សមគួរហើយ បានសួរព្រះសារីបុត្តដ៏មានអាយុដូច្នេះថា

ម្នាលអាវុសោសារីបុត្ត អ្វីហ្ន៎ឈ្មោះថា សុខ អ្វីឈ្មោះថា ទុក្ខ ក្នុងធម្មវិន័យនេះ ។ ព្រះសារីបុត្តឆ្លើយថា ម្នាលអាវុសោ សេចក្តីមិនត្រេកអរនេះឯង ឈ្មោះថា ទុក្ខ សេចក្តីត្រេកអរ ឈ្មោះថា សុខ ក្នុងធម្មវិន័យនេះ ។ ម្នាលអាវុសោ កាលបើមិនមានសេចក្តីត្រេកអរ សេចក្តីទុក្ខនេះ រមែងប្រាកដ គឺបុគ្គលកាលដើរទៅក្តី រមែងមិនបានសេចក្តីសុខ ជាទីត្រេកអរ ឈរនៅក្តី... អង្គុយនៅក្តី... ដេកនៅក្តី... នៅក្នុងស្រុកក្តី... នៅក្នុងព្រៃក្តី... នៅជិតគល់ឈើក្តី... នៅក្នុងផ្ទះស្ងាត់ក្តី... នៅក្នុងទីវាលក្តី... នៅក្នុងកណ្តាលភិក្ខុក្តី ក៏រមែងមិនបានសេចក្តីសុខ ជាទីត្រេកអរឡើយ ។ ម្នាលអាវុសោ កាលបើមិនមានសេចក្តីត្រេកអរ សេចក្តីទុក្ខនេះ រមែងប្រាកដ ។ ម្នាលអាវុសោ កាលបើមានសេចក្តីត្រេកអរ សេចក្តីសុខនេះ រមែងប្រាកដ គឺបុគ្គលកាលដើរទៅ ក៏បានប្រសព្វសេចក្តីសុខ ជាទីត្រេកអរ ឈរក្តី... អង្គុយក្តី... ដេកក្តី... នៅក្នុងស្រុកក្តី... នៅក្នុងព្រៃក្តី... នៅជិតគល់ឈើក្តី... នៅក្នុងផ្ទះស្ងាត់ក្តី... នៅទីវាលក្តី... នៅកណ្តាលភិក្ខុក្តី... រមែងបានប្រសព្វសេចក្តីសុខ ជាទីត្រេកអរ ។ ម្នាលអាវុសោ កាលបើមានសេចក្តីត្រេកអរ សេចក្តីសុខនេះ រមែងប្រាកដ ។

# អដ្ឋកថា

## ទុតិយសុខសូត្រ

[ ៦៦ ] ទុតិយសុខសូត្រទី ៦ សាមណ្ឌកានិបរិព្វាជក សួរព្រះសារីបុត្រដល់ សុខ ទុក្ខ ដែលមានសាសនាជាមូល ។l

### អដ្ឋកថាទុតិយសុខសូត្រទី ៦ ចប់

# សុត្តន្តបិដក

## បឋមនឡកបានសូត្រទី ៧ ជាដើម

[ ៦៧ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិកក្នុងកោសលជនបទ ជាមួយនឹងភិក្ខុសង្ឃច្រើនរូប ស្តេចឆ្ពោះទៅកាន់និគមឈ្មោះនឡកបានៈ របស់អ្នកដែនកោសល ។ ក្នុងទីនោះ បានឮថា ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងព្រៃចារ ទៀបស្រុកឈ្មោះនឡកបានៈ ។ សម័យនោះឯង ព្រះដ៏មានព្រះភាគ មានភិក្ខុសង្ឃចោមរោមហើយ ទ្រង់គង់ក្នុងឧបោសថថ្ងៃនោះ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ពួកភិក្ខុឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាអស់វេលាយប់ជ្រៅ ទ្រង់រមិលមើលភិក្ខុសង្ឃ ដែលអង្គុយនៅស្ងប់ស្ងៀម ហើយក៏ត្រាស់នឹងព្រះសារីបុត្តដ៏មានអាយុថា ម្នាលសារីបុត្ត ភិក្ខុសង្ឃប្រាសចាកថីនមិទ្ធៈហើយ ម្នាលសារីបុត្ត

លោកចូរបំភ្លឺធម្មីកថា ដល់ភិក្ខុទាំងឡាយចុះ តថាគតឈឺខ្នង តថាគតនឹងសម្រាកខ្នងបន្តិច ។ ព្រះសារីបុត្តដ៏មានអាយុ ទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ឲ្យក្រាលសង្ឃាដីមានជាន់ ៤ ហើយ សម្រេចនូវសីហសេយ្យាសន៍ផ្អៀងទៅខាងស្តាំ តម្រួតព្រះបាទលើព្រះបាទ មានព្រះសតិ និងសម្បជញ្ញៈធ្វើមនសិការនូវឧដ្ឋានសញ្ញា ។ ក្នុងទីនោះ ព្រះសារីបុត្តដ៏មានអាយុ ហៅភិក្ខុទាំងឡាយថា ម្នាលអាវុសោភិក្ខុទាំងឡាយ ។ ភិក្ខុទាំងអម្បាលនោះ ទទួលស្តាប់ពាក្យព្រះសារីបុត្តដ៏មានអាយុថា ករុណា អាវុសោ ។ ព្រះសារីបុត្តដ៏មានអាយុ សម្តែងដូច្នេះថា ម្នាលអាវុសោទាំងឡាយ សទ្ធាក្នុងកុសលធម៌ទាំងឡាយ របស់បុគ្គលណានីមួយមិនមាន ហិរិមិនមាន... ឱត្តប្បៈមិនមាន... វីរិយៈមិនមាន... បញ្ញាក្នុងកុសលធម៌ទាំងឡាយមិនមាន យប់ និងថ្ងៃរបស់បុគ្គលនោះមកដល់ សេចក្តីសាបសូន្យក្នុងកុសលធម៌ទាំងឡាយ តែងប្រាកដសេចក្តីចម្រើនមិនប្រាកដឡើយ ។ ម្នាលអាវុសោ ដូចជាយប់ និងថ្ងៃរបស់ព្រះចន្ទក្នុងកាឡបក្ខមកដល់ ព្រះចន្ទនោះ រមែងបាត់ចាកពណ៌ បាត់ចាកមណ្ឌល បាត់ចាកពន្លឺ បាត់ចាកកម្ពស់ និងទំហំ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ សទ្ធាក្នុងកុសលធម៌ទាំងឡាយ របស់បុគ្គលណានីមួយមិនមាន ហិរិមិនមាន... ឱត្តប្បៈមិនមាន... វីរិយៈមិនមាន... បញ្ញាក្នុងកុសលធម៌ទាំងឡាយមិនមាន យប់ និងថ្ងៃរបស់បុគ្គលនោះមកដល់ សេចក្តី

សាបសូន្យក្នុងកុសលធម៌ទាំងឡាយ តែងប្រាកដ សេចក្តីចម្រើនមិនប្រាកដឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គលមិនមានសទ្ធា នេះជាសេចក្តីសាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គលមិនមានហិរិ នេះជាសេចក្តីសាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គលមិនមានឱត្តប្បៈ នេះជាសេចក្តីសាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គលជាអ្នកខ្ជិលច្រអូស នេះជាសេចក្តីសាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គលអប្បឥតបញ្ញា នេះជាសេចក្តីសាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គលជាអ្នកក្រោធ នេះជាសេចក្តីសាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គលជាអ្នកចងសេចក្តីក្រោធទុក នេះជាសេចក្តីសាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គលជាអ្នកប្រាថ្នាអាក្រក់ នេះជាសេចក្តីសាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គលជាអ្នកមានមិត្រអាក្រក់ នេះជាសេចក្តីសាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គលជាអ្នកមានសេចក្តីឃើញខុស នេះជាសេចក្តីសាបសូន្យ ។ ម្នាលអាវុសោទាំងឡាយ ពាក្យថា សទ្ធាក្នុងកុសលធម៌ទាំងឡាយ របស់បុគ្គលណាទីមួយមាន ហិរិមាន ... ឱត្តប្បៈមាន ... វិរិយៈមាន ... បញ្ញាក្នុងកុសល-ធម៌ទាំងឡាយមាន យប់ និងថ្ងៃរបស់បុគ្គលនោះមកដល់ សេចក្តីចម្រើនក្នុងកុសលធម៌ទាំងឡាយ តែងប្រាកដ សេចក្តីសាបសូន្យ រមែងមិនប្រាកដ

ឡើយ ។ ម្នាលអាវុសោទាំងឡាយ ដូចជា យប់ និងថ្ងៃរបស់ព្រះចន្ទ ក្នុងជុណ្ហបក្ខមកដល់ ព្រះចន្ទនោះ រមែងចម្រើនដោយពណ៌ ចម្រើនដោយមណ្ឌល ចម្រើនដោយពន្លឺ ចម្រើនដោយកម្ពស់ និងទំហំ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ សទ្ធាក្នុងកុសលធម៌ទាំងឡាយ របស់បុគ្គលណានីមួយមាន ហិរិមាន ... ឱត្តប្បៈមាន ... វិរិយៈមាន ... បញ្ញាក្នុងកុសលធម៌ទាំងឡាយមាន យប់ និងថ្ងៃរបស់បុគ្គលនោះមកដល់ សេចក្តីចម្រើនក្នុងកុសលធម៌ទាំងឡាយ តែងប្រាកដ សេចក្តីសាបសូន្យមិនប្រាកដឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គលអ្នកមានសទ្ធា នេះជាសេចក្តីមិនសាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គលជាអ្នកមានហិរិ នេះជាសេចក្តីមិនសាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គលជាអ្នកមានឱត្តប្បៈ នេះជាសេចក្តីមិនសាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គលជាអ្នកមានវិរិយៈប្រារព្ធហើយ នេះជាសេចក្តីមិនសាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គលជាអ្នកមានបញ្ញា នេះជាសេចក្តីមិនសាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គលជាអ្នកមិនមានសេចក្តីក្រោធ នេះជាសេចក្តីមិនសាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គលជាអ្នកមិនចងសេចក្តីក្រោធទុក នេះជាសេចក្តីមិនសាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គលជាអ្នកមានសេចក្តីប្រាថ្នាតិច នេះជាសេចក្តីមិនសាបសូន្យ ម្នាលអាវុសោទាំង-

ទ្បាយ ពាក្យថា បុរសបុគ្គលជាអ្នកមានកល្យាណមិត្តនេះ នេះជាសេចក្ដីមិនសាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គលអ្នកមានការយល់ឃើញត្រូវ នេះជាសេចក្ដីមិនសាបសូន្យ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់តើនឡើង ត្រាស់នឹងព្រះសារីបុត្តដ៏មានអាយុថា ប្រពៃហើយៗ សារីបុត្ត ម្នាលសារីបុត្ត សទ្ធាក្នុងកុសលធម៌ទាំងឡាយ របស់បុគ្គលណានីមួយមិនមាន ហិរិមិនមាន ... ឱត្តប្បៈមិនមាន ... វិរិយៈមិនមាន ... បញ្ញាក្នុងកុសលធម៌ទាំងឡាយមិនមាន យប់ និងថ្ងៃរបស់បុគ្គលនោះ មកដល់សេចក្ដីសាបសូន្យក្នុងកុសលធម៌ទាំងឡាយ តែងប្រាកដ សេចក្ដីចម្រើនមិនប្រាកដឡើយ ។ ម្នាលសារីបុត្ត ដូចជា យប់ និងថ្ងៃរបស់ព្រះចន្ទក្នុងកាឡបក្ខមកដល់ ព្រះចន្ទនោះ ក៏បាត់ចាកពណ៌ បាត់ចាកមណ្ឌល បាត់ចាកពន្លឺ បាត់ចាកកម្ពស់ និងទំហំ យ៉ាងណាមិញ ម្នាលសារីបុត្ត សទ្ធាក្នុងកុសលធម៌ទាំងឡាយរបស់បុគ្គលណានីមួយមិនមាន ។បេ។ បញ្ញាក្នុងកុសលធម៌ទាំងឡាយមិនមាន ។បេ។ ក៏យ៉ាងនោះដែរ ម្នាលសារីបុត្ត ពាក្យថា បុរសបុគ្គលមិនមានសទ្ធា នេះជាសេចក្ដីសាបសូន្យ ជាអ្នកមិនមានហិរិ ... ជាអ្នកមិនមានឱត្តប្បៈ ... ជាអ្នកខ្ជិលច្រអូស ... ជាអ្នកអាប់ឥតប្រាជ្ញា ... ជាអ្នកក្រោធ ... ជាអ្នកចងសេចក្ដីក្រោធទុក ... ជាអ្នកមានសេចក្ដីប្រាថ្នាអាក្រក់ ... ជាអ្នកមានមិត្តអាក្រក់ ... ម្នាលសារីបុត្ត ពាក្យថា បុរសបុគ្គលអ្នកមានការយល់ឃើញខុស នេះជាសេចក្ដីសាបសូន្យ ។ ម្នាលសារីបុត្ត សទ្ធាក្នុង

កុសលធម៌ទាំងឡាយរបស់បុគ្គលណាមាន ហិរិមាន ... ឱត្តប្បៈមាន ... វីរិយៈមាន ... បញ្ញាក្នុងកុសលធម៌ទាំងឡាយមាន យប់ និងថ្ងៃរបស់បុគ្គលនោះមកដល់ សេចក្តីចម្រើនក្នុងកុសលធម៌ទាំងឡាយ រមែងប្រាកដ សេចក្តីសាបសូន្យមិនប្រាកដឡើយ ។ ម្នាលសារីបុត្ត ដូចជា យប់ និងថ្ងៃណារបស់ព្រះចន្ទក្នុងជុណ្ហបក្ខមកដល់ ព្រះចន្ទនោះចម្រើនដោយពណ៌ ចម្រើនដោយមណ្ឌល ចម្រើនដោយពន្លឺ ចម្រើនដោយកម្ពស់ និងទំហំ យ៉ាងណាមិញ ម្នាលសារីបុត្ត សទ្ធាក្នុងកុសលធម៌ទាំងឡាយរបស់បុគ្គលណានីមួយមាន ហិរិមាន... ឱត្តប្បៈមាន... វីរិយៈមាន... បញ្ញាក្នុងកុសលធម៌ទាំងឡាយមាន យប់ និងថ្ងៃរបស់បុគ្គលនោះមកដល់ សេចក្តីចម្រើនក្នុងកុសលធម៌ទាំងឡាយតែងប្រាកដ សេចក្តីសាបសូន្យមិនប្រាកដឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលសារីបុត្ត ពាក្យថា បុរសបុគ្គលជាអ្នកមានសទ្ធានេះ ជាសេចក្តីមិនសាបសូន្យ ជាអ្នកមានហិរិ... ជាអ្នកមានឱត្តប្បៈ... ជាអ្នកមានវីរិយៈប្រារព្ធហើយ... ជាអ្នកមានបញ្ញា... ជាអ្នកមិនមានសេចក្តីក្រោធ... ជាអ្នកមិនចងសេចក្តីក្រោធទុក... ជាអ្នកប្រាថ្នាតិច... ជាអ្នកមានមិត្តល្អ... ម្នាលសារីបុត្ត ពាក្យថា បុរសបុគ្គលជាអ្នកមានសេចក្តីយល់ឃើញត្រូវ នេះជាសេចក្តីមិនសាបសូន្យទេ ។

[ ៦៨ ] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងព្រៃចារ ទៀបនិគមឈ្មោះនឡកបានៈ ។ សម័យនោះឯង ព្រះដ៏មានព្រះភាគ មានភិក្ខុសង្ឃចោមរោម គង់នៅក្នុងឧបោសថថ្ងៃនោះ ។ គ្រានោះ ព្រះដ៏មានព្រះភាគពន្យល់

ពួកភិក្ខុឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា អស់វេលាយប់ជ្រៅ ទ្រង់រមិលមើលភិក្ខុសង្ឃដែលអង្គុយនៅស្ងប់ស្ងៀម ហើយត្រាស់នឹងព្រះសារីបុត្តដ៏មានអាយុថា ម្នាលសារីបុត្ត ភិក្ខុសង្ឃប្រាសចាកថីនមិទ្ធៈហើយ ម្នាលសារីបុត្ត លោកចូរបំភ្លឺធម្មីកថាដល់ភិក្ខុទាំងឡាយចុះ តថាគតរួយខ្នង តថាគតនឹងសម្រាកខ្នងបន្តិច ។ ព្រះសារីបុត្តដ៏មានអាយុ ទទួលព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ឲ្យក្រាលសង្ឃាដីមានជាន់ ៤ ហើយទ្រង់សម្រេចនូវសីហសេយ្យាសន៍ផ្អៀងទៅខាងស្តាំ តម្រួតព្រះបាទលើព្រះបាទ មានព្រះសតិ និងសម្បជញ្ញៈធ្វើមនសិការនូវឧដ្ឋានសញ្ញា ។ ក្នុងទីនោះឯង ព្រះសារីបុត្តដ៏មានអាយុ ហៅភិក្ខុទាំងឡាយថា ម្នាលអាវុសោភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយនោះទទួលស្តាប់ពាក្យព្រះសារីបុត្តដ៏មានអាយុថា ករុណាអាវុសោ ។ ព្រះសារីបុត្តដ៏មានអាយុ បានពោលពាក្យនេះថា ម្នាលអាវុសោទាំងឡាយ សទ្ធាក្នុងកុសលធម៌ទាំងឡាយរបស់បុគ្គលណានីមួយមិនមាន ហិរិមិនមាន ... ឱត្តប្បៈមិនមាន ... វិរិយៈមិនមាន ... បញ្ញាមិនមាន ... ការផ្ទង់ដើម្បីស្តាប់មិនមាន ... ការទ្រទ្រង់ធម៌មិនមាន ... ការពិចារណាអត្ថមិនមាន ... ការប្រតិបត្តិធម៌សមគួរតាមធម៌មិនមាន ... សេចក្តីមិនប្រមាទក្នុងកុសលធម៌ទាំងឡាយមិនមាន យប់និងថ្ងៃរបស់បុគ្គលនោះមកដល់ សេចក្តីសាបសូន្យក្នុងកុសលធម៌ទាំងឡាយរមែងប្រាកដ សេចក្តីចម្រើនមិនប្រាកដឡើយ ។ ម្នាលអាវុសោ ដូចជា យប់

និងថ្ងៃរបស់ព្រះចន្ទក្នុងកាឡបក្ខមកដល់ ព្រះចន្ទនោះ រមែងបាត់ចាកពណ៌ បាត់ចាកមណ្ឌល បាត់ចាករស្មី បាត់ចាកកម្ពស់ និងទំហំ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ សទ្ធាក្នុងកុសលធម៌ទាំងឡាយ របស់បុគ្គលណានីមួយមិនមាន ហិរិមិនមាន ... ឱត្តប្បៈមិនមាន ... វិរិយៈមិនមាន ... បញ្ញាមិនមាន ... ការផ្ចង់ដើម្បីស្តាប់មិនមាន ... ការទ្រទ្រង់ធម៌មិនមាន ... ការពិចារណាអត្ថមិនមាន ... ការប្រតិបត្តិធម៌សមគួរតាមធម៌មិនមាន ... សេចក្តីមិនប្រមាទក្នុងកុសលធម៌ទាំងឡាយមិនមាន យប់ និងថ្ងៃរបស់បុគ្គលនោះមកដល់ សេចក្តីសាបសូន្យក្នុងកុសលធម៌ទាំងឡាយប្រាកដ សេចក្តីចម្រើនរមែងមិនប្រាកដឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោទាំងឡាយ សទ្ធាក្នុងកុសលធម៌ទាំងឡាយរបស់បុគ្គលណានីមួយមាន ហិរិមាន ... ឱត្តប្បៈមាន ... វិរិយៈមាន ... បញ្ញាមាន ... ការផ្ចង់ដើម្បីស្តាប់មាន ... ការទ្រទ្រង់ធម៌មាន ... ការពិចារណាអត្ថមាន ... ការប្រតិបត្តិធម៌តាមសមគួរដល់ធម៌មាន ... សេចក្តីមិនប្រមាទក្នុងកុសលធម៌ទាំងឡាយមាន យប់ និងថ្ងៃរបស់បុគ្គលនោះមកដល់ សេចក្តីចម្រើនក្នុងកុសលធម៌ទាំងឡាយ រមែងប្រាកដ សេចក្តីសាបសូន្យរមែងមិនប្រាកដឡើយ ។ ម្នាលអាវុសោទាំងឡាយ ដូចជាយប់ និងថ្ងៃរបស់ព្រះចន្ទក្នុងជុណ្ហបក្ខមកដល់ ព្រះចន្ទនោះ ចម្រើនដោយពណ៌ ចម្រើនដោយមណ្ឌល ចម្រើនដោយពន្លឺ ចម្រើនដោយកម្ពស់ និងទំហំ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ សទ្ធាក្នុងកុសលធម៌ទាំងឡាយ របស់បុគ្គលណា

នីមួយមាន ហិរិមាន ... ឱត្តប្បៈមាន ... វិរិយៈមាន ... បញ្ញាមាន ... ការផ្ចង់ដើម្បីស្តាប់មាន ... ការទ្រទ្រង់ធម៌មាន ... ការពិចារណាអត្ថមាន ... ប្រតិបត្តិធម៌តាមសមគួរដល់ធម៌មាន ... សេចក្តីមិនប្រមាទក្នុងកុសលធម៌ទាំងឡាយមាន យប់ និងថ្ងៃរបស់បុគ្គលនោះមកដល់ សេចក្តីចម្រើនក្នុងកុសលធម៌ទាំងឡាយ រមែងប្រាកដ សេចក្តីសាបសូន្យរមែងមិនប្រាកដឡើយ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់តើនចាកអាសនៈហើយ បានត្រាស់នឹងព្រះសារីបុត្តដ៏មានអាយុថា ប្រពៃណាស់ហើយសារីបុត្ត ម្នាលសារីបុត្ត សទ្ធាក្នុងកុសលធម៌ទាំងឡាយ របស់បុគ្គលណានីមួយមិនមាន ហិរិមិនមាន ... ឱត្តប្បៈមិនមាន ... វិរិយៈមិនមាន ... បញ្ញាមិនមាន ... ការផ្ចង់ដើម្បីស្តាប់មិនមាន ... ការទ្រទ្រង់ធម៌មិនមាន ... ការពិចារណាអត្ថមិនមាន ... ការប្រតិបត្តិធម៌តាមសមគួរដល់ធម៌មិនមាន ... សេចក្តីមិនប្រមាទក្នុងកុសលធម៌ទាំងឡាយមិនមាន ... យប់ និងថ្ងៃរបស់បុគ្គលនោះមកដល់ សេចក្តីសាបសូន្យក្នុងកុសលធម៌ទាំងឡាយ រមែងប្រាកដ សេចក្តីចម្រើន រមែងមិនប្រាកដឡើយ ។ ម្នាលសារីបុត្ត ដូចជាយប់ និងថ្ងៃរបស់ព្រះចន្ទក្នុងកាឡបក្ខមកដល់ ព្រះចន្ទនោះរមែងបាត់ចាកពណ៌ បាត់ចាកមណ្ឌល បាត់ចាកពន្លឺ បាត់ចាកកម្ពស់ និងទំហំ យ៉ាងណាមិញ ម្នាលសារីបុត្ត សទ្ធាក្នុងកុសលធម៌ទាំងឡាយរបស់បុគ្គលណានីមួយមិនមាន ។បេ។ សេចក្តីមិនប្រមាទ ក្នុងកុសលធម៌ទាំងឡាយមិនមាន យប់ និងថ្ងៃរបស់បុគ្គលនោះមកដល់ សេចក្តី

សាបសូន្យក្នុងកុសលធម៌ទាំងឡាយប្រាកដ សេចក្តីចម្រើន រមែងមិនប្រាកដឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលសារីបុត្ត សទ្ធាក្នុងកុសលធម៌ទាំងឡាយរបស់បុគ្គលណានីមួយមាន ហិរិមាន ... ឱត្តប្បៈមាន ... វីរិយៈមាន ... បញ្ញាមាន ... ការផ្ចង់ដើម្បីស្តាប់មាន ... ការទ្រទ្រង់ធម៌មាន ... ការពិចារណាអត្ថមាន ... ការប្រតិបត្តិធម៌តាមសមគួរដល់ធម៌មាន ... សេចក្តីមិនប្រមាទក្នុងកុសលធម៌ទាំងឡាយមាន យប់ និងថ្ងៃរបស់បុគ្គលនោះមកដល់សេចក្តីចម្រើន រមែងប្រាកដ សេចក្តីសាបសូន្យ រមែងមិនប្រាកដឡើយ ។ ម្នាលសារីបុត្ត ដូចជា យប់ និងថ្ងៃរបស់ព្រះចន្ទក្នុងជុណ្ហបក្ខមកដល់ ព្រះចន្ទនោះរមែងចម្រើនដោយពណ៌ ចម្រើនដោយមណ្ឌល ចម្រើនដោយពន្លឺ ចម្រើនដោយកម្ពស់ និងទំហំ យ៉ាងណាមិញ ម្នាលសារីបុត្ត សទ្ធាក្នុងកុសលធម៌ទាំងឡាយរបស់បុគ្គលណានីមួយមាន ។បេ។ សេចក្តីមិនប្រមាទក្នុងកុសលធម៌ទាំងឡាយមាន យប់ និងថ្ងៃរបស់បុគ្គលនោះមកដល់ សេចក្តីចម្រើនក្នុងកុសលធម៌ទាំងឡាយ រមែងប្រាកដ សេចក្តីសាបសូន្យរមែងមិនប្រាកដឡើយ ក៏យ៉ាងនោះដែរ ។

# អដ្ឋកថា

## បឋមឆទ្បកចានសូត្រទី ៧ ជាដើម

[ ៦៧-៦៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមនទ្បកបានសូត្រទី ៧ ដូច្នេះ បទថា **ឆទ្បកចានំ** បានដល់ និគមមានឈ្មោះយ៉ាងនេះ ព្រោះក្នុងអតីតកាល ហ្វូងស្វានៅក្នុងឱវាទរបស់ព្រះពោធិសត្វ ប្រើបំពង់ដើមបបុសដើម្បីផឹកទឹក ។ បទថា **តុណ្ហីភូតំ តុណ្ហីភូតំ** សេចក្តីថា ទ្រង់ឆ្មៀងមើលក្នុងទិសណា ក៏ទ្រង់ឃើញភិក្ខុសង្ឃនាំគ្នានៅស្ងៀម ក្នុងទិសនោះៗ ។ បទថា **អនុវិលោ-កេត្វា** បានដល់ ទ្រង់សម្លឹងមើលអំពីទិសនោះ ។ បទថា **បិដ្ឋិ មេ អាគិលាយតិ** សេចក្តីថា ហេតុអ្វី ទើបព្រះមានព្រះភាគទ្រង់ចុករោយព្រះបិដ្ឋិ ។ ព្រោះព្រះមានព្រះភាគ កាលទ្រង់តាំងមហាបធានអស់ ៦ ឆ្នាំ ក៏មានទុក្ខតាមព្រះវរកាយជាច្រើន ក្រោយមក កាលទ្រង់ព្រះជរា ទើបទ្រង់កើតរោគចុករោយព្រះបិដ្ឋិ ពិតហើយ អាពាធតូចតាចដែលកើតអំពីព្រះឥរិយាបថមានការប្រថាប់គង់យូរជាដើម គ្រប់សង្កត់ព្រះឧបាទិន្នវរកាយមិនបានឡើយ ទ្រង់អាងដល់សេចក្តីនោះ ទើបត្រាស់យ៉ាងនេះ ក៏ដើម្បីធ្វើឱកាសដល់ព្រះថេរៈ ។ បទថា **សង្ឃាដី បញ្ញាបេត្វា** សេចក្តីថា ទ្រង់ក្រាលសង្ឃាដីលើគ្រែដែលជាកប្បិយ ដែលគេរក្សាក្នុងទីដ៏សមគួរនាចំណែកម្ខាង ៕

**អដ្ឋកថា បឋមឆទ្បកចានសូត្រទី ៧ ជាដើម ចប់**

# សុត្តន្តបិដក

## បឋមវត្ថុកថាសូត្រទី ៩

[ ៦៩ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក្នុងសម័យនោះឯង ភិក្ខុទាំង-ឡាយច្រើនរូប ត្រឡប់អំពីបិណ្ឌបាតក្នុងបច្ឆាភត្តហើយ ក៏អង្គុយជួបជុំគ្នាក្នុងឧបដ្ឋានសាលា ប្រកបតិរច្ឆានកថាច្រើនយ៉ាង គឺនិយាយអំពីស្តេច និយាយអំពីចោរ និយាយអំពីអាមាត្យធំ និយាយអំពីសេនាទាហាន និយាយអំពីភ័យ និយាយអំពីចម្បាំង និយាយអំពីម្ហូបចំណី និយាយអំពីទឹក និយាយអំពីសំពត់ និយាយអំពីទីដេក និយាយអំពីផ្កាកម្រង និយាយអំពីគ្រឿងក្រអូប និយាយអំពីញាតិ និយាយអំពីយាន និយាយអំពីស្រុក និយាយអំពីនិគម និយាយអំពីនគរ និយាយអំពីជនបទ និយាយអំពីស្ត្រី និយាយអំពីយោធាដែលក្លៀវក្លា និយាយអំពីច្រកផ្លូវ និយាយអំពីកំពង់ទឹក និយាយអំពីញាតិដែលបែកបាក់ទៅកាន់បរលោក និយាយអំពីពាក្យដែលឥតប្រយោជន៍ មានសភាពផ្សេងៗ និយាយអំពីលោក និយាយអំពីរឿងជីកសមុទ្រ និយាយអំពីសេចក្តីចម្រើន និងមិនចម្រើន ដែលជាហេតុឥតប្រយោជន៍ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ចេញអំពីទីសម្ងំក្នុងសាយណ្ហសម័យហើយ ស្តេចចូលទៅកាន់ឧបដ្ឋានសាលា លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគទ្រង់គង់ស្រេចហើយ ទើបត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលអម្បាញ់មិញនេះ អ្នកទាំង-

ឡាយប្រជុំគ្នាដោយកថាដូចម្តេចហ្ន៎ មួយវិញទៀត អន្តរាកថាដូចម្តេចហ្ន៎ ដែលអ្នកទាំងឡាយបញ្ឈប់ទៅ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីនេះ ពួកខ្ញុំព្រះអង្គត្រឡប់អំពីបិណ្ឌបាត ក្នុងបច្ឆាភត្តហើយអង្គុយជួបជុំគ្នាក្នុងឧបដ្ឋានសាលា ប្រកបតិរច្ឆានកថាជាច្រើនយ៉ាង គឺនិយាយអំពីស្តេច និយាយអំពីចោរ ។បេ។ និយាយអំពីសេចក្តីចម្រើន និងមិនចម្រើនដែលជាហេតុឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយប្រកបតិរច្ឆានកថាជាច្រើនយ៉ាង ដោយហេតុណា ហេតុនោះ មិនសមគួរដល់អ្នកទាំងឡាយ ដែលជាកុលបុត្រ អ្នកចេញចាកផ្ទះដោយសទ្ធា ហើយចូលកាន់ផ្នួសឡើយ តិរច្ឆានកថានោះ គឺនិយាយអំពីស្តេច និយាយអំពីចោរ និយាយអំពីអាមាត្យធំ និយាយអំពីសេនាទាហាន និយាយអំពីភ័យ និយាយអំពីចម្បាំង និយាយអំពីម្ហូបចំណី និយាយអំពីទឹក និយាយអំពីសំពត់ និយាយអំពីទីដេក និយាយអំពីកម្រងផ្កា និយាយអំពីគ្រឿងក្រអូប និយាយអំពីញាតិ និយាយអំពីយាន និយាយអំពីស្រុក និយាយអំពីនិគម និយាយអំពីនគរ និយាយអំពីជនបទ និយាយអំពីស្ត្រី និយាយអំពីយោធាក្លៀវក្លា និយាយអំពីប្រកផ្លូវ និយាយអំពីកំពង់ទឹក និយាយអំពីញាតិដែលចែកឋានទៅកាន់បរលោក និយាយអំពីពាក្យដែលឥតប្រយោជន៍មានសភាពផ្សេងៗ និយាយអំពីលោក និយាយអំពីរឿងជីកសមុទ្រ និយាយអំពីសេចក្តីចម្រើន និងមិនចម្រើន ដែលជាហេតុឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ កថាវត្ថុ

( ហេតុគួរនិយាយ ) អម្បាលនេះមាន ១០ ប្រការ ។ កថាវត្ថុ ១០ ប្រការ តើដូចម្តេចខ្លះ ។ គឺនិយាយអំពីសេចក្តីប្រាថ្នាតិច ១ និយាយអំពីសេចក្តីសន្តោស ១ និយាយអំពីសេចក្តីស្ងាត់ ១ និយាយអំពីសេចក្តីមិនច្រឡូកច្រឡំដោយពួកគណៈ ១ និយាយអំពីប្រារព្ធសេចក្តីព្យាយាម ១ និយាយអំពីសីល ១ និយាយអំពីសមាធិ ១ និយាយអំពីបញ្ញា ១ និយាយអំពីវិមុត្តិ ១ និយាយអំពីវិមុត្តិញាណទស្សនៈ ១ ម្នាលភិក្ខុទាំងឡាយ កថាវត្ថុមាន ១០ ប្រការនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយនិយាយនូវកថាដែលអាស្រ័យកថាវត្ថុ ១០ ប្រការនេះឯង អ្នកទាំងឡាយនឹងគ្របសង្កត់នូវតេជះនៃព្រះចន្ទ និងព្រះអាទិត្យនេះឯង ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពធំយ៉ាងនេះ ដោយតេជះរបស់ខ្លួន នឹងបាច់ពោលទៅថ្វីដល់ពួកបរិព្វាជកជាអន្យតិរ្ថិយឡើយ ។

# អដ្ឋកថា

## បឋមវត្ថុកថាសូត្រ

[ ៦៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមវត្ថុកថាសូត្រទី ៩ ដូចតទៅនេះ បទថា **តិរច្ឆានកថំ** បានដល់ រឿងដែលទទឹងផ្លូវសួគ៌ និងព្រះនិព្វាន ព្រោះជារឿងដែលមិននាំសត្វចេញចាកទុក្ខ ។ បណ្តាតិរច្ឆានកថានោះ កថា គឺរឿងដែលប្រារព្ធព្រះរាជា ហើយប្រព្រឹត្តទៅដោយន័យជាដើមថា ព្រះបាទមហា-

សម្មតរាជ ព្រះបាទមន្ធាតុរាជ ព្រះបាទធម្មាសោករាជ ទ្រង់មានអានុភាព ច្រើនយ៉ាងនេះ ឈ្មោះថា រាជកថា ។ ក្នុងចោរកថាជាដើម ក៏មានន័យដូច្នេះ ។ កថា គឺរឿងដែលពោលទាក់ទងនឹងផ្ទះសម្បែង ដោយន័យជាដើមថា ព្រះរាជា អង្គនោះស្អាត គួរសរសើរ ក៏ជាតិរច្ឆានកថា ។ ចំណែកកថាដែលប្រព្រឹត្តទៅ យ៉ាងនេះថា ព្រះរាជាអង្គនោះ មានអានុភាពច្រើនយ៉ាងនោះ គង់មិនទៀង ដូច្នេះ តាំងនៅក្នុងភាពជាកម្មដ្ឋាន ។ ក្នុងពួកចោរ កថាដែលអាស្រ័យកម្មនៃ ចោរទាំងនោះប្រព្រឹត្តទៅ ដោយន័យថា មូលទេវចោរ មានអំណាចច្រើន យ៉ាងនេះ មេឃមាលចោរ មានអំណាចច្រើនយ៉ាងនេះ កថាដែលពោលទាក់ ទងនឹងផ្ទះសម្បែងថា ចិត្តរបស់ពួកគេជាអ្នកក្លាហាន ដូច្នោះ ទើបជាតិរច្ឆាន-កថា ។ សូម្បីក្នុងរឿងចម្បាំងទាំងឡាយ មានការតយុទ្ធជាដើម កថាដែល ប្រព្រឹត្តទៅ ដោយអំណាចការត្រេកអរក្នុងកម្មថា បុគ្គលនោះ ត្រូវបុគ្គល នោះធ្វើឲ្យស្លាប់ យ៉ាងនេះ បាញ់យ៉ាងនេះ ឈ្មោះថា តិរច្ឆានកថា ។ ឯកថា ដែលប្រព្រឹត្តទៅយ៉ាងនេះ បុគ្គលពួកនោះ ក៏ដល់នូវការអស់ទៅ សូន្យទៅ រមែងជាកម្មដ្ឋាន គ្រប់កថាទាំងអស់ ។ ម្យ៉ាងទៀត ក្នុងរឿងអាហារ មាន បាយជាដើម ពោលដោយអំណាចការត្រេកអរក្នុងវត្ថុដែលគួរប្រាថ្នាថា ខ្ញុំ ទំពាស៊ី ខ្ញុំផឹក បរិភោគអាហារមានរសល្អ មានរសឆ្ងាញ់យ៉ាងនេះ មិនគួរ ។ តែពោលឲ្យមានប្រយោជន៍ថា ក្នុងកាលមុន ខ្ញុំបានប្រគេនបាយ ទឹក សំពត់ ទីដេក ផ្កាកម្រង គ្រឿងក្រអូបដែលសម្បូរដោយពណ៌ជាដើម បានធ្វើការ

បូជាព្រះចេតិយយ៉ាងនេះ ក៏គួរ ។ ក្នុងរឿងញាតិទាំងឡាយ បើពោលដោយ
អំណាចសេចក្តីត្រេកអរថា ពួកញាតិរបស់អញ ជាអ្នកក្លាហាន ឬក្នុងកាល
មុន ពួកយើងនាំគ្នាត្រាច់ទៅដោយយានដ៏វិចិត្រយ៉ាងនេះ មិនគួរ ។ តែគប្បី
ពោលឲ្យជាប្រយោជន៍យ៉ាងនេះថា ពួកញាតិរបស់យើងនោះ ក៏ដល់នូវការ
អស់ទៅ ឬក្នុងកាលមុន ពួកខ្ញុំបានប្រគេនស្បែកជើងយ៉ាងនេះដល់សង្ឃ ។
សូម្បីកថាពោលអំពីស្រុក ដែលប្រព្រឹត្តទៅដោយអំណាចទីតាំងល្អ ទីតាំង
អាក្រក់ រកភិក្ខាបានងាយ រកភិក្ខាបានលំបាកជាដើម ឬដោយអំណាចការ
ត្រេកអរយ៉ាងនេះថា អ្នកស្រុកនោះជាអ្នកក្លាហាន ដូច្នេះ មិនគួរ ។ តែពោល
ឲ្យជាប្រយោជន៍ថា ពួកគេមានសទ្ធាជ្រះថ្លា ឬថា ពួកគេដល់នូវការអស់ទៅ
សូន្យទៅ ដូច្នេះក៏គួរ ។ សូម្បីក្នុងកថាពោលអំពីនិគម នគរ ជនបទ ក៏មាន
ន័យដូចគ្នា ។ សូម្បីកថារឿងស្ត្រី ដែលប្រព្រឹត្តទៅអាស្រ័យពណ៌សម្បុរ
ទ្រង់ទ្រាយជាដើម ដោយអំណាចសេចក្តីត្រេកអរ មិនគួរ ។ តែបើពោល
យ៉ាងនេះថា ស្ត្រីនោះមានសទ្ធាជ្រះថ្លា ក៏ដល់នូវការអស់ទៅ ដូច្នេះក៏គួរ ។
កថាពោលអំពីអ្នកក្លាហាន ដែលប្រព្រឹត្តទៅដោយអំណាចការត្រេកអរ
ប៉ុណ្ណោះថា អ្នកចម្បាំងឈ្មោះនន្ទមិត្ត ជាអ្នកក្លាហាន ដូច្នេះមិនគួរ ។ ដែល
ប្រព្រឹត្តទៅយ៉ាងនេះថា បុគ្គលនោះជាអ្នកមានសទ្ធា តែក៏ដល់នូវការអស់ទៅ
ហើយ ក៏គួរ ។ ការពោលរឿងសុរា ក្នុងបាលី មានច្រើនយ៉ាង ពោលរឿង
គ្រឿងស្រវឹងដោយអំណាចសេចក្តីត្រេកអរ មិនគួរ ពោលដោយអំណាចនៃ

ទោសប៉ុណ្ណោះ ទើបគួរ ។ កថាពោលអំពីផ្លូវ ដែលប្រព្រឹត្តទៅដោយអំណាចសេចក្តីត្រេកអរថា ផ្លូវនោះ តាំងនៅល្អ តាំងនៅមិនល្អ មិនគួរ ដែលប្រព្រឹត្តទៅថា មនុស្សក្នុងផ្លូវនោះ មានសទ្ធាជ្រះថ្លា ក៏ដល់នូវការអស់ទៅ ដូច្នេះគួរ ។ កថាដែលកើតឡើង ប្រចាំត្រង់កំពង់ទឹក កថារឿងកំពង់ទឹក ឬកថាពោលអំពីទាសីទូលក្អមទឹក លោកហៅថា **កុម្ភដ្ឋានកថំ** ។ កុម្ភដ្ឋាន-កថានោះ ដែលប្រព្រឹត្តទៅដោយអំណាចសេចក្តីត្រេកអរប៉ុណ្ណោះថា ស្រ្តីទូលក្អមទឹក គួរជ្រះថ្លា ឈ្លាសក្នុងការរាំច្រៀង ដូច្នេះ មិនគួរ ។ ដែលប្រព្រឹត្តទៅដោយន័យជាដើមថា នាងមានសទ្ធាជ្រះថ្លា ដូច្នេះ ទើបគួរ ។ កថាពោលអំពីញាតិដែលស្លាប់ទៅហើយ ឈ្មោះថា **បុព្វបេតកថំ** ។ ក្នុងបុព្វបេតកថានោះ គប្បីជ្រាបវិនិច្ឆ័យដូចគ្នានឹងកថា ពោលអំពីរឿងញាតិក្នុងបច្ចុប្បន្ន ។ តិរច្ឆានកថាដែលមានសភាពផ្សេងៗ ដ៏សេស ផុតចាកកថាដើម និងកថាខាងក្រោយ ឈ្មោះថា **នានត្តកថំ** ។ កថាសន្ទនាដោយលោកាយតសាស្ត្រ វិតណ្ឌសាស្ត្រជាដើមយ៉ាងនេះថា លោកនេះអ្នកណាសាង ក្អែកស ព្រោះមានឆ្អឹងស សត្វត្រដក់ក្រហម ព្រោះមានឈាមក្រហម ទេវៈឈ្មោះនោះសាង ឈ្មោះថា **លោកក្ខាយិកំ** ។ កថាពោលអំពីសមុទ្រ ដល់រឿងដែលឥតប្រយោជន៍ជាដើមយ៉ាងនេះថា ព្រោះហេតុអ្វី ទើបសមុទ្រ ឈ្មោះថា សាគរ ព្រោះព្រះបាទសាគរទ្រង់ជីក សាគរ ឈ្មោះថា សមុទ្រ ព្រោះព្រះបាទសាគរទ្រង់ប្រកាសដោយព្រះរាជត្រាថា សាគរ យើងជីក ឈ្មោះថា **សមុទ្ទក្ខា-**

**យិកំ។** *បទថា* **ភវោ** *បានដល់ សេចក្តីចម្រើន ។ បទថា* **អភវោ** *បានដល់ សេចក្តីវិនាស ។ បទថា* **ឥតិភវោ** *សេចក្តីថា កថាដែលពោលដល់ហេតុ ដែលឥតប្រយោជន៍ណាមួយប្រព្រឹត្តទៅ ឈ្មោះថា* **ឥតិភវាភវកថា។**

*បទថា* **តេជសា តេជំ** *បានដល់ យកតេជះគ្របសង្កត់តេជះរបស់ព្រះចន្ទ និងព្រះអាទិត្យទាំងនោះ ។ បទថា* **បរិយាទិយេយ្យាថ** *បានដល់ ធ្វើតេជះរបស់ព្រះចន្ទ ព្រះអាទិត្យឲ្យអស់ទៅ តាំងនៅ ។ ក្នុងសេចក្តីនេះ មានរឿងសាធកដូច្នេះថា ភិក្ខុអ្នកសមាទានបិណ្ឌបាតជាវត្តមួយអង្គ សួរព្រះមហាថេរៈថា បពិត្រលោកម្ចាស់ ភិក្ខុទាំងឡាយ កាលយកតេជះគ្របសង្កត់តេជះ ធ្វើដូចម្តេច ។ ព្រះថេរៈពោលថា អាវុសោ ភិក្ខុទាំងឡាយ ឈរកណ្តាលកម្តៅថ្ងៃមួយកន្ទេង ធ្វើដោយអាការដែលស្រមោលមិនចុះខាងក្រោម មិនឡើងខាងលើ ។៙*

**អដ្ឋកថា បឋមវត្ថុកថាសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ទុតិយវគ្គកថាសូត្រទី ១០

[ ៧០ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុច្រើនរូប ត្រឡប់អំពីបិណ្ឌបាតក្នុងបច្ឆាភត្តហើយ អង្គុយជួបជុំគ្នាក្នុងឧបដ្ឋានសាលា ប្រកបតិរច្ឆានកថាច្រើនប្រការ គឺនិយាយអំពីស្ដេច និយាយអំពីចោរ និយាយអំពីអាមាត្យធំ ។បេ។ និយាយអំពីសេចក្ដីចម្រើន និងមិនចម្រើនដែលជាហេតុឥតប្រយោជន៍ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ចេញអំពីទីសម្ងំក្នុងសាយណ្ហសម័យ ហើយស្ដេចចូលទៅកាន់ឧបដ្ឋានសាលា លុះចូលទៅដល់ហើយ គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគ គង់ស្រេចហើយ ទើបត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលអម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយជួបជុំគ្នាដោយកថាដូចម្ដេចហ្ន៎ ចុះអន្តរាកថាដូចម្ដេច ដែលពួកអ្នកបញ្ឈប់ទៅ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ពួកខ្ញុំព្រះអង្គត្រឡប់អំពីបិណ្ឌបាតក្នុងបច្ឆាភត្តហើយ អង្គុយប្រជុំគ្នាក្នុងឧបដ្ឋានសាលា ប្រកបតិរច្ឆានកថាជាច្រើន គឺនិយាយអំពីស្ដេច និយាយអំពីចោរ ។បេ។ និយាយអំពីសេចក្ដីចម្រើន និងមិនចម្រើនដែលជាហេតុឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយប្រកបតិរច្ឆានកថាជាច្រើន ដោយហេតុណា ហេតុនេះមិនសមគួរដល់អ្នកទាំងឡាយដែលជាកុលបុត្រចេញចាកផ្ទះដោយសទ្ធា ចូលមកកាន់ផ្នួសទេ តិរច្ឆានកថា

នោះ គឺនិយាយអំពីស្តេច ។បេ។ និយាយអំពីសេចក្តីចម្រើននិងមិនចម្រើន ដែលជាហេតុឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ ឋានៈដែលគួរសរសើរនេះមាន ១០ យ៉ាង ។ ឋានៈ ១០ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រាថ្នាតិចដោយខ្លួនឯងផង សម្តែងអំពីសេចក្តីប្រាថ្នាតិចដល់ភិក្ខុទាំងឡាយផង នេះជាឋានៈគួរសរសើរថា ភិក្ខុជាអ្នកប្រាថ្នាតិច ដោយខ្លួនឯងផង សម្តែងអំពីសេចក្តីប្រាថ្នាតិចដល់ភិក្ខុទាំងឡាយផង ១ ។ ភិក្ខុជាអ្នកសន្តោសដោយខ្លួនឯងផង សម្តែងអំពីសេចក្តីសន្តោសដល់ភិក្ខុទាំងឡាយផង នេះជាឋានៈដែលគួរសរសើរថា ភិក្ខុជាអ្នកសន្តោសផង សម្តែងអំពីសេចក្តីសន្តោសដល់ភិក្ខុទាំងឡាយផង ១ ។ ភិក្ខុជាអ្នកស្ងប់ស្ងាត់ដោយខ្លួនឯងផង សម្តែងអំពីសេចក្តីស្ងប់ស្ងាត់ដល់ភិក្ខុទាំងឡាយផង នេះជាឋានៈដែលគួរសរសើរថា ភិក្ខុជាអ្នកស្ងប់ស្ងាត់ផង សម្តែងអំពីសេចក្តីស្ងប់ស្ងាត់ ដល់ភិក្ខុទាំងឡាយផង ១ ។ ភិក្ខុជាអ្នកមិនច្រឡូកច្រឡំដោយពួកគណៈ ដោយខ្លួនឯងផង សម្តែងអំពីសេចក្តីមិនច្រឡូកច្រឡំដោយពួកគណៈដល់ភិក្ខុទាំងឡាយផង នេះជាឋានៈដែលគួរសរសើរថា ភិក្ខុជាអ្នកមិនច្រឡូកច្រឡំដោយពួកគណៈផង សម្តែងអំពីសេចក្តីមិនច្រឡូកច្រឡំដោយពួកគណៈដល់ភិក្ខុទាំងឡាយផង ១ ។ ភិក្ខុជាអ្នកមានព្យាយាមប្រារព្ធហើយ ដោយខ្លួនឯងផង សម្តែងអំពីសេចក្តីប្រារព្ធព្យាយាមដល់ភិក្ខុទាំងឡាយផង នេះជាឋានៈដល់គួរសរសើរថា ភិក្ខុជាអ្នកមានព្យាយាមប្រារព្ធហើយផង សម្តែងអំពី

សេចក្តីប្រារព្ធព្យាយាមដល់ភិក្ខុទាំងឡាយផង ១ ។ ភិក្ខុជាអ្នកបរិបូណ៌ដោយសីល ដោយខ្លួនឯងផង សម្តែងអំពីសេចក្តីបរិបូណ៌ដោយសីលដល់ភិក្ខុទាំងឡាយផង នេះជាឋានៈដែលគួរសរសើរថា ភិក្ខុជាអ្នកបរិបូណ៌ដោយសីលផង សម្តែងអំពីការបរិបូណ៌ដោយសីលដល់ភិក្ខុទាំងឡាយផង ១ ។ ភិក្ខុជាអ្នកបរិបូណ៌ដោយសមាធិដោយខ្លួនឯងផង សម្តែងអំពីការបរិបូណ៌ដោយសមាធិដល់ភិក្ខុទាំងឡាយផង នេះជាឋានៈដែលគួរសរសើរថាភិក្ខុជាអ្នកបរិបូណ៌ដោយសមាធិផង សម្តែងអំពីការបរិបូណ៌ដោយសមាធិដល់ភិក្ខុទាំងឡាយផង ១ ។ ភិក្ខុជាអ្នកបរិបូណ៌ដោយបញ្ញាដោយខ្លួនឯងផង សម្តែងអំពីការបរិបូណ៌ដោយបញ្ញាដល់ភិក្ខុទាំងឡាយផង នេះជាឋានៈដែលគួរសរសើរថា ភិក្ខុជាអ្នកបរិបូណ៌ដោយបញ្ញាផង សម្តែងអំពីការបរិបូណ៌ដោយបញ្ញាដល់ភិក្ខុទាំងឡាយផង ១ ។ ភិក្ខុជាអ្នកបរិបូណ៌ដោយវិមុត្តិដោយខ្លួនឯងផង សម្តែងអំពីការបរិបូណ៌ដោយវិមុត្តិដល់ភិក្ខុទាំងឡាយផង នេះជាឋានៈដែលគួរសរសើរថា ភិក្ខុជាអ្នកបរិបូណ៌ដោយវិមុត្តិផង សម្តែងអំពីការបរិបូណ៌ដោយវិមុត្តិដល់ភិក្ខុទាំងឡាយផង ១ ។ ភិក្ខុជាអ្នកបរិបូណ៌ដោយវិមុត្តិញាណទស្សនៈដោយខ្លួនឯងផង សម្តែងអំពីការបរិបូណ៌ដោយវិមុត្តិញាណទស្សនៈដល់ភិក្ខុទាំងឡាយផង នេះជាឋានៈដែលគួរសរសើរថា ភិក្ខុជាអ្នកបរិបូណ៌ដោយវិមុត្តិញាណទស្សនៈផង សម្តែងអំពីការបរិបូណ៌ដោយវិមុត្តិញាណទស្សនៈដល់ភិក្ខុទាំងឡាយផង ១ ។ ម្នាលភិក្ខុទាំងឡាយ ឋានៈដែលគួរ

សរសើរមាន ១០ យ៉ាងនេះឯង ។

យមកវគ្គទី ២ ចប់

### ឧទ្ទាននៃយមកវគ្គនោះ គឺ

និយាយអំពីអវិជ្ជា ១ តណ្ហា ១ ( ព្រះនិព្វាន ) ១ សេចក្តីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះតថាគត ១ សេចក្តីសុខពីរលើកពីព្រះដ៏មានព្រះភាគត្រាច់ទៅកាន់និគម ឈ្មោះនឡកបានៈពីរលើក និងវត្ថុកថាដទៃទៀតពីរលើក ។

# អដ្ឋកថា

## ទុតិយវត្ថុកថាសូត្រ

[ ៧០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយវត្ថុកថាសូត្រទី ១០ ដូចតទៅនេះ បទថា **ចាសំសានិ ឋានានិ** បានដល់ ហេតុដែលនាំសេចក្តីសរសើរមកឲ្យ ។ ពាក្យដ៏សេសក្នុងទីគ្រប់អន្លើ មានអត្ថងាយយល់ហើយ ។

**អដ្ឋកថា ទុតិយវត្ថុកថាសូត្រទី ១០ ចប់**

**យមកវគ្គទី ២ ចប់**

# សុត្តន្តបិដក

## អាកង្ខវគ្គទី ៣

## អាកង្ខសូត្រទី ១

[ ៧១ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះបាន ទទួលស្តាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះដ៏ មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរ បរិបូណ៌ដោយសីល បរិបូណ៌ដោយបាតិមោក្ខ ជាអ្នកសង្រួមក្នុងបាតិមោក្ខ-សំវរៈ បរិបូណ៌ដោយអាចារ និងគោចរ ជាអ្នកឃើញនូវភ័យក្នុងទោសមាន ប្រមាណតិច ជាអ្នកសមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលភិក្ខុ ទាំងឡាយ បើភិក្ខុគប្បីប្រាថ្នាថា អាត្មាអញគប្បីជាទីស្រឡាញ់ ជាទីគាប់ចិត្ត ជាទីគោរព ជាទីសរសើរនៃសព្រហ្មចារីបុគ្គលទាំងឡាយ ភិក្ខុនោះគួរជាអ្នក បំពេញក្នុងសីល ប្រកបរឿយៗ នូវការរម្ងាប់នូវចិត្តខាងក្នុង មានឈានមិន សាបសូន្យ ប្រកបដោយវិបស្សនាញាណ ជាអ្នកចម្រើននូវសុញ្ញាគារ ( ផ្ទះ ស្ងាត់ ) ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុគប្បីប្រាថ្នាថា អាត្មាអញគួរជាបុគ្គល បាននូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ភិក្ខុនោះ គួរជាអ្នកបំពេញក្នុងសីល ប្រកបរឿយៗនូវការរម្ងាប់នូវចិត្តខាងក្នុង មានឈាន

*មិនសាបសូន្យ ប្រកបដោយវិបស្សនាញាណ ជាអ្នកចម្រើននូវសុញ្ញាគារ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុគប្បីប្រាថ្នាថា អាត្មាអញប្រើប្រាស់ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារទាំងឡាយរបស់ទាយកណា ការឲ្យនូវបច្ច័យទាំងនោះ របស់ទាយកទាំងនោះ សូមឲ្យមានផលច្រើន មានអានិសង្សច្រើន ភិក្ខុនោះ គួរជាអ្នកបំពេញក្នុងសីល ... ជាអ្នកចម្រើននូវសុញ្ញាគារ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុគប្បីប្រាថ្នាថា ពួកប្រេតជាញាតិសាលោហិតណា ( របស់អាត្មាអញ ) ដែលធ្វើមរណកាលស្លាប់ទៅហើយ មានចិត្តជ្រះថ្លារឭករឿយៗ ការរឭកនោះរបស់ប្រេតទាំងនោះ សូមឲ្យមានផលច្រើន មានអានិសង្សច្រើន ភិក្ខុនោះ គួរជាអ្នកបំពេញក្នុងសីល ... ជាអ្នកចម្រើននូវសុញ្ញាគារ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុគប្បីប្រាថ្នាថា អាត្មាអញគប្បីជាអ្នកសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារតាមមាន តាមបាន ភិក្ខុនោះគួរជាអ្នកបំពេញក្នុងសីល ... ជាអ្នកចម្រើននូវសុញ្ញាគារ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុគប្បីប្រាថ្នាថា អាត្មាអញគប្បីជាអ្នកអត់ធន់នូវត្រជាក់ ក្តៅ ការឃ្លាន ការស្រេក សម្ផស្ស របោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូច ពស់ធំ ជាអ្នកអត់សង្កត់នូវគន្លងនៃពាក្យដែលគេនិយាយអាក្រក់ មកកាន់សោតទ្វារ ដែលញុំាងទុក្ខឲ្យកើតឡើង នាំឲ្យវេទនាប្រព្រឹត្តទៅក្នុងសរីរៈ ជាទុក្ខក្លាខ្លាំង ខ្លោចផ្សា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត ជាទីនាំទៅនូវជីវិត ភិក្ខុនោះជាអ្នកបំពេញក្នុងសីល ... ជាអ្នក*

ចម្រើនទូវសុញ្ញាគារ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុគប្បីប្រាថ្នាថា អាត្មាអញគប្បីអត់ធន់នូវសេចក្ដីអផ្សុក ( ក្នុងនេក្ខម្មៈ ) និងសេចក្ដីត្រេកអរក្នុងកាមគុណ ( ឯសេចក្ដីត្រេកអរ និងសេចក្ដីអផ្សុក ) ក្នុងនេក្ខម្មៈ និងសេចក្ដីត្រេកអរ ( ក្នុងកាមគុណ ) កុំគប្បីគ្របសង្កត់នូវអាត្មាអញឡើយ អាត្មាអញគប្បីគ្របសង្កត់នូវសេចក្ដីអផ្សុក ( ក្នុងនេក្ខម្មៈ ) និងសេចក្ដីត្រេកអរ ( ក្នុងកាមគុណ ) ដែលកើតឡើងហើយ ភិក្ខុនោះគួរជាអ្នកបំពេញក្នុងសីល ... ជាអ្នកចម្រើននូវសុញ្ញាគារ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុគប្បីប្រាថ្នាថា អាត្មាអញគប្បីជាអ្នកគ្របសង្កត់នូវអារម្មណ៍ដែលគួរខ្លាច ឯអារម្មណ៍ដែលគួរខ្លាច កុំគប្បីគ្របសង្កត់នូវអាត្មាអញឡើយ អាត្មាអញគប្បីគ្របសង្កត់នូវអារម្មណ៍ដែលគួរខ្លាចដែលកើតឡើងហើយ ភិក្ខុនោះគួរជាអ្នកបំពេញក្នុងសីល ... ជាអ្នកចម្រើននូវសុញ្ញាគារ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុគប្បីប្រាថ្នាថា អាត្មាអញគប្បីបានដោយមិនបាច់ប្រាថ្នា បានដោយងាយ បានដោយមិនលំបាកនូវចតុត្ថជ្ឈាន ទាំងកិរិយានៅជាសុខ ក្នុងបច្ចុប្បន្ន ដែលអាស្រ័យនូវចិត្ត ភិក្ខុនោះគួរជាអ្នកបំពេញក្នុងសីល ... ជាអ្នកចម្រើននូវសុញ្ញាគារ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុគប្បីប្រាថ្នាថា អាត្មាអញគប្បីធ្វើ

ឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន បានដល់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈហើយ សម្រេចសម្រាន្តនៅ ភិក្ខុនោះគួរជាអ្នកបំពេញក្នុងសីល ប្រកបនូវការរម្ងាប់នូវចិត្តខាងក្នុង មានឈានមិនសាបសូន្យ ប្រកបដោយវិបស្សនាញាណ ជាអ្នកចម្រើននូវសុញ្ញាគារ ។ ពាក្យណាដែលតថាគតពោលហើយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរបរិបូណ៌ដោយសីល ដោយបាតិមោក្ខ ចូរសង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារ និងគោចរ ឃើញភ័យក្នុងទោសមានប្រមាណតិច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។

# អដ្ឋកថា

# អាកង្ខវគ្គទី ៣

## អាកង្ខសូត្រ

[ ៧១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអាកង្ខសូត្រទី ១ នៃអាកង្ខវគ្គទី ៣ ដូចតទៅនេះ បទថា **សម្បន្នសីលា** បានដល់ ជាអ្នកមានសីលបរិបូណ៌ អធិប្បាយថា ជាអ្នកដល់ព្រមដោយសីល ។ ក្នុងពាក្យថា **សម្បន្នសីលា** នេះ ភាពជាអ្នកមានសីលបរិបូណ៌ រមែងមានដោយវត្ថុ ២ ប្រការ គឺដោយការឃើញទោសនៃសីលវិបត្តិ និងដោយការឃើញគុណនៃសីលសម្បត្តិ ហេតុទាំង ២ នោះ ក៏ពោលពិស្តារហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គ ។ ក្នុងបទទាំងនោះ បទថា **សម្បន្នសីលា** ព្រះសុមត្ថេរដែលនៅត្រង់ទីបវិហារ ពោលថា បានឮថា ព្រះមានព្រះភាគ ទ្រង់លើកចតុប្បារិសុទ្ធិសីលឡើង ទ្រង់សម្ដែងដល់សីល ដែលសំខាន់ឲ្យពិស្តារក្នុងទីនោះ ដោយបទថា **ចាតិមោក្ខសំវរ-សំវុតា** នេះ ។ ចំណែកព្រះចូឡនាគត្ថេរ ជាអ្នកទ្រទ្រង់ព្រះត្រៃបិដក ដែលអន្តេវាសិករបស់លោកពោលថា សូម្បីក្នុងបទទាំង ២ ព្រះមានព្រះភាគ ក៏ត្រាស់បាតិមោក្ខសំវរៈ ដ្បិតថា បាតិមោក្ខសំវរៈនោះឯង គឺសីល ចំណែក ៣ ទៀតក៏ជាសីល ហេតុនោះ ទើបពោលថា មិនឃើញ ដ្បិតថា ឈ្មោះថា ឋានៈដែលពោលហើយ មាន រូបពោលថា ត្រឹមតែរក្សាទ្វារ ៦ ប៉ុណ្ណោះ ក៏ឈ្មោះថា ឥន្ទ្រិយសំវរសីល ត្រឹមតែធ្វើបច្ច័យឲ្យកើតឡើងដោយធម៌ដោយ

ប្រពៃ ក៏ឈ្មោះថា អាជីវបារិសុទ្ធិសីល ។ ត្រឹមតែពិចារណាក្នុងបច្ច័យដែលបានហើយថា នេះមាន រូបបរិភោគ ក៏ឈ្មោះថា បច្ចយសន្និស្សិតសីលដោយត្រង់ បាតិមោក្ខសំវរៈប៉ុណ្ណោះ ឈ្មោះថា សីល បាតិមោក្ខសំវរៈរបស់ភិក្ខុណាដាច់ហើយ ភិក្ខុនេះមិនគប្បីពោលថា នឹងរក្សាសីលដ៏សេសបាន ដូចបុរសមានក្បាលដាច់ហើយ នឹងរក្សាដៃ-ជើងមិនបាន ចំណែកបាតិមោក្ខ-សំវរៈរបស់ភិក្ខុណាមិនខូច ភិក្ខុនេះ ក៏អាចធ្វើសីលដ៏សេសឲ្យជាប្រក្រតីបាន ដូចបុរសមានក្បាលមិនដាច់ ក៏រក្សាជីវិតបាន ព្រោះដូច្នោះ ព្រះមានព្រះភាគទ្រង់លើកបាតិមោក្ខសំវរៈ ដោយបទថា **សម្បន្នសីលា** នេះហើយ ត្រាស់ជាពាក្យជាវេវចនៈនៃបទថា **សម្បន្នសីលា** នោះឯងថា **សម្បន្នបាតិមោក្ខា** កាលទ្រង់សម្តែងបទថា **សម្បន្នបាតិមោក្ខា** នោះឲ្យពិស្តារ ទើបត្រាស់ថា **បាតិមោក្ខសំវរសំវុតា** ជាដើម ។ ពាក្យថា **បាតិមោក្ខសំវរសំវុតា** ជាដើម ក្នុងពាក្យនោះ មានអត្ថបានដូចពោលហើយនោះឯង ។

សួរថា ហេតុអ្វី ទើបព្រះមានព្រះភាគទ្រង់ផ្តើមថា បើភិក្ខុប្រាថ្នា ដូច្នេះ ។ ឆ្លើយថា ដើម្បីទ្រង់សម្តែងអានិសង្សនៃសីល ។ ពិតហើយ បើភិក្ខុអ្នកបួសថ្មី ឬអ្នកមានបញ្ញាថោកថយ គប្បីគិតយ៉ាងនេះថា ព្រះមានព្រះភាគ ទ្រង់ប្រៀនប្រដៅថា ពួកអ្នកចូរបំពេញសីល ចូរបំពេញសីល អ្វីហ្ន៎ ជាអានិសង្សអ្វីជាគុណវិសេស អ្វីជាសេចក្តីចម្រើន ក្នុងការបំពេញសីល ។ ត្រាស់យ៉ាងនេះ ក៏ដើម្បីទ្រង់សម្តែងអានិសង្ស ១០ ប្រការដល់ភិក្ខុនោះថា បើដូច្នោះ

ភិក្ខុទាំងនោះ សូម្បីស្តាប់អានិសង្ស ដែលមានភាពជាទីស្រឡាញ់ ជាទីពេញចិត្តរបស់សព្រហ្មចារីជាខាងដើម មានការអស់អាសវៈជាខាងចុងហើយ គប្បីធ្វើសីលឲ្យបរិបូណ៌ ។ បណ្តាបទទាំងនោះ បទថា **អាកង្ខេយ្យ ចេ** បានដល់ ឧបមាថា គប្បីប្រាថ្នា ។ បទថា **បិយោ ចស្សំ** បានដល់ គប្បីជាបុគ្គលដែលសព្រហ្មចារីសម្លឹងមើល ដោយក្រសែភ្នែកជាទីស្រឡាញ់ គប្បីមានការទំនុកបម្រុងឲ្យកើតសេចក្តីស្រឡាញ់ ។ បទថា **មនាបោ** បានដល់ជាទីត្រេកអរនៃសព្រហ្មចារីទាំងនោះ ឬជាទីត្រេកអររបស់សព្រហ្មចារីទាំងនោះ ដោយរឭកដល់ អធិប្បាយថា ដែលសព្រហ្មចារីផ្សាយដល់ដោយមេត្តាចិត្ត ។ បទថា **គរុ** បានដល់ ជាទីតាំងនៃភាពធ្ងន់ គឺជាទីគោរពនៃសព្រហ្មចារី ដូចឆត្រថ្ម ។ បទថា **ភាវនីយោ** បានដល់ ដែលសព្រហ្មចារីសរសើរយ៉ាងនេះថា អ្នករមែងដឹងប្រការដែលគួរដឹង ឃើញប្រការដែលគួរឃើញមកអស់កាលដ៏យូរ ។ បទថា **សីលេស្វេវស្ស បរិបូរិការី** បានដល់ គប្បីជាបុគ្គលធ្វើឲ្យបរិបូណ៌ក្នុងចតុប្បារិសុទ្ធិសីល លោកអធិប្បាយថា គប្បីជាបុគ្គលប្រកបដោយការធ្វើដែលមិនខ្វះខាត គឺបរិបូណ៌ ។

បទថា **អជ្ឈត្តំ ចេតោសមថមនុយុត្តោ** បានដល់ ប្រកបក្នុងការស្ងប់ចិត្តរបស់ខ្លួន ។ បទថា **អនិរាកតជ្ឈានោ** បានដល់ មានឈានដែលមិនត្រូវនាំចេញខាងក្រៅ ឬមានឈានដែលមិនវិនាសហើយ ។ បទថា **វិបស្សនាយ** បានដល់ អនុបស្សនា ៧ យ៉ាង ។ បទថា **ព្រូហេតា សុញ្ញា-**

**គារាធំ** បានដល់ ចម្រើនសុញ្ញាគារ ។ ក្នុងពាក្យថា **ព្រហោតា សុញ្ញាគារាធំ** នេះ ភិក្ខុទទួលកម្មដ្ឋាន ជាសមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន ចូលទៅកាន់សុញ្ញាគារ អន្ទយអស់ថ្ងៃ និងយប់ គប្បីជ្រាបថា ជាអ្នកចម្រើនសុញ្ញាគារ ។ នេះជាសេចក្តីសង្ខេបក្នុងរឿងនេះ ។ ចំណែកសេចក្តីពិស្តារ បុគ្គលបំណង គប្បីមើលបានក្នុងវណ្ណនាអាកង្ខេយ្យសូត្រ អដ្ឋកថា មជ្ឈិមនិកាយ ។

ក្នុងបទថា **លាភី** គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា ព្រះមានព្រះភាគ មិនបានត្រាស់ការបរិបូណ៌ក្នុងគុណ មានសីលជាដើម ជានិមិត្តនៃលាភ ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់រមែងទូន្មានសាវកទាំងឡាយយ៉ាងនេះថា មុនីហាក់បីដូចកាត់នូវពាក្យដែលស្វែងរកអាហារចេញ ហើយមិនគប្បីពោលបយុត្តវាចាស្វែងរកអាហារ ។ ភិក្ខុនោះ នឹងពោលរឿងភាពបរិបូណ៌ក្នុងគុណមានសីលជាដើម ជានិមិត្តនៃលាភ បានដូចម្តេច ។ ពាក្យនេះ ព្រះមានព្រះភាគត្រាស់ដោយអំណាចអជ្ឈាស្រ័យនៃបុគ្គល ។ ពិតហើយ ភិក្ខុពួកណាគប្បីមានអជ្ឈាស្រ័យយ៉ាងនេះ ទើបព្រះមានព្រះភាគត្រាស់ដោយអំណាចអជ្ឈាស្រ័យប៉ុណ្ណោះរបស់ភិក្ខុទាំងនោះថា បើអាត្មាអញមិនលំបាកដោយបច្ច័យ ៤ សោត អញក៏គប្បីនាំសីលទាំងឡាយឲ្យបរិបូណ៌បាន ។ម្យ៉ាងទៀត ឈ្មោះថា បច្ច័យ ៤ ជាអានិសង្ស ព្រមទាំងកិច្ចរបស់សីល ពិតហើយ បុគ្គលជាបណ្ឌិត នាំទ្រព្យដែលរក្សាទុកក្នុងឃ្លាំងជាដើមចេញមក មិនមែនបរិភោគដោយខ្លួនឯង រមែងឲ្យដល់អ្នកមានសីល ព្រះមានព្រះភាគ ត្រាស់

ពាក្យនេះ ក៏ដើម្បីសម្តែងអានិសង្ស ព្រមទាំងកិច្ចរបស់សីល ។ ក្នុងវារៈទី ៣ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ពាក្យថា **យេសាហំ** កាត់បទជា **យេសំ អហំ** ។ បទថា **តេសន្តេ ការា** សេចក្តីថា សូមសក្ការៈ គឺបច្ច័យទានដែលពួកទេវតា ឬមនុស្សធ្វើក្នុងយើងទាំងនោះ ចូរមានផលច្រើន មានអានិសង្សច្រើន ហេតុនោះ ទើបសក្ការៈទាំងនោះ ឈ្មោះថា មានផលច្រើន ដោយផលជាលោកិយសុខ ឈ្មោះថា មានអានិសង្សច្រើន ដោយផលដែលជាលោកុត្តរ-សុខ ។ម្យ៉ាងទៀត ពាក្យទាំង ២ នេះ ក៏មានអត្ថតែមួយដូចគ្នានោះឯង ។ បាយមួយវែកក្តី បណ្ណសាលាដែលគេសាងលើទីប្រមាណ ៥ ហត្ថក្តី ដែលគេប្រគេនដល់ភិក្ខុប្រកបដោយគុណ មានសីលជាដើម រមែងការពារអំពីទុគ្គតិ វិនិបាត បានច្រើនពាន់កប្ប គង់ជាបច្ច័យដល់អមតធាតុ គឺព្រះនិព្វានក្នុងទីបំផុតផងដែរ ។ ក្នុងរឿងឲ្យនូវបាយលាយ ដោយទឹកដោះស្រស់[១] ជាដើម ជាឧទាហរណ៍ក្នុងពាក្យនេះ ។ បេតវត្ថុ និងវិមានវត្ថុ ជាគ្រឿងសាធកបានទាំងអស់ ។

ក្នុងវារៈទី ៤ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា បទថា **បេតា** បានដល់ អ្នកទៅកាន់កពមច្ចុរាជ ។ បទថា **ញាតិ** បានដល់ ចំណែកខាងឪពុកម្តាយ ។ បទថា **សាលោហិតា** បានដល់ ទាក់ទងដោយខ្សែស្រឡាយជាមួយគ្នា មានជីតាជាដើម ។ បទថា **កាលកតា** បានដល់ ស្លាប់ ។ បទថា **តេសន្តំ** បានដល់ ចិត្តដែលជ្រះថ្លាក្នុងអាត្មាអញនោះ ឬការរឭកដល់ដោយចិត្តដែល

១- បិ. ៥៥ ទំ. ៦៨

*ជ្រះថ្លានោះរបស់ញាតិសាលោហិតនោះ ។ ពិតហើយ បិតា ឬមាតារបស់ភិក្ខុណា ធ្វើកាលកិរិយា មានចិត្តជ្រះថ្លាថា ញាតិរបស់អញដែលមានសីល មានកល្យាណធម៌ រឭកដល់ភិក្ខុនោះ ការជ្រះថ្លានៃចិត្តនោះក្តី ត្រឹមតែការរឭកដល់នោះក្តីរបស់បុគ្គលនោះ រមែងមានផលច្រើន មានអានិសង្សច្រើនទាំងអស់ ។*

*បទថា* **អរតិរតិសហោ** *បានដល់ ជាបុគ្គលអត់ធន់ គ្របសង្កត់ ជោជន់ការមិនត្រេកអរក្នុងនេក្ខម្មបដិបត្តិ និងការត្រេកអរក្នុងកាមគុណទាំងឡាយ ។ បទថា* **ភយភេរវសហោ** *នេះ ការតក់ស្លុតក្តី អារម្មណ៍ក្តី ឈ្មោះថា* **ភយ** *អារម្មណ៍តែម្យ៉ាង ឈ្មោះថា* **ភេរវ** *។ល។*

## អដ្ឋកថាអាកង្ខសូត្រទី ១ ចប់

# សុត្តន្តបិដក

## កណ្ដកសូត្រទី ២

[ ៧២ ] *សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងកូដាគារសាលា នាមហាវ័ន ជិតក្រុងវេសាលី ជាមួយនឹងសាវ័កជាថេរៈច្រើនរូប ដែលមានឈ្មោះល្បីល្បាញ គឺព្រះបាលៈដ៏មានអាយុ ១ ព្រះឧបបាលៈដ៏មានអាយុ ១ ព្រះកក្កដៈដ៏មានអាយុ ១ ព្រះកឡិម្ភៈដ៏មានអាយុ ១ ព្រះនិកដៈ ដ៏មានអាយុ ១ ព្រះកដិស្សហៈដ៏មានអាយុ ១ ព្រមទាំងសាវ័កជាថេរៈ ដែលមានឈ្មោះល្បីល្បាញឯទៀតផង ។ សម័យនោះឯង ពួកស្ដេចលិច្ឆវីច្រើនអង្គ ដែលមានឈ្មោះល្បីល្បាញ ត្រាច់ទៅដោយយានដ៏ប្រសើរក្រៃលែងតៗ គ្នា មានសំឡេងអឺងកងរំពង បរទៅកាន់ព្រៃមហាវ័ន ដើម្បីជួបព្រះដ៏មានព្រះភាគ ។ គ្រានោះឯង ព្រះថេរៈដ៏មានអាយុទាំងនោះ មានសេចក្ដីត្រិះរិះដូច្នេះថា ពួកស្ដេចលិច្ឆវីមានប្រមាណច្រើនទាំងនេះ ដែលមានឈ្មោះល្បីល្បាញ ត្រាច់ទៅដោយយានដ៏ប្រសើរក្រៃលែងតៗ គ្នា មានសំឡេងអឺងកងរំពង ចូលទៅកាន់ព្រៃមហាវ័ន ដើម្បីជួបព្រះដ៏មានព្រះភាគ ឯព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ឈានមានសំឡេងជាបន្លា បើដូច្នោះ គួរតែយើងទាំងឡាយ ចូលទៅរកព្រៃគោសិង្គសាលវ័ន ហើយយើងទាំងឡាយ គប្បីមានសំឡេងតិច មានការនៅប្រឡូកប្រឡំគ្នាតិច ទើបនៅជាសុខក្នុងទីនោះ បានជាព្រះថេរៈដ៏មានអាយុទាំងនោះ ក៏ចូលទៅឯព្រៃគោសិង្គសាលវ័ន ព្រះថេរៈដ៏មានអាយុទាំងនោះ មានសំឡេងតិច មានការប្រឡូកប្រឡំគ្នាតិច ហើយនៅជាសុខក្នុង*

ទីនោះ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាលៈ នៅក្នុងទីណា ភិក្ខុឧបបាលៈ នៅក្នុងទីណា ភិក្ខុកក្កដៈ នៅក្នុងទីណា ភិក្ខុកឡិម្ភៈ នៅក្នុងទីណា ភិក្ខុនិកដៈ នៅក្នុងទីណា ភិក្ខុកដិស្សហៈ នៅក្នុងទីណា ម្នាលភិក្ខុទាំងឡាយ ឯសាវកជាថេរៈទាំងនោះ នៅចំទីណាដែរ ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីនេះព្រះថេរៈដ៏មានអាយុទាំងនោះ មានសេចក្តីត្រិះរិះដូច្នេះថា ពួកស្តេចលិច្ឆវីមានប្រមាណច្រើននេះ ដែលមានឈ្មោះល្បីល្បាញ ត្រាច់ទៅដោយយានដ៏ប្រសើរក្រៃលែងៗ គ្នា មានសំឡេងអឺងកងរំពង ចូលទៅកាន់ព្រៃមហាវ័ន ដើម្បីជួបព្រះដ៏មានព្រះភាគ ព្រះអង្គក៏ទ្រង់សម្តែងថា ឈានមានសំឡេងជាបន្លា បើដូច្នោះ គួរតែយើងទាំងឡាយ ចូលទៅឯព្រៃគោសិង្គ-សាលវ័ន យើងទាំងឡាយគប្បីមានសំឡេងតិច មានការនៅប្រឡូកប្រឡំគ្នាតិច ទើបនៅជាសុខក្នុងទីនោះ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនោះ លោកដ៏មានអាយុទាំងនោះ ចូលទៅឯព្រៃគោសិង្គសាលវ័ន លោកដ៏មានអាយុទាំងនោះ ក៏មានសំឡេងតិច មានការនៅប្រឡូកប្រឡំគ្នាតិច ហើយនៅជាសុខក្នុងទីនោះ ។ ម្នាលភិក្ខុទាំងឡាយ ប្រពៃហើយ ប្រពៃហើយ កាលមហាសាវកទាំងនោះ ព្យាករដោយប្រពៃ គប្បីព្យាករតាមពិត ម្នាលភិក្ខុទាំងឡាយ ព្រោះតថាគតពោលហើយថា ឈានមានសំឡេងជាបន្លា ។ ម្នាលភិក្ខុទាំង-ឡាយ បន្លាទាំងឡាយនេះមាន ១០ យ៉ាង ។ បន្លាទាំង ១០ យ៉ាង តើដូចម្តេច

ខ្វះ ។ គឺសភាពជាអ្នកត្រេកអរក្នុងពួកគណៈ ជាបន្ទារបស់បុគ្គលដែលមានសេចក្ដីស្ងប់ស្ងាត់ ជាទីត្រេកអរ ១ ការប្រកបរឿយៗ នូវសុភនិមិត្ត ជាបន្ទារបស់បុគ្គលដែលប្រកបរឿយៗ នូវអសុភនិមិត្ត ១ ការឃើញនូវសត្រូវ គឺល្បែងផ្សេងៗ ជាបន្ទារបស់បុគ្គលមានទ្វារគ្រប់គ្រងហើយ ក្នុងឥន្ទ្រិយទាំង-ឡាយ ១ ការត្រាច់ទៅជិតមាតុគ្រាម ជាបន្ទារបស់ព្រហ្មចរិយៈ ១ សំឡេងជាបន្ទារបស់បឋមជ្ឈាន ១ វិតក្ក និងវិចារៈ ជាបន្ទារបស់ទុតិយជ្ឈាន ១ បីតិជាបន្ទារបស់តតិយជ្ឈាន ១ អស្សាសបស្សាសៈ ជាបន្ទារបស់ចតុត្ថជ្ឈាន ១ សញ្ញា និងវេទនា ជាបន្ទារបស់សញ្ញាវេទយិតនិរោធសមាបត្តិ ១ រាគៈ ជាបន្ទា ទោសៈ ជាបន្ទា មោហៈ ជាបន្ទា ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយ ចូរកុំមានធម៌ជាបន្ទាឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរកុំមានធម៌ជាបន្ទាឡើយ ចូរនាំធម៌ជាបន្ទាចេញ ម្នាលភិក្ខុទាំងឡាយ ព្រះអរហន្តទាំងឡាយ មិនមានធម៌ជាបន្ទាទេ ម្នាលភិក្ខុទាំងឡាយ ព្រះអរហន្តទាំងឡាយ មិនមានធម៌ជាបន្ទាទេ បាននាំធម៌ជាបន្ទាចេញហើយ ។

# អដ្ឋកថា

## កណ្ដកសូត្រ

[ ៧២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកណ្ដកសូត្រទី ២ ដូចតទៅនេះ បទថា **អភិញ្ញាតេហិ អភិញ្ញាតេហិ** បានដល់ ដែលបុគ្គលណាម្នាក់ក៏ស្គាល់ គឺប្រាកដហើយ ដូចព្រះចន្ទពេញវង់ ដូចព្រះអាទិត្យកណ្ដាលលម្អ ។ ក្នុងពាក្យថា **បរម្បរាយ** នេះ ចំណែកខាងក្រោយ ហៅថា **បរ** ចំណែកខាងមុខ ហៅថា **បុរា** ។ អធិប្បាយថា បរិវារចំនួនច្រើនដែលស្ទុះទៅខាងមុខ និងដែលជាប់ទៅតាមខាងក្រោយ ។ បទថា **កណ្ដកា** បានដល់ ឈ្មោះថា បន្លា ព្រោះអត្ថថា ជង់ មុត ។ បទថា **វិសូកទស្សនំ** បានដល់ មើលការលេងដែលជាបដិលោម ដែលជាសត្រូវ ។ បទថា **មាតុគ្គាមូបចារោ** បានដល់ ជាអ្នកត្រាច់ទៅជិតមាតុគ្រាម ។l៚

**អដ្ឋកថា កណ្ដកសូត្រទី ២ ចប់**

# សុត្តន្តបិដក

## ឥដ្ឋសូត្រទី ៣

[ ៧៣ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាងនេះ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ដែលបុគ្គលបានដោយកម្រក្នុងលោក ។ ធម៌ទាំង ១០ យ៉ាងតើដូចម្តេច ។ គឺភោគៈជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ដែលបុគ្គលបានដោយកម្រក្នុងលោក ១ ពណ៌សម្បុរជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត បុគ្គលបានដោយកម្រក្នុងលោក ១ សភាពមិនមានរោគ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត បុគ្គលបានដោយកម្រក្នុងលោក ១ សីលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត បុគ្គលបានដោយកម្រក្នុងលោក ១ ព្រហ្មចរិយៈជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត បុគ្គលបានដោយកម្រក្នុងលោក ១ មិត្តជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត បុគ្គលបានដោយកម្រក្នុងលោក ១ សភាពជាអ្នកចេះដឹងច្រើន ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត បុគ្គលបានដោយកម្រក្នុងលោក ១ បញ្ញាជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត បុគ្គលបានដោយកម្រក្នុងលោក ១ ធម៌ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត បុគ្គលបានដោយកម្រក្នុងលោក ១ ឋានសួគ៌ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត បុគ្គលបានដោយកម្រក្នុងលោក ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាងនេះឯង ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត បុគ្គលបានដោយកម្រក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាង នាំឲ្យអន្តរាយដល់ធម៌ ១០ យ៉ាងនេះ ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត បុគ្គលបានដោយកម្រក្នុង

លោក ។ គឺការខ្ជិល និងការមិនប្រឹងប្រែង នាំឲ្យអន្តរាយដល់ភោគៈ ១ ការមិនប្រដាប់ មិនតាក់តែង នាំឲ្យអន្តរាយដល់ពណ៌សម្បុរ ១ ការធ្វើនូវសេចក្តីមិនសប្បាយ នាំឲ្យអន្តរាយដល់ភាពមិនមានរោគ ១ មិត្តលាមក នាំឲ្យអន្តរាយដល់សីល ១ ការមិនសង្រួមនូវឥន្ទ្រិយ នាំឲ្យអន្តរាយដល់ព្រហ្មចរិយៈ ១ ការពោលពាក្យខុស នាំឲ្យអន្តរាយដល់ពួកមិត្ត ១ ការធ្វើនូវសេចក្តីមិនស្វាធ្យាយ នាំឲ្យអន្តរាយដល់ភាពចេះដឹងច្រើន ១ ការមិនប្រុងស្តាប់ មិនសាកសួរ នាំឲ្យអន្តរាយដល់បញ្ញា ១ ការមិនប្រកបរឿយៗ ការមិនពិចារណា នាំឲ្យអន្តរាយដល់ធម៌ទាំងឡាយ ១ សេចក្តីប្រតិបត្តិខុស នាំឲ្យអន្តរាយដល់ឋានសួគ៌ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ១០ នេះ នាំឲ្យអន្តរាយដល់ធម៌ ១០ យ៉ាងនេះ ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ដែលបុគ្គលបានដោយកម្រក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ១០ យ៉ាង ជាអាហារនៃធម៌ទាំង ១០ នេះ ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត បុគ្គលបានដោយកម្រក្នុងលោក ។ គឺសេចក្តីមិនខ្ជិល សេចក្តីព្យាយាម ជាអាហាររបស់ភោគៈ ១ ការប្រដាប់ ការតាក់តែង ជាអាហាររបស់ពណ៌សម្បុរ ១ ការធ្វើនូវសេចក្តីសប្បាយ ជាអាហាររបស់ភាពមិនមានរោគ ១ សភាពមិត្តល្អ ជាអាហាររបស់សីល ១ ការសង្រួមឥន្ទ្រិយ ជាអាហាររបស់ព្រហ្មចរិយៈ ១ ការមិនពោលពាក្យខុស ជាអាហាររបស់មិត្តទាំងឡាយ ១ ការធ្វើនូវកិរិយាស្វាធ្យាយ ជាអាហាររបស់ភាពអ្នកចេះដឹង

ច្រើន ១ ការស្តាប់ ការសាកសួរ ជាអាហាររបស់បញ្ញា ១ ការប្រកប រឿយៗ ការពិចារណា ជាអាហាររបស់ធម៌ទាំងឡាយ ១ សេចក្តីប្រតិបត្តិល្អ ជាអាហាររបស់ឋានសួគ៌ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ១០ នេះឯង ជា អាហារនៃធម៌ ១០ យ៉ាងនេះ ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត បុគ្គល បានដោយកម្រក្នុងលោក ។

# អដ្ឋកថា

## ឥដ្ឋសូត្រ

[ ៧៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឥដ្ឋសូត្រទី ៣ ដូចតទៅនេះ បទថា **វណ្ណោ** បានដល់ ពណ៌នៃសរីរៈ ។ បទថា **ធម្មា** បានដល់ លោកុត្តរធម៌ ៩ ។

**អដ្ឋកថា ឥដ្ឋសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## វឌ្ឍិសូត្រទី ៤

[ ៧៤ ] ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក កាលចម្រើនដោយសេចក្តី ១០ យ៉ាង រមែងចម្រើនដោយសេចក្តីចម្រើនដ៏ប្រសើរ ឈ្មោះថា អ្នកកាន់យកនូវខ្លឹមរបស់កាយផង ជាអ្នកកាន់យកនូវវត្ថុដ៏ប្រសើររបស់កាយផង ។ ការចម្រើនដោយសេចក្តីទាំង ១០ យ៉ាង តើដូចម្តេច ។ គឺចម្រើនដោយស្រែចម្ការ ១ ចម្រើនដោយទ្រព្យ និងស្រូវ ១ ចម្រើនដោយកូន និងប្រពន្ធ ១ ចម្រើនដោយបុរសជាទាសៈ និងកម្មករ ១ ចម្រើនដោយសត្វមានជើង ៤ ទាំងឡាយ ១ ចម្រើនដោយសទ្ធា ១ ចម្រើនដោយសីល ១ ចម្រើនដោយសុតៈ ១ ចម្រើនដោយចាគៈ ១ ចម្រើនដោយបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កកាលចម្រើនដោយសេចក្តីចម្រើន ១០ យ៉ាងនេះឯង រមែងចម្រើន ដោយសេចក្តីចម្រើនដ៏ប្រសើរ ឈ្មោះថា អ្នកកាន់យកនូវខ្លឹមរបស់កាយផង ជាអ្នកកាន់យកនូវវត្ថុដ៏ប្រសើររបស់កាយផង ។

បុគ្គលណាក្នុងលោកនេះ ចម្រើនដោយទ្រព្យផង ដោយស្រូវ
ផង ដោយកូនផង ដោយប្រពន្ធផង ដោយសត្វជើង ៤ ផង
បុគ្គលនោះឈ្មោះថា មានភោគៈ មានយស ដែលពួកញាតិ
និងមិត្ត ព្រមទាំងស្តេចបូជាហើយ ។ បុគ្គលណាក្នុងលោកនេះ
ចម្រើនដោយសទ្ធាផង ដោយសីលផង ដោយបញ្ញាផង ដោយ
ចាគៈផង ដោយសុតៈទាំងពីរផង បុគ្គលបែបនោះ ហៅថា

សប្បុរស ជាអ្នកពិចារណាឃើញច្បាស់ រមែងចម្រើនដោយ
ហេតុទាំងពីរ ក្នុងបច្ចុប្បន្ននេះឯង ។

# អដ្ឋកថា

## វឌ្ឍិសូត្រ

[ ៧៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវឌ្ឍិសូត្រទី ៤ ដូចតទៅនេះ បទថា **អរិយាយ** បានដល់ មិនមែនរបស់បុថុជ្ជន ។ ពាក្យនេះ ត្រាស់ក៏ព្រោះលាយឡំដោយធម៌ទាំងឡាយ មានសីលជាដើម ។ បទថា **សារាទាយី ច ហោតិ វរាទាយី** សេចក្ដីថា រមែងជាបុគ្គលទាញបាននូវសារៈ និងចំណែកប្រសើរ ។ អធិប្បាយថា រមែងប្រកាន់នូវសារៈរបស់កាយ និងចំណែកប្រសើររបស់កាយនោះ ៕

**អដ្ឋកថា វឌ្ឍិសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## មិគសាលាសូត្រទី ៥

[ ៧៥ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះអានន្ទដ៏មានអាយុ ស្លៀកស្បង់ ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅឯលំនៅនៃមិគសាលាឧបាសិកា លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈ ដែលគេក្រាលទុក ។ លំដាប់នោះ មិគសាលាឧបាសិកា ចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះអានន្ទដ៏មានអាយុ ហើយអង្គុយក្នុងទីសមគួរ ។ លុះមិគសាលាឧបាសិកា អង្គុយក្នុងទីសមគួរហើយ ក៏បានទូលសួរព្រះអានន្ទដ៏មានអាយុថា បពិត្រព្រះអានន្ទដ៏ចម្រើន ធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយនេះ តើគប្បីយល់ដូចម្តេច ព្រោះដូចជាបុគ្គលពីរពួក គឺព្រហ្មចារីបុគ្គល ១ អព្រហ្មចារីបុគ្គល ១ សឹងមានគតិស្មើៗ គ្នា ក្នុងបរលោក ។ បពិត្រលោកម្ចាស់ដ៏ចម្រើន បិតារបស់ខ្ញុំឈ្មោះបុរាណៈ ជាព្រហ្មចារី ជាអ្នកប្រព្រឹត្តឆ្ងាយ វៀរចាកមេថុនជាធម៌របស់អ្នកស្រុក លុះគាត់ធ្វើមរណកាលទៅ ព្រះដ៏មានព្រះភាគ ទ្រង់ព្យាករថាជាសកទាគាមិសត្វ បានទៅកើតក្នុងពពួកទេវតា ក្នុងជាន់តុសិត ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ឥសិទត្ត ជាទីស្រឡាញ់របស់បិតានៃខ្ញុំ មិនមែនជាព្រហ្មចារី នៅត្រេកអរដោយប្រពន្ធរបស់ខ្លួន លុះធ្វើមរណកាលទៅ ព្រះដ៏មានព្រះភាគ ទ្រង់ព្យាករថាជាសកទាគាមិសត្វ បានទៅកើតក្នុងពពួកទេវតា

ជាន់តុសិតដែរ ។ បពិត្រព្រះអានន្ទដ៏ចម្រើន ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយនេះ តើគប្បីយល់ដូចម្តេច ព្រោះដូចជាបុគ្គលពីរពួក គឺព្រហ្មចារីបុគ្គល ១ អព្រហ្មចារីបុគ្គល ១ សឹងមានគតិស្មើៗ គ្នា ក្នុងបរលោក ។ ម្នាលនាង ដំណើរនេះ ព្រះមានព្រះភាគ ទ្រង់ព្យាករហើយយ៉ាងនេះឯង ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ ទទួលចង្ហាន់បិណ្ឌបាតក្នុងលំនៅនៃមិគ-សាលាឧបាសិការួចហើយ ក៏ក្រោកចាកអាសនៈ ចៀសចេញទៅ ។ ក៏កាលដែលព្រះអានន្ទដ៏មានអាយុ ត្រឡប់អំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្តហើយ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីនេះ ខ្ញុំព្រះអង្គស្លៀកស្បង់ ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅឯលំនៅនៃមិគសាលាឧបាសិកា លុះចូលទៅដល់ហើយ អង្គុយលើអាសនៈដែលគេក្រាលទុក ។ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ មិគសាលាឧបាសិកា ចូលទៅរកខ្ញុំព្រះអង្គ លុះចូលទៅដល់ហើយ ថ្វាយបង្គំខ្ញុំព្រះអង្គ ហើយអង្គុយក្នុងទីសមគួរ ។ បពិត្រព្រះអង្គដ៏ចម្រើន លុះមិគសាលាឧបាសិកា អង្គុយក្នុងទីសមគួរហើយ បាននិយាយនឹងខ្ញុំព្រះអង្គថា បពិត្រព្រះអានន្ទដ៏ចម្រើន ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់ព្យាករហើយនេះ តើគប្បីយល់ដូចម្តេច ព្រោះដូចជាបុគ្គលពីរពួក គឺព្រហ្មចារីបុគ្គល

១ អព្រហ្មចារីបុគ្គល ១ សឹងមានគតិស្មើៗ គ្នាក្នុងបរលោក ។ បពិត្រលោកម្ចាស់ដ៏ចម្រើន បិតាខ្ញុំឈ្មោះបុរាណៈ ជាព្រហ្មចារី ជាអ្នកប្រព្រឹត្តឆ្ងាយ វៀរចាកមេថុន ជាធម៌របស់អ្នកស្រុក លុះគាត់ធ្វើមរណកាលទៅ ព្រះដ៏មានព្រះភាគ ទ្រង់ព្យាករថា ជាសកទាគាមិសត្វ បានទៅកើតក្នុងពួកទេវតាជាន់តុសិត ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ឥសិទត្ត ជាទីស្រឡាញ់នៃបិតារបស់ខ្ញុំ មិនមែនជាព្រហ្មចារី នៅត្រេកអរដោយប្រពន្ធរបស់ខ្លួន លុះគាត់ធ្វើមរណ-កាលទៅ ព្រះដ៏មានព្រះភាគ ទ្រង់ព្យាករថា ជាសកទាគាមិសត្វ បានទៅកើតក្នុងពពួកទេវតាជាន់តុសិតដែរ ។ បពិត្រព្រះអានន្ទដ៏ចម្រើន ធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយនេះ តើគប្បីយល់ដូចម្តេច ព្រោះដូចជាបុគ្គលពីរពួក គឺព្រហ្មចារីបុគ្គល ១ អព្រហ្មចារីបុគ្គល ១ សឹងមានគតិស្មើៗគ្នាក្នុងបរលោក ។ បពិត្រព្រះអង្គដ៏ចម្រើន កាលមិគសាលាឧបាសិកា និយាយយ៉ាងនេះរួចហើយ ខ្ញុំព្រះអង្គក៏បាននិយាយនឹងមិគសាលាឧបាសិកាដូច្នេះថា ម្នាលនាង ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ព្យាករយ៉ាងហ្នឹងឯង ។ ម្នាលអានន្ទ មិគសាលាឧបាសិកា ជាអ្វី ជាស្ត្រីពាល មិនឈ្លាសវៃ ជាស្ត្រីងងឹតមានបញ្ញាងងឹត មួយទៀត បុរសបុគ្គលណា ( មានវិស័យមិនទើសទាល់ ) ក្នុងបរោបរិយញ្ញាណ ( បញ្ញាជាគ្រឿងដឹងនូវឥន្ទ្រិយក្លា និងទន់របស់បុគ្គលដទៃ ) ។ ម្នាលអានន្ទ បុគ្គល ១០ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គលទាំង ១០ ពួក តើដូចម្តេច ។ ម្នាលអានន្ទ បុគ្គលខ្លះ ក្នុងលោកនេះ

ជាអ្នកទ្រុស្តសីល ទាំងមិនដឹងច្បាស់តាមពិត នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិនោះ ដែលជាហេតុនាំឲ្យភាពទ្រុស្តសីលនោះ រលត់ទៅ ដោយមិនមានសេសសល់ បុគ្គលនោះ មិនបានធ្វើដោយការស្តាប់ផង មិនបានធ្វើដោយការៈចេះដឹងច្រើនផង មិនបានចាក់ធ្លុះដោយទិដ្ឋិផង មិនបាននូវវិមុត្តិ ដែលប្រព្រឹត្តទៅតាមកាលផង លុះបុគ្គលនោះបែកធ្លាយរាងកាយស្លាប់ទៅ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ មិនប្រព្រឹត្តទៅ ដើម្បីគុណវិសេសទេ ជាបុគ្គលប្រព្រឹត្ត ដើម្បីសេចក្តីសាបសូន្យតែម្យ៉ាង មិនប្រព្រឹត្តទៅដើម្បីគុណវិសេសឡើយ ។ ម្នាលអានន្ទ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកទ្រុស្តសីល តែដឹងច្បាស់តាមពិត នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ ដែលជាហេតុនាំឲ្យភាពទ្រុស្តសីលនោះ រលត់ទៅដោយមិនមានសេសសល់ បុគ្គលនោះធ្វើដោយការស្តាប់ផង ការៈចេះដឹងច្រើនផង ចាក់ធ្លុះដោយទិដ្ឋិផង បាននូវវិមុត្តិដែលប្រព្រឹត្តទៅតាមកាលផង លុះបុគ្គលនោះ បែកធ្លាយរាងកាយស្លាប់ទៅ រមែងប្រព្រឹត្តទៅដើម្បីគុណវិសេស មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យទេ ជាបុគ្គលប្រព្រឹត្តទៅ ដើម្បីគុណវិសេសតែម្យ៉ាង មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យឡើយ ។ ម្នាលអានន្ទ បុគ្គលអ្នកកាន់យកនូវប្រមាណក្នុងបុគ្គលនោះ អាចត្រិះរិះថា ធម៌ទាំងនោះជាធម៌របស់បុគ្គលនេះ ធម៌ទាំងនោះជាធម៌របស់បុគ្គលដទៃ បណ្តាបុគ្គលទាំងនោះ ហេតុអ្វីបានជាបុគ្គលម្នាក់ថោកទាប បុគ្គលម្នាក់ខ្ពង់ខ្ពស់ ។ ម្នាលអានន្ទ ព្រោះកិរិយាធ្វើនូវប្រមាណនោះ របស់បុគ្គលទាំងនោះ តែងប្រព្រឹត្តទៅ

ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ អស់កាលជាយូរអង្វែង ។ ម្នាល អានន្ទ ក្នុងដំណើរនោះ បុគ្គលណាទ្រុស្តសីល តែដឹងច្បាស់តាមពិតនូវចេតោ-វិមុត្តិ និងបញ្ញាវិមុត្តិនោះ ជាហេតុនាំឲ្យភាពទ្រុស្តសីលនោះ រលត់ទៅដោយមិនសេសសល់ បុគ្គលនោះ ធ្វើការដោយការស្តាប់ផង ធ្វើដោយភាវៈចេះដឹងច្រើនផង ចាក់ធ្លុះដោយទិដ្ឋិផង បាននូវវិមុត្តិ ប្រព្រឹត្តទៅតាមកាលផង ។ ម្នាល អានន្ទ បុគ្គលនេះប្រសើរផង ឧត្តមផង ជាងបុគ្គលមុនឯណោះ ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលអានន្ទ ព្រោះក្រសែធម៌ គឺវិបស្សនាញាណ រមែងដឹកនាំបុគ្គលនេះ ( ឲ្យដល់នូវអរិយភូមិ ) អ្នកណាក្រៅពីតថាគត នឹងគប្បីដឹងហេតុនោះបាន ។ ម្នាលអានន្ទ ព្រោះហេតុនោះ ក្នុងលោកនេះ អ្នកទាំងឡាយជាអ្នកកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយ កុំមានឡើយ ។ កុំកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយឡើយ ។ ម្នាលអានន្ទ បុគ្គលក្នុងលោកនេះកាលកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយ ឈ្មោះថា ជីករម្លើងនូវគុណម្នាលអានន្ទ តថាគតក្តី បុគ្គលណា ដែលប្រហែលនឹងតថាគតក្តី ទើបគួរកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយបាន ។ ម្នាលអានន្ទ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមានសីល តែមិនដឹងច្បាស់តាមពិត នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិនោះ ដែលជាហេតុនាំឲ្យសីលនោះរលត់ទៅ ដោយមិនមានសេសសល់ បុគ្គលនោះ មិនបានធ្វើដោយការស្តាប់ផង មិនបានធ្វើដោយភាវៈចេះដឹងច្រើនផង មិនបានចាក់ធ្លុះដោយទិដ្ឋិផង មិនបាននូវវិមុត្តិ ដែលប្រព្រឹត្តតាមកាលផង លុះបុគ្គល

នោះ បែកធ្លាយរាងកាយស្លាប់ទៅ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ មិនប្រព្រឹត្តទៅ ដើម្បីគុណវិសេសទេ ជាបុគ្គលប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យតែម្យ៉ាង មិនប្រព្រឹត្តទៅ ដើម្បីគុណវិសេសឡើយ ។ ម្នាលអានន្ទ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសីល ទាំងដឹងច្បាស់តាមពិត នូវចេតោ-វិមុត្តិ និងបញ្ញាវិមុត្តិនោះ ដែលជាហេតុនាំឲ្យសីលនោះ រលត់ទៅដោយមិនមានសេសសល់ បុគ្គលនោះ ធ្វើដោយការស្តាប់ផង ធ្វើដោយភាវៈចេះដឹងច្រើនផង ចាក់ធ្លុះដោយទិដ្ឋិផង បាននូវវិមុត្តិដែលប្រព្រឹត្តទៅតាមកាលផង លុះបុគ្គលនោះ បែកធ្លាយរាងកាយស្លាប់ទៅ រមែងប្រព្រឹត្តទៅដើម្បីគុណវិសេស មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យទេ ជាបុគ្គលប្រព្រឹត្តទៅដើម្បីគុណវិសេសតែម្យ៉ាង មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យឡើយ ។ ម្នាលអានន្ទ ក្នុងដំណើរនោះ ។បេ។ ម្នាលអានន្ទ តថាគតក្តី បុគ្គលដែលប្រហែលនឹងតថាគតក្តី ទើបគួរកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយបាន ។ ម្នាលអានន្ទ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមានរាគៈក្លៀវក្លា ទាំងមិនដឹងច្បាស់តាមពិត នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិនោះ ដែលជាហេតុនាំឲ្យរាគៈនោះរលត់ទៅ ដោយមិនមានសេសសល់ បុគ្គលនោះមិនបានធ្វើដោយការស្តាប់ផង មិនបានធ្វើដោយភាវៈចេះដឹងច្រើនផង មិនបានចាក់ធ្លុះដោយទិដ្ឋិផង មិនបានវិមុត្តិ ដែលប្រព្រឹត្តទៅតាមកាលផង លុះបុគ្គលនោះ បែកធ្លាយរាងកាយស្លាប់ទៅ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យ មិនប្រព្រឹត្តទៅ ដើម្បីគុណវិសេសទេ ជាបុគ្គល

ប្រព្រឹត្តទៅ ដើម្បីសេចក្ដីសាបសូន្យតែម្យ៉ាង មិនប្រព្រឹត្តទៅ ដើម្បីគុណវិសេសឡើយ ។ ម្នាលអានន្ទ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានរាគៈក្រៀវក្រា តែដឹងច្បាស់តាមពិត នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិនោះ ដែលជាហេតុនាំឲ្យរាគៈនោះរលត់ទៅ ដោយមិនមានសេសសល់ បុគ្គលនោះ ធ្វើដោយការស្ដាប់ផង ធ្វើដោយការៈចេះដឹងច្រើនផង ចាក់ធ្លុះដោយទិដ្ឋិផង បាននូវវិមុត្តិ ដែលប្រព្រឹត្តទៅតាមកាលផង លុះបុគ្គលនោះ បែកធ្លាយរាងកាយស្លាប់ទៅ រមែងប្រព្រឹត្តទៅ ដើម្បីគុណវិសេស មិនប្រព្រឹត្តទៅ ដើម្បីសេចក្ដីសាបសូន្យទេ ជាបុគ្គលប្រព្រឹត្តទៅ ដើម្បីគុណវិសេសតែម្យ៉ាង មិនប្រព្រឹត្តទៅដើម្បីសេចក្ដីសាបសូន្យឡើយ ។ ម្នាលអានន្ទ ក្នុងដំណើរនោះ ។បេ។ ម្នាលអានន្ទ តថាគតក្ដី បុគ្គលណាដែលប្រហែលនឹងតថាគតក្ដី ទើបគួរកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយបាន ។ ម្នាលអានន្ទ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្ដីក្រោធ ទាំងមិនដឹងច្បាស់តាមពិត នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិនោះ ដែលជាហេតុនាំឲ្យសេចក្ដីក្រោធនោះ រលត់ទៅដោយមិនមានសេសសល់ បុគ្គលនោះ មិនបានធ្វើដោយការស្ដាប់ផង មិនបានធ្វើដោយការៈចេះដឹងច្រើនផង មិនបានចាក់ធ្លុះដោយទិដ្ឋិផង មិនបាននូវវិមុត្តិ ដែលប្រព្រឹត្តទៅតាមកាលផង លុះបុគ្គលនោះ បែកធ្លាយរាងកាយស្លាប់ទៅ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្ដីសាបសូន្យ មិនប្រព្រឹត្តទៅដើម្បីគុណវិសេសទេ ជាបុគ្គលប្រព្រឹត្តទៅ ដើម្បីសេចក្ដីសាបសូន្យតែម្យ៉ាង មិនប្រព្រឹត្តទៅ

ដើម្បីគុណវិសេសឡើយ ។ ម្នាលអានន្ទ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមាន សេចក្ដីក្រោធ តែដឹងច្បាស់តាមពិត នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិនោះ ដែល ជាហេតុនាំឲ្យសេចក្ដីក្រោធនោះរលត់ទៅ ដោយមិនមានសេសសល់ បុគ្គល នោះ ធ្វើដោយការស្ដាប់ផង ធ្វើដោយការៈចេះដឹងច្រើនផង ចាក់ធ្លុះដោយ ទិដ្ឋិផង បាននូវវិមុត្តិ ដែលប្រព្រឹត្តទៅតាមកាលផង លុះបុគ្គលនោះ បែកធ្លាយ រាងកាយស្លាប់ទៅ រមែងប្រព្រឹត្តទៅ ដើម្បីគុណវិសេស មិនប្រព្រឹត្តទៅ ដើម្បី សេចក្ដីសាបសូន្យទេ ជាបុគ្គលប្រព្រឹត្តទៅ ដើម្បីគុណវិសេសតែម្យ៉ាង មិន ប្រព្រឹត្តទៅ ដើម្បីសេចក្ដីសាបសូន្យឡើយ ។ ម្នាលអានន្ទ ក្នុងជំណើរនោះ ។បេ។ ម្នាលអានន្ទ តថាគតក្ដី បុគ្គលណាដែលប្រហែលនឹងតថាគតក្ដី ទើប គួរកាន់យកនូវប្រមាណក្នុងបុគ្គលទាំងឡាយបាន ។ ម្នាលអានន្ទ បុគ្គលខ្លះក្នុង លោកនេះ ជាអ្នកមានចិត្តរវើរវាយ ទាំងមិនដឹងច្បាស់តាមពិត នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិនោះ ដែលជាហេតុនាំឲ្យសេចក្ដីរវើរវាយនោះរលត់ទៅ ដោយ មិនមានសេសសល់ បុគ្គលនោះ មិនបានធ្វើដោយការស្ដាប់ផង មិនបានធ្វើ ដោយការៈចេះដឹងច្រើនផង មិនបានចាក់ធ្លុះដោយទិដ្ឋិផង មិនបាននូវវិមុត្តិដែល ប្រព្រឹត្តទៅតាមកាលផង លុះបុគ្គលនោះ បែកធ្លាយរាងកាយស្លាប់ទៅ រមែង ប្រព្រឹត្តទៅ ដើម្បីសេចក្ដីសាបសូន្យ មិនប្រព្រឹត្តទៅ ដើម្បីគុណវិសេសទេ ជាបុគ្គលប្រព្រឹត្តទៅ ដើម្បីសេចក្ដីសាបសូន្យតែម្យ៉ាង មិនប្រព្រឹត្តទៅ ដើម្បី គុណវិសេសឡើយ ។ ម្នាលអានន្ទ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមានចិត្ត

រើរវាយ តែដឹងច្បាស់តាមពិត នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិនោះ ដែលជាហេតុនាំឲ្យចិត្តរើរវាយនោះរលត់ទៅ ដោយមិនមានសេសសល់ បុគ្គលនោះធ្វើដោយការស្តាប់ផង ធ្វើដោយការៈចេះដឹងច្រើនផង ចាក់ធ្លុះដោយទិដ្ឋិផង បាននូវវិមុត្តិ ដែលប្រព្រឹត្តទៅតាមកាលផង លុះបុគ្គលនោះ បែកធ្លាយរាងកាយស្លាប់ទៅ រមែងប្រព្រឹត្តទៅ ដើម្បីគុណវិសេស មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យទេ ជាបុគ្គលប្រព្រឹត្តទៅ ដើម្បីគុណវិសេសតែម្យ៉ាង មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យឡើយ ។ ម្នាលអានន្ទ បុគ្គលអ្នកកាន់យកនូវប្រមាណក្នុងបុគ្គលនោះ រមែងត្រិះរិះថា ធម៌ទាំងនោះរបស់បុគ្គលនេះ ទុំះជាធម៌របស់បុគ្គលដទៃ បណ្តាបុគ្គលទាំងនោះ ហេតុអ្វី បានជាបុគ្គលម្នាក់ថោកទាប បុគ្គលម្នាក់ ខ្ពង់ខ្ពស់ ។ ម្នាលអានន្ទ ព្រោះកិរិយាធ្វើនូវប្រមាណនោះ របស់បុគ្គលទាំងនោះ តែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ អស់កាលជាយូរអង្វែង ។ ម្នាលអានន្ទ ក្នុងជំណើរនោះ បុគ្គលណាជាអ្នកមានចិត្តរើរវាយ តែដឹងច្បាស់តាមពិត នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិនោះ ដែលជាហេតុនាំឲ្យចិត្តរើរវាយនោះរលត់ទៅ ដោយមិនមានសេសសល់ បុគ្គលនោះ ធ្វើដោយការស្តាប់ផង ធ្វើដោយការៈចេះដឹងច្រើនផង ចាក់ធ្លុះដោយទិដ្ឋិផង បាននូវវិមុត្តិដែលប្រព្រឹត្តទៅតាមកាលផង ។ ម្នាលអានន្ទ បុគ្គលនេះប្រសើរផង ឧត្តមផងជាងបុគ្គលមុនឯណោះ ។ ជំណើរនោះព្រោះហេតុអ្វី ។ ម្នាលអានន្ទ ព្រោះថា ក្រសែធម៌ រមែងដឹកនាំបុគ្គលនោះ

( ឲ្យដល់នូវអរិយភូមិ ) អ្នកណាក្រៅពីព្រះតថាគត នឹងគប្បីដឹងហេតុនោះបាន ។ ម្នាលអានន្ទ ព្រោះហេតុនោះ ក្នុងលោកនេះ អ្នកទាំងឡាយ ជាអ្នកកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយ កុំមានឡើយ កុំកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយឡើយ ។ ម្នាលអានន្ទ បុគ្គលក្នុងលោកនេះកាលកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយ ឈ្មោះថា ជីករម្លើងនូវគុណ ម្នាលអានន្ទ តថាគតក្តី បុគ្គលណាដែលប្រហែលនឹងតថាគតក្តី ទើបគួរកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយបាន ។ ម្នាលអានន្ទ មិគសាលាឧបាសិកា ជាអ្វី ជាស្ត្រីពាល មិនឈ្លាសវៃ ជាស្ត្រីធ្ងន់ធ្ងឹត មានបញ្ញាធ្ងន់ធ្ងឹត មួយទៀត បុរសបុគ្គលណា ( មានវិស័យមិនទើសទាល់ ) ក្នុងបរោបរិយញ្ញាណ ( បញ្ញាជាគ្រឿងដឹងនូវឥន្ទ្រិយក្លា និងទន់របស់បុគ្គលដទៃ ) ។ ម្នាលអានន្ទ បុគ្គល ១០ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។ ម្នាលអានន្ទ ឧបាសកឈ្មោះបុរាណៈ ប្រកបដោយសីលមានសភាពយ៉ាងណា ឥសិទត្ត ក៏ប្រកបដោយសីល មានសភាពយ៉ាងនោះដែរ ។ បុរាណឧបាសក ក្នុងលោកនេះ មានគតិមិនប្លែកអំពីឥសិទត្តទេ ម្នាលអានន្ទ ឥសិទត្ត ប្រកបដោយបញ្ញាមានសភាពយ៉ាងណា បុរាណឧបាសក ប្រកបដោយបញ្ញា មានសភាពយ៉ាងនោះដែរ ។ ឥសិទត្តឧបាសក ក្នុងលោកនេះ មានគតិមិនប្លែកអំពីបុរាណឧបាសកទេ ។ ម្នាលអានន្ទ បុគ្គលទាំងពីរនេះ ថោកទាបដោយគុណធម៌មួយៗ ម្នាក់ ។

# អដ្ឋកថា

## មិគសាលាសូត្រ

[ ៧៥ ] ពាក្យណាគប្បីពោលមុនក្នុងខាងដើមនៃសូត្រទី ៥ ពាក្យនោះក៏ពោលហើយ ក្នុងឆក្កនិបាត ។ ក្នុងពាក្យថា **ទុស្សីលោ ហោតិ** ជាដើម គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា បទថា **ទុស្សីលោ** បានដល់ ជាអ្នកមិនមានសីល ។ បទថា **ចេតោវិមុត្តិំ** បានដល់ ផលសមាធិ ។ បទថា **បញ្ញាវិមុត្តិំ** បានដល់ ផលញ្ញាណ ។ បទថា **ឆប្បជានាតិ** បានដល់ មិនដឹងដោយការរៀន និងការសាកសួរ ។ ក្នុងពាក្យថា **ទុស្សីល្យំ អបរិសេសំ និរុជ្ឈតិ** នេះ ការទ្រុស្តសីល ៥ យ៉ាង សោតាបត្តិមគ្គលះបានមុន ការទ្រុស្តសីល ១០ យ៉ាង អរហត្តមគ្គលះបាន ក្នុងខណៈផលចិត្ត ការទ្រុស្តសីលទាំងនោះ ឈ្មោះថា មគ្គលះបានហើយ ។ ទ្រង់សំដៅដល់ខណៈនៃផលចិត្តក្នុងសូត្រនេះ ទើបត្រាស់ថា **និរុជ្ឈតិ** សីលរបស់បុថុជ្ជន រមែងដាច់ដោយហេតុ ៥ ប្រការ គឺត្រូវអាបត្តិបារាជិក ១ លាសិក្ខា ១ ចូលតិរ្ថិយ ១ សម្រេចអរហត្ត ១ ស្លាប់ ១ ។ ក្នុងហេតុ ៥ ប្រការនោះ ហេតុ ៣ ខាងដើម ប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស ប្រការទី ៤ ប្រព្រឹត្តទៅដើម្បីសេចក្តីចម្រើន ប្រការទី ៥ មិនប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស ឬសេចក្តីចម្រើនឡើយ ។ សួរថា សីលនេះដាច់ព្រោះសម្រេចអរហត្តដូចម្តេច ឆ្លើយថា ព្រោះថា សីលរបស់បុថុជ្ជន ជាកុសលកម្មដោយចំណែកមួយប៉ុណ្ណោះ ឯអរហត្តមគ្គ ប្រព្រឹត្តទៅដើម្បីអស់កុសលកម្ម និងអកុសលកម្ម សីលដាច់ ព្រោះសម្រេចអរហត្តយ៉ាង

នេះ ។

បទថា **សវនេនបិ អកតំ ហោតិ** សេចក្តីថា ប្រការដែលគួរស្តាប់ ក៏ឈ្មោះថា មិនបានស្តាប់ ។ ក្នុងបទថា **ពាហុសច្ចេនបិ អកតំ ហោតិ** នេះ សេចក្តីថា ការដែលគួរធ្វើដោយសេចក្តីព្យាយាម ក៏ឈ្មោះថា មិនបានធ្វើ ព្រោះមិនបានធ្វើសេចក្តីព្យាយាមនោះ ទើបវិនាសចាកស្ថានសួគ៌ខ្លះ ចាកមគ្គខ្លះ ។ បទថា **ទិដ្ឋិយាបិ អប្បដិវិទ្ធំ ហោតិ** សេចក្តីថា ការដែលគប្បីចាក់ធ្លុះដោយទិដ្ឋិ ក៏មិនចាក់ធ្លុះ មិនធ្វើឲ្យប្រចក្ស ។ បទថា **សាមាយិកម្បិ វិមុត្តឹ ន លភតិ** សេចក្តីថា អាស្រ័យការស្តាប់ធម៌តាមកាលសមគួរដល់កាល រមែងមិនបានទូវបីតិ និងបាមោជ្ជ ។ បទថា **ហានាយ បរេតិ** សេចក្តីថា រមែងដល់នូវការវិនាស ។ បទថា **យថាភូតំ បជានាតិ** សេចក្តីថា សម្រេចសោតាបត្តិផលហើយ រមែងដឹងដោយការរៀន និងសាកសួរថា ការទ្រុស្តសីល ៥ យ៉ាង រមែងរលត់មិនមានចំណែកសេសសល់ ។

បទថា **តស្ស សវនេនបិ កតំ ហោតិ** សេចក្តីថា ប្រការដែលគួរស្តាប់ ក៏បានស្តាប់ ។ បទថា **ពាហុសច្ចេនបិ កតំ ហោតិ** សេចក្តីថា កិច្ចដែលគួរធ្វើដោយសេចក្តីព្យាយាម ដោយហោចត្រឹមវិបស្សនាដែលមិនមានកម្លាំង ក៏ឈ្មោះថា បានធ្វើ ។ បទថា **ទិដ្ឋិយាបិ សុប្បដិវិទ្ធំ ហោតិ** សេចក្តីថា ការចាក់ធ្លុះបច្ច័យ ដោយហោច ដោយលោកិយបញ្ញា ក៏ឈ្មោះថា បានឃើញ ពិតហើយ បញ្ញារបស់បុគ្គលនេះ រមែងជម្រះសីល រមែងសម្រេច

*គុណវិសេស ដោយសីលដែលបញ្ញាជម្រះហើយ ។ បទថា* **បមាណិកា** *បានដល់ កាន់យកចំនួនក្នុងបុគ្គលទាំងឡាយ ។ បទថា* **បមិនន្តិ** *បានដល់ គួររាប់ គួរថ្លឹង ។ បទថា* **ឯកោ ហីនោ** *បានដល់ វិនាសចាកគុណទាំងឡាយម្នាក់ឯង ។ បទថា* **បណីតោ** *បានដល់ ឧត្តុង្គឧត្តមដោយគុណទាំងឡាយម្នាក់ឯង ។ បទថា* **តំ ហិ** *បានដល់ ធ្វើនូវការរាប់នោះ ។ បទថា* **អភិក្កន្តតរោ** *ប្រែថា ល្អជាង ។ បទថា* **បណីតតរោ** *ប្រែថា ឧត្តមជាង ។*

*បទថា* **ធម្មសោតោ និព្វហតិ** *សេចក្តីថា វិបស្សនាញាណដែលប្រព្រឹត្តទៅរឹងមាំ រមែងទាញយក គឺឲ្យសម្រេចអរិយភូមិ ។ បទថា* **តទន្តរំ កោ ជានេយ្យ** *សេចក្តីថា បុគ្គលណាគប្បីដឹងហេតុនោះៗ ។ បទថា* **សីលវា ហោតិ** *បានដល់ រមែងមានសីលដោយលោកិយសីល ។ បទថា* **យត្ថស្ស តំ សីលំ** *សេចក្តីថា ដល់នូវវិមុត្តិក្នុងអរហត្តហើយ សីលក៏ឈ្មោះថា រលត់មិនសេសសល់ឡើយ ។ យុត្តិក្នុងសីលនោះ ក៏ពោលហើយទាំងអស់ ។ ក្នុងអង្គទាំង ២ ក្រៅអំពីនេះ អនាគាមិផល ឈ្មោះថា* **វិមុត្តិ** ។

*ក្នុងសូត្រទី ៥ ក៏ត្រាស់អរហត្តតែម្យ៉ាង ។ ពាក្យដ៏សេសក្នុងសូត្រទី ៥ នោះ គប្បីជ្រាបតាមគន្លងន័យដែលពោលហើយ ។*

**អដ្ឋកថា មិគសាលាសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## អភព្វសូត្រទី ៦

[ ៧៦ ] ម្នាលភិក្ខុទាំងឡាយ ( ប្រសិនបើ ) ធម៌ទាំង ៣ នេះមិនមានក្នុងលោកទេ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ក៏មិនគប្បីកើតឡើងក្នុងលោកឡើយ ទាំងធម្មវិន័យ ដែលព្រះតថាគតសម្តែងហើយ ក៏មិនភ្លឺច្បាស់ក្នុងលោកដែរ ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺជាតិ ១ ជរា ១ មរណៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ( ប្រសិនបើ ) ធម៌ទាំង ៣ នេះមិនមានក្នុងលោកទេ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ក៏មិនគប្បីកើតឡើងក្នុងលោក ទាំងធម្មវិន័យ ដែលព្រះតថាគតសម្តែងហើយ ក៏មិនភ្លឺច្បាស់ក្នុងលោកនេះដែរ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៣ នេះ រមែងមានក្នុងលោកព្រោះហេតុណា ព្រោះហេតុនោះ ទើបព្រះតថាគតអរហន្តសម្មាសម្ពុទ្ធកើតឡើងក្នុងលោក ព្រោះហេតុនោះ ទើបធម្មវិន័យដែលព្រះតថាគតសម្តែងហើយ ភ្លឺច្បាស់ក្នុងលោកដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ ហើយ មិនគួរលះបង់ជាតិ លះបង់ជរា លះបង់មរណៈបានទេ ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺមិនលះបង់រាគៈ ១ មិនលះបង់ទោសៈ ១ មិនលះបង់មោហៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនលះបង់ធម៌ទាំង ៣ នេះចេញហើយ មិនគួរលះបង់ជាតិ លះបង់ជរា លះបង់មរណៈបានទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនលះបង់ធម៌ទាំង ៣ ចេញហើយ មិនគួរលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈបានទេ ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺមិនលះបង់សក្កាយទិដ្ឋិ ១ មិនលះបង់

វិចិកិច្ឆា ១ មិនលះបង់សីលព្វតបរាមាស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនលះបង់ធម៌ទាំង ៣ នេះហើយ មិនគួរលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈបានទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនលះបង់ធម៌ទាំង ៣ ហើយ មិនគួរលះបង់សក្កាយទិដ្ឋិ លះបង់វិចិកិច្ឆា លះបង់សីលព្វតបរាមាសបានទេ ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺមិនលះបង់នូវការធ្វើទុកក្នុងចិត្ត ដោយមិនមែនឧបាយ ១ មិនលះបង់នូវកិរិយាសេពគប់នូវផ្លូវខុស ១ មិនលះបង់នូវភាពរួញរានៃចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ នេះចេញហើយ មិនគួរលះបង់សក្កាយទិដ្ឋិ លះបង់វិចិកិច្ឆា លះបង់សីលព្វតបរាមាសបានទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ ចេញហើយ មិនគួរលះបង់នូវការធ្វើទុកក្នុងចិត្តដោយមិនមែនឧបាយ លះបង់នូវកិរិយាសេពគប់នូវផ្លូវខុស លះបង់នូវភាពរួញរានៃចិត្តបានទេ ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺមិនលះបង់ការភ្លេចស្មារតី ១ មិនលះបង់សេចក្តីមិនដឹងខ្លួន ១ មិនលះបង់សេចក្តីរវើរវាយនៃចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ នេះហើយ មិនគួរលះបង់នូវការធ្វើទុកក្នុងចិត្ត ដោយមិនមែនឧបាយ លះបង់នូវកិរិយាសេពគប់នូវផ្លូវខុស លះបង់នូវភាពរួញរានៃចិត្តបានទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ ហើយ មិនគួរលះបង់នូវការភ្លេចស្មារតី លះបង់នូវសេចក្តីមិនដឹងខ្លួន លះបង់នូវសេចក្តីរវើរវាយនៃចិត្តបានទេ ។ ធម៌ទាំង ៣

តើដូចម្តេច ។ គឺលះបង់នូវភាពនៃសេចក្តីប្រាថ្នា ដើម្បីមិនឃើញនូវព្រះអរិយៈទាំងឡាយ ១ មិនលះបង់នូវភាពនៃសេចក្តីប្រាថ្នា ដើម្បីមិនស្តាប់នូវអរិយធម៌ ១ មិនលះបង់នូវភាពនៃចិត្តប្រកាន់ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ នេះហើយ មិនគួរលះបង់នូវការភ្លេចស្មារតី លះបង់នូវសេចក្តីមិនដឹងខ្លួន លះបង់នូវសេចក្តីរវើរវាយនៃចិត្តបានទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ ចេញហើយ មិនគួរលះបង់នូវភាពនៃសេចក្តីប្រាថ្នា ដើម្បីមិនឃើញនូវព្រះអរិយៈទាំងឡាយ លះបង់នូវភាពនៃសេចក្តីប្រាថ្នា ដើម្បីមិនស្តាប់នូវអរិយធម៌ លះបង់នូវភាពនៃចិត្តប្រកួតប្រកាន់បានទេ ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺមិនលះបង់នូវសេចក្តីរវើរវាយ ១ មិនលះបង់នូវសេចក្តីមិនសង្រួម ១ មិនលះបង់នូវភាពទ្រុស្តសីល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ នេះហើយ មិនគួរលះបង់នូវភាពនៃសេចក្តីប្រាថ្នា ដើម្បីមិនឃើញនូវព្រះអរិយៈទាំងឡាយ លះបង់នូវភាពនៃសេចក្តីប្រាថ្នា ដើម្បីមិនស្តាប់នូវអរិយធម៌ទាំងឡាយ លះបង់នូវភាពនៃចិត្តប្រកួតប្រកាន់បានទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ ហើយ មិនគួរលះបង់នូវចិត្តរវើរវាយ លះបង់នូវសេចក្តីមិនសង្រួម លះបង់នូវភាពទ្រុស្តសីលបានទេ ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺមិនលះបង់នូវភាពមិនមានសទ្ធា ១ មិនលះបង់នូវភាពមិនដឹងនូវពាក្យពោល ១ មិនលះបង់នូវសេចក្តីខ្ជិល ១ ។ ម្នាលភិក្ខុទាំង

ឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ នេះហើយ មិនគួរលះបង់នូវសេចក្តីរវើរវាយ លះបង់នូវសេចក្តីមិនសង្រួម លះបង់នូវភាពទ្រុស្តសីលបានទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ ចេញហើយ មិនគួរលះបង់នូវភាពមិនមានសទ្ធា លះបង់នូវភាពមិនដឹងពាក្យពោល លះបង់នូវសេចក្តីខ្ជិលបានទេ ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺមិនលះបង់នូវសេចក្តីមិនអើពើ ១ មិនលះបង់នូវភាពជាអ្នកប្រដៅក្រ ១ មិនលះបង់នូវភាពនៃបាបមិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ នេះហើយ មិនគួរលះបង់នូវភាពមិនមានសទ្ធា លះបង់នូវភាពមិនដឹងពាក្យពោល លះបង់នូវសេចក្តីខ្ជិលបានទេ ។ ម្នាលភិក្ខុទាំឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង៣ហើយ មិនគួរលះបង់នូវសេចក្តីមិនអើពើ លះបង់នូវភាពជាអ្នកប្រដៅក្រ លះបង់ភាពនៃបាបមិត្តបានទេ ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺមិនលះបង់នូវសេចក្តីមិន អៀនខ្មាសនឹងអំពើទុច្ចរិត ១ មិនលះបង់នូវសេចក្តីក្តៅក្រហាយនឹងអំពើទុច្ចរិត ១ មិនលះបង់នូវសេចក្តីធ្វេសប្រហែស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនបានលះបង់ធម៌ទាំង ៣ នេះហើយ មិនគួរលះបង់នូវសេចក្តីមិនអើពើ លះបង់នូវភាពជាអ្នកប្រដៅក្រ លះបង់នូវភាពនៃបាបមិត្តបានទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះជាអ្នកមិនមានសេចក្តីអៀនខ្មាស មិនមានសេចក្តីក្តៅក្រហាយនឹងអំពើទុច្ចរិត ជាអ្នកប្រមាទ ។ កាលបើបុគ្គលនោះ ជាអ្នកប្រមាទហើយ មិនគួរលះបង់នូវសេចក្តី

មិនអើពើ លះបង់នូវភាពជាអ្នកប្រដៅក្រ លះបង់នូវភាពនៃបាបមិត្តបានទេ ។ កាលបើបុគ្គលនោះមានបាបមិត្តហើយ មិនគួរលះបង់នូវភាព មិនមានសទ្ធា លះបង់នូវភាពមិនដឹងពាក្យពោល លះបង់នូវសេចក្ដីខ្ជិលបានទេ ។ កាលបើបុគ្គលនោះមានសេចក្ដីខ្ជិលហើយ មិនគួរលះបង់នូវសេចក្ដីរវើរវាយ លះបង់នូវសេចក្ដីមិនសង្រួម លះបង់នូវភាពទ្រុស្តសីលបានទេ ។ កាលបើបុគ្គលនោះ មានភាពជាអ្នកទ្រុស្តសីលហើយ មិនគួរលះបង់ភាពនៃសេចក្ដីប្រាថ្នាដើម្បីមិនឃើញព្រះអរិយៈទាំងឡាយ លះបង់នូវភាពនៃសេចក្ដីប្រាថ្នា ដើម្បីមិនស្ដាប់នូវអរិយធម៌ លះបង់នូវភាពនៃចិត្តប្រកួតប្រកាន់បានទេ ។ កាលបើបុគ្គលនោះមានភាពនៃចិត្តប្រកួតប្រកាន់ហើយ មិនគួរលះបង់នូវការភ្លេចស្មារតី លះបង់នូវសេចក្ដីមិនដឹងខ្លួន លះបង់នូវចិត្តរវើរវាយបានទេ ។ កាលបើបុគ្គលនោះមានចិត្តរវើរវាយហើយ មិនគួរលះបង់នូវការធ្វើទុកក្នុងចិត្តដោយមិនមែនឧបាយ លះបង់នូវកិរិយាសេពគប់នូវផ្លូវខុស លះបង់នូវសេចក្ដីរួញរានៃចិត្តបានទេ ។ កាលបើបុគ្គលនោះមានចិត្តរួញរា មិនគួរលះបង់នូវសក្កាយទិដ្ឋិ លះបង់នូវវិចិកិច្ឆា លះបង់នូវសីលព្វតបរាមាសបានទេ ។ កាលបើបុគ្គលនោះមានវិចិកិច្ឆា មិនគួរលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈបានទេ ។ កាលបើមិនបានលះបង់រាគៈ មិនបានលះបង់ទោសៈ មិនបានលះបង់មោហៈ មិនគួរលះបង់ជាតិ លះបង់ជរា លះបង់មរណៈបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់ជាតិ

លះបង់ជរា លះបង់មរណៈបាន ។ ធម៌ទាំង ៣ តើដូចម្តេចខ្លះ ។ គឺលះបង់រាគៈ ១ លះបង់ទោសៈ ១ លះបង់មោហៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ទាំង ៣ នេះចេញបានហើយ ទើបគួរលះបង់ជាតិ លះបង់ជរា លះបង់មរណៈបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈបាន ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺលះបង់សក្កាយទិដ្ឋិ ១ លះបង់វិចិកិច្ឆា ១ លះបង់សីលព្វតបរាមាស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ នេះបានហើយ ទើបគួរលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់សក្កាយទិដ្ឋិ លះបង់វិចិកិច្ឆា លះបង់សីលព្វតបរាមាសបាន ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺលះបង់ការធ្វើទុកក្នុងចិត្តដោយមិនមែនឧបាយ ១ លះបង់ការសេពគប់ផ្លូវខុស ១ លះបង់សេចក្តីរួញរានៃចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ នេះបានហើយ ទើបគួរលះបង់សក្កាយទិដ្ឋិ លះបង់វិចិកិច្ឆា លះបង់សីលព្វតបរាមាសបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់ការធ្វើទុកក្នុងចិត្តដោយមិនមែនឧបាយ លះបង់នូវការសេពគប់នូវផ្លូវខុស លះបង់នូវសេចក្តីរួញរានៃចិត្តបាន ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺលះបង់នូវការភ្លេចស្មារតី ១ លះបង់នូវសេចក្តីមិនដឹងខ្លួន ១ លះបង់នូវសេចក្តីរវើរវាយ

នៃចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បាន ហើយ ទើបគួរលះបង់នូវការធ្វើទុកក្នុងចិត្តដោយមិនមែនឧបាយ លះបង់នូវការសេពគប់នូវផ្លូវខុស លះបង់នូវសេចក្តីរួញរានៃចិត្តបាន ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់នូវការភ្លេចស្មារតី លះបង់នូវសេចក្តីមិនដឹងខ្លួន លះបង់នូវសេចក្តីរវើរវាយនៃចិត្តបាន ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺលះបង់នូវសេចក្តីប្រាថ្នា ដើម្បីមិនឃើញនូវព្រះអរិយៈទាំងឡាយ ១ លះបង់នូវសេចក្តីប្រាថ្នា ដើម្បីមិនស្តាប់នូវអរិយធម៌ ១ លះបង់នូវចិត្តប្រកួតប្រកាន់ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ នេះបានហើយ ទើបគួរលះបង់នូវការភ្លេចស្មារតី លះបង់នូវសេចក្តីមិនដឹងខ្លួន លះបង់នូវសេចក្តីរវើរវាយនៃចិត្តបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់សេចក្តីប្រាថ្នា ដើម្បីមិនឃើញនូវព្រះអរិយៈទាំងឡាយ លះបង់នូវសេចក្តីប្រាថ្នា ដើម្បីមិនស្តាប់នូវអរិយធម៌ លះបង់នូវចិត្តប្រកួតប្រកាន់បាន ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺលះបង់នូវសេចក្តីរវើរវាយ ១ លះបង់នូវសេចក្តីមិនសង្រួម ១ លះបង់នូវភាពទ្រុស្តសីល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ នេះបានហើយ ទើបគួរលះបង់នូវសេចក្តីប្រាថ្នា ដើម្បីមិនឃើញនូវព្រះអរិយៈទាំងឡាយ លះបង់នូវសេចក្តីប្រាថ្នា ដើម្បីមិនស្តាប់នូវអរិយធម៌ លះបង់នូវចិត្តប្រកួតប្រកាន់បាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល

កាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់នូវសេចក្តីវេវវាយ លះបង់នូវសេចក្តីមិនសង្រួម លះបង់នូវភាពទ្រុស្តសីល ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺលះបង់នូវភាពមិនមានសទ្ធា ១ លះបង់នូវសេចក្តីមិនដឹងនូវពាក្យពោល ១ លះបង់នូវសេចក្តីខ្ជិល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ នេះបានហើយ ទើបគួរលះបង់នូវសេចក្តីវេវវាយ លះបង់នូវសេចក្តីមិនសង្រួម លះបង់នូវភាពទ្រុស្តសីលបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់នូវភាពមិនមានសទ្ធា លះបង់នូវសេចក្តីមិនដឹងនូវពាក្យពោល លះបង់នូវសេចក្តីខ្ជិលបាន ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺលះបង់នូវសេចក្តីមិនអើពើ ១ លះបង់នូវភាពជាអ្នកប្រដៅក្រ ១ លះបង់នូវភាពនៃបាបមិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់នូវភាពមិនមានសទ្ធា លះបង់នូវភាពមិនដឹងនូវពាក្យពោល លះបង់នូវសេចក្តីខ្ជិលបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់នូវសេចក្តីមិនអើពើ លះបង់នូវភាពជាអ្នកប្រដៅក្រ លះបង់នូវភាពនៃបាបមិត្តបាន ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺលះបង់នូវសេចក្តីមិនអៀនខ្មាសនឹងអំពើទុច្ចរិត ១ លះបង់នូវសេចក្តីមិនក្តៅនឹងអំពើទុច្ចរិត ១ លះបង់នូវសេចក្តីធ្វេសប្រហែស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់នូវសេចក្តីមិនអើពើ លះបង់

នូវភាពជាអ្នកប្រដៅក្រ លះបង់នូវភាពនៃបាបមិត្តបាន ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលនេះជាអ្នកមានសេចក្ដីអៀនខ្មាសនឹងអំពើទុច្ចរិត ក្ដៅនឹងអំពើទុច្ចរិត មិនប្រមាទ ។ កាលបើបុគ្គលនោះមិនប្រមាទហើយ ទើបគួរដើម្បីលះបង់នូវសេចក្ដីមិនអើពើ លះបង់នូវភាពជាអ្នកប្រដៅក្រ លះបង់នូវភាពនៃបាបមិត្តបាន ។ កាលបើបុគ្គលនោះមានកល្យាណមិត្តហើយ ទើបគួរដើម្បីលះបង់នូវភាពមិនមានសទ្ធា លះបង់នូវសេចក្ដីមិនដឹងនូវពាក្យពោល លះបង់នូវសេចក្ដីខ្ជិលបាន ។ កាលបើបុគ្គលនោះ មានសេចក្ដីព្យាយាមប្រារព្ធហើយ ទើបគួរដើម្បីលះបង់នូវសេចក្ដីរវើរវាយ លះបង់នូវការមិនសង្រួម លះបង់នូវភាពទ្រុស្ដសីលបាន ។ កាលបើបុគ្គលនោះមានសីល ទើបគួរដើម្បីលះបង់នូវសេចក្ដីប្រាថ្នា ដើម្បីមិនឃើញនូវព្រះអរិយៈទាំងឡាយ លះបង់នូវសេចក្ដីប្រាថ្នា ដើម្បីមិនស្ដាប់នូវអរិយធម៌ លះបង់នូវចិត្តប្រកួតប្រកាន់បាន ។ កាលបើបុគ្គលនោះមិនមានចិត្តប្រកួតប្រកាន់ហើយ ទើបគួរដើម្បីលះបង់នូវការភ្លេចស្មារតី លះបង់នូវសេចក្ដីមិនដឹងខ្លួន លះបង់នូវសេចក្ដីរសាប់រសល់នៃចិត្តបាន ។ កាលបើបុគ្គលនោះមិនមានចិត្តរសាប់រសល់ហើយ ទើបគួរដើម្បីលះបង់នូវកិរិយាធ្វើទុកក្នុងចិត្តដោយមិនមែនឧបាយ លះបង់នូវការសេពគប់នូវផ្លូវខុស លះបង់នូវសេចក្ដីរួញរានៃចិត្តបាន ។ កាលបើបុគ្គលនោះ មិនមានចិត្តរួញរាហើយ ទើបគួរដើម្បីលះបង់នូវសក្កាយទិដ្ឋិ លះបង់នូវវិចិកិច្ឆា លះបង់នូវសីលព្វតបរាមាសបាន ។ កាលបើបុគ្គលនោះ មិនមានវិចិកិច្ឆា

ហើយ ទើបគួរដើម្បីលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈបាន ។ កាលបើបុគ្គលនោះ លះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈហើយ ទើបគួរដើម្បីលះបង់ជាតិ លះបង់ជរា លះបង់មរណៈបាន ។

# អដ្ឋកថា

## អភព្វសូត្រ

[ ៧៦ ] ក្នុងអភព្វសូត្រទី ៦ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាអភព្វសូត្រទី ៦ ចប់

# សុត្តន្តបិដក

## កាកសូត្រទី ៧

[ ៧៧ ] ម្នាលភិក្ខុទាំងឡាយ ក្អែកប្រកបដោយអសទ្ធម្ម ១០ យ៉ាង ។ ប្រកបដោយអសទ្ធម្មទាំង ១០ យ៉ាង តើដូចម្ដេច ។ គឺជាសត្វកម្ចាត់បង់ ( នូវគុណ ) ១ ក្រអឺតក្រអោង ១ មានសេចក្ដីរេះរាម ១ ស៊ីច្រើន ១ អាក្រក់ ១ មិនមានសេចក្ដីករុណា ១ មានកម្លាំងថយ ១ មានសំឡេងគ្រាវ ១ មានស្មារតីវង្វេង ១ ធ្វើនូវសេចក្ដីសន្សំ ១ ។ ម្នាលភិក្ខុទាំងឡាយ ក្អែក

ប្រកបដោយអសទ្ធម្ម ១០ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាប ប្រកបដោយអសទ្ធម្ម ១០ យ៉ាង ក៏យ៉ាងនោះដែរ ។ ប្រកបដោយអសទ្ធម្ម ១០ យ៉ាង តើដូចម្ដេច ។ គឺជាអ្នកកម្ចាត់បង់ ( នូវគុណ ) ១ ជាអ្នកក្រអឺតក្រអោង ១ ជាអ្នកមានសេចក្ដីវេះវាម ១ ជាអ្នកស៊ីច្រើន ១ ជាមនុស្សអាក្រក់ ១ ជាអ្នកមិនមានសេចក្ដីករុណា ១ ជាអ្នកមានកម្លាំងថយ ១ ជាអ្នកមានសំឡេងអាក្រក់ ១ ជាអ្នកមានស្មារតីវង្វេង ១ ជាអ្នកធ្វើនូវសេចក្ដីសន្សំ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាប ប្រកបដោយអសទ្ធម្ម ១០ យ៉ាង យ៉ាងនេះឯង ។

# អដ្ឋកថា

## កាកសូត្រ

[ ៧៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកាកសូត្រទី ៧ ដូចតទៅនេះ បទថា **ធំសី** បានដល់ អ្នកកម្ចាត់គុណ មិនអើពើដល់គុណរបស់បុគ្គលណា សូម្បីបុគ្គលនោះយកដៃចាប់ ក៏រលាស់ចេញ គង់បន្ទោបង់ឧច្ចារៈស្រោចលើក្បាល ។ បទថា **បគព្ភោ** បានដល់ ប្រកបដោយការគ្គាំគ្គង ឥតខ្មាស ។ តណ្ហា លោកហៅថា **តិនតិណា** ក្នុងបទថា **តិន្តិណោ** ប្រកបដោយការចង់បាននោះ ឬច្រើនដោយការរង្កៀស ។ បទថា **លុទ្ទោ** ប្រែថា គ្រោតគ្រាត ។ បទថា

**អការុណិកោ** ប្រែថា ឥតករុណា ។ បទថា **ទុព្វលោ** បានដល់ មិនមាន កម្លាំង គឺមានកម្លាំងតិច ។ បទថា **ឱរវិតា** បានដល់ ហើរផង យំផង ។ បទថា **នេចយិកោ** បានដល់ ធ្វើការសន្សំ ៕៚

**អដ្ឋកថាកាកសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## និគណ្ឋសូត្រទី ៨

[ ៧៨ ] ម្នាលភិក្ខុទាំងឡាយ ពួកនិគ្រន្ថប្រកបដោយអសទ្ធម្ម ១០ យ៉ាង ។ ប្រកបដោយអសទ្ធម្ម ១០ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកនិគ្រន្ថមិនមានសទ្ធា ១ ម្នាលភិក្ខុទាំងឡាយ ពួកនិគ្រន្ថជាអ្នកទ្រុស្តសីល ១ ម្នាលភិក្ខុទាំងឡាយ ពួកនិគ្រន្ថមិនមានហិរិ ១ ម្នាលភិក្ខុទាំងឡាយ ពួកនិគ្រន្ថមិនមានឱត្តប្បៈ ១ ម្នាលភិក្ខុទាំងឡាយ ពួកនិគ្រន្ថជាអ្នកមានអសប្បុរសជាមិត្ត ១ ម្នាលភិក្ខុទាំងឡាយ ពួកនិគ្រន្ថជាអ្នកតម្កើងខ្លួនឯង ហើយបង្អាប់បុគ្គលដទៃ ១ ម្នាលភិក្ខុទាំងឡាយ ពួកនិគ្រន្ថជាអ្នកស្ទាបអង្អែលក្នុងទិដ្ឋិរបស់ខ្លួន ជាអ្នកប្រកាន់មាំ ជាអ្នកលះបង់នូវអំពើដែលខ្លួនប្រកាន់បានដោយកម្រ ១ ម្នាលភិក្ខុទាំងឡាយ ពួកនិគ្រន្ថជាអ្នកកុហក ១ ម្នាលភិក្ខុទាំងឡាយ

ពួកនិគ្រន្ថ ជាអ្នកមានសេចក្តីប្រាថ្នាដ៏លាមក ១ ម្នាលភិក្ខុទាំងឡាយ ពួកនិគ្រន្ថ ជាអ្នកមានទិដ្ឋិខុស ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិគ្រន្ថ ប្រកបដោយអសទ្ធម្ម ១០ យ៉ាងនេះឯង ។

# អដ្ឋកថា

## និគណ្ឋសូត្រ

[ ៧៨ ] ក្នុងនិគណ្ឋសូត្រទី ៨ មានអត្ថងាយយល់ហើយ ។

អដ្ឋកថានិគណ្ឋសូត្រទី ៨ ចប់

# សុត្តន្តបិដក

## អាឃាតវត្ថុសូត្រទី ៩

[ ៧៩ ] ម្នាលភិក្ខុទាំងឡាយ អាឃាតវត្ថុ ( ហេតុនៃគំនុំ ) នេះមាន ១០ យ៉ាង ។ អាឃាតវត្ថុទាំង ១០ តើដូចម្តេច ។ គឺបុគ្គលចងគំនុំ ដោយគិតថា ជនឯណោះបានប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញហើយ ១ ចងគំនុំ ដោយគិតថា ជនឯណោះកំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ ១ ចងគំនុំ ដោយគិតថា ជនឯណោះនឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ ១ ចងគំនុំដោយគិតថា ជនឯណោះបានប្រព្រឹត្ត

នូវអំពើមិនជាប្រយោជន៍ដល់បុគ្គលជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អាត្មាអញហើយ ... ១ កំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ ... ១ នឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ ១ ចងគំនុំដោយគិតថា ជនឯណោះបានប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តដល់អាត្មាអញហើយ ... ១ កំពុងប្រព្រឹត្តនូវអំពើជាប្រយោជន៍ ... ១ នឹងប្រព្រឹត្តនូវអំពើជាប្រយោជន៍ ១ ក្រោធក្នុងទីដែលមិនគួរ ១ ។ ម្នាលភិក្ខុទាំងឡាយ អាឃាតវត្ថុមាន ១០ យ៉ាងនេះឯង ។

# អដ្ឋកថា

## អាឃាតវត្ថុសូត្រ

[ ៧៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអាឃាតវត្ថុសូត្រទី ៩ ដូចតទៅនេះ បទថា **អដ្ឋានេ** បានដល់ ក្នុងទីមិនមែនហេតុ ពិតហើយ ហេតុជាដើមថា បុគ្គលនោះ បានប្រព្រឹត្តនូវវត្ថុដែលមិនជាប្រយោជន៍ដល់អញ គប្បីមានក្នុងការប្រព្រឹត្តទៅនៃវត្ថុដែលមានចិត្ត ឬក្នុងវត្ថុដែលមិនមានចិត្តជាដើមថា ជន្លត់ឈើ ដុំថ្ម រមែងមិនមាន ព្រោះដូច្នោះ អាឃាតក្នុងរបស់ទាំងនេះ ទើបឈ្មោះថា អាឃាតក្នុងទីមិនមានហេតុ ពាក្យដ៏សេសក្នុងទីគ្រប់អន្លើ មានអត្ថងាយយល់ហើយ ។

# សុត្តន្តបិដក

## អាឃាតបដិវិនយសូត្រទី ១០

[ ៨០ ] ម្នាលភិក្ខុទាំងឡាយ អាឃាតប្បដិវិន័យ ( ការកម្ចាត់បង់នូវគំនុំ ) នេះមាន ១០ យ៉ាង ។ អាឃាតប្បដិវិន័យទាំង ១០ យ៉ាង តើដូចម្ដេច ។ គឺបុគ្គលកម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះបានប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញហើយ អាត្មាអញគប្បីបាននូវអំពើមិនជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះអំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះកំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ អាត្មាអញគប្បីបាននូវអំពើមិនជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះអំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះនឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ អាត្មាអញគប្បីបាននូវអំពើមិនជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះអំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះបានប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់បុគ្គលជាទីស្រឡាញ់ជាទីគាប់ចិត្តរបស់អាត្មាអញហើយ ... ១ កំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ ... ១ នឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ អាត្មាអញគប្បីបាននូវអំពើមិនជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះអំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះបានប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញហើយ ... ១ កំពុងប្រព្រឹត្តនូវអំពើជាប្រយោជន៍ ... ១ នឹងប្រព្រឹត្តនូវអំពើជាប្រយោជន៍ អាត្មាអញគប្បីបាននូវអំពើជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះអំពីណា ១ មិន

ក្រោធក្នុងទីមិនគួរ ១ ។ ម្នាលភិក្ខុទាំងឡាយ អាឃាតប្បដិវិន័យមាន ១០ យ៉ាងនេះឯង ។

អាកង្ខវគ្គទី ៣ ចប់

## ឧទ្ទាននៃអាកង្ខវគ្គនោះ គឺ

និយាយអំពីសេចក្តីប្រាថ្នា ១ អំពីធម៌ជាបន្ទា ១ អំពីធម៌
ជាទីប្រាថ្នា ១ អំពីសេចក្តីចម្រើន ១ អំពីមិគសាលា-
ឧបាសិកា ១ អំពីបុគ្គលមិនគួរលះបង់ ១ អំពីក្អែក ១ អំពី
ពួកនិគ្រន្ថ ១ អំពីវត្ថុ ១០ យ៉ាង មាន ( ពីរលើក ) ១ ។

# អដ្ឋកថា

## អាឃាតបដិវិនយសូត្រ

[ ៨០ ] ក្នុងអាឃាតបដិវិនយសូត្រទី ១០ មានអត្ថងាយយល់ហើយ ។

### អដ្ឋកថា អាឃាតបដិវិនយសូត្រទី ១០ ចប់

### អាកង្ខវគ្គទី ៣ ចប់

# សុត្តន្តបិដក
# ថេរវគ្គទី ៤

## វាហុនសូត្រទី ១

[ ៨១ ] សម័យមួយ ព្រះដ៏មានព្រះភាគ គង់ក្បែរឆ្នេរស្រះឈ្មោះគគ្គរា ជិតក្រុងចម្បា ។ គ្រានោះ ព្រះវាហុនៈដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះវាហុនៈដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះតថាគតមានព្រះហឫទ័យទម្លាយនូវទំនប់ គឺកិលេស តើរលាស់ចេញ ឃ្លាតចេញ រួចស្រឡះចាកធម៌ប៉ុន្មានយ៉ាង ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលវាហុនៈ ព្រះតថាគតមានចិត្តទម្លាយនូវទំនប់ គឺកិលេស រលាស់ចេញ ឃ្លាតចេញ រួចស្រឡះចាកធម៌ ១០ យ៉ាង ។ ធម៌ ១០ យ៉ាង តើអ្វីខ្លះ ។ ម្នាលវាហុនៈ ព្រះតថាគតមានចិត្តទម្លាយនូវទំនប់ គឺកិលេស រលាស់ចេញ ឃ្លាតចេញ រួចស្រឡះចាករូប ១ ម្នាលវាហុនៈ ចាកវេទនា ... ១ ម្នាលវាហុនៈ ចាកសញ្ញា ... ១ ម្នាលវាហុនៈ ចាកសង្ខារទាំងឡាយ ... ១ ម្នាលវាហុនៈ ចាកវិញ្ញាណ ... ១ ម្នាលវាហុនៈ ចាកជាតិ ... ១ ម្នាលវាហុនៈ ចាកជរា ... ១ ម្នាលវាហុនៈ ចាកមរណៈ ... ១ ម្នាលវាហុនៈ ចាកទុក្ខទាំងឡាយ ... ១ ម្នាលវាហុនៈ ព្រះតថាគតមានចិត្តទម្លាយនូវទំនប់ គឺកិលេស រលាស់ចេញ

ឃ្លាតចេញ រួចស្រឡះចាកកិលេស ១ ។ ម្នាលវាហុនៈ ដូចឧប្បលក្តី ឈូកក្រហមក្តី ឈូកសក្តី ដែលដុះក្នុងទឹក លូតលាស់ក្នុងទឹក លូតផុតអំពីទឹក មិនជាប់ដោយទឹក យ៉ាងណាមិញ ម្នាលវាហុនៈ ព្រះតថាគតមានចិត្តទម្លាយនូវទំនប់ គឺកិលេស រលាស់ចេញ ឃ្លាតចេញ ផុតស្រះស្រឡះហើយ ចាកធម៌ទាំង ១០ ប្រការនេះ ក៏យ៉ាងនោះដែរ ។

# អដ្ឋកថា

# ថេរវគ្គទី ៤

## វាហុនសូត្រ

[ ៨១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវាហុនសូត្រទី ១ នៃថេរវគ្គទី ៤ ដូច្នេះ បទថា **វិមរិយាទិកតេន** បានដល់ ទម្លាយព្រំដែននៃកិលេស ហើយធ្វើមិនឲ្យមានព្រំដែន ។l៚

**អដ្ឋកថា វាហុនសូត្រទី ១ ចប់**

# សុត្តន្តបិដក

## អានន្ទសូត្រទី ២

[ ៨២ ] គ្រានោះ ព្រះអានន្ទដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង មិនមានសទ្ធា នឹងដល់នូវសេចក្តីចម្រើន លូតលាស់ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកទ្រុស្តសីល នឹងដល់នូវសេចក្តីចម្រើនលូតលាស់ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកចេះដឹងតិច នឹងដល់នូវសេចក្តីចម្រើនលូតលាស់ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកប្រដៅក្រ នឹងដល់នូវសេចក្តីចម្រើនលូតលាស់ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកមានមិត្តអាក្រក់ នឹងដល់នូវសេចក្តីចម្រើនលូតលាស់ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកខ្ជិលច្រអូស នឹងដល់នូវសេចក្តីចម្រើនលូតលាស់ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកមានស្មារតីភ្លេចភ្លាំង នឹងដល់នូវសេចក្តីចម្រើនលូតលាស់

ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកមិនមានសន្តោស នឹងដល់នូវសេចក្តីចម្រើនលូតលាស់ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកប្រាថ្នាលាមក នឹងដល់នូវសេចក្តីចម្រើនលូតលាស់ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាមិច្ឆាទិដ្ឋិ នឹងដល់នូវសេចក្តីចម្រើនលូតលាស់ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ប្រកបដោយធម៌ទាំង ១០ ប្រការនេះ នឹងដល់នូវសេចក្តីចម្រើនលូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកមានសទ្ធា នឹងដល់នូវសេចក្តីចម្រើនលូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ ទើបជាឋានៈ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកមានសីល នឹងដល់នូវសេចក្តីចម្រើនលូតលាស់ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ ទើបជាឋានៈ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកចេះដឹង អ្នកទ្រទ្រង់ព្រះសូត្រ នឹងដល់នូវសេចក្តីចម្រើនលូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ ទើបជាឋានៈ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកប្រដៅងាយ នឹងដល់នូវសេចក្តីចម្រើនលូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ ទើបជាឋានៈ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកមាន

កល្យាណមិត្ត នឹងដល់នូវសេចក្តីចម្រើនលូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ ទើបជាឋានៈ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកមានព្យាយាមប្រារព្ធហើយ នឹងដល់នូវសេចក្តីចម្រើនលូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ ទើបជាឋានៈ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកមានស្មារតីតាំងមាំ នឹងដល់នូវសេចក្តីចម្រើនលូតលាស់ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ ទើបជាឋានៈ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកមានចិត្តសន្តោស នឹងដល់នូវសេចក្តីចម្រើនលូតលាស់ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ ទើបជាឋានៈ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកប្រាជ្ញាតិច នឹងដល់នូវសេចក្តីចម្រើនលូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ ទើបជាឋានៈ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាសម្មាទិដ្ឋិ នឹងដល់នូវសេចក្តីចម្រើនលូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ ទើបជាឋានៈ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ប្រកបដោយធម៌ទាំង ១០ យ៉ាងនេះ នឹងដល់នូវសេចក្តីចម្រើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ ទើបជាឋានៈ ។

# អដ្ឋកថា

## អានន្ទសូត្រ

[ ៨២ ] ក្នុងអានន្ទសូត្រទី ២ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាអានន្ទសូត្រទី ២ ចប់

# សុត្តន្តបិដក

## បុណ្ណិយសូត្រទី ៣

[ ៨៣ ] គ្រានោះ ព្រះបុណ្ណិយៈដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះបុណ្ណិយៈដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុដូចម្តេច បច្ច័យដូចម្តេច ក្នុងកាលខ្លះ ធម្មទេសនាប្រាកដដល់ព្រះតថាគត ក្នុងកាលខ្លះ មិនប្រាកដ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលបុណ្ណិយៈ ភិក្ខុជាអ្នកមានសទ្ធា តែមិនចូលទៅរកដរាបណា ធម្មទេសនាមិនប្រាកដដល់ព្រះតថាគតដរាបនោះ ។ ម្នាលបុណ្ណិយៈ កាលបើភិក្ខុមានសទ្ធាផង ចូលទៅរកផង យ៉ាងនេះ ទើបធម្មទេសនាប្រាកដដល់ព្រះតថាគត ម្នាលបុណ្ណិយៈ ភិក្ខុអ្នកមានសទ្ធាផង ចូលទៅរកផង តែមិនចូលទៅអង្គុយជិត ... ចូលទៅអង្គុយជិតហើយ តែមិនសាកសួរ ... សាកសួរហើយ តែមិនផ្ចង់ត្រចៀកស្តាប់ធម៌ ...

ផ្ទង់ត្រចៀកស្តាប់ធម៌ហើយ តែស្តាប់មិនចាំធម៌ ... ស្តាប់ចាំធម៌ទុកហើយ តែមិនពិចារណានូវអត្ថនៃធម៌ដែលខ្លួនចាំទុកហើយ ... ពិចារណានូវអត្ថនៃធម៌ដែលខ្លួនចាំទុកហើយ តែមិនដឹងអត្ថ មិនដឹងធម៌ ប្រតិបត្តិសមគួរតាមធម៌ ... ដឹងអត្ថ ដឹងធម៌ ប្រតិបត្តិសមគួរតាមធម៌ហើយ តែមិនមានវាចាល្អ ពោលពាក្យដ៏ពីរោះ ប្រកបដោយសម្តីអ្នកក្រុង ដែលជាវាចាច្បាស់លាស់ ជាវាចាឥតទោស ញុំាងជនដទៃឲ្យដឹងនូវអត្ថបាន មានវាចាល្អ ពោលពាក្យពីរោះប្រកបដោយសម្តីអ្នកក្រុង ជាវាចាឥតទោស ញុំាងជនដទៃឲ្យដឹងនូវអត្ថហើយ តែមិនពន្យល់ មិនណែនាំ មិនឲ្យក្លៀវក្លា មិនឲ្យរីករាយដល់ពួកសព្រហ្មចារីបុគ្គល ធម្មទេសនារមែងមិនប្រាកដដល់ព្រះតថាគតដរាបនោះទេ ។ ម្នាលបុណ្ណិយៈ លុះតែភិក្ខុមានសទ្ធា ១ បានចូលមកជិត ១ ចូលទៅអង្គុយជិត ១ សាកសួរ ១ ផ្ទង់ត្រចៀកស្តាប់ធម៌ ១ ស្តាប់ហើយចាំធម៌ទុក ១ ពិចារណានូវអត្ថនៃធម៌ដែលខ្លួនចាំហើយ ១ ដឹងអត្ថ ដឹងធម៌ហើយ ប្រតិបត្តិសមគួរតាមធម៌ ១ មានវាចាល្អ ពោលពាក្យពីរោះ ប្រកបដោយវាចាអ្នកក្រុង ជាវាចាល្អច្បាស់លាស់ ជាវាចាឥតទោស អាចញុំាងជនដទៃឲ្យដឹងសេចក្តី ១ ពន្យល់ណែនាំ ឲ្យក្លាហាន ឲ្យរីករាយដល់ពួកសព្រហ្មចារីបុគ្គល ១ យ៉ាងនេះ ទើបធម្មទេសនាប្រាកដដល់ព្រះតថាគត ។ ម្នាលបុណ្ណិយៈ ធម្មទេសនាដែលប្រកបដោយធម៌ទាំង ១០ យ៉ាងនេះឯង ទើបប្រាកដដល់ព្រះតថាគតដោយពិត ។

# អដ្ឋកថា

## បុណ្ណិយសូត្រ

[ ៨៣ ] ក្នុងបុណ្ណិយសូត្រទី ៣ បទថា **នោ ច បយិរុបាសិតា** ប្រែថា មិនទំនុកបម្រុង ។ល។

**អដ្ឋកថាបុណ្ណិយសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ព្យាករណសូត្រទី ៤

[ ៨៤ ] ក្នុងទីនោះ ព្រះមហាមោគ្គល្លានដ៏មានអាយុហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ បានទទួលស្តាប់ពាក្យរបស់ព្រះមហាមោគ្គល្លានដ៏មានអាយុថា ព្រះករុណាអាវុសោ ។ ព្រះមហា-មោគ្គល្លានដ៏មានអាយុ ក៏ពោលពាក្យដូច្នេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ អួតនូវអរហត្តផលថា អាត្មាអញដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញប្រព្រឹត្តចប់ហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីកិច្ចនេះទៀត មិនមានឡើយ ។ ព្រះតថាគត ឬសាវករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងនូវចិត្ត នៃបុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្តរបស់បុគ្គលដទៃ តែងសួរឈ្ងេចឈ្ងីដេញដោល ពិនិត្យបញ្ជាក់មើលនូវភិក្ខុ

នោះ ។ ភិក្ខុនោះ កាលបើព្រះតថាគត ឬសាវ័ករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងនូវចិត្តនៃបុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្ត របស់បុគ្គលដទៃ សួរឈ្ងេចឈ្ងីដេញដោល ពិនិត្យបញ្ជាក់មើល ក៏ដល់នូវភាវៈទទេ ដល់នូវភាវៈឥតគុណ ដល់នូវសេចក្ដីមិនចម្រើន ដល់នូវសេចក្ដីវិនាស ដល់នូវសេចក្ដីមិនចម្រើន និងសេចក្ដីវិនាស ។ ព្រះតថាគត ឬសាវ័ករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្តនៃបុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្ត របស់បុគ្គលដទៃ ធ្វើទុកក្នុងចិត្ត ព្រោះបានកំណត់ដឹងនូវចិត្ត ដោយចិត្តយ៉ាងនេះថា ហេតុអ្វីអ្នកដ៏មានអាយុនេះ អួតនូវអរហត្តផលថា អាត្មាអញដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តចប់ហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីកិច្ចនេះទៀត មិនមានឡើយ ។ ព្រះតថាគត ឬសាវ័ករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្តនៃបុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្ត របស់បុគ្គលដទៃ ក៏ដឹងច្បាស់នូវបុគ្គលនោះ ព្រោះបានកំណត់ដឹងនូវចិត្តដោយចិត្ត យ៉ាងនេះថា អ្នកដ៏មានអាយុនេះ ជាអ្នកមានសេចក្ដីក្រោធ មានចិត្តត្រូវសេចក្ដីក្រោធរួបរឹតនៅដោយច្រើន ចំណែកខាងការរួបរឹតដោយសេចក្ដីក្រោធនេះ ជាសេចក្ដីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមានឧបនាហៈ មានចិត្តត្រូវឧបនាហៈ រួបរឹតនៅដោយច្រើន

ចំណែកខាងការរួបរឹត ដោយឧបនាហៈនេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមានមក្ខៈ មានចិត្តត្រូវមក្ខៈរួបរឹតនៅដោយច្រើន ចំណែកខាងការរួបរឹតដោយមក្ខៈនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមានបឡាសៈ មានចិត្តត្រូវបឡាសៈ រួបរឹតនៅដោយច្រើន ចំណែកខាងការរួបរឹតដោយបឡាសៈនេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមានឫស្យា មានចិត្តត្រូវឫស្យារួបរឹតនៅដោយច្រើន ចំណែកខាងការរួបរឹតដោយឫស្យានេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមានមច្ឆរិយៈ មានចិត្តត្រូវមច្ឆរិយៈរួបរឹតនៅដោយច្រើន ចំណែកខាងការរួបរឹតដោយមច្ឆរិយៈនេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមានការអួត មានចិត្តត្រូវសាឋេយ្យៈ រួបរឹតនៅដោយច្រើន ចំណែកខាងការរួបរឹតដោយសាឋេយ្យៈនេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមានមាយា មានចិត្តត្រូវមាយារួបរឹតនៅដោយច្រើន ចំណែកខាងការរួបរឹតដោយមាយានេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមានសេចក្តីប្រាថ្នាលាមក មានចិត្តត្រូវសេចក្តី

ប្រាថ្នាលាមករួបរឹតនៅដោយច្រើន ចំណែកខាងការរួបរឹតដោយសេចក្តីប្រាថ្នាលាមកនេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកភ្លេចស្មារតី ដល់នូវការផ្តាកទុកនូវសេចក្តីព្យាយាមក្នុងចន្លោះ ដោយការបាននូវគុណវិសេសដ៏ថយថោក ក្នុងកិច្ចដែលខ្លួនត្រូវធ្វើតទៅទៀត ចំណែកខាងដំណើរដែលផ្អាកនូវសេចក្តីព្យាយាមក្នុងចន្លោះនេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ ម្នាលអាវុសោទាំងឡាយ ពាក្យថា ភិក្ខុនោះឯង មិនបានលះបង់នូវធម៌ទាំង ១០ នេះ នឹងដល់នូវការចម្រើនលូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអាវុសោទាំងឡាយ ពាក្យថា ភិក្ខុនោះឯង លះបង់នូវធម៌ទាំង ១០ នេះ នឹងដល់នូវការចម្រើនលូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ ទើបជាឋានៈ ។

# អដ្ឋកថា

## ព្យាករណសូត្រ

[ ៨៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងព្យាករណសូត្រទី ៤ ដូចតទៅនេះ បទថា **ឈាយី សមាបត្តិកុសលោ** បានដល់ ដល់ព្រមដោយឈានទាំងឡាយ និងដែលឈ្លាសក្នុងសមាបត្តិ ។ បទថា **ភេណំ** បានដល់ ការសាបសូន្យ

*ប្រយោជន៍ ។ បទថា* **វិចិនំ** *បានដល់ ការសោបសូន្យនូវគុណ ការផុតគុណ ។ ន័យម្យ៉ាងទៀត ប្រៀបដូចចូលដល់ព្រៃធំ ដែលហៅថា* **គហណ** *និងព្រៃធំ ដែលហៅថា* **វិចិន។** *បទថា* **អនយំ** *បានដល់ សេចក្តីមិនចម្រើន ។ បទថា* **ព្យសនំ** *បានដល់ សេចក្តីវិនាស ។ បទថា* **អនយព្យសនំ** *បានដល់ ការមិនចម្រើន គឺវិនាស ។ បទថា* **កឹ នុ ខោ** *ប្រែថា ព្រោះហេតុអ្វី ។*

អដ្ឋកថា ព្យាករណសូត្រទី ៤ ចប់

# សុត្តន្តបិដក

## កត្ថីសូត្រទី ៥

[ ៨៥ ] *សម័យមួយ ព្រះមហាចុន្ទៈដ៏មានអាយុ គង់ក្នុងសហជាតិ-ប្រទេស ក្នុងដែនចេតី ។ ក្នុងទីនោះឯង ព្រះមហាចុន្ទៈដ៏មានអាយុ ហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ បានទទួលស្តាប់ពាក្យ ព្រះមហាចុន្ទៈដ៏មានអាយុថា អាវុសោ ។ ព្រះមហាចុន្ទៈដ៏មានអាយុ បានសម្តែងដូច្នេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ តែងពោលអួតក្នុងអធិគមៈ ( ធម៌ដែលគួរត្រាស់ដឹង ) ថា ខ្ញុំចូលកាន់បឋម-ជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់ទុតិយជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់*

តតិយជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់ចតុត្ថជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់អាកាសានញ្ចាយតនជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់វិញ្ញាណញ្ចា-យតនជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់អាកិញ្ចញ្ញាយតនជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញក៏បាន ។ ព្រះតថាគត ឬសាវ័ករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្តនៃបុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្តរបស់បុគ្គលដទៃ សួរឈ្មេចឈ្មីដេញដោល ពិនិត្យបញ្ជាក់មើលចំពោះភិក្ខុនោះ ។ ភិក្ខុនោះ កាលព្រះតថាគត ឬសាវ័ករបស់ព្រះតថាគតដែលជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្តបុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្តបុគ្គលដទៃ កាលសួរឈ្មេចឈ្មីដេញដោល ពិនិត្យបញ្ជាក់មើលទៅ ក៏ដល់នូវភាវៈទទេ ដល់នូវភាវៈឥតគុណ ដល់នូវសេចក្តីមិនចម្រើន ដល់នូវសេចក្តីវិនាស ដល់នូវសេចក្តីមិនចម្រើន និងសេចក្តីវិនាស ។ ព្រះតថាគត ឬសាវ័ករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្តនៃបុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្តបុគ្គលដទៃ រមែងកំណត់ទុកក្នុងចិត្ត ចំពោះភិក្ខុនោះ ព្រោះបានកំណត់ដឹងនូវចិត្ត ដោយចិត្តយ៉ាងនេះថា ហេតុអ្វីអ្នកដ៏មានអាយុនេះ តែងពោលអួតចំពោះអធិគមធម៌ថា ខ្ញុំចូលទៅកាន់បឋមជ្ឈានក៏បាន ចេញក៏បាន ។បេ។ ខ្ញុំចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញក៏បាន ។ ព្រះតថាគត ឬសាវ័ក

របស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្តនៃបុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្តបុគ្គលដទៃ រមែងកំណត់ដឹងចិត្តភិក្ខុនោះដោយចិត្តយ៉ាងនេះថា អ្នកដ៏មានអាយុនេះ ជាអ្នកធ្វើឲ្យដាច់ ធ្វើឲ្យធ្លុះធ្លាយ ធ្វើឲ្យពពាល ធ្វើឲ្យពព្រុស ធ្វើមិនឲ្យទៀងទាត់ ប្រព្រឹត្តមិនទៀងត្រង់ ក្នុងសីលទាំងឡាយអស់កាលវែង ។ អ្នកដ៏មានអាយុនេះ ជាអ្នកទ្រុស្តសីល ចំណែកខាងភាពនៃបុគ្គលទ្រុស្តសីលនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមិនមានសទ្ធា មិនមានអាចារ ចំណែកខាងការមិនមានសទ្ធានេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកចេះដឹងតិច មិនមានអាចារ ចំណែកខាងការចេះដឹងតិចនេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាបុគ្គលដែលគេប្រដៅក្រ មិនមានអាចារ ចំណែកខាងភាពនៃបុគ្គលប្រដៅក្រនេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ មានមិត្តអាក្រក់ ចំណែកខាងភាពនៃបុគ្គលមានមិត្តអាក្រក់នេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាបុគ្គលខ្ជិលច្រអូស ចំណែកខាងការខ្ជិលច្រអូសនេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកភ្លេចស្មារតី ចំណែកខាងការ

ភ្លេចស្មារតីនេះ ជាសេចក្ដីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាបុគ្គលកុហក ចំណែកខាងការកុហកនេះ ជាសេចក្ដីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាបុគ្គលដែលគេចិញ្ចឹមក្រ ចំណែកខាងភាពនៃបុគ្គលដែលគេចិញ្ចឹមក្រនេះ ជាសេចក្ដីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកឥតបញ្ញា ចំណែកខាងភាពនៃបុគ្គលឥតបញ្ញានេះ ជាសេចក្ដីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ ម្នាលអាវុសោទាំងឡាយ ដូចជា សម្លាញ់ម្នាក់ និយាយទៅនឹងសម្លាញ់យ៉ាងនេះថា ម្នាលសម្លាញ់ បើអ្នកត្រូវការចំពោះធនកិច្ចដោយទ្រព្យក្នុងកាលណា អ្នកគប្បីប្រាប់ធនកិច្ច ( នោះ ) ដល់ខ្ញុំៗ នឹងឲ្យទ្រព្យដល់អ្នក ។ សម្លាញ់នោះ កាលបើធនកិច្ចណាមួយកើតឡើង ក៏និយាយទៅនឹងសម្លាញ់យ៉ាងនេះថា ម្នាលសម្លាញ់ ខ្ញុំត្រូវការដោយទ្រព្យ ចូរអ្នកឯងឲ្យទ្រព្យ ( នោះ ) មកខ្ញុំ ។ សម្លាញ់នោះក៏និយាយយ៉ាងនេះថា ម្នាលសម្លាញ់ បើដូច្នោះ អ្នកចូរជីកក្នុងទីនេះចុះ ។ សម្លាញ់នោះ កាលជីកក្នុងទីនោះទៅក៏មិនបាន ។ សម្លាញ់នោះ និយាយយ៉ាងនេះថា ម្នាលសម្លាញ់ អ្នកឯងនិយាយឡេះឡោះនឹងខ្ញុំ ម្នាលសម្លាញ់ អ្នកឯងនិយាយពាក្យទទេនឹងខ្ញុំថា អ្នកឯងចូរជីកក្នុងទីនេះចុះ ។ សម្លាញ់នោះនិយាយយ៉ាងនេះថា ម្នាលសម្លាញ់ ខ្ញុំមិននិយាយឡេះឡោះនឹងអ្នកទេ ខ្ញុំមិននិយាយពាក្យទទេ នែសម្លាញ់ បើ

ដូច្នោះ អ្នកឯងចូរជីកក្នុងទីនេះដូច្នេះ ។ សម្លាញ់នោះ កាលបើជីកក្នុងទីនោះម្តងទៀត ក៏នៅតែមិនបាន ។ សម្លាញ់នោះនិយាយយ៉ាងនេះថា ម្នាលសម្លាញ់ អ្នកឯងនិយាយឡេះឡោះនឹងខ្ញុំ ម្នាលសម្លាញ់ អ្នកឯងនិយាយពាក្យទទេនឹងខ្ញុំថា អ្នកឯងចូរជីកក្នុងទីនេះចុះ ។ សម្លាញ់នោះនិយាយយ៉ាងនេះថា ម្នាលសម្លាញ់ ខ្ញុំមិននិយាយឡេះឡោះនឹងអ្នកទេ ខ្ញុំមិននិយាយទទេទេ ម្នាលសម្លាញ់ បើដូច្នោះ អ្នកឯងចូរជីកក្នុងទីនេះចុះ ។ សម្លាញ់នោះ កាលជីកក្នុងទីនោះម្តងទៀត ក៏នៅតែមិនបាន ។ សម្លាញ់នោះ និយាយយ៉ាងនេះថា ម្នាលសម្លាញ់ អ្នកឯងនិយាយឡេះឡោះនឹងខ្ញុំ ម្នាលសម្លាញ់ អ្នកឯងនិយាយពាក្យទទេនឹងខ្ញុំថា អ្នកឯងចូរជីកក្នុងទីនេះចុះ ។ សម្លាញ់នោះ និយាយយ៉ាងនេះថា ម្នាលសម្លាញ់ ខ្ញុំមិននិយាយឡេះឡោះនឹងអ្នកទេ ខ្ញុំមិននិយាយពាក្យទទេនឹងអ្នកទេ ប៉ុន្តែ ខ្ញុំដល់នូវភាពជាអ្នកឆ្កួត ប្រែប្រួលចិត្ត សេចក្តីនេះ យ៉ាងណាមិញ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកពោលអួតក្នុងអធិគមធម៌ថា ខ្ញុំចូលកាន់បឋមជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់ទុតិយជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់តតិយជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់ចតុត្ថជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់អាកាសានញ្ចាយតនជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់វិញ្ញាណញ្ចាយតនជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់អាកិញ្ចញ្ញាយតនជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញក៏បាន ។ ព្រះតថាគត ឬ

សាវ័ករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្តនៃបុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្តរបស់បុគ្គលដទៃ តែងសួរឈ្លេចឈ្លី ដេញដោល ពិនិត្យមើលនូវភិក្ខុនោះ ។ ភិក្ខុនោះ កាលបើព្រះតថាគត ឬសាវ័ករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្តនៃបុគ្គលដទៃ ឈ្លាសក្នុងវារៈចិត្តរបស់បុគ្គលដទៃ សួរឈ្លេចឈ្លី ដេញដោល ពិនិត្យបញ្ឆាក់មើលទៅ ក៏ដល់នូវភាវៈទទេ ដល់នូវភាវៈឥតគុណ ដល់នូវសេចក្តីមិនចម្រើន ដល់នូវសេចក្តីវិនាស ដល់នូវសេចក្តីមិនចម្រើន និងសេចក្តីវិនាស ។ ព្រះតថាគត ឬសាវ័ករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្តនៃបុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្តរបស់បុគ្គលដទៃ ធ្វើទុកក្នុងចិត្តចំពោះភិក្ខុនោះ ព្រោះបានកំណត់ដឹងនូវចិត្ត ដោយចិត្តយ៉ាងនេះថា ហេតុអ្វីអ្នកដ៏មានអាយុនេះ តែងពោលអួតក្នុងអធិគមធម៌ថា ខ្ញុំចូលកាន់បឋមជ្ឈានក៏បាន ចេញក៏បាន ។បេ។ ខ្ញុំចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញក៏បាន ។ ព្រះតថាគត ឬសាវ័ករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្តនៃបុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្ត របស់បុគ្គលដទៃ រមែងកំណត់ដឹងនូវចិត្តភិក្ខុនោះ ដោយចិត្តយ៉ាងនេះថា អ្នកដ៏មានអាយុនេះ ជាអ្នកធ្វើឲ្យដាច់ ធ្វើឲ្យធ្លុះធ្លាយ ធ្វើឲ្យពពាល ធ្វើឲ្យពព្រុស ធ្វើមិនទៀងទាត់ ប្រព្រឹត្តមិនទៀងត្រង់ ក្នុងសីលទាំងឡាយអស់កាលវែង ។ អ្នកដ៏មានអាយុ

នេះ ជាបុគ្គលទ្រុស្តសីល ចំណែកខាងភាពនៃបុគ្គលទ្រុស្តសីលនេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមិនមានសទ្ធា ចំណែកខាងការមិនមានសទ្ធានេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាបុគ្គលមានការចេះដឹងតិច មិនមានអាចារ ចំណែកខាងការចេះដឹងតិចនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាបុគ្គលដែលគេប្រដៅក្រ ចំណែកខាងភាវៈនៃបុគ្គលគេប្រដៅក្រនេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាបុគ្គលមានមិត្តអាក្រក់ ចំណែកខាងភាពនៃបុគ្គលមានមិត្តអាក្រក់នេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាបុគ្គលខ្ជិលច្រអូស ចំណែកខាងការខ្ជិលច្រអូសនេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកភ្លេចស្មារតី ចំណែកខាងការភ្លេចស្មារតីនេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាបុគ្គលកុហក ចំណែកខាងការកុហកនេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាបុគ្គលដែលគេចិញ្ចឹមក្រ ចំណែកខាងភាពនៃបុគ្គលដែលគេចិញ្ចឹមក្រនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏

មានអាយុនេះ ជាបុគ្គលអប្បបញ្ញា ចំណែកខាងភាពនៃបុគ្គលអប្បបញ្ញានេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ក៏យ៉ាង នោះឯង ។ ម្នាលអាវុសោទាំងឡាយ ពាក្យថា ភិក្ខុនោះឯង មិនលះបង់នូវ ធម៌ទាំង ១០ ប្រការនេះ នឹងដល់នូវការចម្រើន លូតលាស់ ធំទូលាយ ក្នុង ធម្មវិន័យ ដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអាវុសោទាំងឡាយ ពាក្យ ថា បើភិក្ខុនោះឯង លះបង់នូវធម៌ទាំង ១០ ប្រការនេះ នឹងដល់នូវសេចក្តី ចម្រើនលូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ ទើបជាឋានៈ ។

# អដ្ឋកថា

## កត្ថីសូត្រ

[ ៨៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកត្ថីសូត្រទី ៥ ដូចតទៅនេះ បទថា **កត្ថី ហោតិ វិកត្ថី** ប្រែថា ជាអ្នកមានប្រក្រតីពោល មានប្រក្រតីអួត រមែងបើកបង្ហាញ ។ បទថា **ន សតតការី** ប្រែថា មិនធ្វើជាប់គ្នា ៕

**អដ្ឋកថា កត្ថីសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## អញ្ញសូត្រទី ៦

[ ៨៦ ] សម័យមួយ ព្រះមហាកស្សបដ៏មានអាយុ គង់ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ ក្នុងទីនោះឯង ព្រះមហាកស្សប ដ៏មានអាយុ ហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោភិក្ខុទាំងឡាយ ។ ភិក្ខុ ទាំងនោះ បានទទួលស្តាប់ពាក្យព្រះមហាកស្សប ដ៏មានអាយុថា ករុណា អាវុសោ ។ ព្រះមហាកស្សបដ៏មានអាយុ បានពោលពាក្យដូច្នេះថា ម្នាល អាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពោលអួតអរហត្តផលថា ខ្ញុំដឹងថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញប្រព្រឹត្តស្រេចហើយ សោឡស-កិច្ច អាត្មាអញធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅ ដើម្បី សោឡសកិច្ចនេះទៀត មិនមានឡើយ ។ ព្រះតថាគត ឬសាវ័ករបស់ព្រះ តថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្តនៃ បុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្តបុគ្គលដទៃ តែងសួរឈ្ងេចឈ្ងីដេញដោល ពិនិត្យបញ្ឆោក់មើលនូវភិក្ខុនោះ ។ ភិក្ខុនោះ កាលបើព្រះតថាគត ឬសាវ័ក របស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹង ចិត្តបុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្តរបស់បុគ្គលដទៃ សួរឈ្ងេចឈ្ងីដេញ ដោល ពិនិត្យបញ្ឆោក់មើល ក៏ដល់នូវភាវៈទទេ ដល់នូវភាវៈឥតគុណ ដល់ នូវសេចក្តីមិនចម្រើន ដល់នូវសេចក្តីវិនាស ដល់នូវសេចក្តីមិនចម្រើន និង សេចក្តីវិនាស ។ ព្រះតថាគត ឬសាវ័ករបស់ព្រះតថាគត ជាអ្នកមានឈាន

ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្តនៃបុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្តរបស់បុគ្គលដទៃ រមែងកំណត់ធ្វើទុកក្នុងចិត្ត នូវភិក្ខុនោះដោយចិត្តយ៉ាងនេះថា ដូចម្តេចក៏អ្នកដ៏មានអាយុនេះ ពោលអួតអរហត្តផលថា ខ្ញុំដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញប្រព្រឹត្តស្រេចហើយ សោឡសកិច្ច អាត្មាអញធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះ មិនមានឡើយ ។ ព្រះតថាគត ឬសាវករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្តនៃបុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្តរបស់បុគ្គលដទៃ រមែងកំណត់ដឹងនូវចិត្តភិក្ខុនោះ ដោយចិត្តយ៉ាងនេះថា អ្នកដ៏មានអាយុនេះ ជាអ្នកស្មានហួសហេតុពោលថា ខ្លួនបានគុណវិសេសដោយទៀងទាត់ សម្គាល់ថាដល់ហើយក្នុងធម៌ដែលមិនទាន់បានដល់ សម្គាល់ថា ធ្វើហើយ ក្នុងធម៌ដែលខ្លួនមិនទាន់ធ្វើ សម្គាល់ថា ត្រាស់ដឹងហើយ ក្នុងធម៌ដែលខ្លួនមិនទាន់ត្រាស់ដឹង ពោលអួតអរហត្តផល ដោយការស្មានហួសហេតុថា ខ្ញុំដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញប្រព្រឹត្តរួចហើយ សោឡសកិច្ច អាត្មាអញធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ ព្រះតថាគត ឬសាវករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្តនៃបុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្តរបស់បុគ្គលដទៃ រមែងកំណត់ធ្វើទុកក្នុងចិត្តនូវភិក្ខុនោះ កំណត់ដោយចិត្ត

យ៉ាងនេះថា អ្នកដ៏មានអាយុនេះ អាស្រ័យហេតុដូចម្តេចហ្ន៎ បានជាអ្នកស្មានហួសហេតុ ពោលថា ខ្លួនបានគុណវិសេសដោយទៀងទាត់ ហើយសម្គាល់ថា ដល់ក្នុងធម៌ ដែលខ្លួនមិនទាន់ដល់ សម្គាល់ថា ធ្វើហើយ ក្នុងធម៌ដែលខ្លួនមិនទាន់ធ្វើ សម្គាល់ថា ត្រាស់ដឹងហើយ ក្នុងធម៌ដែលខ្លួនមិនទាន់ត្រាស់ដឹង ហើយពោលអួតអរហត្តផល ដោយការស្មានហួសហេតុថា ខ្ញុំដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញប្រព្រឹត្តស្រេចហើយ សោឡសកិច្ច អាត្មាអញធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ព្រះតថាគត ឬសាវករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្តនៃបុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្តរបស់បុគ្គលដទៃ រមែងកំណត់ដឹងនូវចិត្តភិក្ខុនោះ ដោយចិត្តយ៉ាងនេះថា អ្នកដ៏មានអាយុនេះ ជាអ្នកចេះដឹងច្រើន ជាអ្នកចេះចាំនូវសូត្រ សន្សំនូវសូត្រ ធម៌ទាំងឡាយណា មានលម្អបទដើម លម្អបទកណ្តាល លម្អបទចុង ប្រកាសមគ្គព្រហ្មចរិយៈ ព្រមទាំងអត្ថ និងព្យញ្ជនៈ ដ៏បរិសុទ្ធបរិបូណ៌គ្រប់ទាំងអស់ ធម៌មានសភាពដូច្នោះ បុគ្គលនោះជាអ្នកចេះដឹងច្រើន ចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ដោយចិត្ត ចាក់ធ្លុះចំពោះ ដោយយល់ឃើញ ព្រោះហេតុនោះ អ្នកដ៏មានអាយុនេះ ជាអ្នកស្មានហួសហេតុពោលថា ខ្លួនបានគុណវិសេសដោយទៀងទាត់ សម្គាល់ថា ដល់ហើយ ក្នុងធម៌ដែលខ្លួនមិនទាន់ដល់ សម្គាល់ថា ធ្វើហើយ ក្នុងធម៌ដែល

ខ្ញុំមិនបានធ្វើសម្គាល់ថា ត្រាស់ដឹងហើយ ក្នុងធម៌ដែលខ្ញុំមិនបានត្រាស់ដឹង ទើបពោលអួតអរហត្តផល ដោយការស្មានហួសហេតុថា ខ្ញុំដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញប្រព្រឹត្តស្រេចហើយ សោឡសកិច្ច អាត្មាអញធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ព្រះតថាគត ឬសាវករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្តនៃបុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្តរបស់បុគ្គលដទៃ រមែងកំណត់ដឹងនូវចិត្តភិក្ខុនោះ ដោយចិត្តយ៉ាងនេះថា អ្នកដ៏មានអាយុនេះ មានអភិជ្ឈា មានចិត្តត្រូវអភិជ្ឈារួបរឹតច្រើន ចំណែកខាងការរួបរឹតដោយអភិជ្ឈានេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមានព្យាបាទ មានចិត្តត្រូវព្យាបាទរួបរឹតច្រើន ចំណែកខាងការរួបរឹត ដោយព្យាបាទនេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ មានថីនមិទ្ធៈ មានចិត្តត្រូវថីនមិទ្ធៈរួបរឹតច្រើន ចំណែកខាងការរួបរឹតដោយថីនមិទ្ធៈនេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមានឧទ្ធច្ចៈ មានចិត្តត្រូវឧទ្ធច្ចៈរួបរឹតច្រើន ចំណែកខាងការរួបរឹតដោយឧទ្ធច្ចៈនេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមានវិចិកិច្ឆា មានចិត្តត្រូវវិចិកិច្ឆារួបរឹតច្រើន

ចំណែកខាងការរួបរឹតដោយវិចិកិច្ឆានេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមានការងារជាទីត្រេកអរ ត្រេកអរហើយក្នុងការងារ ប្រកបរឿយៗ នូវសេចក្តីត្រេកអរក្នុងការងារ ចំណែកខាងភាពនៃបុគ្គលដែលមានការងារជាទីត្រេកអរនេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមានតិរច្ឆានកថាជាទីត្រេកអរ ត្រេកអរហើយក្នុងតិរច្ឆានកថា ប្រកបរឿយៗ នូវសេចក្តីត្រេកអរក្នុងតិរច្ឆានកថា ចំណែកខាងភាពនៃបុគ្គលមានតិរច្ឆានកថាជាទីត្រេកអរនេះ ជាសេចក្តីសាបសូន្យក្នុងធម្ម-វិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមានការដេកលក់ជាទីត្រេកអរ ត្រេកអរហើយក្នុងការដេកលក់ ប្រកបរឿយៗ នូវសេចក្តីត្រេកអរក្នុងការដេកលក់ ចំណែកខាងភាពនៃបុគ្គលមានការលក់ជាទីត្រេកអរនេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមានសេចក្តីត្រេកអរក្នុងការប្រឡូកប្រឡំដោយពួក ត្រេកអរហើយក្នុងការប្រឡូកប្រឡំដោយពួក ប្រកបរឿយៗ នូវសេចក្តីត្រេកអរក្នុងការប្រឡូកប្រឡំដោយពួក ចំណែកខាងភាពនៃសេចក្តីត្រេកអរ ក្នុងការប្រឡូកប្រឡំដោយពួកនេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកភ្លេចស្មារតី ដល់នូវការផ្អាកព្យាយាមទុកក្នុងចន្លោះ ដោយការបានគុណវិសេស

ដ៏ថោកថយ ក្នុងកិច្ចដែលខ្លួនត្រូវធ្វើតទៅទៀត ចំណែកខាងការផ្អាកសេចក្តីព្យាយាមក្នុងចន្លោះនេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ ម្នាលអាវុសោទាំងឡាយ ពាក្យថា ភិក្ខុនោះឯង មិនលះបង់នូវធម៌ទាំង ១០ ប្រការនេះ នឹងដល់នូវសេចក្តីចម្រើន លូតលាស់ធំទូលាយក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអាវុសោទាំងឡាយ ពាក្យថា ភិក្ខុនោះឯង លះបង់នូវធម៌ទាំង ១០ ប្រការនេះ នឹងដល់នូវសេចក្តីចម្រើន លូតលាស់ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ ទើបជាឋានៈ ។

# អដ្ឋកថា

## អញ្ញាសូត្រ

[ ៨៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអញ្ញាសូត្រទី ៦ ដូចតទៅនេះ បទថា **អធិមានិកោ** បានដល់ ប្រកបដោយការសម្គាល់ថា សម្រេចហើយក្នុងធម៌ដែលមិនសម្រេច ។ បទថា **អធិមានសច្ចោ** បានដល់ សម្គាល់ថា សម្រេចហើយ ទើបពោលដោយសច្ចៈ ។ល។

**អដ្ឋកថា អញ្ញាសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## អធិករណសូត្រទី ៧

[ ៨៧ ] ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ប្រារព្ធនូវកាឡកភិក្ខុ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលស្ដាប់ព្រះពុទ្ធដីកា ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើអធិករណ៍ មិនពោលសរសើរការរម្ងាប់អធិករណ៍ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកធ្វើអធិករណ៍ មិនពោលសរសើរការរម្ងាប់អធិករណ៍ ដោយហេតុណា នេះឯងជាធម៌មិនប្រព្រឹត្តទៅ ដើម្បីសេចក្ដីស្រឡាញ់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្ដីគោរព មិនប្រព្រឹត្តទៅ ដើម្បីភាពជាសមណៈ មិនប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមិនប្រាថ្នានូវសិក្ខា មិនពោលសរសើរការសមាទាននូវសិក្ខា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមិនមានសេចក្ដីប្រាថ្នាក្នុងសិក្ខា មិនពោលសរសើរការសមាទាននូវសិក្ខា ដោយហេតុណា នេះឯងជាធម៌មិនប្រព្រឹត្តទៅ ដើម្បីសេចក្ដីស្រឡាញ់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្ដីគោរព មិនប្រព្រឹត្តទៅ ដើម្បីសេចក្ដីចម្រើន មិនប្រព្រឹត្តទៅ ដើម្បីភាពជាសមណៈ មិនប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានសេចក្ដីប្រាថ្នាលាមក មិនពោលសរសើរការកម្ចាត់បង់នូវសេចក្ដីប្រាថ្នា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសេចក្ដីប្រាថ្នាលាមក មិនពោលសរសើរការកម្ចាត់បង់នូវសេចក្ដី

ប្រាថ្នា ដោយហេតុណា នេះឯងជាធម៌មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីស្រឡាញ់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីគោរព មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើន មិនប្រព្រឹត្តទៅ ដើម្បីភាពជាសមណៈ មិនប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានសេចក្តីក្រោធ មិនពោលសរសើរការកម្ចាត់បង់សេចក្តីក្រោធ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសេចក្តីក្រោធ មិនពោលសរសើរការកម្ចាត់បង់សេចក្តីក្រោធ ដោយហេតុណា នេះឯងជាធម៌មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីស្រឡាញ់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីគោរព មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើន មិនប្រព្រឹត្តទៅ ដើម្បីភាពជាសមណៈ មិនប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកលុបគុណគេ មិនពោលសរសើរការកម្ចាត់បង់នូវសេចក្តីលុបគុណគេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកលុបគុណគេ មិនពោលសរសើរការកម្ចាត់បង់ នូវសេចក្តីលុបគុណគេ ដោយហេតុណា នេះឯងជាធម៌មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីស្រឡាញ់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីគោរព មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើន មិនប្រព្រឹត្តទៅ ដើម្បីភាពជាសមណៈ មិនប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកអួតអាង មិនពោលសរសើរការកម្ចាត់បង់នូវការអួតអាង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកអួតអាង មិនពោលសរសើរការកម្ចាត់បង់នូវការអួតអាង ដោយហេតុណា នេះឯងជាធម៌

មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីស្រឡាញ់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីគោរព មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើន មិនប្រព្រឹត្តទៅ ដើម្បីភាពជាសមណៈ មិនប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានមាយា មិនពោលសរសើរ ការកម្ចាត់បង់នូវមាយា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានមាយា មិនពោលសរសើរ នូវការកម្ចាត់នូវមាយា ដោយហេតុណា នេះឯង ជាធម៌មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីស្រឡាញ់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីគោរព មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើន មិនប្រព្រឹត្តទៅ ដើម្បីភាពជាសមណៈ មិនប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកប្រកបដោយជាតិ ជាអ្នកមិនពិចារណានូវធម៌ មិនពោលសរសើរការពិចារណានូវធម៌ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រកបដោយជាតិ ជាអ្នកមិនពិចារណានូវធម៌ មិនពោលសរសើរការពិចារណានូវធម៌ ដោយហេតុណា នេះឯង ជាធម៌មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីស្រឡាញ់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីគោរព មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើន មិនប្រព្រឹត្តទៅ ដើម្បីភាពជាសមណៈ មិនប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនមានការពួនសម្ងំ មិនពោលសរសើរការពួនសម្ងំ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមិនពួនសម្ងំ មិនពោលសរសើរការពួនសម្ងំ ដោយហេតុណា នេះឯងជាធម៌មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីស្រឡាញ់ មិនប្រព្រឹត្ត

ទៅ ដើម្បីសេចក្តីគោរព មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើន មិនប្រព្រឹត្តទៅ ដើម្បីភាពជាសមណៈ មិនប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនធ្វើបដិសណ្ឋារៈ ដល់សព្រហ្មចារីបុគ្គលទាំងឡាយ មិនពោលសរសើរបុគ្គលអ្នកធ្វើបដិសណ្ឋារៈ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមិនធ្វើបដិសណ្ឋារៈ ដល់ពួកសព្រហ្មចារីបុគ្គល មិនពោលសរសើរបុគ្គល អ្នកធ្វើបដិសណ្ឋារៈ ដោយហេតុណា នេះឯងជាធម៌មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីស្រឡាញ់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីគោរព មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើន មិនប្រព្រឹត្តទៅ ដើម្បីភាពជាសមណៈ មិនប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសភាពយ៉ាងនេះ ពិតជាមានសេចក្តីប្រាថ្នា កើតឡើងយ៉ាងនេះថា ធ្វើម្តេចហ្ន៎ ពួកសព្រហ្មចារីបុគ្គល គប្បីធ្វើសក្ការៈ គោរព រាប់អាន បូជាចំពោះអាត្មាអញ អេះ ។ ប៉ុន្តែ ពួកសព្រហ្មចារីបុគ្គល មិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជាចំពោះភិក្ខុនោះឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ពួកសព្រហ្មចារីជាវិញ្ញូជន រមែងពិចារណាឃើញច្បាស់ នូវអកុសលធម៌ដ៏លាមកទាំងនោះ ដែលភិក្ខុទាំងនោះមិនទាន់លះបង់ ។ ម្នាលភិក្ខុទាំងឡាយ ដូចសេះល្ងង់ខ្លៅ ពិតជាមានសេចក្តីប្រាថ្នា កើតឡើងយ៉ាងនេះថា ធ្វើម្តេចហ្ន៎ ពួកមនុស្សគប្បីតម្កើងអញ ក្នុងទីជាសេះអាជានេយ្យផង ឲ្យអញបរិភោគនូវភោជន របស់សេះអាជានេយ្យផង

ជុសខាត់អញ ដូចជា ជុសខាត់សេះអាជានេយ្យផង ។ តែថា ពួកមនុស្ស មិនតម្កល់នូវសេះនោះ ក្នុងទីនៃសេះអាជានេយ្យ មិនឲ្យបរិភោគនូវភោជន របស់សេះអាជានេយ្យ មិនជុសខាត់ ដូចជាការជុសខាត់សេះអាជានេយ្យទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ពួកមនុស្សជា អ្នកដឹង រមែងពិចារណាឃើញច្បាស់ នូវអំពើវង្វេង កៀចក្រាញ កកិចកកុច វៀចវេរទាំងនោះ ដែលសេះនោះមិនទាន់លះបង់ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចភិក្ខុមានសភាពយ៉ាងនេះ ពិតជាមាន សេចក្តីប្រាថ្នា កើតឡើងយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ពួកសព្រហ្មចារីបុគ្គល គប្បីធ្វើសក្ការៈ គោរព រាប់អាន បូជាចំពោះអាត្មាអញ អេះ តែបើទុកជា ដូច្នោះ ពួកសព្រហ្មចារីបុគ្គល ក៏មិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិន បូជាចំពោះភិក្ខុនោះឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំង-ឡាយ ព្រោះថា ពួកសព្រហ្មចារីជាវិញ្ញូជន រមែងពិចារណាឃើញច្បាស់ នូវ អកុសលធម៌ដ៏លាមកទាំងនោះ ដែលភិក្ខុនោះ មិនទាន់លះបង់ ។ ម្នាលភិក្ខុ ទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនធ្វើអធិករណ៍ ពោលសរសើរការ រម្ងាប់អធិករណ៍ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមិនធ្វើអធិករណ៍ ពោល សរសើរការរម្ងាប់អធិករណ៍ ដោយហេតុណា នេះឯង ជាធម៌តែប្រព្រឹត្តទៅ ដើម្បីសេចក្តីស្រឡាញ់ ដើម្បីសេចក្តីគោរព ដើម្បីសេចក្តីចម្រើន ដើម្បីភាព ជាសមណៈ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត

ភិក្ខុជាអ្នកប្រាថ្នាក្នុងសិក្ខា ពោលសរសើរការសមាទានសិក្ខា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រាថ្នាក្នុងសិក្ខា ពោលសរសើរការសមាទានសិក្ខា ដោយហេតុណា នេះឯង ជាធម៌ប្រព្រឹត្តទៅ ដើម្បីសេចក្តីស្រឡាញ់ ដើម្បីសេចក្តីគោរព ដើម្បីសេចក្តីចម្រើន ដើម្បីភាពជាសមណៈ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកប្រាថ្នាតិច ពោលសរសើរការកម្ចាត់បង់សេចក្តីប្រាថ្នា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រាថ្នាតិច ពោលសរសើរការកម្ចាត់បង់នូវសេចក្តីប្រាថ្នា ដោយហេតុណា នេះឯងជាធម៌ ។បេ។ ប្រព្រឹត្តទៅដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនក្រោធ ពោលសរសើរការកម្ចាត់បង់សេចក្តីក្រោធ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមិនក្រោធ ពោលសរសើរការកម្ចាត់បង់សេចក្តីក្រោធ ដោយហេតុណា នេះឯង ជាធម៌ ។បេ។ ប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនលុបគុណគេ ពោលសរសើរការកម្ចាត់បង់ការលុបគុណគេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមិនលុបគុណគេ ពោលសរសើរការកម្ចាត់បង់នូវការលុបគុណគេ ដោយហេតុណា នេះឯង ជាធម៌ ។បេ។ ប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនអួតអាង ពោលសរសើរការកម្ចាត់បង់សេចក្តីអួតអាង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមិនអួតអាង ពោលសរសើរនូវការកម្ចាត់បង់សេចក្តីអួតអាង ដោយ

ហេតុណា នេះឯង ជាធម៌ ។បេ។ ប្រព្រឹត្តទៅដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនមានមាយា ពោលសរសើរការកម្ចាត់បង់មាយា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមិនមានមាយា ពោលការសរសើរការកម្ចាត់បង់មាយា ដោយហេតុណា នេះឯង ជាធម៌ ។បេ។ ប្រព្រឹត្ត ទៅដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុប្រកបដោយជាតិជាអ្នកពិចារណានូវធម៌ ពោលសរសើរការពិចារណានូវធម៌ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយជាតិជាអ្នកពិចារណានូវធម៌ ដោយហេតុណា នេះឯង ជាធម៌ ។បេ។ ប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកពួនសម្ងំ ពោលសរសើរការពួនសម្ងំ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកពួនសម្ងំ ពោលសរសើរការពួនសម្ងំ ដោយហេតុណា នេះឯង ជាធម៌ ។បេ។ ប្រព្រឹត្តទៅដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកធ្វើនូវបដិ-សណ្ឋារៈ ដល់ពួកសព្រហ្មចារីបុគ្គល ពោលសរសើរបុគ្គលអ្នកធ្វើបដិ-សណ្ឋារៈ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកធ្វើបដិសណ្ឋារៈដល់ពួកសព្រហ្ម-ចារីបុគ្គល ពោលសរសើរបុគ្គលអ្នកធ្វើនូវបដិសណ្ឋារៈ ដោយហេតុណា នេះឯង ជាធម៌ប្រព្រឹត្តទៅ ដើម្បីស្រឡាញ់ ដើម្បីសេចក្តីគោរព ដើម្បីសេចក្តីចម្រើន ដើម្បីភាពជាសមណៈ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសភាពយ៉ាងនេះ បើទុកជាមិនគប្បីបង្កើតសេចក្តីប្រាថ្នា

យ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ពួកសព្រហ្មចារីបុគ្គលគប្បីធ្វើសក្ការៈ គោរព រាប់អាន បូជាចំពោះអាត្មាអញ ក៏គង់តែពួកសព្រហ្មចារីបុគ្គលធ្វើសក្ការៈ គោរព រាប់អាន បូជាចំពោះភិក្ខុនោះដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ពួកសព្រហ្មចារីជាវិញ្ញូជន រមែងពិចារណាឃើញច្បាស់នូវអកុសលធម៌ដ៏លាមកទាំងនោះ ដែលភិក្ខុនោះលះបង់ហើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាសេះអាជានេយ្យដ៏ចម្រើន បើទុកជាមិនគប្បីបង្កើតសេចក្តីប្រាថ្នាយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ពួកមនុស្សគប្បីតម្កើងអញក្នុងទីជាសេះអាជានេយ្យផង គប្បីឲ្យអញបរិភោគនូវភោជនរបស់សេះអាជា-នេយ្យផង គប្បីជុសខាត់អញដោយការជុសខាត់ ដូចជាសេះអាជានេយ្យផង ពួកមនុស្សក៏គង់តែតម្កើងសេះអាជានេយ្យនោះ ក្នុងទីជាសេះអាជានេយ្យផង ឲ្យបរិភោគនូវភោជនរបស់សេះអាជានេយ្យផង ជុសខាត់ដូចជាជុសខាត់សេះអាជានេយ្យផង ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ពួកមនុស្សជាអ្នកដឹង រមែងពិចារណារឃើញច្បាស់នូវអំពើរឹងត្អឹង គៀចក្រាញ កកិចកកុច វៀចវេរទាំងនោះ ដែលសេះអាជានេយ្យនោះលះបង់ហើយ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចជាភិក្ខុមានសភាពយ៉ាងនេះ បើទុកជាមិនគប្បីបង្កើតសេចក្តីប្រាថ្នាយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ពួកសព្រហ្មចារីបុគ្គលគប្បីធ្វើសក្ការៈ គោរព រាប់អាន បូជាចំពោះអាត្មាអញ ក៏គង់តែពួកសព្រហ្មចារីបុគ្គលធ្វើសក្ការៈ គោរព រាប់អាន

បូជាចំពោះភិក្ខុនោះដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ពួកសព្រហ្មចារីជាវិញ្ញូជន រមែងពិចារណាឃើញច្បាស់ នូវអកុសលធម៌ដ៏លាមកទាំងនោះ ដែលភិក្ខុនោះលះបង់ហើយ ។

# អដ្ឋកថា

## អធិករណសូត្រ

[ ៨៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអធិករណសូត្រទី ៧ ដូចតទៅនេះ បទថា **អធិករណិកោ ហោតិ** បានដល់ ជាអ្នកធ្វើអធិករណ៍ ។ បទថា **ន បិយតាយ** បានដល់ មិនប្រព្រឹត្តទៅដើម្បីជាទីស្រឡាញ់ ។ បទថា **ន គរុតាយ** បានដល់ មិនប្រព្រឹត្តទៅដើម្បីភាពគួរគោរព ។ បទថា **ន សាមញ្ញាយ** បានដល់ មិនប្រព្រឹត្តទៅដើម្បីសមានធម៌ ។ បទថា **ន ឯកីភាវាយ** បានដល់ មិនប្រព្រឹត្តទៅដើម្បីមិនមានឱកាស ។ បទថា **ន ធម្មានំ ន និសាមកជាតិយោ** បានដល់ មិនជាអ្នកពិចារណាលោកុត្តរធម៌ ៩ ជាសភាវៈមិនជាអ្នកទ្រទ្រង់ចាំជាសភាវៈ ។ បទថា **ន បដិសល្លានោ** បានដល់ មិនជាអ្នកពួនសម្ងំ ។ បទថា **សាឋេយ្យានិ** បានដល់ មានការអួតអាង ។ បទថា **កូដេយ្យានិ** បានដល់ មានការកោង ។ បទថា **ជិម្ហេយ្យានិ** បានដល់ មានការមិនត្រង់ ។ បទថា **វង្កេយ្យានិ** បានដល់ មានការវៀច ៕

# សុត្តន្តបិដក

## ព្យសនសូត្រទី ៨

[ ៨៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ជាអ្នកជេរ ប្រទេច ផ្ដាសា ពួកសព្រហ្មចារីបុគ្គល ជាអ្នកតិះដៀលព្រះអរិយៈ ដំណើរនោះ មិនមែនជាហេតុ មិនមែនជាបច្ច័យ ដែលមិននាំឲ្យភិក្ខុនោះ គប្បីដល់នូវសេចក្ដីវិនាសទាំង ១០ ប្រការ សេចក្ដីវិនាសណាមួយទេ ។ សេចក្ដីវិនាសទាំង ១០ ប្រការ តើដូចម្ដេចខ្លះ ។ បុគ្គលនោះ មិនបាននូវគុណធម៌ ដែលខ្លួនមិនទាន់បាន ១ សាបសូន្យចាកគុណធម៌ដែលខ្លួនបានហើយ ១ ព្រះសទ្ធម្មរបស់បុគ្គលនោះមិនផូរផង់ ១ ជាអ្នកស្មានហួសហេតុក្នុងព្រះសទ្ធម្ម ១ ប្រព្រឹត្តព្រហ្មចារ្យទាំងមិនមានសេចក្ដីត្រេកអរ ១ ត្រូវអាបត្តិណាមួយ ដែលសៅហ្មង ១ ប្រទះសេចក្ដីទុក្ខព្រោះរោគដ៏ធ្ងន់ ១ ដល់នូវការឆ្កួតរាយមាយចិត្ត ១ ធ្វើមរណៈទាំងវង្វេង ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ជេរប្រទេច ផ្ដាសាពួកសព្រហ្មចារីបុគ្គល ជាអ្នកតិះដៀលព្រះអរិយៈ ដំណើរនោះ មិនមែនជាហេតុ មិនមែនជាបច្ច័យ ដែលមិនមែននាំឲ្យភិក្ខុនោះ គប្បីដល់នូវសេចក្ដីវិនាសទាំង ១០ ប្រការនេះ សេចក្ដីវិនាសណាមួយទេ ។

# អដ្ឋកថា

## ព្យសនសូត្រ

[ ៨៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងព្យសនសូត្រទី ៨ ដូចតទៅនេះ ក្នុងពាក្យថា **អក្កោសកបរិភាសកោ អរិយុបវាទី សព្រហ្មចារីនំ** នេះ គប្បីប្រកបសព្រហ្មចារី និងអក្កោសនបទ និងបរិភាសកបទថា ជាអ្នកជេរសព្រហ្មចារី ជាអ្នកបរិភាសសព្រហ្មចារី ។ បុគ្គលមានសម្តីអាក្រក់ ដោយអន្តិមវត្ថុថា អញទីងសម្លាប់គុណរបស់ព្រះអរិយៈទាំងឡាយ រមែងឈ្មោះថា **អរិយុបវាទី** ។ បទថា **សទ្ធម្មស្ស ន វោទាយន្តិ** សេចក្តីថា សទ្ធម្ម គឺសាសនាដែលរាប់បានថា ត្រៃសិក្ខារបស់ភិក្ខុនោះ រមែងមិនដល់នូវការផូរផង់រោគប៉ុណ្ណោះ គប្បីជ្រាបថា **អាតង្ក** ព្រោះធ្វើជីវិតឲ្យលំបាក ក្នុងពាក្យថា **រោគាតង្កំ** នេះ ។ល។

**អដ្ឋកថា ព្យសនសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## កោកាលិកសូត្រទី ៩

[ ៨៩ ] គ្រានោះ កោកាលិកភិក្ខុចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះកោកាលិកភិក្ខុអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សារីបុត្ត និងមោគ្គល្លាន ជាអ្នកប្រាថ្នាលាមក លុះក្នុងអំណាចនៃសេចក្តីប្រាថ្នាលាមក ។ ព្រះអង្គត្រាស់ថា ម្នាលកោកាលិកៈ អ្នកកុំនិយាយយ៉ាងនេះ ម្នាលកោកាលិកៈ អ្នកកុំនិយាយយ៉ាងនេះឡើយ ម្នាលកោកាលិកៈ ចូរអ្នកញុំាងចិត្តឲ្យជ្រះថ្លាចំពោះសារីបុត្ត និងមោគ្គល្លានចុះ ព្រោះថា សារីបុត្ត និងមោគ្គល្លាន ជាអ្នកមានសីលជាទីស្រឡាញ់ ។ កោកាលិកភិក្ខុទូលព្រះដ៏មានព្រះភាគ ជាគម្រប់ពីរដងទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ គួរខ្ញុំព្រះអង្គជឿយកតម្រាប់ក៏មែនពិតហើយ តែថា សារីបុត្ត និងមោគ្គល្លាន ជាអ្នកប្រាថ្នាលាមកប្រាកដ លុះក្នុងអំណាចនៃសេចក្តីប្រាថ្នាលាមក ។ ម្នាលកោកាលិកៈ អ្នកកុំនិយាយយ៉ាងនេះ ម្នាលកោកាលិកៈ អ្នកកុំនិយាយយ៉ាងនេះឡើយ ម្នាលកោកាលិកៈ អ្នកចូរញុំាងចិត្តឲ្យជ្រះថ្លាចំពោះសារីបុត្ត និងមោគ្គល្លានចុះ ព្រោះថា សារីបុត្ត និងមោគ្គល្លានមានសីលជាទីស្រឡាញ់ ។ កោកាលិកភិក្ខុ ក៏ទូលព្រះដ៏មានព្រះភាគជាគម្រប់ ៣ ដងទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ គួរខ្ញុំព្រះអង្គជឿយកតម្រាប់ក៏ពិតមែនហើយ តែថា សារីបុត្ត និង

មោគ្គល្លាន សុទ្ធតែជាអ្នកប្រាថ្នាលាមកប្រាកដ លុះក្នុងអំណាចនៃសេចក្តីប្រាថ្នាលាមក ។ ម្នាលកោកាលិកៈ អ្នកកុំនិយាយយ៉ាងនេះ ម្នាលកោកាលិកៈ អ្នកកុំនិយាយយ៉ាងនេះឡើយ ម្នាលកោកាលិកៈ អ្នកចូរញុំាងចិត្តឲ្យជ្រះថ្លាចំពោះសារីបុត្ត និងមោគ្គល្លានចុះ ព្រោះថា សារីបុត្ត និងមោគ្គល្លាន ជាអ្នកមានសីល ជាទីស្រឡាញ់ ។ គ្រានោះ កោកាលិកភិក្ខុក្រោកចាកអាសនៈ ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចក៏ធ្វើប្រទក្សិណ ចៀសចេញទៅ ។ កំកាលដែលកោកាលិកភិក្ខុ ចៀសចេញទៅមិនយូរប៉ុន្មាន ក៏កើតអុតប៉ុនៗគ្រាប់ស្ពៃ រួបរឹតកាយទាំងមូល លុះអុតកើតប៉ុនៗ គ្រាប់ស្ពៃហើយ ក៏ដោរឡើងប៉ុនៗ គ្រាប់សណ្តែកបាយ លុះប៉ុនគ្រាប់សណ្តែកបាយហើយ ក៏ដោរឡើងប៉ុនគ្រាប់សណ្តែកកង់ លុះប៉ុនគ្រាប់សណ្តែកកង់ហើយ ក៏ដោរឡើងប៉ុនគ្រាប់ពុទ្រា លុះប៉ុនគ្រាប់ពុទ្រាហើយ ក៏ដោរឡើងប៉ុនផ្លែពុទ្រា លុះប៉ុនផ្លែពុទ្រាហើយ ក៏ដោរឡើងប៉ុនផ្លែកន្ទួតព្រៃ លុះប៉ុនផ្លែកន្ទួតព្រៃហើយ ក៏ដោរឡើងប៉ុនក្តិបល្ពៅ លុះប៉ុនក្តិបល្ពៅហើយ ក៏ដោរឡើងប៉ុនផ្លែល្ពៅធំ លុះប៉ុនផ្លែល្ពៅធំ ហើយ ខ្ទុះ និងឈាមក៏ហូរចេញរហាម ។ បានឮថា កោកាលិកភិក្ខុនោះ ដេកលើស្លឹកចេកដូចជាត្រីដែលគេប្រាស់ស្រកាហើយ ។ លំដាប់នោះ តុទិបច្ចេកព្រហ្មបានចូលទៅរកកោកាលិកភិក្ខុ លុះចូលទៅដល់ហើយ ក៏ឋិតនៅឰដ៏អាកាស ហើយពោលទៅនឹងកោកាលិកភិក្ខុដូច្នេះថា ម្នាលកោកាលិកៈ ចូរលោកញុំាងចិត្តឲ្យជ្រះថ្លាចំពោះព្រះសារីបុត្ត និងព្រះមោគ្គល្លាន

ចុះ ព្រោះថា ព្រះសារីបុត្ត និងព្រះមោគ្គល្លានមានសីលជាទីស្រឡាញ់ ។ ម្នាលអាវុសោ អ្នកជាអ្វី ។ យើងជាតុទិបច្ចេកព្រហ្ម ។ ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ព្យាករថា អ្នកឯងជាអនាគាមិបុគ្គលហើយតើ ចុះអ្នកឯងមកក្នុងទីនេះ ដើម្បីអ្វីទៀត អ្នកឯងចូរមើលតែនូវកំហុសរបស់អ្នកនោះចុះ ។ លំដាប់នោះ តុទិបច្ចេកព្រហ្មក៏បានពោលនឹងកោកាលិកភិក្ខុ ដោយគាថាដូច្នេះថា

បុគ្គលពាលកាលពោលនូវទុព្ភាសិត ឈ្មោះថា កាប់ខ្លួនឯង
ដោយប៉ូវថៅ គឺផរុសវាចាណា ប៉ូវថៅ គឺផរុសវាចានោះ
កើតតែក្នុងមាត់របស់បុរសជាតិដោយពិត ។

បុគ្គលណាសរសើរនូវបុគ្គលដែលគួរនិន្ទាក្តី តិះដៀលបុគ្គលដែលគួរសរសើរនោះក្តី បុគ្គលនោះ ឈ្មោះថា សន្សំនូវទោសដោយមាត់ រមែងមិនបានសេចក្តីសុខព្រោះទោសនោះទេ ។

ការចាញ់ដោយទ្រព្យណា ព្រោះល្បែងភ្នាល់ទាំងឡាយ
( ព្រមទាំងខ្លួនទាំងអស់ ) ជាកំហុស មានប្រមាណ
តិចទេ បុគ្គលណា ញុំាងចិត្តឲ្យប្រទូស្តចំពោះពួកបុគ្គល
អ្នកប្រព្រឹត្តល្អនេះឯង ជាកំហុសធំក្រៃលែង ។ បុគ្គល
តម្កល់នូវវាចា និងចិត្តដ៏លាមក ហើយតិះដៀលព្រះ
អរិយៈ រមែងទៅកាន់នរកណា នរកនោះមាន ១ សែន
និរព្វុទៈផង និង ៣៦ អព្វុទៈ ( ដោយឡែកទៀត ) ផង

៥ អព្វុទៈផង ។

គ្រានោះ កោកាលិកភិក្ខុក៏ធ្វើមរណកាលដោយជំងឺនោះឯង ។ លុះកោកាលិកភិក្ខុធ្វើមរណកាលហើយ ក៏ទៅកើតក្នុងបទុមនរក ព្រោះថ្នាំងថ្នាក់ចិត្តចំពោះព្រះសារីបុត្ត និងព្រះមោគ្គល្លាន ។ គ្រានោះ កាលបើរាត្រីបឋមយាមកន្លងទៅហើយ សហម្បតិព្រហ្មមានរស្មីរុងរឿង ធ្វើវត្តជេតពនទាំងមូលឲ្យភ្លឺច្បាស់ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឋិតនៅក្នុងទីសមគួរ ។ លុះសហម្បតិព្រហ្មឋិតនៅក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កោកាលិកភិក្ខុធ្វើមរណកាលទៅហើយ បពិត្រព្រះអង្គដ៏ចម្រើន កោកាលិកភិក្ខុធ្វើមរណកាលទៅកើតក្នុងបទុមនរក ព្រោះថ្នាំងថ្នាក់ចិត្តចំពោះព្រះសារីបុត្ត និងព្រះមោគ្គល្លាន ។ សហម្បតិព្រហ្មបានពោលពាក្យនេះហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ ហើយបាត់ចាកទីនោះទៅមួយរំពេច ។ លំដាប់នោះ ព្រះដ៏មានព្រះភាគកាលបើរាត្រីនោះកន្លងទៅហើយ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ក្នុងយប់មិញនេះ កាលរាត្រីបឋមយាមកន្លងទៅហើយ សហម្បតិព្រហ្មមានរស្មីរុងរឿង ធ្វើវត្តជេតពនទាំងមូលឲ្យភ្លឺច្បាស់ ហើយចូលមករកតថាគត លុះចូលមកដល់ថ្វាយបង្គំតថាគត ហើយឋិតនៅក្នុងទីសមគួរ ។ ម្នាលភិក្ខុទាំងឡាយ លុះសហម្បតិព្រហ្មឋិតនៅក្នុងទីសមគួរហើយ បានពោលនឹងតថាគតដូច្នេះថា បពិត្រព្រះអង្គដ៏

ចម្រើន កោកាលិកភិក្ខុធ្វើមរណកាលទៅហើយ បពិត្រព្រះអង្គដ៏ចម្រើន កោកាលិកភិក្ខុធ្វើមរណកាលទៅ ទៅកើតក្នុងបទុមនរក ព្រោះថ្នាំងថ្នាក់ចិត្ត ចំពោះព្រះសារីបុត្ត និងព្រះមោគ្គល្លាន ។ ម្នាលភិក្ខុទាំងឡាយ សហម្បតិ-ព្រហ្មបានពោលពាក្យនេះ លុះពោលពាក្យនេះហើយ ថ្វាយបង្គំលាគថាគត ធ្វើប្រទក្សិណ បាត់ចាកទីនោះទៅមួយរំពេច ។ និមិត្តតែព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ភិក្ខុ ១ រូប ក្រាបថ្វាយបង្គំទូលសួរព្រះដ៏មាន ព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ប្រមាណនៃអាយុក្នុងបទុមនរកវែង ប៉ុន្មាន ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ ប្រមាណនៃអាយុក្នុងបទុមនរកវែង ណាស់ ប្រមាណនៃអាយុក្នុងបទុមនរកនោះ បុគ្គលមិនងាយនឹងរាប់ថា ប៉ុណ្ណេះឆ្នាំ ប៉ុណ្ណោះរយឆ្នាំ ឬប៉ុណ្ណោះពាន់ឆ្នាំ ឬក៏ប៉ុណ្ណោះសែនឆ្នាំបានឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះអង្គអាចធ្វើសេចក្តីឧបមាបានដែរឬ ។ ព្រះដ៏ មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាចធ្វើបានដូច្នេះ ទើបត្រាស់ថា ម្នាល ភិក្ខុទាំងឡាយ ប្រៀបដូចរទេះផ្ទុកល្ងរបស់អ្នកដែនកោសល ចំណុះ ២០ ខារិកៈ ( អម្រែក ) កន្លងទៅបាន ១ សែនឆ្នាំ មានបុរសម្នាក់រើសយកល្ង ១ គ្រាប់ៗ អំពីរទេះនោះចេញ ។ ម្នាលភិក្ខុ រទេះផ្ទុកល្ងរបស់អ្នកដែន កោសលចំណុះ ២០ ខារិកៈនោះ ដល់នូវការអស់រលីងទៅដោយសេចក្តី ព្យាយាមនេះ ឈ្មោះថា ឆាប់រហ័សនៅឡើយ ឯអព្វុទនរក ១ មិនឆាប់ ដូច្នេះទេ ម្នាលភិក្ខុ ដូចជាអព្វុទនរក ២០ ត្រូវជានិរព្វុទនរក ១ ។ ម្នាលភិក្ខុ

ដូចជានិរព្វុទនរក ២០ ត្រូវជាអពព្វនរក ១ ។ ម្នាលភិក្ខុ ដូចជាអពព្វនរក ២០ ត្រូវជាអហហនរក ១ ។ ម្នាលភិក្ខុ ដូចជាអហហនរក ២០ ត្រូវជាអដដនរក ១ ។ ម្នាលភិក្ខុដូចជាអដដនរក ២០ ត្រូវជាកុមុទនរក ១ ។ ម្នាលភិក្ខុដូចជាកុមុទនរក ២០ ត្រូវជាសោគន្ធិកនរក ១ ។ ម្នាលភិក្ខុដូចជាសោគន្ធិកនរក២០ ត្រូវជាឧប្បលនរក១ ។ ម្នាលភិក្ខុដូចជាឧប្បលនរក ២០ ត្រូវជាបុណ្ឌរីកនរក ១ ។ ម្នាលភិក្ខុដូចជាបុណ្ឌរីកនរក ២០ ត្រូវជាបទុមនរក ១ ។ ម្នាលភិក្ខុ ដូចជាកោកាលិកភិក្ខុទៅកើតក្នុងបទុមនរក ព្រោះថ្នាំងថ្នាក់ចិត្តចំពោះសារីបុត្ត និងមោគ្គល្លាន ។ ព្រះមានព្រះភាគទ្រង់សំដែងធម៌នេះហើយ ព្រះសុគតជាសាស្តា លុះសំដែងធម៌នេះហើយ ទើបសំដែងគាថានេះតទៅទៀតថា

បុគ្គលពាល កាលពោលនូវពាក្យទុព្ភាសិត ឈ្មោះថា កាប់នូវ
ខ្លួនដោយប៉ូវថៅ គឺផរុសវាចាណា ប៉ូវថៅ គឺផរុសវាចានោះ
តែងកើតក្នុងមាត់របស់បុរសជាតិ ដោយពិត ។

បុគ្គលណា សរសើរនូវបុគ្គលដែលគួរនិន្ទា ឬតិះដៀលបុគ្គលដែលគួរសរសើរ បុគ្គលនោះ ឈ្មោះថា សន្សំនូវទោសដោយមាត់ រមែងមិនបានសេចក្តីសុខ ព្រោះទោសនោះទេ ។

ការចាញ់ ដោយទ្រព្យណា ព្រោះល្បែង ក្នុងទាំងឡាយ
( ព្រមទាំងខ្លួនទាំងអស់ ) ការចាញ់នេះ ឈ្មោះថា កំហុស

មានប្រមាណតិចទេ បុគ្គលណា ញ៉ាំងចិត្តឲ្យប្រទូស្តចំពោះពួកបុគ្គលដែលប្រព្រឹត្តល្អ បុគ្គលនេះឯង ទើបឈ្មោះថា មានកំហុសធំក្រៃលែង ។ បុគ្គលតម្កល់វាចា និងចិត្ត ដ៏លាមកតិះដៀលព្រះអរិយៈ រមែងទៅកើតក្នុងនរកណា នរកនោះមានមួយសែននិរព្វុទៈ និង ៣៦ និរព្វុទៈ ( ដោយឡែកទៀត ) ផង ៥ អព្វុទៈផង ។

# អដ្ឋកថា

## កោកាលិកសូត្រ

[ ៨៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកោកាលិកសូត្រទី ៩ ដូចតទៅនេះ បទថា **កោកាលិកោ ភិក្ខុ យេន ភគវា តេនុបសង្កមិ** សេចក្តីថា កោកាលិកភិក្ខុជានរណា ហេតុអ្វី ទើបចូលគាល់ បានឮថា កោកាលិកភិក្ខុនេះ ជាបុត្ររបស់កោកាលិកសេដ្ឋី ក្នុងនគរកោកាលិក រដ្ឋកោកាលិក បួសហើយ នៅប្រចាំក្នុងវិហារដែលសេដ្ឋីបិតាសាង តែភិក្ខុដែលជាសិស្សរបស់ទេវទត្ត ឈ្មោះថា ចូឡកោកាលិក កោកាលិកកូនព្រាហ្មណ៍នោះ ឈ្មោះថា មហាកោកាលិក ។ កាលព្រះមានព្រះភាគប្រថាប់នៅក្នុងក្រុងសាវត្ថី អគ្គសាវកទាំង ២ ក៏ចារិកទៅក្នុងជនបទ មួយអន្លើដោយភិក្ខុប្រមាណ ៥០០

រូប កាលថ្ងៃជិតចូលវស្សា បំណងនឹងនៅដោយវិវេក ទើបបញ្ជូនភិក្ខុទាំងនោះ ត្រឡប់ទៅ ខ្លួនឯងកាន់បាត្រ និងចីវរ ដល់នគរនោះ ក្នុងជនបទនោះ កាល ដល់វិហារនោះ ក៏ទៅវិហារនោះ ។ ក្នុងវិហារនោះ កោកាលិកភិក្ខុធ្វើវត្តបដិបត្តិ ដល់អគ្គសាវកទាំង ២ នោះ ព្រះអគ្គសាវកក៏ធ្វើនូវសេចក្តីរាប់អាននឹងកោកា- លិកភិក្ខុនោះ ទទួលពាក្យថា អាវុសោ ខ្ញុំនឹងនៅទីនេះ ៣ ខែ លោកកុំប្រាប់ រឿងរបស់ខ្ញុំដល់បុគ្គលណាមួយ ហើយក៏នៅចាំវស្សា កាលចាំវស្សាហើយ ក៏បវារណាក្នុងថ្ងៃបវារណា ក៏លាកោកាលិកភិក្ខុថា អាវុសោ ខ្ញុំនឹងទៅ កោកាលិកភិក្ខុពោលថា អាវុសោ ថ្ងៃនេះ សូមនៅមួយថ្ងៃចុះ ស្អែកនេះសឹម ទៅ ។ ថ្ងៃស្អែកឡើង ក៏ចូលទៅព្រះនគរ ប្រាប់មនុស្សទាំងឡាយថា អាវុសោ អ្នកមិនដឹងទេឬថា អគ្គសាវកទាំង ២ មកនៅក្នុងទីនេះ បុគ្គលណាមួយមិន និមន្តលោកដោយបច្ច័យខ្លះទេឬ ។ ទើបអ្នកនគរពោលថា បពិត្រលោកម្ចាស់ ព្រះថេរៈនៅឯណា ហេតុអ្វី ទើបមិនប្រាប់ពួកខ្ញុំ ។ កោកាលិកភិក្ខុពោលថា ចាំបាច់ប្រាប់ធ្វើអ្វី ពួកអ្នកមិនឃើញព្រះថេរៈ ២ រូបនោះ អង្គុយលើថេរាសនៈ ទេឬ នុ៎ះឯងអគ្គសាវក ។ អ្នកនគរទាំងនោះ ប្រញាប់ប្រជុំគ្នាប្រមូលសប្បិ ទឹកឃ្មុំជាដើម និងសំពត់ចីវរទាំងឡាយ កោកាលិកភិក្ខុគិតថា អគ្គសាវក មានការប្រាថ្នាតិចក្រៃលែង នឹងមិនត្រេកអរក្នុងលាភដែលកើតឡើងដោយ បយុត្តវាចា គឺវាចាដែលកោសយកលាភ ។ កាលលោកមិនត្រេកអរ ក៏នឹង ប្រាប់ឲ្យប្រគេនដល់ភិក្ខុដែលនៅជាប្រចាំ ទើបឲ្យកាន់យកលាភនោះទៅកាន់

សម្នាក់ព្រះថេរៈ ។ ព្រះថេរៈឃើញហើយ ក៏បដិសេធថា បច្ច័យមិនសមគួរដល់អាត្មាផង មិនសមគួរដល់កោកាលិកភិក្ខុផង ដូច្នេះហើយ ក៏ត្រឡប់ទៅ ។ កោកាលិកភិក្ខុកើតអាឃាតថា ហេតុអ្វីហ្ន៎ អគ្គសាវក បើមិនទទួលខ្លួនឯង ហេតុម្តេចក៏មិនឲ្យដល់យើង ហើយចៀសចេញទៅ ។ អគ្គសាវកទាំង ២ នោះមកគាល់ព្រះមានព្រះភាគ ថ្វាយបង្គំហើយ ក៏នាំបរិស័ទរបស់ខ្លួន ចារិកទៅក្នុងជនបទ ត្រឡប់មកកាន់នគរនោះ ក្នុងរដ្ឋនោះឯងតាមលំដាប់ ។ ពួកអ្នកក្រុងចាំព្រះថេរៈបាន ក៏ចាត់ចែងទាន មួយអន្លើដោយបរិក្ខារ សាងមណ្ឌបកណ្តាលព្រះនគរ ថ្វាយទាន ហើយបង្អោនបរិក្ខារប្រគេនព្រះថេរៈ ។ ព្រះថេរៈក៏បង្អោនដល់ភិក្ខុសង្ឃ ។ កោកាលិកភិក្ខុឃើញដូច្នោះ គិតថា អគ្គសាវកនេះ ពីមុនជាអ្នកប្រាថ្នាតិច ឥឡូវនេះ ក្លាយជាអ្នកមានសេចក្តីប្រាថ្នាលាមកប្រហែលជាកាលមុន ធ្វើជាប្រាថ្នាតិច សន្តោស និងស្ងាត់ ទើបចូលទៅរកព្រះថេរៈ ពោលថា អាវុសោ ពួកលោកក្នុងកាលមុន ធ្វើដូចជាប្រាថ្នាតិច តែឥឡូវនេះ ក្លាយជាភិក្ខុលាមកទៅហើយហ្ន៎ គិតថា អញនឹងទម្លាយទីពឹងរបស់ព្រះថេរៈទាំងនោះ ទើបប្រញាប់ទៅគាល់ព្រះមានព្រះភាគ ។ កោកាលិកភិក្ខុនេះឯង គប្បីជ្រាបថា ចូលទៅគាល់ ដោយហេតុនេះ ។

ព្រះមានព្រះភាគ ឃើញកោកាលិកភិក្ខុនោះរូតរះមក ទ្រង់ពិចារណាដឹងថា ភិក្ខុនេះ មកដើម្បីជេរអគ្គសាវក តថាគតហាមបានទេហ្ន៎ ទ្រង់ឃើញថា ហាមមិនបាន លោកធ្វើខុសក្នុងព្រះថេរៈទាំង ២ មកហើយ នឹងកើតក្នុង

បទុមនរក ដោយចំណែកមួយ ទ្រង់ហាមដល់ ៣ ដងថា កុំពោលយ៉ាងនេះឡើយ កាលទ្រង់ដោះវាទះថា ព្រះមានព្រះភាគទ្រង់ជ្រាបថា កោកាលិកភិក្ខុតិះដៀលព្រះសារីបុត្រ និងព្រះមោគ្គល្លានហើយ ក៏ទ្រង់មិនហាម និងដើម្បីសម្តែងថា អរិយុបវាទមានទោសច្រើន ។ បទថា **មា ហេវំ** ពាក្យនោះប្រែថា កុំពោលយ៉ាងនេះឡើយ ។

បទថា **សទ្ធាយិកោ** បានដល់ ហៅការជឿនាំមកនូវការជ្រះថ្លា ឬមានវាចាដែលគួរជឿបាន ។ បទថា **បច្ចយិកោ** បានដល់ មានវាចាដែលគួររាប់អាន ។ បទថា **បក្កាមិ** បានដល់ ត្រូវអានុភាពនៃកម្មដាស់តឿនក៏ចៀសទៅពិតហើយ កម្មដែលដល់ឱកាសហើយ បុគ្គលណាម្នាក់ ក៏ហាមមិនបាន ។ បទថា **អចិរបក្កន្តស្ស** បានដល់ ចៀសចេញទៅមិនយូរ ។

បទថា **សព្វោ កាយោ ផុដ្ឋោ អហោសិ** សេចក្តីថា ពាសពេញខ្លួនមិនវៀរឱកាសត្រឹមមួយចម្រៀកសក់ ពកទាំងឡាយជ្រែកនូវឆ្អឹង ផុសឡើងពាសពេញ ព្រោះហេតុដែលកម្មបែបនោះ មិនអាចឲ្យវិបាកចំពោះព្រះភក្ត្រព្រះសម្ពុទ្ធទាំងឡាយ ដោយពុទ្ធានុភាព ក៏រមែងឲ្យផលក្នុងកាលផុតទីឧបចារៈដែលចូលគាល់ ដូច្នោះ ទើបពកទាំងឡាយផុសឡើង ក្នុងកាលកោកា-លិកភិក្ខុនោះ ចៀសចេញទៅមិនយូរ ។ បទថា **កឡាយមត្តិយោ** ប្រែថា សណ្តែកខ្មៅ ។ បទថា **វេលុវសលាដុកមត្តិយោ** ប្រែថា ប៉ុនផ្លែព្នៅខ្ចី ។ បទថា **បភិជ្ជឹសុ** ប្រែថា បែកហើយ កាលពកទាំងនោះបែកហើយ ខ្លួនប្រាណ

ទាំងមូល ក៏ដូចជាខ្ទុរទុំ ។ កោកាលិកភិក្ខុនោះ មានខ្លួនធ្ងន់ហើយ ដេកលើស្លឹកចេក ក្បែរខ្លោងទ្វារវត្តជេតពន ដូចត្រីលេបថ្នាំពិស កាលនោះ មនុស្សទាំងឡាយដែលមកស្តាប់ធម៌ ក៏នាំគ្នាពោលថា ថ្វីយ ! កោកាលិកៈ ថ្វីយ ! កោកាលិកៈ ធ្វើមិនត្រឹមត្រូវឡើយ អាស្រ័យមាត់របស់ខ្លួនតែម្យ៉ាង ក៏ដល់នូវការលំបាក អារក្ខទេវតាទាំងឡាយ ស្តាប់សំឡេងរបស់មនុស្សទាំងនោះ ក៏បានធ្វើសំឡេងតិះដៀលដូចគ្នា អាកាសទេវតាស្តាប់អារក្ខទេវតា ក៏តិះដៀលដូចគ្នា ហេតុនោះ ទើបកើតសំឡេងតិះដៀលតែមួយដោយឧបាយយ៉ាងនេះ រហូតដល់អកនិដ្ឋភព ។

បទថា **តុទិ** បានដល់ ឧបជ្ឈាយ៍របស់កោកាលិកៈ ឈ្មោះតុទិត្ថេរបាន អនាគាមិផល កើតក្នុងព្រហ្មលោក បានឮសំឡេងតិះដៀលអំពីកុម្មដ្ឋកទេវតាតៗ គ្នាទៅ រហូតដល់ព្រហ្មលោកថា កោកាលិកៈពោលទោសព្រះអគ្គសាវ័ក ដោយអទ្ថិមវត្ថុ ធ្វើកម្មមិនត្រូវ គិតថា គួរអាណិត បើអាត្មាអញឃើញគេ ក៏កុំវិនាសទៅឡើយ អាត្មាអញនឹងទូន្មានគេ ដើម្បីឲ្យចិត្តជ្រះថ្លាក្នុងអគ្គសាវ័កទាំង ២ ដូច្នេះហើយ ទើបមកឈរត្រង់មុខកោកាលិកភិក្ខុនោះ ។ លោកសំដៅយកតុទិព្រហ្មនោះ ទើបពោលពាក្យនេះថា **តុទិបច្ចេកព្រហ្មា**។

បទថា **បេសលា** សេចក្តីថា មានសីលជាទីស្រឡាញ់ ។ កោកាលិកភិក្ខុ ដេកបើកភ្នែកព្រឹមៗ ពោលយ៉ាងនេះថា អាវុសោ ជានរណា ។ បទថា **បស្ស យាវញ្ច តេ** សេចក្តីថា កោកាលិកភិក្ខុពោលថា ចូរមើលចុះ អ្នក

*ធ្វើខុស មានប្រមាណប៉ុនណា កាលមិនឃើញពក ជំត្រង់ថ្វាសរបស់ខ្លួន សម្គាល់ថា គប្បីជាស់តឿនខ្ញុំ ដោយពកទំហំប៉ុនគ្រាប់ស្ពៃ ។*

*គ្រានោះ តុទិព្រហ្មដឹងថា កោកាលិកៈនេះមិនពេញចិត្ត មិនស្តាប់បុគ្គលណាម្នាក់ ដូចត្រីដែលលេបថ្នាំពិស ទើបពោលនឹងកោកាលិកៈនោះថា* **បុរិ-សស្ស ហិ** *ជាដើម ។ បទថា* **កុឋារិ** *ក្នុងគាថានោះ បានដល់ វាចាគ្រោតគ្រាត ដូចពូថៅ ។ បទថា* **ឆិន្ទតិ** *បានដល់ រមែងកាត់ត្រង់ឫសនោះឯងពោល គឺកុសលមូល ។ បទថា* **និន្ទិយំ** *បានដល់ បុគ្គលទ្រុស្តសីលគប្បីតិះដៀល ។ បទថា* **បសំសតិ** *បានដល់ សរសើរនូវប្រយោជន៍ដ៏ឧត្តម ទើបពោលថា* **ខីណាសវោ។** *បទថា* **តំ វា និន្ទតិ យោ បសំសិយោ** *សេចក្តីថា បុគ្គលណាដែលគេគប្បីសរសើរជាព្រះខីណាស្រព កោកាលិកៈនេះ ក៏នៅចោទបុគ្គលនោះ ពោលថា ភិក្ខុនេះទ្រុស្តសីល ។*

*បទថា* **វិចិនាតិ មុខេន សោ កលឹ** *សេចក្តីថា បុគ្គលនោះ ឈ្មោះថាជួបទោសនោះដោយមាត់ ។ បទថា* **កលិនា តេន** *សេចក្តីថា រមែងមិនជួបនូវសេចក្តីសុខ ព្រោះទោសនោះ ។ ពិតហើយ ការសរសើរបុគ្គលដែលគួរតិះដៀល និងការតិះដៀលបុគ្គលដែលគួរសរសើរ មានវិបាកស្មើគ្នា ។ បទថា* **សព្វស្សាបិ សហាបិ អត្តនា** *សេចក្តីថា ឈ្មោះថា ការចាញ់ខាងទ្រព្យក្នុងការភ្នាល់ទាំងឡាយឯណា ដោយទ្រព្យរបស់ខ្លួនទាំងអស់ ព្រមទាំងខ្លួន ការចាញ់ទ្រព្យនេះ ជាទោសតិចតួច ។ បទថា* **យោ សុគតេសុ**

សេចក្តីថា បុគ្គលណាគិតប្រទូស្តក្នុងបុគ្គលដែលបដិបត្តិប្រពៃ ការប្រទូស្តនៃបុគ្គលនោះ នេះមានទោសច្រើនជាងទោសនោះ ។

ឥឡូវនេះ ត្រូវទ្រង់ព្រហ្មកាលសម្តែងថា ការប្រទូស្តនោះមានទោសច្រើនជាង ទើបពោលពាក្យថា **សតំ សហស្សានំ** ជាដើម ។ បទថា **សតំ សហស្សានំ** បានដល់ មួយសែន ដោយការរាប់និរព្វុទៈ ។ បទថា **ឆត្តឹសតិ** បានដល់ ៣៦ និរព្វុទៈទៀត ។ បទថា **បញ្ច ច** បានដល់ ៥ អព្វុទៈ ដោយការរាប់អព្វុទៈ ។ បទថា **យមរិយគរហី** សេចក្តីថា បុគ្គលតិះដៀលព្រះអរិយៈ រមែងចូលដល់នរកឯណា ទុំះជាអាយុប្រមាណក្នុងនរកនោះ ។ បទថា **កាលមកាសិ** សេចក្តីថា ធ្វើកាលកិរិយា កាលឧបជ្ឈាយ៍ចៀសចេញទៅ ។ បទថា **បទុមនិរយំ** សេចក្តីថា ឈ្មោះថា បទុមនរកដែលបែកចេញដោយឡែក រមែងមិនមាន តែកើតឡើងក្នុងទីតែមួយ ក្នុងអវីចីមហានរកនោះឯង ។

ពាក្យថា **អព្វុទ** នេះ ជាឈ្មោះរបស់ទីដែលសត្វគប្បីឆេះ ដោយការរាប់អព្វុទៈក្នុងអវីចីនរកនោះឯង ។ ក្នុងនរកឈ្មោះថា និរព្វុទៈជាដើម ក៏ន័យនេះ ម្យ៉ាងទៀត ក្នុងនរកនោះ គប្បីជ្រាបការរាប់ឆ្នាំយ៉ាងនេះ ។

១០០ សែនកោដិ ជា ១ បកោដិ យ៉ាងណា ១០០ សែនកោដិ ឈ្មោះថា ១ បកោដិក៏ដូច្នោះ ១០០ សែនបកោដិ ឈ្មោះថា ១ កោដិបកោដិ ១០០ សែនកោដិបកោដិ ឈ្មោះថា ១ នហុ ១០០ សែននហុត ជា ១

*និន្នហុត ១០០ សែននិន្នហុត ជា ១ អព្វុទៈ ។ បន្ទាប់អំពីអព្វុទៈនោះទៅ យក ២០ គុណជានិរព្វុទៈ ។ ក្នុងបទដ៏សេសក៏ន័យនេះឯង ។*

**អដ្ឋកថា កោកាលិកសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ពលសូត្រទី ១០

*[ ៩០ ] គ្រានោះ ព្រះសារីបុត្តដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគក៏ត្រាស់សួរដូច្នេះថា ម្នាលសារីបុត្ត ភិក្ខុជាខីណាស្រពប្រកបដោយកម្លាំងទាំងឡាយណា រមែងប្តេជ្ញានូវការអស់ទៅនៃអាសវៈថា អាសវៈរបស់អាត្មាអញអស់ហើយ កម្លាំងរបស់ភិក្ខុជាខីណាស្រពនោះ តើមានប៉ុន្មាន ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រពប្រកបដោយកម្លាំងទាំងឡាយណា រមែងប្តេជ្ញានូវការអស់ទៅនៃអាសវៈថា អាសវៈរបស់អាត្មាអញអស់ហើយ កម្លាំងរបស់ភិក្ខុជាខីណាស្រពនោះ មាន ១០ យ៉ាង ។ កម្លាំង ១០ យ៉ាង តើដូចម្តេចខ្លះ ។ បពិត្រព្រះអង្គដ៏ចម្រើន គឺភិក្ខុជា*

ខីណាស្រព ក្នុងសាសនានេះ ពិចារណាឃើញច្បាស់ នូវសង្ខារទាំងពួង ដោយសេចក្តីថា មិនទៀង ដោយបញ្ញាដ៏ប្រពៃតាមពិត ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រព ពិចារណាឃើញច្បាស់នូវសង្ខារទាំងពួង ដោយសេចក្តីថា មិនទៀង ដោយបញ្ញាដ៏ប្រពៃតាមពិត ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន នេះឯង ចាត់ជាកម្លាំងរបស់ភិក្ខុជាខីណាស្រព ដែលនាំឲ្យភិក្ខុជាខីណាស្រព អាស្រ័យនូវកម្លាំងហើយ ទើបប្តេជ្ញានូវការអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈរបស់អាត្មាអញអស់ហើយ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ភិក្ខុជាខីណាស្រព ពិចារណាឃើញច្បាស់ នូវកាមទាំងឡាយ មានឧបមាដូចរណ្តៅរងើកភ្លើង ដោយបញ្ញាដ៏ប្រពៃតាមពិត ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រព ពិចារណាឃើញច្បាស់ នូវកាមទាំងឡាយ មានឧបមាដូចរណ្តៅរងើកភ្លើង ដោយបញ្ញាដ៏ប្រពៃតាមពិត ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន នេះឯង ចាត់ជាកម្លាំងរបស់ភិក្ខុជាខីណាស្រព ដែលនាំឲ្យភិក្ខុជាខីណាស្រពអាស្រ័យនូវកម្លាំងហើយ ទើបប្តេជ្ញានូវការអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយរបស់អាត្មាអញអស់ហើយ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ភិក្ខុជាខីណា-ស្រព មានចិត្តឱនទៅកាន់វិវេក ឈមទៅរកវិវេក ទោរទន់ទៅរកវិវេក ឋិតនៅក្នុងវិវេក ត្រេកអរក្នុងការចេញចាកកាម ជាចិត្តវិនាសចាកធម៌ទាំងឡាយដែលជាទីតាំងនៃអាសវៈ ដោយប្រការទាំងពួង ។ បពិត្រព្រះអង្គដ៏ចម្រើន

ភិក្ខុជាខីណាស្រព មានចិត្តឱនទៅរកវិវេក ឈមទៅរកវិវេក ទោរទន់ទៅរកវិវេក ឋិតនៅក្នុងវិវេក ត្រេកអរក្នុងការចេញចាកកាម ជាចិត្តវិនាសចាកធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈ ដោយប្រការទាំងពួង ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន នេះឯង ចាត់ជាកម្លាំងរបស់ភិក្ខុជាខីណាស្រព ដែលនាំឲ្យភិក្ខុជាខីណាស្រពអាស្រ័យនូវកម្លាំងហើយ ទើបប្តេជ្ញានូវការអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយរបស់អាត្មាអញអស់ហើយ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ភិក្ខុជាខីណាស្រព ចម្រើនអប់រំល្អហើយនូវសតិប្បដ្ឋាន ៤ ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រព បានចម្រើនអប់រំល្អហើយនូវសតិប្បដ្ឋាន ៤ ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន នេះឯង ចាត់ជាកម្លាំងរបស់ភិក្ខុជាខីណាស្រព ដែលនាំឲ្យភិក្ខុជាខីណាស្រពអាស្រ័យនូវកម្លាំងហើយ ទើបប្តេជ្ញានូវការអស់ទៅ នៃអាសវៈទាំងឡាយថា អាសវៈរបស់អាត្មាអញអស់ហើយ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ភិក្ខុជាខីណាស្រព បានចម្រើនអប់រំល្អហើយនូវសម្មប្បធាន ៤ ... ១ ចម្រើនអប់រំល្អហើយនូវឥទ្ធិបាទ ៤ ... ១ ចម្រើនអប់រំល្អហើយនូវឥន្ទ្រិយ ៥ ពល ៥ ... ១ ចម្រើនអប់រំល្អហើយនូវពោជ្ឈង្គ ៧ ... ១ ចម្រើនអប់រំល្អហើយ នូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រពចម្រើនអប់រំល្អហើយ នូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន នេះឯង ចាត់ជាកម្លាំងរបស់ភិក្ខុជា

វិណាស្រេត ដែលនាំឲ្យភិក្ខុជាខីណាស្រេត អាស្រ័យនូវកម្លាំងហើយ ទើប ប្ដេជ្ញានូវការអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយរបស់អាត្មា អញអស់ហើយ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រេតប្រកប ដោយកម្លាំងទាំងឡាយណា ប្ដេជ្ញានូវការអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយរបស់អាត្មាអញអស់ហើយ កម្លាំងរបស់ភិក្ខុជាខីណាស្រេត នោះ មាន ១០ យ៉ាងនេះឯង ។

ថេរវគ្គទី ៤ ចប់

## ឧទ្ទាននៃថេរវគ្គនោះគឺ

និយាយអំពីព្រះវាហុនត្ថេរ ១ ព្រះអានន្ទត្ថេរ ១ ព្រះបុណ្ណិយត្ថេរ ១ ការពោលអួតអរហត្តផល ១ ភិក្ខុពោលអួត ១ ការស្មាន ហួសហេតុ ១ អធិករណ៍ ១ កោកាលិកភិក្ខុ ១ កម្លាំង ១ ។

# អដ្ឋកថា

## ពលសូត្រ

[ ៩០ ] ពលសូត្រទី ១០ គប្បីជ្រាបដោយន័យដែលពោលខាងដើម នោះឯង ពាក្យដ៏សេសគ្រប់បទ ងាយយល់ទាំងអស់ហើយ ។

អដ្ឋកថាពលសូត្រទី ១០ ចប់

ថេរវគ្គទី ៤ ចប់

# សុត្តន្តបិដក

# ឧបាសកវគ្គទី ៥

## កាមភោគីសូត្រទី ១

[ ៩១ ] *សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី បានអង្គុយក្នុងទីសមគួរហើយ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលគហបតី អ្នកបរិភោគកាមនេះមាន ១០ ពួកក្នុងលោក ។ ១០ ពួក តើដូចម្តេចខ្លះ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកនូវភោគៈទាំង-ឡាយមិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយមិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេបានមកហើយ មិនធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត មិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ១ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគៈទាំងឡាយមិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកនូវភោគៈទាំងឡាយមិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេបានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត តែមិនចែករលែក មិនធ្វើបុណ្យទាំង-ឡាយ ១ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះ*

ស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិន លុះស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេបានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត ទាំងចែករំលែក ធ្វើបុណ្យទាំងឡាយ ១ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន លុះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនក៏មាន មិនកំហែងសង្កត់សង្កិនក៏មាន បានមកហើយ មិនធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ១ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនក៏មាន មិនកំហែងសង្កត់សង្កិនក៏មាន លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនក៏មាន មិនកំហែងសង្កត់សង្កិនក៏មាន បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត តែទាស់មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ១ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែង

សន្តត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត ចែករលែក ធ្វើបុណ្យទាំងឡាយ ១ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ មិនធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត មិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ១ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត តែទាស់មិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ១ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត ចែករលែក ធ្វើបុណ្យទាំងឡាយ តែនៅជក់ជ្រប់ ឈ្លក់ចិត្តនឹងភោគៈទាំងនោះ មិនឃើញទោស មិនមានបញ្ញាជាគ្រឿងរើខ្លួន ហើយចេះតែបរិភោគ ១ ។ ម្នាលគហបតីក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវ

តាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត ចែករំលែក ធ្វើបុណ្យទាំងឡាយ ថែមទាំងមិនជក់ មិនជ្រប់ មិនឈ្លក់ចិត្តនឹងភោគៈទាំងនោះទេ ឃើញទោស មានបញ្ញាជាគ្រឿងរើខ្លួន ហើយបរិភោគ ១ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ បានមកហើយ មិនធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេតិះដៀលដោយហេតុ ៣ ប្រការ គឺគេតិះដៀលដោយហេតុទី ១ នេះថា ស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ គេតិះដៀលដោយហេតុទី ២ នេះថា មិនធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត គួរគេតិះដៀលដោយហេតុទី ៣ នេះថា មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេតិះដៀលដោយហេតុទាំង ៣ ប្រការនេះ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត តែទាស់មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេតិះដៀលដោយ

ហេតុ ២ ប្រការ គេសរសើរដោយហេតុ ១ ប្រការ គឺគេតិះដៀលដោយហេតុទី ១ នេះថា ស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ គេសរសើរដោយហេតុ ១ ប្រការនេះថា ចេះធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត គេតិះដៀលដោយហេតុទី ២ នេះថា មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេតិះដៀលដោយហេតុទាំង ២ ប្រការនេះ គេសរសើរដោយហេតុ ១ ប្រការនេះ ។ ម្នាលគហបតី បណ្តា អ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត ចែករំលែក ធ្វើបុណ្យទាំងឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេតិះដៀលដោយហេតុ ១ ប្រការ គេសរសើរដោយហេតុ ២ ប្រការ គឺគេតិះដៀលដោយហេតុ ១ ប្រការនេះថា ស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ គេសរសើរដោយហេតុទី ១ នេះថា ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត គេសរសើរដោយហេតុទី ២ នេះថា ចេះចែករំលែក ធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេតិះដៀលដោយហេតុ ១ ប្រការនេះ គេសរសើរដោយហេតុទាំង ២ ប្រការនេះ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ

គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន បានមកហើយ មិនធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត មិនចេះចែករំលែក មិនធ្វើបុណ្យទាំងឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរដោយហេតុ ១ ប្រការ គេតិះដៀលដោយហេតុ ៣ ប្រការ គឺគេសរសើរដោយហេតុ ១ ប្រការនេះថា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ គេតិះដៀលដោយហេតុទី ១ នេះថា ស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ គេតិះដៀលដោយហេតុទី ២ នេះថា មិនធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត គេតិះដៀលដោយហេតុទី ៣ នេះថា មិនចេះចែករំលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរដោយហេតុ ១ ប្រការ គេតិះដៀលដោយហេតុទាំង ៣ ប្រការនេះ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត តែទាស់មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ

ម្នាលគហបតី អ្នកបរិភោគកាមនេះ គេសរសើរដោយហេតុ ២ ប្រការ គេតិះដៀលដោយហេតុ ២ ប្រការ គឺគេសរសើរដោយហេតុទី ១ នេះថា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ គេតិះដៀលដោយហេតុទី ១ នេះថា ស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ គេសរសើរដោយហេតុទី ២ នេះថា ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត គួរគេតិះដៀលដោយហេតុទី ២ នេះថា មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គេសរសើរដោយហេតុទាំង ២ ប្រការនេះ គេតិះដៀលដោយហេតុទាំង ២ ប្រការនេះ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណាស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន បានមកហើយធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត ចែករំលែក ធ្វើបុណ្យទាំងឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរដោយហេតុ ៣ ប្រការ គេតិះដៀលដោយហេតុ ១ ប្រការ គឺគេសរសើរដោយហេតុទី ១ នេះថា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ គេតិះដៀលដោយហេតុ ១ ប្រការនេះថា ស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌

គឺកំហែងសង្កត់សង្កិនគេ គេសរសើរដោយហេតុទី ២ នេះថា ធ្វើខ្លួនឲ្យបាន សុខ ឲ្យឆ្អែត គេសរសើរដោយហេតុទី ៣ នេះថា ចែករំលែក ធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គេសរសើរដោយហេតុទាំង ៣ ប្រការនេះ គេតិះដៀលដោយហេតុ ១ ប្រការនេះ ។ ម្នាលគហបតី បណ្ដាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ មិនធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត មិនចែករំលែក មិនធ្វើបុណ្យទាំង-ឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរដោយហេតុ ១ ប្រការ គេតិះដៀលដោយហេតុ ២ ប្រការ គឺគេសរសើរដោយហេតុ ១ ប្រការនេះថា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិន គេតិះដៀលដោយហេតុទី ១ នេះថា មិនធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត គេតិះដៀលដោយហេតុទី ២ នេះថា មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរដោយហេតុ ១ ប្រការនេះ គេតិះដៀលដោយហេតុ ២ ប្រការនេះ ។ ម្នាលគហបតី បណ្ដាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមក

ហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត តែមិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរដោយហេតុ ២ ប្រការ គេតិះដៀលដោយហេតុ ១ ប្រការ គឺគេសរសើរដោយហេតុទី ១ នេះថា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ គេសរសើរដោយហេតុទី ២ នេះថា ចេះធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត គេតិះដៀលដោយហេតុ ១ ប្រការនេះថា មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរដោយហេតុ ២ ប្រការនេះ គេតិះដៀលដោយហេតុ ១ ប្រការនេះ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត ចែករំលែក ធ្វើបុណ្យទាំងឡាយ តែនៅជក់ជ្រប់ ឈ្លក់ចិត្តនឹងភោគៈទាំងនោះ មិនឃើញទោស មិនមានបញ្ញាជាគ្រឿងរើខ្លួន ហើយចេះតែបរិភោគ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរដោយហេតុ ៣ ប្រការ គេតិះដៀលដោយហេតុ ១ ប្រការ គឺគេសរសើរ ដោយហេតុទី ១ នេះថា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ គេសរសើរដោយហេតុទី ២ នេះថា ចេះធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត គេសរសើរដោយហេតុទី ៣ នេះថា ចេះចែករំលែក ធ្វើបុណ្យទាំងឡាយ គេតិះដៀល

ដោយហេតុ ១ ប្រការនេះថា ជក់ ជ្រប់ ឈ្លក់ចិត្តនឹងភោគៈទាំងនោះ មិនឃើញទោស មិនមានបញ្ញាជាគ្រឿងរើខ្លួន ហើយចេះតែបរិភោគ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរដោយហេតុ ៣ ប្រការនេះ គេតិះដៀលដោយហេតុ ១ ប្រការនេះ ។ ម្នាលគហបតី បណ្ដាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឲ្យបានសុខឲ្យឆ្អែត ចែករំលែក ធ្វើបុណ្យទាំងឡាយ ថែមទាំងមិនជក់ មិនជ្រប់ មិនឈ្លក់ចិត្តនឹងភោគៈទាំងនោះ ឃើញទោស មានបញ្ញាជាគ្រឿងរើខ្លួន ហើយបរិភោគ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរដោយហេតុ ៤ ប្រការ គឺគេសរសើរដោយហេតុទី ១ នេះថា ស្វះស្វែងរកភោគៈទាំងឡាយត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ គេសរសើរដោយហេតុទី ២ នេះថា ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត គេសរសើរដោយហេតុទី ៣ នេះថា ចែករំលែក ធ្វើបុណ្យទាំងឡាយ គេសរសើរដោយហេតុទី ៤ នេះថា មិនជក់ មិនជ្រប់ មិនឈ្លក់ចិត្តនឹងភោគៈទាំងនោះ ឃើញទោស មានបញ្ញាជាគ្រឿងរើខ្លួន ហើយបរិភោគ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គេសរសើរដោយហេតុទាំង ៤ ប្រការនេះ ។ ម្នាលគហបតី អ្នកបរិភោគកាមទាំង ១០ ពួកនេះមានក្នុងលោក ។ ម្នាលគហបតី អ្នកបរិភោគកាមទាំង ១០ ពួកនេះ អ្នក

បរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឲ្យសុខ ឲ្យឆ្អែត ចែករំលែក ធ្វើបុណ្យទាំងឡាយ ថែមទាំងមិនជក់ មិនជ្រប់ មិនឈ្លក់ចិត្តនឹងភោគៈទាំងនោះ ឃើញទោស មានបញ្ញាជាគ្រឿងរំដោះខ្លួន ហើយបរិភោគ បណ្តាអ្នកបរិភោគកាមទាំង ១០ ពួកនេះ អ្នកបរិភោគកាមនេះ ឈ្មោះថា ជាកំពូលផង ប្រសើរផង ចម្បងផង ខ្ពង់ខ្ពស់ផង ថ្លៃថ្លាផង ។ ម្នាលគហបតី ដូចជាទឹកដោះស្រស់ កើតពីមេគោ ទឹកដោះជូរក្លាយពីទឹកដោះស្រស់ ទឹកដោះខាប់ក្លាយពីទឹកដោះជូរ ទឹកដោះរាវក្លាយពីទឹកដោះខាប់ ទឹកដោះថ្លាក្លាយពីទឹកដោះរាវ ទឹកដោះថ្លាប្រាកដជាប្រសើរជាងទឹកដោះទាំងនោះ យ៉ាងណាមិញ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំង ១០ ពួកនេះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត ចែករំលែក ធ្វើបុណ្យទាំងឡាយ ថែមទាំងមិនជក់ មិនជ្រប់ មិនឈ្លក់ចិត្តនឹងភោគៈទាំងនោះ ឃើញទោស មានបញ្ញាជាគ្រឿងរំដោះខ្លួន ហើយបរិភោគ បណ្តាអ្នកបរិភោគកាមទាំង ១០ ពួកនេះ អ្នកបរិភោគកាមនេះ ឈ្មោះថា ជាកំពូលផង ប្រសើរផង ចម្បងផង ខ្ពង់ខ្ពស់ផង ថ្លៃថ្លាផង យ៉ាងនោះដែរ ។

# អដ្ឋកថា

# ឧបាសកវគ្គទី ៥

## កាមភោគីសូត្រ

[ ៩១ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងកាមភោគីសូត្រទី ១ នៃឧបាសកវគ្គទី ៥ ដូចតទៅនេះ បទថា* **សាហសេន** *បានដល់ កម្មដែលគ្រោតគ្រាត ។*

**អដ្ឋកថា កាមភោគីសូត្រទី ១ ចប់**

# សុត្តន្តបិដក

## វេរសូត្រទី ២

[ ៩២ ] *គ្រានោះ អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលគហបតី កាលបើអរិយសាវ័ក រម្ងាប់ភ័យ និងពៀរទាំង ៥ បានហើយ ( អរិយសាវ័កនោះ ) ជាអ្នកបរិបូណ៌ដោយសោតាបត្តិយង្គៈទាំង ៤ ទាំងញាយធម៌ ( មគ្គ ព្រមទាំងវិបស្សនា ) ដ៏ប្រសើរ អរិយសាវ័កនោះ ឃើញហើយដោយប្រពៃ ចាក់ធ្លុះហើយដោយប្រពៃដោយ*

ប្រាជ្ញា កាលបើអរិយសាវកនោះ ចង់ ( ព្យាករ ) ក៏គប្បីព្យាករខ្លួនដោយខ្លួនឯងថា អាត្មាអញអស់នរកហើយ អស់កំណើតតិរច្ឆានហើយ អស់បិត្តិវិស័យហើយ អស់អបាយ ទុគ្គតិ វិនិបាតហើយ អាត្មាអញជាសោតាបន្នបុគ្គល លែងទៅកើតក្នុងអបាយហើយ ជាបុគ្គលទៀងទាត់ ប្រាកដជានឹងបានត្រាស់ដឹងតទៅខាងមុខ ។ ចុះអរិយសាវក បានរម្ងាប់ភ័យ និងពៀរទាំង ៥ តើដូចម្តេច ។ ម្នាលគហបតី អ្នកសម្លាប់សត្វ តែងទទួលភ័យ និងពៀរដែលជាបច្ចុប្បន្នផង ទទួលភ័យ និងពៀរ ក្នុងបរលោកផង រងទុក្ខទោមនស្សដែលប្រព្រឹត្តទៅក្នុងចិត្តផង ព្រោះហេតុតែសម្លាប់សត្វ អ្នកវៀរចាកការសម្លាប់សត្វ តែងមិនទទួលភ័យ និងពៀរជាបច្ចុប្បន្នផង មិនទទួលភ័យ និងពៀរក្នុងបរលោកផង មិនរងទុក្ខទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្តផង ។ កាលអរិយសាវក វៀរចាកការសម្លាប់សត្វ ជាអ្នករម្ងាប់ភ័យ និងពៀរនោះយ៉ាងនេះ ។ ម្នាលគហបតី អ្នកយករបស់ដែលគេមិនបានឲ្យ ... អ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ... អ្នកនិយាយពាក្យកុហក ... អ្នកប្រព្រឹត្តហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកទឹកស្រវឹង គឺសុរា និងមេរ័យ តែងទទួលភ័យ និងពៀរដែលជាបច្ចុប្បន្នផង ក្នុងបរលោកផង រងទុក្ខទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្តផង ព្រោះហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ជាបច្ច័យអ្នកវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកទឹកស្រវឹង គឺសុរា និងមេរ័យ តែងមិនទទួលភ័យ និងពៀរជាបច្ចុប្បន្នផង

មិនទទួលភ័យ និងពៀរ ក្នុងបរលោកផង មិនរងទុក្ខទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្តផង ។ កាលអរិយសាវ័ក វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកទឹកស្រវឹង គឺសុរា និងមេរ័យ រមែងជាអ្នករម្ងាប់ភ័យ និងពៀរនោះយ៉ាងនេះ ។ ភ័យ និងពៀរទាំង ៥ នេះ រមែងស្ងប់រម្ងាប់ទៅ ។ អរិយសាវ័ក អ្នកបរិបូណ៌ដោយសោតាបត្តិយង្គៈ ៤ តើដូចម្តេច ។ ម្នាលគហបតី អរិយសាវ័កក្នុងសាសនានេះ ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លា មិនកម្រើកក្នុងព្រះពុទ្ធថា ព្រះមានព្រះភាគអង្គនោះ ព្រះអង្គឆ្ងាយចាកសឹកសត្រូវ គឺកិលេស ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គឯង ព្រះអង្គបរិបូណ៌ដោយវិជ្ជា និងចរណៈ ព្រះអង្គមានដំណើរល្អ យាងទៅកាន់សុន្ទរដ្ឋាន ព្រះអង្គជ្រាបនូវត្រៃលោក ព្រះអង្គប្រសើរដោយសីលា-ទិគុណ ព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលគួរទូន្មានបាន ព្រះអង្គជាគ្រូរបស់ទេវតា និងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវសច្ចៈទាំងបួន ព្រះអង្គលែងត្រឡប់មកកើតក្នុងត្រៃភព ។ អរិយសាវ័ក ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លា មិនកម្រើកក្នុងព្រះធម៌ថា ព្រះធម៌ដែលព្រះមានព្រះភាគ ទ្រង់សម្តែងហើយដោយប្រពៃ ជាធម៌ គឺព្រះអរិយបុគ្គលឃើញដោយខ្លួនឯង ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌ដែលព្រះអរិយបុគ្គល គួរហៅអ្នកដទៃឲ្យចូលមកមើលបាន ជាធម៌ដែលព្រះអរិយបុគ្គល គួរបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលពួកវិញ្ញូជន គប្បីដឹងដោយខ្លួនឯង ។ អរិយសាវ័ក ជាអ្នកប្រកបដោយ

សេចក្តីជ្រះថ្លា មិនកម្រើកក្នុងព្រះសង្ឃថា ព្រះសង្ឃសាវ័ករបស់ព្រះមានព្រះភាគ ប្រតិបត្តិហើយដោយប្រពៃ ព្រះសង្ឃសាវ័ករបស់ព្រះដ៏មានព្រះភាគ ប្រតិបត្តិហើយដោយត្រង់ ព្រះសង្ឃសាវ័ករបស់ព្រះដ៏មានព្រះភាគ ប្រតិបត្តិហើយដើម្បីត្រាស់ដឹងព្រះនិព្វាន ព្រះសង្ឃសាវ័ក របស់ព្រះដ៏មានព្រះភាគ ប្រតិបត្តិគួរដល់សាមីចិកម្ម ព្រះសង្ឃសាវ័កនេះ បើរាប់ជាគូនៃបុរសមាន ៤ គូ បើរាប់រៀងជាបុរសបុគ្គលមាន ៨ ព្រះសង្ឃសាវ័ករបស់ព្រះមានព្រះភាគនុ៎ះ គួរទទួលវត្ថុដែលបុគ្គលនាំមកបូជា គួរទទួលនូវអាគន្តុកទាន គួរទទួលទក្ខិ-ណាទាន គួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ ជាស្រែបុណ្យដ៏ប្រសើររបស់សត្វលោក ។ អរិយសាវ័ក ជាអ្នកប្រកបដោយសីលទាំងឡាយ ជាទីត្រេកអររបស់ព្រះអរិយៈ ជាសីលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស ជាសីលរបស់អ្នកជា ជាសីលដែលពួកវិញ្ញូជនសរសើរហើយ ជាសីលមិនជ្រោកជ្រាក ជាសីលនាំឲ្យបានសមាធិ ។ អរិយសាវ័កប្រកបដោយសោតាបត្តិយង្គៈទាំង ៤ យ៉ាងនេះឯង ។ ចុះញាយធម៌ដ៏ប្រសើរ ដែលអរិយ-សាវ័កនោះឃើញដោយប្រពៃ ចាក់ធ្លុះដោយប្រពៃដោយបញ្ញា តើដូចម្តេច ។ ម្នាលគហបតី អរិយសាវ័កក្នុងសាសនានេះ ពិចារណាឃើញច្បាស់ថា កាលបើរបស់នេះមាន របស់នេះក៏មាន របស់នេះកើតឡើង ព្រោះកើតរបស់នេះ កាលបើរបស់នេះគ្មាន របស់នេះក៏គ្មាន របស់នេះរលត់ ព្រោះរលត់របស់នេះ យ៉ាងដូចសង្ខារទាំងឡាយ កកើតឡើងព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកកើត

ឡើង ព្រោះសង្ខារជាបច្ច័យ នាមរូបកកើតឡើង ព្រោះវិញ្ញាណជាបច្ច័យ សឡាយតនៈកកើតឡើង ព្រោះនាមរូបជាបច្ច័យ ផស្សៈកកើតឡើង ព្រោះសឡាយតនៈជាបច្ច័យ វេទនាកកើតឡើង ព្រោះផស្សៈជាបច្ច័យ តណ្ហាកកើតឡើង ព្រោះវេទនាជាបច្ច័យ ឧបាទានកកើតឡើង ព្រោះតណ្ហាជាបច្ច័យ ភពកកើតឡើង ព្រោះឧបាទានជាបច្ច័យ ជាតិកកើតឡើង ព្រោះភពជាបច្ច័យ ជរា មរណៈ សោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសកកើតឡើង ព្រោះជាតិជាបច្ច័យ ។ ការកើតនៃកងទុក្ខទាំងអស់នេះ តែងមានយ៉ាងនេះឯង ។ ការរលត់សង្ខារ ព្រោះវិនាស និងការរលត់ អវិជ្ជាមិនមានសេសសល់ ការរលត់វិញ្ញាណ ព្រោះរលត់សង្ខារ ការរលត់នាមរូប ព្រោះរលត់វិញ្ញាណ ការរលត់សឡាយតនៈ ព្រោះរលត់នាមរូប ការរលត់ផស្សៈ ព្រោះរលត់សឡាយតនៈ ការរលត់វេទនា ព្រោះរលត់ផស្សៈ ការរលត់តណ្ហា ព្រោះរលត់វេទនា ការរលត់ឧបាទាន ព្រោះរលត់តណ្ហា ការរលត់ភព ព្រោះរលត់ឧបាទាន ការរលត់ជាតិ ព្រោះរលត់ភព ជរា មរណៈ សោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសរលត់ ព្រោះរលត់ជាតិ ។ ការរលត់នៃកងទុក្ខទាំងអស់នេះ តែងមានយ៉ាងនេះឯង ។ ញាយធម៌ដ៏ប្រសើរនេះ អរិយសាវកនោះបានឃើញច្បាស់ ចាក់ធ្លុះដោយប្រពៃដោយប្រាជ្ញា ។ ម្នាលគហបតី កាលណាអរិយសាវក រម្ងាប់ភ័យ និងពៀរទាំង ៥ ប្រការនេះផង ជាអ្នកបរិបូណ៌ដោយសោតាបត្តិយង្គៈទាំង ៤ ប្រការនេះផង ញាយធម៌ដ៏ប្រសើរនេះផង

អរិយសាវកនោះឃើញដោយប្រពៃ ចាក់ធ្លុះដោយប្រពៃ ដោយប្រាជ្ញាផង ក្នុងកាលនោះ កាលបើអរិយសាវកនោះ ចង់ ( ព្យាករ ) ក៏គប្បីព្យាករខ្លួនដោយខ្លួនឯងថា អាត្មាអញអស់នរកហើយ អស់កំណើតតិរច្ឆានហើយ អស់បិត្តិវិស័យហើយ អស់អបាយ ទុគ្គតិ វិនិបាតហើយ អាត្មាអញជាសោតាបន្នបុគ្គល លែងទៅកើតក្នុងអបាយហើយ ជាបុគ្គលទៀងទាត់ ប្រាកដជានឹងបានត្រាស់ដឹង តទៅខាងមុខ ។

# អដ្ឋកថា

## វេរសូត្រ

[ ៩២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវេរសូត្រទី ២ ដូចតទៅនេះ បទថា **ភយានិ** បានដល់ ភ័យ គឺការតក់ស្លុតនៃចិត្ត ។ បទថា **វេរានិ** បានដល់ អកុសលវេរា និងបុគ្គលវេរា ។ បទថា **អរិយោ ចស្ស ញាយោ** បានដល់ មគ្គ ព្រមទាំងវិបស្សនា ។ បទថា **ឥតិ ឥមស្មឹ សតិ ឥទំ ហោតិ** សេចក្តីថា កាលហេតុមាន អវិជ្ជាជាដើមនេះមានយ៉ាងនេះ ទើបផល មានសង្ខារជាដើមមាន ។ បទថា **ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ** សេចក្តីថា សហជា-តប្បច្ច័យឯណាមាន ព្រោះការកើតឡើងនៃសហជាតប្បច្ច័យនោះ ផលក្រៅ

អំពីនេះ ឈ្មោះថា រមែងកើត ។ បទថា **ឥមស្មឹ អសតិ** សេចក្តីថា កាល ហេតុ មានអវិជ្ជាជាដើមមិនមាន ផល មានសង្ខារជាដើមក៏មិនមាន ។ បទ ថា **ឥមស្ស និរោធា** សេចក្តីថា ព្រោះការមិនប្រព្រឹត្តទៅនៃហេតុ ការមិន ប្រព្រឹត្តទៅនៃផលក៏មាន ៕

**អដ្ឋកថា វេរសូត្រទី ២ ចប់**

# សុត្តន្តបិដក

## ទិដ្ឋិសូត្រទី ៣

[ ៩៣ ] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ អនាថបិណ្ឌិកគហបតី ចេញអំពីក្រុងសាវត្ថីទាំងថ្ងៃត្រង់ ដើម្បីទៅគាល់ព្រះដ៏មានព្រះភាគ ។ ទើប អនាថបិណ្ឌិកគហបតី មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលនេះជាកាលមិនគួរ ដើម្បីទៅគាល់ព្រះមានព្រះភាគទេ ដ្បិតព្រះមានព្រះភាគកំពុងសម្ងំ កាលនេះ ជាកាលមិនគួរដើម្បីទៅជួបនឹងពួកភិក្ខុ អ្នកចម្រើនសមាធិចិត្តទេ ដ្បិតពួកភិក្ខុ អ្នកចម្រើនសមាធិចិត្ត កំពុងសម្ងំដែរ បើដូច្នោះ គួរតែអាត្មាអញ ចូលទៅ ឯអារាម ពួកអន្យតិរ្ថិយបរិព្វាជកសិន ។ គ្រានោះ អនាថបិណ្ឌិកគហបតី

ចូលទៅឯអារាម ពួកអន្យតិរ្ថិយបរិព្វាជក ។ សម័យនោះឯង ពួកអន្យតិរ្ថិយ-បរិព្វាជក ប្រជុំគ្នា មកជួបជុំ និយាយគ្នាកោកកាក គឹកកងរំពង ហើយអង្គុយជជែកគ្នាពីតិរច្ឆានកថាផ្សេងៗ ។ អន្យតិរ្ថិយបរិព្វាជកទាំងនោះ បានឃើញអនាថបិណ្ឌិកគហបតី កំពុងដើរមកពីចម្ងាយ លុះឃើញហើយក៏ឃាត់គ្នីគ្នាថា អ្នកទាំងឡាយនិយាយតិចៗ អ្នកទាំងឡាយកុំនិយាយខ្លាំង ( ព្រោះ ) អនាថបិណ្ឌិកគហបតីនេះ ជាសាវ័កនៃសមណគោតមគាត់មក ពួកគ្រហស្ថអ្នកស្លៀកពាក់ស ជាសាវ័កនៃសមណគោតម ដែលនៅក្នុងក្រុងសាវត្ថីទាំងប៉ុន្មាន បណ្តាគ្រហស្ថជាសាវ័កទាំងនោះ អនាថបិណ្ឌិកគហបតីនេះ ជាសាវ័កម្នាក់ដែរ អ្នកដ៏មានអាយុទាំងនោះ ត្រូវការតែសំឡេងតិច ហាត់ខាងតែសំឡេងតិច និយាយសរសើរតែសំឡេងតិច យើងធ្វើដូចម្តេច ឲ្យទាល់តែអនាថបិណ្ឌិកគហបតីសម្គាល់បរិស័ទ មានសំឡេងតិចថា គួរចូលមកបាន ។ ទើបបរិព្វាជកទាំងនោះ នាំគ្នាសម្ងំស្ងាត់ប្រៀប ។ គ្រានោះ អនាថបិណ្ឌិក-គហបតីចូលទៅរកបរិព្វាជកទាំងនោះ លុះចូលទៅដល់ហើយ និយាយរាក់ទាក់ សំណេះសំណាលជាមួយនឹងអន្យតិរ្ថិយបរិព្វាជកទាំងនោះ លុះបង្ហើយពាក្យដែលគួររាក់ទាក់ សំណេះសំណាល គួរឲ្យរឭកហើយ អង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ អន្យតិរ្ថិយ-បរិព្វាជកទាំងនោះនិយាយយ៉ាងនេះថា ម្នាលគហបតី អ្នកចូរមានប្រសាសន៍មកមើល ព្រះសមណគោតម មានសេចក្តីយល់ដូចម្តេច ។ អនាថបិណ្ឌិក-

គហបតីឆ្លើយថា បពិត្រលោកដ៏ចម្រើនទាំងឡាយ ខ្ញុំមិនដឹងសេចក្ដីយល់សព្វគ្រប់របស់ព្រះដ៏មានព្រះភាគទេ ។ ពួកអន្យតិរ្ថិយបរិព្វាជក សួរថា ម្នាលគហបតី បើឥឡូវនេះ លោកមិនជ្រាបសេចក្ដីយល់សព្វគ្រប់ របស់ព្រះសមណគោតមទេ ម្នាលគហបតី លោកចូរមានប្រសាសន៍មកចុះ ពួកភិក្ខុមានសេចក្ដីយល់ដូចម្ដេច ។ បពិត្រលោកដ៏ចម្រើនទាំងឡាយ ខ្ញុំក៏មិនដឹងសេចក្ដីយល់សព្វគ្រប់របស់ពួកភិក្ខុដែរ ។ ម្នាលគហបតី បើអ្នកមិនដឹងសេចក្ដីយល់សព្វគ្រប់ របស់ព្រះសមណគោតម ទាំងមិនដឹងសេចក្ដី យល់សព្វគ្រប់របស់ពួកភិក្ខុ ដោយប្រការដូច្នេះទេ ម្នាលគហបតី លោកមានប្រសាសន៍មកមើល ចុះលោកមានសេចក្ដីយល់ដូចម្ដេច ។ បពិត្រលោកដ៏ចម្រើនទាំងឡាយ យើងមានសេចក្ដីយល់បែបណា ការដែលយើងព្យាករនូវសេចក្ដីយល់បែបនុ៎ះ មិនជាការក្រទេ ប៉ុន្តែ សូមឲ្យលោកដ៏មានអាយុទាំងឡាយ ព្យាករសេចក្ដីយល់ទាំងឡាយ តាមសមគួររបស់ខ្លួនមុនចុះ យើងមានសេចក្ដីយល់បែបណា ការដែលយើង នឹងព្យាករនូវសេចក្ដីយល់បែបនុ៎ះ មិនជាការក្រទេ សឹមយើងព្យាករក្នុងកាលជាខាងក្រោយ ។ កាលដែលអនាថបិណ្ឌិកគហបតី និយាយយ៉ាងនេះហើយ មានបរិព្វាជកម្នាក់និយាយនឹងអនាថបិណ្ឌិកគហបតីយ៉ាងនេះថា ម្នាលគហបតី អាត្មាមានសេចក្ដីយល់យ៉ាងនេះថា លោកទៀង ពាក្យនេះពិត ពាក្យដទៃមិនពិតទេ ។ មានបរិព្វាជកម្នាក់ទៀត និយាយនឹងអនាថបិណ្ឌិកគហបតីយ៉ាងនេះថា ម្នាលគហបតី អាត្មា

មានសេចក្តីយល់យ៉ាងនេះថា លោកមិនទៀង ពាក្យនេះពិត ពាក្យដទៃមិនពិតទេ ។ មានបរិព្វាជកម្នាក់ទៀត និយាយនឹងអនាថបិណ្ឌិកគហបតីយ៉ាងនេះថា ម្នាលគហបតី អាត្មាមានសេចក្តីយល់យ៉ាងនេះថា លោក មានទីបំផុត ... លោក មិនមានទីបំផុត ... ជីវិតនោះ គឺសរីរៈនោះ ... ជីវិតដទៃ សរីរៈដទៃ ... សត្វ ស្លាប់ទៅកើតទៀត ... សត្វ ស្លាប់ទៅមិនកើតទៀត .. សត្វ ស្លាប់ទៅកើតទៀតក៏មាន មិនកើតទៀតក៏មាន ... សត្វ ស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះពិត ពាក្យដទៃមិនពិតទេ ។ កាលដែលពួកបរិព្វាជកនិយាយយ៉ាងនេះហើយ អនាថបិណ្ឌិកសេដ្ឋីគហបតីនិយាយនឹងពួកបរិព្វាជកទាំងនោះយ៉ាងនេះថា បពិត្រលោកដ៏ចម្រើនទាំងឡាយ លោកដ៏មានអាយុណានិយាយយ៉ាងនេះថា ម្នាលគហបតី អាត្មាយល់យ៉ាងនេះថា លោកទៀង ពាក្យនេះពិត ពាក្យដទៃមិនពិតទេ សេចក្តីយល់របស់លោកដ៏មានអាយុនេះ កើតឡើងព្រោះហេតុនៃការមិនធ្វើទុកក្នុងចិត្តដោយឧបាយនៃខ្លួនឬ ព្រោះហេតុតែសំឡេងរបស់បុគ្គលដទៃ សេចក្តីយល់នោះកើតមានហើយ បច្ច័យតាក់តែងហើយ គិតហើយ ព្រោះអាស្រ័យគ្នាកើតហើយ របស់ណាមួយកើតហើយ បច្ច័យតាក់តែងហើយ គិតហើយ ព្រោះអាស្រ័យគ្នាកើតហើយ របស់នោះមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ លោកដ៏មានអាយុនោះ ឈ្មោះថា ជាប់ស្អិតនឹងរបស់នោះឯង លោកដ៏មានអាយុនោះ ឈ្មោះថា ជំពាក់ស្អិតនឹងរបស់នោះឯង ។ បពិត្រ

លោកដ៏ចម្រើនទាំងឡាយ លោកដ៏មានអាយុណានិយាយយ៉ាងនេះថា ម្នាលគហបតី អាត្មាមានសេចក្ដីយល់យ៉ាងនេះថា លោកមិនទៀង ពាក្យនេះពិត ពាក្យដទៃមិនពិតទេ សេចក្ដីយល់របស់លោកដ៏មានអាយុនេះកើតឡើងព្រោះហេតុ មិនធ្វើទុកក្នុងចិត្តដោយឧបាយនៃខ្លួនឬៗ ព្រោះហេតុតែសំឡេងរបស់បុគ្គលដទៃ សេចក្ដីយល់នោះកើតមានហើយ បច្ច័យតាក់តែងហើយ គិតហើយ ព្រោះអាស្រ័យគ្នាកើតហើយ របស់ណាមួយកើតហើយ បច្ច័យតាក់តែងហើយ គិតហើយ ព្រោះអាស្រ័យគ្នាកើតហើយ របស់នោះមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ លោកដ៏មានអាយុនោះឈ្មោះថា ជាប់ស្អិតនឹងរបស់នោះ លោកដ៏មានអាយុនោះ ឈ្មោះថាជំពាក់ស្អិតនឹងរបស់នោះ ។ បពិត្រលោកដ៏ចម្រើនទាំងឡាយ លោកដ៏មានអាយុណានិយាយយ៉ាងនេះថា ម្នាលគហបតី អាត្មាមានសេចក្ដីយល់យ៉ាងនេះថា លោក មានទីបំផុត ... លោក មិនមានទីបំផុត ... ជីវិតនោះ គឺសរីរៈនោះ ... ជីវិតដទៃ សរីរៈដទៃ ... សត្វ ស្លាប់ទៅកើតទៀត ... សត្វ ស្លាប់ទៅមិនកើតទៀត ... សត្វ ស្លាប់ទៅកើតទៀតក៏មាន មិនកើតទៀតក៏មាន ... សត្វ ស្លាប់កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះពិត ពាក្យដទៃមិនពិតទេ សេចក្ដីយល់របស់លោកដ៏មានអាយុនេះ កើតឡើងហើយព្រោះហេតុនៃការមិនធ្វើទុកក្នុងចិត្តដោយឧបាយនៃខ្លួន ឬព្រោះហេតុតែសំឡេងរបស់បុគ្គលដទៃ សេចក្ដីយល់នោះកើតហើយ បច្ច័យតាក់តែងហើយ គិត

ហើយ អាស្រ័យគ្នាកើតហើយ របស់ណាមួយកើតហើយ បច្ច័យតាក់តែង ហើយ គិតហើយ អាស្រ័យគ្នាកើតហើយ របស់នោះមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ លោកដ៏មានអាយុនោះ ឈ្មោះថា ជាប់ស្អិតនឹងរបស់នោះ លោកដ៏មានអាយុនោះឈ្មោះថា ជំពាក់ស្អិតនឹងរបស់នោះ ។ កាលដែលអនាថបិណ្ឌិកគហបតីនិយាយយ៉ាងនេះហើយ បរិញ្វជកនោះនិយាយនឹងអនាថបិណ្ឌិកគហបតីយ៉ាងនេះថា ម្នាលគហបតី ពួកយើងទាំងអស់គ្នា បានព្យាករសេចក្ដីយល់តាមសមគួររបស់ខ្លួនហើយ ម្នាលគហបតី លោកមានប្រសាសន៍មកមើល ចុះលោកមានសេចក្ដីយល់ដូចម្ដេច ។ អនាថបិណ្ឌិកគហបតីឆ្លើយតបថា បពិត្រលោកដ៏ចម្រើនទាំងឡាយ របស់ណាកើតហើយ បច្ច័យតាក់តែងហើយ គិតហើយ អាស្រ័យគ្នាកើតហើយ របស់នោះមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ បពិត្រលោកដ៏ចម្រើនទាំងឡាយ ខ្ញុំមានសេចក្ដីយល់របស់នោះយ៉ាងនេះថា នុ៎ះ មិនមែនរបស់អញ នុ៎ះ មិនមែនជាអញ នុ៎ះ មិនមែនជាខ្លួនរបស់អញឡើយ ។ ម្នាលគហបតី របស់ណាមួយកើតហើយ បច្ច័យតាក់តែងហើយ គិតហើយ អាស្រ័យគ្នាកើតហើយ របស់នោះមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ ម្នាលគហបតី អ្នកឈ្មោះថា ជាប់ស្អិតនឹងរបស់នោះ ម្នាលគហបតី អ្នកឈ្មោះថា ជំពាក់ស្អិតនឹងរបស់នោះ ។ បពិត្រលោកដ៏ចម្រើនទាំងឡាយ របស់ណាមួយកើតហើយ បច្ច័យតាក់តែង

ហើយ គិតហើយ អាស្រ័យគ្នាកើតហើយ របស់នោះមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ ខ្ញុំយល់របស់នោះដោយប្រពៃដោយប្រាជ្ញាដ៏ត្រឹមត្រូវតាមសេចក្តីពិតយ៉ាងនេះថា នុ៎ះ មិនមែនរបស់អញនុ៎ះ មិនមែនជាអញ នុ៎ះ មិនមែនជាខ្លួនរបស់អញឡើយ ទាំងខ្ញុំដឹងច្បាស់នូវការរលាស់ចេញនូវរបស់នោះ តទៅទៀតតាមសេចក្តីពិត ។ កាលដែលអនាថបិណ្ឌិកគហបតីនិយាយយ៉ាងនេះហើយ បរិព្វាជកទាំងនោះ នៅស្ងៀមអៀនខ្មាស ឱនក សំយុងមុខ អន្ទយសញ្ជប់សញ្ជឹង គ្មានបដិភាណ ។ លំដាប់នោះ អនាថបិណ្ឌិកគហបតី ដឹងថា បរិព្វាជកទាំងនោះ នៅស្ងៀមអៀនខ្មាស ឱនក សំយុងមុខ សញ្ជប់សញ្ជឹង គ្មានបដិភាណហើយ ក៏ក្រោកចាកអាសនៈ ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិក-គហបតីអង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលការចរចាទាំងប៉ុន្មាន ( ដែលខ្លួននិយាយ ) ជាមួយនឹងអន្យតិរ្ថិយបរិព្វាជកទាំងនោះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលគហបតី ល្អហើយៗ ម្នាលគហបតី អ្នកត្រូវផ្ចញ់ផ្ចាល់មោឃបុរសទាំងនោះ ឲ្យរៀបរយតាមគន្លងធម៌ សព្វៗ កាលយ៉ាងនេះចុះ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ណែនាំអនាថ-បិណ្ឌិកគហបតីឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ។ លុះព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ណែនាំឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ

ដោយធម្មីកថាហើយ ទើបអនាថបិណ្ឌិកគហបតីក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយធ្វើប្រទក្សិណ រួចចេញទៅ ។ កាលអនាថបិណ្ឌិកគហបតីចេញទៅមិនយូរប៉ុន្មាន ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាបួសត្រឹមត្រូវក្នុងធម្មវិន័យនេះអស់កាលយូរ ភិក្ខុនោះគួរផ្ចាញ់ផ្ចាល់នូវពួកអន្យតិរ្ថិយបរិញ្វាជក ឲ្យរៀបរយតាមគន្លងធម៌ ដូចជាអនាថបិណ្ឌិកគហបតីផ្ចាញ់ផ្ចាល់យ៉ាងនេះចុះ ។

# អដ្ឋកថា

## ទិដ្ឋិសូត្រ

[ ៩៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទិដ្ឋិសូត្រទី ៣ ដូចតទៅនេះ បទថា **សណ្ឋាបេសុំ** បានដល់ ផ្លូវនៃការដើរខុះ គន្លងនៃវាចាខុះ ។ បទថា **អប្បសទ្ទវិនីតា** បានដល់ បុគ្គលដែលព្រះសាស្តាមានព្រះសូរសៀងតិច ត្រាស់តែល្មមប្រមាណ ទ្រង់ដឹកនាំហើយ ។ បទថា **បរឃោសប្បច្ចយា វា** បានដល់ ឬព្រោះពាក្យរបស់បុគ្គលដទៃជាហេតុ ។ បទថា **ចេតយិតា** បានដល់ កំណត់ហើយ ។ បទថា **មង្កុភូតា** បានដល់ ខូចចិត្ត អស់អំណាច ។ បទថា **បត្តក្ខន្ធា** ប្រែថា ឱនក ។ បទថា **សហធម្មេន** បានដល់ ដោយពាក្យដែលមានហេតុ មានការណ៍ ៕

**អដ្ឋកថា ទិដ្ឋិសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## វជ្ជិយសូត្រទី ៤

[ ៩៤ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្បែរឆ្នេរស្រះបោក្ខរណី ឈ្មោះគគ្គរា ទៀបក្រុងចម្បា ។ គ្រានោះ វជ្ជិយមាហិតគហបតីចេញអំពីក្រុងចម្បាទៅទាំងថ្ងៃត្រង់ ដើម្បីគាល់ព្រះដ៏មានព្រះភាគ ។ លំដាប់នោះ វជ្ជិយមាហិតគហបតីមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលនេះ ជាកាលមិនគួរដើម្បីគាល់ព្រះដ៏មានព្រះភាគទេ ដ្បិតព្រះដ៏មានព្រះភាគ កំពុងសម្ងំ កាលនេះ ជាកាលមិនគួរដើម្បីឲ្យជួបភិក្ខុទាំងឡាយ អ្នកចម្រើនសមាធិចិត្តទេ ដ្បិតភិក្ខុទាំងឡាយ អ្នកចម្រើនសមាធិចិត្ត កំពុងសម្ងំដែរ បើដូច្នោះ គួរតែអាត្មាអញចូលទៅឯអារាម របស់ពួកអន្យតិរ្ថិយបរិព្វាជកសិនចុះ ។ លំដាប់នោះ វជ្ជិយមាហិតគហបតី ចូលទៅឯអារាមរបស់ពួកអន្យតិរ្ថិយបរិព្វាជក ។ សម័យនោះ ពួកអន្យតិរ្ថិយបរិព្វាជកប្រជុំគ្នា មកជួបជុំនិយាយគ្នាកោកកាកគឹកកង រំពង អង្គុយជជែកគ្នាពីតិរច្ឆានកថាផ្សេងៗ ។ អន្យតិរ្ថិយបរិព្វាជកទាំងនោះ បានឃើញវជ្ជិយមាហិតគហបតី កំពុងដើរមកពីចម្ងាយ លុះឃើញហើយ ក៏ឃាត់គ្នីគ្នាថា អ្នកទាំងឡាយនិយាយតិចៗ អ្នកទាំងឡាយកុំនិយាយខ្លាំង ( ព្រោះ ) វជ្ជិយមាហិតគហបតីនេះ ជាសាវកសមណគោតមគាត់មក ។ ពួកគ្រហស្ថអ្នកស្លៀកពាក់ស ជាសាវកសមណគោតម ដែលនៅក្នុងក្រុងចម្បាទាំងប៉ុន្មាន បណ្តាគ្រហស្ថជាសាវកទាំងនោះ វជ្ជិយមាហិតគហបតីនេះជាសាវកម្នាក់ដែរ ។ អ្នកដ៏មានអាយុទាំងនោះ ត្រូវការតែសំឡេងតិច ហាត់

តែសំឡេងតិច និយាយសរសើរតែសំឡេងតិច យើងធ្វើដូចម្ដេចឲ្យទាល់តែវជ្ជិយមាហិតគហបតីសម្គាល់បរិស័ទ មានសំឡេងតិចថា គួរចូលមករក ។ ទើបបរិព្វាជកទាំងនោះ នាំគ្នាស្ងៀម ។ លំដាប់នោះ វជ្ជិយមាហិតគហបតីចូលទៅរកបរិព្វាជកទាំងនោះ លុះចូលទៅដល់ហើយ ក៏និយាយរាក់ទាក់សំណេះសំណាលជាមួយនឹងអន្យតិ្ថិយបរិព្វាជកទាំងនោះ លុះបង្ហើយពាក្យដែលគួររាក់ទាក់ សំណេះសំណាលគួរឲ្យរឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះវជ្ជិយមាហិតគហបតី អង្គុយក្នុងទីសមគួរហើយ បរិព្វាជកទាំងនោះ ក៏និយាយយ៉ាងនេះថា ម្នាលគហបតី ឮថា ព្រះសមណគោតមតែងតិះដៀលតបធម៌ទាំងនោះ ត្មះតិះដៀល បន្តុះបង្អាប់បុគ្គលមានតបៈ រស់នៅដោយសេចក្ដីសៅហ្មងទាំងអស់តែម្យ៉ាងមែនឬ ។ បពិត្រលោកដ៏ចម្រើនទាំងឡាយ ព្រះដ៏មានព្រះភាគមិនមែនតិះដៀលតបធម៌ទាំងអស់ ទាំងមិនត្មះតិះដៀល បន្តុះ-បង្អាប់បុគ្គលមានតបៈ រស់នៅដោយសេចក្ដីសៅហ្មងទាំងអស់តែម្យ៉ាងទេ ។ បពិត្រលោកដ៏ចម្រើនទាំងឡាយ ព្រះដ៏មានព្រះភាគ តែងតិះដៀលបុគ្គលដែលគេគួរតិះដៀល តែងសរសើរបុគ្គលដែលគេគួរសរសើរ បពិត្រលោកដ៏ចម្រើនទាំងឡាយ កាលព្រះដ៏មានព្រះភាគ តិះដៀលបុគ្គលដែលគេគួរតិះដៀល សរសើរបុគ្គលដែលគេគួរសរសើរ ព្រះដ៏មានព្រះភាគព្រះអង្គសម្ដែងចែករលែក ព្រះដ៏មានព្រះភាគនោះ ព្រះអង្គមិនមែនជាអ្នកសម្ដែងម៉ៅក្នុងហេតុនុ៎ះទេ ។ កាលដែលវជ្ជិយមាហិតគហបតី និយាយយ៉ាងនេះ

ហើយ មានបរិព្វាជកម្នាក់ និយាយនឹងវជ្ជិយមាហិតគហបតីយ៉ាងនេះថា ម្នាល គហបតី អ្នកចូរបង្អង់សិន អ្នកនិយាយសរសើរគុណ នៃព្រះសមណគោតម ណា ព្រះសមណគោតមនោះ ជាអ្នកញ៉ាំងសត្វឲ្យវិនាស ជាអ្នកបញ្ញត្តព្រះនិព្វាន មិនច្បាស់លាស់ទេតើ ។ បពិត្រលោកដ៏ចម្រើនទាំងឡាយ ខ្ញុំសូមនិយាយនឹងពួកលោកដ៏មានអាយុ តាមគន្លងធម៌ ត្រង់រឿងនេះបន្តិច បពិត្រលោកដ៏ចម្រើនទាំងឡាយ ( ព្រោះ ) ពាក្យនេះ ជាកុសល ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តិហើយ បពិត្រលោកដ៏ចម្រើនទាំងឡាយ ពាក្យនេះ ជាអកុសល ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តិហើយ កាលព្រះដ៏មានព្រះភាគបញ្ញត្តិនូវកុសល និងអកុសលដោយប្រការដូច្នេះ ឈ្មោះថា ជាអ្នកបញ្ញត្តិព្រះនិព្វានត្រឹមត្រូវ ព្រះដ៏មានព្រះភាគនោះ មិនមែនជាអ្នកញ៉ាំងសត្វឲ្យវិនាស មិនមែនជាអ្នកបញ្ញត្តិព្រះនិព្វានមិនច្បាស់លាស់ទេ ។ កាលដែលវជ្ជិយមាហិតគហបតីនិយាយយ៉ាងនេះហើយ បរិព្វាជកទាំងឡាយ នៅស្ងៀមអៀនខ្មាស ឱនក សំយុងមុខ អង្គុយសញ្ជប់សញ្ជឹង គ្មានបដិភាណ ។ លំដាប់នោះ វជ្ជិយមាហិតគហបតីដឹងថា បរិព្វាជកទាំងនោះ នៅស្ងៀម អៀនខ្មាស ឱនក សំយុងមុខ សញ្ជប់សញ្ជឹង គ្មានបដិភាណហើយ ក៏ក្រោកចាកអាសនៈចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះវជ្ជិយមាហិតគហបតីអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលការចរចាទាំងប៉ុន្មាន ដែលខ្លួន

និយាយជាមួយនឹងអន្យតិរ្ថិយបរិព្វាជកទាំងឡាយនោះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលគហបតីល្អហើយៗ ម្នាលគហបតី អ្នកត្រូវផ្ចាញ់ផ្ចាល់មោឃបុរសទាំងនោះ ឲ្យរៀបរយតាមគន្លងធម៌ សព្វៗ កាលយ៉ាងនេះចុះ ។ ម្នាលគហបតី តថាគតមិនហៅតបៈ ថាជាធម៌ដែលគេត្រូវដុតកម្តៅទាំងអស់ទេ ម្នាលគហបតី តថាគតក៏មិនហៅតបៈ ថាជាធម៌ដែលគេមិនត្រូវដុតកម្តៅទាំងអស់ទេ ម្នាលគហបតី តថាគតមិនហៅការសមាទានថាជាកិច្ចដែលគេត្រូវសមាទានទាំងអស់ទេ ម្នាលគហបតី តថាគតមិនហៅការសមាទាន ថាជាកិច្ចដែលគេមិនត្រូវសមាទានទាំងអស់ទេ ម្នាលគហបតី តថាគតមិនហៅបធាន ថាជាកិច្ចដែលគេត្រូវតម្កល់ទាំងអស់ទេ ម្នាលគហបតី តថាគតមិនហៅបធាន ថាជាកិច្ចដែលគេមិនត្រូវតម្កល់ទាំងអស់ទេ ម្នាលគហបតី តថាគតមិនហៅបដិនិស្សគ្គៈ ថាជាធម៌ដែលគេត្រូវលះបង់ទាំងអស់ទេ ម្នាលគហបតី តថាគតមិនហៅវិមុត្តិ ថាជាធម្មជាតដែលគេត្រូវរួចស្រឡះទាំងអស់ទេ ម្នាលគហបតី តថាគតមិនហៅវិមុត្តិ ថាជាធម្មជាតដែលគេមិនត្រូវរួចស្រឡះទាំងអស់ទេ ម្នាលគហបតី ព្រោះថា កាលបុគ្គលដុតកម្តៅដោយតបៈណា អកុសលធម៌ទាំងឡាយចម្រើនឡើង កុសលធម៌ទាំងឡាយសាបសូន្យទៅ ទើបតថាគតហៅតបៈ មានសភាពយ៉ាងនេះ ថាជាធម៌ដែលគេមិនត្រូវដុតកម្តៅ ។ ម្នាលគហបតី លុះតែបុគ្គលនោះ ដុតកម្តៅដោយតបៈណា អកុសលធម៌ទាំងឡាយសាបសូន្យទៅ កុសលធម៌ទាំងឡាយ ចម្រើនឡើង

ទើបតថាគតហៅតបៈ មានសភាពយ៉ាងនេះ ថាជាធម៌ដែលគេត្រូវដុតកម្តៅ ។ ម្នាលគហបតី កាលបុគ្គលកាន់យកដោយការសមាទានណា អកុសលធម៌ទាំងឡាយចម្រើនឡើង កុសលធម៌ទាំងឡាយសាបសូន្យទៅ តថាគតហៅការសមាទានមានសភាពយ៉ាងនេះ ថាជាកិច្ចដែលគេមិនត្រូវសមាទាន ។ ម្នាលគហបតី លុះតែបុគ្គលនោះកាន់យកដោយការសមាទានណា អកុសលធម៌ទាំងឡាយសាបសូន្យទៅ កុសលធម៌ទាំងឡាយ ចម្រើនឡើង តថាគតហៅការសមាទានមានសភាពយ៉ាងនេះ ថាជាកិច្ចដែលគេត្រូវកាន់យក ។ ម្នាលគហបតី កាលបុគ្គលតម្កល់ដោយបធានណា អកុសលធម៌ទាំងឡាយចម្រើនឡើង កុសលធម៌ទាំងឡាយសាបសូន្យទៅ តថាគតហៅបធាន មានសភាពយ៉ាងនេះ ថាជាកិច្ចដែលគេមិនត្រូវតម្កល់ ។ ម្នាលគហបតី លុះតែបុគ្គលនោះតម្កល់ដោយបធានណា អកុសលធម៌ទាំងឡាយ សាបសូន្យទៅ កុសលធម៌ទាំងឡាយចម្រើនឡើង តថាគតហៅបធាន មានសភាពយ៉ាងនេះ ថាជាកិច្ចដែលគេត្រូវតម្កល់ ។ ម្នាលគហបតី កាលបុគ្គលលះដោយបដិនិស្សគ្គៈណា អកុសលធម៌ទាំងឡាយ ចម្រើនឡើង កុសលធម៌ទាំងឡាយសាបសូន្យទៅ តថាគតហៅបដិនិស្សគ្គៈ មានសភាពយ៉ាងនេះ ថាជាធម៌ដែលគេមិនត្រូវលះ ។ ម្នាលគហបតី លុះតែបុគ្គលនោះ លះដោយបដិនិស្សគ្គៈណា អកុសលធម៌ទាំងឡាយ សាបសូន្យទៅ កុសលធម៌ទាំងឡាយចម្រើនឡើង តថាគតហៅបដិនិស្សគ្គៈ មានសភាពយ៉ាងនេះ ថាជាធម៌ដែល

គេត្រូវលះ ។ ម្នាលគហបតី កាលបុគ្គលរួបរួមស្រឡះដោយវិមុត្តិណា អកុសលធម៌ទាំងឡាយ ចម្រើនឡើង កុសលធម៌ទាំងឡាយ សាបសូន្យទៅ តថាគតហៅវិមុត្តិ មានសភាពយ៉ាងនេះ ថាជាធម្មជាត ដែលគេមិនត្រូវរួបស្រឡះ ។ ម្នាលគហបតី លុះតែបុគ្គលនោះរួបស្រឡះដោយវិមុត្តិណា អកុសលធម៌ទាំងឡាយ សាបសូន្យទៅ កុសលធម៌ទាំងឡាយ ចម្រើនឡើង តថាគតហៅវិមុត្តិមានសភាពយ៉ាងនេះ ថាជាធម្មជាតិដែលគេត្រូវរួបស្រឡះ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏វជ្ជិយមាហិតគហបតី ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយធ្វើប្រទក្សិណ ចៀសចេញទៅ ។ កាលដែលវជ្ជិយមាហិតគហបតី ចៀសចេញទៅមិនទាន់យូរប៉ុន្មាន ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បើភិក្ខុណាមានធូលីតិចក្នុងភ្នែក ( មិនសូវងងឹតខ្វល់ ) ក្នុងធម្មវិន័យនេះ អស់កាលយូរ ភិក្ខុនោះឯង គួរផ្ចាញ់ផ្ចាល់ពួកអន្យតិរ្ថិយបរិព្វាជកឲ្យរៀបរយ តាមគន្លងធម៌ ដូចជាវជ្ជិយមាហិតគហបតីដែលផ្ចាញ់ផ្ចាល់យ៉ាងនេះបាន ។

# អដ្ឋកថា

## វជ្ជិយសូត្រ

[ ៩៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវជ្ជិយសូត្រទី ៤ ដូចតទៅនេះ គហបតីឈ្មោះយ៉ាងនេះថា **វជ្ជិយមាហិត**។ បទថា **សព្វំ តបំ** សេចក្តីថា មានការធ្វើកិច្ចដែលធ្វើបានលំបាក ជាតបៈគ្រប់យ៉ាង ។ បទថា **សព្វំ តបស្សឹ** បានដល់ ដែលអាស្រ័យតបៈគ្រប់យ៉ាង ។ បទថា **លូខាជីវឹ** បានដល់ ប្រកបរឿយៗ នូវការចិញ្ចឹមជីវិត ដោយធ្វើកិច្ចដែលធ្វើបានលំបាក ។ បទថា **គារយ្ហំ** ប្រែថា បុគ្គលគួរតិះដៀល ។ បទថា **បសំសិយំ** ប្រែថា បុគ្គលគួរសរសើរ ។ បទថា **វេនយិកោ** បានដល់ បុគ្គលដែលខ្លួនឯងមិនបានទូន្មាន តែបុគ្គលដទៃទូន្មាន ។ បទថា **អប្បញ្ញត្តិកោ** សេចក្តីថា មិនអាចបញ្ញត្តិវត្ថុណាមួយ ។ម្យ៉ាងទៀត បទថា **វេនយិកោ** ប្រែថា ដែលធ្វើសត្វឲ្យវិនាស ។ បទថា **អប្បញ្ញត្តិកោ** បានដល់ បញ្ញត្តិព្រះនិព្វានដែលមិនប្រែប្រួល មិនអាចបញ្ញត្តិវត្ថុណាមួយ ក្នុងសស្សតទិដ្ឋិជាដើម ។ បទថា **ន សោ ភគវា វេនយិកោ** សេចក្តីថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ដឹងតាមសេចក្តីពិតយ៉ាងនេះ ទ្រង់បញ្ញត្តិកុសល អកុសល មិនមែនអ្នកដទៃគប្បីដឹកនាំ មិនមែនប្រើអ្នកដទៃឲ្យសិក្សា អធិប្បាយថា ព្រះមានព្រះភាគ មិនមែនជាអ្នកធ្វើសត្វឲ្យវិនាស ទ្រង់ទូន្មានសត្វដោយល្អ ទ្រង់ឲ្យសិក្សាដោយល្អ ទ្រង់ដឹកនាំសត្វ ព្រោះទ្រង់បញ្ញត្តិធម៌ ដែលទ្រង់អាស្រ័យបញ្ញត្តិប្រកបដោយសតិ លោកសម្តែងថា បញ្ញត្តិរបស់ព្រះមានព្រះភាគនោះ ជាបញ្ញត្តិដែលល្អទាំងអស់ ។

បទថា **វិមុត្តិ វិមុច្ចតោ អកុសលា ធម្មា** សេចក្តីថា អកុសលធម៌ទាំងឡាយ ឈ្មោះថា រមែងចម្រើនដល់ចិត្តដែលបង្អោនទៅកាន់អធិមុត្តិ គឺមិច្ឆាទិដ្ឋិ ។ ទ្រង់សំដៅយកសេចក្តីនោះ ទើបត្រាស់ពាក្យនេះ ។ តែការរួចផុតនៃចិត្តក្នុងព្រះសាសនា រមែងមិនស្មុះទៅកាន់សង្ខតធម៌ ព្រោះហេតុនោះ ទើបវិមុត្តិ គឺការរួចផុត ជាបច្ច័យនៃកុសលធម៌ប៉ុណ្ណោះ ។ល។

**អដ្ឋកថា វឌ្ឍិយសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## ឧត្តិយសូត្រទី ៩

[ ៩៥ ] លំដាប់នោះ ឧត្តិយបរិព្វាជកចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏និយាយរាក់ទាក់ សំណេះសំណាលជាមួយនឹងព្រះដ៏មានព្រះភាគ លុះបង្ហើយពាក្យដែលគួររាក់ទាក់ សំណេះសំណាល គួរឲ្យរឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះឧត្តិយបរិព្វាជក អង្គុយក្នុងទីសមគួរហើយ បានទូលសួរព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ចុះលោកទៀង ពាក្យនេះ ពិត ពាក្យដទៃមិនពិតទេ ឬដូចម្តេច ។ ព្រះអង្គត្រាស់ថា ម្នាលឧត្តិយៈ ពាក្យថា លោកទៀង ពាក្យនេះ ពិត ពាក្យ

ដទៃមិនពិតនេះ តថាគតមិនដែលព្យាករទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះលោកមិនទៀង ពាក្យនេះពិត ពាក្យដទៃមិនពិតទេ ឬដូចម្ដេច ។ ម្នាលឧត្តិយៈ ពាក្យថា លោកមិនទៀង ពាក្យនេះពិត ពាក្យដទៃមិនពិតនេះ តថាគតក៏មិនដែលព្យាករដែរ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះលោកមានទីបំផុត ... លោកមិនមានទីបំផុត ... ជីវិតនោះ គឺសរីរៈនោះ ... ជីវិតដទៃ សរីរៈដទៃ ... សត្វ ស្លាប់ទៅកើតទៀត ... សត្វ ស្លាប់ទៅមិនកើតទៀត ... សត្វ ស្លាប់ទៅកើតទៀតក៏មាន មិនកើតទៀតក៏មាន ... សត្វ ស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះ ពិត ពាក្យដទៃមិនពិតទេ ឬដូចម្ដេច ។ ម្នាលឧត្តិយៈ ពាក្យថា សត្វ ស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះ ពិត ពាក្យដទៃមិនពិតនេះ ក៏តថាគតមិនព្យាករដែរ ។ បពិត្រព្រះគោតមដ៏ចម្រើន កាលខ្ញុំសួរថា ចុះលោកនេះ ទៀង ពាក្យនេះ ពិត ពាក្យដទៃមិនពិតទេ ឬដូចម្ដេច ដូច្នេះ ព្រះអង្គត្រាស់ថា ម្នាលឧត្តិយៈ ពាក្យថា លោកទៀង ពាក្យនេះពិត ពាក្យដទៃមិនពិតនេះ តថាគតមិនព្យាករទេ ។ បពិត្រព្រះគោតមដ៏ចម្រើន កាលខ្ញុំសួរថា ចុះលោកមិនទៀង ពាក្យនេះ ពិត ពាក្យដទៃមិនពិតទេ ឬដូចម្ដេច ដូច្នេះ ព្រះអង្គត្រាស់ថា មាលឧត្តិយៈ ពាក្យថា លោកមិនទៀង ពាក្យនេះ ពិត ពាក្យដទៃមិនពិតនេះ តថាគតក៏មិនព្យាករដែរ ។ បពិត្រព្រះគោតមដ៏ចម្រើន កាលខ្ញុំសួរថា លោកមានទីបំផុត ... លោកមិនមានទីបំផុត ... ជីវិតនោះ គឺសរីរៈ

នោះ ... ជីវិតដទៃ សរីរៈដទៃ ... សត្វ ស្លាប់ទៅកើតទៀត ... សត្វ ស្លាប់ទៅមិនកើតទៀត ... សត្វ ស្លាប់ទៅកើតទៀតក៏មាន មិនកើតទៀតក៏មាន ... សត្វ ស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះ ពិត ពាក្យដទៃមិនពិតទេ ឬដូចម្តេច ដូច្នេះ ព្រះអង្គត្រាស់ថា ម្នាលឧត្តិយៈ ពាក្យថា សត្វ ស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះ ពិត ពាក្យដទៃមិនពិតនេះ តថាគតក៏មិនព្យាករដែរ កាលបើយ៉ាងនេះ ចុះព្រះគោតមដ៏ចម្រើនទ្រង់ព្យាករដូចម្តេចវិញ ។ ព្រះអង្គត្រាស់ថា ម្នាលឧត្តិយៈ តថាគតដឹងច្បាស់ហើយ សម្តែងធម៌ដល់សាវកទាំងឡាយ ដើម្បីបរិសុទ្ធដល់ពួកសត្វ ដើម្បីកន្លងនូវសោក និងការខ្សឹកខ្សួល ដើម្បីអស់ទៅនៃទុក្ខទោមនស្ស ដើម្បីត្រាស់ដឹងនូវធម៌ដែលគួរដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ ព្រះគោតមដ៏ចម្រើន ដឹងច្បាស់នូវធម៌ណា ហើយសម្តែងធម៌ដល់ពួកសាវក ដើម្បីបរិសុទ្ធដល់ពួកសត្វ ដើម្បីកន្លងនូវសោក និងការខ្សឹកខ្សួល ដើម្បីអស់ទៅនៃទុក្ខ និងទោមនស្ស ដើម្បីត្រាស់ដឹងនូវធម៌ដែលគួរដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន បើចុះមានតែព្រះអង្គនឹងជញ្ជូនលោកទាំងមូល ឬលោកពាក់កណ្តាល ឬក៏លោកទាំង ៣ ភាគ យកទៅដោយធម៌នោះ ( មិនខាន ) ។ កាលដែលឧត្តិយបរិព្វាជក និយាយយ៉ាងនេះហើយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ស្ងៀម ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ មានសេចក្តីត្រិះរិះយ៉ាងនេះថា កុំឲ្យឧត្តិយបរិព្វាជក បាននូវសេចក្តី

យល់ដ៏លាមកថា អាត្មាអញសួរប្រស្នាទាំងអស់ដែលកើតឡើងដោយខ្លួនឯង ព្រះសមណគោតមទាល់ មិនឆ្លើយ ពិតជាឆ្លើយមិនរួច ដូច្នេះឡើយ ការបាននូវសេចក្ដីយល់នោះ មិនជាប្រយោជន៍ ជាទុក្ខដល់ឧត្តិយបរិញ្វជកនោះ អស់កាលយូរ ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ មានថេរវាចាចំពោះឧត្តិយ-បរិញ្វជកយ៉ាងនេះថា ម្នាលអាវុសោឧត្តិយៈ បើដូច្នោះ មានតែអាត្មានឹងធ្វើសេចក្ដីប្រៀបធៀបឲ្យអ្នកស្ដាប់ ដ្បិតពួកវិញ្ញូបុរសខ្លះ ក្នុងលោកនេះ យល់សេចក្ដីនៃភាសិតបានដោយសារការប្រៀបធៀប ។ ម្នាលអាវុសោឧត្តិយៈ ដូចជាបច្ចន្តិមនគររបស់ព្រះរាជា នគរនោះមានប៉មដ៏មាំ មានកំពែង និងមេទ្វារដ៏មាំ មានទ្វារតែមួយ ។ ត្រង់ទ្វារនៃនគរនោះ មានឆ្មាំទ្វារប៉ិនប្រសប់ ឆ្លៀវឆ្លាស វាងវៃ ឃាត់ពួកជនដែលមិនស្គាល់ បើកឲ្យតែពួកជនដែលស្គាល់ចូលបាន ឆ្មាំទ្វារនោះ ដើរយាមល្បាតតាមផ្លូវជិតកំពែង ជុំវិញនគរនោះ មិនឃើញទីតនៃកំពែង និងចន្លោះនៃកំពែង ល្មមឲ្យឆ្មាចូលរួច ក៏មិនបានឃើញឆ្មាំទ្វារនោះ ថែមទាំងមិនបានដឹងយ៉ាងនេះថា ពួកសត្វតូចៗ ប៉ុណ្ណេះ ចូលទៅកាន់នគរនេះ ឬចេញពីនគរនេះទេ ។ ឆ្មាំទ្វារនោះ គ្រាន់តែចំណាំត្រង់ទ្វារនុ៎ះ យ៉ាងនេះថា ពួកសត្វធំៗ ណាមួយ ចូលមកកាន់នគរនេះ ឬចេញទៅពួកសត្វទាំងអស់នោះ ចូលក្ដី ចេញក្ដី តាមទ្វារនេះ យ៉ាងណាមិញ ។ ម្នាលអាវុសោឧត្តិយៈ ព្រះតថាគតមិនមានសេចក្ដីខ្វល់ខ្វាយយ៉ាងនេះថា តថាគតនឹងជញ្ជូនលោកទាំងមូល ឬលោកពាក់កណ្ដាល ឬក៏លោកទាំង ៣ ភាគទៅ

ដោយធម៌នោះទេ ។ ព្រះតថាគតគ្រាន់តែជ្រាបក្នុងហេតុនុ៎ះយ៉ាងនេះថា តថាគត ជញ្ជូនហើយ ឬកំពុងជញ្ជូន ឬក៏នឹងជញ្ជូនពួកសត្វណាមួយ ចាកលោកបាន ( ទាល់តែ ) សត្វទាំងអស់នោះ លះនីវរណធម៌ទាំង ៥ ប្រការ ជាគ្រឿងសៅហ្មងចិត្ត ដែលធ្វើបញ្ញាឲ្យមានកម្លាំងថយ តម្កល់ចិត្តស៊ប់ក្នុងសតិប្បដ្ឋាន ៤ ចម្រើនពោជ្ឈង្គ ៧ តាមសេចក្តីពិត ទើបតថាគតជញ្ជូនហើយ ឬកំពុងជញ្ជូន ឬក៏នឹងជញ្ជូនសត្វទាំងនុ៎ះចាកលោកយ៉ាងនេះ យ៉ាងនោះដែរ ។ ម្នាលអាវុសោឧត្តិយៈ អ្នកបានសួរប្រស្នាណានឹងព្រះដ៏មានព្រះភាគហើយ អ្នកបានសួរប្រស្នានោះនឹងព្រះដ៏មានព្រះភាគ ដោយទំនងដទៃ ហេតុនោះ បានជាព្រះដ៏មានព្រះភាគ ទ្រង់មិនព្យាករប្រស្នានោះ ឲ្យអ្នកស្តាប់ ។

# អដ្ឋកថា

## ឧត្តិយសូត្រ

[ ៩៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧត្តិយសូត្រទី ៥ ដូចតទៅនេះ បទថា **តុណ្ហី អហោសិ** សេចក្តីថា ឧត្តិយបរិព្វាជកតាំងនៅក្នុងសត្តូបលទ្ធិ គឺលទ្ធិថា មានសត្វ ទើបសួរក្នុងសេចក្តីដែលមិនគួរសួរ ហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ស្ងៀម ។ បទថា **សព្ពំ សាមុក្កំសិកំ វត មេ** សេចក្តីថា ព្រះសមណគោតម ត្រូវយើងសួរពាក្យដ៏ខ្ពស់បំផុតនៃពាក្យសួរគ្រប់យ៉ាង ក៏

ស្ងៀមមិនឆ្លើយ បែបមិនអាចនឹងឆ្លើយបានពិត អ្នកកុំបីមានការយើញខុស ដូចដែលពោលមកនេះឡើយ ។ បទថា **តថស្ស** បានដល់ ទិដ្ឋិនោះ គប្បី កើតឡើងយ៉ាងនេះ ។

បទថា **បច្ចន្តិមំ** សេចក្ដីថា ព្រោះហេតុដែលថែវ និងកំពែងជាដើមនៃ នគរក្នុងមជ្ឈិមប្រទេស មាំទាំ ឬទន់ជ្រាយ ឬមិនជាទីដែលចោររង្កៀសដោយ ប្រការទាំងពួង ដូច្នោះ ទ្រង់មិនកាន់យកសេចក្ដីនោះ ទើបត្រាស់ថា **បច្ចន្តិមំ នគរំ**។ បទថា **ទឡ្ហុទ្ទាលំ** ប្រែថា មានកំពែងរឹង ។ បទថា **ទឡ្ហប្បាការ-តោរណំ** បានដល់ មានកំពែងរឹង និងមានសន្ទះទ្វាររឹង ។ ព្រោះហេតុអ្វី ទើបត្រាស់ថា មានទ្វារមួយ ព្រោះថា ក្នុងនគរដែលមានទ្វារច្រើន ចាំបាច់ មានអ្នករក្សាទ្វារ ដែលឈ្លាសច្រើននាក់ ទ្វារមួយមនុស្សម្នាក់ក៏ល្មម ។ មនុស្សដទៃដែលស្មើដោយបញ្ញារបស់ព្រះតថាគតមិនមាន ព្រោះដូច្នោះ ទើប ពោលថា មានទ្វារមួយ ដើម្បីសម្ដែងការប្រៀបធៀបដែលព្រះសាស្ដា ទ្រង់ ជាបណ្ឌិត និងដូចអ្នកយាមទ្វារ ដូច្នោះ ។

បទថា **បណ្ឌិតោ** បានដល់ ប្រកបដោយភាពជាបណ្ឌិត ។ បទថា **ព្យត្តោ** បានដល់ ប្រកបដោយភាពជាអ្នកអាច ។ បទថា **មេធាវី** បានដល់ ប្រកបដោយមេធា ពោល គឺបញ្ញាដឹងការកើតនៃឋានៈ ។ បទថា **អនុបរិ-យាយបថំ** បានដល់ កំពែងដែលមានឈ្មោះថា ផ្លូវជិតកំពែង ។ បទថា **បាការសន្ធឹ** បានដល់ ទីដែលមិនមានឥដ្ឋ ២ ដុំ ។ បទថា **បាការវិវរំ** បាន

ដល់ ទីដែលប្រហោងនៃកំពែង ។ បទថា **តទេវេតំ បញ្ហំ** សេចក្តីថា ឧត្តិយបរិព្វាជកសួរប្រស្នាដដែល ដែលសួរដោយន័យថា លោកទៀងជាដើម ហើយឈប់ស្ងៀមនោះឯង ។ ដោយបទថា **សព្វោ ច តេន លោកោ** ព្រះថេរៈសម្តែងថា ឧត្តិយបរិព្វាជកតាំងនៅក្នុងសត្តូបលទ្ធិ ទើបសួរដោយអាការដទៃ ។ល។

## អដ្ឋកថា ឧត្តិយសូត្រទី ៥ ចប់

# សុត្តន្តបិដក

## កោកនុទសូត្រទី ៦

[ ៩៦ ] សម័យមួយ ព្រះអានន្ទដ៏មានអាយុ ក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី ដើរចូលទៅរកស្ទឹងតបោទា ដើម្បីលាបស្រឡាបខ្លួន ។ លុះលាបស្រឡាបខ្លួនក្នុងស្ទឹងតបោទាហើយ មានចីវរតែមួយឡើងមក ឈរសំដិលខ្លួនឲ្យស្ងួតដូចមុន ។ កោកនុទបរិព្វាជក ក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី ហើយក៏ចូលទៅរកស្ទឹងតបោទា ដើម្បីលាបស្រឡាបខ្លួនដែរ ។ កោកនុទបរិព្វាជក បានឃើញព្រះអានន្ទដ៏មានអាយុ កំពុងនិមន្តមកអំពីចម្ងាយ លុះឃើញហើយ ក៏សួរព្រះអានន្ទដ៏មានអាយុថា ម្នាលអាវុសោ លោកជាអ្វី

ដែរក្នុងពួកសមណៈទាំងនោះ ។ ម្នាលអាវុសោ យើងជាភិក្ខុ ។ ម្នាលអាវុសោ ពួកជនដូចម្ដេចដែលហៅថា ភិក្ខុ ។ ម្នាលអាវុសោ ពួកសមណៈជាសក្យបុត្តិយ៍ ។ យើងសូមសួរហេតុណាមួយ នឹងលោកដ៏មានអាយុ បើលោកដ៏មានអាយុឲ្យឱកាស ដើម្បីឆ្លើយប្រស្នា ។ ម្នាលអាវុសោ អ្នកចូរសួរមកចុះ យើងស្ដាប់ហើយនឹងប្រាប់បាន ។ ម្នាលលោកដ៏ចម្រើន លោកមានទិដ្ឋិយ៉ាងនេះថា លោកទៀង ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យដែរឬ ។ ម្នាលអាវុសោ យើងមិនមានទិដ្ឋិយ៉ាងនេះថា លោកទៀង ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យ ដូច្នេះទេ ។ ម្នាលលោកដ៏ចម្រើន លោកមានទិដ្ឋិយ៉ាងនេះថា លោក មិនទៀង ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យដែរឬ ។ ម្នាលអាវុសោ យើងមិនមានទិដ្ឋិយ៉ាងនេះថា លោក មិនទៀង ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យ ដូច្នេះទេ ។ ម្នាលលោកដ៏ចម្រើន លោកមានទិដ្ឋិយ៉ាងនេះថា លោកមានទីបំផុត ... លោកមិនមានទីបំផុត ... ជីវិតនោះគឺសរីរៈនោះ ... ជីវិតដទៃ សរីរៈដទៃ ... សត្វ ស្លាប់ទៅរមែងកើតទៀតក៏មាន ... សត្វស្លាប់ទៅមិនកើតទៀតក៏មាន ... សត្វ ស្លាប់ទៅកើតទៀតខ្លះមិនកើតទៀតខ្លះ ... សត្វ ស្លាប់ទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃជាពាក្យសោះសូន្យដែរឬ ។ ម្នាលអាវុសោ យើងមិនមានទិដ្ឋិយ៉ាងនេះថា សត្វ ស្លាប់ទៅកើតទៀតក៏មិន

មែន មិនកើតទៀតក៏មិនមែន ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យ ដូច្នេះទេ ។ បើដូច្នោះ លោកមិនដឹង មិនឃើញទេឬ ។ ម្នាលអាវុសោ យើងមិនមែនមិនដឹង មិនមែនមិនឃើញទេ ម្នាលអាវុសោ យើងដឹង យើងឃើញ ។ កាលខ្ញុំសួរថា ម្នាលលោកដ៏ចម្រើន លោកមានទិដ្ឋិយ៉ាងនេះថា លោកទៀង ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យដែរឬ លោកឆ្លើយថា ម្នាលអាវុសោ យើងមិនមានទិដ្ឋិយ៉ាងនេះថា លោកទៀង ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យដូច្នេះទេ ។ កាលខ្ញុំសួរថា ម្នាលលោកដ៏ចម្រើន លោកមានទិដ្ឋិយ៉ាងនេះថា លោកមិនទៀង ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យដែរឬ លោកឆ្លើយថា ម្នាលអាវុសោ យើងមិនមានទិដ្ឋិយ៉ាងនេះថា លោកមិនទៀង ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃជាពាក្យសោះសូន្យដូច្នេះទេ ។ កាលខ្ញុំសួរដូច្នេះថា ម្នាលលោកដ៏ចម្រើន លោកមានទិដ្ឋិយ៉ាងនេះថា លោកមានទីបំផុត ... លោកមិនមានទីបំផុត ... ជីវិតនោះ គឺសរីរៈនោះ ... ជីវិតដទៃ សរីរៈដទៃ ... សត្វ ស្លាប់ទៅកើតទៀតក៏មាន ... សត្វ ស្លាប់ទៅមិនកើតទៀតក៏មាន ... សត្វស្លាប់ទៅកើតទៀតខ្លះ មិនកើតទៀតខ្លះ ... សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យ ដូច្នេះដែរឬ លោកឆ្លើយថា ម្នាលអាវុសោ យើងមិនមានទិដ្ឋិយ៉ាងនេះថា សត្វ ស្លាប់ទៅកើតទៀតក៏មិនមែន

មិនកើតទៀតក៏មិនមែន ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យ ដូច្នេះទេ ។ កាលខ្ញុំសួរដូច្នេះថា បើដូច្នេះ មានតែលោកមិនដឹង មិនឃើញទេ លោកឆ្លើយថា ម្នាលអាវុសោ យើងមិនមែនមិនដឹង មិនមែនមិនឃើញទេ ម្នាលអាវុសោ យើងដឹង យើងឃើញ ។ ម្នាលអាវុសោ សេចក្ដីនៃភាសិតនេះ តើគប្បីយល់ដូចម្ដេច ។ ម្នាលអាវុសោ ត្រង់ទិដ្ឋិ ( សេចក្ដីយល់ឃើញថា ) លោកទៀង ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យ ម្នាលអាវុសោ ត្រង់ទិដ្ឋិថា លោកមិនទៀង ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យ ម្នាលអាវុសោ ត្រង់ទិដ្ឋិថា លោកមានទីបំផុត ... លោកមិនមានទីបំផុត ... ជីវិតនោះ គឺសរីរៈនោះ ... ជីវិតដទៃ សរីរៈដទៃ ... សត្វ ស្លាប់ទៅកើតទៀតក៏មាន ... សត្វ ស្លាប់ទៅមិនកើតទៀតក៏មាន ... សត្វ ស្លាប់ទៅកើតទៀតខ្លះ មិនកើតទៀតខ្លះ ... សត្វ ស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យ ។ ម្នាលអាវុសោ ទិដ្ឋិទាំងប៉ុន្មាន ហេតុនៃទិដ្ឋិទាំងប៉ុន្មាន ការតាំងនៅនៃទិដ្ឋិ ការរួបរឹតដោយទិដ្ឋិ ការដកឡើងនូវទិដ្ឋិទាំងប៉ុន្មាន យើងដឹងនូវទិដ្ឋិនោះ ឃើញនូវទិដ្ឋិនោះ កាលយើងដឹងនូវទិដ្ឋិនោះ ទើបពោលថា ដឹង កាលឃើញនូវទិដ្ឋិនោះ ទើបពោលថា ឃើញ យើងនឹងពោលថា យើងមិនដឹង មិនឃើញដូចម្ដេចកើត ម្នាលអាវុសោ យើងដឹងមែន ឃើញមែន ។ លោកដ៏មានអាយុ នាមជាអ្វី ពួក

សព្រហ្មចារីបុគ្គលស្គាល់លោកដ៏មានអាយុ ថាដូចម្ដេច ។ ម្នាលអាវុសោ នាមរបស់យើងថា អានន្ទ ដូច្នេះ ពួកសព្រហ្មចារីក៏ស្គាល់យើងថា អានន្ទ ដូច្នេះដែរ ។ លោកដ៏ចម្រើន យើងកាលប្រឹក្សាជាមួយនឹងអាចារ្យជាធំ តែមិនដែលស្គាល់ថា អានន្ទដ៏មានអាយុដូច្នេះសោះ ។ ពិតណាស់ បើយើងស្គាល់ថា នេះជាព្រះអានន្ទដ៏មានអាយុ ដូច្នេះមែន យើងក៏មិនហ៊ានពោលដេញដោលប៉ុណ្ណោះឡើយ សូមព្រះអានន្ទដ៏មានអាយុ អត់ទោសដល់ខ្ញុំឲ្យទាន ។

# អដ្ឋកថា

## កោកនុទសូត្រ

[ ៩៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកោកនុទសូត្រទី ៦ ដូចតទៅនេះ បទថា **បុព្វាបយមានោ** បានដល់ ធ្វើខ្លួនឲ្យប្រាសចាកទឹក ដូចគ្នាមុននឹងស្ងួត ។ សព្ទថា **ក្វេត្ថ** កាត់បទជា **កោ ឯត្ថ អាវុសោ** ។ បទថា **យាវតា អាវុសោ ទិដ្ឋិ** សេចក្ដីថា ឈ្មោះថា ទិដ្ឋិ ៦២ យ៉ាង មានដរាបណា ។ បទថា **យាវតា ទិដ្ឋិដ្ឋានំ** សេចក្ដីថា ឋានៈនៃទិដ្ឋិ ៨ យ៉ាង មានប្រមាណយ៉ាងនេះ គឺខន្ធជាឋានៈទិដ្ឋិក៏មាន អវិជ្ជាក៏មាន ផស្សៈក៏មាន សញ្ញាក៏មាន វិតក្កក៏មាន អយោនិសោមនសិការក៏មាន បាបមិត្តក៏មាន បរតោឃោស ការបបួល

របស់អ្នកដទៃក៏មាន ឈ្មោះថា ហេតុនៃទិដ្ឋិ ។ បទថា **អធិដ្ឋានំ** បានដល់ទីតាំងមាំនៃទិដ្ឋិ ពាក្យនេះជាឈ្មោះនៃទិដ្ឋិដែលតាំងមាំ គ្របសង្កត់ប្រព្រឹត្តទៅ ។

បទថា **ទិដ្ឋិបរិយុដ្ឋានំ** បានដល់ ការចោមរោមនៃទិដ្ឋិដែលលោកពោលយ៉ាងនេះថា ទិដ្ឋិ គឺទិដ្ឋិគតៈ ១ ទិដ្ឋិគហនៈ ទិដ្ឋិ គឺព្រៃស្តុក ១ ទិដ្ឋិកន្តារ ទិដ្ឋិ គឺផ្លូវដាច់ស្រយាល ១ ទិដ្ឋិវិសូក ទិដ្ឋិ គឺសត្រូវ ១ ទិដ្ឋិវិប្ផន្ទិត ទិដ្ឋិ គឺការអន្ទះអន្ទេញ ១ ទិដ្ឋិសំយោជនៈ ទិដ្ឋិ គឺគ្រឿងចង ១ ទិដ្ឋិសល្ល ទិដ្ឋិ គឺព្រួញ ១ ទិដ្ឋិសម្ពាធ ទិដ្ឋិ គឺការបង្អៀតបង្អល់ ១ ទិដ្ឋិបលិពោធ ទិដ្ឋិ គឺគ្រឿងកង្វល់ ១ ទិដ្ឋិពន្ធនៈ ទិដ្ឋិ គឺចំណង ១ ទិដ្ឋិបបាតៈ ទិដ្ឋិ គឺជ្រោះ ១ ទិដ្ឋានុស័យ អនុស័យ គឺទិដ្ឋិ ១ ទិដ្ឋិសន្តាបៈ ទិដ្ឋិ គឺគ្រឿងដុតរោល ១ ទិដ្ឋិបរិឡាហៈ ទិដ្ឋិ គឺគ្រឿងក្តៅក្រហាយ ១ ទិដ្ឋិគន្ថៈ ទិដ្ឋិ គឺគ្រឿងចង ១ ទិដ្ឋុបាទាន ទិដ្ឋិ គឺឧបាទាន ១ ទិដ្ឋាភិនិវេស ទិដ្ឋិ គឺការប្រកាន់មាំ ១ ទិដ្ឋិ-បរាមាស ទិដ្ឋិ គឺការបបោសអង្អែល ១ ។ ពាក្យថា **សមុដ្ឋានំ** ជាវេវចនៈនៃ **ទិដ្ឋាន** នោះឯង សមដូចពាក្យដែលលោកពោលថា **ខន្ធា បច្ចយោ ទិដ្ឋីនំ ឧបាទាយ សមុដ្ឋានដ្ឋេន** ខន្ធជាបច្ច័យ ព្រោះអត្ថថា ទាញយកនូវឋានៈនៃទិដ្ឋិតាំងឡើង ។ គ្រប់បទគប្បីឲ្យពិស្តារ ។ សោតាបត្តិមគ្គ ឈ្មោះថា **ទិដ្ឋិសមុគ្ឃាត** ព្រោះដកទិដ្ឋិគ្រប់យ៉ាងបានជាសមុច្ឆេទ ។ បទថា **តមហំ** បានដល់ យើងដឹងទិដ្ឋិនោះបានគ្រប់យ៉ាង ។ បទថា **ក្យាហំ វក្ខាមិ** ប្រែថា យើងពោលព្រោះហេតុអ្វី ៕

# សុត្តន្តបិដក

## អាហុនេយ្យសូត្រទី ៧

[ ៩៧ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ១០ ប្រការ ជាអ្នកគួរទទួលវត្ថុដែលគេនាំមកបូជា គួរទទួលវត្ថុ ដែលគេនាំមកទទួលភ្ញៀវ គួរទទួលទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។ ប្រកបដោយធម៌ ១០ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារ និងគោចារ ឃើញនូវភ័យក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ១ ជាពហុស្សុតទ្រទ្រង់នូវសូត្រ ចេះចាំដោយច្បាស់លាស់នូវសូត្រ ធម៌ទាំងឡាយណា ដែលមានលម្អបទដើម មានលម្អបទកណ្តាល មានលម្អបទចុង ប្រកាសនូវព្រហ្មចរិយៈព្រមទាំងអត្ថ ទាំងព្យញ្ជនៈ ដ៏បរិសុទ្ធបរិបូណ៌សព្វគ្រប់ ពួកធម៌ដែលមានសភាពដូច្នោះ ភិក្ខុនោះ បានរៀនសូត្រច្រើន បានទ្រទ្រង់ ចាំស្ទាត់រត់មាត់ យល់ច្បាស់ក្នុងចិត្ត ចាក់ធ្លុះល្អដោយទិដ្ឋិ ១ ជាអ្នកមានកល្យាណជនជាមិត្ត មានកល្យាណជនជាសម្លាញ់ មានកល្យាណជនជាទីមូលមិត្ត ១ ជាសម្មាទិដ្ឋិ ប្រកបដោយការឃើញត្រូវ ១ រមែងបាននូវឥទ្ធិវិធញ្ញាណ គឺការតាក់តែងឫទ្ធិបានច្រើនយ៉ាង គឺមនុស្សម្នាក់ ធ្វើឲ្យទៅជាច្រើននាក់ក៏បាន ឬមនុស្សច្រើននាក់ ធ្វើឲ្យទៅជាម្នាក់វិញក៏បាន ដើរទៅកាន់ទីវាល ទីខាងក្រៅ ទីខាងក្រៅជញ្ជាំង ទីខាងក្រៅកំពែង ទីខាងក្រៅភ្នំ មិនទើសទាក់ ដូចគេដើរទៅលើ

អាកាសក៏បាន ងើបឡើង និងមុជចុះក្នុងផែនដី ដូចគេងើបមុជក្នុងទឹកក៏បាន ដើរទៅក្នុងទឹក ក៏មិនបែកធ្លាយទឹក ដូចគេដើរលើផែនដីក៏បាន ទៅក្នុងអាកាសទាំងភ្នែន ដូចសកុណជាត ដែលមានស្លាបក៏បាន យកដៃទៅស្ទាបអង្អែលចាប់ពាល់នូវព្រះចន្ទ និងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះក៏បាន ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោកក៏បាន ១ ឮសំឡេងពីរប្រការបាន គឺសំឡេងជាទិព្វ និងសំឡេងជារបស់មនុស្សធម្មតា ក្នុងទីឆ្ងាយក្តី ជិតក្តី ដោយទិព្វសោតធាតុដ៏បរិសុទ្ធ កន្លងបង់នូវសោតធាតុជារបស់មនុស្សធម្មតា ១ កំណត់ដឹងនូវចិត្តនៃសត្វដទៃ បុគ្គលដទៃ ដោយចិត្តរបស់ខ្លួនបាន គឺដឹងច្បាស់ថា ចិត្តដែលប្រកបដោយរាគៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ចិត្តដែលប្រាសចាករាគៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រាសចាករាគៈ ចិត្តប្រកបដោយទោសៈក្តី ... ចិត្តប្រាសចាកទោសៈក្តី ... ចិត្តប្រកបដោយមោហៈក្តី ... ចិត្តប្រាសចាកមោហៈក្តី ... ចិត្តដែលរួញថយក្តី ... ចិត្តដែលរាយមាយក្តី ... ចិត្តជាមហគ្គតៈក្តី ... ចិត្តមិនមែនជាមហគ្គតៈក្តី ... ចិត្តដែលជាសឧត្តរៈ គឺកាមាវចរក្តី ... ចិត្តដែលជាអនុត្តរៈ គឺរូបាវចរ និងអរូបាវចរក្តី ... ចិត្តដែលខ្ជាប់ខ្ជួនក្តី ... ចិត្តដែលមិនខ្ជាប់ខ្ជួនក្តី ... ចិត្តដែលរួចស្រឡះក្តី ... ចិត្តដែលមិនទាន់រួចផុតស្រឡះក្តី ក៏ដឹងច្បាស់ថា ចិត្តមិនទាន់រួចស្រឡះ ១ រមែងរឭកនូវខន្ធដែលអាស្រ័យនៅក្នុងកាលមុនជាច្រើនប្រការ គឺរឭកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ

៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១ រយជាតិខ្លះ ១ ពាន់ជាតិខ្លះ ១ សែនជាតិខ្លះ អស់សំវដ្តកប្បជាច្រើនខ្លះ អស់វិវដ្តកប្បជាច្រើនខ្លះ អស់សំវដ្តវិវដ្តកប្បជាច្រើនខ្លះថា អាត្មាអញបានកើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខ និងទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះអាត្មាអញច្យុតចាកអត្តភាពនោះហើយ ក៏បានទៅកើតក្នុងភពឯណោះ ដែលទៅកើតក្នុងភពនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខ និងទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះច្យុតចាកអត្តភាពនោះហើយ បានមកកើតក្នុងភពនេះ រមែងរឭកនូវខន្ធដែលអាស្រ័យនៅក្នុងកាលមុនជាច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសដោយប្រការដូច្នេះ ១ មានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងបង់ចក្ខុរបស់មនុស្សធម្មតា ឃើញនូវសត្វទាំងឡាយ ដែលច្យុតដែលកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួនថា អើហ្ន៎ សត្វទាំងឡាយនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលព្រះអរិយៈ ជាមិច្ឆាទិដ្ឋិ ប្រកាន់នូវអំពើជាមិច្ឆាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ ក៏តែងទៅកើតក្នុងអបាយ ទុគ្គតិ

វិនិបាត នរក មួយទៀត សត្វទាំងអម្បាលនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត មិនតិះដៀលព្រះអរិយៈ ជាសម្មាទិដ្ឋិ ប្រកាន់នូវអំពើជាសម្មាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏តែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក មានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុជារបស់មនុស្សធម្មតា ឃើញពួកសត្វដែលច្យុតដែលកើត ជាសត្វថោកទាប ឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ដោយប្រការដូច្នេះ ១ រមែងធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ១០ នេះឯង ទើបជាអ្នកគួរទទួលវត្ថុ ដែលគេនាំមកបូជា គួរទទួលវត្ថុដែលគេនាំមកទទួលភ្ញៀវ គួរទទួលទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។

# អដ្ឋកថា

## អាហុនេយ្យសូត្រ

[ ៩៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអាហុនេយ្យសូត្រទី ៧ ដូចតទៅនេះ បទថា **សម្មាទិដ្ឋិកោ** បានដល់ ដែលមានការឃើញតាមសេចក្តីពិត ។ល។

**អដ្ឋកថាអាហុនេយ្យសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ថេរសូត្រទី ៨

[ ៩៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈប្រកបដោយធម៌ ១០ យ៉ាង នៅក្នុងទិសណាៗ រមែងនៅជាសុខសប្បាយ ។ ប្រកបដោយធម៌ទាំង ១០ យ៉ាង តើដូចម្តេចខ្លះ ។ ភិក្ខុជាថេរៈ ជាអ្នកដឹងរាត្រី បួសយូរ ១ ជាអ្នកមានសីល សមាទាន សិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ជាពហុស្សូត ទ្រទ្រង់នូវសូត្រ ចាំស្ទាត់នូវសូត្រ ធម៌ទាំងឡាយណា មានលម្អបទខាងដើម មានលម្អបទកណ្តាល មានលម្អបទចុង ប្រកាសនូវព្រហ្មចរិយៈ ព្រមទាំងអត្ថ ព្រមទាំងព្យញ្ជនៈដ៏បរិសុទ្ធ បរិបូណ៌ សព្វគ្រប់ ពួកធម៌ដែលមានសភាពដូច្នោះ ភិក្ខុនោះ បានរៀនសូត្រច្រើន បានទ្រទ្រង់ ចាំស្ទាត់រត់មាត់ យល់ច្បាស់ក្នុងចិត្ត ចាក់ធ្លុះល្អដោយទិដ្ឋិ ១ ទាំងបាតិមោក្ខពីរប្រការ ក៏ភិក្ខុនោះ ចាំស្ទាត់ល្អដោយពិស្តារ ចែករលែកដោយល្អ ឲ្យប្រព្រឹត្តទៅដោយល្អ វិនិច្ឆ័យដោយល្អតាមសូត្រ តាមអនុព្យញ្ជនៈ ១ ជាអ្នកឈ្លាសក្នុងការរម្ងាប់អធិករណ៍ដែលកើតឡើង ១ ជាអ្នកប្រាថ្នាធម៌ មានសណ្តាប់ធ្នាប់ គួរជាទីស្រឡាញ់ មានសេចក្តីត្រេកអរដ៏លើសលុប ក្នុងអភិធម្ម និងអភិវិន័យ ១ ជាអ្នកសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារតាមមាន តាមបាន ១ ជាបុគ្គលគួរជ្រះថ្លា ក្នុងការឈានទៅមុខ និងការត្រឡប់ថយក្រោយ ជាអ្នកសង្រួមដោយល្អ ក្នុងការអង្គុយ សូម្បីក្នុងចន្លោះផ្ទះ ១ ជាអ្នកបានតាមសេចក្តីប្រាថ្នា បានដោយមិនលំបាក បានដោយងាយ

នូវឈានទាំង ៤ ដែលប្រព្រឹត្តទៅក្នុងចិត្តដ៏ប្រសើរ នៅជាសុខក្នុងបច្ចុប្បន្ន ១ ធ្វើឲ្យជាក់ច្បាស់សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ដែលប្រកបដោយធម៌ទាំង ១០ យ៉ាងនេះឯង នៅក្នុងទិសណាៗ រមែងនៅជាសុខសប្បាយដោយពិត ។

# អដ្ឋកថា

## ថេរសូត្រ

[ ៩៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងថេរសូត្រទី ៨ ដូចតទៅនេះ បទថា **អធិករណសមុប្បាទវូបសមកុសលោ** បានដល់ ជាបុគ្គលឈ្លាសក្នុងការរម្ងាប់ការកើតឡើង ព្រោះចាប់មូលនៃអធិករណ៍ ៤ បានហើយរម្ងាប់ ។ល។

**អដ្ឋកថា ថេរសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## ឧបាលិសូត្រទី ៩

[ ៩៩ ] គ្រានោះឯង ព្រះឧបាលិដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីសមគួរ ។ លុះព្រះឧបាលិដ៏មានអាយុ អង្គុយនៅក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានប្រាថ្នា ដើម្បីចូលទៅគប់រកសេនាសនៈដ៏ស្ងាត់ ដែលជាព្រៃស្បាត និងព្រៃស្រោង ។ ម្នាលឧបាលិ ពិតណាស់ សេនាសនៈដ៏ស្ងាត់ ដែលជាព្រៃស្បាត និងព្រៃស្រោង សុទ្ធតែជាទីកម្រទ្រាំនៅបាន សេចក្តីស្ងប់ស្ងាត់តែម្នាក់ឯង កម្រនឹងធ្វើបាន កម្រនឹងត្រេកអរម្នាក់ឯងបាន ព្រៃទាំងឡាយ ហាក់ដូចនឹងនាំចិត្តរបស់ភិក្ខុ អ្នកមិនបាននូវសមាធិយកទៅ ។ ម្នាលឧបាលិ បុគ្គលណាពោលយ៉ាងនេះថា អាត្មាអញកាលបើមិនបានសមាធិ នឹងចូលទៅអាស្រ័យ គប់រកសេនាសនៈដ៏ស្ងាត់ ដែលជាព្រៃស្បាត និងព្រៃស្រោង សេចក្តីប៉ុនប៉ងនុ៎ះរបស់ភិក្ខុនោះ នឹងលិចបាត់ទៅវិញ ឬនឹងរសាត់អណ្តែតបានទៅវិញមិនខាន ។ ម្នាលឧបាលិ ដូចជាអន្លង់ទឹកធំ ក្នុងកាលនោះ ដំរីដ៏ប្រសើរមានកម្ពស់ ៧ ហត្ថ ឬ ៧ ហត្ថកន្លះ គប្បីដើរមក ដំរីនោះ មានគំនិតយ៉ាងនេះថា បើដូច្នោះមានតែអាត្មាអញ ចុះកាន់អន្លង់ទឹកនេះ លាងស្លឹកត្រចៀកលេងផង លាងខ្នងលេងផង លុះលាងស្លឹកត្រចៀកលេង លាងខ្នងលេងរួចហើយ ក៏ងូតផងផឹកផងសិន សឹមឡើងដើរចេញទៅតាមប្រាថ្នា ។ ដំរីនោះ ក៏ចុះទៅកាន់អន្លង់

ទឹក ហើយលាងស្លឹកត្រចៀកលេងផង លាងខ្នងលេងផង លុះលាងស្លឹកត្រចៀកលេង លាងខ្នងលេងរួចហើយ ក៏ងូតផង ផឹកផង ហើយឡើងដើរចេញទៅតាមប្រាថ្នា ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលឧបាលិ ព្រោះថា អត្តភាព ( នៃដំរីនោះ ) ធំ តែងបានទួរទីពឹងក្នុងអន្លង់ដ៏ជ្រៅ កាលបើសត្វទន្សាយ ឬសំពោចដើរមក ទន្សាយ ឬសំពោចនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា ចុះអញជាអ្វីទៅ ដំរីជាអ្វីទៅ បើដូច្នោះ មានតែអញចុះទៅកាន់អន្លង់ទឹកនេះ លាងស្លឹកត្រចៀកលេងផង លាងខ្នងលេងផង លុះលាងស្លឹកត្រចៀកលេង លាងខ្នងលេងរួចហើយ ក៏ងូតផង ផឹកផងរួចសិន សឹមឡើងដើរចេញទៅតាមប្រាថ្នា ។ សត្វនោះ មិនបានពិចារណាអន្លង់ទឹកនោះដោយរហ័ស សេចក្ដីប៉ុនប៉ងនុ៎ះ របស់សត្វនោះ នឹងលិចបាត់ទៅវិញ ឬនឹងរសាត់អណ្ដែតបាត់ទៅវិញមិនខាន ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលឧបាលិ ព្រោះថា អត្តភាពវាតូច មិនត្រូវបានទីពឹងក្នុងអន្លង់ដ៏ជ្រៅទេ សេចក្ដីនេះឧបមាយ៉ាងណា ។ ម្នាលឧបាលិ ឧបមេយ្យដូចជាបុគ្គលណា ពោលយ៉ាងនេះថា អាត្មាអញ កាលបើមិនបានសមាធិ នឹងចូលទៅអាស្រ័យ គប់រកសេនាសនៈដ៏ស្ងាត់ ដែលជាព្រៃស្បាត និងព្រៃស្រោង សេចក្ដីប៉ុនប៉ងនុ៎ះ របស់ភិក្ខុនោះ នឹងលិចបាត់ទៅវិញ ឬនឹងរសាត់អណ្ដែតបាត់ទៅវិញមិនខាន ។ ម្នាលឧបាលិ ឬដូចកុមារក្មេងតូចខ្ចីនៅដេកផ្ងារ តែងលេងមូត្រ និងករីសរបស់ខ្លួន ។ ម្នាលឧបាលិ អ្នកសម្គាល់ដំណើរនោះដូចម្ដេច ល្បែងនៃក្មេង

តូចនេះ ពេញបរិបូណ៌ទាំងអស់ហើយឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាល ឧបាលិ កុមារនោះឯង លុះដល់សម័យខាងក្រោយមក អាស្រ័យនូវសេចក្តីចម្រើន អាស្រ័យនូវសេចក្តីចាស់ក្លា នៃឥន្ទ្រិយទាំងឡាយ ល្បែងណារបស់ពួកកុមារ ល្បែងនោះ គឺលេងនង្គ័លតូច លេងហ៊ឹង លេងជាំដូង លេងកង្ហារ លេងពួនជីខ្យាច់ លេងរទេះតូច លេងធ្នូតូច កុមារនោះ តែងលេងដោយល្បែងទាំងនោះ ។ ម្នាលឧបាលិ អ្នកសម្គាល់ដំណើរនោះដូចម្តេច តើល្បែងនេះល្អប្រសើរជាងល្បែងពីមុនហើយឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាល ឧបាលិ កុមារនោះឯង លុះសម័យខាងក្រោយមក អាស្រ័យនូវសេចក្តីចម្រើន អាស្រ័យនូវសេចក្តីចាស់ក្លា នៃឥន្ទ្រិយទាំងឡាយ ក៏ឆ្អែតស្កប់ស្កល់ មូលមិត្តមានគេបម្រើ ដោយកាមគុណទាំង ៥ គឺរូបដែលគប្បីដឹងដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាមគួររីករាយ ១ សំឡេងដែលគប្បីដឹងដោយត្រចៀក ... ១ ក្លិនដែលគប្បីដឹងដោយច្រមុះ ... ១ រសដែលគប្បីដឹងដោយអណ្តាត ... ១ សម្ផស្សដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរជាទីរីករាយ ១ ។ ម្នាលឧបាលិ អ្នកសម្គាល់ដំណើរនោះដូចម្តេច តើល្បែងនេះល្អប្រសើរជាងល្បែងពីមុន ឬមិនមែនទេ ។ មែនហើយ ព្រះអង្គ ។ ម្នាលឧបាលិ ព្រះតថាគតកើតឡើងក្នុងលោកនេះ ព្រះតថាគតឆ្ងាយចាកកិលេស ត្រាស់ដឹងដោយប្រពៃ ដោយខ្លួន

ឯង បរិបូណ៌ដោយវិជ្ជា និងចរណៈ មានដំណើរល្អ ដឹងច្បាស់នូវលោក ជាសារថីអ្នកទូន្មាននូវបុរស មិនមានបុគ្គលណាស្មើ ជាសាស្ដានៃពួកទេវតា និងមនុស្ស ត្រាស់ដឹងនូវសច្ចធម៌ ជាអ្នកចែករំលែកនូវព្រះសទ្ធម្ម ។ ព្រះតថាគតនោះ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក និងពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ព្រមទាំងទេវតា និងមនុស្សដ៏សេស ហើយប្រកាសនូវព្រហ្មចរិយធម៌ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ។ ព្រះតថាគតនោះ សម្ដែងធម៌មានលម្អបទដើម មានលម្អបទកណ្ដាល មានលម្អបទចុង ប្រកាសព្រហ្មចរិយធម៌ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈដ៏បរិសុទ្ធបរិបូណ៌សព្វគ្រប់ ។ គហបតី ឬគហបតិបុត្ត ឬក៏ជន ដែលកើតក្នុងត្រកូលណាមួយ តែងស្ដាប់ធម៌នោះ ។ បុគ្គលនោះ លុះស្ដាប់ហើយ រមែងបាននូវសទ្ធាចំពោះព្រះតថាគត ។ បុគ្គលនោះ ប្រកបដោយការបាននូវសទ្ធានេះហើយ រមែងពិចារណាឃើញច្បាស់ថា ឃរាវាសចង្អៀតចង្អល់ ជាផ្លូវនៃធូលីគឺកិលេស បព្វជ្ជា ទើបមានឱកាសល្អ បុគ្គលអ្នកនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌នេះឲ្យបរិបូណ៌ បរិសុទ្ធដោយចំណែកមួយ ឲ្យដូចជាសង្ខដែលគេខាត់ហើយទេ បើដូច្នោះ គួរតែអាត្មាអញកោរសក់ និងពុកមាត់ ស្លៀកដណ្ដប់សំពត់កាសាយៈ ហើយចេញចាកផ្ទះចូលទៅកាន់ផ្នួស ។ បុគ្គលនោះ លុះសម័យខាងក្រោយមក ក៏លះបង់គំនរទ្រព្យតិច ឬលះបង់គំនរទ្រព្យច្រើន លះបង់វង្សញាតិតិច ឬលះបង់វង្សញាតិច្រើន ហើយកោរ

សក់ និងពុកមាត់ ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ។ បុគ្គលនោះ កាលបួសយ៉ាងនេះហើយ ក៏បំពេញនូវសិក្ខាសាជីវៈសម្រាប់ពួកភិក្ខុ លះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្រ្តាដាក់ចុះហើយ មានសេចក្តីអៀនខ្មាស ដល់នូវសេចក្តីអាណិត មានសេចក្តីអនុគ្រោះដោយប្រយោជន៍ដល់សព្វសត្វ លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន កាន់យកតែរបស់ដែលគេឲ្យ ប្រាថ្នាតែរបស់ដែលគេឲ្យ មានខ្លួនដ៏ស្អាត មិនមែនជាអ្នកលួច លះបង់អព្រហ្មចរិយធម៌ប្រព្រឹត្តតែព្រហ្មចរិយធម៌ ចៀសវាង វៀរចាកមេថុនធម្ម ជាធម៌របស់អ្នកស្រុក លះបង់មុសាវាទ វៀរចាកមុសាវាទ ពោលតែពាក្យពិតដោយពាក្យពិត ជាអ្នកខ្ជាប់ខ្ជួន ដែលគួរអ្នកផងជឿបាន មិនពោលពាក្យបំភ្លាត់សត្វលោក លះបង់បិសុណាវាចា វៀរចាកបិសុណាវាចា មិនស្តាប់ពីនេះ ទៅប្រាប់ក្នុងទីឯណោះ ដើម្បីបំបែកពួកជនទាំងនេះ ឬឮពាក្យក្នុងទីឯណោះ មិនទៅប្រាប់ដល់ពួកជនឯនេះ ដើម្បីបំបែកពួកជនឯណោះ ដូច្នេះ ជាអ្នកផ្សះផ្សាពួកជនដែលបែកគ្នាហើយ ឲ្យកម្លាំងដល់ពួកជន ដែលព្រមព្រៀងគ្នាហើយ មានសេចក្តីព្រមព្រៀងជាទីត្រេកអរ ត្រេកអរក្នុងសេចក្តីព្រមព្រៀង រីករាយក្នុងការព្រមព្រៀង ពោលវាចាដែលជាគ្រឿងនាំឲ្យព្រមព្រៀងគ្នា លះបង់ផរុសវាចា វៀរចាកផរុសវាចា វាចាណាដែលមិនមានទោស ជាវាចាស្រួលដល់ត្រចៀក ជាពាក្យគួរជាទីស្រឡាញ់ គួរតម្កល់ទុកក្នុងហឫទ័យ ជាសម្តី

របស់អ្នកក្រុង ជាទីត្រេកអរដល់ជនច្រើន ជាទីពេញចិត្តដល់ជនច្រើន ពោល តែវាចាបែបនោះឯង លះបង់សម្ផប្បលាបៈ វៀរចាកសម្ផប្បលាបៈ ពោលពាក្យតាមកាលគួរ ពោលពាក្យពិត ពោលពាក្យប្រកបដោយប្រយោជន៍ ពោលពាក្យប្រកបដោយធម៌ ពោលពាក្យប្រកបដោយវិន័យ ពោលពាក្យដែលគួរតម្កល់ទុកក្នុងហឫទ័យ ប្រកបដោយគ្រឿងអាង តាមកាលគួរ ជាពាក្យមានកំណត់ ជាពាក្យប្រកបដោយប្រយោជន៍ ។ ភិក្ខុនោះ វៀរចាកការផ្តាច់ផ្តិលនូវពីជគាម ភូតគាម ជាអ្នកបរិភោគកត្តតែ ១ ពេល វៀរស្រឡះចាកសេចក្តីត្រេកអរក្នុងការបរិភោគក្នុងរាត្រី វៀរចាកការបរិភោគក្នុងវេលាខុស វៀរចាកការច្រៀង រាំ ប្រគំ និងមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌ វៀរចាកការទ្រទ្រង់ និងប្រដាប់តាក់តែងស្អិតស្អាតរាងកាយ ដោយផ្កាកម្រង គ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ វៀរចាកទីដេក ទីអង្គុយ ដ៏ខ្ពស់និងទីដេក ទីអង្គុយដ៏ប្រសើរ វៀរចាកការទទួលមាសប្រាក់ វៀរចាកការទទួលធញ្ញជាតិ ស្រូវស្រស់ វៀរចាកការទទួលកាន់យកនូវសាច់ឆៅ វៀរចាកការទទួលស្ត្រី និងកុមារី វៀរចាកការទទួលខ្ញុំស្រី និងខ្ញុំប្រុស វៀរចាកការទទួលពពែ និងចៀម វៀរចាកការទទួលមាន់ និងជ្រូក វៀរចាកការទទួលដំរី គោ សេះឈ្មោល និងសេះញី វៀរចាកការទទួលស្រែនិងចម្ការ វៀរចាកការទទួលប្រកបទូតកម្ម គឺនាំសំបុត្រ ឬពាក្យបណ្តាំដល់គ្រហស្ថនិងទៅដោយគេបញ្ជូន អំពីផ្ទះ ១ ទៅផ្ទះ ១ វៀរចាកការលក់ និងទិញ វៀរ

ចាកការកោងដោយជញ្ជីង ការបន្លំដោយភាជន៍មាស និងការកោងដោយរង្វាស់រង្វាល់ វៀរចាកអំពើកោងកាច ដោយមួលបង្កាច់បំភាន់ ដោយឧបាយនិងការបន្លំ ដោយរបស់ប្លម វៀរចាកការកាត់នូវអវយវៈ មានដៃ និងជើងជាដើម សម្លាប់ ចាប់ចង ធ្វើឲ្យវង្វេងផ្លូវ ប្លន់អ្នកស្រុក និងកំហែងរឹបយកទ្រព្យគេ ។ ភិក្ខុនោះ ជាអ្នកសន្តោសដោយចីវរជាគ្រឿងរក្សាកាយ ដោយបិណ្ឌបាតជាគ្រឿងរក្សាផ្ទៃ ចៀសចេញទៅក្នុងទិសណាៗ តែងកាន់យក ( គ្រឿងបរិក្ខារ ) តែប៉ុណ្ណោះ ហើយចៀសចេញទៅ ក្នុងទិសនោះៗ ។ ដូចសត្វស្លាបហើរទៅក្នុងទិសណាៗ ក៏មានតែទម្ងន់ស្លាបរបស់ខ្លួនប៉ុណ្ណោះហើរទៅដូចម្តេចមិញ ភិក្ខុជាអ្នកសន្តោសដោយចីវរជាគ្រឿងរក្សាកាយ ដោយបិណ្ឌ-បាតជាគ្រឿងរក្សាផ្ទៃ ចៀសចេញទៅក្នុងទីណាៗ តែងកាន់យក ( គ្រឿងបរិក្ខារ ) តែប៉ុណ្ណោះ ចៀសចេញទៅ ដូច្នេះដែរ ។ ភិក្ខុនោះ ប្រកបព្រមដោយសីលក្ខន្ធដ៏ប្រសើរនេះហើយ រមែងទទួលសេចក្តីសុខ មិនមានទោសខាងក្នុងសន្តាន ។ ភិក្ខុនោះ ឃើញរូបដោយចក្ខុ រមែងមិនកាន់យកនូវនិមិត្តមិនកាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ដ៏លាមកទាំងឡាយ គឺអភិជ្ឈា និងទោមនស្ស គប្បីជាប់តាមនូវបុគ្គល ដែលជាអ្នកមិនសង្រួមនូវឥន្ទ្រិយ គឺចក្ខុណា ភិក្ខុនោះ ក៏ប្រតិបត្តិដើម្បីសង្រួមនូវឥន្ទ្រិយ គឺចក្ខុនោះ រក្សាឥន្ទ្រិយគឺចក្ខុ ដល់នូវការសង្រួមក្នុងឥន្ទ្រិយ គឺចក្ខុ ។ ឮសំឡេងដោយត្រចៀក ... ធុំក្លិនដោយច្រមុះ ... លិទ្ធរសដោយអណ្តាត ... ពាល់ត្រូវផោដ្ឋព្វៈដោយ

កាយ ... ដឹងច្បាស់ធម្មារម្មណ៍ដោយចិត្ត មិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ដ៏លាមកទាំងឡាយ គឺអភិជ្ឈា និងទោមនស្ស គប្បីជាប់តាមនូវបុគ្គល ដែលជាអ្នកមិនសង្រួមនូវឥន្ទ្រិយ គឺចិត្តណា ភិក្ខុនោះក៏ប្រតិបត្តិដើម្បីសង្រួមនូវឥន្ទ្រិយ គឺចិត្តនោះ រក្សាឥន្ទ្រិយ គឺចិត្ត ដល់នូវការសង្រួមក្នុងឥន្ទ្រិយ គឺចិត្ត ។ ភិក្ខុនោះ ប្រកបដោយសេចក្ដីសង្រួមនូវឥន្ទ្រិយដ៏ប្រសើរនេះហើយ ទើបទទួលនូវសេចក្ដីសុខ ដែលមិនច្រឡំដោយកិលេសក្នុងសន្តាន ។ ភិក្ខុនោះ កាលឈានទៅមុខ និងត្រឡប់មកខាងក្រោយ ក៏មានសេចក្ដីដឹងខ្លួន កាលក្រឡេកមើលទៅមុខ និងក្រឡេកមើលទៅទិសផ្សេងៗ ក៏មានសេចក្ដីដឹងខ្លួន កាលបត់ដៃជើង និងលាដៃជើង ក៏មានសេចក្ដីដឹងខ្លួន កាលទ្រទ្រង់នូវសង្ឃាដិ បាត្រ និងចីវរ ក៏មានសេចក្ដីដឹងខ្លួន កាលបរិភោគ ផឹក ទំពាស៊ី ជញ្ជាប់ជញ្ជក់ ក៏មានសេចក្ដីដឹងខ្លួន កាលបន្ទោបង់នូវឧច្ចារៈ និងបស្សាវៈ ក៏មានសេចក្ដីដឹងខ្លួន កាលដើរ ឈរ អង្គុយ ដេក ភ្ញាក់ឡើង និយាយស្ដី ស្ងៀមនៅ ក៏មានសេចក្ដីដឹងខ្លួន ។ ភិក្ខុនោះ ប្រកបដោយសីលក្ខន្ធដ៏ប្រសើរនេះផង ប្រកបដោយការសង្រួមឥន្ទ្រិយដ៏ប្រសើរនេះផង ប្រកបដោយសតិ និងសម្បជញ្ញៈដ៏ប្រសើរនេះផង រមែងគប់រកសេនាសនៈស្ងាត់ គឺព្រៃ ម្លប់ឈើ ភ្នំ ជ្រោះភ្នំ គុហា ក្នុងភ្នំ ព្រៃស្មសាន ព្រៃស្រោង ទីវាល គំនរចំបើង ។ ភិក្ខុនោះ ទៅកាន់ព្រៃក្ដី ទៅកាន់ម្លប់ឈើក្ដី ទៅកាន់ផ្ទះស្ងាត់ក្ដី អង្គុយពែនភ្នែន តាំងកាយឲ្យត្រង់

ហើយតម្រង់ស្មារតី ( ឲ្យមានមុខឆ្ពោះទៅរកកម្មដ្ឋាន ) ។ ភិក្ខុនោះ ក៏លះបង់នូវអភិជ្ឈាក្នុងលោក មានចិត្តប្រាសចាកអភិជ្ឈា ជម្រះចិត្តចាកអភិជ្ឈា លះបង់ព្យាបាទ និងសេចក្តីប្រទូស្ត មានចិត្តមិនមានព្យាបាទ មានសេចក្តីអនុគ្រោះដោយប្រយោជន៍ដល់សព្វសត្វ ជម្រះចាកព្យាបាទ និងសេចក្តីប្រទូស្ត លះបង់ថីនមិទ្ធៈ ប្រាសចាកថីនមិទ្ធៈ មានសេចក្តីសម្គាល់នូវពន្លឺ មានសតិសម្បជញ្ញៈ ជម្រះចិត្តចាកថីនមិទ្ធៈ លះបង់ឧទ្ធច្ចកុក្កុច្ចៈ មិនមានសេចក្តីរាយមាយ មានចិត្តស្ងប់ខាងក្នុងសន្តាន ជម្រះចិត្តចាកឧទ្ធច្ចកុក្កុច្ចៈ លះបង់វិចិកិច្ឆា ឆ្លងចាកវិចិកិច្ឆា មិនមានសេចក្តីសង្ស័យ ក្នុងកុសលធម៌ទាំងឡាយ ជម្រះចិត្តចាកវិចិកិច្ឆា ។ ភិក្ខុនោះ លះបង់នូវនីវរណៈទាំង ៥ នេះ ដែលជាគ្រឿងសៅហ្មងចិត្ត ធ្វើបញ្ញាឲ្យថយកម្លាំង ហើយស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ក៏បានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កៈ និងវិចារៈ មានបីតិ និងសុខដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ។ ម្នាលឧបាលិ អ្នកសម្គាល់ដំណើរនោះដូចម្តេច វិហារធម៌នេះ ល្អវិសេស ប្រសើរវិសេសជាងវិហារធម៌ពីមុនឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលឧបាលិ ពួកសាវករបស់តថាគត កាលពិចារណាឃើញធម៌នេះ ក្នុងខ្លួនហើយ ទើបអាស្រ័យ គប់រកសេនាសនៈដ៏ស្ងាត់ គឺព្រៃស្បាត និងព្រៃស្រោង ដរាបណា តែថាពួកសាវកមិនមែនសុទ្ធតែមានប្រយោជន៍របស់ខ្លួន ដល់ដោយលំដាប់ ដរាបនោះទេ ។ ម្នាលឧបាលិ មួយទៀត ភិក្ខុ ព្រោះរម្ងាប់វិតក្កវិចារៈ ... បានដល់ទុតិយជ្ឈាន ។

ម្នាលឧបាលិ អ្នកសម្គាល់ដំណើរនោះដូចម្តេច វិហារធម៌នេះល្អវិសេស ប្រសើរវិសេសជាងវិហារធម៌ ក្នុងកាលមុនឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលឧបាលិ ពួកសាវ័ករបស់តថាគត កាលពិចារណាឃើញធម៌នេះក្នុងខ្លួនហើយ រមែងអាស្រ័យ គប់រកសេនាសនៈដ៏ស្ងាត់ គឺព្រៃស្បាត និងព្រៃស្រោងជរាបណា តែថា ពួកសាវ័កមិនមែនសុទ្ធតែមានប្រយោជន៍របស់ខ្លួន ដល់ដោយលំដាប់ដរាបនោះទេ ។ ម្នាលឧបាលិ មួយទៀត ភិក្ខុ ព្រោះប្រាសចាកបីតិផង ... ហើយបានដល់នូវតតិយជ្ឈាន ។ ម្នាលឧបាលិ អ្នកសម្គាល់ដំណើរនោះដូចម្តេច វិហារធម៌នេះល្អវិសេស ប្រសើរវិសេសជាងពួកវិហារធម៌ ក្នុងកាលមុនឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលឧបាលិ ពួកសាវ័ករបស់តថាគត កាលពិចារណាឃើញធម៌នេះក្នុងខ្លួនហើយ ក៏រមែងអាស្រ័យ គប់រកសេនា-សនៈដ៏ស្ងាត់ គឺព្រៃស្បាត និងព្រៃស្រោងជរាបណា តែថា ពួកសាវ័កមិនមែនសុទ្ធតែមានប្រយោជន៍របស់ខ្លួនដល់ដោយលំដាប់ ដរាបនោះទេ ។ ម្នាលឧបាលិ មួយទៀត ភិក្ខុព្រោះលះបង់នូវសុខផង ... ហើយបានដល់នូវចតុត្ថជ្ឈាន ។ ម្នាលឧបាលិ អ្នកសម្គាល់នូវដំណើរនោះដូចម្តេច វិហារធម៌នេះល្អវិសេស ប្រសើរវិសេសជាងពួកវិហារធម៌ ក្នុងកាលមុនឬ ។ ព្រះករុណា ព្រះអង្គ ។ ឯពួកសាវ័ករបស់តថាគត កាលពិចារណាឃើញធម៌នេះក្នុងខ្លួនហើយ រមែងអាស្រ័យ គប់រកសេនាសនៈដ៏ស្ងាត់ គឺព្រៃស្បាត និងព្រៃស្រោងជរាបណា តែថា ពួកសាវ័កមិនមែនសុទ្ធតែមានប្រយោជន៍របស់

ខ្លួន ដល់ដោយលំដាប់ដរាបនោះទេ ។ ម្នាលឧបាលិ មួយទៀត ភិក្ខុព្រោះកន្លងបង់នូវរូបសញ្ញា ដោយសព្វគ្រប់ ព្រោះវិនាសទៅនៃបដិឃសញ្ញា ព្រោះមិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ក៏បានដល់នូវអាកាសានញ្ចាយតនជ្ឈាន ដោយបរិកម្មថា អាកាសមិនមានទីបំផុត ។ ម្នាលឧបាលិ អ្នកសម្គាល់ដំណើរនោះដូចម្តេច វិហារធម៌នេះល្អវិសេស ប្រសើរវិសេសជាងពួកវិហារធម៌ ក្នុងកាលមុនឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលឧបាលិ ពួកសាវ័ករបស់តថាគត កាលពិចារណាឃើញធម៌នេះក្នុងខ្លួនហើយ រមែងអាស្រ័យគប់រកសេនាសនៈដ៏ស្ងាត់ គឺព្រៃស្បាត និងព្រៃស្រោងដរាបណា តែថា ពួកសាវ័កមិនមែនសុទ្ធតែមានប្រយោជន៍របស់ខ្លួន ដល់ដោយលំដាប់ដរាបនោះទេ ។ ម្នាលឧបាលិ មួយទៀត ភិក្ខុកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយសព្វគ្រប់ហើយ បានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត ... ភិក្ខុកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈានដោយសព្វគ្រប់ បានដល់អាកិញ្ចញ្ញាយតនជ្ឈាន ដោយបរិកម្មថា វត្ថុតិចតួចមិនមាន ... ភិក្ខុកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយសព្វគ្រប់ បានដល់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយបរិកម្មថា គុណជាតនោះស្ងប់ គុណជាតនោះប្រសើរ ។ ម្នាលឧបាលិ អ្នកសម្គាល់ដំណើរនោះដូចម្តេច ឯវិហារធម៌នេះ ល្អវិសេស ប្រសើរវិសេសជាងពួកវិហារធម៌ក្នុងកាលមុន ឬមិនមែនទេ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលឧបាលិ ពួកសាវ័ករបស់តថាគត កាលពិចារណាឃើញធម៌

នេះក្នុងខ្លួនហើយ រមែងអាស្រ័យ គប់រកសេនាសនៈដ៏ស្ងាត់ គឺព្រៃស្បាត និងព្រៃស្រោងដរាបណា តែថា ពួកសាវក មិនមែនសុទ្ធតែមានប្រយោជន៍របស់ខ្លួន ដល់ដោយលំដាប់ដរាបនោះទេ ។ ម្នាលឧបាលិ មួយទៀត ភិក្ខុកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយសព្វគ្រប់ បានដល់សញ្ញាវេទ-យិតនិរោធ អាសវៈទាំងឡាយរបស់ភិក្ខុនោះ ក៏អស់ទៅ ព្រោះឃើញច្បាស់ដោយប្រាជ្ញា ។ ម្នាលឧបាលិ អ្នកសម្គាល់ដំណើរនោះដូចម្តេច វិហារធម៌នេះ ល្អវិសេស ប្រសើរវិសេសជាងពួកវិហារធម៌ ក្នុងកាលមុន ឬមិនមែនទេ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលឧបាលិ សាវករបស់តថាគត កាលពិចា-រណាឃើញធម៌នេះ ក្នុងខ្លួនហើយ រមែងអាស្រ័យ គប់រកសេនាសនៈដ៏ស្ងាត់ គឺព្រៃស្បាត និងព្រៃស្រោងដរាបណា តែថា ពួកសាវក មិនមែនសុទ្ធតែមានប្រយោជន៍របស់ខ្លួន ដល់ដោយលំដាប់ដរាបនោះទេ ។ ម្នាលឧបាលិ ណ្ហើយ អ្នកចូរនៅក្នុងសង្ឃចុះ កាលបើអ្នកនៅក្នុងសង្ឃ សេចក្តីសុខសប្បាយ នឹងមានប្រាកដ ។

# អដ្ឋកថា

## ឧបាលិសូត្រ

[ ៩៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧបាលិសូត្រទី ៩ ដូចតទៅនេះ បទថា **ទុរភិសម្ភវានិ ហិ** បានដល់ មានបានដោយលំបាក រកបានដោយលំបាក លោកអធិប្បាយថា បុគ្គលមានសក្តិតូចមិនអាចទាញទុកបាន ។ បទថា **អរញ្ញវនបត្ថានិ** សេចក្តីថា ព្រៃធំ និងព្រៃក្រាស់ ឈ្មោះថា **អរញ្ញ** ព្រោះសម្រេចអង្គនៃភាពជាព្រៃ ។ ឈ្មោះថា **វនបត្ថ** ព្រោះហួសចន្លោះស្រុកជាទីដែលពួកមនុស្សមិនចូលទៅជិត ។ បទថា **បត្ថានិ** បានដល់ ឆ្ងាយពន់ពេក ។ បទថា **ទុក្ករំ បវិវេកំ** បានដល់ កាយវិវេកដែលធ្វើលំបាក ។ បទថា **ទុរភិរមំ** បានដល់ មិនមែនត្រេកអរបានងាយ ។ បទថា **ឯកត្តេ** ប្រែថា ភាពជាបុគ្គលម្នាក់ឯង ។ ទ្រង់សំដែងអ្វី ទ្រង់សំដែងថា កាលធ្វើកាយវិវេកបានហើយ ក៏លំបាកដែលនឹងឲ្យចិត្តត្រេកអរក្នុងសេនាសនៈនោះ ។ ពិតហើយ លោកនេះមានរបស់ជាគូៗ គ្នាជាទីត្រេកអរ ។ បទថា **ហរន្តិ មញ្ញេ** បានដល់ ដូចនាំទៅ ដូចទាញយកទៅ ។ បទថា **មនោ** បានដល់ ចិត្ត ។ បទថា **សមាធឹ អលភមានស្ស** បានដល់ បុគ្គលមិនបានឧបចារសមាធិ ឬអប្បនាសមាធិ ។ ទ្រង់សំដែងអ្វី ទ្រង់សំដែងថា ព្រៃទាំងឡាយ ដូចធ្វើចិត្តរបស់ភិក្ខុបែបនេះឲ្យរាយមាយ ដោយសំឡេងស្លឹក ស្មៅ និងម្រឹគជាដើម និងវត្ថុដែលគួរខ្លាច មានប្រភេទផ្សេងៗ ។ បទថា **សំសីទិស្សតិ** បានដល់ លិចចុះដោយកាមវិតក្ក ។ បទថា **ឧប្បិលវិស្សតិ** បានដល់ អណ្តែតឡើងខាងលើ

ដោយព្យាបាទវិតក្ក និងវិហិង្សាវិតក្ក ។

បទថា **កណ្ណាសន្ទោវិកំ** បានដល់ លាងស្លឹកត្រចៀកលេង ។ បទថា **បិដ្ឋិសន្ទោវិកំ** បានដល់ លាងខ្នងលេង ។ ទាំង ២ យ៉ាងនោះ ការចាប់ប្រមោយ និងស្រោចទឹកត្រង់ត្រចៀកទាំងសងខាង ឈ្មោះថា **កណ្ណាសន្ទោ-វិក** ស្រោចទឹកត្រង់ខ្នង ឈ្មោះថា **បិដ្ឋិសន្ទោវិក** ។ បទថា **គាធំ វិន្ទតិ** បានដល់ បាននូវទីពឹង ។ បទថា **កោ ចាហំ កោ ច ហត្ថិនាគោ** សេចក្តីថា យើងជាអ្វី ស្តេចដំរីជាអ្វី ដ្បិតថា យើងក្តី ស្តេចដំរីនេះក្តី ក៏ជាសត្វតិរច្ឆាន ស្តេចដំរីនេះក៏ជើង ៤ យើងក៏ជើង ៤ យើងទាំង ២ ក៏ស្មើគ្នា មិនមែនឬ ។ បទថា **វង្កកំ** បានដល់ នង្គ័លតូចៗ សម្រាប់ក្មេងលេង ។ បទថា **ឃដិកំ** បានដល់ គ្រឿងលេង ឈើខ្លីប្រហារដោយឈើវែង ( លេងហ៊ឹង ) ។ បទថា **មោក្ខចិកំ** បានដល់ គ្រឿងលេងដែលវិលទៅជុំវិញ លោកអធិប្បាយថា គ្រឿងលេងដែលចាប់ជើងលើអាកាស ដាក់ក្បាលចុះត្រង់ផែនដី វិលទៅទាំងខាងក្រោម និងខាងលើ ( លេងដាំដូង ) ។ បទថា **ចិង្គុលិកំ** បានដល់ គ្រឿងលេង មានកង់ដែលធ្វើដោយស្លឹកត្នោតជាដើម វិលទៅបាន ព្រោះខ្យល់ល្អ ( លេងកង្ហារស្លឹកឈើ ) ។ នាឡិស្លឹកឈើ ហៅថា **បត្តាឡ្ហកំ** ពួកក្មេងៗ យកស្លឹកឈើធ្វើជានាឡិនោះវាល់ខ្សាច់លេង ។ បទថា **រថកំ** បានដល់ រថតូចៗ ។ បទថា **ធនុកំ** បានដល់ ធ្នូតូចៗ ។

ពាក្យថា **ភោ** ក្នុងពាក្យថា **ឥធ ខោ បន ភោ** ត្រឹមតែជានិបាត ។

អធិប្បាយថា ក្នុងលោកនេះឯង ។ បទថា **ឥង្ឃ** ក្នុងពាក្យថា **ឥង្ឃ ត្វំ ឧបាលិ សង្ឃេ វិហរាហិ** នេះ ជានិបាត ចុះក្នុងអត្ថថា ដាស់តឿន ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ដាស់តឿនព្រះថេរៈ ដើម្បីជាប្រយោជន៍ដល់ការនៅក្នុងចំណោមសង្ឃ មិនមែនទ្រង់អនុញ្ញាតការនៅព្រៃដល់ព្រះថេរៈនោះ ព្រោះហេតុអ្វី ព្រោះព្រះសាស្តាទ្រង់ត្រិះរិះថា បានឮថា ព្រះថេរៈនៅក្នុងសេនាសនៈព្រៃ នឹងបំពេញបានត្រឹមតែវាសធុរៈ គឺវិបស្សនាធុរៈតែម្យ៉ាង បំពេញគន្ថធុរៈមិនបាន តែព្រះថេរៈកាលនៅក្នុងចំណោមសង្ឃ បំពេញធុរៈនេះបានទាំង ២ យ៉ាង ហើយនឹងសម្រេចអរហត្ត ទាំងជាប្រធានក្នុងចំណែកវិនយបិដក ដូច្នោះ តថាគតនឹងពោលការប្រាថ្នាអំពីមុន និងបុណ្យចាស់របស់លោក និងស្ថាបនាភិក្ខុនេះ ក្នុងតំណែងឯតទគ្គៈរបស់ពួកភិក្ខុ ដែលទ្រទ្រង់វិន័យក្នុងកណ្តាលបរិស័ទ កាលទ្រង់ឃើញសេចក្តីនេះ ទើបទ្រង់មិនអនុញ្ញាតការនៅព្រៃដល់ព្រះថេរៈ ។៚

**អដ្ឋកថា ឧបាលិសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## អភព្វសូត្រទី ១០

[ ១០០ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ទាំង ១០ យ៉ាងនេះចេញ មិនគួរដើម្បីធ្វើឲ្យច្បាស់នូវអរហត្តបានទេ ។ ធម៌ទាំង ១០ យ៉ាងនោះតើដូចម្តេចខ្លះ ។ គឺរាគៈ ១ ទោសៈ ១ មោហៈ ១ កោធៈ ១ ឧបនាហៈ ១ មក្ខៈ ១ បលាសៈ ១ ឥស្សា ១ មច្ឆរិយៈ ១ មានះ ១ ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលមិនបានលះបង់នូវធម៌ទាំង ១០ ប្រការនេះឯង មិនគួរធ្វើឲ្យច្បាស់ នូវអរហត្តបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់នូវធម៌ទាំង ១០ ប្រការនេះ ទើបគួរដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអរហត្ត ។ ធម៌ទាំង ១០ នោះ តើដូចម្តេចខ្លះ ។ គឺរាគៈ ១ ទោសៈ ១ មោហៈ ១ កោធៈ ១ ឧបនាហៈ ១ មក្ខៈ ១ បលាសៈ ១ ឥស្សា ១ មច្ឆរិយៈ ១ មានះ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់នូវធម៌ទាំង ១០ ប្រការនេះឯង ទើបគួរដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអរហត្តបាន ។

ឧបាសកវគ្គទី ៥ ចប់

### ឧទ្ទាននៃវគ្គនោះគឺ

និយាយអំពីបុគ្គល អ្នកបរិភោគកាម ១ អំពីភ័យ និង
ពៀរ ៥ យ៉ាង ១ អំពីទិដ្ឋិ ១ អំពីវជ្ជិយមាហិតគហបតី
និងឧត្តិយបរិព្វាជកទាំងពីរ អំពីកោកនុទបរិព្វាជក ១
អំពីភិក្ខុអ្នកគួរទទួលគ្រឿងបូជា ១ អំពិភិក្ខុជាថេរៈ ១

អំពីឧបាលិដ៏មានអាយុ ១ អំពីបុគ្គលដែលមិនគួរធ្វើឲ្យជាក់ច្បាស់ នូវអរហត្ត ១ ។

ទុតិយបណ្ណាសកទី ២ ចប់

# អដ្ឋកថា

## អភព្វសូត្រ

[ ១០០ ] ក្នុងអភព្វសូត្រទី ១០ មានអត្ថងាយយល់ហើយ ។

**អដ្ឋកថា អភព្វសូត្រទី ១០ ចប់**

**ឧបាសកវគ្គទី ៥ ចប់**

**ទុតិយបណ្ណាសក ចប់**

# សុត្តន្តបិដក
# អង្គុត្តរនិកាយ ទសកនិបាត
# ទ្វាទសមភាគ
# តតិយបណ្ណាសក

## សមណសញ្ញាវគ្គទី ១
### សមណសញ្ញាសូត្រទី ១

[ ១ ] ម្នាលភិក្ខុទាំងឡាយ សមណសញ្ញា ( សេចក្តីសម្គាល់របស់សមណៈ ) ៣ យ៉ាង ដែលភិក្ខុបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ រមែងញុំាងធម៌ ៧ ប្រការឲ្យពេញលេញបាន ។ ៣ យ៉ាង តើអ្វីខ្លះ ។ គឺ ( បព្វជិតគប្បីពិចារណារឿយៗ ថា ) អាត្មាអញនេះ កាន់យកនូវភេទផ្សេង ( អំពីភេទរបស់គ្រហស្ថ ) ១ ការប្រព្រឹត្តចិញ្ចឹមជីវិតរបស់អាត្មាអញ រមែងប្រព្រឹត្តជាប់ដោយបុគ្គលដទៃ ១ អាត្មាអញគប្បីធ្វើអាកប្បកិរិយាផ្សេង ( អំពីគ្រហស្ថ ) ១ ។ ម្នាលភិក្ខុទាំងឡាយ សមណសញ្ញា ៣ យ៉ាងនេះឯង ដែលភិក្ខុបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ រមែងញុំាងធម៌ ៧ ប្រការឲ្យពេញលេញ

បាន ។ ធម៌ ៧ ប្រការ តើអ្វីខ្លះ ។ គឺភិក្ខុជាអ្នកធ្វើរឿយៗ ជានិច្ច ប្រព្រឹត្ត មិនដាច់ក្នុងសីលទាំងឡាយ ១ ជាអ្នកមិនមានសេចក្តីលោភ ១ ជាអ្នកមិនបៀតបៀន ១ ជាអ្នកមិនមើលងាយគេ ១ ជាអ្នកមានសេចក្តីប្រាថ្នាក្នុងសិក្ខា ១ ភិក្ខុនោះមានសេចក្តីយល់ថា នេះជាប្រយោជន៍ ក្នុងជីវិតបរិក្ខារទាំងឡាយ ១ ជាអ្នកប្រារព្ធនូវព្យាយាម ១ ។ ម្នាលភិក្ខុទាំងឡាយ សមណសញ្ញា ៣ យ៉ាងនេះឯង ដែលភិក្ខុបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ រមែងញ៉ាំង ធម៌ ៧ ប្រការនេះ ឲ្យពេញលេញបាន ។

# អដ្ឋកថា
# តតិយបណ្ណាសក

## សមណសញ្ញាវគ្គទី ១

### សមណសញ្ញាសូត្រ

*[ ១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសមណសញ្ញាសូត្រទី ១ នៃទុតិយ-បណ្ណាសកដូចតទៅនេះ បទថា* **សមណសញ្ញា** *បានដល់ ការសម្គាល់ដែលកើតឡើងដល់សមណៈទាំងឡាយ ។ បទថា* **សតតការី** *បានដល់ ធ្វើមិនមានចន្លោះ ។ បទថា* **អព្យាបជ្ឈា** *បានដល់ មិនមានទុក្ខ ។ បទថា* **ឥច្ចុត្តន្តិស្ស ហោតិ** *សេចក្តីថា សមណសញ្ញារមែងមានដល់ភិក្ខុនោះ ក្នុងបច្ច័យជាគ្រឿងតាក់តែងជីវិតយ៉ាងនេះថា ទាំងនេះ ជាបច្ច័យដើម្បីវត្ថុនេះ អធិប្បាយថា ភិក្ខុបរិភោគបច្ច័យដែលពិចារណាហើយ ។*

**អដ្ឋកថា សមណសញ្ញាសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ពោជ្ឈង្គសូត្រទី ២

[ ២ ] ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គ ( អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង ) ៧ យ៉ាងនេះ ដែលភិក្ខុបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ រមែងញ៉ាំងវិជ្ជា ៣ ប្រការឲ្យពេញលេញបាន ។ ៧ យ៉ាង តើអ្វីខ្លះ ។ គឺសតិសម្ពោជ្ឈង្គ ១ ធម្មវិចយសម្ពោជ្ឈង្គ ១ វីរិយសម្ពោជ្ឈង្គ ១ បីតិសម្ពោជ្ឈង្គ ១ បស្សទ្ធិ-សម្ពោជ្ឈង្គ ១ សមាធិសម្ពោជ្ឈង្គ ១ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គ ៧ នេះឯង ដែលភិក្ខុបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ រមែងញ៉ាំងវិជ្ជា ៣ ប្រការ ឲ្យពេញលេញបាន ។ វិជ្ជា ៣ ប្រការ តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងរឭកឃើញនូវបុព្វេនិវាសច្រើនប្រការ គឺរឭកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ រមែងរឭកឃើញនូវបុព្វេនិវាសច្រើនប្រការ ព្រមទាំងអាការ ទាំងឧទ្ទេស ដោយប្រការដូច្នេះ ១ មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធកន្លងបង់នូវចក្ខុរបស់មនុស្ស ។បេ។ រមែងដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមយថាកម្ម ១ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ។បេ។ ធ្វើឲ្យជាក់ច្បាស់ហើយ សម្រេចសម្រាន្តនៅ ១ ។ ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គ ៧ នេះឯង ដែលភិក្ខុបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ រមែងញ៉ាំងវិជ្ជា ៣ ប្រការនេះ ឲ្យពេញលេញបាន ។

# អដ្ឋកថា

## ពោជ្ឈង្គសូត្រ

[ ២ ] ក្នុងពោជ្ឈង្គសូត្រទី ២ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាពោជ្ឈង្គសូត្រទី ២ ចប់

# សុត្តន្តបិដក

## មិច្ឆត្តសូត្រទី ៣

[ ៣ ] ម្នាលភិក្ខុទាំងឡាយ កិរិយាឃ្លាត ( ចាកស្ថានសួគ៌ និងមគ្គ ) មិនបានសម្រេច ព្រោះអាស្រ័យមិច្ឆត្តៈ ( សភាពដែលខុស ) ។ ម្នាលភិក្ខុទាំងឡាយ កិរិយាឃ្លាត ( ចាកស្ថានសួគ៌ និងមគ្គ ) មិនបានសម្រេច ព្រោះអាស្រ័យមិច្ឆត្តៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានសេចក្តីយល់ខុស រមែងមានតម្រិះខុស បុគ្គលអ្នកមានតម្រិះខុស រមែងមានវាចាខុស បុគ្គលអ្នកមានវាចាខុស រមែងមានការងារខុស បុគ្គលអ្នកមានការងារខុស រមែងមានការចិញ្ចឹមជីវិតខុស បុគ្គលអ្នកចិញ្ចឹមជីវិតខុស រមែងមានសេចក្តីព្យាយាមខុស បុគ្គលអ្នកមានសេចក្តីព្យាយាមខុស រមែងមានការរឭកខុស បុគ្គលអ្នកមានការរឭកខុស រមែងមានការតម្កល់ចិត្តខុស បុគ្គលអ្នកតម្កល់ចិត្តខុស រមែងមានការដឹងខុស បុគ្គលអ្នកមានការដឹងខុស រមែងមាន

ការរួចខុស ។ ម្នាលភិក្ខុទាំងឡាយ កិរិយាឃ្លាត ( ចាកស្ថានសួគ៌ និងមគ្គ ) មិនបានសម្រេច ព្រោះអាស្រ័យនូវមិច្ឆត្តៈ យ៉ាងនេះឯង ។

# អដ្ឋកថា

## មិច្ឆត្តសូត្រ

[ ៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមិច្ឆត្តសូត្រទី ៣ ដូចតទៅនេះ បទថា **វិរាធនា ហោតិ** សេចក្តីថា ឃ្លៀងឃ្លាតចាកសួគ៌ និងមគ្គរមែងមាន ។ បទថា **នោ អារាធនា** សេចក្តីថា ការសម្រេចផលក៏មិនមាន ការធ្វើឲ្យបរិបូណ៌ក៏មិនមាន ។ បទថា **បហោតិ** ប្រែថា រមែងប្រព្រឹត្តទៅ ។ល។

**អដ្ឋកថា មិច្ឆត្តសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## សម្មត្តសូត្រទី ៤

[ ៤ ] ម្នាលភិក្ខុទាំងឡាយ ការបានសម្រេច មិនឃ្លាត ( ចាកស្ថានសួគ៌ និងមគ្គ ) ព្រោះអាស្រ័យនូវសម្មត្ត: ( សភាពដែលត្រូវ ) ។ ការបានសម្រេច មិនឃ្លាត ( ចាកស្ថានសួគ៌ និងមគ្គ ) ព្រោះអាស្រ័យនូវសម្មត្ត: ( សភាពដែលត្រូវ ) តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានសេចក្តីយល់ត្រូវ រមែងមានតម្រិះត្រូវ បុគ្គលអ្នកមានតម្រិះត្រូវ រមែងមានវាចាត្រូវ បុគ្គលអ្នកមានវាចាត្រូវ រមែងមានការងារត្រូវ បុគ្គលអ្នកមានការងារត្រូវ រមែងមានការចិញ្ចឹមជីវិតត្រូវ បុគ្គលអ្នកមានការចិញ្ចឹមជីវិតត្រូវ រមែងមានសេចក្តីព្យាយាមត្រូវ បុគ្គលអ្នកមានសេចក្តីព្យាយាមត្រូវ រមែងមានការរឭកត្រូវ បុគ្គលអ្នកមានការរឭកត្រូវ រមែងមានការតម្កល់ចិត្តត្រូវ បុគ្គលអ្នកមានការតម្កល់ចិត្តត្រូវ រមែងមានការដឹងត្រូវ បុគ្គលអ្នកមានការដឹងត្រូវ រមែងមានការរួចត្រូវ ។ ម្នាលភិក្ខុទាំងឡាយ ការបានសម្រេច មិនឃ្លាត ( ចាកស្ថានសួគ៌ និងមគ្គ ) ព្រោះអាស្រ័យនូវសម្មត្ត:យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គលដែលប្រកបដោយមិច្ឆាទិដ្ឋិ មិច្ឆាសង្កប្ប: មិច្ឆាវាចា មិច្ឆាកម្មន្ត: មិច្ឆាអាជីវ: មិច្ឆាវាយាម: មិច្ឆាសតិ មិច្ឆាសមាធិ មិច្ឆាញាណ: មិច្ឆាវិមុត្តិ បានសមាទាននូវកាយកម្មណាផង ដ៏បរិបូណ៌តាមទិដ្ឋិវចីកម្មណាផង ... បានសមាទាននូវមនោកម្មណាផង ដ៏បរិបូណ៌តាមទិដ្ឋិចេតនាណាផង សេចក្តីប្រាថ្នាណាផង ការតម្កល់ចិត្តណាផង សង្ខារទាំងឡាយ

៧ទាំងអស់នោះ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត មិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះទិដ្ឋិជាអំពើអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ ដូចពូជស្ដៅក្តី ពូជននោងព្រៃក្តី ពូជម្រះក្តី ដែលបុគ្គលដាំ ក្នុងផែនដីដែលសើមស្រូបយកនូវសេចបរិជាតុណាផង ស្រូបយកនូវសេអាបោជាតុណាផង របស់ទាំងអស់នោះ រមែងប្រព្រឹត្តទៅ ដើម្បីមានរសល្វីង រសហឹរ រសចត់ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះពូជជារបស់អាក្រក់យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គលដែលប្រកបដោយមិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បៈ មិច្ឆាវាចា មិច្ឆាកម្មន្តៈ មិច្ឆាអាជីវៈ មិច្ឆាវាយាមៈ មិច្ឆាសតិ មិច្ឆាសមាធិ មិច្ឆាញាណៈ មិច្ឆាវិមុត្តិ បានសមាទាននូវកាយកម្មណាផង ដ៏បរិបូណ៌តាមទិដ្ឋិ វចីកម្មណាផង ... បានសមាទាននូវមនោកម្មណាផង ដ៏បរិបូណ៌តាមទិដ្ឋិចេតនាណាផង សេចក្តីប្រាថ្នាណាផង ការតម្កល់ចិត្តណាផង សង្ខារទាំងឡាយណាផង ( របស់បុរសបុគ្គលដែលប្រកបដោយមិច្ឆាទិដ្ឋិជាដើមនោះ ) ធម៌ទាំងអស់នោះ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត មិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ក៏យ៉ាងនោះដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះទិដ្ឋិជាធម្មជាតអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គលដែលប្រកបដោយសម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាមៈ

សម្មាសតិ សម្មាសមាធិ សម្មាញាណៈ សម្មាវិមុត្តិ បានសមាទាននូវកាយកម្មណាផង ដ៏បរិបូណ៌តាមទិដ្ឋិ បានសមាទាននូវវចីកម្មណាផង ដ៏បរិបូណ៌តាមទិដ្ឋិ បានសមាទាននូវមនោកម្មណាផង ដ៏បរិបូណ៌តាមទិដ្ឋិ ចេតនាណាផង សេចក្តីប្រាថ្នាណាផង ការតម្កល់ចិត្តណាផង សង្ខារទាំង-ឡាយណាផង ( របស់បុរសបុគ្គលដែលប្រកបដោយសម្មាទិដ្ឋិជាដើមនោះ ) ធម៌ទាំងអស់នោះ រមែងប្រព្រឹត្តទៅ ដើម្បីជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាប្រយោជន៍ ដើម្បីសេចក្តីសុខ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះទិដ្ឋិជាធម្មជាតល្អ ។ ម្នាលភិក្ខុទាំងឡាយ ដូចពូជអំពៅក្តី ពូជស្រូវសាលីក្តី ពូជចន្ទន៍ក្តី ដែលបុគ្គលដាំក្នុងផែនដីសើម ស្រូបយកនូវរសបឋវីធាតុណាផង ស្រូបយកនូវរសអាបោធាតុណាផង រសទាំងអស់នោះ រមែងប្រព្រឹត្តទៅ ដើម្បីរសឆ្ងាញ់ មានរសផ្អែម មានរសមិនបានប្រឡំ ( ដោយរសដទៃ ) យ៉ាងណាមិញ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះពូជជារបស់ល្អ ។ ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គលដែលប្រកបដោយសម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ សម្មា-អាជីវៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ សម្មាញាណៈ សម្មាវិមុត្តិ បានសមាទាននូវកាយកម្មណាផង ដ៏បរិបូណ៌តាមទិដ្ឋិ វចីកម្មណាផង ... បានសមាទាននូវមនោកម្មណាផង ដ៏បរិបូណ៌តាមទិដ្ឋិ ចេតនាណាផង សេចក្តីប្រាថ្នាណាផង ការតម្កល់ចិត្តណាផង សង្ខារទាំងឡាយណាផង ( របស់បុរស

បុគ្គលដែលប្រកបដោយសម្មាទិដ្ឋិជាដើមនោះ ) ធម៌ទាំងអស់នោះ រមែង ប្រព្រឹត្តទៅ ដើម្បីជាទីប្រាថ្នា ដើម្បីជាទីត្រេកអរ ជាទីពេញចិត្ត ជាប្រយោជន៍ ដើម្បីសេចក្តីសុខ ក៏យ៉ាងនោះដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះទិដ្ឋិ ជាធម្មជាតល្អ ។

# អដ្ឋកថា

## សម្មត្តសូត្រ

[ ៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសម្មត្តសូត្រទី ៤ ដូចតទៅនេះ បទថា **យថាទិដ្ឋិសម្មត្តំ សមាទិន្នំ** បានដល់ សមាទានឲ្យបរិបូណ៌ ដោយការប្រកាន់តាមសមគួរដល់ទិដ្ឋិ ។ បទថា **ចេតនា** បានដល់ ចេតនាដែលកើតក្នុងទ្វារទាំង ៣ ប្រកាន់មាំហើយ ។ បទថា **បត្ថនា** បានដល់ សេចក្តីប្រាថ្នាដែលប្រាថ្នាយ៉ាងនេះថា អាត្មាអញគប្បីបែបនេះ ។ បទថា **បណិធិ** បានដល់ ការតាំងចិត្តថា អញនឹងជាទេវតា ឬទេវតាអង្គណាមួយ ។ បទថា **សង្ខារា** បានដល់ សង្ខារដែលប្រកបព្រមហើយ ។៚

### អដ្ឋកថា សម្មត្តសូត្រទី ៤ ចប់

# សុត្តន្តបិដក

## អវិជ្ជាវិជ្ជាសូត្រទី ៥

[ ៥ ] ម្នាលភិក្ខុទាំងឡាយ អវិជ្ជាជាប្រធាន នៃការចូបប្រទះ នូវពួកអកុសលធម៌ អហិរិកៈ អនោត្តប្បៈ ក៏គង់ជាប់តាមដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកលុះក្នុងអវិជ្ជា អ្នកមិនចេះដឹង រមែងមានមិច្ឆាទិដ្ឋិ បុគ្គលអ្នកប្រកបដោយមិច្ឆាទិដ្ឋិ រមែងមានមិច្ឆាសង្កប្បៈ បុគ្គលជាមិច្ឆាសង្កប្បៈ រមែងមានមិច្ឆាវាចា បុគ្គលជាមិច្ឆាវាចា រមែងមានមិច្ឆាកម្មន្តៈ បុគ្គលជាមិច្ឆាកម្មន្តៈ រមែងមានមិច្ឆាអាជីវៈ បុគ្គលជាមិច្ឆាអាជីវៈ រមែងមានមិច្ឆាវាយាមៈ បុគ្គលជាមិច្ឆាវាយាមៈ រមែងមានមិច្ឆាសតិ បុគ្គលជាមិច្ឆាសតិ រមែងមានមិច្ឆាសមាធិ បុគ្គលជាមិច្ឆាសមាធិ រមែងមានមិច្ឆាញាណៈ បុគ្គលជាមិច្ឆាញាណៈ រមែងមានមិច្ឆាវិមុត្តិ ។ ម្នាលភិក្ខុទាំងឡាយ វិជ្ជាជាប្រធានក្នុងការចូបប្រសព្វនូវពួកកុសលធម៌ ហិរិ និងឱត្តប្បៈ ក៏គង់ជាប់តាមដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកប្រកបដោយវិជ្ជា ជាអ្នកចេះដឹង រមែងមានសម្មាទិដ្ឋិ បុគ្គលជាសម្មាទិដ្ឋិ រមែងមានសម្មាសង្កប្បៈ បុគ្គលជាសម្មាសង្កប្បៈ រមែងមានសម្មា-វាចា បុគ្គលជាសម្មាវាចា រមែងមានសម្មាកម្មន្តៈ បុគ្គលជាសម្មាកម្មន្តៈ រមែងមានសម្មាអាជីវៈ បុគ្គលជាសម្មាអាជីវៈ រមែងមានសម្មាវាយាមៈ បុគ្គលជាសម្មាវាយាមៈ រមែងមានសម្មាសតិ បុគ្គលជាសម្មាសតិ រមែងមានសម្មា-សមាធិ បុគ្គលជាសម្មាសមាធិ រមែងមានសម្មាញាណៈ បុគ្គលជាសម្មា-ញាណៈ រមែងមានសម្មាវិមុត្តិ ។

# អដ្ឋកថា

## អវិជ្ជាវិជ្ជាសូត្រ

[ ៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអវិជ្ជាវិជ្ជាសូត្រទី ៥ ដូចតទៅនេះ អវិជ្ជា ឈ្មោះថា ជាប្រធាន ព្រោះអត្ថថា ប្រព្រឹត្តទៅមុន ។ បទថា **អន្វទេវ** បានដល់ ជាប់តាមទៅ ។ល។

**អដ្ឋកថា អវិជ្ជាវិជ្ជាសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## និជ្ជរវត្ថុសូត្រទី ៦

[ ៦ ] ម្នាលភិក្ខុទាំងឡាយ ហេតុដែលនាំឲ្យសាបរលាបទៅនេះ មាន ១០ យ៉ាង ។ ១០ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលប្រកបដោយសម្មាទិដ្ឋិ រមែងមានមិច្ឆាទិដ្ឋិសាបរលាបទៅ អកុសលទាំងឡាយដ៏លាមកច្រើនប្រការណា មានមិច្ឆាទិដ្ឋិជាបច្ច័យ អកុសលធម៌ទាំងឡាយនោះ របស់បុគ្គលជាសម្មាទិដ្ឋិនោះ រមែងសាបរលាបទៅ កុសលធម៌ច្រើនប្រការ ដែលមានសម្មាទិដ្ឋិជាបច្ច័យ ក៏ដល់នូវការបរិបូណ៌ដោយភាវនា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសង្កប្បៈ រមែងមានមិច្ឆាសង្កប្បៈ សាបរលាបទៅ អកុសលធម៌ទាំងឡាយ ដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆាសង្កប្បៈ ជា

បច្ច័យកើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលជាសម្មាសង្កប្បៈនោះ រមែងសាបរលាបទៅ កុសលធម៌ច្រើនប្រការ ដែលមានសម្មាសង្កប្បៈជាបច្ច័យ ក៏ដល់នូវការបរិបូណ៌ដោយភាវនា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាវាចា រមែងមានមិច្ឆាវាចាសាបរលាបទៅ អកុសលធម៌ទាំងឡាយដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆាវាចាជាបច្ច័យកើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលជាសម្មាវាចានោះ រមែងសាបរលាបទៅ កុសលធម៌ច្រើនប្រការ ដែលមានសម្មាវាចាជាបច្ច័យ ក៏ដល់នូវការបរិបូណ៌ដោយភាវនា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាកម្មន្តៈ រមែងមានមិច្ឆាកម្មន្តៈ សាបរលាបទៅអកុសលធម៌ទាំងឡាយដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាកម្មន្តៈជាបច្ច័យកើតព្រម អកុសលធម៌ទាំងឡាយនោះ របស់បុគ្គលដែលជាសម្មាកម្មន្តៈនោះ រមែងសាបរលាបទៅ កុសលធម៌ច្រើនប្រការ ដែលមានសម្មាកម្មន្តៈជាបច្ច័យ ក៏រមែងដល់នូវការបរិបូណ៌ដោយភាវនា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាអាជីវៈ រមែងមានមិច្ឆាអាជីវៈសាបរលាបទៅ អកុសលធម៌ទាំងឡាយដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាអាជីវៈ ជាបច្ច័យកើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលជាសម្មាអាជីវៈនោះ រមែងសាបរលាបទៅ កុសលធម៌ច្រើនប្រការ ដែលមានសម្មាអាជីវៈជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាវាយាមៈ រមែងមានមិច្ឆាវាយាមៈសាបរលាបទៅ អកុសលធម៌ទាំង-

ឡាយដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាវាយាមៈ ជាបច្ច័យកើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលជាសម្មាអាជីវៈនោះ រមែងសាបរលាបទៅ កុសលធម៌ច្រើនប្រការ ដែលមានសម្មាវាយាមៈជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសតិ រមែងមានមិច្ឆាសតិសាបរលាបទៅ អកុសលធម៌ទាំងឡាយដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាសតិជាបច្ច័យកើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលជាសម្មាសតិនោះ រមែងសាបរលាបទៅ កុសលធម៌ច្រើនប្រការ ដែលមានសម្មាសតិជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសមាធិ រមែងមានមិច្ឆាសមាធិសាបរលាបទៅ អកុសលធម៌ទាំងឡាយដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាសមាធិជាបច្ច័យកើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលជាសម្មាសមាធិនោះ រមែងសាបរលាបទៅ ទើបកុសលធម៌ច្រើនប្រការ ដែលមានសម្មាសមាធិជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាញាណៈ រមែងមានមិច្ឆាញាណៈសាបរលាបទៅ អកុសលធម៌ទាំងឡាយដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាញាណៈជាបច្ច័យកើតព្រម អកុសលធម៌ទាំងអស់នោះ របស់បុគ្គលជាសម្មាញាណៈនោះ រមែងសាបរលាបទៅ កុសលធម៌ច្រើនប្រការ ដែលមានសម្មាញាណៈជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលជា

សម្មាវិមុត្តិ រមែងមានមិច្ឆាវិមុត្តិ សាបរលាបទៅ អកុសលធម៌ទាំងឡាយ ដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាវិមុត្តិជាបច្ច័យកើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលជាសម្មាវិមុត្តិនោះ រមែងសាបរលាបទៅ កុសលធម៌ច្រើនប្រការដែលមានសម្មាវិមុត្តិជាបច្ច័យ រមែងដល់នូវការបរិបូណ៌ ដោយភាវនា ។ ម្នាលភិក្ខុទាំងឡាយ ហេតុដែលនាំឲ្យសាបរលាបទៅ មាន ១០ យ៉ាងនេះឯង ។

# អដ្ឋកថា

## និជ្ជរវត្ថុសូត្រ

[ ៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិជ្ជរវត្ថុសូត្រទី ៦ ដូចតទៅនេះ បទថា **និជ្ជរវត្ថូនិ** បានដល់ ហេតុនៃការសូន្យទៅ ។ បទថា **មិច្ឆាទិដ្ឋិ និជ្ជិណ្ណា ហោតិ** សេចក្តីថា មិច្ឆាទិដ្ឋិដែលដល់នូវការសូន្យទៅ ព្រោះវិបស្សនាយ៉ាងទាប ដែលលោកលះបានហើយយ៉ាងនេះ ។ សួរថា ព្រោះហេតុអ្វី ទើបលោកកាន់យកទៀត ។ ឆ្លើយថា ព្រោះមិច្ឆាទិដ្ឋិនោះ លោកមិនទាន់ដកបាន ។ ដ្បិតថា មិច្ឆាទិដ្ឋិ សូម្បីដកមិនបានដោយវិបស្សនាក៏ពិត តែមគ្គកើតឡើង ក៏ដកមិច្ឆាទិដ្ឋិបាន គឺមិនកើតឡើងទៀត ព្រោះដូច្នោះ ទើបលោកកាន់យកទៀត ។ ក្នុងបទទាំងអស់គប្បីជ្រាប តាមន័យយ៉ាងនេះ ។

ម្យ៉ាងទៀត ក្នុងសូត្រនេះ ធម៌ ៦៤ រមែងដល់នូវការចម្រើនបរិបូណ៌ ព្រោះសម្មាវិមុត្តិជាបច្ច័យ គឺធម៌ ៦៤ បានដល់ ក្នុងខណៈនៃសោតាបត្តិមគ្គចិត្ត សទ្ធិន្ទ្រិយរមែងបរិបូណ៌ ព្រោះអត្ថថា បង្អោនចិត្តទៅ វិរិយិន្ទ្រិយបរិបូណ៌ ព្រោះអត្ថថា ផ្គងចិត្ត សតិន្ទ្រិយបរិបូណ៌ ព្រោះអត្ថថា ចូលទៅតាំងទុក សមាធិន្ទ្រិយបរិបូណ៌ ព្រោះអត្ថថា មិនរាយមាយ បញ្ញិន្ទ្រិយបរិបូណ៌ ព្រោះអត្ថថា ឃើញ មនិន្ទ្រិយបរិបូណ៌ ព្រោះអត្ថថា ដឹងច្បាស់ សោមនស្សិន្ទ្រិយបរិបូណ៌ ព្រោះអត្ថថា ហូរជ្រាបទៅ ជីវិតិន្ទ្រិយបរិបូណ៌ ព្រោះអត្ថថា មានសន្តិបន្តគ្នាប្រព្រឹត្តទៅជាធំ ។បេ។ ក្នុងខណៈនៃអរហត្តផលចិត្ត សទ្ធិន្ទ្រិយបរិបូណ៌ ព្រោះអត្ថថា បង្អោនចិត្តជឿ ។បេ។ ជីវិតិន្ទ្រិយបរិបូណ៌ ព្រោះអត្ថថា មានសន្តិប្រព្រឹត្តទៅជាធំ ធម៌ ៦៤ គឺមគ្គ ៤ ផល ៤ នីមួយៗ ៨ រមែងដល់នូវភាពបរិបូណ៌ ដោយប្រការដូចពោលមក ដូច្នេះ ។៙

## អដ្ឋកថា ឆិដ្ឋវត្ថុសូត្រទី ៦ ចប់

# សុត្តន្តបិដក

## លោវឥសូត្រទី ៧

[ ៧ ] ម្នាលភិក្ខុទាំងឡាយ ក្នុងទក្ខិណាជនបទ តែងមានពិធីលាងឆ្អឹង ជាធម្មតា បាយក្តី ទឹកក្តី បង្អែមក្តី ចម្អាបក្តី វត្ថុដែលគប្បីលិទ្ធក្តី ទឹកដែលគប្បីផឹកក្តី ការរាំក្តី ច្រៀងក្តី ប្រគំក្តី តែងមានក្នុងពិធីលាងឆ្អឹងនោះ ។ ម្នាលភិក្ខុទាំងឡាយ ពិធីលាងឆ្អឹងនុ៎ះ មានមែន តថាគតមិនពោលថា ពិធីលាងឆ្អឹងនោះ មិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ តែថាពិធីលាងឆ្អឹងនោះឯង ជារបស់ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយៈ មិនមានប្រយោជន៍ មិនមែនប្រព្រឹត្តទៅ ដើម្បីនឿយណាយ មិនប្រព្រឹត្តទៅ ដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅ ដើម្បីរលត់ មិនប្រព្រឹត្តទៅ ដើម្បីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ មិនប្រព្រឹត្តទៅ ដើម្បីត្រាស់ដឹង មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វានទេ ។ ម្នាលភិក្ខុទាំងឡាយ ពិធីលាងណា រមែងប្រព្រឹត្តទៅ ដើម្បីនឿយណាយតែម្យ៉ាង ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ពួកសត្វមានជាតិជាធម្មតា រមែងរួចចាកជាតិ ពួកសត្វមានជរាជាធម្មតា តែងរួចចាកជរា ពួកសត្វមានមរណៈជាធម្មតា រមែងរួចចាកមរណៈ ពួកសត្វមានសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ចិត្តជាធម្មតា រមែងរួចចាកសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ទាំងឡាយបាន ព្រោះអាស្រ័យនូវពិធីលាងណា តថាគតនឹងសម្តែងនូវពិធីលាងដ៏ប្រសើរ

នោះ អ្នកទាំងឡាយ ចូរប្រុងស្តាប់ នូវពិធីលាងនោះចុះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែងប្រាប់ ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានជាតិជាធម្មតា រមែងរួចចាកជាតិ ពួកសត្វមានជរាជាធម្មតា រមែងរួចចាកជរា ពួកសត្វមានមរណៈជាធម្មតា រមែងរួចចាកមរណៈ ពួកសត្វមានសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ជាធម្មតា រមែងរួចចាកសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ទាំងឡាយបាន ព្រោះអាស្រ័យនូវពិធីលាងណា ពិធីលាងដ៏ប្រសើរនោះ រមែងប្រព្រឹត្តទៅ ដើម្បីនឿយណាយតែម្យ៉ាង ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាទិដ្ឋិ ឈ្មោះថា បានលាងមិច្ឆាទិដ្ឋិស្អាតហើយ អកុសលធម៌ទាំងឡាយដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆាទិដ្ឋិជាបច្ច័យកើតព្រម អកុសលធម៌ទាំងនោះរបស់បុគ្គលដែលជាសម្មាទិដ្ឋិនោះ ឈ្មោះថា បានលាងស្អាតហើយ ពួកកុសលធម៌ច្រើនប្រការ ដែលមានសម្មាទិដ្ឋិជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសង្កប្បៈ ឈ្មោះថា បានលាងមិច្ឆាសង្កប្បៈស្អាតហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាវាចា ឈ្មោះថា បានលាងមិច្ឆាវាចាស្អាតហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជា

សម្មាកម្មន្តៈ ឈ្មោះថាបានលាងមិច្ឆាកម្មន្តៈស្អាតហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាអាជីវៈ ឈ្មោះថា បានលាងមិច្ឆាអាជីវៈស្អាតហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាវាយាមៈ ឈ្មោះថា បានលាងមិច្ឆាវាយាមៈស្អាតហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសតិ ឈ្មោះថា បានលាងមិច្ឆាសតិស្អាតហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសមាធិ ឈ្មោះថា បានលាងមិច្ឆាសមាធិស្អាតហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាញាណៈ ឈ្មោះថា បានលាងមិច្ឆាញាណៈស្អាតហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាវិមុត្តិ ឈ្មោះថា បានលាងមិច្ឆាវិមុត្តិស្អាតហើយ អកុសលធម៌ទាំងឡាយដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាវិមុត្តិ ជាបច្ច័យ កើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលដែលជាសម្មាវិមុត្តិនោះ ឈ្មោះថា បានលាងស្អាតហើយ កុសលធម៌ច្រើនប្រការ ដែលមានសម្មាវិមុត្តិជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានជាតិជាធម្មតា រមែងរួចចាកជាតិ ពួកសត្វមានជរាជាធម្មតា រមែងរួចចាកជរា ពួកសត្វមានមរណៈជាធម្មតា រមែងរួចចាកមរណៈ ពួកសត្វមានសេចក្ដីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ជាធម្មតា រមែងរួចចាកសេចក្ដីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ទាំងឡាយបាន ព្រោះអាស្រ័យពិធីលាងណា ពិធីលាងដ៏ប្រសើរនេះឯង រមែងប្រព្រឹត្តទៅដើម្បីនឿយណាយតែម្យ៉ាង ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ ដើម្បីស្ងប់

*រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ។*

# អដ្ឋកថា

## ធោវនសូត្រ

*[ ៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងធោវនសូត្រទី ៧ ដូចតទៅនេះ បទថា* **ធោវនំ** *បានដល់ លាងឆ្អឹង ។ ពិតហើយ ក្នុងជនបទនោះ មនុស្សទាំង-ឡាយ កាលញាតិស្លាប់ក៏មិនដុត តែជីករណ្តៅកប់ក្នុងដី ។ រួចហើយ ទើបនាំឆ្អឹងដែលពុកហើយរបស់ញាតិទាំងនោះមកលាង ហើយលើកឡើងតម្រៀបគ្នា បូជាដោយគ្រឿងក្រអូប និងផ្កាជាដើម ។ ក្នុងកាលមានបុណ្យនក្ខត្តឫក្ស នាំឆ្អឹងទាំងនោះមកហើយ ក៏ទ្រហោយំខ្សឹកខ្សួល បន្ទាប់អំពីនោះ ក៏លេងនក្ខត្តឫក្ស ។*

**អដ្ឋកថា ធោវនសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## តិកិច្ឆសូត្រទី ៨

[ ៨ ] ម្នាលភិក្ខុទាំងឡាយ ពួកពេទ្យឲ្យថ្នាំបញ្ចុះដើម្បីឃាត់នូវអាពាធទាំងឡាយ ដែលកើតពីប្រមាត់ខ្លះ ដើម្បីឃាត់នូវអាពាធទាំងឡាយ ដែលកើតពីស្លេស្មខ្លះ ដើម្បីឃាត់នូវអាពាធទាំងឡាយ ដែលកើតពីខ្យល់ខ្លះ ម្នាលភិក្ខុទាំងឡាយ ថ្នាំបញ្ចុះនោះមានមែន តថាគតមិនមែនពោលថា ថ្នាំបញ្ចុះនុ៎ះមិនមានទេ ម្នាលភិក្ខុទាំងឡាយ តែថា ថ្នាំបញ្ចុះនោះឯង សម្រេចខ្លះ មិនសម្រេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ថ្នាំបញ្ចុះណា សុទ្ធតែសម្រេច មិនមែនមិនសម្រេច ពួកសត្វមានជាតិជាធម្មតា រមែងរួចចាកជាតិ ពួកសត្វមានជរាជាធម្មតា រមែងរួចចាកជរា ពួកសត្វមានមរណៈជាធម្មតា រមែងរួចចាកមរណៈ ពួកសត្វមានសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ជាធម្មតា រមែងរួចចាកសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ទាំងឡាយបាន ព្រោះអាស្រ័យថ្នាំបញ្ចុះណា តថាគតនឹងសម្តែងនូវថ្នាំបញ្ចុះដ៏ប្រសើរនោះឯង អ្នកទាំងឡាយ ចូរប្រុងស្តាប់នូវពាក្យនោះចុះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែងប្រាប់ ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានជាតិជាធម្មតា រមែងរួចចាកជាតិ ពួកសត្វមានជរាជាធម្មតា រមែងរួចចាកជរា ពួកសត្វមានមរណៈជាធម្មតា រមែងរួចចាកមរណៈ ពួកសត្វមានសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ

ទោមនស្ស ចង្អៀតចង្អល់ជាធម្មតា រមែងរួចចាកសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ទាំងឡាយបាន ព្រោះអាស្រ័យថ្នាំបញ្ចុះណា ថ្នាំបញ្ចុះដ៏ប្រសើរនោះ សុទ្ធតែសម្រេច មិនមែនមិនសម្រេចទេ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាទិដ្ឋិ ឈ្មោះថា បានបញ្ចុះមិច្ឆាទិដ្ឋិចេញហើយ អកុសលធម៌ទាំងឡាយដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆាទិដ្ឋិជាបច្ច័យ កើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលជាសម្មាទិដ្ឋិនោះ ឈ្មោះថា បានបញ្ចុះហើយ កុសលធម៌ច្រើនប្រការ ដែលមានសម្មាទិដ្ឋិ ជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសង្កប្បៈ ឈ្មោះថា បានបញ្ចុះមិច្ឆាសង្កប្បៈចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលជាសម្មាវាចា ឈ្មោះថា បានបញ្ចុះមិច្ឆាវាចាចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាកម្មន្តៈ ឈ្មោះថា បានបញ្ចុះមិច្ឆាកម្មន្តៈចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាអាជីវៈ ឈ្មោះថា បានបញ្ចុះមិច្ឆាអាជីវៈចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាវាយាមៈ ឈ្មោះថា បានបញ្ចុះមិច្ឆាវាយាមៈចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសតិ ឈ្មោះថា បានបញ្ចុះមិច្ឆាសតិចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសមាធិ ឈ្មោះថា បានបញ្ចុះមិច្ឆាសមាធិចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាញាណៈ ឈ្មោះថា បានបញ្ចុះមិច្ឆាញាណៈចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាវិមុត្តិ

ឈ្មោះថា បានបញ្ចុះមិច្ឆាវិមុត្តិចេញហើយ អកុសលធម៌ទាំងឡាយ ដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាវិមុត្តិជាបច្ច័យ កើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលដែលជាសម្មាវិមុត្តិនោះ ឈ្មោះថា បានបញ្ចុះចេញហើយ កុសលធម៌ច្រើនប្រការ ដែលមានសម្មាវិមុត្តិជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា ។ ម្នាលភិក្ខុទាំងឡាយ ថ្នាំបញ្ចុះណា សុទ្ធតែសម្រេច មិនមែនមិនសម្រេច ពួកសត្វមានជាតិជាធម្មតា រមែងរួចចាកជាតិ ពួកសត្វមានជរាជាធម្មតា រមែងរួចចាកជរា ពួកសត្វមានមរណៈជាធម្មតា រមែងរួចចាកមរណៈ ពួកសត្វមានសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ជាធម្មតា រមែងរួចចាកសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ទាំងឡាយបាន ព្រោះអាស្រ័យថ្នាំបញ្ចុះណា ថ្នាំបញ្ចុះនោះឯងជាថ្នាំដ៏ប្រសើរ ។

# អដ្ឋកថា

## តិកិច្ឆសូត្រ

[ ៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតិកិច្ឆសូត្រទី ៨ ដូចតទៅនេះ បទថា **វិរេចនំ** បានដល់ ថ្នាំបញ្ចុះរបស់ដែលមានទោសចេញ ។ បទថា **វិរេចនា ហោតិ** បានដល់ កម្ចាត់ចេញ ។៚

**អដ្ឋកថា តិកិច្ឆសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## វេមជសូត្រទី ៩

[ ៩ ] ម្នាលភិក្ខុទាំងឡាយ ពួកពេទ្យឲ្យថ្នាំក្អួត ដើម្បីឃាត់នូវអាពាធទាំងឡាយ ដែលកើតពីប្រមាត់ខ្លះ ដើម្បីឃាត់នូវអាពាធទាំងឡាយ ដែលកើតពីស្លេស្មខ្លះ ដើម្បីឃាត់នូវអាពាធទាំងឡាយ ដែលកើតពីខ្យល់ខ្លះ ម្នាលភិក្ខុទាំងឡាយ ថ្នាំក្អួតនោះមានមែន តថាគតមិនពោលថា ថ្នាំក្អួតនុ៎ះមិនមានទេ ម្នាលភិក្ខុទាំងឡាយ តែថ្នាំក្អួតនោះឯង សម្រេចខ្លះ មិនសម្រេចខ្លះ ម្នាលភិក្ខុទាំងឡាយ ថ្នាំក្អួតណាសុទ្ធតែសម្រេច មិនមែនមិនសម្រេច ពួកសត្វមានជាតិជាធម្មតា រមែងរួចចាកជាតិ ពួកសត្វមានជរាជាធម្មតា រមែងរួចចាកជរា ពួកសត្វមានមរណៈជាធម្មតា រមែងរួចចាកមរណៈ ពួកសត្វមានសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ជាធម្មតា រមែងរួចចាកសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ទាំងឡាយបាន ព្រោះអាស្រ័យថ្នាំក្អួតណា តថាគតនឹងសម្តែងនូវថ្នាំក្អួត ដ៏ប្រសើរនោះ អ្នកទាំងឡាយ ចូរប្រុងស្តាប់នូវពាក្យនោះចុះ ... ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានជាតិជាធម្មតា រមែងរួចចាកជាតិ ។បេ។ ពួកសត្វមានសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ជាធម្មតា រមែងរួចចាកសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ទាំងឡាយបាន ព្រោះអាស្រ័យថ្នាំក្អួតណា ថ្នាំក្អួតដ៏ប្រសើរនោះ សុទ្ធតែសម្រេច មិនមែនមិនសម្រេច តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាទិដ្ឋិ ឈ្មោះថា បានក្អួតមិច្ឆាទិដ្ឋិ

ចេញហើយ អកុសលធម៌ទាំងឡាយ ដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាទិដ្ឋិជាបច្ច័យ កើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលជាសម្មាទិដ្ឋិនោះ ឈ្មោះថា បានក្អួតចេញហើយ កុសលធម៌ច្រើនប្រការដែលមានសម្មាទិដ្ឋិជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសង្កប្បៈ ឈ្មោះថា បានក្អួតមិច្ឆាសង្កប្បៈចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាវាចា ឈ្មោះថា បានក្អួតមិច្ឆាវាចាចេញហើយ ... បុគ្គលជាសម្មាកម្មន្តៈ ឈ្មោះថា បានក្អួតមិច្ឆាកម្មន្តៈចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាអាជីវៈ ឈ្មោះថា បានក្អួតមិច្ឆាអាជីវៈចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាវាយាមៈ ឈ្មោះថា បានក្អួតមិច្ឆាវាយាមៈចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសតិ ឈ្មោះថា បានក្អួតមិច្ឆាសតិចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសមាធិ ឈ្មោះថា បានក្អួតមិច្ឆាសមាធិចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាញាណៈ ឈ្មោះថា បានក្អួតមិច្ឆាញាណៈចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាវិមុត្តិ ឈ្មោះថា បានក្អួតមិច្ឆាវិមុត្តិចេញហើយ ... អកុសលធម៌ទាំងឡាយដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆាវិមុត្តិជាបច្ច័យ កើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលដែលជាសម្មាវិមុត្តិនោះ ឈ្មោះថា បានក្អួតចេញហើយ កុសលធម៌ច្រើនប្រការ ដែលមានសម្មាវិមុត្តិ ជាបច្ច័យ រមែងដល់នូវការបរិបូណ៌ ដោយភាវនា ។ ម្នាលភិក្ខុទាំងឡាយ ពួក

សត្វមានជាតិជាធម្មតា រមែងរួចចាកជាតិ ពួកសត្វមានជរាជាធម្មតា រមែងរួចចាកជរា ពួកសត្វមានមរណៈជាធម្មតា រមែងរួចចាកមរណៈ ពួកសត្វមានសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ជាធម្មតា រមែងរួចចាកសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ទាំងឡាយបាន ព្រោះអាស្រ័យនូវថ្នាំក្អួតណា ថ្នាំក្អួតដ៏ប្រសើរនោះឯង សុទ្ធតែសម្រេច មិនមែនមិនសម្រេចទេ ។

# អដ្ឋកថា

## វមនសូត្រ

[ ៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវមនសូត្រទី ៩ ដូចតទៅនេះ បទថា **វមនំ** បានដល់ ថ្នាំធ្វើឲ្យក្អួត ។ល។

**អដ្ឋកថា វមនសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## និទ្ទេសសូត្រទី ១០

[ ១០ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ដែលគប្បីកម្ចាត់បង់នេះ មាន ១០ យ៉ាង ។ ១០ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាទិដ្ឋិ បានកម្ចាត់បង់មិច្ឆាទិដ្ឋិចេញហើយ អកុសលធម៌ទាំងឡាយដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆាទិដ្ឋិជាបច្ច័យ កើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលដែលជាសម្មាទិដ្ឋិនោះ ឈ្មោះថា បានកម្ចាត់បង់ហើយ កុសលធម៌ច្រើនប្រការ ដែលមានសម្មាទិដ្ឋិជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយការនា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសង្កប្បៈ ឈ្មោះថា បានកម្ចាត់បង់មិច្ឆាសង្កប្បៈចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាវាចា ឈ្មោះថា បានកម្ចាត់បង់មិច្ឆាវាចាចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាកម្មន្តៈ ឈ្មោះថា បានកម្ចាត់បង់មិច្ឆាកម្មន្តៈចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាអាជីវៈ ឈ្មោះថា បានកម្ចាត់បង់មិច្ឆាអាជីវៈចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាវាយាមៈ ឈ្មោះថា បានកម្ចាត់បង់មិច្ឆាវាយាមៈចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសតិ ឈ្មោះថា បានកម្ចាត់បង់មិច្ឆាសតិចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសមាធិ ឈ្មោះថា បានកម្ចាត់បង់មិច្ឆាសមាធិចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាញាណៈ ឈ្មោះថា បានកម្ចាត់បង់មិច្ឆាញាណៈចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាវិមុត្តិ ឈ្មោះថា បាន

កម្ចាត់បង់មិច្ឆាវិមុត្តិចេញហើយ អកុសលធម៌ទាំងឡាយដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆាវិមុត្តិជាបច្ច័យ កើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលដែលជាសម្មាវិមុត្តិនោះ ឈ្មោះថា បានកម្ចាត់បង់ហើយ កុសលធម៌ច្រើនប្រការ ដែលមានសម្មាវិមុត្តិជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយដែលគប្បីកម្ចាត់បង់មាន ១០ យ៉ាងនេះឯង ។

# អដ្ឋកថា

## និទ្ធមសូត្រ

[ ១០ ] បទថា គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ធមសូត្រទី ១០ ដូចតទៅនេះ បទថា **និទ្ធមនិយា** បានដល់ គប្បីកម្ចាត់បង់ ។៚

**អដ្ឋកថា និទ្ធមសូត្រទី ១០ ចប់**

# សុត្តន្តបិដក

## អសេក្ខសូត្រទី ១១

[ ១១ ] គ្រានោះ ភិក្ខុ ១ រូបបានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះ អង្គុយក្នុងទីសមគួរហើយ បានក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់ត្រាស់ថា អសេក្ខៈ អសេក្ខៈ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាអសេក្ខៈ តើដោយហេតុប៉ុន្មានយ៉ាង ។ ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រកបដោយសម្មាទិដ្ឋិ ជាអសេក្ខៈ ប្រកបដោយសម្មាសង្កប្បៈ ជាអសេក្ខៈ ប្រកបដោយសម្មាវាចា ជាអសេក្ខៈ ប្រកបដោយសម្មាកម្មន្តៈ ជាអសេក្ខៈ ប្រកបដោយសម្មាអាជីវៈ ជាអសេក្ខៈ ប្រកបដោយសម្មាវាយាមៈ ជាអសេក្ខៈ ប្រកបដោយសម្មាសតិ ជាអសេក្ខៈ ប្រកបដោយសម្មាសមាធិ ជាអសេក្ខៈ ប្រកបដោយសម្មាញាណៈ ជាអសេក្ខៈ ប្រកបដោយសម្មាវិមុត្តិ ជាអសេក្ខៈ ។ ម្នាលភិក្ខុ ( ភិក្ខុ ) ជាអសេក្ខៈយ៉ាងនេះឯង ។

# អដ្ឋកថា

## អសេក្ខសូត្រ

[ ១១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអសេក្ខសូត្រទី ១១ ដូចតទៅនេះ ព្រះមានព្រះភាគ ត្រាស់សម្មាទិដ្ឋិតែម្យ៉ាងថា សម្មាញាណ ដើម្បីកាពបរិបូណ៌នៃអដ្ឋមគ្គ ធម៌ គឺអរហត្តផលទាំងអស់នោះ ក៏ដូច្នោះ ។ សូម្បីបច្ចវេក្ខណញ្ញាណ ក៏ត្រាស់ថា អសេក្ខៈ ព្រោះអសេក្ខធម៌ប្រព្រឹត្តទៅហើយ ។

**អដ្ឋកថាអសេក្ខសូត្រទី ១១ ចប់**

# សុត្តន្តបិដក

## អសេក្ខធម្មសូត្រទី ១២

[ ១២ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ជាអសេក្ខៈនេះ មាន ១០ យ៉ាង ។ ១០ យ៉ាង តើអ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ជាអសេក្ខៈ ១ សម្មាសង្កប្បៈ ជាអសេក្ខៈ ១ សម្មាវាចា ជាអសេក្ខៈ ១ សម្មាកម្មន្តៈ ជាអសេក្ខៈ ១ សម្មាអាជីវៈ ជាអសេក្ខៈ ១ សម្មាវាយាមៈ ជាអសេក្ខៈ ១ សម្មាសតិ ជាអសេក្ខៈ ១ សម្មាសមាធិ ជាអសេក្ខៈ ១ សម្មាញាណៈ ជាអសេក្ខៈ ១ សម្មាវិមុត្តិ ជាអសេក្ខៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយជាអសេក្ខៈ មាន ១០ យ៉ាងនេះឯង ។

*សមណសញ្ញាវគ្គទី ១ ចប់*

## ឧទ្ទាននៃសមណសញ្ញាវគ្គនោះ គឺ

និយាយអំពីសេចក្តីសម្គាល់របស់សមណៈ ១ អំពីការចម្រើនពោជ្ឈង្គទាំង ៧ ជាបច្ច័យឲ្យបានបំពេញនូវវិជ្ជា ៣ យ៉ាង ១ អំពីការមិនបានស្ថានសួគ៌ ព្រោះអាស្រ័យមិច្ឆត្តៈ ១ អំពីការបានស្ថានសួគ៌ព្រោះអាស្រ័យសម្មត្តៈ ១ អំពីវិជ្ជា ជាប្រធាន ក្នុងការជួបប្រសព្វនូវកុសលធម៌ ១ អំពីការលោងថ្នឹងក្នុងទក្ខិណាជនបទ ១ អំពីពេទ្យអ្នកឲ្យថ្នាំបញ្ចុះ ១ អំពីពេទ្យអ្នកឲ្យថ្នាំក្អួត ១ អំពីធម៌ដែលគប្បីកម្ចាត់មាន ២ លើក ។

# អដ្ឋកថា

## អសេក្ខធម្មសូត្រ

[ ១២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអសេក្ខធម្មសូត្រទី ១២ ដូចតទៅនេះ បទថា **អសេក្ខិយា** បានដល់ អសេក្ខៈតែម្យ៉ាង ឬជារបស់ព្រះអសេក្ខៈ ទ្រង់ត្រាស់ព្រះទីណាស្រេចប៉ុណ្ណោះក្នុងសូត្រនេះ ។

**អដ្ឋកថា អសេក្ខធម្មសូត្រទី ១២ ចប់**

**សមណសញ្ញាវគ្គទី ១ ចប់**

# សុត្តន្តបិដក
# បច្ចោរោហណិវគ្គទី ២

## បឋមអធម្មសូត្រទី ១ ជាដើម

[ ១៣ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីដឹងសភាវៈ មិនមែនធម៌ផង សភាវៈ មិនមែនប្រយោជន៍ផង គប្បីដឹងធម៌ផង ប្រយោជន៍ផង លុះដឹងច្បាស់សភាវៈមិនមែនធម៌ផង សភាវៈមិនមែនប្រយោជន៍ផង ដឹងនូវធម៌ផង នូវប្រយោជន៍ផង ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា ភិក្ខុគប្បីប្រតិបត្តិតាមយ៉ាងនោះ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌ សភាវៈមិនមែនប្រយោជន៍ តើដូចម្តេច ។ គឺមិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បៈ មិច្ឆាវាចា មិច្ឆាកម្មន្តៈ មិច្ឆាអាជីវៈ មិច្ឆាវាយាមៈ មិច្ឆាសតិ មិច្ឆាសមាធិ មិច្ឆាញាណៈ មិច្ឆាវិមុត្តិ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សភាវៈមិនមែនធម៌ សភាវៈមិនមែនប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ និងប្រយោជន៍ តើដូចម្តេច ។ គឺសម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ សម្មាញាណៈ សម្មាវិមុត្តិ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ ហៅថា ប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យណាថា ភិក្ខុគប្បីដឹងសភាវៈមិនមែនធម៌ផង មិនមែនប្រយោជន៍ផង គប្បីដឹងធម៌ផង ប្រយោជន៍ផង លុះដឹងច្បាស់នូវសភាវៈមិនមែនធម៌ផង មិនមែនប្រយោជន៍ផង ដឹងនូវធម៌ផង ប្រយោជន៍ផង ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា ភិក្ខុគប្បីប្រតិបត្តិ

យ៉ាងនោះដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

[ ១៤ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីដឹងសភាវៈមិនមែនធម៌ផង ធម៌ផង គប្បីដឹងសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង លុះដឹងនូវសភាវៈមិនមែនធម៌ផង ធម៌ផង ដឹងនូវសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា ភិក្ខុគប្បីប្រតិបត្តិតាមយ៉ាងនោះ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌ តើដូចម្តេច ធម៌ តើដូចម្តេច សភាវៈមិនមែនប្រយោជន៍ តើដូចម្តេច ប្រយោជន៍ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មិច្ឆាទិដ្ឋិជាសភាវៈមិនមែនធម៌ សម្មាទិដ្ឋិជាធម៌ ពួកអកុសលធម៌លាមកច្រើនប្រការណា ដែលមានមិច្ឆាទិដ្ឋិជាបច្ច័យ កើតព្រម នេះជាសភាវៈមិនមែនប្រយោជន៍ ពួកអកុសលធម៌ច្រើនប្រការ មានសម្មាទិដ្ឋិជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា នេះជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ មិច្ឆា-សង្កប្បៈ ជាសភាវៈមិនមែនធម៌ សម្មាសង្កប្បៈជាធម៌ ពួកអកុសលធម៌ដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆាសង្កប្បៈជាបច្ច័យ កើតព្រម នេះជាសភាវៈមិនមែនប្រយោជន៍ ពួកកុសលធម៌ច្រើនប្រការ ដែលមានសម្មាសង្កប្បៈជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា នេះជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ មិច្ឆាវាចា ជាសភាវៈមិនមែនធម៌ សម្មាវាចាជាធម៌ ពួកអកុសលធម៌ដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆាវាចាជាបច្ច័យ កើត

ព្រម នេះជាសភាវៈមិនមែនប្រយោជន៍ ពួកកុសលធម៌ច្រើនប្រការ ដែលមានសម្មាវាចាជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា នេះជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ មិច្ឆាកម្មន្តៈ ជាសភាវៈមិនមែនធម៌ សម្មាកម្មន្តៈជាធម៌ ពួកអកុសលធម៌ដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆាកម្មន្តៈជាបច្ច័យ កើតព្រម នេះជាសភាវៈមិនមែនប្រយោជន៍ ពួកកុសលធម៌ច្រើនប្រការ ដែលមានសម្មាកម្មន្តៈជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា នេះជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ មិច្ឆាអាជីវៈជាសភាវៈមិនមែនធម៌ សម្មាអាជីវៈជាធម៌ ពួកអកុសលធម៌ដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាអាជីវៈជាបច្ច័យ កើតព្រម នេះជាសភាវៈមិនមែនជាប្រយោជន៍ ពួកកុសលធម៌ច្រើនប្រការ ដែលមានសម្មាអាជីវៈជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា នេះជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ មិច្ឆាវាយាមៈ ជាសភាវៈមិនមែនធម៌ សម្មាវាយាមៈជាធម៌ ពួកអកុសលធម៌ដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆាវាយាមៈជាបច្ច័យ កើតព្រម នេះជាសភាវៈមិនមែនប្រយោជន៍ ពួកកុសលធម៌ច្រើនប្រការ ដែលមានសម្មាវាយាមៈជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា នេះជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ មិច្ឆាសតិជាសភាវៈមិនមែនធម៌ សម្មាសតិជាធម៌ ពួកអកុសលធម៌ដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆាសតិជាបច្ច័យ កើតព្រម នេះជាសភាវៈមិនមែនជាប្រយោជន៍ ពួកកុសលធម៌ច្រើនប្រការ ដែលមានសម្មាសតិ

ជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយការនៃភាវនា នេះជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ មិច្ឆាសមាធិ ជាសភាវៈមិនមែនធម៌ សម្មាសមាធិជាធម៌ ពួកអកុសលធម៌ដ៏លាមកច្រើនប្រការណាដែលមានមិច្ឆាសមាធិ ជាបច្ច័យ កើតព្រម នេះជាសភាវៈមិនមែនប្រយោជន៍ ពួកកុសលធម៌ច្រើនប្រការ ដែលមានសម្មាសមាធិជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយការនៃភាវនា នេះជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ មិច្ឆាញាណៈ ជាសភាវៈមិនមែនធម៌ សម្មាញាណៈជាធម៌ ពួកអកុសលធម៌ដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាញាណៈជាបច្ច័យ កើតព្រម នេះជាសភាវៈមិនមែនប្រយោជន៍ ពួកកុសលធម៌ច្រើនប្រការ ដែលមានសម្មាញាណៈជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយការនៃភាវនា នេះជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ មិច្ឆាវិមុត្តិជាសភាវៈមិនមែនធម៌ សម្មាវិមុត្តិជាធម៌ ពួកអកុសលធម៌ដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាវិមុត្តិ ជាបច្ច័យកើតព្រម នេះជាសភាវៈមិនមែនប្រយោជន៍ ពួកកុសលធម៌ច្រើនប្រការ ដែលមានសម្មាវិមុត្តិជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយការនៃភាវនា នេះជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យណាថា ភិក្ខុគប្បីដឹងសភាវៈ មិនមែនធម៌ផង ធម៌ផង គប្បីដឹងសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង លុះដឹងនូវសភាវៈមិនមែនធម៌ផង ធម៌ផង ដឹងនូវសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា ភិក្ខុគប្បីប្រតិបត្តិតាមយ៉ាងនោះដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

# អដ្ឋកថា

# បច្ចោរោហណិវគ្គទី ២

## បឋមអធម្មសូត្រទី ១ ជាដើម

[ ១៣-១៤ ] *បឋមអធម្មសូត្រទី ១ ជាដើម នៃបច្ចោរោហណិវគ្គទី ២ ព្រះមានព្រះភាគត្រាស់បុច្ឆា និងវិសជ្ជនាដាច់ចេញអំពីគ្នា ទុតិយអធម្មសូត្រ ត្រាស់រួមគ្នា ។ល។*

**អដ្ឋកថា បឋមអធម្មសូត្រទី ១ ជាដើមចប់**

# សុត្តន្តបិដក

## តតិយអធម្មសូត្រទី ៣

[ ១៥ ] *ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីដឹងសភាវៈមិនមែនធម៌ផង ធម៌ផង គប្បីដឹងសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង លុះដឹងនូវសភាវៈមិនមែនធម៌ផង ធម៌ផង ដឹងនូវសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា ភិក្ខុគប្បីប្រតិបត្តិតាមយ៉ាងនោះ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ភាសិតនេះហើយ ព្រះសុគតពោលនូវពាក្យនេះហើយ ក្រោកចាកអាសនៈ ចូលទៅកាន់វិហារ ។ លុះព្រះមានព្រះភាគ ទ្រង់ចេញទៅមិនយូរប៉ុន្មាន ពួកភិក្ខុទាំងនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ម្នាល*

អាវុសោ ព្រះមានព្រះភាគ ទ្រង់សម្តែងឧទ្ទេសនេះដោយសេចក្តីបង្រួញ ទ្រង់មិនទាន់ចែកនូវអត្ថ ដោយពិស្តារ ដល់យើងទាំងឡាយ ហើយស្តេចក្រោកចាកអាសនៈ ចូលទៅកាន់វិហារ ( ឧទ្ទេសនោះថា ) ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីដឹងសភាវៈ មិនមែនធម៌ផង ធម៌ផង គប្បីដឹងនូវសភាវៈ មិនមែនជាប្រយោជន៍ផង ប្រយោជន៍ផង លុះដឹងនូវសភាវៈ មិនមែនធម៌ផង ធម៌ផង ដឹងនូវសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា ភិក្ខុគប្បីប្រតិបត្តិតាមយ៉ាងនោះ នរណាហ្ន៎ គប្បីចែកនូវអត្ថនៃឧទ្ទេសនេះ ដែលព្រះមានព្រះភាគ ទ្រង់សម្តែងដោយសេចក្តីបង្រួញ មិនទាន់ចែកអត្ថដោយពិស្តារ ឲ្យពិស្តារទៅបាន ។ លំដាប់នោះ ពួកភិក្ខុនោះ មានសេចក្តីត្រិះរិះដូច្នេះថា មានតែអានន្ទដ៏មានអាយុនេះទេ ដែលព្រះសាស្តាទ្រង់សរសើរផង ទាំងពួកសព្រហ្មចារីជាអ្នកប្រាជ្ញ ក៏សរសើរហើយដែរ អានន្ទដ៏មានអាយុ ទើបអាចនឹងចែកអត្ថនៃឧទ្ទេសនេះ ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងដោយសេចក្តីបង្រួញ មិនទាន់ចែកអត្ថដោយពិស្តារ ឲ្យពិស្តារទៅបាន បើដូច្នោះ គួរយើងនាំគ្នាចូលទៅរកអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយគប្បីសួរអត្ថនេះ នឹងអានន្ទដ៏មានអាយុ អានន្ទដ៏មានអាយុនឹងឆ្លើយដល់យើងរាល់គ្នាយ៉ាងណា យើងនឹងចាំទុកនូវអត្ថនោះយ៉ាងនោះ ។ លំដាប់នោះ ពួកភិក្ខុទាំងនោះ នាំគ្នាចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយក៏ធ្វើសេចក្តីរីករាយជាមួយនឹងអានន្ទដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ

និងពាក្យដែលគួរវេញកហើយ ក៏អង្គុយក្នុងទីសមគួរ លុះពួកភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ បានពោលពាក្យនេះនឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអាវុសោអានន្ទ ព្រះមានព្រះភាគទ្រង់សំដែងឧទ្ទេសនេះ ដោយសេចក្តីបង្រួញ មិនទាន់ចែកអត្ថដោយពិស្តារ ដល់យើងទាំងឡាយសោះ ហើយទ្រង់ក្រោកចាកអាសនៈចូលទៅកាន់ព្រះវិហារ ( ឧទ្ទេសនោះថា ) ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុគប្បីដឹងសភាវៈមិនមែនធម៌ផង ធម៌ផង គប្បីដឹងសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង លុះដឹងនូវសភាវៈមិនមែនធម៌ផង ធម៌ផង ដឹងនូវសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា ភិក្ខុប្រតិបត្តិតាមយ៉ាងនោះ ។ ម្នាលអាវុសោ ព្រះមានព្រះភាគរបស់យើង ទ្រង់ចៀសចេញទៅមិនយូរប៉ុន្មាន យើងទាំងនោះ មានសេចក្តីត្រិះរិះដូច្នេះថា ម្នាលអាវុសោ ព្រះដ៏មានព្រះភាគទ្រង់សំដែងឧទ្ទេសនេះដោយសេចក្តីបង្រួញ ទ្រង់មិនទាន់ចែកអត្ថ ដោយពិស្តារ ដល់យើងទាំងឡាយ ហើយក្រោកចាកអាសនៈ ចូលទៅកាន់វិហារ ( ឧទ្ទេសនោះថា ) ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីដឹងសភាវៈមិនមែនធម៌ផង ធម៌ផង គប្បីដឹងសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង លុះដឹងសភាវៈមិនមែនធម៌ផង ធម៌ផង ដឹងសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា ភិក្ខុប្រតិបត្តិតាមយ៉ាងនោះ នរណាហ្ន៎ គប្បីចែកអត្ថនៃឧទ្ទេសនេះដែលព្រះមានព្រះភាគ ទ្រង់សំដែងដោយសេចក្តីបង្រួញមិនទាន់ចែកអត្ថដោយ

ពិស្តារ ឲ្យពិស្តារបាន ។ ម្នាលអាវុសោ យើងទាំងនោះ មានសេចក្តីត្រិះរិះ ដូច្នេះថា មានតែអានន្ទដ៏មានអាយុនេះឯង ដែលព្រះសាស្តា សរសើរហើយ ផង ទាំងពួកសព្រហ្មចារីជាអ្នកប្រាជ្ញ ក៏សរសើរហើយដែរ អានន្ទដ៏មានអាយុ ទើបអាចនឹងចែកអត្ថនៃឧទ្ទេសនេះ ដែលព្រះមានព្រះភាគ ទ្រង់សម្តែងដោយ សេចក្តីបង្រួញ មិនទាន់ចែកអត្ថដោយពិស្តារ ឲ្យពិស្តារបាន បើដូច្នោះ គួរ យើងចូលទៅរកអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ គប្បីសួរអត្ថនេះ នឹងអានន្ទដ៏មានអាយុ អានន្ទដ៏មានអាយុនឹងឆ្លើយ ដល់យើងទាំងឡាយយ៉ាង ណា យើងទាំងឡាយ គប្បីចាំទុកនូវអត្ថយ៉ាងនោះ សូមអានន្ទដ៏មានអាយុ ចែក ( សេចក្តីនេះឲ្យទាន ) ។ ព្រះអានន្ទដ៏មានអាយុឆ្លើយថា ម្នាលអាវុសោ ដូចជាបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅរកខ្លឹមឈើ កាលបើឈើធំ មានខ្លឹមឋិតនៅ ( ចំពោះមុខ ) ក៏រំលងគល់ រំលងដើម ហើយ សម្គាល់ថា គួរស្វែងរកខ្លឹម ត្រង់មែក និងសន្លឹកទៅវិញ មានឧបមាយ៉ាងណា មិញ សេចក្តីឧបមេយ្យក៏យ៉ាងនោះដែរ កាលបើព្រះសាស្តាគង់ក្នុងទីចំពោះមុខ នៃលោកដ៏មានអាយុទាំងឡាយ លោកទាំងឡាយ រំលងព្រះមានព្រះភាគនោះ ហើយសម្គាល់ថា គប្បីសួរសេចក្តីនេះនឹងខ្ញុំវិញ ម្នាលអាវុសោ ព្រោះថា ព្រះ មានព្រះភាគនោះ តែងទ្រង់ជ្រាបនូវហេតុដែលគួរជ្រាប ទ្រង់ឃើញនូវហេតុ ដែលគួរឃើញព្រះតថាគតនោះមានចក្ខុកើតហើយ មានញាណកើតហើយ មាន ធម៌កើតហើយ ព្រះអង្គជាបុរសប្រសើរ ព្រះអង្គជាអ្នកស្តីថា ជាអ្នកប្រៀន

ប្រដៅ ជាអ្នកបង្អោនទូវប្រយោជន៍ អ្នកឲ្យនូវព្រះនិព្វាន ជាម្ចាស់នៃធម៌ កាលនេះ ជាកាលគួរ ដល់ព្រះតថាគតនុ៎ះហើយ លោកទាំងឡាយ គប្បីចូលទៅគាល់ព្រះមានព្រះភាគ ហើយសាកសួរនូវសេចក្តីនៃឧទ្ទេសនេះ ( បើ ) ព្រះមានព្រះភាគនៃយើងសម្តែងយ៉ាងណា អ្នកទាំងឡាយ គប្បីចាំទុកនូវឧទ្ទេសនោះ យ៉ាងនោះចុះ ។ ម្នាលអាវុសោអានន្ទ ព្រះមានព្រះភាគទ្រង់ជ្រាបនូវហេតុដែលគួរជ្រាប ទ្រង់ឃើញនូវហេតុដែលគួរឃើញ ដោយពិតណាស់ ព្រះតថាគតនោះមានចក្ខុកើតហើយ មានញាណកើតហើយ មានធម៌កើតហើយ ព្រះអង្គជាបុរសប្រសើរ ព្រះអង្គជាអ្នកស្តីថា ជាអ្នកប្រៀនប្រដៅ ជាអ្នកបង្អោនមកនូវប្រយោជន៍ អ្នកឲ្យនូវព្រះនិព្វាន ជាម្ចាស់នៃធម៌ កាលនេះជាកាលគួរដល់ព្រះតថាគតនុ៎ះហើយ យើងទាំងឡាយ គប្បីចូលទៅគាល់ព្រះដ៏មានព្រះភាគ ហើយសាកសួរនូវសេចក្តីនៃឧទ្ទេសនុ៎ះ ( បើ ) ព្រះមានព្រះភាគ ទ្រង់ដោះស្រាយ ដល់យើងទាំងឡាយ យ៉ាងណា យើងទាំងឡាយ គប្បីចាំទុកនូវឧទ្ទេសនោះ យ៉ាងនោះ ក៏ពិតមែនហើយ ប៉ុន្តែអានន្ទដ៏មានអាយុ ( នេះ ) ព្រះសាស្តាទ្រង់សរសើរផង ទាំងពួកសព្រហ្មចារី ជាអ្នកប្រាជ្ញ ក៏សរសើរដែរ អានន្ទដ៏មានអាយុនេះ អាចនឹងចែកអត្ថ នៃឧទ្ទេសនេះ ដែលព្រះមានព្រះភាគទ្រង់សម្តែងដោយសេចក្តីបង្រួញ មិនទាន់ចែកអត្ថ ដោយពិស្តារ ឲ្យពិស្តារទៅបាន សូមអានន្ទដ៏មានអាយុ កុំឲ្យបង្អែបង្អង់ មេត្តាចែកអត្ថនេះឲ្យទាន ។ ម្នាលអាវុសោ បើដូច្នោះ អ្នកទាំងឡាយ ចូរប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យ

ប្រពៃចុះ ខ្ញុំនឹងសម្ដែងប្រាប់ ។ ពួកភិក្ខុទាំងនោះ ទទួលស្ដាប់ថេរវាចា របស់ព្រះអានន្ទដ៏មានអាយុថា ករុណាអាវុសោ ។ ព្រះអានន្ទដ៏មានអាយុបានពោលពាក្យនេះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគរបស់យើង ទ្រង់សម្ដែងនូវឧទ្ទេសណា ដោយសេចក្ដីបង្រួញ ទ្រង់មិនទាន់ចែកអត្ថដោយពិស្ដារ ស្រាប់តែក្រោកចាកអាសនៈចូលទៅកាន់វិហារ ( ឧទ្ទេសនោះថា ) ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុគប្បីដឹងសភាវៈមិនមែនធម៌ផង ធម៌ផង គប្បីដឹងសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង លុះដឹងនូវសភាវៈមិនមែនធម៌ផង ធម៌ផង ដឹងនូវសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា ភិក្ខុគប្បីប្រតិបត្តិតាមយ៉ាងនោះ ម្នាលអាវុសោ សភាវៈមិនមែនធម៌ តើដូចម្ដេច ធម៌ តើដូចម្ដេច សភាវៈមិនមែនប្រយោជន៍ តើដូចម្ដេច ប្រយោជន៍ តើដូចម្ដេច ។ ម្នាលអាវុសោ មិច្ឆាទិដ្ឋិ ជាសភាវៈមិនមែនធម៌ សម្មាទិដ្ឋិជាធម៌ ពួកអកុសលធម៌ដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆា-ទិដ្ឋិជាបច្ច័យ កើតព្រម នេះជាសភាវៈមិនមែនប្រយោជន៍ ពួកកុសលធម៌ច្រើនប្រការ ដែលមានសម្មាទិដ្ឋិជាបច្ច័យ រមែងដល់នូវការបរិបូណ៌ ដោយភាវនា នេះជាប្រយោជន៍ ម្នាលអាវុសោ មិច្ឆាសង្កប្បៈ ជាសភាវៈមិនមែនធម៌ សម្មាសង្កប្បៈ ជាធម៌ ... ម្នាលអាវុសោ មិច្ឆាវាចា ជាសភាវៈមិនមែនធម៌ សម្មាវាចា ជាធម៌ ... ម្នាលអាវុសោ មិច្ឆាកម្មន្តៈ ជាសភាវៈមិនមែនធម៌ សម្មាកម្មន្តៈ ជាធម៌ ... ម្នាលអាវុសោ មិច្ឆាអាជីវៈ ជាសភាវៈមិនមែន

ធម៌ សម្មាអាជីវៈ ជាធម៌ ... ម្នាលអាវុសោ មិច្ឆាវាយាមៈ ជាសភាវៈមិនមែនធម៌ សម្មាវាយាមៈ ជាធម៌ ... ម្នាលអាវុសោ មិច្ឆាសតិ ជាសភាវៈមិនមែនធម៌ សម្មាសតិ ជាធម៌ ... ម្នាលអាវុសោ មិច្ឆាសមាធិ ជាសភាវៈមិនមែនធម៌ សម្មាសមាធិ ជាធម៌ ... ម្នាលអាវុសោ មិច្ឆាញាណៈជាសភាវៈមិនមែនធម៌ សម្មាញាណៈ ជាធម៌ ... ម្នាលអាវុសោ មិច្ឆាវិមុត្តិ ជាសភាវៈមិនមែនធម៌ សម្មាវិមុត្តិ ជាធម៌ ពួកអកុសលធម៌ដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆាវិមុត្តិជាបច្ច័យ កើតព្រម នេះជាសភាវៈមិនមែនប្រយោជន៍ ពួកកុសលធម៌ច្រើនប្រការ ដែលមានសម្មាវិមុត្តិជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា នេះជាប្រយោជន៍ ម្នាលអាវុសោ ព្រះមានព្រះភាគនៃយើង ទ្រង់សម្តែងនូវឧទ្ទេសណា ដោយសេចក្តីបង្រួញ មិនទាន់ចែកអត្ថដោយពិស្តារ ស្រាប់តែស្តេចក្រោកចាកអាសនៈ ចូលទៅកាន់ព្រះវិហារ ( ឧទ្ទេសនោះថា ) ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីដឹងសភាវៈមិនមែនធម៌ផង ធម៌ផងគប្បីដឹងសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង លុះដឹងនូវសភាវៈមិនមែនធម៌ផង ធម៌ផង ដឹងនូវសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា ភិក្ខុគប្បីប្រតិបត្តិតាមយ៉ាងនោះ ម្នាលអាវុសោ ខ្ញុំដឹងនូវអត្ថនៃឧទ្ទេសនេះ ដែលព្រះមានព្រះភាគ ទ្រង់សម្តែងដោយសេចក្តីបង្រួញ ទ្រង់មិនទាន់ចែកអត្ថដោយពិស្តារ ឲ្យពិស្តារយ៉ាងនេះ ម្នាលអាវុសោ ប្រសិនបើអ្នកទាំងឡាយប្រាថ្នា ( នឹងសួរ ) គប្បីចូលទៅគាល់ព្រះមានព្រះភាគ ហើយទូលសួរនូវសេចក្តីនុ៎ះចុះ ព្រះមានព្រះភាគ ទ្រង់

ព្យាករដល់យើងទាំងឡាយយ៉ាងណា ចូរអ្នកទាំងឡាយ ចាំទុកសេចក្ដីនោះយ៉ាងនោះចុះ ។ ពួកភិក្ខុទាំងនោះទទួលតបថា ករុណាអាវុសោ ហើយត្រេកអររីករាយនឹងភាសិត របស់ព្រះអានន្ទដ៏មានអាយុ ហើយក្រោកចាកអាសនៈចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ លុះពួកភិក្ខុទាំងនោះអង្គុយក្នុងទីសមគួរហើយក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះមានព្រះភាគដ៏ចម្រើន ព្រះអង្គទ្រង់សម្ដែងឧទ្ទេសណា ដោយសេចក្ដីបង្រួញ ទ្រង់មិនទាន់ចែកអត្ថ ដោយពិស្ដារ ដល់យើងទាំងឡាយ ស្រាប់តែក្រោកចាកអាសនៈ ចូលទៅកាន់ព្រះវិហារ ( ឧទ្ទេសនោះថា ) ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីដឹងសភាវៈមិនមែនធម៌ផង ធម៌ផង គប្បីដឹងសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង លុះដឹងនូវសភាវៈមិនមែនធម៌ផង ធម៌ផង ដឹងនូវសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា ភិក្ខុគប្បីប្រតិបត្តិតាមយ៉ាងនោះ បពិត្រព្រះអង្គដ៏ចម្រើន កាលព្រះមានព្រះភាគ ទ្រង់ចៀសចេញទៅមិនយូរប៉ុន្មាន ពួកខ្ញុំព្រះអង្គទាំងនោះ មានសេចក្ដីត្រិះរិះដូច្នេះថា ម្នាលអាវុសោ ព្រះមានព្រះភាគ ទ្រង់សម្ដែងឧទ្ទេសនេះ ដោយសេចក្ដីបង្រួញមិនទាន់ចែកអត្ថដោយពិស្ដារដល់យើងទាំងឡាយ ហើយស្រាប់តែក្រោកចាកអាសនៈ ចូលទៅកាន់ព្រះវិហារ ( ឧទ្ទេសនោះថា ) ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីដឹងសភាវៈមិនមែនធម៌ផង ធម៌ផង គប្បីដឹងសភាវៈមិនមែនប្រយោជន៍

ផង ប្រយោជន៍ផង លុះដឹងនូវសភាវៈមិនមែនធម៌ផង ធម៌ផង ដឹងនូវសភាវៈ មិនមែនប្រយោជន៍ផង ប្រយោជន៍ផង ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា ភិក្ខុគប្បីប្រតិបត្តិតាមយ៉ាងនោះ នរណាហ្ន៎ គប្បីចែកអត្ថនៃឧទ្ទេសនេះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់សម្តែង ដោយសេចក្តីបង្រួញ មិនទាន់បានចែកអត្ថដោយពិស្តារ ឲ្យពិស្តារទៅបាន បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គទាំងនោះ មានសេចក្តីត្រិះរិះដូច្នេះថា មានតែអានន្ទដ៏មានអាយុនេះឯង ដែលព្រះសាស្តា ទ្រង់សរសើរហើយផង ទាំងពួកសព្រហ្មចារី ជាអ្នកប្រាជ្ញ ក៏សរសើរហើយដែរ អានន្ទដ៏មានអាយុនេះ ទើបអាចដើម្បីចែកអត្ថនៃឧទ្ទេសនេះ ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងដោយសេចក្តីបង្រួញ មិនទាន់បានចែកអត្ថដោយពិស្តារ ឲ្យពិស្តារបាន បើដូច្នោះ គួរតែយើងទាំងឡាយ ចូលទៅរកអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ គប្បីសាកសួរសេចក្តីនុ៎ះនឹងអានន្ទដ៏មានអាយុ ( បើ ) អានន្ទដ៏មានអាយុ ឆ្លើយចំពោះពួកយើងទាំង-ឡាយយ៉ាងណា យើងទាំងឡាយ គប្បីចាំទុកនូវអត្ថនោះយ៉ាងនោះ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ ពួកខ្ញុំព្រះអង្គ ក៏ចូលទៅរកអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ទើបសាកសួរសេចក្តីនុ៎ះ នឹងអានន្ទដ៏មានអាយុ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីដែលអានន្ទដ៏មានអាយុចែកហើយ ដោយអាការទាំងនេះ ដោយបទទាំងនេះ ដោយព្យញ្ជនៈទាំងនេះ ដល់ពួកខ្ញុំព្រះអង្គទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ ប្រពៃហើយៗ ម្នាលភិក្ខុទាំងឡាយ

អានន្ទជាបណ្ឌិត ម្នាលភិក្ខុទាំងឡាយ អានន្ទ ជាអ្នកមានបញ្ញាច្រើន ម្នាលភិក្ខុទាំងឡាយ ប្រសិនបើអ្នកទាំងឡាយ ចូលមករកតថាគតហើយ គប្បីសាកសួរសេចក្តីនុ៎ះ តថាគតគប្បីដោះស្រាយសេចក្តីនុ៎ះយ៉ាងនោះ ដូចជាអានន្ទឆ្លើយហើយដែរ នេះជាសេចក្តីនៃឧទ្ទេសនោះ អ្នកទាំងឡាយ គប្បីចាំទុកនូវសេចក្តីនោះ យ៉ាងនេះចុះ ។

# អដ្ឋកថា

## តតិយអធម្មសូត្រ

[ ១៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតតិយអធម្មសូត្រទី ៣ ដូចតទៅនេះ បទថា **ឧទ្ទេសំ ឧទ្ទិសិត្វា** បានដល់ តាំងបទមាតិកា ។ បទថា **សត្ថុ ចេវ សំវណ្ណិតោ** សេចក្តីថា ព្រះអានន្ទដែលព្រះសាស្តា ទ្រង់ស្ថាបនាទុកក្នុងតំណែងឯតទគ្គៈ ក្នុងឋានៈ ៥ ប្រការ ទ្រង់សរសើរហើយ ។ បទថា **សម្ភាវិតោ** សេចក្តីថា ដែលពួកសព្រហ្មចារីសរសើរហើយ ដោយការសរសើរគុណ ។ បទថា **បហោតិ** ប្រែថា រមែងអាច ។

បទថា **អតិសិត្វា** ប្រែថា កន្លង ។ បទថា **ជានំ ជានាតិ** ប្រែថា ទ្រង់ដឹងប្រការដែលគួរដឹង ។ បទថា **បស្សំ បស្សតិ** ប្រែថា ទ្រង់ឃើញប្រការដែលគួរឃើញ ។ បទថា **ចក្ខុភូតោ** បានដល់ ទ្រង់ហាក់ដូចមានចក្ខុ

*កើតឡើងហើយ ។ បទថា* **ញាណភូតោ** *បានដល់ ទ្រង់មានការដឹងជាសភាវៈ ។ បទថា* **ធម្មភូតោ** *បានដល់ ទ្រង់មានធម៌ជាសភាវៈ ។ បទថា* **ព្រហ្មភូតោ** *បានដល់ ទ្រង់ជាបុគ្គលប្រសើរបំផុតជាសភាវៈ ។ បទថា* **វត្តា** *បានដល់ ទ្រង់អាចដំណើរការឯង ។ បទថា* **បវត្តា** *បានដល់ ទ្រង់ប្រើឲ្យអ្នកដទៃប្រព្រឹត្តទៅ ។ បទថា* **អត្ថស្ស និន្នេតា** *បានដល់ ទ្រង់ទាញនូវអត្ថមកសម្ដែង ។ បទថា* **យថា នោ ភគវា** *ប្រែថា ព្រះមានព្រះភាគ គប្បីព្យាករដល់ពួកយើង ដោយប្រការណា ។*

**អដ្ឋកថា តតិយអធម្មសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## អាជិនសូត្រទី ៤

*[ ១៦ ] គ្រានោះ អាជិនបរិព្វាជក បានចូលទៅគាល់ព្រះមានព្រះភាគ លុះបានចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយ ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ទើបអង្គុយក្នុងទីសមគួរ លុះអាជិនបរិព្វាជកអង្គុយក្នុងទីសមគួរហើយ បានពោលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន សព្រហ្មចារីរបស់យើងខ្ញុំឈ្មោះថា ជាបណ្ឌិត ( ព្រោះ ) ពួកអន្យតិរ្ថិយ ដែលសព្រហ្មចារីនោះ*

សន្តត់សន្តិនហើយ ដោយចិត្តប្បាទ ចំនួន ៥០០ រមែងដឹងខ្លួនថា ពួកយើងត្រូវគេសន្តត់សន្តិនហើយ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចាំទុកនូវបណ្ឌិតវត្ថុដែរឬទេ ។ ព្រះមានព្រះភាគទ្រង់សម្តែងភាសិតណា បពិត្រព្រះមានព្រះភាគ កាលនេះជាកាលគួរដល់ភាសិតនុ៎ះ បពិត្រព្រះសុគត កាលនេះ ជាកាលគួរដល់ភាសិតនុ៎ះ ពួកភិក្ខុលុះបានស្តាប់នូវភាសិត របស់ព្រះមានព្រះភាគហើយ នឹងចាំទុកបាន ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយ ចូរប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ករុណាព្រះអង្គ ។ ទើបឯព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ រមែងសន្តត់សន្តិន ញាំញីនូវវាទៈ ដែលមិនប្រកបដោយធម៌ ដោយវាទៈដែលមិនប្រកបដោយធម៌ រមែងដឹកនាំបរិស័ទដែលមិនប្រកបដោយធម៌ ឲ្យត្រេកអរដោយវាទៈនោះផង ព្រោះហេតុនោះ បរិស័ទដែលមិនប្រកបដោយធម៌នោះ ជាអ្នកមានសំឡេងខ្ពស់សំឡេងខ្លាំងថា ឱហ្ន៎ ជននេះជាបណ្ឌិត ឱហ្ន៎ ជននេះជាបណ្ឌិត ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ រមែងសន្តត់សន្តិន ញាំញីនូវវាទៈដែលប្រកបដោយធម៌ ដោយវាទៈដែលមិនប្រកបដោយធម៌ រមែងដឹកនាំបរិស័ទដែលមិនប្រកបដោយធម៌ ឲ្យត្រេកអរបាន ដោយវាទៈនោះផង ព្រោះហេតុនោះ បរិស័ទដែលមិនប្រកបដោយធម៌

នោះ ជាអ្នកមានសំឡេងខ្ពស់ សំឡេងខ្លាំងថា ឱហ្ន៎ ជននេះជាបណ្ឌិត ឱហ្ន៎ ជននេះជាបណ្ឌិត ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ រមែងសន្កត់សង្កិន ញាំញីនូវវាទៈ ដែលប្រកបដោយធម៌ផង នូវវាទៈ ដែលមិនប្រកបដោយធម៌ផង ដោយវាទៈដែលមិនប្រកបដោយធម៌ រមែងដឹកនាំបរិស័ទ ដែលមិនប្រកបដោយធម៌ ឲ្យត្រេកអរដោយវាទៈនោះផង ព្រោះហេតុនោះ បរិស័ទដែលមិនប្រកបដោយធម៌នោះ ជាអ្នកមានសំឡេងខ្ពស់ សំឡេងខ្លាំងថា ឱហ្ន៎ ជននេះជាបណ្ឌិត ឱហ្ន៎ ជននេះជាបណ្ឌិត ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ រមែងសន្កត់សង្កិន ញាំញីនូវវាទៈដែលមិនប្រកបដោយធម៌ ដោយវាទៈដែលប្រកបដោយធម៌ រមែងដឹកនាំបរិស័ទ ដែលមិនប្រកបដោយធម៌ ឲ្យត្រេកអរ ដោយវាទៈនោះផង ព្រោះហេតុនោះ បរិស័ទដែលមិនប្រកបដោយធម៌នោះ ជាអ្នកមានសំឡេងខ្ពស់ សំឡេងខ្លាំងថា ឱហ្ន៎ ជននេះជាបណ្ឌិត ឱហ្ន៎ ជននេះជាបណ្ឌិត ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ រមែងសន្កត់សង្កិន ញាំញីនូវវាទៈដែលប្រកបដោយធម៌ ដោយវាទៈ ដែលប្រកបដោយធម៌ រមែងដឹកនាំបរិស័ទដែលប្រកបដោយធម៌ ឲ្យត្រេកអរដោយវាទៈនោះផង ព្រោះហេតុនោះ បរិស័ទដែលប្រកបដោយធម៌នោះ ជាអ្នកមានសំឡេងខ្ពស់ សំឡេងខ្លាំងថា ឱហ្ន៎ ជននេះជាបណ្ឌិត ឱហ្ន៎ ជននេះជាបណ្ឌិត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីដឹងសភាវៈមិនមែនធម៌ផង ធម៌ផង គប្បីដឹងសភាវៈមិនមែនប្រយោជន៍

ផង ប្រយោជន៍ផង លុះដឹងសភាវៈមិនមែនធម៌ផង ធម៌ផង ដឹងនូវសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា ភិក្ខុគប្បីប្រតិបត្តិតាមយ៉ាងនោះ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌ តើដូចម្តេច ធម៌ តើដូចម្តេច សភាវៈមិនមែនប្រយោជន៍ តើដូចម្តេច ប្រយោជន៍ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មិច្ឆាទិដ្ឋិជាសភាវៈមិនមែនធម៌ សម្មាទិដ្ឋិជាធម៌ អកុសលធម៌ដ៏លាមកទាំងឡាយ ច្រើនប្រការណា ដែលមានមិច្ឆាទិដ្ឋិជាបច្ច័យ កើតព្រម នេះជាសភាវៈមិនមែនប្រយោជន៍ ពួកកុសលធម៌ច្រើនប្រការ ដែលមានសម្មាទិដ្ឋិជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា នេះជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ មិច្ឆាសង្កប្បៈ ជាសភាវៈមិនមែនធម៌ សម្មាសង្កប្បៈ ជាធម៌ ... ម្នាលភិក្ខុទាំងឡាយ មិច្ឆាវាចា ជាសភាវៈមិនមែនធម៌ សម្មាវាចា ជាធម៌ ... ម្នាលភិក្ខុទាំងឡាយ មិច្ឆាកម្មន្តៈ ជាសភាវៈមិនមែនធម៌ សម្មាកម្មន្តៈ ជាធម៌ ... ម្នាលភិក្ខុទាំងឡាយ មិច្ឆាអាជីវៈ ជាសភាវៈមិនមែនធម៌ សម្មាអាជីវៈ ជាធម៌ ... ម្នាលភិក្ខុទាំងឡាយ មិច្ឆាវាយាមៈ ជាសភាវៈមិនមែនធម៌ សម្មាវាយាមៈជាធម៌ ... ម្នាលភិក្ខុទាំងឡាយ មិច្ឆាសតិជាសភាវៈមិនមែនធម៌ សម្មាសតិ ជាធម៌ ... ម្នាលភិក្ខុទាំងឡាយ មិច្ឆាសមាធិជាសភាវៈមិនមែនធម៌ សម្មាសមាធិ ជាធម៌ ... ម្នាលភិក្ខុទាំងឡាយ មិច្ឆាញាណៈ ជាសភាវៈមិនមែនធម៌ សម្មាញាណៈ ជាធម៌ ... ម្នាលភិក្ខុទាំងឡាយ មិច្ឆាវិមុត្តិជាសភាវៈមិនមែនធម៌ សម្មាវិមុត្តិ ជាធម៌ ពួកអកុសលធម៌ដ៏លាមក

ច្រើនប្រការណា ដែលមានមិច្ឆាវិមុត្តិ ជាបច្ច័យកើតព្រម នេះជាសភាវៈមិនមែនប្រយោជន៍ ពួកកុសលធម៌ច្រើនប្រការ ដែលមានសម្មាវិមុត្តិ ជាបច្ច័យរមែងដល់នូវការបរិបូណ៌ដោយភាវនា នេះជាប្រយោជន៍ ។ ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីដឹងសភាវៈមិនមែនធម៌ផង ធម៌ផង គប្បីដឹងសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង លុះដឹងនូវសភាវៈមិនមែនធម៌ផង ធម៌ផង ដឹងនូវសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា ភិក្ខុគប្បីប្រតិបត្តិតាមយ៉ាងនោះដូច្នេះ ដែលតថាគតបានពោលហើយ ក៏ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

## អដ្ឋកថា

## អាជិនសូត្រ

[ ១៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអាជិនសូត្រទី ៤ ដូចតទៅនេះ បទថា **អាជិនោ** បានដល់ បរិព្វាជកមានឈ្មោះយ៉ាងនេះ ។ បទថា **ចិត្តដ្ឋានសតានិ** បានដល់ ចិត្តុប្បាទ ១០០ ។ បទថា **យេហិ** ប្រែថា ការប្រកបដោយចិត្តុប្បាទទាំងឡាយ ១០០ ណា ។ បទថា **ឧចារទ្ធាវ ជានន្តិ ឧចារទ្ធស្មា** សេចក្តីថា អន្យតិរ្ថិយដែលភ្លាំងភ្លាត់ហើយ កាន់យកខុសហើយ រមែងដឹងយ៉ាងនេះថា អាត្មាអញជាអ្នកភ្លាំងភ្លាត់ហើយ អាត្មាអញជាអ្នកកាន់

យកខុសហើយ អាត្មាអញត្រូវគេលើកទោសឡើងហើយ ដូច្នេះ ។ បទថា **បណ្ឌិតវត្ថូនិ** ប្រែថា ដើម្បីជាប្រយោជន៍ដល់ភាពជាបណ្ឌិត ។៚

## អដ្ឋកថាអាជិនសូត្រទី ៤ ចប់

# សុត្តន្តបិដក

## សគារវសូត្រទី ៥

[ ១៧ ] គ្រានោះ សគារវព្រាហ្មណ៍ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ លុះសគារវព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន អ្វីជាត្រើយខាងអាយ អ្វីជាត្រើយខាងនាយ ។ ម្នាលព្រាហ្មណ៍ មិច្ឆាទិដ្ឋិ ជាត្រើយខាងអាយ សម្មាទិដ្ឋិ ជាត្រើយខាងនាយ មិច្ឆាសង្កប្បៈ ជាត្រើយខាងអាយ សម្មាសង្កប្បៈ ជាត្រើយខាងនាយ មិច្ឆាវាចា ជាត្រើយខាងអាយ សម្មាវាចា ជាត្រើយខាងនាយ មិច្ឆាកម្មន្តៈ ជាត្រើយខាងអាយ សម្មាកម្មន្តៈ ជាត្រើយខាងនាយ មិច្ឆាអាជីវៈ ជាត្រើយខាងអាយ សម្មាអាជីវៈ ជាត្រើយខាងនាយ មិច្ឆាវាយាមៈ

ជាត្រើយខាងអាយ សម្មាវាយាមៈ ជាត្រើយខាងនាយ មិច្ឆាសតិ ជាត្រើយខាងអាយ សម្មាសតិ ជាត្រើយខាងនាយ មិច្ឆាសមាធិ ជាត្រើយខាងអាយ សម្មាសមាធិ ជាត្រើយខាងនាយ មិច្ឆាញាណៈ ជាត្រើយខាងអាយ សម្មាញាណៈ ជាត្រើយខាងនាយ មិច្ឆាវិមុត្តិ ជាត្រើយខាងអាយ សម្មាវិមុត្តិ ជាត្រើយខាងនាយ ។ ម្នាលព្រាហ្មណ៍ នេះជាត្រើយខាងអាយ នេះជាត្រើយខាងនាយ ។

បណ្តាមនុស្សទាំងឡាយ ពួកជនណា បានដល់នូវត្រើយខាងនាយ ( ព្រះនិព្វាន ) ពួកជននោះមានប្រមាណតិច ឯសត្វក្រៅពីនេះរមែងស្ទុះទៅកាន់ត្រើយ គឺសក្កាយទិដ្ឋិ ( នេះច្រើនជាង ) ។ ពួកជនណា ប្រព្រឹត្តតាមធម៌ក្នុងធម៌ ដែលតថាគតសម្តែងហើយ ដោយប្រពៃ ពួកជននោះ ( បានឆ្លង ) នូវវដ្តៈជាទីនៅនៃមច្ចុ ដែលសត្វកម្រឆ្លងបាន ដោយក្រក្រៃពេក ហើយនឹងដល់នូវត្រើយខាងនាយ គឺព្រះនិព្វាន ។ បណ្ឌិតត្រូវលះបង់នូវធម៌ខ្មៅ ហើយចម្រើននូវធម៌ស ហើយចេញចាកអាល័យ អាស្រ័យនូវព្រះនិព្វាន ដែលមិនមានអាល័យ ការត្រេកអរបានដោយកម្រ ក្នុងវិវេកណា បណ្ឌិតអ្នកមិនមានសេចក្តីកង្វល់ គប្បីលះបង់នូវកាមទាំងឡាយ ហើយប្រាថ្នានូវសេចក្តី

ត្រេកអរក្នុងវិវេកនោះ បណ្ឌិតគប្បីធ្វើខ្លួនឲ្យផូរផង់ ចាក គ្រឿងសៅហ្មងនៃចិត្តទាំងឡាយ ។ ចិត្តដែលពួកជនណា ចម្រើនល្អប្រពៃហើយក្នុងអង្គនៃធម៌ ជាគ្រឿងត្រាស់ដឹង ទាំងឡាយ ពួកជនណា ត្រេកអរក្នុងការលះបង់នូវសេចក្តី ប្រកាន់ ព្រោះមិនប្រកាន់ ពួកជនទាំងនោះ ឈ្មោះថា ជាខីណាស្រព ជាអ្នកមានសេចក្តីរុងរឿង បរិនិព្វាន ហើយ ក្នុងលោកនេះ ។

# អដ្ឋកថា

## សគារវសូត្រ

[ ១៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសគារវសូត្រទី ៥ ដូចតទៅនេះ បទថា **ឱរិមំ តីរំ** បានដល់ លោកិយ ឈ្មោះថា ត្រើយអាយ ។ បទថា **បារិមំ តីរំ** បានដល់ លោកុត្តរ ឈ្មោះថា ត្រើយនាយ ។

បទថា **បារគាមិនោ** បានដល់ ដល់នូវព្រះនិព្វាន ។ បទថា **តីរមេវានុធាវតិ** បានដល់ ស្ទុះទៅកាន់ត្រើយអាយ គឺសក្កាយទិដ្ឋិ ។ បទថា **ធម្មេ ធម្មានុវត្តិនោ** សេចក្តីថា ប្រព្រឹត្តតាមសមគួរក្នុងលោកុត្តរធម៌ ៩ ដែលត្រាស់ហើយដោយប្រពៃ បានដល់ ប្រព្រឹត្តតាមបដិបទាខាងដើម មួយ

អន្ទើដោយសីល ដែលសមគួរដល់ធម៌នោះ ។ បទថា **មច្ចុធេយ្យំ សុទុត្តរំ** បានដល់ ឆ្លងវដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលជាទីតាំងនៃមច្ចុមារដែលឆ្លងបានលំបាក ។ បទថា **ចរាមេស្សន្តិ** បានដល់ នឹងសម្រេចព្រះនិព្វាន ។ បទថា **ឱកា អនោកមាគម្ម** បានដល់ អាស្រ័យវិវដ្តៈអំពីវដ្តៈ ។ បទថា **វិវេកេ យត្ថ ទូរមំ** ប្រែថា គប្បីប្រាថ្នាការត្រេកអរក្រៃលែងក្នុងកាយវិវេក ចិត្តវិវេក និងឧបធិវិវេក ដែលត្រេកអរបានលំបាកក្រៃលែង ។ បទថា **ហិត្វា កាមេ** បានដល់ លះកាមទាំង ២ ។ បទថា **អកិញ្ចនោ** ប្រែថា កិលេសជាគ្រឿងកង្វល់ ។ បទថា **អាទានប្បដិនិស្សគ្គេ** បានដល់ ក្នុងព្រះនិព្វាន ពោល គឺការលះបង់នូវការប្រកាន់មាំ ។ បទថា **អនុបាទាយ យេ រតា** សេចក្តីថា ជនពួកណា មិនប្រកាន់ សូម្បីវត្ថុណាមួយ ដោយឧបាទាន ៤ ត្រេកអរក្រៃលែងហើយ ។ បទថា **បរិនិព្វុតា** បានដល់ ជនទាំងនោះ គប្បីជ្រាបថា ឈ្មោះថា បរិនិព្វានហើយ ដោយអប្បច្ចយបរិនិព្វាន ។៚

## អដ្ឋកថាសគារវសូត្រទី ៩ ចប់

# សុត្តន្តបិដក

## ឱរិមសូត្រទី ៦

[ ១៨ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវត្រើយខាងអាយផង នូវត្រើយខាងនាយផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវពាក្យនោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែងប្រាប់ ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ករុណា ព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អ្វីជាត្រើយខាងអាយ អ្វីជាត្រើយខាងនាយ ។ ម្នាលភិក្ខុទាំងឡាយ មិច្ឆាទិដ្ឋិ ជាត្រើយខាងអាយ សម្មាទិដ្ឋិ ជាត្រើយខាងនាយ ។បេ។ មិច្ឆាវិមុត្តិ ជាត្រើយខាងអាយ សម្មាវិមុត្តិ ជាត្រើយខាងនាយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ត្រើយខាងអាយ នេះហៅថា ត្រើយខាងនាយ ។

បណ្តាមនុស្សទាំងឡាយ ពួកជនណាបានដល់នូវត្រើយ
ខាងនាយ ( ព្រះនិព្វាន ) ពួកជននោះមានប្រមាណតិច
ឯសត្វក្រៅពីនេះរមែងស្ទុះទៅកាន់ត្រើយ គឺសក្កាយទិដ្ឋិ
( នេះច្រើនជាង ) ។ ពួកជនណា ប្រព្រឹត្តតាមធម៌ក្នុង
ធម៌ ដែលតថាគតសម្តែងហើយដោយប្រពៃ ពួកជន
នោះ បានឆ្លងនូវវដ្តៈ ជាទីនៅនៃមច្ចុ ដែលសត្វឆ្លងបាន
ដោយក្រក្រៃពេក ហើយនឹងបានដល់នូវត្រើយខាង
នាយ គឺព្រះនិព្វាន ។ បណ្ឌិតត្រូវលះបង់នូវធម៌ខ្មៅ

ហើយចម្រើននូវធម៌ស ហើយចេញចាកអាល័យ អាស្រ័យនូវព្រះនិព្វាន ដែលមិនមានអាល័យ ការត្រេកអរបានដោយកម្រ ក្នុងវិវេកណា បណ្ឌិតអ្នកមិនមានសេចក្តីកង្វល់ គប្បីលះបង់នូវកាមទាំងឡាយ ហើយប្រាថ្នានូវសេចក្តីត្រេកអរក្នុងវិវេកនោះ បណ្ឌិតគប្បីធ្វើខ្លួន ឲ្យផូរផង់ចាកគ្រឿងសៅហ្មងនៃចិត្តទាំង-ឡាយ ។ ចិត្តដែលពួកជនណា ចម្រើនល្អប្រពៃហើយ ក្នុងអង្គនៃធម៌ជាគ្រឿងត្រាស់ដឹងទាំងឡាយ ពួកជនណាត្រេកអរក្នុងការលះបង់នូវសេចក្តីប្រកាន់ ព្រោះមិនប្រកាន់ ពួកជនទាំងនោះ ឈ្មោះថា ជាខីណាស្រព ជាអ្នកមានសេចក្តីរុងរឿង បរិនិព្វានហើយក្នុងលោក ។

# អដ្ឋកថា

## ឱរិមសូត្រ

[ ១៨ ] ឱរិមសូត្រទី ៦ ទ្រង់សម្តែងដល់ភិក្ខុទាំងឡាយ ។

អដ្ឋកថាឱរិមសូត្រទី ៦ ចប់

# សុត្តន្តបិដក

## បឋមបច្ចោរោហណិសូត្រទី ៧

[ ១៩ ] សម័យនោះឯង ជាណុស្សោណិព្រាហ្មណ៍ កក់ជម្រះក្បាល ក្នុងថ្ងៃឧបោសថនោះហើយ ស្លៀកនូវគូសំពត់សម្បកឈើដ៏ថ្មី កាន់យកស្បូវស្រស់ ១ ក្តាប់ ហើយឋិតនៅក្នុងទីសមគួរ ក្នុងទីជិតនៃព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ទតឃើញជាណុស្សោណិព្រាហ្មណ៍កំពុងកក់ជម្រះក្បាល ក្នុងថ្ងៃឧបោសថនោះ ស្លៀកនូវគូសំពត់សម្បកឈើដ៏ថ្មី កាន់យកស្បូវស្រស់ ១ ក្តាប់ ឋិតនៅក្នុងទីសមគួរ ក្នុងទីជិតនៃ ( ព្រះអង្គ ) លុះទ្រង់ទតឃើញហើយ ទើបទ្រង់ត្រាស់នឹងជាណុស្សោណិព្រាហ្មណ៍ដូច្នេះថា ម្នាលព្រាហ្មណ៍ ចុះហេតុដូចម្តេច បានជាអ្នកកក់ជម្រះក្បាល ក្នុងថ្ងៃឧបោសថនោះ ស្លៀកនូវគូសំពត់សម្បកឈើដ៏ថ្មី កាន់យកនូវស្បូវស្រស់ ១ ក្តាប់ ហើយឋិតនៅក្នុងទីសមគួរ ក្នុងថ្ងៃនេះ មានហេតុដូចម្តេច ដល់ត្រកូលរបស់ព្រាហ្មណ៍ ។ បពិត្រព្រះគោតមដ៏ចម្រើន ការជម្រះបាប ( នឹងមាន ) ដល់ត្រកូលរបស់ព្រាហ្មណ៍ ក្នុងថ្ងៃនេះ ។ ម្នាលព្រាហ្មណ៍ ការជម្រះបាបរបស់ពួកព្រាហ្មណ៍ តើដូចម្តេច ។ បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍ក្នុងលោកនេះ តែងកក់ជម្រះក្បាល ក្នុងថ្ងៃឧបោសថនោះហើយ ស្លៀកនូវគូសំពត់សម្បកឈើដ៏ថ្មីនេះ លាបនូវផែនដីដោយអាចម៍គោស្រស់ ក្រាលដោយស្បូវទាំងឡាយដ៏ខៀវ ហើយសម្រេចនូវទីដេក ក្នុងចន្លោះផ្នុកខ្សាច់ និងចន្លោះរោងភ្លើង ពួកព្រាហ្មណ៍ទាំងនោះតែងក្រោកឡើងធ្វើអញ្ជលី សំពះភ្លើង ៣ ដងក្នុងរាត្រីនោះថា យើងខ្ញុំជម្រះបាប

នឹងលោកដ៏ចម្រើន យើងខ្ញុំជម្រះបាបនឹងលោកដ៏ចម្រើន តែងញុាំងភ្លើងឲ្យឆ្អែត ដោយទឹកដោះរាវ ប្រេង ទឹកដោះខាប់ដ៏ល្មមគ្រាន់ លុះកន្លងរាត្រីនោះទៅ ក៏នាំគ្នាញុាំងពួកព្រាហ្មណ៍ឲ្យឆ្អែត ដោយខាទនីយភោជនីយាហារ ដ៏ថ្លៃថ្លាទៀត បពិត្រព្រះគោតមដ៏ចម្រើន ការជម្រះបាបរបស់ពួកព្រាហ្មណ៍ យ៉ាងនេះឯង ។ ម្នាលព្រាហ្មណ៍ ការជម្រះបាបរបស់ពួកព្រាហ្មណ៍ ដោយឡែក ចំណែកឯការជម្រះបាប ក្នុងវិន័យរបស់អរិយៈដោយឡែក ។ បពិត្រព្រះគោតមដ៏ចម្រើន ការជម្រះបាប ក្នុងវិន័យរបស់អរិយៈ តើដូចម្តេច ការជម្រះបាបក្នុងវិន័យរបស់អរិយៈយ៉ាងណា សូមអាពធនាព្រះគោតមដ៏ចម្រើន សម្តែងធម៌យ៉ាងនោះដល់ខ្ញុំព្រះអង្គ ។ ម្នាលព្រាហ្មណ៍ បើដូច្នោះ ចូរអ្នកប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែងប្រាប់ ។ ជាណុស្សោណិព្រាហ្មណ៍ ក៏ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលព្រាហ្មណ៍ អរិយសាវក ក្នុងសាសនានេះតែងពិចារណាដូច្នេះថា ផលដ៏លាមករបស់មិច្ឆាទិដ្ឋិ ( តែងមាន ) ក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង លុះអរិយសាវកនោះ ពិចារណាដូច្នេះហើយ ក៏លះបង់មិច្ឆាទិដ្ឋិចេញ ឈ្មោះថា ជម្រះមិច្ឆាទិដ្ឋិ ផលដ៏លាមករបស់មិច្ឆាសង្កប្បៈ ( តែងមាន ) ក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង លុះអរិយសាវកនោះពិចារណាដូច្នេះហើយ ក៏លះបង់មិច្ឆាសង្កប្បៈចេញ ឈ្មោះថាជម្រះមិច្ឆាសង្កប្បៈ ផលដ៏លាមករបស់មិច្ឆាវាចា ( តែងមាន ) ក្នុងបច្ចុប្បន្នផង ក្នុងលោកខាង

មុខផង លុះអរិយសាវកនោះពិចារណាដូច្នេះហើយ ក៏លះបង់មិច្ឆាវាចាចេញ ផលដ៏លាមករបស់មិច្ឆាកម្មន្តៈ ( តែងមាន ) ក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង លុះអរិយសាវកនោះ ពិចារណាដូច្នេះហើយ ក៏លះបង់មិច្ឆាកម្មន្តៈចេញ ឈ្មោះថា ជម្រះមិច្ឆាកម្មន្តៈ ផលដ៏លាមករបស់មិច្ឆាអាជីវៈ ( តែងមាន ) ក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង លុះអរិយសាវកនោះពិចារណាដូច្នេះហើយ ក៏លះបង់មិច្ឆាអាជីវៈចេញ ឈ្មោះថា ជម្រះមិច្ឆាអាជីវៈ ផលដ៏លាមករបស់មិច្ឆាវាយាមៈ ( តែងមាន ) ក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង លុះអរិយសាវកនោះពិចារណាដូច្នេះហើយ ក៏លះបង់មិច្ឆាវាយាមៈចេញ ឈ្មោះថា ជម្រះមិច្ឆាវាយាមៈ ផលដ៏លាមករបស់មិច្ឆាសតិ ( តែងមាន ) ក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង លុះអរិយសាវកនោះ ពិចារណាដូច្នេះហើយ ក៏លះបង់មិច្ឆាសតិចេញ ឈ្មោះថា ជម្រះមិច្ឆាសតិ ផលដ៏លាមករបស់មិច្ឆាសមាធិ ( តែងមាន ) ក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង លុះអរិយសាវកនោះ ពិចារណាដូច្នេះហើយ ក៏លះបង់មិច្ឆាសមាធិចេញ ឈ្មោះថា ជម្រះមិច្ឆាសមាធិ ផលដ៏លាមករបស់មិច្ឆាញាណៈ ( តែងមាន ) ក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង លុះអរិយសាវកនោះពិចារណាដូច្នេះហើយ ក៏លះបង់មិច្ឆាញាណៈចេញ ឈ្មោះថា ជម្រះមិច្ឆាញាណៈ ផលដ៏លាមករបស់មិច្ឆាវិមុត្តិ ( តែងមាន ) ក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង លុះអរិយសាវកនោះ ពិចារណាដូច្នេះហើយ ក៏លះបង់មិច្ឆាវិមុត្តិចេញ ឈ្មោះថា ជម្រះ

មិច្ឆាវិមុត្តិ ម្នាលព្រាហ្មណ៍ ការជម្រះបាប ក្នុងវិន័យរបស់អរិយៈយ៉ាងនេះឯង ។ បពិត្រព្រះគោតមដ៏ចម្រើន ការជម្រះបាប របស់ពួកព្រាហ្មណ៍ដោយឡែក ចំណែកការជម្រះបាប ក្នុងវិន័យរបស់អរិយៈដោយឡែក ។ បពិត្រព្រះគោតមដ៏ចម្រើន ការជម្រះបាប របស់ពួកព្រាហ្មណ៍ មិនដល់នូវចំណែក ដែលចែកជា ១៦ អស់ ១៦ ដង នៃការជម្រះបាប ក្នុងវិន័យរបស់អរិយៈនេះឡើយ ។ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ណាស់ ។បេ។ សូមព្រះគោតមដ៏ចម្រើន ទ្រង់ជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសកអ្នកដល់នូវសរណគមន៍ ស្មើដោយជីវិត តាំងពីថ្ងៃនេះទៅ ។

# អដ្ឋកថា

## បឋមបច្ចោរោហណិសូត្រ

[ ១៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមបច្ចោរោហណិសូត្រទី ៧ ដូច្នេះ បទថា **បច្ចោរោហណី** បានដល់ ការបន្សាត់បាប ។ បទថា **បត្ថរិត្វា** បានដល់ លាតក្រាល ។ បទថា **អន្តរា ច វេលំ អន្តរា ច អគ្យាគារំ** បានដល់ រវាងគំនរខ្សាច់ និងរោងភ្លើង ។

**អដ្ឋកថា បឋមបច្ចោរោហណិសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ទុតិយបច្ចោរោហណិសូត្រទី ៨

[ ២០ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែង នូវការជម្រះបាបដ៏ប្រសើរដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរប្រុងចាំស្តាប់ពាក្យនោះចុះ ... ម្នាលភិក្ខុទាំងឡាយ ការជម្រះបាបដ៏ប្រសើរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ក្នុងសាសនានេះ តែងពិចារណាដូច្នេះថា ផលដ៏លាមករបស់មិច្ឆាទិដ្ឋិ ( តែងមាន ) ក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង លុះអរិយសាវកនោះពិចារណាដូច្នេះហើយ ក៏លះបង់មិច្ឆាទិដ្ឋិចេញ ឈ្មោះថា ជម្រះមិច្ឆាទិដ្ឋិ ផលដ៏លាមករបស់មិច្ឆាសង្កប្បៈ ... របស់មិច្ឆាវាចា ... របស់មិច្ឆាកម្មន្តៈ ... របស់មិច្ឆាអាជីវៈ ... របស់មិច្ឆាវាយាមៈ ... របស់មិច្ឆាសតិ ... របស់មិច្ឆា-សមាធិ ... របស់មិច្ឆាញាណៈ ... ផលដ៏លាមករបស់មិច្ឆាវិមុត្តិ ( តែងមាន ) ក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង លុះអរិយសាវកនោះពិចារណាដូច្នេះហើយ ក៏លះបង់មិច្ឆាវិមុត្តិចេញ ឈ្មោះថា ជម្រះមិច្ឆាវិមុត្តិ ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគត ហៅថា ការជម្រះបាបដ៏ប្រសើរ ។

# អដ្ឋកថា

## ទុតិយបច្ចោរោហណិសូត្រ

[ ២០ ] ទុតិយបច្ចោរោហណិសូត្រទី ៨ ទ្រង់សម្តែងដល់ភិក្ខុសង្ឃ ។ ពាក្យដ៏សេសក្នុងទីគ្រប់អន្លើ មានអត្ថងាយយល់ហើយ ។

**អដ្ឋកថា ទុតិយបច្ចោរោហណិសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## បុព្វង្គសូត្រទី ៩

[ ២១ ] ម្នាលភិក្ខុទាំងឡាយ ការរះឡើងនៃអរុណ នេះជាប្រធាន នេះជាបុព្វនិមិត្ត នៃព្រះអាទិត្យកាលរះឡើង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិនេះជាប្រធាន នេះជាបុព្វនិមិត្ត នៃពួកកុសលធម៌ យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយសម្មាទិដ្ឋិ រមែងមានសម្មាសង្កប្បៈ បុគ្គលប្រកបដោយសម្មាសង្កប្បៈ រមែងមានសម្មាវាចា បុគ្គលប្រកបដោយសម្មាវាចា រមែងមានសម្មាកម្មន្តៈ បុគ្គលប្រកបដោយសម្មាកម្មន្តៈ រមែងមានសម្មាអាជីវៈ បុគ្គលប្រកបដោយសម្មាអាជីវៈ រមែងមានសម្មាវាយាមៈ បុគ្គលប្រកបដោយសម្មាវាយាមៈ រមែងមានសម្មាសតិ បុគ្គលប្រកបដោយសម្មាសតិ រមែងមានសម្មាសមាធិ បុគ្គលប្រកបដោយសម្មាសមាធិ រមែងមានសម្មាញាណៈ បុគ្គលប្រកបដោយសម្មាញាណៈ រមែងមានសម្មាវិមុត្តិ ។

# អដ្ឋកថា

## បុព្វង្គសូត្រ

[ ២១ ] ក្នុងបុព្វង្គសូត្រទី ៩ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាបុព្វង្គសូត្រទី ៩ ចប់

# សុត្តន្តបិដក

## អាសវសូត្រទី ១០

[ ២២ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ១០ ប្រការនេះ ដែលភិក្ខុចម្រើនហើយ តែងប្រព្រឹត្តទៅ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយ ។ ធម៌ ១០ ប្រការ តើដូចម្តេច ។ គឺសម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ សម្មាញាណៈ ១ សម្មាវិមុត្តិ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ១០ ប្រការនេះឯង ដែលភិក្ខុចម្រើនហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយ ។

បច្ចោរោហណិវគ្គទី ២ ចប់

### ឧទ្ទាននៃបច្ចោរោហណិវគ្គនោះ គឺ

និយាយអំពីសេចក្តីចម្រើន ១ សភាពមិនមែនធម៌ ១
អជិតបរិព្វាជក ១ សគារវព្រាហ្មណ៍ ១ ធម៌ជាត្រើយ
ខាងអាយពីរលើក ការជម្រះបាប ១ ប្រធាននៃសម្មា-
ទិដ្ឋិ ប្រៀបដោយព្រះអាទិត្យ ១ ធម៌ធ្វើឲ្យអស់ទៅនៃ
អាសវៈ ១ ។

# អដ្ឋកថា

## អាសវសូត្រ

[ ២២ ] *ក្នុងអាសវសូត្រទី ១០ មានអត្ថងាយយល់ហើយ ។*

**អដ្ឋកថា អាសវសូត្រទី ១០ ចប់**

**បច្ចោរោហណិវគ្គទី ២ ចប់**

# សុត្តន្តបិដក

## ចារិសុទ្ធិវគ្គទី ៣

### បរិសុទ្ធសូត្រទី ១

[ ២៣ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ១០ នេះ បរិសុទ្ធផូរផង់ ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។ ធម៌ ១០ តើអ្វីខ្លះ ។ សេចក្តីយល់ត្រូវ ១ សេចក្តីត្រិះរិះត្រូវ ១ សម្តីត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ សេចក្តីព្យាយាមត្រូវ ១ ការរឭកត្រូវ ១ ការតម្កល់ចិត្តមាំត្រូវ ១ ការដឹងត្រូវ ១ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ១០ នេះឯង បរិសុទ្ធផូរផង់ ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។

# អដ្ឋកថា
# បារិសុទ្ធិវគ្គទី ៣

## បរិសុទ្ធសូត្រទី ១

[ ២៣ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងបរិសុទ្ធសូត្រទី ១ នៃបារិសុទ្ធិវគ្គទី ៣ ដូចតទៅ បទថា* **បរិសុទ្ធា** *បានដល់ ឥតមន្ទិល ។ បទថា* **បរិយោទាតា** *បានដល់ បកស្រះ ជាទីបាចសាចនៃរស្មី ។*

**អដ្ឋកថា បរិសុទ្ធសូត្រទី ១ ចប់**

# សុត្តន្តបិដក
## ឧប្បន្នសូត្រទី ២

[ ២៤ ] *ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ១០ នេះ មិនទាន់កើតហើយកើតឡើង ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។ ធម៌ ១០ តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ១០ នេះឯង មិនទាន់កើតហើយ កើតឡើង ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។*

## មហប្ផលសូត្រទី ៣

[ ២៥ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ១០ នេះ មានផលច្រើន មានអានិសង្សច្រើន ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។ ធម៌ ១០ តើអ្វីខ្លះ ។ គឺសេចក្ដីយល់ត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ១០ នេះឯង មានផលច្រើន មានអានិសង្សច្រើន ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។

## បរិយោសានសូត្រទី ៤

[ ២៦ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ១០ នេះ មានកិរិយាកម្ចាត់បង់នូវរាគៈជាទីបំផុត កម្ចាត់បង់នូវទោសៈជាទីបំផុត កម្ចាត់បង់នូវមោហៈជាទីបំផុត ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។ ធម៌ទាំង ១០ តើអ្វីខ្លះ ។ គឺសេចក្ដីយល់ត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំង-ឡាយ ធម៌ទាំង ១០ នេះឯង មានកិរិយាកម្ចាត់បង់នូវរាគៈជាទីបំផុត កម្ចាត់បង់នូវទោសៈជាទីបំផុត កម្ចាត់បង់នូវមោហៈជាទីបំផុត ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។

## ឯកន្តសូត្រទី ៥

[ ២៧ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ១០ នេះ ប្រព្រឹត្តទៅព្រម ដើម្បីសេចក្ដីនឿយណាយតែម្យ៉ាង ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ ដើម្បីសេចក្ដីស្ងប់ ដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។ ធម៌ ១០ តើអ្វីខ្លះ ។ គឺសេចក្ដី

យល់ត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ១០ នេះឯង ប្រព្រឹត្តទៅ ដើម្បីនឿយណាយតែម្យ៉ាង ដើម្បីប្រាសចាកតម្រេក ដើម្បីរម្ងត់ ដើម្បីសេចក្តីស្ងប់ ដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹងព្រម ដើម្បីព្រះនិព្វាន ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។

## បឋមភាវិតសូត្រទី ៦

[ ២៨ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ១០ នេះ ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យរឿយៗ ហើយ មិនទាន់កើត ហើយកើតឡើង ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។ ធម៌ ១០ តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ១០ នេះឯង បុគ្គលបានចម្រើនហើយ ធ្វើឲ្យរឿយៗ ហើយ មិនទាន់កើត ហើយកើតឡើង ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។

## ទុតិយបឋមភាវិតសូត្រទី ៧

[ ២៩ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ១០ នេះ ដែលបុគ្គលបានចម្រើនហើយ ធ្វើឲ្យរឿយៗ ហើយ មានផលច្រើន មានអានិសង្សច្រើន ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។ ធម៌ ១០ តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ១០ នេះឯង ដែលបុគ្គលបានចម្រើនហើយ បានធ្វើឲ្យរឿយៗ ហើយ មានផលច្រើន មានអានិសង្សច្រើន ក្រៅអំពីវិន័យរបស់ព្រះសុគតមិនមានឡើយ ។

# តតិយបឋមភាវិតសូត្រទី ៨

[ ៣០ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ១០ នេះ ដែលបុគ្គលបានចម្រើនហើយ បានធ្វើឲ្យរឿយៗ ហើយ មានកិរិយាកម្ចាត់បង់នូវរាគៈជាទីបំផុត កម្ចាត់បង់នូវទោសៈជាទីបំផុត កម្ចាត់បង់នូវមោហៈជាទីបំផុត ក្រៅអំពីវិន័យរបស់ព្រះសុគតមិនមានឡើយ ។ ធម៌ ១០ តើអ្វីខ្លះ ។ គឺសេចក្ដីយល់ត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ១០ នេះឯង ដែលបុគ្គលបានចម្រើនហើយ បានធ្វើឲ្យរឿយៗ ហើយ មានកិរិយាកម្ចាត់បង់នូវរាគៈជាទីបំផុត កម្ចាត់បង់នូវទោសៈជាទីបំផុត កម្ចាត់បង់នូវមោហៈជាទីបំផុត ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។

# ចតុត្ថបឋមភាវិតសូត្រទី ៩

[ ៣១ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ១០ នេះ ដែលបុគ្គលបានចម្រើនហើយ បានធ្វើឲ្យរឿយៗ ហើយ តែងប្រព្រឹត្តទៅ ដើម្បីសេចក្ដីនឿយណាយតែម្យ៉ាង ដើម្បីប្រាសចាកតម្រេក ដើម្បីរម្ងាត់ ដើម្បីសេចក្ដីស្ងប់ ដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹងព្រម ដើម្បីព្រះនិព្វាន ក្រៅអំពីវិន័យរបស់ព្រះសុគតមិនមានឡើយ ។ ធម៌ ១០ តើអ្វីខ្លះ ។ គឺសេចក្ដីយល់ត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ១០ នេះឯង ដែលបុគ្គលបានចម្រើនហើយ បានធ្វើឲ្យរឿយៗ ហើយ តែងប្រព្រឹត្តទៅដើម្បីសេចក្ដីនឿយណាយតែម្យ៉ាង ដើម្បីប្រាសចាកតម្រេក ដើម្បីរម្ងាត់ ដើម្បីសេចក្ដីស្ងប់ ដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹងព្រម ដើម្បីព្រះនិព្វាន ក្រៅអំពីវិន័យ

របស់ព្រះសុគត មិនមានឡើយ ។

## មិច្ឆត្តសូត្រទី ១០

[ ៣២ ] ម្នាលភិក្ខុទាំងឡាយ មិច្ឆត្តធម៌ ( ធម៌ខុស ) ទាំងឡាយនេះ មាន ១០ ។ មិច្ឆត្តធម៌ទាំង ១០ តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ សេចក្តីត្រិះរិះខុស ១ សម្តីខុស ១ ការងារខុស ១ ការចិញ្ចឹមជីវិតខុស ១ សេចក្តីព្យាយាមខុស ១ ការរឭកខុស ១ ការតម្កល់ចិត្តមាំខុស ១ ការដឹងខុស ១ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ មិច្ឆត្តធម៌មាន ១០ នេះឯង ។

## សម្មត្តសូត្រទី ១១

[ ៣៣ ] ម្នាលភិក្ខុទាំងឡាយ សម្មត្តធម៌ ( ធម៌ត្រូវ ) ទាំងឡាយនេះ មាន ១០ ។ សម្មត្តធម៌ ១០ តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ សេចក្តីត្រិះរិះត្រូវ ១ សម្តីត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ សេចក្តីព្យាយាមត្រូវ ១ ការរឭកត្រូវ ១ ការតម្កល់ចិត្តត្រូវ ១ ការដឹងត្រូវ ១ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ សម្មត្តធម៌មាន ១០ នេះឯង ។

បារិសុទ្ធិវគ្គទី ៣ ចប់

# អដ្ឋកថា

## ឧប្បន្នសូត្រទី ២ ជាដើម

*[ ២៤-៣៣ ] ក្នុងឧប្បន្នសូត្រទី ២ ជាដើម មានអត្ថងាយយល់ហើយ ។*

*អដ្ឋកថាឧប្បន្នសូត្រទី ២ ជាដើម ចប់*

*បារិសុទ្ធិវគ្គទី ៣ ចប់*

# សុត្តន្តបិដក

## សាធុវគ្គទី ៤

### សាធុសូត្រទី ១

[ ៣៤ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវសេចក្តីចម្រើនផង សេចក្តីមិនចម្រើនផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សេចក្តីមិនចម្រើន តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ សេចក្តីត្រិះរិះខុស ១ សម្តីខុស ១ ការងារខុស ១ ការចិញ្ចឹមជីវិតខុស ១ សេចក្តីព្យាយាមខុស ១ ការរឭកខុស ១ ការតម្កល់ចិត្តមាំខុស ១ ការដឹងខុស ១ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សេចក្តីមិនចម្រើន ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ សេចក្តីត្រិះរិះត្រូវ ១ សម្តីត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ ការព្យាយាមត្រូវ ១ ការរឭកត្រូវ ១ ការតម្កល់ចិត្តមាំត្រូវ ១ ការដឹងត្រូវ ១ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សេចក្តីចម្រើន ។

# អដ្ឋកថា

# សាធុវគ្គទី ៤

## សាធុសូត្រ

[ ៣៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសាធុសូត្រទី ១ នៃសាធុវគ្គទី ៤ ដូចតទៅនេះ បទថា **សាធុំ** បានដល់ ចម្រើនស្អាតស្អំ ។

**អដ្ឋកថា សាធុសូត្រទី ១ ចប់**

# សុត្តន្តបិដក

## អរិយធម្មសូត្រទី ២

[ ៣៥ ] ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសម្តែងនូវធម៌ដ៏ប្រសើរផង ធម៌មិនប្រសើរផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ចុះធម៌មិនប្រសើរ តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។បេ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌មិនប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដ៏ប្រសើរ តើអ្វីខ្លះ ។ គឺ

សេចក្តីយល់ត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដ៏ប្រសើរ ។

# កុសលសូត្រទី ៣

[ ៣៦ ] ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសំដែងនូវកុសលធម៌ផង អកុសលធម៌ផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ពួកភិក្ខុទាំងនោះទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។បេ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អកុសលធម៌ ។ ម្នាលភិក្ខុទាំងឡាយ កុសលធម៌ តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កុសលធម៌ ។

# អត្ថសូត្រទី ៤

[ ៣៧ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវធម៌ជាប្រយោជន៍ផង ធម៌មិនជាប្រយោជន៍ផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌មិនជាប្រយោជន៍ តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។បេ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំង-

ឡាយ នេះហៅថា ធម៌មិនជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ជាប្រយោជន៍ តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ជាប្រយោជន៍ ។

# ធម្មសូត្រទី ៥

[ ៣៨ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវធម៌ផង នូវអធម៌ផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អធម៌ តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។បេ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អធម៌ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ ។

# អាសវធម្មសូត្រទី ៦

[ ៣៩ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវធម៌ ដែលប្រកបដោយអាសវៈផង នូវធម៌មិនមានអាសវៈផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែល

ប្រកបដោយអាសវៈ តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។បេ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ប្រកបដោយអាសវៈ ។ ម្នាលភិក្ខុទាំងឡាយ ធម៌មិនមានអាសវៈ តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌មិនមានអាសវៈ ។

## សាវជ្ជធម្មសូត្រទី ៧

[ ៤០ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវធម៌ ដែលប្រកបដោយទោសផង នូវធម៌មិនមានទោសផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ប្រកបដោយទោស តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។បេ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ប្រកបដោយទោស ។ ម្នាលភិក្ខុទាំងឡាយ ធម៌មិនមានទោស តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌មិនមានទោស ។

## តបនិយធម្មសូត្រទី ៨

[ ៤១ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវធម៌ ដែលគួរដុតកម្តៅផង មិនគួរដុតកម្តៅផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ពួកភិក្ខុទាំង

នោះ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគួរដុតកម្តៅ តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។បេ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំង-ឡាយ នេះហៅថា ធម៌គួរដុតកម្តៅ ។ ម្នាលភិក្ខុទាំងឡាយ ធម៌មិនគួរដុតកម្តៅ តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌មិនគួរដុតកម្តៅ ។

## អាចយគាមិធម្មសូត្រទី ៩

[ ៤២ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវធម៌ ដែលញុំាងសត្វឲ្យដល់នូវការសន្សំវដ្តៈផង នូវធម៌ដែលមិនញុំាងសត្វឲ្យដល់នូវការសន្សំវដ្តៈផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលញុំាងសត្វឲ្យដល់នូវការសន្សំវដ្តៈ តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។បេ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលញុំាងសត្វឲ្យដល់នូវការសន្សំវដ្តៈ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមិនញុំាងសត្វឲ្យដល់នូវការសន្សំវដ្តៈ តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ ដែលមិនញុំាងសត្វឲ្យដល់នូវការសន្សំវដ្តៈ ។

## ទុក្ខុទ្រយធម្មសូត្រទី ១០

[ ៤៣ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងនូវធម៌ដែលញ៉ាំងទុក្ខឲ្យកើតឡើងផង នូវធម៌ដែលញ៉ាំងសុខឲ្យកើតឡើងផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្ដាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្ដែង ។ ពួកភិក្ខុទាំងនោះ ទទួលស្ដាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលញ៉ាំងទុក្ខឲ្យកើតឡើង តើអ្វីខ្លះ ។ គឺសេចក្ដីយល់ខុស ១ ។បេ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលញ៉ាំងទុក្ខឲ្យកើតឡើង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលញ៉ាំងសុខឲ្យកើតឡើង តើអ្វីខ្លះ ។ គឺសេចក្ដីយល់ត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលញ៉ាំងសុខឲ្យកើតឡើង ។

## ទុក្ខវិបាកធម្មសូត្រទី ១១

[ ៤៤ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងនូវធម៌ដែលមានផលជាទុក្ខផង នូវធម៌ដែលមានផលជាសុខផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំង-ឡាយ ស្ដាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្ដែង ។ ពួកភិក្ខុទាំងនោះ ទទួលស្ដាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមានផលជាទុក្ខ តើអ្វីខ្លះ ។ គឺសេចក្ដីយល់ខុស ១ ។បេ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលមានផលជាទុក្ខ ។

ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមានផលជាសុខ តើអ្វីខ្លះ ។ គឺសេចក្ដីយល់ត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលមានផលជាសុខ ។

សាធុវគ្គទី ៤ ចប់

# អដ្ឋកថា

## អរិយធម្មសូត្រទី ២ ជាដើម

[ ៣៥-៤៤ ] ក្នុងអរិយធម្មសូត្រទី ២ ជាដើម មានអត្ថងាយយល់ ហើយ ។

**អដ្ឋកថា អរិយធម្មសូត្រទី ២ ជាដើមចប់**

**អដ្ឋកថា សាធុវគ្គទី ៤ ចប់**

# សុត្តន្តបិដក

# អរិយមគ្គវគ្គទី ៥

## អរិយមគ្គសូត្រទី ១

[ ៤៥ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវធម៌ជាមគ្គដ៏ប្រសើរផង នូវធម៌ជាមគ្គមិនប្រសើរផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ មគ្គមិនប្រសើរ តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។បេ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា មគ្គមិនប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ មគ្គដ៏ប្រសើរ តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា មគ្គដ៏ប្រសើរ ។

## កណ្ហមគ្គសូត្រទី ២

[ ៤៦ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវធម៌ជាមគ្គខ្មៅផង នូវធម៌ជាមគ្គសផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ មគ្គខ្មៅ តើអ្វីខ្លះ ។ គឺសេចក្តីយល់

ខុស ១ ។បេ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា មគ្គខ្មៅ ។ ម្នាលភិក្ខុទាំងឡាយ មគ្គស តើអ្វីខ្លះ ។ គឺសេចក្ដីយល់ត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា មគ្គស ។

# សទ្ធម្មសូត្រទី ៣

[ ៤៧ ] ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសម្ដែងនូវសទ្ធម្មផង នូវអសទ្ធម្មផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្ដាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្ដែង ។ ពួកភិក្ខុទាំងនោះ ទទួលស្ដាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អសទ្ធម្ម តើអ្វីខ្លះ ។ គឺសេចក្ដីយល់ខុស ១ ។បេ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសទ្ធម្ម ។ ម្នាលភិក្ខុទាំងឡាយ សទ្ធម្ម តើអ្វីខ្លះ ។ គឺសេចក្ដីយល់ត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សទ្ធម្ម ។

# សប្បុរិសធម្មសូត្រទី ៤

[ ៤៨ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងនូវធម៌របស់សប្បុរសផង នូវធម៌របស់អសប្បុរសផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្ដាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្ដែង ។ ពួកភិក្ខុទាំងនោះ ទទួលស្ដាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌របស់អសប្បុរស

តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។បេ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំង-ឡាយ នេះហៅថា ធម៌របស់អសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ធម៌របស់សប្បុរស តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌របស់សប្បុរស ។

# ឧប្បាទេតព្វធម្មសូត្រទី ៥

[ ៤៩ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវធម៌ដែលគួរឲ្យកើតឡើងផង នូវធម៌ដែលមិនគួរឲ្យកើតឡើងផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំង-ឡាយ ស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមិនគួរឲ្យកើតឡើង តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។បេ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលមិនគួរឲ្យកើតឡើង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគួរឲ្យកើតឡើង តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលគួរឲ្យកើតឡើង ។

# អាសេវិតព្វធម្មសូត្រទី ៦

[ ៥០ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវធម៌ដែលគួរគប់រកផង នូវធម៌ដែលមិនគួរគប់រកផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ

ស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមិនគួរគប់រក តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។បេ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលមិនគួរគប់រក ។ ម្នាលភិក្ខុទាំង-ឡាយ ធម៌ដែលគួរគប់រក តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលគួរគប់រក ។

## ភាវេតព្វធម្មសូត្រទី ៧

[ ៥១ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវធម៌ដែលគួរចម្រើនផង នូវធម៌ដែលមិនគួរចម្រើនផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមិនគួរចម្រើន តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។បេ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលមិនគួរចម្រើន ។ ម្នាលភិក្ខុទាំង-ឡាយ ធម៌ដែលគួរចម្រើន តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលគួរចម្រើន ។

## ពហុលីការតព្វធម្មសូត្រទី ៨

[ ៥២ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងនូវធម៌ដែលគួរធ្វើឲ្យច្រើនផង នូវធម៌ដែលមិនគួរធ្វើឲ្យច្រើនផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្ដាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្ដែង ។ ពួកភិក្ខុទាំងនោះ ទទួលស្ដាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមិនគួរធ្វើឲ្យច្រើន តើអ្វីខ្លះ ។ គឺសេចក្ដីយល់ខុស ១ ។បេ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលមិនគួរធ្វើឲ្យច្រើន ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគួរធ្វើឲ្យច្រើន តើអ្វីខ្លះ ។ គឺសេចក្ដីយល់ឃើញត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលគួរធ្វើឲ្យច្រើន ។

## អនុស្សរិតព្វធម្មសូត្រទី ៩

[ ៥៣ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងនូវធម៌ដែលគួររឭករឿយៗ ផង នូវធម៌ដែលមិនគួររឭករឿយៗ ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្ដាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្ដែង ។ ពួកភិក្ខុទាំងនោះ ទទួលស្ដាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមិនគួររឭករឿយៗ តើអ្វីខ្លះ ។ គឺសេចក្ដីយល់ខុស ១ ។បេ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលមិនគួររឭករឿយៗ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគួររឭករឿយៗ តើអ្វីខ្លះ ។

គឺសេចក្តីយល់ត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលគួរ រលឹករឿយៗ ។

## សច្ឆិកាតព្វធម្មសូត្រទី ១០

[ ៥៤ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ផង នូវធម៌ដែលមិនគួរធ្វើឲ្យជាក់ច្បាស់ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមិនគួរធ្វើឲ្យជាក់ច្បាស់ តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។បេ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលមិនគួរធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។បេ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅ ថា ធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ។

**អរិយមគ្គវគ្គទី ៥ ចប់**

**តតិយបណ្ណាសកទី ៣ ចប់**

# អដ្ឋកថា

## សាធុវគ្គទី ៤

## អរិយមគ្គវគ្គទី ៥

[ ៤៥-៥៤ ] ក្នុងអរិយមគ្គវគ្គទី ៥ មានអត្ថងាយយល់ហើយ ។

**អដ្ឋកថា អរិយមគ្គវគ្គទី ៥ ចប់**

**អដ្ឋកថា តតិយបណ្ណាសក ចប់**

# សុត្តន្តបិដក

# ចតុត្ថបណ្ណាសក

## បុគ្គលវគ្គទី ១

[ ៥៥ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាង ពុំគួរសេពគប់ទេ ។ ប្រកបដោយធម៌ទាំង ១០ តើអ្វីខ្លះ ។ គឺជាអ្នកយល់ខុស ១ មានតម្រិះខុស ១ មានសម្តីខុស ១ មានការងារខុស ១ មានការចិញ្ចឹមជីវិតខុស ១ មានព្យាយាមខុស ១ មានស្មារតីខុស ១ មានការតម្កល់ចិត្តមាំខុស ១ មានការដឹងខុស ១ មានការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ទាំង ១០ នេះឯង ពុំគួរសេពគប់ឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាង ទើបគួរសេពគប់ ។ ប្រកបដោយធម៌ ១០ តើអ្វីខ្លះ ។ គឺជាអ្នកយល់ត្រូវ ១ មានតម្រិះត្រូវ ១ មានសម្តីត្រូវ ១ មានការងារត្រូវ ១ មានការចិញ្ចឹមជីវិតត្រូវ ១ មានព្យាយាមត្រូវ ១ មានស្មារតីត្រូវ ១ មានការតម្កល់ចិត្តមាំត្រូវ ១ មានការដឹងត្រូវ ១ មានការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាងនេះឯង ទើបគួរសេពគប់ ។ ( សូត្រមានចំនួនមួយរយហាសិបប្រាំមួយជាដើម បណ្ឌិតគប្បីរាប់ដោយអំណាចនៃបេយ្យាលៈចុះ ) ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាង ពុំគួរគប់រក ... គួរគប់រក ... ពុំគួរចូលទៅអង្គុយជិត ... គួរចូលទៅអង្គុយជិត ... ពុំគួរបូជា ... គួរបូជា ...

ពុំគួរសរសើរ ... គួរសរសើរ ... ពុំគួរគោរព ... គួរគោរព ... ពុំគួរកោតក្រែង ... គួរកោតក្រែង ... ពុំគួរត្រេកអរ ... គួរត្រេកអរ ... មិនស្អាត ... ស្អាត ... មិនគ្របសង្កត់នូវមានះ ... គ្របសង្កត់នូវមានះ ... មិនចម្រើនដោយបញ្ញា ... ចម្រើនដោយបញ្ញា ... រមែងបានបាបច្រើន ... រមែងបានបុណ្យច្រើន ។ ប្រកបដោយធម៌ ១០ យ៉ាង តើអ្វីខ្លះ ។ គឺអ្នកមានប្រាជ្ញាយល់ត្រូវ ១ មានតម្រិះត្រូវ ១ មានសម្ដីត្រូវ ១ មានការងារត្រូវ ១ មានការចិញ្ចឹមជីវិតត្រូវ ១ មានព្យាយាមត្រូវ ១ មានស្មារតីត្រូវ ១ មានការតម្កល់ចិត្តមាំត្រូវ ១ មានការដឹងត្រូវ ១ មានការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាងនេះឯង រមែងបានបុណ្យច្រើន ។

បុគ្គលវគ្គទី ១ ចប់

# អដ្ឋកថា

## ចតុត្ថបណ្ណាសក

### បុគ្គលវគ្គទី ១

[ ៥៥ ] ក្នុងបុគ្គលវគ្គទី ១មានអត្ថងាយយល់ទាំងអស់ហើយ ។

អដ្ឋកថាបុគ្គលវគ្គទី ១ ចប់

# សុត្តន្តបិដក
# ជាណុស្សោណិវគ្គទី ២

## បឋមបច្ចោរោហណិសូត្រទី ១

[ ៥៦ ] សម័យនោះឯង ព្រាហ្មណ៍ឈ្មោះជាណុស្សោណិ កក់ក្បាល ក្នុងថ្ងៃឧបោសថនោះ ហើយស្លៀកនូវគូសំពត់សម្បកឈើដ៏ថ្មី កាន់ស្បូវស្រស់ ១ ក្តាប់ ឈរនៅក្នុងទីសមគួរ ក្នុងទីជិតនៃព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ បានឃើញជាណុស្សោណិព្រាហ្មណ៍ កក់ក្បាល ក្នុងថ្ងៃឧបោសថនោះ ហើយស្លៀកនូវគូសំពត់សម្បកឈើដ៏ថ្មី កាន់ស្បូវស្រស់មួយក្តាប់ ឈរនៅក្នុងទីសមគួរ លុះឃើញហើយ ក៏ទ្រង់ត្រាស់នឹងជាណុស្សោណិព្រាហ្មណ៍ដូច្នេះថា ម្នាលព្រាហ្មណ៍ ហេតុដូចម្តេចហ្ន៎ បានជាអ្នកកក់ក្បាលក្នុងថ្ងៃឧបោសថនោះ ហើយស្លៀកនូវគូសំពត់សម្បកឈើដ៏ថ្មី កាន់យកស្បូវស្រស់មួយក្តាប់ ឈរនៅក្នុងទីសមគួរ ចុះការឆ្លងដូចម្តេចរបស់ត្រកូលព្រាហ្មណ៍ក្នុងថ្ងៃនេះ ។ បពិត្រព្រះគោតមដ៏ចម្រើន ថ្ងៃនេះ ទុកជាថ្ងៃបន្សាត់បង់នូវបាប របស់ត្រកូលព្រាហ្មណ៍ ។ ម្នាលព្រាហ្មណ៍ ការបន្សាត់បង់នូវបាប របស់ព្រាហ្មណ៍ទាំងឡាយ ដូចម្តេចទៅ ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រាហ្មណ៍ទាំងឡាយក្នុងលោកនេះ តែងកក់ក្បាលក្នុងថ្ងៃឧបោសថនោះ ហើយស្លៀកនូវគូសំពត់សម្បកឈើដ៏ថ្មី លាញ់នូវផែនដីដោយអាចម៍គោស្រស់ ក្រាលដោយស្បូវទាំងឡាយដ៏ខៀវ ហើយដេកក្នុងចន្លោះ នៃគំនរដីខ្សាច់ផង ក្នុងចន្លោះរោងភ្លើងផង ។

ព្រាហ្មណ៍ទាំងឡាយនោះ តែងក្រោកឡើង ៣ ដងក្នុងរាត្រីនោះ ហើយផ្គង អញ្ជលីនមស្ការចំពោះភ្លើងថា យើងទាំងឡាយបន្សាត់បង់នូវបាប នឹងលោក ដ៏ចម្រើន យើងទាំងឡាយបន្សាត់បង់នូវបាប នឹងលោកដ៏ចម្រើន ទើបញុំាង ភ្លើងឲ្យឆ្អែត ដោយទឹកដោះរាវ និងប្រេង និងទឹកដោះខាប់ដ៏ច្រើន ។ លុះកន្លង រាត្រីនោះទៅហើយ ក៏ញុំាងព្រាហ្មណ៍ទាំងឡាយ ឲ្យឆ្អែតដោយខាទនីយភោ-ជនីយាហារដ៏ផ្ចិតផ្ចង់ ។ បពិត្រព្រះគោតមដ៏ចម្រើន ការបន្សាត់បង់នូវបាប របស់ព្រាហ្មណ៍ទាំងឡាយ យ៉ាងនេះឯង ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ការ បន្សាត់បង់នូវបាប របស់ព្រាហ្មណ៍ទាំងឡាយ រមែងមានដោយឡែក ការ បន្សាត់បង់នូវបាប ក្នុងអរិយវិន័យ រមែងមានដោយឡែក ។ បពិត្រព្រះគោតម ដ៏ចម្រើន ការបន្សាត់បង់បាប ក្នុងអរិយវិន័យ តើដូចម្តេច សូមទ្រង់ព្រះមេត្តា ប្រោស ការបន្សាត់បង់បាប ក្នុងអរិយវិន័យបែបណា សូមព្រះគោតមដ៏ចម្រើន សម្តែងនូវធម៌បែបនោះដល់ខ្ញុំព្រះអង្គ ។ ម្នាលព្រាហ្មណ៍ បើដូច្នោះ ចូរអ្នក ស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ជាណុស្សោណិ-ព្រាហ្មណ៍ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលព្រាហ្មណ៍ អរិយ-សាវកក្នុងសាសនានេះ តែងពិចារណាដូច្នេះថា ផលដ៏លាមករបស់បាណា-តិបាត តែងមានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផងដោយពិត អរិយ-សាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវបាណាតិបាត បន្សាត់បង់

បាណាតិបាត ។ ផលដ៏លាមករបស់អទិន្នាទាន មានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផងដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវអទិន្នាទាន បន្សាត់បង់អទិន្នាទាន ។ ផលដ៏លាមករបស់កាមេសុមិច្ឆាចារ តែងមានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផងដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវកាមេសុមិច្ឆាចារ បន្សាត់បង់កាមេ-សុមិច្ឆាចារ ។ ផលដ៏លាមករបស់មុសាវាទ តែងមានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផងដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវមុសាវាទ បន្សាត់បង់មុសាវាទ ។ ផលដ៏លាមករបស់បិសុណវាចា តែងមានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផងដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវបិសុណវាចា បន្សាត់បង់បិសុណវាចា ។ ផលដ៏លាមករបស់ផរុសវាចា តែងមានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផងដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវផរុស-វាចា បន្សាត់បង់ផរុសវាចា ។ ផលដ៏លាមករបស់សម្ផប្បលាប តែងមានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផងដោយពិត អរិយសាវកនោះលុះពិចា-រណាដូច្នេះហើយ លះបង់នូវសម្ផប្បលាប បន្សាត់បង់សម្ផប្បលាប ។ ផលដ៏លាមករបស់អភិជ្ឈា តែងមានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផងដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវអភិជ្ឈា បន្សាត់បង់អភិជ្ឈា ។ ផលដ៏លាមករបស់ព្យាបាទ តែងមានក្នុងបច្ចុប្បន្នផង ក្នុង

លោកខាងមុខផងដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវព្យាបាទ បន្សាត់បង់ព្យាបាទ ។ ផលដ៏លាមករបស់មិច្ឆាទិដ្ឋិ តែងមានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផងដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវមិច្ឆាទិដ្ឋិ បន្សាត់បង់មិច្ឆាទិដ្ឋិ ។ ម្នាលព្រាហ្មណ៍ ការបន្សាត់បង់បាបក្នុងអរិយវិន័យ យ៉ាងនេះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន ការបន្សាត់បង់បាប របស់ព្រាហ្មណ៍ទាំងឡាយ ដោយឡែក ការបន្សាត់បង់បាបក្នុងអរិយវិន័យវិញ ដោយឡែក ។ បពិត្រព្រះគោតមដ៏ចម្រើន ការបន្សាត់បង់បាបរបស់ព្រាហ្មណ៍ទាំងឡាយ មិនដល់នូវចំណិតទី ១៦ ដែលចែក ១៦ ដង នៃការបន្សាត់បង់បាប ក្នុងអរិយវិន័យនេះឡើយ ។ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ ។បេ។ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសកដល់នូវសរណៈស្មើដោយជីវិតចាប់ដើមតាំងអំពីថ្ងៃនេះតទៅ ។

## ទុតិយបច្ចោរោហណិសូត្រទី ២

[ ៥៧ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវការបន្សាត់បង់ដ៏ប្រសើរ ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ការបន្សាត់បង់ដ៏ប្រសើរ តើដូចម្តេច ។

ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ពិចារណាដូច្នេះថា ផល ដ៏លាមករបស់បាណាតិបាត មានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង ដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវបាណា-តិបាត បន្សាត់បង់បាណាតិបាត ។ ផលដ៏លាមករបស់អទិន្នាទាន មានក្នុង បច្ចុប្បន្នផង ក្នុងលោកខាងមុខផងដោយពិត អរិយសាវកនោះ លុះពិចា-រណាដូច្នេះហើយ លះបង់នូវអទិន្នាទាន បន្សាត់បង់អទិន្នាទាន ។ ផលដ៏ លាមករបស់កាមេសុមិច្ឆាចារ មានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង ដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវកាមេ-សុមិច្ឆាចារ បន្សាត់បង់កាមេសុមិច្ឆាចារ ។ ផលដ៏លាមករបស់មុសាវាទ មានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផងដោយពិត អរិយសាវកនោះ លុះ ពិចារណាដូច្នេះហើយ លះបង់នូវមុសាវាទ បន្សាត់បង់មុសាវាទ ។ ផលដ៏ លាមករបស់បិសុណវាចា មានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផងដោយ ពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវបិសុណវាចា បន្សាត់បង់បិសុណវាចា ។ ផលដ៏លាមករបស់ផរុសវាចា មានក្នុងបច្ចុប្បន្ន ផង ក្នុងលោកខាងមុខផងដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះ ហើយ លះបង់នូវផរុសវាចា បន្សាត់បង់ផរុសវាចា ។ ផលដ៏លាមករបស់ សម្ផប្បលាបមានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផងដោយពិត អរិយ-សាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវសម្ផប្បលាប បន្សាត់បង់

សម្ផប្បលាប ។ ផលដ៏លាមករបស់អភិជ្ឈា មានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផងដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវអភិជ្ឈា បន្សាត់បង់អភិជ្ឈា ។ ផលដ៏លាមករបស់ព្យាបាទ មានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផងដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវព្យាបាទ បន្សាត់បង់ព្យាបាទ ។ ផលដ៏លាមករបស់មិច្ឆាទិដ្ឋិ មានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផងដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវមិច្ឆាទិដ្ឋិ បន្សាត់បង់មិច្ឆាទិដ្ឋិ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការបន្សាត់បង់ដ៏ប្រសើរ ។

## សង្គារវសូត្រទី ៣

[ ៥៨ ] គ្រានោះឯង សង្គារវព្រាហ្មណ៍ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះសង្គារវព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន អ្វីហ្ន៎ ជាត្រើយខាងអាយ អ្វីហ្ន៎ ជាត្រើយខាងនាយ ។ ម្នាលព្រាហ្មណ៍ ការសម្លាប់សត្វ ជាត្រើយខាងអាយ កិរិយាវៀរចាកការសម្លាប់សត្វ ជាត្រើយខាងនាយ ។ កិរិយាកាន់យកទ្រព្យដែលគេមិនបានឲ្យ ជាត្រើយខាងអាយ កិរិយាវៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ ជាត្រើយខាងនាយ ។ ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ

ជាត្រើយខាងអាយ កិរិយាវៀរចាកការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ជាត្រើយខាងនាយ ។ ការពោលពាក្យកុហក ជាត្រើយខាងអាយ កិរិយាវៀរចាកការពោលពាក្យកុហក ជាត្រើយខាងនាយ ។ សម្ដីញុះញង់ ជាត្រើយខាងអាយ កិរិយាវៀរចាកសម្ដីញុះញង់ ជាត្រើយខាងនាយ ។ សម្ដីអាក្រក់ ជាត្រើយខាងអាយ កិរិយាវៀរចាកសម្ដីអាក្រក់ ជាត្រើយខាងនាយ ។ សម្ដីរោយរាយឥតប្រយោជន៍ ជាត្រើយខាងអាយ កិរិយាវៀរចាកសម្ដីរោយរាយឥតប្រយោជន៍ ជាត្រើយខាងនាយ ។ ការសម្លឹងរំពៃចំពោះទ្រព្យអ្នកដទៃ ជាត្រើយខាងអាយ ការមិនសម្លឹងរំពៃចំពោះទ្រព្យអ្នកដទៃ ជាត្រើយខាងនាយ ។ ការចង់ឲ្យគេវិនាស ជាត្រើយខាងអាយ ការមិនចង់ឲ្យគេវិនាស ជាត្រើយខាងនាយ ។ ការយល់ខុស ជាត្រើយខាងអាយ ការយល់ត្រូវ ជាត្រើយខាងនាយ ។ ម្នាលព្រាហ្មណ៍ នេះឯងជាត្រើយខាងអាយ នេះជាត្រើយខាងនាយ ។

បណ្ដាមនុស្សទាំងឡាយ ពួកជនណាបានដល់នូវត្រើយ
ខាងនាយ ( ព្រះនិព្វាន ) ពួកជននោះមានប្រមាណតិច
ឯសត្វក្រៅពីនេះរមែងស្ទុះទៅកាន់ត្រើយ គឺសក្កាយទិដ្ឋិ
( សត្វនេះច្រើនជាង ) ។ ពួកជនណា ប្រព្រឹត្តតាមនូវ
ធម៌ក្នុងធម៌ ដែលតថាគតសម្ដែងហើយដោយប្រពៃ ពួក
ជននោះ បានឆ្លងនូវវដ្ដៈជាទីនៅនៃមច្ចុ ដែលសត្វឆ្លង
បានដោយក្រក្រៃពេក នឹងដល់នូវត្រើយខាងនាយ គឺ

ព្រះនិព្វាន ។ បណ្ឌិតគប្បីលះបង់នូវធម៌ខ្មៅ ចម្រើននូវធម៌ស ចេញចាកអាល័យ អាស្រ័យនូវព្រះនិព្វានដែលមិនមានអាល័យ សេចក្ដីត្រេកអរបានដោយកម្រ ក្នុងវិវេកណា បណ្ឌិតអ្នកមិនមានសេចក្ដីកង្វល់ លះបង់នូវកាមទាំងឡាយ ហើយប្រាថ្នានូវសេចក្ដីត្រេកអរក្នុងវិវេកនោះ បណ្ឌិតគប្បីធ្វើខ្លួនឲ្យផូរផង់ ចាកគ្រឿងសៅហ្មងនៃចិត្តទាំងឡាយ ។ ចិត្តដែលពួកជនណាចម្រើនល្អប្រពៃហើយ ក្នុងអង្គនៃធម៌ជាគ្រឿងត្រាស់ដឹងទាំងឡាយ ពួកជនណាត្រេកអរក្នុងការលះបង់សេចក្ដីប្រកាន់ ព្រោះមិនប្រកាន់ ពួកជនទាំងនោះ ឈ្មោះថាជាខីណាស្រព មានសេចក្ដី ( រុងរឿង ) បរិនិព្វានហើយ ក្នុងលោក ។

# ឱរិមសូត្រទី ៤

[ ៥៩ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងនូវត្រើយខាងអាយផង នូវត្រើយខាងនាយផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្ដាប់នូវធម៌នោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ ត្រើយខាងអាយ តើដូចម្ដេច ត្រើយខាងនាយ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ការសម្លាប់សត្វ ជាត្រើយខាងអាយ កិរិយាវៀរចាកការសម្លាប់សត្វ ជាត្រើយខាងនាយ ។ ការកាន់

យកទ្រព្យ ដែលគេមិនបានឲ្យ ជាត្រើយខាងអាយ កិរិយាវៀរចាកការកាន់យកទ្រព្យ ដែលគេមិនបានឲ្យ ជាត្រើយខាងនាយ ។ ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ជាត្រើយខាងអាយ កិរិយាវៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ជាត្រើយខាងនាយ ។ ការពោលនូវពាក្យកុហក ជាត្រើយខាងអាយ កិរិយាវៀរចាកការពោលពាក្យកុហក ជាត្រើយខាងនាយ ។ សម្តីញុះញង់ជាត្រើយខាងអាយ កិរិយាវៀរចាកសម្តីញុះញង់ ជាត្រើយខាងនាយ ។ សម្តីអាក្រក់ជាត្រើយខាងអាយ កិរិយាវៀរចាកសម្តីអាក្រក់ ជាត្រើយខាងនាយ ។ ការពោលនូវពាក្យរោយរាយ ឥតប្រយោជន៍ ជាត្រើយខាងអាយ កិរិយាវៀរចាកការពោលនូវពាក្យឥតប្រយោជន៍ ជាត្រើយខាងនាយ ។ ការសម្លឹងរំពៃចំពោះទ្រព្យអ្នកដទៃ ជាត្រើយខាងអាយ ការមិនសម្លឹងរំពៃចំពោះទ្រព្យអ្នកដទៃ ជាត្រើយខាងនាយ ។ ការចង់ឲ្យគេវិនាស ជាត្រើយខាងអាយ ការមិនចង់ឲ្យគេវិនាស ជាត្រើយខាងនាយ ។ ការយល់ខុស ជាត្រើយខាងអាយ ការយល់ត្រូវ ជាត្រើយខាងនាយ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ត្រើយខាងអាយ នេះត្រើយខាងនាយ ។

បណ្តាមនុស្សទាំងឡាយ ពួកជនណាបានដល់នូវត្រើយ
ខាងនាយ ( ព្រះនិព្វាន ) ពួកជននោះមានប្រមាណតិច
ឯសត្វក្រៅពីនេះរមែងស្ទុះទៅកាន់ត្រើយ គឺសក្កាយទិដ្ឋិ
( សត្វនេះច្រើនជាង ) ។ ពួកជនណា ប្រព្រឹត្តតាម

ធម៌ក្នុងធម៌ ដែលតថាគតសម្តែងហើយដោយប្រពៃ ពួកជននោះ បានឆ្លងនូវវដ្តៈ ជាទីនៅនៃមច្ចុ ដែលសត្វឆ្លងបានដោយក្រក្រៃពេក ហើយដល់នូវត្រើយខាងនាយ គឺព្រះនិព្វាន ។ បណ្ឌិតគប្បីលះបង់នូវធម៌ខ្មៅ ចម្រើននូវធម៌ស ហើយចេញចាកអាល័យ អាស្រ័យនូវព្រះនិព្វានដែលមិនមានអាល័យ សេចក្តីត្រេកអរបានដោយកម្រ ក្នុងវិវេកណា បណ្ឌិតអ្នកមិនមានសេចក្តីកង្វល់ គប្បីលះបង់នូវកាមទាំងឡាយ ប្រាថ្នានូវសេចក្តីត្រេកអរក្នុងវិវេកនោះ បណ្ឌិតគប្បីធ្វើខ្លួនឲ្យផូរផង់ចាកគ្រឿងសៅហ្មងនៃចិត្តទាំងឡាយ ។ ចិត្តដែលពួកជនណា ចម្រើនល្អប្រពៃហើយ ក្នុងអង្គនៃធម៌ជាគ្រឿងត្រាស់ដឹងទាំងឡាយ ពួកជនណាត្រេកអរក្នុងការលះបង់នូវសេចក្តីប្រកាន់ ព្រោះមិនប្រកាន់ ពួកជនទាំងនោះជាខីណាស្រព ឈ្មោះថា មានសេចក្តីរុងរឿង បរិនិព្វានហើយ ក្នុងលោក ។

## បឋមអធម្មសូត្រទី ៥

[ ៦០ ] ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនជាធម៌ផង សភាវៈមិនមែនជាប្រយោជន៍ផង ភិក្ខុគប្បីដឹងធម៌ផង ប្រយោជន៍ផង ភិក្ខុគប្បីដឹង

( ទាំងអស់ ) លុះបានដឹងនូវសភាវៈមិនមែនធម៌ និងសភាវៈមិនមែនប្រយោជន៍ បានដឹងនូវធម៌ និងប្រយោជន៍ហើយ ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា ភិក្ខុគប្បីប្រតិបត្តិយ៉ាងនោះចុះ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌ និងសភាវៈមិនមែនប្រយោជន៍ តើដូចម្ដេច ។ គឺការសម្លាប់សត្វ ការកាន់យកនូវទ្រព្យ ដែលគេមិនបានឲ្យ ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ការពោលនូវពាក្យកុហក សម្ដីញុះញង់ សម្ដីអាក្រក់ ការពោលនូវពាក្យរោយរាយ ឥតប្រយោជន៍ ការសម្លឹងរំពៃ ចំពោះទ្រព្យអ្នកដទៃ ការចង់ឲ្យគេវិនាស ការយល់ខុស ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សភាវៈមិនមែនធម៌ និងសភាវៈមិនមែនប្រយោជន៍ទេ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ និងប្រយោជន៍ តើដូចម្ដេច ។ កិរិយាវៀរចាកការសម្លាប់សត្វ កិរិយាវៀរចាកការកាន់យកនូវទ្រព្យ ដែលគេមិនបានឲ្យ កិរិយាវៀរចាកការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ កិរិយាវៀរចាកការពោលនូវពាក្យកុហក កិរិយាវៀរចាកសម្ដីញុះញង់ កិរិយាវៀរចាកសម្ដីអាក្រក់ កិរិយាវៀរចាកការពោលពាក្យរោយរាយ ឥតប្រយោជន៍ មិនសម្លឹងរំពៃ ចំពោះទ្រព្យអ្នកដទៃ ការមិនចង់ឲ្យគេវិនាស ការយល់ត្រូវ ។ ម្នាលភិក្ខុទាំងឡាយ នេះទើបហៅថា ធម៌ និងប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌ក្ដី សភាវៈមិនមែនប្រយោជន៍ក្ដី ភិក្ខុគប្បីដឹង ធម៌ក្ដី ប្រយោជន៍ក្ដី ក៏ភិក្ខុគប្បីដឹង ( ទាំងអស់ ) លុះបានដឹងនូវសភាវៈមិនមែនជាធម៌ និងសភាវៈមិនមែនជាប្រយោជន៍ បានដឹងនូវធម៌ និងប្រយោជន៍ហើយ ធម៌យ៉ាង

ណា ប្រយោជន៍យ៉ាងណា គប្បីប្រតិបត្តិយ៉ាងនោះចុះ ពាក្យណា ដែល តថាគតពោលហើយដូច្នេះ ពាក្យនេះ តថាគតពោលហើយ ព្រោះអាស្រ័យនូវសេចក្តីនុ៎ះ ។

# ទុតិយអធម្មសូត្រទី ៦

[ ៦១ ] ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌ និងធម៌ ភិក្ខុគប្បីដឹង សភាវៈមិនមែនប្រយោជន៍ និងប្រយោជន៍ ភិក្ខុគប្បីដឹង ( ទាំងអស់ ) លុះបានដឹងនូវសភាវៈមិនមែនធម៌ និងធម៌ បានដឹងនូវសភាវៈមិនមែនប្រយោជន៍ និងប្រយោជន៍ហើយ ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា គប្បីប្រតិបត្តិតាមយ៉ាងនោះចុះ ។ ព្រះមានព្រះភាគទ្រង់បានត្រាស់ពាក្យនេះ លុះព្រះសុគតត្រាស់ពាក្យនេះរួចហើយ ក្រោកចាកអាសនៈចូលទៅកាន់វិហារ ។ គ្រានោះឯង ព្រះមានព្រះភាគទ្រង់ចៀសចេញទៅមិនយូរប៉ុន្មាន ភិក្ខុទាំងនោះមានសេចក្តីត្រិះរិះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគទ្រង់សម្តែងនូវឧទ្ទេសនេះឯង ដោយសង្ខេបពេក មិនទ្រង់ចែករំលែកនូវអត្ថ ដោយសេចក្តីពិស្តារ ដល់យើងទាំងឡាយសោះ ស្រាប់តែក្រោកចាកអាសនៈ ហើយយាងចូលទៅកាន់វិហារថា ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌ និងធម៌ ភិក្ខុគប្បីដឹង សភាវៈមិនមែនប្រយោជន៍ និងប្រយោជន៍ ក៏ភិក្ខុគប្បីដឹង លុះបានដឹងនូវសភាវៈមិនមែនធម៌ និងធម៌ បានដឹងនូវសភាវៈមិនមែនប្រយោជន៍ និងប្រយោជន៍ ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា គប្បីប្រតិបត្តិតាម យ៉ាងនោះចុះ ។ ភិក្ខុអង្គ

ណាហ្ន៎ គប្បីចែករំលែក នូវអត្ថនៃឧទ្ទេសនេះ ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ដោយសង្ខេប មិនចែករំលែកនូវអត្ថដោយពិស្តារ ឲ្យពិស្តារបាន ។ គ្រានោះឯង ភិក្ខុទាំងនោះ មានសេចក្តីត្រិះរិះដូច្នេះថា ព្រះមហាកច្ចានៈដ៏មានអាយុអង្គនេះ ព្រះសាស្តាទ្រង់សរសើរហើយ ទាំងពួកសព្រហ្មចារីបុគ្គលជាអ្នកប្រាជ្ញ ក៏សរសើរហើយដែរ មានតែព្រះមហាកច្ចានៈដ៏មានអាយុទើបអាចចែករំលែក នូវអត្ថនៃឧទ្ទេសនេះ ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយដោយសង្ខេប មិនបានចែករំលែកនូវអត្ថ ដោយពិស្តារ ឲ្យពិស្តារបាន បើដូច្នោះ គួរតែយើងទាំងអស់គ្នា ចូលទៅរកព្រះមហាកច្ចានៈដ៏មានអាយុ លុះចូលទៅដល់ហើយ គប្បីសាកសួរនូវសេចក្តីនុ៎ះ នឹងព្រះមហាកច្ចានៈដ៏មានអាយុ ព្រះមហាកច្ចានៈដ៏មានអាយុ នឹងព្យាករ ដល់យើងទាំងឡាយ យ៉ាងណា យើងទាំងអស់គ្នា នឹងចាំទុកនូវរឿងនុ៎ះ យ៉ាងនោះ ។ លំដាប់នោះឯង ពួកភិក្ខុទាំងនោះ ចូលទៅរកព្រះមហាកច្ចានៈដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរាក់ទាក់ជាមួយនឹងព្រះមហាកច្ចានៈដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក៏បានពោលទៅនឹងព្រះមហាកច្ចានៈដ៏មានអាយុដូច្នេះថា ម្នាលអាវុសោកច្ចានៈ ព្រះមានព្រះភាគ ទ្រង់សម្តែងឡើងនូវឧទ្ទេសនេះឯង ដោយសង្ខេប មិនបានចែករំលែក នូវអត្ថដោយពិស្តារ ដល់យើងទាំងឡាយ ស្រាប់តែក្រោកចាកអាសនៈ ហើយយាងចូល

ទៅកាន់វិហារថា ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌ក្តី ធម៌ក្តី ភិក្ខុគប្បីដឹង សភាវៈមិនមែនប្រយោជន៍ក្តី ប្រយោជន៍ក្តី ភិក្ខុគប្បីដឹង ( ទាំងអស់ ) លុះបានដឹងនូវសភាវៈមិនមែនធម៌ និងធម៌ បានដឹងនូវសភាវៈមិនមែនប្រយោជន៍ និងប្រយោជន៍ហើយ ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា គប្បីប្រតិបត្តិតាមយ៉ាងនោះចុះ ។ ម្នាលអាវុសោ កាលព្រះមានព្រះភាគចៀសចេញទៅ មិនយូរប៉ុន្មាន យើងទាំងអស់គ្នានោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគទ្រង់សម្តែងឡើងនូវឧទ្ទេសនេះឯង ដោយសេចក្តីសង្ខេប មិនចែករំលែកនូវអត្ថ ដោយសេចក្តីពិស្តារ ដល់យើងទាំងឡាយសោះ ក៏ស្រាប់តែក្រោកចាកអាសនៈ ហើយយាងចូលទៅកាន់វិហារថា ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌ និងធម៌ ភិក្ខុគប្បីដឹង សភាវៈមិនមែនប្រយោជន៍ និងប្រយោជន៍ ភិក្ខុគប្បីដឹង ( ទាំងអស់ ) លុះបានដឹងនូវសភាវៈមិនមែនជាធម៌ និងធម៌ផង បានដឹងនូវសភាវៈមិនមែនជាប្រយោជន៍ និងប្រយោជន៍ផងហើយ ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា គប្បីប្រតិបត្តិតាមយ៉ាងនោះចុះ ។ ភិក្ខុអង្គណាហ្ន៎ គប្បីចែករំលែក នូវអត្ថនៃឧទ្ទេសនេះ ដែលព្រះមានព្រះភាគ ទ្រង់សម្តែងឡើងហើយ ដោយសង្ខេប មិនបានចែករំលែកនូវអត្ថ ដោយពិស្តារ ឲ្យពិស្តារបាន ។ ម្នាលអាវុសោ កាលពួកយើងទាំងនោះ មានសេចក្តីត្រិះរិះដូច្នេះថា ព្រះមហាកច្ចានៈដ៏មានអាយុអង្គនេះឯង ព្រះសាស្តាទ្រង់សរសើរហើយ ទាំងពួកសព្រហ្មចារីបុគ្គល ជាអ្នកប្រាជ្ញក៏សរសើរ

ហើយដែរ មានតែព្រះមហាកច្ចានៈដ៏មានអាយុ ទើបអាចចែករំលែក នូវអត្ថនៃឧទ្ទេសនេះ ដែលព្រះមានព្រះភាគ ទ្រង់សម្តែងឡើងហើយ ដោយសង្ខេប មិនចែករំលែក នូវអត្ថដោយពិស្តារ ឲ្យពិស្តារបាន បើដូច្នោះ គួរតែយើងទាំងអស់គ្នា ចូលទៅរកព្រះមហាកច្ចានៈដ៏មានអាយុ លុះចូលទៅដល់ហើយ គប្បីសួរនូវសេចក្តីនុ៎ះ នឹងព្រះមហាកច្ចានៈដ៏មានអាយុ ព្រះមហាកច្ចានៈដ៏មានអាយុ នឹងព្យាករដល់យើងទាំងឡាយ យ៉ាងណា យើងទាំងអស់គ្នា នឹងចាំនូវសេចក្តីនុ៎ះយ៉ាងនោះ សូមព្រះមហាកច្ចានៈដ៏មានអាយុ ចែករំលែក ( នូវសេចក្តីនុ៎ះ ) ។ ព្រះមហាកច្ចានៈតបថា ម្នាលអាវុសោទាំងឡាយ ដូចបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ ( ចំពោះមុខ ) ក៏រំលងគល់ រំលងដើម ហើយសម្គាល់ថា គួរស្វែងរកខ្លឹមត្រង់មែក និងសន្លឹកទៅវិញ យ៉ាងណាមិញ សេចក្តីប្រៀបធៀបក៏យ៉ាងនោះ កាលព្រះសាស្តា គង់នៅចំពោះមុខ នៃលោកដ៏មានអាយុទាំងឡាយ លោកទាំងឡាយ ក៏រំលងព្រះមានព្រះភាគអង្គនោះ ហើយមកសម្គាល់នូវសេចក្តីដែលត្រូវសួរនុ៎ះនឹងយើងវិញ ។ ម្នាលអាវុសោទាំងឡាយ សេចក្តីពិតថា ព្រះមានព្រះភាគអង្គនោះទ្រង់ជ្រាបនូវហេតុដែលគួរជ្រាប ទ្រង់ឃើញនូវហេតុដែលគួរឃើញ ព្រះតថាគតមានចក្ខុកើតហើយ មានញាណកើតហើយ មានធម៌កើតហើយ មានសភាពជាបុគ្គលប្រសើរ ជាអ្នកស្តីថា អ្នកប្រៀនប្រដៅ អ្នកចង្អុលបង្ហាញនូវប្រយោជន៍ អ្នកឲ្យនូវព្រះនិព្វាន ម្ចាស់

ព្រោះធម៌ ។ អើ ! កាលនោះ ជាកាលសមគួរដល់ព្រះតថាគតអង្គនុ៎ះហើយ អ្នកទាំងឡាយ គប្បីចូលទៅគាល់ព្រះមានព្រះភាគ ហើយសួរនូវសេចក្តីនុ៎ះចុះ ព្រះមានព្រះភាគទ្រង់ព្យាករ ដល់យើងរាល់គ្នាយ៉ាងណា អ្នកទាំងឡាយគប្បីចាំនូវសេចក្តីនុ៎ះ យ៉ាងនោះចុះ ។ ម្នាលកច្ចានៈដ៏មានអាយុ ព្រះមានព្រះភាគទ្រង់ជ្រាបនូវហេតុដែលគួរជ្រាប ទ្រង់ឃើញនូវហេតុដែលគួរឃើញតាមពិត ព្រះតថាគតមានចក្ខុកើតហើយ មានញាណកើតហើយ មានធម៌កើតហើយ ជាបុគ្គលប្រសើរ ជាអ្នកស្តីថា ជាអ្នកប្រៀនប្រដៅ អ្នកចង្អុលបង្ហាញនូវប្រយោជន៍ អ្នកឲ្យនូវព្រះនិព្វាន ម្ចាស់ព្រោះធម៌ ។ អើ ! កាលនោះ ជាកាលសមគួរ ដល់ព្រះតថាគតអង្គនុ៎ះហើយ យើងទាំងឡាយ គប្បីចូលទៅគាល់ព្រះមានព្រះភាគ ហើយសួរនូវសេចក្តីនុ៎ះចុះ ព្រះមានព្រះភាគទ្រង់ព្យាករដល់យើងទាំងឡាយយ៉ាងណា យើងទាំងឡាយ គប្បីចាំទុកនូវសេចក្តីនុ៎ះ យ៉ាងនោះចុះ ។ ចំណែកខាងព្រះមហាកច្ចានៈដ៏មានអាយុ ព្រះសាស្តាទ្រង់សរសើរហើយ ទាំងពួកសព្រហ្មចារីបុគ្គលជាអ្នកប្រាជ្ញ ក៏សរសើរហើយដែរ មានតែព្រះមហាកច្ចានៈដ៏មានអាយុ ទើបអាចចែករំលែក នូវអត្ថនៃឧទ្ទេសនេះ ដែលព្រះមានព្រះភាគ ទ្រង់សម្តែងឡើងហើយដោយសង្ខេប មិនចែករំលែកនូវអត្ថដោយពិស្តារ ឲ្យពិស្តារបាន សូមព្រះមហាកច្ចានៈដ៏មានអាយុ កុំបង្អែបង្អង់ឡើយ ចែករំលែក ( សេចក្តី ) ទៅចុះ ។ បើដូច្នោះ អ្នកទាំងឡាយ ចូរស្តាប់ ចូរធ្វើទុកក្នុងចិត្ត ឲ្យប្រពៃចុះ ខ្ញុំនឹងសម្តែង ។ ពួក

ភិក្ខុទាំងនោះ ទទួលស្តាប់នូវថេរវាចា របស់ព្រះមហាកច្ចានៈដ៏មានអាយុថា ករុណាអាវុសោ ។ ព្រះមហាកច្ចានៈដ៏មានអាយុ ពោលដូច្នេះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគទ្រង់សម្តែងឡើង នូវឧទ្ទេស ដោយសង្ខេប មិនបានចែករំលែកនូវអត្ថ ដោយពិស្តារ ដល់យើងទាំងឡាយ ក៏ស្រាប់តែក្រោកចាកអាសនៈ ហើយយាងចូលទៅកាន់វិហារថា ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌ និងធម៌ ភិក្ខុគប្បីដឹង សភាវៈមិនមែនប្រយោជន៍ និងប្រយោជន៍ ក៏ភិក្ខុគប្បីដឹង លុះបានដឹងនូវសភាវៈមិនមែនធម៌ និងធម៌ បានដឹងនូវសភាវៈមិនមែនប្រយោជន៍ និងប្រយោជន៍ហើយ ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា គប្បីប្រតិបត្តិយ៉ាងនោះចុះ ។ ម្នាលអាវុសោទាំង-ឡាយ ចុះសភាវៈមិនមែនធម៌ តើដូចម្តេច ធម៌ តើដូចម្តេច សភាវៈមិនមែនប្រយោជន៍ តើដូចម្តេច ប្រយោជន៍ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ការសម្លាប់សត្វ មិនមែនធម៌ទេ កិរិយាវៀរចាកការសម្លាប់សត្វជាធម៌ ឯធម៌ទាំងឡាយណា ជាអកុសលធម៌ដ៏លាមកច្រើន កើតឡើង ព្រោះបច្ច័យ គឺការសម្លាប់សត្វនេះ ជាសភាវៈមិនមែនប្រយោជន៍ទេ ធម៌ទាំងឡាយ ជាកុសលច្រើន រមែងដល់នូវការបរិបូណ៌ដោយភាវនា ព្រោះបច្ច័យ គឺកិរិយាវៀរចាកការសម្លាប់សត្វនេះ ទើបជាប្រយោជន៍ ។ ការកាន់យកនូវទ្រព្យដែលគេមិនបានឲ្យ មិនមែនជាធម៌ កិរិយាវៀរចាកការកាន់យកនូវទ្រព្យដែលគេមិនបានឲ្យ ជាធម៌ ឯធម៌ទាំងឡាយណា ជាអកុសលដ៏លាមកច្រើន

រមែងកើតឡើងព្រម ព្រោះបច្ច័យ គឺការកាន់យកនូវទ្រព្យ ដែលគេមិនបានឲ្យ នេះមិនមែនប្រយោជន៍ ធម៌ទាំងឡាយ ជាកុសលច្រើន រមែងដល់នូវការបរិបូណ៌ដោយការនា ព្រោះបច្ច័យ គឺកិរិយាវៀរចាកការកាន់យកនូវទ្រព្យដែលគេមិនបានឲ្យ នេះជាប្រយោជន៍ ។ ម្នាលអាវុសោទាំងឡាយ ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ មិនមែនជាធម៌ទេ កិរិយាវៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ជាធម៌ ធម៌ទាំងឡាយណា ជាអកុសលដ៏លាមកច្រើន រមែងកើតឡើងព្រម ព្រោះបច្ច័យ គឺការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ នេះមិនមែនជាប្រយោជន៍ ។ ធម៌ទាំងឡាយ ជាកុសលច្រើន រមែងដល់នូវការបរិបូណ៌ដោយការនា ព្រោះបច្ច័យ គឺកិរិយាវៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ នេះទើបជាប្រយោជន៍ ។ ម្នាលអាវុសោទាំងឡាយ ការពោលនូវពាក្យកុហក មិនមែនជាធម៌ កិរិយាវៀរចាកការពោលនូវពាក្យកុហក ជាធម៌ ឯធម៌ទាំងឡាយណា ជាអកុសលដ៏លាមកច្រើន រមែងកើតឡើងព្រម ព្រោះបច្ច័យ គឺការពោលនូវពាក្យកុហក នេះមិនមែនជាប្រយោជន៍ទេ ធម៌ទាំងឡាយ ជាកុសលច្រើន រមែងដល់នូវការបរិបូណ៌ដោយការនា ព្រោះបច្ច័យ គឺកិរិយាវៀរចាកការពោលនូវពាក្យកុហក នេះជាប្រយោជន៍ ។ ម្នាលអាវុសោទាំងឡាយ សម្ផប្បលាបៈ មិនមែនជាធម៌ កិរិយាវៀរចាកសម្ផប្បលាបៈ ជាធម៌ ឯធម៌ទាំងឡាយណា ជាអកុសលដ៏លាមកច្រើន រមែងកើតឡើងព្រម ព្រោះបច្ច័យ គឺសម្ផប្បលាបៈ នេះមិនមែនជាប្រ-

យោជន៍ ធម៌ទាំងឡាយ ជាកុសលច្រើន រមែងដល់នូវការបរិបូណ៌ដោយភាវនា ព្រោះបច្ច័យ គឺកិរិយាវៀរចាកសម្ដីញុះញង់ នេះទើបជាប្រយោជន៍ ។ ម្នាលអាវុសោទាំងឡាយ សម្ដីអាក្រក់មិនមែនជាធម៌ ឯធម៌ទាំងឡាយណា ជាអកុសលដ៏លាមកច្រើនកើតឡើងព្រម ព្រោះបច្ច័យ គឺសម្ដីអាក្រក់ នេះមិនមែនជាប្រយោជន៍ទេ ធម៌ទាំងឡាយជាកុសលច្រើន តែងដល់នូវការបរិបូណ៌ដោយភាវនា ព្រោះបច្ច័យ គឺកិរិយាវៀរចាកសំដីអាក្រក់ នេះជាប្រយោជន៍ ។ ម្នាលអាវុសោទាំងឡាយ ការពោលពាក្យរោយរាយ ឥតប្រយោជន៍ មិនមែនជាធម៌ កិរិយាវៀរចាកការពោលពាក្យរោយរាយ ឥតប្រយោជន៍ ជាធម៌ ឯធម៌ទាំងឡាយណា ជាអកុសលដ៏លាមកច្រើន តែងកើតឡើងព្រម ព្រោះបច្ច័យ គឺការពោលពាក្យរោយរាយឥតប្រយោជន៍ នេះមិនមែនជាប្រយោជន៍ ធម៌ទាំងឡាយ ជាកុសលច្រើន រមែងដល់នូវការបរិបូណ៌ដោយភាវនា ព្រោះបច្ច័យ គឺកិរិយាវៀរចាកការពោលពាក្យរោយរាយ ឥតប្រយោជន៍ នេះជាប្រយោជន៍ ។ ម្នាលអាវុសោទាំងឡាយ ការសម្លឹងរំពៃចំពោះទ្រព្យអ្នកដទៃ មិនមែនជាធម៌ ការមិនសម្លឹងរំពៃចំពោះទ្រព្យអ្នកដទៃ ជាធម៌ ឯធម៌ទាំងឡាយណា ជាអកុសលដ៏លាមកច្រើន តែងកើតឡើងព្រម ព្រោះបច្ច័យ គឺការសម្លឹងរំពៃចំពោះទ្រព្យអ្នកដទៃ នេះមិនមែនជាប្រយោជន៍ ធម៌ទាំងឡាយជាកុសលច្រើន តែងដល់នូវការបរិបូណ៌ដោយភាវនា ព្រោះបច្ច័យ គឺការមិនសម្លឹងរំពៃចំពោះទ្រព្យអ្នកដទៃ នេះជាប្រយោជន៍ ។ ម្នាលអាវុសោទាំង-

ឡាយ ការចង់ឲ្យគេវិនាស មិនមែនជាធម៌ ការមិនចង់ឲ្យគេវិនាស ជាធម៌ ឯធម៌ទាំងឡាយណា ជាអកុសលដ៏លាមកច្រើន រមែងកើតឡើងព្រម ព្រោះបច្ច័យ គឺការចង់ឲ្យគេវិនាស នេះមិនមែនជាប្រយោជន៍ទេ ធម៌ទាំងឡាយ ជាកុសលច្រើន រមែងដល់នូវការបរិបូណ៌ដោយភាវនា ព្រោះបច្ច័យ គឺការមិនចង់ឲ្យគេវិនាស នេះទើបជាប្រយោជន៍ ។ ម្នាលអាវុសោទាំងឡាយ ការយល់ខុស មិនមែនជាធម៌ ការយល់ត្រូវ ជាធម៌ ឯធម៌ទាំងឡាយណា ជាអកុសលដ៏លាមកច្រើន កើតឡើងព្រម ព្រោះបច្ច័យ គឺការយល់ខុស នេះមិនមែនជាប្រយោជន៍ ធម៌ទាំងឡាយ ជាកុសលច្រើន រមែងដល់នូវការបរិបូណ៌ដោយភាវនា ព្រោះបច្ច័យ គឺការយល់ត្រូវ នេះជាប្រយោជន៍ ។ ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគ ទ្រង់សម្តែងនូវឧទ្ទេសណា ដោយសង្ខេប មិនចែករលែកនូវអត្ថ ( នៃឧទ្ទេសនុ៎ះ ) ដោយពិស្តារ ដល់យើងទាំងឡាយ ក៏ស្រាប់តែក្រោកចាកអាសនៈ ហើយយាងចូលទៅកាន់វិហារ ថា ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌ និងធម៌ ភិក្ខុគប្បីដឹង សភាវៈមិនមែនប្រយោជន៍ និងប្រយោជន៍ ក៏ភិក្ខុគប្បីដឹង លុះបានដឹងសភាវៈមិនមែនជាធម៌ និងធម៌ បានដឹងនូវសភាវៈមិនមែនជាប្រយោជន៍ និងប្រយោជន៍ ហើយ ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា គប្បីប្រតិបត្តិយ៉ាងនោះចុះ ម្នាលអាវុសោទាំងឡាយ ចំណែកខាងខ្ញុំ តែងដឹងនូវអត្ថនៃឧទ្ទេសនេះឯង ដែលព្រះមានព្រះភាគ ទ្រង់សម្តែងឡើងដោយសង្ខេប មិនចែករលែកនូវអត្ថដោយ

ពិស្តារ ឲ្យពិស្តារបានយ៉ាងនេះ ។ ម្នាលអាវុសោទាំងឡាយ លោកទាំងឡាយ កាលបើប្រាថ្នា ត្រូវតែចូលទៅគាល់ព្រះមានព្រះភាគ ហើយសួរសេចក្តីនុ៎ះ ព្រះមានព្រះភាគព្យាករ ដល់យើងទាំងឡាយ យ៉ាងណា អ្នកទាំងឡាយ ត្រូវចាំទុកនូវសេចក្តីនុ៎ះ យ៉ាងនោះចុះ ។ ពួកភិក្ខុទាំងនោះ ត្រេកអរ អនុ-មោទនា ចំពោះភាសិតរបស់ព្រះមហាកច្ចានៈដ៏មានអាយុថា ករុណាអាវុសោ ហើយក៏ក្រោកចាកអាសនៈ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយនៅក្នុងទីសមគួរ ។ ភិក្ខុទាំងនោះ លុះអង្គុយក្នុងទីសមគួរហើយ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគទ្រង់សម្តែងនូវឧទ្ទេសណា ដោយសង្ខេប មិនចែករំលែកនូវអត្ថ ( នៃឧទ្ទេសនុ៎ះ ) ដោយពិស្តារ ក៏ស្រាប់តែក្រោកចាកអាសនៈ ហើយយាងចូលទៅកាន់វិហារថា ម្នាលភិក្ខុទាំង-ឡាយ សភាវៈមិនមែនធម៌ និងធម៌ ភិក្ខុគប្បីដឹង សភាវៈមិនមែនប្រយោជន៍ និងប្រយោជន៍ ក៏ភិក្ខុគប្បីដឹង លុះបានដឹងសភាវៈមិនមែនធម៌ និងធម៌ បាន ដឹងសភាវៈមិនមែនប្រយោជន៍ និងប្រយោជន៍ហើយ ធម៌យ៉ាងណា ប្រ-យោជន៍យ៉ាងណា គប្បីប្រតិបត្តិយ៉ាងនោះចុះ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលព្រះមានព្រះភាគ ទ្រង់ចេញទៅ មិនយូរប៉ុន្មាន យើងខ្ញុំទាំងឡាយនោះ មានសេចក្តីត្រិះរិះដូច្នេះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគ ទ្រង់ សម្តែងនូវឧទ្ទេសនេះឯងដោយសង្ខេប មិនបានចែករំលែកនូវអត្ថដោយពិស្តារ

ដល់យើងទាំងឡាយ ក៏ស្រាប់តែក្រោកចាកអាសនៈ ហើយយាងចូលទៅកាន់វិហារថា ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌ និងធម៌ ភិក្ខុគប្បីដឹងសភាវៈមិនមែនប្រយោជន៍ និងប្រយោជន៍ ក៏ភិក្ខុគប្បីដឹង លុះបានដឹងសភាវៈមិនមែនធម៌ និងធម៌ បានដឹងសភាវៈមិនមែនប្រយោជន៍ និងប្រយោជន៍ហើយ ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា គប្បីប្រតិបត្តិយ៉ាងនោះចុះ ។ ភិក្ខុអង្គណាហ្ន៎ គប្បីចែករំលែកនូវអត្ថនៃឧទ្ទេសនេះ ដែលព្រះមានព្រះភាគ ទ្រង់សំដែងហើយដោយសង្ខេប មិនបានចែករំលែកនូវអត្ថដោយពិស្តារ ឲ្យពិស្តារបាន ។ បពិត្រព្រះអង្គដ៏ចម្រើន យើងទាំងនោះមានសេចក្តីត្រិះរិះដូច្នេះថា ព្រះមហាកច្ចានៈដ៏មានអាយុនេះឯង ព្រះសាស្តាទ្រង់សរសើរហើយ ទាំងពួកសព្រហ្មចារីបុគ្គល ជាអ្នកប្រាជ្ញ ក៏សរសើរហើយដែរ មានតែព្រះមហាកច្ចានៈដ៏មានអាយុ ទើបអាចចែករំលែកនូវអត្ថនៃឧទ្ទេសនេះ ដែលព្រះមានព្រះភាគទ្រង់សំដែងឡើង ដោយសង្ខេប មិនបានចែករំលែកនូវអត្ថដោយពិស្តារឲ្យពិស្តារបាន បើដូច្នោះ គួរតែយើងទាំងឡាយ ចូលទៅរកព្រះមហាកច្ចានៈដ៏មានអាយុ លុះចូលទៅដល់ហើយ គប្បីសួរនូវសេចក្តីនុ៎ះ នឹងព្រះមហាកច្ចានៈដ៏មានអាយុ ព្រះមហាកច្ចានៈដ៏មានអាយុនឹងព្យាករដល់យើងទាំងឡាយយ៉ាងណា យើងទាំងឡាយ នឹងចាំទុកនូវសេចក្តីនោះ យ៉ាងនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ យើងទាំងឡាយ ក៏ចូលទៅរកព្រះមហាកច្ចានៈដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏បានសួរនូវសេចក្តីនុ៎ះ នឹងព្រះ

មហាកច្ចានៈដ៏មានអាយុ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមហាកច្ចានៈដ៏មាន អាយុ បានចែករំលែកសេចក្តីស្រួលបួល ដោយអាការទាំងឡាយនេះ ដោយ បទទាំងឡាយនេះ ដោយព្យញ្ជនៈទាំងឡាយនេះ ដល់យើងទាំងឡាយនោះ ។ ម្នាលភិក្ខុទាំងឡាយ ប្រពៃហើយ ប្រពៃហើយ ម្នាលភិក្ខុទាំងឡាយ មហា-កច្ចានៈជាបណ្ឌិត ម្នាលភិក្ខុទាំងឡាយ មហាកច្ចានៈ ជាអ្នកមានប្រាជ្ញាច្រើន ម្នាលភិក្ខុទាំងឡាយ ប្រសិនបើអ្នកទាំងឡាយ ចូលមករកតថាគត ហើយ សួរនូវសេចក្តីនុ៎ះ តថាគតក៏ព្យាករនូវសេចក្តីនុ៎ះដូចសេចក្តីដែលមហាកច្ចានៈ បានព្យាករហើយ យ៉ាងនោះដែរ សេចក្តីនោះឯងនែឧទ្ទេសនោះ អ្នកទាំងឡាយ គប្បីចាំទុកនូវសេចក្តីនោះ យ៉ាងនេះចុះ ។

## តតិយអធម្មសូត្រទី ៧

[ ៦២ ] ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌ និងធម៌ ភិក្ខុគប្បី ដឹង សភាវៈមិនមែនប្រយោជន៍ និងប្រយោជន៍ ក៏ភិក្ខុគប្បីដឹង លុះបានដឹង នូវសភាវៈ មិនមែនធម៌ និងធម៌ បានដឹងសភាវៈ មិនមែនប្រយោជន៍ និង ប្រយោជន៍ហើយ ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា គប្បីប្រតិបត្តិយ៉ាងនោះ ចុះ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌ តើដូចម្តេច ធម៌ តើដូចម្តេច សភាវៈមិនមែនប្រយោជន៍ តើដូចម្តេច ប្រយោជន៍ តើដូចម្តេច ។ ម្នាលភិក្ខុ ទាំងឡាយ ការសម្លាប់សត្វមិនមែនធម៌ទេ កិរិយាវៀរចាកការសម្លាប់សត្វជា ធម៌ ឯធម៌ទាំងឡាយណា ជាអកុសលដ៏លាមកច្រើន តែងកើតឡើងព្រម

ព្រោះបច្ច័យ គឺការសម្លាប់សត្វ នេះមិនមែនប្រយោជន៍ទេ ធម៌ទាំងឡាយ ជាកុសលច្រើន រមែងដល់នូវការបរិបូណ៌ដោយភាវនា ព្រោះបច្ច័យ គឺកិរិយាវៀរចាកការសម្លាប់សត្វ នេះទើបជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ ការកាន់យកនូវទ្រព្យ ដែលគេមិនបានឲ្យ មិនមែនជាធម៌ទេ កិរិយាវៀរចាកការកាន់យកនូវទ្រព្យ ដែលគេមិនបានឲ្យ ជាធម៌ ... ម្នាលភិក្ខុទាំងឡាយ ការប្រព្រឹត្តិខុសក្នុងកាមទាំងឡាយ មិនមែនជាធម៌ទេ កិរិយាវៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ជាធម៌ ... ម្នាលភិក្ខុទាំងឡាយ ការពោលនូវពាក្យកុហក មិនមែនជាធម៌ទេ កិរិយាវៀរចាកការពោលនូវពាក្យកុហក ជាធម៌ ... ម្នាលភិក្ខុទាំងឡាយ សម្តីញុះញង់គេ មិនមែនជាធម៌ទេ កិរិយាវៀរចាកសម្តីញុះញង់គេ ជាធម៌ ... ម្នាលភិក្ខុទាំងឡាយ សម្តីអាក្រក់ មិនមែនជាធម៌ទេ ការវៀរចាកសម្តីអាក្រក់ ជាធម៌ ... ម្នាលភិក្ខុទាំងឡាយ សម្តីរោយរាយឥតប្រយោជន៍ មិនមែនជាធម៌ទេ កិរិយាវៀរចាកសម្តីរោយរាយ ឥតប្រយោជន៍ ជាធម៌ ... ម្នាលភិក្ខុទាំងឡាយ ការសម្លឹងរំពៃចំពោះទ្រព្យអ្នកដទៃ មិនមែនជាធម៌ទេ ការមិនសម្លឹងរំពៃចំពោះទ្រព្យអ្នកដទៃ ជាធម៌ ... ម្នាលភិក្ខុទាំងឡាយ ការចង់ឲ្យគេវិនាស មិនមែនជាធម៌ទេ ការមិនចង់ឲ្យគេវិនាស ជាធម៌ ... ម្នាលភិក្ខុទាំងឡាយ ការយល់ខុស មិនមែនជាធម៌ទេ ការយល់ត្រូវ ជាធម៌ ធម៌ទាំងឡាយណា ជាអកុសលដ៏លាមកច្រើន តែងកើតឡើងព្រម ព្រោះបច្ច័យ គឺការយល់ខុស នេះមិនមែនជាប្រយោជន៍ទេ

ធម៌ទាំងឡាយ ជាកុសលច្រើន រមែងដល់នូវការបរិបូណ៌ ដោយការនា ព្រោះបច្ច័យ គឺការយល់ត្រូវ នេះជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនជាធម៌ និងធម៌ ភិក្ខុគប្បីដឹង សភាវៈមិនមែនជាប្រយោជន៍ និងប្រយោជន៍ ក៏ភិក្ខុគប្បីដឹង លុះបានដឹងសភាវៈមិនមែនជាធម៌ និងធម៌ ដឹងនូវសភាវៈមិនមែនជាប្រយោជន៍ និងប្រយោជន៍ហើយ ធម៌យ៉ាងណា ប្រ-យោជន៍ យ៉ាងណា គប្បីប្រតិបត្តិយ៉ាងនោះចុះ ពាក្យណា ដែលតថាគតពោលហើយដូច្នេះ ពាក្យនុ៎ះ តថាគតបានពោលហើយ ព្រោះអាស្រ័យនូវសេចក្តីនេះ ។

# អដ្ឋកថា

# ជាណុស្សោណិវគ្គទី ២

## បឋមបច្ចោរោហណិសូត្រទី ១ ជាដើម

[ ៥៦-៦២ ] បឋមបច្ចោរោហណិសូត្រទី ១ ជាដើម មានអត្ថងាយយល់ហើយ ។

អដ្ឋកថាបឋមបច្ចោរោហណិសូត្រទី ១ ជាដើមចប់

# សុត្តន្តបិដក

## តតិយសូត្រទី ៨

[ ៦៣ ] ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បាណាតិបាត មាន ៣ ប្រការ គឺមានលោភៈជាហេតុ ១ មានទោសៈជាហេតុ ១ មានមោហៈជាហេតុ ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា អទិន្នាទាន មាន ៣ ប្រការ គឺមានលោភៈជាហេតុ ១ មានទោសៈជាហេតុ ១ មានមោហៈជាហេតុ ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា កាមេសុមិច្ឆាចារ មាន ៣ ប្រការ គឺមានលោភៈជាហេតុ ១ មានទោសៈជាហេតុ ១ មានមោហៈជាហេតុ ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា មុសាវាទ មាន ៣ ប្រការ គឺមានលោភៈជាហេតុ ១ មានទោសៈជាហេតុ ១ មានមោហៈជាហេតុ ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បិសុណាវាចា មាន ៣ ប្រការ គឺមានលោភៈជាហេតុ ១ មានទោសៈជាហេតុ ១ មានមោហៈជាហេតុ ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ផរុសវាចា មាន ៣ ប្រការ គឺមានលោភៈជាហេតុ ១ មានទោសៈជាហេតុ ១ មានមោហៈជាហេតុ ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សម្ផប្បលាប មាន ៣ ប្រការ គឺមានលោភៈជាហេតុ ១ មានទោសៈជាហេតុ ១ មានមោហៈជាហេតុ ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា អភិជ្ឈា មាន ៣ ប្រការ គឺមានលោភៈជាហេតុ ១ មានទោសៈជាហេតុ ១ មានមោហៈជាហេតុ ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ព្យាបាទ មាន ៣

ប្រការ គឺមានលោភៈជាហេតុ ១ មានទោសៈជាហេតុ ១ មានមោហៈជាហេតុ ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា មិច្ឆាទិដ្ឋិ មាន ៣ ប្រការ គឺមានលោភៈជាហេតុ ១ មានទោសៈជាហេតុ ១ មានមោហៈជាហេតុ ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះដំណើរដូច្នេះឯង លោភៈឈ្មោះថាជាហេតុ ជាដែនកើតនៃកម្ម ទោសៈឈ្មោះថាជាហេតុ ជាដែនកើតនៃកម្ម មោហៈឈ្មោះថាជាហេតុ ជាដែនកើតនៃកម្ម ព្រោះអស់លោភៈ ទើបអស់ហេតុនៃកម្ម ព្រោះអស់ទោសៈ ទើបអស់ហេតុនៃកម្ម ព្រោះអស់មោហៈ ទើបអស់ហេតុនៃកម្ម ។

# អដ្ឋកថា

## តិកិច្ចសូត្រ

[ ៦៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតិកិច្ចសូត្រទី ៨ នៃជាណុស្សោណិវគ្គទី ២ ដូចតទៅ បទថា **លោភហេតុកម្បិ** សេចក្តីថា ការលោភជាហេតុ ដោយជាចំណែកឧបនិស្សយប្បច្ច័យ ដល់បាណាតិបាត ដែលប្រកបដោយទោសៈនិងមោហៈក៏មាន គប្បីជ្រាបសេចក្តីក្នុងគ្រប់បទដោយឧបាយនេះ ។

**អដ្ឋកថា តិកិច្ចសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## សបរិក្កមនសូត្រទី ៩

[ ៦៤ ] ម្នាលភិក្ខុទាំងឡាយ ធម៌នេះ ប្រកបដោយការប្រែត្រឡប់ ធម៌នេះ មិនមែនជាមិនមានការប្រែត្រឡប់ទេ ។ ម្នាលភិក្ខុទាំងឡាយ ធម៌នេះប្រកបដោយការប្រែត្រឡប់ ធម៌នេះ មិនមែនជាមិនមានការប្រែត្រឡប់ តើដោយអធិប្បាយ ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកសម្លាប់សត្វ វៀរចាកការសម្លាប់សត្វវិញ ឈ្មោះថា ការប្រែត្រឡប់ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកលួចទ្រព្យគេ វៀរចាកការលួចទ្រព្យគេវិញ ឈ្មោះថា ការប្រែត្រឡប់ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកប្រព្រឹត្តខុសក្នុងកាម វៀរចាកការប្រព្រឹត្តខុសក្នុងកាមវិញ ឈ្មោះថា ការប្រែត្រឡប់ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកពោលពាក្យកុហក វៀរចាកការពោលពាក្យកុហកវិញ ឈ្មោះថា ការប្រែត្រឡប់ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកពោលពាក្យញុះញង់ វៀរចាកការពោលពាក្យញុះញង់វិញ ឈ្មោះថា ការប្រែត្រឡប់ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកពោលពាក្យអាក្រក់ វៀរចាកការពោលពាក្យអាក្រក់វិញ ឈ្មោះថា ការប្រែត្រឡប់ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកពោលពាក្យឥតប្រយោជន៍ វៀរចាកការពោលពាក្យឥតប្រយោជន៍វិញ ឈ្មោះថា ការប្រែត្រឡប់ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានអភិជ្ឈា មិនមានអភិជ្ឈាវិញ ឈ្មោះថា ការប្រែត្រឡប់ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានព្យាបាទ មិនមានព្យាបាទវិញ ឈ្មោះថា ការប្រែត្រឡប់ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកយល់ខុស មានការយល់ត្រូវវិញ

ឈ្មោះថា ការប្រែត្រឡប់ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ហៅថា ការប្រែត្រឡប់ ។ ម្នាលភិក្ខុទាំងឡាយ ធម៌នេះ ដែលប្រកបដោយការប្រែត្រឡប់ មិនមែនជាមិនមានការប្រែត្រឡប់ យ៉ាងនេះឯង ។

# អដ្ឋកថា

## សបរិក្កមនសូត្រ

[ ៦៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសបរិក្កមនសូត្រទី ៩ ដូចតទៅនេះ បទថា **បរិក្កមនំ ហោតិ** បានដល់ ការវៀរមែងមាន ។

**អដ្ឋកថា សបរិក្កមនសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ចុន្ទសូត្រទី ១០

[ ៦៥ ] សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅ ក្នុងអម្ពវ័ន ( ព្រៃស្វាយ ) របស់កម្មារបុត្រឈ្មោះចុន្ទ ជិតក្រុងបាវា ។ គ្រានោះ ចុន្ទកម្មារបុត្របានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមាន

ព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះចុន្ទកម្មារបុត្រ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់សួរដូច្នេះថា ម្នាលចុន្ទ អ្នកពេញចិត្តនឹងការស្អាតរបស់អ្នកណា ។ ចុន្ទកម្មារបុត្រក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រាហ្មណ៍ទាំងឡាយ ដែលនៅខាងក្រោយភូមិ ជាអ្នកប្រើប្រាស់ល័ក្កចាន់ ប្រើប្រាស់សំពត់ដូចផ្កាសារាយ ជាអ្នកបម្រើភ្លើង ជាអ្នកចុះត្រាំទឹកព្រឹកល្ងាច តែងបញ្ញត្តនូវការស្អាត ខ្ញុំព្រះអង្គពេញចិត្តចំពោះការស្អាត របស់ព្រាហ្មណ៍ទាំងនោះ ។ ម្នាលចុន្ទ ចុះពួកព្រាហ្មណ៍ ដែលនៅខាងក្រោយភូមិ ជាអ្នកប្រើប្រាស់ល័ក្កចាន់ ប្រើប្រាស់សំពត់ដូចផ្កាសារាយ ជាអ្នកបម្រើភ្លើង ជាអ្នកចុះត្រាំទឹកព្រឹកល្ងាច តែងបញ្ញត្តនូវការស្អាតយ៉ាងណាខ្លះ ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងលោកនេះ ពួកព្រាហ្មណ៍ ដែលនៅខាងក្រោយភូមិ ជាអ្នកប្រើប្រាស់ល័ក្កចាន់ ប្រើប្រាស់សំពត់ដូចផ្កាសារាយ ជាអ្នកបម្រើភ្លើង ជាអ្នកចុះត្រាំទឹកព្រឹកល្ងាច ព្រាហ្មណ៍ទាំងនោះតែងបបួលពួកសាវ័កថា នែបុរសអើយ អ្នកចូរមកអាយ កាលបើអ្នកក្រោកអំពីដំណេក ក្នុងវេលាព្រឹកព្រហាម គប្បីស្ទាបផែនដី បើអ្នកមិនស្ទាបផែនដីទេ គប្បីស្ទាបអាចម៍គោស្រស់ បើអ្នកមិនស្ទាបអាចម៍គោស្រស់ទេ គប្បីស្ទាបស្មៅស្រស់ បើអ្នកមិនស្ទាបស្មៅស្រស់ទេ គប្បីបម្រើភ្លើង បើអ្នកមិនបម្រើភ្លើងទេ គប្បីប្រណម្យអញ្ជលីនមស្ការព្រះអាទិត្យ បើអ្នកមិនប្រណម្យអញ្ជលី នមស្ការព្រះអាទិត្យទេ គប្បីចុះត្រាំទឹកជាគម្រប់ ៣ ដង និងពេលល្ងាច ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកព្រាហ្មណ៍

ដែលនៅខាងក្រោយភូមិ ជាអ្នកប្រើប្រាស់លក្កចាន់ ប្រើប្រាស់សំពត់ដូចផ្កាសារាយ ជាអ្នកបម្រើភ្លើង ជាអ្នកចុះត្រាំទឹកព្រឹកល្ងាច តែងបញ្ញត្តនូវការស្អាត យ៉ាងនេះឯង ខ្ញុំព្រះអង្គតែងពេញចិត្តនឹងការស្អាត របស់ព្រាហ្មណ៍ទាំងនោះ ។ នែចុន្ទ ពួកព្រាហ្មណ៍ ដែលនៅខាងក្រោយភូមិ ជាអ្នកប្រើប្រាស់លក្កចាន់ ប្រើប្រាស់សំពត់ដូចផ្កាសារាយ ជាអ្នកបម្រើភ្លើង ជាអ្នកចុះត្រាំទឹកព្រឹកល្ងាច បញ្ញត្តនូវការស្អាត ដោយឡែក ចំណែកការស្អាត ក្នុងអរិយវិន័យដោយឡែក ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះការស្អាតក្នុងអរិយវិន័យ តើដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គសម្តែងធម៌ តាមដំណើរការស្អាត ក្នុងអរិយវិន័យ ឲ្យទានដល់ខ្ញុំព្រះអង្គ ។ ម្នាលចុន្ទ បើដូច្នោះ អ្នកចូរស្តាប់ ចូរធ្វើទុកក្នុងចិត្ត ដោយប្រពៃចុះ តថាគតនឹងសម្តែង ។ ចុន្ទកម្មារបុត្រ ទទួលតបព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលចុន្ទ ការមិនស្អាតដោយកាយ មាន ៣ ប្រការ ការមិនស្អាតដោយវាចា មាន ៤ ប្រការ ការមិនស្អាតដោយចិត្ត មាន ៣ ប្រការ ។ ម្នាលចុន្ទ ចុះការមិនស្អាតដោយកាយ មាន ៣ ប្រការ តើដូចម្តេច ។ ម្នាលចុន្ទ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ជាមនុស្សមានចិត្តអាក្រក់ មានដៃប្រឡាក់ឈាម មានចិត្តប្មោះជាប់ ក្នុងការសម្លាប់សត្វ មានចិត្តមិនអាសូរចំពោះពួកសត្វ ១ ជាអ្នកលួចទ្រព្យគេ គឺជាអ្នកកាន់យកនូវគ្រឿងឧបករណ៍ ដែលជាសម្បត្តិនៃបុគ្គលដទៃ គេទុកក្នុងស្រុកក្តី ទុកក្នុងព្រៃក្តី ដែលគេមិនបានឲ្យ

ដែលហៅថា លួច ១ ជាអ្នកប្រព្រឹត្តខុសក្នុងកាម គឺជាអ្នកដល់នូវការប្រព្រឹត្ត កន្លងក្នុងស្ត្រីទាំងឡាយ ដែលមានមាតារក្សា បិតារក្សា បងប្អូនប្រុសរក្សា បងប្អូនស្រីរក្សា ញាតិរក្សា ធម៌រក្សា ជាស្ត្រីមានប្តី មានអាជ្ញា ( កំណត់ទុក ) ដោយហោចទៅ សូម្បីតែស្ត្រីដែលបុរសបំពាក់កម្រងផ្កាឲ្យ ១ ។ ម្នាលចុន្ទ ការមិនស្អាតដោយកាយ មាន ៣ ប្រការយ៉ាងនេះឯង ។ ម្នាលចុន្ទ ការមិនស្អាតដោយវាចា មាន ៤ ប្រការ តើដូចម្តេច ។ ម្នាលចុន្ទ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកពោលពាក្យកុហក ទោះបីឋិតនៅក្នុងរោងក្តី ឋិតនៅក្នុងបរិសទ្យក្តី ឋិតនៅក្នុងកណ្តាលញាតិក្តី ឋិតនៅក្នុងកណ្តាលសេនីក្តី ឋិតនៅក្នុងកណ្តាលរាជត្រកូលក្តី ដែលគេនាំទៅធ្វើជាសាក្សី ហើយសួរថា នែបុរសអើយ ចូរអ្នកមកអាយ បើអ្នកដឹងហេតុណា ចូរនិយាយប្រាប់ហេតុនោះ បុគ្គលនោះ កាលមិនដឹង ក៏និយាយថា ខ្ញុំដឹងក៏មាន កាលដឹងនិយាយថា ខ្ញុំមិនដឹងក៏មាន កាលមិនឃើញនិយាយថា ខ្ញុំឃើញក៏មាន កាលឃើញ និយាយថា ខ្ញុំមិនឃើញក៏មាន ជាអ្នកពោលពាក្យកុហកទាំងដឹងខ្លួនដូច្នេះ ព្រោះហេតុតែខ្លួនក្តី ហេតុអ្នកដទៃក្តី ព្រោះហេតុសំណូក គឺអាមិសបន្តិចបន្តួចក្តី ១ ជាអ្នកពោលពាក្យញុះញង់ គឺឮពាក្យអំពីសម្នាក់ជននេះហើយ នាំទៅប្រាប់ជនឯណោះ ដើម្បីនឹងបំបែកជនទាំងនេះ ឬឮពាក្យអំពីសម្នាក់ជនឯណោះ នាំមកប្រាប់ជននេះ ដើម្បីនឹងបំបែកជនឯណោះ ជាអ្នកបំបែកពួកជនដែលព្រមព្រៀងគ្នាផង ជាអ្នកជម្រុលពួកជន ដែលបែកគ្នាហើយផង ជាអ្នកត្រេកអរតែក្នុងពួក មាន

តម្រេកក្នុងពួក ជាអ្នករីករាយតែក្នុងពួក ជាអ្នកពោលវាចាធ្វើឲ្យប្រកាន់ពួក ដោយប្រការដូច្នេះ ១ ជាអ្នកពោលពាក្យអាក្រក់ គឺជាអ្នកពោលវាចាទ្រគោះបោះបោក ខ្ទោះខ្ទរ រោលរាល ស្អក់ដំណើរជនដទៃ ជាវាចាជិតនឹងសេចក្តីក្រោធ មិនប្រព្រឹត្តទៅដើម្បីសមាធិ ១ ជាអ្នកពោលពាក្យឥតប្រយោជន៍ គឺពោលពាក្យខុសកាល ពោលពាក្យមិនពិត ពោលពាក្យមិនមែនជាអត្ថ ពោលពាក្យមិនមែនជាធម៌ ពោលពាក្យមិនមែនជាវិន័យ ពោលពាក្យដែលមិនគួរឲ្យតាំងទុកក្នុងហឫទ័យបាន ជាពាក្យពោលខុសកាល ប្រាសចាកគ្រឿងអាង ជាពាក្យមិនមានទីបំផុត មិនប្រកបដោយប្រយោជន៍ ១ ។ ម្នាលចុន្ទ ការមិនស្អាតដោយវាចា មាន ៤ ប្រការ យ៉ាងនេះឯង ។ ម្នាលចុន្ទ ចុះការមិនស្អាតដោយចិត្ត មាន ៣ ប្រការ តើដូចម្តេច ។ ម្នាលចុន្ទ បុគ្គលខ្លះ ក្នុងលោកនេះ ច្រើនដោយអភិជ្ឈា គឺជាអ្នកគយគន់នូវគ្រឿងឧបករណ៍ ដែលជាសម្បត្តិនៃបុគ្គលដទៃ ដោយគិតថា ឱហ្ន៎ គ្រឿងឧបករណ៍ ដែលជាទ្រព្យសម្បត្តិនៃបុគ្គលដទៃណា គ្រឿងឧបករណ៍នោះ គប្បីបានមកអញ ១ ជាអ្នកមានចិត្តព្យាបាទ គឺជាមនុស្សមានតម្រិះក្នុងចិត្ត ដែលទោសប្រទូស្តហើយថា សត្វទាំងឡាយនេះ ចូរលំបាកខ្លះ ចូរបែកគ្នាខ្លះ ចូរសាបសូន្យទៅខ្លះ ចូរវិនាសទៅខ្លះ កុំបីមានបាន ( អ្វីបន្តិចបន្តួច ) ឡើយ ១ ជាអ្នកមានគំនិតយល់ខុស គឺជាមនុស្សយល់ឃើញនូវសេចក្តីវិបរិតថា ទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជាធំ មិនមានផល ការបូជាតូច មិនមានផល

ផលវិបាករបស់កុសលាកុសលកម្ម ដែលសត្វធ្វើល្អធ្វើអាក្រក់ មិនមាន លោកនេះ មិនមាន លោកខាងមុខ មិនមាន មាតាមិនមាន បិតា មិនមាន សត្វទាំងឡាយជាឱបបាតិកកំណើត មិនមាន ពួកសមណព្រាហ្មណ៍ក្នុងលោក ជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិដោយត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តមរបស់ខ្លួនឯង ហើយសម្តែងប្រាប់ មិនមាន ១ ។ ម្នាលចុន្ទ ការមិនស្អាតដោយចិត្ត មាន ៣ ប្រការ យ៉ាងនេះឯង ។ ម្នាលចុន្ទ ការមិនស្អាតទាំង ១០ នេះឯង ហៅថា អកុសលកម្មបថ ។ ម្នាលចុន្ទ បុគ្គលដែលប្រកបដោយអកុសលកម្មបថទាំង ១០ នេះហើយ បើទុកជាក្រោកឡើងអំពីដំណេក ក្នុងវេលាព្រឹកព្រហាម ហើយស្ទាបផែនដីក្តី ក៏នៅតែជាមនុស្សមិនស្អាតដដែល បើទុកជាមិនស្ទាបផែនដីក្តី ក៏នៅតែមិនស្អាតដដែល បើទុកជាស្ទាបអាចម៍គោស្រស់ក្តី ក៏នៅតែមិនស្អាតដដែល បើទុកជាមិនស្ទាបអាចម៍គោស្រស់ក្តី ក៏នៅតែមិនស្អាតដដែល បើទុកជាស្ទាបស្មៅស្រស់ក្តី ក៏នៅតែមិនស្អាតដដែល បើទុកជា មិនស្ទាបស្មៅស្រស់ក្តី ក៏នៅតែមិនស្អាតដដែល បើទុកជាបម្រើភ្លើងក្តី ក៏នៅតែមិនស្អាតដដែល បើទុកជាមិនបម្រើភ្លើងក្តី ក៏នៅតែមិនស្អាតដដែល បើទុកជាប្រណម្យអញ្ជលីនមស្ការព្រះអាទិត្យក្តី ក៏នៅតែមិនស្អាតដដែល បើទុកជាមិនប្រណម្យអញ្ជលីនមស្ការព្រះអាទិត្យក្តី ក៏នៅតែមិនស្អាតដដែល បើទុកជាចុះត្រាំទឹកជាគម្រប់ ៣ ដង នឹងពេលល្ងាចក្តី ក៏នៅតែមិនស្អាតដដែល បើទុកជាមិនចុះត្រាំទឹក

ជាគម្រប់ ៣ ដងនឹងពេលល្ងាចក្តី ក៏នៅតែមិនស្អាតដដែល ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលចុន្ទ ព្រោះអកុសលកម្មបថទាំង ១០ នេះឯង ជាគន្ធងមិនស្អាតផង ជាផ្លូវក៏ឲ្យកើតរបស់មិនស្អាតផង ។ ម្នាលចុន្ទ មួយទៀត ព្រោះហេតុនៃការប្រកបដោយអកុសលកម្មបថទាំង ១០ ប្រការនេះ នរកក៏ប្រាកដ តិរច្ឆានក៏ប្រាកដ បិត្តិវិស័យក៏ប្រាកដឡើង ឬក៏មានទុគ្គតិ ( ដំណើរអាក្រក់ ) ក្រៅពីនេះ ណាមួយ ( មានទៀតមិនខាន ) ។ ម្នាលចុន្ទ ការស្អាតដោយកាយមាន ៣ ប្រការ ការស្អាតដោយវាចាមាន ៤ ប្រការ ការស្អាតដោយចិត្តមាន ៣ ប្រការ ។ ម្នាលចុន្ទ ចុះការស្អាតដោយកាយមាន ៣ ប្រការ តើដូចម្តេច ។ ម្នាលចុន្ទ បុគ្គលខ្លះ ក្នុងលោកនេះ លះបង់នូវបាណាតិបាត វៀរស្រឡះចាកបាណាតិបាត ជាអ្នកដាក់ចុះនូវអាជ្ញា ដាក់ចុះនូវគ្រឿងសស្ត្រាវុធ ប្រកបដោយសេចក្តីខ្មាស ដល់នូវមេត្តាចិត្ត ជាអ្នកអនុគ្រោះដោយប្រយោជន៍ ចំពោះពួកសត្វទាំងអស់ ១ ជាអ្នកលះបង់អទិន្នាទាន វៀរស្រឡះចាកអទិន្នាទាន ជាអ្នកមិនកាន់យកនូវគ្រឿងឧបករណ៍ ដែលជាសម្បត្តិនៃបុគ្គលដទៃ គេទុកក្នុងស្រុកក្តី ទុកក្នុងព្រៃក្តី ដែលគេមិនបានឲ្យ ដោយចិត្តលួចឡើយ ១ ជាអ្នកលះបង់កាមេសុមិច្ឆាចារ វៀរស្រឡះចាកកាមេសុ-មិច្ឆាចារ ជាអ្នកមិនដល់នូវការប្រព្រឹត្តកន្លងក្នុងស្ត្រីទាំងឡាយ ដែលមានមាតារក្សា បិតារក្សា បងប្អូនប្រុសរក្សា បងប្អូនស្ត្រីរក្សា ញាតិរក្សា ត្រកូលប្រកបដោយធម៌រក្សា ជាស្ត្រីមានប្តី មានអាជ្ញា ( កំណត់ទុក ) ដោយហោច

ទៅ សូម្បីតែស្ត្រីដែលបុរសបំពាក់កម្រងផ្កាឲ្យ ១ ។ ម្នាលចុន្ទ ការស្អាត ដោយកាយមាន ៣ ប្រការ យ៉ាងនេះឯង ។ ម្នាលចុន្ទ ចុះការស្អាតដោយ វាចាមាន ៤ ប្រការ តើដូចម្តេច ។ ម្នាលចុន្ទ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកលះបង់មុសាវាទ វៀរស្រឡះចាកមុសាវាទ ទោះបីឋិតនៅក្នុងរោងក្តី ឋិតនៅក្នុងបរិសទ្យក្តី ឋិតនៅក្នុងកណ្តាលញាតិក្តី ឋិតនៅក្នុងកណ្តាលសេនីក្តី ឋិតនៅក្នុងកណ្តាលរាជត្រកូលក្តី ដែលគេនាំទៅធ្វើជាសាក្សីហើយសួរថា នែបុរសអើយ ចូរអ្នកមកអាយ បើអ្នកដឹងហេតុណា ចូរនិយាយប្រាប់ហេតុនោះ បុគ្គលនោះ កាលមិនដឹង ក៏និយាយថា ខ្ញុំមិនដឹង កាលដឹងនិយាយថា ខ្ញុំដឹង កាលមិនឃើញ និយាយថា ខ្ញុំមិនឃើញ ឬកាលឃើញ និយាយថា ខ្ញុំឃើញ ជាអ្នកមិនពោលពាក្យកុហកទាំងដឹង ដូច្នេះ ព្រោះហេតុតែខ្លួនក្តី ហេតុអ្នកដទៃក្តី ព្រោះហេតុសំណូក គឺអាមិសបន្តិចបន្តួចក្តី ១ ជាអ្នកលះបង់បិសុណាវាចា វៀរស្រឡះចាកបិសុណាវាចា ឮពាក្យអំពីសម្នាក់ជននេះហើយមិននាំទៅប្រាប់ជនឯណោះ ដើម្បីនឹងបំបែកជនទាំងនេះ ឬឮពាក្យអំពីសម្នាក់ជនឯណោះ ហើយមិននាំមកប្រាប់ជនទាំងនេះ ដើម្បីនឹងបំបែកជនឯណោះ ជាអ្នកផ្សះផ្សានូវពួកជនដែលបែកគ្នាផង ជាអ្នកទំនុកបម្រុងនូវពួកជនដែលរួបរួមគ្នាផង ជាអ្នកត្រេកអរក្នុងសេចក្តីព្រមព្រៀងគ្នាផង ជាអ្នកមានតម្រេកតែក្នុងសេចក្តីព្រមព្រៀងគ្នា ជាអ្នករីករាយក្នុងសេចក្តីព្រមព្រៀងគ្នា ពោលនូវវាចាដែលធ្វើឲ្យកើតសេចក្តីព្រមព្រៀងគ្នា ដោយប្រការដូច្នេះ ១ ជាអ្នក

លះបង់ផរុសវាចា វៀរស្រឡះចាកផរុសវាចា ជាអ្នកពោលតែវាចាមិនមានទោស ជាសុខដល់ត្រចៀក គួរឲ្យកើតសេចក្ដីស្រឡាញ់ ចូលទៅកាន់ហឫទ័យ ជាវាចាអ្នកបុរី ជាទីស្រឡាញ់នៃជនច្រើន ជាទីពេញចិត្តនៃជនច្រើន ១ ជាអ្នកលះបង់សម្ផប្បលាប វៀរស្រឡះចាកសម្ផប្បលាប ពោលពាក្យត្រូវតាមកាល ពោលពាក្យពិត ពោលពាក្យដែលជាអត្ថ ពោលពាក្យដែលជាធម៌ ពោលពាក្យដែលជាវិន័យ ពោលពាក្យដែលគួរតាំងទុកក្នុងហឫទ័យ ជាពាក្យត្រូវតាមកាលវេលា ប្រកបដោយគ្រឿងអាង ជាវាចាមានទីបំផុត ប្រកបដោយប្រយោជន៍ ១ ។ ម្នាលចុន្ទ ការស្អាតដោយវាចាមាន ៤ ប្រការយ៉ាងនេះឯង ។ ម្នាលចុន្ទ ចុះការស្អាតដោយចិត្តមាន ៣ ប្រការ តើដូចម្ដេច ។ ម្នាលចុន្ទ បុគ្គលខ្លះ ក្នុងលោកនេះ មិនមានអភិជ្ឈា ជាអ្នកមិនគយគន់នូវគ្រឿងឧបករណ៍ ដែលជាទ្រព្យសម្បត្តិនៃបុគ្គលដទៃ ដោយគិតថា ឱហ្ន៎ គ្រឿងឧបករណ៍ ដែលជាទ្រព្យសម្បត្តិនៃបុគ្គលណា គ្រឿងឧបករណ៍នោះគប្បីបានមកអញ ដូច្នេះឡើយ ១ ជាអ្នកមានចិត្តមិនព្យាបាទ គឺជាមនុស្សមានតម្រិះក្នុងចិត្ត ដែលទោសមិនប្រទូស្តហើយថា សត្វទាំងឡាយនេះ កុំមានពៀរនឹងគ្នា កុំព្យាបាទគ្នា កុំមានទុក្ខ ចូររក្សាខ្លួនឲ្យបានសេចក្ដីសុខចុះ ១ ជាអ្នកមានសេចក្ដីយល់ត្រូវ គឺជាមនុស្សយល់ឃើញនូវសេចក្ដីមិនវិបរិតថា ទានដែលបុគ្គលឲ្យហើយ មានផល ការបូជាធំ មានផល ការបូជាតូច មានផល ផលវិបាកនៃកុសលាកុសលកម្ម ដែលសត្វធ្វើល្អ ធ្វើអាក្រក់ មាន

លោកនេះ មាន លោកខាងមុខ មាន មាតា មាន បិតា មាន ពួកសត្វទាំងឡាយ ជាឱបបាតិកកំណើតមាន ពួកសមណព្រាហ្មណ៍ក្នុងលោក ដែលជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិដោយត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តមរបស់ខ្លួនឯង ហើយសម្តែងប្រាប់ មាន ១ ។ ម្នាលចុន្ទ ការស្អាតដោយចិត្ត មាន ៣ ប្រការ យ៉ាងនេះឯង ។ ម្នាលចុន្ទ ការស្អាតទាំង ១០ ប្រការនេះ ហៅថា កុសលកម្មបថ ១០ ។ ម្នាលចុន្ទ បុគ្គលដែលប្រកបដោយកុសលកម្មបថទាំង ១០ នេះហើយ បើទុកជាក្រោកឡើងអំពីដំណេកក្នុងវេលាព្រឹកព្រហាម ហើយស្ទាបផែនដីក្តី ក៏នៅជាមនុស្សស្អាតដដែល បើទុកជាមិនស្ទាបផែនដីក្តី ក៏នៅស្អាតដដែល បើទុកជាស្ទាបអាចម៍គោស្រស់ក្តី ក៏នៅស្អាតដដែល បើទុកជាមិនស្ទាបអាចម៍គោស្រស់ក្តី ក៏នៅស្អាតដដែល បើទុកជាស្ទាបស្មៅស្រស់ក្តី ក៏នៅស្អាតដដែល បើទុកជាមិនស្ទាបស្មៅស្រស់ក្តី ក៏នៅស្អាតដដែល បើទុកជាបម្រើភ្លើងក្តី ក៏នៅស្អាតដដែល បើទុកជាមិនបម្រើភ្លើងក្តី ក៏នៅស្អាតដដែល បើទុកជាប្រណម្យអញ្ជលី នមស្ការព្រះអាទិត្យក្តី ក៏នៅស្អាតដដែល បើទុកជាមិនប្រណម្យអញ្ជលី នមស្ការព្រះអាទិត្យក្តី ក៏នៅតែស្អាតដដែល បើទុកជាចុះត្រាំទឹកជាគម្រប់ ៣ ដងនឹងពេលល្ងាចក្តី ក៏នៅតែស្អាតដដែល បើទុកជាមិនចុះត្រាំទឹកជាគម្រប់ ៣ ដងនឹងពេលល្ងាចក្តី ក៏នៅតែស្អាតដដែល ។ ដំណើរនោះ តើព្រោះហេតុអ្វី ។ ម្នាលចុន្ទ ព្រោះកុសលកម្មបថទាំង ១០ ប្រការ

នេះឯង ជាគន្លងស្អាតផង ជាផ្លូវក៏ឲ្យកើតរបស់ស្អាតផង ។ ម្នាលចុន្ទ មួយទៀត ព្រោះហេតុនៃការប្រកបព្រមដោយកុសលកម្មបថទាំង ១០ ប្រការនេះ ទេវតាក៏ប្រាកដ មនុស្សក៏ប្រាកដ ឬក៏មានសុគតិ ( ដំណើរល្អ ) ក្រៅពីនេះណាមួយ ( មានទៀតមិនខាន ) ។ កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ចុន្ទកម្មារបុត្រ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ចាំទុកនូវខ្ញុំព្រះអង្គ ថាជាឧបាសក អ្នកដល់នូវសរណៈ ស្មើដោយជីវិត ចាប់ដើមអំពីថ្ងៃនេះតទៅ ។

# អដ្ឋកថា

## ចុន្ទសូត្រ

[ ៦៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចុន្ទសូត្រទី ១០ ដូចតទៅនេះ បទថា **កម្មារបុត្តស្ស** ប្រែថា កូនជាងមាស ។ ពាក្យថា **កស្ស នោ ត្វំ** កាត់បទជា **កស្ស នុ ត្វំ**។ បទថា **បច្ឆាភូមិកា** ប្រែថា អ្នកបច្ឆាភូមិ ។ បទថា **កមណ្ឌលុកា** ប្រែថា ពាក់កុណ្ឌល ។ បទថា **សេវាលមាលកា** បានដល់ រមែងទ្រទ្រង់ ដូចពាក់កម្រងមាល័យ ធ្វើអំពីសារាយ ដូច្នោះ ទើបហៅថា ស្លៀកសំពត់សារាយក៏មាន ។ បទថា **ឧទកោរោហកា** បានដល់ ការចុះ

ផ្ទុតទឹកព្រឹកល្ងាច ។ បទថា **អាមសេយ្យាសិ** ប្រែថា គប្បីពាល់ត្រូវដោយដៃ ។ល។

## អដ្ឋកថាចុន្ទសូត្រទី ១០ ចប់

# សុត្តន្តបិដក

## ជាណុស្សោណិសូត្រទី ១១

[ ៦៦ ] លំដាប់នោះ ជាណុស្សោណិព្រាហ្មណ៍ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭក នាំឲ្យកើតសេចក្តីស្និទ្ធស្នាលហើយ អង្គុយក្នុងទីសមគួរ ។ លុះជាណុស្សោណិព្រាហ្មណ៍អង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន យើងជាព្រាហ្មណ៍តែងឲ្យទាន តែងធ្វើអំពើដែលគេគប្បីធ្វើ ដោយសទ្ធាហើយឧទ្ទិសថា ទាននេះសូមឲ្យសម្រេចផល ដល់ប្រេតទាំងឡាយ ជាញាតិសាលោហិត ពួកប្រេតទាំងឡាយ ជាញាតិសាលោហិត សូមបរិភោគនូវទាននេះ បពិត្រព្រះគោតមដ៏ចម្រើន ចុះទាននោះនឹងសម្រេចផលដល់ប្រេតទាំងឡាយ ជាញាតិសាលោហិតដែរឬទេ ប្រេតទាំងឡាយជាញាតិសាលោហិតនោះ នឹងបរិភោគនូវទាននោះ បានដែរឬទេ ។ ព្រះមានព្រះភាគទ្រង់ត្រាស់តប

ថា ម្នាលព្រាហ្មណ៍ ទាននេះសម្រេចផលក្នុងទីគួរ មិនសម្រេចផល ក្នុងទីមិនគួរ ។ បពិត្រព្រះគោតមដ៏ចម្រើន ទីដែលគួរ តើដូចម្ដេច ទីដែលមិនគួរ តើដូចម្ដេច ។ ម្នាលព្រាហ្មណ៍ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ពោលពាក្យកុហក ពោលពាក្យញុះញង់ ពោលពាក្យអាក្រក់ ពោលពាក្យឥតប្រយោជន៍ ជាអ្នកច្រើនដោយអភិជ្ឈា មានចិត្តព្យាបាទ មានសេចក្ដីយល់ខុស បុគ្គលនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ ក៏ទៅកើតក្នុងនរក អាហារណា ជាអាហារសម្រាប់សត្វទាំងឡាយ កើតក្នុងនរក សត្វនរកនោះ តែងញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅ ក្នុងនរកនោះ ដោយសារអាហារនោះ សត្វនរកនោះ ឋិតនៅក្នុងនរកនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះ មិនសម្រេចផល ដល់សត្វដែលឋិតនៅ ក្នុងទីណា ទីនេះឯង ហៅថា ទីមិនគួរ ។ ម្នាលព្រាហ្មណ៍មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។បេ។ មានសេចក្ដីយល់ខុស បុគ្គលនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ ក៏ទៅកើត ក្នុងកំណើតនៃតិរច្ឆាន អាហារណា ជាអាហារ សម្រាប់សត្វទាំងឡាយ ដែលកើតក្នុងកំណើតតិរច្ឆាន សត្វតិរច្ឆាននោះ ក៏ញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ សត្វតិរច្ឆាននោះ ឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះ មិនសម្រេចផល ដល់សត្វដែលឋិតនៅក្នុងទីណា ទីនេះឯង ហៅថា ទីមិនគួរ ។ ម្នាលព្រាហ្មណ៍ ចំណែកឯបុគ្គល

ខ្លះ ក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន វៀរស្រឡះចាកមុសាវាទ វៀរស្រឡះចាកបិសុណាវាចា វៀរស្រឡះចាកផរុសវាចា វៀរស្រឡះចាកសម្ផប្បលាប ជាអ្នកមិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ មានសេចក្តីយល់ត្រូវ បុគ្គលនោះលុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងពួកមនុស្ស អាហារណា ជាអាហារសម្រាប់ពួកមនុស្ស បុគ្គលនោះ ក៏ញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ បុគ្គលនោះ ឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះមិនសម្រេចផល ដល់សត្វដែលឋិតនៅក្នុងទីណា ទីនេះឯង ហៅថា ទីមិនគួរ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកបាណាតិបាត ។បេ។ មានសេចក្តីយល់ត្រូវ បុគ្គលនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ ក៏ទៅកើតក្នុងពួកទេវតា អាហារណាជាអាហារសម្រាប់ពួកទេវតា ទេវតានោះ ក៏ញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅ ក្នុងទីនោះ ដោយអាហារនោះ ទេវតានោះ ឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះ មិនសម្រេចផល ដល់សត្វដែលឋិតនៅក្នុងទីណា ទីនេះឯង ហៅថា ទីមិនគួរ ។ ម្នាលព្រាហ្មណ៍ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។បេ។ មានសេចក្តីយល់ខុស បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងបិត្តិវិស័យ អាហារណា ជាអាហារសម្រាប់សត្វទាំងឡាយ ដែលកើតក្នុងបិត្តិវិស័យ ប្រេតនោះ ក៏ញុំាងអត្តភាព ឲ្យប្រព្រឹត្ត

ទៅ ក្នុងទីនោះ ដោយអាហារនោះ ប្រេតនោះ ឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ ឬក៏ពួកមិត្រអាមាត្យក្តី ជនជាញាតិសាលោហិតក្តី ឧទ្ទិសឲ្យនូវទានណា ដល់ប្រេតនោះ អំពីលោកនេះ ប្រេតនោះ ក៏ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ ប្រេតនោះ ឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះ សម្រេចផល ដល់សត្វដែលឋិតនៅក្នុងទីណា ទីនេះឯង ហៅថាទីគួរ ។ ជាណុស្សោណិព្រាហ្មណ៍ក្រាបទូលសួរថា បពិត្រព្រះគោតមដ៏ចម្រើន ចុះប្រសិនបើប្រេតជាញាតិសា-លោហិតនោះ មិនបានទៅកើត ក្នុងទីនោះទេ តើអ្នកណាបរិភោគទាននោះ ។ អើព្រាហ្មណ៍ ពួកប្រេតដែលជាញាតិសាលោហិតដទៃទៀតរបស់គេ គង់ទៅកើតក្នុងទីនោះមិនខាន ប្រេតទាំងនោះឯង បរិភោគទាននោះ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះប្រសិនបើប្រេតជាញាតិសាលោហិតនោះ មិនបានទៅកើតក្នុងទីនោះទេ ទាំងពួកប្រេតជាញាតិសាលោហិតដទៃទៀតរបស់គេ ក៏មិនបានទៅកើតក្នុងទីនោះដែរ តើអ្នកណា បរិភោគទាននោះ ។ នែព្រាហ្មណ៍ ទីណាដែលស្ងាត់ចាកប្រេតទាំងឡាយ ជាញាតិសាលោហិត ដោយកាលជាយូរអង្វែងនេះ ទីនោះ មិនមែនជាហេតុ មិនមែនជាឱកាស គឺថា មិនធ្លាប់មានឡើយ ម្នាលព្រាហ្មណ៍ មួយទៀត ធម្មតាអ្នកឲ្យទាន មិនមែនជាគ្មានផលទេ ។ ឱ ព្រះគោតមដ៏ចម្រើន ពោលកំណត់ ក្នុងទីមិនគួរបានដែរតើ ។ អើព្រាហ្មណ៍ តថាគតពោលកំណត់ក្នុងទីមិនគួរបានដែរ ម្នាលព្រាហ្មណ៍ បុគ្គល

ខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាម ពោលពាក្យកុហក ពោលពាក្យញុះញង់ ពោលពាក្យអាក្រក់ ពោលពាក្យឥតប្រយោជន៍ ជាអ្នកច្រើនដោយអភិជ្ឈា មានចិត្តព្យាបាទ មានសេចក្តីយល់ខុស ប៉ុន្តែ បុគ្គលនោះ ជាអ្នកឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ គ្រឿងឧបករណ៍របស់ប្រទីប ដល់សមណៈ ឬព្រាហ្មណ៍ បុគ្គលនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ ក៏ទៅកើតជាមួយពួកដំរី ឯដំរីនោះ ជាសត្វតែងស្វាក់បាយ ទឹក កម្រងផ្កា និងគ្រឿងឧបករណ៍ផ្សេងៗ ក្នុងកំណើតនៃដំរីនោះ ម្នាលព្រាហ្មណ៍ ត្រង់ដែលបុគ្គលក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាម ពោលពាក្យកុហក ពោលពាក្យញុះញង់ ពោលពាក្យអាក្រក់ ពោលពាក្យឥតប្រយោជន៍ ជាអ្នកច្រើនដោយអភិជ្ឈា មានចិត្តព្យាបាទ មានសេចក្តីយល់ខុស ជាទោសនាំឲ្យបុគ្គលនោះបែកធ្លាយរាងកាយ ស្លាប់ទៅ ទៅកើតជាមួយនឹងពួកដំរី ត្រង់ដែលបុគ្គលនោះ ជាអ្នកឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ គ្រឿងឧបករណ៍របស់ប្រទីប ដល់សមណៈ ឬព្រាហ្មណ៍ ជាគុណបណ្តាលឲ្យបុគ្គលនោះជាសត្វតែងស្វាក់បាយ ទឹក កម្រងផ្កា គ្រឿងប្រដាប់ផ្សេងៗ ក្នុងកំណើតនៃដំរីនោះ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាម ពោលពាក្យកុហក ពោលពាក្យញុះញង់

ពោលពាក្យអាក្រក់ ពោលពាក្យឥតប្រយោជន៍ ជាអ្នកច្រើនដោយអភិជ្ឈា មានចិត្តព្យាបាទ មានសេចក្ដីយល់ខុស ប៉ុន្តែ បុគ្គលនោះជាអ្នកឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ គ្រឿងឧបករណ៍របស់ប្រទីបដល់សមណៈ ឬព្រាហ្មណ៍ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាមួយពួកសេះ ... កើតជាមួយពួកគោ ... កើតជាមួយពួកឆ្កែ ឯសត្វនោះ តែងស្វាក់បាយ ទឹក កម្រងផ្កា និងគ្រឿងប្រដាប់ផ្សេងៗ ម្នាលព្រាហ្មណ៍ ត្រង់ដែលបុគ្គលក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ពោលពាក្យកុហក ពោលពាក្យញុះញង់ ពោលពាក្យអាក្រក់ ពោលពាក្យឥតប្រយោជន៍ ជាអ្នកច្រើនដោយអភិជ្ឈា មានចិត្តព្យាបាទ មានសេចក្ដីយល់ខុស ជាទោសនាំឲ្យបុគ្គលនោះ បែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតជាមួយនឹងពួកឆ្កែ ត្រង់ដែលបុគ្គលនោះ ជាអ្នកឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ គ្រឿងឧបករណ៍របស់ប្រទីបដល់សមណៈ ឬព្រាហ្មណ៍ ជាគុណនាំឲ្យបុគ្គលនោះ ជាសត្វតែងស្វាក់បាយ ទឹក កម្រងផ្កា គ្រឿងប្រដាប់ផ្សេងៗ ក្នុងកំណើតឆ្កែនោះ ។ ម្នាលព្រាហ្មណ៍ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន វៀរស្រឡះចាកកាមេសុមិច្ឆាចារ វៀរស្រឡះចាកមុសាវាទ វៀរស្រឡះចាកបិសុណាវាចា វៀរស្រឡះចាកផរុសវាចា វៀរស្រឡះចាកសម្ផប្បលាប ជា

អ្នកមិនមានអភិជ្ឈា មានចិត្តមិនព្យាបាទ មានសេចក្តីយល់ត្រូវ បុគ្គលនោះ ជាអ្នកឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ គ្រឿងឧបករណ៍របស់ប្រទីបដល់សមណៈ ឬព្រាហ្មណ៍ លុះ បុគ្គលនោះ បែកធ្លាយរាងកាយ ស្លាប់ទៅ ក៏ទៅកើតជាមួយនឹងពួកមនុស្ស បុគ្គលនោះ តែងស្វាក់នូវកាមគុណ ៥ ជារបស់មនុស្ស ក្នុងកំណើតនៃ មនុស្សនោះ ម្នាលព្រាហ្មណ៍ ត្រង់ដែលបុគ្គលក្នុងលោកនេះ ជាអ្នកវៀរ ស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន វៀរស្រឡះចាកកាមេ-សុមិច្ឆាចារ វៀរស្រឡះចាកមុសាវាទ វៀរស្រឡះចាកបិសុណាវាចា វៀរ ស្រឡះចាកផរុសវាចា វៀរស្រឡះចាកសម្ផប្បលាប ជាអ្នកមិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ មានសេចក្តីយល់ត្រូវ ជាគុណនាំឲ្យបុគ្គលនោះ បែក ធ្លាយរាងកាយស្លាប់ទៅ ទៅកើតជាមួយនឹងពួកមនុស្ស ត្រង់ដែលបុគ្គលជា អ្នកឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ គ្រឿងឧបករណ៍របស់ប្រទីបដល់សមណៈ ឬព្រាហ្មណ៍ ជាគុណ បណ្តាលឲ្យបុគ្គលនោះ ទៅជាអ្នកស្វាក់នូវកាមគុណ ៥ ជារបស់មនុស្ស ក្នុងកំណើតនៃមនុស្សនោះ ។ ម្នាលព្រាហ្មណ៍ បុគ្គលខ្លះក្នុងលោកនេះ វៀរ ស្រឡះចាកបាណាតិបាត ។បេ។ មានសេចក្តីយល់ត្រូវ ប៉ុន្តែ បុគ្គលនោះ ជាអ្នកឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ គ្រឿងឧបករណ៍របស់ប្រទីបដល់សមណៈ ឬព្រាហ្មណ៍ បុគ្គល

នោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាមួយពួកទេវតា ទេវតានោះជាអ្នកស្វាក់នូវកាមគុណ ៥ ជាទិព្វ ក្នុងទេវលោកនោះ ម្នាលព្រាហ្មណ៍ ត្រង់ដែលបុគ្គលក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកបាណាតិបាត ។បេ។ មានសេចក្តីយល់ត្រូវ ជាគុណនាំឲ្យបុគ្គលនោះ បែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតជាមួយពួកទេវតា ត្រង់ដែលបុគ្គលនោះ ជាអ្នកឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ គ្រឿងឧបករណ៍ របស់ប្រទីបដល់សមណៈ ឬព្រាហ្មណ៍ ជាគុណនាំឲ្យបុគ្គលនោះ ជាអ្នកស្វាក់នូវកាមគុណ ៥ ជាទិព្វ ក្នុងទេវលោកនោះ ម្នាលព្រាហ្មណ៍ ក៏ធម្មតាអ្នកឲ្យទាន មិនមែនជាគ្មានផលឡើយ ។ ជាណុស្សោណិព្រាហ្មណ៍ទូលថា បពិត្រព្រះគោតមដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះគោតមដ៏ចម្រើន ចម្លែកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ដំណើរនេះ គួរណាស់តែឲ្យទាន គួរណាស់តែធ្វើអំពើដែលគេគប្បីធ្វើដោយសទ្ធា ព្រោះថា អ្នកឲ្យទាន មិនមែនជាគ្មានផលឡើយ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា អើព្រាហ្មណ៍ ដំណើរនុ៎ះ យ៉ាងហ្នឹងឯង អើព្រាហ្មណ៍ ដំណើរនុ៎ះ យ៉ាងហ្នឹងឯង អើព្រាហ្មណ៍ អ្នកឲ្យទាន មិនមែនជាគ្មានផលទេ ។ ជាណុស្សោណិព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ ។បេ។ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គ ថាជាឧបាសក អ្នកដល់នូវសរណៈ ស្មើដោយជីវិត ចាប់ដើមពីថ្ងៃនេះតទៅ ។

ជាណុស្សោណិវគ្គទី ២ ចប់

# អដ្ឋកថា

## ជាណុស្សោណិសូត្រ

[ ៦៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងជាណុស្សោណិសូត្រទី ១១ ដូចតទៅនេះ បទថា **ឧបកប្បតុ** ប្រែថា សម្រេច ។ បទថា **ឋានេ** បានដល់ ក្នុងឱកាស ។ បទថា **នោ អដ្ឋានេ** បានដល់ មិនមែនជាអដ្ឋានៈ ។ កម្មដែលឲ្យកើតក្នុងនរកនោះឯង ឈ្មោះថា អាហាររបស់ពួកសត្វនរក ដ្បិតថា ពួកសត្វនរកនោះ ប្រព្រឹត្តទៅបានក្នុងនរកនោះ ដោយកម្មនោះឯង ។ ឯអាហាររបស់ពួកសត្វតិរច្ឆាន ក៏គប្បីជ្រាប គឺស្មៅជាដើម ។ របស់ពួកមនុស្សមានបាយ នំស្រស់ជាដើម របស់ទេវតា គឺសុធាភោជនដែលជាអាហារទិព្វជាដើម របស់ពួកសត្វដែលកើតក្នុងបិត្តិវិស័យ គឺទឹកមាត់ ទឹកសម្បោរជាដើម ។ បទថា **យំ វា បនស្ស ឥតោ អនុប្បវេច្ឆន្តិ** សេចក្តីថា ពួកមិត្រជាដើមឲ្យទាន ឧទ្ទិសផលទៅឯណាទៅ អំពីលោកនេះ ។ ពួកសត្វដែលកើតក្នុងបិត្តិវិស័យប៉ុណ្ណោះ រមែងរស់នៅបានដោយផលបុណ្យនោះដែលបុគ្គលដទៃឧទ្ទិសទៅឲ្យ ។ ផលបុណ្យដែលមនុស្សទាំងនោះឧទ្ទិសឲ្យមិនសម្រេចដល់សត្វដទៃ ។

បទថា **ទាយកោបិ អនិប្ផលោ** សេចក្តីថា ទានដែលថ្វាយនោះ សំដៅយកសត្វណា សម្រេច ឬមិនសម្រេចក៏ដោយ ចំណែកទាយកក៏មិនឥតផល ទាយករមែងបានផលនៃទាននោះពិត ។ ក្នុងបទថា **អដ្ឋានេបិ ភវំ គោតមោ**

**បរិកប្បំ វទតិ** សេចក្តីថា ជាណុស្សោណិព្រាហ្មណ៍សួរថា កាលញាតិនោះមិនកើតឡើង ក្នុងទីមិនមែនឱកាស ព្រះគោតមនៅតែបញ្ញត្តថា ផលទានគង់សម្រេចទៀតឬ ។ ពិតហើយ ព្រាហ្មណ៍មានលទ្ធិប្រកាន់ថា ផលទានដែលឲ្យយ៉ាងនេះ ទាយកដែលឲ្យរមែងមិនបាន ។ កាលនោះ ព្រះមានព្រះភាគ ទ្រង់យល់បញ្ហារបស់ជាណុស្សោណិព្រាហ្មណ៍នោះ ដើម្បីទ្រង់សម្តែងថា ធម្មតាទាយកកើតក្នុងទីណាមួយ អាស្រ័យផលបុណ្យចិញ្ចឹមជីវិតក្នុងទីណាមួយ រមែងបានផលនៃទានទាំងនោះ ទើបត្រាស់ថា **ឥធ ព្រាហ្មណ** ជាដើម ។ បទថា **សោ តត្ថ លាភី ហោតិ** សេចក្តីថា ទាយកនោះសូម្បីកើតក្នុងកំណើតដំរី កំណើតតិរច្ឆាននោះ ក៏បានគ្រឿងជាមង្គលហត្ថី សូម្បីក្នុងសត្វ មានសេះជាដើម ក៏ន័យនេះដូចគ្នា ។៚

## អដ្ឋកថា ជាណុស្សោណិសូត្រទី ១១ ចប់

## ជាណុស្សោណិវគ្គទី ២ ចប់

# សុត្តន្តបិដក

# សុទ្ធវគ្គទី ៣

## សាធុអសាធុសូត្រទី ១

[ ៦៧ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងកម្មល្អផង កម្មមិនល្អផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ ទទួលតបព្រះមានព្រះភាគដូច្នេះថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ កម្មមិនល្អ តើដូចម្តេច ។ គឺបាណាតិបាត អទិន្នាទាន កាមេសុ-មិច្ឆាចារ មុសាវាទ បិសុណាវាចា ផរុសវាចា សម្ផប្បលាប អភិជ្ឈា ព្យាបាទ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មមិនល្អ ។ ម្នាលភិក្ខុទាំងឡាយ កម្មល្អ តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកបិសុណ-វាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាប ការមិនមានអភិជ្ឈា មិនមានព្យាបាទ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មល្អ ។

## អរិយានរិយធម្មសូត្រទី ២

[ ៦៨ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងអរិយធម៌ ( ធម៌ដ៏ប្រសើរ ) ផង អនរិយធម៌ ( ធម៌មិនប្រសើរ ) ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសម្តែង ។

ភិក្ខុទាំងនោះ ទទួលតបព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អនរិយធម៌ តើដូចម្តេច ។ គឺបាណាតិបាត ។បេ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អនរិយធម៌ ។ ម្នាលភិក្ខុទាំងឡាយ អរិយធម៌ តើដូចម្តេច ។ គឺចេតនា ជាហេតុវៀរចាកបាណាតិបាត ។បេ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អរិយធម៌ ។

## កុសលាកុសលសូត្រទី ៣

[ ៦៩ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងកុសលកម្មផង អកុសលកម្មផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ ទទួលតបព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អកុសលកម្ម តើដូចម្តេច ។ គឺបាណាតិបាត ។បេ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អកុសលកម្ម ។ ម្នាលភិក្ខុទាំងឡាយ កុសលកម្ម តើដូចម្តេច ។ គឺចេតនា ជាហេតុវៀរចាកបាណាតិបាត ។បេ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កុសលកម្ម ។

## អត្ថានត្ថសូត្រទី ៤

[ ៧០ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងធម៌ដែលមានប្រយោជន៍ផង ឥតប្រយោជន៍ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ

ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ ទទួលតបព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ឥតប្រយោជន៍ តើដូចម្តេច ។ គឺបាណាតិបាត ។បេ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ ធម៌មានប្រយោជន៍ តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។បេ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌មានប្រយោជន៍ ។

## ធម្មាធម្មសូត្រទី ៥

[ ៧១ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវធម៌ផង នូវអធម៌ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ ទទួលតបព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អធម៌ តើដូចម្តេច ។ គឺបាណាតិបាត ។បេ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អធម៌ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។បេ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ ។

## សាសវានាសវសូត្រទី ៦

[ ៧២ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវសាសវធម៌ ( ធម៌

ប្រកបដោយអាសវៈ ) ផង អនាសវធម៌ ( ធម៌មិនមានអាសវៈ ) ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ ទទួលតបព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ សាសវធម៌ តើដូចម្តេច ។ គឺបាណាតិបាត ។បេ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សាសវធម៌ ។ ម្នាលភិក្ខុទាំងឡាយ អនាសវធម៌ តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។បេ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អនាសវធម៌ ។

## សាវជ្ជានវជ្ជសូត្រទី ៧

[ ៧៣ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវសាវជ្ជធម៌ ( ធម៌ប្រកបដោយទោស ) ផង អនវជ្ជធម៌ ( ធម៌មិនមានទោស ) ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ ទទួលតបព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ សាវជ្ជធម៌ តើដូចម្តេច ។ គឺបាណាតិបាត ។បេ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំង-ឡាយ នេះហៅថា សាវជ្ជធម៌ ។ ម្នាលភិក្ខុទាំងឡាយ អនវជ្ជធម៌ តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។បេ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អនវជ្ជធម៌ ។

# តបនិយាតបនិយធម្មសូត្រទី ៨

[ ៧៤ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវតបនិយធម៌ ( ធម៌ដែលធ្វើសត្វឲ្យក្តៅ ) ផង អតបនិយធម៌ ( ធម៌ដែលមិនធ្វើសត្វឲ្យក្តៅ ) ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ តបនិយធម៌ តើដូចម្តេច ។ គឺបាណាតិបាត ។បេ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំង-ឡាយ នេះហៅថា តបនិយធម៌ ។ ម្នាលភិក្ខុទាំងឡាយ អតបនិយធម៌ តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។បេ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អតបនិយធម៌ ។

# អាចយគាមយាបចយគាមិធម្មសូត្រទី ៩

[ ៧៥ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងអាចយគាមិធម៌ ( ធម៌ដល់នូវការសន្សំបាប ) ផង អបចយគាមិធម៌ ( ធម៌មិនដល់នូវការសន្សំបាប ) ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ ទទួលតបព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អាចយគាមិធម៌ តើដូចម្តេច ។ គឺបាណាតិបាត ។បេ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អាចយគាមិធម៌ ។ ម្នាលភិក្ខុទាំងឡាយ អបចយ-គាមិធម៌ តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។បេ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អបចយគាមិធម៌ ។

## ទុក្ខុទ្រយសុខុទ្រយធម្មសូត្រទី ១០

[ ៧៦ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវទុក្ខុទ្រយធម៌ ( ធម៌ចម្រើនសេចក្ដីទុក្ខ ) ផង សុខុទ្រយធម៌ ( ធម៌ចម្រើនសេចក្ដីសុខ ) ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្ដាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះ ទទួលតបព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ទុក្ខុទ្រយធម៌ តើដូចម្ដេច ។ គឺបាណាតិបាត ។បេ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុក្ខុទ្រយធម៌ ។ ម្នាលភិក្ខុទាំងឡាយ សុខុទ្រយធម៌ តើដូចម្ដេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។បេ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សុខុទ្រយធម៌ ។

## ទុក្ខវិបាកសុខវិបាកសូត្រទី ១១

[ ៧៧ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវទុក្ខវិបាកធម៌ ( ធម៌ឲ្យផលជាទុក្ខ ) ផង សុខវិបាកធម៌ ( ធម៌ឲ្យផលជាសុខ ) ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្ដាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងឡាយនោះ ទទួលតបព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ

ទុក្ខវិបាកធម៌ តើដូចម្ដេច ។ គឺបាណាតិបាត ។បេ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំង-ឡាយ នេះហៅថា ទុក្ខវិបាកធម៌ ។ ម្នាលភិក្ខុទាំងឡាយ សុខវិបាកធម៌ តើដូចម្ដេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។បេ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សុខវិបាកធម៌ ។

សុន្ទរវគ្គទី ៣ ចប់

# អដ្ឋកថា

# សុន្ទរវគ្គទី ៣

[ ៦៧-៧៧ ] អដ្ឋកថាសុន្ទរវគ្គទី ៣ មានអត្ថងាយយល់ហើយ ។

**អដ្ឋកថា សុន្ទរវគ្គទី ៣ ចប់**

**ចតុត្ថបណ្ណាសក ចប់**

# សុត្តន្តបិដក

# សេដ្ឋវគ្គទី ៤

## អរិយមគ្គានរិយមគ្គសូត្រទី ១

[ ៧៨ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងផ្លូវដ៏ប្រសើរផង ផ្លូវមិនប្រសើរផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ ផ្លូវមិនប្រសើរ តើដូចម្តេច ។ គឺបាណាតិបាត ។បេ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ផ្លូវមិនប្រសើរ ។ ម្នាលភិក្ខុទាំង-ឡាយ ផ្លូវប្រសើរ តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។បេ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ផ្លូវប្រសើរ ។

## កណ្ហមគ្គសុក្កមគ្គសូត្រទី ២

[ ៧៩ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងផ្លូវខ្មៅផង ផ្លូវសផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ។បេ។ ម្នាលភិក្ខុទាំង-ឡាយ ផ្លូវខ្មៅ តើដូចម្តេច ។ គឺបាណាតិបាត ។បេ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ផ្លូវខ្មៅ ។ ម្នាលភិក្ខុទាំងឡាយ ផ្លូវស តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។បេ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ផ្លូវស ។

## សទ្ធម្មាសទ្ធម្មសូត្រទី ៣

[ ៨០ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវសទ្ធម្ម ( ធម៌ស្ងប់

រម្ងាប់ ) ផង អសទ្ធម្ម ( ធម៌មិនស្ងប់រម្ងាប់ ) ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ អសទ្ធម្ម តើដូចម្តេច ។ គឺបាណាតិបាត ។បេ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសទ្ធម្ម ។ ម្នាលភិក្ខុទាំងឡាយ សទ្ធម្ម តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។បេ។ ការយល់ឃើញត្រូវ នេះហៅថា សទ្ធម្ម ។

## សប្បុរិសធម្មាសប្បុរិសធម្មសូត្រទី ៨

[ ៨១ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវសប្បុរិសធម៌ ( ធម៌របស់សប្បុរស ) ផង អសប្បុរិសធម៌ ( ធម៌របស់អសប្បុរស ) ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ អសប្បុរិសធម៌ តើដូចម្តេច ។ គឺបាណាតិបាត ។បេ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសប្បុរិសធម៌ ។ ម្នាលភិក្ខុទាំងឡាយ សប្បុរិសធម៌ តើដូចម្តេច ។ គឺចេតនា ជាហេតុវៀរចាកបាណាតិបាត ។បេ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សប្បុរិសធម៌ ។

## ឧប្បាទេតព្វាឧប្បាទេតព្វធម្មសូត្រទី ៩

[ ៨២ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងធម៌ដែលគួរឲ្យកើតឡើងផង ធម៌ដែលមិនគួរឲ្យកើតឡើងផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមិនគួរឲ្យកើតឡើង តើដូចម្តេច ។ គឺបាណាតិបាត ។បេ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា

ធម៌ដែលមិនគួរឲ្យកើតឡើង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគួរឲ្យកើតឡើង តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។បេ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលគួរឲ្យកើតឡើង ។

## អាសេវិតព្វានាសេវិតព្វធម្មសូត្រទី ៦

[ ៨៣ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងធម៌ដែលគេគួរសេពផង ធម៌ដែលគេមិនគួរសេពផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់ធម៌នោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគេមិនគួរសេព តើដូចម្តេច ។ គឺបាណាតិបាត ។បេ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលគេមិនគួរសេព ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគេគួរសេព តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។បេ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលគេគួរសេព ។

## ភាវេតព្វាភាវេតព្វធម្មសូត្រទី ៧

[ ៨៤ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងធម៌ ដែលគួរចម្រើនផង ធម៌ដែលមិនគួរចម្រើនផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់ធម៌នោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌ដែលមិនគួរចម្រើន តើដូចម្តេច ។ គឺបាណាតិបាត ។បេ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលមិនគួរចម្រើន ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌ដែលគួរចម្រើន តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។បេ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុ

ទាំងឡាយ នេះហៅថា ធម៌ដែលគួរចម្រើន ។

## ពហុលីកាតព្វាពហុលីកាតព្វធម្មសូត្រទី ៨

[ ៨៥ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងធម៌ដែលគេគួរធ្វើឲ្យច្រើនផង ធម៌ដែលគេមិនគួរធ្វើឲ្យច្រើនផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំង-ឡាយ ស្តាប់ធម៌នោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគេមិនគួរធ្វើឲ្យច្រើន តើដូចម្តេច ។ គឺបាណាតិបាត ។បេ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលគេមិនគួរធ្វើឲ្យច្រើន ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគេគួរធ្វើឲ្យច្រើន តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។បេ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលគេគួរធ្វើឲ្យច្រើន ។

## អនុស្សរិតព្វានុស្សរិតព្វធម្មសូត្រទី ៩

[ ៨៦ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងធម៌ដែលគួរនឹករកផង ធម៌ដែលមិនគួរនឹករកផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមិនគួរនឹករក តើដូចម្តេច ។ គឺបាណាតិបាត ។បេ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលមិនគួរនឹករក ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគួរនឹករក តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។បេ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលគួរនឹករក ។

## សច្ចិកាតព្វាសច្ចិកាតព្វធម្មសូត្រទី ១០

[ ៨៧ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ផង ធម៌ដែលមិនគួរធ្វើឲ្យជាក់ច្បាស់ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមិនគួរធ្វើឲ្យជាក់ច្បាស់ តើដូចម្តេច ។ គឺបាណាតិបាត ។បេ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលមិនគួរធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។បេ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ។

សេដ្ឋវគ្គទី ៤ ចប់

## អដ្ឋកថា

## សេដ្ឋវគ្គទី ៤

[ ៧៨-៨៧] អដ្ឋកថាសេដ្ឋវគ្គទី ៤ មានអត្ថាធិប្បាយយល់ហើយ ។

**អដ្ឋកថា សេដ្ឋវគ្គទី ៤ ចប់**

# សុត្តន្តបិដក

## សេវិតព្វាសេវិតព្វវគ្គទី ៥

[ ៨៨ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលប្រកបដោយធម៌ ១០ ប្រការ មិនគួរសេពគប់ឡើយ ។ ធម៌ ១០ ប្រការ តើដូចម្ដេច ។ គឺបុគ្គលជាអ្នកសម្លាប់សត្វ ១ លួចទ្រព្យគេ ១ ប្រព្រឹត្តខុសក្នុងកាម ១ ពោលពាក្យកុហក ១ ពោលពាក្យញុះញង់ ១ ពោលពាក្យអាក្រក់ ១ ពោលពាក្យឥតប្រយោជន៍ ១ ជាអ្នកច្រើនដោយអភិជ្ឈា ១ មានចិត្តព្យាបាទ ១ មានសេចក្ដីយល់ខុស ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលប្រកបដោយធម៌ ១០ ប្រការនេះឯង មិនគួរសេពគប់ឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលប្រកបដោយធម៌ ១០ ប្រការ ទើបគួរសេពគប់ ។ ធម៌ ១០ ប្រការ តើដូចម្ដេច ។ គឺបុគ្គលជាអ្នកវៀរស្រឡះចាកបាណាតិបាត ១ វៀរស្រឡះចាកអទិន្នាទាន ១ វៀរស្រឡះចាកកាមេសុមិច្ឆាចារ ១ វៀរស្រឡះចាកមុសាវាទ ១ វៀរស្រឡះចាកបិសុណាវាចា ១ វៀរស្រឡះចាកផរុសវាចា ១ វៀរស្រឡះចាកសម្ផប្បលាប ១ ជាអ្នកមិនមានអភិជ្ឈា ១ មិនមានចិត្តព្យាបាទ ១ មានសេចក្ដីយល់ត្រូវ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលប្រកបដោយធម៌ ១០ ប្រការនេះឯង ទើបគួរសេពគប់ ។ ( ក្នុងទីនេះ បណ្ឌិតត្រូវរាប់សូត្រមាន ២០០ សូត្រជាដើមដោយអំណាចបេយ្យាលៈ ) ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលប្រកបដោយធម៌ ១០ ប្រការ មិនគួរគប់រកឡើយ ... គួរគប់រក ... មិនគួរចូលទៅអង្គុយជិត ... គួរចូលទៅអង្គុយជិត ... ជាបុគ្គលមិនគួរបូជា ... គួរបូជា ... មិនគួរ

សរសើរ ... គួរសរសើរ ... មិនគួរគោរព ... គួរគោរព ... មិនគួរកោតក្រែង ... គួរកោតក្រែង ... មិនគួរប្រោសប្រាណ ... គួរប្រោសប្រាណ ... មិនបរិសុទ្ធ ... បរិសុទ្ធ ... មិនគ្របសង្កត់នូវមានះ ... គ្របសង្កត់នូវមានះ ... មិនចម្រើនដោយប្រាជ្ញា ... ចម្រើនដោយប្រាជ្ញា ... រមែងបានបាបច្រើន ... រមែងបានបុណ្យច្រើន ។ ចុះបុគ្គលដែលប្រកបដោយធម៌ ១០ ប្រការ តើដូចម្តេច ។ បុគ្គលជាអ្នកវៀរស្រឡះចាកបាណាតិបាត ១ វៀរស្រឡះចាកអទិន្នាទាន ១ វៀរស្រឡះចាកកាមេសុមិច្ឆាចារ ១ វៀរស្រឡះចាកមុសាវាទ ១ វៀរស្រឡះចាកបិសុណាវាចា ១ វៀរស្រឡះចាកផរុសវាចា ១ វៀរស្រឡះចាកសម្ផប្បលាប ១ មិនមានអភិជ្ឈា ១ មិនមានចិត្តព្យាបាទ ១ មានសេចក្តីយល់ត្រូវ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលប្រកបដោយធម៌ ១០ ប្រការនេះឯង រមែងបាននូវបុណ្យច្រើន ។

សោវិតព្វាសោវិតព្វវគ្គទី ៥ ចប់

## ចតុត្ថបណ្ណាសកទី ៤ ចប់

# អដ្ឋកថា

## សោវិតព្វាសោវិតព្វវគ្គទី ៥

[ ៨៨ ] អដ្ឋកថាសោវិតព្វសោវិតព្វវគ្គទី ៥ មានអត្ថងាយយល់ហើយ ។

**អដ្ឋកថា សោវិតព្វសោវិតព្វាវគ្គទី ៥ ចប់**

**ចតុត្ថបណ្ណាសក ចប់**

# សុត្តន្តបិដក

# បញ្ចមបណ្ណាសក

## បឋមវគ្គទី ១

### យថាភតសូត្រទី ១

[ ៨៩ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាង នឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំទៅទម្លាក់ ។ ធម៌ ១០ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ អ្នកមានចិត្តអាក្រក់ អ្នកមានបាតដៃប្រឡាក់ដោយឈាម តាំងនៅខ្ជាប់ក្នុងការសម្លាប់រឿយៗ មិនដល់នូវសេចក្តីអាណិតអាសូរ ចំពោះសព្វសត្វទាំងឡាយ ១ ជាអ្នកលួចទ្រព្យគេ គឺថាជាអ្នកកាន់យកនូវគ្រឿងឧបករណ៍ ជាសម្បត្តិនៃបុគ្គលដទៃដែលគេមិនបានឲ្យ ពោលគឺការលួច ដែលជាទ្រព្យ ឋិតនៅក្នុងស្រុកក្តី ឋិតនៅក្នុងព្រៃក្តី ១ ជាអ្នកប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ អ្នកដល់នូវការប្រព្រឹត្តកន្លងចំពោះស្រ្តីទាំងឡាយ ដែលមានមាតារក្សា បិតារក្សា បងប្អូនប្រុសរក្សា បងប្អូនស្រីរក្សា ញាតិរក្សា ធម៌រក្សា ជាស្ត្រីមានប្តី មានអាជ្ញា ( កំណត់ទុក ) ដោយហោចទៅ សូម្បីតែស្ត្រីដែលមានគេបំពាក់កម្រងផ្កា ១ ជាអ្នកនិយាយកុហក ទោះបីឋិតនៅក្នុងរោងក្តី ឋិតនៅក្នុងបរិសទ្យក្តី ឋិតនៅក្នុងកណ្តាលនៃ

ញាតិក្តី ឋិតនៅក្នុងកណ្តាលសេនីក្តី ឋិតនៅក្នុងកណ្តាលរាជត្រកូលក្តី ដែលគេនាំមក សួរជាសាក្សីថា នែបុរសអើយ ចូរអ្នកចូលមកអាយ បើអ្នកដឹងនូវហេតុណា ចូរនិយាយប្រាប់ហេតុនោះ បុរសនោះកាលបើមិនដឹង ក៏និយាយថា ខ្ញុំដឹង ក៏មាន កាលបើដឹង និយាយថា ខ្ញុំមិនដឹង ក៏មាន កាលបើមិនឃើញ និយាយថា ខ្ញុំឃើញ ក៏មាន កាលបើឃើញនិយាយថា ខ្ញុំមិនឃើញក៏មាន ជាអ្នកពោលនូវពាក្យកុហកទាំងដឹងខ្លួនដូច្នេះ ព្រោះហេតុនៃខ្លួនក្តី ព្រោះហេតុនៃបុគ្គលដទៃក្តី ព្រោះហេតុសំណូក គឺអាមិសបន្តិចបន្តួចក្តី ១ ជាអ្នកពោលពាក្យញុះញង់ គឺឮពាក្យអំពីសម្នាក់ជននេះ ហើយនាំទៅប្រាប់ជនឯណោះ ដើម្បីទឹងបំបែកជនទាំងនេះ ឬឮពាក្យអំពីសម្នាក់ជនឯណោះ មកប្រាប់ជនឯណោះ ដើម្បីទឹងបំបែកជនឯណោះ ជាអ្នកបំបែកនូវពួកជនដែលព្រមព្រៀងគ្នា អ្នកជម្រុលពួកជនដែលបែកគ្នាហើយ អ្នកត្រេកអរក្នុងពួក មានតម្រេកក្នុងពួក អ្នករីករាយក្នុងពួក អ្នកពោលវាចាធ្វើឲ្យប្រកាន់ពួកដូច្នេះ អ្នកពោលពាក្យអាក្រក់ អ្នកពោលពាក្យទ្រគោះ ខ្នោះខ្នូរ រោលរាលដល់អ្នកដទៃ ជៀមដាមដល់អ្នកដទៃ ជាវាចាជិតសេចក្តីក្រោធ មិនប្រព្រឹត្តទៅ ដើម្បីសមាធិ ១ ជាអ្នកពោលពាក្យឥតប្រយោជន៍ គឺពោលពាក្យខុសកាល ពោលពាក្យមិនពិត ពោលពាក្យមិនមែនជាអត្ថ ពោលពាក្យមិនមែនជាធម៌ ពោលពាក្យមិនមែនជាវិន័យ ពាក្យដែលមិនគួរ ឲ្យអ្នកផងតាំងទុកក្នុងហឫទ័យ ជាពាក្យខុសកាល មិនមានគ្រឿងអាង មិនមានទីបំផុត មិនប្រកបដោយប្រយោជន៍ ១

ជាអ្នកច្រើនដោយអភិជ្ឈា សម្លឹងគ្រឿងឧបករណ៍ ដែលជាសម្បត្តិនៃបុគ្គល ដទៃណាថា ឱហ្ន៎ គ្រឿងឧបករណ៍នោះ គប្បីបានមកអញ ១ ជាអ្នកមានចិត្ត ព្យាបាទ ជាអ្នកមានតម្រិះក្នុងចិត្តដែលប្រទូស្តហើយថា សត្វទាំងឡាយនេះ ចូរលំបាកខ្លះ ចូរបែកគ្នាខ្លះ ចូរសាបសូន្យទៅខ្លះ កុំកើតមានឡើយខ្លះ ១ ជាអ្នកមានគំនិតយល់ខុស ជាអ្នកយល់ឃើញសេចក្តីវិបរិតថា ទានដែលបុគ្គល ឲ្យហើយ មិនមានផល ការបូជាធំ មិនមានផល ការបូជាតូច មិនមានផល ផលវិបាករបស់កុសលាកុសលកម្ម ដែលសត្វធ្វើល្អ និងធ្វើអាក្រក់មិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន មាតាមិនមាន បិតាមិនមាន សត្វ ទាំងឡាយជាឱបបាតិកកំណើតមិនមាន សមណព្រាហ្មណ៍ទាំងឡាយ ក្នុង លោក ជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិដោយត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់នូវលោក នេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តមរបស់ខ្លួន ហើយសម្តែងប្រាប់ មិន មាន ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបព្រមដោយធម៌ ១០ នេះឯង នឹងធ្លាក់ក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ប្រកបដោយធម៌ ១០ យ៉ាងនេះ នឹងទៅកើតឯស្ថានសួគ៌ ដូចជាគេនាំយកទៅ តម្កល់ទុក ។ ធម៌ ១០ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុង លោកនេះ លះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះ ហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ ជាអ្នកអៀនខ្មាស ដល់នូវសេចក្តី អាណិតអាសូរ អ្នកមានសេចក្តីអនុគ្រោះដោយប្រយោជន៍ ដល់សព្វសត្វ ១

លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន ជាអ្នកមិនលួចទ្រព្យគេដែលជាគ្រឿងឧបករណ៍ គឺសម្បត្តិនៃបុគ្គលដទៃ ដែលជាទ្រព្យឋិតនៅក្នុងស្រុកក្តី ឋិតនៅក្នុងព្រៃក្តី ដែលគេមិនឲ្យ ពោលគឺការលួច ១ លះបង់កាមេសុមិច្ឆាចារ វៀរចាកកាមេសុមិច្ឆាចារ អ្នកមិនដល់នូវការប្រព្រឹត្តកន្លង ចំពោះស្ត្រីទាំងឡាយដែលមានមាតារក្សា បិតារក្សា បងប្អូនប្រុសរក្សា បងប្អូនស្រីរក្សា ញាតិរក្សា ធម៌រក្សា ជាស្ត្រីមានប្តី មានអាជ្ញា ( កំណត់ទុក ) ដោយហោចទៅ សូម្បីតែស្ត្រីដែលគេបំពាក់កម្រងផ្កា ១ លះបង់នូវមុសាវាទ វៀរចាកមុសាវាទ ទោះបីឋិតនៅក្នុងរោងក្តី ឋិតនៅក្នុងបរិសទ្យក្តី ឋិតនៅក្នុងកណ្តាលនៃញាតិក្តី ឋិតនៅក្នុងកណ្តាលសេនីក្តី ឋិតនៅក្នុងកណ្តាលនៃរាជត្រកូលក្តី ដែលគេនាំមកសួរជាសាក្សីថា នែបុរសអើយ ចូរអ្នកមកអាយ អ្នកដឹងនូវហេតុណា ចូរនិយាយប្រាប់ហេតុនោះ បុរសនោះ កាលមិនដឹង និយាយថា ខ្ញុំមិនដឹងក៏មាន កាលដឹង និយាយថា ខ្ញុំដឹងក៏មាន កាលមិនឃើញ និយាយថា ខ្ញុំមិនឃើញក៏មាន កាលឃើញនិយាយថា ខ្ញុំឃើញក៏មាន ជាអ្នកមិនពោលនូវពាក្យកុហកទាំងដឹងខ្លួនដូច្នេះ ព្រោះហេតុនៃខ្លួនក្តី ព្រោះហេតុនៃបុគ្គលដទៃក្តី ព្រោះហេតុសំណូក គឺអាមិសបន្តិចបន្តួចក្តី ១ លះបង់នូវបិសុណវាចា វៀរចាកបិសុណ-វាចា ឮពាក្យអំពីសម្នាក់ជននេះ ហើយមិននាំទៅប្រាប់ជនឯណោះ ដើម្បីនឹងបំបែកជនទាំងនេះ ឬឮពាក្យអំពីសម្នាក់ជនឯណោះ មិននាំមកប្រាប់ដល់ជននេះ ដើម្បីនឹងបំបែកជនឯណោះ ជាអ្នកផ្សះផ្សាពួកជនដែលបែកគ្នា ឬជាអ្នក

ទំនុកបម្រុងនូវពួកជនដែលព្រមព្រៀង ជាអ្នកត្រេកអរ ក្នុងការព្រមព្រៀង ជាអ្នកមានតម្រេក ក្នុងសេចក្តីព្រមព្រៀង ជាអ្នករីករាយ ក្នុងការព្រមព្រៀង ពោលវាចាដែលធ្វើឲ្យកើតសេចក្តីព្រមព្រៀងគ្នា ១ លះបង់ផរុសវាចា វៀរចាកផរុសវាចា ជាអ្នកពោលតែវាចាដែលមិនមានទោស ជាវាចាស្រួលដល់ត្រចៀក គួរឲ្យគេស្រឡាញ់ ចូលទៅកាន់ហឫទ័យ ជាវាចាអ្នកបុរី ជាទីស្រឡាញ់នៃជនច្រើន ជាសម្តីពេញចិត្តនៃជនច្រើន ១ លះបង់នូវសម្ផប្បលាប វៀរចាកសម្ផប្បលាប ជាអ្នកពោលត្រូវតាមកាល ពោលពាក្យពិត ពោលពាក្យដែលជាអត្ថ ពោលពាក្យដែលជាធម៌ ពោលពាក្យដែលជាវិន័យ ពោលពាក្យដែលគួរឲ្យគេតាំងទុក ជាពាក្យត្រូវតាមកាល ប្រកបដោយគ្រឿងអាងជាវាចាមានទីបំផុត ប្រកបព្រមដោយប្រយោជន៍ ១ ជាអ្នកមិនមានអភិជ្ឈា ជាអ្នកមិនគយគន់នូវគ្រឿងឧបករណ៍ ដែលជាសម្បត្តិនៃបុគ្គលដទៃថា ឱហ្ន៎ គ្រឿងឧបករណ៍ ដែលជាសម្បត្តិនៃបុគ្គលដទៃណា គ្រឿងឧបករណ៍នោះគប្បីបានមកអញ ដូច្នេះឡើយ ១ ជាអ្នកមានចិត្តមិនព្យាបាទ មានតម្រិះក្នុងចិត្តដែលទោសមិនប្រទូស្តថា សត្វទាំងឡាយនេះ កុំចងពៀរគ្នា កុំព្យាបាទគ្នា កុំមានទុក្ខ ចូររក្សាខ្លួន ឲ្យបានសេចក្តីសុខចុះ ១ ជាអ្នកយល់ត្រូវ ឃើញសេចក្តីមិនវិបរិតថា ទានដែលបុគ្គលឲ្យហើយ មានផល ការបូជាធំ មានផល ការបូជាតូច មានផល ផលវិបាកនៃកុសលាកុសលកម្ម ដែលបុគ្គលធ្វើល្អ និងអាក្រក់ មាន លោកនេះ មាន លោកខាងមុខ មាន មាតា មាន បិតា មាន

សត្វទាំងឡាយជាឱបបាតិកកំណើត មាន សមណព្រាហ្មណ៍ទាំងឡាយ ក្នុងលោកនេះ ជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះនិងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយសម្តែងប្រាប់ មាន ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាងនេះឯង នឹងទៅកើតឯស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។

## មាតុគាមសូត្រទី ២

[ ៩០ ] ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយធម៌ ១០ យ៉ាង នឹងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ធម៌ ១០ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកសម្លាប់សត្វ ។បេ។ ជាអ្នកយល់ខុស ។ ម្នាលភិក្ខុទាំងឡាយ មាតុ-គ្រាមប្រកបដោយធម៌ ១០ យ៉ាងនេះឯង នឹងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយធម៌ ១០ យ៉ាង នឹងទៅកើតឯស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។ ធម៌ ១០ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកវៀរចាកបាណាតិបាត ។បេ។ ជាអ្នកយល់ត្រូវ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយធម៌ ១០ យ៉ាងនេះឯង នឹងទៅកើតឯស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។

## បឋមឧបាសិកាសូត្រទី ៣

[ ៩១ ] ម្នាលភិក្ខុទាំងឡាយ ឧបាសិកាប្រកបដោយធម៌ ១០ យ៉ាង នឹងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ធម៌ ១០ យ៉ាងតើអ្វីខ្លះ ។

គឺជាអ្នកសម្លាប់សត្វ ។បេ។ ជាអ្នកយល់ខុស ។ ម្នាលភិក្ខុទាំងឡាយ ឧបាសិកាប្រកបដោយធម៌ ១០ យ៉ាងនេះឯង នឹងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសិកាប្រកបដោយធម៌ ១០ យ៉ាង នឹងទៅកើតឯស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។ ធម៌ ១០ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកវៀរចាកបាណាតិបាត ។បេ។ ជាអ្នកយល់ត្រូវ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសិកាប្រកបដោយធម៌ ១០ យ៉ាងនេះឯង នឹងទៅកើតឯស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។

## ទុតិយឧបាសិកាសូត្រទី ៨

[ ៩២ ] ម្នាលភិក្ខុទាំងឡាយ ឧបាសិកាប្រកបដោយធម៌ ១០ យ៉ាង ជាអ្នកមិនក្លៀវក្លា គ្រប់គ្រងផ្ទះ ។ ធម៌ ១០ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកសម្លាប់សត្វ ។បេ។ ជាអ្នកយល់ខុស ។ ម្នាលភិក្ខុទាំងឡាយ ឧបាសិកាប្រកបដោយធម៌ ១០ យ៉ាងនេះឯង ជាអ្នកមិនក្លៀវក្លា គ្រប់គ្រងផ្ទះ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសិកាប្រកបដោយធម៌ ១០ យ៉ាងជាអ្នកក្លៀវក្លា គ្រប់គ្រងផ្ទះ ។ ធម៌ ១០ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកវៀរចាកបាណាតិបាត ។បេ។ ជាអ្នកយល់ត្រូវ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសិកាប្រកបដោយធម៌ ១០ យ៉ាងនេះឯង ជាអ្នកក្លៀវក្លា គ្រប់គ្រងផ្ទះ ។

# អដ្ឋកថា

# បញ្ចមបណ្ណាសក

## បឋមវគ្គទី ១

## យថាភតសូត្រជាដើម

[ ៨៩-៩២ ] ក្នុងយថាភតសូត្រទី ១ ជាដើម មានអត្ថងាយយល់ហើយ ។

អដ្ឋកថាយថាភតសូត្រទី ១ ជាដើមចប់

# សុត្តន្តបិដក

## ធម្មបរិយាយសូត្រទី ៤

[ ៩៣ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងនូវធម្មបរិយាយ ជាហេតុនៃសេចក្ដីវិនាស ចូរអ្នកទាំងឡាយ ស្ដាប់នូវធម៌នោះ ធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសម្ដែង ។ ពួកភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់សួរដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម្មបរិយាយជាហេតុនៃសេចក្ដីវិនាស តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ មានកម្មជារបស់ខ្លួន មានកម្មជាទាយាទ មាន

កម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីរឭក ទោះធ្វើនូវកម្មណា ជាបុណ្យក្តី ជាបាបក្តី រមែងជាទាយាទនៃកម្មនោះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ មានចិត្តអាក្រក់ មានបាតដៃប្រឡាក់ដោយឈាម តាំងនៅខ្ជាប់ ក្នុងការសម្លាប់រឿយៗ មិនមានសេចក្តីរន្ធត់អាណិតអាសូរចំពោះពួកសត្វទាំងពួង ។ បុគ្គលនោះ រមែងរន្ធត់ដោយកាយ រន្ធត់ដោយវាចា រន្ធត់ដោយចិត្ត ។ បុគ្គលនោះ ឈ្មោះថា មានកាយកម្មវៀច ( របិញរបុញ ) វចីកម្មវៀច មនោកម្មវៀច គតិវៀច ឧបបត្តិ ( ការកើតឡើង ) ក៏វៀច ។ ម្នាលភិក្ខុទាំងឡាយ បណ្តាគតិទាំងពីររបស់សត្វមានគតិវៀច មានឧបបត្តិវៀច តថាគតពោលនូវគតិណាមួយ គឺនិរយគតិ មានទុក្ខតែម្យ៉ាង ឬតិរច្ឆានយោនិគតិ មានជាតិដ៏រន្ធត់ ។ ម្នាលភិក្ខុទាំងឡាយ តិរច្ឆានយោនិគតិ ប្រកបដោយរន្ធត់នោះ តើដូចម្តេច គឺពស់ ខ្ជយ ក្អែប ស្កា សំពោចកណ្តុរ មៀម ឬក៏ពួកសត្វកើតក្នុងកំណើតតិរច្ឆានណាមួយក្រៅពីនេះ ឃើញមនុស្សទាំងឡាយហើយ ក៏រមែងរន្ធត់ ។ ម្នាលភិក្ខុទាំងឡាយ ឧបបត្តិរបស់សត្វតាមសភាវៈ រមែងមាន ដោយប្រការដូច្នេះឯង ។ បុគ្គលធ្វើនូវកម្មណា រមែងកើតឡើងដោយអំណាចកម្មនោះ ផស្សៈទាំងឡាយ ( របស់វិបាក ) ក៏រមែងពាល់ត្រូវនូវបុគ្គលដែលកើតមកនោះ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សត្វទាំងឡាយ មានកម្មជាទាយាទ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ លួចយកទ្រព្យដែលគេមិនបានឲ្យ ... ប្រព្រឹត្តខុស

ក្នុងកាមទាំងឡាយ ... ពោលពាក្យកុហក ... មានសម្ដីញុះញង់ ... មានសម្ដីអាក្រក់ ... ពោលពាក្យឥតប្រយោជន៍ ... មានចិត្តច្រើនដោយអភិជ្ឈា ... មានចិត្តព្យាបាទ ... ជាមិច្ឆាទិដ្ឋិ យល់ឃើញសេចក្ដីវិបរិតថា ទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជាធំ មិនមានផល ការបូជាតូច មិនមានផល ផលវិបាករបស់កុសលាកុសលកម្ម ដែលសត្វធ្វើល្អ និងអាក្រក់ មិនមាន លោកនេះ មិនមាន លោកខាងមុខ មិនមាន មាតា មិនមាន បិតា មិនមាន សត្វទាំងឡាយជាឱបបាតិកកំណើត មិនមាន សមណព្រាហ្មណ៍ទាំងឡាយក្នុងលោក អ្នកប្រព្រឹត្តល្អ ប្រតិបត្តិដោយត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្ដមរបស់ខ្លួន ហើយសម្ដែងប្រាប់មិនមាន ។ បុគ្គលនោះ រមែងវេទ្ធត់ដោយកាយ វេទ្ធត់ដោយវាចា វេទ្ធត់ដោយចិត្ត ។ បុគ្គលនោះ ឈ្មោះថា មានកាយកម្មវៀច វចីកម្មវៀច មនោកម្មវៀច គតិវៀច ឧបបត្តិវៀច ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាគតិពីរយ៉ាង របស់សត្វមានគតិវៀច មានឧបបត្តិវៀច តថាគតពោលគតិណាមួយ គឺនិរយគតិមានទុក្ខតែម្យ៉ាង ឬតិរច្ឆានយោនិគតិ មានជាតិវេទ្ធត់ ។ ម្នាលភិក្ខុទាំងឡាយ តិរច្ឆានយោនិគតិ ប្រកបដោយជាតិវេទ្ធត់នោះ តើអ្វីខ្លះ គឺពស់ ខ្យាយ ក្អែប ស្កា សំពោច កណ្ដុរ មៀម ឬក៏ពួកសត្វកើតក្នុងកំណើតតិរច្ឆានណាមួយក្រៅពីនេះ ឃើញមនុស្សហើយ រមែងវេទ្ធត់ ។ ម្នាលភិក្ខុទាំងឡាយ ឧបបត្តិនៃសត្វតាមសភាវៈ រមែងមានដោយប្រការដូច្នេះឯង ។ បុគ្គលធ្វើនូវកម្មណា

រមែងកើតដោយអំណាចកម្មនោះ ផស្សៈទាំងឡាយ ( របស់វិបាក ) រមែងពាល់ត្រូវនូវបុគ្គលដែលកើតមកនោះ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សត្វទាំងឡាយ មានកម្មជាទាយាទយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ មានកម្មជារបស់ខ្លួន មានកម្មជាទាយាទ មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីរឭក ទោះធ្វើនូវកម្មណា ជាបុណ្យក្តី ជាបាបក្តី រមែងជាទាយាទនៃកម្មនោះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ លះបង់នូវបាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាវុធដាក់ចុះហើយ ជាអ្នកអៀនខ្មាស មានសេចក្តីអាណិតអាសូរ មានសេចក្តីអនុគ្រោះ ដោយប្រយោជន៍ដល់សព្វសត្វ ។ បុគ្គលនោះមិនវន្ធត់ដោយកាយ មិនវន្ធត់ដោយវាចា មិនវន្ធត់ដោយចិត្ត ។ បុគ្គលនោះ ឈ្មោះថា មានកាយកម្មត្រង់ វចីកម្មត្រង់ មនោកម្មត្រង់ គតិត្រង់ ឧបបត្តិត្រង់ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាគតិទាំងពីរ របស់សត្វមានគតិត្រង់ មានឧបបត្តិត្រង់ តថាគតពោលនូវគតិណាមួយ គឺសត្វទាំងឡាយ ដែលមានសុខតែម្យ៉ាង ឬពួកត្រកូលខ្ពស់ ដែលជាត្រកូលខត្តិយមហាសាល ឬព្រាហ្មណមហាសាល ឬក៏គហបតិមហាសាល ដែលជាត្រកូលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានមាស និងប្រាក់ច្រើន មានសម្បត្តិ និងគ្រឿងឧបករណ៍ច្រើន មានទ្រព្យ និងស្រូវច្រើន ។ ម្នាលភិក្ខុទាំងឡាយ ឧបបត្តិនៃសត្វតាមសភាវៈរមែងមានដោយប្រការដូច្នេះឯង ។ បុគ្គលធ្វើនូវកម្មណា រមែងកើតដោយអំណាច

កម្មនោះ ផស្សៈទាំងឡាយ ( របស់វិបាក ) រមែងពាល់ត្រូវ នូវបុគ្គលដែលកើតមកនោះ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សត្វទាំងឡាយ មានកម្មជាទាយាទ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន ... លះបង់ការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ វៀរចាកការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ... លះបង់មុសាវាទ វៀរចាកមុសាវាទ ... លះបង់បិសុណវាចា វៀរចាកបិសុណវាចា ... លះបង់ផរុសវាចា វៀរចាកផរុសវាចា ... លះបង់សម្ផប្បលាបៈ វៀរចាកសម្ផប្បលាបៈ ... មិនច្រើនដោយអភិជ្ឈា ... មានចិត្តមិនព្យាបាទ ... ជាសម្មាទិដ្ឋិ មានសេចក្តីយល់ឃើញមិនវិបរិតថា ទានដែលបុគ្គលឲ្យហើយ មានផល ការបូជាធំ មានផល ការបូជាតូច មានផល ផលវិបាករបស់កុសលាកុសលកម្ម ដែលសត្វធ្វើល្អ និងអាក្រក់ មាន លោកនេះ មាន លោកខាងមុខ មាន មាតា មាន បិតា មាន សត្វទាំងឡាយ ជាឱបបាតិកកំណើតមាន ពួកសមណព្រាហ្មណ៍ទាំងឡាយ ជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិដោយត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់ នូវលោកនេះ និងលោកខាងមុខ ដោយបញ្ញាដ៏ឧត្តម របស់ខ្លួនហើយ សម្តែងប្រាប់ មាន ។ បុគ្គលនោះ រមែងមិនរន្ធត់ដោយកាយ មិនរន្ធត់ដោយវាចា មិនរន្ធត់ដោយចិត្ត ។ បុគ្គលនោះ ឈ្មោះថា មានកាយកម្មត្រង់ វចីកម្មត្រង់ មនោកម្មត្រង់ មានគតិត្រង់ មានឧបបត្តិត្រង់ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាគតិទាំងពីរ របស់សត្វមានគតិត្រង់ មានឧបបត្តិត្រង់ តថាគតពោលនូវ

គតិណាមួយ គឺសត្វទាំងឡាយដែលមានសុខតែម្យ៉ាង ឬពួកត្រកូលខ្ពស់ៗ ដែលជាត្រកូលខត្តិយមហាសាល ឬព្រាហ្មណមហាសាល ឬក៏គហបតិមហាសាល ដែលជាត្រកូលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានមាសនិងប្រាក់ច្រើន មានសម្បត្តិ និងគ្រឿងឧបករណ៍ច្រើន មានទ្រព្យនិងស្រូវច្រើន ។ ម្នាលភិក្ខុទាំងឡាយ ឧបបត្តិនៃសត្វតាមសភាវៈ រមែងមានដោយប្រការដូច្នេះឯង ។ បុគ្គលធ្វើនូវកម្មណា រមែងកើតឡើងដោយអំណាចកម្មនោះ ផស្សៈទាំងឡាយ ( របស់វិបាក ) រមែងពាល់ត្រូវនូវបុគ្គលដែលកើតមកនោះ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សត្វទាំងឡាយ មានកម្មជាទាយាទ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ មានកម្មជារបស់ខ្លួន មានកម្មជាទាយាទ មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីរឭក ទោះធ្វើនូវកម្មណា ជាបុណ្យក្តី ជាបាបក្តី រមែងជាទាយាទនៃកម្មនោះ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងឈ្មោះថា ធម្មបរិយាយជាហេតុនៃសេចក្តីវិនាស ។

# អដ្ឋកថា

## ធម្មបរិយាយសូត្រ

[ ៩៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងធម្មបរិយាយសូត្រទី ៥ នៃបញ្ចមបណ្ណាសក ដូចតទៅនេះ បទថា **សំសប្បតិបរិយាយំ វោ ភិក្ខវេ ធម្មបរិយាយំ** បានដល់ ការសម្តែងធម៌ ពោល គឺការសម្តែងហេតុនៃការរសាប់រសល់ ។ បទថា **សំសប្បតិ** សេចក្តីថា សត្វធ្វើកម្មនោះ រមែងរសាប់រសល់ អន្ទះអន្ទែងទៅ ញាប់ញ័រទៅ ។ បទថា **ជិម្ហា គតិ** សេចក្តីថា សត្វនឹងទៅកាន់គតិណា ដោយកម្មនោះ គតិនោះ ឈ្មោះថា វៀច ។ បទថា **ជិម្ហុបបត្តិ** សេចក្តីថា សត្វនឹងចូលដល់គតិណា គតិរបស់សត្វនោះ ក៏វៀចដូចគ្នា ។ បទថា **សំសប្បជាតិកា** បានដល់ មានការលូនទៅជាសភាវៈ ។ បទថា **ភូតា ភូតស្ស ឧបបត្តិ ហោតិ** សេចក្តីថា ការកើតឡើងរបស់សត្វរមែងមាន ព្រោះកម្មដែលមានហើយ គឺព្រោះកម្មដែលមានដោយសភាវៈ ។ បទថា **ផស្សា ផុសន្តិ** បានដល់ ផស្សៈដែលជាវិបាករមែងពាល់ត្រូវ ។

**អដ្ឋកថា ធម្មបរិយាយសូត្រទី ៥ ចប់**[១]

---

១- អដ្ឋកថាបាលីជាសូត្រទី ៦

# សុត្តន្តបិដក

## បឋមកម្មសូត្រទី ៦

[ ៩៤ ] ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលពោលនូវការអស់ទៅនៃកម្មទាំងឡាយ ប្រកបដោយចេតនា ដែលសត្វធ្វើហើយ សន្សំហើយ ព្រោះមិនបានទទួលនូវផលទេ ឯផលនោះឯង រមែងកើតក្នុងបច្ចុប្បន្នក៏មាន ក្នុងអត្តភាពជាលំដាប់ក៏មាន ក្នុងអត្តភាពដទៃតទៅក៏មាន ។ ម្នាលភិក្ខុទាំងឡាយ តថាគត មិនដែលពោលនូវកិរិយាធ្វើនូវទីបំផុតនៃទុក្ខ ព្រោះមិនបានទទួលនូវផលនៃកម្ម ប្រកបដោយចេតនា ដែលសត្វបានធ្វើហើយ សន្សំហើយទេ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាអកុសលកម្មទាំងនោះ វិបត្តិ គឺទោសនៃកាយកម្មមាន ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល វិបត្តិ គឺទោសនៃវចីកម្ម ៤ យ៉ាង ដែលប្រកបដោយអកុសល-ចេតនា មានទុក្ខជាកម្រៃ មានទុក្ខជាផល វិបត្តិ គឺទោស នៃមនោកម្ម ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនា មានទុក្ខជាកម្រៃ មានទុក្ខជាផល ។ ម្នាលភិក្ខុទាំងឡាយ វិបត្តិ គឺទោសនៃកាយកម្ម ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនា មានទុក្ខជាកម្រៃ មានទុក្ខជាផល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ មានចិត្តអាក្រក់ មានបាតដៃប្រឡាក់ដោយឈាម តាំងនៅខ្ជាប់ក្នុងការសម្លាប់រឿយៗ មិនមានសេចក្តីអាណិតអាសូរ ចំពោះសព្វសត្វទាំងឡាយ ជាអ្នកលួចយកទ្រព្យដែលគេមិនបានឲ្យ ជាអ្នកកាន់យកនូវសម្បត្តិ និងគ្រឿងឧបករណ៍ នៃបុគ្គលដទៃ

ជាទ្រព្យឋិតនៅក្នុងស្រុកក្តី ឋិតនៅក្នុងព្រៃក្តី ដែលគេមិនបានឲ្យ ពោលគឺការលួច ជាអ្នកប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ជាអ្នកដល់នូវការប្រព្រឹត្តកន្លងក្នុងស្ត្រីទាំងឡាយ ដែលមានមាតារក្សា បិតារក្សា បងប្អូនប្រុសរក្សា បងប្អូនស្រីរក្សា ញាតិរក្សា ធម៌រក្សា ជាស្ត្រីមានប្តី មានអាជ្ញា ( កំណត់ទុក ) ដោយហោចទៅ សូម្បីតែស្ត្រីដែលគេបំពាក់កម្រងផ្កា ។ ម្នាលភិក្ខុទាំងឡាយ វិបត្តិគឺទោស នៃកាយកម្ម ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ វិបត្តិ គឺទោស នៃវចីកម្ម មាន ៤ យ៉ាង ដែលប្រកបដោយអកុសលចេតនា មានទុក្ខជាកម្រៃ មានទុក្ខជាផល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកនិយាយពាក្យកុហក ទោះបីឋិតនៅក្នុងរោងក្តី ឋិតនៅក្នុងបរិសទ្យក្តី ឋិតនៅក្នុងកណ្តាលនៃញាតិក្តី ឋិតនៅក្នុងកណ្តាលនៃសេនីក្តី ឋិតនៅក្នុងកណ្តាលរាជត្រកូលក្តី ដែលគេនាំទៅសួរជាសាក្សីថា នែបុរសអើយ អ្នកចូរមកអាយ បើអ្នកដឹងហេតុណា ចូរនិយាយប្រាប់ហេតុនោះ បុរសនោះ កាលបើមិនដឹង និយាយថា ខ្ញុំដឹងក៏មាន កាលបើដឹង និយាយថា ខ្ញុំមិនដឹងក៏មាន កាលបើមិនឃើញ និយាយថា ខ្ញុំឃើញក៏មាន កាលបើឃើញនិយាយថា ខ្ញុំមិនឃើញក៏មាន ជាអ្នកពោលពាក្យកុហក ទាំងដឹងខ្លួន ដូច្នេះព្រោះហេតុនៃខ្លួនក្តី ហេតុនៃបុគ្គលដទៃក្តី ព្រោះសំណូក គឺអាមិសបន្តិចបន្តួចក្តី ជាអ្នកពោលពាក្យញុះញង់ ឮពាក្យអំពីសម្នាក់ជននេះហើយ នាំទៅប្រាប់

ជនឯណោះ ដើម្បីនឹងបំបែកជនទាំងនេះ ឬព្រួញពាក្យអំពីសម្នាក់ជនឯណោះ មកប្រាប់ពួកជននេះ ដើម្បីនឹងបំបែកជនឯណោះ ជាអ្នកបំបែកពួកជនដែលព្រមព្រៀងគ្នាផង ជាអ្នកជម្រុលពួកជនដែលបែកគ្នាស្រាប់ហើយផង មានសេចក្តីត្រេកអរក្នុងពួក រីករាយក្នុងពួក មានតម្រេកក្នុងពួក ជាអ្នកពោលវាចាធ្វើឲ្យប្រកាន់ពួក ជាអ្នកពោលពាក្យអាក្រក់ ជាអ្នកពោលពាក្យទ្រគោះខ្ទោះខ្ទួរ រោលរាល ដល់អ្នកដទៃ ជៀមជាមដល់អ្នកដទៃ ជាវាចាជិតសេចក្តីក្រោធ មិនប្រព្រឹត្តទៅ ដើម្បីសមាធិ ជាអ្នកពោលពាក្យឥតប្រយោជន៍ ពោលពាក្យខុសកាល ពោលពាក្យមិនពិត ពោលពាក្យមិនមែនជាអត្ថ ពោលពាក្យ មិនមែនជាធម៌ ពោលពាក្យមិនមែនជាវិន័យ ពោលពាក្យដែលមិនគួរឲ្យគេតាំងទុកក្នុងហឫទ័យ ជាពាក្យខុសកាល មិនមានគ្រឿងអាង មិនមានទីបំផុត មិនប្រកបដោយប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ វិបត្តិ គឺទោសនៃវចីកម្ម ៤ យ៉ាង ដែលប្រកបដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ វិបត្តិ គឺទោសនៃមនោ កម្មមាន ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកច្រើនដោយអភិជ្ឈា សម្លឹងសម្បត្តិ និងគ្រឿងឧបករណ៍នៃបុគ្គលដទៃថា ធ្វើដូចម្តេចហ្ន៎ សម្បត្តិ និងគ្រឿងឧបករណ៍នោះគប្បីបានមកអញ ជាអ្នកមានចិត្តព្យាបាទ គឺមានតម្រិះក្នុងចិត្ត ដែលទោស

ប្រទូស្តហើយថា សត្វទាំងឡាយនេះ ចូរលំបាកខ្វះ ចូរដាច់របេទៅខ្វះ ចូរសាបសូន្យទៅខ្វះ ចូរហិនហោចទៅខ្វះ កុំកើតមានទៀតខ្វះ ជាអ្នកយល់ខុស សេចក្តីយល់វិបរិតថា ទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជាធំមិនមានផល ការបូជាតូច មិនមានផល ផលវិបាកនៃកុសលាកុសលកម្មដែលសត្វធ្វើល្អ និងអាក្រក់ មិនមាន លោកនេះ មិនមាន លោកខាងមុខមិនមាន មាតា មិនមាន បិតា មិនមាន សត្វជាឱបបាតិកកំណើតមិនមានសមណព្រាហ្មណ៍ទាំងឡាយ ក្នុងលោក ជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិដោយត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយបញ្ញាដ៏ឧត្តមរបស់ខ្លួន ហើយសម្តែងប្រាប់ មិនមាន ។ ម្នាលភិក្ខុទាំងឡាយ វិបត្តិ គឺទោសនៃមនោកម្ម មាន ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ ពួកសត្វលុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងអបាយទុគ្គតិ វិនិបាត នរក ព្រោះហេតុតែវិបត្តិ គឺទោសនៃកាយ កម្មមាន ៣ យ៉ាងដែលប្រកបដោយអកុសលចេតនាក៏មាន ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយលុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាតនរក ព្រោះហេតុតែវិបត្តិ គឺទោសនៃវចីកម្មមាន ៤ យ៉ាង ដែលប្រកបដោយអកុសលចេតនាក៏មាន ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត នរក

ព្រោះហេតុតែវិបត្តិ គឺទោសនៃមនោកម្មមាន ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនាក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ដូចជាកូនបាសកា ( មានជ្រុង ៤ ) ដែលបុគ្គលបោះទៅខាងលើហើយធ្លាក់ចុះមកត្រង់ទីណា រមែងតាំងនៅស៊ប់ក្នុងទីនោះ ឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ឧបមេយ្យដូចជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុតែវិបត្តិ គឺទោសនៃកាយកម្ម មាន ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនាក៏មាន សត្វទាំងឡាយ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុតែវិបត្តិ គឺទោសនៃវចីកម្មមាន ៤ យ៉ាង ដែលប្រកបដោយអកុសលចេតនាក៏មាន សត្វទាំងឡាយ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុតែវិបត្តិ គឺទោសនៃមនោ កម្មមាន ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនាក៏មាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលពោលនូវសេចក្តីអស់ទៅនៃកម្មទាំងឡាយ ប្រកបដោយចេតនា ដែលសត្វធ្វើហើយ សន្សំហើយ ព្រោះមិនបានទទួលនូវផលទេ ឯផលនោះឯងរមែងកើតក្នុងបច្ចុប្បន្ននេះក៏មាន ក្នុងអត្តភាពជាលំដាប់ក៏មាន ក្នុងអត្តភាពដទៃក៏មាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលពោលនូវកិរិយាធ្វើនូវទីបំផុតនៃទុក្ខ ព្រោះមិនទាន់បានទទួលនូវផលនៃកម្ម ដែលប្រកបដោយចេតនាដែលសត្វធ្វើហើយ សន្សំហើយទេ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាកុសលកម្ម

ទាំងនោះ សម្បត្តិ គឺសេចក្តីចម្រើននៃកាយកម្មមាន ៣ យ៉ាង ដែលប្រកប ដោយកុសលចេតនា រមែងមានសុខជាកម្រៃ មានសុខជាផល សម្បត្តិនៃ វចីកម្មមាន ៤ យ៉ាង ដែលប្រកបដោយកុសលចេតនា រមែងមានសុខជា កម្រៃ មានសុខជាផល សម្បត្តិនៃមនោកម្មមាន ៣ យ៉ាង ដែលប្រកប ដោយកុសលចេតនា រមែងមានសុខជាកម្រៃ មានសុខជាផល ។

ម្នាលភិក្ខុទាំងឡាយ សម្បត្តិនៃកាយកម្មមាន ៣ យ៉ាង ដែលប្រកប ដោយកុសលចេតនា រមែងមានសុខជាកម្រៃ មានសុខជាផល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ លះបង់បាណាតិបាត វៀរចាក បាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានសស្ត្រាដាក់ចុះហើយ ជាអ្នកអៀន ខ្មាស ប្រកបដោយសេចក្តីអាណិតអាសូរ មានសេចក្តីអនុគ្រោះដោយប្រ- យោជន៍ដល់សត្វទាំងឡាយ លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន ជាអ្នក មិនកាន់យកសម្បត្តិ និងគ្រឿងឧបករណ៍នៃបុគ្គលដទៃ ដែលជាសម្បត្តិឋិត នៅក្នុងស្រុកក្តី ឋិតនៅក្នុងព្រៃក្តី ដែលគេមិនបានឲ្យ ពោល គឺការលួច លះបង់កាមេសុមិច្ឆាចារ វៀរចាកកាមេសុមិច្ឆាចារ មិនដល់នូវការប្រព្រឹត្ត ខុសក្នុងស្ត្រីទាំងឡាយ ដែលមាតារក្សា បិតារក្សា បងប្អូនប្រុសរក្សា បង ប្អូនស្រីរក្សា ញាតិរក្សា ធម៌រក្សា ជាស្ត្រីមានប្តី មានអាជ្ញា ( កំណត់ទុក ) ដោយហោចទៅ សូម្បីតែស្ត្រីដែលគេបំពាក់កម្រងផ្កា ម្នាលភិក្ខុទាំងឡាយ សម្បត្តិនៃកាយកម្ម មាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនា រមែង

មានសុខជាកម្រៃ មានសុខជាផល ដោយប្រការដូច្នេះឯង ។

ម្នាលភិក្ខុទាំងឡាយ សម្បត្តិនៃវចីកម្មមាន ៤ យ៉ាង ដែលប្រកបដោយកុសលចេតនា រមែងមានសុខជាកម្រៃ មានសុខជាផល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ លះបង់មុសាវាទ វៀរចាកមុសាវាទ ទោះបីឋិតនៅក្នុងរោងក្តី ឋិតនៅក្នុងបរិសទ្យក្តី ឋិតនៅក្នុងកណ្តាលនៃញាតិក្តី ឋិតនៅក្នុងកណ្តាលនៃសេនីក្តី ឋិតនៅក្នុងកណ្តាលនៃរាជត្រកូលក្តី ដែលគេនាំទៅសួរជាសាក្សីថា នែបុរសអើយ អ្នកចូរមកអាយ បើអ្នកដឹងនូវហេតុណា ចូរនិយាយហេតុនោះ បុរសនោះ កាលមិនដឹង និយាយថា ខ្ញុំមិនដឹងក៏មាន កាលដឹង និយាយថា ខ្ញុំដឹងក៏មាន កាលមិនឃើញ និយាយថា ខ្ញុំមិនឃើញក៏មាន កាលឃើញ និយាយថា ខ្ញុំឃើញក៏មាន ជាអ្នកមិនពោលពាក្យកុហក ទាំងដឹងខ្លួនដូច្នេះ ព្រោះហេតុនៃខ្លួនក្តី ព្រោះហេតុនៃបុគ្គលដទៃក្តី ព្រោះហេតុសំណូក គឺអាមិសបន្តិចបន្តួចក្តី លះបង់បិសុណវាចា វៀរចាកបិសុណ-វាចា ឮពាក្យពីជននេះហើយមិននាំទៅប្រាប់ជនឯណោះ ដើម្បីនឹងបំបែកពួកជននេះ ឬឮពាក្យអំពីសម្នាក់ជនឯណោះ មិននាំទៅប្រាប់ជននេះ ដើម្បីនឹងបំបែកពួកជនឯណោះ ជាអ្នកពោលពាក្យផ្សះផ្សាពួកជនដែលបែកគ្នា ឬជាអ្នកទំនុកបម្រុងពួកជនដែលព្រមព្រៀងគ្នាស្រាប់ ជាអ្នកត្រេកអរ ក្នុងការព្រមព្រៀង មានតម្រេក ក្នុងសេចក្តីព្រមព្រៀង រីករាយក្នុងសេចក្តីព្រមព្រៀង ពោលវាចាដែលធ្វើឲ្យកើតសេចក្តីព្រមព្រៀង លះបង់ផរុសវាចា វៀរចាក

ផរុសវាចា ជាអ្នកពោលតែវាចា ដែលមិនមានទោស ជាវាចាស្រួលដល់ត្រចៀក គួរឲ្យគេស្រឡាញ់ ចូលទៅកាន់ហឫទ័យ ជាវាចាអ្នកក្រុង ជាទីស្រឡាញ់នៃជនច្រើន ជាទីពេញចិត្តនៃជនច្រើន លះបង់សម្ផប្បលាប វៀរចាកសម្ផប្បលាប ជាអ្នកពោលពាក្យត្រូវតាមកាល ពោលពាក្យពិត ពោលពាក្យជាអត្ថ ពោលពាក្យជាធម៌ ពោលពាក្យជាវិន័យ ពោលពាក្យដែលគួរឲ្យគេតាំងទុក ជាពាក្យត្រូវតាមកាល ប្រកបដោយគ្រឿងអាង ជាវាចាមានទីបំផុត ប្រកបដោយប្រយោជន៍ ម្នាលភិក្ខុទាំងឡាយ សម្បត្តិនៃវចីកម្មមាន ៤ យ៉ាង ដែលប្រកបដោយកុសលចេតនា រមែងមានសុខជាកម្រៃ មានសុខជាផល ដោយប្រការដូច្នេះឯង ។

ម្នាលភិក្ខុទាំងឡាយ សម្បត្តិនៃមនោកម្មមាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនា រមែងមានសុខជាកម្រៃ មានសុខជាផល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ មិនច្រើនដោយអភិជ្ឈា ជាអ្នកមិនគយគន់សម្បត្តិ និងគ្រឿងឧបករណ៍នៃបុគ្គលដទៃថា ធ្វើដូចម្តេចហ្ន៎ សម្បត្តិនិងគ្រឿងឧបករណ៍នៃបុគ្គលដទៃគប្បីបានមកអញ ដូច្នេះឡើយ មានចិត្តមិនព្យាបាទ មានតម្រិះក្នុងចិត្ត ដែលទោសមិនប្រទូស្តថា សត្វទាំងឡាយនេះ កុំចងពៀរនឹងគ្នា កុំព្យាបាទនឹងគ្នា កុំមានទុក្ខ ចូររក្សាខ្លួនឲ្យបានសេចក្តីសុខចុះ ជាសម្មាទិដ្ឋិ ជាអ្នកយល់ឃើញនូវសេចក្តីមិនវិបរិតថា ទានដែលបុគ្គលឲ្យហើយ មានផល ការបូជាធំ មានផល ការបូជាតូច មានផល ។បេ។

សមណព្រាហ្មណ៍ទាំងឡាយ ក្នុងលោកនេះ ជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិដោយត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយបញ្ញាដ៏ឧត្តមខ្លួនឯង ហើយសម្តែងប្រាប់ក៏មាន ម្នាលភិក្ខុទាំងឡាយ សម្បត្តិនៃមនោកម្ម មាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនា រមែងមានសុខជាកម្រៃ មានសុខជាផល ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតឯសុគតិសួគ៌ទេវលោក ព្រោះហេតុតែសម្បត្តិនៃកាយកម្ម មាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនាក៏មាន ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតឯសុគតិសួគ៌ទេវលោក ព្រោះហេតុតែសម្បត្តិនៃវចីកម្មមាន ៤ យ៉ាង ដែលប្រកបដោយកុសលចេតនាក៏មាន ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតឯសុគតិសួគ៌ទេវ-លោក ព្រោះហេតុតែសម្បត្តិនៃមនោកម្ម មាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនាក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ដូចជាកូនបាសកា ( មានជ្រុង ៤ ) ដែលបុគ្គលបោះទៅខាងលើ ហើយធ្លាក់ចុះមក តាំងនៅត្រង់ជ្រុងណា រមែងតាំងនៅស៊ប់ត្រង់ជ្រុងនោះ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ឧបមេយ្យដូចជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតឯសុគតិសួគ៌ទេវលោក ព្រោះហេតុនៃសម្បត្តិនៃកាយកម្ម មាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនាក៏មាន សត្វទាំងឡាយ លុះបែកធ្លាយរាង

កាយស្លាប់ទៅ រមែងទៅកើតឯសុគតិសួគ៌ទេវលោក ព្រោះហេតុតែសម្បត្តិនៃវចីកម្មមាន ៤ យ៉ាង ដែលប្រកបដោយកុសលចេតនាក៏មាន សត្វទាំងឡាយ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតឯសុគតិសួគ៌ទេវលោក ព្រោះហេតុតែសម្បត្តិនៃមនោកម្ម មាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនាក៏មាន ។

# អដ្ឋកថា

## បឋមកម្មសូត្រ

[ ៩៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមកម្មសូត្រទី ៦ ដូចតទៅនេះ បទថា **សញ្ចេតនិកានំ** បានដល់ ដែលចងចិត្ត គួចចិត្ត ធ្វើហើយ ។ បទថា **ឧបចិតានំ** បានដល់ ដែលកសាងឲ្យរីកធំឡើង ។ បទថា **អប្បដិសំវិទិត្វា** បានដល់ មិនទាន់សោយវិបាកនៃការចាស់នោះ ។ បទថា **ព្យន្តិភាវំ** បានដល់ កម្មដែលមិនទាន់អស់ទៅ គឺហេតុជុំវិញផ្លូវ ដែលកម្មទាំងនោះកំណត់ ។ បទថា **តញ្ច ខោ ទិដ្ឋេវ ធម្មេ** សេចក្តីថា ទិដ្ឋធម្មវេទនីយកម្មរមែងឲ្យផលនោះឯងក្នុងបច្ចុប្បន្ន ។ បទថា **ឧបបជ្ជេ** សេចក្តីថា ឧបបជ្ជវេទនីយកម្មរមែងឲ្យផលក្នុងភពតទៅ ។ បទថា **អបរេ វា បរិយាយេ** សេចក្តីថា ឯអបរាបរវេទនីយកម្ម កាលសត្វនៅប្រព្រឹត្តទៅក្នុងសង្សារវដ្ត រមែងឲ្យផល

ដល់រាប់សែនអត្តភាពនោះឯង ដោយបទនេះ ទ្រង់សម្តែងសេចក្តីដូច្នេះថា ក្នុងកម្មដែលសមគួរដល់វិបាកដែលបានហើយ ក្នុងកាលសត្វប្រព្រឹត្តទៅក្នុងសង្សារវដ្ត មិនមានបទេសនៃផែនដី ដែលសត្វតាំងនៅហើយ គប្បីផុតចាកបាបកម្មទៅបាន ។ បទថា **តិវិធំ** ប្រែថា ៣ ប្រការ ។ បទថា **កាយកម្មន្តសន្ទោសព្យាបត្តិ** ប្រែថា វិបត្តិ ពោល គឺទោសនៃកាយកម្ម ។ បទថា **អបណ្ណកោមណិ** បានដល់ កូនបាសកា ដែលមានជ្រុង ៤ ដោយជុំវិញ ។ គប្បីជ្រាបបទទាំងអស់ដោយន័យនេះឯង ៕

**អដ្ឋកថាបឋមកម្មសូត្រទី ៦ ចប់**[១]

# សុត្តន្តបិដក

## ទុតិយកម្មសូត្រទី ៧

[ ៩៥ ] ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលពោលនូវការអស់ទៅនៃកម្មទាំងឡាយ ប្រកបដោយចេតនា ដែលសត្វធ្វើហើយ សន្សំហើយ ព្រោះមិនបានទទួលនូវផលទេ ឯផលនោះឯង រមែងកើតមានក្នុងបច្ចុប្បន្ននេះក៏មាន ក្នុងអត្តភាពជាលំដាប់ក៏មាន ក្នុងអត្តភាពដទៃក៏មាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលពោលនូវកិរិយាធ្វើនូវទីបំផុតនៃទុក្ខ ព្រោះមិនទាន់ទទួលផល

១- អដ្ឋកថាបាលីជាសូត្រទី ៧

នៃកម្មប្រកបដោយចេតនា ដែលសត្វធ្វើហើយ សន្សំហើយទេ ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាអកុសលកម្មទាំងនោះ វិបត្តិ គឺទោសនៃកាយកម្មមាន ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល វិបត្តិ គឺទោសនៃវចីកម្មមាន ៤ យ៉ាង ដែលប្រកបដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល វិបត្តិ គឺទោសរបស់មនោកម្មមាន ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល ។

ម្នាលភិក្ខុទាំងឡាយ វិបត្តិ គឺទោសរបស់កាយកម្មមាន ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល តើដូចម្ដេច ។បេ។ ម្នាលភិក្ខុទាំងឡាយ វិបត្តិ គឺទោសនៃកាយកម្ម ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល ដោយប្រការដូច្នេះឯង ។

ម្នាលភិក្ខុទាំងឡាយ វិបត្តិ គឺទោសនៃវចីកម្មមាន ៤ យ៉ាង ដែលប្រកបដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល តើដូចម្ដេច ។បេ។ ម្នាលភិក្ខុទាំងឡាយ វិបត្តិ គឺទោសនៃវចីកម្ម មាន ៤ យ៉ាង ដែលប្រកបដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល ដោយប្រការដូច្នេះឯង ។

ម្នាលភិក្ខុទាំងឡាយ វិបត្តិ គឺទោសរបស់មនោកម្មមាន ៣ យ៉ាង ដែល

ប្រកបដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល តើដូចម្តេច ។បេ។ ម្នាលភិក្ខុទាំងឡាយ វិបត្តិ គឺទោសនៃមនោកម្ម មាន ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល ដោយប្រការដូច្នេះឯង ។

ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុតែវិបត្តិ គឺទោសរបស់កាយកម្ម មាន ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនាក៏មាន ព្រោះហេតុតែវិបត្តិ គឺទោសរបស់វចីកម្មមាន ៤ យ៉ាង ដែលប្រកបដោយអកុសល-ចេតនាក៏មាន ។បេ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុតែវិបត្តិ គឺទោសនៃមនោកម្មមាន ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនាក៏មាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលពោលនូវសេចក្តីអស់ទៅនៃកម្មទាំងឡាយ ប្រកបដោយចេតនា ដែលសត្វធ្វើហើយ សន្សំហើយ ព្រោះមិនបានទទួលនូវផលទេ ឯផលនោះឯង រមែងកើតក្នុងបច្ចុប្បន្នក៏មាន ក្នុងអត្តភាពជាលំដាប់ក៏មាន ក្នុងអត្តភាពដទៃទៅក៏មាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលពោលនូវកិរិយាធ្វើនូវទីបំផុតនៃទុក្ខ ព្រោះមិនទទួលនូវផលនៃកម្មទាំងឡាយ ប្រកបដោយចេតនាដែលសត្វធ្វើហើយ សន្សំហើយទេ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាកុសលកម្មទាំងនោះ សម្បត្តិ គឺកាយកម្មមាន ៣ យ៉ាង

ដែលប្រកបដោយកុសលចេតនា រមែងមានសុខជាកម្រៃ មានសុខជាផល សម្បត្តិ គឺវចីកម្មមាន ៤ យ៉ាង ដែលប្រកបដោយកុសលចេតនា រមែងមានសុខជាកម្រៃ មានសុខជាផល សម្បត្តិ គឺមនោកម្មមាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនា រមែងមានសុខជាកម្រៃ មានសុខជាផល ។

ម្នាលភិក្ខុទាំងឡាយ សម្បត្តិ គឺកាយកម្ម មាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនា មានសុខជាកម្រៃ មានសុខជាផល តើដូចម្តេច ។បេ។ ម្នាលភិក្ខុទាំងឡាយ សម្បត្តិ គឺកាយកម្ម មាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនា រមែងមានសុខជាកម្រៃ មានសុខជាផល ដូច្នេះឯង ។

ម្នាលភិក្ខុទាំងឡាយ សម្បត្តិ គឺវចីកម្ម មាន ៤ យ៉ាង ដែលប្រកបដោយកុសលចេតនា មានសុខជាកម្រៃ មានសុខជាផល តើដូចម្តេច ។បេ។ ម្នាលភិក្ខុទាំងឡាយ សម្បត្តិ គឺវចីកម្ម មាន ៤ យ៉ាង ដែលប្រកបដោយកុសល-ចេតនា រមែងមានសុខជាកម្រៃ មានសុខជាផល ដូច្នេះឯង ។

ម្នាលភិក្ខុទាំងឡាយ សម្បត្តិ គឺមនោកម្ម មាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនា មានសុខជាកម្រៃ មានសុខជាផល តើដូចម្តេច ។បេ។ ម្នាលភិក្ខុទាំងឡាយ សម្បត្តិ គឺមនោកម្ម មាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនា រមែងមានសុខជាកម្រៃ មានសុខជាផល ដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ រមែងទៅកើតឯសុគតិសួគ៌ទេវលោក ព្រោះហេតុតែសម្បត្តិ គឺកាយកម្មមាន ៣ យ៉ាង

ដែលប្រកបដោយកុសលចេតនាក៏មាន ព្រោះហេតុតែសម្បត្តិគឺវចីកម្ម មាន ៤ យ៉ាង ដែលប្រកបដោយកុសលចេតនាក៏មាន ។បេ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតឯសុគតិសួគ៌ ទេវលោក ព្រោះហេតុតែសម្បត្តិ គឺមនោកម្ម ដែលប្រកបដោយកុសល-ចេតនាក៏មាន ។

# អដ្ឋកថា

## ទុតិយកម្មសូត្រ

[ ៩៥ ] ក្នុងទុតិយកម្មសូត្រទី ៧ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាទុតិយកម្មសូត្រទី ៧ ចប់

# សុត្តន្តបិដក

## តតិយកម្មសូត្រទី ៨

[ ៩៦ ] ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលពោលនូវសេចក្តីអស់ទៅនៃកម្មទាំងឡាយ ប្រកបដោយចេតនា ដែលសត្វធ្វើហើយ សន្សំហើយ ព្រោះមិនបានទទួលនូវផលទេ ឯផលនោះឯង រមែងកើតក្នុងបច្ចុប្បន្នក៏មាន ក្នុងអត្តភាពជាលំដាប់ក៏មាន ក្នុងអត្តភាពដទៃក៏មាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលនូវកិរិយា ធ្វើនូវទីបំផុតនៃទុក្ខ ព្រោះមិនបានទទួលនូវផលនៃកម្មទាំងឡាយ ប្រកបដោយចេតនា ដែលសត្វធ្វើហើយ សន្សំហើយទេ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កនោះឯង ប្រាសចាកអភិជ្ឈា ប្រាសចាកព្យាបាទ ជាអ្នកមិនវង្វេង មានប្រាជ្ញាស្មារតីខ្ជាប់ខ្ជួន មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយមេត្តាដ៏ធំទូលាយ មានប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់ទិសខាងលើ ខាងក្រោម និងទិសទទឹង គឺទិសតូចៗ ផ្សាយទៅកាន់លោកទាំងមូល ដោយយកខ្លួន ទៅប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទិសទាំងពួង ដោយប្រការដូច្នេះ ភិក្ខុនោះដឹងច្បាស់យ៉ាងនេះថា ចិត្តអាត្មាអញនេះ ជាកាមាវចរ ដែលមិនបានចម្រើនហើយ ក្នុងកាលមុន លុះដល់ក្នុងកាលឥឡូវនេះ ចិត្តអាត្មាអញនេះ ជាអរូបាវចរ ដែលបានចម្រើនល្អហើយ ម្យ៉ាងទៀត កម្មណាមួយ ដែលជាកាមាវចរ កម្មនោះ រមែងមិនសល់នៅក្នុងចិត្តនោះ កម្មនោះមិនឋិតនៅក្នុងចិត្តនោះទេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-

ទ្បាយ សម្គាល់នូវកម្មនោះដូចម្តេច បើកុមារនេះ ចម្រើនមេត្តាចេតោវិមុត្តិ ចាប់ដើមតាំងអំពីខ្ចីនៅក្មេង តើកុមារនោះ គប្បីធ្វើនូវបាបកម្ម បានដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនបានទេ ។ សេចក្តីទុក្ខគប្បីពាល់ត្រូវនូវកុមារនេះ កាលដែលមិនធ្វើនូវបាបកម្ម បានដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនបានទេ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា សេចក្តីទុក្ខនឹងពាល់ត្រូវអ្នកដែលមិនធ្វើនូវបាបកម្មអំពីណាបាន ។ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងមេត្តាចេតោវិមុត្តិនេះ ស្ត្រីក្តី បុរសក្តី គួរចម្រើនដោយពិត ម្នាលភិក្ខុទាំងឡាយ ស្ត្រីក្តី បុរសក្តី មិនអាចកាន់យកនូវកាយនេះហើយ ទៅកាន់បរលោកទេ ម្នាលភិក្ខុទាំង-ឡាយ សត្វនេះ មានចិត្តជាមូលហេតុ ។ ភិក្ខុនោះ ដឹងច្បាស់យ៉ាងនេះថា បាបកម្មណាមួយ ដែលអាត្មាអញធ្វើហើយ ដោយករជកាយនេះ ក្នុងកាលមុន បាបកម្មទាំងអស់នោះ អាត្មាអញត្រូវទទួលផលក្នុងលោកនេះ បាបកម្មនោះនឹងលែងមានតទៅ ។ ម្នាលភិក្ខុទាំងឡាយ មេត្តាចេតោវិមុត្តិ ដែលភិក្ខុអ្នកមានប្រាជ្ញា ក្នុងសាសនានេះ កាលមិនបានពិចារណា ឃើញច្បាស់នូវវិមុត្តិ គឺអរហត្តផលតទៅ ចម្រើនហើយយ៉ាងនេះ ក៏រមែងប្រព្រឹត្តទៅ ដើម្បីអនាគាមិ-ធម៌ ។ ភិក្ខុមានចិត្តប្រកបដោយករុណា ... មានចិត្តប្រកបដោយមុទិតា ... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយឧបេក្ខា ដ៏ធំទូលាយ មានប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់ទិសខាងលើ ទិសខាង

ក្រោម និងទិសទទឹង គឺទិសតូចៗ ផ្សាយទៅកាន់លោកទាំងមូល ដោយយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងពួង ដោយប្រការដូច្នេះ ភិក្ខុនោះដឹងច្បាស់យ៉ាងនេះថា ចិត្តអាត្មាអញនេះ ជាកាមាវចរចិត្ត មិនទាន់បានចម្រើនក្នុងកាលមុនទេ លុះដល់ក្នុងកាលឥឡូវនេះ ចិត្តអាត្មាអញនេះ ជាអរូបាវចរដែលបានចម្រើនល្អហើយ ចំណែកខាងកម្មណាមួយ ជាកាមាវចរ កម្មនោះនឹងមិនសល់នៅក្នុងចិត្តនោះទេ កម្មនោះមិនឋិតនៅក្នុងចិត្តនោះទេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់នូវហេតុនោះដូចម្ដេច បើកុមារនេះចម្រើនឧបេក្ខាចេតោវិមុត្តិ ចាប់ដើមតាំងអំពីខ្លួននៅក្មេង តើគប្បីធ្វើបាបកម្មបានដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនបានទេ ។ សេចក្ដីទុក្ខគប្បីពាល់ត្រូវនូវកុមារនោះ កាលដែលមិនធ្វើនូវបាបកម្ម ដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនបានទេ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា សេចក្ដីទុក្ខនឹងពាល់ត្រូវនូវអ្នកដែលមិនធ្វើបាបកម្មអំពីណាបាន ។ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងឧបេក្ខា-ចេតោវិមុត្តិនេះ ស្ត្រីក្ដី បុរសក្ដី គួរចម្រើនដោយពិត ម្នាលភិក្ខុទាំងឡាយ ស្ត្រីក្ដី បុរសក្ដី មិនអាចកាន់យកនូវកាយនេះ ទៅកាន់បរលោកទេ ម្នាលភិក្ខុទាំងឡាយ សត្វនេះមានចិត្តជាមូលហេតុ ។ ភិក្ខុនោះ ដឹងច្បាស់យ៉ាងនេះថា បាបកម្មឯណាមួយ ដែលអាត្មាអញបានធ្វើហើយ ដោយករជកាយនេះ ក្នុងកាលមុន បាបកម្មទាំងអស់នោះ អាត្មាអញត្រូវទទួលផល ក្នុងលោកនេះ បាបកម្មនោះនឹងលែងមានតទៅ ។ ម្នាលភិក្ខុទាំងឡាយ ឧបេក្ខាចេតោវិមុត្តិ

ដែលភិក្ខុអ្នកមានប្រាជ្ញា ក្នុងសាសនានេះ កាលមិនបានពិចារណាឃើញច្បាស់នូវវិមុត្តិ គឺអរហត្តផលតទៅ ចម្រើនហើយយ៉ាងនេះ ក៏រមែងប្រព្រឹត្តទៅ ដើម្បីជាអនាគាមិធម៌ ។

# អដ្ឋកថា

## តតិយកម្មសូត្រ

[ ៩៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុង តតិយកម្មសូត្រ ៨ ដូចតទៅនេះ បទថា **ទុក្ខស្ស** បានដល់ ទុក្ខដែលជាវិបាក ឬទុក្ខក្នុងវដ្ដ: ក្នុងសូត្រនេះ មិនមានឧបមាដោយកូនបាសកា ។ ពាក្យថា **ឯវំ** ក្នុងបទថា **ឯវំ វិគតាភិជ្ឈោ** នេះ ត្រឹមតែជានិបាត ។ម្យ៉ាងទៀត ជនទាំងឡាយ ចម្រើនមេត្តា រមែងជាបុគ្គលប្រាសចាកអភិជ្ឈា យ៉ាងណា ព្រះអរិយសាវក ក៏ជាអ្នកប្រាសចាកអភិជ្ឈា ដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងការដែលព្រះអរិយសាវកនោះ សង្កត់នីវរណៈបាន ដោយភាពជាបុគ្គលប្រាសចាកអភិជ្ឈាជាដើម យ៉ាងនេះហើយ កាលត្រាស់និស្សរណៈ គឺការស្ទុះចេញទៅអំពីអកុសល ទើបត្រាស់ថា **មេត្តាសហគតេន** ជាដើម ។ បទថា **អប្បមាណំ** បានដល់ ឈ្មោះថា មិនមានប្រមាណ ព្រោះជាបុគ្គលមានសត្វមិនមានប្រមាណជាអារម្មណ៍ ឬព្រោះជាបុគ្គលដែលមានការជំនាញសន្សំហើយ កាមាវចរកម្ម ឈ្មោះថា កម្ម

ដែលធ្វើដោយប្រមាណ ។ បទថា **ន តំ តត្រាវតិដ្ឋតិ** សេចក្ដីថា កាមាវចរកម្មនោះ មិនអាចកាន់យកឱកាសរបស់ខ្លួន តាំងនៅបាន ដូចទឹកតិចតួចក្នុងអន្លង់ទឹកធំ ដែលពិត កម្មមិនមានប្រមាណនេះប៉ុណ្ណោះ គ្របសង្កត់កាមាវចរ កម្មនោះដូចទឹកតិចក្នុងអន្លង់ទឹក រមែងធ្វើវិបាករបស់ខ្លួនឲ្យកើតឡើង ។

បទថា **ទហរតគ្គេ** ប្រែថា តាំងអំពីនៅជាកុមារ ។ បទថា **នាយំ កាយោ អាទាយ គមនីយោ** សេចក្ដីថា មិនអាចនាំកាយនេះទៅកាន់បរលោកបាន ។ បទថា **ចិត្តន្តរោ** ប្រែថា មានចិត្តជាហេតុ ។ ម្យ៉ាងទៀត ប្រែថា ប្រព្រឹត្តទៅក្នុងលំដាប់ដោយចិត្តនោះឯង អធិប្បាយថា ពិតហើយ ឈ្មោះថាទេវតា ឈ្មោះថា សត្វនរក ឈ្មោះថា សត្វតិរច្ឆាន ក៏ព្រោះបដិសន្ធិចិត្តដួងទី ២ ក្នុងលំដាប់នៃចុតិចិត្តដួងទី ១ នោះឯង ។ តែក្នុងន័យដើម ជាទេវក្ដីសត្វនរកក្ដី ក៏ត្រឹមជាចិត្តដែលជាតួហេតុ ។ បទថា **សព្វន្តំ ឥធ វេទនីយំ** នេះ ត្រាស់ដោយអំណាចចំណែកនៃទិដ្ឋធម្មវេទនីយកម្ម ។ បទថា **ន តំ អនុភវិស្សតិ** សេចក្ដីថា ចាត់ជាកម្មដែលមិនប្រព្រឹត្តតាមដោយអំណាចឧបបជ្ជវេទនីយកម្ម ព្រោះភាពជាឧបបជ្ជវេទនីយកម្ម ត្រូវមេត្តាកាត់ផ្ដាច់ហើយ តែសេចក្ដីនេះ គប្បីជ្រាបថា ជាបច្ចវេក្ខណញ្ញាណរបស់ព្រះអរិយបុគ្គល គឺព្រះសោតាបន្ន និងព្រះសកទាគាមី ។ បទថា **អនាគាមិតាយ** បានដល់ដើម្បីភាពជាព្រះអនាគាមីដោយឈាន ។ បទថា **ឥធ បញ្ញស្ស** សេចក្ដីថា ឈ្មោះថា បញ្ញាក្នុងព្រះសាសនានេះ ជារបស់សម្រាប់ព្រះអរិយសាវកដែល

តាំងនៅក្នុងអរិយបញ្ញា ដែលជាសាសនចរិត ។ បទថា **អនុត្តរំ វិមុត្តឹ** បានដល់ អរហត្ត ។ល។

**អដ្ឋកថា តតិយកម្មសូត្រ ៨ ចប់**[១]

# សុត្តន្តបិដក

## ព្រាហ្មណសូត្រទី ៩

[ ៩៧ ] គ្រានោះ ព្រាហ្មណ៍ម្នាក់ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រាហ្មណ៍នោះ អង្គុយក្នុងទីសមគួរហើយ ក៏ទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យពួកសត្វខ្លះ ក្នុងលោកនេះ បែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ព្រះអង្គត្រាស់ថា ម្នាលព្រាហ្មណ៍ សត្វពួកខ្លះក្នុងលោកនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុនៃការមិនប្រព្រឹត្តធម៌ និងការប្រព្រឹត្តមិនស្មើយ៉ាងនេះឯង ។

---

១- អដ្ឋកថាបាលីសូត្រទី ៩

បពិត្រព្រះគោតមដ៏ចម្រើន ចុះអ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យពួកសត្វខ្លះ ក្នុងលោកនេះ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតឯសុគតិសួគ៌ទេវលោក ។ ម្នាលព្រាហ្មណ៍ សត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតឯសុគតិសួគ៌ ទេវលោក ព្រោះហេតុនៃការប្រព្រឹត្តធម៌ និងការប្រព្រឹត្តស្មើយ៉ាងនេះឯង ។ ភាសិតសង្ខេបរបស់ព្រះគោតមដ៏ចម្រើននេះ ខ្ញុំព្រះអង្គមិនដឹងច្បាស់នូវសេចក្តីដោយពិស្តារបានទេ ភាសិតសង្ខេបរបស់ព្រះគោតមដ៏ចម្រើននេះ ខ្ញុំព្រះអង្គគប្បីដឹងនូវសេចក្តីដោយពិស្តារបានយ៉ាងណា សូមព្រះគោតមដ៏ចម្រើន សម្តែងធម៌យ៉ាងនោះ ដល់ខ្ញុំព្រះអង្គឲ្យទាន ។ ម្នាលព្រាហ្មណ៍ បើដូច្នោះ ចូរអ្នកស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ព្រាហ្មណ៍នោះ ទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងដូច្នេះថា ម្នាលព្រាហ្មណ៍ ការមិនប្រព្រឹត្តធម៌ និងការប្រព្រឹត្តមិនស្មើដោយកាយ មាន ៣ យ៉ាង ការមិនប្រព្រឹត្តធម៌ និងការប្រព្រឹត្តមិនស្មើដោយវាចា ៤ យ៉ាង ការមិនប្រព្រឹត្តធម៌ និងការប្រព្រឹត្តមិនស្មើដោយចិត្ត ៣ យ៉ាង ។

ម្នាលព្រាហ្មណ៍ ការមិនប្រព្រឹត្តធម៌ និងការប្រព្រឹត្តមិនស្មើដោយកាយ មាន ៣ យ៉ាង តើដូចម្តេច ។បេ។ ម្នាលព្រាហ្មណ៍ ការមិនប្រព្រឹត្តធម៌ និងការប្រព្រឹត្តមិនស្មើដោយកាយ ៣ យ៉ាងនេះឯង ។

ម្នាលព្រាហ្មណ៍ ការមិនប្រព្រឹត្តធម៌ និងការប្រព្រឹត្តមិនស្មើដោយវាចា

៤ យ៉ាង តើដូចម្តេច ។បេ។ ម្នាលព្រាហ្មណ៍ ការមិនប្រព្រឹត្តធម៌ និងការប្រព្រឹត្តមិនស្មើដោយវាចា ៤ យ៉ាងនេះឯង ។

ម្នាលព្រាហ្មណ៍ ចុះការប្រព្រឹត្តធម៌ និងការប្រព្រឹត្តមិនស្មើ ដោយចិត្តមាន ៣ យ៉ាង តើដូចម្តេច ។បេ។ ម្នាលព្រាហ្មណ៍ ការប្រព្រឹត្តធម៌ និងការប្រព្រឹត្តមិនស្មើដោយចិត្ត មាន ៣ យ៉ាងនេះឯង ។ ម្នាលព្រាហ្មណ៍ សត្វពួកខ្លះ ក្នុងលោកនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុនៃការមិនប្រព្រឹត្តធម៌ និងការប្រព្រឹត្តមិនស្មើ យ៉ាងនេះឯង ។ ម្នាលព្រាហ្មណ៍ ការប្រព្រឹត្តធម៌ និងការប្រព្រឹត្តស្មើដោយកាយ ៣ យ៉ាង ការប្រព្រឹត្តធម៌ និងការប្រព្រឹត្តស្មើដោយវាចា ៤ យ៉ាង ការប្រព្រឹត្តធម៌ និងការប្រព្រឹត្តស្មើដោយចិត្ត ៣ យ៉ាង ។

ម្នាលព្រាហ្មណ៍ ការប្រព្រឹត្តធម៌ និងការប្រព្រឹត្តស្មើដោយកាយ មាន ៣ យ៉ាង តើដូចម្តេច ។បេ។ ម្នាលព្រាហ្មណ៍ ការប្រព្រឹត្តធម៌ និងការប្រព្រឹត្តស្មើដោយកាយ ៣ យ៉ាងនេះឯង ។

ម្នាលព្រាហ្មណ៍ ការប្រព្រឹត្តធម៌ និងការប្រព្រឹត្តស្មើ ដោយវាចាមាន ៤ យ៉ាង តើដូចម្តេច ។បេ។ ម្នាលព្រាហ្មណ៍ ការប្រព្រឹត្តធម៌ និងការប្រព្រឹត្តស្មើដោយវាចា ៤ យ៉ាងនេះឯង ។

ម្នាលព្រាហ្មណ៍ ការប្រព្រឹត្តធម៌ និងការប្រព្រឹត្តស្មើដោយចិត្តមាន ៣ យ៉ាង តើដូចម្តេច ។បេ។ ម្នាលព្រាហ្មណ៍ ការប្រព្រឹត្តធម៌ និងការប្រព្រឹត្ត

ស្មើដោយចិត្ត ៣ យ៉ាងនេះឯង ។ ម្នាលព្រាហ្មណ៍ សត្វពួកខ្លះ ក្នុងលោកនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតឯសុគតិសួគ៌ទេវលោក ព្រោះហេតុនៃការប្រព្រឹត្តធម៌ និងការប្រព្រឹត្តស្មើ យ៉ាងនេះឯង ។ បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ ។បេ។ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គ ជាជាឧបាសក ដល់នូវសរណៈស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះតទៅ ។

បឋមវគ្គទី ១ ចប់

# អដ្ឋកថា

## ព្រាហ្មណសូត្រ

[ ៩៧ ] ក្នុងព្រាហ្មណសូត្រទី ៩ មានអត្ថងាយយល់ហើយ ។

**អដ្ឋកថាព្រាហ្មណសូត្រទី ៩ ចប់**

**បឋមវគ្គទី ១ ចប់**

# សុត្តន្តបិដក

## ទុតិយវគ្គទី ២

[ ៩៨ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាង នឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ធម៌ ១០ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកសម្លាប់សត្វ ១ ជាអ្នកកាន់យកទ្រព្យដែលគេមិនបានឲ្យ ១ ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ជាអ្នកពោលនូវពាក្យកុហក ១ ជាអ្នកពោលនូវពាក្យញុះញង់ ១ ជាអ្នកពោលនូវពាក្យអាក្រក់ ១ ជាអ្នកពោលនូវពាក្យរោយរាយឥតប្រយោជន៍ ១ ជាអ្នកច្រើនដោយការសម្លឹងរំពៃចំពោះទ្រព្យអ្នកដទៃ ១ ជាអ្នកមានចិត្តព្យាបាទ ១ ជាអ្នកយល់ខុស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាងនេះឯង នឹងធ្លាក់ទៅក្នុងនរកដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាង នឹងទៅកើតឯស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។ ធម៌ទាំង ១០ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកវៀរចាកបាណាតិបាត ១ វៀរចាកអទិន្នាទាន ១ វៀរចាកកាមេសុមិច្ឆាចារ ១ វៀរចាកមុសាវាទ ១ វៀរចាកបិសុណាវាចា ១ វៀរចាកផរុសវាចា ១ វៀរចាកសម្ផប្បលាប ១ ជាអ្នកមិនច្រើនដោយអភិជ្ឈា ១ មានចិត្តមិនព្យាបាទ ១ ជាសម្មាទិដ្ឋិ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាងនេះឯង នឹងទៅកើតឯស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។

[ ៩៩ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ២០ យ៉ាង នឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ធម៌ ២០ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកសម្លាប់សត្វ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការសម្លាប់សត្វ ១ កាន់យកទ្រព្យដែលគេមិនឲ្យ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការកាន់យកទ្រព្យដែលគេមិនឲ្យ ១ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ពោលពាក្យកុហកដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការពោលពាក្យកុហក ១ ពោលពាក្យញុះញង់ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការពោលពាក្យញុះញង់ ១ ពោលពាក្យអាក្រក់ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការពោលពាក្យអាក្រក់ ១ ពោលពាក្យឥតប្រយោជន៍ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការពោលពាក្យឥតប្រយោជន៍ ១ ច្រើនដោយអភិជ្ឈា ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងអភិជ្ឈា ១ មានចិត្តព្យាបាទដោយខ្លួនឯង ១ បបួលអ្នកដទៃក្នុងការព្យាបាទ ១ ជាអ្នកយល់ខុស ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការយល់ខុស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ២០ យ៉ាងនេះឯង នឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ២០ យ៉ាង នឹងទៅកើតឯស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។ ធម៌ ២០ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកវៀរចាកបាណាតិបាត ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកបាណាតិបាត ១ វៀរចាក

អទិន្នាទាន ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកអទិន្នាទាន ១ វៀរចាកកាមេសុមិច្ឆាចារ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកកាមេសុមិច្ឆាចារ ១ វៀរចាកមុសាវាទ ដោយខ្លួនឯង ១ បបួលអ្នកដទៃក្នុងការវៀរចាកមុសាវាទ ១ វៀរចាកបិសុណវាចា ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកបិសុណវាចា ១ វៀរចាកផរុសវាចា ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកផរុសវាចា ១ វៀរចាកសម្ផប្បលាប ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកសម្ផប្បលាប ១ ជាអ្នកមិនច្រើនដោយអភិជ្ឈា ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងអនភិជ្ឈា ១ មិនមានចិត្តព្យាបាទ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការមិនព្យាបាទ ១ ជាសម្មាទិដ្ឋិ ដោយខ្លួនឯង ១ បបួលអ្នកដទៃក្នុងសម្មាទិដ្ឋិ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ២០ យ៉ាងនេះឯង នឹងទៅកើតឯស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។

[ ១០០ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣០ យ៉ាងនឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ធម៌ ៣០ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកសម្លាប់សត្វ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការសម្លាប់សត្វ ១ ពេញចិត្តក្នុងការសម្លាប់សត្វ ១ កាន់យកទ្រព្យដែលគេមិនបានឲ្យ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការកាន់យកទ្រព្យដែលគេមិនបានឲ្យ ១ ពេញចិត្ត ក្នុងការកាន់យកទ្រព្យដែលគេមិនបានឲ្យ ១ ប្រព្រឹត្តខុសក្នុងកាមទាំង-

ឡាយ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការប្រព្រឹត្តខុស ក្នុងកាមទាំង-ឡាយ ១ ពេញចិត្តក្នុងការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ១ ពោលពាក្យកុហក ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការពោលពាក្យកុហក ១ ពេញចិត្ត ក្នុងការពោលពាក្យកុហក ១ ពោលពាក្យញុះញង់ ដោយខ្លួនឯង ១ បបួលអ្នកដទៃក្នុងការពោលពាក្យញុះញង់ ១ ពេញចិត្តក្នុងការពោលពាក្យញុះញង់ ១ ពោលពាក្យអាក្រក់ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការពោលពាក្យអាក្រក់ ១ ពេញចិត្តក្នុងការពោលពាក្យអាក្រក់ ១ ពោលពាក្យឥតប្រយោជន៍ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការពោលពាក្យឥតប្រយោជន៍ ១ ពេញចិត្តក្នុងការពោលពាក្យឥតប្រយោជន៍ ១ ច្រើនសម្លឹងរំពៃ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការសម្លឹងរំពៃ ១ ពេញចិត្តក្នុងការសម្លឹងរំពៃ ១ មានចិត្តគុំកួន ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការគុំកួន ១ ពេញចិត្តក្នុងការគុំកួន ១ យល់ខុស ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការយល់ខុស ១ ពេញចិត្តក្នុងការយល់ខុស ១ ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលប្រកបដោយធម៌ ៣០ យ៉ាងនេះឯង នឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣០ យ៉ាង នឹងទៅកើតឯស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។ ធម៌ ៣០ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកវៀរចាកបាណាតិបាត ដោយខ្លួនឯង ១ បបួលអ្នកដទៃក្នុងការវៀរចាកបាណាតិបាត ១ ពេញចិត្តក្នុងការវៀរចាកបាណា-

តិបាត ១ វៀរចាកអទិន្នាទាន ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកអទិន្នាទាន ១ ពេញចិត្តក្នុងការវៀរចាកអទិន្នាទាន ១ វៀរចាកកាមេសុមិច្ឆាចារ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកកាមេសុមិច្ឆាចារ ១ ពេញចិត្តក្នុងការវៀរចាកកាមេសុមិច្ឆាចារ ១ វៀរចាកមុសាវាទ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកមុសាវាទ ១ ពេញចិត្តក្នុងការវៀរចាកមុសាវាទ ១ វៀរចាកបិសុណាវាចា ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកបិសុណាវាចា ១ ពេញចិត្តក្នុងការវៀរចាកបិសុណាវាចា ១ វៀរចាកផរុសវាចា ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកផរុសវាចា ១ ពេញចិត្តក្នុងការវៀរចាកផរុសវាចា ១ វៀរចាកសម្ផប្បលាប ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកសម្ផប្បលាប ១ ពេញចិត្តក្នុងការវៀរចាកសម្ផប្បលាប ១ ជាអ្នកមិនមានអភិជ្ឈា ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការមិនមានអភិជ្ឈា ១ ពេញចិត្តក្នុងការមិនមានអភិជ្ឈា ១ មានចិត្តមិនព្យាបាទ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការមិនព្យាបាទ ១ ពេញចិត្តក្នុងការមិនព្យាបាទ ១ យល់ត្រូវដោយខ្លួនឯង ១ បបួលអ្នកដទៃក្នុងការយល់ត្រូវ ១ ពេញចិត្តក្នុងការយល់ត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣០ យ៉ាងនេះឯង នឹងទៅកើតឯស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។

[ ១០១ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤០ យ៉ាង នឹង

ធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ធម៌ ៤០ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកសម្លាប់សត្វ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការសម្លាប់សត្វ ១ ពេញចិត្តក្នុងការសម្លាប់សត្វ ១ ពោលសរសើរគុណ នៃការសម្លាប់សត្វ ១ កាន់យកទ្រព្យដែលគេមិនឲ្យ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការកាន់យកទ្រព្យ ដែលគេមិនឲ្យ ១ ពេញចិត្តក្នុងការកាន់យកទ្រព្យ ដែលគេមិនឲ្យ ១ ពោលសរសើរគុណ នៃការកាន់យកទ្រព្យ ដែលគេមិនឲ្យ ១ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ពេញចិត្តក្នុងការប្រព្រឹត្តខុសក្នុងកាមទាំង-ឡាយ ១ ពោលសរសើរគុណ នៃការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ពោលពាក្យកុហក ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការពោលពាក្យកុហក ១ ពេញចិត្តក្នុងការពោលពាក្យកុហក ១ ពោលសរសើរគុណ នៃការពោលពាក្យកុហក ១ ពោលពាក្យញុះញង់ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការពោលពាក្យញុះញង់ ១ ពេញចិត្តក្នុងការពោលពាក្យញុះញង់ ១ ពោលសរសើរគុណ នៃការពោលពាក្យញុះញង់ ១ ពោលពាក្យអាក្រក់ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការពោលពាក្យអាក្រក់ ១ ពេញចិត្តក្នុងការពោលពាក្យអាក្រក់ ១ ពោលសរសើរគុណ នៃការពោលពាក្យអាក្រក់ ១ ពោលពាក្យឥតប្រយោជន៍ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការពោលពាក្យឥតប្រយោជន៍ ១ ពេញចិត្តក្នុងការពោលពាក្យឥតប្រយោជន៍ ១ ពោល

សរសើរគុណនៃការពោលពាក្យឥតប្រយោជន៍ ១ ជាអ្នកមានអភិជ្ឈា ដោយខ្លួនឯង ១ បបួលអ្នកដទៃក្នុងអភិជ្ឈា ១ ពេញចិត្តក្នុងអភិជ្ឈា ១ ពោលសរសើរគុណនៃអភិជ្ឈា ១ មានចិត្តព្យាបាទ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការព្យាបាទ ១ ពេញចិត្តក្នុងការព្យាបាទ ១ ពោលសរសើរគុណនៃការព្យាបាទ ១ យល់ខុសដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការយល់ខុស ១ ពេញចិត្តក្នុងការយល់ខុស ១ ពោលសរសើរគុណ នៃការយល់ខុស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤០ យ៉ាងនេះឯង នឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤០ យ៉ាង នឹងទៅកើតឯស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។ ធម៌ ៤០ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកវៀរចាកបាណាតិបាត ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកបាណាតិបាត ១ ពេញចិត្តក្នុងការវៀរចាកបាណាតិបាត ១ ពោលសរសើរគុណ នៃការវៀរចាកបាណា-តិបាត ១ វៀរចាកអទិន្នាទាន ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកអទិន្នាទាន ១ ពេញចិត្តក្នុងការវៀរចាកអទិន្នាទាន ១ ពោលសរសើរគុណ នៃការវៀរចាកអទិន្នាទាន ១ វៀរចាកកាមេសុមិច្ឆាចារ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកកាមេសុមិច្ឆាចារ ១ ពេញចិត្តក្នុងការវៀរចាកកាមេសុមិច្ឆាចារ ១ ពោលសរសើរគុណនៃការវៀរចាកកាមេសុមិច្ឆាចារ ១ វៀរចាកមុសាវាទ ដោយខ្លួនឯង ១ បបួលអ្នកដទៃក្នុងការវៀរចាក

មុសាវាទ ១ ពេញចិត្តក្នុងការវៀរចាកមុសាវាទ ១ ពោលសរសើរគុណនៃការវៀរចាកមុសាវាទ ១ វៀរចាកបិសុណាវាចា ដោយខ្លួនឯង ១ បបួលអ្នកដទៃក្នុងការវៀរចាកបិសុណាវាចា ១ ពេញចិត្តក្នុងការវៀរចាកបិសុណា-វាចា ១ ពោលសរសើរគុណ នៃការវៀរចាកបិសុណាវាចា ១ វៀរចាកផរុសវាចា ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកផរុសវាចា ១ ពេញចិត្តក្នុងការវៀរចាកផរុសវាចា ១ ពោលសរសើរគុណ នៃការវៀរចាកផរុសវាចា ១ វៀរចាកសម្ផប្បលាប ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកសម្ផប្បលាប ១ ពេញចិត្តក្នុងការវៀរចាកសម្ផប្បលាប ១ ពោលសរសើរគុណនៃការវៀរចាកសម្ផប្បលាប ១ ជាអ្នកមិនមានអភិជ្ឈា ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការមិនមានអភិជ្ឈា ១ ពេញចិត្តក្នុងការមិនមានអភិជ្ឈា ១ ពោលសរសើរគុណនៃការមិនមានអភិជ្ឈា ១ មិនមានចិត្តព្យាបាទដោយខ្លួនឯង ១ បបួលអ្នកដទៃក្នុងការមិនព្យាបាទ ១ ពេញចិត្តក្នុងការមិនព្យាបាទ ១ ពោលសរសើរគុណនៃការមិនព្យាបាទ ១ ជាអ្នកយល់ត្រូវ ដោយខ្លួនឯង ១ បបួលអ្នកដទៃក្នុងការយល់ត្រូវ ១ ពេញចិត្តក្នុងការយល់ត្រូវ ១ ពោលសរសើរគុណនៃការយល់ត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤០ យ៉ាងនេះឯង នឹងទៅកើតឯស្ថានសួគ៌ដូចជាគេនាំយកទៅតម្កល់ទុក ។

[ ១០២ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាង

ឈ្មោះថា រក្សាទុកនូវខ្លួន ដែលមានកុសលធម៌គាស់រម្លើង ផ្តាច់ផ្តិលចោលហើយ ... ឈ្មោះថា រក្សាទុកនូវខ្លួន ដែលមានកុសលធម៌មិនបានគាស់រម្លើង ផ្តាច់ផ្តិលចោលហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ២០ យ៉ាង ... ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣០ យ៉ាង ... ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤០ យ៉ាង ឈ្មោះថា រក្សាទុកនូវខ្លួន ដែលមានកុសលធម៌គាស់រម្លើង ផ្តាច់ផ្តិលចោលហើយ ... ឈ្មោះថា រក្សាទុកនូវខ្លួន ដែលមានកុសលធម៌មិនបានគាស់រម្លើង ផ្តាច់ផ្តិល ។បេ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤០ យ៉ាងនេះឯង ឈ្មោះថា រក្សាទុកនូវខ្លួន ដែលមានកុសលធម៌ មិនបានគាស់រម្លើង ផ្តាច់ផ្តិលចោលឡើយ ។

**ទុតិយវគ្គទី ២ ចប់**

# អដ្ឋកថា

# ទុតិយវគ្គទី ២

[ ៩៨-១០២ ] ទុតិយវគ្គ បាលីបេយ្យាលទាំងអស់ តាំងអំពីសូត្រទី ១ ជាដើមទៅ មានអត្ថងាយយល់ទាំងអស់ហើយ ។

**អដ្ឋកថា ទុតិយវគ្គទី ២ ចប់**

# សុត្តន្តបិដក

## តតិយវគ្គទី ៣

[ ១០៣ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ប្រកបដោយធម៌ទាំង ១០ យ៉ាង លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ... បុគ្គលខ្លះ ក្នុងលោកនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតឯសុគតិ សួគ៌ ទេវលោក ... ម្នាលភិក្ខុទាំង-ឡាយ បុគ្គលប្រកបដោយធម៌ ២០ យ៉ាង ... ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣០ យ៉ាង ... ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ប្រកបដោយធម៌ ៤០ យ៉ាង លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ... បុគ្គលខ្លះ ក្នុងលោកនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតឯសុគតិសួគ៌ទេវលោក ។បេ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាង គេគប្បីដឹងថា ជាបុគ្គលពាល ... គប្បីដឹងថា ជាបណ្ឌិត ... ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលប្រកបដោយធម៌ ២០ យ៉ាង ... ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣០ យ៉ាង ... ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤០ យ៉ាង គេគប្បីដឹងថា ជាបុគ្គលពាល ... គប្បីដឹងថា ជាបណ្ឌិត ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤០ យ៉ាងនេះឯង គេគប្បីដឹងថា ជាបណ្ឌិត ។

**តតិយវគ្គទី ៣ ចប់**

# អដ្ឋកថា

## តតិយវគ្គទី ៣

*[ ១០៣ ] មានអត្ថងាយយល់ទាំងអស់ហើយ ។*

**អដ្ឋកថា តតិយវគ្គទី ៣ ចប់**

# សុត្តន្តបិដក

*( ការរាប់នូវសូត្រ ក្នុងវគ្គទី ៤ និងវគ្គទី ៥ នេះ បណ្ឌិតគប្បីដឹង ដោយអំណាចបេយ្យាលៈ ) ។*

*[ ១០៤ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាង បុគ្គលគប្បីចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ១០ យ៉ាង តើអ្វីខ្លះ ។ គឺអសុភសញ្ញា ១ មរណសញ្ញា ១ អាហារេបដិកូលសញ្ញា ១ សព្វលោកេ អនភិរតសញ្ញា ១ អនិច្ចសញ្ញា ១ អនិច្ចេ ទុក្ខសញ្ញា ១ ទុក្ខេ អនត្តសញ្ញា ១ បហានសញ្ញា ១ វិរាគសញ្ញា ១ និរោធសញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាង នេះ បុគ្គលគប្បីចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។*

*[ ១០៥ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាង បុគ្គលគប្បីចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ១០ យ៉ាង តើអ្វីខ្លះ ។ គឺអនិច្ចសញ្ញា ១ អនត្តសញ្ញា ១ អាហារេបដិកូលសញ្ញា ១ សព្វលោកេ អនភិរតសញ្ញា ១*

អដ្ឋិកសញ្ញា ១ បុឡុវកសញ្ញា ១ វិនីលកសញ្ញា ១ វិបុព្វកសញ្ញា ១ វិច្ឆិទ្ទកសញ្ញា ១ ឧទ្ធុមាតកសញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាង នេះ បុគ្គលគប្បីចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។

[ ១០៦ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាង បុគ្គលគប្បីចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ១០ យ៉ាង តើអ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ សម្មាញាណៈ ១ សម្មាវិមុត្តិ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាងនេះ បុគ្គលគប្បីចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។

[ ១០៧ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាង បុគ្គលគប្បីចម្រើន ដើម្បីកំណត់ដឹង អស់រលីង លះបង់ អស់ទៅ សូន្យទៅ នឿយណាយ រម្ងត់ ស្ងប់រម្ងាប់ លះចោល រលាស់ចោល នូវរាគៈ ។បេ។ ធម៌ ១០ យ៉ាងនេះ បុគ្គលគប្បីចម្រើន ដើម្បីដឹងច្បាស់ កំណត់ដឹង អស់រលីង លះបង់ អស់ទៅ សូន្យទៅ នឿយណាយ រម្ងត់ ស្ងប់រម្ងាប់ លះចោល រលាស់ចោល នូវ

ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ ឥស្សា មច្ឆរិយៈ មាយា សាថេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ ។

បណ្ណាសកទី ៥ ចប់

ទសកនិបាត ចប់

# អដ្ឋកថា

## វគ្គទី ៤ ទី ៥

[ ១០៣-១០៧ ] មានអត្ថងាយយល់ទាំងអស់ហើយ ។

**អដ្ឋកថាតតិយវគ្គទី ៤-៥ ចប់**

**បញ្ចមបណ្ណាសក ចប់**

**ទសកនិបាត ចប់**

# សុត្តន្តបិដក
# អង្គុត្តរនិកាយ ឯកាទសកនិបាត

សូមក្រាបថ្វាយបង្គំ ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ

## និស្សយវគ្គទី ១

### កិមត្ថិយសូត្រទី ១

[ ១០៨ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សីលទាំងឡាយ ជាកុសលមានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ព្រះអង្គត្រាស់ថា ម្នាលអានន្ទ សីលទាំងឡាយ ជាកុសលមានអវិប្បដិសារៈ ( សេចក្តីមិនក្តៅក្រហាយ ) ជាប្រយោជន៍ មានអវិប្បដិសារៈជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចម្រើន អវិប្បដិសារៈ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ អវិប្បដិសារៈ មានបាមុជ្ជ ( សេចក្តីរីករាយទន់ ) ជាប្រយោជន៍ មានបាមុជ្ជជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចម្រើន បាមុជ្ជ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាល

អានន្ទ បាមុជ្ជ មានបីតិ ( សេចក្តីរីករាយខ្លាំង ) ជាប្រយោជន៍ មានបីតិជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចម្រើន បីតិ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ បីតិ មានបស្សទ្ធិ ( សេចក្តីស្ងប់រម្ងាប់ ) ជាប្រយោជន៍ មានបស្សទ្ធិជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចម្រើន បស្សទ្ធិមានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ បស្សទ្ធិ មានសុខជាប្រយោជន៍ មានសុខជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចម្រើន សុខមានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ សុខមានសមាធិ ( ការតាំងចិត្តមាំ ) ជាប្រយោជន៍ មានសមាធិជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចម្រើន សមាធិ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ សមាធិ មានយថាភូតញ្ញាណទស្សនៈ ( ការឃើញនូវសច្ចៈ ៤ ដោយញាណតាមពិត ) ជាប្រយោជន៍ មានយថាភូតញ្ញាណទស្សនៈ ជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចម្រើន យថាភូតញ្ញាណទស្សនៈ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ យថាភូតញ្ញាណទស្សនៈ មាននិព្វិទា ( សេចក្តីនឿយណាយ ) ជាប្រយោជន៍ មាននិព្វិទាជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចម្រើន និព្វិទា មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ និព្វិទា មានវិរាគៈ ( ការប្រាសចាកតម្រេក ) ជាប្រយោជន៍ មានវិរាគៈជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចម្រើន វិរាគៈ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ វិរាគៈ មានវិមុត្តិញ្ញាណទស្សនៈ ( បច្ចវេក្ខ-

ណញ្ញាណ ) ជាប្រយោជន៍ មានវិមុត្តិញ្ញាណទស្សនៈ ជាអានិសង្ស ។ ម្នាលអានន្ទ សីលទាំងឡាយជាកុសល មានអវិប្បដិសារៈជាប្រយោជន៍ មានអវិប្បដិសារៈជាអានិសង្ស អវិប្បដិសារៈ មានបាមុជ្ជជាប្រយោជន៍ មានបាមុជ្ជជាអានិសង្ស បាមុជ្ជ មានបីតិជាប្រយោជន៍ មានបីតិជាអានិសង្ស បីតិ មានបស្សទ្ធិជាប្រយោជន៍ មានបស្សទ្ធិជាអានិសង្ស បស្សទ្ធិ មានសុខជាប្រយោជន៍ មានសុខជាអានិសង្ស សុខ មានសមាធិជាប្រយោជន៍ មានសមាធិជាអានិសង្ស សមាធិ មានយថាភូតញ្ញាណទស្សនៈ ជាប្រយោជន៍ មានយថាភូតញ្ញាណទស្សនៈជាអានិសង្ស យថាភូតញ្ញាណទស្សនៈ មាននិព្វិទាជាប្រយោជន៍ មាននិព្វិទាជាអានិសង្ស និព្វិទា មានវិរាគៈជាប្រយោជន៍ មានវិរាគៈជាអានិសង្ស វិរាគៈ មានវិមុត្តិញ្ញាណទស្សនៈជាប្រយោជន៍ មានវិមុត្តិញ្ញាណទស្សនៈជាអានិសង្ស ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ សីលទាំងឡាយជាកុសល តែងបរិបូណ៌ ដើម្បីព្រះអរហត្ត តាមលំដាប់ដោយប្រការដូច្នេះឯង ។

## ចេតនាសូត្រទី ២

[ ១០៩ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានសីល បរិបូណ៌ដោយសីល មិនគប្បីធ្វើដោយចេតនាថា អវិប្បដិសារៈ ចូរកើតដល់អាត្មាអញដូច្នេះទេ ។ ម្នាលភិក្ខុទាំងឡាយ អវិប្បដិសារៈ តែងកើតឡើងដល់បុគ្គលអ្នកមានសីល បរិបូណ៌ដោយសីល នេះជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នក

មិនមានវិប្បដិសារៈ មិនគប្បីធ្វើដោយចេតនាថា បាមុជ្ជ ចូរកើតឡើងដល់អាត្មាអញដូច្នេះទេ ។ ម្នាលភិក្ខុទាំងឡាយ បាមុជ្ជ តែងកើតឡើងដល់បុគ្គលអ្នកមិនមានវិប្បដិសារៈ នេះជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានបាមុជ្ជ មិនគប្បីធ្វើដោយចេតនាថា បីតិ ចូរកើតឡើងដល់អាត្មាអញដូច្នេះទេ ។ ម្នាលភិក្ខុទាំងឡាយ បីតិ តែងកើតឡើងដល់បុគ្គលមានបាមុជ្ជ នេះជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានបីតិចិត្ត មិនគប្បីធ្វើដោយចេតនាថា កាយរបស់អាត្មាអញ ចូរស្ងប់រម្ងាប់ ដូច្នេះទេ ។ ម្នាលភិក្ខុទាំងឡាយ កាយរបស់បុគ្គលមានបីតិចិត្ត តែងស្ងប់រម្ងាប់ នេះជាធម្មតា ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលអ្នកមានកាយប្បស្សទ្ធិ មិនគប្បីធ្វើដោយចេតនាថា អាត្មាអញទទួលសេចក្តីសុខដូច្នេះទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានកាយប្បស្សទ្ធិ តែងទទួលសេចក្តីសុខ នេះជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានសេចក្តីសុខ មិនគប្បីធ្វើដោយចេតនាថា ចិត្តរបស់អាត្មាអញ ចូរតាំងមាំដូច្នេះទេ ។ ម្នាលភិក្ខុទាំងឡាយ ចិត្តរបស់បុគ្គលអ្នកមានសេចក្តីសុខ តែងតាំងមាំ នេះជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានសមាធិចិត្ត មិនគប្បីធ្វើដោយចេតនាថា អាត្មាអញដឹង អាត្មាអញឃើញ តាមពិតដូច្នេះទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសមាធិចិត្ត តែងដឹង តែងឃើញតាមពិត នេះជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹង កាលឃើញតាមពិត មិនគប្បីធ្វើដោយចេតនាថា អាត្មាអញនឿយណាយដូច្នេះទេ ។ ម្នាលភិក្ខុទាំង-

ឡាយ បុគ្គលកាលដឹង កាលឃើញតាមពិត តែងនឿយណាយ នេះជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនឿយណាយ មិនគប្បីធ្វើដោយចេតនាថា អាត្មាអញប្រាសចាកតម្រេកដូច្នេះទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនឿយណាយប្រាសចាកតម្រេក នេះជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានចិត្តប្រាសចាកតម្រេក មិនគប្បីធ្វើ ដោយចេតនាថា អាត្មាអញ ធ្វើឲ្យជាក់ច្បាស់នូវវិមុត្តិញ្ញាណទស្សនៈ ដូច្នេះទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកប្រាសចាកតម្រេក តែងធ្វើឲ្យជាក់ច្បាស់ នូវវិមុត្តិញ្ញាណទស្សនៈ នេះជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ វិរាគៈមានវិមុត្តិញ្ញាណទស្សនៈជាប្រយោជន៍ មានវិមុត្តិ-ញ្ញាណទស្សនៈជាអានិសង្ស និព្វិទា មានវិរាគៈជាប្រយោជន៍ មានវិរាគៈជាអានិសង្ស យថាភូតញ្ញាណទស្សនៈ មាននិព្វិទាជាប្រយោជន៍ មាននិព្វិទាជាអានិសង្ស សមាធិ មានយថាភូតញ្ញាណទស្សនៈ ជាប្រយោជន៍ មានយថា-ភូតញ្ញាណទស្សនៈ ជាអានិសង្ស សុខ មានសមាធិ ជាប្រយោជន៍ មានសមាធិ ជាអានិសង្ស បស្សទ្ធិ មានសុខជាប្រយោជន៍ មានសុខជាអានិសង្ស បីតិ មានបស្សទ្ធិជាប្រយោជន៍ មានបស្សទ្ធិជាអានិសង្ស បាមុជ្ជ មានបីតិជាប្រយោជន៍ មានបីតិជាអានិសង្ស អវិប្បដិសារៈ មានបាមុជ្ជជាប្រយោជន៍ មានបាមុជ្ជជាអានិសង្ស សីលទាំងឡាយជាកុសល មានអវិប្បដិសារៈជាប្រយោជន៍ មានអវិប្បដិសារៈជាអានិសង្ស ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ តែងញ៉ាំងធម៌ទាំងឡាយ ឲ្យប្រព្រឹត្តទៅ ធម៌

ទាំងឡាយ តែងញុំាំងធម៌ទាំងឡាយ ឲ្យបរិបូណ៌ ដើម្បីចេញអំពីទីមិនមែន ជាត្រើយ ទៅកាន់ត្រើយ គឺព្រះនិព្វាន ដោយប្រការដូច្នេះ ។

## បឋមឧបនិសាសូត្រទី ៣

[ ១១០ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកទ្រុស្តសីល វិបត្តិចាកសីល តែងសាបសូន្យចាកឧបនិស្ស័យ នៃអវិប្បដិសារៈ កាលបើអវិប្បដិសារៈមិនមាន បុគ្គលអ្នកវិបត្តិចាកអវិប្បដិសារៈ តែងសាបសូន្យចាកឧបនិស្ស័យនៃបាមុជ្ជ កាលបើបាមុជ្ជមិនមាន បុគ្គលអ្នកវិបត្តិចាកបាមុជ្ជ តែងសាបសូន្យចាកឧបនិស្ស័យនៃបីតិ កាលបើបីតិមិនមាន បុគ្គលអ្នកវិបត្តិចាកបីតិ តែងសាបសូន្យចាកឧបនិស្ស័យនៃបស្សទ្ធិ កាលបើបស្សទ្ធិមិនមាន បុគ្គលអ្នកវិបត្តិចាកបស្សទ្ធិ តែងសាបសូន្យចាកឧបនិស្ស័យនៃសុខ កាលបើសុខមិនមាន បុគ្គលអ្នកវិបត្តិចាកសុខ តែងសាបសូន្យចាកឧបនិស្ស័យនៃសម្មាសមាធិ កាលបើសម្មាសមាធិមិនមាន បុគ្គលអ្នកវិបត្តិចាកសម្មាសមាធិតែងសាបសូន្យចាកឧបនិស្ស័យនៃយថាភូតញ្ញាណទស្សនៈ កាលបើយថាភូតញ្ញាណទស្សនៈមិនមាន បុគ្គលអ្នកវិបត្តិចាកយថាភូតញ្ញាណទស្សនៈ តែងសាបសូន្យ ចាកឧបនិស្ស័យនៃនិព្វិទា កាលបើនិព្វិទាមិនមាន បុគ្គលអ្នកវិបត្តិចាកនិព្វិទា តែងសាបសូន្យចាកឧបនិស្ស័យនៃវិរាគៈ កាលបើវិរាគៈមិនមាន បុគ្គលអ្នកវិបត្តិចាកវិរាគៈ តែងសាបសូន្យចាកឧបនិស្ស័យនៃវិមុត្តិញ្ញាណទស្សនៈ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាដើមឈើ ដែលប្រាសចាកមែក និងស្លឹកហើយ ក្រមរ

របស់ឈើនោះក្តី ក៏មិនដល់នូវការពេញលេញ សម្បកក្តី ស្រាយក្តី ខ្លឹមក្តី ក៏មិនដល់នូវការពេញលេញ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ បុគ្គលទ្រុស្ត-សីល វិបត្តិចាកសីល តែងសាបសូន្យ ចាកឧបនិស្ស័យ នៃអវិប្បដិសារៈ កាលបើអវិប្បដិសារៈមិនមាន បុគ្គលអ្នកវិបត្តិចាកអវិប្បដិសារៈ តែងសាបសូន្យ ចាកឧបនិស្ស័យ ។បេ។ នៃវិមុត្តិញ្ញាណទស្សនៈ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានសីល បរិបូណ៌ដោយសីល តែងបរិបូណ៌ដោយឧបនិស្ស័យ នៃអវិប្បដិសារៈ កាលបើអវិប្បដិសារៈមាន បុគ្គលអ្នកបរិបូណ៌ដោយអវិប្បដិសារៈ តែងបរិបូណ៌ដោយឧបនិស្ស័យនៃបាមុជ្ជ កាលបើបាមុជ្ជមាន បុគ្គលអ្នកបរិបូណ៌ដោយបាមុជ្ជ តែងបរិបូណ៌ដោយឧបនិស្ស័យនៃបីតិ កាលបើបីតិមាន បុគ្គលអ្នកបរិបូណ៌ដោយបីតិ តែងបរិបូណ៌ដោយឧបនិស្ស័យនៃបស្សទ្ធិ កាលបើបស្សទ្ធិមាន បុគ្គលអ្នកបរិបូណ៌ដោយបស្សទ្ធិ តែងបរិបូណ៌ដោយឧបនិស្ស័យនៃសុខ កាលបើសុខមាន បុគ្គលអ្នកបរិបូណ៌ដោយសុខ តែងបរិបូណ៌ដោយឧបនិស្ស័យនៃសម្មាសមាធិ កាលបើសម្មា-សមាធិមាន បុគ្គលអ្នកបរិបូណ៌ដោយសម្មាសមាធិ តែងបរិបូណ៌ដោយឧបនិស្ស័យនៃយថាភូតញ្ញាណទស្សនៈ កាលបើយថាភូតញ្ញាណទស្សនៈមាន បុគ្គលអ្នកបរិបូណ៌ដោយយថាភូតញ្ញាណទស្សនៈ តែងបរិបូណ៌ដោយឧប-និស្ស័យនៃនិព្វិទា កាលបើនិព្វិទាមាន បុគ្គលអ្នកបរិបូណ៌ដោយនិព្វិទា តែងបរិបូណ៌ដោយឧបនិស្ស័យនៃវិរាគៈ កាលបើវិរាគៈមាន បុគ្គលអ្នកបរិបូណ៌

ដោយវិរាគៈ តែងបរិបូណ៌ដោយឧបនិស្ស័យនៃវិមុត្តិញ្ញាណទស្សនៈ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចដើមឈើដែលបរិបូណ៌ដោយមែក និងស្លឹក ហើយក្រមររបស់ឈើនោះក្តី ដល់នូវការពេញលេញ សម្បកក្តី ស្រាយក្តី ខ្លឹមក្តី ក៏ដល់នូវការពេញលេញ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានសីល បរិបូណ៌ដោយសីល តែងបរិបូណ៌ដោយឧបនិស្ស័យនៃអវិប្បដិ-សារៈ កាលបើអវិប្បដិសារៈមាន បុគ្គលអ្នកបរិបូណ៌ដោយអវិប្បដិសារៈ តែងបរិបូណ៌ដោយឧបនិស្ស័យ ។បេ។ នៃវិមុត្តិញ្ញាណទស្សនៈ ក៏យ៉ាងនោះដែរ ។

# ទុតិយឧបនិសាសូត្រទី ៤

[ ១១១ ] ក្នុងទីនោះឯង ព្រះសារីបុត្រដ៏មានអាយុហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលស្តាប់ថេរវាចានៃព្រះសារីបុត្រដ៏មានអាយុថា ករុណាអាវុសោ ។ ព្រះសារីបុត្រដ៏មានអាយុបានពោលដូច្នេះថា ម្នាលអាវុសោទាំងឡាយ បុគ្គលអ្នកទ្រុស្តសីល វិបត្តិចាកសីលហើយ តែងសាបសូន្យចាកឧបនិស្ស័យនៃអវិប្បដិសារៈ កាលបើអវិ-ប្បដិសារៈមិនមាន បុគ្គលអ្នកវិបត្តិចាកអវិប្បដិសារៈ តែងសាបសូន្យចាកឧបនិស្ស័យនៃបាមុជ្ជ កាលបើបាមុជ្ជមិនមាន បុគ្គលអ្នកវិបត្តិចាកបាមុជ្ជ តែងសាបសូន្យចាកឧបនិស្ស័យនៃបីតិ កាលបើបីតិមិនមាន បុគ្គលអ្នកវិបត្តិចាកបីតិ តែងសាបសូន្យចាកឧបនិស្ស័យនៃបស្សទ្ធិ កាលបើបស្សទ្ធិមិនមាន

បុគ្គលអ្នកវិបត្តិចាកបស្សទ្ធិ តែងសាបសូន្យចាកឧបនិស្ស័យនៃសុខ កាលបើសុខមិនមាន បុគ្គលអ្នកវិបត្តិចាកសុខ តែងសាបសូន្យចាកឧបនិស្ស័យ នៃសម្មាសមាធិ កាលបើសម្មាសមាធិមិនមាន បុគ្គលអ្នកវិបត្តិចាកសម្មាសមាធិ តែងសាបសូន្យចាកឧបនិស្ស័យនៃយថាភូតញ្ញាណទស្សនៈ កាលបើយថា-ភូតញ្ញាណទស្សនៈមិនមាន បុគ្គលអ្នកវិបត្តិចាកយថាភូតញ្ញាណទស្សនៈ តែងសាបសូន្យចាកឧបនិស្ស័យនៃនិព្វិទា កាលបើនិព្វិទាមិនមាន បុគ្គលអ្នកវិបត្តិចាកនិព្វិទា តែងសាបសូន្យចាកឧបនិស្ស័យនៃវិរាគៈ កាលបើវិរាគៈមិនមាន បុគ្គលអ្នកវិបត្តិចាកវិរាគៈ តែងសាបសូន្យចាកឧបនិស្ស័យនៃវិមុត្តិញ្ញាណទស្សនៈ ។ ម្នាលអាវុសោទាំងឡាយ ប្រៀបដូចដើមឈើដែលប្រាសចាកមែក និងស្លឹកហើយ ក្រមររបស់ឈើនោះក្តី ក៏មិនដល់នូវការពេញលេញ សម្បកក្តី ស្រាយក្តី ខ្លឹមក្តី ក៏មិនដល់នូវការពេញលេញ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ បុគ្គលអ្នកទ្រុស្តសីល វិបត្តិចាកសីល តែងសាបសូន្យចាកឧបនិស្ស័យនៃអវិប្បដិសារៈ កាលបើអវិប្បដិសារៈមិនមាន បុគ្គលអ្នកវិបត្តិចាកអវិប្បដិសារៈ តែងសាបសូន្យចាកឧបនិស្ស័យ ។បេ។ នៃវិមុត្តិញ្ញាណទស្សនៈ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលអ្នកមានសីល បរិបូណ៌ដោយសីល តែងបរិបូណ៌ដោយឧបនិស្ស័យនៃអវិប្បដិសារៈ កាលបើអវិប្បដិសារៈមាន បុគ្គលអ្នកបរិបូណ៌ដោយអវិប្បដិ-សារៈ តែងបរិបូណ៌ដោយឧបនិស្ស័យនៃបាមុជ្ជ កាលបើបាមុជ្ជមាន បុគ្គល

អ្នកបរិបូណ៌ដោយបាមុជ្ជ តែងបរិបូណ៌ដោយឧបនិស្ស័យនៃបីតិ កាលបើបីតិមាន បុគ្គលអ្នកបរិបូណ៌ដោយបីតិ តែងបរិបូណ៌ដោយឧបនិស្ស័យនៃបស្សទ្ធិ កាលបើបស្សទ្ធិមាន បុគ្គលអ្នកបរិបូណ៌ដោយបស្សទ្ធិ តែងបរិបូណ៌ដោយឧបនិស្ស័យនៃសុខ កាលបើសុខមាន បុគ្គលអ្នកបរិបូណ៌ដោយសុខ តែងបរិបូណ៌ដោយឧបនិស្ស័យនៃសម្មាសមាធិ កាលបើសម្មាសមាធិមាន បុគ្គលអ្នកបរិបូណ៌ដោយសម្មាសមាធិ តែងបរិបូណ៌ដោយឧបនិស្ស័យ នៃយថាភូតញ្ញាណទស្សនៈ កាលបើយថាភូតញ្ញាណទស្សនៈមាន បុគ្គលអ្នកបរិបូណ៌ដោយយថាភូតញ្ញាណទស្សនៈ តែងបរិបូណ៌ដោយឧបនិស្ស័យនៃនិព្វិទា កាលបើនិព្វិទាមាន បុគ្គលអ្នកបរិបូណ៌ដោយនិព្វិទា តែងបរិបូណ៌ដោយឧបនិស្ស័យនៃវិរាគៈ កាលបើវិរាគៈមាន បុគ្គលអ្នកបរិបូណ៌ដោយវិរាគៈ តែងបរិបូណ៌ដោយឧបនិស្ស័យនៃវិមុត្តិញ្ញាណទស្សនៈ ។ ម្នាលអាវុសោទាំងឡាយ ប្រៀបដូចដើមឈើ ដែលបរិបូណ៌ដោយមែក និងស្លឹក ក្រមររបស់ឈើនោះក្តី ក៏ដល់នូវការពេញលេញ សម្បកក្តី ស្រាយក្តី ខ្លឹមក្តី ក៏ដល់នូវការពេញលេញ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ បុគ្គលអ្នកមានសីល បរិបូណ៌ដោយសីល តែងបរិបូណ៌ដោយឧបនិស្ស័យនៃអវិប្បដិសារៈ កាលបើអវិប្បដិសារៈមាន បុគ្គលអ្នកបរិបូណ៌ដោយអវិប្បដិសារៈ តែងបរិបូណ៌ដោយឧបនិស្ស័យ ។បេ។ នៃវិមុត្តិញ្ញាណទស្សនៈ ក៏យ៉ាងនោះដែរ ។

# តតិយឧបនិសាសូត្រទី ៥

[ ១១២ ] ក្នុងទីនោះឯង ព្រះអានន្ទដ៏មានអាយុហៅភិក្ខុទាំងឡាយ ។បេ។ ម្នាលអាវុសោទាំងឡាយ បុគ្គលអ្នកទ្រុស្តសីល វិបត្តិចាកសីល តែងសាបសូន្យចាកឧបនិស្ស័យនៃអវិប្បដិសារៈ កាលបើអវិប្បដិសារៈមិនមាន បុគ្គលអ្នកវិបត្តិចាកអវិប្បដិសារៈ តែងសាបសូន្យចាកឧបនិស្ស័យនៃបាមុជ្ជ កាលបើបាមុជ្ជមិនមាន បុគ្គលអ្នកវិបត្តិចាកបាមុជ្ជ តែងសាបសូន្យចាកឧបនិស្ស័យនៃបីតិ កាលបើបីតិមិនមាន បុគ្គលអ្នកវិបត្តិចាកបីតិ តែងសាបសូន្យចាកឧបនិស្ស័យនៃបស្សទ្ធិ កាលបើបស្សទ្ធិមិនមាន បុគ្គលអ្នកវិបត្តិចាកបស្សទ្ធិ តែងសាបសូន្យចាកឧបនិស្ស័យនៃសុខ កាលបើសុខមិនមាន បុគ្គលអ្នកវិបត្តិចាកសុខ តែងសាបសូន្យចាកឧបនិស្ស័យនៃសម្មាសមាធិ កាលបើសម្មាសមាធិមិនមាន បុគ្គលអ្នកវិបត្តិចាកសម្មាសមាធិ តែងសាបសូន្យចាកឧបនិស្ស័យនៃយថាភូតញ្ញាណទស្សនៈ កាលបើយថាភូតញ្ញាណទស្សនៈមិនមាន បុគ្គលអ្នកវិបត្តិចាកយថាភូតញ្ញាណទស្សនៈ តែងសាបសូន្យចាកឧបនិស្ស័យនៃនិព្វិទា កាលបើនិព្វិទាមិនមាន បុគ្គលអ្នកវិបត្តិចាកនិព្វិទា តែងសាបសូន្យចាកឧបនិស្ស័យនៃវិរាគៈ កាលបើវិរាគៈមិនមាន បុគ្គលអ្នកវិបត្តិចាកវិរាគៈ តែងសាបសូន្យចាកឧបនិស្ស័យ នៃវិមុត្តិញ្ញាណទស្សនៈ ។ ម្នាលអាវុសោទាំងឡាយ ប្រៀបដូចដើមឈើ ដែលប្រាសចាកមែក និងស្លឹក ក្រមររបស់ឈើនោះក្តី ក៏មិនដល់នូវការពេញលេញ សម្បកក្តី ស្រាយក្តី ខ្លឹមក្តី ក៏មិនដល់នូវការពេញលេញ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ បុគ្គលអ្នក

ទ្រុស្តសីល វិបត្តិចាកសីល តែងសាបសូន្យចាកឧបនិស្ស័យនៃអវិប្បដិសារៈ កាលបើអវិប្បដិសារៈមិនមាន បុគ្គលអ្នកវិបត្តិចាកអវិប្បដិសារៈ តែងសាបសូន្យចាកឧបនិស្ស័យ ។បេ។ នៃវិមុត្តិញ្ញាណទស្សនៈ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលអ្នកមានសីល បរិបូណ៌ដោយសីល តែងបរិបូណ៌ដោយឧបនិស្ស័យនៃអវិប្បដិសារៈ កាលបើអវិប្បដិសារៈមាន បុគ្គលអ្នកបរិបូណ៌ដោយអវិប្បដិសារៈ តែងបរិបូណ៌ដោយឧបនិស្ស័យនៃបាមុជ្ជ កាលបើបាមុជ្ជមាន បុគ្គលអ្នកបរិបូណ៌ដោយបាមុជ្ជ តែងបរិបូណ៌ដោយឧបនិស្ស័យនៃបីតិ កាលបើបីតិមាន បុគ្គលអ្នកបរិបូណ៌ដោយបីតិ តែងបរិបូណ៌ដោយឧបនិស្ស័យនៃបស្សទ្ធិ កាលបើបស្សទ្ធិមាន បុគ្គលអ្នកបរិបូណ៌ដោយបស្សទ្ធិ តែងបរិបូណ៌ដោយឧបនិស្ស័យនៃសុខ កាលបើសុខមាន បុគ្គលអ្នកបរិបូណ៌ដោយសុខ តែងបរិបូណ៌ដោយឧបនិស្ស័យនៃសម្មាសមាធិ កាលបើសម្មាសមាធិមាន បុគ្គលអ្នកបរិបូណ៌ដោយសម្មាសមាធិ តែងបរិបូណ៌ដោយឧបនិស្ស័យនៃយថាភូតញ្ញាណទស្សនៈ កាលបើយថាភូតញ្ញាណទស្សនៈមាន បុគ្គលអ្នកបរិបូណ៌ដោយយថាភូតញ្ញាណទស្សនៈ តែងបរិបូណ៌ដោយឧបនិស្ស័យនៃនិព្វិទា កាលបើនិព្វិទាមាន បុគ្គលអ្នកបរិបូណ៌ដោយនិព្វិទា តែងបរិបូណ៌ដោយឧបនិស្ស័យនៃវិរាគៈ កាលបើវិរាគៈមាន បុគ្គលអ្នកបរិបូណ៌ដោយវិរាគៈ តែងបរិបូណ៌ដោយឧបនិស្ស័យនៃវិមុត្តិញ្ញាណទស្សនៈ ។ ម្នាលអាវុសោទាំងឡាយ ប្រៀបដូចដើមឈើ ដែលបរិបូណ៌ដោយមែក និង

ស្ទឹកហើយ ក្រមររបស់ឈើនោះក្តី ក៏ដល់នូវការពេញលេញ សម្បកក្តី ស្រាយក្តី ខ្លឹមក្តី ក៏ដល់នូវការពេញលេញ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ បុគ្គលអ្នកមានសីល បរិបូណ៌ដោយសីល តែងបរិបូណ៌ដោយឧបនិស្ស័យនៃអវិប្បដិសារៈ កាលបើអវិប្បដិសារៈមាន បុគ្គលអ្នកបរិបូណ៌ដោយអវិប្បដិសារៈ តែងបរិបូណ៌ដោយឧបនិស្ស័យ ។បេ។ នៃវិមុត្តិញ្ញាណទស្សនៈ ក៏យ៉ាងនោះដែរ ។

# អដ្ឋកថា

# ឯកាទសកនិបាត

## និស្សាយវគ្គទី ១

### កិមត្ថិយសូត្រទី ១ ជាដើម

[ ១០៨-១១២ ] *ឯកាទសកនិបាត កិមត្ថិយសូត្រទី ១ ជាដើម មានន័យដូចពោលហើយខាងដើមនោះឯង ។ ពិតហើយ ក្នុងឯកាទសកនិបាត ៥ សូត្រខាងដើម លោកពោលអង្គ ១១ ចែកនិព្វិទា និងវិរាគៈចេញជា ២ ៗ ។*

**អដ្ឋកថា កិមត្ថិយសូត្រទី ១ ជាដើមចប់**

# សុត្តន្តបិដក

### ព្យសនសូត្រទី ៦

[ ១១៣ ] *ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលតិះដៀលព្រះអរិយៈ ជេរប្រទេចពួកភិក្ខុជាសព្រហ្មចារី ហើយមិនគប្បីដល់នូវសេចក្ដីវិនាសទាំង ១១ យ៉ាងណាមួយ នុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យ*

ឡើយ ។ សេចក្តីវិនាសទាំង ១១ យ៉ាង តើអ្វីខ្លះ ។ គឺមិនបាននូវគុណវិសេសដែលខ្លួនមិនទាន់បាន ១ សាបសូន្យចាកគុណវិសេសដែលខ្លួនបានហើយ ១ ព្រះសទ្ធម្មរបស់ភិក្ខុនោះ មិនផូរផង់ ១ ប្រកបដោយសេចក្តីស្មានថា បានក្នុងព្រះសទ្ធម្ម ១ មិនត្រេកអរនឹងប្រព្រឹត្តព្រហ្មចរិយៈ ១ ត្រូវអាបត្តិណាមួយដ៏សៅហ្មង ១ លះបង់សិក្ខាហើយត្រឡប់មក ដើម្បីកេទថោកទាប ១ ប៉ះនឹងរោគធ្ងន់ខ្លាំង ១ ដល់នូវការឆ្កួត វង្វេងវង្វាយចិត្ត ១ ធ្វើកាលកិរិយាទាំងវង្វេង ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលតិះដៀលព្រះអរិយៈ ជេរប្រទេចពួកភិក្ខុជាសព្រហ្មចារី ហើយមិនគប្បីដល់នូវសេចក្តីវិនាសទាំង ១១ យ៉ាងណាមួយនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យឡើយ ។

# អដ្ឋកថា

## ឰសនសូត្រ

[ ១១៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឰសនសូត្រទី ៦ ដូចតទៅនេះថា ការសម្តែងសិក្ខាបទ គប្បីជ្រាបថា លើស ។ល។

**អដ្ឋកថា ឰសនសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## សញ្ញាសូត្រទី ៧

[ ១១៤ ] គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុបាននូវសមាធិ មានសភាពដូច្នេះ មានដែរឬ ដូចជាភិក្ខុមិនសម្គាល់ថា ដីក្នុងដី មិនសម្គាល់ថា ទឹកក្នុងទឹក មិនសម្គាល់ថា ភ្លើងក្នុងភ្លើង មិនសម្គាល់ថា ខ្យល់ក្នុងខ្យល់ មិនសម្គាល់ថា អាកាសានញ្ចាយតនៈក្នុងអាកាសានញ្ចាយតនៈ មិនសម្គាល់ថា វិញ្ញាណញ្ចាយតនៈក្នុងវិញ្ញាណញ្ចាយតនៈ មិនសម្គាល់ថា អាកិញ្ចញ្ញាយតនៈក្នុងអាកិញ្ចញ្ញាយតនៈ មិនសម្គាល់ថា នេវសញ្ញានាសញ្ញាយតនៈក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសម្គាល់ថា លោកនេះក្នុងលោកនេះ មិនសម្គាល់ថា លោកខាងមុខក្នុងលោកខាងមុខ ភិក្ខុមិនសម្គាល់ក្នុងរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត គ្រាន់តែមានសញ្ញាជាធម្មតាតែប៉ុណ្ណោះ ។ ម្នាលអានន្ទ ភិក្ខុបានសមាធិមានសភាពដូច្នោះក៏មាន ដូចជាភិក្ខុ មិនសម្គាល់ថា ដីក្នុងដី មិនសម្គាល់ថា ទឹកក្នុងទឹក មិនសម្គាល់ថា ភ្លើងក្នុងភ្លើង មិនសម្គាល់ថា ខ្យល់ក្នុងខ្យល់ មិនសម្គាល់ថា អាកាសានញ្ចាយតនៈក្នុងអាកាសានញ្ចាយតនៈ មិនសម្គាល់ថា វិញ្ញាណញ្ចាយតនៈក្នុងវិញ្ញាណញ្ចាយតនៈ មិនសម្គាល់ថា អាកិញ្ចញ្ញា-

យតនៈក្នុងអាកិញ្ចញ្ញាយតនៈ មិនសម្គាល់ថា នេវសញ្ញានាសញ្ញាយតនៈក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសម្គាល់ថា លោកនេះក្នុងលោកនេះ មិនសម្គាល់ថា លោកខាងមុខក្នុងលោកខាងមុខ មិនសម្គាល់ ក្នុងរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត គ្រាន់តែមានសញ្ញាជាធម្មតាតែប៉ុណ្ណោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ដូចភិក្ខុបានសមាធិ មានសភាពដូច្នោះក៏មាន តើដូចម្តេច ដូចជាភិក្ខុមិនសម្គាល់ថា ដីក្នុងដី មិនសម្គាល់ថា ទឹកក្នុងទឹក មិនសម្គាល់ថា ភ្លើងក្នុងភ្លើង មិនសម្គាល់ថា ខ្យល់ក្នុងខ្យល់ មិនសម្គាល់ថា អាកាសានញ្ចាយតនៈក្នុងអាកាសាន-ញ្ចាយតនៈ មិនសម្គាល់ថា វិញ្ញាណញ្ចាយតនៈក្នុងវិញ្ញាណញ្ចាយតនៈ មិនសម្គាល់ថា អាកិញ្ចញ្ញាយតនៈក្នុងអាកិញ្ចញ្ញាយតនៈ មិនសម្គាល់ថា នេវ-សញ្ញានាសញ្ញាយតនៈ ក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសម្គាល់ថា លោកនេះក្នុងលោកនេះ មិនសម្គាល់ថា លោកខាងមុខក្នុងលោកខាងមុខ មិនសម្គាល់ក្នុងរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត គ្រាន់តែមានសញ្ញាជាធម្មតាតែប៉ុណ្ណោះ ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ មានសេចក្តីសម្គាល់យ៉ាងនេះថា ការរម្ងាប់នូវសង្ខារទាំងអស់ ការលះចោលនូវកិលេសទាំងអស់ ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ទុក្ខ គឺព្រះនិព្វានណា ព្រះនិព្វាននុ៎ះ ជាទីស្ងប់ ព្រះនិព្វាននុ៎ះដ៏ឧត្តម ។ ម្នាលអានន្ទ ភិក្ខុបានសមាធិមានសភាពដូច្នោះ យ៉ាងនេះឯង ដូចជាភិក្ខុ មិន

សម្គាល់ថា ដីក្នុងដី មិនសម្គាល់ថា ទឹកក្នុងទឹក មិនសម្គាល់ថា ភ្លើងក្នុងភ្លើង មិនសម្គាល់ថា ខ្យល់ក្នុងខ្យល់ មិនសម្គាល់ថា អាកាសានញ្ចាយតនៈក្នុងអាកាសានញ្ចាយតនៈ មិនសម្គាល់ថា វិញ្ញាណញ្ចាយតនៈ ក្នុងវិញ្ញាណញ្ចាយតនៈ មិនសម្គាល់ថា អាកិញ្ចញ្ញាយតនៈក្នុងអាកិញ្ចញ្ញាយតនៈ មិនសម្គាល់ថា នេវសញ្ញានាសញ្ញាយតនៈក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសម្គាល់ថា លោកនេះក្នុងលោកនេះ មិនសម្គាល់ថា លោកខាងមុខក្នុងលោកខាងមុខ មិនសម្គាល់ក្នុងរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត គ្រាន់តែមានសញ្ញាជាធម្មតាតែប៉ុណ្ណោះ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ ត្រេកអរ រីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគហើយ ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយចូលទៅរកព្រះសារីបុត្រដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏រីករាយ ទៅរកព្រះសារីបុត្រដ៏មានអាយុ លុះបញ្ចប់ពាក្យ ដែលគួររីករាយនិងពាក្យដែលគួររឭកហើយ អង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ បាននិយាយទៅនឹងព្រះសារីបុត្រដ៏មានអាយុដូច្នេះថា ម្នាលអាវុសោសារីបុត្រ ភិក្ខុបានសមាធិ មានសភាពដូច្នោះ មានដែរឬ ដូចជាភិក្ខុ មិនសម្គាល់ថា ដីក្នុងដី ។បេ។ មិនសម្គាល់ក្នុងរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត គ្រាន់តែមានសញ្ញាជាធម្មតាតែប៉ុណ្ណោះ ។ ម្នាលអាវុសោអានន្ទ ភិក្ខុបានសមាធិ

មានសភាពដូច្នោះក៏មាន ដូចជាភិក្ខុមិនសម្គាល់ថា ដីក្នុងដី ។បេ។ មិនសម្គាល់ក្នុងរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត គ្រាន់តែមានសញ្ញាជាធម្មតាតែប៉ុណ្ណោះ ។ ម្នាលអាវុសោសារីបុត្រ ដូចភិក្ខុបានសមាធិមានសភាពដូច្នោះដែលមាន តើដូចម្តេច ដូចជាភិក្ខុមិនសម្គាល់ថា ដីក្នុងដី ។បេ។ មិនសម្គាល់ក្នុងរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត គ្រាន់តែមានសញ្ញាជាធម្មតាតែប៉ុណ្ណោះ ។ ម្នាលអាវុសោអានន្ទ ភិក្ខុក្នុងសាសនានេះ មានសេចក្តីសម្គាល់យ៉ាងនេះថា ការរម្ងាប់នូវសង្ខារទាំងអស់ ការលះបោលនូវកិលេសទាំងអស់ ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ទុក្ខ គឺព្រះនិព្វានណា ព្រះនិព្វាននុ៎ះជាទីស្ងប់ ព្រះនិព្វាននុ៎ះដ៏ឧត្តម ។ ម្នាលអាវុសោអានន្ទ ភិក្ខុបានសមាធិ មានសភាពដូច្នោះ យ៉ាងនេះឯង ដូចជាភិក្ខុមិនសម្គាល់ថាដី ក្នុងដី ។បេ។ មិនសម្គាល់ក្នុងរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត គ្រាន់តែមានសញ្ញាជាធម្មតាតែប៉ុណ្ណោះ ។ ម្នាលអាវុសោ អស្ចារ្យណាស់ ម្នាលអាវុសោ ចម្លែកណាស់ ព្រោះថា អត្ថ និងព្យញ្ជនៈរបស់ព្រះសាស្តា និងសាវកត្រូវគ្នា សមគ្នា មិនបានខុសគ្នា ដោយអត្ថ ដោយព្យញ្ជនៈ ក្នុងបទដ៏ប្រសើរនេះឡើយ ។ ម្នាលអាវុសោ អម្បាញ់មិញនេះ ខ្ញុំបានចូលទៅគាល់ព្រះមានព្រះភាគ ហើយសួរសេចក្តីនេះ ។ ព្រះមានព្រះភាគ ក៏បានព្យាករសេចក្តីនេះ ដោយបទទាំងនេះ ដោយព្យញ្ជនៈទាំង

នេះដល់ខ្ញុំ ដូចជាព្រះសារីបុត្រ ដ៏មានអាយុដែរ ។ ម្នាលអាវុសោ អស្ចារ្យណាស់ ម្នាលអាវុសោ ចម្លែកណាស់ ព្រោះថា អត្ថ និងព្យញ្ជនៈរបស់ព្រះសាស្តា និងសាវកត្រូវគ្នា សមគ្នា មិនបានខុសគ្នា ដោយអត្ថ ដោយព្យញ្ជនៈ ក្នុងបទដ៏ប្រសើរនេះឡើយ ។

# អដ្ឋកថា

## សញ្ញាសូត្រ

[ ១១៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសញ្ញាសូត្រទី ៧ ដូចតទៅនេះ បទថា **អត្ថេន អត្ថោ** បានដល់ អត្ថ និងអត្ថ ។ បទថា **ព្យញ្ជនេន ព្យញ្ជនំ** បានដល់ ព្យញ្ជនៈ និងព្យញ្ជនៈ ។ បទថា **សំសន្ទិស្សតិ** ប្រែថា នឹងប្រព្រឹត្តទៅបាន ។ បទថា **សមេស្សតិ** ប្រែថា នឹងស្មើគ្នាបាន ។ បទថា **ន វិគ្គយ្ហិស្សតិ** បានដល់ នឹងមិនខុសគ្នា ។ បទថា **អគ្គបទស្មឹ** បានដល់ ក្នុងព្រះនិព្វាន ។ល។

**អដ្ឋកថាសញ្ញាសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## មនសិការសូត្រទី ៨

[ ១១៥ ] គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុបានសមាធិមានសភាពដូច្នោះ មានដែរឬ ដូចជាភិក្ខុមិនធ្វើទុកក្នុងចិត្ត នូវចក្ខុ មិនធ្វើទុកក្នុងចិត្ត នូវរូប មិនធ្វើទុកក្នុងចិត្ត នូវសោតៈ មិនធ្វើទុកក្នុងចិត្តនូវសទ្ទៈ មិនធ្វើទុកក្នុងចិត្ត នូវឃានៈ មិនធ្វើទុកក្នុងចិត្ត នូវគន្ធៈ មិនធ្វើទុកក្នុងចិត្ត នូវជិវ្ហា មិនធ្វើទុកក្នុងចិត្ត នូវរស មិនធ្វើទុកក្នុងចិត្ត នូវកាយ មិនធ្វើទុកក្នុងចិត្ត នូវផោដ្ឋព្វៈ មិនធ្វើទុកក្នុងចិត្ត នូវបឋវី មិនធ្វើទុកក្នុងចិត្ត នូវអាបោ មិនធ្វើទុកក្នុងចិត្ត នូវតេជោ មិនធ្វើទុកក្នុងចិត្ត នូវវាយោ មិនធ្វើទុកក្នុងចិត្ត នូវអាកាសានញ្ចាយតនៈ មិនធ្វើទុកក្នុងចិត្ត នូវវិញ្ញាណញ្ចាយតនៈ មិនធ្វើទុកក្នុងចិត្ត នូវអាកិញ្ចញ្ញាយតនៈ មិនធ្វើទុកក្នុងចិត្ត នូវនេវសញ្ញានាសញ្ញាយតនៈ មិនធ្វើទុកក្នុងចិត្ត នូវលោកនេះ មិនធ្វើទុកក្នុងចិត្តនូវលោកខាងមុខ មិនធ្វើទុកក្នុងចិត្ត នូវរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត គ្រាន់តែធ្វើទុកក្នុងចិត្តជាធម្មតាតែប៉ុណ្ណោះ ។ ម្នាលអានន្ទ ភិក្ខុបានសមាធិ មានសភាពដូច្នោះក៏មាន ដូចជាភិក្ខុ មិនធ្វើទុកក្នុងចិត្តនូវចក្ខុ មិនធ្វើទុកក្នុងចិត្តនូវរូប មិនធ្វើទុកក្នុងចិត្តនូវសោតៈ មិនធ្វើទុកក្នុងចិត្តនូវសទ្ទៈ

មិនធ្វើទុកក្នុងចិត្ត នូវឃានៈ មិនធ្វើទុកក្នុងចិត្ត នូវគន្ធៈ មិនធ្វើទុកក្នុងចិត្ត នូវជិវ្ហា មិនធ្វើទុកក្នុងចិត្ត នូវរស មិនធ្វើទុកក្នុងចិត្ត នូវកាយ មិនធ្វើទុកក្នុងចិត្ត នូវផោដ្ឋព្វៈ មិនធ្វើទុកក្នុងចិត្ត នូវបឋវី មិនធ្វើទុកក្នុងចិត្ត នូវអាបោ មិនធ្វើទុកក្នុងចិត្ត នូវតេជោ មិនធ្វើទុកក្នុងចិត្ត នូវវាយោ មិនធ្វើទុកក្នុងចិត្ត នូវអាកាសានញ្ចាយតនៈ មិនធ្វើទុកក្នុងចិត្ត នូវវិញ្ញាណញ្ចាយតនៈ មិនធ្វើទុកក្នុងចិត្ត នូវអាកិញ្ចញ្ញាយតនៈ មិនធ្វើទុកក្នុងចិត្ត នូវនេវសញ្ញានាសញ្ញាយតនៈ មិនធ្វើទុកក្នុងចិត្ត នូវលោកនេះ មិនធ្វើទុកក្នុងចិត្ត នូវលោកខាងមុខ មិនធ្វើទុកក្នុងចិត្ត នូវរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត គ្រាន់តែធ្វើទុកក្នុងចិត្តជាធម្មតាប៉ុណ្ណោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ដូចភិក្ខុបានសមាធិ មានសភាពដូច្នោះក៏មាន តើដូចម្តេច ដូចជាភិក្ខុមិនធ្វើទុកក្នុងចិត្ត នូវចក្ខុ មិនធ្វើទុកក្នុងចិត្ត នូវរូប ។បេ។ មិនធ្វើទុកក្នុងចិត្ត នូវរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត គ្រាន់តែធ្វើទុកក្នុងចិត្តជាធម្មតាប៉ុណ្ណោះ ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ធ្វើទុកក្នុងចិត្តយ៉ាងនេះថា ការរម្ងាប់សង្ខារទាំងអស់ ការលះបោលកិលេសទាំងអស់ ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ទុក្ខ គឺព្រះនិព្វានណា ព្រះនិព្វាននុ៎ះ ជាទីស្ងប់ ព្រះនិព្វាននុ៎ះ ដ៏ឧត្តម ។ ម្នាលអានន្ទ ភិក្ខុបានសមាធិ មានសភាពដូច្នោះ យ៉ាងនេះឯង ដូចជាភិក្ខុមិនធ្វើទុកក្នុងចិត្ត នូវចក្ខុ មិនធ្វើទុកក្នុងចិត្ត នូវរូប មិនធ្វើទុកក្នុងចិត្ត នូវសោតៈ

មិនធ្វើទុកក្នុងចិត្ត នូវសទ្ទៈ មិនធ្វើទុកក្នុងចិត្ត នូវឃានៈ មិនធ្វើទុកក្នុងចិត្ត នូវគន្ធៈ មិនធ្វើទុកក្នុងចិត្ត នូវជិវ្ហា មិនធ្វើទុកក្នុងចិត្ត នូវរស មិនធ្វើទុកក្នុងចិត្ត នូវកាយ មិនធ្វើទុកក្នុងចិត្ត នូវផោដ្ឋព្វៈ មិនធ្វើទុកក្នុងចិត្ត នូវបឋវី មិនធ្វើទុកក្នុងចិត្ត នូវអាបោ មិនធ្វើទុកក្នុងចិត្ត នូវតេជោ មិនធ្វើទុកក្នុងចិត្ត នូវវាយោ មិនធ្វើទុកក្នុងចិត្ត នូវអាកាសានញ្ចាយតនៈ មិនធ្វើទុកក្នុងចិត្តនូវវិញ្ញាណញ្ចាយតនៈ មិនធ្វើទុកក្នុងចិត្ត នូវអាកិញ្ចញ្ញាយតនៈ មិនធ្វើទុកក្នុងចិត្ត នូវនេវសញ្ញានាសញ្ញាយតនៈ មិនធ្វើទុកក្នុងចិត្ត នូវលោកនេះ មិនធ្វើទុកក្នុងចិត្ត នូវលោកខាងមុខ មិនធ្វើទុកក្នុងចិត្ត នូវរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត គ្រាន់តែធ្វើទុកក្នុងចិត្តជាធម្មតាប៉ុណ្ណោះ ។

# អដ្ឋកថា

## មនសិការសូត្រ

[ ១១៥ ] មនសិការសូត្រទី ៨ ព្រះមានព្រះភាគត្រាស់ បច្ចវេក្ខណប្បញ្ញា ។l

### អដ្ឋកថាមនសិការសូត្រទី ៨ ចប់

# សុត្តន្តបិដក

## អសេក្ខសូត្រទី ៩

[ ១១៦ ] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងប្រាសាទ ដែលគេធ្វើអំពីឥដ្ឋ ជិតស្រុកនាទិកៈ ។ គ្រានោះ ព្រះសន្ធៈដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំ ចំពោះព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះសន្ធៈដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលសន្ធៈ អ្នកត្រូវគិតដូចគំនិតសេះអាជានីយ កុំគិតដូចគំនិតសេះ ដែលមានពុតត្បុតឡើយ ។ ម្នាលសន្ធៈ គំនិតសេះដែលមានពុតត្បុត តើដូចម្ដេច ។ ម្នាលសន្ធៈ សេះមានពុតត្បុត ដែលគេចងក្បែរក្រង់នៃស្រូវ តែងគិតថា ស្រូវដំណើប ស្រូវដំណើប ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលសន្ធៈ ព្រោះថា សេះមានពុតត្បុត ដែលគេចងក្បែរក្រង់នៃស្រូវ មិនមានគំនិតយ៉ាងនេះថា ថ្ងៃនេះ នាយសារថីអ្នកបង្ហាត់សេះ នឹងឲ្យអញធ្វើនូវហេតុ ដូចម្ដេច អញធ្វើតបទៅវិញ ដូចម្ដេច ។ សេះនោះ ត្រូវគេចងក្បែរក្រង់នៃស្រូវហើយ តែងគិតថា ស្រូវដំណើប ស្រូវដំណើប ។ ម្នាលសន្ធៈ បុរសមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ ទៅនៅក្នុងព្រៃក្ដី នៅក្រោមម្លប់ឈើក្ដី នៅក្នុងផ្ទះស្ងាត់ក្ដី មានចិត្តដែលកាមរាគ រួបរឹតដែលកាមរាគ គ្របសង្កត់ហើយ រមែងមិនដឹងនូវការរលាស់ចោលនូវកាម-រាគដែលកើតឡើងដោយពិត ក៏យ៉ាងនោះដែរ ។ បុរសនោះតែងគិតជញ្ជឹងជ្រុលជ្រប់ សុបសៅ ព្រោះធ្វើកាមរាគ ឲ្យនៅខាងក្នុង ។ បុគ្គលមានចិត្ត

ដែលព្យាបាទ រួបរឹតហើយ ... មានចិត្តដែលថីនមិទ្ធៈ រួបរឹតហើយ ... មានចិត្តដែលឧទ្ធច្ចកុក្កុច្ចៈ រួបរឹតហើយ ... មានចិត្តដែលវិចិកិច្ឆា រួបរឹត ដែលវិចិកិច្ឆា គ្របសង្កត់ហើយ រមែងមិនដឹងការរលាស់ចោលនូវវិចិកិច្ឆា ដែលកើតឡើងដោយពិត ។ បុគ្គលនោះ តែងគិតជញ្ជឹង ជ្រុលជ្រប់ សុបសៅព្រោះធ្វើវិចិកិច្ឆា ឲ្យនៅតែខាងក្នុង ។ បុគ្គលនោះ តែងគិតព្រោះអាស្រ័យនូវផែនដីខ្លះ គិត ព្រោះអាស្រ័យនូវទឹកខ្លះ គិត ព្រោះអាស្រ័យនូវភ្លើងខ្លះ គិតព្រោះអាស្រ័យនូវខ្យល់ខ្លះ គិត ព្រោះអាស្រ័យនូវអាកាសានញ្ចាយតនៈខ្លះ គិត ព្រោះអាស្រ័យនូវវិញ្ញាណញ្ចាយតនៈខ្លះ គិត ព្រោះអាស្រ័យ នូវអាកិញ្ចញ្ញាយតនៈខ្លះ គិត ព្រោះអាស្រ័យ នូវនេវសញ្ញានាសញ្ញាយតនៈខ្លះ គិតព្រោះអាស្រ័យ នូវលោកនេះខ្លះ គិត ព្រោះអាស្រ័យនូវលោកខាងមុខខ្លះ គិតព្រោះអាស្រ័យ នូវរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ស្វែងរក ត្រិះរិះដោយចិត្ត ។ ម្នាលសន្ធៈ គំនិតរបស់បុរសដែលមានពុតត្បុតយ៉ាងនេះឯង ។ ម្នាលសន្ធៈ គំនិតរបស់សេះអាជានីយ តើដូចម្តេច ។ ម្នាលសន្ធៈ សេះអាជានីយដ៏ចម្រើន ដែលគេចងក្បែរក្រង់នៃស្រូវដំណើប រមែងមិនគិតថា ស្រូវដំណើប ស្រូវដំណើបទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ម្នាលសន្ធៈ ព្រោះថា សេះអាជានីយដ៏ចម្រើន ដែលគេចងក្បែរក្រង់នៃស្រូវតែងមានសេចក្តីត្រិះរិះយ៉ាងនេះថា ក្នុងថ្ងៃនេះ នាយសារថីអ្នកបង្ហាត់សេះ នឹងឲ្យអញធ្វើនូវហេតុ ដូចម្តេច អញនឹងធ្វើតបទៅវិញ ដូចម្តេច ។ សេះដែលគេ

ចង្កៀរក្រង់នៃស្រូវនោះ រមែងមិននឹកថា ស្រូវជំណើប ស្រូវជំណើបទេ ។ ម្នាលសន្ធៈ សេះអាជានីយដ៏ចម្រើន តែងពិចារណា នូវការចាក់ដោយជន្ទញ យ៉ាងនេះថា ដូចជាបំណុល ដូចជាចំណង ដូចជាសេចក្តីសាបសូន្យ ឬដូចជាទោស ។ ម្នាលសន្ធៈ បុរសអាជានីយដ៏ចម្រើន ទោះនៅក្នុងព្រៃក្តី នៅក្រោមម្លប់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងមិនឲ្យកាមរាគ រួបរឹតចិត្តបាន មិនឲ្យកាមរាគគ្របសង្កត់ចិត្តបាន ទាំងដឹងច្បាស់ នូវការរលាស់ចោលនូវកាមរាគ ដែលកើតឡើងហើយដោយពិត ។ មិនឲ្យព្យាបាទ រួបរឹតចិត្តបាន ... មិនឲ្យថីនមិទ្ធៈ រួបរឹតចិត្តបាន ... មិនឲ្យឧទ្ធច្ចកុក្កុច្ចៈ រួបរឹតចិត្តបាន ... មិនឲ្យវិចិកិច្ឆា រួបរឹតចិត្តបាន មិនឲ្យវិចិកិច្ឆា គ្របសង្កត់ចិត្តបាន ទាំងដឹងច្បាស់ នូវការរលាស់ចោលនូវវិចិកិច្ឆា ដែលកើតឡើងហើយដោយពិត ។ បុរសនោះ មិនគិត ព្រោះអាស្រ័យនូវបឋវី មិនគិត ព្រោះអាស្រ័យ នូវអាបោ មិនគិត ព្រោះអាស្រ័យ នូវតេជោ មិនគិត ព្រោះអាស្រ័យ នូវវាយោ មិនគិត ព្រោះអាស្រ័យ នូវអាកាសានញ្ចាយតនៈ មិនគិត ព្រោះអាស្រ័យ នូវវិញ្ញាណញ្ចាយតនៈ មិនគិត ព្រោះអាស្រ័យ នូវអាកិញ្ចញ្ញាយតនៈ មិនគិត ព្រោះអាស្រ័យ នូវនេវសញ្ញានាសញ្ញាយតនៈ មិនគិត ព្រោះអាស្រ័យ នូវលោកនេះ មិនគិត ព្រោះអាស្រ័យ នូវលោកខាងមុខ មិនគិត ព្រោះអាស្រ័យ នូវរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត គ្រាន់តែគិតជាធម្មតាប៉ុណ្ណោះ ។ ម្នាលសន្ធៈ ទេវតាទាំងឡាយ ព្រម

ទាំងព្រះឥន្ទ្រ ព្រមទាំងព្រះព្រហ្ម ព្រមទាំងបជាបតិទេវរាជ តែងនមស្ការបុរស ជាអាជានីយដ៏ចម្រើន អំពីចម្ងាយ ដែលជាអ្នកមានឈាន យ៉ាងនេះថា

យើងទាំងឡាយ មិនស្គាល់អ្នកណាជាបុរសអាជានីយ
តែងគិត ព្រោះអាស្រ័យនូវគុណធម៌ណា បពិត្របុរស
អាជានីយ យើងសូមនមស្ការចំពោះអ្នក បពិត្របុរស
ដ៏ឧត្តម យើងសូមនមស្ការ ចំពោះអ្នក ។

កាលព្រះអង្គទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះសទ្ធៈដ៏មានអាយុបានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន បុរសអាជានីយដ៏ចម្រើន មានឈាន តែងគិតដូចម្តេច ។ បុរសអាជានីយនោះ មិនគិត ព្រោះអាស្រ័យ នូវបឋវី មិនគិត ព្រោះអាស្រ័យ នូវអាបោ មិនគិត ព្រោះអាស្រ័យ នូវតេជោ មិនគិត ព្រោះអាស្រ័យ នូវវាយោ មិនគិត ព្រោះអាស្រ័យ នូវអាកាសានញ្ចាយតនៈ មិនគិត ព្រោះអាស្រ័យ នូវវិញ្ញាណញ្ចាយតនៈ មិនគិត ព្រោះអាស្រ័យ នូវអាកិញ្ចញ្ញាយតនៈ មិនគិត ព្រោះអាស្រ័យ នូវនេវសញ្ញានាសញ្ញាយតនៈ មិនគិត ព្រោះអាស្រ័យ នូវលោកនេះ មិនគិត ព្រោះអាស្រ័យ នូវលោកខាងមុខ មិនគិត ព្រោះអាស្រ័យ នូវរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត គ្រាន់តែគិតជាធម្មតាតែប៉ុណ្ណោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុម្តេច ទេវតាទាំងឡាយ ព្រមទាំងព្រះឥន្ទ្រ ព្រមទាំងព្រហ្ម ព្រមទាំងបជាបតិទេវរាជ នមស្ការ

អំពីចម្ងាយ ចំពោះបុរសអាជានីយដ៏ចម្រើន ដែលមានឈានយ៉ាងនេះថា

យើងទាំងឡាយ មិនស្គាល់អ្នកណាជាបុរសអាជានីយ

តែងគិត ព្រោះអាស្រ័យនូវគុណធម៌ណា បពិត្របុរស

អាជានីយ យើងសូមនមស្ការចំពោះអ្នក បពិត្របុរស

ដ៏ឧត្តម យើងសូមនមស្ការ ចំពោះអ្នក ។

ម្នាលសន្ធៈ បុរសអាជានីយដ៏ចម្រើន ក្នុងលោកនេះ សម្គាល់ថា ដី ក្នុងដី ជាប្រាកដ សម្គាល់ថា ទឹកក្នុងទឹក ជាប្រាកដ សម្គាល់ថា ភ្លើងក្នុងភ្លើង ជាប្រាកដ សម្គាល់ថា ខ្យល់ក្នុងខ្យល់ ជាប្រាកដ សម្គាល់ថា អាកាសានញ្ចាយតនៈក្នុងអាកាសានញ្ចាយតនៈ ជាប្រាកដ សម្គាល់ថា វិញ្ញាណញ្ចាយតនៈ ក្នុងវិញ្ញាណញ្ចាយតនៈ ជាប្រាកដ សម្គាល់ថា អាកិញ្ចញ្ញាយតនៈ ក្នុងអាកិញ្ចញ្ញាយតនៈ ជាប្រាកដ សម្គាល់ថា នេវសញ្ញានាសញ្ញាយតនៈ ក្នុងនេវសញ្ញានាសញ្ញាយតនៈ ជាប្រាកដ សម្គាល់ថា លោកនេះក្នុងលោកនេះ ជាប្រាកដ សម្គាល់ថា លោកខាងមុខក្នុងលោកខាងមុខ ជាប្រាកដ សម្គាល់ក្នុងរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត ជាប្រាកដ ។ ម្នាលសន្ធៈ បុរសអាជានីយដ៏ចម្រើន អ្នកមានឈានយ៉ាងនេះ មិនគិត ព្រោះអាស្រ័យ នូវបឋវី មិនគិត ព្រោះអាស្រ័យ នូវអាបោ មិនគិត ព្រោះអាស្រ័យ នូវតេជោ មិនគិត ព្រោះអាស្រ័យ នូវវាយោ មិនគិត ព្រោះអាស្រ័យ នូវអាកាសានញ្ចាយតនៈ មិនគិត ព្រោះអាស្រ័យ នូវ

វិញ្ញាណញ្ចាយតនៈ មិនគិត ព្រោះអាស្រ័យ នូវអាកិញ្ចញ្ញាយតនៈ មិនគិត ព្រោះអាស្រ័យ នូវនេវសញ្ញានាសញ្ញាយតនៈ មិនគិត ព្រោះអាស្រ័យ នូវលោកនេះ មិនគិត ព្រោះអាស្រ័យ នូវលោកខាងមុខ មិនគិត ព្រោះអាស្រ័យ នូវរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ស្វែងរក ត្រិះរិះដោយចិត្ត គ្រាន់តែគិតជាធម្មតាប៉ុណ្ណោះ ។ ម្នាលសទ្ធៈ ហេតុយ៉ាងនេះ ទេវតាទាំងឡាយ ព្រមទាំងព្រះឥន្ទ្រ ព្រមទាំងព្រហ្ម ព្រមទាំងបជាបតិទេវរាជ តែងនមស្ការ អំពីចម្ងាយ ចំពោះបុរសអាជានីយដ៏ចម្រើន អ្នកមានឈាន យ៉ាងនេះថា

យើងមិនស្គាល់ច្បាស់ អ្នកណាជាបុរសអាជានីយ តែងគិត ព្រោះអាស្រ័យ នូវគុណធម៌ណា បពិត្របុរសអាជានីយ យើងសូមនមស្ការចំពោះអ្នក បពិត្របុរសដ៏ឧត្តម យើងសូមនមស្ការ ចំពោះអ្នក ។

# អដ្ឋកថា

## អសេក្ខសូត្រ

[ ១១៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអសេក្ខសូត្រទី ៩ ដូចតទៅនេះ បទថា **ទោណិយា ពន្ធោ** សេចក្តីថា សេះខ្ចកដែលគេរៀបចំទុកក្បែរស្នូកស្រូវដំណើប ។ បទថា **អន្តរំ ករិត្វា** សេចក្តីថា ធ្វើភាគៈទុកខាងក្នុង ។ បទថា

**ឈាយតិ** សេចក្ដីថា រមែងគិត ។ បទថា **បជ្ឈាយតិ** សេចក្ដីថា រមែងសម្លឹងឈាន មានប្រការផ្សេងៗ ខាងនោះខ្លះ ខាងនេះខ្លះ ។ បទថា **និជ្ឈាយតិ** សេចក្ដីថា រមែងសម្លឹងឈានជានិច្ច ដោយមិនមានចន្លោះ ។ ពាក្យថា **បឋវិម្បិ និស្សាយ ឈាយតិ** នេះ ព្រះមានព្រះភាគ ត្រាស់ដោយអំណាចបុគ្គលដែលនៅត្រេកអរក្នុងសមាបត្តិ ព្រោះថា បឋវីធាតុនេះ ឈ្មោះថា ជាចំណែកតូចតាចដែលបុគ្គលធ្វើហើយ ព្រោះខ្លួននៅត្រេកអរក្នុងសមាបត្តិ ក្នុងអាបោធាតុជាដើម ក៏មានន័យដូចគ្នា ។

ពាក្យថា **កថញ្ច សន្ធ អាជានីយឈាយិតំ ហោតិ** សេចក្ដីថា សេះសិន្ធពដឹងហេតុដែលសមគួរ និងមិនសមគួរ គិតដូចម្ដេច ។ ក្នុងពាក្យថា **យថា ឥណំ** ជាដើម គប្បីជ្រាបអធិប្បាយថា សេះអាជានេយ្យ រមែងមើលឃើញ ការធ្លាក់ត្រូវ ពោល គឺការដាក់ខ្សែតីត្រង់មុខខ្លួន ធ្វើឲ្យដូចជាបំណុល ដូចត្រូវចង ដូចវិនាស ដូចការខុសច្រើន ពោល គឺទោស ។

បទថា **នេវ បឋវឹ និស្សាយ ឈាយតិ** សេចក្ដីថា បុរសអាជានេយ្យនោះ រមែងមិនសម្លឹងដោយសញ្ញាក្នុងឈានដែលប្រកបដោយអង្គ ៤ និងអង្គ ៥ ដែលមានបឋវីធាតុជាអារម្មណ៍ ព្រោះមិនត្រេកអរនឹងសេចក្ដីសុខក្នុងសមាបត្តិ រមែងសម្លឹងអារម្មណ៍ដែលប្រាកដច្បាស់ថា បុរសនេះ ឈ្មោះថា បុរសអាជានេយ្យ ព្រោះមិនមានសេចក្ដីត្រេកអរ រមែងសម្លឹងដោយផលសមាបត្តិ ដែលមានព្រះនិព្វានជាអារម្មណ៍ ។ បទថា **បឋវិយំ បឋវីសញ្ញា**

**វិភូតា ហោតិ** *សេចក្តីថា ការសម្គាល់ក្នុងឈានមានអង្គ ៤ ឬមានអង្គ ៥ មានបឋវីធាតុជាអារម្មណ៍កើតឡើងហើយ រមែងជាធម្មជាតជាក់ច្បាស់ គឺប្រាកដហើយ ។ ក្នុងព្រះសូត្រនេះថា បពិត្រព្រះអង្គដ៏ចម្រើន រូបសញ្ញាប្រាកដច្បាស់ អដ្ឋិកសញ្ញាមិនប្រាកដច្បាស់ ដូច្នេះជាដើម ឈ្មោះថា ព្រះសន្ធៈ ពោលដល់ភាពជាបឋវីធាតុប្រាកដច្បាស់ ព្រោះនៅមានការឈានកន្លង ។ ក្នុងព្រះសូត្រនេះ រូបសញ្ញានោះ ឈ្មោះថា ប្រាកដច្បាស់ ព្រោះជាធម្មជាតដែលឃើញបានដោយភាពជារបស់មិនទៀង ជាទុក្ខ និងជាអនត្តា ដោយអំណាចនៃវិបស្សនា ក្នុងអាបោសញ្ញាជាដើម ក៏ន័យនេះដូចគ្នា ។ ក្នុងព្រះសូត្រនេះ មិនត្រាស់ការឈានកន្លងដោយអំណាចសមាបត្តិ តែត្រាស់ការឈានកន្លង ដោយអំណាចវិបស្សនាវារៈដូចខាងដើម ដោយប្រការដូច្នេះ ។ បទថា* **ឈំ ឈាយី** *សេចក្តីថា បុរសជាអាជានេយ្យសម្លឹងដោយផលសមាបត្តិ ដែលកើតមក តាមលំដាប់នៃវិបស្សនាយ៉ាងនេះ ៕*

## អដ្ឋកថា អសេក្ខសូត្រទី ៩ ចប់

# សុត្តន្តបិដក

## មោរនិវាបនសូត្រទី ១០

[ ១១៧ ] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងបរិព្វាជការាម ជាមោរនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយនោះ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ ប្រការ ឈ្មោះថា ជាអ្នកសម្រេចមែន ក្សេមចាកយោគៈមែន ប្រព្រឹត្តព្រហ្មចរិយៈមែន ចប់មែន ប្រសើរជាងទេវតា និងមនុស្សទាំងឡាយ ។ ធម៌ ៣ ប្រការតើដូចម្តេច ។ គឺសីលក្ខន្ធជាអសេក្ខៈ ១ សមាធិក្ខន្ធជាអសេក្ខៈ ១ បញ្ញាខន្ធ ជាអសេក្ខៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ ប្រការនេះឯង ទើបឈ្មោះថា ជាអ្នកសម្រេចមែន ក្សេមចាកយោគៈមែន ប្រព្រឹត្តព្រហ្មចរិយៈមែន ចប់មែន ប្រសើរជាងទេវតា និងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុប្រកបដោយធម៌ ៣ ប្រការដទៃទៀត ក៏ឈ្មោះថាជាអ្នកសម្រេចមែន ឈ្មោះថា ក្សេមចាកយោគៈមែន ប្រព្រឹត្តព្រហ្មចរិយៈមែន ចប់មែន ប្រសើរជាងទេវតា និងមនុស្សទាំងឡាយ ។ ធម៌ ៣ ប្រការតើដូចម្តេច ។ គឺ ឥទ្ធិប្បាដិហារិយ៍ ១ អាទេសនាបាដិហារិយ៍ ១ អនុសាសនីបាដិហារិយ៍ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ ប្រការនេះឯង ឈ្មោះថាជាអ្នកសម្រេចមែន ក្សេមចាកយោគៈមែន ប្រព្រឹត្តព្រហ្មចរិយៈមែន ចប់មែន ប្រសើរ

ជាងទេវតា និងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ ប្រការដទៃទៀត ឈ្មោះថា ជាអ្នកសម្រេចមែន ក្សេមចាកយោគៈមែន ប្រព្រឹត្តព្រហ្មចរិយៈមែន ចប់មែន ប្រសើរជាងទេវតា និងមនុស្សទាំងឡាយ ។ ធម៌ ៣ ប្រការ តើដូចម្ដេច ។ គឺសម្មាទិដ្ឋិ ១ សម្មាញាណៈ ១ សម្មាវិមុត្តិ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ ប្រការនេះឯង ឈ្មោះថា ជាអ្នកសម្រេចមែន ក្សេមចាកយោគៈមែន ប្រព្រឹត្តព្រហ្មចរិយៈមែន ចប់មែន ប្រសើរជាងទេវតា និងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ២ ប្រការ ឈ្មោះថា ជាអ្នកសម្រេចមែន ក្សេមចាកយោគៈមែន ប្រព្រឹត្តព្រហ្មចរិយៈមែន ចប់មែន ប្រសើរជាងទេវតា និងមនុស្សទាំងឡាយ ។ ធម៌ ២ ប្រការ តើដូចម្ដេច ។ គឺវិជ្ជា ១ ចរណៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ២ ប្រការនេះ ទើបឈ្មោះថា ជាអ្នកសម្រេចមែន ក្សេមចាកយោគៈមែន ប្រព្រឹត្តព្រហ្មចរិយៈមែន ចប់មែន ប្រសើរជាងទេវតា និងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ គាថានេះ ព្រហ្ម ឈ្មោះ សនង្កុមារៈ បានពោលហើយថា

ជនទាំងឡាយណា ជាអ្នកប្រកាន់ចំពោះគោត្រ ( បណ្ដា
ជនទាំងនោះ ) ក្សត្រិយ៍ ប្រសើរជាងប្រជុំជន ជនណា
បរិបូណ៌ដោយវិជ្ជា និងចរណៈ ជននោះជាបុគ្គលប្រសើរ
ជាងទេវតា និងមនុស្ស ។

ម្នាលភិក្ខុទាំងឡាយ គាថានេះឯង សនង្កុមារព្រហ្មបានច្រៀងត្រូវហើយ មិនមែនច្រៀងខុសទេ ជាសុភាសិត មិនមែនទុព្ភាសិតទេ ប្រកបដោយប្រយោជន៍ មិនមែនមិនប្រកបដោយប្រយោជន៍ទេ ទាំងតថាគតក៏យល់ព្រម ម្នាលភិក្ខុទាំងឡាយ ចំណែកតថាគតក៏ពោលយ៉ាងនេះថា

ជនទាំងឡាយណា ជាអ្នកប្រកាន់ចំពោះគោត្រ ( បណ្តាជនទាំងនោះ ) ក្សត្រិយ៍ ប្រសើរជាងប្រជុំជន ជនណាបរិបូណ៌ដោយវិជ្ជា និងចរណៈ ជននោះជាបុគ្គលប្រសើរជាងទេវតា និងមនុស្សដែរ ។

**និស្សយវគ្គទី ១ ចប់**

## ឧទ្ទាននៃនិស្សយវគ្គនោះ គឺ

និយាយអំពីសីល មានប្រយោជន៍ដូចម្តេច ១ ចេតនាមានបីលើក ឧបនិស្ស័យ ១ សេចក្តីវិនាស ១ សញ្ញា ១ មិនធ្វើទុកក្នុងចិត្ត ១ សេក្ខៈ ១ បរិព្វាជកភារមជាមោរនិវាបស្ថាន ១ ។

# អដ្ឋកថា

## មោរនិវាបនសូត្រ

[ ១១៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមោរនិវាបនសូត្រទី ១០ ដូចតទៅនេះ បទថា **អច្ចន្តនិដ្ឋោ** គប្បីជ្រាបវិគ្គហៈថា ព្រះនិព្វាន ពោល គឺអច្ចន្ត ព្រោះកន្លងទីបំផុតហើយ មានការវិនាសជាធម្មតា ឈ្មោះថា **និដ្ឋា** ការសម្រេចរបស់ភិក្ខុណា ព្រោះហេតុនោះ ភិក្ខុនោះ ឈ្មោះថា **អច្ចន្តនិដ្ឋោ** បុគ្គលមានការសម្រេចកន្លងចំណែក ។ បទដ៏សេស គប្បីជ្រាបដោយន័យនេះឯង ។

បទថា **ជនេតស្មឹ** បានដល់ ក្នុងពពួកជន អធិប្បាយថា ក្នុងពពួកសត្វ ។ បទថា **យេ គោត្តប្បដិសារិនោ** សេចក្តីថា ជនទាំងឡាយណារមែងរឭក រង្កៀសក្នុងត្រកូលនោះថា អញជាត្រកូលគោតម ឬអញជាត្រកូលកស្សបៈ ដូច្នេះ ក្នុងបណ្តាការរឭក រង្កៀសដោយត្រកូលទាំងនោះត្រកូលក្សត្រប្រសើរបំផុតក្នុងលោក ។ បទថា **អនុមតា មយា** សេចក្តីថា គាថាដែលសនង្កុមារព្រហ្មសម្តែង ប្រៀបបាននឹងសព្វញ្ញុតញ្ញាណរបស់តថាគត តថាគតក៏អនុញ្ញាត ។ បទដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថា មោរនិវាបនសូត្រទី ១០ ចប់**

**និវាបវគ្គទី ១ ចប់**

# សុត្តន្តបិដក

# ទុតិយវគ្គទី ២

## បឋមមហានាមសូត្រទី ១

[ ១១៨ ] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងនិគ្រោធារាម ជិតក្រុងកបិលពស្តុ ក្នុងដែនសក្កៈ ។ សម័យនោះឯង ភិក្ខុទាំងឡាយច្រើនរូប ធ្វើចីវរកម្ម ថ្វាយចំពោះព្រះមានព្រះភាគ ដោយគិតថា ព្រះមានព្រះភាគមាន ចីវរសម្រេចហើយ ទ្រង់នឹងចៀសចេញទៅកាន់ចារិក ដោយកាលកន្លងទៅ ៣ ខែ ។ មហានាមសក្កៈ បានឮថា ពួកភិក្ខុច្រើនរូប ធ្វើចីវរកម្ម ថ្វាយព្រះ មានព្រះភាគ មានចីវរសម្រេចហើយ ទ្រង់ចៀសចេញទៅកាន់ចារិក ដោយ កាលកន្លងទៅ ៣ ខែ ។ គ្រានោះ មហានាមសក្កៈបានចូលទៅគាល់ព្រះមាន ព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុង ទីសមគួរ ។ លុះមហានាមសក្កៈ អង្គុយក្នុងទីសមគួរហើយ បានក្រាបទូល ព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮពាក្យនេះ ថា ពួកភិក្ខុច្រើនរូប ធ្វើចីវរកម្ម ថ្វាយចំពោះព្រះមានព្រះភាគ ដោយគិតថា ព្រះមានព្រះភាគ មានចីវរសម្រេចហើយ ទ្រង់នឹងចៀសចេញទៅកាន់ចារិក ដោយកាលកន្លងទៅ ៣ ខែ ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គទាំងនោះ កាលនៅដោយវិហារធម៌ផ្សេងៗ តើគួរនៅ ដោយវិហារធម៌ដូចម្តេច ។ ព្រះ អង្គត្រាស់ថា បពិត្រមហានាម ប្រពៃហើយ ប្រពៃហើយ បពិត្រមហានាម

ការសួរនេះឯង ជាកិច្ចដ៏សមគួរ ដល់ព្រះអង្គជាកុលបុត្រហើយ ដ្បិតថា ព្រះអង្គចូលមកគាល់តថាគតហើយសួរថា បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងនោះ កាលនៅដោយវិហារធម៌ផ្សេងៗ តើគួរនៅដោយវិហារធម៌ ដូចម្ដេច ។ បពិត្រមហានាម បុគ្គលអ្នកមានសទ្ធា ញុំាងសទ្ធាឲ្យសម្រេច មិនមែនជាអ្នកមិនមានសទ្ធា ១ អ្នកប្រារព្ធសេចក្ដីព្យាយាម ញុំាងព្យាយាម ឲ្យសម្រេចមិនមែនជាអ្នកខ្ជិលច្រអូស ១ អ្នកមានសតិខ្ជាប់ខ្ជួន ញុំាងសតិឲ្យសម្រេច មិនមែនជាអ្នកភ្លេចសតិ ១ អ្នកមានចិត្តតាំងមាំ ញុំាងចិត្តដែលតាំងមាំឲ្យសម្រេច មិនមែនជាអ្នកមានចិត្តមិនតាំងមាំ ១ អ្នកមានប្រាជ្ញា ញុំាងប្រាជ្ញាឲ្យសម្រេច មិនមែនជាអ្នកឥតប្រាជ្ញា ១ ។ បពិត្រមហានាម ព្រះអង្គតាំងនៅក្នុងធម៌ទាំង ៥ នេះហើយ គប្បីចម្រើនធម៌ ៦ យ៉ាងទៀត ។ បពិត្រមហានាម ក្នុងសាសនានេះ ព្រះអង្គគប្បីរឭកនូវតថាគតថា ព្រះមានព្រះភាគអង្គនោះ ជាអរហន្ត-សម្មាសម្ពុទ្ធ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ជាព្រះសុគត ជ្រាបច្បាស់នូវលោក ព្រះអង្គ ប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាសារថីទូន្មាននូវបុរស ព្រះអង្គជាសាស្ដានៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គបំបាក់បង់នូវភពដូច្នេះ ។ បពិត្រមហានាម អរិយសាវករឭកនូវតថាគតក្នុងសម័យណា អរិយសាវកនោះឥតមានរាគៈរួបរឹតចិត្តបាន ឥតមានទោសៈរួបរឹតចិត្តបាន ឥតមានមោហៈរួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវកនោះ ជាចិត្តត្រង់ក្នុងសម័យ

*នោះ បពិត្រមហានាម លុះអរិយសាវកមានចិត្តត្រង់ ប្រារព្ធនូវតថាគតហើយ រមែងបាននូវសេចក្តីយល់នូវអត្ថ សេចក្តីយល់នូវធម៌ មានសេចក្តីរីករាយប្រកបដោយធម៌ កាលបើអរិយសាវក មានចិត្តរីករាយហើយ បីតិ តែងកើតឡើង កាលបើអរិយសាវកមានចិត្តប្រកបដោយបីតិហើយ កាយក៏ស្ងប់រម្ងាប់ លុះអរិយសាវក មានកាយស្ងប់រម្ងាប់ហើយ តែងបានទទួលនូវសេចក្តីសុខ កាលបើអរិយសាវក មានសេចក្តីសុខហើយ ចិត្តក៏បានតាំងនៅល្អ ។ បពិត្រមហានាម អរិយសាវកនេះ តថាគតហៅថា អ្នកដល់នូវការស្មោះស្មើក្នុងពួកសត្វដែលមិនស្មោះស្មើ អ្នកមិនមានព្យាបាទ ក្នុងពួកសត្វដែលមានសេចក្តីព្យាបាទ អ្នកដល់នូវខ្សែនៃធម៌ តែងចម្រើននូវពុទ្ធានុស្សតិ ។*

*បពិត្រមហានាម មួយទៀត ព្រះអង្គគប្បីរឭកនូវព្រះធម៌ថា ព្រះបរិយត្តិធម៌ ដែលព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងហើយដោយល្អ ព្រះនព្វលោកុត្តរធម៌ ជាធម៌ដែលព្រះអរិយបុគ្គលទាំង ៨ ពួក ដឹងពិត ឃើញពិត ដោយបច្ចវេក្ខណញ្ញាណ ជាធម៌ឲ្យនូវផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី ជាធម៌ដែលព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួន ដោយអំណាចនៃភាវនា ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីឃើញច្បាស់ ក្នុងចិត្តនៃខ្លួន ។ បពិត្រមហានាម អរិយសាវក រឭកនូវព្រះធម៌ ក្នុងសម័យណា អរិយសាវកនោះ ឥតមានរាគៈរួបរឹតចិត្តបាន ឥតមានទោសៈរួបរឹតចិត្តបាន ឥតមានមោហៈរួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្ត*

របស់អរិយសាវកនោះ ជាចិត្តត្រង់ ក្នុងសម័យនោះ បពិត្រមហានាម លុះអរិយសាវកមានចិត្តត្រង់ ប្រារព្ធនូវព្រះធម៌ តែងបានសេចក្តីយល់នូវអត្ថ បានសេចក្តីយល់នូវធម៌ បាននូវសេចក្តីរីករាយ ប្រកបដោយធម៌ កាលបើអរិយ-សាវក មានសេចក្តីរីករាយហើយ បីតិ រមែងកើតឡើង កាលបើអរិយសាវកមានចិត្តប្រកបដោយបីតិហើយ កាយក៏ស្ងប់រម្ងាប់ លុះអរិយសាវកមានកាយស្ងប់រម្ងាប់ហើយ រមែងទទួលនូវសេចក្តីសុខ កាលបើអរិយសាវកមានសេចក្តីសុខហើយ ចិត្តក៏តាំងនៅល្អ ។ បពិត្រមហានាម អរិយសាវកនេះ តថាគតហៅថា អ្នកដល់នូវការស្មោះស្មើក្នុងពួកសត្វ ដែលមិនស្មោះស្មើ អ្នកមិនមានព្យាបាទ ក្នុងពួកសត្វដែលមានសេចក្តីព្យាបាទ អ្នកដល់នូវខ្សែនៃធម៌ តែងចម្រើននូវធម្មានុស្សតិ ។

បពិត្រមហានាម មួយទៀត ព្រះអង្គគប្បីរឭក នូវព្រះសង្ឃថា ព្រះសង្ឃសាវកនៃព្រះមានព្រះភាគ លោកប្រតិបត្តិហើយ ដោយប្រពៃ ព្រះសង្ឃសាវកនៃព្រះមានព្រះភាគ លោកប្រតិបត្តិហើយ ដោយត្រង់ ព្រះសង្ឃសាវក នៃព្រះមានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ព្រះសង្ឃសាវកនៃព្រះមានព្រះភាគ លោកប្រតិបត្តិគួរដល់សាមីចិកម្ម ព្រះសង្ឃណា បើរាប់ជាគូនៃបុរសមាន ៤ គូ បើរាប់រៀងជាបុរសបុគ្គលមាន ៨ ព្រះសង្ឃសាវកនៃព្រះមានព្រះភាគនុ៎ះ លោកគួរទទួលរបស់ដែលគេនាំមកបូជា លោកគួរទទួលរបស់ ដែលគេបម្រុងទទួលភ្ញៀវ លោកគួរទទួលទក្ខិណាទាន

លោកគួរដល់អញ្ជលិកម្ម លោកជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។ បពិត្រមហានាម អរិយសាវករឭកនូវព្រះសង្ឃ ក្នុងសម័យណា អរិយសាវកនោះ ឥតមានរាគៈរួបរឹតចិត្តបាន ឥតមានទោសៈរួបរឹតចិត្តបាន ឥតមានមោហៈរួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវកនោះ ជាចិត្តត្រង់ ក្នុងសម័យនោះ បពិត្រមហានាម លុះអរិយសាវក មានចិត្តត្រង់ប្រារព្ធនូវព្រះសង្ឃហើយ តែងបានសេចក្តីយល់នូវអត្ថ បានសេចក្តីយល់នូវធម៌ បានសេចក្តីរីករាយប្រកបដោយធម៌ កាលបើអរិយសាវក មានចិត្តរីករាយហើយ បីតិ តែងកើតឡើង កាលបើអរិយសាវក មានចិត្តប្រកបដោយបីតិហើយ កាយក៏ស្ងប់រម្ងាប់ លុះអរិយសាវក មានកាយស្ងប់រម្ងាប់ហើយ តែងទទួលនូវសេចក្តីសុខ កាលបើអរិយសាវក មានសេចក្តីសុខហើយ ចិត្តក៏តាំងនៅល្អ ។ បពិត្រមហានាម អរិយសាវកនេះ តថាគតហៅថា អ្នកដល់នូវការស្មោះស្មើក្នុងពួកសត្វ ដែលមិនមានសេចក្តីស្មោះស្មើ អ្នកមិនមានសេចក្តីព្យាបាទ ក្នុងពួកសត្វដែលមានសេចក្តីព្យាបាទ អ្នកដល់នូវខ្សែនៃធម៌ តែងចម្រើននូវសង្ឃានុស្សតិ ។

បពិត្រមហានាម មួយទៀត ព្រះអង្គគប្បីរឭកនូវសីលទាំងឡាយរបស់ខ្លួនថា សីលមិនដាច់ មិនធ្លុះ មិនពព្រុស មិនពពាល ជាសីលជានា ដែលពួកវិញ្ញូជនសរសើរ ជាសីលដែលតណ្ហា និងទិដ្ឋិ មិនបានស្ទាបអង្អែល ជាសីលប្រព្រឹត្តទៅ ដើម្បីសមាធិ ។ បពិត្រមហានាម អរិយសាវក រឭកនូវ

សីល ក្នុងសម័យណា អរិយសាវកនោះ ឥតមានរាគៈរួបរឹតចិត្តបាន ឥត មានទោសៈរួបរឹតចិត្តបាន ឥតមានមោហៈរួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវកនោះ ជាចិត្តត្រង់ក្នុងសម័យនោះ បពិត្រមហានាម លុះ អរិយសាវកមានចិត្តត្រង់ ប្រារព្ធនូវសីលហើយ តែងបានសេចក្ដីយល់នូវអត្ថ បានសេចក្ដីយល់នូវធម៌ បានសេចក្ដីរីករាយ ប្រកបដោយធម៌ កាលបើអរិយ-សាវក មានចិត្តរីករាយហើយ បីតិក៏កើតឡើង កាលបើអរិយសាវក មាន ចិត្តប្រកបដោយបីតិហើយ កាយក៏ស្ងប់រម្ងាប់ លុះអរិយសាវក មានកាយ ស្ងប់រម្ងាប់ហើយ តែងបានទទួលនូវសេចក្ដីសុខ កាលបើអរិយសាវក មាន សេចក្ដីសុខហើយ ចិត្តក៏តាំងនៅល្អ ។ បពិត្រមហានាម អរិយសាវកនេះ តថាគតហៅថា អ្នកដល់នូវការស្មោះស្មើ ក្នុងពួកសត្វដែលមិនមានសេចក្ដី ស្មោះស្មើ អ្នកមិនមានសេចក្ដីព្យាបាទ ក្នុងពួកសត្វដែលមានសេចក្ដីព្យាបាទ អ្នកដល់នូវខ្សែនៃធម៌ តែងចម្រើននូវសីលានុស្សតិ ។

បពិត្រមហានាម មួយទៀត ព្រះអង្គគប្បីរឭកនូវចាគៈ របស់ព្រះអង្គ ថា ឱហ្ន៎ អាត្មាអញ ចំជាមានលាភ ឱហ្ន៎ អាត្មាអញបានល្អហើយតើ អាត្មា អញមានចិត្ត មានមន្ទិល គឺសេចក្ដីកំណាញ់ប្រាសចេញហើយ ក្នុងពួកសត្វ ដែលមានមន្ទិល គឺសេចក្ដីកំណាញ់រួបរឹតហើយ បានបរិច្ចាគរួចហើយ មានដៃ លាងស្អាតហើយ ត្រេកអរ ក្នុងការលះបង់ គួរឲ្យគេសូមបាន ត្រេកអរ ក្នុង ការចែករំលែកទាន នៅគ្រប់គ្រងផ្ទះ ។ បពិត្រមហានាម អរិយសាវករឭក

នូវបាត: ក្នុងសម័យណា អរិយសាវកនោះ ឥតមានរាគៈរួបរឹតចិត្តបាន ឥតមានទោសៈរួបរឹតចិត្តបាន ឥតមានមោហៈរួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវកនោះ ជាចិត្តត្រង់ ក្នុងសម័យនោះ បពិត្រមហានាម លុះអរិយសាវក មានចិត្តត្រង់ ប្រារព្ធនូវបាគៈហើយ តែងបានសេចក្តីយល់នូវអត្ថ បានសេចក្តីយល់នូវធម៌ បានសេចក្តីរីករាយប្រកបដោយធម៌ កាលបើអរិយសាវកមានចិត្តរីករាយហើយ បីតិតែងកើតឡើង កាលបើអរិយសាវកមានចិត្តប្រកបដោយបីតិហើយ កាយក៏ស្ងប់រម្ងាប់ លុះអរិយសាវកមានកាយស្ងប់រម្ងាប់ហើយ តែងបានទទួលនូវសេចក្តីសុខ កាលបើអរិយសាវក មានសេចក្តីសុខហើយ ចិត្តក៏តាំងនៅល្អ ។ បពិត្រមហានាម អរិយសាវកនេះ តថាគតហៅថា អ្នកដល់នូវការស្មោះស្មើ ក្នុងពួកសត្វដែលមិនមានសេចក្តីស្មោះស្មើ អ្នកមិនមានសេចក្តីព្យាបាទ ក្នុងពួកសត្វដែលមានសេចក្តីព្យាបាទ អ្នកដល់នូវខ្សែនៃធម៌ តែងចម្រើននូវបាគានុស្សតិ ។

បពិត្រមហានាម មួយវិញទៀត ព្រះអង្គគប្បីរឭកនូវពួកទេវតាថា ពួកទេវតាជាន់ចាតុម្មហារាជិកៈ មានពួកទេវតាជាន់តាវត្តិង្ស មានពួកទេវតាជាន់យាមៈ មានពួកទេវតាជាន់តុសិត មានពួកទេវតាជាន់និម្មានរតី មានពួកទេវតាជាន់បរនិម្មិតវសវត្តី មានពួកទេវតាដែលរាប់បញ្ចូលក្នុងពួកព្រហ្ម មានពួកទេវតាតពីនោះទៅទៀតក៏មាន ពួកទេវតាទាំងនោះ ប្រកបដោយសទ្ធាមានសភាពយ៉ាងណា ច្យុតអំពីទីនេះ ទៅកើតក្នុងទីនោះ អាត្មាអញមានសទ្ធា

មានសភាពដូច្នោះដែរ ពួកទេវតាទាំងនោះ ប្រកបដោយសីល មានសភាព យ៉ាងណា ច្យុតអំពីទីនេះ ទៅកើតក្នុងទីនោះ អាត្មាអញមានសីល មាន សភាព ដូច្នោះ ពួកទេវតាទាំងនោះ ប្រកបដោយសុតៈ មានសភាពយ៉ាង ណា ច្យុតអំពីទីនេះ ទៅកើតក្នុងទីនោះ អាត្មាអញមានសុតៈ មានសភាព ដូច្នោះដែរ ពួកទេវតាទាំងនោះ ប្រកបដោយចាគៈ មានសភាពយ៉ាងណា ច្យុតអំពីទីនេះ ទៅកើតក្នុងទីនោះ អាត្មាអញមានចាគៈ មានសភាពដូច្នោះដែរ ពួកទេវតាទាំងនោះ ប្រកបដោយបញ្ញា មានសភាពយ៉ាងណា ច្យុតអំពីទីនេះ ទៅកើតក្នុងទីនោះ អាត្មាអញមានបញ្ញា មានសភាពដូច្នោះដែរ ។ បពិត្រ មហានាម អរិយសាវករឭកនូវសទ្ធា សីល សុតៈ ចាគៈ បញ្ញា របស់ខ្លួន ផង របស់ពួកទេវតាទាំងនោះផង ក្នុងសម័យណា អរិយសាវកនោះ ឥត មានរាគៈរួបរឹតចិត្តបាន ឥតមានទោសៈរួបរឹតចិត្តបាន ឥតមានមោហៈរួបរឹត ចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវកនោះ ជាចិត្តត្រង់ក្នុងសម័យ នោះ បពិត្រមហានាម លុះអរិយសាវក មានចិត្តត្រង់ ប្រារព្ធនូវពួកទេវតា ហើយ តែងបានសេចក្តីយល់នូវអត្ថ បានសេចក្តីយល់នូវធម៌ បានសេចក្តី រីករាយ ប្រកបដោយធម៌ កាលបើអរិយសាវក មានចិត្តរីករាយហើយ បីតិ ក៏កើតឡើង កាលបើអរិយសាវក មានចិត្តប្រកបដោយបីតិហើយ កាយក៏ ស្ងប់រម្ងាប់ លុះអរិយសាវក មានកាយស្ងប់រម្ងាប់ហើយ តែងបានទទួលនូវ សេចក្តីសុខ កាលបើអរិយសាវក មានសេចក្តីសុខហើយ ចិត្តក៏តាំងនៅ

ល្អ ។ បពិត្រមហានាម អរិយសាវកនេះ តថាគតហៅថា អ្នកដល់នូវការស្មោះស្មើ ក្នុងពួកសត្វដែលមិនមានសេចក្តីស្មោះស្មើ អ្នកមិនមានព្យាបាទ ក្នុងពួកសត្វ ដែលមានសេចក្តីព្យាបាទ អ្នកដល់នូវខ្សែនៃធម៌ តែងចម្រើននូវទេវតានុស្សតិ ។

# អដ្ឋកថា

## ទុតិយវគ្គទី ២

### បឋមមហានាមសូត្រ

[ ១១៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមមហានាមសូត្រទី ១ នៃទុតិយវគ្គទី ២ ដូចតទៅនេះ បទថា **នានាវិហារេហិ វិហរតំ** សេចក្តីថា ឈ្មោះថាធម៌ជាគ្រឿងនៅប្រចាំសម្រាប់គ្រហស្ថ មិនមានតែម្យ៉ាង ព្រោះហេតុនោះទើបព្រះបាទមហានាមសក្យៈទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គទាំងនោះ កាលនៅដោយវិហារធម៌ផ្សេងៗ ... ។ បទថា **កេន វិហារេន** ព្រះបាទមហានាមសក្យៈទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគប្បីនៅដោយវិហារធម៌ដូចម្តេច ។ បទថា **អារាធកោ** បានដល់ បុគ្គលធ្វើឲ្យដល់ព្រម ឲ្យបរិបូណ៌ ។ បទថា **ធម្មសោតសមាបន្នោ ធម្មានុស្សតឹ**

**ភាវេតិ** សេចក្តីថា ជាអ្នកដល់ព្រមដោយការសម្តែងធម៌ហើយ រមែងចម្រើនពុទ្ធានុស្សតិ ។ល។

**អដ្ឋកថា បឋមមហានាមសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ទុតិយមហានាមសូត្រទី ២

[ ១១៩ ] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងនិគ្រោធារាម ជិតក្រុងកបិលពស្តុ ក្នុងដែនសក្កៈ ។ សម័យនោះឯង មហានាមសក្កៈ ទើបនឹងសះស្បើយចាកជំងឺ បានសះស្បើយចាកជំងឺ មិនទាន់យូរប៉ុន្មាន ។ សម័យនោះឯង ស្រាប់តែពួកភិក្ខុច្រើនរូប កំពុងធ្វើចីវរកម្ម ថ្វាយចំពោះព្រះមានព្រះភាគ ដោយគិតថា ព្រះមានព្រះភាគ មានចីវរសម្រេចហើយ ទ្រង់នឹងចៀសចេញទៅកាន់ចារិក ដោយកាលកន្លងទៅ ៣ ខែ ។ មហានាមសក្កៈ បានឮថា ពួកភិក្ខុច្រើនរូប កំពុងធ្វើចីវរកម្ម ថ្វាយចំពោះព្រះមានព្រះភាគ ដោយគិតថា ព្រះមានព្រះភាគ មានចីវរសម្រេចហើយនឹងចៀសចេញទៅកាន់ចារិក ដោយកាលកន្លងទៅ ៣ ខែ ។ គ្រានោះ មហានាមសក្កៈ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយ

អង្គុយក្នុងទីសមគួរ ។ លុះមហានាមសក្កៈ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮពាក្យនេះថា ពួកភិក្ខុច្រើនរូប កំពុងធ្វើចីវរកម្ម ថ្វាយចំពោះព្រះមានព្រះភាគ ដោយគិតថា ព្រះមានព្រះភាគ មានចីវរសម្រេចហើយ ទ្រង់នឹងចៀសចេញទៅកាន់ចារិក ដោយកាលកន្លងទៅ ៣ ខែ ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គទាំងនោះ កាលនៅដោយវិហារធម៌ផ្សេងៗ តើគួរនៅដោយវិហារធម៌ដូចម្តេច ។ ព្រះអង្គត្រាស់ថា បពិត្រមហានាម ប្រពៃហើយ ប្រពៃហើយ បពិត្រមហានាម ការសួរនេះឯង ជាកិច្ចដ៏សមគួរ ដល់ព្រះអង្គជាកុលបុត្រហើយដ្បិតថា ព្រះអង្គចូលមកគាល់តថាគត ហើយសួរថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងនោះ កាលនៅដោយវិហារធម៌ផ្សេងៗ តើគួរនៅដោយវិហារធម៌ដូចម្តេច ។ បពិត្រមហានាម បុគ្គលជាអ្នកមានសទ្ធា បានញុំាងសទ្ធាឲ្យសម្រេច មិនមែនជាអ្នកមិនមានសទ្ធា ១ អ្នកប្រារព្ធសេចក្តីព្យាយាម ញុំាងព្យាយាមឲ្យសម្រេច មិនមែនជាអ្នកខ្ជិលច្រអូស ១ អ្នកមានសតិខ្ជាប់ខ្ជួន ញុំាងសតិឲ្យសម្រេច មិនមែនជាអ្នកភ្លេចសតិ ១ ជាអ្នកមានចិត្តតាំងមាំ បានញុំាងចិត្តដែលតាំងមាំ ឲ្យសម្រេច មិនមែនជាអ្នកមានចិត្តមិនតាំងមាំ ១ អ្នកមានប្រាជ្ញាបានញុំាងប្រាជ្ញាឲ្យសម្រេច មិនមែនជាអ្នកអប្បឥតប្រាជ្ញា ១ ។ បពិត្រមហានាម កាលបើព្រះអង្គ បានតាំងនៅក្នុងធម៌ទាំង ៥ នេះហើយ គប្បីចម្រើននូវធម៌ ៦ យ៉ាង តទៅទៀត ។ បពិត្រមហានាម ព្រះអង្គគប្បីរឭកនូវព្រះតថាគត ក្នុង

លោកនេះថា ព្រះមានព្រះភាគអង្គនោះ ។បេ។ ជាសាស្តាចារ្យនៃទេវតា និង មនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលមក កាន់ភពថ្មីទៀត ។ បពិត្រមហានាម អរិយសាវករឭកនូវព្រះតថាគត ក្នុង សម័យណា អរិយសាវកនោះ ឥតមានរាគៈរួបរឹតចិត្តបាន ឥតមានទោសៈ រួបរឹតចិត្តបាន ឥតមានមោហៈរួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយ-សាវកនោះ ជាចិត្តត្រង់ ក្នុងសម័យនោះ បពិត្រមហានាម លុះអរិយសាវក មានចិត្តត្រង់ ប្រារព្ធនូវព្រះតថាគតហើយ តែងបានសេចក្តីយល់នូវអត្ថ បាន សេចក្តីយល់នូវធម៌ បានសេចក្តីរីករាយ ប្រកបដោយធម៌ កាលបើអរិយ-សាវកមានចិត្តរីករាយហើយ បីតិក៏កើតឡើង កាលបើអរិយសាវក មានចិត្ត ប្រកបដោយបីតិហើយ កាយក៏ស្ងប់រម្ងាប់ លុះអរិយសាវក មានកាយស្ងប់ រម្ងាប់ហើយ តែងបានទទួលនូវសេចក្តីសុខ កាលបើអរិយសាវកមានសេចក្តី សុខហើយ ចិត្តក៏តាំងនៅល្អ ។ បពិត្រមហានាម ព្រះអង្គកំពុងស្តេចយាងក្តី គប្បីចម្រើន ឋិតក្តី គប្បីចម្រើន គង់ក្តី គប្បីចម្រើន ផ្ទំក្តី គប្បីចម្រើន ផ្គួផ្គងការងារក្តី គប្បីចម្រើន គ្រប់គ្រងទីផ្ទំដែលចង្អៀតដោយព្រះរាជបុត្រក្តី គប្បី ចម្រើន នូវពុទ្ធានុស្សតិនេះបានដែរ ។

បពិត្រមហានាម មួយទៀត ព្រះអង្គគប្បីរឭកនូវព្រះធម៌ ... គប្បីរឭក នូវព្រះសង្ឃ ... គប្បីរឭកនូវសីលទាំងឡាយរបស់ព្រះអង្គ ... គប្បីរឭក នូវចាគៈរបស់ព្រះអង្គ ... គប្បីរឭកនូវពួកទេវតាថា ពួកទេវតាក្នុងជាន់ចាតុ-

ម្មហារាជិកៈមាន ... ពួកទេវតាក្រៅពីនោះទៅទៀតក៏មាន ពួកទេវតាទាំងនោះ ប្រកបដោយសទ្ធា មានសភាពយ៉ាងណា ច្យុតអំពីទីនេះ ទៅកើតក្នុងទីនោះ អាត្មាអញមានសទ្ធា មានសភាពដូច្នោះដែរ ដោយសីល មានសភាពយ៉ាងណា ... ដោយសុតៈ ... ដោយចាគៈ ... ពួកទេវតាទាំងនោះ ប្រកបដោយបញ្ញា ច្យុតអំពីទីនេះ មានសភាពយ៉ាងណា ទៅកើតក្នុងទីនោះ អាត្មាអញមានបញ្ញា មានសភាពដូច្នោះដែរ ។ បពិត្រមហានាម អរិយសាវករឭកនូវសទ្ធា សីល សុតៈ ចាគៈ បញ្ញា របស់ខ្លួនផង របស់ពួកទេវតាទាំងនោះផង ក្នុងសម័យណា អរិយសាវកនោះ ឥតមានរាគៈរួបរឹតចិត្តបាន ឥតមានទោសៈរួបរឹតចិត្តបាន ឥតមានមោហៈរួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវកនោះ ជាចិត្តត្រង់ ក្នុងសម័យនោះ បពិត្រមហានាម លុះអរិយ-សាវកមានចិត្តត្រង់ ប្រារព្ធនូវពួកទេវតាហើយ រមែងបានសេចក្តីយល់នូវអត្ថ បានសេចក្តីយល់នូវធម៌ បានសេចក្តីរីករាយប្រកបដោយធម៌ កាលបើអរិយ-សាវកមានចិត្តប្រកបដោយបីតិហើយ កាយក៏ស្ងប់រម្ងាប់ លុះអរិយសាវកមានកាយស្ងប់រម្ងាប់ហើយ តែងបានទទួលនូវសេចក្តីសុខ កាលបើអរិយសាវកមានសេចក្តីសុខហើយ ចិត្តតាំងនៅល្អ ។ បពិត្រមហានាម ព្រះអង្គកំពុងស្តេចយាងក្តី គប្បីចម្រើន ឋិតក្តី គប្បីចម្រើន គង់ក្តី គប្បីចម្រើន ផ្ទំក្តី គប្បីចម្រើន ផ្ចង់ការងារក្តី គប្បីចម្រើន គ្រប់គ្រងនូវទីផ្ទំដែលចង្អៀត ដោយព្រះរាជបុត្តក្តី គប្បីចម្រើន នូវទេវតានុស្សតិនេះបានដែរ ។

# អដ្ឋកថា

## ទុតិយមហានាមសូត្រ

[ ១១៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយមហានាមសូត្រទី ២ ដូចតទៅនេះ បទថា **គិលានា វុដ្ឋិតោ** សេចក្ដីថា ព្រះបាទមហានាមសក្យៈប្រឈួនហើយ ក៏ជាពីប្រឈួនមកវិញ ។

**អដ្ឋកថា ទុតិយមហានាមសូត្រទី ២ ចប់**

# សុត្តន្តបិដក

## នន្ទិយសូត្រទី ៣

[ ១២០ ] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងនិគ្រោធារាម ជិតក្រុងកបិលពស្តុ ក្នុងដែនសក្កៈ ។ សម័យនោះឯង ព្រះមានព្រះភាគមានបំណងនឹងចូលទៅគង់ចាំវស្សា ក្នុងក្រុងសាវត្ថី ។ នន្ទិយសក្កៈបានឮដំណឹងថា ព្រះមានព្រះភាគ មានបំណងនឹងចូលទៅគង់ចាំវស្សា ក្នុងក្រុងសាវត្ថី ។ គ្រានោះ នន្ទិយសក្កៈ មានសេចក្ដីត្រិះរិះដូច្នេះថា បើដូច្នោះ ទាំងអាត្មាអញក៏គួរចូលទៅនៅចាំវស្សា ក្នុងក្រុងសាវត្ថីដែរ អាត្មាអញនឹងផ្គងការងារ ក្នុងក្រុងសាវត្ថីនោះផង នឹងបានចួបព្រះមានព្រះភាគ មួយដងមួយកាលផង ។ លំដាប់នោះ ព្រះមានព្រះភាគស្ដេចទៅគង់ចាំវស្សា ក្នុងក្រុងសាវត្ថី ។ ចំណែក

ខាងនន្ទិយសក្កៈ ក៏ចូលទៅនៅចាំវស្សា ក្នុងក្រុងសាវត្ថីដែរ ទាំងភ្ជួងនូវការងារ ក្នុងក្រុងសាវត្ថីនោះផង បានចួបព្រះមានព្រះភាគ មួយដងមួយកាលផង ។ សម័យនោះឯង ពួកភិក្ខុជាច្រើនរូប ធ្វើចីវរកម្ម ថ្វាយចំពោះព្រះមានព្រះភាគ ដោយគិតថា ព្រះមានព្រះភាគ មានចីវរសម្រេចហើយ ទ្រង់ចៀសចេញទៅកាន់ចារិក ដោយកាលកន្លងទៅ ៣ ខែ ។ នន្ទិយសក្កៈ បានឮថា ពួកភិក្ខុច្រើនរូប ធ្វើចីវរកម្ម ថ្វាយចំពោះព្រះមានព្រះភាគ ដោយគិតថា ព្រះមានព្រះភាគ មានចីវរសម្រេចហើយ ទ្រង់នឹងចៀសចេញទៅកាន់ចារិក ដោយកាលកន្លងទៅ ៣ ខែ ។ លំដាប់នោះ នន្ទិយសក្កៈ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះនន្ទិយសក្កៈ អង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮពាក្យនេះថា ពួកភិក្ខុច្រើនរូប ធ្វើចីវរកម្ម ថ្វាយចំពោះព្រះមានព្រះភាគ ដោយគិតថា ព្រះមានព្រះភាគ មានចីវរសម្រេចហើយ ទ្រង់នឹងចៀសចេញទៅកាន់ចារិក ដោយកាលកន្លងទៅ ៣ ខែ ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងនោះកាលនៅដោយវិហារធម៌ផ្សេងៗ តើគួរនៅដោយវិហារធម៌ដូចម្តេច ។ ព្រះអង្គត្រាស់ថា ម្នាលនន្ទិយៈ ប្រពៃហើយ ប្រពៃហើយ ម្នាលនន្ទិយៈ ការសួរនេះឯង ជាកិច្ចដ៏សមគួរដល់ទ្រង់ជាកុលបុត្រហើយ ដ្បិតថា ទ្រង់ចូលមកគាល់តថាគត ហើយសួរថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គទាំងនោះ កាលនៅដោយវិហារធម៌ផ្សេងៗ

តើគួរនៅដោយវិហារធម៌ ដូចម្ដេច ។ ម្នាលនន្ទិយៈ បុគ្គលជាអ្នកមានសទ្ធា បានញុំាងសទ្ធា ឲ្យសម្រេច មិនមែនជាអ្នកមិនមានសទ្ធា ១ ជាអ្នកមានសីល បានញុំាងសីល ឲ្យសម្រេច មិនមែនជាអ្នកទ្រុស្តសីល ១ ជាអ្នកប្រារព្ធសេចក្ដីព្យាយាម បានញុំាងព្យាយាម ឲ្យសម្រេច មិនមែនជាអ្នកខ្ជិលច្រអូស ១ ជាអ្នកមានសតិខ្ជាប់ខ្ជួន បានញុំាងសតិ ឲ្យសម្រេច មិនមែនជាអ្នកភ្លេចសតិ ១ ជាអ្នកមានចិត្តតាំងមាំ បានញុំាងចិត្តដែលតាំងមាំ ឲ្យសម្រេច មិនមែនជាអ្នកមានចិត្តមិនតាំងមាំ ១ ជាអ្នកមានប្រាជ្ញា បានញុំាងប្រាជ្ញា ឲ្យសម្រេច មិនមែនជាអ្នកអប្បឥតប្រាជ្ញា ១ ។ ម្នាលនន្ទិយៈ បើទ្រង់បានតាំងនៅក្នុងធម៌ទាំង ៦ នេះហើយ គួរតម្កល់សតិ ក្នុងធម៌ ៥ យ៉ាង ក្នុងព្រះហឫទ័យតទៅទៀត ។ ម្នាលនន្ទិយៈ ទ្រង់គប្បីរឭកនូវព្រះតថាគត ក្នុងលោកនេះថា ព្រះមានព្រះភាគអង្គនោះជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ជាព្រះសុគត ជ្រាបច្បាស់នូវលោក ទ្រង់ប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាសារថី ទូន្មាននូវបុរស ព្រះអង្គជាសាស្ដាចារ្យនៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលមកកាន់កពថ្មីទៀត ។ ម្នាលនន្ទិយៈ ព្រះអង្គទ្រង់គួរតម្កល់សតិក្នុងព្រះហឫទ័យ ប្រារព្ធនូវព្រះតថាគត ដោយប្រការដូច្នេះ ។

ម្នាលនន្ទិយៈ មួយទៀត ព្រះអង្គទ្រង់គប្បីរឭក នូវព្រះធម៌ថា ព្រះបរិយត្តិធម៌ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សម្ដែងហើយដោយល្អ ព្រះ

នព្វលោកុត្តរធម៌ ជាធម៌ដែលអរិយបុគ្គលទាំងពួង ដឹងពិត ឃើញពិត ដោយបច្ចវេក្ខណញ្ញាណ ជាធម៌ឲ្យនូវផល មិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី ជាធម៌ដែលអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួន ដោយអំណាចនៃភាវនា ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើមឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។ ម្នាលនន្ទិយៈ ព្រះអង្គទ្រង់គួរតម្កល់សតិក្នុងព្រះហឫទ័យ ប្រារព្ធនូវព្រះធម៌ ដោយប្រការដូច្នេះ ។

ម្នាលនន្ទិយៈ មួយទៀត ទ្រង់គប្បីរឭកនូវពួកកល្យាណមិត្តថា ឱហ្ន៎ អាត្មាអញចំជាមានលាភ អាត្មាអញបានល្អហើយ ដែលមានពួកជន ជាកល្យាណមិត្ត ជាអ្នកអនុគ្រោះ អ្នកប្រាថ្នានូវប្រយោជន៍ អ្នកទូន្មាន អ្នកប្រៀនប្រដៅ ។ ម្នាលនន្ទិយៈ ទ្រង់គួរតម្កល់សតិ ក្នុងព្រះហឫទ័យ ប្រារព្ធនូវពួកកល្យាណមិត្ត ដោយប្រការដូច្នេះ ។

ម្នាលនន្ទិយៈ មួយទៀត ទ្រង់គប្បីរឭក នូវចាគៈរបស់ទ្រង់ថា ឱហ្ន៎ អាត្មាអញចំជាមានលាភ អាត្មាអញល្អហើយតើ ដែលអាត្មាអញ មានចិត្តមានមន្ទិល គឺសេចក្តីកំណាញ់ប្រាសចេញហើយ ក្នុងពួកសត្វដែលមានមន្ទិលគឺសេចក្តីកំណាញ់ រួបរឹតហើយ មានទានបរិច្ចាគហើយ មានដៃលាងស្អាតហើយ ត្រេកអរក្នុងការលះ គួរឲ្យគេសូមបាន ត្រេកអរក្នុងការឲ្យ និងការចែករំលែក ហើយនៅគ្រប់គ្រងផ្ទះ ។ ម្នាលនន្ទិយៈ ទ្រង់គួរតម្កល់នូវសតិក្នុងព្រះហឫទ័យ ប្រារព្ធនូវចាគៈ ដោយប្រការដូច្នេះ ។

ម្នាលនន្ទិយៈ មួយទៀត ទ្រង់គប្បីរឭកពួកទេវតាថា ទេវតាណាដែល រំលងនូវពួកទេវតា ដែលមានកពឡីការាហារ ជាចំណី ( កាមាវចរទេវតា ) បានទៅកើតក្នុងពួកទេវតា ដែលសម្រេចដោយឈានចិត្ត ( ព្រហ្ម ) ណាមួយ ទេវតាទាំងនោះ មិនពិចារណាឃើញនូវកិច្ចរបស់ខ្លួន ឬនូវសេចក្ដីចម្រើន នៃអំពើដែលខ្លួនធ្វើហើយ ម្នាលនន្ទិយៈ ដូចជាភិក្ខុអសមយវិមុត្ត រមែងមិនពិចារណាឃើញ នូវកិច្ចរបស់ខ្លួន ឬនូវសេចក្ដីចម្រើននៃអំពើដែលខ្លួនធ្វើហើយ យ៉ាងណាមិញ ម្នាលនន្ទិយៈ ទេវតាណា ដែលផ្ទោះរំលងនូវពួកទេវតា ដែលមានកពឡីការាហារជាចំណី បានទៅកើតក្នុងពួកទេវតា ដែលសម្រេចដោយឈានចិត្តណាមួយ ទេវតាទាំងនោះ រមែងមិនពិចារណាឃើញ នូវកិច្ចរបស់ខ្លួន ឬនូវសេចក្ដីចម្រើន នៃអំពើដែលខ្លួនធ្វើហើយ ក៏យ៉ាងនោះដែរ ។ ម្នាលនន្ទិយៈ ទ្រង់គប្បីតម្កល់សតិ ក្នុងព្រះហឫទ័យ ប្រារព្ធនូវពួកទេវតា ដោយប្រការដូច្នេះឯង ។ ម្នាលនន្ទិយៈ អរិយសាវកប្រកបដោយធម៌ទាំង ១១ នេះឯង តែងលះបង់ មិនប្រកាន់ពួកអកុសលធម៌ដ៏លាមកឡើយ ។ ម្នាលនន្ទិយៈ ដូចជាក្អមផ្កាប់ រមែងមិនស្រូបយកទឹក ដែលហូរចេញបានឡើយ យ៉ាងណាមិញ ម្នាលនន្ទិយៈ ពុំនោះសោត ដូចជាភ្លើង កាលឆេះរាលដាលផុតអំពីស្មៅហើយ ក៏មិនត្រឡប់មករកស្មៅដែលឆេះរួចហើយវិញ យ៉ាងណាមិញ ម្នាលនន្ទិយៈ អរិយសាវកប្រកបដោយធម៌ទាំង ១១ នេះ តែងលះបង់ មិនប្រកាន់ពួកអកុសលធម៌លាមកឡើយ ក៏យ៉ាងនោះដែរ ។

# អដ្ឋកថា

## ឆន្ទិយសូត្រ

[ ១២០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនន្ទិយសូត្រទី ៣ ដូចតទៅនេះ បទថា **កល្យាណមិត្តេ** ប្រែថា នូវមិត្រល្អទាំងឡាយ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់សង្ឃានុស្សតិ ដោយអំណាចនៃកល្យាណមិត្ត ដោយប្រការដូច្នេះ ។ បទថា **កពឡីការភក្ខានំ** បានដល់ ( អាហារ ) របស់ទេវតាជាន់កាមាវចរ ។ បទថា **អសមយវិមុត្តោ** សេចក្ដីថា ព្រះខីណាស្រពដែលរួចផុតហើយ ដោយអសមយវិមុត្តិ ៕

**អដ្ឋកថា ឆន្ទិយសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## សុភូតិសូត្រទី ៤

[ ១២១ ] គ្រានោះ ព្រះសុភូតិដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ ជាមួយនឹងសទ្ធភិក្ខុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំចំពោះព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះសុភូតិដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលសុភូតិ ភិក្ខុនេះឈ្មោះអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះឈ្មោះសទ្ធៈ ជាកូនឧបាសក

អ្នកមានសទ្ធា បានចេញចាកផ្ទះ ចូលមកកាន់ផ្នួសដោយសទ្ធា ។ ម្នាលសុភូតិ សទ្ធិភិក្ខុនេះ ជាកូនឧបាសក អ្នកមានសទ្ធា បានចេញចាកផ្ទះ ចូលមកកាន់ផ្នួស ដោយសទ្ធា នឹងប្រាកដ ក្នុងសទ្ធាចរិតទាំងឡាយ ដែរឬ ។ បពិត្រព្រះមានព្រះភាគ កាលនេះ ជាកាលគួរដល់ព្រះអង្គហើយ បពិត្រព្រះសុគត កាលនេះ ជាកាលគួរដល់ព្រះអង្គហើយ ព្រះមានព្រះភាគគួរសម្តែងសទ្ធាចរិតទាំងឡាយ របស់បុគ្គលអ្នកមានសទ្ធា ទោះភិក្ខុនេះប្រាកដ ក្នុងសទ្ធាចរិតទាំងឡាយក្តី មិនប្រាកដក្តី ខ្ញុំព្រះអង្គនឹងដឹង ក្នុងកាលឥឡូវនេះ ។ ម្នាលសុភូតិ បើដូច្នោះ អ្នកចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែងប្រាប់ ។ ព្រះសុភូតិដ៏មានអាយុ ទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ដូច្នេះថា ម្នាលសុភូតិ ភិក្ខុក្នុងសាសនានេះ អ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារ និងគោចរ ឃើញភ័យក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច ហើយសមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលសុភូតិ ព្រោះថា ភិក្ខុជាអ្នកមានសីល ។បេ។ សមាទាន សិក្សាក្នុងសិក្ខាបទទាំងឡាយ ម្នាលសុភូតិ នេះជាសទ្ធាចរិត របស់បុគ្គលអ្នកមានសទ្ធា ។

ម្នាលសុភូតិ មួយទៀត ភិក្ខុជាពហុស្សូត អ្នកទ្រទ្រង់នូវពុទ្ធវចនៈ ដែលខ្លួនបានស្តាប់ហើយ សន្សំទុកពុទ្ធវចនៈ ដែលខ្លួនបានស្តាប់ហើយ ធម៌ទាំងឡាយណា មានលម្អបទដើម លម្អបទកណ្តាល លម្អបទចុង ប្រកាសព្រហ្ម-

ចរិយធម៌ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈ ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ធម៌ទាំង-ឡាយមានសភាពដូច្នោះ ភិក្ខុនោះក៏បានស្តាប់ច្រើន បានទ្រទ្រង់ ចាំស្ទាត់ រត់មាត់ ត្រិះរិះដោយចិត្ត ត្រាស់ដឹងល្អដោយទិដ្ឋិ ។ ម្នាលសុភូតិ ភិក្ខុជាពហុស្សុត ។បេ។ ត្រាស់ដឹងល្អ ដោយទិដ្ឋិ ម្នាលសុភូតិ នេះជាសទ្ធាចរិត របស់បុគ្គលអ្នកមានសទ្ធា ។

ម្នាលសុភូតិ មួយវិញទៀត បុគ្គលជាភិក្ខុតែងជាអ្នកមានមិត្តល្អ មានសម្លាញ់ល្អ បែរឈមទៅរកមិត្តល្អ ។ ម្នាលសុភូតិ ព្រោះថា ភិក្ខុជាអ្នកមានមិត្តល្អ មានសម្លាញ់ល្អ បែរទៅរកមិត្តល្អ ម្នាលសុភូតិ នេះជាសទ្ធាចរិត របស់បុគ្គលអ្នកមានសទ្ធា ។

ម្នាលសុភូតិ មួយទៀត ភិក្ខុដែលគេប្រដៅងាយ ប្រកបដោយធម៌ទាំងឡាយ ជាគ្រឿងធ្វើនូវភាពជាអ្នកប្រដៅងាយ ជាអ្នកអត់ធន់ ទទួលយកពាក្យប្រៀនប្រដៅ ដោយចំណែកខាងស្តាំ ។ ម្នាលសុភូតិ ព្រោះភិក្ខុដែលគេប្រដៅងាយ ប្រកបដោយធម៌ទាំងឡាយ ជាគ្រឿងធ្វើនូវភាពជាអ្នកប្រដៅងាយ ជាអ្នកអត់ធន់ ទទួលយកពាក្យប្រៀនប្រដៅ ដោយចំណែកខាងស្តាំ ម្នាលសុភូតិ នេះជាសទ្ធាចរិត របស់បុគ្គលអ្នកមានសទ្ធា ។

ម្នាលសុភូតិ មួយទៀត កិច្ចទាំងឡាយ ណាមួយ ធំ ឬតូច របស់សព្រហ្មចារីបុគ្គលទាំងឡាយ ភិក្ខុជាអ្នកប៉ិនប្រសប់ មិនខ្ជិលច្រអូស ក្នុងកិច្ចទាំងនោះ ប្រកបដោយការពិចារណា ដោយឧបាយ ក្នុងកិច្ចទាំងនោះ ជា

បុគ្គលអាចធ្វើបាន អាចចាត់ចែងបាន ។ ម្នាលសុក្កូតិ ព្រោះកិច្ចទាំងឡាយណា របស់សព្រហ្មចារីបុគ្គលទាំងឡាយ ។បេ។ ភិក្ខុជាអ្នកអាចធ្វើបាន អាចចាត់ចែងបាន ម្នាលសុក្កូតិ នេះជាសទ្ធាចរិត របស់បុគ្គលអ្នកមានសទ្ធា ។

ម្នាលសុក្កូតិ មួយទៀត ភិក្ខុជាអ្នកប្រាថ្នាធម៌ មានការហៅរកដោយពាក្យជាទីស្រឡាញ់ មានសេចក្តីរីករាយ ដ៏លើសលុប ក្នុងអភិធម៌ និងអភិវិន័យ ។ ម្នាលសុក្កូតិ ព្រោះភិក្ខុជាអ្នកប្រាថ្នាធម៌ មានការហៅរក ដោយពាក្យជាទីស្រឡាញ់ មានសេចក្តីរីករាយដ៏លើសលុប ក្នុងអភិធម៌ និងអភិវិន័យ ម្នាលសុក្កូតិ នេះជាសទ្ធាចរិត របស់បុគ្គលអ្នកមានសទ្ធា ។

ម្នាលសុក្កូតិ មួយទៀត ភិក្ខុអ្នកប្រារព្ធព្យាយាម ដើម្បីលះបង់អកុសលធម៌ទាំងឡាយ ដើម្បីធ្វើកុសលធម៌ទាំងឡាយ ឲ្យបរិបូណ៌ ជាអ្នកមានកម្លាំង មានសេចក្តីប្រឹងប្រែងមាំមួន មិនដាក់ធុរៈ ក្នុងកុសលធម៌ទាំងឡាយចោល ។ ម្នាលសុក្កូតិ ព្រោះភិក្ខុអ្នកប្រារព្ធព្យាយាម ។បេ។ ម្នាលសុក្កូតិ នេះជាសទ្ធាចរិត របស់បុគ្គលអ្នកមានសទ្ធា ។

ម្នាលសុក្កូតិ មួយទៀត ភិក្ខុជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយនូវឈានទាំង ៤ ដែលប្រព្រឹត្តទៅ ក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅសប្បាយ ក្នុងបច្ចុប្បន្ន ។ ម្នាលសុក្កូតិ ព្រោះភិក្ខុជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយ នូវឈានទាំង ៤ ដែលប្រព្រឹត្តទៅ ក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅសប្បាយ ក្នុងបច្ចុប្បន្ន ម្នាលសុក្កូតិ នេះជា

សទ្ធាចរិត របស់បុគ្គលអ្នកមានសទ្ធា ។

ម្នាលសុភូតិ មួយទៀត ភិក្ខុរឭកឃើញនូវជាតិ ដែលខ្លួនធ្លាប់អាស្រ័យនៅ ក្នុងកាលមុន ជាច្រើនជាតិ គឺរឭកឃើញបាន ១ ជាតិ ២ ជាតិ ៣ ជាតិ ៤ ជាតិ ៥ ជាតិ ១០ ជាតិ ២០ ជាតិ ៣០ ជាតិ ៤០ ជាតិ ៥០ ជាតិ ១០០ ជាតិ មួយពាន់ជាតិ មួយសែនជាតិក៏បាន រឭកឃើញបានច្រើនសំវដ្តកប្ប ច្រើនវិវដ្តកប្ប ច្រើនសំវដ្តវិវដ្តកប្ប ក៏បានថា អាត្មាអញ បានកើតក្នុងភពឯនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះអាត្មាអញនោះ ច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងទីណា លុះអាត្មាអញទៅកើត ក្នុងទីនោះហើយ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុ ត្រឹមប៉ុណ្ណេះ លុះអាត្មាអញនោះ ច្យុតចាកអត្តភាពនោះហើយ ទើបបានមកកើត ក្នុងទីនេះ ( ភិក្ខុ ) រឭកឃើញជាតិដែលខ្លួនធ្លាប់អាស្រ័យនៅ ក្នុងកាលមុនបានច្រើនជាតិ ព្រមទាំងអាការ ទាំងឧទ្ទេស ដោយប្រការដូច្នេះ ។

ម្នាលសុភូតិ ព្រោះភិក្ខុរឭកឃើញជាតិ ដែលខ្លួនធ្លាប់អាស្រ័យនៅក្នុងកាលមុន គឺរឭកឃើញបាន ១ ជាតិ ២ ជាតិ ។បេ។ រឭកឃើញជាតិដែលខ្លួនធ្លាប់អាស្រ័យនៅ ក្នុងកាលមុន បានច្រើនជាតិ ព្រមទាំងអាការ ទាំង

ឧទ្ទេស ដោយប្រការដូច្នេះ ម្នាលសុភូតិ នេះជាសទ្ធាចរិត របស់បុគ្គលអ្នកមានសទ្ធា ។

ម្នាលសុភូតិ មួយទៀត ភិក្ខុមានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងចក្ខុរបស់មនុស្សធម្មតា បានឃើញពួកសត្វដែលច្យុត និងការចាប់បដិសន្ធិ ជាសត្វថោកទាប និងខ្ពង់ខ្ពស់ មានសម្បុរល្អ និងសម្បុរអាក្រក់ ទៅកាន់សុគតិ និងទុគ្គតិ ដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមយថាកម្ម ( របស់ខ្លួន ) ថា អើហ្ន៎ សត្វទាំងនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកនិយាយតិះដៀល នូវព្រះអរិយបុគ្គលទាំងឡាយ មានសេចក្តីយល់ខុស ប្រកាន់មាំនូវអំពើដែលយល់ខុស សត្វទាំងនោះ លុះដល់បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ពុំខាន អើហ្ន៎ ចំណែកពួកសត្វទាំងអម្បាលនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិននិយាយតិះដៀលព្រះអរិយបុគ្គលទាំងឡាយ មានសេចក្តីយល់ត្រូវ ប្រកាន់មាំនូវអំពើ ដែលយល់ត្រូវ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិសួគ៌ទេវលោក ភិក្ខុមានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងនូវចក្ខុ របស់មនុស្សធម្មតា មើលឃើញនូវពួកសត្វដែលច្យុត និងការចាប់បដិសន្ធិ ជាសត្វថោកទាប និងឧត្តម មានសម្បុរល្អ និងសម្បុរអាក្រក់ ទៅកាន់សុគតិ និងទុគ្គតិ ដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមយថាកម្ម ( របស់ខ្លួន ) ដោយប្រការដូច្នេះ ។

ម្នាលសុភូតិ ព្រោះភិក្ខុមានទិព្វចក្ខុដ៏បរិសុទ្ធ ។បេ។ ដឹងច្បាស់នូវពួកសត្វដែលអន្ទោលទៅតាមយថាកម្ម ( របស់ខ្លួន ) ម្នាលសុភូតិ នេះជាសទ្ធាចរិត របស់បុគ្គលអ្នកមានសទ្ធា ។

ម្នាលសុភូតិ មួយវិញទៀត ភិក្ខុបានធ្វើឲ្យជាក់ច្បាស់ នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយដោយបញ្ញាដ៏ឧត្តមរបស់ខ្លួន ក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅ ។ ម្នាលសុភូតិ ព្រោះភិក្ខុបានធ្វើឲ្យជាក់ច្បាស់ ។បេ។ ព្រោះអស់ទៅ នៃអាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅ ម្នាលសុភូតិ នេះជាសទ្ធាចរិត របស់បុគ្គលអ្នកមានសទ្ធា ។

កាលដែលព្រះមានព្រះភាគទ្រង់សម្តែងយ៉ាងនេះហើយ ព្រះសុភូតិដ៏មានអាយុ ក្រាបទូលចំពោះព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សទ្ធាចរិតទាំងឡាយណា របស់បុគ្គលអ្នកមានសទ្ធា ដែលព្រះមានព្រះភាគបានទ្រង់សម្តែងហើយ សទ្ធាចរិតទាំងនោះ រមែងមានប្រាកដ ដល់ភិក្ខុនេះ ទាំងភិក្ខុនេះ ក៏នឹងប្រាកដ ក្នុងសទ្ធាចរិតទាំងនុ៎ះ ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារនិងគោចរ ឃើញភ័យក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះជាពហុស្សូតអ្នកទ្រទ្រង់នូវពុទ្ធវចនៈ ដែលខ្លួនបានស្តាប់ហើយ សន្សំទុកនូវពុទ្ធវចនៈ ដែល

ខ្លួនបានស្តាប់ហើយ ធម៌ទាំងឡាយណា មានលម្អបទដើម លម្អបទកណ្តាល លម្អបទចុង ប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ធម៌ទាំងឡាយ មានសភាពដូច្នោះ ភិក្ខុនោះ ក៏បានស្តាប់ច្រើន បានទ្រទ្រង់ ចាំទុក រត់មាត់ ត្រិះរិះដោយចិត្ត ត្រាស់ដឹងល្អដោយទិដ្ឋិ ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះជាអ្នកមានមិត្តល្អ មានសម្លាញ់ល្អ បែរឈមទៅរកមិត្តល្អ ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះ ជាបុគ្គលដែលគេប្រដៅងាយ ប្រកបដោយធម៌ទាំងឡាយ ជាគ្រឿងធ្វើនូវភាព ជាអ្នកប្រដៅងាយ ជាអ្នកអត់ធន់ ទទួលយកពាក្យប្រៀនប្រដៅដោយចំណែកខាងស្តាំ ។ បពិត្រព្រះអង្គដ៏ចម្រើន ករណីយកិច្ចទាំងឡាយណាមួយ ធំ ឬតូច របស់សព្រហ្មចារីបុគ្គលទាំងឡាយ ភិក្ខុនេះជាអ្នកប៉ិនប្រសប់ មិនខ្ជិលច្រអូស ក្នុងកិច្ចទាំងនោះ ប្រកបដោយការពិចារណា ដោយឧបាយក្នុងកិច្ចទាំងនោះ ជាបុគ្គលអាចធ្វើបាន អាចចាត់ចែងបាន ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះ ជាអ្នកប្រាថ្នានូវធម៌ ពោលរកដោយពាក្យជាទីស្រឡាញ់ មានសេចក្តីរីករាយដ៏លើសលុប ក្នុងអភិធម៌ និងអភិវិន័យ ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះជាអ្នកប្រារព្ធព្យាយាម មានកម្លាំង មានសេចក្តីប្រឹងប្រែងដ៏មាំមួន មិនដាក់ធុរៈ ក្នុងកុសលធម៌ទាំង-ឡាយចោល ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះ ជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយ នូវឈានទាំង ៤ ដែលប្រព្រឹត្តទៅ ក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅសប្បាយ ក្នុងបច្ចុប្បន្ន ។ បពិត្រព្រះអង្គដ៏ចម្រើន

ភិក្ខុនេះ រឭកឃើញនូវជាតិ ដែលខ្លួនធ្លាប់អាស្រ័យនៅ ក្នុងកាលមុនច្រើនជាតិ គឺរឭកឃើញបាន ១ ជាតិ ២ ជាតិ ។បេ។ រឭកឃើញជាតិ ដែលខ្លួនធ្លាប់អាស្រ័យនៅ ក្នុងកាលមុនជាច្រើនជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះ មានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងនូវចក្ខុរបស់មនុស្សធម្មតា ។បេ។ ដឹងច្បាស់នូវពួកសត្វដែលអន្ទោលទៅតាមយថាកម្ម ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះបានធ្វើឲ្យជាក់ច្បាស់ ។បេ។ ព្រោះអស់អាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅ ។ បពិត្រព្រះអង្គដ៏ចម្រើន សទ្ធាចរិតទាំងឡាយណា របស់បុគ្គលអ្នកមានសទ្ធា ដែលព្រះមានព្រះភាគ ទ្រង់សម្តែងហើយ សទ្ធាចរិតទាំងនោះ រមែងមានប្រាកដដល់ភិក្ខុនេះ ទាំងភិក្ខុនេះ នឹងប្រាកដក្នុងសទ្ធាចរិតទាំងនុ៎ះ ។ ម្នាលសុភូតិ ប្រពៃហើយ ប្រពៃហើយ ម្នាលសុភូតិ បើដូច្នោះ អ្នកគប្បីនៅជាមួយនឹងសទ្ធភិក្ខុនេះចុះ ម្នាលសុភូតិ កាលណាបើអ្នកប្រាថ្នា ដើម្បីចួបតថាគត អ្នកគប្បីចូលមក ជាមួយនឹងសទ្ធភិក្ខុ ដើម្បីចួបតថាគត ( ក្នុងកាលនោះចុះ ) ។

# អដ្ឋកថា

## សុភូតិសូត្រ

[ ១២១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសុភូតិសូត្រទី ៤ ដូចតទៅនេះ ព្រះសាស្តា សូម្បីទ្រង់ជ្រាប ក៏នៅតែត្រាស់សួរថា ម្នាលសុភូតិ ភិក្ខុនេះឈ្មោះអ្វី ដូច្នេះ ។ ព្រះសុភូតិក្រាបទូលថា ភិក្ខុនេះឈ្មោះថា សទ្ធៈ ជាកូនរបស់ឧបាសកអ្នកមានសទ្ធា សំដៅដល់អនាថបិណ្ឌិកគហបតី ព្រោះថា សទ្ធភិក្ខុជាកូនរបស់អនាថបិណ្ឌិកគហបតី បួសក្នុងសម្នាក់ព្រះសុភូតិ ដែលជាឪពុកមារបស់ខ្លួន ។ លំដាប់នោះ ព្រះសុភូតិត្ថេរបាននាំសទ្ធភិក្ខុទៅគាល់ព្រះសាស្តា ។ បទថា **សទ្ធាបទានេសុ** សេចក្តីថា ក្នុងអបទាន គឺលក្ខណៈនៃបុគ្គលអ្នកមានសទ្ធាទាំងឡាយ ។៚

**អដ្ឋកថាសុភូតិសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## មេត្តាសូត្រទី ៩

[ ១២២ ] ម្នាលភិក្ខុទាំងឡាយ មេត្តាចេតោវិមុត្តិ ដែលបុគ្គលបាន សេពគប់ បានចម្រើន បានធ្វើឲ្យច្រើន បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំទុក បានប្រារព្ធល្អហើយ អានិសង្ស ១១ ប្រការ រមែងកើតប្រាកដ ។ អានិសង្ស ១១ ប្រការ តើដូចម្តេច ។ គឺមេត្តាវិហារិ-បុគ្គល រមែងដេកលក់ស្រួល ១ ភ្ញាក់ឡើងស្រួល ១ មិនឃើញនូវសុបិន អាក្រក់ ១ ជាទីស្រឡាញ់ របស់ពួកមនុស្ស ១ ជាទីស្រឡាញ់ របស់ពួក អមនុស្ស ១ ពួកទេវតាតែងរក្សា ១ ភ្លើងក្តី ថ្នាំពិសក្តី គ្រឿងសស្ត្រាវុធក្តី មិនចូលទៅក្នុងកាយ របស់មេត្តាវិហារិបុគ្គលនោះ ១ ចិត្តរមែងតាំងនៅមាំ ឆាប់ ១ សម្បុរមុខថ្លាស្រស់បស់ ១ ជាអ្នកមិនវង្វេងហើយធ្វើមរណកាល ១ កាលបើមិនទាន់ត្រាស់ដឹង នូវអរហត្តដ៏ក្រៃលែងជាងមេត្តាសមាបត្តិទេ រមែង បានទៅកើតក្នុងព្រហ្មលោក ១ ។ ម្នាលភិក្ខុទាំងឡាយ មេត្តាចេតោវិមុត្តិដែល បុគ្គលបានសេពគប់ បានចម្រើន បានធ្វើឲ្យច្រើន បានធ្វើឲ្យដូចជាយាន បាន តម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំទុក បានប្រារព្ធល្អហើយ អានិសង្ស ទាំង ១១ ប្រការនេះ រមែងកើតប្រាកដ ។

# អដ្ឋកថា

## មេត្តាសូត្រ

[ ១២២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមេត្តាសូត្រទី ៥ ដូចតទៅនេះ បទថា **សុខំ សុបតិ** សេចក្តីថា ឈ្មោះថា ដេកលក់ជាសុខ ព្រោះមិនដេកលក់ដូចបុគ្គលក្រៅអំពីនោះ ដែលដេករសាប់រសល់ជាទុក្ខ កាលឈមចុះកាន់ការដេកលក់ក៏ជាសុខ ដូចអ្នកចូលសមាបត្តិ ។

បទថា **សុខំ បដិពុជ្ឈតិ** សេចក្តីថា បុគ្គលដទៃដកចិត្ត រសាប់រសល់ភ្ញាក់ឡើងជាទុក្ខ យ៉ាងណា បុគ្គលដែលសេពមេត្តាចេតោវិមុត្តិ មិនភ្ញាក់ជាទុក្ខដូច្នោះឡើយ មិនមានការខុសប្រក្រតី ភ្ញាក់ជាសុខ ដូចផ្កាឈូកកំពុងរីក ។

បទថា **ន ចាបកំ សុបិនំ បស្សតិ** សេចក្តីថា បុគ្គលដែលសេពមេត្តាចេតោវិមុត្តិ កាលយល់សប្តិឃើញ ក៏ឃើញតែរឿងដែលចម្រើនប៉ុណ្ណោះ ហាក់ដូចជាថ្វាយបង្គំព្រះចេតិយ ហាក់ដូចជាធ្វើការបូជា ហាក់ដូចកំពុងស្តាប់ធម៌ និងរមែងមិនយល់សប្តិឃើញទីអាក្រក់ ដូចបុគ្គលដទៃដែលយល់សប្តិឃើញខ្លួន ត្រូវចោរហ៊ុមព័ទ្ធ ត្រូវសត្វសាហាវខាំ និងដូចកំពុងធ្លាក់ជ្រោះដូច្នោះ ។

បទថា **មនុស្សានំ បិយោ ហោតិ** សេចក្តីថា បុគ្គលសេពមេត្តា-ចេតោវិមុត្តិ រមែងជាទីស្រឡាញ់ ជាទីពេញចិត្តរបស់មនុស្សទាំងឡាយ ដូចកែវមុក្តាហារដែលពាក់ត្រង់ទ្រូង និងដូចកម្រងផ្កាប្រដាប់សីសៈ ដូច្នោះ ។

បទថា **អមនុស្សានំ បិយោ ហោតិ** សេចក្តីថា បុគ្គលសេពចេតោ-

វិមុត្តិ រមែងជាទីស្រឡាញ់របស់អមនុស្សទាំងឡាយ ដូចព្រះវិសាខត្ថេរ ។ រឿងពោលពិស្តារហើយ ក្នុងមេត្តាកម្មដ្ឋាននិទ្ទេស គម្ពីរវិសុទ្ធិមគ្គនោះឯង ។

បទថា **ទេវតា រក្ខន្តិ** សេចក្តីថា ទេវតាទាំងឡាយរមែងរក្សា ដូចមាតា និងបិតារក្សាបុត្រ ដូច្នោះ ។ បទថា **នាស្ស អគ្គិ វា វិសំ វា សត្ថំ វា កមតិ** សេចក្តីថា ភ្លើងមិនលោក គឺមិនចូលទៅឆាបឆេះរាងកាយរបស់បុគ្គលដែលនៅដោយមេត្តា ដូចនាងឧត្តរាឧបាសិកា ថ្នាំពិសរមែងមិនជ្រួតជ្រាប គឺមិនចូលទៅធ្វើអន្តរាយដល់រាងកាយរបស់បុគ្គល ដែលនៅដោយមេត្តា ដូចព្រះចូឡសីវត្ថេរ អ្នកសូធ្យសំយុត្តនិកាយ ដូច្នោះ សស្ត្រារមែងមិនទម្លុះ គឺមិនចូលទៅជិតរាងកាយរបស់បុគ្គលដែលនៅដោយមេត្តា ដូចសង្កិច្ចសាមណេរ ដូច្នោះ មានពាក្យអធិប្បាយថា ភ្លើង ថ្នាំពិស សស្ត្រារមែងមិនធ្វើអន្តរាយរាងកាយនៃបុគ្គលដែលនៅដោយមេត្តា ក្នុងសេចក្តីនេះ លោកអាចារ្យទាំងឡាយ បានពោលរឿងមេគោទឹកដោះ ។

## រឿង មេគោ និងកូនគោ

បានឮថា មេគោមួយ កំពុងឈរបង្អូរទឹកដោះឲ្យដល់កូន ព្រានម្នាក់គិតថា អញនឹងចាក់មេគោនោះ ទើបឆាដៃពួយលំពែងដងវែងទៅ លំពែងនោះឯង ហោះទៅពាល់រាងកាយមេគោនោះ ដូចស្លឹកត្នោតហើរទៅប៉ះដូច្នោះ ព្រោះកម្លាំងឧបចារភាវនាក៏មិនមែន ព្រោះកម្លាំងអប្បនាភាវនាក៏មិនមែន ព្រោះមេគោនោះ មានចិត្តអនុគ្រោះដ៏ខ្លាំងក្លាក្នុងកូនគោតែម្យ៉ាង មេត្តាមាន

អានុភាពយ៉ាងនេះ ។

បទថា **តុវដំ ចិត្តំ សមាធិយតិ** សេចក្ដីថា ចិត្តរបស់បុគ្គលដែលនៅដោយមេត្តា រមែងតាំងមាំបានរហ័ស ។ ភាពដែលចិត្តនោះតាំងមាំយូរមិនមាន ។ បទថា **មុខវណ្ណោ វិប្បសីទតិ** សេចក្ដីថា មុខរបស់បុគ្គលនោះរមែងមានពណ៌ផូរផង់ ដូចផ្លែត្នោតទុំ ដែលផុតចាកទង ដូច្នោះ ។

បទថា **អសម្មុឡ្ហោ កាលំ ករោតិ** សេចក្ដីថា ឈ្មោះថា ការវង្វេងក្នុងពេលជិតស្លាប់របស់បុគ្គលដែលនៅដោយមេត្តាមិនមាន រមែងមិនវង្វេងក្នុងពេលធ្វើកាលកិរិយា ដូចបុគ្គលដេកលក់ ។ បទថា **ឧត្តរឹ អប្បដិវិជ្ឈន្តោ** សេចក្ដីថា បុគ្គលដែលនៅដោយមេត្តា កាលមិនសម្រេចអរហត្ត ដែលជាគុណវិសេសក្រៃលែងជាងមេត្តាសមាបត្តិ ចុតិចាកអត្តភាពនោះហើយ ទៅកើតក្នុងព្រហ្មលោក ដូចដេកលក់ហើយភ្ញាក់ឡើង ។៚

## អដ្ឋកថា មេត្តាសូត្រទី ៥ ចប់

# សុត្តន្តបិដក

## ទសមសូត្រទី ៦

[ ១២៣ ] សម័យមួយ ព្រះអានន្ទដ៏មានអាយុ គង់នៅក្នុងវេឡុវគ្រាម ជិតក្រុងវេសាលី ។ សម័យនោះឯង ទសមគហបតី អ្នកនៅក្នុងក្រុងឈ្មោះ អដ្ឋកៈ បានមកដល់ក្រុងបាតលិបុត្ត ដោយកិច្ចនីមួយ ។ លំដាប់នោះ ទសមគហបតី អ្នកនៅក្នុងក្រុងអដ្ឋកៈ បានចូលទៅរកភិក្ខុ ១ រូប ក្នុងកុក្កុដារាម លុះចូលទៅដល់ហើយ បានពោលពាក្យនេះ នឹងភិក្ខុនោះដូច្នេះថា បពិត្រលោកដ៏ចម្រើន ឥឡូវនេះ ព្រះអានន្ទដ៏មានអាយុគង់នៅក្នុងទីណា បពិត្រលោកដ៏ចម្រើន ព្រោះយើងចង់ចួបព្រះអានន្ទដ៏មានអាយុ ។ ភិក្ខុនោះ តបថា ម្នាលគហបតី ព្រះអានន្ទដ៏មានអាយុនុ៎ះ គង់នៅក្នុងវេឡុវគ្រាម ជិតក្រុងវេសាលី ។ លំដាប់នោះ ទសមគហបតី អ្នកនៅក្នុងក្រុងអដ្ឋកៈ សម្រេចនូវកិច្ចនោះ ក្នុងក្រុងបាតលិបុត្ត ហើយចូលទៅរកព្រះអានន្ទដ៏មានអាយុ ក្នុងវេឡុវគ្រាម ជិតក្រុងវេសាលី លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះអានន្ទដ៏មានអាយុ ហើយអង្គុយក្នុងទីសមគួរ ។ លុះទសមគហបតី អ្នកនៅក្នុងក្រុងអដ្ឋកៈ អង្គុយក្នុងទីសមគួរហើយ បានពោលពាក្យនឹងព្រះអានន្ទដ៏មានអាយុ ដូច្នេះថា បពិត្រព្រះអានន្ទដ៏ចម្រើន ចិត្តរបស់ភិក្ខុអ្នកមិនមានសេចក្តីប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តផ្ចាះទៅកាន់ព្រះនិព្វាន មិនទាន់រួចស្រឡះក្តី រមែងរួចស្រឡះ អាសវៈទាំងឡាយ មិនទាន់អស់ក្តី រមែងដល់នូវការអស់ ចិត្តដែលមិនទាន់ដល់ក្តី ក៏រមែងដល់នូវធម៌ជាទីក្សេមចាកយោគៈដ៏ប្រសើរ

ក្នុងធម៌តែមួយណា ធម៌តែមួយនោះ ដែលព្រះមានព្រះភាគអង្គនោះជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសម្តែងហើយ ដោយប្រពៃ មានដែរឬ ។ ម្នាលគហបតី ចិត្តរបស់ភិក្ខុ ដែលមិនមានសេចក្តីប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តឆ្ពោះទៅកាន់ព្រះនិព្វាន មិនទាន់រួចស្រឡះក្តី រមែងរួចស្រឡះ អាសវៈទាំងឡាយ មិនទាន់អស់ក្តី រមែងដល់នូវការអស់ ចិត្តដែលមិនទាន់ដល់ក្តី ក៏រមែងដល់នូវធម៌ជាទីក្សេមចាកយោគៈដ៏ប្រសើរ ក្នុងធម៌តែមួយណា ធម៌តែមួយនោះ ដែលព្រះមានព្រះភាគអង្គនោះជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសម្តែងហើយ ដោយប្រពៃ មានដែរ ។ បពិត្រព្រះអានន្ទដ៏ចម្រើន ចិត្តរបស់ភិក្ខុអ្នកមិនមានសេចក្តីប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តឆ្ពោះទៅកាន់ព្រះនិព្វាន មិនទាន់រួចស្រឡះក្តី រមែងរួចស្រឡះ អាសវៈទាំងឡាយមិនទាន់អស់ក្តី រមែងដល់នូវការអស់ ចិត្តដែលមិនទាន់ដល់ក្តី ក៏រមែងដល់នូវធម៌ជាទីក្សេមចាកយោគៈដ៏ប្រសើរ ក្នុងធម៌តែមួយណា ធម៌តែមួយនោះ ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសម្តែងហើយ ដោយប្រពៃ តើដូចម្តេច ។ ម្នាលគហបតី ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ក៏បានចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្ក ប្រកបដោយវិចារៈ មានបីតិ និងសុខដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ។ ភិក្ខុនោះបានពិចារណាដូច្នេះ ក៏ដឹងច្បាស់

ថា បឋមជ្ឈាននេះ ដែល ( អាត្មាអញ ) បានតាក់តែង បានពិចារណាដោយផ្ចិតផ្ចង់ ឈានណាមួយដែលអាត្មាអញ បានតាក់តែង បានពិចារណាដោយផ្ចិតផ្ចង់ហើយ ឈាននោះ ក៏មិនទៀង មានការរលត់ទៅជាធម្មតា ។ ភិក្ខុនោះ បានឋិតនៅក្នុងសមថវិបស្សនាធម៌នោះ រមែងដល់នូវការអស់អាសវៈទាំងឡាយ បើមិនដល់នូវការអស់អាសវៈទាំងឡាយទេ ក៏បានជាឱបបាតិកៈ ព្រោះអស់សំយោជនៈទាំងឡាយជាចំណែកខាងក្រោម ៥ ដោយតម្រេកក្នុងធម៌នោះ ដោយសេចក្តីរីករាយ ក្នុងធម៌នោះ បរិនិព្វានក្នុងលោកនោះ មានការមិនត្រឡប់ចាកលោកនោះជាធម្មតា ។ ម្នាលគហបតី ចិត្តរបស់ភិក្ខុដែលគ្មានសេចក្តីប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តឆ្ពោះទៅកាន់ព្រះនិព្វាន បើមិនទាន់រួចស្រឡះក្តី រមែងរួចស្រឡះ អាសវៈទាំងឡាយ មិនទាន់អស់ក្តី រមែងដល់នូវការអស់ ចិត្តដែលមិនទាន់ដល់ក្តី រមែងដល់នូវធម៌ជាទីក្សេមចាកយោគៈដ៏ប្រសើរ ក្នុងធម៌តែមួយណា ធម៌តែមួយនេះឯង ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសម្តែងហើយ ដោយប្រពៃ ។

ម្នាលគហបតី មួយទៀត ភិក្ខុព្រោះបានរម្ងាប់វិតក្ក និងវិចារៈ ( ក៏បានចូល ) កាន់ទុតិយជ្ឈាន ជាធម្មជាត កើតមានក្នុងសន្តានខ្លួន ប្រកបដោយសេចក្តីជ្រះថ្លា គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក ដែលមិនមានវិតក្ក មិនមានវិចារៈ មានតែបីតិ និងសុខ ដែលកើតអំពីសមាធិ គឺទុតិយជ្ឈាន ...

តតិយជ្ឈាន ... ចូលកាន់ចតុត្ថជ្ឈាន ។ ភិក្ខុនោះ បានពិចារណាដូច្នេះ ក៏ដឹងច្បាស់ថា ចតុត្ថជ្ឈាននេះឯង ( ដែលអាត្មាអញ ) បានតាក់តែង បានពិចារណាដោយផ្ចិតផ្ចង់ ឈានឯណានីមួយ ដែលអាត្មាអញបានតាក់តែង បានពិចារណាដោយផ្ចិតផ្ចង់ហើយ ឈាននោះ ក៏មិនទៀង មានកិរិយារលត់ទៅជាធម្មតា ។ ភិក្ខុនោះបានឋិតនៅក្នុងសមថវិបស្សនាធម៌នោះ រមែងដល់នូវការអស់អាសវៈទាំងឡាយ បើមិនទាន់ដល់នូវការអស់អាសវៈទាំងឡាយទេ រមែងបានជាឱបបាតិកៈ ព្រោះអស់សំយោជនៈទាំងឡាយ ជាចំណែកខាងក្រោម ៥ ដោយតម្រេកក្នុងធម៌នោះ ដោយសេចក្តីរីករាយក្នុងធម៌នោះ ក៏បរិនិព្វានក្នុងលោកនោះបាន ការមិនត្រឡប់ចាកលោកនោះជាធម្មតា ។ ម្នាលគហបតី ចិត្តរបស់ភិក្ខុដែលមិនមានសេចក្តីប្រមាទ អ្នកមានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តឆ្ពោះទៅកាន់ព្រះនិព្វាន មិនទាន់រួចស្រឡះក្តី រមែងរួចស្រឡះ អាសវៈទាំងឡាយមិនទាន់អស់ក្តី រមែងដល់នូវការអស់ ចិត្តដែលមិនទាន់ដល់ក្តី រមែងដល់នូវធម៌ជាទីក្សេមចាកយោគៈដ៏ប្រសើរ ក្នុងធម៌តែមួយណា ធម៌តែមួយនេះឯង ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្ត-សម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសម្តែងហើយដោយប្រពៃ ។

ម្នាលគហបតី មួយទៀត ភិក្ខុមានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទី ២ ទី ៣ ទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ខាងក្រោម និងទិសទទឹង មានចិត្តប្រកបដោយមេត្តាដ៏ធំទូលាយមានប្រមាណមិនបាន មិន

មានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយយកខ្លួនទៅប្រៀបនឹងសត្វទាំងពួង ក្នុងទីទាំងពួង ។ ភិក្ខុនោះបានពិចារណាដូច្នេះ ក៏ដឹងច្បាស់ថា មេត្តាចេតោវិមុត្តិនេះឯង ( ដែលអាត្មាអញ ) បានតាក់តែង បានពិចារណា ដោយផ្ចិតផ្ចង់ហើយ ឈានណានីមួយ ដែលអាត្មាអញ បានតាក់តែង បានពិចារណា ដោយផ្ចិតផ្ចង់ហើយ ឈាននោះ ក៏មិនទៀង មានការរលត់ទៅជាធម្មតា ។ ភិក្ខុនោះ បានឋិតនៅ ក្នុងសមថវិបស្សនាធម៌នោះ រមែងដល់នូវការអស់អាសវៈទាំងឡាយ បើមិនទាន់បានដល់នូវការអស់អាសវៈទាំងឡាយទេ ក៏គង់បានជាឧបបាតិកៈ ព្រោះអស់សំយោជនៈទាំងឡាយ ជាចំណែកខាងក្រោម ៥ ដោយតម្រេកក្នុងធម៌នោះ ដោយសេចក្តីរីករាយក្នុងធម៌នោះ ហើយក៏បរិនិព្វាន ក្នុងលោកនោះ មានការមិនត្រឡប់ចាកលោកនោះជាធម្មតា ។ ម្នាលគហបតី ចិត្តរបស់ភិក្ខុ ដែលមិនមានសេចក្តីប្រមាទ មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស មានចិត្តឆ្ពោះទៅកាន់ព្រះនិព្វានមិនទាន់រួចស្រឡះក្តី រមែងរួចស្រឡះ អាសវៈទាំងឡាយ មិនទាន់អស់ក្តី រមែងដល់នូវការអស់ ចិត្តដែលមិនទាន់ដល់ក្តី រមែងដល់នូវធម៌ជាទីក្សេមចាកយោគៈដ៏ប្រសើរ ក្នុងធម៌តែមួយណា ធម៌តែមួយនេះឯង ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសម្តែងហើយ ដោយប្រពៃ ។

ម្នាលគហបតី មួយទៀត ភិក្ខុមានចិត្តប្រកបដោយករុណា ... មានចិត្ត

ប្រកបដោយមុទិតា ... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទី ២ ទី ៣ ទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ខាងក្រោម និង ទិសទទឹង មានចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយ រកប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបនឹងសត្វទាំងពួង ក្នុងទីទាំងពួង ។ ភិក្ខុនោះ បានពិចារណាដូច្នេះ ក៏ដឹងច្បាស់ថា ឧបេក្ខាចេតោវិមុត្តិនេះឯង ដែល ( អាត្មាអញ ) បានតាក់តែង បានពិចារណា ដោយផ្ចិតផ្ចង់ហើយ ក៏ឈានឯណានីមួយ ដែលអាត្មាអញបានតាក់តែង បានពិចារណា ដោយផ្ចិតផ្ចង់ហើយ ឈាននោះ ក៏មិនទៀង មានការរលត់ទៅជាធម្មតា ។ ភិក្ខុនោះបានឋិតនៅក្នុងសមថវិបស្សនា-ធម៌នោះហើយ រមែងដល់នូវការអស់អាសវៈទាំងឡាយ បើមិនទាន់បានដល់នូវការអស់អាសវៈទាំងឡាយទេ ក៏គង់បានជាឱបបាតិកៈ ព្រោះអស់សំយោជនៈទាំងឡាយ ជាចំណែកខាងក្រោម ៥ ដោយតម្រេក ក្នុងធម៌នោះ ដោយសេចក្តីរីករាយ ក្នុងធម៌នោះ ហើយក៏បរិនិព្វាន ក្នុងលោកនោះ មានការមិនត្រឡប់ចាកលោកនោះជាធម្មតា ។ ម្នាលគហបតី ចិត្តរបស់ភិក្ខុ អ្នកមិនមានសេចក្តីប្រមាទ មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស មានចិត្តឆ្ពោះទៅកាន់ព្រះនិព្វាន មិនទាន់រួចស្រឡះក្តី រមែងរួចស្រឡះ អាសវៈទាំងឡាយមិនទាន់អស់ក្តី រមែងដល់នូវការអស់ ចិត្តដែលមិនទាន់ដល់ក្តី រមែងដល់នូវធម៌ជាទីក្សេមចាកយោគៈដ៏ប្រសើរ ក្នុងធម៌តែមួយណា ធម៌តែមួយនេះឯង ដែល

ព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសម្តែងហើយ ដោយប្រពៃ ។

ម្នាលគហបតី មួយទៀត ភិក្ខុបានដល់អាកាសានញ្ចាយតនជ្ឈានដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ ព្រោះប្រព្រឹត្តកន្លងនូវរូបសញ្ញា ដោយប្រការទាំងពួង ព្រោះវិនាសនៃបដិឃសញ្ញាទាំងឡាយ ព្រោះលែងធ្វើទុកក្នុងចិត្ត នូវនានត្តសញ្ញា ។ ភិក្ខុនោះ បានពិចារណាដូច្នេះ ក៏ដឹងច្បាស់ថា អាកាសានញ្ចាយតនសមាបត្តិនេះឯង ដែលអាត្មាអញ បានតាក់តែង បានពិចារណា ដោយផ្ចិតផ្ចង់ហើយ ឈានណាមួយ ដែលអាត្មាអញបានតាក់តែង បានពិចារណាដោយផ្ចិតផ្ចង់ហើយ ឈាននោះ ក៏មិនទៀង មានការរលត់ជាធម្មតា ។ ភិក្ខុនោះឋិតនៅក្នុងសមថវិបស្សនាធម៌នោះ រមែងដល់នូវការអស់អាសវៈទាំងឡាយ បើមិនទាន់ដល់នូវការអស់អាសវៈទាំងឡាយទេ ក៏គង់បានជាឱបបាតិកៈ ព្រោះអស់សំយោជនៈទាំងឡាយ ជាចំណែកខាងក្រោម ៥ ដោយសេចក្តីត្រេកអរ ក្នុងធម៌នោះ ដោយសេចក្តីរីករាយ ក្នុងធម៌នោះហើយ ក៏បរិនិព្វាន ក្នុងលោកនោះ មានការមិនត្រឡប់ចាកលោកនោះ ជាធម្មតា ។ ម្នាលគហបតី ចិត្តរបស់ភិក្ខុ ដែលមិនមានសេចក្តីប្រមាទ មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស មានចិត្តឆ្ពោះទៅកាន់ព្រះនិព្វាន ចិត្តមិនទាន់រួចស្រឡះក្តី រមែងរួចស្រឡះ អាសវៈទាំងឡាយ មិនទាន់អស់ក្តី ក៏រមែងដល់នូវការអស់ ចិត្តដែលមិនទាន់ដល់ក្តី រមែងដល់នូវធម៌ជាទីក្សេមចាកយោគៈដ៏ប្រសើរ

ក្នុងធម៌តែមួយណា ធម៌តែមួយនេះឯង ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសម្តែងហើយដោយប្រពៃ ។

ម្នាលគហបតី មួយទៀត ភិក្ខុកន្លងអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វិញ្ញាណ មិនមានទីបំផុត ... កន្លងវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់អាកិញ្ចញ្ញាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វត្ថុតិចតួចមិនមានដូច្នេះ ។ ភិក្ខុនោះ ពិចារណាដូច្នេះ ក៏ដឹងច្បាស់ថា អាកិញ្ចញ្ញាយតន-សមាបត្តិនេះឯង ដែលអាត្មាអញបានតាក់តែង បានពិចារណា ដោយផ្ចិតផ្ចង់ហើយ ក៏ឈានណានីមួយ ដែលអាត្មាអញ បានតាក់តែង បានពិចារណាដោយផ្ចិតផ្ចង់ហើយ ឈាននោះ ក៏មិនទៀង មានការរលត់ជាធម្មតា ។ ភិក្ខុនោះ បានឋិតនៅក្នុងសមថវិបស្សនាធម៌នោះហើយ រមែងដល់នូវការអស់អាសវៈទាំងឡាយ បើមិនទាន់បានដល់នូវការអស់អាសវៈទាំងឡាយទេ ក៏គង់បានជាឱបបាតិកៈ ព្រោះអស់សំយោជនៈទាំងឡាយជាចំណែកខាងក្រោម ៥ ដោយតម្រេក ក្នុងធម៌នោះ ដោយសេចក្តីរីករាយ ក្នុងធម៌នោះ ហើយបរិនិព្វានក្នុងលោកនោះ មានការមិនត្រឡប់ចាកលោកនោះជាធម្មតា ។ ម្នាលគហបតី ចិត្តរបស់ភិក្ខុ ដែលមិនមានសេចក្តីប្រមាទ មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស មានចិត្តផ្ចោះទៅកាន់ព្រះនិព្វាន មិនទាន់រួចស្រឡះក្តី រមែងរួចស្រឡះ

អាសវៈទាំងឡាយ ដែលមិនទាន់អស់ក្តី រមែងដល់នូវការអស់ ចិត្តដែលមិនទាន់ដល់ក្តី រមែងដល់នូវធម៌ជាទីក្សេមចាកយោគៈដ៏ប្រសើរ ក្នុងធម៌តែមួយណា ធម៌តែមួយនេះឯង ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសម្តែងហើយ ដោយប្រពៃ ។

កាលដែលព្រះអានន្ទដ៏មានអាយុ បានពោលយ៉ាងនេះហើយ ទសមគហបតី អ្នកនៅក្នុងក្រុងអដ្ឋកៈ បានពោលនឹងព្រះអានន្ទដ៏មានអាយុដូច្នេះថា បពិត្រព្រះអានន្ទដ៏ចម្រើន ដូចជាបុរសអ្នកស្វែងរកកំណប់ទ្រព្យតែមួយ ស្រាប់តែបានកំណប់ទ្រព្យ ១១ តែម្តង យ៉ាងណាមិញ បពិត្រលោកដ៏ចម្រើន ខ្ញុំព្រះករុណា ស្វែងរកទ្វារនៃព្រះនិព្វានឈ្មោះអមតៈតែមួយទេ ស្រាប់តែបានស្តាប់នូវទ្វារនៃព្រះនិព្វានឈ្មោះអមតៈទាំងឡាយ ១១ តែម្តង យ៉ាងនោះដែរ ។ បពិត្រលោកដ៏ចម្រើន ដូចជាផ្ទះរបស់បុរសមានទ្វារ ១១ កាលបើភ្លើងឆេះផ្ទះនោះ បុរសនោះ ក៏អាចធ្វើខ្លួនឲ្យមានសួស្តី ដោយទ្វារតែមួយៗ បាន យ៉ាងណាមិញ បពិត្រលោកដ៏ចម្រើន បណ្តាអមតទ្វារ ១១ នេះ ខ្ញុំព្រះករុណានឹងអាចធ្វើខ្លួន ឲ្យមានសួស្តី ដោយអមតទ្វារតែមួយៗ បាន ក៏យ៉ាងនោះដែរ ។ បពិត្រលោកដ៏ចម្រើន អម្បាលដូចជាពួកអន្យតិរ្ថិយទាំងនេះ តែងស្វែងរកទ្រព្យសម្រាប់អាចារ្យ ដើម្បីអាចារ្យ ចុះខ្ញុំព្រះករុណា នឹងធ្វើនូវការបូជា ដល់ព្រះអានន្ទដ៏មានអាយុ តើដូចម្តេចទៅវិញ ។ គ្រានោះ ទសមគហបតីអ្នកនៅក្នុងក្រុងអដ្ឋកៈ ក៏បានប្រជុំភិក្ខុសង្ឃ ដែលនៅក្នុងក្រុងវេសាលីផង នៅក្នុងក្រុង

បាតលិបុត្តផង ហើយអង្គាសភិក្ខុសង្ឃ ឲ្យឆ្អែតស្កប់ស្កល់ ដោយខាទនីយ-ភោជនីយាហារដ៏ផ្ចិតផ្ចង់ ដោយដៃរបស់ខ្លួន គ្រាតែហាមឃាត់ ហើយញុំាង ភិក្ខុ ១ រូបៗ ឲ្យស្លៀកដណ្តប់ ដោយគូនៃសំពត់គ្រប់អង្គ ញុំាងព្រះអានន្ទដ៏មានអាយុ ឲ្យស្លៀកដណ្តប់ ដោយត្រៃចីវរផង ញុំាងជាងឲ្យធ្វើវិហារ តម្លៃ ៥០០ កហាបណៈ ប្រគេនព្រះអានន្ទដ៏មានអាយុផង ។

# អដ្ឋកថា

## ទសមសូត្រ

[ ១២៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទសមសូត្រទី ៦ ដូចតទៅនេះ បទថា **ទសមោ** សេចក្តីថា គហបតីនោះ គេរាប់ក្នុងតំណែងទី ១០ ដោយអំណាចជាតិ និងត្រកូល និងដោយការរាប់ត្រកូល ដែលជាគហបតិមហាសាល ព្រោះដូច្នោះ ទើបបុគ្គលនោះ ឈ្មោះថា **ទសម** នោះឯង ។ បទថា **អដ្ឋក-នាគរោ** ប្រែថា អ្នកក្រុងអដ្ឋកៈ ។ បទថា **កុក្កុដារាមេ** បានដល់ អារាមដែលកុក្កុដសេដ្ឋីកសាង ។

ក្នុងពាក្យថា **តេន ភគវតា ។បេ។ សម្មទក្ខាតោ** នេះ មានសេចក្តីសង្ខេបដូចតទៅនេះថា ទសមគហបតីសួរព្រះអានន្ទថា ព្រះមានព្រះភាគទ្រង់ជាបុគ្គលបំពេញបារមី ៣០ ហើយ ទ្រង់កាច់បំបាក់កិលេសទាំងពួង ទ្រង់ដឹង

ក្រៃលែងនូវអនុត្តរសម្មាសម្ពោធិញ្ញាណនោះ ដែលទេវតា និងមនុស្សទាំង-ឡាយសរសើរដោយហេតុ ៤ ប្រការ ដោយអំណាចនៃវេសារជ្ជញ្ញាណ ៤ យ៉ាង គឺទ្រង់ដឹងអធ្យាស្រ័យ និងអនុស័យរបស់សត្វទាំងឡាយនោះៗ ទ្រង់ឃើញញេយ្យធម៌ទាំងពួង ដូចផ្លែកន្ទួតព្រៃដែលដាក់លើបាតដៃ ។ ម្យ៉ាងទៀត ទ្រង់ដឹងបុព្វេនិវាសញ្ញាណជាដើម ទ្រង់ឃើញដោយទិព្វចក្ខុ ឬទ្រង់ដឹងដោយវិជ្ជា ៣ ដោយអភិញ្ញា ៦ ទ្រង់ឃើញដោយសមន្តចក្ខុ ដែលមិនជាប់ជំពាក់ក្នុងលោកទាំងពួង ទ្រង់ដឹងដោយបញ្ញាដែលអាចដឹងក្នុងធម៌ទាំងពួង ឬទ្រង់ឃើញរូបដែលកន្លងបង់នូវចក្ខុវិស័យនៃសត្វទាំងពួង និងរូបដែលនៅខាងក្រៅជញ្ជាំងផ្ទះជាដើម ដោយមំសចក្ខុដ៏បរិសុទ្ធក្រៃពេក ទ្រង់ឃើញដោយបដិវេធប្បញ្ញា ជាគ្រឿងត្រាស់ដឹង ដែលមានសមាធិជាបទដ្ឋាន ដែលញុំាងប្រយោជន៍ឲ្យសម្រេច ទ្រង់ឃើញដោយបញ្ញា ជាគ្រឿងសម្ដែងធម៌ មានករុណាជាបទដ្ឋាន ដែលញុំាងប្រយោជន៍អ្នកដទៃឲ្យសម្រេច ឬទ្រង់ដឹងធម៌ដែលធ្វើនូវអន្តរាយ ទ្រង់ឃើញធម៌ដែលជាហេតុនាំសត្វចេញចាកទុក្ខ ឈ្មោះថា ទ្រង់ជាព្រះអរហន្ត ព្រោះទ្រង់កម្ចាត់សត្រូវ គឺកិលេសចេញបាន ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធ ព្រោះត្រាស់ដឹងធម៌ដោយប្រពៃដោយព្រះអង្គឯង ទ្រង់ត្រាស់ធម៌ឯក មានឬហ្ន៎ ។

បទថា **អភិសង្ខតំ** សេចក្ដីថា ដែលភិក្ខុធ្វើហើយ គឺឲ្យកើតឡើងហើយ ។ បទថា **អភិសញ្ចេតយិតំ** សេចក្ដីថា ដែលភិក្ខុគិតគឺឲ្យសម្រេច

ហើយ ។ បទថា **សោ តត្ថ ឋិតោ** សេចក្តីថា ភិក្ខុនោះតាំងនៅហើយក្នុងធម៌ គឺសមថៈ និងវិបស្សនា ។ ដោយបទទាំង ២ ថា **ធម្មរាគេន ធម្មនន្ទិយា** ព្រះអានន្ទពោលនូវការត្រេកអរដោយអំណាចការពេញចិត្ត ក្នុងសមថៈ និងវិបស្សនា ។ ពិតហើយ ភិក្ខុកាលកំណត់ទាញយកឆន្ទរាគៈដោយប្រការទាំងពួងក្នុងសមថៈ និងវិបស្សនា រមែងជាព្រះអរហន្ត កាលមិនអាចទាញយកបាន ក៏បានជាអនាគាមី រមែងកើតឡើងក្នុងព្រហ្មលោកជាន់សុទ្ធាវាស ព្រោះនៅលះឆន្ទរាគៈ ក្នុងសមថៈ និងវិបស្សនាមិនបាន នេះជាពាក្យរបស់អាចារ្យទាំងឡាយ ដែលមានការឃើញស្មើគ្នា ។ តែលោកអាចារ្យដែលចូលចិត្តពោលទ្រគោះ ពោលថា ភិក្ខុនេះកើតហើយ ក្នុងសុទ្ធាវាសភូមិ ដោយអកុសលចិត្ត ព្រោះបាលីថា **តេនេវ ធម្មរាគេន** ដូច្នេះ ។ អាចារ្យម្នាងទៀតដែលត្រូវគេទ្រគោះ ពោលតវ៉ាថា សូមលោកនាំព្រះសូត្រមកផង ដូច្នេះ ។ កាលអាចារ្យនោះ មើលមិនឃើញព្រះសូត្រដទៃ ក៏នាំចំពោះព្រះសូត្រនេះមកអាង ។ លំដាប់នោះ ក៏នឹងត្រូវជំទាស់ថា ព្រះសូត្រនេះឬ ដែលលោកនាំមកអាងហើយ ឬដើម្បីនឹងនាំមក ដូច្នេះ ឆ្លើយថា នាំមកអាងហើយពិតប្រាកដ លំដាប់នោះ អាចារ្យអ្នកពោលទ្រគោះ ពោលថា កាលបើដូច្នោះ ភិក្ខុដែលត្រូវការអនាគាមិផល នឹងត្រូវធ្វើសេចក្តីត្រេកអរដោយអំណាចការពេញចិត្តក្នុងសមថៈ និងវិបស្សនា កាលកើតឆន្ទរាគៈឡើងហើយ នឹងបានអនាគាមិផល លោកកុំសម្តែងបែបរលកអណ្តែតថា ខ្ញុំបាន

អានសូត្រមកហើយឡើយ បើសួរបញ្ហា គួរនឹងរៀនក្នុងសម្នាក់របស់អាចារ្យ ទំពាអត្ថរសឲ្យបែបហើយ សឹមពោល ព្រោះថា ឈ្មោះថា បដិសន្ធិក្នុងស្ថានសួគ៌ ដោយអកុសលមិនមាន និងបដិសន្ធិក្នុងអបាយដោយកុសលក៏មិនមាន ។

សមដូចពាក្យដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ពួកទេវតាក្តី ពួកមនុស្សក្តី ឬសុគតិណាមួយឯទៀត មិនមែនបានប្រាកដអំពីកម្មដែលកើតអំពីលោភៈ កម្មដែលកើតអំពីទោសៈ កម្មដែលកើតអំពីមោហៈទេ ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នោះ នរកក្តី កំណើតតិរច្ឆានក្តី ប្រេតវិស័យក្តី ឬក៏ទុគ្គតិណាមួយឯទៀត រមែងកើតប្រាដកមកអំពីកម្ម ដែលកើតអំពីលោភៈ កម្មដែលកើតអំពីទោសៈ កម្មដែលកើតអំពីមោហៈជាប្រាកដ ។ អាចារ្យអ្នកពោលគោះ ដែលបណ្ឌិតគប្បីធ្វើឲ្យយល់យ៉ាងនេះ បើបុគ្គលនោះយល់សោត ក៏ចូរយល់ទៅចុះ តែបើមិនយល់ ហើយគប្បីបញ្ជូនទៅ ដោយពាក្យថា លោកចូរទៅកាន់វិហារអំពីព្រលឹម ហើយឆាន់បបរចុះ ដូច្នេះ ។

ពាក្យថា **អយម្បិ ខោ គហបតិ ។បេ។ ឯកាទសមោ សម្មុខក្ខាតោ** សេចក្តីថា ព្រះអានន្ទត្រូវសួរដល់ធម៌ណាមួយ ក៏ធ្វើធម៌ ១១ ប្រការ ឲ្យឈ្មោះថា ធម៌ទីមួយៗ ដោយអំណាចពាក្យសួរយ៉ាងនេះថា ធម៌ណាមួយនេះព្រះមានព្រះភាគ ក៏ត្រាស់ហើយ ធម៌ណាមួយ នេះព្រះមានព្រះភាគ ក៏

ត្រាស់ហើយ ។

ម្យ៉ាងទៀត ការពោលថា ធម៌ទាំងពួង ឈ្មោះថា ធម៌មួយក៏គួរ ព្រោះអត្ថថា ឲ្យកើតអមតធម៌ឡើងបាន ។

បទថា **និធិមុខំ គវេសន្តោ** បានដល់ ស្វែងរកវណ្ដាទ្រព្យ ។ បទថា **សកិំនេវ** បានដល់ ដោយការព្យាយាមម្ដងប៉ុណ្ណោះ ។ សួរថា ការជួបកំណប់ទ្រព្យ ១១ រណ្ដៅដោយការព្យាយាមតែម្ដងប៉ុណ្ណោះដូចម្ដេច ឆ្លើយថា បុគ្គលពួកខ្លះ ក្នុងលោកនេះ ត្រាច់ទៅក្នុងព្រៃស្វែងរកគ្រឿងចិញ្ចឹមជីវិត បុគ្គលអ្នកមានបំណងល្អម្នាក់ ឃើញបុរសនោះហើយ សួរថា អ្នកដ៏ចម្រើនត្រាច់ទៅណា បុរសនោះឆ្លើយថា ស្វែងរកគ្រឿងចិញ្ចឹមជីវិត បុគ្គលបំណងល្អនោះពោលថា បើយ៉ាងនោះ អ្នកចូរមកណេះ អ្នកចូរប្រមៀលថ្មនេះឡើង បុរសនោះប្រមៀលថ្មនោះឡើងហើយ ក៏ជួបឆ្នាំងទ្រព្យ ១១ ឆ្នាំងដែលដាក់ត្រួតគ្នា ឬដាក់តម្រៀបគ្នា យ៉ាងនេះ ឈ្មោះថា ជួបកំណប់ទ្រព្យ ១១ រណ្ដៅដោយការព្យាយាមតែម្ដងប៉ុណ្ណោះ ។ បទថា **អាចរិយធនំ បរិយេសិស្សន្តិ** សេចក្ដីថា ពិតហើយ អន្យតិរ្ថិយរៀនសិប្បៈក្នុងសម្នាក់អាចារ្យណា រមែងនាំទ្រព្យចេញអំពីផ្ទះមកឲ្យអាចារ្យនោះមុន ឬក្រោយ ឬរវាងរៀនសិប្បៈ តិរ្ថិយដែលមិនមានទ្រព្យក្នុងផ្ទះ ក៏រមែងស្វែងរកអំពីញាតិ ឬអំពីសម្លាញ់ឲ្យ កាលមនុស្សទាំងនោះមិនមាន រមែងស្វែងរកអំពីទីដែលពេញចិត្តគ្នានៃជនទាំងនោះ កាលមិនបានយ៉ាងនោះ រមែងត្រាច់សូមគេឲ្យក៏មាន ទសមគហបតីពោល

សំដៅយកសេចក្តីនោះ ទើបពោលពាក្យនេះ ។

បទថា **កឹ បនាហំ** សេចក្តីថា ទសមគហបតីពោលថា ជាដំបូង ពួកតិរ្ថិយក្រៅសាសនា ស្វែងរកទ្រព្យដើម្បីអាចារ្យដែលឲ្យត្រឹមតែសិប្បៈ ក្នុងសាសនា ដែលមិនទាំសត្វចេញចាកទុក្ខ តែយើងនឹងមិនធ្វើការបូជាដល់អាចារ្យដែលសម្តែងបដិបទាដែលឲ្យកើតអមតៈ ១១ ប្រការ ក្នុងសាសនាដែលនាំសត្វចេញចាកទុក្ខ មានប្រការយ៉ាងនោះ ឬនឹងធ្វើ ។ បទថា **បច្ចេក-ទុស្សយុគេន អច្ឆាទេសិ** សេចក្តីថា ទសមគហបតីបានថ្វាយគូសំពត់ដល់ភិក្ខុមួយរូបមួយគូ ក្នុងរឿងនេះ ពាក្យដែលពោលឡើង រមែងដូច្នេះ ព្រោះដូច្នោះ ទើបលោកពោលថា **អច្ឆាទេសិ** ។ បទថា **បញ្ចសតំ វិហារំ** សេចក្តីថា ឲ្យ សាងបណ្ណសាលា មានតម្លៃ ៥០០ កហាបណៈ ។ល។

## អដ្ឋកថាទសមសូត្រទី ៦ ចប់

# សុត្តន្តបិដក

## គោបាលសូត្រទី ៧

[ ១២៤ ] ម្នាលភិក្ខុទាំងឡាយ គង្វាលគោប្រកបដោយអង្គ ១១ ប្រការ មិនគួររក្សាហ្វូងគោ មិនគួរធ្វើគោ ឲ្យចម្រើនបានឡើយ ។ ប្រកបដោយអង្គ ១១ ប្រការ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គង្វាលគោ ក្នុងលោកនេះ មិនស្គាល់រូបគោ ១ មិនឈ្លាសវៃក្នុងលក្ខណៈ ( គ្រឿងចំណាំ ) ១ មិនចេះគ្ចឹះធ្លៀលពងរុយ ១ មិនចេះបិទដំបៅ ១ មិនធ្វើផ្សែងផ្សែង ១ មិនស្គាល់កំពង់ ១ មិនស្គាល់ទឹកដែលគោផឹក ១ មិនស្គាល់ផ្លូវ ១ មិនឈ្លាសវៃក្នុងគោចរដ្ឋាន ១ រីតយកទឹកដោះមិនឲ្យសេសសល់ ១ មិនបូជាពួកគោឈ្មោល ជាបិតារបស់គោ ជាមេដឹកនាំហ្វូងគោ ដោយអតិរេកបូជា ១ ។ ម្នាលភិក្ខុទាំងឡាយ គង្វាលគោប្រកបដោយអង្គ ១១ ប្រការនេះ មិនគួររក្សាហ្វូងគោ មិនគួរធ្វើគោ ឲ្យចម្រើនបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ១១ ប្រការ មិនគួរដល់នូវការចម្រើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ យ៉ាងនេះឯង ។ ប្រកបដោយអង្គ ១១ ប្រការ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនស្គាល់រូប ១ មិនឈ្លាសវៃក្នុងលក្ខណៈ ១ មិនចេះគ្ចឹះធ្លៀលពងរុយ ១ មិនចេះបិទដំបៅ ១ មិនធ្វើផ្សែងផ្សែង ១ មិនស្គាល់កំពង់ ១ មិនស្គាល់ទឹក ១ មិនស្គាល់ផ្លូវ ១ មិនឈ្លាសវៃក្នុងគោចរដ្ឋាន ១ រីតយកទឹកដោះទាល់តែអស់រលីង ១ មិនបូជាពួកភិក្ខុដែលជាថេរៈ អ្នកដឹងនូវរាត្រី បួសយូរ ជាបិតារបស់សង្ឃ ជាអ្នកត្រួតត្រាសង្ឃ

ដោយអតិរេកបូជា ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមិនស្គាល់រូប តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនដឹងច្បាស់តាមសេចក្ដីពិត នូវរូបឯណានីមួយ គឺមហាភូតរូបទាំង ៤ ផង ឧបាទាយរូប ដែលអាស្រ័យនឹងមហាភូតរូបទាំង ៤ ផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនស្គាល់រូបយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមិនឈ្លាសវៃក្នុងលក្ខណៈ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនដឹងច្បាស់តាមពិតថា បុគ្គលពាល មានកម្មជាលក្ខណៈ បុគ្គលជាបណ្ឌិត ក៏មានកម្មជាលក្ខណៈដែរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនឈ្លាសវៃ ក្នុងលក្ខណៈយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមិនចេះឆ្កឹះចៀលពងរុយ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទទួលត្រងរងយកកាមវិតក្ក ដែលកើតឡើងហើយ មិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យវិនាស មិនបានធ្វើ មិនឲ្យកើតតទៅទៀត ទទួលត្រងរងយកព្យាបាទវិតក្ក ដែលកើតឡើងហើយ ... វិហឹសាវិតក្កដែលកើតឡើងហើយ ... អកុសលធម៌ដ៏លាមក ដែលកើតឡើងហើយៗ មិនលះបង់ មិនបន្ទោបង់ មិនបានធ្វើឲ្យវិនាស មិនបានធ្វើមិនឲ្យកើតតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនចេះឆ្កឹះចៀលពងរុយ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមិនចេះបិទដំបៅ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុ ហើយប្រកាន់និមិត្ត ប្រកាន់អនុព្យញ្ជនៈ ពួកអកុសលធម៌ដ៏លាមក គឺអភិជ្ឈា និងទោមនស្ស គប្បីគ្របសង្កត់បុគ្គលនុ៎ះ

ដែលមិនសង្រួមចក្ខុន្ទ្រិយ ព្រោះមិនសង្រួមចក្ខុន្ទ្រិយណា ក៏មិនប្រតិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយនោះ មិនរក្សាចក្ខុន្ទ្រិយ មិនដល់នូវការសង្រួម ក្នុងចក្ខុន្ទ្រិយឡើយ ស្តាប់សំឡេងដោយត្រចៀក ... ធុំក្លិនដោយច្រមុះ ... ភ្លក្សរសដោយអណ្តាត ... ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ... ដឹងធម្មារម្មណ៍ដោយចិត្ត ហើយប្រកាន់និមិត្ត ប្រកាន់អនុព្យញ្ជនៈ ពួកអកុសលធម៌ដ៏លាមក គឺអភិជ្ឈា និងទោមនស្ស គប្បីគ្របសង្កត់បុគ្គលនុ៎ះ ដែលមិនសង្រួមនូវមនិន្ទ្រិយ ព្រោះហេតុមិនសង្រួមនូវមនិន្ទ្រិយណា ក៏មិនប្រតិបត្តិ ដើម្បីសង្រួមនូវមនិន្ទ្រិយនោះ មិនរក្សាមនិន្ទ្រិយ មិនដល់នូវការសង្រួម ក្នុងមនិន្ទ្រិយឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនចេះបិទដំបៅ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមិនធ្វើផ្សែង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនសម្តែងធម៌ តាមខ្លួនស្តាប់មក តាមខ្លួនរៀនមក ដល់ជនទាំងឡាយដទៃដោយពិស្តារ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនធ្វើផ្សែងយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមិនស្គាល់កំពង់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលទៅរកពួកភិក្ខុដែលជាអ្នកចេះដឹងច្រើន ចេះចាំនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា គឺបាតិមោក្ខទាំងពីរ គ្រប់ៗ កាល ប៉ុន្តែមិនបានសាកសួរ មិនបានដេញដោលថា បពិត្រលោកដ៏ចម្រើន ហេតុនេះ ដូចម្តេច សេចក្តីនៃពាក្យនេះ តើដូចម្តេច ។ លោកដ៏មានអាយុទាំងនោះ មិនបើកចំហនូវសេចក្តី ដែលកំបាំងផង មិនធ្វើឲ្យរាក់នូវសេចក្តី ដែលជ្រៅ

ផង មិនបន្ទោបង់នូវសេចក្តីសង្ស័យ ក្នុងធម៌ទាំងឡាយ ដែលគួរសង្ស័យច្រើនប្រការ ដល់ភិក្ខុនោះផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនស្គាល់កំពង់យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមិនស្គាល់ទឹកផឹក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលបើធម្មវិន័យ ដែលតថាគតបានប្រាប់ បានសម្តែងហើយ ក៏មិនបាននូវការដឹងអត្ថ មិនបាននូវការដឹងធម៌ មិនបានបាមុជ្ជ ដែលប្រកបដោយធម៌ឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនស្គាល់ទឹកផឹក យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមិនស្គាល់ផ្លូវ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនដឹងច្បាស់តាមពិត នូវមគ្គដែលប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនស្គាល់ផ្លូវ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមិនឈ្លាសវៃ ក្នុងគោចរដ្ឋាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនដឹងច្បាស់តាមពិត នូវសតិប្បដ្ឋាន ៤ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនឈ្លាសវៃ ក្នុងគោចរដ្ឋាន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុរឹតយកទឹកដោះអស់រលីង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានពួកគហបតី អ្នកមានសទ្ធា នាំគ្នាមកបវារណា ដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនស្គាល់ប្រមាណ ក្នុងការទទួលបច្ច័យទាំងនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុរឹតយកទឹកដោះអស់រលីង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមិនបូជា

ពួកភិក្ខុដែលជាថេរៈអ្នកដឹងរាត្រី បួសយូរ ជាបិតារបស់សង្ឃ ជាអ្នកត្រួតត្រាសង្ឃ ដោយអតិរេកបូជា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណាជាថេរៈ អ្នកដឹងរាត្រី បួសយូរ ជាបិតារបស់សង្ឃ ជាអ្នកត្រួតត្រាសង្ឃ ភិក្ខុក្នុងសាសនានេះ មិនតម្កល់កាយកម្មប្រកបដោយមេត្តា ក្នុងពួកភិក្ខុទាំងនោះ ក្នុងទីចំពោះមុខក្តី ក្នុងទីកំបាំងមុខក្តី មិនតម្កល់វចីកម្ម ប្រកបដោយមេត្តា ... មិនតម្កល់មនោកម្ម ប្រកបដោយមេត្តា ក្នុងទីចំពោះមុខក្តី ក្នុងទីកំបាំងក្តី ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនបូជាពួកភិក្ខុ ដែលជាថេរៈ អ្នកដឹងរាត្រី បួសយូរ ជាបិតារបស់សង្ឃ ជាអ្នកត្រួតត្រាសង្ឃ ដោយអតិរេកបូជាយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ១១ ប្រការនេះ មិនគួរដល់នូវការចម្រើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះទេ ។ ម្នាលភិក្ខុទាំងឡាយ គង្វាលគោ ប្រកបដោយអង្គ ១១ ប្រការ ទើបគួររក្សាហ្វូងគោ ធ្វើគោឲ្យចម្រើនបាន ។ ប្រកបដោយអង្គ ១១ ប្រការ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គង្វាលគោ ក្នុងលោកនេះ ជាអ្នកស្គាល់រូបគោ ១ ឈ្លាសវៃក្នុងលក្ខណៈ ១ ចេះក្តិះក្តៀលពងរុយ ១ ចេះបិទដំបៅ ១ ចេះធ្វើភ្នក់ផ្សែង ១ ស្គាល់កំពង់ ១ ស្គាល់ទឹកផឹក ១ ស្គាល់ផ្លូវ ១ ឈ្លាសវៃក្នុងគោចរដ្ឋាន ១ រីតយកទឹកដោះ ឲ្យមានសេសសល់ ១ បូជានូវពួកគោឈ្មោលដែលជាបិតារបស់គោ ជាមេដឹកនាំហ្វូងគោ ដោយអតិរេកបូជា ១ ។ ម្នាលភិក្ខុទាំង-ឡាយ គង្វាលគោ ប្រកបដោយអង្គទាំង ១១ ប្រការនេះ ទើបគួររក្សាហ្វូង

គោ ធ្វើគោឲ្យចម្រើនបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ១១ ប្រការ ទើបគួរដល់នូវការចម្រើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះបាន ក៏យ៉ាងនោះឯង ។ ប្រកបដោយធម៌ ១១ ប្រការ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកស្គាល់រូប ១ ឈ្លាសវៃក្នុងលក្ខណៈ ១ ចេះគ្រឹះគ្រៀលពងរុយ ១ ចេះបិទដំបៅ ១ ចេះធ្វើភ្នក់ផ្សែង ១ ស្គាល់កំពង់ ១ ស្គាល់ទឹកផឹក ១ ស្គាល់ផ្លូវ ១ ឈ្លាសវៃក្នុងគោចរដ្ឋាន ១ រីតយកទឹកដោះឲ្យមានសេសសល់ ១ បូជាពួកភិក្ខុដែលជាថេរៈ អ្នកដឹងរាត្រី បួសយូរ ជាបិតារបស់សង្ឃ ជាអ្នកត្រួតត្រាសង្ឃ ដោយអតិរេកបូជា ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុស្គាល់រូប តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិត នូវរូបណានីមួយ គឺមហាភូតរូបទាំង ៤ ផង ឧបាទាយរូប ដែលអាស្រ័យនឹងមហាភូតរូបទាំង ៤ ផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកស្គាល់រូប យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកឈ្លាសវៃក្នុងលក្ខណៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា បុគ្គលពាលមានកម្មជាលក្ខណៈ បុគ្គលជាបណ្ឌិតមានកម្មជាលក្ខណៈ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកឈ្លាសវៃក្នុងលក្ខណៈ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកចេះគ្រឹះគ្រៀលពងរុយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនទទួលត្រងរងយកកាមវិតក្កដែលកើតឡើងហើយ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យ

កើតទៅទៀតបាន នូវព្យាបាទវិតក្កដែលកើតឡើងហើយ ... វិហឹសាវិតក្ក ដែលកើតឡើងហើយ ... មិនទទួលត្រងវងយកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយៗ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបេះធ្មឹះធ្មៀលពងរុយ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបេះបិទដំបៅ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុហើយ ជាអ្នកមិនប្រកាន់និមិត្ត មិនប្រកាន់អនុព្យញ្ជនៈ អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈា និងទោមនស្ស គប្បីជាប់តាមបុគ្គលនុ៎ះ ដែលមិនសង្រួមចក្ខុន្ទ្រិយ ព្រោះហេតុមិនសង្រួមចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិ ដើម្បីសង្រួមចក្ខុន្ទ្រិយនោះ រក្សាចក្ខុន្ទ្រិយ ដល់នូវការសង្រួម ក្នុងចក្ខុន្ទ្រិយ ស្ដាប់សំឡេង ដោយត្រចៀក ... ធុំក្លិនដោយប្រមុះ ... ភ្លក្សរស ដោយអណ្ដាត ... ពាល់ត្រូវផោដ្ឋព្វៈ ដោយកាយ ... ដឹងច្បាស់ធម្មារម្មណ៍ ដោយចិត្តហើយ ជាអ្នកមិនប្រកាន់និមិត្ត មិនប្រកាន់អនុព្យញ្ជនៈ អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈា និងទោមនស្ស គប្បីជាប់តាមបុគ្គលនុ៎ះ ដែលមិនសង្រួមមនិន្ទ្រិយ ព្រោះហេតុមិនសង្រួមមនិន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមមនិន្ទ្រិយនោះ រក្សាមនិន្ទ្រិយ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបេះបិទដំបៅ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបេះធ្វើភ្នក់ផ្សែង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកសម្ដែងធម៌តាមខ្លួនបានស្ដាប់ តាម

ខ្លួនបានរៀនមក ដល់ជនទាំងឡាយដទៃ ដោយសេចក្តីពិស្តារ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកចេះធ្វើភ្នក់ផ្សែង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលទៅរកពួកភិក្ខុ ដែលជាអ្នកចេះដឹងច្រើន ចេះចាំនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា គ្រប់កាល ហើយសាកសួរថា បពិត្រលោកដ៏ចម្រើន ហេតុនេះ ដូចម្តេច សេចក្តីនៃភាសិតនេះ ដូចម្តេច ។ លោកដ៏មានអាយុទាំងនោះ ក៏បើកបង្ហាញ កម្ចាត់កម្ចាយសេចក្តីដែលកំបាំងផង ធ្វើឲ្យរាក់នូវរបស់ដែលជ្រៅផង បន្ទោបង់ កម្ចាត់កម្ចាយសេចក្តីសង្ស័យក្នុងធម៌ទាំងឡាយ ដែលគួរសង្ស័យច្រើនប្រការ ដល់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្គាល់កំពង់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុស្គាល់ទឹកផឹក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលបើធម្មវិន័យ ដែលតថាគតបានប្រាប់ បានសម្តែងហើយ ក៏បាននូវការដឹងអត្ថ បាននូវការដឹងធម៌ បានបាមុជ្ជៈ ដែលប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្គាល់ទឹកផឹក យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុស្គាល់ផ្លូវ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្គាល់តាមពិត នូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្គាល់ផ្លូវ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុឈ្លាសវៃក្នុងគោចរដ្ឋាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិត នូវសតិប្បដ្ឋាន ៤ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកឈ្លាសវៃក្នុង

គោចរដ្ឋាន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុរឹតយកទឹកដោះ ឲ្យមានសេសសល់ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានពួកគហបតី អ្នកមានសទ្ធា នាំគ្នាមកបវារណាដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ភិក្ខុក៏ស្គាល់ប្រមាណ ក្នុងការទទួលបច្ច័យទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នករឹតយកទឹកដោះ ឲ្យមានសេសសល់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបូជាពួកភិក្ខុដែលជាថេរៈ អ្នកដឹងរាត្រី បួសយូរ ជាបិតារបស់សង្ឃ ជាអ្នកត្រួតត្រាសង្ឃ ដោយអតិរេកបូជា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ តម្កល់កាយកម្ម ប្រកបដោយមេត្តា ចំពោះពួកភិក្ខុដែលជាថេរៈ អ្នកដឹងរាត្រី បួសយូរ ជាបិតារបស់សង្ឃ ជាអ្នកត្រួតត្រាសង្ឃ ក្នុងទីចំពោះមុខក្តី ក្នុងទីកំបាំងមុខក្តី តម្កល់វចីកម្មប្រកបដោយមេត្តា ... តម្កល់មនោកម្ម ប្រកបដោយមេត្តា ក្នុងទីចំពោះមុខផង ក្នុងទីកំបាំងមុខផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបូជាពួកភិក្ខុដែលជាថេរៈ អ្នកដឹងរាត្រី បួសយូរ ជាបិតារបស់សង្ឃ ជាអ្នកត្រួតត្រាសង្ឃ ដោយអតិរេកបូជា យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ១១ ប្រការនេះ ទើបគួរដល់នូវការចម្រើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះបាន ។

# អដ្ឋកថា

## គោបាលសូត្រ

[ ១២៤ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងគោបាលសូត្រទី ៧ ដូចតទៅនេះ មានកថា ៣ គឺឯកនាឡិកាកថា ១ ចតុរស្សកថា ១ និសិន្នវត្តិកាកថា ១ ។ ក្នុងកថា ៣ នោះ ការពោលបាលីហើយ ពោលអត្ថនៃបទត្រង់បទណាមួយ ឈ្មោះថា **ឯកនាឡិកាកថា** ការពោលចងឲ្យជាបទ ៤ ដូច្នេះថា នាយគោបាលដែលមិនឈ្លាស ភិក្ខុដែលមិនឈ្លាស នាយគោបាលដែលឈ្លាស ភិក្ខុដែលឈ្លាស ឈ្មោះថា **ចតុរស្សកថា** កថាយ៉ាងនេះ គឺការសម្តែងនាយគោបាលដែលមិនឈ្លាស រហូតដល់ចប់ ការសម្តែងភិក្ខុដែលមិនឈ្លាស រហូតដល់ចប់ ការសម្តែងនាយគោបាលដែលឈ្លាស រហូតដល់ចប់ ការសម្តែងភិក្ខុដែលឈ្លាស រហូតដល់ចប់ ឈ្មោះថា **និសិន្នវត្តិកាកថា។** កថានេះ គ្រប់អាចារ្យក្នុងសាសនានេះ ធ្លាប់ប្រព្រឹត្តមកហើយ ។

បទថា **ឯកាទសហិ ភិក្ខវេ អង្គេហិ** បានដល់ ដោយចំណែកដែលមិនមែនគុណ ១១ ប្រការ ។ បទថា **គោគណំ** បានដល់ ហ្វូងគោ ។ បទថា **បរិហរិតុំ** បានដល់ ដើម្បីនាំត្រាច់ទៅ ។ បទថា **ផាតិកាតុំ** បានដល់ ដើម្បី ឲ្យដល់នូវការធំធាត់ ។

បទថា **ឥធ** ប្រែថា ក្នុងលោកនេះ ។ បទថា **ន រូបញ្ញូ ហោតិ** សេចក្តីថា រមែងមិនស្គាល់រូបដោយចំនួន ឬដោយពណ៌ រមែងមិនដឹងការរាប់ថា គោរបស់ខ្លួនមាន ១០០ ក្បាល ឬ ១០០០ ក្បាល ឈ្មោះថា រមែង

មិនដឹងដោយចំនួន ។ នាយគោបាលនោះ កាលគោទាំងឡាយត្រូវលួចទៅ ឬគេចទៅ ក៏រាប់ហ្វូងគោរបស់ខ្លួន ដឹងថា ថ្ងៃនេះ មេគោចំនួនប៉ុណ្ណោះមិនឃើញ ក៏ត្រាច់ទៅអស់ ២-៣ ភូមិ ឬសព្វព្រៃ ក៏រកមិនឃើញ កាលមេគោរបស់អ្នកដទៃ ទៅចូលហ្វូងគោរបស់ខ្លួន ក៏ដឹងថា មេគោចំនួនប៉ុណ្ណោះមិនមែនរបស់អញ ក៏យករំពាត់ដេញចេញ មេគោទាំងឡាយរបស់នាយគោបាលនោះ ដែលបាត់ទៅ ក៏ឈ្មោះថា បាត់ទៅរហូត នាយគោបាលក៏នាំមេគោរបស់អ្នកដទៃត្រាច់ទៅ ម្ចាស់របស់គោឃើញ ក៏គំរាមថា នេះមេគោរបស់ខ្ញុំ រឹតទឹកដោះអស់កាលប៉ុណ្ណោះ ហើយក៏នាំមេគោរបស់ខ្លួនទៅ មេគោរបស់នាយគោបាលនោះក៏រលស់ទៅ គាត់រមែងជាបុគ្គលឆ្ងាយចាកការបរិភោគបញ្ចគោរស នាយគោបាលមិនដឹងថា មេគេចំនួនប៉ុណ្ណោះ ពណ៌ក្រហមចំនួនប៉ុណ្ណោះ ពណ៌សប៉ុណ្ណោះ ពណ៌ខ្មៅប៉ុណ្ណោះ ពណ៌ចម្រ៉ាប៉ុណ្ណោះ ពណ៌ក្រហមខ្ចីប៉ុណ្ណោះ ឈ្មោះថា ស្គាល់ដោយពណ៌ នាយគោបាលនោះ កាលមេគោទាំងឡាយ ត្រូវលួច ឬគេចទៅ ។បេ។ រមែងជាអ្នកឆ្ងាយចាកការបរិភោគបញ្ចគោរស ។

បទថា **ន លក្ខណកុសលោ ហោតិ** សេចក្តីថា រមែងមិនដឹងគ្រឿងសម្គាល់ជាភាជន៍ធ្នូ លំពែង និងចម្រៀងជាដើម ដែលគេធ្វើទុកត្រង់ខ្លួនរបស់មេគោទាំងឡាយ កាលណាត្រូវលួចទៅ ឬគេចទៅ បុរសនោះគិតថា ថ្ងៃនេះ គោលក្ខណៈឈ្មោះនោះ និងគោមានលក្ខណៈឈ្មោះនោះមិនឃើញ ។បេ។

រមែងជាអ្នកឆ្ងាយអំពីការបរិភោគបញ្ចគោរស ។

បទថា **ន អាសាដិកំ សាដេតា** សេចក្តីថា គោទាំងឡាយ រមែងមានដំបៅក្នុងទីដែលត្រូវដង្កត់ និងបន្ទាជាដើមជន់ រុយក្បាលខៀវរមែងតែ្បងខាងក្នុងទីដែលមានដំបៅនោះ ពងរបស់រុយទាំងនោះ ឈ្មោះថា ពងរុយ គប្បីប្រើឈើឆ្កឹះពងរុយនោះចេញ ហើយដាក់ថ្នាំ ។ នាយគោបាលល្ងង់ខ្លៅមិនធ្វើយ៉ាងនោះ ដោយហេតុនោះ ទើបត្រាស់ថា **ន អាសាដិកំ សាដេតា ហោតិ** ។ ដំបៅរបស់គោនៃបុគ្គលនោះ រមែងរីកធំជ្រៅ ដង្កូវទាំងឡាយ ក៏ចូលក្នុងពោះ គោទាំងឡាយក៏ឈឺ មិនអាចស៊ីស្មៅ ផឹកទឹកបានតាមត្រូវការ ទឹកដោះរបស់គោទាំងឡាយក្នុងឋានៈនោះ រមែងដាច់ទៅ សម្ទុះរបស់គោក៏ថមថយ អន្តរាយនៃជីវិតរបស់គោទាំង ២ ពួកនោះ ក៏រមែងមាន ហ្វូងគោរបស់បុគ្គលនោះ រមែងរលស់ ដោយប្រការដូច្នេះ ។បេ។ បុគ្គលនោះរមែងជាអ្នកឆ្ងាយចាកបញ្ចគោរស ។ បទថា **ន វណំ បដិច្ឆាទេតា ហោតិ** សេចក្តីថា គប្បីដាក់ថ្នាំក្នុងដំបៅដែលកើតដល់គោដោយន័យដូចពោលហើយ ត្រូវបិទដោយផ្ទៃ ឬសំពត់ស្បូវក្លាំងក្រង ។ នាយគោបាលល្ងង់ខ្លៅមិនធ្វើដូច្នោះ ។ បន្ទាប់អំពីនោះ ខ្ទុះរមែងហូរចេញអំពីដំបៅរបស់គោនៃបុគ្គលនោះ គោទាំងនោះ រមែងជ្រៀតបៀតនូវគ្នានិងគ្នា ដោយហេតុនោះ ដំបៅរបស់គោដទៃក៏កើតឡើង គោទាំងឡាយ ក៏នឹងឈឺដោយអាការយ៉ាងនោះ មិនអាចស៊ីស្មៅ ផឹកទឹកបានតាមសេចក្តីត្រូវការ ។បេ។ បុគ្គលនោះរមែងឆ្ងាយចាក

ការបរិភោគបញ្ចគោរស ។

បទថា **ន ធូមំ កត្តា ហោតិ** សេចក្តីថា ខាងក្នុងរដូវភ្លៀង ក្នុងកាលជាទីដេរដាសទៅដោយសត្វល្អិតតូចៗ មានរបោម និងមូសជាដើម កាលហ្វូងគោចូលក្រោល នាយគោបាល គប្បីបំពក់ផ្សែងក្បែរៗ ក្រោលនោះ នាយគោបាលមិនឈ្លាស មិនធ្វើដូច្នោះ ហ្វូងគោត្រូវសត្វល្អិតតូចៗ មានរបោមជាដើម បៀតបៀនមួយយប់ទល់ភ្លឺ មិនបានដេកលក់ ព្រឹកឡើងដេកលក់ត្រង់គល់ឈើជាដើមនោះៗ ក្នុងព្រៃ គោទាំងនោះក៏មិនអាចស៊ីស្មៅ និងផឹកទឹកបានតាមត្រូវការ ។បេ។ នាយគោបាលនោះក៏ធ្លាយចាកបញ្ចគោរស ។

បទថា **ន តិត្ថំ ជានាតិ** សេចក្តីថា រមែងមិនដឹងកំពង់ថា រាបស្មើ ឬមិនរាបស្មើ មានសត្វកាច ឬមិនមានសត្វកាច នាយគោបាលនោះ រមែងឲ្យមេគោចុះក្នុងទីដែលមិនមែនកំពង់ កាលមេគោទាំងនោះ ជាន់ដុំថ្មជាដើមក្នុងទីមិនរាបស្មើ ជើងក៏បែក សត្វសាហាវ មានក្រពើជាដើម រមែងចាប់មេគោដែលចុះកំពង់ទឹកជ្រៅ មានសត្វកាច ។ មេគោទាំងឡាយក៏នឹងត្រូវគេពោលថា ថ្ងៃនេះ មេគោបាត់ចំនួនប៉ុណ្ណោះ ថ្ងៃនេះ មេគោបាត់ចំនួនប៉ុណ្ណោះ ។ មេគោរបស់នាយគោបាលនោះរមែងរលស់ ដោយប្រការដូច្នេះ ។បេ។ បុគ្គលនោះ រមែងជាអ្នកធ្លាយចាកបញ្ចគោរស ។

បទថា **ន បីតំ ជានាតិ** សេចក្តីថា រមែងមិនដឹងថា គោផឹកទឹកហើយ ឬនៅ នាយគោបាលគួរដឹងថា គោផឹកទឹកហើយ ឬមិនបានផឹកយ៉ាង

*នេះថា មេគោនេះផឹកទឹកហើយ មេគោនេះមិនទាន់បានផឹក មេគោនេះបាន ឱកាសត្រង់កំពង់ផឹកទឹក មេគោនេះមិនបានឱកាស ។ នាយគោបាលនេះរក្សាហ្វូងគោក្នុងព្រៃកន្ទះថ្ងៃហើយ គិតថា ឲ្យគោផឹកទឹក ក៏នាំទៅកាន់ស្ទឹង ឬបឹង ក្នុងទីនោះ គោមេហ្វូង និងគោកូនហ្វូង និងមេគោដែលមានកម្លាំង ក៏នឹងយកស្មែង ឬធ្មឹងជំនីរប្រជ្រៀតគោដែលមានកម្លាំងតិច ធ្វើឱកាសឲ្យដល់ខ្លួន ហើយចុះទឹកត្រឹមដើមទ្រូង ផឹកទឹកតាមពេញចិត្ត ។ គោក្រៅអំពីនោះ កាលមិនបានឱកាស ក៏ឈរត្រង់ច្រាំង ផឹកទឹកលើកក់ ឬមិនផឹក ពេលនោះនាយគោបាលនោះ ក៏វាយត្រង់ខ្នង ដេញចូលព្រៃទៀត មេគោដែលមិនបានផឹកទឹកក្នុងទីនោះ ក៏ខ្សោយកម្លាំង ព្រោះស្រេកទឹក ក៏ស៊ីស្មៅតាមត្រូវការមិនបាន ក្នុងឋានៈនោះ ទឹកដោះរបស់គោទាំងឡាយក៏ខះទៅ សម្ទុះរបស់គោទាំងឡាយក៏ថមថយទៅ ។បេ។ បុគ្គលនោះ រមែងជាអ្នកឆ្ងាយចាកការបរិភោគបញ្ចគោរស ។*

*បទថា* **ន វីថឹ ជានាតិ** *សេចក្តីថា រមែងមិនដឹងថា ផ្លូវនេះ រាបស្មើ ជាផ្លូវមិនមានអន្តរាយ ផ្លូវនេះ មិនរាបស្មើ គួររង្កៀស គួរមានភ័យ នាយគោ-បាលនោះ វៀរផ្លូវដែលរាប និងផុតភ័យ ឲ្យគោដើរទៅតាមផ្លូវក្រៅអំពីនេះ ។ ក្នុងទីនោះ គោទាំងឡាយបានទូវក្លិនរាជសីហ៍ និងខ្លាជាដើម និងអន្តរាយអំពីចោរគំរាម ជួបនូវសត្វសាហាវចោមរោម ឈរអើត-ក មិនស៊ីស្មៅ មិនផឹកទឹកតាមត្រូវការ ក្នុងឋានៈនោះ ទឹកដោះរបស់គោនោះ ក៏ខះទៅ ។បេ។ បុគ្គល*

នោះ រមែងជាអ្នកឆ្ងាយចាកការបរិភោគបញ្ចគោរស ។

បទថា **ន គោចរក្ខុសលោ ហោតិ** សេចក្តីថា នាយគោបាលគប្បីជាអ្នកឈ្លាសក្នុងគោចរ គប្បីដឹង ៥ ថ្ងៃមួង ឬ ៧ ថ្ងៃមួង គៀងគោទៅក្នុងទិសមួយ ស្មែកឡើង មិនគប្បីគៀងទៅក្នុងទិសនោះ ដ្បិតថា ទីដែលហ្វូងគោធំត្រាច់មកហើយ រមែងរេចរឹល ដូចមុខស្គរ មិនមានស្មៅ សូម្បីតែទឹកក៏ល្អក់ ព្រោះដូច្នោះ ក្នុងថ្ងៃទី ៥ ឬទី ៧ ទើបនាយគោបាល គួរគៀងទៅក្នុងទីនោះទៀត ដោយហេតុប៉ុណ្ណោះ សូម្បីស្មៅក៏ដុះឡើងជាថ្មី ទឹកក្តីក៏ថ្លា នាយគោបាលនេះ មិនស្គាល់ ៥ ថ្ងៃមួង ឬ ៧ ថ្ងៃមួង រមែងគៀងគោក្នុងទីចិញ្ចឹមហើយរាល់ៗ ថ្ងៃ ។ ដូច្នោះ ហ្វូងគោរបស់នាយគោបាលក៏មិនបានស៊ីស្មៅស្រស់ស៊ីតែស្មៅស្ងួត ផឹកតែទឹកលើកក់ ។ ក្នុងឋានៈនោះ ទឹកដោះរបស់មេគោទាំងឡាយក៏ដាច់ទៅ ។បេ។ បុគ្គលនោះ រមែងជាអ្នកឆ្ងាយចាកការបរិភោគបញ្ចគោរស ។

បទថា **អនវសេសទោហី ហោតិ** សេចក្តីថា នាយគោបាលដែលឈ្លាស គប្បីរឹតទឹកដោះគោឲ្យសល់ខ្លះ វៀរដោះ ១-២ កន្សោម សមល្មមដល់សាច់ និងឈាមរបស់កូនគោ គង់នៅបាន ។ នាយគោបាលនេះ រឹតមិនឲ្យសេសសល់សម្រាប់កូនគោ កូនគោដែលបៅដោះក៏ស្គមស្គាំង ព្រោះស្រេកទឹកដោះ មិនអាចតាំងនៅបាន ។ ញាប់ញ័រដួលចុះ ស្ទាប់ចំពោះមុខមេ មេឃើញកូនតូច គិតថា កូនអញមិនបានបៅដោះម្តាយរបស់ខ្លួន ដោយការសោក

សង្រែង ក៏ស៊ីស្មៅ ផឹកទឹកមិនបានតាមត្រូវការ ទឹកដោះក្នុងកន្សោម ក៏រីងស្ងួតទៅ មេគោរបស់នាយគោបាលនោះ ក៏រលស់ ។បេ។ បុគ្គលនោះ រមែងជាអ្នកឆ្ងាយចាកបញ្ចគោរស ។

ឈ្មោះថា **គោបិតរ** ព្រោះធ្វើកិច្ចរបស់បាគោទាំងឡាយ ឈ្មោះថា គោបរិនាយក ព្រោះបរិហារគោទាំងឡាយ គឺនាំទៅតាមពេញចិត្ត ។ បទថា **តេ ន អតិរេកបូជាយ** សេចក្តីថា នាយគោបាលអ្នកឈ្លាស រមែងបូជាគោឧសភៈបែបនោះ ដោយការបូជាដ៏ក្រៃលែង រមែងឲ្យអាហារគោដ៏ប្រណីត ។ រមែងប្រដាប់ដោយការលាបដោយគ្រឿងក្រអូប ៥ ម្រាម ប្រដាប់កម្រងផ្កា ពាក់ចង្កំមាសចង្កំប្រាក់នៅត្រង់ស្នែង អុជប្រទីបនៅពេលយប់ ឲ្យដេកខាងក្រោមពិតានសំពត់ នាយគោបាលនេះ រមែងមិនធ្វើសក្ការៈ សូម្បីតែម្យ៉ាងអំពីសក្ការៈនោះ ពួកគោឧសភៈកាលមិនបានការបូជាដ៏លើសលប់ ក៏មិនរក្សាហ្វូងគោ រមែងមិនការពារអន្តរាយ សូម្បីហ្វូងគោរបស់នាយគោបាលនោះ ក៏ថយតិចចុះទៅ ដោយអាការយ៉ាងនេះ ។បេ។ បុគ្គលនោះ រមែងជាអ្នកឆ្ងាយចាកបញ្ចគោរស ។

បទថា **ឥធ** បានដល់ ក្នុងសាសនានេះ ។ បទថា **ន រូបញ្ញូ ហោតិ** សេចក្តីថា រមែងមិនដឹងរូបដែលត្រាស់ដោយអាការ ២ យ៉ាង គឺមហាភូតរូប ៤ និងរូបដែលអាស្រ័យមហាភូតរូប ៤ ដោយការរាប់ ឬដោយសមុដ្ឋាន ភិក្ខុដែលមិនឈ្លាស រមែងមិនដឹងថា ចំណែកនៃរូបមាន ២៥ ដែលមកក្នុង

ព្រះបាលីយ៉ាងនេះ គឺអាយតនៈ បានដល់ ចក្ខុ សោតៈ ឃានៈ ជិវ្ហា កាយ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ កាយ-វិញ្ញត្តិ វចីវិញ្ញត្តិ អាកាសធាតុ អាបោធាតុ រូបស្សលហុតា រូបស្សមុទុតា រូបស្សកម្មញ្ញតា រូបស្សឧបចយៈ រូបស្សសន្តតិ រូបស្សជរតា រូបស្ស-អនិច្ចតា កពឡិង្ការាហារ ឈ្មោះថា មិនដឹងដោយការរាប់ ។ ភិក្ខុនេះ ក៏ប្រៀបដូចនាយគោបាល ដែលមិនស្គាល់រូបរបស់គោទាំងឡាយ ដោយការរាប់ ។ ភិក្ខុនោះ កាលមិនដឹងរូបរបស់គោទាំងឡាយ ដោយការរាប់កំណត់រូប ហើយកំណត់អរូប ហើយកំណត់រូប និងនាម កំណត់បច្ច័យ លើកឡើងកាន់លក្ខណៈ មិនអាចឲ្យកម្មដ្ឋានដល់ទីបំផុតបាន ភិក្ខុនោះរមែងមិនចម្រើនដោយសីល សមាធិ វិបស្សនា មគ្គ ផល និងនិព្វានក្នុងសាសនានេះ ដូចហ្វូងគោរបស់នាយគោបាលនោះ មិនចម្រើនឡើងដូច្នោះ ។ម្យ៉ាងទៀត ភិក្ខុនោះរមែងជាអ្នកឆ្ងាយចាកធម្មក្ខន្ធ ៥ គឺសីលក្ខន្ធដែលជាអសេក្ខៈ សមា-ធិក្ខន្ធ បញ្ញាក្ខន្ធ វិមុត្តិក្ខន្ធ និងវិមុត្តិញាណទស្សនក្ខន្ធដែលជាអសេក្ខៈ ដូចនាយគោបាលនោះ ជាអ្នកឆ្ងាយចាកបញ្ចគោរស ដូច្នោះ ភិក្ខុនោះរមែងមិនដឹងថា រូបមានប្រមាណប៉ុណ្ណោះ មានសមុដ្ឋាន ១ រូបមានប្រមាណប៉ុណ្ណោះ មានសមុដ្ឋាន ២ រូបមានប្រមាណប៉ុណ្ណោះ មានសមុដ្ឋាន ៣ រូបមានប្រមាណប៉ុណ្ណោះ មានសមុដ្ឋាន ៤ រូបមានប្រមាណប៉ុណ្ណោះ មិនកើតអំពីសមុដ្ឋានណាឡើយ ឈ្មោះថា មិនដឹងដោយសមុដ្ឋាន ។ ភិក្ខុនេះ ក៏ប្រៀប

ដូចនាយគោបាលនោះ រមែងមិនដឹងរូបរបស់គោទាំងឡាយដោយពណ៌ ។ ភិក្ខុនោះ កាលមិនដឹងរូបដោយសមុដ្ឋាន កំណត់រូបហើយ កំណត់អរូប ។បេ។ រមែងជាអ្នកឆ្ងាយចាកព្រះសទ្ធម្ម ។

បទថា **ន លក្ខណកុសលោ ហោតិ** សេចក្តីថា ភិក្ខុរមែងមិនដឹងកុសលធម៌ និងអកុសលធម៌ ដែលព្រះមានព្រះភាគត្រាស់យ៉ាងនេះថា បុគ្គលពាល មានកម្មជាលក្ខណៈ បុគ្គលជាបណ្ឌិត មានកម្មជាលក្ខណៈ ដូច្នេះថា លក្ខណៈនៃបុគ្គលពាល និងបណ្ឌិត ។ ភិក្ខុនោះមិនដឹងយ៉ាងនេះ វៀរបុគ្គលពាលហើយ រមែងមិនសេពបណ្ឌិត កាលវៀរបុគ្គលពាល មិនសេពបណ្ឌិត ឈ្មោះថា រមែងមិនដឹងវត្ថុដែលគួរ និងមិនគួរ កម្មដែលជាកុសល និងអកុសល កម្មដែលមានទោស និងមិនមានទោស កម្មធ្ងន់ និងកម្មស្រាល កម្មដែលកែខៃបាន កែខៃមិនបាន ហេតុ និងមិនមែនហេតុ កាលមិនដឹងដូច្នោះ ទទួលកម្មដ្ឋានទៅហើយ ក៏មិនអាចឲ្យចម្រើនបាន ភិក្ខុនោះ រមែងមិនចម្រើនដោយសីលជាដើម តាមដែលពោលហើយ ក្នុងព្រះសាសនានេះ ដូចហ្វូងគោរបស់នាយគោបាលដែលមិនឈ្លាសនោះ មិនកើនឡើងបាន ដូច្នោះ ។ ភិក្ខុនោះរមែងជាបុគ្គលឆ្ងាយចាកធម្មក្ខន្ធ ៥ ដូចនាយគោបាល ដែលមិនឈ្លាសនោះ ឆ្ងាយចាកបញ្ចគោរស ដូច្នោះ ។ បទថា **ន អាសាដិកំ សាដេតា ហោតិ** សេចក្តីថា ភិក្ខុមិនបន្ទោបង់កាមវិតក្កជាដើម ដែលព្រះមានព្រះភាគត្រាស់ហើយយ៉ាងនេះថា កាមវិតក្កកើតឡើងហើយ ដូច្នេះ ។ ភិក្ខុនោះមិនធ្វើ

អកុសលវិតក្កនេះឲ្យបរិសុទ្ធ ហើយជាអ្នកធ្លាក់នៅក្នុងអំណាចនៃវិតក្ក ត្រាច់ទៅ ទទួលកម្មដ្ឋានហើយ ក៏មិនអាចឲ្យចម្រើនបាន ។ ភិក្ខុនោះរមែងជាអ្នកធ្លាយ ។បេ។ ដូចហ្វូងគោរបស់នាយគោបាលនោះ ដូច្នោះ ។

បទថា **ន វណំ បដិច្ឆាទេតា ហោតិ** សេចក្តីថា ភិក្ខុនោះកាន់យកនិមិត្តក្នុងអារម្មណ៍ទាំងពួង ដោយន័យជាដើមថា ភិក្ខុឃើញរូបដោយចក្ខុហើយ ជាអ្នកកាន់យកដោយនិមិត្ត ដូច្នេះ រមែងមិនញុំាងការសង្រួមឲ្យដល់ព្រម ដូចនាយគោបាលដែលមិនឈ្លាសនោះ មិនបិទដំបៅ ដូច្នោះ ។ ភិក្ខុនោះជាអ្នកបើកទ្វារត្រាច់ទៅ ទទួលកម្មដ្ឋានហើយ ក៏មិនអាចធ្វើឲ្យចម្រើនបាន ។បេ។ រមែងជាអ្នកធ្លាយចាកព្រះធម៌ ។ បទថា **ន ធូមំ កត្តា ហោតិ** សេចក្តីថា ភិក្ខុរមែងមិនធ្វើការបំពក់ផ្សែង គឺធម្មទេសនា មិនពោលធម៌ មិនសូធ្យសរភញ្ញ មិនអង្គុយសន្ទនាធម៌ មិនធ្វើអនុមោទនា ដូចនាយគោបាលមិនបំពក់ភ្លើង ។ បន្ទាប់អំពីនោះ មនុស្សទាំងឡាយ ក៏មិនស្គាល់ភិក្ខុនោះថា ភិក្ខុនេះជាពហុស្សូត ជាអ្នកមានគុណធម៌ ដូច្នេះ ។ មនុស្សទាំងនោះកាលមិនដឹងគុណ ឬមិនមែនគុណ ក៏មិនធ្វើការសង្គ្រោះដោយបច្ច័យ ៤ ។ ភិក្ខុនោះ កាលលំបាកដោយបច្ច័យទាំងឡាយ រមែងមិនអាចធ្វើការស្វាធ្យាយព្រះពុទ្ធវចនៈ មិនអាចបំពេញវត្តបដិបត្តិឲ្យបរិបូណ៌ ទទួលកម្មដ្ឋានហើយ រមែងមិនអាចឲ្យចម្រើនបាន ។បេ។ រមែងជាអ្នកធ្លាយចាកព្រះសទ្ធម្ម ។

បទថា **ន តិត្ថំ ជានាតិ** សេចក្តីថា ភិក្ខុនោះរមែងមិនចូលទៅរកភិក្ខុ

ដែលជាពហូសូតទាំងឡាយ ដូចកំពង់ទឹក កាលមិនចូលទៅរក រមែងមិនបាននូវការសាកសួរ រមែងមិនបានសាកសួរយ៉ាងនេះថា បពិត្រលោកម្ចាស់ គប្បីបំពេញព្យញ្ជនៈនេះឲ្យបរិបូណ៌បានដូចម្តេច ភាសិតនេះ មានអត្ថដូចម្តេច ក្នុងទីនេះ បាលីថាដូចម្តេច ក្នុងទីនេះ អធិប្បាយដូចម្តេច ក្នុងទីនេះ អត្ថសម្តែងអំពីអ្វី អធិប្បាយថា រមែងមិនធ្វើឲ្យបុគ្គលនោះដឹង ។ ភិក្ខុជាពហូសូតទាំងនោះ ដែលភិក្ខុនោះមិនបានសួរយ៉ាងនេះ រមែងមិនបើកផ្សារធម៌ ដែលមិនទាន់បានបើកផ្សារ រមែងមិនចែកធម៌ រមែងមិនធ្វើអត្ថដែលមិនទាន់រាក់ឲ្យរាក់ឡើង និងរមែងមិនធ្វើធម៌ដែលមិនប្រាកដ ឲ្យប្រាកដ រមែងមិនបន្ទោបង់សេចក្តីសង្ស័យណាមួយ ក្នុងបណ្តាសេចក្តីសង្ស័យដែលមានច្រើនប្រការ ក្នុងធម៌ទាំងឡាយ ដែលជាទីតាំងនៃសេចក្តីសង្ស័យ ដែលមានច្រើនយ៉ាង ។ ពិតហើយ សេចក្តីនោះឯង ឈ្មោះថា ធម៌ជាទីតាំងនៃសេចក្តីសង្ស័យ បណ្តាការសង្ស័យទាំងនោះ សូម្បីមួយក៏មិនបាននាំចេញទៅ ។ ភិក្ខុនោះ មិនចូលទៅរកកំពង់ទឹក គឺភិក្ខុដែលជាពហូសូតយ៉ាងនេះ នៅមានសេចក្តីសង្ស័យ ទទួលកម្មដ្ឋានហើយ ក៏មិនអាចឲ្យចម្រើនបាន ។ម្យ៉ាងទៀត ភិក្ខុនេះមិនដឹងកំពង់ទឹក គឺធម៌ ដូចនាយគោបាលនោះមិនស្គាល់កំពង់ទឹក កាលមិនដឹង រមែងសួរបញ្ហា ក្នុងទីមិនមែនវិស័យ ចូលទៅរកភិក្ខុដែលជំនាញអភិធម្ម សួរវិន័យដែលជាកប្បិយ និងអកប្បិយ ចូលទៅរកព្រះវិនយធរ សួរដល់ការកំណត់នាម និងរូប ។ ភិក្ខុទាំងនោះ ក៏ឆ្លើយសំណួរ

ក្នុងទីមិនមែនវិស័យមិនបាន ។ ភិក្ខុនោះ ជាអ្នកមានសេចក្ដីសង្ស័យ ដោយខ្លួនទទួលកម្មដ្ឋានហើយ ក៏មិនអាចធ្វើឲ្យចម្រើនបាន ។បេ។ រមែងជាអ្នកឆ្ងាយចាកព្រះសទ្ធម្ម ។

បទថា **ន បីតំ ជានាតិ** សេចក្ដីថា ភិក្ខុនោះរមែងមិនដឹង រមែងមិនបាននូវបាមោជ្ជដែលអាស្រ័យធម៌ ដូចនាយគោបាលមិនដឹងថា គោទាំង-ឡាយផឹកទឹកហើយ ឬមិនទាន់បានផឹក ដូច្នោះ រមែងមិនបានអានិសង្ស អាស្រ័យបុញ្ញកិរិយាវត្ថុដែលសម្រេចដោយការស្ដាប់ កាលទៅកាន់រោងស្ដាប់ធម៌ ក៏មិនស្ដាប់ដោយគោរព បែរជាអង្គុយនិទ្រា ជជែកគ្នា បញ្ជូនចិត្តទៅក្នុងទីដទៃ ។ ភិក្ខុនោះកាលមិនស្ដាប់ធម៌ដោយគោរព ទទួលកម្មដ្ឋានហើយ ក៏មិនអាចធ្វើឲ្យចម្រើនបាន ។បេ។ រមែងជាអ្នកឆ្ងាយចាកព្រះសទ្ធម្ម ។

បទថា **ន វីថឹ ជានាតិ** សេចក្ដីថា ភិក្ខុនោះរមែងមិនដឹងច្បាស់តាមសេចក្ដីពិតនូវអរិយមគ្គ ដែលប្រកបដោយអង្គ ៨ ថា ផ្លូវនេះជាលោកិយ ផ្លូវនេះជាលោកុត្តរ ដូច្នេះ ដូចនាយគោបាលមិនដឹងផ្លូវ និងមិនមែនផ្លូវ ដូច្នោះ កាលមិនដឹងផ្លូវ កាន់យកផ្លូវដែលជាលោកិយហើយ មិនអាចធ្វើផ្លូវដែលជាលោកុត្តរឲ្យកើតឡើងបាន ។បេ។ រមែងជាអ្នកឆ្ងាយចាកព្រះសទ្ធម្ម ។

បទថា **ន គោចរកុសលោ ហោតិ** សេចក្ដីថា ភិក្ខុនោះរមែងមិនដឹងតាមសេចក្ដីពិតនូវសតិប្បដ្ឋាន ៤ ថា នេះជាលោកិយ នេះជាលោកុត្តរ ដូចនាយគោបាលមិនស្គាល់វារៈ ៥ ថ្ងៃ ៧ ថ្ងៃ កាលមិនដឹង មិនបង្អោនញាណ

របស់ខ្លួនចូលទៅក្នុងកម្មដ្ឋានដ៏ល្អិតសុខុម ទាញយកក្នុងសតិប្បដ្ឋានដែលជាលោកិយ ក៏មិនអាចធ្វើសតិប្បដ្ឋានដែលជាលោកុត្តរឲ្យកើតឡើងបាន ។បេ។ រមែងជាអ្នកឆ្ងាយចាកព្រះសទ្ធម្ម ។

បទថា **អនវសេសទោហី ហោតិ** សេចក្តីថា ភិក្ខុនោះ កាលមិនដឹងប្រមាណក្នុងការទទួល ឈ្មោះថា រមែងរីតដោយមិនមានចំណែកសេសសល់ ។ ក្នុងនិទ្ទេសវារៈនៃពាក្យនេះ មានអធិប្បាយដូចតទៅនេះ បទថា **អភិហដ្ឋុំ បវារេន្តិ** សេចក្តីថា នាំទៅចំពោះបវារណា ។

ការនាំទៅដោយចំពោះ មាន ២ យ៉ាង គឺការនាំទៅដោយចំពោះដោយវាចា ១ ការនាំទៅដោយចំពោះដោយបច្ច័យ ១ ។ មនុស្សទាំងឡាយទៅកាន់សម្នាក់របស់ភិក្ខុ រមែងបវារណាថា បពិត្រលោកម្ចាស់ លោកម្ចាស់មានសេចក្តីត្រូវការវត្ថុណា សូមប្រាប់មកចុះ នេះឈ្មោះថា ការនាំទៅដោយចំពោះដោយវាចា ។ មនុស្សទាំងឡាយកាន់យកសំពត់ ឬសប្បិ និងខ្លាញ់ខាប់ជាដើម ទៅកាន់សម្នាក់របស់ភិក្ខុ ហើយពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់មានសេចក្តីត្រូវការប៉ុនណា សូមទទួលទុកចុះ ។ ឈ្មោះថា ការនាំទៅចំពោះដោយបច្ច័យ ។

បទថា **តត្រ ភិក្ខុ មត្តំ ន ជានាតិ** សេចក្តីថា ភិក្ខុរមែងមិនដឹងប្រមាណក្នុងបច្ច័យទាំងនោះ ។ អធិប្បាយថា ភិក្ខុមិនទទួលយករបស់ដែលសមគួរដល់ប្រមាណដោយទំនងនេះថា គប្បីជ្រាបអំណាចរបស់ទាយក គប្បីជ្រាប

អំណាចទេយ្យធម៌ គប្បីជ្រាបកម្លាំងរបស់ខ្លួន រមែងទទួលយកបច្ច័យដែលពួកទាយកនាំមកទាំងអស់ ។ មនុស្សទាំងឡាយក្តៅក្រហាយចិត្ត ទើបមិននាំមកបវារណាទៀត ភិក្ខុនោះកាលលំបាកដោយបច្ច័យទាំងឡាយ ទទួលកម្មដ្ឋានហើយ មិនអាចឲ្យចម្រើនបាន ។បេ។ រមែងជាអ្នកឆ្ងាយចាកព្រះសទ្ធម្ម ។

បទថា **តេ ន អតិរេកបូជាយ បូជេតា ហោតិ** សេចក្តីថា ភិក្ខុនោះរមែងមិនបូជាភិក្ខុទាំងនោះ ដោយការបូជាដ៏ឧត្តម ដែលមានកាយកម្មប្រកបដោយមេត្តាជាដើម ទាំងក្នុងទីចំពោះមុខ និងទីកំបាំងមុខ ដូចនាយគោបាលនោះមិនលើកតម្កើង មិនបូជាគោម្ចាស់ហ្វូង បន្ទាប់អំពីនោះ ព្រះថេរៈទាំងនោះគិតថា ភិក្ខុទាំងនេះមិនធ្វើសេចក្តីគោរពកោតក្រែងក្នុងពួកយើង ទើបមិនសង្គ្រោះពួកភិក្ខុថ្មី ដោយការសង្គ្រោះ ២ យ៉ាង គឺមិនសង្គ្រោះដោយធម្មសង្គហៈ ១ មិនសង្គ្រោះដោយអាមិសសង្គហៈ ១ ។ រមែងសង្គ្រោះដោយអាមិសសង្គហៈ គឺដោយចីវរ ឬដោយអំបោះ ឬដោយវត្ថុដែលទាក់ទងដោយបាត្រ ឬដោយលំនៅ ។ ព្រះថេរៈទាំងនោះ រមែងមិនទំនុកបម្រុងភិក្ខុដែលបួសថ្មីទាំងឡាយដែលកំពុងលំបាក មិនឲ្យសិក្សាបាលី អដ្ឋកថា ពោល ឬចងធម្មកថា ឬគម្ពីរដែលមានអត្ថកំបាំង ។ ភិក្ខុបួសថ្មីទាំងឡាយ កាលមិនបានការសង្គ្រោះទាំង ២ យ៉ាងនោះអំពីសម្នាក់ព្រះថេរៈទាំងឡាយ ដោយប្រការទាំងពួង រមែងមិនអាចតាំងនៅក្នុងព្រះសាសនានេះបាន រមែងមិនចម្រើនសីលក្ខន្ធជាដើម ដូចហ្វូងគោរបស់នាយគោបាលនោះ រមែងមិនកើនឡើង ។ ភិក្ខុទាំងនោះ រមែង

ជាអ្នកឆ្ងាយចាកធម្មក្ខន្ធ ៥ ដូចនាយគោបាលនោះឆ្ងាយចាកបញ្ចគោរសដូច្នោះ ធម៌ចំណែកស គប្បីជ្រាបប្រកបដោយអំណាចការផ្ទុយគ្នា អំពីសេចក្តីដែលបានពោលហើយ ក្នុងធម៌ដែលជាចំណែកខ្មៅ ។ល។

**អដ្ឋកថា គោបាលសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## បឋមសមាធិសូត្រទី ៨

[ ១២៥ ] គ្រានោះ ពួកភិក្ខុជាច្រើនរូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុបាននូវសមាធិ មានសភាពដូច្នោះ មានដែរឬ ដូចជាភិក្ខុមិនសម្គាល់ថា ដីក្នុងដី មិនសម្គាល់ថា ទឹកក្នុងទឹក មិនសម្គាល់ថា ភ្លើងក្នុងភ្លើង មិនសម្គាល់ថា ខ្យល់ក្នុងខ្យល់ មិនសម្គាល់ថា អាកាសានញ្ចាយតនៈក្នុងអាកាសានញ្ចាយតនៈ មិនសម្គាល់ថា វិញ្ញាណញ្ចាយតនៈក្នុងវិញ្ញាណញ្ចាយតនៈ មិនសម្គាល់ថា អាកិញ្ចញ្ញាយតនៈក្នុងអាកិញ្ចញ្ញាយតនៈ មិនសម្គាល់ថា នេវសញ្ញានាសញ្ញាយតនៈក្នុងនេវសញ្ញា-

នាសញ្ញាយតនៈ មិនសម្គាល់ថា លោកនេះក្នុងលោកនេះ មិនសម្គាល់ថា លោកខាងមុខក្នុងលោកខាងមុខ របស់ណាដែលគេបានឃើញ ឮ ទទួលរស ដឹងដល់ ស្វែងរក ត្រិះរិះដោយចិត្តហើយ ក៏មិនសម្គាល់ក្នុងរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញាជាធម្មតាតែប៉ុណ្ណោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកបានសមាធិ មានសភាពដូច្នោះ មានដែរ ដូចជាភិក្ខុដែលមិនសម្គាល់ថា ដីក្នុងដី ។បេ។ របស់ណាដែលគេបានឃើញឮ ទទួលរស ដឹងដល់ ស្វែងរក ត្រិះរិះដោយចិត្តហើយ ក៏មិនសម្គាល់ ក្នុងរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញាជាធម្មតាតែប៉ុណ្ណោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុបានសមាធិ មានសភាពដូច្នោះ តើដូចម្តេច ដូចជាភិក្ខុដែលមិនសម្គាល់ថា ដីក្នុងដី ។បេ។ របស់ណាដែលគេបានឃើញ ឮ ទទួលរស ដឹងដល់ ស្វែងរក ត្រិះរិះដោយចិត្តហើយ ក៏មិនសម្គាល់ក្នុងរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញា ជាធម្មតាតែប៉ុណ្ណោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានសេចក្តីសម្គាល់យ៉ាងនេះថា ការរម្ងាប់សង្ខារទាំងអស់ ការលះកិលេសទាំងអស់ ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់តណ្ហា គឺព្រះនិព្វានណា ព្រះនិព្វាននុ៎ះ ជាទីស្ងប់ ព្រះនិព្វាននុ៎ះ ដ៏ឧត្តម ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានសមាធិ មានសភាពដូច្នេះ យ៉ាងនេះឯង ដូចជាភិក្ខុដែលមិនសម្គាល់ថា ដីក្នុងដី មិនសម្គាល់ថា ទឹកក្នុងទឹក មិនសម្គាល់ថា ភ្លើងក្នុងភ្លើង មិនសម្គាល់ថា ខ្យល់ក្នុងខ្យល់ មិនសម្គាល់ថា អាកាសានញ្ចាយតនៈក្នុងអាកាសាន-

ញ្ចាយតនៈ មិនសម្គាល់ថា វិញ្ញាណញ្ចាយតនៈក្នុងវិញ្ញាណញ្ចាយតនៈ មិនសម្គាល់ថា អាកិញ្ចញ្ញាយតនៈក្នុងអាកិញ្ចញ្ញាយតនៈ មិនសម្គាល់ថា នេវសញ្ញានាសញ្ញាយតនៈ ក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសម្គាល់ថា លោកនេះក្នុងលោកនេះ មិនសម្គាល់ថា លោកខាងមុខក្នុងលោកខាងមុខ របស់ណា ដែលគេបានឃើញ ឮ ទទួលរស ដឹងដល់ ស្វែងរក ត្រិះរិះដោយចិត្ត ក៏មិនសម្គាល់ក្នុងរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញា ជាធម្មតាតែប៉ុណ្ណោះ ។

# ទុតិយសមាធិសូត្រទី ៩

[ ១២៦ ] ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ចំពោះភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលបានសមាធិ មានសភាពដូច្នេះ មានដែរឬ ដូចជាភិក្ខុមិនសម្គាល់ថា ដីក្នុងដី មិនសម្គាល់ថា ទឹកក្នុងទឹក មិនសម្គាល់ថា ភ្លើងក្នុងភ្លើង មិនសម្គាល់ថា ខ្យល់ក្នុងខ្យល់ មិនសម្គាល់ថា អាកាសានញ្ចាយតនៈក្នុងអាកាសានញ្ចាយតនៈ មិនសម្គាល់ថា វិញ្ញាណញ្ចាយតនៈក្នុងវិញ្ញាណញ្ចាយតនៈ មិនសម្គាល់ថា អាកិញ្ចញ្ញាយតនៈក្នុងអាកិញ្ចញ្ញាយតនៈ មិនសម្គាល់ថា នេវសញ្ញានាសញ្ញាយតនៈក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសម្គាល់ថា លោកនេះក្នុងលោកនេះ មិនសម្គាល់ថា លោក

ខាងមុខក្នុងលោកខាងមុខ របស់ណាដែលបានឃើញ ឮ ទទួលរស ដឹងដល់ ស្វែងរក ត្រិះរិះដោយចិត្តហើយ ក៏មិនសម្គាល់ក្នុងរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញា ជាធម្មតាតែប៉ុណ្ណោះ ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់យើងខ្ញុំព្រះអង្គ មានតែព្រះមានព្រះភាគជាមូល មានតែព្រះមានព្រះភាគ ជាអ្នកណែនាំ មានតែព្រះមានព្រះភាគជាទីពឹង បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ព្រះមេត្តាប្រោស សូមទ្រង់បំភ្លឺសេចក្តីនៃភាសិតនេះឲ្យទាន ភិក្ខុទាំងឡាយបានស្តាប់ព្រះវាចានៃព្រះមានព្រះភាគហើយ នឹងចាំទុកបាន ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរអ្នកប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកបានសមាធិ មានសភាពដូច្នេះ មានដែរ ដូចជាភិក្ខុមិនសម្គាល់ថា ដីក្នុងដី ។បេ។ របស់ណាដែលបានឃើញ ឮ ទទួលរស ដឹងដល់ ស្វែងរក ត្រិះរិះដោយចិត្តហើយ ក៏មិនសម្គាល់ ក្នុងរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញា ជាធម្មតាតែប៉ុណ្ណោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុដែលបានសមាធិ មានសភាពដូច្នោះ តើដូចម្តេច ដូចជាភិក្ខុដែលមិនសម្គាល់ថា ដីក្នុងដី ។បេ។ របស់ណា ដែលបានឃើញ ឮ ទទួលរស ដឹងដល់ ស្វែងរក ត្រិះរិះដោយចិត្តហើយ ក៏មិនសម្គាល់ក្នុងរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញា ជាធម្មតាតែប៉ុណ្ណោះ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានសេចក្តីសម្គាល់យ៉ាងនេះថា ការរម្ងាប់សង្ខារទាំងអស់ ការលះឧបធិទាំងអស់ ការអស់តណ្ហា ការប្រាសចាកតម្រេក ការរម្លត់តណ្ហា គឺព្រះនិព្វានណា ព្រះនិព្វាននុ៎ះ ជាទីស្ងប់ ព្រះនិព្វាននុ៎ះ ដ៏ឧត្តម ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានសមាធិ មានសភាពដូច្នោះយ៉ាងនេះឯង ដូចជាភិក្ខុមិនសម្គាល់ថា ដីក្នុងដី មិនសម្គាល់ថា ទឹកក្នុងទឹក មិនសម្គាល់ថា ភ្លើងក្នុងភ្លើង មិនសម្គាល់ថា ខ្យល់ក្នុងខ្យល់ មិនសម្គាល់ថា អាកាសានញ្ចាយតនៈក្នុងអាកាសានញ្ចាយតនៈ មិនសម្គាល់ថា វិញ្ញាណញ្ចាយតនៈក្នុងវិញ្ញាណញ្ចាយតនៈ មិនសម្គាល់ថា អាកិញ្ចញ្ញាយតនៈក្នុងអាកិញ្ចញ្ញាយតនៈ មិនសម្គាល់ថា នេវសញ្ញានាសញ្ញាយតនៈក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសម្គាល់ថា លោកនេះក្នុងលោកនេះ មិនសម្គាល់លោកខាងមុខក្នុងលោកខាងមុខ របស់ណា ដែលបានឃើញ ឮ ទទួលរសដឹងដល់ ស្វែងរក ត្រិះរិះដោយចិត្តហើយ ក៏មិនសម្គាល់ក្នុងរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញាជាធម្មតាតែប៉ុណ្ណោះ ។

## តតិយសមាធិសូត្រទី ១០

[ ១២៧ ] លំដាប់នោះ ពួកភិក្ខុជាច្រើនរូប ចូលទៅរកព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងព្រះសារីបុត្តដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក៏បានពោលទៅនឹង

ព្រះសារីបុត្រដ៏មានអាយុដូច្នេះថា ម្នាលអាវុសោសារីបុត្ត ចុះភិក្ខុបានសមាធិមានសភាពដូច្នោះ មានដែរឬ ដូចជាភិក្ខុដែលមិនសម្គាល់ថា ដីក្នុងដី មិនសម្គាល់ថា ទឹកក្នុងទឹក មិនសម្គាល់ថា ភ្លើងក្នុងភ្លើង មិនសម្គាល់ថា ខ្យល់ក្នុងខ្យល់ មិនសម្គាល់ថា អាកាសានញ្ចាយតនៈ ក្នុងអាកាសានញ្ចាយតនៈ មិនសម្គាល់ថា វិញ្ញាណញ្ចាយតនៈក្នុងវិញ្ញាណញ្ចាយតនៈ មិនសម្គាល់ថា អាកិញ្ចញ្ញាយតនៈក្នុងអាកិញ្ចញ្ញាយតនៈ មិនសម្គាល់ថា នេវសញ្ញានា-សញ្ញាយតនៈក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសម្គាល់ថា លោកនេះក្នុងលោកនេះ មិនសម្គាល់ថា លោកខាងមុខក្នុងលោកខាងមុខ របស់ណាដែលបានឃើញ ឮ ទទួលរស ដឹងដល់ ស្វែងរក ត្រិះរិះដោយចិត្តហើយ ក៏មិនសម្គាល់ក្នុងរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញាជាធម្មតាតែប៉ុណ្ណោះ ។ ម្នាលអាវុសោ ភិក្ខុបានសមាធិ មានសភាពដូច្នោះ មានដែរ ដូចជាភិក្ខុដែលមិនសម្គាល់ថា ដីក្នុងដី ។បេ។ របស់ណា ដែលបានឃើញ ឮ ទទួលរស ដឹងដល់ ស្វែងរក ត្រិះរិះដោយចិត្តហើយ ក៏មិនសម្គាល់ក្នុងរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញា ជាធម្មតាតែប៉ុណ្ណោះ ។ ម្នាលអាវុសោសារីបុត្ត ចុះភិក្ខុបានសមាធិមានសភាពដូច្នោះ តើដូចម្តេច ដូចជាភិក្ខុដែលមិនសម្គាល់ថា ដីក្នុងដី ។បេ។ របស់ណា ដែលបានឃើញ ឮ ទទួលរស ដឹងដល់ ស្វែងរក ត្រិះរិះដោយចិត្តហើយ ក៏មិនសម្គាល់ក្នុងរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញា ជាធម្មតាតែប៉ុណ្ណោះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុង

សាសនានេះ មានសេចក្តីសម្គាល់យ៉ាងនេះថា ការរម្ងាប់សង្ខារទាំងអស់ ការលះឧបធិទាំងអស់ ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់តណ្ហា គឺព្រះនិព្វានណា ព្រះនិព្វាននុ៎ះជាទីស្ងប់ ព្រះនិព្វាននុ៎ះដ៏ឧត្តម ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុបានសមាធិ មានសភាពដូច្នោះ យ៉ាងនេះ ដូចជាភិក្ខុដែលមិនសម្គាល់ថា ដីក្នុងដី មិនសម្គាល់ថា ទឹកក្នុងទឹក មិនសម្គាល់ថា ភ្លើងក្នុងភ្លើង មិនសម្គាល់ថា ខ្យល់ក្នុងខ្យល់ មិនសម្គាល់ថា អាកាសានញ្ចាយតនៈក្នុងអាកាសានញ្ចាយតនៈ មិនសម្គាល់ថា វិញ្ញាណញ្ចាយតនៈក្នុងវិញ្ញាណញ្ចាយតនៈ មិនសម្គាល់ថា អាកិញ្ចញ្ញាយតនៈក្នុងអាកិញ្ចញ្ញាយតនៈ មិនសម្គាល់ថា នេវសញ្ញានាសញ្ញាយតនៈក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសម្គាល់ថា លោកនេះក្នុងលោកនេះ មិនសម្គាល់ថា លោកខាងមុខក្នុងលោកខាងមុខ របស់ណា ដែលបានឃើញ ឮ ទទួលរស ដឹងដល់ ស្វែងរក ត្រិះរិះដោយចិត្តហើយ ក៏មិនសម្គាល់ក្នុងរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញាជាធម្មតាតែប៉ុណ្ណោះ ។

## ចតុត្ថសមាធិសូត្រទី ៦

[ ១២៨ ] ក្នុងទីនោះឯង ព្រះសារីបុត្តដ៏មានអាយុ ហៅភិក្ខុទាំងឡាយថា ម្នាលអាវុសោទាំងឡាយ ភិក្ខុបានសមាធិ មានសភាពដូច្នោះ មានដែរឬ ដូចជាភិក្ខុដែលមិនសម្គាល់ថា ដីក្នុងដី មិនសម្គាល់ថា ទឹកក្នុងទឹក មិនសម្គាល់ថា ភ្លើងក្នុងភ្លើង មិនសម្គាល់ថា ខ្យល់ក្នុងខ្យល់ មិនសម្គាល់ថា

អាកាសានញ្ចាយតនៈក្នុងអាកាសានញ្ចាយតនៈ មិនសម្គាល់ថា វិញ្ញាណញ្ចាយតនៈក្នុងវិញ្ញាណញ្ចាយតនៈ មិនសម្គាល់ថា អាកិញ្ចញ្ញាយតនៈក្នុងអាកិញ្ចញ្ញាយតនៈ មិនសម្គាល់ថា នេវសញ្ញានាសញ្ញាយតនៈ ក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសម្គាល់ថា លោកនេះក្នុងលោកនេះ មិនសម្គាល់ថា លោកខាងមុខក្នុងលោកខាងមុខ របស់ណា ដែលបានឃើញ ឮ ទទួលរស ដឹងដល់ ស្វែងរក ត្រិះរិះដោយចិត្តហើយ ក៏មិនសម្គាល់ក្នុងរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញាជាធម្មតាតែប៉ុណ្ណោះ ។ ម្នាលអាវុសោ យើងទាំងឡាយ មកអំពីចម្ងាយ ចង់ដឹងសេចក្តីនៃសុភាសិតនេះ ក្នុងសម្នាក់នៃព្រះសារីបុត្តដ៏មានអាយុ សូមអភ័យទោស សូមព្រះសារីបុត្តដ៏មានអាយុបំភ្លឺសេចក្តីនៃភាសិតនេះឲ្យទាន ភិក្ខុទាំងឡាយបានស្តាប់ភាសិត របស់ព្រះសារីបុត្តដ៏មានអាយុ នឹងចាំទុកបាន ។ ម្នាលអាវុសោទាំងឡាយ បើដូច្នោះអ្នកទាំងឡាយ ចូរស្តាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ ខ្ញុំនឹងសម្តែង ។ ភិក្ខុទាំងនោះ ទទួលថេរវាចា របស់ព្រះសារីបុត្តដ៏មានអាយុថា ករុណាអាវុសោ ។ ព្រះសារីបុត្តដ៏មានអាយុបានពោលដូច្នេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុបានសមាធិមានសភាពដូច្នោះ មានដែរ ដូចជាភិក្ខុមិនសម្គាល់ថា ដីក្នុងដី ។បេ។ របស់ណា ដែលបានឃើញ ឮ ទទួលរស ដឹងដល់ ស្វែងរក ត្រិះរិះដោយចិត្តហើយ ក៏មិនសម្គាល់នូវរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញា ជាធម្មតាតែប៉ុណ្ណោះ ។ ម្នាលអាវុសោសារីបុត្ត ចុះភិក្ខុ

បានសមាធិមានសភាពដូច្នោះ តើដូចម្តេច ដូចជាភិក្ខុដែលមិនសម្គាល់ថា ដី ក្នុងដី ។បេ។ របស់ណា ដែលបានឃើញ ឮ ទទួលរស ជីងដល់ ស្វែងរក ត្រិះរិះដោយចិត្តហើយ ក៏មិនសម្គាល់ក្នុងរបស់ទាំងនោះឡើយ គ្រាន់តែមាន សញ្ញាជាធម្មតាតែប៉ុណ្ណោះ ។ ម្នាលអាវុសោសារីបុត្ត ចុះភិក្ខុបានសមាធិ មាន សភាពដូច្នោះ ជាអ្នកមិនសម្គាល់ថា ដីក្នុងដី តើយ៉ាងណា ។បេ។ របស់ ណា ដែលបានឃើញ ឮ ទទួលរស ជីងដល់ ស្វែងរក ត្រិះរិះដោយចិត្ត មិនសម្គាល់ ក្នុងរបស់ទាំងនោះ គ្រាន់តែមានសញ្ញា ជាធម្មតាតែប៉ុណ្ណោះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានសេចក្តីសម្គាល់យ៉ាងនេះថា ការរម្ងាប់សង្ខារទាំងអស់ ការលះឧបធិទាំងអស់ ការអស់តណ្ហា ការប្រាស ចាកតម្រេក ការរលត់តណ្ហា គឺព្រះនិព្វានណា ព្រះនិព្វាននុ៎ះ ជាទីស្ងប់ ព្រះ និព្វាននុ៎ះ ដ៏ឧត្តម ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុបានសមាធិ មានសភាព ដូច្នោះ យ៉ាងនេះ ដូចជាភិក្ខុដែលមិនសម្គាល់ថា ដីក្នុងដី មិនសម្គាល់ថា ទឹកក្នុងទឹក មិនសម្គាល់ថា ភ្លើងក្នុងភ្លើង មិនសម្គាល់ថា ខ្យល់ក្នុងខ្យល់ មិន សម្គាល់ថា អាកាសានញ្ចាយតនៈក្នុងអាកាសានញ្ចាយតនៈ មិនសម្គាល់ថា វិញ្ញាណញ្ចាយតនៈក្នុងវិញ្ញាណញ្ចាយតនៈ ម្នាលអាវុសោទាំងឡាយ បុគ្គល អ្នកមានសីល បរិបូណ៌ដោយសីល តែងបរិបូណ៌ដោយឧបនិស្ស័យ នៃ អវិប្បដិសារៈ កាលបើអវិប្បដិសារៈមាន បុគ្គលអ្នកបរិបូណ៌ដោយអវិប្ប-ដិសារៈ តែងបរិបូណ៌ដោយឧបនិស្ស័យនៃបាមុជ្ជ កាលបើបាមុជ្ជមាន បុគ្គល អ្នកបរិបូណ៌ដោយបាមុជ្ជ តែងបរិបូណ៌ដោយឧបនិស្ស័យនៃបីតិ កាលបើបីតិ

មាន បុគ្គលអ្នកបរិបូណ៌ដោយបីតិ តែងបរិបូណ៌ដោយឧបនិស្ស័យនៃបស្សទ្ធិ កាលបើបស្សទ្ធិមាន បុគ្គលអ្នកបរិបូណ៌ដោយបស្សទ្ធិ តែងបរិបូណ៌ដោយឧបនិស្ស័យនៃសុខ កាលបើសុខមាន បុគ្គលអ្នកបរិបូណ៌ដោយសុខ តែងបរិបូណ៌ដោយឧបនិស្ស័យនៃសម្មាសមាធិ កាលបើសម្មាសមាធិមាន បុគ្គលអ្នកបរិបូណ៌ដោយសម្មាសមាធិ តែងបរិបូណ៌ដោយឧបនិស្ស័យ នៃយថា-ភូតញ្ញាណទស្សនៈ កាលបើយថាភូតញ្ញាណទស្សនៈមាន បុគ្គលអ្នកបរិបូណ៌ដោយយថាភូតញ្ញាណទស្សនៈ តែងបរិបូណ៌ដោយឧបនិស្ស័យនៃនិព្វិទា កាលបើនិព្វិទាមាន បុគ្គលអ្នកបរិបូណ៌ដោយនិព្វិទា តែងបរិបូណ៌ដោយឧប-និស្ស័យនៃវិរាគៈ កាលបើវិរាគៈមាន បុគ្គលអ្នកបរិបូណ៌ដោយវិរាគៈ តែងបរិបូណ៌ដោយឧបនិស្ស័យនៃវិមុត្តិញ្ញាណទស្សនៈ ។

# អដ្ឋកថា

## បឋមសមាធិសូត្រទី ៨ ជាដើម

[ ១២៥-១២៨ ] ពាក្យដ៏សេសក្នុងវគ្គនេះ និងព្រះសូត្រទាំងពួង ក្រៅអំពីនេះ មានអត្ថងាយយល់ទាំងអស់ហើយ ដូច្នេះឯង ។៚

**អដ្ឋកថា បឋមសមាធិសូត្រទី ៨ ជាដើមចប់**

**ទុតិយវគ្គទី ២ ចប់**

**ឯកាទសកនិបាត ចប់**

# សុត្តន្តបិដក

## សូត្រដែលមិនរួបរួមដោយបណ្ណាសក

[ ១២៩ ] ម្នាលភិក្ខុទាំងឡាយ គង្វាលគោ ប្រកបដោយអង្គ ១១ ប្រការ មិនគួររក្សាហ្វូងគោ មិនគួរធ្វើគោឲ្យចម្រើនបានទេ ។ ប្រកបដោយអង្គ ១១ ប្រការ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គង្វាលគោ ក្នុងលោកនេះ មិនស្គាល់រូបគោ ១ មិនឈ្លាសវៃក្នុងលក្ខណៈ ១ មិនចេះគ្ញីរឆ្កៀលពងរុយ ១ មិនចេះបិទដំបៅ ១ មិនចេះធ្វើផ្សែងផ្សែង ១ មិនស្គាល់កំពង់ ១ មិនស្គាល់ទឹកផឹក ១ មិនស្គាល់ផ្លូវ ១ មិនឈ្លាសវៃក្នុងគោចរដ្ឋាន ១ រឹតទឹកដោះមិនឲ្យមានសេសសល់ ១ មិនបូជាគោឈ្មោល ដែលជាបិតារបស់គោជាមេដឹកនាំគោ ដោយអតិរេកបូជា ១ ។ ម្នាលភិក្ខុទាំងឡាយ នាយគោបាលប្រកបដោយអង្គ ១១ នេះឯង មិនគួររក្សាហ្វូងគោ មិនគួរធ្វើគោឲ្យចម្រើនបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាភិក្ខុប្រកបដោយធម៌ទាំង ១១ ប្រការ មិនគួរឃើញរឿយៗ ថា មិនទៀង ក្នុងចក្ខុ ។បេ។ មិនគួរឃើញរឿយៗ នូវសេចក្តីទុក្ខក្នុងចក្ខុ មិនគួរឃើញរឿយៗ នូវការមិនមានខ្លឹមសារក្នុងចក្ខុ មិនគួរឃើញរឿយៗ នូវការអស់ទៅក្នុងចក្ខុ មិនគួរឃើញរឿយៗ នូវការសូន្យទៅក្នុងចក្ខុ មិនគួរឃើញរឿយៗ នូវការប្រាសចាកតម្រេកក្នុងចក្ខុ មិនគួរឃើញរឿយៗ នូវការរលត់ទៅក្នុងចក្ខុ មិនគួរឃើញរឿយៗ នូវការលះបោលក្នុងចក្ខុ មិនគួរឃើញរឿយៗ នូវការមិនទៀង មិនគួរឃើញរឿយៗ នូវសេចក្តីទុក្ខ មិនគួរឃើញរឿយៗ នូវការមិនមានខ្លឹមសារ មិនគួរឃើញ

រឿយៗ នូវការអស់ទៅ មិនគួរឃើញរឿយៗ នូវការសូន្យទៅ មិនគួរឃើញរឿយៗ នូវការប្រាសចាកតម្រេក មិនគួរឃើញរឿយៗ នូវការរលត់ទៅ មិនគួរឃើញរឿយៗ នូវការលះបោល ក្នុងត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត រូប សំឡេង ក្លិន រស ផ្សព្វ ធម្មារម្មណ៍ ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ ចក្ខុសម្ផស្ស សោតសម្ផស្ស ឃានសម្ផស្ស ជិវ្ហាសម្ផស្ស កាយសម្ផស្ស មនោសម្ផស្ស វេទនាដែលកើតអំពីចក្ខុសម្ផស្ស វេទនាដែលកើត អំពីសោតសម្ផស្ស វេទនាដែលកើតអំពីឃានសម្ផស្ស វេទនាដែលកើតអំពីជិវ្ហាសម្ផស្ស វេទនាដែលកើតអំពីកាយសម្ផស្ស វេទនាដែលកើតអំពីមនោសម្ផស្ស រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា ធម្មសញ្ញា រូបសញ្ចេតនា សទ្ទសញ្ចេតនា គន្ធសញ្ចេតនា រសសញ្ចេតនា ផោដ្ឋព្វសញ្ចេតនា ធម្មសញ្ចេតនា រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា រូបវិតក្ក សទ្ទវិតក្ក គន្ធវិតក្ក រសវិតក្ក ផោដ្ឋព្វវិតក្ក ធម្មវិតក្ក រូបវិចារ សទ្ទវិចារៈ គន្ធវិចារៈ រសវិចារៈ ផោដ្ឋព្វវិចារៈ ធម្មវិចារៈ ។

[ ១៣០ ] ម្នាលភិក្ខុទាំងឡាយ គង្វាលគោ ប្រកបដោយអង្គទាំង ១១ ប្រការ ទើបគួរដើម្បីរក្សាហ្វូងគោ ធ្វើគោឲ្យចម្រើនបាន ។ ប្រកបដោយអង្គទាំង ១១ ប្រការ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គង្វាលគោក្នុងលោកនេះ ជាអ្នកស្គាល់រូបគោ ១ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌

១១ ប្រការ ទើបគួរឃើញរឿយៗ នូវការមិនទៀង ក្នុងចក្ខុ ។បេ។ ឃើញរឿយៗ នូវការលះបោលយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ១១ ប្រការ បុគ្គលគួរចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ទាំង ១១ ប្រការ តើដូចម្តេច ។ គឺបឋមជ្ឈាន ១ ទុតិយជ្ឈាន ១ តតិយជ្ឈាន ១ ចតុត្ថជ្ឈាន ១ មេត្តាចេតោវិមុត្តិ ១ ករុណាចេតោវិមុត្តិ ១ មុទិតាចេតោវិមុត្តិ ១ ឧបេក្ខា-ចេតោវិមុត្តិ ១ អាកាសានញ្ចាយតនៈ ១ វិញ្ញាណញ្ចាយតនៈ ១ អាកិញ្ច-ញ្ញាយតនៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ១១ ប្រការនេះ បុគ្គលគួរចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។

[ ១៣១ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ១១ ប្រការនេះ បុគ្គលគប្បីចម្រើន ដើម្បីដឹងច្បាស់ កំណត់ដឹង អស់រលីង លះបង់អស់ទៅ សូន្យទៅ ប្រាសចាកតម្រេក រលត់ លះបោល បោះបង់នូវរាគៈ ។ ធម៌ទាំង ១១ ប្រការនេះ បុគ្គលគប្បីចម្រើន ដើម្បីដឹងច្បាស់ កំណត់ដឹង អស់រលីង លះបង់អស់ទៅ សូន្យទៅ ប្រាសចាកតម្រេក រលត់ លះបោល បោះបង់នូវទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះចប់ហើយ ។ ភិក្ខុទាំងនោះ មានចិត្តរីករាយ ត្រេកអរចំពោះភាសិត របស់ព្រះមានព្រះភាគ ។

សូត្រទាំងឡាយ ៩៥០០ និង ៥៧ សូត្រដ៏ក្រៃលែង មានមកក្នុងគម្ពីរអង្គុត្តរនិកាយ ។

ឯកាទសកនិបាត ចប់

# អដ្ឋកថា

## សូត្រដែលមិនរួបរួមដោយបណ្ណាសក

[ ១២៩-១៣១ ] ក្នុងសូត្រដែលមិនរួបរួមដោយបណ្ណាសកៈ មានអត្ថងាយយល់ទាំងអស់ហើយ ។

អដ្ឋកថា សូត្រដែលមិនរួបរួមដោយបណ្ណាសក ចប់

# និគមគាថា

ដោយពណ៌នាមកដូច្នេះ ខ្ញុំដែលព្រះជោតិបាលត្ថេរជាអ្នកមានបញ្ញាល្អ ដែលធ្លាប់នៅរួមគ្នាជាមួយខ្ញុំ ក្នុងក្រុងកញ្ចីបុរៈជាដើម អារាធនាក្នុងខណៈ ដែលនៅក្នុងមហាវិហារ នាលង្កាទ្វីប កាលព្រះសទ្ធម្មកំពុងទ្រុឌទ្រោម ដូចដើមឈើត្រូវព្យុះគំរាមហើយ ម្យ៉ាងទៀត ជីវកឧបាសក ជាអ្នកដល់នូវត្រើយសាគរ គឺរៀបចប់ព្រះត្រៃបិដក ជាអ្នកមានបញ្ញាល្អអារាធនាហើយ ប្រាថ្នានូវការស្ថិតស្ថេរនៃព្រះសាសនា ទើបផ្តើមចងគម្ពីរអដ្ឋកថាឯណា នៃបាលីអង្គុត្តរនិកាយ ដែលវិចិត្រដោយលទ្ធិសម័យ ដែលព្រះធម្មកថិកទាំងឡាយដ៏ច្រើន ដែលជាអ្នកល្អិតល្អន់ក្នុងន័យរបស់ធម្មកថា ចងជាកម្រងកែវ បានកម្រងកាព្យហើយ ៗ គម្ពីរអដ្ឋកថានេះ ផ្ទុកសារសំខាន់របស់គម្ពីរមហាអដ្ឋកថា សម្រេចហើយ តែព្រោះមនោរថ គឺសេចក្តីប្រាថ្នារបស់ខ្ញុំ ថានឹងអធិប្បាយនិកាយទាំងអស់ ដោយភាណវារនៃបាលីប្រមាណ ៩៤ ភាណវារបរិបូណ៌ហើយ ទើបអដ្ឋកថានោះ ឈ្មោះថា មនោរថបូរណី បន្ទាប់អំពីនោះ ព្រោះហេតុដែលគម្ពីរវិសុទ្ធិមគ្គ មានប្រមាណ ៥៩ ភាណវារ នៃមនោរថបូរណីនោះ ខ្ញុំក៏តែងដើម្បីប្រកាសអត្ថនៃនិកាយទាំងឡាយហើយ ដូច្នោះ អដ្ឋកថានេះ និង

គម្ពីរវិសុទ្ធមគ្គនោះ គប្បីជ្រាបថា មាន ១៥៣ ភាណវារ តាមន័យនៃការរាប់គាថា ។

អដ្ឋកថានេះ ប្រកាសលទ្ធិសម័យរបស់ព្រះថេរៈ អ្នកនៅក្នុងមហាវិហារ ដោយភាណវារ ១៥៣ ខ្ញុំចងគម្ពីរមនោរថបូរណីនេះ ផ្ទុកសារសំខាន់របស់អដ្ឋកថាដើម សន្សំនូវបុណ្យឯណា ដោយបុណ្យនោះ សូមសត្វលោកទាំងអស់ មានសេចក្ដីសុខចុះ ។

ព្រះថេរៈដែលគ្រូទាំងឡាយឲ្យឈ្មោះថា ពុទ្ធឃោសៈ ដែលប្រដាប់ដោយសទ្ធា ពុទ្ធិ វិរិយៈ សេចក្ដីព្យាយាមដ៏បរិសុទ្ធល្អក្រៃលែង ដែលញុំាងកំណើតនៃគុណសមុទយៈ គឺសីលាចារ និងការស្មោះត្រង់ ការទន់ភ្លន់ និងការមិនញាប់ញ័រ ជាអ្នកអាចក្នុងការថ្កោលទូវព្រៃស្កុក គឺលទ្ធិរបស់ខ្លួន និងលទ្ធិរបស់អ្នកដទៃ ដែលប្រកបដោយចំណេះដឹង និងភាពឈ្លាសវៃ ជាអ្នកមានបដិភាណ គឺញាណដែលមិនទើសទាក់ក្នុងសត្ថុសាសនៈ ព្រមទាំងអដ្ឋកថា ដែលតាំងដោយព្រះត្រៃបិដកបរិយត្តិ ជាអ្នកទ្រទ្រង់នូវមហាវេយ្យាករណ៍ប្រកបដោយគុណ គឺមានវាចាពីរោះឱឡារ ពាល់ត្រូវតាម

*ឋានករណៈ ស្រួលមាត់ ពីរោះត្រចៀក ជាអ្នកមានវាទៈពាល់ត្រូវ បែកធ្លាយ ជាមហាកវី ជាអ្នកមានវោហារពីរោះ ជាអលង្ការរបស់វង្សនៃព្រះថេរៈ ដែលនៅក្នុងមហាវិហារ ជាប្រទីបនៃថេរវង្ស ដែលមានការដឹង តាំងមាំល្អហើយក្នុងឧត្តរិមនុស្សធម៌ ដែលប្រដាប់ដោយគុណ មានអភិញ្ញាជាដើម ដែលជាបរិវារនៃបដិសម្ភិទា ដែលបែកធ្លាយហើយ ជាអ្នកមានការដឹងដ៏បរិបូណ៌បរិសុទ្ធល្អ ចងអដ្ឋកថាអង្គុត្តរនិកាយ ឈ្មោះមនោរថបូរណីនេះ ។*

*សូមគម្ពីរអដ្ឋកថានេះ សម្តែងន័យ ដើម្បីបរិសុទ្ធនៃចិត្តនៃពួកកុលបុត្ត ដែលប្រាថ្នានឹងស្រោចស្រង់លោក ចូរតាំងនៅក្នុងលោកដរាបស្មើនឹងព្រះនាមថា* **ពុទ្ធោ** *របស់ព្រះមានជោគ ដែលមានចិត្តបរិសុទ្ធ ជាអ្នកមាំទាំប្រសើរបំផុតក្នុងលោក បុគ្គលស្វែងរកព្រះគុណដ៏ធំ គង់ប្រព្រឹត្តទៅក្នុងលោក ដូច្នេះ ៕*

**អដ្ឋកថា អង្គុត្តរនិកាយ**
**ឈ្មោះ មនោរថបូរណី ចប់**

# ក្បាលទី ៣១

# សុត្តន្តបិដក បាលីប្រែ -៤៩

## សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ

### សម្ពោធវគ្គ


| | |
|---|---|
| សម្ពោធិសូត្រ ...... ...... ...... ...... ...... | ២ |
| អដ្ឋកថាសម្ពោធិសូត្រ ...... ...... ...... ...... ...... | ៧ |
| និស្សយសូត្រ ...... ...... ...... ...... ...... | ១០ |
| អដ្ឋកថានិស្សយសូត្រ ...... ...... ...... ...... ...... | ១១ |
| មេឃិយសូត្រ ...... ...... ...... ...... ...... | ១២ |
| អដ្ឋកថាមេឃិយសូត្រ ...... ...... ...... ...... ...... | ១៩ |
| នន្ទកសូត្រ ...... ...... ...... ...... ...... | ២២ |
| អដ្ឋកថានន្ទកសូត្រ ...... ...... ...... ...... ...... | ២៩ |
| ពលសូត្រ ...... ...... ...... ...... ...... | ៣២ |
| អដ្ឋកថាពលសូត្រ ...... ...... ...... ...... ...... | ៣៦ |
| សេវនាសូត្រ ...... ...... ...... ...... ...... | ៣៧ |
| អដ្ឋកថាសេវនាសូត្រ ...... ...... ...... ...... ...... | ៤៤ |
| សុតវាសូត្រ ...... ...... ...... ...... ...... | ៤៥ |
| អដ្ឋកថាសុតវាសូត្រ ...... ...... ...... ...... ...... | ៤៧ |
| សជ្ឈសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... | ៤៨ |
| បុគ្គលសូត្រ ...... ...... ...... ...... ...... | ៥១ |

អដ្ឋកថាបុគ្គលសូត្រ ...... ...... ...... ...... ...... ៥១
អាហុនេយ្យសូត្រ ...... ...... ...... ...... ...... ៥២
អដ្ឋកថាអាហុនេយ្យសូត្រ ...... ...... ...... ...... ...... ៥៣

## បណ្ណាសក សីហនាទវគ្គ

វុដ្ឋិសូត្រ ...... ...... ...... ...... ...... ៥៤
អដ្ឋកថាវុដ្ឋិសូត្រ ...... ...... ...... ...... ...... ៦១
សឧបាទិសេសសូត្រ ...... ...... ...... ...... ...... ៦៦
អដ្ឋកថាសឧបាទិសេសសូត្រ ...... ...... ...... ...... ...... ៧១
កោដ្ឋិកសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៧៣
សមិទ្ធិសូត្រ ...... ...... ...... ...... ...... ៧៩
អដ្ឋកថាសមិទ្ធិសូត្រ ...... ...... ...... ...... ...... ៨១
គណ្ឌសូត្រ ...... ...... ...... ...... ...... ៨៣
អដ្ឋកថាគណ្ឌសូត្រ ...... ...... ...... ...... ...... ៨៤
សញ្ញាសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៨៥
កុលសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៨៦
សត្តសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៨៨
ទេវតាសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៩១
វេលាមសូត្រ ...... ...... ...... ...... ...... ៩៤
អដ្ឋកថាវេលាមសូត្រ ...... ...... ...... ...... ...... ១០០

## សត្តាវាសវគ្គ

ឋានសូត្រ ...... ...... ...... ...... ...... ១១២
អដ្ឋកថាឋានសូត្រ ...... ...... ...... ...... ...... ១១៣
ខឡុង្គសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ១១៤

តណ្ហាសូត្រ ...... ...... ...... ...... ...... ១២១
អដ្ឋកថាតណ្ហាសូត្រ ...... ...... ...... ...... ...... ១២២
សត្តសញ្ញាសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ១២៤
បឋមសិលាយូបសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ១២៧
ទុតិយសិលាយូបសូត្រ ...... ...... ...... ...... ...... ១២៩
អដ្ឋកថាទុតិយសិលាយូបសូត្រ ...... ...... ...... ...... ...... ១៣៥
បឋមវេរសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ១៣៦
ទុតិយវេរសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ១៤១
បឋមអាឃាតសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ១៤៤
ទុតិយអាឃាតសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ១៤៥
អនុបុព្វនិរោធសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ១៤៨

មហាវគ្គ

បឋមវិហារសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ១៥០
ទុតិយវិហារសូត្រ ...... ...... ...... ...... ...... ១៥១
អដ្ឋកថាទុតិយវិហារសូត្រ ...... ...... ...... ...... ...... ១៥៩
និព្វានសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ១៦០
គាវីសូត្រ ...... ...... ...... ...... ...... ១៦៧
អដ្ឋកថាគាវីសូត្រ ...... ...... ...... ...... ...... ១៧៥
ឈានសូត្រ ...... ...... ...... ...... ...... ១៧៦
អដ្ឋកថាឈានសូត្រ ...... ...... ...... ...... ...... ១៨៦
អានន្ទសូត្រ ...... ...... ...... ...... ...... ១៩០
អដ្ឋកថាអានន្ទសូត្រ ...... ...... ...... ...... ...... ១៩៣

ព្រាហ្មណសូត្រ ...... ...... ...... ...... ...... ១៩៦
អដ្ឋកថាព្រាហ្មណសូត្រ ...... ...... ...... ...... ...... ២០២
ទេវសូត្រ ...... ...... ...... ...... ...... ២០៤
អដ្ឋកថាទេវសូត្រ ...... ...... ...... ...... ...... ២០៨
នាគសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ២១០
តបុស្សសូត្រ ...... ...... ...... ...... ...... ២១៥
អដ្ឋកថាតបុស្សសូត្រ ...... ...... ...... ...... ...... ២៣៥

### បញ្ចាលវគ្គ

បញ្ចាលសូត្រ ...... ...... ...... ...... ...... ២៣៨
អដ្ឋកថាបញ្ចាលសូត្រ ...... ...... ...... ...... ...... ២៤៣
បឋមកាមហេសសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ២៤៤
ទុតិយកាមហេសសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ២៤៧
តតិយកាមហេសសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ២៤៨
បឋមសន្ទិដ្ឋិកសូត្រជាដើម ...... ...... ...... ...... ...... ២៥០
អដ្ឋកថាបឋមសន្ទិដ្ឋិកសូត្រជាដើម ...... ...... ...... ...... ...... ២៥៣

### ខេមវគ្គ និងសតិប្បដ្ឋានវគ្គ

ខេមវគ្គជាដើម ...... ...... ...... ...... ...... ២៥៤
អដ្ឋកថាខេមវគ្គជាដើម ...... ...... ...... ...... ...... ២៦៦

### សម្មប្បធានវគ្គ

សម្មប្បធានវគ្គសូត្រជាដើម ...... ...... ...... ...... ...... ២៦៧
អដ្ឋកថាសម្មប្បធានវគ្គសូត្រ ...... ...... ...... ...... ...... ២៦៩

### ឥទ្ធិបាទវគ្គ

ឥទ្ធិបាទវគ្គសូត្រជាដើម ...... ...... ...... ...... ...... ២៦៩
អដ្ឋកថាឥទ្ធិបាទវគ្គសូត្រ ...... ...... ...... ...... ...... ២៧១

### វគ្គទី ៥

វគ្គទី ៥ ...... ...... ...... ...... ...... ២៧១
អដ្ឋកថាវគ្គទី ៥ ...... ...... ...... ...... ...... ២៧៣

## សុត្តន្តបិដក បាលីប្រែ –៥០

### អានិសំសវគ្គ

កិមត្ថិយសូត្រ ...... ...... ...... ...... ...... ២៧៤
អដ្ឋកថាកិមត្ថិយសូត្រ ...... ...... ...... ...... ...... ២៧៧
ចេតនាសូត្រ ...... ...... ...... ...... ...... ២៧៨
អដ្ឋកថាចេតនាសូត្រ ...... ...... ...... ...... ...... ២៨១
សីលសូត្រ ...... ...... ...... ...... ...... ២៨១
អដ្ឋកថាសីលសូត្រ ...... ...... ...... ...... ...... ២៨៤
ឧបនិសាសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ២៨៤
សមាធិសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ២៨៩
សារិបុត្តសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ២៩២
សទ្ធាសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ២៩៥
សន្តសូត្រ ...... ...... ...... ...... ...... ២៩៧
អដ្ឋកថាសន្តសូត្រ ...... ...... ...... ...... ...... ២៩៩
វិជយសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ២៩៩

### ឆាទករណវគ្គ

សេនាសនសូត្រ ...... ...... ...... ...... ...... ៣០៣

អដ្ឋកថាសេនាសនសូត្រ ...... ...... ...... ...... ...... ៣០៥

អគ្គិសូត្រ ...... ...... ...... ...... ...... ៣០៦

អដ្ឋកថាអគ្គិសូត្រ ...... ...... ...... ...... ...... ៣០៧

សំយោជនសូត្រ ...... ...... ...... ...... ...... ៣០៨

អដ្ឋកថាសំយោជនសូត្រ ...... ...... ...... ...... ...... ៣០៨

ទីលសូត្រ ...... ...... ...... ...... ...... ៣០៩

អដ្ឋកថាទីលសូត្រ ...... ...... ...... ...... ...... ៣១៥

អប្បមាទសូត្រ ...... ...... ...... ...... ...... ៣១៦

អដ្ឋកថាអប្បមាទសូត្រ ...... ...... ...... ...... ...... ៣១៨

អាហុនេយ្យសូត្រ ...... ...... ...... ...... ...... ៣២០

អដ្ឋកថាអាហុនេយ្យសូត្រ ...... ...... ...... ...... ...... ៣២១

បឋមនាថសូត្រ ...... ...... ...... ...... ...... ៣២១

អដ្ឋកថាបឋមនាថសូត្រ ...... ...... ...... ...... ...... ៣២៥

ទុតិយនាថសូត្រ ...... ...... ...... ...... ...... ៣២៧

អដ្ឋកថាទុតិយនាថសូត្រ ...... ...... ...... ...... ...... ៣៣៣

បឋមអរិយាវាសសូត្រ ...... ...... ...... ...... ...... ៣៣៤

អដ្ឋកថាបឋមអរិយាវាសសូត្រ ...... ...... ...... ...... ...... ៣៣៥

ទុតិយអរិយាវាសសូត្រ ...... ...... ...... ...... ...... ៣៣៥

អដ្ឋកថាទុតិយអរិយាវាសសូត្រ ...... ...... ...... ...... ...... ៣៤០


## មហាវគ្គ


សីហសូត្រ ...... ...... ...... ...... ...... ៣៤៣

អដ្ឋកថាសីហសូត្រ ...... ...... ...... ...... ...... ៣៤៩

អធិមុត្តិសូត្រ ...... ...... ...... ...... ...... ៣៦៣

អដ្ឋកថាអធិមុត្តិសូត្រ ...... ...... ...... ...... ...... ៣៦៧
កាយសូត្រ ...... ...... ...... ...... ...... ៣៦៩
អដ្ឋកថាកាយសូត្រ ...... ...... ...... ...... ...... ៣៧៣
ចុន្ទសូត្រ ...... ...... ...... ...... ...... ៣៧៤
អដ្ឋកថាចុន្ទសូត្រ ...... ...... ...... ...... ...... ៣៨១
កសិណសូត្រ ...... ...... ...... ...... ...... ៣៨១
អដ្ឋកថាកសិណសូត្រ ...... ...... ...... ...... ...... ៣៨២
កាឡីសូត្រ ...... ...... ...... ...... ...... ៣៨៤
អដ្ឋកថាកាឡីសូត្រ ...... ...... ...... ...... ...... ៣៨៦
បឋមមហាបញ្ហាសូត្រ ...... ...... ...... ...... ...... ៣៨៨
អដ្ឋកថាបឋមមហាបញ្ហាសូត្រ ...... ...... ...... ...... ...... ៣៩៨
ទុតិយមហាបញ្ហាសូត្រ ...... ...... ...... ...... ...... ៤០៣
អដ្ឋកថាទុតិយមហាបញ្ហាសូត្រ ...... ...... ...... ...... ...... ៤១០
បឋមកោសលសូត្រ ...... ...... ...... ...... ...... ៤១១
អដ្ឋកថាបឋមកោសលសូត្រ ...... ...... ...... ...... ...... ៤២១
ទុតិយកោសលសូត្រ ...... ...... ...... ...... ...... ៤២៤
អដ្ឋកថាទុតិយកោសលសូត្រ ...... ...... ...... ...... ...... ៤៣៣

## ឧបាលិវគ្គ

បឋមឧបាលិសូត្រ និងទុតិយឧបាលិសូត្រ ...... ...... ...... ...... ...... ៤៣៨
អដ្ឋកថាបឋមឧបាលិសូត្រ និងទុតិយឧបាលិសូត្រ ... ...... ...... ...... ៤៤០
ឧញ្ញាហិកាសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៤៤៥
ឧបសម្បទាសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៤៤៧
និស្សយសូត្រ និងសាមណេរសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៤៤៩

ឧបាលិសង្ឃភេទសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៤៥១
ឧបាលិសាមគ្គីសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៤៥២
អានន្ទសង្ឃភេទសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៤៥៤
អានន្ទសង្ឃសាមគ្គីសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៤៥៦

### អក្កោសវគ្គ

វិវាទសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៤៥៩
បឋមវិវាទមូលសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៤៦១
ទុតិយវិវាទមូលសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៤៦២
កុសិនារាសូត្រ ...... ...... ...... ...... ...... ៤៦៣
អដ្ឋកថាកុសិនារាសូត្រ ...... ...... ...... ...... ...... ៤៦៧
បវេសនសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៤៦៩
សក្កសូត្រ ...... ...... ...... ...... ...... ៤៧៣
អដ្ឋកថាសក្កសូត្រ ...... ...... ...... ...... ...... ៤៧៧
មហាលិសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៤៧៩
អភិណ្ហប្បច្ចវេក្ខណធម្មសូត្រ ...... ...... ...... ...... ...... ៤៨១
អដ្ឋកថាអភិណ្ហប្បច្ចវេក្ខណធម្មសូត្រ ...... ...... ...... ...... ...... ៤៨៣
សារីរដ្ឋធម្មសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៤៨៨
ភណ្ឌនសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៤៨៩

### សចិត្តវគ្គ

សចិត្តសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៤៩៦
សារិបុត្តសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៥០០
ឋិតិសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៥០៣
សមថសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៥០៨

បរិហានសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៥១៥
បឋមសញ្ញាសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៥២១
ទុតិយសញ្ញាសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៥២២
មូលសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៥២៣
បព្វជិតសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៥២៦
គិរិមានន្ទសូត្រ ...... ...... ...... ...... ...... ៥២៨
អដ្ឋកថាអាពាធសូត្រ ( សូត្រនេះមានឈ្មោះ ២ ) ...... ...... ...... ...... ៥៣៦

យមកវគ្គ

អវិជ្ជាសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៥៣៨
តណ្ហាសូត្រ ...... ...... ...... ...... ...... ៥៤៥
អដ្ឋកថាតណ្ហាសូត្រ ...... ...... ...... ...... ...... ៥៥១
និដ្ឋាសូត្រ ...... ...... ...... ...... ...... ៥៥២
អដ្ឋកថានិដ្ឋាសូត្រ ...... ...... ...... ...... ...... ៥៥៣
អវេច្ចសូត្រ ...... ...... ...... ...... ...... ៥៥៣
អដ្ឋកថាអវេច្ចសូត្រ ...... ...... ...... ...... ...... ៥៥៤
បឋមសុខសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៥៥៥
ទុតិយសុខសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៥៥៦
បឋមនឡកបានសូត្រជាដើម ...... ...... ...... ...... ...... ៥៥៨
អដ្ឋកថាបឋមនឡកបានសូត្រជាដើម ...... ...... ...... ...... ...... ៥៦៨
បឋមវត្ថុកថាសូត្រ ...... ...... ...... ...... ...... ៥៦៩
អដ្ឋកថាបឋមវត្ថុកថាសូត្រ ...... ...... ...... ...... ...... ៥៧១
ទុតិយវត្ថុកថាសូត្រ ...... ...... ...... ...... ...... ៥៧៦

អដ្ឋកថាទុតិយវត្ថុកថាសូត្រ ...... ...... ...... ...... ...... ៥៧៩

### អាកង្ខវគ្គ

អាកង្ខសូត្រ ...... ...... ...... ...... ...... ៥៨០
អដ្ឋកថាអាកង្ខសូត្រ ...... ...... ...... ...... ...... ៥៨៤
កណ្ដកសូត្រ ...... ...... ...... ...... ...... ៥៩០
អដ្ឋកថាកណ្ដកសូត្រ ...... ...... ...... ...... ...... ៥៩៣
ឥដ្ឋសូត្រ ...... ...... ...... ...... ...... ៥៩៤
អដ្ឋកថាឥដ្ឋសូត្រ ...... ...... ...... ...... ...... ៥៩៦
វឌ្ឍិសូត្រ ...... ...... ...... ...... ...... ៥៩៧
អដ្ឋកថាវឌ្ឍិសូត្រ ...... ...... ...... ...... ...... ៥៩៨
មិគសាលាសូត្រ ...... ...... ...... ...... ...... ៥៩៩
អដ្ឋកថាមិគសាលាសូត្រ ...... ...... ...... ...... ...... ៦០៩
អភព្វសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៦១២
កាកសូត្រ ...... ...... ...... ...... ...... ៦២១
អដ្ឋកថាកាកសូត្រ ...... ...... ...... ...... ...... ៦២២
និគ្គណ្ឋសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៦២៣
អាឃាតវត្ថុសូត្រ ...... ...... ...... ...... ...... ៦២៤
អដ្ឋកថាអាឃាតវត្ថុសូត្រ ...... ...... ...... ...... ...... ៦២៥
អាឃាតបដិវិនយសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៦២៦

### ថេរវគ្គ

អាហុនសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៦២៨
អានន្ទសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៦៣០
បុណ្ណិយសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៦៣៣

ព្យាករណសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៦៣៥
កត្ថីសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៦៣៩
អញ្ញសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៦៤៧
អធិករណសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៦៥៣
ព្យសនសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៦៦២
កោកាលិកសូត្រ ...... ...... ...... ...... ...... ៦៦៤
អដ្ឋកថា កោកាលិកសូត្រ ...... ...... ...... ...... ...... ៦៧០
ពលសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៦៧៧

ឧបាសកវគ្គ

កាមភោគីសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៦៨១
វេរសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៦៩២
ទិដ្ឋិសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៦៩៨
វជ្ជិយសូត្រ ...... ...... ...... ...... ...... ៧០៦
អដ្ឋកថាវជ្ជិយសូត្រ ...... ...... ...... ...... ...... ៧១២
ឧត្តិយសូត្រ ...... ...... ...... ...... ...... ៧១៣
អដ្ឋកថាឧត្តិយសូត្រ ...... ...... ...... ...... ...... ៧១៧
កោកនុទសូត្រ ...... ...... ...... ...... ...... ៧១៩
អដ្ឋកថាកោកនុទសូត្រ ...... ...... ...... ...... ...... ៧២៣
អាហុនេយ្យសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៧២៥
ថេរសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៧២៩
ឧបាលិសូត្រ ...... ...... ...... ...... ...... ៧៣១
អដ្ឋកថាឧបាលិសូត្រ ...... ...... ...... ...... ...... ៧៤៣

អកព្ទសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៧៤៦

# សុត្តន្តបិដក ចាលីប្រែ -៥១

## សមណសញ្ញាវគ្គ

សមណសញ្ញាសូត្រ ...... ...... ...... ...... ...... ៧៤៨
អដ្ឋកថាសមណសញ្ញាសូត្រ ...... ...... ...... ...... ...... ៧៥០
ពោជ្ឈង្គសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៧៥១
មិច្ឆត្តសូត្រ ...... ...... ...... ...... ...... ៧៥២
អដ្ឋកថាមិច្ឆត្តសូត្រ ...... ...... ...... ...... ...... ៧៥៣
សម្មត្តសូត្រ ...... ...... ...... ...... ...... ៧៥៤
អដ្ឋកថាសម្មត្តសូត្រ ...... ...... ...... ...... ...... ៧៥៧
អវិជ្ជាវិជ្ជាសូត្រ ...... ...... ...... ...... ...... ៧៥៨
អដ្ឋកថាអវិជ្ជាវិជ្ជាសូត្រ ...... ...... ...... ...... ...... ៧៥៩
និជ្ជរវត្ថុសូត្រ ...... ...... ...... ...... ...... ៧៥៩
អដ្ឋកថានិជ្ជរវត្ថុសូត្រ ...... ...... ...... ...... ...... ៧៦២
ធោវនសូត្រ ...... ...... ...... ...... ...... ៧៦៤
អដ្ឋកថាធោវនសូត្រ ...... ...... ...... ...... ...... ៧៦៧
តិកិច្ឆសូត្រ ...... ...... ...... ...... ...... ៧៦៨
អដ្ឋកថាតិកិច្ឆសូត្រ ...... ...... ...... ...... ...... ៧៧០
វមនសូត្រ ...... ...... ...... ...... ...... ៧៧១
អដ្ឋកថាវមនសូត្រ ...... ...... ...... ...... ...... ៧៧៣
និទ្ធមសូត្រ ...... ...... ...... ...... ...... ៧៧៤
អដ្ឋកថានិទ្ធមសូត្រ ...... ...... ...... ...... ...... ៧៧៥
អសេក្ខសូត្រ ...... ...... ...... ...... ...... ៧៧៦

អដ្ឋកថាអសេក្ខសូត្រ ...... ...... ...... ...... ...... ៧៧៧
អសេក្ខធម្មសក្ខសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៧៧៧

## បច្ចោរោហណិវគ្គ

បឋមអធម្មសូត្រជាដើម ...... ...... ...... ...... ...... ៧៧៩
អដ្ឋកថាបឋមអធម្មសូត្រជាដើម ...... ...... ...... ...... ...... ៧៨៣
តតិយអធម្មសូត្រ ...... ...... ...... ...... ...... ៧៨៣
អដ្ឋកថាតតិយអធម្មសូត្រ ...... ...... ...... ...... ...... ៧៩២
អាជិនសូត្រ ...... ...... ...... ...... ...... ៧៩៣
អដ្ឋកថាអាជិនសូត្រ ...... ...... ...... ...... ...... ៧៩៧
សគារវសូត្រ ...... ...... ...... ...... ...... ៧៩៨
អដ្ឋកថាសគារវសូត្រ ...... ...... ...... ...... ...... ៨០០
ឱរិមសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៨០២
បឋមបច្ចោរោហណិសូត្រ ...... ...... ...... ...... ...... ៨០៤
អដ្ឋកថាបឋមបច្ចោរោហណិសូត្រ ...... ...... ...... ...... ...... ៨០៧
ទុតិយបច្ចោរោហណិសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៨០៨
បុព្វង្គសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៨០៩
អាសវសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៨១០

## បរិសុទ្ធិវគ្គ

បារិសុទ្ធិសូត្រ ...... ...... ...... ...... ...... ៨១២
អដ្ឋកថាបរិសុទ្ធសូត្រ ...... ...... ...... ...... ...... ៨១៣
ឧប្បន្នសូត្រជាដើម ...... ...... ...... ...... ...... ៨១៣
អដ្ឋកថាឧប្បន្នសូត្រជាដើម ...... ...... ...... ...... ...... ៨១៨

## សាធុវគ្គ

សាធុសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៨១៩

អរិយធម្មសូត្រជាដើម ...... ...... ...... ...... ...... ៨២០

អដ្ឋកថាអរិយធម្មសូត្រជាដើម ...... ...... ...... ...... ...... ៨២៦

### អរិយមគ្គវគ្គ

អរិយមគ្គវគ្គ ...... ...... ...... ...... ...... ៨២៧

អដ្ឋកថាអរិយមគ្គវគ្គ ...... ...... ...... ...... ...... ៨៣៣

## ចតុត្ថបណ្ណាសក

### បុគ្គលវគ្គ

បុគ្គលវគ្គ ...... ...... ...... ...... ...... ៨៣៤

អដ្ឋកថាបុគ្គលវគ្គ ...... ...... ...... ...... ...... ៨៣៥

### ជាណុស្សោណិវគ្គ

បឋមបច្ចោរោហណិសូត្រជាដើម ...... ...... ...... ...... ...... ៨៣៦

អដ្ឋកថាបឋមបច្ចោរោហណិសូត្រជាដើម ...... ...... ...... ...... ...... ៨៦០

តិវិធសូត្រ ...... ...... ...... ...... ...... ៨៦១

អដ្ឋកថាតិវិធសូត្រ ...... ...... ...... ...... ...... ៨៦២

សបរិក្កមនសូត្រ ...... ...... ...... ...... ...... ៨៦៣

អដ្ឋកថាសបរិក្កមនសូត្រ ...... ...... ...... ...... ...... ៨៦៤

ចុន្ទសូត្រ ...... ...... ...... ...... ...... ៨៦៤

អដ្ឋកថាចុន្ទសូត្រ ...... ...... ...... ...... ...... ៨៧៤

ជាណុស្សោណិសូត្រ ...... ...... ...... ...... ...... ៨៧៥

អដ្ឋកថាជាណុស្សោណិសូត្រ ...... ...... ...... ...... ...... ៨៨៣

### សុទ្ធវគ្គ

សុទ្ធវគ្គ ...... ...... ...... ...... ...... ៨៨៥

អដ្ឋកថាសុន្ទរវគ្គ ...... ...... ...... ...... ...... ៨៩១

សេដ្ឋវគ្គ

សេដ្ឋវគ្គ ...... ...... ...... ...... ...... ៨៩២

អដ្ឋកថាសេដ្ឋវគ្គ ...... ...... ...... ...... ...... ៨៩៦

សេវិតព្វាសេវិតព្វវគ្គ

សេវិតព្វាសេវិតព្វវគ្គ ...... ...... ...... ...... ...... ៨៩៧

អដ្ឋកថាសេវិតព្វាសេវិតព្វវគ្គ ...... ...... ...... ...... ...... ៨៩៨

បឋមវគ្គ

យថាកតសូត្រជាដើម ...... ...... ...... ...... ...... ៨៩៩

អដ្ឋកថាយថាកតសូត្រជាដើម ...... ...... ...... ...... ...... ៩០៦

ធម្មបរិយាយសូត្រ ...... ...... ...... ...... ...... ៩០៦

អដ្ឋកថាធម្មបរិយាយសូត្រ ...... ...... ...... ...... ...... ៩១២

បឋមកម្មសូត្រ ...... ...... ...... ...... ...... ៩១៣

អដ្ឋកថាបឋមកម្មសូត្រ ...... ...... ...... ...... ...... ៩២២

ទុតិយកម្មសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៩២៧

តតិយកម្មសូត្រ ...... ...... ...... ...... ...... ៩២៨

អដ្ឋកថាតតិយកម្មសូត្រ ...... ...... ...... ...... ...... ៩៣១

ព្រាហ្មណសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៩៣៣

ទុតិយវគ្គ

ទុតិយវគ្គ ...... ...... ...... ...... ...... ៩៣៧

អដ្ឋកថាទុតិយវគ្គ ...... ...... ...... ...... ...... ៩៤៥

តតិយវគ្គ

តតិយវគ្គ ...... ...... ...... ...... ...... ៩៤៦

អដ្ឋកថាតតិយវគ្គ ...... ...... ...... ...... ...... ៩៤៧

## និស្សាយវគ្គ

កិមត្ថិយសូត្រជាដើម ...... ...... ...... ...... ...... ៩៥០

អដ្ឋកថាកិមត្ថិយសូត្រជាដើម ...... ...... ...... ...... ...... ៩៦៣

ព្យសនសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៩៦៣

សញ្ញាសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៩៦៥

មនសិការសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៩៧០

អសេក្ខសូត្រ ...... ...... ...... ...... ...... ៩៧៣

អដ្ឋកថាអសេក្ខសូត្រ ...... ...... ...... ...... ...... ៩៧៨

មោរនិវាបនសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៩៨១

## ទុតិយវគ្គ

បឋមមហានាមសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៩៨៥

ទុតិយមហានាមសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៩៩៤

នន្ទិយសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ៩៩៨

សុភូតិសូត្រ និងអដ្ឋកថា ...... ...... ...... ...... ...... ១០០៣

មេត្តាសូត្រ ...... ...... ...... ...... ...... ១០១៣

អដ្ឋកថាមេត្តាសូត្រ ...... ...... ...... ...... ...... ១០១៤

រឿងមេគោ និងកូនគោ ...... ...... ...... ...... ...... ១០១៥

ទសមសូត្រ ...... ...... ...... ...... ...... ១០១៧

អដ្ឋកថាទសមសូត្រ ...... ...... ...... ...... ...... ១០២៦

គោបាលសូត្រ ...... ...... ...... ...... ...... ១០៣២

អដ្ឋកថាគោបាលសូត្រ ...... ...... ...... ...... ..... ១០៤១

បឋមសមាធិសូត្រជាដើម ...... ...... ...... ...... ...... ១០៥៥

អដ្ឋកថាបឋមសមាធិសូត្រជាដើម ...... ...... ...... ...... ...... ១០៦៤

## សូត្រដែលមិនរួបរួមដោយបណ្ណាសក

សូត្រដែលមិនរួបរួមដោយបណ្ណាសក ...... ...... ...... ...... ..... ១០៦៥

អដ្ឋកថាសូត្រដែលមិនរួបរួមដោយបណ្ណាសក ...... ...... ...... ...... ...... ១០៦៨